ព្រះ
ត្រៃបិដក

ប្រែរួមនឹង
ព្រះអដ្ឋកថា

ភាគ១០

បាលីប្រែ ១៥ - ១៦

ពុទ្ធសកាជ ២៥៥៣

ច្បាប់ពិឯក្យ លើកទី២

ព្រះ
សុត្តន្តបិដក
និង
សុមង្គលវិលាសិនី អដ្ឋកថា
សេចក្តីប្រែជាភាសាខ្មែរ
ទីឃនិកាយ
ទុតិយភាគ សីលក្ខន្ធវគ្គ
តតិយភាគ មហាវគ្គ

๑๐
ឆាលីប្រែ ๑๕-๑๖



ពោះពុទ្ធលើកទី ๑ ពុទ្ធសករាជ ๒๕๕๓

ภาคที่ ๑๐

มหาสีหนาทสูตรที่ ๘

[๖๒] ข้าพเจ้าได้สดับมาอย่างนี้ ฯ สมัยหนึ่ง พระผู้มีพระภาคเจ้าประทับอยู่ในป่าไพรเวฬุวันกลันทกนิวาปสถาน ใกล้กรุงราชคฤห์ ฯ ครั้งนั้น อเจลกสัจจกนิครนถ์ (ผู้มีวาทะว่าไม่ประกอบความเพียรเผากิเลส) เข้าไปเฝ้าพระผู้มีพระภาคเจ้าถึงที่ประทับ ครั้นเข้าไปเฝ้าแล้ว ได้ปราศรัยกับพระผู้มีพระภาคเจ้าพอให้ระลึกถึงกันได้ ครั้นผ่านการปราศรัยที่น่ารื่นรมย์ใจกันแล้ว ได้นั่งลง ณ ที่สมควรแล้ว ฯ ครั้นอเจลกสัจจกนิครนถ์นั่งลง ณ ที่สมควรแล้ว ได้กราบทูลพระผู้มีพระภาคเจ้าดังนี้ว่า ข้าแต่พระโคดมผู้เจริญ ข้าพเจ้าได้ฟังมาดังนี้ว่า พระสมณโคดมทรงแสดงธรรมเพื่อให้สาวกถึงความสิ้นไปแห่งตัณหาเป็นเครื่องดองสัตว์ไว้ในภพ ทั้งหมดทั้งสิ้นเพียงอย่างเดียว ข้าแต่พระโคดมผู้เจริญ ก็พวกสมณพราหมณ์เหล่าใดเหล่าหนึ่ง ได้กล่าวอย่างนี้ว่า พระสมณโคดมทรงแสดงธรรมเพื่อให้สาวกถึงความสิ้นไปแห่งตัณหาเป็นเครื่องดองสัตว์ไว้ในภพ ทั้งหมดทั้งสิ้นเพียงอย่างเดียว สมณพราหมณ์เหล่านั้น ชื่อว่ากล่าวตามเหตุ ที่พระโคดมผู้เจริญตรัสแล้วหรือ ชื่อว่าไม่กล่าวตู่พระโคดมผู้เจริญด้วยคำไม่จริงหรือ ชื่อว่าพยากรณ์ธรรมสมควรแก่ธรรม ชื่อว่าไม่ถูกเหตุอันควรติเตียนโดยชอบธรรมแก่วาทะของตนหรือ

ទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលកស្សប ពួកសមណព្រាហ្មណ៍ណា បានពោលហើយយ៉ាងនេះថា ព្រះសមណគោតម រមែងតិះដៀលតបៈទាំងពួង រមែងចំអកមើលងាយតែមួយយ៉ាង នូវអ្នកកាន់តបៈទាំងអស់គ្នា ដែលមានអាជីវៈសៅហ្មង ពួកសមណព្រាហ្មណ៍ទាំងនោះ មិនមែនពោលតាមវាទៈដែលតថាគតពោលហើយ (ដោយសព្វគ្រប់) ទេ ពោលបង្កាច់តថាគត (ខ្លះក៏មាន) មួយវិញទៀត ពួកសមណព្រាហ្មណ៍ទាំងនោះ មិនមែនពោលបង្កាច់តថាគត ដោយពាក្យមិនមាន មិនពិត (ក៏មាន) ។ ម្នាលកស្សប តថាគតបានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងវិស័យរបស់មនុស្ស មើលឃើញបុគ្គលអ្នកកាន់តបៈ ដែលមានអាជីវៈសៅហ្មងពួកខ្លះ ក្នុងលោកនេះ ដែលរំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលកស្សប តថាគតមានចក្ខុទិព្វដ៏បរិសុទ្ធកន្លងវិស័យរបស់មនុស្ស តថាគតមើលឃើញបុគ្គលអ្នកកាន់តបៈពួកខ្លះ ក្នុងលោកនេះ ជាអ្នកចិញ្ចឹមជីវិតសៅហ្មង ដែលរំលាងខន្ធខាងមុខអំពីសេចក្តីស្លាប់ ទៅកាន់លោក គឺមនុស្សសុគតិ និងឋានសួគ៌ ។ ម្នាលកស្សប តថាគតមានចក្ខុទិព្វកន្លងវិស័យរបស់មនុស្ស មើលឃើញបុគ្គលអ្នកកាន់តបៈពួកខ្លះ ក្នុងលោកនេះ ដែលនៅដោយមានសេចក្តីទុក្ខតិច លុះរំលាងខន្ធខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលកស្សប តថាគតមានចក្ខុទិព្វកន្លងវិស័យរបស់មនុស្ស មើលឃើញបុគ្គលអ្នកកាន់តបៈពួកខ្លះ ក្នុងលោកនេះ ដែលនៅដោយមានសេចក្តីទុក្ខតិច លុះរំលាងខន្ធអំពីសេចក្តីស្លាប់ ទៅកាន់

លោក គឺមនុស្ស សុគតិ និងស្ថានសួគ៌ ។ ម្នាលកស្សប តថាគតដឹងជាក់នូវដំណើរមកផង ដំណើរទៅផង ដំណើរឃ្លាតចេញផង ដំណើរកើតផង របស់ពួកអ្នកកាន់តប:ទាំងនេះ តាមពិតយ៉ាងនេះឯង តថាគតឯងនឹងតិះដៀលតប:ទាំងពួង និងចំអកមើលងាយតែមួយយ៉ាង នូវអ្នកកាន់តប:ទាំងអស់គ្នា ដែលមានអាជីវ:សៅហ្មង ដូចម្តេចបាន (តថាគតតិះដៀលតែកម្មដែលគួរតិះដៀល សរសើរកម្មដែលគួរសរសើរទេតើ) ។

[๖๓] *ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាបណ្ឌិត មានប្រាជ្ញាស្ទាត ដឹងច្បាស់នូវវាទ:របស់អ្នកដទៃ អាចទម្លាយនូវទិដ្ឋិរបស់បុគ្គលដទៃ ដោយកម្លាំងប្រាជ្ញារបស់ខ្លួន ដូចជាខ្មាន់ធ្នូអ្នកបាញ់នូវសរសៃសក់បាន ។ សមណព្រាហ្មណ៍ទាំងនោះ ត្រូវគ្នានឹងតថាគតក្នុងស្ថានខ្លះក៏មាន មិនត្រូវគ្នាក្នុងស្ថានខ្លះក៏មាន ។ សមណព្រាហ្មណ៍ទាំងនោះពោលនូវអ្វីខ្លះថា ល្អ យើងក៏ពោលថា ល្អដែរក៏មាន ។ សមណព្រាហ្មណ៍ទាំងនោះពោលនូវអ្វីខ្លះ ថា មិនល្អ យើងក៏ពោលថា មិនល្អដែរក៏មាន ។ សមណព្រាហ្មណ៍ទាំងនោះ ពោលនូវអ្វីខ្លះ ថាល្អ តែយើងពោលថា មិនល្អក៏មាន ។ សមណ-ព្រាហ្មណ៍ទាំងនោះពោលនូវអ្វីខ្លះ ថាមិនល្អ តែយើងពោលថា ល្អក៏មាន ។ យើងពោលនូវអ្វីខ្លះថាល្អ ពួកសមណព្រាហ្មណ៍ដទៃក៏ពោលថាល្អដែរក៏មាន ។ យើងពោលនូវអ្វីខ្លះ ថាមិនល្អ ពួកសមណព្រាហ្មណ៍ដទៃពោលថាមិនល្អដែរក៏មាន ។ យើងពោលនូវអ្វីខ្លះ ថាល្អ តែពួកសមណព្រាហ្មណ៍ដទៃពោលថា មិនល្អក៏មាន ។ យើងពោលនូវអ្វីខ្លះ ថាមិនល្អ តែពួកសមណព្រាហ្មណ៍*

ដទៃពោលថា ល្អក៏មាន ។ តថាគតចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ក៏និយាយយ៉ាងនេះថា នែអាវុសោទាំងឡាយ ស្ថានណាដែលមិនត្រូវគ្នានឹងតថាគត ស្ថាននោះលើកទុកសិនចុះ ស្ថានណាដែលត្រូវគ្នានឹងតថាគត ពួកវិញ្ញូជនត្រូវសួរកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិ និងហេតុទាំង ២ ប្រៀបធៀបគ្រូនិងគ្រូ ឬពួកនិងពួក ក្នុងស្ថាននោះថា ធម៌ទាំងឡាយដែលជាអកុសល រាប់ថា ជាអកុសល មានទោស រាប់ថា មានទោស មិនគួរសេព រាប់ថា មិនគួរសេព មិនប្រសើរ រាប់ថា មិនប្រសើរ ជាចំណែកខ្មៅ រាប់ថា ជាចំណែកខ្មៅ របស់ជនដ៏ចម្រើនទាំងនេះ តើនរណាលះបង់ធម៌ទាំងនេះ មិនឲ្យសេសសល់ ហើយប្រព្រឹត្តកាន់បាន សមណគោតមឬៗ ក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។

[៦៤] ម្នាលកស្សប សេចក្តីនេះជាឋានៈមានច្រើនដ កាលបើពួកវិញ្ញូជនសួរកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិ និងហេតុ ក៏និយាយយ៉ាងនេះថា ធម៌ទាំងឡាយដែលជាអកុសល រាប់ថា ជាអកុសល មានទោស រាប់ថា មានទោសមិនគួរសេព រាប់ថា មិនគួរសេព មិនប្រសើរ រាប់ថាមិនប្រសើរ ជាចំណែកខ្មៅ រាប់ថា ជាចំណែកខ្មៅរបស់ជនដ៏ចម្រើនទាំងនេះ ព្រះសមណគោតមលះបង់ធម៌ទាំងនេះមិនឲ្យសេសសល់ ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀតទេ ។ ម្នាលកស្សប ពួកវិញ្ញូជនក្នុងលោកនេះ កាលបើសួរកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិ និងហេតុ ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌ទាំងនោះ ដោយ

ប្រការដូច្នេះឯង ។

[๖๕] *ម្នាលកស្សប មួយយ៉ាងទៀត ពួកវិញ្ញូជនកាលបើមិនសួរពេក លទ្ធិ មិនដេញដោលពេកហេតុ មិនសួរស្ទាក់ពេកលទ្ធិ និងហេតុ មិនប្រៀបធៀបគ្រូនិងគ្រូ ឬពួកនិងពួកថា ធម៌ទាំងឡាយដែលជាកុសល រាប់ថា ជាកុសល មិនមានទោស រាប់ថា មិនមានទោស គួរសេព រាប់ថា គួរសេព ប្រសើរ រាប់ថា ប្រសើរ ជាចំណែកស រាប់ថា ជាចំណែកស របស់ពួកជនដ៏ចម្រើនទាំងនេះ តើនរណាសមាទានធម៌ទាំងនេះ មិនឲ្យសេសសល់ ហើយប្រព្រឹត្តកាន់បាន ព្រះសមណគោតម ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប សេចក្តីនេះ ជាឋានៈមានច្រើនក ពួកវិញ្ញូជនកាលបើសួរពេកលទ្ធិ ដេញដោលពេកហេតុ សួរស្ទាក់ពេកលទ្ធិ និងហេតុ ក៏មុខជានិយាយយ៉ាងនេះថា ធម៌ទាំងឡាយដែលជាកុសល រាប់ថា ជាកុសល មិនមានទោស រាប់ថា មិនមានទោស គួរសេព រាប់ថា គួរសេព ប្រសើរ រាប់ថា ប្រសើរ ជាចំណែកស រាប់ថា ជាចំណែកស របស់ជនដ៏ចម្រើនទាំងនេះព្រះសមណគោតម សមាទានធម៌ទាំងនេះមិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប ពួកវិញ្ញូជនក្នុងលោកនេះ កាលបើសួរពេកលទ្ធិ ដេញដោលពេកហេតុ សួរស្ទាក់ ពេកលទ្ធិ និងហេតុ ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌នោះដោយប្រការដូច្នេះឯង ។*

[๖๖] *ម្នាលកស្សប មួយយ៉ាងទៀត ពួកវិញ្ញូជន កាលបើមិនសួរពេកលទ្ធិ មិនដេញដោលពេកហេតុ មិនសួរស្ទាក់ពេកលទ្ធិ និងហេតុ មិនប្រៀប*

ជៀបគ្រូនិងគ្រូ ឬពួកនិងពួកថា ធម៌ទាំងឡាយដែលជាអកុសល រាប់ថា ជាអកុសល មានទោស រាប់ថា មានទោស មិនគួរសេព រាប់ថា មិនគួរសេព មិនប្រសើរ រាប់ថា មិនប្រសើរ ជាចំណែកខ្មៅ រាប់ថា ជាចំណែកខ្មៅ របស់ពួកជនដ៏ចម្រើនទាំងនេះ នរណាលះបង់ធម៌ទាំងនេះ មិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ពួកសាវ័ករបស់ព្រះគោតម ឬក៏ពួកសាវ័ករបស់គណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប សេចក្តីនេះជាហានៈមានប្រាកដ ពួកវិញ្ញូជនកាលបើ សួរកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិ និងហេតុ ក៏មុខជានិយាយយ៉ាងនេះថា ធម៌ទាំងឡាយដែលជាអកុសល រាប់ថា ជាអកុសល មានទោស រាប់ថា មានទោស មិនគួរសេព រាប់ថា មិនគួរសេព មិនប្រសើរ រាប់ថា មិនប្រសើរ ជាចំណែកខ្មៅ រាប់ថា ជាចំណែកខ្មៅ របស់ជនដ៏ចម្រើនទាំងនេះ ពួកសាវ័ករបស់ព្រះគោតម លះបង់ធម៌ទាំងនេះ មិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកសាវ័ករបស់ពួកគណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប ពួកវិញ្ញូជនក្នុងលោកនេះ កាលបើសួរកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិ និងហេតុ ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌នោះ ដោយប្រការដូច្នេះឯង ។

[๖๗] ម្នាលកស្សប មួយយ៉ាងទៀត ពួកវិញ្ញូជន កាលបើមិនសួរកលទ្ធិ មិនដេញដោលរកហេតុ មិនសួរស្ទាក់រកលទ្ធិនិងហេតុ មិនប្រៀបជៀបគ្រូនិងគ្រូ ឬពួកនិងពួកថា ធម៌ទាំងឡាយដែលជាកុសល រាប់ថា ជាកុសល មិនមានទោស រាប់ថា មិនមានទោស គួរសេព រាប់ថា គួរសេព

ប្រសើរ ភប់ថា ប្រសើរ ជាចំណែកស ភប់ថា ជាចំណែកស របស់ជនដ៏ចម្រើនទាំងនេះ នរណាសមាទានធម៌ទាំងនេះ មិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ពួកសាវ័ករបស់ព្រះគោតម ឬក៏ពួកសាវ័ករបស់គណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ពួកវិញ្ញូជនកាលបើសួររក លទ្ធិដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិ និងហេតុ ក៏មុខជានិយាយយ៉ាងនេះថា ធម៌ទាំងឡាយដែលជាកុសល ភប់ថា ជាកុសល មិនមានទោស ភប់ថា មិនមានទោស គួរសេព ភប់ថា គួរសេព ប្រសើរ ភប់ថា ប្រសើរ ជាចំណែកស ភប់ថា ជាចំណែកសរបស់ពួកជនដ៏ចម្រើនទាំងនេះ ពួកសាវ័ករបស់ព្រះគោតម សមាទានធម៌ទាំងនេះមិនសេសសល់ ហើយប្រព្រឹត្តកាន់បាន ឬក៏ពួកសាវ័ករបស់គណាចារ្យដ៏ចម្រើនឯទៀត ។ ម្នាលកស្សប ពួកវិញ្ញូជនក្នុងលោកនេះ កាលបើសួររកលទ្ធិ ដេញដោលរកហេតុ សួរស្ទាក់រកលទ្ធិនិងហេតុ ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌ទាំងនោះ ដោយប្រការដូច្នេះឯង ។ ម្នាលកស្សប លោកុត្តរមគ្គក៏មាន បុព្វ-ភាគប្បដិបទា (សេចក្តីប្រតិបត្តិ ជាចំណែកខាងដើម) ក៏មាន ដែលបុគ្គលប្រតិបត្តិឲ្យសមគួរហើយ គង់ដឹងជាក់ច្បាស់នូវសាមញ្ញផល គង់នឹងឃើញដោយខ្លួនឯងថា ព្រះសមណគោតម និយាយត្រូវតាមកាល និយាយពិត និយាយប្រកបដោយប្រយោជន៍ និយាយត្រូវតាមធម៌ និយាយត្រូវតាមវិន័យ ។ ម្នាលកស្សប ចុះលោកុត្តរមគ្គនោះ តើដូចម្តេច បុព្វភាគប្បដិបទា តើដូចម្តេច ដែលបុគ្គលប្រតិបត្តិឲ្យសមគួរ ហើយគង់ដឹងជាក់ច្បាស់នូវ

សាមញ្ញផល គង់នឹងឃើញដោយខ្លួនឯងថា ព្រះសមណគោតម និយាយត្រូវតាមកាល និយាយពិត និយាយប្រកបដោយប្រយោជន៍ និយាយត្រូវតាមធម៌ និយាយត្រូវតាមវិន័យ ។ នេះឯង ជាមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺសេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ សេចក្តីរឭកត្រូវ ១ តម្កល់ចិត្តត្រូវ ១ ។ ម្នាលកស្សប នេះឯងជាលោកុត្តរមគ្គ នេះឯងជាបុព្វភាគបដិបទា ដែលបុគ្គលប្រតិបត្តិឲ្យសមគួរហើយ គង់ដឹងច្បាស់នូវសាមញ្ញផល គង់នឹងឃើញដោយខ្លួនឯងថា ព្រះសមណគោតមនិយាយត្រូវតាមកាល និយាយពិត និយាយប្រកបដោយប្រយោជន៍ និយាយត្រូវតាមធម៌ និយាយត្រូវតាមវិន័យ ។

[៦៨] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា អាវុសោគោតម ការផ្តើមនូវតបៈទាំងនេះ ដែលរាប់ថាជាកិច្ចការរបស់សមណៈផង រាប់ថាជាកិច្ចការរបស់ព្រាហ្មណ៍ផង របស់ពួកសមណព្រាហ្មណ៍ទាំងនេះ (មានច្រើនប្រការ) គឺជាបុគ្គលគ្មានសំពត់ (អាក្រាត) លះបង់មារយាទល្អ ស៊ីលិទ្ធដៃ ឬជម្រះឧច្ចារៈដោយម្រាមដៃ គេអញ្ជើញថា ចូលមក ក៏មិនមក គេឃាត់ថា ឈប់ ក៏មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកមុន មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងកិច្ចនិមន្តន៍ អចេលកៈនោះ មិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ជើ មិនទទួលភត្តដែល

*គេនាំមកត្រង់ចន្លោះធរណីទ្វារ មិនទទួលភត្តដែលគេនាំមកត្រង់ចន្លោះកំណាត់ឈើ មិនទទួលភត្តដែលគេនាំមកត្រង់ចន្លោះអង្រែ មិនទទួលភត្តរបស់មនុស្សពីរនាក់កំពុងបរិភោគ មិនទទួលភត្តរបស់ស្រីមានគភ៌ មិនទទួលភត្តរបស់ស្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្រីដែលនៅក្នុងចន្លោះបុរស មិនទទួលភត្តក្នុងទីដែលពួកគ្នាឯងណែនាំ មិនទទួលភត្តក្នុងទីដែលមានឆ្កែចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកត្រាំថ្នាំ ។ អចេលក:នោះ ទទួលភត្តចំពោះតែក្នុងផ្ទះមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយមួយពំនូតខ្ញុះ ទទួលភត្តចំពោះតែក្នុងផ្ទះពីរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្ញុះ ទទួលភត្តចំពោះតែក្នុងផ្ទះ ៧ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅចំពោះតែក្នុងដុំបាយ ៧ ពំនូតខ្ញុះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងកាជន៍ ១ ខ្ញុះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងកាជន៍ ២ ខ្ញុះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងកាជន៍ ៧ ខ្ញុះ សុីអាហារលង ១ ថ្ងៃខ្ញុះ សុីអាហារលង ២ ថ្ងៃខ្ញុះ សុីអាហារលង ៧ ថ្ងៃខ្ញុះ ។ អចេលក:ប្រកបដោយសេចក្តីព្យាយាមក្នុងការផ្ចាស់ប្តូរនូវការបរិភោគភត្តរំលងកន្ទុះខ្ញែ មានសភាពយ៉ាងនេះដូច្នេះឯង ។ អាវុសោគោតម ការផ្តើមតប:ទាំងនេះ ដែលរាប់ថាជាកិច្ចការរបស់សមណ:ផង រាប់ថាជាកិច្ចការរបស់ព្រាហ្មណ៍ផង របស់ពួកសមណព្រាហ្មណ៍ទាំងនេះ (មានច្រើនប្រការ) គឺបុគ្គលមានបន្លែស្រស់ជាអាហារខ្ញុះ មានអង្ករស្រែងជាអាហារខ្ញុះ មានស្លួយជាអាហារខ្ញុះ មានកម្ទេចស្បែក (ចំនៀរស្បែក)

ជាអាហារខ្លះ មានជ័រជាអាហារខ្លះ មានស្ករ ឬសាវយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើ និងផ្លែឈើព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះស្រោចចម្អែតអាត្មា ។ អាវុសោគោតម ការផ្តើមតបៈទាំងនេះ រាប់ថាជាកិច្ចការរបស់សមណៈផង រាប់ថាជាកិច្ចការរបស់ព្រាហ្មណ៍ផង របស់ពួកសមណព្រាហ្មណ៍ទាំងនេះ (មានច្រើនប្រការ) គឺទ្រទ្រង់សំពត់សម្បកឆ្មៃខ្លះ ទ្រទ្រង់សំពត់ដែលត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំពត់បង្សុកូលខ្លះ ទ្រទ្រង់សម្បកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់ស្បូវភ្លាំងក្រងជាសំពត់ខ្លះ ទ្រទ្រង់សំពត់ត្បាញដោយសម្បកក្រចៀខ្លះ ទ្រទ្រង់ចម្រៀកក្តារជាសំពត់ខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយរោមកន្ទុយសត្វខ្លះ ទ្រទ្រង់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ដកសក់ និងពុកមាត់ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមដកសក់ និងពុកមាត់ខ្លះ ឈរសម្រឹងហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោង ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមច្រហោងខ្លះ ផ្អែកលើបន្ទា សម្រេចការដេកលើបន្ទាខ្លះ សម្រេចការដេកលើផែនក្តារខ្លះ សម្រេចការដេកផ្ទាល់ផែនដីខ្លះ ដេកផ្អៀងតែម្ខាង មានសរីរៈប្រឡាក់ដោយធូលីខ្លះ នៅកណ្តាលវាល អង្គុយលើអាសនៈតាមតែបានខ្លះ បរិភោគតែលាមក ប្រព្រឹត្តកាន់វត្ត ក្នុងការព្យាយាមបរិភោគតែលាមកខ្លះ តមទឹកត្រជាក់ ប្រព្រឹត្ត

កាន់វត្តតមទឹកត្រជាក់ខ្លះ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺ ព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។

[៦៩] *ម្នាលកស្សប បើអចេលក: ជាអ្នកលះបង់មារយាទល្អ បរិភោគលិទ្ធដៃ ។បេ។ ប្រព្រឹត្តកាន់វត្ត ក្នុងការព្យាយាមផ្ចាស់ប្តូរនូវការ បរិភោគកត្ត រំលងកន្ទុះខែ មានសភាពយ៉ាងនេះដូច្នេះឯង ។ ចំណែកខាង សីលសម្បទា ចិត្តសម្បទា និងបញ្ញាសម្បទានេះ ក៏អចេលក:នោះ មិនបាន ចម្រើន មិនបានធ្វើឲ្យជាក់ច្បាស់ឡើយ ។ អចេលក:នោះ ឈ្មោះថា ឆ្ងាយ ចាកសាមញ្ញគុណផង ឆ្ងាយចាកព្រហ្មញ្ញគុណផង ដោយពិត ។ ម្នាល កស្សប កិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ជីងច្បាស់ ធ្វើ ឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវ: ព្រោះអស់ទៅនៃអាសវ:ទាំងឡាយ ។ ម្នាល កស្សប កិក្ខុនេះ តថាគតហៅថា សមណ:ក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលក:មានបន្លែស្រស់ជាអាហារ មានអង្ករស្រែងជា អាហារ ។បេ។ មានមើមឈើ ផ្លែឈើព្រៃជាអាហារ បរិភោគតែផ្លែឈើ ដែលជ្រុះស្រាប់ចម្អែតអាត្មា ។ ខាងឯសីលសម្បទា ចិត្តសម្បទា និងបញ្ញា-សម្បទានេះ ក៏អចេលក:នោះ មិនដែលបានចម្រើន មិនដែលបានធ្វើឲ្យ ជាក់ច្បាស់ឡើយ ។ អចេលក:នោះឈ្មោះថា ឆ្ងាយចាកសាមញ្ញគុណផង ឆ្ងាយចាកព្រហ្មញ្ញគុណផង ដោយពិត ។ ម្នាលកស្សប កិក្ខុចម្រើនមេត្តា ចិត្ត មិនមានពៀរ មិនមានព្យាបាទ ជីងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួន*

ឯងក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគត ហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈនោះ ទ្រទ្រង់សំពត់សំបុកផ្លែខ្នុះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្នុះ ។បេ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្នុះ ។ ចំណែកខាងសីលសម្បទា ចិត្តសម្បទា និងបញ្ញាសម្បទានេះ ក៏អចេលកៈនោះ មិនបានចម្រើន មិនបានធ្វើឲ្យជាក់ច្បាស់ឡើយ ។ អចេលកៈនោះ ឈ្មោះថា ឆ្ងាយចាកសាមញ្ញគុណផង ឆ្ងាយចាកព្រហ្មញ្ញគុណផង ដោយពិត ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ដ៏ងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯងក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគត ហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។

[๗๐] *កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អចេលកស្សបបានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សាមញ្ញគុណកម្រធ្វើបានណាស់ ព្រហ្មញ្ញគុណកម្រធ្វើបានណាស់ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សប សម្តីដែលថាសាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបាននេះ ជាសម្តីប្រក្រតីក្នុងលោកទេ ។ ម្នាលកស្សប បើអចេលកៈ លះបង់នូវមារយោនល្អ បរិភោគលិទ្ធដៃ ។បេ។*

ប្រព្រឹត្តកាន់វត្ត ក្នុងការព្យាយាម ផ្ចាស់ប្តូរនូវការបរិភោគកត្តរំលងកន្ទុះខែ មានសភាពយ៉ាងនេះ ដូច្នេះ ។ ម្នាលកស្សប សាមញ្ញគុណ ឬព្រហ្មញ្ញ-គុណដែលថា កម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះតែសេចក្តីប្រតិបត្តិបន្តិចនេះ និងការផ្តើមតបៈប៉ុណ្ណោះឯង តែពាក្យដែលពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណធ្វើបានដោយលំបាក នុ៎ះមិនគួរទេ ព្រោះគហបតី និងបុត្រនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចធ្វើសាមញ្ញគុណ និងព្រហ្មញ្ញគុណនេះបានដែរ ដោយគេគិតឃើញថា ណ្ហើយចុះ អាត្មាអញធ្លាប់ជាអ្នកអាក្រាត ជាអ្នកលះបង់មារយាទល្អ ជាអ្នកបរិភោគលិទ្ធដៃ ។បេ។ អាត្មាអញប្រព្រឹត្តកាន់វត្ត បរិភោគកត្តផ្ចាស់ប្តូររំលងកន្ទុះខែមានសភាពយ៉ាងនេះហើយ ។ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តបន្តិចប៉ុណ្ណោះ និងវៀរចាកការផ្តើមតបៈនេះចេញ (គឺមិនធ្លាប់ធ្វើតបៈហើយ) សាមញ្ញគុណ ឬព្រហ្មញ្ញគុណ ដែលថា កម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះហេតុនោះ ពាក្យដែលពោលថា សាមញ្ញ-គុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបានក្រៃពេក នុ៎ះក៏គួរខ្លះដែរ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ជីងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះ តថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈ មានបន្ទៃស្រស់ជាអាហារ

មានអង្ករស្រែឆៃ ជាអាហារ ฯបេฯ មានមើមឈើ ផ្លែឈើព្រៃ ជាអាហារ បរិភោគផ្លែឈើដែលជ្រុះស្រោចចម្អែតអាត្មា ฯ ម្នាលកស្សប សាមញ្ញគុណ ឬព្រហ្មញ្ញគុណដែលថា កម្រធ្វើបាន រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះតែសេចក្តីប្រតិបត្តិបន្តិចបន្តួចនេះ និងការផ្តើមតបៈប៉ុណ្ណោះឯង តែពាក្យដែលពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបាន នុ៎ះមិនគួរទេ្បីយ ព្រោះគហបតី និងបុត្រនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចធ្វើសាមញ្ញគុណ និងព្រហ្មញ្ញគុណនេះបានដែរ ដោយគេគិតឃើញថា ណ្ហើយចុះ អាត្មាអញធ្លាប់ជាអ្នកមានបន្លែស្រស់ជាអាហារ ឬអង្ករស្រែឆៃជាអាហារ ฯបេฯ អាត្មាអញធ្លាប់ជាអ្នកមានមើមឈើ ផ្លែឈើព្រៃ ជាអាហារ បរិភោគតែផ្លែឈើដែលជ្រុះស្រោចចម្អែតអាត្មា ฯ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តបន្តិចនេះ និងវៀរចាកការផ្តើមតបៈប៉ុណ្ណោះចេញ (គឺមិនធ្លាប់ធ្វើតបៈហើយ) សាមញ្ញគុណ ឬព្រហ្មញ្ញគុណ ដែលថាកម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះហេតុនោះ ក៏គួរនឹងពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបានដូច្នេះក៏គួរដែរ ฯ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ជីឯងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះហើយ បានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ฯ ម្នាលកស្សប ភិក្ខុនេះ តថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ฯ ម្នាលកស្សប បើអចេលកៈទ្រទ្រង់សំពត់សម្បកឆ្នែខ្លះ

ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។បេ។ ប្រព្រឹត្តកាន់វត្ត ចុះត្រាំទឹក ๑ ថ្ងៃ ๓ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាច ។ ម្នាលកស្សប សាមញ្ញគុណ ឬ ព្រហ្មញ្ញគុណដែលថា កម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះតែអចេលកវត្តបន្ទិចនេះ និងការផ្តើមតបៈប៉ុណ្ណោះឯង តែមិនគួរនឹងពោលថាសាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបានដូច្នេះទេ ព្រោះគហបតី និងបុត្តនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចធ្វើសាមញ្ញគុណ និងព្រហ្មញ្ញគុណនេះបានដែរ ដោយគេគិតឃើញថា ណ្ហើយចុះ អាត្មាអញ ធ្លាប់ទ្រទ្រង់សំពត់សម្បកឆៃខ្លះទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។បេ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ๑ ថ្ងៃ ๓ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តមានប្រមាណតិចប៉ុណ្ណោះ និងវៀរចាកការផ្តើមតបៈប៉ុណ្ណោះចេញ (គឺមិនធ្លាប់ធ្វើតបៈហើយ) សាមញ្ញគុណ ឬ ព្រហ្មញ្ញគុណ ដែលថាកម្រធ្វើបាន ក៏រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះហេតុនោះ ពាក្យដែលពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបាន នោះក៏គួរខ្លះ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ជីងច្បាស់ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សប ភិក្ខុនេះតថាគតហៅថាសមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។

[๗๑] *កាលបើព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ អចេល-*

កស្សប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ដែលហៅថា សមណៈបុគ្គលដឹងបានដោយកម្រ ហៅថា ព្រាហ្មណ៍ ក៏បុគ្គលដឹងបានដោយកម្រ ។ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សប សម្តីដែលថា សមណៈបុគ្គលដឹងបានដោយកម្រ ព្រាហ្មណ៍ក៏បុគ្គលដឹងបានដោយកម្រ នេះជាសម្តីប្រក្រតីក្នុងលោកទេ ។ ម្នាលកស្សប បើអចេលកៈលះបង់នូវមាយាទល្អ បរិភោគលិទ្ធដៃ ។បេ។ ប្រព្រឹត្តកាន់វត្ត បរិភោគភត្តផ្ងាស់ប្តូរំលងកន្ទុះខែ មានសភាពយ៉ាងនេះដូច្នេះ ។ ម្នាលកស្សប សមណៈ ឬព្រាហ្មណ៍ដែលថា បុគ្គលដឹងបានដោយកម្រ ក៏វិតតែដឹងបានដោយកម្រក្រៃពេក ព្រោះតែអចេលកវត្តបន្ទិចនេះ និងការផ្តើមតបៈប៉ុណ្ណោះឯង តែពាក្យដែលពោលថា សមណៈ បុគ្គលដឹងបានដោយកម្រ ព្រាហ្មណ៍ក៏បុគ្គលដឹងបានដោយកម្រទុំៈ មិនគួរទេ ព្រោះគហបតី ឬបុត្តនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចដឹងនូវបុគ្គលនេះថា នេះជាអចេលកៈ អ្នកលះបង់មាយាទល្អ បរិភោគលិទ្ធដៃ ។បេ។ ប្រព្រឹត្តកាន់វត្តបរិភោគភត្តផ្ងាស់ប្តូរំលងកន្ទុះខែ មានសភាពយ៉ាងនេះដូច្នេះ ។ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តបន្ទិចនេះ និងវៀរចាកការផ្តើមតបៈប៉ុណ្ណោះចេញហើយ សមណៈ ឬព្រាហ្មណ៍ដែលថា គេដឹងបានដោយក្រ ក៏វិតតែដឹងបានដោយក្រក្រៃពេក ព្រោះហេតុនោះ ក៏គួរនឹងពោលថា សមណៈគេដឹងបានដោយក្រដូច្នេះដែរ ។ ម្នាលកស្សប កាលណាបើកិក្ខុចម្រើនមេត្តាចិត្តមិនមានពៀរ មិនមានព្យាបាទ ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយខ្លួនឯង ក្នុង

*អត្តភាពនេះ ហើយបានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ម្នាលកស្សប ភិក្ខុនេះ តថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើអចេលកៈមានបន្លែស្រស់ជាអាហារ មានអង្គរស្រែងជាអាហារ ។បេ។ មានមើមឈើផ្លែឈើព្រៃជាអាហារ បរិភោគផ្លែឈើដែលជ្រុះស្រេច ចម្អែតអាត្មា ។ ម្នាលកស្សប សមណៈ ឬព្រាហ្មណ៍ ឈ្មោះថា គេជីងបានដោយក្រ ក៏រឹតតែជីងបានដោយក្រក្រៃពេក ព្រោះអចេលកវត្ត និងការផ្តើមនូវតបៈមានប្រមាណប៉ុណ្ណេះ តែពាក្យដែលពោលថា សមណៈគេជីងបានដោយក្រ ព្រាហ្មណ៍ក៏គេជីងបានដោយក្រ នុ៎ះមិនគួរឡើយ ទោះបីគហបតី ឬបុត្តនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចជីងនូវបុគ្គលនេះបានថា បុគ្គលនេះមានបន្លែស្រស់ជាអាហារ ឬមានអង្គរស្រែងជាអាហារ ។បេ។ មានមើមឈើ ផ្លែឈើព្រៃជាអាហារ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ចម្អែតអាត្មា ។ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តបន្តិចនេះ និងវៀរចាកការផ្តើមតបៈប៉ុណ្ណេះចេញហើយសមណៈ ឬព្រាហ្មណ៍ដែលថា គេជីងបានដោយក្រ ក៏រឹតតែជីងបានដោយក្រក្រៃពេក ព្រោះហេតុនោះ ពាក្យដែលពោលថា សមណៈ គេជីងបានដោយក្រ ព្រាហ្មណ៍គេជីងបានដោយក្រនុ៎ះក៏គួរដែរ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ជីងច្បាស់ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះហើយ បានដល់នូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។

ម្នាលកស្សប ភិក្ខុនេះ តថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។ ម្នាលកស្សប បើបុគ្គលទ្រទ្រង់សំពត់សម្បកឆ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។បេ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។ ម្នាលកស្សប សមណៈ ឬព្រាហ្មណ៍ដែលថាគេជីងបានដោយក្រ ក៏វិតតែជីងបានដោយក្រក្រៃពេក ព្រោះតែអចេលកវត្តបន្ទិចនេះ និងការផ្តើមតបៈប៉ុណ្ណោះ ពាក្យដែលពោលថា សមណៈគេជីងបានដោយក្រ ព្រាហ្មណ៍គេជីងបានដោយក្រនុ៎ះ មិនគួរទេ ទោះបីគហបតី ឬបុត្រនៃគហបតី ដោយហោចទៅសូម្បីតែកុម្ភទាសី ក៏អាចជីងបុគ្គលនេះបានថា បុគ្គលនេះ ទ្រទ្រង់សំពត់សម្បកឆ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ។បេ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។ ម្នាលកស្សប កាលណាបើវៀរចាកអចេលកវត្តបន្ទិចនេះ និងការផ្តើមតបៈប៉ុណ្ណោះចេញហើយ សមណៈ ឬព្រាហ្មណ៍ដែលថា គេជីងបានដោយក្រ ក៏វិតតែជីងបានដោយក្រក្រៃពេក ព្រោះហេតុនោះ ពាក្យដែលនិយាយថា សមណៈគេជីងបានដោយក្រ ព្រាហ្មណ៍គេជីងបានដោយក្រនុ៎ះ ក៏គួរដែរ ។ ម្នាលកស្សប កាលណាបើភិក្ខុចម្រើនមេត្តាចិត្ត មិនមានពៀរ មិនមានព្យាបាទ ជីងច្បាស់ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះហើយ បានដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលកស្សបភិក្ខុនេះ តថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ។

[๗๒] *កាលបើ ព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ អចេល-*

កស្សប បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សីលសម្បទាតើដូចម្តេច ចិត្តសម្បទាតើដូចម្តេច បញ្ញាសម្បទាតើដូចម្តេច ។ ព្រះអង្គត្រាស់ថា ម្នាលកស្សប ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាអរហំសម្មាសម្ពុទ្ធ ។បេ។ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារផងចុះ ។ ម្នាលកស្សប ដូចម្តេចដែលហៅថា ភិក្ខុជាអ្នកបរិបូណ៌ដោយសីល ម្នាលកស្សប ភិក្ខុក្នុងសាសនានេះ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ មានសេចក្តីអៀនខ្មាសជាប់ហើយនូវសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងពួង នេះជាសីលសម្បទា នៃភិក្ខុនោះឯង ។បេ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ រមែងទទួលនូវសេចក្តីសុខ មិនមានទោសតាំងនៅខាងក្នុង ម្នាលកស្សប យ៉ាងនេះ ហៅថា ភិក្ខុបរិបូណ៌ដោយសីល ម្នាលកស្សប នេះឯងឈ្មោះថាសីលសម្បទា ។បេ។ បានដល់នូវបឋមជ្ឈាន នេះជាចិត្តសម្បទានៃភិក្ខុនោះឯង ម្នាលកស្សប នេះឯងឈ្មោះថា ចិត្តសម្បទា ។បេ។ ភិក្ខុផ្ងត់តម្រង់បង្អោនចិត្តដើម្បីញាណទស្សនៈ នេះឯងជាបញ្ញាសម្បទារបស់ភិក្ខុនោះ ។បេ។ ដឹងច្បាស់ថា កិច្ចដទៃក្រៅអំពីនេះមិនមានឡើយ នេះឯងជាបញ្ញាសម្បទារបស់ភិក្ខុនោះ ម្នាលកស្សប នេះឯងឈ្មោះថា បញ្ញាសម្បទា ។ ម្នាលកស្សប សីលសម្បទា ចិត្តសម្បទា និងបញ្ញាសម្បទាឯទៀតដ៏លើសលប់ ថ្លៃថ្លា ជាងសីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទានេះគ្មានទេ ។

[๗๓] *ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាសីលវាទៈ (អ្នកពោលអាងសីល) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណរបស់សីលដោយអនេកបរិយាយ ។ ម្នាលកស្សប (បើទុកជា) អរិយសីលដ៏ក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណា ត្រឹមស្មើតថាគតក្នុងអរិយសីលនោះទេ ក្រៃលែងជាងមកពីណាបាន តថាគតឯងជាអ្នកក្រៃលែងក្នុងគុណ គឺអធិសីលនោះដោយពិត ។ ម្នាលកស្សប មានសមណ-ព្រាហ្មណ៍ពួកមួយជាតបោជិគុច្ឆវាទៈ (អ្នកពោលអាងការខ្ពើមកិលេសដោយតបៈ) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណនៃការខ្ពើមកិលេសដោយតបៈជាអនេកបរិយាយ ។ ម្នាលកស្សប (បើទុកជា) ការខ្ពើមកិលេសដោយតបៈដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណាត្រឹមស្មើនឹងការខ្ពើមកិលេស របស់តថាគតក្នុងតបៈនោះទេ ក្រៃលែងមកពីណាបាន តថាគតឯង ជាអ្នកក្រៃលែងក្នុងគុណ គឺការខ្ពើមកិលេសដោយពិត ។ ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាបញ្ញាវាទៈ (អ្នកពោលអាងបញ្ញា) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរគុណនៃបញ្ញាដោយអនេក-បរិយាយ ។ ម្នាលកស្សប (បើទុកជា) បញ្ញាដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណាត្រឹមស្មើនឹងបញ្ញា របស់តថាគតក្នុងបញ្ញានោះទេ ក្រៃលែងមកពីណាបាន តថាគតឯងជាអ្នកក្រៃលែងក្នុងគុណ គឺអធិបញ្ញានោះដោយពិត ។ ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ជាវិមុត្តិវាទៈ (អ្នកពោលអាងវិមុត្តិ) សមណព្រាហ្មណ៍ទាំងនោះ តែងសរសើរ*

គុណរបស់វិមុត្តិដោយអនេកបរិយាយ ។ ម្នាលកស្សប (បើទុកជា) វិមុត្តិ ដ៏ប្រសើរក្រៃលែងប៉ុន្មាន ក៏តថាគតមិនឃើញមានបុគ្គលណា ត្រឹមស្មើនឹង វិមុត្តិរបស់តថាគតក្នុងវិមុត្តិនោះទេ ក្រៃលែងមកពីណាបាន តថាគតឯងជា អ្នកក្រៃលែងក្នុងគុណ គឺអធិវិមុត្តិនោះដោយពិត ។

[๗๔] ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដ ដែលពួកអន្យ-តិរ្ថិយបរិព្វាជកនិយាយយ៉ាងនេះថា ព្រះសមណគោតម តែងតែបន្ទឹសីហនាទ ប៉ុន្តែបន្ទឹសីហនាទនោះ បានតែក្នុងផ្ទះស្ងាត់ មិនបន្ទឹក្នុងពួកបរិសទ្យទេ ។ អ្នក ត្រូវប្រាប់ពួកគេថា អ្នកទាំងឡាយកុំពោលយ៉ាងនេះឡើយ ម្នាលកស្សប អ្នក ត្រូវប្រាប់គេថាព្រះសមណគោតមតែងតែបន្ទឹសីហនាទ បន្ទឹតែក្នុងពួកបរិសទ្យ មិនបន្ទឹក្នុងផ្ទះសាត់ទេ ។ ម្នាលកស្សប សេចក្តីនេះជាឋានៈមានប្រាកដដែល ពួកអន្យតិរ្ថិយបរិព្វាជកនិយាយយ៉ាងនេះថា ព្រះសមណគោតម តែងតែបន្ទឹ សីហនាទ បន្ទឹក្នុងពួកបរិសទ្យដែរហើយ តែមិនជាអ្នកក្បៀវក្បាបន្ទឹទេ ។ អ្នក ត្រូវប្រាប់ពួកបរិព្វាជកទាំងនោះថា អ្នកទាំងឡាយ កុំពោលយ៉ាងនេះឡើយ ។ ម្នាលកស្សប អ្នកត្រូវប្រាប់ពួកគេថា ព្រះសមណគោតមបន្ទឹសីហនាទ តែង បន្ទឹក្នុងពួកបរិសទ្យជាអ្នកក្បៀវក្បាបន្ទឹ ។ ម្នាលកស្សប សេចក្តីនេះ ជាឋានៈ មានប្រាកដដែលពួកតិរ្ថិយបរិព្វាជក និយាយយ៉ាងនេះថា ព្រះសមណគោតម បន្ទឹសីហនាទ តែងបន្ទឹក្នុងពួកបរិសទ្យ ជាអ្នកក្បៀវក្បាបន្ទឹ តែទេវតា និង មនុស្សទាំងឡាយ មិនដែលសួរប្រស្នានឹងលោកឡើយ ទោះបីសួរប្រស្នានឹង លោក លោកក៏ដោះប្រស្នា ដែលពួកទេវតា និងមនុស្សទាំងនោះសួរ មិន

បានទេ ទោះបីលោកដោះប្រស្នា ដែលពួកទេវតានឹងមនុស្សទាំងនោះសួរបាន លោកក៏មិនញុាំងចិត្តឲ្យត្រេកអរ ដោយការដោះប្រស្នា បើទុកជាញុាំងចិត្តឲ្យត្រេកអរ ដោយការដោះប្រស្នាបាន ជនទាំងឡាយ ក៏មិនសម្គាល់ថា គួរស្តាប់ទេ ទោះសម្គាល់ថា គួរស្តាប់ ក៏គ្រាន់តែស្តាប់ហើយមិនជ្រះថ្លាទេ ទុកជាស្តាប់ហើយជ្រះថ្លា ក៏គ្រាន់តែជ្រះថ្លាប៉ុណ្ណោះ តែមិនធ្វើអាការជ្រះថ្លា (មែនទែន) ទេ ទុកជាជ្រះថ្លា ហើយធ្វើអាការជ្រះថ្លា ក៏មិនប្រតិបត្តិតាមសេចក្តីជ្រះថ្លានោះទេ បើទុកជាប្រតិបត្តិ តាមសេចក្តីជ្រះថ្លានោះបាន ក៏មិនប្រតិបត្តិឲ្យពេញព្រះទ័យនៃលោកបានទេ ។ អ្នកត្រូវប្រាប់ពួកគេថា អ្នកទាំងឡាយកុំពោលយ៉ាងនេះឡើយ ។ ម្នាលកស្សប អ្នកត្រូវប្រាប់ពួកគេថា ព្រះសមណ-គោតមបន្ទឹសីហនាទ តែងបន្ទឹក្នុងពួកបរិសទ្យជាអ្នកក្លៀវក្លាបន្ទឹ ពួកទេវតានិងមនុស្សសួរប្រស្នានឹងលោក លោកក៏ដោះប្រស្នាដែលពួកទេវតា និងមនុស្សទាំងនោះសួរបាន លោកញុាំងចិត្តឲ្យត្រេកអរដោយការដោះប្រស្នាបានទាំងពួកជនក៏សម្គាល់ថា ពាក្យរបស់លោកជាពាក្យគួរស្តាប់ លុះស្តាប់ហើយក៏ជ្រះថ្លានឹងលោក លុះជ្រះថ្លាហើយ ក៏ធ្វើអាការជ្រះថ្លា ប្រតិបត្តិតាមសេចក្តីជ្រះថ្លានោះ ប្រតិបត្តិឲ្យពេញព្រះទ័យលោកបាន ។ ម្នាលកស្សប សម័យមួយ តថាគតនៅលើភ្នំគិជ្ឈកូដ ជិតនគរោជគ្រឹះ ។ មានបរិព្វាជកម្នាក់ឈ្មោះនិគ្រោធជាសព្រហ្មចារី នៃអ្នកក្នុងនគរោជគ្រឹះទាំងនោះ មកសួរប្រស្នានឹងតថាគតក្នុងការខ្ពើមកិលេសយ៉ាងក្រៃលែង តថាគតក៏បានដោះប្រស្នាដែលនិគ្រោធបរិព្វាជកនោះសួរ ក្នុងការខ្ពើមកិលេសយ៉ាងក្រៃលែង លុះតថាគត

ដោះប្រស្នារួចហើយ បរិព្វាជកនោះ ក៏មានចិត្តត្រេកអរពន់ប្រមាណ ។

[៧៥] *បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ ដែលបានស្តាប់ធម៌របស់ព្រះមានព្រះភាគហើយ មិនមានចិត្តត្រេកអរពន់ប្រមាណ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គស្តាប់ធម៌ របស់ព្រះមានព្រះភាគហើយ មានចិត្តត្រេកអរពន់ប្រមាណណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ ដូចជាគេផ្ងារបស់ដែលគេផ្តាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានភ្នែកភ្លឺ នឹងឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។*

[៧៦] *ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សប បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយមកហើយ តែចង់ចូលមកក្នុងធម្មវិន័យនេះ ចង់បព្វជ្ជា និងឧបសម្បទា អន្យតិរ្ថិយនោះ ត្រូវនៅបរិវាសអស់ ៤ ខែ លុះកន្លង ៤ ខែហើយ ទើបភិក្ខុទាំងឡាយមានចិត្តត្រេកអរ ឲ្យបព្វជ្ជា ឲ្យឧបសម្បទាដើម្បីភាវៈជាភិក្ខុ ឯតថាគតដឹងនូវសេចក្តីផ្សេងគ្នា នៃបុគ្គលក្នុងកិច្ចដែលនៅបរិវាសនេះ ។ អចេលកស្សបក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលធ្លាប់ជា*

អន្យតិរ្ថិយមកហើយ ចង់ចូលមកក្នុងធម្មវិន័យនេះ ចង់បព្វជ្ជានិងឧបសម្បទា ត្រូវនៅបរិវាសអស់ ៤ ខែ លុះកន្លង ៤ ខែហើយ ទើបភិក្ខុទាំងឡាយមានចិត្តត្រេកអរ ឲ្យបព្វជ្ជា ឲ្យឧបសម្បទាដើម្បីភាវៈជាភិក្ខុ ដូច្នេះ ខ្ញុំព្រះអង្គនឹងនៅបរិវាសរហូត ៤ ឆ្នាំបាន លុះកន្លង ៤ ឆ្នាំហើយ ភិក្ខុទាំងឡាយ គង់មានចិត្តត្រេកអរ ឲ្យបព្វជ្ជា ឲ្យឧបសម្បទាដើម្បីភាវៈជាភិក្ខុ ។ អចេលកស្សប ក៏បានបព្វជ្ជា បានឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ លុះព្រះកស្សបមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ជាបុគ្គលម្នាក់ឯង ដោះខ្លួនចេញចាកពួក ឥតមានសេចក្តីប្រមាទ ខំព្យាយាមជុតនូវកិលេស ប្រថុយលះបង់នូវអត្តភាព ពួកកុលបុត្តដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយៈ ដោយបញ្ញារបស់ខ្លួនដោយខ្លួនឯង ក្នុងអត្តភាពនេះ សម្រាន្តនៅដោយឥរិយាបថទាំង ៤ មិនយូរប៉ុន្មាន ក៏បានដឹងច្បាស់ថា ជាតិ (កំណើត) របស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញក៏បានអប់រំចប់ហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញ ក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីនេះតទៅទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តអង្គមួយដែរ ។

មហាសីហនាទសូត្រទី ៨ ចប់

อัฏฐกถา

มหาสีหนาทสูตร

อเจลกัสสปกถา

[๖๒] มหาสีหนาทสูตรมีพากยเบื้องต้นว่า **เอวมฺเม สุตํ ฯเปฯ อุรุญฺญายํ** เป็นเบื้องต้น ฯ ในมหาสีหนาทสูตรนั้น มีพจนานุกรมเป็นที่สุดแห่งบทดังต่อไปนี้ บทว่า **อุรุญฺญายํ** มีเนื้อความว่า พากยว่า **อุรุญฺญา** นี้ เป็นชื่อของแคว้นน้อย ของหมู่บ้านน้อย ฯ พระผู้มีพระภาคทรงอาศัยอยู่ในกรุงอุรุญญา ฯ บทว่า **กณฺณกตฺถเล มิคทายเย** ได้แก่ ภูมิภาคที่ควรเที่ยวไปแห่งหนึ่ง ชื่อว่ากัณณกัตถละ มีอยู่ในที่ไม่ไกลแห่งกรุงนั้น ฯ ภูมิภาคนั้น ชื่อว่าป่าเนื้อ เพราะพระราชาทรงให้อภัยแก่สัตว์เนื้อ ฯ ในป่าเนื้อชื่อ **กณฺณกตฺถล** นั้น ฯ

บทว่า **อเจโล** ได้แก่ ผู้เปลือยกาย ฯ บทว่า **กสฺสโป** เป็นชื่อของผู้เปลือยกายนั้น ฯ บทว่า **ตปสฺสิโน** ได้แก่ ผู้ประพฤติตบะ ฯ บทว่า **ลูขาชีวี** ได้แก่ ผู้มีการเลี้ยงชีพของผู้เปลือยกายนั้น เป็นไปด้วยอำนาจแห่งการกระทำให้ลำบาก และมีการประพฤติปฏิบัติเป็นเหตุ ฯ เพราะเหตุนั้น จึงเรียกว่ามีการเลี้ยงชีพเป็นไป ฯ ผู้มีการเลี้ยงชีพเป็นไปนั้น ฯ บทว่า **อุปกาสติ** ได้แก่ ย่อมเข้าไปใกล้ ฯ บทว่า **อุปาคจฺฉติ** ได้แก่ ย่อมเข้าไปถึงโดยรอบ ฯ บทว่า **ธมฺมสฺส จ อนุธมฺมํ พฺยากโรนฺติ** ได้แก่ ย่อมพยากรณ์ธรรมและอนุธรรม ฯ บทว่า **สหา-**

ធម្មិកោ វាធានុវាធោ *គឺវាទៈ និងអនុវាទៈរបស់ព្រះអង្គ មានហេតុដោយហេតុ ដែលអ្នកជនៃពោលហើយ គឺហេតុដែលបណ្ឌិតគប្បីតិះដៀលថា បុគ្គលណាមួយ សូម្បីមិនប្រមាទ ក៏មិនមកឬ ។ ពាក្យនេះ លោកពោលថា ហេតុដែលគួរតិះដៀល ព្រោះវាទៈរបស់ទ្រង់មិនមានឬ ។ បទថា* **អនព្ភក្ខា-តុកាមា** *គឺមិនត្រូវការនិយាយពាក្យមិនពិត ។*

ក្នុងបទថា **ឯកកេ្ខ តបស្សី លូខាជីវី** *ជាដើម គប្បីជ្រាបដូច្នេះ ។ បុគ្គលក្នុងលោកអ្នកខ្វះមានតបៈ ព្រោះអាស្រ័យតបៈមានការបួសជាអចេលក៍ជាដើម គិតថា អញនឹងចិញ្ចឹមជីវិតដោយរបស់សៅហ្មង ទើបធ្វើខ្លួនឲ្យលំបាកដោយប្រការផ្សេងៗ មានស៊ីស្មៅ និងអាចម៍គោជាដើម និងមិនបានញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខ ព្រោះមានបុណ្យតិច ។ បុគ្គលនោះ បំពេញទុច្ចរិត ៣ ហើយ កើតក្នុងនរក ។*

បុគ្គលមួយទៀត អាស្រ័យតបៈដូច្នោះ ជាអ្នកមានបុណ្យ រមែងបានលាភសក្ការៈ ។ បុគ្គលនោះយល់ថា ឥឡូវនេះ បុគ្គលដូចជាអញមិនមានហើយលើកតម្កើងខ្លួនក្នុងឋានៈខ្ពស់ គិតថា នឹងញុំាងលាភឲ្យកើតក្រៃលែងឡើងៗ និងបំពេញទុច្ចរិត ៣ ដោយអំណាចនៃអនេសនា ហើយនឹងកើតក្នុងនរក ន័យដើមពោលសំដៅដល់បព្វជិតទាំងពីរនេះ ។

បុគ្គលមួយទៀត ចិញ្ចឹមជីវិតសៅហ្មង អាស្រ័យតបៈ ជាអ្នកមានបុណ្យតិច រមែងមិនអាចញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខបាន ។ បុគ្គលនោះ គិតថា ការរស់នៅសប្បាយ រមែងមិនកើតឡើងដល់អញ ព្រោះមិនបានធ្វើបុណ្យទុកក្នុងកាលមុន ណ្ហើយចុះ ឥឡូវនេះ អញនឹងធ្វើបុណ្យ

ដូច្នេះហើយ បំពេញសុចរិត ๓ កើតក្នុងស្ថានសួគ៌ ។

បុគ្គលមួយទៀត ចិញ្ចឹមជីវិតសៅហ្មង ជាអ្នកមានបុណ្យ រមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខ បុគ្គលនោះគិតថា ការរស់នៅសប្បាយរមែងកើតដល់អញ ព្រោះជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន លះអនេសនាហើយ បំពេញសុចរិត ๓ កើតក្នុងស្ថានសួគ៌ ។ នយទី ๒ ពោលសំដៅដល់បព្វជិតទាំងពីរនេះ ។

ឯអ្នកបំពេញតបៈម្នាក់ មានទុក្ខតិច ប្រកបដោយការប្រព្រឹត្តខាងក្រៅជាតាបស ឬជាបរិព្វាជកដែលមានសម្បុកបំពាក់ រមែងមិនបានបច្ច័យដែលពេញចិត្ត ព្រោះមានបុណ្យតិច ។ បុគ្គលនោះ បំពេញទុច្ចរិត ๓ ដោយអំណាចនៃអនេសនា តម្កល់ខ្លួនក្នុងសេចក្តីសុខ កើតក្នុងនរក ។ មួយរូបទៀតមានបុណ្យ កើតមានះឡើងថា ឥឡូវនេះ បុគ្គលដូចអញមិនមាន ក៏ញុំាងលាភសក្ការៈឲ្យកើតឡើង ដោយអំណាចអនេសនា ។ គិតរឿយៗ ដោយអំណាចមិច្ឆាទិដ្ឋិថា សម្ផស្សនៃបរិព្វាជិកាក្រមុំ ដែលមានវោមទន់ល្មៃនេះ ជាសេចក្តីសុខ ឬដល់ការជ្រមុជជ្រមុលក្នុងកាម បំពេញទុច្ចរិត ๓ នឹងធ្លាក់នរក ។ នយទី ๓ ពោលដល់បព្វជិតទាំងពីរ ។

ចំណែកមួយរូបទៀត មានទុក្ខតិច មានបុណ្យតិច ។ បុគ្គលនោះគិតថា អញមិនមានជីវិតដោយសេចក្តីសុខ ព្រោះមិនបានធ្វើបុណ្យទុកក្នុងកាលមុនដូច្នេះហើយ បំពេញសុចរិត ๓ ទើបកើតក្នុងស្ថានសួគ៌ ។ មួយរូបទៀត មានបុណ្យ ។ បុគ្គលនោះគិតថា អញបានសេចក្តីសុខ ព្រោះធ្វើបុណ្យទុកក្នុងកាលមុន សូម្បីឥឡូវនេះ ក៏នឹងធ្វើបុណ្យដូចគ្នា ទើបបំពេញសុចរិត ๓ កើត

ក្នុងស្ថានសួគ៌ ។ នយទី ៤ ពោលដល់បព្វជិតពីរូបនេះ ។ ការធ្វើនេះ មក ដោយអំណាចនៃតិរ្ថិយ មិនមានក្នុងសាសនានេះ ។

អ្នកបួសខ្លះ ជាអ្នកមានការរស់នៅសៅហ្មង ដោយអំណាចនៃការ សមាទានធុតង្គ ឬត្រាច់ទៅកាន់ស្រុក ក៏មិនបានអាហារពេញពោះ ព្រោះមាន បុណ្យតិច ។ បុគ្គលនោះគិតថា នឹងញុំាងបច្ច័យឲ្យកើតឡើង ទើបធ្វើ អនេសនា ដោយអំណាចវេជ្ជកម្មជាដើម អួតអាងព្រះអរហត្ត សេពទូវឿង កុហក ៣ ប្រការ រមែងកើតក្នុងនរក ។ មួយរូបទៀត ជាអ្នកមានបុណ្យច្រើន បុគ្គលនោះញុំាងមានះឲ្យកើតឡើង ។ ព្រោះបុញ្ញសម្បត្តិនោះ ប្រាថ្នានឹងធ្វើ លាភដែលកើតឡើងហើយ ឲ្យវិនាំ ទើបបំពេញទុច្ចរិត ៣ ដោយអំណាច អនេសនា រមែងកើតក្នុងនរក ។ មួយរូបទៀត សមាទានធុតង្គ ជាអ្នក មានបុណ្យតិច រមែងមិនបានញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្តីសុខ ។ បុគ្គលនោះគិតថា អញមិនបានបច្ច័យ ៤ ណាមួយ ព្រោះមិនបានធ្វើបុណ្យ ទុកក្នុងកាលមុន ឥឡូវនេះ បើអញធ្វើអនេសនាហើយ សូម្បីតទៅ ក៏នឹង បានសេចក្តីសុខដោយលំបាក ដូច្នេះ ក៏បំពេញសុចរិត ៣ កាលមិនអាច សម្រេចអរហត្ត ក៏កើតក្នុងស្ថានសួគ៌ ។ មួយរូបទៀត ជាអ្នកមានបុណ្យ ។ បុគ្គលនោះគិតថា ឥឡូវនេះ អញមានសេចក្តីសុខ ព្រោះធ្វើបុណ្យទុកក្នុង កាលមុន ឥឡូវនេះ អញនឹងធ្វើបុណ្យ ដូច្នេះហើយ លះអនេសនា បំពេញ សុចរិត ៣ កាលមិនអាចសម្រេចអរហត្ត ក៏ឯកើតក្នុងស្ថានសួគ៌ ។

បទថា **អាគតិញ្ច** គឺអ្នកទាំងនេះមកពីទីឯណោះ ដូច្នោះ ទើបឈ្មោះថា ដែលមកយ៉ាងនេះ ។ បទថា **គតិញ្ច** សេចក្តីថា ស្ថានទីដែលគប្បីទៅក្នុង

ឥឡូវនេះ ។ បទថា **ចុតិញ្ច** *គឺឃ្លាតចាកទីនោះផង ។ បទថា* **ឧបបត្តិញ្ច** *គឺការកើតទៀត របស់អ្នកចុតិអំពីទីនោះ ។ បទថា* **សញ្ជានបំ ភវេហិសង្ខាមិ** *គឺ តថាគតនឹងតិះដៀលដោយហេតុណា ។ ព្រោះថា តថាគតរមែងតិះដៀល វត្ថុដែលគួរតិះដៀល សរសើរវត្ថុដែលគួរសរសើរ ។ ពិតហើយ បុគ្គល នោះក៏ដូចជាជាងជ្រលក់សំពត់ ធ្វើការខ្ចប់សំពត់ មិនបង្ហាញថា អញនឹងធ្វើ សំពត់ដែលជ្រលក់ហើយ និងមិនទាន់បានជ្រលក់ ទុកក្នុងកញ្ចប់ជាមួយគ្នា ។*

[๖๓] *ឥឡូវនេះ កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ពាក្យ ជាដើមថា ម្នាលកស្សប មានសមណព្រាហ្មណ៍មួយពួកជាដើម ។*

បទថា **យំ តេ ឯកច្ចំ** *គឺសីល ៥ ។ មិនមានអ្នកណាក្នុងលោកពោល សីល ៥ នោះថា មិនល្អ ។ បទថា* **យំ តេ ឯកច្ចំ** *មួយទៀត គឺវេរ ៥ ។ មិនមានបុគ្គលណាម្នាក់ ពោលដល់វេរានោះ ថាល្អ ។ បទថា* **យំ តេ ឯកច្ចំ** *ម្យ៉ាងទៀត គឺការមិនសង្រួមក្នុងទ្វារទាំង ៥ ។ បានឮថា គេពោលថា ដែល ឈ្មោះថា ចក្ខុមិនត្រូវបិទ ក៏គប្បីឃើញរូបដែលគួរពេញចិត្តដោយចក្ខុ ។ នយ នេះ រមែងមានក្នុងទ្វារដទៃ មានសោតៈជាដើម ។ បទថា* **យំ តេ ឯកច្ចំ** *ម្យ៉ាងទៀត គឺការសង្រួមក្នុងទ្វារទាំង ៥ ។ កាលព្រះដ៏មានព្រះភាគ ទ្រង់ សម្តែងសេចក្តីស្មើ និងមិនស្មើនៃវាទៈរបស់ព្រះអង្គ និងវាទៈរបស់អ្នកដទៃ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់នឹងសម្តែងសេចក្តីស្មើ និងមិនស្មើនៃវាទៈរបស់ អ្នកដទៃ និងវាទៈរបស់ព្រះអង្គ ទើបត្រាស់ពាក្យជាដើមថា* **យំ មយំ** ។ *ក្នុងសេចក្តីនោះគប្បីជ្រាបអត្ថដោយអំណាចសីលមានសីល ៥ ជាដើម ។*

ការសាកសួរ

បទថា **សមនុយញ្ជន្តំ** *គឺចូរសាកសួរ ។ ក្នុងទីនេះ កាលសួរកលទ្ធិ ឈ្មោះថា* **សមនុយុជ្ជន្តំ** ។ *កាលសួរកហេតុ ឈ្មោះថា* **សមនុគ្គាហន្តំ** ។ *កាលសួរស្ទាក់កលទ្ធិ និងហេតុទាំងពីរ ឈ្មោះថា* **សមនុភាសន្តំ** ។ *បទថា* **សត្ថារា វា សត្ថារំ** *គឺប្រៀបធៀបគ្រូជាមួយនឹងគ្រូថា គ្រូរបស់លោកលះបង់ធម៌ទាំងនោះ ដោយប្រការទាំងពួងដូចម្តេចក្តី ព្រះសមណគោតម ... ។ សូម្បីក្នុងបទទី ២ ក៏ដូចគ្នា ។*

ឥឡូវនេះ កាលនឹងទ្រង់សម្តែងប្រកបសេចក្តីនោះ ទើបត្រាស់ពាក្យជាដើមថា **យេ ឥមេសំ ភវន្តំ** ។ *ក្នុងបទទាំងនោះ បទថា* **អកុសលា អកុសលសង្ខាតា** *អធិប្បាយថា ដែលជាអកុសលផង ដែលរាប់ថា ដែលដឹងថាជាអកុសលផង ឬថា ដែលតាំងជាចំណែក ។ នយក្នុងបទទាំងពួងក៏យ៉ាងនេះ ។ មួយទៀត ក្នុងបទទាំងនេះ បទថា* **សាវជ្ជា** *គឺប្រព្រឹត្តទៅដោយទោស ។ បទថា* **ន អលមរិយា** *គឺមិនអាចជាធម៌ដ៏ប្រសើរ ដោយអត្ថថា មិនមានទោស ។*

[๖๔-๖๗] *បទថា* **យំ ឥញ្ញ សមនុយញ្ញន្តា** *គឺកាលបណ្ឌិតសួរតថាគតនឹងអ្នកជនៃ ដោយប្រការណា គប្បីពោលយ៉ាងនេះ ហាន:នោះ មានសេចក្តីថា មានហេតុនោះ ។ បទថា* **យំ វា បន ភោន្តោ បរេ គណាចរិយា** *គឺគណាចារ្យជនៃលះហេតុដែលមានប្រមាណតិចនោះ តាមមាន តាមបានប្រព្រឹត្តទៅ ។*

ព្រះមានព្រះភាគ ត្រាស់ពាក្យនេះថា ច្រើនតែសរសើរពួកតថាគត ក្នុង

ធម៌នោះ ដូច្នេះ ។ ទាំងក្នុងការសាកសួរគ្រូនិងគ្រូ ទាំងក្នុងការសាកសួរពួក និងពួក ព្រោះហេតុអ្វី ព្រោះការសរសើរព្រះសង្ឃ ក៏ឈ្មោះថា សរសើរព្រះសាស្តាដូចគ្នា ។ ពិតហើយ កាលបណ្ឌិតជ្រះថ្លា ក៏រមែងជ្រះថ្លាក្នុងសង្ឃ ព្រមទាំងព្រះពុទ្ធ និងរមែងជ្រះថ្លាក្នុងព្រះពុទ្ធ ព្រមទាំងសង្ឃ ។ ពិតហើយ បណ្ឌិតឃើញសេចក្តីសម្រេចនៃព្រះសរីរៈរបស់ព្រះមានព្រះភាគ ឬស្តាប់ព្រះធម៌ទេសនាហើយ ពោលថា ម្នាលអ្នកដ៏ចម្រើន ជាលាភរបស់ព្រះសាវក អ្នកត្រាច់ទៅក្នុងសម្នាក់របស់សាស្តាបែបនេះហ្ន៎ ឈ្មោះថា រមែងជ្រះថ្លាក្នុងព្រះសង្ឃ ព្រមទាំងព្រះពុទ្ធសម្បត្តិយ៉ាងនេះ វិញ្ញូជនទាំងឡាយ ឃើញអាចារគោចរ និងឥរិយាបថ មានការឈានមុខទៅ ឈានថយក្រោយជាដើម របស់ភិក្ខុទាំងឡាយ ជាអ្នកពោលថា ម្នាលលោកដ៏ចម្រើន នេះជាឥរិយាបថរបស់សាវក អ្នកត្រាច់ទៅក្នុងសម្នាក់ ឯគុណ គឺសេចក្តីស្ងប់នេះ របស់ព្រះសាស្តានឹងមានប្រមាណប៉ុនណាហ្ន៎ ឈ្មោះថា រមែងជ្រះថ្លាក្នុងព្រះពុទ្ធ ព្រមទាំងព្រះសង្ឃ ដូច្នោះ ការសរសើរព្រះសាស្តា ក៏ឈ្មោះថា សរសើរព្រះសង្ឃ សូម្បីការសរសើរព្រះសង្ឃ ក៏ស្មើនឹងការសរសើរព្រះសាស្តាដូចគ្នា ព្រះដ៏មានព្រះភាគត្រាស់ថា ក៏ច្រើនតែសរសើរពួកតថាគត ក្នុងធម៌ទាំងនោះ សូម្បីក្នុងនយទាំង ២ ។ ព្រោះការសរសើរព្រះសង្ឃ ក៏ឈ្មោះថា សរសើរព្រះសាស្តាដូចគ្នា ។ ព្រះសមណគោតមលះបង់ធម៌ទាំងនេះ មិនឲ្យសេសសល់ប្រព្រឹត្តទៅ ។ នេះជាសេចក្តីបំណងក្នុងសេចក្តីនេះ និងក្នុងពាក្យជាដើមថា ឬក៏ពួកគណាចារ្យដ៏ចម្រើនឯទៀត ។

ឯវិរតិមាន ៣ ដោយអំណាចនៃសម្បត្តវិរតិ សមាទានវិរតិ និងសេតុ-

ឃាតវិរតិ ក្នុងវិរតិទាំងនោះ ត្រឹមតែសម្បត្តវិរតិ និងសមាទានវិរតិ រមែងមានដល់អ្នកជនៃ ចំណែកសេតុឃាតិវិរតិមិនមានឡើយ ដោយប្រការទាំងពួង ។ ក្នុងតទង្គប្បហាន វិក្ខម្ភនប្បហាន សមុច្ឆេទប្បហាន បដិបស្សទ្ធិប្បហាន និងនិស្សរណប្បហាន ៥ យ៉ាង បហាន ២ គឺតទង្គប្បហាន និងវិក្ខម្ភនប្បហាន រមែងមានដល់អ្នកជនៃ ដោយអំណាចនៃសមាបត្តិ ៨ និងដោយអំណាចនៃវិបស្សនា បហាន ៣ ក្រៅពីនេះមិនមានឡើយ ដោយប្រការទាំងពួង ។ ពិតហើយ សំវរៈ ៥ គឺសីលសំវរៈ ឥន្ទ្រិយសំវរៈ ញាណសំវរៈ សតិសំវរៈ វីរិយសំវរៈ ក្នុងសំវរៈទាំងនោះ អ្នកជនៃមានត្រឹមតែសីល ៥ និងអធិវាសនឥន្ទ្រិយប៉ុណ្ណោះ ដ៏សេសរមែងមិនមានដោយប្រការទាំងពួង ។ ឧទ្ទេសរបស់ឧបោសថនេះមាន ៥ យ៉ាង ក្នុងឧទ្ទេសនៃឧបោសថទាំងនោះ ត្រឹមតែសីល ៥ ប៉ុណ្ណោះ រមែងមានដល់អ្នកជនៃ ជាតិមោក្ខសំវរសីល រមែងមិនមានដោយប្រការទាំងពួង ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាប ទើបបន្ទឹសីហនាទថា ក្នុងវិរតិ ៣ ក្នុងបហាន: ៥ ក្នុងសំវរៈ ៥ ក្នុងឧទ្ទេស ៥ ក្នុងការលះអកុសល និងក្នុងការសមាទានកុសល តថាគតផង សង្ឃសាវកបស់តថាគតផង តែងប្រាកដក្នុងលោក ។ ពិតណាស់ ឈ្មោះថា សាស្តាដូចតថាគត និងឈ្មោះថាសង្ឃដូចជាសង្ឃសាវកបស់តថាគត មិនមាន ។ កាលព្រះដ៏មានព្រះភាគទ្រង់បន្ទឹសីហនាទយ៉ាងនេះហើយ ទើបត្រាស់ពាក្យជាដើមថា ម្នាលកស្សបមគ្គរមែងមានដើម្បីជ័ងសេចក្តីមិនវិបរិតនៃសីហនាទនោះ ។

មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ

បណ្តាបទទាំងនោះ បទថា **មគ្គោ** *គឺលោកុត្តរមគ្គ ។ បទថា* **បដិបទា**

គឺបដិបទាខាងដើម ។ បទថា **កាលវាទី** *ជាដើម បានពណ៌នាហើយក្នុងព្រហ្មជាលសូត្រ ។ ឥឡូវនេះ កាលនឹងសម្តែងមគ្គ និងបដិបទាទាំងពីរយ៉ាងដូចគ្នា ទើបត្រាស់ពាក្យជាដើមថា* **អយមេវ អរិយោ** *ដូច្នេះ ។*

ឯអចេលក៍ បានស្តាប់ពាក្យនេះហើយ ទើបគិតថា ព្រះសមណគោតមសម្គាល់ថា មគ្គ និងបដិបទា មានដល់តថាគតប៉ុណ្ណោះ មិនមានដល់អ្នកដទៃ ទើបសម្គាល់ថា ណ្ហើយចុះ អញនឹងពោលមគ្គទាំងឡាយរបស់អញដល់ព្រះសមណគោតមនោះ ។ លំដាប់នោះ ទើបពោលដល់បដិបទារបស់អចេលក៍ ។ កាលព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ ទើបអចេលកសាវបក្រាបទូលព្រះដ៏មានព្រះភាគថា អាវុសោគោតម ការផ្តើមនូវតបៈទាំងនេះ ។បេ។ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ ។

[៦៨] *ក្នុងបទទាំងនោះ បទថា* **តចោបក្កមា** *សេចក្តីថា ប្រារព្ធតបៈធ្វើតបៈ ។ បទថា* **សាមញ្ញសង្ខាតា** *គឺពាប់ថា ការងារបស់សមណៈ ។ បទថា* **ព្រហ្មញ្ញសង្ខាតា** *គឺពាប់ថា ការងារបស់ព្រាហ្មណ៍ ។ បទថា* **អចេលកោ** *សេចក្តីថា មិនមានសំពត់ស្បៀកដណ្តប់ អធិប្បាយថា ជាអ្នកអាក្រាត ។ បទថា* **មុត្តាចាគោ** *គឺលះបង់មារយាទ ។ ក្នុងមារយាទទាំងឡាយ មានការបន្ទោបង់ឧច្ចារៈជាដើម គេវៀរចាកមារយាទរបស់កុលបុត្រអ្នកស្រុក ឈរបន្ទោបង់ឧច្ចារបស្សាវៈ ទំពា និងបរិភោគ ។*

ពាក្យថា **ហត្ថាវលេខនោ** *គឺកាលដុំបាយក្នុងដៃអស់ហើយ លិទ្ធដៃដោយអណ្តាត ។ ឬបន្ទោបង់ឧច្ចារៈ ក៏យកដៃជូតគូថជំនួសឈើ ។ គេពោលថា លោកម្ចាស់និមន្តមកទទួលភិក្ខា ក៏មិនមក ដូច្នោះ ទើបឈ្មោះថា* **ន**

ឯហិភទន្តិកោ ។ សូម្បីគេពោលថា លោកម្ចាស់ ចូរឈប់ ក៏មិនឈប់ ដូច្នោះ ទើបឈ្មោះថា **ន តិដ្ឋភទន្តិកោ** ។ បានព្ចថា អចេលក៏គិតថា ពាក្យ របស់បុគ្គលនេះ ក៏ជាការធ្វើហើយ ទើបមិនធ្វើទាំង ២ យ៉ាង ។

បទថា **អភិហតំ** គឺមិនទទួលភិក្ខា ដែលគេបែងចែកមុន ហើយនាំ មក ។ បទថា **ឧទ្ទិស្ស កតំ** គឺមិនទទួលភិក្ខាដែលគេលើកមកប្រគេន ដោយ ពោលយ៉ាងនេះថា (សូមទទួលភិក្ខា) ដែលពួកខ្ញុំធ្វើចំពោះលោកទាំង-ឡាយនេះ ។ បទថា **ន និមន្តំ** គឺមិនត្រេកអរ មិនកាន់យកភិក្ខាដែលគេ និមន្តថា សូមលោកទាំងឡាយ ចូលទៅកាន់ត្រកូល ឬថ្នល់ ឬភូមិឯណោះ ។

ពាក្យថា មិនទទួលអំពីមាត់ឆ្នាំង គឺមិនទទួលយកភិក្ខាដែលគេដួសពី ឆ្នាំងថ្វាយ ។ ពាក្យថា មិនទទួលភិក្ខាអំពីមាត់កញ្ជើ គឺបទថា **កណ្ឌោបិ** បានដល់ កញ្ជើ ឬបំពង់ មិនទទួល (ភិក្ខា) អំពីកញ្ជើ ឬបំពង់នោះ ។ ព្រោះ ហេតុអ្វី ។ ឆ្នាំង និងកញ្ជើអាស្រ័យយើង ទើបត្រូវប្រហារដោយវែក ។

បទថា **ន កុម្ភិមុខា** គឺមិនទទួលយកភិក្ខា ដែលគេដួសអំពីឆ្នាំង ប្រគេន ។ បទថា **ន កលោបិមុខា** គឺពាក្យថា កលោបិ បានដល់ឆ្នាំបាយ ឬកញ្ជើ មិនទទួលភិក្ខា អំពីឆ្នាំបាយ ឬកញ្ជើនោះ ព្រោះហេតុអ្វី ព្រោះ អាចេលក៏គិតថា ឆ្នាំង និងកញ្ជើ អាស្រ័យអញ្ចទើបត្រូវប្រហារដោយវែក ។

បទថា **ន ឯឡកមន្តរំ** គឺមិនទទួលភិក្ខា ដែលគេធ្វើត្រង់ធរណីទ្វារ[1] ឲ្យ នៅក្នុងចន្លោះប្រគល់ឲ្យ ។ ព្រោះហេតុអ្វី ព្រោះអាចេលក៏គិតថា បុគ្គលនេះ

១- ធរណីទ្វារ គឺឈើក្របដែលនៅទទឹងទ្វារ ផ្នែកខាងក្រោម ដែលយើងដើរកន្ទងទៅមក ផ្ទះខ្ទះ គេកាត់ចោល ព្រោះក្រែងជំពប់ជើង ។

អាស្រ័យអញ ទើបបានធ្វើក្នុងចន្លោះ សូម្បីក្នុងកំណាត់ឈើ និងអង្រែក៏មានន័យដូចគ្នា ។

បទថា **ន ទិន្នំ** *គឺក្នុងកាលមនុស្សពីរនាក់កំពុងបរិភោគ កាលម្នាក់ក្រោកទៅឯងឲ្យក៏មិនទទួល ។ ព្រោះហេតុអ្វី ព្រោះអន្តរាយដែលលេបពំនូតបាយរមែងមានដល់ម្នាក់ទៀត ។ ក្នុងបទថា* **ន គព្ភិនិយា** *ជាដើម សេចក្តីថា អាចេលក៏គិតថា ទារកក្នុងផ្ទៃរបស់ស្ត្រីមានគភ៌ រមែងលំបាក កាលស្ត្រីកំពុងឲ្យកូនបៅដោះ អន្តរាយក្នុងការបៅដោះនោះ រមែងមានដល់ទារក អន្តរាយនៃការត្រេកអរ រមែងមានដល់ស្ត្រីដែលនៅជាមួយបុរស ។ បទថា* **សង្ឃិត្តីសុ** *គឺក្នុងកត្តដែលគេត្រៀម ។ បានឮថា ក្នុងកាលមានទុរ្ភិក្ស សាវ័ករបស់អាចេលក៏ប្រមូលអង្ករជាដើមពីទីនោះៗ ដាំបាយដើម្បីប្រយោជន៍ដល់អាចេលក៏ទាំងឡាយ ។ អាចេលក៏អ្នកឧក្រិដ្ឋបំផុត មិនទទួលសូម្បីពីទីនោះ ។*

បទថា **ន យត្ត សា** *គឺក្នុងទីណាមានឆ្កែ ដែលគេចិញ្ចឹម ឆ្កែគិតថា អញនឹងបានដុំបាយ អាចេលក៏មិនទទួលភិក្ខា ដែលម្ចាស់មិនឲ្យដល់ឆ្កែក្នុងទីនោះនាំមក ។ ព្រោះហេតុអ្វី ព្រោះអន្តរាយក្នុងដុំបាយ រមែងមានដល់ឆ្កែនោះ ។ បទថា* **សណ្ឋសណ្ឋចារិនិ** *គឺចោមរោមជាហ្វូងៗ បើពួកមនុស្សឃើញអាចេលក៏ហើយ គិតថា អញនឹងឲ្យភិក្ខាដល់អាចេលក៏នោះ ចូលទៅកាន់រោងបាយ កាលពួកអាចេលក៏ចូលទៅ រុយលាក់ខ្លួននៅត្រង់មាត់ឆ្នាំងបាយជាដើម ហើរព្រោងព្រាតជាហ្វូងៗ ក៏មិនកាន់យកភិក្ខាដែលនាំមកពីទីនោះ ព្រោះហេតុអ្វី ព្រោះអាចេលក៏គិតថា អន្តរាយនៃការត្រាច់រកស៊ីរបស់រុយ កើតព្រោះអាស្រ័យអញ ។*

បទថា **ជុសោឧកំ** *គឺទឹកត្រាំដែលធ្វើដោយស្រូវទាំងពួង ។ ក្នុងទីនេះ ការផឹកស្រា រមែងមានទោស ឯអចេលក៍សម្គាល់ថា មានទោសក្នុងទឹកស្រវឹងទាំងពួង ។ បទថា* **ឯកាគារិកោ** *គឺបានកិក្ខា ក្នុងផ្ទះតែមួយប៉ុណ្ណោះ ក៏ត្រឡប់ ។ បទថា* **ឯកាលោបិកោ** *គឺញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយអាហារតែមួយពំនូត ។ សូម្បីក្នុងការទទួលកត្តក្នុងពីរផ្ទះ ក៏មានន័យដូចគ្នា ។ បទថា* **ឯកិស្សាបិ ឧត្តិយា** *គឺក្នុងថាសមួយ ។*

ដែលឈ្មោះថា **ឧត្តិ** *បានដល់ ថាសតូចៗ មួយប្រភេទដែលសម្រាប់ជាក់ពំនូតកិក្ខា ។ បទថា* **ឯកាហិកំ** *គឺនៅក្នុងចន្លោះមួយថ្ងៃ ។ បទថា* **អឌ្ឍមាសិកំ** *គឺនៅក្នុងចន្លោះកន្លះខែ ។ បទថា* **បរិយាយភត្តភោជនំ** *គឺបរិភោគកត្តតាមវារៈ បានដល់ បរិភោគកត្តដែលមកតាមវារៈនៃថ្ងៃយ៉ាងនេះ គឺតាមវារៈមួយថ្ងៃ តាមវារៈពីរថ្ងៃ តាមវារៈកន្លះខែ ។*

បទថា **សាកភក្ខោ** *គឺមានបន្លែស្រស់ៗ ជាអាហារ ។ បទថា* **សមាកភក្ខោ** *គឺមានបាយអង្ករស្រែងជាអាហារ ។ ក្នុង* **និវារ** *ជាដើម ស្រូវដែលកើតឯងក្នុងព្រៃ ឈ្មោះថា ស្លូយ ។ បទថា* **ឧទ្ទុំ** *គឺចំនៀរស្បែកដែលគេចៀរចោល ដែលជាងសែចោល ។ បទថា* **ហាតំ** *សំដៅដល់ ជ័រខ្លះ សាវយខ្លះ ។ បទថា* **កណំ** *គក់ ។ បទថា* **អាចាមោ** *គឺបាយដែលជាប់ក្នុងបាតឆ្នាំង ។ អចេលក៍កាន់យកបាយក្តាំងទាំងនោះអំពីទីដែលគេចោលមកបរិភោគ ។ ហៅថា បាយចុងអង្ករក៏មាន ។ បទថា* **បុញ្ញាកាឧយោ** *គឺមេរ្យជាដើមច្បាស់លាស់ហើយ ។ បទថា* **បវត្តផលភោជី** *គឺបរិភោគតែ*

ផ្លែឈើ ដែលជ្រុះស្រោប់ ។ បទថា **សាណានិ** គឺសំពត់សំបុកឆ្នែ ។ បទថា **មសាណានិ** គឺសំពត់ដែលត្បាញលាយគ្នា ។ បទថា **ឆវទុស្សានិ** គឺសំពត់ដែលគេទុកចោលអំពីរាងកាយអ្នកស្លាប់ ឬសំពត់ស្មៀកដែលគេត្បាញដោយវៃទឹក និងស្មៅជាដើម ។ បទថា **បំសុកូលានិ** គឺសំពត់ប្រឡាក់ ដែលគេទុកចោលលើដី ។ បទថា **តិរីដានិ** គឺសំពត់សម្បុកឈើ ។ បទថា **អជិនំ** គឺសំពត់ស្បែកខ្លា ។ បទថា **អជិនក្ខិបំ** គឺស្បែកខ្លានោះឯង ត្រូវពុះចំពាក់កណ្តាល (ស្បែកខ្លាទាំងក្រចក) ។ បទថា **កុសចីរំ** គឺសំពត់ដែលគេក្រងដោយស្មៅ ។ សំពត់ត្បាញដោយសម្បុកក្រចៅ និងសំពត់ដែលក្រងពីផ្លែឈើ[1] ជាដើម ក៏នយនេះឯង ។ បទថា **កេសកម្ពលំ** គឺសំពត់កម្ពលដែលធ្វើដោយសក់មនុស្ស ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំពត់ទាំងឡាយណាមួយ ដែលគេត្បាញដោយតម្បាញសំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ច្រោកជាជាអាក្រក់បំផុត ជាង សំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ត្រជាក់ក្នុងពេលត្រជាក់ ក្តៅក្នុងពេលក្តៅ មានតម្លៃថោក មានសម្ផស្សអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់ ។ បទថា **វាលកម្ពលំ** គឺសំពត់កម្ពលដែលត្បាញដោយកន្ទុយសេះ ។ បទថា **ឧលូកបក្ខិកំ** គឺសំពត់ស្មៀកដែលចងស្លាបសត្វមៀមធ្វើ ។ បទថា **ឧក្កុដិកប្បធានមនុយុត្តោ** គឺប្រកបការផ្គងឡើង នូវការអង្គុយច្រហោង សូម្បីដើរទៅក៏នៅច្រហោង ។ បទថា **កណ្ដកបស្សយិកោ** គឺដេកបន្ទាដែក ឬបន្ទាធម្មតាលើផែនដី ក្រាលបន្ទះ

๑- ផលកចីរំ បិដកខ្មែរប្រែថា សំពត់ចម្រៀកក្តារ ។

ស្បែកក្នុងទីនោះ ហើយធ្វើជាទីឈរ និងទីចង្ក្រមជាដើម ។ បទថា **សេយ្យំ** គឺ សូម្បីកាលដេក ក៏ដេកក្នុងទីនោះឯង ។ បទថា **ឆលកសេយ្យំ** គឺទីដេកធ្វើ ដោយបន្ទះឈើ ។ បទថា **តណ្ឌិលសេយ្យំ** គឺទីដេកលើផ្ទៃដីទូលខ្ពស់ៗ ។ បទ ថា **ឯកបស្សយិកោ** គឺដេកដោយការផ្អៀងតែមួយចំហៀងប៉ុណ្ណោះ ។ បទថា **រជោជល្ជធរោ** គឺលាបរាងកាយដោយប្រេង ហើយឈរក្នុងទីដែលមានធូលី ហុយ លំដាប់នោះ ធូលីនឹងជាប់រាងកាយរបស់អចេលក៍នោះ ឲ្យធូលីនោះ គោងជាប់ ។ បទថា **យថាសន្ថតិកោ** គឺមិនញ្ចុំងអាសនៈឲ្យកម្រើក បាន អាសនៈណា ក៏អង្គុយក្នុងអាសនៈនោះជាប្រក្រតី ។ បទថា **វេកដិកោបិ** គឺ បរិភោគលាមកជាប្រក្រតី ។ គូថ គេហៅថា លាមក ។ បទថា **អចាណកោ** គឺមិនផឹកទឹកត្រជាក់ ។ បទថា **សាយ តតិយកំ** គឺវេលាល្ងាចជាលើកទី ៣ ។ អចេលក៍គិតថា អញនឹងបណ្តែតបាបមួយថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាច ទើបប្រកបការខ្ងល់ខ្ងាយ ចុះងូតទឹក ។

[៦៩] លំដាប់នោះ កាលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងសេចក្តីនៃ ការព្យាយាមបំពេញតបៈនោះ វៀរចាកសីលសម្បទាជាដើម ជាការធ្វើដែល ឥតប្រយោជន៍ ទើបត្រាស់ពាក្យជាដើមថា ម្នាលកស្សប បើអចេលក៍ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ឆ្ងាយ** គឺក្នុងទីឆ្ងាយ ។ បទថា **អវេរំ** គឺវៀរចាកពៀរវេរាដែលឲ្យកើតទោស ។ បទថា **អព្យាបជ្ជំ** គឺវៀរចាកការ បៀតបៀនដែលកើតអំពីទោមនស្ស ។

[៧០] បទថា **ឧក្ការំ ភោ គោតម** នេះ កស្សបពោលថា កាលមុន

ពួកខ្ញុំព្រះអង្គយល់ថា ភាពជាសមណៈ និងជាព្រាហ្មណ៍ មានត្រឹមតែប៉ុណ្ណោះ តែព្រះអង្គត្រាស់ភាពជាសមណៈ និងជាព្រាហ្មណ៍ជាយ៉ាងដទៃ ។ បទថា **បកតិ ខោ ឯសោ** *គឺពាក្យនេះ ជាសម្តីប្រក្រតី ។ បទថា* **តមាយ ត្វ កស្សប មត្តាយ** *គឺព្រះមានព្រះភាគត្រាស់ថា ម្នាលកស្សប សាមញ្ញគុណ ឬព្រហ្មញ្ញគុណ ដែលថា កម្រធ្វើបាន រឹតតែធ្វើបានដោយកម្រក្រៃពេក ព្រោះតែសេចក្តីប្រតិបត្តិបន្ទិចបន្តួចនេះ និងការផ្តើមតបៈប៉ុណ្ណោះឯង តែពាក្យដែលពោលថា សាមញ្ញគុណកម្រធ្វើបាន ព្រហ្មញ្ញគុណកម្រធ្វើបាន នុ៎ះមិនគួរទ្បើយ ដូច្នេះ នេះជាអត្ថាធិប្បាយ និងដោយការភ្ជាប់បទក្នុងសេចក្តីនេះ ។ ការភ្ជាប់បទក្នុងទីទាំងពួង គប្បីជ្រាបដោយនយនេះ ។*

[๗๑] *បទថា* **ឧជ្ជាឧោ** *នេះ អចេលកស្សបនោះ ពោលសំដៅយកពាក្យនេះថា កាលមុនពួកខ្ញុំព្រះអង្គយល់ថា ជាសមណៈ ឬជាព្រាហ្មណ៍ ដោយហេតុប៉ុណ្ណោះ តែទ្រង់ត្រាស់ដោយប្រការដទៃ ។*

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បដិសេធពាក្យជំទាស់របស់កស្សបនោះហើយ ទ្រង់បើកបង្ហាញនូវភាពជាអ្នកដឹងបានដោយក្រតាមសភាពពិត ហើយត្រាស់ពាក្យមានជាដើមថា នេះជាសម្តីប្រក្រតីក្នុងលោកទេទៀត ។ គប្បីភ្ជាប់បទ ហើយជ្រាបសេចក្តី ដោយនយដែលបានពោលហើយក្នុងសេចក្តីនោះ ។

សម្បទា ๓ យ៉ាង

[๗๒] *ព្រោះហេតុអ្វី ទើបអចេលកស្សបសួរថា បពិត្រព្រះគោតមដ៏ចម្រើន សីលសម្បទាតើដូចម្តេចជាដើម ។ បានឮថា អចេលកស្សបនេះ*

ជាអ្នកឈ្វាស កាលព្រះដ៏មានព្រះភាគកំពុងត្រាស់ ទើបសិក្សាពាក្យខាងក្រោយ ដឹងការបដិបត្តិរបស់ខ្លួនថា មិនជាប្រយោជន៍ ទើបគិតថា ព្រះសមណគោតមត្រាស់ពាក្យជាដើមថា សីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទានេះ ដែលគេមិនបានអប់រំហើយ មិនបានធ្វើឲ្យច្បាស់ហើយ គេធ្វើយចាកភាពជាសមណៈដោយពិត ដូច្នេះ ណ្ហើយចុះ ឥឡូវនេះ អញនឹងសួរដល់សម្បត្តិទាំងនោះនឹងព្រះដ៏មានព្រះភាគ ទើបទូលសួរដើម្បីដឹងច្បាស់នូវសីលសម្បទាជាដើម ។

លំដាប់នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់សម្តែងការកើតឡើងនៃព្រះពុទ្ធកាលនឹងត្រាស់ដល់បៃបផែន ដើម្បីសម្តែងដល់សម្បទាទាំងនោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលកស្សប តថាគតកើតឡើងក្នុងលោក ដូច្នេះ ។ ពាក្យថា ម្នាលកស្សប សីលសម្បទា ចិត្តសម្បទា និងបញ្ញាសម្បទាឯទៀតដ៏លើសលប់ថ្លៃថ្លាជាងសីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទានេះគ្មានទេ ទ្រង់ត្រាស់សំដៅដល់អរហត្តផល ។ ពិតហើយ សាសនារបស់ព្រះដ៏មានព្រះភាគ មានអរហត្តផលជាទីបំផុត ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា សម្បទាឯទៀតដ៏លើសលប់ថ្លៃថ្លាជាងសីលសម្បទា ចិត្តសម្បទា បញ្ញាសម្បទានេះគ្មានទេ កាលត្រាស់យ៉ាងនេះហើយ ។ ឥឡូវនេះ កាលនឹងទ្រង់បន្ទឺសីហនាទដែលក្រៃលែង ទើបត្រាស់ពាក្យជាដើមថា ម្នាលកស្សប មានសមណព្រាហ្មណ៍ពួកមួយ ។

[๗๓] *ក្នុងបទទាំងនោះ បទថា* **អរិយំ** *គឺប្រាសចាកឧបក្កិលេសបរិសុទ្ធក្រៃលែង ។ បទថា* **បរមំ** *គឺឧត្តម ។ សីលរាប់អំពីសីល ๕ ជាដើម*

រហូតដល់ជាតិមោក្ខសំវរសីល ឈ្មោះថា សីលដូចគ្នា ចំណែកសីលដែលប្រកបដោយលោកុត្តរមគ្គ និងផល ឈ្មោះថា បរមសីល ។ បទថា **ជានាំ តត្ត** *មានអត្ថថា តថាគត មិនឃើញបុគ្គលដែលស្មើ បានដល់បុគ្គលដែលស្មើនឹងតថាគតដោយសីល ដែលស្មើដោយសីលរបស់តថាគតក្នុងសីល ក្នុងបរមសីលនោះ ។ បទថា* **អហាមេវ តត្ត ភិយ្យោ** *គឺតថាគតប៉ុណ្ណោះ ជាអ្នកឧត្តមក្នុងសីលនោះ ។*

សួរថា ត្រាស់ក្នុងទីណា ឆ្លើយថា ក្នុងអធិសីល ។ បទថា **អធិសីលំ** *អធិប្បាយថា អធិសីលនេះ ជាឧត្តមសីល ។ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទឺសីហនាទនេះ ជាគ្រាដំបូង ដូច្នេះ ។*

បទថា **តចោដិគុច្ឆវាចា** *គឺបុគ្គលដែលតិះដៀលតបៈ ។ ក្នុងពាក្យនោះ សេចក្តីព្យាយាមណា រមែងដុត (កិលេស) ដូច្នោះ សេចក្តីព្យាយាមនោះ ឈ្មោះថា* **តប** *នុ៎ះជាឈ្មោះរបស់សេចក្តីព្យាយាមដែលដុតកិលេស ។ តបៈនោះ រមែងខ្ពើមកិលេសទាំងនោះ ហេតុនោះ តបៈនោះ ឈ្មោះថា ការខ្ពើម ។ ក្នុងបទថា* **អរិយោ បរមោ** *នេះ សេចក្តីថា ឈ្មោះថា* **អរិយ** *ព្រោះប្រាសចាកទោស ការខ្ពើមដោយតបៈ ពោល គឺសេចក្តីព្យាយាមដោយវិបស្សនា កើតឡើងដោយអំណាចនៃវត្ថុ មានអារម្មណ៍ ៨ ប្រការ ឈ្មោះថា ការខ្ពើមដោយតបៈនោះឯង ។ បញ្ញាដែលសម្បយុត្តដោយមគ្គ និងផល ឈ្មោះថា* **បរមោ ។** *ការខ្ពើមក្នុងបទនេះថា* **អធិជេគុច្ឆំ** *ជាការខ្ពើម ការខ្ពើមយ៉ាងក្រៃលែង ឈ្មោះថា* **អធិជេគុច្ឆំ** *ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងបទនោះ យ៉ាងនេះថា គឺ* **អធិជេគុច្ឆ** *តថាគតតែមួយអង្គ ជាបុគ្គលក្រៃលែង ក្នុង* **អធិជេគុច្ឆ** *នោះ ។*

ក្នុងបញ្ញាធិការ មានអធិប្បាយដូច្នេះថា កម្មស្សកតាបញ្ញា និងវិបស្សនា-បញ្ញា ឈ្មោះថា **បញ្ញា** ។ បញ្ញាដែលសម្បយុត្តដោយមគ្គ និងផល ឈ្មោះថា **បរមបញ្ញា** ។ ក្នុងបទថា **អធិប្បញ្ញំ** នេះ គប្បីជ្រាបថា ជាលិង្គវិបល្លាស អត្ថក្នុងបទនោះមានយ៉ាងនេះ គឺឈ្មោះថា អធិប្បញ្ញានេះ តថាគតតែមួយអង្គ ជាបុគ្គលក្រៃលែង ក្នុងអធិប្បញ្ញានោះ ។

ក្នុងវិមុត្តាធិការមានអត្ថដូច្នេះថា តទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ឈ្មោះថា **វិមុត្តិ** ។ចំណែកសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ គប្បីជ្រាបថា ជាបរមវិមុត្តិ ។ ក្នុងបទនេះថា **យទិទំ អធិវិមុត្តិ** មានអត្ថថា អធិវិមុត្តិនេះ តថាគតតែមួយអង្គ ជាបុគ្គលក្រៃលែងក្នុងអធិវិមុត្តិនោះ ។

[๗๔] បទថា **សុញ្ញាគារេ** អធិប្បាយថា អង្គុយម្នាក់ឯងក្នុងផ្ទះស្ងាត់ ។ បទថា **បរិសាសុ ច** សេចក្តីថា ក្នុងបរិស័ទ ๘ ។ សមដូចព្រះតម្រាស់ថា ម្នាលសារីបុត្រ វេសារជ្ជញ្ញាណ ๔ នេះ ដែលតថាគតដល់ព្រមហើយ ទើបប្តេជ្ញាអាសភស្ថាន បន្ទឺសីហនាទក្នុងបរិស័ទទាំងឡាយ ដូច្នេះ ។ ព្រះសូត្រគប្បីឲ្យពិស្តារ ។ បទថា **បញ្ហេញ្ច នំ បុច្ឆន្តិ** សេចក្តីថា ទេវតា និងមនុស្សទាំងឡាយដែលជាបណ្ឌិត រួបរួមបញ្ចោហើយ រមែងទូលសួរ ។ បទថា **ព្យាករោតិ** សេចក្តីថា ទ្រង់ឆ្លើយក្នុងខណៈនោះមួយរំពេច ។ បទថា **ចិត្តំ អារាធេតិ** សេចក្តីថា ទ្រង់ញ៉ាំងចិត្តរបស់មហាជនឲ្យឆ្អែត ដោយការដោះស្រាយបញ្ហា ។ បទថា **នោ ច ខោ សោតវ្ហំ មញ្ញន្តិ** សេចក្តីថា កាលទ្រង់ត្រាស់ធ្វើចិត្តឲ្យត្រេកអរ ពួកអ្នកជទៃក៏មិនទាស់ចិត្តក្នុងការស្តាប់ អធិប្បាយថា

គប្បីពោលយ៉ាងនោះ ។ បទថា **សោតព្វញ្ចស្ស មញ្ញន្តិ** *សេចក្តីថា ទេវតាក្តី មនុស្សក្តី រមែងជាក់ចិត្តស្តាប់ដោយឧស្សាហៈធំ ។ បទថា* **បសីទន្តិ** *សេចក្តីថា ជាអ្នកជ្រះថ្លាល្អហើយ មានចិត្តគួរ មានចិត្តទន់ ។ បទថា* **បសន្នាការំ ករោន្តិ** *សេចក្តីថា មិនមែនជាអ្នកល្ងង់ហើយជ្រះថ្លា កាលបរិច្ចាគវត្តុ មានចីវរជាដើម ដែលប្រណីត និងមហាវិហារ មានវេឡុវនវិហារជាដើម ឈ្មោះថា ធ្វើអាការនៃអ្នកជ្រះថ្លា ។ បទថា* **តថត្តាយ** *សេចក្តីថា ព្រះមានព្រះភាគនោះ ទ្រង់សម្តែងធម៌ណា រមែងបដិបត្តិដើម្បីការមាននៃធម៌ដោយប្រការនោះ គឺដើម្បីប្រយោជន៍ដល់បដិបត្តិធម៌ សមគួរដល់ធម៌ ។ បទថា* **តថត្តាយ ច បដិបជ្ជន្តិ** *សេចក្តីថា រមែងបដិបត្តិដើម្បីការមានយ៉ាងនោះ ។ ពិតហើយ ទេវតា និងមនុស្សស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគអង្គនោះហើយ ពួកខ្លះតាំងនៅក្នុងសរណៈ ពួកខ្លះ តាំងនៅក្នុងសីល ៥ ពួកខ្លះ ចេញបួស ។ បទថា* **បដិបន្នា ច អារាធេន្តិ** *សេចក្តីថា អ្នកបដិបត្តិបដិបទានោះ រមែងអាចឲ្យបរិបូណ៌ តែឲ្យបរិបូណ៌ដោយអាការទាំងពួង គប្បីពោលថា រមែងញុំងចិត្តរបស់ព្រះគោតមដ៏ចម្រើននោះឲ្យត្រេកអរ ដោយការបំពេញបដិបត្តិ ។ ក៏បណ្ឌិតតាំងនៅក្នុងឱកាសនេះហើយ គប្បីប្រមូលសីហនាទទាំងឡាយ ។*

សីហនាទមួយរបស់ព្រះមានព្រះភាគថា តថាគត បានចក្ខុទិព្វដ៏បរិសុទ្ធកន្ធវិស័យរបស់មនុស្ស មើលឃើញបុគ្គលអ្នកកាន់តបៈ ដែលមានអាជីវៈសៅហ្មងពួកខ្លះក្នុងលោកនេះ ដែលរំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងនរក ។ សីហនាទមួយថា តថាគត មានចក្ខុទិព្វដ៏បរិសុទ្ធកន្ធវិស័យរបស់មនុស្ស តថាគតមើលឃើញបុគ្គលអ្នកកាន់តបៈពួកខ្លះក្នុងលោក

នេះ ជាអ្នកចញ្ចឹមជីវិតសៅហ្មង ដែលរំលាងខន្ធ ខាងមុខអំពីសេចក្តី ស្ងាប់ ទៅកាន់ស្ថានសួគ៌ ។ សីហនាទមួយថា តថាគតតែម្នាក់ ជាអ្នកប្រសើរបំផុត ក្នុងការលះអកុសលធម៌ ។ សីហនាទមួយថា តថាគតតែម្នាក់ ជាអ្នកប្រសើរ ទីបំផុត សូម្បីក្នុងការសមាទានកុសលធម៌ ។ សីហនាទមួយថា សង្ឃសាវ័ក របស់តថាគតប៉ុណ្ណោះ ជាអ្នកប្រសើរបំផុត ក្នុងការលះអកុសលធម៌ ។ សីហនាទមួយថា សង្ឃសាវ័កតថាគតប៉ុណ្ណោះ ជាអ្នកប្រសើរបំផុត ក្នុងការ សមាទានកុសលធម៌ ។ សីហនាទមួយថា មិនមានអ្នកណាដូចតថាគតដោយ សីល ។ សីហនាទមួយថា មិនមានអ្នកណាដូចតថាគត ដោយវីរិយៈ ។ សីហនាទមួយថា មិនមានអ្នកណាដូចតថាគត ដោយបញ្ញា ។ សីហនាទ មួយថា មិនមានអ្នកណាដូចតថាគត ដោយវិមុត្តិ ។ សីហនាទមួយថា តថាគតបន្ទឺសីហនាទ ក៏អង្គុយត្រង់កណ្តាលបរិស័ទបន្ទឺ ។ សីហនាទមួយថា តថាគតជាអ្នកអង់អាចក្នុងការបន្ទឺ ។ សីហនាទមួយថា ទេវតា និងមនុស្ស រមែងសួរបញ្ហាចំពោះតថាគត ។ សីហនាទមួយថា តថាគតនឹងដោះស្រាយ បញ្ហា ។ សីហនាទមួយថា តថាគតនឹងញុំាងចិត្តរបស់អ្នកដទៃឲ្យត្រេកអរ ដោយការដោះស្រាយ ។ សីហនាទមួយថា ស្តាប់ហើយ រមែងពេញចិត្ត នឹងស្តាប់ ។ សីហនាទមួយថា ស្តាប់ហើយ រមែងជ្រះថ្លាក្នុងតថាគត ។ សីហនាទមួយថា ជ្រះថ្លាហើយ រមែងធ្វើអាការរបស់អ្នកជ្រះថ្លា ។ សីហនាទ មួយថា តថាគតសម្តែងរបដិបត្តិណា ទេវតា និងមនុស្ស រមែងបដិបត្តិ ដើម្បីសភាពជាយ៉ាងនោះ ។ សីហនាទមួយថា នឹងរមែងឲ្យតថាគតត្រេកអរ ដោយបដិបត្តិ ។ សីហនាទទាំង៤យ៉ាយជាដើមថា បន្ទឺក្នុងបរិស័ទទាំង៤យ៉ាយ

នៃបរិស័ទមុនតែមួយយ៉ាងៗ ១០ ជាដើម រួមជាបរិវារតែមួយយ៉ាងៗ ១០ ដោយប្រការដូច្នេះ ។ សីហនាទមានមួយរយ គឺសីហនាទទាំង ១០ នោះរួមជា ១០០ ដោយអំណាចនៃបរិវារបស់សីហនាទ ១០ និងសីហនាទ ១០ មុន ។ ក្នុងព្រះសូត្រដទៃអំពីព្រះសូត្រនេះ សីហនាទមានប្រមាណត្រឹមប៉ុណ្ណេះ រកបានដោយកម្រ ព្រោះហេតុនោះ ទើបសូត្រនេះឈ្មោះថា មហាសីហនាទសូត្រ ។

ព្រះដ៏មានព្រះភាគ ទ្រង់បដិសេធវាទៈ និងអនុវាទៈ យ៉ាងនេះថា ព្រះសមណគោតម រមែងបន្ទឺសីហនាទ តែបន្ទឺក្នុងផ្ទះស្ងាត់ ឥឡូវនេះ កាលទ្រង់បន្ទឺសីហនាទ ដែលធ្លាប់បន្ទឺហើយក្នុងបរិស័ទទៀត ទើបត្រាស់ពាក្យមានជាដើមថា **ឯកមិទាហំ** *ដោយប្រការដូច្នេះ ។*

ក្នុងបទទាំងនោះ បទថា **តត្រ មំ អញ្ញតរោ តេ សព្រហ្មចារី** *សេចក្តីថា ដើម្បីព្រហ្មចារីរបស់បរិព្វាជកម្នាក់ ឈ្មោះនិគ្រោធបរិព្វាជក (បានសួរបញ្ហា) ចំពោះតថាគតនៅត្រង់ភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះនោះ ។ បទថា* **អធិដេគុច្ឆេ** *សេចក្តីថា សួរបញ្ហាក្នុងរឿងខ្ពើមបាប ដោយវិរិយៈ ។ ព្រះមានព្រះភាគប្រថាប់គង់ក្នុងមហាវិហារក្បែរភ្នំគិជ្ឈកូដ ទ្រង់ស្តាប់ពាក្យសន្ទនារបស់និគ្រោធបរិព្វាជក និងសន្ធានឧបាសក ដែលអង្គុយក្នុងឧទ្យានរបស់ព្រះនាងឧទុម្ពរិ-កាទេវី ដោយទិព្វសោតធាតុ ទ្រង់ក៏ពុទ្ធដំណើរតាមអាកាសមកប្រថាប់គង់លើអាសនៈ ដែលបានក្រាលក្នុងសម្នាក់របស់អ្នកទាំងពីរនោះ ហើយទ្រង់បានដោះស្រាយបញ្ហា ដែលនិគ្រោធបរិព្វាជកទូលសួរក្នុងរឿងខ្ពើមយ៉ាងក្រៃលែងនេះឯណា លោកពោលសំដៅដល់បញ្ហានោះ ។ បទថា* **បរំ វិយ មត្តាយ** *សេចក្តីថា ដោយប្រមាណយ៉ាងក្រៃលែង គឺដោយប្រមាណធំ ។*

[៧៥] បទថា **ភោ ហិ ភន្តេ** សេចក្តីថា អ្នកដទៃដែលមានជាតិ បណ្ឌិត រៀរអន្ធពាលអ្នកមានទិដ្ឋិណាហ្នឹ ដែលស្តាប់ព្រះធម៌របស់ព្រះមានព្រះភាគហើយ ពោលថា មិនគប្បីត្រេកអរ ។ អចេលកស្សបគិតថា អញប្រកបខ្ជូនក្នុងចំណែកដែលមិននាំចេញចាកទុក្ខ បានទទួលសេចក្តីលំបាកអស់កាលយូរហ្នឹ អញងូតទឹកក្នុងត្រើយទន្ទេរីងស្ជូត អញដូចប្រមៀលត្រឡប់ទៅត្រឡប់មក ដូចរោយអង្ការ ក៏មិនញ្ចុាំងប្រយោជន៍អ្វីឲ្យសម្រេចបាន ណ្ហើយចុះ អញនឹងប្រកបខ្ជូនក្នុងសេចក្តីព្យាយាម ទើបទូលថា ខ្ញុំព្រះអង្គគួរបាន ... ដូច្នេះ ។

មួយទៀត តិរ្ថិយបរិវាសណា ដែលព្រះអង្គទ្រង់បញ្ញត្តិទុកក្នុងខន្ធកៈ ដែលធ្លាប់ជាអន្យតិរ្ថិយតាំងនៅក្នុងសាមណេរភូមិ នឹងត្រូវសមាទាន នៅបរិវាស ដោយន័យជាដើមថា បពិត្រលោកដ៏ចម្រើន ខ្ញុំធ្លាប់ជាអន្យតិរ្ថិយឈ្មោះនេះ ប្រាថ្នាឧបសម្បទក្នុងព្រះធម៌វិន័យនេះ ខ្ញុំនោះ សូមសង្ឃនៅបរិវាសរហូតដល់អស់បួនខែ ដូច្នេះ ព្រះដ៏មានព្រះភាគទ្រង់សំដៅដល់តិរ្ថិយ-បរិវាសនោះ ទើបត្រាស់ថា ម្នាលកស្សប បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយមកហើយ ដូច្នេះជាដើម ។

[៧៦] ក្នុងបទទាំងនោះ បទថា **បព្វជ្ជំ** លោកពោលដោយអំណាចការពីរោះរណ្តំនៃវចនៈប៉ុណ្ណោះ ។ ព្រោះមិននៅបរិវាស រមែងបានបព្វជ្ជា ។ តែអ្នកត្រូវការឧបសម្បទាគប្បីនៅបរិវាស បំពេញវត្ត ៨ ប្រការថា ចូលស្រុកតាមកាលវេលាជាដើម ។

បទថា **អារទ្ធចិត្តា** សេចក្តីថា មានចិត្តត្រេកអរដោយការបំពេញវត្ត ៨ ។

សេចក្តីសង្ខេបក្នុងបទនោះ ដូច្នេះ ។ ចំណែកតិរិយបរិវាសនោះ គប្បីពោលឲ្យពិស្តារ ដោយនយដែលពោលទុកក្នុងបព្វជ្ជាខន្ធកវណ្ណនា ក្នុងវិនយដ្ឋកថា ឈ្មោះសមន្តបាសាទិកានោះចុះ ។

បទថា **អបិ ច មេត្ត** *សេចក្តីថា តែតថាគតជីង (ការផ្សេងគ្នានៃបុគ្គល) ក្នុងសេចក្តីនេះ ។ បទថា* **បុគ្គលវេមត្តតា វិនិតា** *សេចក្តីថា តថាគតជីងសេចក្តីផ្សេងគ្នានៃបុគ្គល ។ ព្រះដ៏មានព្រះភាគទ្រង់ជីងថា បុគ្គលនេះគួរនៅបរិវាស នេះមិនគួរនៅបរិវាស ទើបទ្រង់សម្តែងថា ប្រការនេះជ្រាកដដល់តថាគត ។ លំដាប់នោះ កស្សបគិតថា ឱហ្ន៎ ព្រះពុទ្ធសាសនាជារបស់អស្ចារ្យ ដែលបុគ្គលទាំងឡាយប្រកាសហើយ សម្តែងចេញហើយយ៉ាងនេះ រមែងកាន់យកវត្តុដែលគួរប៉ុណ្ណោះ លះចោលវត្តុដែលមិនគួរ មានសេចក្តីឧស្សាហ៍កើតឡើងព្រមក្នុងបព្វជ្ជាដ៏ក្រៃលែងជាងនោះ ទើបទូលថា* **សចេ ភន្តេ** *ដូច្នេះជាដើម ។*

លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ជីងសេចក្តីដែលកស្សបនោះជាអ្នកមានឆន្ទៈខ្លាំងក្លាថា កស្សបមិនគួរនៅបរិវាស ទើបត្រាស់ហៅភិក្ខុជនៃមកថា ម្នាលភិក្ខុ អ្នកចូរនាំកស្សបនោះទៅឯតទីក ហើយឲ្យបព្វជ្ជានាំមក ។ ភិក្ខុនោះ បានធ្វើតាមព្រះតម្រាស់យ៉ាងនោះ ឲ្យកស្សបបួសហើយ នាំគ្នាទៅកាន់សម្នាក់របស់ព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យកស្សបនោះអង្គុយត្រង់កណ្តាលគណៈ ហើយទ្រង់ឲ្យឧបសម្បទា ដោយហេតុនោះ ទើបលោកពោលថា អចេលកស្សបក៏បានបព្វជ្ជា បានឧបសម្បទាក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ បទថា **អចិរូបសម្បន្នោ** *សេចក្តីថា ជាអ្នកឧបសម្បទា*

សម្បទា ហើយមិនយូរ ។ បទថា **វូបកដ្ឋោ** *សេចក្តីថា ជាអ្នកមានកាយនិងចិត្តស្ងប់ចាកវត្ថុកាម និងកិលេសកាមទាំងឡាយ ។ បទថា* **អប្បមត្តោ** *សេចក្តីថា មិនលះបង់សតិក្នុងកម្មដ្ឋាន ។ បទថា* **អាតាបិ** *សេចក្តីថា មានការដុតដោយវីរិយៈពោល គឺសេចក្តីព្យាយាមតាមផ្លូវកាយ និងចិត្ត ។*

បទថា **បហិតត្តោ** *សេចក្តីថា មានចិត្តបញ្ជូនហើយ គឺមានអត្តភាពលះបង់ហើយ ព្រោះភាពជាអ្នកមិនមានសេចក្តីជាប់ជំពាក់ក្នុងកាយ និងជីវិត ។ បទថា* **យស្សត្តាយ** *សេចក្តីថា ដើម្បីផលឯណា ។បទថា* **កុលបុត្តា** *បានដល់កុលបុត្រអ្នកមានមារយាទ ។ បទថា* **សទ្ធាយ** *សេចក្តីថា ដោយហេតុនោះឯង ដោយការណ៍នោះឯង ។ បទថា* **តទត្ថំ** *សេចក្តីថា ប្រយោជន៍ដ៏ប្រសើរនោះ ។ បទថា* **ព្រហ្មចរិយបរិយោសានំ** *សេចក្តីថា អរហត្តផលដែលជាទីបំផុតដោយជុំវិញនៃមគ្គព្រហ្មចរិយៈ ។ កុលបុត្រទាំងឡាយ តែងបួសដើម្បីផលនោះ ។ បទថា* **ឥដ្ឋេវ ធម្មេ** *សេចក្តីថា ក្នុងអត្តភាពនេះឯង ។*

បទថា **សយំ អភិញ្ញា សច្ឆិកត្វា** *សេចក្តីថា ធ្វើឲ្យប្រចក្សដោយបញ្ញាខ្លួនឯង គឺដឹងដោយមិនមានអ្នកដទៃជាបច្ច័យ ។ បទថា* **ឧបសម្បជ្ជ វិហរតិ** *សេចក្តីថា សម្រេចហើយ ឲ្យដល់ព្រមហើយ ។ ព្រះដ៏មានព្រះភាគកាលទ្រង់សម្តែងភូមិនៃបច្ចវេក្ខណៈរបស់កស្សបនោះ យ៉ាងនេះថា កិក្ខុកាលរស់នៅយ៉ាងនេះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ ។បេ។ ញុំាងទេសនាឲ្យចប់ស្រេចដោយធម៌ដ៏ប្រសើរ គឺអរហត្ត ទើបត្រាស់ថា បណ្តាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ដូច្នេះ ។ ក្នុង*

បទទាំងនោះ បទថា **អញ្ញតរោ** *សេចក្តីថា មួយអង្គ ។ បទថា* **អរហតំ** *សេចក្តីថា នៃព្រះអរហន្តទាំងឡាយ ។ ក្នុងបទនោះ មានអធិប្បាយយ៉ាងនេះថា ជាព្រះអរហន្តមួយអង្គ ក្នុងចំណោមព្រះអរហន្តសាវ័ករបស់ព្រះមានព្រះភាគ ។ បទណាមួយ មិនបានពោលទុកតាមលំដាប់បទនោះៗ ប្រាកដហើយ ព្រោះបានពោលហើយក្នុងទីនោះៗ ដូច្នេះឯង ។*

មហាសីហនាទសូត្រវណ្ណនា ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ហើយ ដោយប្រការដូច្នេះ ៗ

មហាសីហនាទសូត្រ ចប់

សូត្រតី ៨ ចប់

សុត្តន្តបិដក

ចោជ្ឈាឧសូត្រទី ៩

[៧៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង មានបរិព្វាជកម្នាក់ ឈ្មោះចោជ្ឈបាទ នៅអាស្រ័យក្នុង មល្លិ-កាវាម ដែលមានសាលាមួយ មានជួរនៃដើមទន្ទាប់ព័ទ្ធជុំវិញ ជាទី (សម្រាប់ពួកជនមានព្រាហ្មណ៍ជាដើម) ប្រជុំគ្នាជជែកអំពីលទ្ធិ (របស់ខ្លួន) ជាមួយនឹងបរិព្វាជកបរិសទ្យជាច្រើន ចំនួន ៣០០០ នាក់ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធ-ដំណើរចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា ការគ្រាប់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី នៅព្រឹកពេក ណាស់ បើដូច្នោះ គួរតែតថាគតចូលទៅរកចោជ្ឈបាទបរិព្វាជក នៅក្នុងមល្លិ-កាវាម ដែលមានសាលាមួយ មានជួរនៃដើមទន្ទាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រជុំគ្នាជជែកអំពីលទ្ធិ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរ ចូលទៅឯមល្លិកាវាម ដែលមានសាលាមួយ មានជួរនៃដើមទន្ទាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រជុំគ្នាជជែកអំពីលទ្ធិ ។

[៧៨] សម័យនោះឯង ចោជ្ឈបាទបរិព្វាជក អង្គុយជាមួយនឹងបរិព្វាជកបរិសទ្យច្រើននាក់ កំពុងតែនិយាយពាក្យតិរច្ឆានកថាច្រើនយ៉ាង ដោយសំឡេងហ៊ោ សំឡេងញ្ជ្រាំងកងរំពង គឺនិយាយអំពីស្តេច និយាយអំពីចោរ

និយាយអំពីមហាមាត្យ និយាយអំពីសេនា និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីគ្រឿងសុី និយាយអំពីគ្រឿងផឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្រី និយាយអំពីប្រុស និយាយអំពីយោធាដែលកៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីបុព្វប្រេត គឺញាតិដែលចែកឋានទៅហើយ និយាយអំពីពាក្យឥតប្រយោជន៍មានប្រការផ្សេងៗ និយាយអំពីលោក (មានរឿងក្អែកស និងកុកក្រហមជាដើម) និយាយអំពីរឿងជីកសមុទ្រ និយាយអំពីសេចក្តីចម្រើន និងសេចក្តីសាបសូន្យជួច្នេះៗ ។ ពោជ្ឈបាទបរិព្វាជក បានឃើញព្រះមានព្រះភាគកំពុងស្តេចមកអំពីចម្ងាយ លឺមៗ លុះឃើញហើយក៏បញ្ឈប់បរិសទ្យរបស់ខ្លួនថា ម្នាលគ្នាយើង ចូរនិយាយសំឡេងតិចៗ ម្នាលគ្នាយើង កុំនិយាយសំឡេងឮខ្លាំងឡើយ (ដ្បិត) ព្រះសមណគោតមអង្គនេះស្តេចមក ឯព្រះសមណគោតមមានអាយុនោះឯង លោកពេញព្រះទ័យនឹងសំឡេងតិច តែងពោលសរសើរសំឡេងតិច ធ្វើដូចម្តេច ឲ្យលោកជ្រាបថា បរិសទ្យនិយាយសំឡេងតិច ហើយសម្គាល់ថា គួរនឹងចូលមកបាន ។ កាលពោជ្ឈបាទបរិព្វាជក និយាយយ៉ាត់យ៉ាងនេះហើយ បរិព្វាជកទាំងនោះក៏នាំគ្នាស្ងៀម ។

[๗๙] *លំដាប់នោះឯងព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចូលសំដៅទៅរកកន្លែងដែលពោជ្ឈបាទបរិព្វាជកនៅ ។ ពោជ្ឈបាទបរិព្វាជក ក៏បានក្រាប*

บัดนี้ขอทูลถามพระผู้มีพระภาคเจ้าอย่างนี้ว่า ข้าแต่พระองค์ผู้เจริญ ขอพระผู้มีพระภาคเจ้าจงเสด็จมา ข้าแต่พระองค์ผู้เจริญ ขณะที่พระผู้มีพระภาคเจ้าเสด็จมาดีแล้ว ข้าแต่พระองค์ผู้เจริญ ก็นานแล้วหนอ ที่พระผู้มีพระภาคเจ้าได้ทรงกระทำปริยายนี้ เพื่อจะมาในที่นี้ ข้าแต่พระองค์ผู้เจริญ ขอพระผู้มีพระภาคเจ้าจงทรงรับนิมนต์ด้วยอาสนะที่จัดไว้นี้ ฯ พระผู้มีพระภาคเจ้าได้ทรงรับนิมนต์ด้วยอาสนะที่เขาจัดไว้แล้ว ฯ ลำดับนั้น โปฏฐปาทปริพาชก ได้นั่งบนอาสนะต่ำกว่าพระผู้มีพระภาคเจ้าบ้าง ได้นั่งในที่สมควรบ้าง ฯ ครั้นโปฏฐปาทปริพาชกนั่งในที่สมควรแล้ว พระผู้มีพระภาคเจ้าได้ตรัสถามว่า ดูกรโปฏฐปาทะ ก่อนนี้ในขณะที่เธอทั้งหลายประชุมกันนั่งสนทนากันในโรงกลางนี้ ได้สนทนากันด้วยเรื่องอะไร และเรื่องอะไรที่เธอทั้งหลายสนทนากันค้างไว้ ฯ

[๘๐] *ครั้นพระผู้มีพระภาคเจ้าตรัสถามอย่างนี้แล้ว โปฏฐปาทปริพาชกได้กราบทูลพระผู้มีพระภาคเจ้าว่า ข้าแต่พระองค์ผู้เจริญ ก่อนนี้ในขณะที่ข้าพระองค์ทั้งหลายประชุมกันนั่งสนทนากันในโรงกลางนี้ ได้สนทนากันด้วยเรื่องนี้ ข้าแต่พระองค์ผู้เจริญ ก็เรื่องที่ข้าพระองค์ทั้งหลายสนทนากันค้างไว้ ขอพระผู้มีพระภาคเจ้าจงทรงสดับเถิด ข้าแต่พระองค์ผู้เจริญ ก็เรื่องที่ข้าพระองค์ทั้งหลายสนทนากันค้างไว้ ได้ยินว่าพวกสมณพราหมณ์ที่มีลัทธิต่างๆ กัน ได้นั่งประชุมกันในโรงกลางนี้ ได้เกิดการสนทนากันขึ้นในระหว่างว่า ผู้ปฏิบัติดีเพื่อความเป็นผู้มีสัญญาเป็นที่ดับ ผู้ปฏิบัติดีเพื่อความเป็นผู้มีสัญญาเป็นที่ดับ ดังนี้ ข้าแต่พระองค์ผู้เจริญ ก็ในเรื่องนี้ ผู้ปฏิบัติดีเพื่อความเป็นผู้มีสัญญาเป็นที่ดับ ผู้ปฏิบัติดีเพื่อความเป็นผู้มีสัญญาเป็นที่ดับ ดังนี้ ข้อนี้เป็นอย่างไรหนอ*

សមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ខ្លះពោលយ៉ាងនេះថា សញ្ញា របស់បុរសកើតក្តី រលត់ក្តី មិនមានហេតុ មិនមានបច្ច័យឡើយ សញ្ញាកើត ឡើងក្នុងសម័យណា សត្វក៏មានសញ្ញាក្នុងសម័យនោះ សញ្ញារលត់ទៅក្នុង សម័យណា សត្វក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួក មួយក្នុងលោកនេះ បានបញ្ញត្តអភិសញ្ញានិរោធដោយប្រការយ៉ាងនេះ តែ សមណព្រាហ្មណ៍ដទៃក្រៅអំពីនោះ ពោលយ៉ាងនេះថា អ្នកទាំងឡាយដ៏ ចម្រើន ដំណើរនុ៎ះ មិនមែនជាយ៉ាងនេះទេ នែអ្នកទាំងឡាយដ៏ចម្រើន ព្រោះ ថា សញ្ញាជាខ្លួនរបស់បុរស ឯខ្លួននោះមាននៅខ្លះ ច្រាសទៅខ្លះ ខ្លួនមាននៅ ក្នុងសម័យណា សត្វក៏មានសញ្ញាក្នុងសម័យនោះ ខ្លួនច្រាសទៅក្នុងសម័យ ណា សត្វក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួកមួយក្នុង លោកនេះ បញ្ញត្តអភិសញ្ញានិរោធដោយប្រការយ៉ាងនេះ សមណព្រាហ្មណ៍ ដទៃក្រៅអំពីនោះពោលយ៉ាងនេះថា អ្នកទាំងឡាយដ៏ចម្រើន ដំណើរនុ៎ះ មិន មែនយ៉ាងនេះទេ អ្នកទាំងឡាយដ៏ចម្រើន ព្រោះថា សមណព្រាហ្មណ៍ មាន ឫទ្ធិច្រើន មានអានុភាពច្រើនក៏មាន សមណព្រាហ្មណ៍ទាំងនោះឯង ទាញ ចូលខ្លះ ដកចេញខ្លះ នូវសញ្ញារបស់បុរសនេះ ទាញសញ្ញាចូលក្នុងសម័យ ណា សត្វក៏មានសញ្ញាក្នុងសម័យនោះ ដកសញ្ញាចេញក្នុងសម័យណា សត្វ ក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួកមួយក្នុងលោកនេះ បញ្ញត្តអភិសញ្ញានិរោធ ដោយប្រការយ៉ាងនេះ សមណព្រាហ្មណ៍ដទៃក្រៅ អំពីនោះ ពោលយ៉ាងនេះថា អ្នកទាំងឡាយដ៏ចម្រើន ដំណើរនុ៎ះ មិនមែន

យ៉ាងនេះទេ អ្នកទាំងឡាយដ៏ចម្រើន ព្រោះថា ពួកទេវតាមានឫទ្ធិច្រើន មានអានុភាពច្រើនក៏មាន ទេវតាទាំងនោះ ទាញចូលខ្លះ ជកចេញខ្លះ នូវសញ្ញារបស់បុរសនេះ ទាញសញ្ញាចូលក្នុងសម័យណា សត្វក៏មានសញ្ញាក្នុងសម័យនោះ ជកសញ្ញាចេញក្នុងសម័យណា សត្វក៏មិនមានសញ្ញាក្នុងសម័យនោះ សមណព្រាហ្មណ៍ពួកមួយក្នុងលោកនេះ បញ្ញត្តអកិសញ្ញានិរោធដោយប្រការយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានចាប់ភ្ជាប់នឹកប្រារព្ធចំពោះព្រះមានព្រះភាគតែមួយយ៉ាងថា ព្រះមានព្រះភាគណា ទ្រង់ឈ្វាសវៃក្នុងធម៌ទាំងនេះ ព្រះមានព្រះភាគអង្គនោះ គប្បីសម្តែងបានដោយអស្ចារ្យក្រៃលែង ព្រះសុគតណា ទ្រង់ឈ្វាសវៃក្នុងធម៌ទាំងនោះ ព្រះសុគតអង្គនោះ គប្បីសម្តែងបាន ដោយអស្ចារ្យក្រៃលែង បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ព្រះអង្គឈ្វាសវៃ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវអកិសញ្ញានិរោធ បពិត្រព្រះអង្គដ៏ចម្រើន អកិសញ្ញានិរោធនោះ តើដូចម្តេច ។

[៨១] *ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលដោជ្ឈបាទ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ដែលពោលយ៉ាងនេះថា សញ្ញារបស់បុរសកើតក្តី រលត់ក្តី មិនមានហេតុ មិនមានបច្ចយដូច្នេះ សេចក្តីយល់ឃើញរបស់សមណព្រាហ្មណ៍ទាំងនោះ ចាត់ជាខុសតាំងអំពីដើមទាំងស្រុង ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលដោជ្ឈបាទ ព្រោះថា សញ្ញារបស់បុរសប្រកបដោយហេតុ ប្រកបដោយបច្ចយ ទាំងកើត ទាំងរលត់ សញ្ញាខ្លះ កើតព្រោះការហាត់ក៏មាន សញ្ញាខ្លះរលត់ទៅព្រោះការហាត់ក៏មាន*

ก็ការហាត់សញ្ញានោះ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ឆ្លើយដោយព្រះអង្គឯងថា ម្នាលចុដ្ឋបាទ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោកនេះ ។បេ។ (បណ្ឌិតគប្បីសម្តែងឲ្យពិស្តារ ដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ ម្នាលចុដ្ឋបាទ ភិក្ខុអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។បេ។ កាលភិក្ខុនោះ ពិចារណាឃើញនូវនីវរណៈទាំង ៥ នេះ ក្នុងខ្លួនដែលលះបង់បានហើយ ជាមោជ្ជ គឺសេចក្តីរីករាយក៏កើតឡើង កាលបើភិក្ខុមានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ ភិក្ខុដែលមានកាយស្ងប់រម្ងាប់ហើយ ក៏ទទួលនូវសុខ ចិត្តរបស់ភិក្ខុដែលមានសុខក៏តាំងនៅមាំ ។ ភិក្ខុនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយក៏បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខកើតអំពីសេចក្តីស្ងាត់នោះ កាមសញ្ញា (តម្រេកប្រកបដោយកាមគុណទាំង ៥) ខាងដើមរបស់ភិក្ខុនោះក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិត ពោល គឺបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់ ក៏មានឡើងក្នុងសម័យនោះ ភិក្ខុនោះ ឈ្មោះថា មានសច្ចសញ្ញាដ៏ល្អិត ពោល គឺបីតិ និងសុខដែលកើតអំពីវិវេកក្នុងសម័យនោះឯង សញ្ញាខ្ទះ កើតព្រោះការហាត់ សញ្ញាខ្ទះ រលត់ទៅព្រោះការហាត់ (ដូចពណ៌នាមកនេះ) នេះឯង ដែលហៅថា ការហាត់សញ្ញា ។

[๘๒] *ម្នាលចុដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះរម្ងាប់វិតក្ក វិចារៈចេញបាន ភិក្ខុក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាន*

នៃខ្លួន មានសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្ក គ្មានវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន សច្ចៈ-សញ្ញាដ៏ល្អិត ពោល គឺបីតិ និងសុខដែលកើតអំពីសេចក្តីស្ងាត់ ជាខាងដើមរបស់កិក្ខុនោះក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិត ពោល គឺបីតិ និងសុខដែលកើតអំពីសមាធិ ក៏មានក្នុងសម័យនោះឡើង កិក្ខុនោះ ឈ្មោះថា មានសច្ចៈ-សញ្ញាដ៏ល្អិត ពោល គឺបីតិ និងសុខដែលកើតអំពីសមាធិ ក្នុងសម័យនោះឯង សញ្ញាខ្លះ កើតព្រោះការហាត់ សញ្ញាខ្លះ រលត់ទៅព្រោះការហាត់ដូចពណ៌នាមកនេះ នេះឯងដែលហៅថា ការហាត់ ។

[๘๓] ម្នាលចេដ្ឋជាត សេចក្តីផ្សេងទៀតថា ព្រោះនឿយណាយចាកបីតិប្រកបដោយឧបេក្ខា កិក្ខុមានសតិ និងសម្បជញ្ញៈ រមែងទទួលនូវសេចក្តីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលអ្នកបានតតិយជ្ឈាននោះ ថាជាអ្នកប្រកបដោយឧបេក្ខា មានស្មារតី មានប្រក្រតីនៅជាសុខ ក៏បានដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ๔ សច្ចសញ្ញាដ៏ល្អិត ពោល គឺបីតិសុខដ៏កើតអំពីសមាធិជាខាងដើមរបស់កិក្ខុនោះក៏រលត់ទៅ សច្ចសញ្ញាដ៏ល្អិត ពោល គឺឧបេក្ខា និងសុខ ក៏មានក្នុងសម័យនោះ កិក្ខុនោះ ឈ្មោះថា មានសច្ចសញ្ញាដ៏ល្អិត ពោល គឺឧបេក្ខា និងសុខ ក្នុងសម័យនោះឯង សញ្ញាខ្លះកើតព្រោះការហាត់ សញ្ញាខ្លះរលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯង ដែលហៅថា ការហាត់សញ្ញា ។

[៨៤] *ម្នាលចុដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះលះបង់នូវសុខ និងទុក្ខហើយ ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុន ភិក្ខុក៏បានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខមិនមែនជាសុខ គឺឧបេក្ខាមានសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ សចេ្ចសញ្ញាដ៏ល្អិត ពោល គឺឧបេក្ខា និងសុខជាខាងដើមរបស់ភិក្ខុនោះ ក៏រលត់ទៅ សចេ្ចសញ្ញាដ៏ល្អិតដែលឥតទុក្ខឥតសុខ ក៏មានក្នុងសម័យនោះ ភិក្ខុនោះ ឈ្មោះថា មានសចេ្ចសញ្ញាដ៏ល្អិត ឥតទុក្ខឥតសុខក្នុងសម័យនោះ សញ្ញាខ្លះកើតឡើងព្រោះការហាត់ សញ្ញាខ្លះរលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯង ដែលហៅថា ការហាត់សញ្ញា ។*

[៨៥] *ម្នាលចុដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះកន្លងនូវរូបសញ្ញា ព្រោះអស់ទៅនៃបដិឃសញ្ញា ព្រោះលែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួងហើយ ភិក្ខុក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ រូបសញ្ញាជាខាងដើមរបស់ភិក្ខុនោះក៏រលត់ទៅ សចេ្ចសញ្ញាដ៏ល្អិត ពោល គឺអាកាសានញ្ចាយតនជ្ឈានក៏មានក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថា មានសចេ្ចសញ្ញាដ៏ល្អិត ពោល គឺអាកាសានញ្ចាយតនជ្ឈានក្នុងសម័យនោះឯង សញ្ញាខ្លះកើតព្រោះការហាត់ សញ្ញាខ្លះរលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯង ដែលហៅថា ការហាត់សញ្ញា ។*

[៨៦] *ម្នាលចុដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះកន្លងនូវអាកា-*

សានញ្ចាយតនជ្ឈានដោយប្រការទាំងពួង ភិក្ខុបានដល់នូវវិញ្ញាណញ្ចាយ-
តនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ក៏សម្រេច
សម្រាន្តនៅដោយឥរិយាបថទាំង ៤ សចូសញ្ញាដ៏ល្អិត ពោល គឺអាកាសា-
នញ្ចាយតនជ្ឈានជាខាងដើម របស់ភិក្ខុនោះក៏រលត់ទៅ សចូសញ្ញាដ៏ល្អិត
ពោល គឺវិញ្ញាណញ្ចាយតនជ្ឈាន ក៏មានក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថា
មានសចូសញ្ញាដ៏ល្អិត ពោល គឺវិញ្ញាណញ្ចាយតនជ្ឈាន ក្នុងសម័យនោះឯង
សញ្ញាខ្ជះកើតព្រោះការហាត់ សញ្ញាខ្ជះរលត់ទៅព្រោះការហាត់ ដូចពណ៌នា
មកនេះ នេះឯង ដែលហៅថា ការហាត់សញ្ញា ។

[៨៧] ម្នាលបោដ្ឋបាទ សេចក្តីផ្សេងទៀតថា ព្រោះកន្ជងនូវវិញ្ញាណ-
ញ្ចាយតនជ្ឈានដោយប្រការទាំងពួង ភិក្ខុក៏បានដល់នូវអាកិចូញ្ញាយតនជ្ឈាន
ដោយធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមាន ដូច្នេះហើយ សម្រេចសម្រាន្តនៅ
ដោយឥរិយាបថទាំង ៤ សចូសញ្ញាដ៏ល្អិត ពោល គឺវិញ្ញាណញ្ចាយតនជ្ឈាន
ជាខាងដើមរបស់ភិក្ខុនោះក៏រលត់ទៅ សចូសញ្ញាដ៏ល្អិត ពោល គឺអាកិញ្ចញ្ញា-
យតនជ្ឈាន ក៏មានក្នុងសម័យនោះ ភិក្ខុនោះឈ្មោះថា មានសចូសញ្ញាដ៏ល្អិត
ពោល គឺអាកិញ្ចញ្ញាយតនជ្ឈានក្នុងសម័យនោះឯង សញ្ញាខ្ជះកើតព្រោះការ
ហាត់ សញ្ញាខ្ជះរលត់ទៅព្រោះការហាត់ ដូចពណ៌នាមកនេះ នេះឯង ដែល
ហៅថា ការហាត់សញ្ញា ។

[៨៨] ម្នាលបោដ្ឋបាទ ភិក្ខុណាក្នុងសាសនានេះ មានសេចក្តី
សម្គាល់ (ក្នុងបឋមជ្ឈាន) របស់ខ្លួន ភិក្ខុនោះចេញចាកបឋមជ្ឈាននោះ

ហើយ ចូលទុតិយជ្ឈានឯណោះ ចេញចាកទុតិយជ្ឈាននោះហើយ ចូលតតិ-យជ្ឈានឯណោះ (លុះចូលឈាន) តាមលំដាប់ហើយ ក៏បាននូវសញ្ញាជាកំពូល គឺអាកិញ្ចញ្ញាយតនជ្ឈាន កាលបើភិក្ខុនោះ ឋិតនៅក្នុងសញ្ញាជាកំពូល គឺអកិញ្ចញ្ញាយតនជ្ឈានហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើអាត្មាអញចូលឈាន មិនប្រសើរឡើយ បើអាត្មាអញមិនចូលឈាន ទើបប្រសើរ ព្រោះថា ប្រសិនបើអាត្មាអញចូលឈាន រវល់តែនឹងចូលឈានសញ្ញាក្នុងអាកិញ្ចញ្ញាយតនជ្ឈានទាំងនេះ របស់អាត្មាអញ មុខជារលត់ទៅ សញ្ញាដ៏គ្រោតគ្រោតឯទៀត គឺភវង្គសញ្ញាមុខជាកើតឡើង បើដូច្នោះ អាត្មាអញមិនគួរនឹងចូលឈាន មិនគួររវល់តែនឹងចូលឈានឡើយ ។ ភិក្ខុនោះឯង ក៏លែងចូលឈាន លែងរវល់នឹងចូលឈាន កាលបើភិក្ខុនោះ លែងចូលឈាន លែងរវល់នឹងចូលឈាន សញ្ញាទាំងនោះក៏រលត់ទៅ សញ្ញាដ៏គ្រោតគ្រោតឯទៀត គឺភវង្គសញ្ញាក៏មិនកើតឡើង ភិក្ខុនោះបាននូវនិរោធ ។ ម្នាលចោដ្ឋបាទ យ៉ាងនេះ ហៅថា អនុបុព្ភាភិសញ្ញានិរោធសម្បជានសមាបត្តិ ។ ម្នាលចោដ្ឋបាទ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច អនុបុព្ភាភិសញ្ញានិរោធ-សម្បជានសមាបត្តិមានសភាពយ៉ាងនេះ អ្នកធ្លាប់បានឮមកក្នុងកាលមុនពីកាលនេះដែរឬ ។ ចោដ្ឋបាទបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនេះ ខ្ញុំព្រះអង្គមិនធ្លាប់បានឮទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទើបតែនឹងជឿនូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយអាការយ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលចោដ្ឋបាទ ភិក្ខុណា

មានសេចក្តីសម្គាល់ (ក្នុងបឋមជ្ឈាន) របស់ខ្លួន ភិក្ខុនោះ ចេញចាកបឋមជ្ឈាននោះហើយ ចូលទុតិយជ្ឈានឯណោះ ចេញចាកទុតិយជ្ឈាននោះហើយ ចូលតតិយជ្ឈានឯណោះ (លុះចូលឈាន) តាមលំដាប់ ក៏បានទូវសញ្ញាជាកំពូល គឺអាកិញ្ចញ្ញាយតនជ្ឈាន កាលបើភិក្ខុនោះឋិតនៅក្នុងសញ្ញាជាកំពូល គឺអាកិញ្ចញ្ញាយតនជ្ឈាន ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើអាត្មាអញចូលឈានមិនប្រសើរទេឬយ បើអាត្មាអញមិនចូលឈាន ទើបប្រសើរ ព្រោះថា ប្រសិនបើអាត្មាអញចូលឈាន រវល់តែនឹងចូលឈានសញ្ញាក្នុងអាកិញ្ចញ្ញាយតនជ្ឈានទាំងនេះ របស់អាត្មាអញ មុខជារលត់ទៅ សញ្ញាដ៏គ្រោតគ្រោតដទៃ គឺកវឡ្គសញ្ញាមុខជាកើតឡើង បើដូច្នោះ អាត្មាអញ មិនគួរនឹងចូលឈាន មិនគួររវល់តែនឹងឈាន ។ ភិក្ខុនោះឯង ក៏លែងចូលឈាន លែងរវល់នឹងចូលឈាន កាលបើភិក្ខុនោះ លែងចូលឈាន លែងរវល់នឹងឈាន សញ្ញាទាំងនោះក៏រលត់ទៅ សញ្ញាដ៏គ្រោតគ្រោតឯទៀត គឺកវឡ្គសញ្ញាក៏មិនកើតឡើង ភិក្ខុនោះបានទូវនិរោធ ។ ម្នាលដោដ្ឋបាទ យ៉ាងនេះ ហៅថា អនុបុព្ភាភិសញ្ញានិរោធសម្បជានសមាបត្តិ ។

[๘๙] ម្នាលដោដ្ឋបាទ អភិសញ្ញានិរោធយ៉ាងនេះឯង ។ ដោដ្ឋបាទ-បរិព្វាជក ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់បញ្ញត្តទូវសញ្ញា ជាកំពូលតែមួយយ៉ាងប៉ុណ្ណោះទេ ឬទ្រង់បញ្ញត្តទូវសញ្ញា ជាកំពូលច្រើនយ៉ាង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលដោដ្ឋបាទ តថាគតបញ្ញត្តទូវសញ្ញាជាកំពូលតែមួយប៉ុណ្ណោះក៏មាន បញ្ញត្តទូវសញ្ញាជាកំពូលច្រើន

យ៉ាងក៏មាន ฯ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់បញ្ញត្តនូវសញ្ញា ជាកំពូលតែមួយយ៉ាងក៏មាន ទ្រង់បញ្ញត្តនូវសញ្ញា ជាកំពូលច្រើនយ៉ាងក៏មាន តើដូចម្តេច ฯ ម្នាលចោជ្ឈបាទ កិកុ្ខបាននូវនិរោធយ៉ាងណាៗ តថាគត ក៏បញ្ញត្តនូវសញ្ញាជាកំពូលយ៉ាងនោះៗ ฯ ម្នាលចោជ្ឈបាទ តថាគតបញ្ញត្តនូវសញ្ញាជាកំពូលតែមួយយ៉ាងក៏មាន បញ្ញត្តនូវសញ្ញា ជាកំពូលច្រើនយ៉ាងក៏មាន យ៉ាងនេះឯង ฯ

[๙๐] *បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាកើតមុន ញាណកើតក្រោយ ឬញាណកើតមុន សញ្ញាកើតក្រោយ ឬក៏ទាំងសញ្ញាទាំងញាណ កើតជំណាលគ្នាតែម្តង ฯ ម្នាលចោជ្ឈបាទ សញ្ញាកើតមុន ញាណកើតក្រោយ ដ្បិតថាការកើតឡើងនៃញាណបាន ក៏ព្រោះតែសេចក្តីកើតឡើងនៃសញ្ញា កិកុ្ខនោះក៏ដឹងយ៉ាងនេះថា ញាណរបស់អាត្មាអញកើតហើយ ព្រោះសញ្ញានេះជាបច្ច័យ ฯ ម្នាលចោជ្ឈបាទ រឿងនេះ អ្នកត្រូវដឹងតាមទំនងនេះចុះថា សញ្ញាកើតមុន ញាណកើតក្រោយ ដ្បិតញាណកើតឡើងបាន ក៏ព្រោះតែសញ្ញាកើតឡើង ฯ*

[๙๑] *បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាឈ្មោះថា ខ្លួនរបស់បុរស ឬក៏សញ្ញាដទៃ ខ្លួនដទៃទេ ฯ ម្នាលចោជ្ឈបាទ អ្នកជឿថា ខ្លួនដូចម្តេច ฯ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿថា ខ្លួនដ៏គ្រោតគ្រោតមានរូប ប្រកបដោយមហាភូតរូប ๔ មានកវឡិង្ការាហារជាចំណី ฯ ម្នាលចោជ្ឈបាទ មែនហើយ ខ្លួនរបស់អ្នកដ៏គ្រោតគ្រោតមានរូប ប្រកបដោយមហាភូតរូប ๔ មានកវឡិង្កា-*

ภหาวาชาจำณี ฯ ม้าลโปฏฐปาท กาลโบีโหตุย่างนีะมานหีย สญญา
โบสม่อกก็ชโท ขันธโบสม่อกก็ชโท ฯ ม้าลโปฏฐปาท อกตรูวชีงสีจกี
น่ะตามทีนงนีะจุะถา สญญาก็ชโท ขันธก็ชโทยพีต ฯ ม้าลโปฏฐปาท
ขันธชีลคราตคราตมานรูป ปรกปโดยมหาภูตรูป ๔ มานกวลิงกา-
ภหาวาชาจำณีนีะ จูรลีกทุกสินจุะ กาลโบีชูโจ๊ะสญญาชโทรโบสม่อปุรส
นีะกีตเจ๊ีง สญญาเอกไตรลต่ะท ม้าลโปฏฐปาท อกตรูวชีงสีจกีน่ะ
ตามทีนงนีะจุะถา สญญาก็ชโท ขันธก็ชโทยพีต ฯ

[๙๒] *บพีตรพระองคชีจมีน ขุ้พระองคชีถา ขันธสมีรจโดย*
จิตมานอายวะ:ตูจทำสพุกรบ มานอินทรียมินโจกทาบ ฯ ม้าลโปฏฐปาท
ประสินโบีขันธโบสม่อกสมีรจโดยจิต มานอายวะ:ตูจทำสพุกรบ มาน
อินทรียมินโจกทาบ ฯ ม้าลโปฏฐปาท กาลโบีโหตุชูโจ๊ะมานหีย สญญา
โบสม่อกก็ชโท ขันธโบสม่อกก็ชโท ฯ ม้าลโปฏฐปาท อกตรูวชีงสีจกี
น่ะ ตามบริยายนีะถา สญญาก็ชโท ขันธก็ชโทมีน ฯ ม้าลโปฏฐปาท ก็
ขันธสมีรจโดยจิต มานอายวะ:ตูจทำสพุกรบ มานอินทรียมินโจกทาบ
นีะ จูรลีกทุกสินจุะ กาลโบีชูโจ๊ะ สญญาชโทรโบสม่อปุรสนีะกีตเจ๊ีง
สญญาเอกไตรก็รลต่ะทวิญญาโดยจิต ฯ ม้าลโปฏฐปาท อกตรูวชีงสีจกี
น่ะ โดยบริยายนีะถา สญญาก็ชโท ขันธก็ชโทมีน ฯ

[๙๓] *บพีตรพระองคชีจมีน ขุ้พระองคชีถา ขันธมินมานรูป*
สมีรจโดยสญญาโดยจิต ฯ ม้าลโปฏฐปาท ขันธโบสม่อกมินมานรูป

สម្រេចដោយសញ្ញាមែនហើយ ។ ម្នាលចោដ្ឋបាទ កាលបើហេតុយ៉ាងនេះ មានហើយ សញ្ញារបស់អ្នកក៏ជនៃ ខ្លួនក៏ជនៃពិត ។ ម្នាលចោដ្ឋបាទ អ្នកគប្បីដឹងសេចក្តីនុ៎ះ ដោយបរិយាយនេះថា សញ្ញាក៏ជនៃ ខ្លួនក៏ជនៃដោយពិត ។ ម្នាលចោដ្ឋបាទ ខ្លួនមិនមានរូប សម្រេចដោយសញ្ញានេះចូរលើកទុកសិនចុះ កាលបើយ៉ាងនេះសញ្ញាជនៃរបស់បុរសនេះ តែងកើតឡើង សញ្ញាជនៃតែងរលត់ទៅ ។ ម្នាលចោដ្ឋបាទ អ្នកគប្បីដឹងសេចក្តីនុ៎ះ ដោយបរិយាយនេះថា សញ្ញាក៏ជនៃ ខ្លួនក៏ជនៃដោយពិត ។

[៩៤] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ អាចដឹងសេចក្តីនុ៎ះថា សញ្ញាជាខ្លួនរបស់បុរសដូច្នេះខ្លះ សញ្ញាក៏ជនៃ ខ្លួនក៏ជនៃដូច្នេះខ្លះ ។ ម្នាលចោដ្ឋបាទ អ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីផ្សេង មានអាចារ្យក្នុងទីផ្សេង កម្រនឹងដឹងសេចក្តីនុ៎ះថា សញ្ញាជាខ្លួនរបស់បុរសដូច្នេះខ្លះ សញ្ញាក៏ជនៃ ខ្លួនក៏ជនៃដូច្នេះខ្លះបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គជាអ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានការព្យាយាមក្នុងទីផ្សេង មានអាចារ្យក្នុងទីផ្សេង កម្រនឹងដឹងសេចក្តីនុ៎ះថា សញ្ញាជាខ្លួនរបស់បុរសដូច្នេះខ្លះ សញ្ញាក៏ជនៃ ខ្លួនក៏ជនៃដូច្នេះខ្លះ បពិត្រព្រះអង្គដ៏ចម្រើន ចុះដែលគេថា លោកទៀងនេះឯង ជាពាក្យពិត ពាក្យជនៃ ជាពាក្យឥតអំពើឬ ។ ម្នាលចោដ្ឋបាទ តថាគតមិនដែលព្យាករសេចក្តីនុ៎ះថា ពាក្យថា លោកទៀងនេះឯង ជាពាក្យពិត ពាក្យ

ដទៃ ជាពាក្យឥតអំពើដូច្នេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះពាក្យថា លោកមិនទៀងនេះឯងជាពាក្យពិត ពាក្យដទៃជាពាក្យឥតអំពើទេឬ ។ ម្នាលចោជ្ជបាទ តថាគតមិនដែលព្យាករសេចក្តីនុ៎ះថា ពាក្យថា លោកមិនទៀងនេះឯងជាពាក្យពិត ពាក្យដទៃជាពាក្យឥតអំពើដូច្នេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះពាក្យថា លោកមានទីបំផុត ។បេ។ លោកមិនមានមានទីបំផុត ។ ជីវៈនោះ ក៏គឺសរីរៈនោះ ។ ជីវៈផ្សេង សរីរៈក៏ផ្សេងទេ ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅមាន ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនមាន ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានខ្លះ មិនមានខ្លះ ។ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែននេះឯង ជាពាក្យពិត ពាក្យដទៃ ជាពាក្យឥតអំពើឬ ។ ម្នាលចោជ្ជបាទ តថាគតមិនដែលព្យាករសេចក្តីនុ៎ះថា ពាក្យថា សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ (ពាក្យឥតអំពើ) ដូច្នេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រោះហេតុអ្វី បានជាព្រះមានព្រះភាគ មិនទ្រង់ព្យាករសេចក្តីនុ៎ះ ។ ម្នាលចោជ្ជ-បាទ ព្រោះថា ពាក្យនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនប្រកបដោយនវ-លោកុត្តរធម៌ មិនមែនជាអាទិព្រហ្មចរិយកាសិក្ខា គឺមិនមែនអធិសីលសិក្ខាទេ មិនប្រព្រឹត្តទៅដើម្បីនឿយណាយក្នុងសំសារវដ្ត មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេកក្នុងវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីរម្ងាប់វដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីរម្ងាប់វដ្តៈ មិនប្រព្រឹត្តទៅដើម្បីដឹងចំពោះវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់

នូវវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតមិនព្យាករសេចក្ដីនោះឡើយ ។

[๙๕] *បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គ ទ្រង់ព្យាករពាក្យអ្វីទៅវិញ ។ ម្នាលចុន្ទបុត្ត តថាគតព្យាករដូច្នេះឯងថា នេះជាទុក្ខ ម្នាលចុន្ទ-បុត្ត តថាគតព្យាករដូច្នេះឯងថា នេះជាហេតុនាំឲ្យកើតទុក្ខ ម្នាលចុន្ទបុត្ត តថាគតព្យាករដូច្នេះឯងថា នេះជាធម៌ដែលរម្ងាប់ទុក្ខ ម្នាលចុន្ទបុត្ត តថាគតព្យាករដូច្នេះឯងថា នេះជាបដិបទាជាដំណើរទៅកាន់ធម៌រម្ងាប់ទុក្ខ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគ ទ្រង់ព្យាករពាក្យនេះ ។ ម្នាលចុន្ទបុត្ត ព្រោះថា ពាក្យនេះប្រកបដោយប្រយោជន៍ ពាក្យនេះប្រកបដោយធម៌ ពាក្យនេះ ជាអាទិព្រហ្មចរិយកាសិក្ខា គឺអធិសីលសិក្ខា ប្រព្រឹត្តទៅដើម្បីនឿយណាយក្នុងសំសារវដ្ដ ដើម្បីប្រាសចាកតម្រេកក្នុងវដ្ដៈ ដើម្បីរម្ងាប់នូវវដ្ដៈ ដើម្បីរម្ងាប់នូវវដ្ដៈ ដើម្បីដឹងចំពោះនូវវដ្ដៈ ដើម្បីដឹងច្បាស់នូវវដ្ដៈ ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតព្យាករពាក្យនេះ ។ បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះមានព្រះភាគទ្រង់សម្គាល់នូវកាលដែលនឹងធ្វើនូវពុទ្ធដំណើរចុះ ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ក្រោកអំពីអាសនៈ ហើយទ្រង់ពុទ្ធដំណើរចេញទៅ ។*

[๙๖] *លំដាប់នោះឯង កាលបើព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចៀសចេញទៅ មិនទាន់បានយូរប៉ុន្មាន ស្រាប់តែពួកបរិព្វាជកទាំងនោះ ពោល*

ពាក្យចាក់ដោត នូវដោដ្ឋបាទបរិព្វាជក ដោយជន្ជញ្ញ គឺសម្តីជុំវិញខ្លួនថា ព្រះសមណគោតម និយាយពាក្យណាៗ ដោដ្ឋបាទដ៏ចម្រើននេះ ក៏អនុមោទនាពាក្យនោះៗ របស់ព្រះសមណគោតមនោះថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ឯពួកយើងមិនទាន់ដឹងច្បាស់នូវធម៌ណាមួយដោយជាច់ខាត ដែលព្រះសមណ-គោតម ទ្រង់សម្តែងហើយថា លោកទៀង ឬថាលោកមិនទៀង ។បេ។ ឬថាសត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះទេ ។

[๙๗] កាលបើពួកបរិព្វាជកទាំងនោះ ពោលពាក្យយ៉ាងនេះហើយ ដោដ្ឋបាទបរិព្វាជក ក៏និយាយទៅនឹងបរិព្វាជកទាំងនោះយ៉ាងនេះថា នែអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំឯងក៏មិនដឹងច្បាស់នូវធម៌ណាមួយដោយជាច់ខាត ដែលព្រះសមណគោតមទ្រង់សម្តែងហើយថា លោកទៀងឬ ។បេ។ ឬថាសត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះដែរទេ ប៉ុន្តែព្រះសមណគោតមទ្រង់បញ្ញត្តបដិបទា ដែលពិតប្រាកដទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ ដែលត្រឹមត្រូវតាមទំនងនៃធម៌ ក៏កាលបើព្រះសមណគោតម ទ្រង់បញ្ញត្តបដិបទាដែលពិតប្រាកដ ទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ ដែលត្រឹមត្រូវតាមទំនងនៃធម៌ ដូច្នោះហើយ មិនសមបើបុរសជាវិញ្ញូជួចយ៉ាងខ្ញុំ មិនអនុមោទនាសុភាសិតរបស់ព្រះសមណគោតមដោយសុភាសិតវិញសោះ ។

[៩៨] *លុះកន្លងពីនោះទៅបាន ២-៣ ថ្ងៃ ចិត្តហត្ថិសារីបុត្ត និង ជោដ្ឋបាទបរិព្វាជក ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ទើបចិត្តហត្ថិសារីបុត្ត ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏ សមគួរ ។ ឯជោដ្ឋបាទបរិព្វាជក ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួរ រឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះជោដ្ឋបាទបរិព្វាជក អង្គុយក្នុងទី ដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ ចម្រើន កាលដែលព្រះអង្គទ្រង់ពុទ្ធដំណើរចេញមក មិនទាន់បានយូរប៉ុន្មាន ក្នុងកាលនោះ ក៏ស្រាប់តែពួកបរិព្វាជកទាំងនោះ ពោលពាក្យចាក់ដោតខ្ញុំ ព្រះអង្គ ដោយជន្លួញគឺវាចាជុំវិញខ្លួនថា ព្រះសមណគោតម និយាយពាក្យ ណាៗ ជោដ្ឋបាទបរិព្វាជកដ៏ចម្រើននេះ ក៏អនុមោទនាពាក្យនោះៗ របស់ព្រះ សមណគោតមនោះថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ពួកយើងមិនដឹងច្បាស់នូវធម៌ ណាមួយដោយជាច់ខាត ដែលព្រះសមណគោតមបានសម្តែងថា លោកទៀង ឬថា លោកមិនទៀង ។បេ។ ឬថា សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះទេ បពិត្រព្រះអង្គដ៏ចម្រើន កាលបើ បរិព្វាជកទាំងនោះនិយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏និយាយទៅនឹងបរិព្វា-ជកទាំងនោះដូច្នេះថា នែអ្នកទាំងឡាយដ៏ចម្រើន ខ្ញុំឯងក៏មិនដឹងច្បាស់នូវធម៌ ណាមួយដោយជាច់ខាត ដែលព្រះសមណគោតមបានសម្តែងថា លោក*

ទៀង ឬ ฯបេฯ ឬថា សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះដែរ ប៉ុន្តែព្រះសមណគោតម ទ្រង់បញ្ញត្តបដិបទាដែលពិតប្រាកដទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ ដែលត្រឹមត្រូវតាមទំនងធម៌ ក៏កាលព្រះសមណគោតមទ្រង់បញ្ញត្តបដិបទា ដែលពិតប្រាកដទៀងទាត់ មានសភាពតាំងនៅក្នុងធម៌ ដែលត្រឹមត្រូវតាមទំនងនៃធម៌ដូច្នោះ មិនសមបើបុរសជាវិញ្ញូជនយ៉ាងខ្ញុំហើយ មិនអនុមោទនាសុភាសិតរបស់ព្រះសមណគោតម ដោយសុភាសិតវិញ្ញូសោះ ฯ

[๙๙] ម្នាលចោដ្ឋបាទ ឯបរិព្វាជកទាំងអស់គ្នានោះឯង សុទ្ធតែជាបុគ្គលខ្វាក់ឥតមានចក្ខុ គឺបញ្ញាសោះឡើយ បណ្តាបរិព្វាជកទាំងនោះ មានតែអ្នកឯងមួយជាបុគ្គលមានចក្ខុ គឺបញ្ញាដោយពិត ฯ ម្នាលចោដ្ឋបាទ ព្រោះថា ធម៌ដែលប្រព្រឹត្តទៅដោយចំណែក ๑ តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយក៏មាន ฯ ម្នាលចោដ្ឋបាទ ធម៌ទាំងឡាយដែលមិនប្រព្រឹត្តទៅដោយចំណែក ๑ តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយក៏មាន ฯ ម្នាលចោដ្ឋបាទ ធម៌ទាំងឡាយដែលមិនប្រព្រឹត្តទៅដោយចំណែក ๑ តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយតើដូចម្តេច ฯ ម្នាលចោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយថា លោកទៀងដូច្នេះឯង តថាគតបានសម្តែងហើយ បញ្ញត្តិហើយ ฯបេฯ ម្នាលចោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយថា លោកមិនទៀងដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ฯ ម្នាលចោដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅ ដោយចំណែក

មួយថា លោកមានទីបំផុតដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។ ម្នាលចុដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយថា លោកមិនមានទីបំផុតដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ។ ម្នាលចុដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយថា ជីវៈនោះ គឺសរីរៈនោះដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។ ម្នាលចុដ្ឋបាទ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយថា ជីវៈផ្សេងសរីរៈផ្សេងដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។ ម្នាលចុដ្ឋបាទ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅមាន ។បេ។ ម្នាលចុដ្ឋបាទ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅមិនមាន ។បេ។ ម្នាលចុដ្ឋបាទ សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានខ្លះ មិនមានខ្លះ ។បេ។ ម្នាលចុដ្ឋបាទ ធម៌មិនប្រព្រឹត្តទៅដោយចំណែកមួយ តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយថា សត្វខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ មានក៏មិនមែន មិនមានក៏មិនមែនដូច្នេះឯង ។ ម្នាលចុដ្ឋបាទ ក៏ធម៌មិនប្រព្រឹត្តទៅដោយចំណែកមួយទាំងនុ៎ះ ដែលតថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ព្រោះហេតុអ្វី ។ ម្នាលចុដ្ឋបាទ ព្រោះធម៌ទាំងនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនប្រកបដោយធម៌ មិនមែនជាអាទិព្រហ្មចរិយកាសិក្ខា មិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្ត

ទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ ធម៌ដែលមិនប្រព្រឹត្តទៅដោយចំណែកមួយទាំងនុ៉ះ បានជាតថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។

[១០០] ម្នាលឧាដ្ឋបាទ ចុះធម៌ទាំងឡាយប្រព្រឹត្តទៅដោយចំណែកមួយ ដែលតថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ តើដូចម្តេច ។ ម្នាលឧាដ្ឋបាទ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយថា នេះជាទុក្ខដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។ ម្នាលឧាដ្ឋបាទ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយថា នេះជាហេតុនាំឲ្យកើតទុក្ខដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។ ម្នាលឧាដ្ឋបាទ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយថា នេះជាសេចក្តីរម្ងត់ទុក្ខដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។ ម្នាលឧាដ្ឋបាទ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយថា នេះជាបដិបទាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខដូច្នេះឯង តថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។ ម្នាលឧាដ្ឋបាទ ចុះធម៌ប្រព្រឹត្តទៅដោយចំណែកមួយទាំងនុ៉ះ ដែលតថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ តើព្រោះហេតុអ្វី ។ ម្នាលឧាដ្ឋបាទ ព្រោះថា ធម៌ទាំងនុ៉ះប្រកបដោយប្រយោជន៍ ធម៌ទាំងនុ៉ះប្រកបដោយធម៌ ធម៌ទាំងនុ៉ះជាអាទិព្រហ្មចរិយកាសិក្ខា ធម៌ទាំងនុ៉ះប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរម្ងត់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ ធម៌ប្រព្រឹត្តទៅដោយចំណែកមួយទាំងនុ៉ះ បានជាតថាគតបានសម្តែងហើយ បានបញ្ញត្តិហើយ ។

[๑๐๑] *ម្នាលភោជ្ជបាទ មានសមណព្រាហ្មណ៍ទាំងនុ៎ះ តែងមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម៉្យាង មិនមានភេទខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ឮថា អ្នកទាំងឡាយមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម៉្យាង មិនមានភេទ ខាងមុខបន្ទាប់អំពីស្លាប់ទៅដូច្នេះ ពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ កាលបើតថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា កវុណា (ពិតមែន) តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយបានដឹង បានឃើញថា សត្វលោកមានសេចក្តីសុខតែមួយយ៉ាងមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថា មិនមែនទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ ចាំបាននូវខ្លួនថា មានសេចក្តីសុខតែមួយយ៉ាង អស់យប់មួយ ថ្ងៃមួយ ឬអស់កន្លះយប់ កន្លះថ្ងៃដូច្នេះឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថា មិនមែនទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ ស្គាល់ថា នេះជាមគ្គ នេះជាបដិបទាប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខតែមួយយ៉ាងឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ

ก็ឆ្លើយថា មិនមែនទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះ ទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ បានឮសំឡេងរបស់ពួកទេវតាដែលកើតក្នុងលោក មានសេចក្តីសុខតែម្យ៉ាង និយាយច្រាប់ថា ម្នាលគ្នាយើងទាំងឡាយ ចូរអ្នកទាំងឡាយ ប្រតិបត្តិដោយល្អទៅ ម្នាលគ្នាយើងទាំងឡាយ ចូរអ្នកទាំងឡាយ ប្រតិបត្តិឲ្យត្រង់ទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខតែមួយយ៉ាង ម្នាលគ្នាយើងទាំង-ឡាយ ព្រោះថា បើពួកយើងប្រតិបត្តិយ៉ាងនេះហើយ នឹងទៅកើតក្នុងលោកដែលមានសេចក្តីសុខតែមួយយ៉ាងដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថា មិនមែនទេ ។ ម្នាលបោដ្ឋបាទ អ្នកសម្គាល់សេចក្តីនោះថា ដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ កាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនមែនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ កាសិតរបស់សមណ-ព្រាហ្មណ៍ទាំងនោះ មិនមែនជាអស្ចារ្យដោយពិតទេ ។

[๑๐๒] ម្នាលបោដ្ឋបាទ ប្រៀបដូចបុរស និយាយយ៉ាងនេះថា ខ្ញុំត្រូវការចង់បាននូវនាងជនបទកល្យាណី ក្នុងជនបទនេះ ពួកជនសួរទៅបុរសនោះ យ៉ាងនេះថា នែបុរសអើយ អ្នកត្រូវការចង់បាននូវនាងជនបទកល្យាណីណា អ្នកស្គាល់នូវនាងជនបទកល្យាណីនោះថា ជាក្សត្រិយានីព្រាហ្មណី វេស្សី ឬសុទ្ទីដែរឬ ។ បុរសនោះ លុះពួកជនសួរយ៉ាងនេះហើយ ច្រាប់ថា មិនស្គាល់ទេ ជនទាំងឡាយសួរទៅបុរសនោះ យ៉ាងនេះ

ទៀតថា នែបុរសអើយ អ្នកប្រាថ្នាចង់បាននូវនាងជនបទកល្យាណីណា អ្នកស្គាល់នូវនាងជនបទកល្យាណីនោះថា មានឈ្មោះយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ ខ្ពស់ ទាប ឬយ៉ាងកណ្តាល មានសម្បុរខ្មៅ សម្បុរខ្មៅស្រអែម ឬសម្បុរខ្មៅស្រស់ ក្នុងស្រុក ឬនិគម ឬក៏ក្នុងនគរឯណោះដូច្នេះដែរឬ ។ បុរសនោះ លុះពួកជនសួរយ៉ាងនេះហើយ ក៏ប្រាប់ថា ខ្ញុំមិនស្គាល់ទេ ជនទាំងឡាយសួរទៅបុរសនោះយ៉ាងនេះទៀតថា នែបុរសអើយ អ្នកឯងមិនស្គាល់ មិនឃើញនូវស្ត្រីណាហើយ ប្រាថ្នាចង់បាននូវស្ត្រីនោះដែរឬ ។ បុរសនោះលុះពួកជនសួរយ៉ាងនេះហើយ ក៏ប្រាប់ថា បាទ ។ ម្នាលភោជ្ជបាទ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ សម្តីរបស់បុរសនោះមិនមែនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ សម្តីរបស់បុរសនោះមិនជាអស្ចារ្យដោយពិត ។ ម្នាលភោជ្ជបាទ ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណា ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ បានឮថា អ្នកទាំងឡាយមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្លួនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅដូច្នេះពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ កាលបើតថាគតសួរយ៉ាងនេះហើយ ឆ្លើយថា កុណា ពិតមែន តថាគតសួរ

ទៅសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយបានដឹង បានឃើញថាលោកមានសេចក្តីសុខតែម្យ៉ាងដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយក៏ឆ្លើយថា មិនដឹង មិនឃើញទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយចាំបាននូវខ្ជួនដែលមានសេចក្តីសុខតែមួយយ៉ាងអស់យប់មួយ ថ្ងៃមួយ ឬអស់ត្រឹមតែកន្លះយប់ កន្លះថ្ងៃ ដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ឆ្លើយថា មិនមែនទេ តថាគតសួរទៅសមណ-ព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយស្គាល់ថា នេះជាមគ្គ នេះជាបដិបទា ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានសេចក្តីសុខតែមួយយ៉ាងដូច្នេះដែរឬ ។ សមណ-ព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ឆ្លើយថា មិនស្គាល់ទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំង-ឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ បានឲ្យសំឡេងរបស់ពួកទេវតាដែលកើតក្នុងលោក ដែលមានសេចក្តីសុខតែមួយយ៉ាង និយាយប្រាប់ថា នែគ្នាយើងទាំងឡាយ ចូរអ្នកប្រតិបត្តិដោយល្អទៅ នែគ្នាយើងទាំងឡាយ ចូរអ្នកប្រតិបត្តិដោយត្រង់ទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវលោកដែលមានសេចក្តីសុខតែមួយយ៉ាង នែគ្នាយើងទាំងឡាយ ព្រោះថា បើពួកយើងទាំងឡាយ ប្រតិបត្តិយ៉ាងនេះហើយនឹងទៅកើតក្នុងលោក ដែលមានសេចក្តីសុខតែមួយ

យ៉ាង ដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះ ហើយឆ្លើយថា មិនបានឮទេ ។ ម្នាលចោដ្ឋបាទ អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ កាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ កាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យដោយពិតទេ ។

[១០៣] ម្នាលចោដ្ឋបាទ ពុំនោះសោត ប្រៀបដូចបុរសធ្វើជណ្តើរក្នុងផ្លូវធំទាំង ៤ បម្រុងនឹងឡើងទៅកាន់ប្រាសាទ ជនទាំងឡាយ សួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកធ្វើជណ្តើរបម្រុងនឹងឡើងទៅកាន់ប្រាសាទណា អ្នកស្គាល់ប្រាសាទនោះថា នៅក្នុងទិសខាងកើត ឬខាងត្បូង ខាងលិច ឬខាងជើងជាប្រាសាទខ្ពស់ ទាប ឬយ៉ាងកណ្តាលដែរឬ ។ បុរសនោះ ដែលគេសួរដូច្នេះហើយ ក៏ប្រាប់ថា មិនស្គាល់ទេ ពួកជនក៏សួរទៅបុរសនោះយ៉ាងនេះទៀតថា នែបុរសដ៏ចម្រើន អ្នកធ្វើជណ្តើរបម្រុងនឹងឡើងទៅកាន់ប្រាសាទដែលខ្លួនមិនស្គាល់ មិនឃើញបានដែរឬ ។ បុរសនោះ លុះគេសួរដូច្នេះហើយ ក៏ប្រាប់ថា បាទ ។ ម្នាលចោដ្ឋបាទ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ សម្តីរបស់បុរសនោះ មិនមែនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ សម្តីរបស់បុរសនោះ មិនជាអស្ចារ្យដោយពិតទេ ។ ម្នាលចោដ្ឋ-បាទ មានឧបមេយ្យ ដូចពួកសមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មាន

ទិដ្ឋិយ៉ាងនេះថា ខ្ញុំនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ តថាគតចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះហើយ សួរយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ បានឮថា អ្នកទាំងឡាយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ខ្ញុំនមានសេចក្តីសុខតែម្យ៉ាង មិនមានរោគ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ ពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ កាលបើតថាគតសួរដូច្នេះហើយ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ តថាគតក៏សួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយ បានដឹង បានឃើញថា លោកមានសេចក្តីសុខតែម្យ៉ាងដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរដូច្នេះហើយ ក៏ឆ្លើយថា ទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយចាំបាននូវខ្ញុំន ដែលមានសេចក្តីសុខតែមួយយ៉ាង អស់យប់មួយ ថ្ងៃមួយ ឬត្រឹមតែកន្ទុះយប់ កន្ទុះថ្ងៃ ដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរដូច្នេះហើយ ក៏ឆ្លើយថា ទេ តថាគតសួរទៅសមណព្រាហ្មណ៍ទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះអ្នកទាំងឡាយស្គាល់ថា នេះជាមគ្គ នេះជាបដិបទា ប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខតែមួយយ៉ាងដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរដូច្នេះហើយ ក៏ឆ្លើយថា ទេ តថាគតសួរទៅសមណ-ព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ចុះ

អ្នកទាំងឡាយ បានឮសំឡេងរបស់ពួកទេវតាដែលកើតក្នុងលោក ដែលមានសេចក្តីសុខតែមួយយ៉ាង និយាយប្រាប់ថា ម្នាលគ្នាយើងទាំងឡាយ អ្នកទាំងឡាយ ចូរប្រតិបត្តិដោយល្អទៅ ម្នាលគ្នាយើងទាំងឡាយ ចូរអ្នកទាំង-ឡាយ ប្រតិបត្តិដោយត្រង់ទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខតែមួយយ៉ាង ម្នាលគ្នាយើងទាំងឡាយ ព្រោះថា បើពួកយើងប្រតិបត្តិយ៉ាងនេះហើយ នឹងទៅកើតក្នុងលោកដែលមានសេចក្តីសុខតែមួយយ៉ាង ដូច្នេះដែរឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរដូច្នេះហើយ ឆ្លើយថា ទេ ។ ម្នាលភោជ្ជបាទ អ្នកសម្គាល់សេចក្តីនោះថា ដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ កាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ កាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ មិនជាអស្ចារ្យដោយពិតទេ ។

[๑๐๔] ម្នាលភោជ្ជបាទ ការបាននូវអត្តភាពនេះមាន ๓ យ៉ាង គឺ បាននូវឱឡារិកអត្តភាព (អត្តភាពគ្រោតគ្រាត) ๑ បាននូវមនោមយអត្តភាព (អត្តភាពសម្រេចអំពីចិត្ត) ๑ បាននូវអរូបអត្តភាព (អត្តភាពគ្មានរូប) ๑ ។ ម្នាលភោជ្ជបាទ ចុះការបាននូវឱឡារិកអត្តភាព តើដូចម្តេច ។ កាយដែលមានរូបប្រកបដោយមហាភូតរូប៤ មានកវឡីការាហារជាចំណី នេះឈ្មោះថា ការបាននូវឱឡារិកអត្តភាព ។ ការបាននូវមនោមយអត្តភាពតើដូចម្តេច ។ កាយដែលមានរូបសម្រេចហើយដោយចិត្ត មានអវយវៈតូចធំ គ្រប់សព្វ មានឥន្ទ្រិយមិនថោកទាប នេះឈ្មោះថា ការបាននូវមនោមយអត្តភាព ។ ការ

បាននូវអរូបអត្តភាព តើដូចម្តេច ។ សត្វដែលមិនមានរូបសម្រេចហើយ ដោយសញ្ញា នេះឈ្មោះថា ការបាននូវអរូបអត្តភាព ។

[๑๐๕] *ម្នាលចោដ្ឋបាទ តថាគតសម្តែងធម៌ដើម្បីឲ្យលះបង់នូវការបានឱឡារិកអត្តភាពចេញ កាលបើអ្នកទាំងឡាយ ប្រតិបត្តិតាមហើយ សង្ខិ-លេសិកធម៌ទាំងឡាយ ពួកអ្នកនឹងលះបង់បាន ភោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយ នឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នឹងបានដល់នូវការៈពេញលេញ និងការៈធំទូលាយនៃមគ្គបញ្ញា និងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថនៅ ។ ម្នាលចោដ្ឋបាទ ប្រសិនបើអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា សង្ខិលេសិកធម៌ទាំងឡាយបុគ្គលនឹងលះបង់បាន ភោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើងបាន បុគ្គលនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នឹងបានដល់នូវការៈពេញលេញ និងការៈធំទូលាយនៃមគ្គបញ្ញានិងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថនៅ តែការសម្រេចឥរិយាបថនៅ រមែងនាំមកនូវសេចក្តីលំបាក ។ ម្នាលចោដ្ឋបាទ អ្នកមិនគួរយល់ឃើញដំណើរនុ៎ះយ៉ាងនេះឡើយ ។ សង្ខិលេសិកធម៌ទាំងឡាយនឹងសាបសូន្យទៅផង ភោទានិយធម៌ទាំងឡាយនឹងចម្រើនដុះដាលឡើងផង បុគ្គលនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវការៈពេញលេញ និងការៈធំទូលាយនៃមគ្គ-បញ្ញា និងផលបញ្ញា ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថ ឯបាមោជ្ជ បីតិ បស្សទ្ធិ សតិ សម្បជញ្ញៈ ការសម្រេចឥរិយាបថនៅជាសុខ ក៏នឹងកើត*

มានឡើង ฯ

[๑๐๖] *ម្នាលភោជ្ជបុត្ត តថាគតសម្តែងធម៌ ដើម្បីឲ្យលះបង់នូវការ បាននូវមនោមយអត្តភាពនោះចេញ កាលបើអ្នកទាំងឡាយ ប្រតិបត្តិតាម ហើយ សង្កិលេសិកធម៌ទាំងឡាយនឹងសាបសូន្យទៅ ភោគនិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើងផង អ្នកទាំងឡាយនឹងបានធ្វើឲ្យជាក់ច្បាស់ ដោយ បញ្ញាដ៏ឧត្តមដោយខ្លួនឯង និងបានដល់នូវការៈពេញលេញ និងការៈធំ ទូលាយនៃមគ្គបញ្ញា និងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថ ។ ម្នាលភោជ្ជបុត្ត ប្រសិនបើអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា សង្កិលេសិកធម៌ ទាំងឡាយនឹងសាបសូន្យទៅ ភោគនិយធម៌ទាំងឡាយ នឹងចម្រើនដុះដាល ឡើង បុគ្គលនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបាន ដល់នូវការៈពេញលេញ និងការៈធំទូលាយនៃមគ្គបញ្ញា និងផលបញ្ញា ក្នុង បច្ចុប្បន្ន សម្រេចសម្រាន្តឥរិយាបថ តែការសម្រេចឥរិយាបថនៅ រមែងនាំ មកនូវសេចក្តីលំបាក ។ ម្នាលភោជ្ជបុត្ត អ្នកមិនគួរយល់ឃើញដំណើរនុ៎ះ យ៉ាងនេះឡើយ ។ សង្កិលេសិកធម៌ទាំងឡាយនឹងសាបសូន្យទៅផង ភោគ-និយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើងផង (សេចក្តីបង្រួញ) បាមោជ្ជ បីតិ បស្សទ្ធិ សតិ សម្បជញ្ញៈ ការសម្រេចឥរិយាបថនៅជាសុខ ក៏កើត មានឡើង ។*

[๑๐๗] *ម្នាលភោជ្ជបុត្ត តថាគតសម្តែងធម៌ ដើម្បីឲ្យលះបង់នូវការ បាននូវអរូបអត្តភាពនោះចេញ កាលបើអ្នកទាំងឡាយ ប្រតិបត្តិតាមហើយ*

សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ រៅទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយនឹងធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញ និងភាវៈធំទូលាយនៃមគ្គបញ្ញា និងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថនៅ ។ (សេចក្តីបង្រួញ) បាមោជ្ជ បីតិ បស្សទ្ធិ សតិ សម្បជញ្ញៈ និងការសម្រេចឥរិយាបថនៅជាសុខ ក៏កើតមានឡើង ។

[១០៨] ម្នាលឧោដ្ឋបាទ ប្រសិនបើពួកជនដទៃសួរយើងយ៉ាងនេះថា ម្នាលអាវុសោ អ្នកទាំងឡាយសម្តែងធម៌ថា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ រៅទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយនឹងធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញ និងភាវៈធំទូលាយនៃមគ្គបញ្ញា និងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថនៅដូច្នេះ ដើម្បីលះបង់នូវការបានឱឡារិកអត្តភាពណា ការបាននូវឱឡារិកអត្តភាពនោះ តើដូចម្តេច ។ យើងកាលបើពួកជនទាំងនោះសួរយ៉ាងនេះហើយ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកយើងសម្តែងធម៌ថា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ រៅទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវភាវៈពេញលេញ និងភាវៈធំទូលាយនៃមគ្គបញ្ញា និងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថ

នៅដូច្នេះ ដើម្បីលះបង់នូវការបាននូវឱឡារិកអត្តភាពណា ការបាននូវឱឡារិកអត្តភាពនោះ គឺអត្តភាពប្រកបដោយមហាភូតរូប ๔ នេះឯង ។

[๑๐๙] ម្នាលចោដ្ឋបាទ ប្រសិនបើពួកជនដទៃសួរពួកយើងយ៉ាងនេះថា ម្នាលអ្នកទាំងឡាយមានអាយុ ចុះការបាននូវមនោមយអត្តភាពនោះ តើដូចម្តេច ។ (សេចក្តីបង្រៀញដូចគ្នានឹងន័យមុននោះដែរ) អ្នកទាំងឡាយសម្តែងធម៌ថា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមហើយ សង្កិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ វោទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើង ។បេ។ នឹងសម្រេចឥរិយាបថនៅដូច្នេះ ដើម្បីលះបង់នូវការបាននូវអរូបអត្តភាពណា ការបាននូវអរូបអត្តភាពនោះ តើដូចម្តេច ។ ម្នាលចោដ្ឋបាទ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ ភាសិត (របស់តថាគត) ប្រកបដោយសេចក្តីអស្ចារ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ភាសិត (របស់ព្រះអង្គ) ប្រកបដោយសេចក្តីអស្ចារ្យដោយពិត ។

[๑๑๐] ម្នាលចោដ្ឋបាទ ប្រៀបដូចបុរសធ្វើជណ្តើរ បម្រុងនឹងឡើងកាន់ប្រាសាទ ជាក់ខាងក្រោមប្រាសាទនោះឯង ពួកជនសួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកធ្វើជណ្តើរ បម្រុងនឹងឡើងកាន់ប្រាសាទណា អ្នកស្គាល់ប្រាសាទនោះថា នៅក្នុងទិសខាងកើត ឬទិសខាងត្បូង ទិសខាងលិច ឬទិសខាងជើង ជាប្រាសាទខ្ពស់ ទាប ឬយ៉ាងកណ្តាលដូច្នេះដែរឬ ។ បើបុរសនោះប្រាប់ពួកជនយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏មានអាយុ ខ្ញុំធ្វើ

ជណ្តើរបម្រុងនឹងឡើងកាន់ប្រាសាទណា ជាក់ខាងក្រោមប្រាសាទនោះឯង ។ ម្នាលបាដលិបុត្ត អ្នកសម្គាល់នូវសេចក្តីនោះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ សម្តីរបស់បុរសនោះ ប្រកបដោយសេចក្តីអស្ចារ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ សម្តីរបស់បុរសនោះ ប្រកបដោយសេចក្តីអស្ចារ្យដោយពិត ។ ម្នាលបាដលិបុត្ត បើពួកជនៃសូរពួកយើងយ៉ាងនេះថា ម្នាលអ្នកទាំងឡាយមានអាយុ ចុះការបាននូវឱឡារិកអត្តភាពនោះតើដូចម្តេច ។បេ។ ម្នាលអ្នកទាំងឡាយមានអាយុ ចុះការបាននូវមនោមយអត្តភាពនោះតើដូចម្តេច ។ ម្នាលអ្នកទាំងឡាយមានអាយុ អ្នកទាំងឡាយសម្តែងធម៌ថា កាលបើអ្នកទាំងឡាយប្រតិបត្តិតាមហើយ សង្ខិលេសិកធម៌ទាំងឡាយ នឹងសាបសូន្យទៅ ភោទានិយធម៌ទាំងឡាយ នឹងចម្រើនដុះដាលឡើង អ្នកទាំងឡាយ នឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នឹងបានដល់នូវការៈពេញលេញ និងការៈធំទូលាយនៃមគ្គបញ្ញា និងផលបញ្ញាក្នុងបច្ចុប្បន្ន សម្រេចឥរិយាបថនៅដូច្នេះ ដើម្បីលះបង់នូវការបាននូវអរូបអត្តភាពណា ការបាននូវអរូបអត្តភាពនោះ តើដូចម្តេច ។ យើងកាលដែលជនទាំងនោះ សួរយ៉ាងនេះហើយ គប្បីព្យាករយ៉ាងនេះថា ម្នាលអ្នកទាំងឡាយមានអាយុ ការបាននូវអរូបអត្តភាពនោះ គឺសត្វដែលមិនមានរូប សម្រេចដោយសញ្ញានេះឯង ។បេ។ ម្នាលបាដលិបុត្ត អ្នកសម្គាល់នូវសេចក្តីនេះថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ តាសិត (របស់តថាគត) ប្រកបដោយសេចក្តីអស្ចារ្យដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាល

បើហេតុយ៉ាងនេះមានហើយ កាសិតរបស់ព្រះអង្គ ប្រកបដោយសេចក្តីអស្ចារ្យដោយពិត ។

[๑๑๑] *កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ចិត្តហត្ថិសារីបុត្ត ក៏ក្រាបទូលសួរចំពោះព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវឱឡារិកអត្តភាព ក្នុងសម័យណា (របស់សត្វណា) សម័យនោះ ការបាននូវមនោមយអត្តភាព ការបាននូវអរូបអត្តភាពរបស់សត្វនោះ ក៏ទទេសោះសូន្យ គឺខានបានក្នុងសម័យនោះ បានត្រឹមតែឱឡារិកអត្តភាពប៉ុណ្ណោះឬ បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវមនោមយអត្តភាព ក្នុងសម័យណា (របស់សត្វណា) សម័យនោះ ការបាននូវឱឡារិកអត្តភាព ការបាននូវអរូបអត្តភាពរបស់សត្វនោះ ក៏ទទេសោះសូន្យ ក្នុងសម័យនោះ បានត្រឹមតែមនោមយអត្តភាពប៉ុណ្ណោះឬ បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវអរូបអត្តភាព ក្នុងសម័យណា (របស់សត្វណា) សម័យនោះ ការបាននូវឱឡារិអត្តភាព ការបាននូវមនោមយអត្តភាព របស់សត្វនោះទទេសោះសូន្យ ក្នុងសម័យនោះ បានត្រឹមតែអរូបអត្តភាពប៉ុណ្ណោះឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចិត្ត: ការបាននូវឱឡារិកអត្តភាព ក្នុងសម័យណា សម័យនោះ រមែងមិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាព ទាំងមិនដល់នូវការរាប់ថា បាននូវអរូបអត្តភាពក្នុងសម័យនោះ ដល់នូវការរាប់ថា បានត្រឹមតែឱឡារិកអត្តភាពប៉ុណ្ណោះ ម្នាលចិត្ត: ការបាននូវមនោមយអត្តភាព ក្នុងសម័យណា សម័យនោះ រមែងមិនដល់នូវការរាប់ថា បាន*

នូវឧឡារិអត្តភាព ទាំងមិនដល់នូវការរាប់ថា បាននូវអរូបអត្តភាពទេ ក្នុងសម័យនោះ ដល់នូវការរាប់ថា បានត្រឹមតែមនោមយអត្តភាពប៉ុណ្ណោះ ម្នាលចិត្ត: ការបាននូវអរូបអត្តភាព ក្នុងសម័យណា សម័យនោះ រមែងមិនដល់នូវការរាប់ថា បាននូវឧឡារិកអត្តភាព ទាំងមិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាពទេ ក្នុងសម័យនោះ ដល់នូវការរាប់ថា បានត្រឹមតែអរូប-អត្តភាពប៉ុណ្ណោះ ។

[១១២] ម្នាលចិត្ត: បើជនទាំងឡាយ សួរអ្នកយ៉ាងនេះថា អ្នកធ្លាប់កើតក្នុងអតីតកាល អ្នកមិនមែនជាមិនធ្លាប់កើតទេ អ្នកនឹងកើតក្នុងអនាគតកាលអ្នកមិនមែនជាមិនកើតទេ អ្នកកើតក្នុងកាលឥឡូវនេះ អ្នកមិនមែនជាមិនកើតទេឬ ។ ម្នាលចិត្ត: កាលបើគេសួរយ៉ាងនេះហើយ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើជនទាំងឡាយសួរខ្ញុំព្រះអង្គយ៉ាងនេះថា អ្នកធ្លាប់កើតក្នុងអតីតកាល អ្នកមិនមែនជាមិនធ្លាប់កើតទេ អ្នកនឹងកើតក្នុងអនាគតកាល អ្នកមិនមែនជានឹងមិនកើតទេ អ្នកកើតក្នុងកាលឥឡូវនេះ អ្នកមិនមែនជាមិនកើតទេឬ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ខ្ញុំធ្លាប់កើតក្នុងអតីតកាល ខ្ញុំមិនមែនជាមិនធ្លាប់កើតទេ ខ្ញុំនឹងកើតក្នុងអនាគតកាល ខ្ញុំមិនមែនជានឹងមិនកើតទេ ខ្ញុំកើតក្នុងកាលឥឡូវនេះ ខ្ញុំមិនមែនជាមិនកើតទេ បពិត្រព្រះអង្គដ៏ចម្រើន កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។

[๑๑๓] *ម្នាលចិត្ត: បើជនទាំងឡាយសួរអ្នកយ៉ាងនេះថា ការបាន នូវអតីតអត្តភាពណារបស់អ្នក ការបាននូវអត្តភាពនោះរបស់អ្នក ជាសភាវៈពិត ចំណែកអនាគត និងបច្ចុប្បន្ន ជាការសូន្យទទេ ការបាននូវអនាគត-អត្តភាពណារបស់អ្នក ការបាននូវអត្តភាពនោះរបស់អ្នក ជាសភាវៈពិត ចំណែកអតីត និងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវបច្ចុប្បន្ន-អត្តភាពណារបស់អ្នក ក្នុងកាលឥឡូវនេះ ការបាននូវអត្តភាពនោះរបស់អ្នក ជាសភាវៈពិត ឯអតីត និងអនាគតជាការសោះសូន្យទទេឬ ម្នាលចិត្ត: កាលដែលគេសួរយ៉ាងនេះហើយ តើអ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើជនទាំងឡាយសួរខ្ញុំព្រះអង្គយ៉ាងនេះថា ការបាននូវអតីតអត្តភាពណារបស់អ្នក ការបាននូវអត្តភាពនោះរបស់អ្នកជាសភាវៈពិត ចំណែកអនាគត និងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវអនាគត-អត្តភាពណារបស់អ្នក ការបាននូវអត្តភាពនោះរបស់អ្នក ជាសភាវៈពិត ចំណែកអតីត និងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវបច្ចុប្បន្ន-អត្តភាពណារបស់អ្នក ក្នុងកាលឥឡូវនេះ ការបាននូវអត្តភាពនោះរបស់អ្នក ជាសភាវៈពិត ឯអតីត និងអនាគត ជាការសោះសូន្យទទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលគេសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះថា ការបាននូវអតីតអត្តភាពណារបស់ខ្ញុំ ការបាននូវអត្ត-ភាពនោះរបស់ខ្ញុំជា សភាវៈពិត ក្នុងសម័យនោះ ចំណែកអនាគត និងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបាននូវអនាគតអត្តភាពណារបស់ខ្ញុំ*

ការបានន្ទូវអត្តភាពនោះរបស់ខ្ញុំ ជាសភាវៈពិតក្នុងសម័យនោះ ចំណែក អតីត និងបច្ចុប្បន្ន ជាការសោះសូន្យទទេ ការបានន្ទូវបច្ចុប្បន្នអត្តភាពរបស់ ខ្ញុំក្នុងកាលឥឡូវនេះ ការបានន្ទូវអត្តភាពនោះរបស់ខ្ញុំ ជាសភាវៈពិត ឯអតីត និងអនាគត ជាការសោះសូន្យទទេ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលគេ សួរយ៉ាងហើយ ខ្ញុំព្រះអង្គគប្បីដោះស្រាយយ៉ាងនេះឯង ។

[១១៤] ម្នាលចិត្តៈ យ៉ាងនោះឯងហើយ ការបានន្ទូវឱឡារិក-អត្តភាព ក្នុងសម័យណា សម័យនោះ មិនដល់ន្ទូវការរាប់ថា បានន្ទូវមនោ-មយអត្តភាព ទាំងមិនដល់ន្ទូវការរាប់ថា បានន្ទូវអរូបអត្តភាពក្នុងសម័យនោះ ដល់ន្ទូវការរាប់ថា បានត្រឹមតែឱឡារិកអត្តភាពប៉ុណ្ណោះ ម្នាលចិត្តៈ ការបាន ន្ទូវមនោមយអត្តភាព ។បេ។ ម្នាលចិត្តៈ ការបានន្ទូវអរូបអត្តភាពក្នុងសម័យ ណា សម័យនោះ ក៏មិនដល់ន្ទូវការរាប់ថា បានន្ទូវឱឡារិកអត្តភាព ទាំងមិន ដល់ន្ទូវការរាប់ថា បានន្ទូវមនោមយអត្តភាពទេ ក្នុងសម័យនោះ ដល់ន្ទូវការ រាប់ថា បានត្រឹមតែអរូបអត្តភាពប៉ុណ្ណោះ ។ ម្នាលចិត្តៈ ប្រៀបដូចទឹកដោះ ស្រស់ (កើត) អំពីមេគោ ទឹកដោះជូរ (កើត) អំពីទឹកដោះស្រស់ ទឹក ដោះខាប់ (កើត) អំពីទឹកដោះជូរ ទឹកដោះរាវ (កើត) អំពីទឹកដោះខាប់ ទឹកដោះថ្លា (កើត) អំពីទឹកដោះរាវ ទឹកដោះស្រស់មានក្នុងសម័យណា សម័យនោះមិនដល់ន្ទូវការរាប់ថា ទឹកដោះជូរ មិនដល់ន្ទូវការរាប់ថា ទឹកដោះ ខាប់ មិនដល់ន្ទូវការរាប់ថា ទឹកដោះរាវ មិនដល់ន្ទូវការរាប់ថា ទឹកដោះថ្លា ដល់ការរាប់ថា ត្រឹមតែទឹកដោះស្រស់ប៉ុណ្ណោះ ។ សម័យណាជាទឹកដោះជូរ ។

ជាទឹកដោះខាប់ ។ ជាទឹកដោះរាវ ។ ជាទឹកដោះថ្លា សម័យនោះ មិនដល់នូវការរាប់ថា ទឹកដោះស្រស់ មិនដល់នូវរាប់ថា ទឹកដោះជូរ មិនដល់នូវការរាប់ថា ទឹកដោះខាប់ មិនដល់នូវការរាប់ថា ទឹកដោះរាវ ក្នុងសម័យនោះ ដល់នូវការរាប់ត្រឹមតែថា ទឹកដោះថ្លាប៉ុណ្ណោះ ។ ម្នាលចិត្ត: ការបាននូវឱឡារិកអត្តភាពក្នុងសម័យណា សម័យនោះ មិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាព មិនដល់នូវការរាប់ថា បាននូវអរូបអត្តភាពទេ ក្នុងសម័យនោះ ដល់នូវការរាប់ថា បានត្រឹមតែឱឡារិកអត្តភាពប៉ុណ្ណោះ ។ ម្នាលចិត្ត: ការបាននូវមនោមយអត្តភាព ។បេ។ ការបាននូវអរូបអត្តភាព ក្នុងសម័យណា សម័យនោះ មិនដល់នូវការរាប់ថា បាននូវឱឡារិកអត្តភាព មិនដល់នូវការរាប់ថា បាននូវមនោមយអត្តភាពទេ ក្នុងសម័យនោះ ដល់នូវការរាប់ថា បានត្រឹមតែអរូបអត្តភាពប៉ុណ្ណោះ ក៏យ៉ាងនោះឯង ។ ម្នាលចិត្ត: សម្តីទាំងនេះឯង ជាឈ្មោះសម្រាប់លោក ជាភាសាសម្រាប់លោក ជាវោហារបស់លោក ជាបញ្ញត្តិក្នុងលោក តថាគតរមែងពោលដែរ តែមិនប៉ះពាល់ដោយសេចក្តីប្រកាន់ទេ ។

[១១៥] *កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ចោដ្ឋបាទបរិព្វាជក ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ ។បេ។ សូមព្រះមានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់សរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះទៅ ។ ចំណែកខាងចិត្តហត្ថិសារីបុត្ត ក្រាប*

ទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចគេបើកនូវបេះដែលកំបាំង ។បេ។ ទ្រោលបំភ្លឺប្រទីបដោយគិតថា មនុស្សមានភ្នែកភ្លឺ នឹងឃើញរូបទាំងឡាយបាន ធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទាក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ ចិត្តហត្ថិសារីបុត្ត ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ ចិត្តហត្ថិសារីបុត្តដ៏មានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ដោះខ្លួនចេញចាកពួក ជាបុគ្គលតែម្នាក់ឯង ឥតមានសេចក្តីប្រមាទឡើយ ព្យាយាមដុតកិលេស បញ្ជូនចិត្តឲ្យបែរទៅកាន់ (ព្រះនិព្វាន) ពួកកុលបុត្រដែលចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចរិយៈក្នុងបច្ចុប្បន្ន មិនយូរប៉ុន្មានសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ បានដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញ ក៏បានអប់រំហើយ សោឡសកិច្ចអាត្មាអញ ក៏បានធ្វើរួចហើយ កិច្ចដទៃក្រៅពីនេះទៅទៀតគ្មានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះចិត្តហត្ថិសារីបុត្តមានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។

ពោជ្ឈបាទសូត្រទី ៩ ចប់

អដ្ឋកថា

ចោឡធាទស្សូត្រ

ចោឡធាទបរិព្វាជកកថា

[៧៧] **ឯវម្មេ សុតំ ។បេ។ សាវត្ថិយន្តិ ចោឡធាទ សុត្តំ ។** *ក្នុងបោដ្ឋបាទសូត្រនោះ មានពាក្យពណ៌នាតាមលំដាប់បទដូច្នេះ បទថា* **សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ** *សេចក្តីថា ប្រថាប់នៅក្នុងជេតវនារាម ដែលអនាថបិណ្ឌិកសេដ្ឋីសាងក្នុងឧទ្យានរបស់រាជកុមារ ព្រះនាមថា* **ជេត** *ជិតក្រុងសាវត្ថី ។ បទថា* **ចោឡធាធោ បរិព្វាជកោ** *សេចក្តីថា ឆន្នបរិព្វាជក ឈ្មោះបោដ្ឋបាទ ។ បានឮថា ក្នុងកាលជាគ្រហស្ថ បរិព្វាជកនេះជាព្រាហ្មណ៍មហាសាល ឃើញទោសក្នុងកាមទាំងឡាយ ហើយលះគំនរភោគទ្រព្យចំនួនសែសិបកោដិ បួសជាគណាចារ្យរបស់តិរ្ថិយទាំងឡាយ ។ ព្រាហ្មណ៍ និងបព្វជិតទាំងឡាយ រមែងជជែកគ្នាអំពីលទ្ធិក្នុងកន្លែងនោះ ព្រោះដូច្នោះ ទើបទីនោះឈ្មោះថា* **សមយប្បវាទកំ** *ជាទីសម្រាប់ជេញជោលលទ្ធិ ។ បានឮថា ព្រាហ្មណ៍ទាំងឡាយ មានចង្កីព្រាហ្មណ៍ រុក្ខព្រាហ្មណ៍ និងបោក្ខរសាតិព្រាហ្មណ៍ជាដើម និងបព្វជិតទាំងឡាយ មាននិគណ្ឋបរិព្វាជក និងអចេលកបរិព្វាជកជាដើម ប្រជុំគ្នាក្នុងស្ថានទីនោះ ហើយជជែកឆ្លើយឆ្លងពោលសម្តែងលទ្ធិរៀងៗ ខ្លួន ក្នុងស្ថានទីនោះ ព្រោះដូច្នោះ ទើបអារាមនោះហៅថា* **សមយប្បវាទកោ ។** *អារាមនោះឯង ឈ្មោះថា មានជួរនៃដើមទន្លាប់ព័ទ្ធជុំវិញ ព្រោះជាអារាមដែលមានជួរដើមទន្លាប់ គឺជួរដើមទន្លាប់ព័ទ្ធ*

ជុំវិញ ។ ព្រោះក្នុងអារាមនោះ មុនដំបូង មានសាលាត្រឹមតែមួយខ្នងប៉ុណ្ណោះ ក្រោយមក ជនទាំងឡាយ អាស្រ័យបរិព្វាជកអ្នកមានបុណ្យច្រើន សាងសាលាច្រើនខ្នង ព្រោះដូច្នោះ ទើបអារាមនោះ ហៅថា **ឯកសាលកោ** *ដោយអំណាចនៃឈ្មោះដែលបានមក ព្រោះអាស្រ័យសាលាមួយខ្នងនោះឯង ។ អារាមនោះសម្បូរណ៌ដោយផ្កា និងផ្លែ ជាសួនព្រះនាងមល្លិកាពជទេវីរបស់ព្រះបាទបសេនទិកោសលសាងថ្វាយ ទើបហៅថា* **មល្លិកាយារាម ។** *ក្នុងស្ថានទីសម្រាប់ដេញដោលលទ្ធិ ជួរព្រៃឈើទន្ទាប់ មានសាលាសម្រាប់សម្រាកមួយខ្នង ជាអារាមរបស់ព្រះនាងមល្លិកានោះ ។ បទថា* **បដិវសតិ** *សេចក្តីថា ទីសម្រាក ព្រោះជាទីនៅសុខស្រួល ។ ថ្ងៃមួយ ក្នុងបច្ចូសសម័យ ព្រះដ៏មានព្រះភាគ ទ្រង់ផ្សាយព្រះសព្វញ្ញុតញ្ញាណ ទ្រង់ពិចារណាមើលលោក ទ្រង់ឃើញបរិព្វាជកចូលមកខាងក្នុងសំណាញ់ គឺព្រះញាណ ទ្រង់ពិចារណាថា ចោជ្ជបាទនេះ ជ្រាកជក្នុងសំណាញ់ គឺញាណរបស់តថាគត តើមានហេតុអ្វីហ្ន៎ ដូច្នេះ ទ្រង់ឃើញថា ក្នុងថ្ងៃនេះ តថាគតនឹងទៅក្នុងអារាមនោះ លំដាប់នោះ ចោជ្ជបាទ នឹងសួរតថាគតជាលំនៀងនិងការចេញចាកនិរោធ តថាគតនឹងប្រៀបធៀបដោយញាណរបស់ព្រះពុទ្ធទាំងពួង សម្តែងទាំងពីរយ៉ាងនោះ ជាលំដាប់ចោជ្ជបាទនោះ លុះកន្លងទៅ ២-៣ ថ្ងៃ គេនឹងនាំចិត្តបរិព្វាជកដែលជាបុត្រហ្មជំរី មកកាន់សម្នាក់របស់តថាគត តថាគតនឹងសម្តែងធម៌ជាលំដាប់ជនទាំងពីរនាក់នោះ ក្នុងទីបំផុតទេសនា ចោជ្ជបាទនឹងជាតថាគតជាសរណៈ ចិត្តហត្ថិសារីបុត្តបួសក្នុងសម្នាក់របស់តថាគត នឹងសម្រេចអរហត្ត ដូច្នេះ ។ តពីនោះ ព្រះដ៏មានព្រះភាគ ទ្រង់បដិបត្តិព្រះសរីរៈអំពីព្រលឹម ទ្រង់ប្រដាប់*

អន្តរវាសកពីរជាន់ដែលជ្រលក់ល្អហើយ ទ្រង់ក្រវាត់ព្រះវត្តពន្ធចង្កេះ ដូចជាផ្នែកបន្ទោរ ទ្រង់ដណ្តប់សំពត់បង្សុកូលពណ៌មេឃ ប្រដូចជាមហាមេឃ ឡោមព័ទ្ធជុំវិញភ្នំយុគន្ធរ ដូច្នោះ ទ្រង់ប្រជាប់បាត្រសិលាដែលមានតម្លៃច្រើន ដោយព្រះអង្សាខាងឆ្វេង ទ្រង់ព្រះតម្រិះថា តថាគតនឹងចូលទៅក្នុងក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ស្តេចលីលា ចេញចាកព្រះវិហារ ដូចរាជសីហ៍ចេញចាកជើងភ្នំហិមពាន្តដូច្នោះ ។ លោកសំដៅដល់អត្ថនេះ ទើបពោលថា **អថខោ ភគវា** *ជាដើម ។ បទថា* **ឯតទវោចសិ** *សេចក្តីថា ព្រះដ៏មានព្រះភាគ ទ្រង់ចូលទៅជិតទ្វារព្រះនគរហើយ ទ្រង់សម្លឹងមើលព្រះអានិត្យ ដោយការពេញព្រះទ័យរបស់ព្រះអង្គ ទ្រង់ឃើញថា វេលានៅព្រឹក ទើបមានព្រះតម្រិះនោះ ។ បទថា* **យទ្ធនាហំ** *សេចក្តីថា ជានិបាត ដូចសម្តែងសេចក្តីសង្ស័យ ។ ព្រះពុទ្ធទាំងឡាយមិនមានសេចក្តីសង្ស័យ ។ តែនោះជាចំណែកខាងដើមរបស់ព្រះបរិវិតក្កយ៉ាងនេះថា តថាគតនឹងធ្វើកិច្ចនេះ នឹងមិនធ្វើកិច្ចនេះ តថាគតនឹងសម្តែងធម៌ដល់បុគ្គលនេះ នឹងមិនសម្តែងធម៌ដល់បុគ្គលនេះ រមែងមានដល់ព្រះពុទ្ធទាំងឡាយ ។ ដោយហេតុនោះ ទើបត្រាស់ថា* **យទ្ធនាហំ** *សេចក្តីថា បើដូច្នោះ គួរតែតថាគត ។*

[๗๘] *បទថា* **ឧដ្ឋានិនិយា** *សេចក្តីថា ដែលបន្ទឺលាន់ឮខ្លាំង ។ សំឡេងនោះ ដែលបន្ទឺយ៉ាងនេះ ឈ្មោះថា ហោ ដោយអំណាចឮទៅខាងលើ ឈ្មោះថា ខ្លាំង ដោយអំណាចកងរំពងទៅកាន់ទិសទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា ដោយសំឡេងឮខ្លាំងកងរំពង ។ ពិតហើយ ចេតិយវត្ត ពោធិវត្ត អាចរិយវត្ត ឧបជ្ឈាយវត្ត ឬយោនិសោមនសិការ ដែលឈ្មោះថា គួរ*

ក្រោកឡើងធ្វើពីព្រឹក រមែងមិនមានដល់បរិព្វាជកទាំងនោះ ព្រោះហេតុនោះ បរិព្វាជកទាំងនោះ ក្រោកឡើងពីព្រឹកព្រលឹម ហើយអង្គុយក្នុងទីមានកម្តៅថ្ងៃស្រទន់ ប្រារព្ធដល់អវយវៈ មានដៃ និងជើងជាដើម នៃគ្នានិងគ្នា យ៉ាងនេះថា ដៃរបស់អ្នកនេះល្អ ជើងរបស់អ្នកនេះល្អ ឬប្រារព្ធដល់ពណ៌សម្បុរ របស់ស្រីប្រុស ក្មេងប្រុស និងក្មេងស្រីទាំងឡាយ ឬប្រារព្ធដល់វត្ថុជទៃដែលញុំាងសេចក្តីត្រេកអរក្នុងកាម និងសេចក្តីត្រេកអរក្នុងកពជាដើម តាំងពាក្យឡើងហើយ ពោលតិរច្ឆានកថាផ្សេងៗ មាននិយាយដល់ស្តេចផែនដីជាដើម ដោយលំដាប់ ដោយហេតុនោះ ទើបលោកពោលថា ពោលតិរច្ឆានកថាផ្សេងៗ ដោយសំឡេងដែលលាន់ឮដូច្នេះ ។

បន្ទាប់អំពីនោះ ភោជ្ជបាទបរិព្វាជកសម្លឹងមើលបរិព្វាជកទាំងនោះ គិតថា បរិព្វាជកទាំងនេះ មិនគោរពចំពោះគ្នានិងគ្នាសោះ ហើយពួកយើងក៏នឹងដូចជាអំពិលអំពែកកាលព្រះអាទិត្យរះឡើង ចាប់ផ្តើមតាំងពីព្រះសមណ-គោតម ស្តេចប្រាកដឡើង សូម្បីលាភសក្ការៈរបស់ពួកយើង ក៏សាបសូន្យទៅ បើសមណគោតមសាវ័ករបស់ព្រះគោតម ឬគ្រហស្ថអ្នកទំនុកបម្រុងព្រះសមណគោតមនោះមកកាន់ស្ថានទីនេះសោត ក៏នឹងមានសេចក្តីគួរខ្មាសពន់ពេក មួយវិញទៀត ទោសរបស់បរិស័ទនឹងធ្លាក់ទៅលើប្រធានបរិស័ទប៉ុណ្ណោះដូច្នេះ ក្រឡេកមើលជុំវិញ ក៏ឃើញព្រះដ៏មានព្រះភាគ ដោយហេតុនោះ ទើបលោកពោលថា ភោជ្ជបាទបរិព្វាជក បានឃើញព្រះមានព្រះភាគ ។បេ។ បរិព្វាជកទាំងនោះ ក៏នាំគ្នាស្ងៀម ។

ក្នុងបទទាំងនោះ បទថា **សណ្ឋបេសិ** អធិប្បាយថា ឲ្យសិក្សាដល់

ទោសនៃសំឡេងនោះ គឺមិនឲ្យមានសំឡេង បញ្ឈប់សំឡេងនោះ ដោយប្រការ ដែលសំឡេងនឹងត្រូវស្ងៀមយ៉ាងល្អ ។ ដើម្បីបិទបាំងទោសរបស់សំឡេង នោះ ដូចជាបុរសចូលមកកាន់កណ្តាលបរិស័ទ រមែងស្លៀកសំពត់រៀបរយ ដណ្តប់សំពត់រៀបរយ ជូតទីដែលស្មោកគ្រោកដោយធូលី ដើម្បីបិទបាំងទោស ដូច្នោះ ។ បទថា **អប្បសទ្ទា កោណ្ឌោ** *សេចក្តីថា កាលឲ្យសិក្សា ក៏ឲ្យស្ងាត់ សំឡេងនោះ ដោយប្រការដែលសំឡេងនឹងស្ងាត់យ៉ាងល្អ ។ បទថា* **អប្ប-សទ្ទកាមោ** *សេចក្តីថា សូមធ្វើសំឡេងឲ្យតិចៗ ម្នាក់អង្គុយ ម្នាក់ឈរ រមែង មិនឲ្យប្រព្រឹត្តទៅដោយការច្របូកច្របល់ដោយពួក ។ បទថា* **ឧបសង្កមិតព្វំ មញ្ញេយ្យ** *សេចក្តីថា សម្គាល់ថា ទ្រង់នឹងចូលមកក្នុងទីនេះ ។ សួរថា ព្រោះ ហេតុអ្វី ទើបចោដ្ឋបាទបរិព្វាជកនោះ ប្រាថ្នាឲ្យព្រះមានព្រះភាគស្តេចយាង ចូលមក ឆ្លើយថា ព្រោះប្រាថ្នាសេចក្តីចម្រើនដល់ខ្លួន ។ បានឮថា បរិព្វាជក ទាំងឡាយ កាលព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ មកកាន់សម្នាក់របស់ខ្លួន ហើយ រមែងលើកខ្លួនឡើងក្នុងសម្នាក់របស់ឧបដ្ឋាកទាំងឡាយរបស់ខ្លួន រមែង តាំងខ្លួនទុកក្នុងទីខ្ពស់ថា ក្នុងថ្ងៃនេះ សមណគោតម ស្តេចយាងមកកាន់សម្នាក់ របស់ពួកយើង ព្រះសារីបុត្រក៏មក លោកមិនទៅកាន់សម្នាក់របស់អ្នកណា ឡើយ អ្នកទាំងឡាយគប្បីមើលភាពជាធំក្រៃលែង របស់ពួកយើង ដូច្នេះ ។ រមែងព្យាយាមដើម្បីសេពគប់ឧបដ្ឋាកទាំងឡាយ របស់ព្រះដ៏មានព្រះភាគផង ដែរ ។ បានឮថា បរិព្វាជកទាំងនោះ ឃើញឧបដ្ឋាកទាំងឡាយរបស់ព្រះដ៏ មានព្រះភាគហើយ ពោលយ៉ាងនេះថា គ្រូរបស់ពួកលោកទោះជាព្រះគោតម ក្តី ទោះជាសាវ័ករបស់ព្រះគោតមក្តី ជាបុគ្គលចម្រើន រមែងមកកាន់សម្នាក់*

របស់ពួកយើង ពួកយើងព្រមព្រៀងគ្នា តែលោកទាំងឡាយ មិនចង់សម្ងឹងមើលពួកយើងសោះ មិនធ្វើសាមីចិកម្ម ពួកយើងធ្វើទុសអ្វីដល់ពួកលោកហ្ន៎ ។ មួយទៀត មនុស្សពួកខ្លះគិតថា សូម្បីព្រះពុទ្ធទាំងឡាយ រមែងទៅកាន់សម្នាក់របស់បរិព្វាជកទាំងនោះបាន នឹងទៅកាន់សម្នាក់របស់ពួកយើងបានមិនមែនឬ ចាប់តាំងពីនោះ កាលឃើញព្រះពុទ្ធហើយ ក៏មិនប្រមាទ ។

បទថា **តុណ្ហី អហោសុំ** *សេចក្តីថា ពួកបរិព្វាជកទាំងនោះ អង្គុយជុំវិញ ចោដ្ឋបាទ ហើយក៏នៅស្ងៀម ។*

[៧៩] *បទថា* **ស្វាគតំ ភន្តេ** *សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ការយាងមករបស់ព្រះដ៏មានព្រះភាគ ជាការល្អ ។ លោកសម្តែងថា កាលព្រះដ៏មានព្រះភាគយាងមក ក៏មានសេចក្តីត្រេកអរ កាលយាងទៅក៏សុបសៅ ។ សួរថា ព្រោះហេតុអ្វី ទើបចោដ្ឋបាទទូលថា បពិត្រព្រះអង្គដ៏ចម្រើន អស់វេលាយូរសូម្បីក្នុងកាលមុន ព្រះដ៏មានព្រះភាគស្តេចគង់ទៅក្នុងទីនោះឬ ឬយ៉ាងថា ទ្រង់មិនគង់ទៅឡើយ ។ មនុស្សទាំងឡាយ រមែងរាក់ទាក់ដោយពាក្យគួរស្រឡាញ់ជាដើមយ៉ាងនេះថា លោកទៅណាមកណា លោកវង្វេងផ្លូវឬ លោកមកយូរហើយឬ ដូច្នេះ ព្រោះហេតុនោះ ទើបចោដ្ឋបាទទូលយ៉ាងនោះ ។ កាលទូលយ៉ាងនេះហើយ ជាអ្នកមិនអង្គុយដោយភាពរឹងត្អឹងដោយមានះ ក្រោកចាកអាសនៈ ហើយធ្វើការទទួលព្រះដ៏មានព្រះភាគ ។ ព្រោះថា ឃើញព្រះដ៏មានព្រះភាគ ទ្រង់យាងចូលទៅហើយ មិនអាចធនាដោយអាសនៈ ឬមិនធ្វើការឱនលំទោន ជាការក្រ ។ ព្រោះហេតុអ្វី ព្រោះជាអ្នកមានត្រកូលខ្ពស់ៗបរិព្វាជកនេះ ទះអាសនៈដែលខ្ជិនអង្គុយហើយកាលទូល*

អរាធនាព្រះដ៏មានព្រះភាគដោយអាសនៈ បានទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ និមន្តគង់លើអាសនៈដែលរៀបចំស្រាប់នេះ ដូច្នេះ ។

បទថា **អន្តរាកថា វិប្បកតា** *សេចក្តីថា ទ្រង់សម្តែងដោយព្រះសព្វញ្ញុតាតាំងពីពួកអ្នកអង្គុយមក ជរាបដល់តថាគតមកដល់ សន្ទនាគ្នារឿងអ្វីដែលផ្អាកទុកក្នុងចន្លោះនោះ គឺពាក្យអ្វីដែលនៅមិនទាន់ចប់ ព្រោះហេតុតថាគតមកដល់ អ្នកទាំងឡាយចូរប្រុងចុះ តថាគតនឹងនាំពាក្យនោះសម្តែងឲ្យចប់ ។ លំដាប់នោះ បរិព្វាជកពោលថា កថានោះ ជាកថាគ្មានប្រយោជន៍ មិនមានសារៈ អាស្រ័យវដ្តៈ មិនគួរនាំមកពោលចំពោះព្រះភក្ត្របស់ព្រះអង្គ ទើបទូលពាក្យជាដើមថា ពាក្យដែលយើងខ្ញុំទាំងឡាយ ប្រជុំគ្នានិយាយអម្បាញ់មិញនេះ ទុកស្រេះសិនចុះ ។*

អភិសញ្ញានិរោធកថា

[๘๐] *បទថា* **តិដ្ឋតេសា ភន្តេ** *សេចក្តីថា បរិព្វាជកពោលថា បើព្រះដ៏មានព្រះភាគប្រថ្នានឹងស្តាប់សោត កថានោះ ទ្រង់នឹងស្តាប់ខាងក្រោយក៏បាន មិនលំបាក ប្រយោជន៍ដោយកថានេះ មិនមានដល់ពួកខ្ញុំព្រះអង្គ តែពួកខ្ញុំព្រះអង្គ បានការយោងមករបស់ព្រះដ៏មានព្រះភាគហើយ នឹងទូលសួរដល់ហេតុការណ៍ល្អយ៉ាងដទៃវិញ ។ បន្ទាប់អំពីនោះ កាលនឹងទូលសួរហេតុការណ៍នោះ ទើបទូលពាក្យជាដើមថា* **បុរិមានិ ភន្តេ** *ដូច្នេះ ។ ក្នុងបទទាំងនោះបទថា* **កោតុហាលសាលាយំ** *សេចក្តីថា សាលាតែមួយខ្នង ឈ្មោះថាសាលាអ៊ូអរមិនមាន តែសមណៈ និងព្រាហ្មណ៍ទាំងឡាយ អ្នកកាន់លទ្ធិផ្សេងៗ ពោលពាក្យប្រកែកផ្សេងៗ ឲ្យប្រព្រឹត្តទៅក្នុងសាលាណា សាលានោះ*

ហៅថា **កោតុហលសាលា** ព្រោះជាទីកន្លែងកើតភាពអ៊ូអរ ច្របូកច្របល់ ដល់ជនជាច្រើនថា អ្នកនេះពោលអ្វី អ្នកនេះពោលអ្វី។ បទថា **អភិ** ក្នុងបទ ថា **អភិសញ្ញានិរោធេ**នោះ ត្រឹមតែឧបសគ្គ ។ បទថា **សញ្ញានិរោធេ** សេចក្តី ថា កថាកើតឡើងហើយក្នុងចិត្តនិរោធ គឺខណិកនិរោធ ។ ពាក្យថា ក្នុង សញ្ញានិរោធនេះ ជាហេតុការណ៍កើតឡើងនៃកថានោះ បានឮថា ក្នុងកាល ណាព្រះដ៏មានព្រះភាគសម្តែងជាតក ឬទ្រង់បញ្ញត្តសិក្ខាបទ ក្នុងកាលនោះ សំឡេងសរសើរកិត្តិគុណរបស់ព្រះដ៏មានព្រះភាគ ក៏ផ្សាយខ្ចរខ្ចាយទៅទូទាំង ជម្ពូទ្វីប ។ ពួកតិរ្ថិយបានស្តាប់កិត្តិគុណនោះហើយ ក៏ធ្វើកិរិយាផ្ទុយនឹងព្រះ ដ៏មានព្រះភាគថា បានឮថា ព្រះគោតមដ៏ចម្រើន ទ្រង់សម្តែងបុព្វចរិយា ពួក យើងមិនអាចដើម្បីពោលបុព្វចរិយាយ៉ាងដូច្នេះខ្លះ ដូច្នោះខ្លះឬ ពោលលទ្ធិ ចន្លោះកពមួយ បញ្ញត្តសិក្ខាបទយ៉ាងណាមួយដល់សាវ័ករបស់ខ្លួនថា ព្រះ គោតមដ៏ចម្រើនបានបញ្ញត្តិសិក្ខាបទហើយ ពួកយើងនឹងមិនអាចបញ្ញត្តិឬ ។ ក្នុងកាលនោះ ព្រះដ៏មានព្រះភាគ ប្រថាប់គង់ត្រង់កណ្តាលបរិស័ទទាំង ៨ ទ្រង់សម្តែងនិរោធកថា ។

ពួកតិរ្ថិយបានស្តាប់និរោធកថានោះហើយ នាំគ្នាប្រជុំពោលថា បានឮថា ព្រះគោតមដ៏ចម្រើន ទ្រង់សម្តែងកថាឈ្មោះនិរោធ ពួកយើងក៏នឹងសម្តែង ។ ដោយហេតុនោះ ទើបលោកពោលថា កថាបានកើតហើយ ក្នុងអភិសញ្ញា-និរោធ ដូច្នេះ ។

បទថា **តត្រេកច្ចេ** សេចក្តីថា ក្នុងបណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកខ្លះ ។ ក្នុងរឿងនេះ បព្វជិតក្នុងលទ្ធិតិរ្ថិយខាងក្រៅ អ្នកដំបូងណាមួយ

ឃើញទោសក្នុងការប្រព្រឹត្តទៅរបស់ចិត្ត ចម្រើនសមាបត្តិថា ការមិនមានចិត្ត សូប់ហើយ ចុតិចាកពីលោកនេះ ទៅនៅក្នុងអសញ្ញីភពអស់ ៥០០ កប្ប ក៏មកកើតក្នុងលោកនេះទៀត កាលមិនឃើញការកើតឡើងរបស់សញ្ញា និង ហេតុក្នុងការរលត់របស់បុគ្គលនោះ ទើបពោលថា មិនមានហេតុ មិនមាន បច្ច័យ ។

អ្នកទីពីរបដិសេធពាក្យពោលនោះ កាន់យកសេចក្តីដែលមិគសិង្គតាបស មិនមានសញ្ញា ទើបពោលថា មាននៅខ្លះ ប្រាសទៅខ្លះ ។ បានឮថា មិគសិង្គ-តាបសមានតបៈក្តៅ មានតបៈខ្លាំងក្លា មានឥន្ទ្រិយតាំងមាំយ៉ាងក្រៃលែង ។ ដោយតេជៈនៃសីលរបស់តាបសនោះ ធ្វើឲ្យវិមានរបស់សក្កទេវរាជក្តៅ ។ សក្កទេវរាជទ្រង់គិតថា តាបសត្រូវការតំណែងជាសក្កៈហ្ន៎ ទើបបញ្ជូនទេវ-កញ្ញានាមថា អលម្ពុសា ដោយទេវបញ្ជាថា នាងចូរទៅទម្លាយតបៈរបស់តាបស ។ ទេវកញ្ញានោះ ទៅហើយក្នុងទីនោះ ។ តាបសឃើញទេវកញ្ញាក្នុងថ្ងៃដំបូង ក៏ចៀសទៅកាន់បណ្ណសាលា ។ ក្នុងថ្ងៃទីពីរ តាបសត្រូវនីវរណៈគឺកាមឆន្ទៈរបរឹត ទើបចាប់ដៃទេវកញ្ញានោះ ។ តាបសនោះត្រូវទិព្វសម្ផស្ស នោះ ក៏អស់សញ្ញា កាលកន្ទងទៅបីឆ្នាំ ទើបត្រឡប់បានសញ្ញា ។ សមណ-ព្រាហ្មណ៍មួយពួក ឃើញមិគសិង្គតាបសនោះហើយ មានទិដ្ឋិតាំងមាំ សម្គាល់ថា ចេញចាកនិរោធដោយកន្ទងទៅបីឆ្នាំ ទើបពោលយ៉ាងនោះ ។

បុគ្គលទីបីបដិសេធពាក្យពោលរបស់អ្នកទីពីរនោះ ប្រាថ្នាដល់ការ ប្រកបអថ៌ន ទើបពោលថា ទាញចូលខ្លះ ដកចេញខ្លះ ដូច្នេះ ។ បានឮថា ពួកអថ៌ន ប្រកបអថ៌ន សម្តែងសត្វឲ្យដូចជាចាប់សីសៈ ជាចាប់ដៃ និងដូចស្ទាប់

ហើយ ។ សមណព្រាហ្មណ៍មួយពួក ឃើញសត្វនោះជាប្រក្រតីទៀត ទើបមានទិដ្ឋិថា សត្វនេះចេញចាកនិរោធ ទើបពោលយ៉ាងនោះ ។

បុគ្គលទីបួនជំទាស់បុគ្គលទីបី ប្រាថ្នាដល់ការស្រវឹង និងការដេកលក់របស់នាងយក្ខទាសីទាំងឡាយ ទើបពោលពាក្យជាដើមថា អ្នកទាំងឡាយដ៏ចម្រើន ព្រោះថា ពួកទេវតាមានឫទ្ធិច្រើន មានអានុភាពច្រើនក៏មាន ដូច្នេះ ។ បានឮថា ពួកយក្ខិនីទាសី ធ្វើការបម្រើទេវតាអស់រាត្រីដោយការរាំ និងច្រៀង ក្នុងពេលអរុណរះ ក៏ផឹកសុរាមួយភាជន៍រមៀលទៅមក ហើយដេកលក់ ភ្ញាក់កណ្តាលថ្ងៃ ។ សមណព្រាហ្មណ៍មួយពួក ឃើញហេតុការណ៍នោះ ក៏មានទិដ្ឋិសម្គាល់ថា ក្នុងវេលាដេកលក់ប្រកបដោយនិរោធ ក្នុងវេលាភ្ញាក់ក៏ចេញពីនិរោធ ដូច្នេះ ទើបពោលយ៉ាងនោះ ។

ចោដ្ឋបាទបរិព្វាជកនេះ មានជាតិជាបណ្ឌិត ដោយហេតុនោះ គាត់មានសេចក្តីក្តៅក្រហាយ ព្រោះស្តាប់កថានេះ កថារបស់សមណព្រាហ្មណ៍ទាំងនោះ ដូចជាពាក្យរបស់ពពែគ រមែងដល់និរោធបួននោះ និងធម្មតានិរោធនេះ គប្បីមានតែម្យ៉ាង មិនគប្បីមានច្រើន សូម្បីនិរោធនោះ គប្បីជាយ៉ាងដទៃតែម្យ៉ាងប៉ុណ្ណោះ បរិព្វាជកដែលអ្នកដទៃមិនអាចនឹងឲ្យដឹងបាន ក្រៅពីព្រះសព្វញ្ញូ ទើបវត្កដល់ព្រះទសពលប៉ុណ្ណោះថា បើព្រះដ៏មានព្រះភាគនឹងមានក្នុងទីនេះ ក៏នឹងធ្វើនិរោធឲ្យប្រាកដក្នុងថ្ងៃនេះឯង ដូចជុតប្រទីបរាប់ពាន់ឲ្យភ្លឺសន្ធោសន្ធៅថា នេះនិរោធ នេះមិនមែននិរោធ ព្រោះដូច្នោះ ទើបទូលពាក្យជាដើមថា **តស្ស មយ្ហំ ភន្តេ ។**

ក្នុងបទទាំងនោះ បទថា **អហោ ន្វូន** *ទាំងពីរបទជានិបាតចុះក្នុងអត្ថថា*

ព្រួកជល់ ដោយហេតុនោះ ចោដ្ឋបាទកាលព្រួកជល់ព្រះដ៏មានព្រះភាគ ទើប
មានសតិយ៉ាងនេះថា **អហោ ន្វូន ភគវា អហោ ន្វូន សុគតោ** *ឱព្រះដ៏*
មានព្រះភាគ គួរឲ្យជ្រះថ្លាពិតហ្ន៎ ឱព្រះសុគតគួរឲ្យជ្រះថ្លាពិតហ្ន៎ ។ ក្នុងបទថា
យោ ឥមេសំ *មានអធិប្បាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គណា ទ្រង់*
ឈ្វាសវៃ គឺឈ្វាសដោយល្អ វាងវៃ ឈ្វាសក្នុងនិរោធធម៌ទាំងនោះ ឱហ្ន៎
ព្រះដ៏មានព្រះភាគអង្គនោះ គប្បីត្រាស់ ឱហ្ន៎ ព្រះសុគតព្រះអង្គនោះគប្បី
ត្រាស់ ។ បទថា **បកតញ្ញូ** *សេចក្តីថា ព្រះដ៏មានព្រះភាគជឿថា ទ្រង់ដឹង*
ប្រក្រតី គឺព្រោះព្រះអង្គទ្រង់ឈ្វាសជាប់ជានិច្ច ព្រោះដូច្នោះ ទើបព្រះអង្គ
ព្រះនាមថា **បកតញ្ញូ** ។

អហេតុកសញ្ញុប្បាទនិរោធកថា

បរិព្វាជក កាលនឹងទូលសូមថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ
មិនដឹង ព្រះអង្គទ្រង់ដឹង មេត្តាត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គចុះ ទើបពោល
ពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន អកិសញ្ញានិរោធនោះ តើដូចម្តេច ។

[๘๑-๘๗] *កាលព្រះដ៏មានព្រះភាគទ្រង់សម្តែង ទើបត្រាស់ថា* **តត្រ**
ចោដ្ឋបាទ *ជាដើម ។ ក្នុងបទទាំងនោះ បទថា* **តត្រ** *សេចក្តីថា ក្នុងសមណ-*
ព្រាហ្មណ៍ទាំងនោះ ។

បទថា **អាឯិតោ វ តេសំ អបរទ្ធំ** *សេចក្តីថា ការឃើញរបស់សមណ-*
ព្រាហ្មណ៍ទាំងនោះ ខុសតាំងអំពីដើមនេះឯង ។ លោកសម្តែងថា ខុសក្រាំង
ក្រាត់ត្រង់ទីកណ្តាលផ្ទះនោះឯង ។ ហេតុក្តី បច្ច័យក្តី ក្នុងបទនេះថា **សហេតុ**

សប្បច្ចយា ជាឈ្មោះរបស់ហេតុការណ៍នោះឯង សេចក្តីថា មានការណ៍ ។ កាលទ្រង់សម្តែងការណ៍នោះ ទើបត្រាស់ថា **សិក្ខា ឯកា** ។ ក្នុងបទទាំងនោះ បទថា **សិក្ខា ឯកា សញ្ញា ឧប្បជ្ជតិ** សេចក្តីថា សញ្ញាខ្លះ រមែងកើតឡើង ព្រោះសិក្សា ។ បទថា **កា ច សិក្ខាតិ ភគវា អវោច** សេចក្តីថា សិក្ខានោះយ៉ាងណា ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ដោយអំណាចការសួរ ព្រោះមានព្រះបំណងនឹងឲ្យសិក្ខានោះពិស្តារ ។

ម្យ៉ាងទៀត ព្រោះសិក្ខាមាន ៣ ប្រការ គឺអធិសីលសិក្ខា អធិចិត្ត-សិក្ខា អធិប្បញ្ញាសិក្ខា ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសិក្ខាទាំងនោះ ទើបទ្រង់ផ្តើមតន្តិធម៌ ចាប់ផ្តើមតាំងពីការកើតឡើងរបស់ព្រះអង្គ ដើម្បីទ្រង់សម្តែងនិរោធកើតឡើង ដោយមានហេតុព្រោះសញ្ញា ទើបត្រាស់ថា ម្នាលភោជដ្ឋបុត្រ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោកនេះជាដើម ។ បណ្តាទាំង ៣ សិក្ខា នោះ ២ សិក្ខា គឺអធិសីលសិក្ខា អធិចិត្តសិក្ខាប៉ុណ្ណោះ មកដោយសង្ខេប ចំណែកសិក្ខាទី ៣ គប្បីជ្រាបថា មកហើយ ព្រោះជាសិក្ខាដែលជាប់ទាក់ទងដោយអំណាចនៃសម្មាទិដ្ឋិ និងសម្មាសង្កប្ប ក្នុងព្រះបាលីនេះថា ម្នាលភោជដ្ឋបុត្រ តថាគតព្យាករដូច្នេះឯងថា នេះបដិបទាជាដំណើរទៅកាន់ធម៌រម្ងាប់ទុក្ខ ដូច្នេះឯង ។

បទថា **កាមសញ្ញា** បានដល់ រាគៈដែលលាយដោយកាមគុណ ៥ ខ្លះ កាមរាគៈដែលកើតឡើងមិនស្មើខ្លះ ។ ទាំងពីរយ៉ាងនោះ រាគៈដែលលាយដោយកាមគុណ ៥ រមែងកម្ចាត់ដោយអនាគាមិមគ្គ ចំណែកកាមរាគៈ ដែលកើតឡើងមិនស្មើ រមែងប្រព្រឹត្តទៅក្នុងឋាននេះ ព្រោះដូច្នោះ បទថា **តស្ស**

យា បុរិមា កាមសញ្ញា ទើបមានអត្ថថា សញ្ញាណារបស់ភិក្ខុនោះ ដែលប្រកបព្រមដោយបឋមជ្ឈាន គប្បីហៅថា សញ្ញាទាក់ទងដោយកាម មានក្នុងកាលមុន ព្រោះដូចគ្នានឹងកាមសញ្ញា ដែលធ្លាប់កើតក្នុងកាលមុន សញ្ញានោះរមែងរលត់ និងដែលមិនទាន់កើត ក៏រមែងមិនកើត ។ បទថា **វិវេកជប្បីតិ-សុខសុខុមសច្ចសញ្ញា តស្មឹ សមយេ ហោតិ** សេចក្តីថា សញ្ញាដែលល្អិតពោល គឺមានបីតិ និងសុខដែលកើតអំពីវិវេក ក្នុងសម័យបឋមជ្ឈាននោះជាសច្ចៈ គឺមានពិត ។ ម្យ៉ាងទៀត សញ្ញានោះ ដែលល្អិតដោយអំណាចលះបង់អង្គដែលគ្រោតគ្រោត មានកាមឆន្ទៈជាដើម និងឈ្មោះថា ជាសច្ចៈ ព្រោះជារបស់មានពិត ព្រោះដូច្នោះ ទើបសញ្ញានោះ ជាសញ្ញាក្នុងសច្ចៈដែលល្អិត សញ្ញាក្នុងសច្ចៈដែលល្អិតដែលសម្បយុត្តដោយបីតិ និងសុខដែលកើតអំពីវិវេក ព្រោះដូច្នោះ ទើបឈ្មោះថា **វិវេកបីតិ សុខសុខុមសច្ចសញ្ញា** សញ្ញានោះរបស់ភិក្ខុមាន ព្រោះដូច្នោះ ទើបភិក្ខុនោះ ឈ្មោះថា មានសញ្ញាក្នុងសច្ចៈដែលល្អិត មានបីតិ និងសុខដែលកើតអំពីវិវេក គប្បីឃើញអត្ថក្នុងបទនោះមានប្រមាណប៉ុណ្ណេះ ។ ក្នុងបទទាំងពួងក៏មានន័យដូច្នោះ ។

ក្នុងបទថា **ឯវំបិ សិក្ខា** នោះ សេចក្តីថា ព្រោះភិក្ខុចូលដល់ និងអធិដ្ឋានបឋមជ្ឈានសិក្សា ព្រោះដូច្នោះ បឋមជ្ឈាននោះហៅថា សិក្ខា ព្រោះជាកិច្ចដែលគួរសិក្សាយ៉ាងនេះ សញ្ញាក្នុងសច្ចៈដែលល្អិត មានបីតិ និងសុខដែលកើតអំពីវិវេកខ្លះ រមែងកើតឡើងយ៉ាងនេះ ដោយបឋមជ្ឈាន ពោល គឺសិក្ខានោះ កាមសញ្ញាខ្លះ រមែងរលត់យ៉ាងនេះ ។ បទថា **អយំ សិក្ខាតិ ភគវា អវោច** សេចក្តីថា ព្រះដ៏មានព្រះភាគត្រាស់ថា នេះក៏ជាសិក្ខាម្យ៉ាង គឺ

បឋមជ្ឈាន ។ គប្បីឃើញអត្តក្នុងបទទាំងពួង ដោយទំនងនោះ ។

[๘๘] *ព្រោះការពិចារណាដោយអង្គនៃសមាបត្តិទី ៨ រមែងមានដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ មិនមានដល់សាវកទាំងឡាយ សូម្បីព្រះសារីបុត្រ តែការពិចារណាដោយរួមក្រុមប៉ុណ្ណោះ រមែងមានដល់សាវកទាំងឡាយ និងការពិចារណាដោយអង្គយ៉ាងនេះថា សញ្ញា សញ្ញា នេះបានលើកឡើងហើយព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលចោដ្ឋបាទ ភិក្ខុណា ក្នុងសាសនានេះ ។បេ។ បាននូវសញ្ញាជាកំពូល ដូច្នេះ ដើម្បីទ្រទ្រង់សម្តែងអាកិញ្ចញ្ញាយតនសញ្ញាដ៏កំពូល ហើយសម្តែងសញ្ញានោះទៀតថា កំពូលសញ្ញា ។*

ក្នុងបទទាំងនោះ បទថា **យតោ ខោ ចោដ្ឋបាទ ភិក្ខុ** *សេចក្តីថា ម្នាលចោដ្ឋបាទ ភិក្ខុណា ។ បទថា* **สกสญฺญี โหติ** *សេចក្តីថា ភិក្ខុក្នុងសាសនានេះ មានសកសញ្ញា ។ មួយទៀត បាលីក៏យ៉ាងនេះ សេចក្តីថា ភិក្ខុមានសញ្ញាដោយសញ្ញា ក្នុងបឋមជ្ឈានរបស់ខ្លួន ។ បទថា* **សោ តតោ អមุตฺร តតោ อมุตฺร** *សេចក្តីថា ភិក្ខុនោះ មានសកសញ្ញាដោយឈានសញ្ញានោះៗ យ៉ាងនេះ គឺចេញចាកបឋមជ្ឈាននោះហើយ មានសញ្ញាក្នុងទុតិយជ្ឈានចេញចាកទុតិយជ្ឈាននោះហើយ មានសញ្ញាក្នុងតតិយជ្ឈាន ដោយលំដាប់ទៅដល់កំពូលសញ្ញា ។ អាកិញ្ចញ្ញាយតនៈ ហៅថា* **សញฺญคฺค** *គឺកំពូលសញ្ញា ។ ព្រោះហេតុអ្វី ព្រោះជាអង្គទីបំផុតនៃសមាបត្តិ ដែលមាននាទីធ្វើកិច្ចជាលោកិយ ។ ភិក្ខុតាំងនៅក្នុងអាកិញ្ចញ្ញាយតនសមាបត្តិហើយ រមែងចូលដល់នេវសញ្ញានាសញ្ញាយតនសមាបត្តិខ្លះ និរោធសមាបត្តិខ្លះ ។ អាកិញ្ចញ្ញ-*

យតនសញ្ញានោះ ហៅថា កំពូលសញ្ញា ព្រោះជាអង្គក្នុងទីបំផុតនៃសមាបត្តិ ដែលមាននាទីធ្វើកិច្ចជាលោកិយ ដោយប្រការដូច្នេះ សេចក្តីថា កិក្ខុដល់ គឺ សម្រេចកំពូលសញ្ញានោះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងអកិសញ្ញានិរោធ ទើបត្រាស់ថា **តស្ស សញ្ញគ្គេ ឋិតស្ស** *ប្រែថា កាលបើកិក្ខុនោះ ឋិតនៅក្នុងសញ្ញាជាកំពូលជាដើម ។ ក្នុងបទទាំងនោះ សេចក្តីថា កិក្ខុចូលដល់ឈាន ក្នុងពីរបទថា យើងគប្បីបំណង យើងគប្បីប្រាថ្នា ឈ្មោះថា រមែងគិត គឺឲ្យសម្រេចរឿយៗ ។ កិក្ខុធ្វើសេចក្តីប្រាថ្នា ដើម្បីប្រយោជន៍ដល់សមាបត្តិជាន់ខ្ពស់ឡើងទៅ ឈ្មោះថា គប្បីប្រាថ្នា ។ បទថា* **ឥមា ច មេ សញ្ញា និរុជ្ឈេយ្យុំ** *សេចក្តីថា អាកិញ្ចញ្ញាយតនសញ្ញានេះ គប្បីរលត់ ។*

បទថា **អញ្ញា ច ឱឡារិកា** *សេចក្តីថា ភវង្គសញ្ញាដែលគ្រោតគ្រោតជាងគប្បីកើតទ្បើង ។ ក្នុងបទនេះថា* **សោ ន ចេវ ចេតេតិ ន ច អភិសង្ខរោតិ** *កិក្ខុនោះកាលបំណង ឈ្មោះថា មិនបំណង កាលប្រាថ្នា ឈ្មោះថា មិនប្រាថ្នាពិត ការពិចារណាដោយធ្វើទុកក្នុងចិត្តថា អញចេញចាកអាកិញ្ចញ្ញាយតនៈហើយ ចូលដល់នៅវិសញ្ញានាសញ្ញាយតនៈ តាំងនៅក្នុងវារៈចិត្តមួយ ឬពីរ រមែងមិនមានដល់កិក្ខុនេះ តែរមែងមានដើម្បីប្រយោជន៍ដល់និរោធសមាបត្តិជាន់ខ្ពស់ប៉ុណ្ណោះ ។ សេចក្តីនេះ គប្បីសម្តែងដោយការសម្លឹងមើលផ្ទះរបស់បុត្រ ។*

បានឮថា ព្រះថេរៈសួរកិក្ខុកំលោះដែលទៅដល់ផ្ទះរបស់បិតា ហើយនាំយកភោជនដ៏ប្រណីត អំពីផ្ទះរបស់បុត្រ ក្នុងកាលខាងក្រោយ មកកាន់

អាសនសាលាថា បិណ្ឌបាតប្រណីត លោកនាំមកអំពីទីណា ។ ទើបលោកប្រាប់ផ្ទះដែលបានកោជនថា មកអំពីផ្ទះឈ្មោះនោះ ។ កិកូកំលោះទៅហើយក្តី មកហើយក្តី ដោយផ្ទះបិតាណា សូម្បីការចងចិត្តរបស់លោកត្រង់ផ្ទះនោះ រមែងមិនមាន ។ ក្នុងរឿងនោះ គប្បីឃើញអាកិញ្ចញ្ញាយតនសមាបត្តិ ដូចអាសនសាលា ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ដូចជាផ្ទះរបស់បិតា និរោធសមាបត្តិដូចផ្ទះរបស់បុត្រ ការមិនពិចារណាដោយឧបាយនៃប្រាជ្ញាថា អញចេញចាកអាកិញ្ចញ្ញាយតនៈហើយ ចូលដល់នេវសញ្ញានាសញ្ញាយតនៈនឹងតាំងនៅក្នុងវារៈចិត្តមួយពីរ ហើយមនសិការដើម្បីប្រយោជន៍ដល់និរោធ-សមាបត្តិជាន់ខ្ពស់ប៉ុណ្ណោះ ប្រៀបដូចការឈរក្នុងអាសនសាលា មិនផ្ងង់ចិត្តដល់ផ្ទះរបស់បិតា ហើយប្រាប់ផ្ទះរបស់បុត្រដូច្នោះ ។ កិកូនោះ កាលបំណងក៏ឈ្មោះថា មិនបំណង កាលប្រាថ្នា ក៏ឈ្មោះថា មិនប្រាថ្នា ដោយប្រការដូច្នេះ ។

បទថា **តា ចេវ សញ្ញា** *សេចក្តីថា ឈានសញ្ញានោះ រមែងរលត់ ។ បទថា* **អញ្ញា ច** *សេចក្តីថា ទាំងកវង្គសញ្ញាយ៉ាងគ្រោតគ្រោតជនៃ រមែងមិនកើតឡើង ។ បទថា* **សោ និរោធំ ផុសតិ** *សេចក្តីថា កិកូនោះ បដិបត្តិយ៉ាងនេះ រមែងដល់ គឺរមែងបាន រមែងបានទទួលសញ្ញាវេទយិតនិរោធ ។ បទថា* **អភិ** *ក្នុងបទថា* **អនុបុព្ពាភិសញ្ញានិរោធសម្បជានសមាបត្តិ** *នោះ ត្រឹមតែជាឧបសគ្គ ។ បទថា* **សម្បជាន** *បានពោលទុកក្នុងចន្លោះនិរោធបទ ។ ក្នុងបទថា* **សម្បជានសញ្ញានិរោធសមាបត្តិ** *នោះ មានសេចក្តីតាមលំដាប់ដូច្នេះថា ក្នុងបទនោះ បទថា* **សម្បជានសញ្ញានិរោធសមាបត្តិ** *មានអត្ថ*

ពិសេសយ៉ាងនេះថា សញ្ញានិរោធសមាបត្តិក្នុងទីបំផុត រមែងមានដល់ភិក្ខុ ដែលជីងខ្លួន ឬដល់ភិក្ខុអ្នកជាបណ្ឌិតដែលជីងខ្លួន ។ ឥឡូវនេះ អ្នកដែលនៅក្នុងទីនេះ គប្បីសម្តែងនិរោធសមាបត្តិកថា ។ និរោធសមាបត្តិកថានេះ បានសម្តែងហើយ ក្នុងមាតិកាពោលអំពីអានិសង្សនៃការចម្រើនបញ្ញា ក្នុងវិសុទ្ធិ-មគ្គ ដោយអាការទាំងពួង ព្រោះដូច្នោះ គប្បីកាន់យកពីទីដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះចុះ ។

ព្រះដ៏មានព្រះភាគ ត្រាស់និរោធកថា ដល់ចោដ្ឋបាទបរិព្វាជកយ៉ាងនេះហើយ បន្ទាប់មក ដើម្បីឲ្យចោដ្ឋបាទបរិព្វាជកនោះ ទទួលជីងដល់កថានោះ មិនមានក្នុងទីដទៃ ទើបត្រាស់ថា អ្នកសម្គាល់ហេតុនោះដូចម្តេចជាដើម ។ ចំណែកបរិព្វាជកកាលទទួល ទើបទូលថា បពិត្រព្រះមានព្រះភាគ ក្នុងថ្ងៃនេះ ក្រៅអំពីកថារបស់ព្រះអង្គហើយ ខ្ញុំព្រះអង្គមិនធ្លាប់បានស្តាប់កថាដូច្នេះឡើយ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនេះ ខ្ញុំព្រះអង្គមិនធ្លាប់បានឮទេ កាលនឹងសម្តែងដល់សេចក្តីនៃកថារបស់ព្រះមានព្រះភាគ ដែលខ្លួនបានរៀនដោយគោរពទៀត ទើបទូលថា ខ្ញុំព្រះអង្គទើបតែនឹងជីងនូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយអាការយ៉ាងនេះឯងជាដើម ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់អនុញ្ញាតដល់បរិព្វាជកនោះថា អ្នកចូរទទួលដោយល្អចុះ ទើបត្រាស់ថា ម្នាលចោដ្ឋបាទ យ៉ាងនេះ ... ។

[៨៩] គ្រានោះ បរិព្វាជកគិតថា អាកិញ្ចញ្ញាយតនៈដែលព្រះមានព្រះភាគត្រាស់ថា កំពូលសញ្ញា អាកិញ្ចញ្ញាយតនៈប៉ុណ្ណោះហ្ន៎ ជាកំពូល

សញ្ញា ឬថា នៅមានកំពូលសញ្ញាក្នុងសមាបត្តិដ៏សេសទៀត កាលនឹងទូលសួរអត្ថនោះ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់បញ្ញត្តនូវសញ្ញាជាកំពូលតែមួយយ៉ាងប៉ុណ្ណោះទេ ឬទ្រង់បញ្ញត្តនូវសញ្ញាជាកំពូលច្រើនយ៉ាងជាដើម ។ ចំណែកព្រះមានព្រះភាគ ទ្រង់ដោះស្រាយពាក្យសួររបស់បរិព្វាជកនោះហើយ ។ បណ្តាបទទាំងនោះ បទថា **បុថូបិ** បានដល់ច្រើនក៏មាន ។ បទថា **យថា យថា ទោ ចោជ្ជចាធ និរោធំ ជុសតិ** សេចក្តីថា ដោយកសិណណាមួយ ក្នុងបណ្តាកសិណទាំងឡាយ មានបឋវីកសិណជាដើម ឬដោយឈានណាមួយ បណ្តាឈានទាំងឡាយ មានបឋមជ្ឈានជាដើម ។ លោកពោលយ៉ាងនេះថា បើភិក្ខុចូលដល់បឋវីកសិណសមាបត្តិ ដោយបឋវីកសិណជាហេតុត្រឹមតែម្តង រមែងដល់សញ្ញានិរោធ មុនកំពូលសញ្ញាក៏មាន បើចូលដល់ពីរដង បីដង រយដង ពាន់ដង ឬសែនដង រមែងដល់សញ្ញានិរោធមុន កំពូលសញ្ញាក៏មានដល់ ១ សែន ។ ក្នុងកសិណដ៏សេសទាំងឡាយក៏មានន័យដូចគ្នា ។ ក្នុងឈានទាំងឡាយ ក៏ចូលដល់សញ្ញានិរោធមុន ដោយបឋមជ្ឈានជាហេតុត្រឹមតែតែម្តង កំពូលសញ្ញា ក៏មានតែម្តង បើចូលដល់សញ្ញានិរោធមុនពីរដង បីដង រយដង ពាន់ដង ឬសែនដង កំពូលសញ្ញាក៏មានដល់សែនដង ។ ក្នុងឈានសមាបត្តិដ៏សេសទាំង-ឡាយក៏ន័យនេះ ។ កំពូលសញ្ញា រមែងមានមួយ ដោយអំណាចការចូលដល់ត្រឹមតែម្តង ឬព្រោះសង្ត្រោះវារៈទាំងពួង ដោយលក្ខណៈនៃការដឹង ។ កំពូលសញ្ញា រមែងមានច្រើន ដោយអំណាចការចូលដល់រឿយៗ ។

[៩០] បទថា **សញ្ញា នុ ទោ ភន្តេ** សេចក្តីថា បរិព្វាជកទូលសួរថា

បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាកើតមុន ញាណកើតក្រោយ ឬញាណកើតមុន សញ្ញាកើតក្រោយ ។ ព្រះមានព្រះភាគ ទ្រង់ព្យាករដល់បរិព្វាជកនោះថា ម្នាលឧោដ្ឋបាទ សញ្ញានោះឯងកើតមុន ។ បណ្តាបទទាំងនោះ បទថា **សញ្ញា** បានដល់ ឈានសញ្ញា ។ បទថា **ញាណំ** បានដល់ វិបស្សនាញាណ ។ នយម្យ៉ាងទៀត បទថា **សញ្ញា** បានដល់ វិបស្សនា ។ បទថា **ញាណំ** បានដល់ មគ្គសញ្ញា ។ នយម្យ៉ាងទៀត បទថា **សញ្ញា** បានដល់ មគ្គសញ្ញា ។ បទថា **ញាណំ** បានដល់ ផលញ្ញាណ ។ ព្រះមហាសិវត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា ភិក្ខុទាំងនេះនិយាយអ្វី ឧោដ្ឋបាទបានទូលសួរនិរោធចំពោះព្រះដ៏មានព្រះភាគមកហើយ ឥឡូវនេះ កាលនឹងទូលសួរដល់ការចេញចាកនិរោធ ទើបទូលថា បពិត្រព្រះដ៏មានព្រះភាគ កាលភិក្ខុចេញចាកនិរោធ អរហត្តផលសញ្ញាកើតមុន ឬថា បច្ចវេក្ខណញ្ញាណកើតមុន ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ដល់បរិព្វាជកនោះថា ផលសញ្ញាកើតមុន បច្ចវេក្ខ-ណញ្ញាណកើតពេលក្រោយ ព្រោះដូច្នោះ ម្នាលឧោដ្ឋបាទ សញ្ញានោះឯងកើតមុន ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សញ្ញុប្បាទា** សេចក្តីថា ការកើតឡើងនៃ បច្ចវេក្ខណញ្ញាណ រមែងមានយ៉ាងនេះថា ព្រោះអរហត្តផលសញ្ញាកើតឡើង ទើបអរហត្តផលនេះកើតក្រោយ ។ បទថា **ឥទប្បច្ចយា កិរ មេ** សេចក្តីថា បានឮថា បច្ចវេក្ខណញ្ញាណបានកើតឡើងហើយដល់អញ ព្រោះផលសមាធិ សញ្ញាជាបច្ចយ ។

អត្តសញ្ញា

[៩១-៩៤] ឥឡូវនេះ ជ្រូកស្រុកត្រូវឲ្យងូតទឹកក្រអូប លាបស្រឡាប ដោយគ្រឿងក្រអូប ប្រដាប់ដោយកម្រងផ្កា សូម្បីលើកឲ្យដេកលើទីដេកដែលជាសិរី ក៏មិនបានសេចក្តីសុខ រមែងស្ទុះទៅកាន់ទីស្មោកគ្រោកដោយរហ័ស នឹងបានសេចក្តីសុខអំពីណា បរិព្វាជកក៏យ៉ាងនោះដែរ ត្រូវព្រះមានព្រះភាគឲ្យងូត លាបស្រឡាប ប្រដាប់ដោយទេសនាដែលប្រកបដោយត្រៃលក្ខណ៍ដ៏ល្អិតសុខុម លើកឡើងកាន់ទីដេកដែលជាសិរី គឺនិរោធកថា កាលមិនបានសេចក្តីសុខក្នុងនិរោធកថានោះ កាន់យកលទ្ធិរបស់ខ្លួនដូចគ្នានឹងទីស្មោកគ្រោក កាលនឹងទូលអត្តនោះឯង ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាឈ្មោះថា ខ្លួនរបស់បុរសដូច្នេះជាដើម លំដាប់នោះព្រះដ៏មានព្រះភាគ ទ្រង់កាន់មតិបន្តិចបន្តួចរបស់បរិព្វាជកនោះ មានព្រះបំណងនឹងព្យាករ ទើបត្រាស់ថា អ្នកជឿថា ខ្លួនដូចម្តេចជាដើម ។ ដោយបរិព្វាជកនោះ ជាអ្នកមានលទ្ធិយ៉ាងនេះថា ខ្លួនមិនមានរូប ទើបគិតថា ព្រះដ៏មានព្រះភាគ ទ្រង់ឈ្វាសល្អក្នុងការសម្តែង ព្រះអង្គគង់មិនកម្ចាត់លទ្ធិរបស់អញតាំងអំពីខាងដើម កាលនឹងនាំលទ្ធិរបស់ខ្លួន ទើបទូលថា ខ្លួនដ៏គ្រោតគ្រោតមានរូប ... ជាដើម ។ កាលព្រះដ៏មានព្រះភាគទ្រង់សម្តែងទោសក្នុងលទ្ធិនោះ ដល់បរិព្វាជកនោះ ទើបត្រាស់ពាក្យជាដើមថា ខ្លួនរបស់អ្នកដ៏គ្រោតគ្រោតមានរូប ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឃវំ សន្តំ** សេចក្តីថា កាលបើហេតុយ៉ាងនេះមាន ។ ពិតហើយ ពាក្យនោះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ម្យ៉ាងទៀត ក្នុងបទថា **ឃវំ សន្តំ** មានអត្តដូច្នេះថា ។ លោកពោលថា ព្រោះខន្ធទី ៤ កើតព្រមគ្នា រលត់ព្រមគ្នា សញ្ញាណាកើត សញ្ញានោះរលត់ ក៏ព្រោះអាស្រ័យគ្នា

នឹងគ្នា សញ្ញាជនៃកើត និងសញ្ញាជនៃរលត់ ។

ឥឡូវនេះ បរិព្វាជកកាលសម្តែងលទ្ធិជនៃ ទើបពោលពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿថា ខ្លួនសម្រេចដោយចិត្ត ដូច្នេះជាដើម ។ ក្នុងលទ្ធិនោះ ឲ្យទោសហើយ កាន់យកលទ្ធិជនៃ លះលទ្ធិជនៃ កាលនឹងពោលលទ្ធិរបស់ខ្លួនក្នុងកាលឥឡូវនេះ ទើបទូលថា ខ្លួនមិនមានរូបដោយពិត ដូច្នេះជាដើម ដូចមនុស្សឆ្កួតកាន់សញ្ញាជនៃ លះបង់សញ្ញាជនៃ ជរាបដល់សញ្ញារបស់គេមិនតាំងមាំ តែនឹងពោលពាក្យដែលគួរពោលក្នុងកាលដែលមានសញ្ញាតាំងមាំ ។ ក្នុងលទ្ធិនោះ ព្រោះបរិព្វាជក ប្រាថ្នាការកើត និងការរលត់នៃសញ្ញា តែសម្គាល់ខ្លួនថា ទៀង ព្រោះដូច្នោះ កាលព្រះមានព្រះភាគទ្រង់សម្តែងទោសដល់បរិព្វាជកយ៉ាងនោះ ទើបត្រាស់ថា កាលបើហេតុដូច្នេះមានហើយជាដើម ។

លំដាប់នោះ បរិព្វាជកមិនដឹងខ្លួនផ្សេងៗ នោះ ដែលព្រះដ៏មានព្រះភាគត្រាស់ ព្រោះខ្លួនត្រូវសេចក្តីឃើញខុសគ្របសង្កត់ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអាចដឹងសេចក្តីនុ៎ះថា សញ្ញាជាខ្លួនរបស់បុរសដូច្នេះខ្លះ សញ្ញាជនៃ ខ្លួនក៏ជនៃ ដូច្នេះជាដើម ។

លំដាប់នោះ ព្រោះបរិព្វាជកនោះ ឃើញការកើត និងការរលត់ នៃសញ្ញា ទើបសម្គាល់ខ្លួន ដែលសម្រេចដោយសញ្ញា ជារបស់ទៀងនោះឯង ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ពាក្យថា កម្រនឹងដឹងសេចក្តីនុ៎ះជាដើម ដល់បរិព្វាជកនោះ ។ ក្នុងបទនោះ សេចក្តីដោយសង្ខេបដូច្នេះ អ្នកមានទិដ្ឋិជាជនៃ មានខន្តិជនៃ មានសេចក្តីគាប់ចិត្តជនៃ មានទស្សនៈប្រព្រឹត្ត

ទៅដោយប្រការដទៃ និងទស្សនៈយ៉ាងដទៃ គួរដល់អ្នក និងពេញចិត្តដល់អ្នក មានសេចក្តីព្យាយាមក្នុងលទ្ធដទៃ មានអាចារ្យក្នុងលទ្ធដទៃ ព្រោះការដែលប្រកបសេចក្តីខ្វល់ខ្វាយបដិបត្តិយ៉ាងដទៃ គឺភាពជាអាចារ្យក្នុងលទ្ធិតិរ្ថិយដទៃ ដោយហេតុនោះ ប្រការដែលថា សញ្ញាជាខ្លួនរបស់បុរស ឬសញ្ញាក៏ដទៃ ខ្លួនក៏ដទៃ ដូច្នោះ ព្រោះលោកអ្នកមានទិដ្ឋិដទៃ មានខន្តិដទៃ មានសេចក្តីពេញគាប់ចិត្តដទៃ មានសេចក្តីព្យាយាមក្នុងលទ្ធដទៃ មានអាចារ្យក្នុងលទ្ធដទៃ កម្រនឹងដឹងសេចក្តីនុ៎ះ ។

លំដាប់នោះ បរិព្វាជកគិតថា សញ្ញាជាខ្លួនរបស់បុរស ឬថា សញ្ញាជារបស់ដទៃ អញនឹងទូលសួរដល់នយដែលថាខ្លួននោះ ជារបស់ទៀងជាដើមនោះ ទើបទូលទៀតថា **កឹ បន ភន្តេ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **លោកោ** *សេចក្តីថា បរិព្វាជកពោលសំដៅដល់ខ្លួន ។ បទថា* **ន ហោតំ កោជ្ជចាន អត្តសញ្ញិតំ** *សេចក្តីថា ម្នាលកោជ្ជបាទ សេចក្តីនោះអាស្រ័យទិដ្ឋិមិនប្រកបដោយប្រយោជន៍ក្នុងលោកនេះ ឬក្នុងលោកដទៃ មិនប្រកបដោយប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ។ បទថា* **ន ធម្មសញ្ញិតំ** *សេចក្តីថា មិនប្រកបដោយលោកុត្តរធម៌ ៩ ។ បទថា* **ន អាធិព្រហ្មចរិយកំ** *សេចក្តីថា មិនជាខាងដើមនៃព្រហ្មចរិយៈក្នុងសាសនា ពោល គឺត្រៃសិក្ខា ទាំងមិនជាអធិសីលសិក្ខាផង ។ បទថា* **ន និព្ពិទាយ** *សេចក្តីថា មិនប្រព្រឹត្តទៅ ដើម្បីប្រយោជន៍នៃសេចក្តីនឿយណាយ ក្នុងសង្សារវដ្ត ។ បទថា* **ន វិរាគាយ** *សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍នៃការខ្ជាក់ចោលវដ្ត ។ បទថា* **ន និរោធាយ** *សេចក្តីថា មិនប្រព្រឹត្តទៅ ដើម្បីប្រយោជន៍នៃការរម្ងាប់វដ្ត ។ បទ*

ថា **ន ឧបសមាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ ក្នុងការស្ងប់រម្ងាប់វដ្ត ។ បទថា **ន អភិញ្ញាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បី ដឹងច្បាស់នូវវដ្ត គឺដើម្បីធ្វើឲ្យប្រចក្ស ។

បទថា **ន សម្ពោធាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការដឹងប្រពៃនូវវដ្ត ។

បទថា **ន និព្វានាយ** សេចក្តីថា មិនប្រព្រឹត្តទៅដើម្បីធ្វើឲ្យប្រចក្សនូវអមតមហានិព្វាន ។

[๙๕] ក្នុងបទថា **ឥមំ ទុក្ខំ** ជាដើម មានអត្ថថា ខន្ធ ๕ ដែលប្រព្រឹត្តទៅក្នុងភូមិ ๓ រឿងតណ្ហា តថាគតព្យាករថា ទុក្ខ តណ្ហា ដែលមានខន្ធ ๕ នោះជាបច្ច័យ ព្រោះជាប្រកពកើតនៃទុក្ខនោះ តថាគតព្យាករថា ទុក្ខ-សមុទយៈ ការមិនប្រព្រឹត្តទៅនៃខន្ធ និងតណ្ហាទាំងពីរនោះ តថាគតព្យាករថា ទុក្ខនិរោធ មគ្គមានអង្គ ๘ ដ៏ប្រសើរ តថាគតព្យាករថា ទុក្ខនិរោធគាមិនីបដិបទា ។ កាលព្រះដ៏មានព្រះភាគ ត្រាស់ដូច្នេះហើយ ទ្រង់ត្រិះរិះថា ឈ្មោះថា ការប្រាកដនៃមគ្គ ឬការធ្វើឲ្យច្បាស់នូវផល មិនមានដល់បរិព្វាជកនេះហើយ ក៏ជាវេលាកិច្ចាការរបស់តថាគតដល់ហើយ ទើបទ្រង់នៅស្ងៀម ។ ចំណែកបរិព្វាជកដឹងព្រះអាការនោះ ដូចជាការប្រាប់ដល់វេលាទ្រង់ត្រាស់យោងរបស់ព្រះដ៏មានព្រះភាគ ទើបទូលថា **ឯវមេតំ** ជាដើម ។

[๙๖] បទថា **វាចាយ សន្និបតោឧកេន** សេចក្តីថា ដោយជន្ទូញ គឺវាចា ។ បទថា **សញ្ឆម្ភរិមកំសុ** សេចក្តីថា បានធ្វើការចាក់ជោតពោជ្ឈបាទបរិព្វាជកដោយជុំវិញ គឺចាក់ជោតជានិច្ច ។ លោកពោលថា ចាក់ជោតខាងលើ ។

[๙๗] *បទថា* **ភូតំ** *សេចក្តីថា មានដោយសភាវៈ ។ បទថា* **តច្ឆំ តថំ** *ជាវេវចនៈរបស់បទនោះឯង ។ បទថា* **ធម្មដ្ឋិតតំ** *សេចក្តីថា សភាព តាំងនៅក្នុងលោកុត្តរធម៌ ៩ ។ បទថា* **ធម្មនិយាមតំ** *សេចក្តីថា ត្រឹមត្រូវ តាមគន្លងនៃលោកុត្តរធម៌ ។ ពិតហើយ ដែលឈ្មោះថា ការនិយាយដែល រួចផុតចាកសច្ចៈទាំង ៤ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ទើបកថាមានដូច្នេះ ។*

ចិត្តហត្ថិសារីបុត្តកថា

[๙๘] *បទថា* **ចិត្តោ ច หตฺถิสารีปุตฺโต** *សេចក្តីថា បានឮថា ចិត្ត-ហត្ថិសារីបុត្តនោះ ជាបុត្ររបស់ហ្មជីរក្នុងក្រុងសាវត្ថី បួសក្នុងសម្នាក់របស់ ព្រះដ៏មានព្រះភាគ រៀនព្រះត្រៃបិដក ជាអ្នកឈ្លាសក្នុងចន្លោះនៃអត្តដ៏ល្អិត ទាំងឡាយ ។ តែបួសហើយសឹកជាគ្រហស្ថជាន់ ๗ ជង ដោយអំណាចនៃ បាបកម្មដែលធ្លាប់ធ្វើក្នុងកាលមុន ។ បានឮថា ក្នុងសាសនារបស់ព្រះសម្ម-សម្ពុទ្ធ ព្រះនាមថាកស្សប មានសម្ងាញ់ពីរនាក់ ព្រមព្រៀងគ្នាស្វាធ្យាយ ។ សម្ងាញ់ទាំងពីរនោះ សម្ងាញ់ម្នាក់មិនមានសេចក្តីត្រេកអរ ញុាំងចិត្តឲ្យកើត ឡើងក្នុងភាពជាគ្រហស្ថ ទើបពោលដល់សម្ងាញ់ម្នាក់ទៀត ។ សម្ងាញ់ម្នាក់ នោះសម្តែងទោសក្នុងភាពជាគ្រហស្ថ និងអានិសង្សនៃបព្វជ្ជា ប្រៀនប្រដៅ លោក ។ សម្ងាញ់នោះ ស្តាប់សម្ងាញ់ម្នាក់ទៀតហើយ ក៏មានចិត្តត្រេកអរ ក្នុងថ្ងៃមួយ កាលចិត្តដូច្នោះកើតឡើងទៀត ទើបប្រាប់សម្ងាញ់ថា លោកដ៏ មានអាយុ ចិត្តបែបនោះកើតឡើងដល់ខ្ញុំៗនឹងឲ្យបាត្រ និងចីវរនេះដល់លោក។ សម្ងាញ់ម្នាក់នោះ ព្រោះមានសេចក្តីលោភក្នុងបាត្រ និងចីវរ ទើបសម្តែង*

អានិសង្សក្នុងភាពជាគ្រហស្ថ សម្តែងទោសនៃបព្វជ្ជាវិញ ។ គ្រានោះ ព្រោះ
ការស្តាប់សម្ងាញ់ហើយ ក៏សឹកជាគ្រហស្ថ ចិត្តក៏នឿយណាយក្នុងបព្វជ្ជា ។
ចិត្តហត្ថិសារីបុត្តនោះ បានសឹកដល់ ៦ ដង ក្នុងកាលឥឡូវនេះ ព្រោះលោក
សម្តែងអានិសង្សក្នុងភាពជាគ្រហស្ថ ដល់ភិក្ខុអ្នកមានសីល ក្នុងកាលនោះ ក៏
បួសក្នុងលើកទី ៧ បានជំទាស់ឡើង ក្នុងចន្ទោះដែលព្រះមហាមោគ្គល្ទាន
និងព្រះមហាកោដ្ឋិតត្ថេរ ពោលអភិធម្មកថា ។ លំដាប់នោះ ទើបព្រះមហា-
កោដ្ឋិតត្ថេរបានតិះដៀលលោក ។ លោកកាលមិនអាចតាំងនៅក្នុងវាទៈដែល
មហាសាវ័កពោលបាន ទើបសឹកជាយរាវាស ។ ចិត្តហត្ថិសារីបុត្តនេះ ជា
សម្ងាញ់កាលនៅគ្រហស្ថ របស់ជោដ្ឋបាទបរិព្វាជក ព្រោះដូច្នោះ ទើបសឹក
ទៅកាន់សម្នាក់របស់ជោដ្ឋបាទបរិព្វាជកដោយកន្ទងទៅ ២-៣ ថ្ងៃ ។

បន្ទាប់មក ជោដ្ឋបាទនោះឃើញចិត្តៈហើយ ទើបនិយាយថា នែសម្ងាញ់
លោកមានរឿងអ្វី ទើបចេញចាកសាសនារបស់ព្រះសាស្តាបែបនេះ ចូរមក
លោកសមគួរបួសក្នុងកាលឥឡូវនេះ ហើយក៏នាំទៅកាន់សម្នាក់របស់ព្រះ
មានព្រះភាគ ដោយហេតុនោះ ទើបលោកពោលថា ចិត្តហត្ថិសារីបុត្ត និង
ជោដ្ឋបាទបរិព្វាជក ដូច្នេះ ។

[៩៩-១០០] បទថា **អន្ធា** សេចក្តីថា ព្រោះចក្ខុ គឺបញ្ញាមិនមាន ។
ឈ្មោះថា មិនមានចក្ខុ ព្រោះមិនមានចក្ខុ គឺបញ្ញានោះ ។ បទថា **ត្វញ្ញេវ នេសំ
ឯកោ ចក្ខុមា** សេចក្តីថា មានចក្ខុ គឺបញ្ញា ត្រឹមតែដឹងសុភាសិត និងទុព្ភា-
សិត ។ បទថា **ឯកំសិកា** សេចក្តីថា ចំណែកមួយ ។ បទថា **បញ្ញត្តា**
សេចក្តីថា បញ្ញត្តិហើយ ។ បទថា **អនេកំសិកា** សេចក្តីថា មិនមែនចំណែក

តែមួយ អធិប្បាយថា មិនបានត្រាស់ថា ទៀង ឬថា មិនទៀង ដោយចំណែកតែមួយ ។

ឯកំសិកធម្មកថា

[๑๐๑] *ព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធពាក្យថា* **សន្តិ ចោដ្ឋចាឧ** *នេះ ព្រោះហេតុអ្វី ។ ដើម្បីទ្រង់សម្តែងដល់បញ្ញត្តិទីបំផុត ដែលពួកពាហិរៈទាំង-ឡាយបញ្ញត្តិទុក មិនមែនជាគ្រឿងចេញចាកទុក្ខបាន ។ តិរ្ថិយទាំងពួង រមែងបញ្ញត្តិទីបំផុតដោយអំណាចថា លោកមានទីបំផុតជាដើម ក្នុងលទ្ធិរៀងៗ ខ្លួនជូចព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តអមតនិព្វានដូច្នោះ ។ បញ្ញត្តទីបំផុតនោះ មិនជាទីនាំចេញចាកទុក្ខបាន មានត្រឹមតែបញ្ញត្ត រមែងមិននាំចេញចាកទុក្ខបាន ដែលបណ្ឌិតទាំងឡាយបដិសេធការប្រព្រឹត្តត្រឡប់ដោយប្រការដទៃ ដើម្បីទ្រង់សម្តែងបញ្ញត្តិទីបំផុតនោះ ទើបព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ ។ ក្នុងបទទាំងនោះ បទនេះថា* **ឯកន្តសុខំ លោកំ ជានំ បស្សំ** *សេចក្តីថា អ្នកទាំង-ឡាយកាលដឹង កាលឃើញយ៉ាងនេះថា ក្នុងទិសខាងកើត លោកមានសុខដោយចំណែកតែមួយ ឬក្នុងទិសណាមួយ បណ្តាទិសទាំងឡាយ មានទិសខាងលិចជាដើមចុះ វត្តទាំងឡាយ មានទ្រង់ទ្រាយនៃរាងកាយជាដើម របស់មនុស្សទាំងឡាយក្នុងលោកនោះ អ្នកទាំងឡាយធ្លាប់ឃើញហើយ ។ បទថា* **អប្បាដិហីរកតំ** *សេចក្តីថា ការសិតគ្មានផល គឺវៀរចាកការឲ្យជាក់ច្បាស់ឲ្យជ្រាប លោកពោលថា មិនាំចេញចាកទុក្ខ ។*

[๑๐๒] *បទថា* **ជនបទកល្យាណី** *សេចក្តីថា មិនដូចជាស្រីទាំង-ឡាយដទៃ ដែលមានពណ៌សម្បុរ ទ្រង់ទ្រាយ អាកប្បកិរិយាជាដើម ក្នុង*

ជនបទ ។

[๑๐๔] *ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបញ្ញត្តិទីបំផុត ក្នុងសមណ-ព្រាហ្មណ៍ពួកជដៃ មិននាំចេញចាកទុក្ខយ៉ាងនេះហើយ ទើបត្រាស់ថា* **តយោ ខោ មេ ចោជ្ជចាឧ** *ជាដើម ដើម្បីទ្រង់សម្តែងបញ្ញត្តិរបស់ព្រះអង្គ ជាធម៌នាំចេញចាកទុក្ខបាន ។ ក្នុងបទទាំងនោះ បទថា* **អត្តប្បដិលាភោ** *សេចក្តីថា ការត្រឡប់បានអត្តភាព ។ ក្នុងបទថា* **អត្តប្បដិលាភោ** *នោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងកព ៣ ដោយការត្រឡប់បានអត្តភាព ៣ យ៉ាង ។ ទ្រង់សម្តែងកាមភពតាំងពីអវីចី ដល់បរនិម្មិតវសវត្តីជាទីបំផុត ដោយការត្រឡប់បានអត្តភាពដែលគ្រោតគ្រាត ។ ទ្រង់សម្តែងរូបភពតាំងពីជាន់បឋមជ្ឈាន ដល់អកនិដ្ឋព្រហ្មលោកជាទីបំផុត ដោយការត្រឡប់បានអត្តភាពដែលសម្រេចដោយចិត្ត ។ ទ្រង់សម្តែងអរូបភព តាំងពីអាកាសានញ្ចាយតនព្រហ្មលោកដល់នេវសញ្ញានាសញ្ញាយតនព្រហ្មលោកជាទីបំផុត ដោយការត្រឡប់បានអត្តភាពដែលមិនមានរូប ។ អកុសលចិត្តុប្បាទ ១២ យ៉ាង ឈ្មោះថា សង្កិលេសធម៌ ។ សមថវិបស្សនា ឈ្មោះថា វោទានធម៌ ។*

[๑๐๕-๑๐๗] *បទថា* **បញ្ញាចារិប្បរិ វេបុល្លត្តំ** *សេចក្តីថា នូវភាពបរិបូណ៌ និងភាពទូលាយនៃមគ្គប្បញ្ញា និងផលប្បញ្ញា ។ បទថា* **ចាមោដ្ឋ** *បានដល់ បីតិយ៉ាងទន់ ។ បទថា* **បីតិ** *បានដល់ សេចក្តីត្រេកអរមានកម្លាំង លោកពោលដូចម្តេច លោកពោលយ៉ាងនេះថា ក្នុងបទដែលលោកពោលថា នឹងធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញាដោយខ្លួនឯង និងចូលដល់កាលកិរិយានោះនៅ*

យ៉ាងនេះ ក៏នឹងមានបាមោជ្ជ បីតិ សេចក្តីស្ងប់ចិត្ត និងកាយ សតិតាំងមាំល្អ ឧត្តមញ្ញាណ នឹងនៅជាសុខ និងក្នុងបណ្តាការនៅទាំងពួង ការនៅយ៉ាងនេះ សមគួរពោលថា ជាសុខ គឺស្ងប់ហើយ មានសេចក្តីសុខយ៉ាងក្រៃលែង ។

បណ្តាឈានទាំងនោះ ក្នុងបឋមជ្ឈាន រមែងបានធម៌ ៦ យ៉ាង មានបាមោជ្ជជាដើម ។ ក្នុងទុតិយជ្ឈាន បាមោជ្ជ ពោល គឺបីតិយ៉ាងទន់ រមែងប្រព្រឹត្តទៅ រមែងបានធម៌ ៥ យ៉ាងដ៏សេស ។ ក្នុងតតិយជ្ឈាន បីតិប្រព្រឹត្តទៅ រមែងបានធម៌ ៤ យ៉ាងដ៏សេស ។ ក្នុងចតុត្ថជ្ឈានក៏ដូចគ្នា ។ ក្នុងឈានទាំងនេះ លោកពោលឈានដែលជាបាទនៃវិបស្សនាបរិសុទ្ធប៉ុណ្ណោះ ទុកក្នុងសម្បសាទសូត្រ ។ ពោលវិបស្សនាមួយអន្ទើដោយមគ្គ ៤ ក្នុងបាសាទិក-សូត្រ ។ ពោលផលសមាបត្តិ ដែលជាប់ទាក់ទងនឹងចតុត្ថជ្ឈានក្នុងទសុត្តរ-សូត្រ ។ ផលសមាបត្តិជាប់ទាក់ទងនឹងទុតិយជ្ឈាន ធ្វើបាមោជ្ជឲ្យជាវេវចនៈរបស់បីតិ គប្បីជ្រាបថា លោកពោលហើយក្នុងភោជ្ជបាទសូត្រនេះ ។

[๑๐๘] **ปา** *សព្ទក្នុងបទនេះថា* **អយំ ปา เสา** *ជាអត្ថចុះក្នុងការធ្វើឲ្យច្បាស់ ។តថាគតឲ្យជាក់ច្បាស់ហើយ ប្រកាសហើយថា គប្បីព្យាករយ៉ាងនេះសេចក្តីថា សមណព្រាហ្មណ៍ពួកដទៃ ត្រូវតថាគតសួរយ៉ាងនេះថា អ្នកទាំង-ឡាយស្គាល់ខ្លួនដែលមានសុខដោយចំណែកតែមួយ ឬក៏ពោលថា មិនស្គាល់ដោយប្រការណា តថាគតនឹងមិនពោលដោយប្រការនោះ ។*

[๑๐๙-๑๑๐] *បទថា* **สปฺปาฏิหาริกตฺถํ** *សេចក្តីថា ការសិតនឹងមានការឲ្យជ្រាបច្បាស់ គឺជាទីនាំចេញចាកទុក្ខ ។*

[๑๑๑-๑๑๓] *បទថា* **เมาเฬฺยา เหาติ**[๑] *សេចក្តីថា ជារបស់ទេ*

๑- *ចិដកខ្មែរ ហោតិ មោឃោ ។*

អធិប្បាយថា ការបានអត្តភាពនោះ រមែងមិនមានក្នុងសម័យនោះ ។ បទថា **សច្ចោ ហោតិ** *សេចក្តីថា ជារបស់មានពិត អធិប្បាយថា ការបានអត្តភាពនោះឯង ជារបស់មានមែន ក្នុងសម័យនោះ ។ ក្នុងសេចក្តីនេះ ចិត្តហត្ថិ-សារីបុត្រនេះ សម្តែងការបានអត្តភាព ៣ យ៉ាង ព្រោះខ្លួនមិនមែនជាសព្វញ្ញូ ទើបមិនអាចលើកឡើងអាងថា ធម្មតាការបានអត្តភាពនោះ មានត្រឹមតែបញ្ញត្តិ ទើបពោលបញ្ចៀសថា ការបានអត្តភាពប៉ុណ្ណោះ ។*

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រោថ្នានឹងសម្តែងដល់ចិត្តហត្ថិ-សារីបុត្តនោះថា ក្នុងសេចក្តីនេះ ធម៌ទាំងឡាយ មានរូបជាដើម ការបានអត្តភាពនោះមានត្រឹមតែឈ្មោះ លុះធម៌ទាំងឡាយ មានរូបជាដើមនោះៗ មានវោហារដោយសភាពបែបនេះ ក៏រមែងមាន ទ្រង់ចាប់យកពាក្យរបស់ចិត្ត-ហត្ថិសារីបុត្រនុ៎ះឯង បង្វែរព្រះតម្រាស់ដោយអំណាចនៃនាមប្បញ្ញត្តិ ទើបត្រាស់ពាក្យជាដើមថា ម្នាលចិត្ត: ការបាននូវឱឡារិកអត្តភាព ក្នុងសម័យណាៗ ។

កាលត្រាស់យ៉ាងនោះហើយ ដើម្បីនឹងសាកសួរ ទើបត្រាស់ទៀតថា ម្នាលចិត្ត: បើជនទាំងឡាយ សួរអ្នកយ៉ាងនេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យោ មេ អហោសិ** *សេចក្តីថា ការបានអត្តភាពដែលជាអតីតរបស់ខ្ញុំព្រះអង្គ ជារបស់មានពិតក្នុងសម័យនោះ ។ ក្នុងពាក្យថា ចំណែកអនាគត និងបច្ចុប្បន្ន ជាការសោះសូន្យទទេនោះ ចិត្តហត្ថិសារីបុត្រពោលសេចក្តីនេះត្រឹមតែប៉ុណ្ណោះថា ធម៌ទាំងឡាយ ដែលជាអតីត មិនមានក្នុងបច្ចុប្បន្ននេះ ដល់នូវការរាប់ថា មានហើយ ព្រោះដូច្នោះ ទើបការបានអត្តភាព*

របស់ខ្ញុំព្រះអង្គនោះ មានពិតក្នុងសម័យនោះ ចំណែកការបានអត្តភាព ដែលជាអនាគតក៏ជាមោឃៈ ដែលជាបច្ចុប្បន្នក៏សោះសូន្យទទេ ក្នុងសម័យនោះ ព្រោះធម៌ទាំងឡាយដែលជាអនាគត និងដែលជាបច្ចុប្បន្ន មិនមានក្នុងវេលានោះ ។ ចិត្តៈទទួលដឹងការបានអត្តភាពត្រឹមតែជានាម ដោយអត្តយ៉ាងនេះ ។ ក្នុងអនាគត និងបច្ចុប្បន្ន ក៏មានន័យដូចគ្នា ។

[๑๑๔] *លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រៀបធៀបព្យាករណ៍របស់ព្រះអង្គ និងព្យាករណ៍របស់ចិត្តហត្ថិសារីបុត្តនោះ ទើបត្រាស់ថា* **ឯវមេវ ខោ ចិត្ត** *ដូច្នេះជាដើម កាលទ្រង់សម្តែងអត្តនេះដោយឧបមាទៀត ទើបត្រាស់ថា* **សេយ្យថាបិ ចិត្ត គង្គា ឯវំ** *ជាដើម ។ ក្នុងបទនោះ មានសេចក្តីដោយសង្ខេបដូច្នេះថា ទឹកដោះស្រស់មានអំពីគោ ទឹកដោះជូរជាដើម មានពីទឹកដោះស្រស់ជាដើម ក្នុងសេចក្តីនេះ សម័យណានៅជាទឹកដោះស្រស់ សម័យនោះក៏មិនដល់ការរាប់ គឺនិវុត្តិ នាមវោហារថា ជាទឹកដោះជូរ ឬជាសប្បិ[1] ជាដើមណាមួយ ព្រោះហេតុអ្វី ព្រោះមិនមានធម៌ទាំងឡាយដែលបានវោហារជាដើមថា ទឹកដោះជូរ តែសម័យនោះដល់ការរាប់ថា ជាទឹកដោះស្រស់តែម្យ៉ាង ព្រោះហេតុអ្វី ព្រោះមានធម៌ទាំងឡាយដល់នូវការរាប់ គឺនិវុត្តិ នាមវោហារថា ទឹកដោះស្រស់ ។ ក្នុងបទទាំងពួងក៏នយនេះ ។*

បទថា **ឥមា ខោ ចិត្ត** *សេចក្តីថា ម្នាលចិត្តៈ ការបានអត្តភាពដែលគ្រោតគ្រោត ការបានអត្តភាពដែលសម្រេចអំពីចិត្ត និងការបានអត្តភាពដែល*

๑- បិដកខ្មែរ ប្រែថា ទឹកដោះរាវ តែសប្បិ មិនមែនទឹកដោះរាវទេ ជាទឹកដោះដែលគេរម្ងាស់ទៅជាដុំ អាចកាន់បាន ដូតក៏នេះ ។

មិនមានរូប ទាំងនេះឯងជាលោកសញ្ញា ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងការ បានអត្តភាព ៣ យ៉ាងខាងក្រោម យ៉ាងនេះថា ទាំងនោះមានត្រឹមតែឈ្មោះ ក្នុងលោក មានត្រឹមតែសញ្ញា ទាំងនោះមានត្រឹមតែកាសាក្នុងលោក មានត្រឹម តែគន្ធងនៃវាចា មានត្រឹមតែវោហារ មានត្រឹមតែនាមប្បញ្ញត្តិ ដូច្នេះហើយ ទើបឥឡូវនេះ ត្រាស់ថា ទាំងអស់នោះ មានត្រឹមតែវោហារ ។ ព្រោះហេតុអ្វី ព្រោះដោយបរមត្ថ មិនមានសត្វ លោកនោះ សោះសូន្យទទេ ។

កថារបស់ព្រះពុទ្ធទាំងឡាយ មានពីរយ៉ាង គឺសម្មតិកថា និងបរមត្ថកថា ។ ក្នុងកថាទាំងពីរយ៉ាងនោះ កថាថា សត្វ មនុស្ស ទេវតា ព្រហ្មជាដើម ឈ្មោះ ថា **សម្មតិកថា** *។ កថាថា អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ អាយតន: សតិប្បដ្ឋាន សម្មប្បធានជាដើម ឈ្មោះថា* **បរមត្ថកថា** *។ ក្នុងកថាទាំងនោះ បុគ្គលណា កាលព្រះមានព្រះភាគត្រាស់ថា សត្វ មនុស្ស ទេវតា ឬព្រហ្ម រមែងអាចដឹងច្បាស់ ត្រាស់ដឹង នាំចេញចាកទុក្ខ កាន់យកនូវទង់ គឺអរហត្ត ដោយសម្មតិទេសនា ព្រះមានព្រះភាគក៏ទ្រង់ត្រាស់ថា សត្វ មនុស្ស ទេវតា ឬព្រហ្ម ជាខាងដើមដល់បុគ្គលនោះ ។ បុគ្គលណាស្តាប់ធម៌ណាមួយជាដើមថា* **អនិច្ចំ** *ឬ* **ទុក្ខំ** *ដោយបរមត្ថទេសនា រមែងដឹងច្បាស់ ចាក់ធ្លុះរហូតដល់អស់ អាសវៈ ដើម្បីនាំចេញចាកទុក្ខ ដើម្បីចាប់កាន់នូវទង់ គឺអរហត្ត ព្រះមាន ព្រះភាគ ទ្រង់សម្តែងធម៌យ៉ាងណានីមួយជាដើមថា* **អនិច្ចំ** *ឬ* **ទុក្ខំ** *ដល់ បុគ្គលនោះ ព្រោះដូច្នោះ ទើបមិនសម្តែងបរមត្ថកថាមុន ដល់សត្វដែលនឹង ដឹងដោយសម្មតិកថា តែទ្រង់ឲ្យដឹងដោយសម្មតិកថាហើយ ទើបទ្រង់សម្តែង បរមត្ថកថាក្នុងកាលជាក្រោយ និងទ្រង់មិនសម្តែងសម្មតិកថាមុន ដល់សត្វ*

អ្នកនឹងដឹងដោយបរមត្ថកថា តែទ្រង់សម្តែងឲ្យដឹងដោយបរមត្ថកថាហើយ ទើបទ្រង់សម្តែងសម្មតិកថា ក្នុងកាលជាខាងក្រោយ ។

តែដោយប្រក្រតី កាលទ្រង់សម្តែងបរមត្ថកថាមុន ទេសនាក៏នឹងមានអាការគ្រោតគ្រោត ព្រោះដូច្នោះ ព្រះពុទ្ធទាំងឡាយ ទ្រង់សម្តែងសម្មតិកថាមុនហើយ ទើបទ្រង់សម្តែងបរមត្ថកថាជាខាងក្រោយ កាលទ្រង់សម្តែងសម្មតិកថា ទ្រង់សម្តែងតាមសេចក្តីពិត តាមសភាពពិត មិនកុហក កាលទ្រង់សម្តែងបរមត្ថកថា ទ្រង់សម្តែងតាមសេចក្តីពិត តាមសភាវៈពិត មិនកុហក ។ បុរាណាចារ្យបានពោលគាថាថា

ព្រះពុទ្ធដ៏ប្រសើរ កាលត្រាស់ ក៏ត្រាស់សច្ចៈ ២ យ៉ាង គឺ សម្មតិសច្ច ១ បរមត្ថសច្ច ១ មិនត្រាស់សច្ចៈទី ៣ ឡើយ សម្មតិវចនៈ ជាសច្ចៈ ជាហេតុនៃលោកសម្មតិ បរមត្ថវចនៈ ជាសច្ចៈ ជាលក្ខណៈមានពិត នៃធម៌ទាំងឡាយ ដូច្នេះ ។

បទថា **យាហិ តថាគតោ ភោមារតិ អបរាមសន្តោ** *សេចក្តីថា ព្រះតថាគតទ្រង់ប្រមូលទេសនាថា ឈ្មោះថា ទ្រង់មិនជាប់ជំពាក់ ព្រោះមិនមានការជាប់ជំពាក់ដោយតណ្ហា មានៈ និងទិដ្ឋិ ត្រាស់ដោយលោកសម្មតិ ដោយលោកនិរុត្តិ ទ្រង់បញ្ចប់ទេសនាដល់កំពូល គឺអរហត្ត ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ទាំងអស់ហើយ ។*

ចោជ្ឈបាទសុត្តវណ្ណនា ក្នុងទីឃនិកាយ ឈ្មោះថា សុមង្គលវិលាសិនី ចប់ហើយ ដោយប្រការដូច្នេះ ៗ

ចោជ្ឈបាទសូត្រទី ៩ ចប់

សុត្តន្តបិដក

សុភសូត្រទី ១០

[១១៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានទៅហើយ មិនទាន់យូរប៉ុន្មាន ព្រះអានន្ទមានអាយុ គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកគហបតី ជិតក្រុងសាវត្ថី ។

[១១៧] សម័យនោះឯង សុភមាណពជាកូននៃតោទេយ្យព្រាហ្មណ៍ នៅអាស្រ័យក្នុងក្រុងសាវត្ថីដោយកិច្ចឯណានីមួយ ។ លំដាប់នោះសុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ហៅមាណពម្នាក់មកថា ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈឈ្មោះអានន្ទ លុះចូលទៅដល់ហើយ ចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយ នឹងព្រះសមណៈឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ ផ្តាំឲ្យសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយ ឯងចូរនិមន្តថា សូមព្រះអានន្ទជាម្ចាស់ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ។ មាណពនោះទទួលពាក្យសុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ថា បាទអ្នកម្ចាស់ ហើយក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ទៅនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួរ

រីករាយ និងពាក្យដែលគួរពេកហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះមាណព នោះអង្គុយក្នុងទីដ៏សមគួរហើយ បានទូលស្នើសេចក្តីនេះនឹងព្រះអានន្ទមាន អាយុថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ សួរនូវអាការមិនមានអាពាធ មិនមានរោគ ក្រោកទៅមកបានរហ័សរហួន កម្លាំង និងអាការនៅជាសុខ សប្បាយ ចំពោះព្រះអានន្ទជាម្ចាស់ រួចហើយឲ្យនិមន្តយ៉ាងនេះថា សូមព្រះ អានន្ទដ៏ចម្រើនអាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តទៅកាន់លំនៅរបស់សុក-មាណពជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ។

[๑๑๘] កាលមាណពពោលពាក្យយ៉ាងនេះហើយ ព្រះអានន្ទមាន អាយុ ក៏មានថេរវាចាដូច្នេះទៅនឹងមាណពនោះថា ម្នាលមាណព កាលនេះ មិនគួរ (នឹងទៅទេ) ដ្បិតថ្ងៃនេះ យើងបានឆាន់ថ្នាំខ្លះទៅហើយ បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក ។ មាណពនោះទទួលពាក្យព្រះអានន្ទមានអាយុថា ករុណាលោកម្ចាស់ ហើយ ក្រោកចាកអាសនៈ ចូលទៅរកសុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ លុះ ចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងសុភមាណពជាកូនតោទេយ្យ ព្រាហ្មណ៍ថា ខ្ញុំបាននិយាយនឹងព្រះអានន្ទដ៏ចម្រើននោះ តាមពាក្យរបស់អ្នក រួចហើយថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ សួរនូវអាការមិនមាន អាពាធ មិនមានរោគ ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការ នៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន ហើយនិមន្តយ៉ាងនេះថា សូម ព្រះអានន្ទដ៏ចម្រើន អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តទៅកាន់លំនៅ សុក-

មាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន បពិត្រអ្នកម្ចាស់ កាលដែលខ្ញុំ ពោលយ៉ាងនេះហើយ ព្រះសមណអានន្ទ បានពោលពាក្យនេះនឹងខ្ញុំថា ម្នាល មាណព កាលនេះមិនគួរ (នឹងទៅទេ) ជ្បិតថ្ងៃនេះ យើងបានធាន់ថ្នាំខ្ងះ ទៅហើយ បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យសិន ហើយ សឹមទៅក្នុងថ្ងៃស្អែក បពិត្រអ្នកម្ចាស់ ព្រះអានន្ទដ៏ចម្រើននោះ បានធ្វើ ឧកាសដើម្បីនិមន្តមកធាន់ក្នុងថ្ងៃស្អែក ដោយកិច្ចណា កិច្ចនេះ ខ្ញុំបានធ្វើ សម្រេចហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

[១១៩] លុះកន្ងងរាត្រីនោះហើយ ព្រះអានន្ទមានអាយុ ទ្រង់ស្បង់ និងបាត្រចីវរក្នុងបុព្វណ្ហសម័យ មានភិក្ខុ ១ រូបឈ្មោះចេតក: ជាបច្ឆា-សមណ: ក៏ចូលសំដៅទៅត្រង់ទីលំនៅ របស់សុភមាណពជាកូនតោទេយ្យ-ព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើអាសន:ដែលគេក្រាលបម្រុង ទុក ។ លំដាប់នោះ សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ចូលទៅរកព្រះ អានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះ សំណាល នឹងព្រះអានន្ទមានអាយុ លុះបញ្ចប់នូវពាក្យដែលគួររីករាយ និង ពាក្យដែលគួររឲ្យកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះសុភមាណពជា កូនតោទេយ្យព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលស្នើរឿងនេះ នឹងព្រះអានន្ទមានអាយុថា ព្រះអានន្ទដ៏ចម្រើនជាឧបដ្ឋាក ជាអ្នកនៅជិតដិត ជាអ្នកបម្រើជិត នៃព្រះគោតមដ៏ចម្រើននោះ អស់កាលជាអង្វែង ព្រះអានន្ទ ដ៏ចម្រើនគួរដឹងរឿងនុ៉ះ ព្រះគោតមដ៏ចម្រើននោះ បានពោលសរសើរធម៌

ទាំងឡាយណា ទាំងណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋានក្នុងធម៌ទាំង-ឡាយណា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះគោតមដ៏ចម្រើននោះ បានពោលសរសើរធម៌ទាំងឡាយនោះដូចម្តេចខ្លះ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាន ក្នុងធម៌ដូចម្តេចខ្លះ ។ ព្រះអានន្ទតបថា ម្នាលមាណព ព្រះមានព្រះភាគនោះ ព្រះអង្គបានពោលសរសើរខន្ធ ៣ យ៉ាង ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋានក្នុងខន្ធទាំង ៣ យ៉ាងនុ៎ះ ខន្ធទាំង ៣ យ៉ាងនោះ តើដូចម្តេចខ្លះ គឺអរិយសីលក្ខន្ធ ១ អរិយសមាធិក្ខន្ធ ១ អរិយ-បញ្ញាខន្ធ ១ ម្នាលមាណព ព្រះមានព្រះភាគនោះ ព្រះអង្គបានពោលសរសើរខន្ធទាំង ៣ យ៉ាងនេះឯង ទាំងបានណែនាំប្រជុំជននេះ ឲ្យតាំងនៅ ឲ្យប្រតិស្ឋានក្នុងខន្ធទាំង ៣ យ៉ាងនេះ ។

[๑๒๐] *សុភមាណព ទូលសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះអរិយសីលក្ខន្ធ ដែលព្រះគោតមដ៏ចម្រើននោះ ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះ ឲ្យតាំងនៅ ឲ្យប្រតិស្ឋាននោះ តើដូចម្តេច ។ ព្រះអានន្ទតបថា ម្នាលមាណព ព្រះតថាគតកើតឡើងក្នុងលោកនេះ បានជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ ។បេ។ ព្រះអង្គញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ។បេ។ ព្រះអង្គទ្រង់ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ។ គហបតីក្តី កូនរបស់គហបតិក្តី ឬបុគ្គលកើតក្នុងត្រកូលឯណានីមួយជាខាងក្រោយក្តី ស្តាប់នូវធម៌នោះ លុះបុគ្គលនោះស្តាប់នូវធម៌នោះហើយ រមែងបាននូវសទ្ធាក្នុងព្រះតថាគត លុះបុគ្គលនោះប្រកប*

ដោយការបាននូវសទ្ធានេះហើយ រមែងពិចារណាឃើញច្បាស់ថា ឃរាវាស ចង្អៀតចង្អល់ ជាផ្លូវហួរមកនៃធូលី គឺកិលេស បព្វជ្ជា ទើបមានឱកាសទំនេរ បុគ្គលដែលនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យ បរិបូណ៌ពេញលេញ ឲ្យបរិសុទ្ធពេញលេញ ដូចសង្ខ៍ដែលគេខាត់ហើយនោះ ទេ បើដូច្នោះ មានតែអាត្មាអញកោរសក់ និងពុកមាត់ ពុកចង្ការួចហើយ ស្លៀកដណ្តប់នូវសំពត់ជ្រលក់អមួត ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ លុះកាលជាខាងក្រោយមក បុគ្គលនោះលះបង់គំនរភោគៈតិចក្តី លះបង់គំនរភោគៈច្រើនក្តី លះបង់នូវញាតិវង្សតិចក្តី លះបង់នូវញាតិវង្សច្រើនក្តី កោរសក់ និងពុកមាត់ ពុកចង្កា រួចហើយ ស្លៀកដណ្តប់សំពត់ជ្រលក់អមួត ហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ កាលបើបុគ្គលនោះបួសយ៉ាងនេះ ហើយ ក៏សង្រួមក្នុងបាតិមោក្ខសំវរសីល ប្រកបដោយអាចារៈ និងគោចរ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ប្រកបដោយកាយកម្ម និងវចីកម្មជាកុសល មានអាជីវៈដ៏បរិសុទ្ធ ដ៏បរិបូណ៌ ដោយសីល រក្សានូវទ្វារក្នុងឥន្ទ្រិយទាំងឡាយ ប្រកបដោយសតិសម្បជញ្ញៈ ជាអ្នកសន្តោស ។

[๑๒๑] ម្នាលមាណព ចុះភិក្ខុជាអ្នកបរិបូណ៌ដោយសីលតើដូចម្តេច ម្នាលមាណព ភិក្ខុក្នុងសាសនានេះ លះបង់បាណាតិបាត វៀរស្រឡះចាក បាណាតិបាត ជាអ្នកមានគ្រឿងវាយសំពងដាក់ចុះហើយ មានគ្រឿងសស្ត្រា ដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានចិត្តអាណិតអាសូរ ជាអ្នកមាន

សេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ។ ម្នាលមាណព ភិក្ខុលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកមានគ្រឿងវាយសំពងជាក់ចុះហើយ មានគ្រឿងសស្ត្រាជាក់ចុះហើយ មានសេចក្តីខ្មាសបាប មានចិត្តអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ដោយអំពើណា អំពើនេះឯង ជាសីលរបស់ភិក្ខុនោះ (សីលទាំងពួងក្រៅអំពីនោះ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារផងចុះ) ។បេ។

[๑๒๒] មួយយ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចម្រើនពួកមួយ បរិភោគជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្តេច ។ គឺវិធីបន់ស្រន់ខ្លះ វិធីលាបំណន់ខ្លះ វិធីធ្វើប្រយោគមន្តដែលបុគ្គលនៅក្នុងភូមិផ្ទះគួរវៀនខ្លះ វិធីធ្វើមនុស្សខ្ទើយឲ្យដូចជាមនុស្សប្រុសខ្លះ វិធីធ្វើមនុស្សប្រុសឲ្យដូចជាមនុស្សខ្ទើយខ្លះ វិធីសង់ផ្ទះលើទីដីដែលមិនធ្លាប់បានធ្វើខ្លះ វិធីធ្វើពលីកម្មចំពោះសំណង់ផ្ទះខ្លះ វិធីជម្រះមុខឲ្យស្អាតដោយទឹកខ្លះ វិធីស្រោចទឹកបង្គក់ប្រសិទ្ធឲ្យជនដទៃខ្លះ វិធីបូជាភ្លើងខ្លះ វិធីផ្សំថ្នាំក្អកខ្លះ វិធីផ្សំថ្នាំបញ្ចុះខ្លះ វិធីផ្សំថ្នាំកម្ចាត់បង់នូវទោសខាងលើ មានប្រមាត់ជាដើមខ្លះ វិធីផ្សំថ្នាំកម្ចាត់បង់នូវទោសខាងក្រោម មានបំពង់បស្សាវៈជាដើមខ្លះ វិធីផ្សំថ្នាំកម្ចាត់បង់នូវទោសក្នុងក្បាលនាំចេញនូវសេស្មជាដើមខ្លះ វិធីស្រេចបន្តក់ត្រចៀកខ្លះ វិធីស

ប្រេងសម្រាប់ស្អុំភ្នែកខ្ញុះ វិធីផ្សំថ្នាំសម្រាប់ហិតខ្ញុះ វិធីផ្សំថ្នាំសម្រាប់បន្តក់ភ្នែកខ្ញុះ វិធីផ្សំថ្នាំត្រជាក់សម្រាប់លាបភ្នែកខ្ញុះ វិធីធ្វើវេជ្ជកម្មរក្សាភ្នែកខ្ញុះ វិធីធ្វើកម្មរបស់ពេទ្យវះខ្ញុះ វិធីធ្វើពេទ្យរក្សាកូនក្មេងខ្ញុះ វិធីឲ្យកម្ចាំងថ្នាំក្រោយដល់ថ្នាំមុខខ្ញុះ វិធីលាងថ្នាំដើមចេញខ្ញុះ ។ ភិក្ខុវៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ ម្នាលមាណព ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងចិញ្ចឹមជីវិតដោយមិច្ឆាជីវ: ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្តេច ។ វិធីបន់ស្រន់ខ្ញុះ វិធីលាបំណន់ខ្ញុះ ។បេ។ វិធីលាងថ្នាំដើមចេញខ្ញុះ ។ ភិក្ខុវៀរស្រឡះចាកការចិញ្ចឹមជីវិតខុស ព្រោះតែតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះ ដោយអំពើណា អំពើនោះឯងជាសីលរបស់ភិក្ខុនោះដែរ ។ ម្នាលមាណព ភិក្ខុនោះឯងបានបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនឃើញនូវភ័យអំពីទីណាមួយ ដែលកើតអំពីសេចក្តីសង្រួមក្នុងសីលឡើយ ។ ម្នាលមាណព ប្រៀបដូចព្រះបរមក្សត្រិយ៍ដែលបានមុទ្ធាភិសេកជាស្តេចហើយ បានកម្ចាត់បង់នូវសត្រូវអស់ហើយ រមែងមិនឃើញនូវភ័យអំពីទីណាមួយ ដែលកើតអំពីសត្រូវឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានបរិបូណ៌ដោយសីលយ៉ាងនេះហើយ រមែងមិនឃើញនូវភ័យអំពីទីណាមួយ ដែលកើតអំពីសេចក្តីសង្រួមក្នុងសីលដូច្នោះឯង ។ ភិក្ខុនោះប្រកបព្រមដោយអរិយសីលក្ខន្ធនេះហើយ រមែង

ទទួលសេចក្តីសុខឥតមានទោសក្នុងសន្តាននៃខ្លួន ។ ម្នាលមាណព ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។ ម្នាលមាណព នេះឯងជាអរិយ-សីលក្ខន្ធ ដែលព្រះមានព្រះភាគ ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះ ឲ្យតាំងនៅ ឲ្យប្រតិស្ឋាន កិច្ចដែលគួរធ្វើតទៅក្នុងសាសនានេះនៅមានទៀត ។ សុភមាណពពោលសរសើរថា បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះជាអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះមិនធ្លាប់មានបែរជាមានបាន បពិត្រព្រះអានន្ទដ៏ចម្រើន ក៏អរិយសីលក្ខន្ធនោះបរិបូណ៌ហើយ មិនមែនជាមិនបរិបូណ៌ទេ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណាមិនដែលឃើញនូវអរិយសីលក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះ ក្នុងពួកសមណៈដទៃខាងក្រៅព្រះពុទ្ធសាសនានេះទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ពួកសមណព្រាហ្មណ៍ដទៃខាងក្រៅព្រះពុទ្ធសាសនានេះ គង់បានឃើញអរិយ-សីលក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះក្នុងខ្លួនដែរ តែសមណព្រាហ្មណ៍ទាំងនោះ ពេញចិត្តដោយគុណត្រឹមតែសីលក្ខន្ធប៉ុណ្ណោះថា ល្មមហើយដោយគុណមានប្រមាណប៉ុណ្ណោះ សម្រេចហើយដោយគុណ មានប្រមាណប៉ុណ្ណោះ ប្រយោជន៍នៃសាមញ្ញគុណ យើងបានដល់ដោយលំដាប់ហើយ កិច្ចនីមួយដែលយើងទាំងឡាយគប្បីធ្វើតទៅ មិនមានឡើយ ។ ចំណែកព្រះអានន្ទដ៏ចម្រើន ពោលយ៉ាងនេះថា កិច្ចដែលគួរធ្វើតទៅក្នុងសាសនានេះនៅមានទៀត ។

[๑๒๓] *បពិត្រព្រះអានន្ទដ៏ចម្រើន ចុះអរិយសមាធិក្ខន្ធ ដែលព្រះ*

គោតមដ៏ចម្រើន ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះ ឲ្យតាំងនៅ ឲ្យប្រតិស្ឋាននោះ តើដូចម្តេច ។ ម្នាលមាណព ចុះភិក្ខុជាអ្នករក្សានូវទ្វារក្នុងឥន្ទ្រិយទាំងឡាយតើដូចម្តេច ។ ម្នាលមាណព ភិក្ខុក្នុងសាសនានេះ ឃើញនូវរូបារម្មណ៍ដោយចក្ខុហើយ តែមិនបានកួចកាន់នូវនិមិត្ត មិនបានកួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងជាប់តាមនូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀកហើយ ។បេ។ បានធុំក្លិនដោយច្រមុះហើយ ។ បានទទួលរសដោយអណ្តាតហើយ ។ បានពាល់ត្រូវនូវផោដ្ឋព្វារម្មណ៍ដោយកាយហើយ ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែមិនកួចកាន់នូវនិមិត្ត មិនកួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមកតែងជាប់តាមនូវបុគ្គល ដែលមិនសង្រួមនូវមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះ បានប្រកបព្រមដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះហើយ រមែងទទួលនូវអធិចិត្ត សុខដែលមិនបានច្របូកច្របល់ដោយកិលេស ក្នុងសន្តាននៃខ្លួន ។ ម្នាលមាណព ភិក្ខុជាអ្នករក្សានូវទ្វារ ក្នុងឥន្ទ្រិយទាំងឡាយយ៉ាងនេះឯង ។

[๑๒๔] *ម្នាលមាណព ភិក្ខុជាអ្នកប្រកបដោយសតិសម្បជញ្ញៈ តើ*

ដូចម្តេច ។ ម្នាលមាណព ភិក្ខុក្នុងសាសនានេះ កាលដើរទៅមុខ ឬថយក្រោយ ក៏មានសេចក្តីដឹងខ្លួន កាលក្រឡេកមើលទៅមុខ ឬក្រឡេកមើលទៅទិសផ្សេងៗ (ឆ្វេងស្តាំ) ក៏មានសេចក្តីដឹងខ្លួន កាលបត់ដៃជើង ឬលាដៃជើង ក៏មានសេចក្តីដឹងខ្លួន កាលទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ក៏មានសេចក្តីដឹងខ្លួន កាលបរិភោគភោជន ឬផឹកទឹក ទំពាស៊ីខាទនីយៈ លិទ្ធភ្លក់នូវភេសជ្ជៈ មានសប្បិជាដើម ក៏មានសេចក្តីដឹងខ្លួន កាលបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ក៏មានសេចក្តីដឹងខ្លួន កាលដើរ ឬឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ស្ងៀម ក៏មានសេចក្តីដឹងខ្លួន ម្នាលមាណព ភិក្ខុជាអ្នកប្រកបដោយសតិ និងសម្បជញ្ញៈយ៉ាងនេះឯង ។

[๑๒๕] ម្នាលមាណព ចុះភិក្ខុជាអ្នកសន្តោសតើដូចម្តេច ។ ម្នាលមាណព ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ភិក្ខុនោះ កាលបើចៀសចេញទៅក្នុងទិសណាៗ តែងកាន់យក (នូវគ្រឿងបរិក្ខារតែ ៨ ប៉ុណ្ណោះ) ជាប់ជាមួយនឹងខ្លួនចេញទៅ ម្នាលមាណព ប្រៀបដូចជាសត្វសកុណជាតិដែលមានស្លាប កាលហើរទៅក្នុងទិសណាៗ រមែងមានតែទម្ងន់ស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅដូចម្តេចមិញ ម្នាលមាណព ភិក្ខុជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ភិក្ខុនោះកាលបើចេញទៅទិសណាៗ តែងកាន់យក (នូវគ្រឿងបរិក្ខារតែ ៨ ប៉ុណ្ណោះ) ជាប់ជាមួយនឹងខ្លួនចេញទៅក៏ដូច្នោះឯង ។ ម្នាលមាណព ភិក្ខុជាអ្នកសន្តោសយ៉ាងនេះឯង ។

[๑๒๖] *ភិក្ខុនោះប្រកបដោយអរិយសីលក្ខន្ធនេះផង ប្រកបដោយ ឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិសម្បជញ្ញៈដ៏ប្រសើរនេះផង ប្រកបដោយសេចក្តីសន្តោស ដ៏ប្រសើរនេះផង តែងគប់រកនូវសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ជ្រោះភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃធ្លាយ ទីវាល គំនរចំបើង ឬស្តុកឈើ ។ ភិក្ខុនោះលុះត្រឡប់ពីបិណ្ឌបាតក្នុងវេលាខាងក្រោយនៃភត្តហើយ ក៏អង្គុយពត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខចំពោះ (ទៅរកកម្មដ្ឋាន) ។ ភិក្ខុនោះក៏លះបង់នូវអភិជ្ឈាក្នុងលោក គឺបញ្ចុបាទានក្ខន្ធ មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់នូវព្យាបាទ និងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជម្រះចិត្តឲ្យស្អាតចាកព្យាបាទ និងសេចក្តីប្រទូស្ត លះបង់នូវថីនមិទ្ធៈ គឺសេចក្តីធុញ្ង និងងោកងក់ ជាអ្នកប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់នូវពន្លឺ ជាអ្នកបរិបូណ៌ដោយសតិ និងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយ និងសេចក្តីរសាយចិត្ត មានចិត្តមិនរាយមាយ ជាអ្នកមានចិត្តស្ងប់ស្ងាត់ ក្នុងសន្តានរបស់ខ្លួន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់នូវវិចិកិច្ឆា គឺសេចក្តីសង្ស័យ ជាអ្នកឆ្លងផុតវិចិកិច្ឆាហើយ មិនមានសេចក្តីងឿងឆ្ងល់ក្នុងកុសលធម៌ទាំងឡាយទេ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។*

[๑๒๗] *ម្នាលមាណព ដូចជាបុរសដែលយកទ្រព្យជាបំណុលទៅប្រកបការងារទាំងឡាយ ឯការងារទាំងនោះរបស់បុរសនោះក៏បានសម្រេច ។*

បុរសនោះបានសងទ្រព្យជាដើមបំណុលចាស់រួច ឯទ្រព្យដែលចំណេញរបស់បុរសនោះ ក៏មានសល់នៅច្រើន ល្មមចិញ្ចឹមប្រពន្ធ (កូន) បាន ។ ទើបបុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញ បានយកទ្រព្យជាបំណុលមកប្រកបការងារទាំងឡាយ ឯការងារទាំងនោះ របស់អាត្មាអញបានសម្រេច អាត្មាអញសោត ក៏បានសងទ្រព្យជាដើមបំណុលចាស់អស់ហើយ ទាំងទ្រព្យដែលចំណេញរបស់អាត្មាអញ ក៏មានសល់នៅច្រើនល្មមចិញ្ចឹមប្រពន្ធ (កូន) បាន ។ បុរសនោះគប្បីបានទូវបាមោជ្ជ គឺសេចក្តីរីករាយ គប្បីបានទូវសេចក្តីសោមនស្សមានទ្រព្យដែលចំណេញនោះជាហេតុ ។ ម្នាលមាណព មួយទៀត ដូចជាបុរសដែលមានអាពាធ ដល់ទូវសេចក្តីទុក្ខវេទនាមានជំងឺធ្ងន់ បរិភោគអាហារក៏មិនបាន ទាំងកម្លាំងក្នុងខ្លួនក៏មិនមាន ។ លុះសម័យជាខាងក្រោយមក បុរសនោះឯង បានជាសះស្បើយអំពីអាពាធនោះ បរិភោគអាហារក៏បាន ទាំងកម្លាំងក្នុងខ្លួនក៏មាន ។ ទើបបុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញមានអាពាធ ដល់ទូវសេចក្តីទុក្ខវេទនាមានជំងឺធ្ងន់ បរិភោគអាហារក៏មិនបាន ទាំងកម្លាំងក្នុងខ្លួនក៏មិនមាន ឥឡូវនេះអាត្មាអញបានជាសះស្បើយ អំពីអាពាធនោះហើយ បរិភោគអាហារក៏បាន ទាំងកម្លាំងក្នុងខ្លួនក៏មាន ។ បុរសនោះ គប្បីបានទូវបាមោជ្ជ គប្បីបានទូវសេចក្តីសោមនស្ស មានជាអំពីអាពាធនេះជាហេតុ ។ ម្នាលមាណព មួយទៀតដូចជាបុរសដែលជាប់គុក លុះសម័យខាងក្រោយមក បុរសនោះបានរួចពីគុកនោះ ដោយសួស្តីឥតមានកិតភ័យ ទាំងសេចក្តីបង់ខាតនៃភោគៈរបស់

បុរសនោះ សូម្បីបន្តិចបន្តួចក៏មិនមាន ។ ទើបបុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញជាប់គុក ឥឡូវនេះអាត្មាអញបានរួចអំពីគុកនោះដោយសួស្តីឥតមានកិតភ័យ ទាំងសេចក្តីបង់ខាតនៃភោគៈ របស់អាត្មាអញសូម្បីបន្តិចបន្តួចក៏មិនមាន ។ បុរសនោះគប្បីបាននូវបាមោជ្ជ គប្បីបាននូវសេចក្តីសោមនស្ស មានការរួចអំពីគុកនោះជាហេតុ ។ ម្នាលមាណព មួយទៀត ដូចជាបុរសដែលជាទាសៈគេ តែងមិនបានធ្វើការអ្វីមួយតាមអំពើចិត្តរបស់ខ្លួន ប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ ទៅទីណាតាមសេចក្តីពេញចិត្តខ្លួន មិនបានទេ ។ លុះសម័យជាខាងក្រោយមក បុរសនោះបានរួចអំពីការៈនៃខ្លួន ជាទាសៈគេនោះ ជាអ្នកធ្វើការងារអ្វីមួយ តាមអំពើចិត្តរបស់ខ្លួនបាន មិនប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ បានរួចជាអ្នកជា ទៅទីណាតាមសេចក្តីពេញចិត្តរបស់ខ្លួនក៏បាន ។ បុរសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញជាទាសៈគេ មិនបានធ្វើការអ្វីមួយ តាមអំពើចិត្តរបស់ខ្លួន ប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ ទៅទីណាតាមសេចក្តីពេញចិត្តខ្លួនមិនបានឡើយ ឥឡូវនេះ អាត្មាអញរួចអំពីការៈនៃខ្លួនជាទាសៈគេហើយ ជាអ្នកធ្វើការងារអ្វីមួយ តាមអំពើចិត្តរបស់ខ្លួនបាន មិនប្រព្រឹត្តទៅតាមអំពើចិត្តរបស់បុគ្គលដទៃ បានជាអ្នកជា ទៅទីណា តាមសេចក្តីពេញចិត្តខ្លួនក៏បាន ។ បុរសនោះ គប្បីបាននូវបាមោជ្ជបាននូវសេចក្តីសោមនស្ស មានការរួចអំពីការៈនៃខ្លួនជាទាសៈគេនោះជាហេតុ ។ ម្នាលមាណព មួយទៀត ដូចបុរសដែលមានទ្រព្យ មានភោគៈ ដើរទៅកាន់ផ្លូវ

ឆ្ងាយជាច់ស្រយាល ដែលជាផ្លូវភេកអាហារបានដោយក្រ ជាផ្លូវប្រកបដោយភ័យចំពោះមុខ ។ លុះសម័យខាងក្រោយមក បុរសនោះក៏បានឆ្លងផុតអំពីផ្លូវជាច់ស្រយាលនោះ បានដល់ទៅខាងក្នុងស្រុក ដែលជាទីក្សេមឥតមានកិតភ័យ ដោយសួស្តី ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុន អាត្មាអញសោត ជាអ្នកមានទ្រព្យ មានភោគៈ បានដើរទៅកាន់ផ្លូវឆ្ងាយជាច់ស្រយាល ដែលជាផ្លូវភេកអាហារបានដោយក្រ ជាផ្លូវប្រកបដោយភ័យចំពោះមុខ ឥឡូវនេះ អាត្មាអញបានឆ្លងផុតអំពីផ្លូវឆ្ងាយជាច់ស្រយាលនោះហើយ បានចូលមកដល់ខាងក្នុងស្រុក ដែលជាទីក្សេម ឥតមានកិតភ័យដោយសួស្តី។ បុរសនោះក៏បានទទួលបាមោជ្ជ បានទទួលសេចក្តីសោមនស្ស មានការដល់មកខាងក្នុងស្រុក ជាទីក្សេមនោះជាហេតុ យ៉ាងណាមិញ ។ ម្នាលមាណព ភិក្ខុពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនេះក្នុងខ្លួន ដែលមិនទាន់លះបង់បាន ដូចជាបំណុល ដូចជាភេគ ដូចជាគុក ដូចជាអ្នកមិនរួចជាអ្នកជា ឬដូចជាផ្លូវឆ្ងាយជាច់ស្រយាល ដូច្នោះឯង ។ ម្នាលមាណព ភិក្ខុដែលពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនេះក្នុងខ្លួន ដែលលះបង់បានហើយ ដូចជាមិនជំពាក់បំណុល ដូចជាមិនមានភេគ ដូចរួចអំពីគុក ដូចជាអ្នករួចជាអ្នកជា ដូចជាទីដ៏ក្សេមដូច្នោះឯង កាលបើភិក្ខុនោះ ពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនេះក្នុងខ្លួន ដែលលះបង់បានហើយ បាមោជ្ជ គឺសេចក្តីរីករាយរមែងកើតឡើង កាលបើភិក្ខុនោះមានចិត្តរីករាយហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយរមែងស្ងប់រម្ងាប់ កាលបើភិក្ខុ

มានកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលមានសេចក្តីសុខ រមែងតាំងខ្ជាប់ ។ ភិក្ខុនោះ ក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកពួកអកុសលធម៌ ហើយបានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កវិចារៈ មានបីតិ និងសុខកើតអំពីសេចក្តីស្ងាត់ សម្រាន្តឥរិយាបថនៅ ។ ភិក្ខុនោះតែងញុំាងកាយនេះ ឲ្យជ្រួតជ្រាប ឲ្យស្កប់ស្កល់ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ មិនមានឡើយ ។ ម្នាលមាណព ដូចជាងកោរកាត់ក្តី កូនសិស្សរបស់ជាងកោរកាត់ក្តី ដែលជាអ្នកឈ្លាសវៃ រោយរាយនូវលម្អិតសម្រាប់ងូតក្នុងភាជន៍សំរឹទ្ធ ហើយស្រោចប្រោះព្រំដោយទឹក ឯដុំលម្អិតសម្រាប់ងូតនោះ ក៏រលាយទៅដោយទឹក ជ្រួតជ្រាបទៅក្នុងទឹក ច្រឡូកច្រឡំទៅដោយទឹក ទាំងខាងក្នុងខាងក្រៅ មិនបានខ្ចាត់ខ្ចាយពីគ្នាឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុបានសម្រេចបឋមជ្ឈាន ក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុស្ងាត់ចាកកាមទាំង-ឡាយហើយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ បានដល់នូវបឋម-ជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខ កើតអំពីសេចក្តីស្ងាត់ សម្រាន្តឥរិយាបថនៅ ភិក្ខុនោះតែងញុំាងកាយនេះ ឲ្យជ្រួតជ្រាប ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ

ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់ មិនមានឡើយ ដោយអំពើណា ។ អំពើនោះឯង ជាសមាធិរបស់ភិក្ខុនោះ ។

[๑๒๘] ម្នាលមាណព មួយវិញទៀត ភិក្ខុបានរម្ងាប់វិតក្ក វិចារៈហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាធម្មជាតជាក់ច្បាស់ក្នុងខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្ក វិចារៈ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន សម្រាន្តឥរិយាបថនៅ ។ ភិក្ខុនោះតែងញ៉ាំងកាយនេះ ឲ្យជ្រួតជ្រាប ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិ និងសុខដែលកើតអំពីសមាធិ មិនមានឡើយ ។ ម្នាលមាណព ដូចជាអន្ទង់ទឹកដ៏ជ្រៅ មានទឹកជោរឡើង ប្រឡាយជាទីហូរនៃទឹកក្នុងទិសខាងកើតនៃអន្ទង់ទឹកនោះ ក៏មិនមានឡើយ ប្រឡាយជាទីហូរនៃទឹកក្នុងទិសខាងត្បូង ក៏មិនមាន ប្រឡាយជាទីហូរនៃទឹកក្នុងទិសខាងលិចក៏មិនមាន ប្រឡាយជាទីហូរនៃទឹកក្នុងទិសខាងជើង ក៏មិនមាន បើមានភ្លៀងបង្អុរចុះនូវធារទឹក ដោយប្រពៃសព្វៗ កាល ធារទឹកត្រជាក់ ក៏ស្រោចតែជោរឡើងអំពីអន្ទង់ទឹកនោះ ហើយញ៉ាំងអន្ទង់ទឹកនោះឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់នោះឯង ប្រទេសបន្តិចបន្តួចនៃអន្ទង់ទឹកទាំងអស់នោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយទឹកត្រជាក់ មិនមានឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានទុតិយជ្ឈាន ក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុ

បានរម្ងាប់វិតក្ក និងវិចារៈហើយ ฯបេฯ បានដល់នូវទុតិយជ្ឈាន សម្រាន្ត តវិយោបថនៅ ភិក្ខុនោះតែងញ៉ាំងកាយនេះឲ្យជ្រួតជ្រាប ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសមាធិ មិនមានឡើយ ដោយអំពើណា ។ អំពើនេះឯង ជាសមាធិរបស់ភិក្ខុនោះដែរ ។

[๑๒๙] ម្នាលមាណព មួយវិញទៀត ភិក្ខុនឿយណាយចាកបីតិ ហើយប្រកបដោយឧបេក្ខាផង មានសតិ និងសម្បជញ្ញៈផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបានតតិយជ្ឈានថា បុគ្គលដែលបាននូវតតិយជ្ឈាន មានចិត្តប្រកបដោយឧបេក្ខា មានស្មារតី នៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ សម្រាន្តតវិយោបនថនៅ ។ ភិក្ខុនោះតែងញ៉ាំងកាយនេះឲ្យជ្រួតជ្រាប ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយសុខដែលប្រាសចាកបីតិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខ ដែលប្រាសចាកបីតិ មិនមានឡើយ ។ ម្នាលមាណព ដូចជាជលជាតិពួកខ្លះ គឺផ្កាព្រលឹតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងត្រពាំងព្រលឹតក្តី ក្នុងត្រពាំងឈូកក្រហមក្តី ក្នុងត្រពាំងឈូកសក្តី ដុះក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់តាម ទឹកលិចនៅក្នុងទឹក ឯជលជាតិទាំងនោះតែងជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់ រហូត

ដល់ចុង រហូតដល់គល់ អាយវៈបន្ទិចបន្ទួចនៃជលជាតិទាំងអស់ គឺព្រលឹតក្តី ឈូកក្រហមក្តី ឈូកសក្តី ឈ្មោះថា មិនបានផ្សព្វផ្សាយ ដោយទឹកត្រជាក់មិនមានឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានតតិយជ្ឈាន ក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុនឿយណាយចាកបីតិហើយ ។បេ។ ក៏បានដល់នូវតតិយជ្ឈាន សម្រាន្តឥរិយាបថនៅ ភិក្ខុនោះញុំាងកាយនេះ ឲ្យជ្រួតជ្រាប ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយសុខ ដែលប្រាសចាកបីតិ ប្រទេសបន្ទិចបន្ទួចនៃកាយទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខ ដែលប្រាសចាកបីតិមិនមានឡើយ ដោយអំពើណា ។ អំពើនេះ ជាសមាធិរបស់ភិក្ខុនោះឯងដែរ ។

[๑๓๐] ម្នាលមាណព មួយវិញទៀត ព្រោះលះបង់នូវសុខ ព្រោះលះបង់នូវទុក្ខ ព្រោះរម្ងាប់នូវសោមនស្ស និងទោមនស្សក្នុងកាលមុនហើយ ភិក្ខុក៏បានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍ មិនជាទុក្ខ មិនជាសុខ គឺជាឧបេក្ខា មានសតិបរិសុទ្ធ ដែលកើតអំពីឧបេក្ខា សម្រាន្តឥរិយាបថនៅ ។ ភិក្ខុនោះតែងញុំាងកាយនេះ ឲ្យផ្សព្វផ្សាយដោយចិត្តបរិសុទ្ធផូរផង់ អង្គុយនៅ ឯប្រទេសបន្ទិចបន្ទួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ មិនមានឡើយ ។ ម្នាលមាណព ដូចបុរសយកសំពត់សស្អាត ដណ្តប់កាយព្រមទាំងក្បាលអង្គុយនៅ ប្រទេសបន្ទិចបន្ទួចនៃកាយទាំងអស់ របស់បុរសនោះឯង ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសំពត់សស្អាត មិនមានឡើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុ

។បេ។ ម្នាលមាណព ភិក្ខុព្រោះលះបង់នូវសុខ ។បេ។ ក៏បានដល់ចតុត្ថជ្ឈាន សម្រាន្តឥរិយាបថនៅ ភិក្ខុនោះតែញ៉ាំងកាយនេះ ឲ្យផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់អង្គុយនៅ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយចិត្តដ៏សុទ្ធផូរផង់ មិនមានឡើយ ដូច្នោះឯង ដោយអំពើណា ។ អំពើនេះឯង ជាសមាធិរបស់ភិក្ខុនោះ ។ ម្នាលមាណព នេះឯងជាអរិយសមាធិក្ខន្ធនោះ ដែលសម្តេចព្រះមានព្រះភាគទ្រង់បានពោលសរសើរហើយ ទាំងទ្រង់ណែនាំប្រជុំជននេះ ឲ្យប្រតិបត្តិ ឲ្យតាំងនៅ ឲ្យប្រតិស្ឋាន ឯកិច្ចដែលគួរធ្វើតទៅក្នុងសាសនានេះនៅមានទៀត ។ សុភមាណព ពោលសរសើរថា បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះមិនធ្លាប់មាន បែរជាមានបានបពិត្រព្រះអានន្ទដ៏ចម្រើន ក៏អរិយសមាធិក្ខន្ធនោះ បរិបូណ៌ហើយ មិនមែនមិនបរិបូណ៌ទេ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណា មិនដែលឃើញនូវអរិយសមាធិក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះ ក្នុងពួកសមណព្រាហ្មណ៍ជនៃ ខាងក្រៅព្រះពុទ្ធសាសនានេះឡើយ បពិត្រព្រះអានន្ទដ៏ចម្រើន ឯពួកសមណព្រាហ្មណ៍ជនៃ ខាងក្រៅព្រះពុទ្ធសាសនានេះ គង់បានឃើញអរិយ-សមាធិក្ខន្ធ ដែលបរិបូណ៌ហើយយ៉ាងនេះ ក្នុងខ្លួនដែរ តែសមណព្រាហ្មណ៍ទាំងនោះឯង ពេញចិត្តដោយគុណត្រឹមតែសមាធិក្ខន្ធប៉ុណ្ណោះថា ល្មមហើយដោយគុណមានប្រមាណប៉ុណ្ណេះ សម្រេចហើយដោយគុណមានប្រមាណប៉ុណ្ណេះ ប្រយោជន៍នៃសាមញ្ញគុណ យើងបានដល់ហើយដោយលំដាប់ កិច្ច

នីមួយដែលយើងទាំងឡាយគប្បីធ្វើតទៅ មិនមានទេ្បីយ ។ ចំណែកព្រះអានន្ទដ៏ចម្រើន ពោលយ៉ាងនេះថា កិច្ចដែលគួរធ្វើតទៅ ក្នុងសាសនានេះ នៅមានទៀត ។

[๑๓๑] *មាណពសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះអរិយបញ្ញាខន្ធ ដែលព្រះគោតមដ៏ចម្រើន ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាននោះ តើដូចម្តេច ។ ព្រះអានន្ទតបថា កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ កិក្ខុនោះរមែងផ្ងន់ តម្រង់បង្អោនចិត្តទៅដើម្បីញ្ញាណទស្សនៈ ។ កិក្ខុនោះដឹងច្បាស់យ៉ាងនេះថា កាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតរូប ๔ កើតមកអំពីមាតាបិតា មានសេចក្តីចម្រើនដោយជាតិបាយ និងនំ មានការលាបជុសខាត់បំបាត់ភ្ជិនអាក្រក់ និងការគក់ច្របាច់ជានិច្ច និងការបែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ក៏វិញ្ញាណរបស់អាត្មាអញនេះ អាស្រ័យនៅក្នុងកាយនេះ ជាប់នៅក្នុងកាយនេះ ។ ម្នាលមាណព ដូចកែវពៃទូរ្យដ៏ល្អ មានជាតិដ៏បរិសុទ្ធ មានជ្រុង ๘ ដែលជាងបានច្នៃល្អហើយ មានសម្បុរភ្លឺថ្លា ជ្រះថ្លាដោយវិសេស បរិបូណ៌ដោយអាការទាំងពួង (មានជុសលាងជាដើម) ប្រសិនបើគេជោតអំបោះទៅក្នុងកែវនោះ ជាអំបោះមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី សសុទ្ធក្តី សស្រេទន់ក្តី បុរសដែលមានភ្នែកភ្លឺ គប្បីយកកែវមណីនោះមកដាក់លើដៃ*

ហើយ ពិចារណាមើលថា នេះជាកែវពៃទូរ្យដ៏ល្អ មានជាតិដ៏បរិសុទ្ធ មានជ្រុង ๘ ដែលជាងបានច្នៃល្អហើយ មានសម្បុរភ្លឺថ្លា ជ្រះថ្លាដោយវិសេស បរិបូណ៌ដោយអាការទាំងពួង អំបោះដែលគេជោតក្នុងកែវនោះ ជាអំបោះមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី សសុទ្ធក្តី សស្រេចន់ក្តី យ៉ាងណាមិញ ម្នាលមាណព កិក្ខុដែលបានញាណទស្សនៈ ក៏យ៉ាងនោះឯង ฯបេฯ ម្នាលមាណព កិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេសប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងាកម្មជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ តម្រង់ផ្ងង់បង្អោនចិត្តទៅដើម្បីញាណទស្សនៈ គឺវិបស្សនាញាណ កិក្ខុក៏ដឹងច្បាស់យ៉ាងនេះថា កាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតរូប ๔ កើតអំពីមាតាបិតា មានសេចក្តីចម្រើនដោយជាតិជាយ និងនំ មានការលាបដុសខាត់បំបាត់ក្លិនអាក្រក់ និងការគក់ច្របាច់ជានិច្ច និងការបែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ក៏ឯវិញ្ញាណរបស់អាត្មាអញនេះ អាស្រ័យនៅក្នុងកាយនេះ ជាប់នៅក្នុងកាយនេះ ដោយអំពើណា ฯ អំពើនេះឯង ជាបញ្ញារបស់កិក្ខុនោះ ฯ

[๑๓๒] *កិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីនិម្មិតនូវកាយដែលសម្រេចអំពីចិត្ត ฯ កិក្ខុនោះក៏និម្មិតនូវកាយដទៃចេញអំពីកាយនេះ មានរូបសម្រេចអំពីចិត្ត មាន*

អវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ ។ ម្នាលមាណព ដូចជាបុរសជកបណ្តុលចេញអំពីស្មៅយាប្ចង បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាស្មៅយាប្ចង នេះជាបណ្តុល ឯស្មៅយាប្ចងជាទៃ បណ្តុលជាទៃ តែថា បណ្តុលដែលអាត្មាអញជកចេញមក គឺជកចេញអំពីស្មៅយាប្ចងហ្នឹងឯង។ ម្នាលមាណព មួយទៀត ដូចជាបុរសហូតជាវចេញអំពីស្រោម បុរសនោះរមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាជាវ នេះជាស្រោម ឯជាវជាទៃ ស្រោមជាទៃ តែថា ជាវដែលអាត្មាអញហូតចេញ គឺហូតចេញអំពីស្រោមហ្នឹងឯង ។ ម្នាលមាណព ពុំនោះសោត ដូចបុរសទាញយកពស់ចេញអំពីស្រោម បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះជាពស់ នេះជាស្រោម ឯពស់ជាទៃ ស្រោមជាទៃ តែថា ពស់ដែលអាត្មាអញទាញចេញពីស្រោមហ្នឹងឯង ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានញាណទស្សនៈក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីនិម្មិតនូវកាយដែលសម្រេចមកអំពីចិត្ត ដោយអំពើណា ។បេ។ អំពើនេះឯងជាបញ្ញារបស់ភិក្ខុនោះ ។

[๑๓๓] *ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់គួរដល់កាវនាកម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីតាក់តែងឫទ្ធិ ។ ភិក្ខុនោះ រមែងបាននូវការតាក់តែងឫទ្ធិ*

ជាច្រើនប្រការ គឺថា មនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង និងទីខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន ។ ភិក្ខុនោះ ធ្វើនូវការងើបឡើង ឬមុជចុះក្នុងផែនដី ដូចជាងើបឡើង ឬមុជចុះក្នុងទឹកក៏បាន ដើរលើទឹកក៏មិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែន ដូចជាសត្វសកុណជាតិដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែលចាប់ពាល់ព្រះចន្ទ និងព្រះអាទិត្យនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ ម្នាលមាណព មួយទៀត ដូចជាស្មូនធ្នាំងក្តី កូនសិស្សរបស់ស្មូនធ្នាំងក្តី ដែលឈ្លាសវៃ កាលបើដីស្អិតដែលគេធ្វើបរិកម្មល្អហើយ បើប្រាថ្នានឹងធ្វើភាជន៍ដ៏ប្លែកណាៗ ក៏គប្បីធ្វើឲ្យសម្រេចនូវភាជន៍នោះៗ បាន ម្នាលមាណព ពុំនោះសោត ដូចជាជាងភ្លុកក្តី កូនសិស្សរបស់ជាងភ្លុកក្តី ដែលឈ្លាសវៃ កាលបើភ្លុកដែលគេធ្វើបរិកម្មល្អហើយ បើចង់ធ្វើនូវគ្រឿងប្រើប្រាស់ជាវិការនៃភ្លុកដ៏ប្លែកណាៗ គប្បីធ្វើឲ្យសម្រេចនូវគ្រឿងប្រើប្រាស់ជាវិការនៃភ្លុកដ៏ប្លែកនោះៗ បាន ម្នាលមាណព ពុំនោះសោត ដូចជាជាងមាសក្តី កូនសិស្សរបស់ជាងមាសក្តីដែលឈ្លាសវៃ កាលបើមាសដែលគេធ្វើបរិកម្មល្អហើយ បើចង់ធ្វើគ្រឿងប្រើប្រាស់ជាវិការនៃមាសដ៏ប្លែកណាៗ ក៏គប្បីធ្វើឲ្យសម្រេចនូវគ្រឿងប្រើប្រាស់ជាវិការនៃមាសដ៏ប្លែកនោះៗ បាន ដូចម្តេចមិញ ម្នាល

មាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីតាក់តែងឫទ្ធិបាន ភិក្ខុនោះរមែងបាននូវការតាក់តែងឫទ្ធិ ជាច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន ។បេ។ ញុំងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[๑๓๔] *ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅដើម្បីទិព្វសោតធាតុ (ត្រចៀកទិព្វ) ។ ភិក្ខុនោះរមែងឮនូវសំឡេងពីរយ៉ាងបាន គឺសំឡេងជាទិព្វ ๑ សំឡេងជារបស់មនុស្សធម្មតា ๑ ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដោយទិព្វសោតធាតុដ៏បរិសុទ្ធស្អាត កន្លងបង់នូវសោតធាតុ ជារបស់មនុស្សធម្មតា ។ ម្នាលមាណព ដូចបុរសអ្នកដើរទៅកាន់ផ្លូវឆ្ងាយ បុរសនោះឮនូវសំឡេងស្គរធំក្តី សំឡេងសម្ភោរក្តី សំឡេងស័ង្ខក្តី សំឡេងស្គរជ័យក្តី សំឡេងស្គរតូចក្តី បុរសនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា សំឡេងស្គរធំដូច្នេះក្តី សំឡេងសម្ភោរដូច្នេះក្តី សំឡេងស័ង្ខដូច្នេះក្តី សំឡេងស្គរជ័យដូច្នេះក្តី សំឡេងស្គរតូចដូច្នេះក្តី ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានទិព្វសោត-ធាតុក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ រមែងឮសំឡេងពីរយ៉ាងបាន*

គឺសំឡេងជាទិព្វ ๑ សំឡេងជារបស់មនុស្សធម្មតា ๑ ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តីដោយទិព្វសោតធាតុដ៏បរិសុទ្ធស្អាត កន្ទងបង់នូវសោតធាតុជារបស់មនុស្សធម្មតា ។ អំពើនេះឯង ជាបញ្ញារបស់កិក្ខុនោះ ។

[๑๓๕] *កិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅដើម្បីចេតោបរិយញ្ញាណ គឺការកំណត់ដឹងនូវចិត្តនៃសត្វដទៃ ។ កិក្ខុនោះ ក៏កំណត់ដឹងនូវចិត្តរបស់ពួកសត្វដទៃ បុគ្គលដទៃដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តដែលរួញថយក្តី ក៏ដឹងច្បាស់ថា ចិត្តរួញថយ ចិត្តដែលរាយមាយក្តី ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ គឺចិត្តដល់នូវការៈជាធំ បានខាងរូបាវចរ និងអរូបាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈ គឺកាមាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈ គឺកាមាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្តដែលជា*

អនុត្តរៈ គឺជារូបាវចរ និងអរូបាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តដែលតាំងខ្ជាប់ខ្ជួនក្តី ក៏ដឹងច្បាស់ថា ចិត្តតាំងខ្ជាប់ខ្ជួន ចិត្តដែលមិនទាន់បានតាំងខ្ជាប់ខ្ជួនក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់បានតាំងខ្ជាប់ខ្ជួន ចិត្តដែលរួចស្រឡះ (ចាកកិលេស) ហើយក្តី ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះហើយ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។ ម្នាលមាណព ដូចស្ត្រីក្តី បុរសក្តី ដែលនៅក្មេងជាក្រមុំកំលោះ នៅកំពុងចូលចិត្តនឹងគ្រឿងប្រដាប់តាក់តែងរាងកាយ កាលឆ្លុះមើលស្រមោលមុខរបស់ខ្លួននៅក្នុងកញ្ចក់ដ៏ស្អាតផូរផង់ក្តី ក្នុងភាជន៍ដ៏ពេញដោយទឹកថ្លាក្តី បើស្រមោលមុខរបស់ខ្លួនប្រកបដោយទោស មានមុន (ជាដើម) ក្តី ក៏ដឹងថា ប្រកបដោយទោស បើស្រមោលមុខរបស់ខ្លួនមិនប្រកបដោយទោសក្តី ក៏ដឹងថាមិនប្រកបដោយទោស ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានចេតោបរិយ-ញ្ញាណ ក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុបើចិត្តតាំងខ្ជាប់ខ្ជួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅដើម្បីចេតោបរិយញ្ញាណ ។ ភិក្ខុនោះ ក៏កំណត់ដឹងនូវចិត្តរបស់ពួកសត្វដទៃ បុគ្គលដទៃដោយចិត្តរបស់ខ្លួន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ។បេ។ ចិត្តមិនទាន់បានរួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់បានរួចស្រឡះ ដោយអំពើណា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[๑๓๖] *ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន ។បេ។ មិនញាប់ញ័រទៅ*

តាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះ ក៏រឭកនូវខន្ធដែលសត្វអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ រឭកខន្ធដូចម្តេច គឺរឭកបាន ๑ ជាតិ ๒ ជាតិ ๓ ជាតិ ๔ ជាតិ ๕ ជាតិ ๑๐ ជាតិ ๒๐ ជាតិ ๓๐ ជាតិ ๔๐ ជាតិ ๕๐ ជាតិ ๑๐๐ ជាតិ ๑ ពាន់ជាតិ ๑ សែនជាតិក៏បាន រឭកនូវសំវដ្តកប្បជាច្រើនក៏បាន វិវដ្តកប្បជាច្រើនក៏បាន សំវដ្តវិវដ្តកប្បជាច្រើនក៏បានថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ។ ភិក្ខុនោះ រឭកបានន្ទូវខន្ធដែលខ្លួនអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ ព្រមទាំងអាការ គឺសម្បុរ និងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះ និងគោត្រយ៉ាងនេះ ។ ម្នាលមាណព ដូចបុរសចេញអំពីស្រុករបស់ខ្លួន ហើយទៅកាន់ស្រុកដទៃ ចេញអំពីស្រុកនោះហើយទៅកាន់ស្រុកដទៃទៀត បុរសនោះឯង ក៏ត្រឡប់មកស្រុកនោះ មកកាន់ស្រុករបស់ខ្លួនវិញ ហើយបុរសនោះក៏នឹករឭកឃើញយ៉ាងនេះថា អាត្មាអញបានចេញអំពីស្រុករបស់ខ្លួនហើយ ទៅកាន់ស្រុកឯណោះដែលទៅដល់ស្រុកនោះ

អាត្មាអញបានឈរយ៉ាងនេះ បានអង្គុយយ៉ាងនេះ បាននិយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ លុះអាត្មាអញចេញអំពីស្រុកនោះហើយ ទៅកាន់ស្រុកឯណោះ ដែលទៅដល់ស្រុកនោះ អាត្មាអញបានឈរយ៉ាងនេះ បានអង្គុយយ៉ាងនេះ បាននិយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ ឥឡូវនេះ អាត្មាអញត្រឡប់មកពីស្រុកនោះ មកកាន់ស្រុករបស់ខ្លួនវិញហើយ ដូចម្តេចមិញ ម្នាលមាណព ភិក្ខុដែលបានបុព្វេនិវាសានុស្សតិញ្ញាណ ក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្លួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះក៏រឭកនូវបុព្វេនិវាសជាច្រើនប្រការ រឭកបានដូចម្តេច គឺរឭកបាន ๑ ជាតិ ๒ ជាតិ ។បេ។ ភិក្ខុនោះ រឭកបាននូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ដោយអំពើណា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[๑๓๗] *ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្លួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីសត្តានំចុតូ-បបាតញ្ញាណ គឺសេចក្តីដឹងនូវចុតិ និងឧបបជិសន្ធិនៃសត្វទាំងឡាយ ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វជ័ប្បវិសុទ្ធ កន្លងបង់នូវចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយដែលច្យុតដែលកើត ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងអម្បាលនេះប្រកប*

ដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកជៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់អំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះលុះរំលាងកាយទៅបន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគតិ វិនិបាត នរក មួយសោត អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះជៀលនូវព្រះអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ សត្វទាំងនោះលុះដល់រំលាងកាយទៅ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងលោក គឺ មនុស្ស សុគតិ និងសួគ៌ ភិក្ខុនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្ទងបង់នូវចក្ខុជារបស់មនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយដែលច្យុត ដែលកើត ជាសត្វទាបថោក ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះឯង ។ ម្នាលមាណព ដូចជាប្រាសាទដែលតាំងនៅក្បែរផ្លូវត្រឡែងកែង ជាកណ្តាលក្រុង បុរសមានភ្នែកភ្លឺ ឈរលើប្រាសាទនោះ គប្បីឃើញនូវមនុស្សទាំងឡាយ ដែលចូលទៅកាន់ផ្ទះក្តី ចេញអំពីផ្ទះក្តី ត្រាច់សញ្ជរអំពីច្រកផ្លូវទៅកាន់ថ្នល់ក្តី ដែលអង្គុយក្បែរផ្លូវត្រឡែងកែង នាកណ្តាលក្រុងក្តី បុរសនោះ ក៏ដឹងច្បាស់យ៉ាងនេះថា មនុស្សទាំងនុ៎ះ ដើរចូលទៅកាន់ផ្ទះ មនុស្សទាំងនុ៎ះ ចេញមកអំពីផ្ទះ មនុស្សទាំងនុ៎ះសញ្ជរអំពីច្រកផ្លូវទៅកាន់ថ្នល់ មនុស្សទាំងនុ៎ះ អង្គុយនៅក្បែរផ្លូវត្រឡែងកែង នាកណ្តាលក្រុង ដូចម្តេចមិញ ម្នាលមាណព

ភិក្ខុដែលបានសត្តានំចុតូបបាតញ្ញាណក៏ដូច្នោះឯង ។បេ។ ម្នាលមាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីសត្តានំចុតូបបាតញ្ញាណ ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្ទងបង់នូវចក្ខុជារបស់មនុស្ស ធម្មតារមែងឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វទាបថោក ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយអំពើណា ។ អំពើនេះឯង ជាបញ្ញារបស់ភិក្ខុនោះ ។

[๑๓๘] *ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ គឺសេចក្តីដឹងនូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ។ ភិក្ខុនោះក៏ដឹងតាមពិតថា នេះជាទុក្ខ ដឹងតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងតាមពិតថា នេះជាបដិបទា នាំឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ដឹងតាមពិតថា នេះជាអាសវៈ ដឹងតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងតាមពិតថា នេះជាសេចក្តីរលត់អាសវៈ ដឹងតាមពិតថា នេះជាបដិបទានាំឲ្យបានដល់នូវសេចក្តីរលត់អាសវៈ ។ កាលបើភិក្ខុនោះដឹងយ៉ាងនេះ ឃើញ*

យ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង ។ កាលបើចិត្តផុតស្រឡះហើយ សេចក្តីដឹងក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ ភិក្ខុនោះក៏ដឹងច្បាស់ថា កំណើតអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡកិច្ចអាត្មាអញបានធ្វើស្រេចហើយ ករណីយកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលមាណព ដូចជាអន្ទង់ទឹកលើកំពូលភ្នំ ដែលថ្លាឈ្វង ឥតមានកកស្អុក បុរសដែលមានភ្នែកភ្លឺ ឈរទៀបមាត់នៃអន្ទង់ទឹកនោះ គប្បីឃើញនូវខ្យង និងគ្រួក្តី ដុំក្រួស និងបំណែកក្តី ហ្វូងត្រីដែលហែលទៅមក ឬឋិតនៅក្តី បុរសនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អន្ទង់ទឹកនេះឯងថ្លាឈ្វង ឥតមានកកស្អុកខ្យង និងគ្រួទាំងឡាយនេះក្តី ដុំក្រួស និងបំណែកទាំងឡាយនេះក្តី ហ្វូងត្រីទាំងឡាយនេះ ដែលកំពុងហែលទៅមក ឬកំពុងឋិតនៅក្តី ក្នុងអន្ទង់ទឹកនោះយ៉ាងណាមិញ ម្នាលមាណព ភិក្ខុដែលបានអាសវក្ខយញ្ញាណ ក៏យ៉ាងនោះឯង ។បេ។ ម្នាលមាណព ភិក្ខុកាលបើចិត្តតាំងខ្ជាប់ខ្ជួន ។បេ។ មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ។ ភិក្ខុនោះ ក៏ដឹងតាមពិតថា នេះជាទុក្ខ ។បេ។ ដឹងតាមពិតថា នេះជាបដិបទានាំឲ្យបានដល់នូវសេចក្តីរលត់អាសវៈ ។ ភិក្ខុនោះកាលបើដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង ។ កាល

បើចិត្តផុតស្រឡះហើយ សេចក្តីដឹង ក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ ភិក្ខុនោះក៏ដឹងច្បាស់ថា កំណើតនៃអាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើស្រេចហើយ ការណីយកិច្ចដទៃនៃអាត្មាអញ ដែលប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ដោយអំពើណា ។ អំពើនេះឯងជាបញ្ញារបស់ភិក្ខុនោះ ។

[๑๓๙] ម្នាលមាណព នេះឯងជាអរិយបញ្ញាខន្ធ ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បានពោលសរសើរហើយ ទាំងបានណែនាំប្រជុំជននេះឲ្យតាំងនៅ ឲ្យប្រតិស្ឋាន កិច្ចដែលគួរធ្វើតទៅទៀតក្នុងសាសនានេះ មិនមានឡើយ ។ សុភមាណពពោលសរសើរថា បពិត្រព្រះអានន្ទដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះ មិនធ្លាប់មាន បែរជាមានបាន បពិត្រព្រះអានន្ទដ៏ចម្រើន អរិយបញ្ញាខន្ធនោះ បរិបូណ៌ហើយ មិនមែនមិនបរិបូណ៌ទេ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណាមិនដែលឃើញនូវអរិយ-បញ្ញាខន្ធ ដែលបរិបូណ៌យ៉ាងនេះ ក្នុងសមណព្រាហ្មណ៍ទាំងឡាយដទៃ ខាងក្រៅព្រះពុទ្ធសាសនានេះឡើយ កិច្ចទីមួយដែលយើងទាំងឡាយ គប្បីធ្វើតទៅទៀត មិនមានឡើយ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលលោកម្ចាស់សម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ (ក្តីច្បាស់ណាស់) ដូចជាគេផ្ងារនូវកាជន៍ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំ

នោះដូចជាគេប្រាប់ផ្លូវ ដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាគេបំភ្លឺប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុ (ភ្លឺ) នឹងមើលឃើញរូបទាំងឡាយ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណានេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះអានន្ទដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះករុណា ថាជាឧបាសក ដល់នូវសរណាគមន៍ស្មើដោយជីវិត ។

សុភសូត្រទី ១០ ចប់

អដ្ឋកថា

សុភសូត្រ

សុភមាណវកកថា

[១១៦] *សុភសូត្រមានពាក្យផ្តើមថា* **ឯវម្មេ សុតំ ។បេ។ សាវត្ថិយំ** *ជាដើម ។*

តទៅនេះជាការអធិប្បាយបទ ដែលលំបាកក្នុងសុភសូត្រនោះ បទថា **អចិរបរិនិព្វុតេ ភគវតិ** *អធិប្បាយថា កាលព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វាន ហើយមិនយូរ ប្រមាណ ១ ខែ បន្ទាប់ពីថ្ងៃបរិនិព្វាន សេចក្តីនេះ លោកពោលសំដៅដល់ថ្ងៃដែលព្រះអានន្ទកាន់បាត្រ និងចីវរបស់ព្រះដ៏មានព្រះភាគ ហើយមកគង់ឆាន់ថ្នាំបញ្ចុះផ្សុំដោយទឹកដោះក្នុងវិហារ ដោយនយដែលពោលហើយក្នុងពាហិរនិទាន ។*

[១១៧] *បទថា* **តោទេយ្យបុត្តោ** *ប្រែថា បុត្ររបស់តោទេយ្យ-ព្រាហ្មណ៍ មានរឿងតំណាលថា មិនឆ្ងាយពីក្រុងសាវត្ថី មានស្រុកមួយឈ្មោះតុទិគ្រាម ព្រោះព្រាហ្មណ៍ជាអ្នកធំ ក្នុងស្រុកតុទិគ្រាម ទើបមានឈ្មោះថា តោទេយ្យព្រាហ្មណ៍ មានទ្រព្យសម្បត្តិប្រមាណ ៤៥ កោដិ តែគាត់ជាអ្នកកំណាញ់យ៉ាងក្រៃលែង គាត់គិតថា ឈ្មោះថា ការមិនអស់នៃភោគសម្បត្តិរមែងមិនមានដល់អ្នកឲ្យ ហើយគាត់ក៏មិនឲ្យអ្វីដល់បុគ្គលណាមួយ គាត់ទូន្មានបុត្រថា បុគ្គលអ្នកឈ្លាសវៃ គួរមើលការអស់ទៅនៃថ្នាំបន្តក់ភ្នែក ការធ្វើដំបូករបស់កណ្តៀរ ការធ្វើសម្បករបស់ឃ្មុំ ហើយគប្បីគ្រប់គ្រងផ្ទះ កាលគេឲ្យបុត្រសញ្ជឹងគិតដល់ការមិនឲ្យយ៉ាងនេះហើយ កាលស្លាប់ទៅក៏ទៅកើត*

ជាឆ្កែ នៅត្រង់ផ្ទះនោះឯង សុភមាណពជាបុត្រ ស្រឡាញ់ឆ្កែនោះណាស់ ឲ្យ
សុីអាហារដូចគ្នានឹងខ្លួន ពាដេកលើទីដេកយ៉ាងល្អ ។ ថ្ងៃមួយ កាលសុភ-
មាណពចេញអំពីស្រុកទៅ ព្រះដ៏មានព្រះភាគទ្រង់ចូលទៅបិណ្ឌបាតក្នុងស្រុក
នោះ ឆ្កែឃើញព្រះដ៏មានព្រះភាគ ទើបព្រុសរត់ចូលទៅជិតព្រះអង្គ ព្រះដ៏
មានព្រះភាគ បានត្រាស់ចំពោះឆ្កែនោះថា ម្នាលតោទេយ្យៈ កាលមុន អ្នកឯង
ក៏ពោលមើលងាយតថាគតថា នែលោក នែលោក ដូច្នេះ ទើបកើតជាឆ្កែ
ឥឡូវនេះ អ្នកឯងក៏នៅតែព្រុសតថាគត អ្នកនឹងធ្លាក់ទៅអវីចីមហានរក ។ ឆ្កែ
ស្តាប់ដូច្នោះ ទើបមានសេចក្តីក្តៅក្រហាយ ដេកលើផេះក្នុងចង្រ្កាន ។ ពួក
មនុស្សមិនអាចនឹងលើកត្រកងពាទៅ ឲ្យដេកលើទីដេកបាន ។ សុភមាណព
ត្រឡប់មកដល់សួរថា អ្នកណានាំឆ្កែនេះចុះពីទីដេក ។ ពួកមនុស្សទាំងឡាយ
នាំគ្នាប្រាប់ថា មិនមានអ្នកណាធ្វើ ហើយតំណាលរឿង៉ាវឲ្យស្តាប់ ។ សុភ-
មាណពបានស្តាប់ហើយ ខឹងក្រោធ គិតថា ឪពុករបស់អញកើតក្នុងព្រហ្ម-
លោក តែព្រះសមណគោតមហាមាត់ថា ឪពុករបស់អញជាឆ្កែ សមណៈនេះ
មាត់អាក្រក់ ប្រាថ្នានឹងជំទាស់ជាមួយព្រះដ៏មានព្រះភាគថា និយាយកុហក
ទើបទៅកាន់វិហារសួររឿង៉ាវនឹងព្រះអង្គ ។

ទើបព្រះដ៏មានព្រះភាគ ត្រាស់ដល់សុភមាណពយ៉ាងនោះ ហើយ
ត្រាស់សេចក្តីពិតថា ម្នាលសុភមាណព ទ្រព្យដែលបិតារបស់អ្នកឯងមិនទាន់
បានប្រាប់មានទេ ។ សុភមាណពទូលថា បពិត្រព្រះគោតម មួកមាសមាន
តម្លៃមួយសែន ស្បែកជើងមាសមានតម្លៃមួយសែន ថាសមាសមានតម្លៃ
មួយសែន កហាបណៈមួយសែនមាន ។ ព្រះមានព្រះភាគត្រាស់ថា អ្នកចូរ

ទៅឲ្យឆ្អែបរិភោគមធុបាយាសមានទឹកតិច ហើយបីទៅកាន់ទីដេក ពេលឆ្អែលក់មួយស្របក់ ចូរសួរមើល ឆ្អែនឹងប្រាប់វត្ថុគ្រប់យ៉ាងដល់អ្នក ពេលនោះ ឯង អ្នកនឹងដឹងថា ឆ្អែនោះ គឺបិតារបស់អ្នក ។ សុភមាណព បានធ្វើតាមនោះ ។ ឆ្អែក៏ប្រាប់វត្ថុគ្រប់យ៉ាង សុភព្រាហ្មណ៍ដឹងពិតថា ឆ្អែនោះ គឺបិតារបស់ខ្លួន ទើបជ្រះថ្លាក្នុងព្រះដ៏មានព្រះភាគ ទៅទូលសួរបញ្ហា ១៤ ប្រការ ចំពោះព្រះមានព្រះភាគ កាលចប់បញ្ហាសុភមាណព សូមដល់ព្រះមានព្រះភាគ ជាសរណៈ លោកពោលសេចក្តីនោះ សំដៅដល់សុភមាណព-តោទេយ្យបុត្រនេះ ។

បទថា **សាវត្ថិយំ បដិវសតិ** *សេចក្តីថា សុភមាណពមកអំពីភោគ-គ្រាមរបស់ខ្លួន ហើយអាស្រ័យនៅ ។ បទថា* **អញ្ញតរំ មាណវកំ អាមន្តេសិ** *សេចក្តីថា កាលព្រះសាស្តាទ្រង់បរិនិព្វានហើយ សុភមាណពបានស្តាប់ថា ព្រះអានន្ទកាន់បាត្រ និងចីវររបស់ព្រះអង្គមក មហាជន រមែងចូលទៅរកលោកដើម្បីសួរសុខទុក្ខ ដូច្នេះ ទើបគិតថា កាលយើងនឹងទៅវិហារ ក៏គង់មិនអាចធ្វើបដិសណ្ឋារៈ ឬស្តាប់ធម្មកថាបានសប្បាយត្រង់កណ្តាលពួកជនជាច្រើន ឃើញលោកមកកាន់ផ្ទះនុ៎ះឯង នឹងធ្វើបដិសណ្ឋារៈបានដោយងាយ ហើយអញមានសេចក្តីសង្ស័យក្នុងប្រការមួយ អញក៏នឹងសួរលោក ទើបហៅមាណពម្នាក់មក ។ វេទនាដែលជាសត្រូវ លោកពោលថា អាពាធ ក្នុងបទជាដើមថា* **អប្បាពាធំ** *នេះ ។ សុភមាណពពោលថា វេទនាណាកើតក្នុងចំណែកមួយ ហើយប្រកាន់ទុកនូវឥរិយាបថ ៤ ដូចយកផែនដែកសង្កត់ អ្នកចូរសួរសេចក្តីមិនមាននៃវេទនានោះ ។ បទថា* **អប្បាតង្កំ** *លោកពោល*

ដល់រោគដែលធ្វើជីវិតឲ្យលំបាក អ្នកចូរសួរការមិនមាននៃរោគនោះ ។ សុភ-មាណពពោលថា ឈ្មោះថា ការក្រោកឡើងរបស់អ្នកជំងឺនុ៎ះឯង រមែងធ្ងន់កម្ចាំងកាយរមែងមិនមាន ព្រោះដូច្នោះ អ្នកចូរសួរការមិនមានជំងឺ និងការមានកម្ចាំង ។

បទថា **ផាសុវិហារំ** *សេចក្តីថា អ្នកចូរសួរការរស់នៅជាសុខ ក្នុងឥរិយាបថ ๔ គឺដើរ ឈរ អង្គុយ ដេក ការព្រះគន្ថរចនាចារ្យសម្តែងដល់អាការដែលគួរសួរដល់មាណពនោះ ទើបពោលពាក្យថា* **សុភោ** *ជាដើម ។*

[๑๑๘] *បទថា* **កាលញ្ញូ សមយញ្ញូ ឧចាឋាយ** *សេចក្តីថា កាន់ គឺពិចារណាវេលា និងសម័យដោយបញ្ញា មានអធិប្បាយថា បើស្អែកនេះនឹងជាវេលាទៅរបស់យើង កម្ចាំងរបស់យើងនឹងជ្រួតជ្រាបទៅក្នុងកាយ នឹងមិនមានការមិនសប្បាយយ៉ាងដូច្នេះ ព្រោះការទៅជាហេតុ ពេលនោះយើងនឹងពិចារណា វេលានោះ និងសម័យ ពោល គឺការទៅ ហេតុ ពួក ក្រុម បើយ៉ាងណា គប្បីមកក្នុងថ្ងៃស្អែកនេះ ។*

[๑๑๙] *បទថា* **ចេតកេន ភិក្ខុនា** *សេចក្តីថា បានឈ្មោះថា* **ចេតក** *ព្រោះកើតក្នុងចេតិយរដ្ឋ ។ បទថា* **សម្មោទនីយំ កថំ សារាណីយំ** *សេចក្តីថា សុភមាណពបានពោលសម្មោទនីយកថាល្មមឲ្យរឭកដល់គ្នា ដែលជាប់ទាក់ទងនឹងមរណៈ បានកន្លងទៅហើយ ដោយនយជាដើមយ៉ាងនេះថា ព្រះអានន្ទ ព្រះសាស្តាមានរោគអ្វី ព្រះដ៏មានព្រះភាគសោយអ្វី មួយវិញទៀត សេចក្តីសោកបានកើតឡើងដល់លោកម្ចាស់ទាំងឡាយ ដោយការបរិនិព្វានរបស់ព្រះសាស្តា ព្រះសាស្តារបស់លោកម្ចាស់ទាំងឡាយ បរិនិព្វានហើយ*

តែម្យ៉ាងក៏ទេ សេចក្តីសាបសូន្យដ៏ធំក៏កើតដល់មនុស្សលោក ព្រមទាំងទេវ-លោក ឥឡូវនេះ អ្នកដទៃណាហ្ន៎ នឹងផុតសេចក្តីស្ងាប់ បុគ្គលដ៏ប្រសើរ របស់មនុស្សលោក ព្រមទាំងទេវលោក គង់បរិនិព្វានបាន ឥឡូវនេះ មច្ចុរាជ នឹងខ្វាសអ្នកណា សុភមាណពប្រគេនអាហារ ដែលសមគួរដល់ការធាន់ និង កេសជ្ជៈដល់ព្រះថេរៈកាលថ្ងៃម្សិលមិញ កាលសម្រេចភត្តកិច្ច ទើបអង្គុយ ក្នុងចំណែកម្ខាង ។ បទថា **ឧបដ្ឋាកោ សន្តិកាវចរោ** *សេចក្តីថា ជាឧបដ្ឋាក នៅក្នុងសម្នាក់ មិនស្វែងរកទោស ។ បទថា* **សមីបចារី** *នេះ ជាវេវចនៈ របស់បទមុន ព្រោះហេតុអ្វី ទើបសុភមាណពសួរថា ព្រះគោតមបានត្រាស់ សរសើរគុណនៃធម៌ពួកណា ។បានឮថា សុភមាណពមានបរិវិតក្កយ៉ាងនេះថា ព្រះគោតមដ៏ចម្រើន ញុំាងមនុស្សលោកនេះឲ្យតាំងនៅក្នុងធម៌ទាំងឡាយណា ធម៌ទាំងឡាយនោះ កាលព្រះគោតមបរិនិព្វានទៅហើយ សាបសូន្យទៅដែរឬ ហ្ន៎ ឬតាំងនៅ បើតាំងនៅ ព្រះអានន្ទនឹងដឹង ខ្ញុំសូមឱកាសសួរ ដូច្នេះ ព្រោះ ហេតុនោះ ទើបសុភមាណពសួរ ។ គ្រានោះ ព្រះថេរៈបានសង្គ្រោះបិដក ៣ ដោយខន្ធ ៣ កាលនឹងសម្តែងដល់សុភមាណព ទើបពោលថា* **តិណ្ណំ ខោ** *ដូច្នេះជាដើម ។ សុភមាណពគិតថា អញកំណត់សេចក្តី ដែលលោកពោល ដោយសង្ខេបមិនបាន នឹងសួរដោយពិស្តារ ទើបពោលថា* **កតមេសំ តិណ្ណំ** *ដូច្នេះជាដើម ។*

សីលក្ខន្ធ

[១២០-១២១] *កាលព្រះអានន្ទសម្តែងខន្ធទាំងនោះ ដោយបទថា* **អរិយស្ស សីលក្ខន្ធស្ស** *ដូច្នេះ ទើបសុភមាណពសួរជាសេចក្តីមួយៗ ទៀត*

ថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះអរិយសីលក្ខន្ធ ... តើដូចម្តេច ។ សូម្បី ព្រះថេរៈក៏សម្តែងដល់ការកើតឡើងរបស់ព្រះពុទ្ធ ដល់សុភមាណពនោះ គ្រា នឹងសម្តែងធម៌ដែលជាបែបផែន ទើបវិសជ្ជនាធម៌ទាំងពួង ដោយន័យដែល ព្រះដ៏មានព្រះភាគត្រាស់ដោយលំដាប់នោះឯង ។

[๑๒๒] ក្នុងបទថា **អត្ថិ ចេវេត្ត ឧត្តរឹ ករណីយំ** លោកសម្តែងថា ក្នុងសាសនារបស់ព្រះមានព្រះភាគនេះ មិនមែនត្រឹមតែសីលប៉ុណ្ណោះ ដែល មានសារៈ សីលនោះត្រឹមតែជាបាទតែម្យ៉ាងប៉ុណ្ណោះ នៅមានកិច្ចដទៃ ដែល ត្រូវធ្វើក្រៃលែងជាងនេះទៀត ។ បទថា **ឥតោ ពហិទ្ធា** គឺខាងក្រៅពីព្រះ ពុទ្ធសាសនា ។

[๑๒๓-๑๒๙] បទថា **កថញ្ច មណាវ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ** ព្រះអានន្ទសូម្បីត្រូវសួរដល់សមាធិក្ខន្ធយ៉ាងនេះថា បពិត្រព្រះអានន្ទ ដ៏ចម្រើន ចុះអរិយសមាធិក្ខន្ធ ... តើដូចម្តេច ព្រះថេរៈមានបំណងនឹង សម្តែងឲ្យឃើញ នូវធម៌មានឧបការៈដល់ធម៌ទាំងពីរ ក្នុងវាងសីល និង សមាធិ ដែលមានឥន្ទ្រិយសំវរៈជាដើម ដែលលោកលើកឡើងសម្តែងក្នុង លំដាប់សីលយ៉ាងនេះថា ភិក្ខុបរិបូណ៌ដោយសីល មានទ្វារឃុំគ្រងហើយក្នុង ឥន្ទ្រិយទាំងឡាយ ដល់ព្រមដោយសតិសម្បជញ្ញៈ ជាអ្នកសន្តោស ដូច្នេះ ហើយ ទើបសម្តែងសមាធិក្ខន្ធ បានពោលពាក្យផ្តើមឡើង ។ ក្នុងទីនេះ សម្តែងដល់រូបជ្ឈានប៉ុណ្ណោះ ទើបមិនគួរនាំអរូបជ្ឈានមកសម្តែង ។ ព្រោះ ឈ្មោះថា អរូបសមាបត្តិ មិនបានសង្គ្រោះដោយចតុត្ថជ្ឈាន ទើបមិនមាន ។

[๑๓๐-๑๓๙] *បទថា* **អត្ថិ ចេវេត្ត ឧត្តរិ ករណីយំ** *លោកសម្តែងថា ឈ្មោះថា ការកើតឡើងនៃទីបំផុត មិនមានក្នុងសាសនារបស់ព្រះមានព្រះភាគនេះ ដោយត្រឹមតែចិត្តមានអារម្មណ៍តែមួយប៉ុណ្ណោះទេ នៅមានកិច្ចដទៃ ដែលត្រូវធ្វើក្រៃលែងជាងនេះទៀត ។*

បទថា **ឯត្ថិ ចេវេត្ត ឧត្តរិ ករណីយំ** *លោកសម្តែងថា ឈ្មោះថា កិច្ចដែលនឹងត្រូវធ្វើឲ្យក្រៃលែងជាងនេះ មិនមានក្នុងសាសនារបស់ព្រះដ៏មានព្រះភាគនេះ ព្រោះសាសនារបស់ព្រះដ៏មានព្រះភាគ មានអរហត្តជាទីបំផុត ។ បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។*

សុភសុត្តវណ្ណនា ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ហើយ ដោយប្រការដូច្នេះ ៗ

សុភសូត្រ ចប់

សូត្រទី ๑๐ ចប់

សុត្តន្តបិដក

កេវដ្ដសូត្រ ที่ ๑๑

[๑๔๐] ខ្ញុំបានស្តាប់មកយ៉ាងនេះ ฯ សម័យមួយ ព្រះមានព្រះភាគ ជាម្ចាស់ ទ្រង់គង់នៅក្នុងបាវារិកម្ពវន ជិតស្រុកនាលន្ទា ฯ គ្រានោះ គហបតិបុត្រ ឈ្មោះកេវដ្ដៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ฯ លុះកេវដ្ដគហបតិបុត្រអង្គុយ ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសេចក្តីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ស្រុកនាលន្ទានេះ ជាស្រុកស្តុកស្តម្ភ បរិបូណ៌ (ដោយទ្រព្យរបស់ផ្សេងៗ) មានជនច្រើន មានមនុស្សកុះករ មានមនុស្សជ្រះថ្លាក្រាស់ក្រែលចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាអាចនឹងធ្វើឥទ្ធិបាដិហារ្យ ឲ្យក្រៃលែងជាងមនុស្សធម៌ គឺកុសលកម្ម ๑๐ សូមព្រះមានព្រះភាគ បង្គាប់ភិក្ខុនោះ๑ រូប (ឲ្យធ្វើ) កាលបើយ៉ាងនេះ អ្នកស្រុកនាលន្ទានេះ ក៏នឹងរឹងរឹតតែជ្រះថ្លាឡើង ក្នុងព្រះមានព្រះភាគ ฯ កាលកេវដ្ដគហបតិបុត្រ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងកេវដ្ដគហបតិបុត្រថា ម្នាលកេវដ្ដៈ តថាគតមិនសម្តែងធម៌ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមកធ្វើឥទ្ធិបាដិហារ្យ ឲ្យក្រៃលែងជាងមនុស្សធម៌ ដល់ពួកគ្រហស្ថ អ្នកស្លៀកពាក់សដូច្នេះឡើយ ฯ កេវដ្ដគហបតិបុត្របានក្រាបបង្គំទូលសេចក្តីនេះ នឹងព្រះមានព្រះភាគជាគម្រប់ ๒ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន

ខ្ញុំព្រះអង្គមិនបានតាំងព្រះមានព្រះភាគ (ឲ្យសម្តែង) ទេ ខ្ញុំព្រះអង្គគ្រាន់តែក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ស្រុកនាលន្ទានេះ ជាស្រុកស្តុកស្តម្ភ បរិបូណ៌ (ដោយទ្រព្យរបស់ផ្សេងៗ) មានជនច្រើន មានមនុស្សកុះករ មានមនុស្សជ្រះថ្លាក្រាស់ក្រែល ចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន កិកុណាអាចនឹងធ្វើឥទ្ធិបាដិហារ្យ ឲ្យក្រៃលែងជាងមនុស្សធម៌បាន សូមព្រះមានព្រះភាគ បង្គាប់កិកុនោះ១ រូប (ឲ្យធ្វើ) កាលបើយ៉ាងនេះ អ្នកស្រុកនាលន្ទានេះ នឹងរឹងរឹតតែជ្រះថ្លាឡើង ក្នុងព្រះមានព្រះភាគ ។ (កេវដ្តគហបតិបុត្រក្រាបបង្គំទូលនូវសេចក្តីនេះទៀត) ជាគម្រប់ ៣ ដង ដង ។បេ។

[១៤១] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ បាដិហារ្យ ៣ យ៉ាងនេះ ដែលតថាគតធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយ អាចនឹងសម្តែងបាន បាដិហារ្យ ៣ យ៉ាងតើដូចម្តេច គឺឥទ្ធិបាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ ម្នាលកេវដ្ដៈ ចុះឥទ្ធិបាដិហារ្យតើដូចម្តេច ម្នាលកេវដ្ដៈ កិកុក្នុងសាសនានេះ បាននូវឥទ្ធិវិធិ គឺការតាក់តែងឫទ្ធិបានជាច្រើនប្រការ មនុស្សម្នាក់ឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ឲ្យទៅជាម្នាក់ក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង និងទីខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន ងើបឡើងទាំងមុជចុះក្នុងផែនដី ដូចជាងើបមុជ ក្នុងទឹកក៏បាន ដើរទៅក្នុងទឹក ក៏មិនបែកធ្លាយទឹក ដូចជាដើរលើផែនដីក៏បាន ទៅក្នុងអាកាសទាំង

ក្នែន ដូចជាសកុណជាតិដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែល ចាប់ពាល់នូវព្រះចន្ទ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ កុលបុត្រឯណានីមួយ ជាអ្នកមានសទ្ធាជ្រះថ្លា ឃើញភិក្ខុនោះ ដែលបាននូវឥទ្ធិវិធីជាច្រើនប្រការ គឺមនុស្សម្នាក់ ឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ឲ្យទៅជាម្នាក់ក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង និងខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន ងើបឡើងទាំងមុជចុះក្នុងផែនដី ហាក់ដូចជាងើបមុជក្នុងទឹកក៏បាន ដើរទៅក្នុងទឹក ក៏មិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដីក៏បាន ទៅក្នុងអាកាសទាំងក្នែន ដូចជាសកុណជាតិដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែល ចាប់ពាល់នូវព្រះចន្ទ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោកក៏បាន ។ កុលបុត្រដែលមានសទ្ធាជ្រះថ្លានោះ ក៏ប្រាប់នូវដំណើរភិក្ខុនោះ ដល់អ្នកដទៃ ដែលមិនទាន់មានសទ្ធា មិនទាន់មានសេចក្តីជ្រះថ្លាថា ឱហ្ន៎ ហេតុនេះ ជាអស្ចារ្យពេក ឱហ្ន៎ ហេតុនេះ មិនធ្លាប់មាន បែរជាមានបាន ភាវៈនៃសមណៈជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះខ្ញុំបានឃើញភិក្ខុឯណោះ ដែលបាននូវឥទ្ធិវិធីជាច្រើនប្រការ គឺធ្វើមនុស្សម្នាក់ឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ឲ្យទៅជាម្នាក់វិញក៏បាន ។បេ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្ម-

លោកក៏បាន ។ ជនដែលមិនទាន់មានសទ្ធា មិនទាន់មានសេចក្តីជ្រះថ្លានោះ គប្បីនិយាយប្រាប់ដំណើរភិក្ខុនោះ ទៅនឹងកុលបុត្រដែលមានសទ្ធាជ្រះថ្លានោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន មានវិជ្ជាមួយយ៉ាង ឈ្មោះគន្ធារិ គឺវិជ្ជាដែលឫសីឈ្មោះគន្ធារៈ តាក់តែងទុកមក ភិក្ខុនោះ បាននូវឥទ្ធិវិធិជាច្រើនប្រការ ដោយវិជ្ជានោះ ។បេ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្ម-លោកក៏បាន ។ ម្នាលកេវដ្ដៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ជនដែលមិនទាន់មានសទ្ធា មិនទាន់មានសេចក្តីជ្រះថ្លានោះ នឹងគប្បីនិយាយពាក្យយ៉ាងនេះទៅនឹងកុលបុត្រ ដែលមានសទ្ធាជ្រះថ្លានោះដែរឬ ។ កេវដ្ដគហបតិបុត្រក្រាបបង្គំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ជននោះគប្បីនិយាយដែរ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកេវដ្ដៈ តថាគត ពិចារណាឃើញច្បាស់នូវទោសក្នុងឥទ្ធិបាដិហារ្យនេះហើយ ទើបទៀយណាយធុញទ្រាន់ ខ្ពើមរអើមចាកឥទ្ធិ-បាដិហារ្យ ។

[១៤២] ម្នាលកេវដ្ដៈ ចុះអាទេសនាបាដិហារ្យតើដូចម្តេច ។ ម្នាលកេវដ្ដៈ ភិក្ខុក្នុងសាសនានេះ ទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ កុលបុត្រឯណានីមួយ ដែលមានសទ្ធាជ្រះថ្លា ឃើញភិក្ខុនោះដែលទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃថា មនោរបស់អ្នកយ៉ាងនេះខ្លះ

មនោរបស់អ្នក មានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ កុលបុត្រដែលមានសទ្ធាជ្រះថ្លានោះ ក៏ជ្រាប់នូវដំណើរភិក្ខុនោះ ដល់ជនដទៃដែលជាអ្នកមិនទាន់មានសទ្ធា មិនទាន់មានសេចក្តីជ្រះថ្លាថា ម្នាលអ្នក ហេតុនេះ ជាអស្ចារ្យណាស់ ម្នាលអ្នក ហេតុនេះ មិនធ្លាប់មាន បែរជាមានបាន ភាវៈនៃសមណៈ ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះខ្ញុំបានឃើញភិក្ខុឯណោះដែលទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ជនដែលមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លានោះ គប្បីនិយាយជ្រាប់ដំណើរភិក្ខុនោះ ទៅនឹងកុលបុត្រដែលមានសទ្ធាជ្រះថ្លានោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន មានវិជ្ជាមួយយ៉ាងឈ្មោះមណិកា ជាវិជ្ជាសម្រាប់ដឹងចិត្តបុគ្គលដទៃ ភិក្ខុនោះទាយនូវចិត្តខ្លះ ទាយនូវចេតសិកខ្លះ ទាយនូវការត្រិះរិះខ្លះ ទាយនូវការពិចារណាខ្លះ របស់ពួកសត្វដទៃ បុគ្គលដទៃ ដោយវិជ្ជានោះថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នក មានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ម្នាលកេវដ្ដៈ អ្នកសម្គាល់នូវហេតុនោះដូចម្តេច ជនដែលមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លានឹងគប្បីនិយាយពាក្យយ៉ាងនេះ ទៅនឹងកុលបុត្រដែលមានសទ្ធា មានសេចក្តីជ្រះថ្លានោះដែរឬ ។ គហបតិបុត្រក្រាបបង្គំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ជននោះគប្បីនិយាយដែរ ។ ម្នាលកេវដ្ដៈ តថាគតកាលពិចារណាឃើញច្បាស់នូវទោស ក្នុងអាទេសនាបាដិហារ្យនេះឯង ទើបនឿយណាយ

ធុញទ្រាន់ ខ្ពើមរអើមចាកអាទេសនាបាដិហារ្យ ។

[១៤៣] ម្នាលកេវដ្ត: ចុះអនុសាសនីបាដិហារ្យតើដូចម្តេច ។ ម្នាលកេវដ្ត: ភិក្ខុក្នុងសាសនានេះ តែងប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយចូរត្រិះរិះយ៉ាងនេះចុះ កុំត្រិះរិះយ៉ាងនេះឡើយ អ្នកទាំងឡាយចូរធ្វើទុកក្នុងចិត្តយ៉ាងនេះចុះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ អ្នកទាំងឡាយ ចូរលះបង់នូវតម្រេកក្នុងបញ្ចកាមគុណនេះ អ្នកទាំងឡាយ ចូរដល់នូវលោកុត្តរធម៌នេះ ហើយសម្រេចឥរិយាបថនៅ ។ ម្នាលកេវដ្ត: នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។

[១៤៤] ម្នាលកេវដ្ត: មួយវិញទៀត ព្រះតថាគត កើតឡើងក្នុងលោកនេះ ជាអរហន្តសម្ចាសម្ពុទ្ធ ។បេ។ (អ្នកប្រាជ្ញគប្បីសម្តែងឲ្យពិស្តារដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។បេ។ ម្នាលកេវដ្ត: នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។ ភិក្ខុបានដល់នូវទុតិយជ្ឈាន ។ តតិយជ្ឈាន ។ ចតុត្ថជ្ឈាន ហើយសម្រាន្តឥរិយាបថនៅ ។ ម្នាលកេវដ្ត: នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។បេ។ ភិក្ខុតម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីញាណទស្សន: ។ ម្នាលកេវដ្ត: នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។បេ។ ភិក្ខុដឹងច្បាស់ថា កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ម្នាលកេវដ្ត: នេះតថាគតហៅថា អនុសាសនីបាដិហារ្យ ។ ម្នាលកេវដ្ត: បាដិហារ្យទាំង ៣ យ៉ាងនេះឯង ដែលតថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយអាចសម្តែងបាន ។

[១៤៥] *ម្នាលកេវដ្ដៈ រឿងធ្លាប់មានមកថា ភិក្ខុមួយរូបក្នុងភិក្ខុសង្ឃនេះឯង កើតមានសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ លំដាប់នោះ ភិក្ខុចូលកាន់សមាធិ តាមបែបផែននៃចិត្តរបស់យោគី ដែលតាំងខ្ជាប់ដោយសមាធិ ផ្លូវជាទីទៅកាន់ទេវលោក ក៏កើតប្រាកដឡើង ។ ម្នាលកេវដ្ដៈ គ្រានោះ ភិក្ខុនោះ ចូលទៅរកពួកទេវតា ដែលឋិតនៅក្នុងឋានចាតុម្មហារាជិកា លុះចូលទៅដល់ហើយ បានសួរសេចក្តីនេះនឹងពួកទេវតា ដែលឋិតនៅក្នុងឋានចាតុម្មហារាជិកាថា ម្នាលអាវុសោទាំងឡាយ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ ពួកទេវតាដែលឋិតនៅក្នុងឋានចាតុម្មហារាជិកា បានឆ្លើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ យើងទាំងឡាយនេះឯង មិនដឹងថា មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ ឥតមានសេសសល់ក្នុងទីណាទេ បពិត្រភិក្ខុ តែមានមហារាជ ៤ ព្រះអង្គ ឧត្តមថ្លៃថ្លាជាងយើងទាំងឡាយ មហារាជទាំង ៤ នោះ គប្បីដឹងយ៉ាងនេះថា មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ ឥតមានសេសសល់ក្នុងទីណាដូច្នេះ (មិនខាន) ។ ម្នាលកេវដ្ដៈ លំដាប់នោះ ភិក្ខុក៏ចូលទៅ*

រកមហារាជទាំង ៤ ព្រះអង្គ លុះចូលទៅដល់ហើយ ក៏សួរសេចក្តីនេះនឹង មហារាជទាំង ៤ ថា ម្នាលអារុសោទាំងឡាយ មហាភូតរូបទាំង ៤ នេះ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ ឥត មានសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះ ហើយ មហារាជទាំង ៤ ព្រះអង្គឆ្លើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រ ភិក្ខុ សូម្បីយើងទាំងឡាយ ក៏មិនដឹងសេចក្តីនេះដែរ ។បេ។ បពិត្រភិក្ខុ តែ មានទេវតាទាំងឡាយ ដែលឋិតនៅក្នុងឋានតាវត្តិង្ស ខ្ពស់លើសជាងយើង ទាំងឡាយ ពួកទេវតាទាំងនោះឯង គប្បីដឹងសេចក្តីយ៉ាងនេះ ។បេ។ ម្នាល កេវដ្ដៈ គ្រានោះ ភិក្ខុក៏ចូលទៅរកពួកទេវតា ឋិតនៅក្នុងឋានតាវត្តិង្ស លុះចូល ទៅដល់ហើយ ក៏បានសួរសេចក្តីនេះនឹងពួកទេវតា ដែលឋិតនៅក្នុងឋាន តាវត្តិង្សថា ម្នាលអារុសោទាំងឡាយ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ ឥតមានសេស សល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ ពួក ទេវតាដែលឋិតនៅក្នុងឋានតាវត្តិង្ស ឆ្លើយតបសេចក្តីនេះ នឹងភិក្ខុនោះថា បពិត្រភិក្ខុ យើងទាំងឡាយ ក៏មិនដឹងសេចក្តីនេះដែរ ។បេ។ បពិត្រភិក្ខុ តែ មានទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតាទាំងឡាយ ខ្ពស់លើសជាងយើង ទាំងឡាយ សក្កទេវរាជនោះឯង គប្បីដឹងសេចក្តីយ៉ាងនេះ ។បេ។ ម្នាល កេវដ្ដៈ ភិក្ខុនោះ ក៏ចូលទៅរកសក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ លុះ ចូលទៅដល់ហើយ ក៏សួរនូវសេចក្តីនេះនឹងសក្កទេវរាជ ជាធំជាងទេវតាទាំង-

ឡាយថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេស សល់ក្នុងទីណាហ្នឹ ។ ម្នាលកេវដ្ដ: កាលបើភិក្ខុនោះសួរយ៉ាងនេះហើយ សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ បានធ្វើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ខ្ញុំព្រះករុណា ក៏មិនដឹងសេចក្តីនេះដែរ ។បេ។ បពិត្រភិក្ខុ តែមានទេវតាឈ្មោះយាម: (ទេវតាឋិតនៅក្នុងឋានយាម:) ។បេ។ ទេវបុត្រឈ្មោះសុយាម: ។បេ។ ទេវបុត្រឈ្មោះតុសិត: (ទេវតាឋិតនៅក្នុងឋានតុសិត) ។បេ។ ទេវបុត្រឈ្មោះសន្តុសិត: ។បេ។ ទេវតាឈ្មោះនិម្មានរតី (ទេវតាឋិតនៅក្នុងឋាននិម្មានរតី) ។បេ។ ទេវបុត្រឈ្មោះសុនិម្មិត: ។បេ។ ទេវតាឈ្មោះបរនិម្មិតវសវត្តី (ទេវតាឋិតនៅក្នុងឋានបរនិម្មិតវសវត្តី) ។បេ។ ទេវបុត្រឈ្មោះបរនិម្មិតវសវត្តី ឧត្តមថ្វៃថ្លាជាងយើងទាំងឡាយ ទេវបុត្រឈ្មោះបរនិម្មិតវសវត្តីនោះគប្បីដឹងយ៉ាងនេះថា មហាភូតរូបទាំង ៤ នេះ គឺបឋវី-ធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណា (មិនខាន) ។

[១៤៦] ម្នាលកេវដ្ដ: លំដាប់នោះឯង ភិក្ខុនោះចូលទៅរកទេវបុត្រឈ្មោះវសវត្តី លុះចូលទៅដល់ហើយ ក៏បានសួរសេចក្តីនេះនឹងទេវបុត្រឈ្មោះវសវត្តីថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោ-ធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្នឹ ។ ម្នាលកេវដ្ដ: កាលភិក្ខុនោះសួរយ៉ាងនេះហើយ ទេវបុត្រឈ្មោះ

វសវត្តី ក៏បានឆ្លើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ខ្ញុំព្រះករុណាក៏មិនដឹងថា មហាភូតរូបទាំង ៤ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាដែរ ។ បពិត្រភិក្ខុ តែមានពួកទេវតាឈ្មោះព្រហ្មកាយិកៈ (ទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម) ឧត្តមថ្លៃថ្លាជាងយើងទាំងឡាយ ពួកទេវតានោះគប្បីដឹងសេចក្តីយ៉ាងនេះ (មិនខាន) ។បេ។ ម្នាលកេវដ្ដៈ លំដាប់នោះ ភិក្ខុនោះក៏ចូលកាន់សមាធិ តាមបែបផែននៃចិត្តរបស់យោគីដែលតាំងខ្ជាប់ដោយសមាធិ ផ្លូវជាទីទៅកាន់ព្រហ្មលោក ក៏កើតប្រាកដឡើង ។

[១៤៧] ម្នាលកេវដ្ដៈ គ្រានោះឯង ភិក្ខុនោះក៏ទៅរកពួកទេវតា ដែលរាប់បញ្ចូលក្នុងពួកព្រហ្ម លុះចូលទៅដល់ហើយ ក៏បានសួរសេចក្តីនេះនឹងទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មថា ម្នាលអាវុសោទាំងឡាយ មហាភូតរូប ៤ នេះ ។បេ។ វាយោធាតុ ១ រលត់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម បានឆ្លើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ យើងក៏មិនដឹងសេចក្តីនេះដែរ ។បេ។ បពិត្រភិក្ខុ តែមានព្រហ្មឈ្មោះមហាព្រហ្មគ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកបែងសត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតចេញមកហើយ និងសត្វនៅ

ក្នុងផ្ទៃ ខត្តមថ្ថៃថ្ថាជាងយើងទាំងឡាយ មហាព្រហ្មនោះឯង គប្បីដឹងសេចក្តីយ៉ាងនេះថា មហាភូតរូបទាំង ៤ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណា (មិនខាន) ។ ភិក្ខុនោះសួរថា ម្នាលអាវុសោ ចុះឥឡូវនេះ មហាព្រហ្មនោះ នៅក្នុងទីណា ។ ពួកទេវតានោះធ្វើយតបថា បពិត្រភិក្ខុ យើងទាំងឡាយក៏មិនដឹងថា ព្រហ្មនៅក្នុងទីណា ឬនៅក្នុងទីចំណែកនៃទិសណាដែរ បពិត្រភិក្ខុ ប៉ុន្តែនិមិត្តទាំង-ឡាយតែងប្រាកដ ពន្ធឺតែងកើតច្បាស់ រស្មីតែងកើតប្រាកដក្នុងទីណា ព្រហ្មនឹងមានប្រាកដក្នុងទីនោះ នេះជាបុព្វនិមិត្តដើម្បីមានប្រាកដនៃព្រហ្ម គឺពន្ធឺក៏កើតច្បាស់ រស្មីមានប្រាកដ ។ ម្នាលកេវដ្ដ: លំដាប់នោះ មិនយូរប៉ុន្មានឡើយ មហាព្រហ្មនោះ ក៏មានរូបប្រាកដឡើង ។

[១៤៨] ម្នាលកេវដ្ដ: គ្រានោះឯង ភិក្ខុនោះចូលទៅរកមហាព្រហ្ម លុះចូលទៅដល់ហើយ បានសួរសេចក្តីនេះ នឹងមហាព្រហ្មនោះថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោ-ធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្នឹ ។ ម្នាលកេវដ្ដ: កាលភិក្ខុនោះសួរយ៉ាងនេះហើយ មហាព្រហ្មនោះក៏ធ្វើយតបសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ខ្ញុំជាព្រហ្មឈ្មោះមហាព្រហ្ម គ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួង ឲ្យលុះក្នុងអំណាចរបស់ខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នក

បែងសត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតមក ហើយ និងសត្វនៅក្នុងផ្ទៃ ។ ម្នាលកេវដ្ដៈ ភិក្ខុនោះបានសួរសេចក្ដីនេះ និង មហាព្រហ្មនោះជាគម្រប់ ២ ដងទៀតថា ម្នាលអាវុសោ អាត្មាមិនមែនសួរ អ្នកយ៉ាងនេះថា អ្នកជាព្រហ្មឈ្មោះមហាព្រហ្ម គ្របសង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នក ធ្វើជនទាំងពួង ឲ្យលុះក្នុងអំណាចរបស់ខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នក សាងលោក តាក់តែងលោក ជាចម្បងជាងសត្វ ជាអ្នកបែងសត្វលោក ជា អ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតចេញមកហើយ និងសត្វនៅ ក្នុងផ្ទៃដូច្នេះទេ ម្នាលអាវុសោ ឯអាត្មាសួរអ្នកយ៉ាងនេះថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ដូច្នេះទេតើ ។ ម្នាលកេវដ្ដៈ មហាព្រហ្មនោះបានឆ្លើយតបសេចក្ដីនេះ និងភិក្ខុនោះជាគម្រប់ ២ ដងទៀតថា បពិត្រភិក្ខុ ខ្ញុំជាព្រហ្មឈ្មោះមហាព្រហ្ម គ្របសង្កត់លើសត្វ ឯទៀត សត្វឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួង ឲ្យលុះក្នុងអំណាចរបស់ខ្លួន ជាឥស្សរៈក្នុងលោក ជា អ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកបែងសត្វ លោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់សត្វដែលប្រសូតចេញមកហើយ និងសត្វនៅក្នុងផ្ទៃ ។ ម្នាលកេវដ្ដៈ ភិក្ខុនោះបានសួរនូវសេចក្ដីនេះនឹងមហា-ព្រហ្មជាគម្រប់ ៣ ដងទៀតថា ម្នាលអាវុសោ អាត្មាមិនមែនសួរអ្នកយ៉ាង

នេះថា អ្នកជាព្រហ្មឈ្មោះមហាព្រហ្ម គ្រប់សង្កត់លើសត្វឯទៀត សត្វឯទៀតមិនអាចគ្រប់សង្កត់លើបាន ជាអ្នកឃើញហេតុគ្រប់យ៉ាង ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកបែងសត្វលោក ជាអ្នកស្ទាត់ជំនាញ ជាបិតានៃសត្វដែលប្រសូតចេញមកហើយ និងសត្វនៅក្នុងផ្នែដូច្នេះទេ ម្នាលអាវុសោ ឯអាត្មាសួរអ្នកយ៉ាងនេះថា ម្នាលអាវុសោ មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ๑ អាបោធាតុ ๑ តេជោធាតុ ๑ វាយោធាតុ ๑ តែងរលត់ឥមានសេសសល់ក្នុងទីណាហ្ន៎ ដូច្នេះទេតើ ។

[๑๔๙] ម្នាលកេវដ្ដៈ គ្រានោះ មហាព្រហ្មនោះចាប់ដើមដៃភិក្ខុនោះ ហើយនាំចៀសចេញទៅក្នុងទីជិតសមគួរ ហើយនិយាយសេចក្តីនេះនឹងភិក្ខុនោះថា បពិត្រភិក្ខុ ទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មទាំងនេះឯង តែងស្គាល់នូវខ្ញុំយ៉ាងនេះថា ហេតុអ្វីនីមួយឈ្មោះថា ព្រហ្មមិនជឿង មិនឃើញ មិនស្គាល់ មិនធ្វើឲ្យច្បាស់នោះមិនមានឡើយ ព្រោះហេតុនោះ ទើបខ្ញុំមិនព្យាករក្នុងទីចំពោះមុខនៃទេវតាទាំងនុ៎ះ បពិត្រភិក្ខុ ខ្ញុំសោត ក៏មិនជឿងថា មហាភូតរូប ๔ ទាំងនេះ គឺបឋវីធាតុ ๑ អាបោធាតុ ๑ តេជោធាតុ ๑ វាយោធាតុ ๑ តែងរលត់ឥមានសេសសល់ក្នុងទីណាដែរ បពិត្រភិក្ខុ លោកម្ចាស់លះបង់ចោលព្រះមានព្រះភាគហើយ ដល់នូវការស្វែងរក (បុគ្គល) ខាងក្រៅវិញ ដើម្បីព្យាករនូវប្រស្នានេះ ដោយអំពើណា អំពើនោះ លោកម្ចាស់ធ្វើមិនល្អទេ អំពើនោះ លោកម្ចាស់ធ្វើខុសហើយ បពិត្រភិក្ខុ ព្រោះហេតុនោះ លោក

ម្ចាស់ចូរទៅគាល់ព្រះមានព្រះភាគអង្គនោះហើយ សួរនូវប្រស្នានេះចុះ បើព្រះមានព្រះភាគទ្រង់ព្យាករ ដល់លោកម្ចាស់យ៉ាងណា លោកម្ចាស់គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ។

[๑๕๐] *ម្នាលកេវដ្ដៈ គ្រានោះឯង ភិក្ខុនោះក៏បាត់អំពីព្រហ្មលោកមកប្រាកដក្នុងទីចំពោះមុខតថាគត (រហ័ស) ប្រៀបដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ ម្នាលកេវដ្ដៈ គ្រានោះឯងភិក្ខុនោះ ថ្វាយបង្គំតថាគតរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលកេវដ្ដៈ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានសួរនូវសេចក្តីនេះ នឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ๑ អាបោធាតុ ๑ តេជោធាតុ ๑ វាយោធាតុ ๑ តែងរលត់ឥតសេសសល់ក្នុងទីណាហ្ន៎ ។ ម្នាលកេវដ្ដៈ កាលភិក្ខុនោះសួរយ៉ាងនេះហើយ តថាគតក៏បានសម្តែងសេចក្តីនេះនឹងភិក្ខុនោះថា ម្នាលភិក្ខុរឿងធ្លាប់មានមកហើយថា មានពួកឈ្មួញសមុទ្រ បាននាំយកសត្វស្វាប ដែលជាសត្វមើលឃើញត្រើយសមុទ្រ ហើយចុះទៅកាន់សមុទ្រដោយសំពៅ ពួកឈ្មួញទាំងនោះ កាលបើសំពៅដែលបើកទៅ មើលមិនឃើញត្រើយសមុទ្រ ក៏លែងសត្វបក្សីដែលមើលឃើញត្រើយសមុទ្រ សត្វបក្សីនោះក៏ហើរទៅកាន់ទិសខាងកើត ទៅកាន់ទិសខាងត្បូង ទៅកាន់ទិសខាងលិច ទៅកាន់ទិសខាងជើង ទៅកាន់ទិសខាងលើ ទៅកាន់ទិសតូច បើសត្វបក្សីនោះមើលឃើញត្រើយសមុទ្រជុំវិញ ក៏ហើរបាត់ទៅតែម្តង ប្រសិនបើសត្វបក្សីនោះ មើលមិនឃើញត្រើយសមុទ្រជុំវិញ*

ទេ ក៏ហើរត្រឡប់មករកសំពៅនោះវិញ ម្នាលភិក្ខុ ខ្លួនអ្នកបានដើរស្វែងរក (បុគ្គល) ដើម្បីព្យាករនូវប្រស្នានេះរហូតដល់ព្រហ្មលោក ក៏ត្រឡប់មកកាន់សម្នាក់នៃតថាគតវិញដូច្នោះឯង ម្នាលភិក្ខុប្រស្នានេះ អ្នកមិនត្រូវសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន មហាភូតរូបទាំង ៤ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ តែងរលត់ឥតមានសេសសល់ក្នុងទីណាហ្ន៎ ដូច្នេះឡើយ ។ ម្នាលភិក្ខុ ប្រស្នានោះ អ្នកត្រូវសួរយ៉ាងនេះថា ។

[๑๕๑] អាបោធាតុក្តី បឋវីធាតុក្តី តេជោធាតុក្តី វាយោធាតុក្តី មិនតាំងនៅក្នុងទីណា (ឧបាទាយរូប) ដែលមានសណ្ឋានវែងក្តី ខ្លីក្តី តូចក្តី ធំក្តី ល្អ អាក្រក់ក្តី រលត់ក្នុងទីណា នាម និងរូបរលត់ឥតមានសេសសល់ក្នុងទីណា ។ សេចក្តីដោះស្រាយក្នុងប្រស្នានោះ ដូច្នេះ ។

[๑๕๒] វិញ្ញាណ គឺព្រះនិព្វាន មិនមែនជាទីសម្រាប់ឃើញ (ដោយចក្ខុបាន) ទេ ជាធម្មជាតគ្មានទីបំផុត មានពន្លឺ (កម្មដ្ឋាន) ដោយជុំវិញ អាបោធាតុក្តី បឋវីធាតុក្តី តេជោធាតុក្តី វាយោធាតុក្តី មិនតាំងនៅក្នុងព្រះនិព្វានទុំ៎ះឡើយ (ឧបាទាយរូប) ដែលមានសណ្ឋានវែងក្តី ខ្លីក្តី តូចក្តី ធំក្តី ល្អ អាក្រក់ក្តី តែងរលត់ក្នុងព្រះនិព្វានទុំ៎ះ នាម និងរូបតែងរលត់ឥតមានសេសសល់ ក្នុងព្រះនិព្វានទុំ៎ះ

នាម និងរូបនេះ តែងរលត់ក្នុងព្រះនិព្វានធ្លុះ ព្រោះរលត់ទៅនៃវិញ្ញាណ ។

ព្រះមានព្រះភាគ បានសម្តែងព្រះសូត្រនេះចប់ហើយ ។ កេវដ្ដគហបតិបុត្រ ក៏មានចិត្តរីករាយត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

កេវដ្ដសូត្រទី ๑๑ ចប់

อัฏฐกถา

เกวัฏฏสูตร

เกวัฏฏคหบดิปุตตกถา

[๑๔๐] เกวัฏฏสูตรมีอาทิว่า **เอวัมเม สุตัง ฯเปฯ ฌานัญจายัง** ดังนี้เป็นต้น พระผู้มีพระภาคเจ้าตรัสไว้ด้วยอำนาจแห่งบทที่ตั้งไว้ในเกวัฏฏสูตรนั้น ก็บัดนี้ บทว่า **ฉายาวิกัมมวาเรน** ความว่า ด้วยโอกาสแห่งการทำเงา ๆ บทว่า **เกวัฏโฏ** นี้ เป็นชื่อของบุตรคหบดี ๆ ได้ยินว่า เกวัฏฏคหบดีบุตรนั้น มีทรัพย์ประมาณ ๔๐ โกฏิ เป็นคหบดีผู้ตั้งมั่น เป็นผู้มีศรัทธาเลื่อมใสในพระรัตนตรัย (ในพระพุทธศาสนา) อย่างยิ่ง เพราะเหตุที่เกวัฏฏคหบดีบุตรนั้นมีศรัทธาอันยิ่ง จึงได้คิดว่า ถ้าแม้นว่าภิกษุเพียงรูปเดียวเท่านั้นพึงเหาะไปในอากาศ ด้วยฤทธิ์ได้ ภิกษุสงฆ์ก็จักอาศัยภิกษุรูปนั้นข้ามไปได้ในวันเดียวบ้าง ในกึ่งเดือนบ้าง ในเดือนหนึ่งบ้าง ในปีหนึ่งบ้าง ชนเป็นอันมากก็จักพากันเลื่อมใสในพระรัตนตรัยอย่างยิ่ง ถ้ากระไรเราพึงเข้าไปเฝ้าพระผู้มีพระภาคเจ้าทูลขอภิกษุรูปหนึ่งผู้สามารถเพื่อการทำฤทธิ์ได้ ครั้นแล้วจึงเข้าไปเฝ้าพระผู้มีพระภาคเจ้าทูลขอภิกษุรูปหนึ่งผู้สามารถเพื่อการทำฤทธิ์ได้ ดังนี้ ๆ บทว่า **ฆนา** ได้แก่ ตั้งมั่นดีแล้ว ๆ บทว่า **ฉันนา** ได้แก่ ถึงพร้อมแล้วด้วยเครื่องมุงบังทั้งปวง ๆ บทว่า **สมวิปากินิยา** ได้แก่ ให้ผลสม่ำเสมอ ๆ บทว่า **อากิณณมนุสสายา** ความว่า ชุกชุมไปด้วยมนุษย์ทั้งหลาย ๆ บทว่า **สมาธิสตฺตุ** ขอจงได้ ขอจงมี ๆ บทว่า **อุตฺตริมนุสฺสธมฺมา** ความว่า ธรรมของมนุษย์ที่ยิ่งกว่าธรรมของมนุษย์ทั้งหลาย

បំផុត ឬធម៌របស់មនុស្ស បានដល់ កុសល ๑๐ ។ បទថា **ភយ្យោសោ មត្តាយ** *អធិប្បាយថា និងជ្រះថ្លាយ៉ាងក្រៃលែងបំផុត ដែលនឹងប្រមាណបាន ដូចជួងប្រទីបដ៏រុងរឿងសូម្បីជាងប្រក្រតី ព្រោះអាស្រ័យប្រែង ។*

បទថា **ន ខោ អហំ** *មានអធិប្បាយថា ព្រះមានព្រះភាគទ្រង់បញ្ញត្ត សិក្ខាបទក្នុងរឿងរាជគហាសេដ្ឋី ព្រោះដូច្នោះ ទើបត្រាស់ពាក្យជាដើមថា តថាគតមិនសម្តែងធម៌យ៉ាងនេះ ។ បទថា* **ឆឆំសេមិ** *អធិប្បាយថា គហបតីបុត្រពោលថា ខ្ញុំមិនទម្លាយឲ្យគុណធម៌វិនាសទៅ គឺឲ្យដល់ការទម្លាយសីល ហើយចេញចុះពីឋានៈខ្ពស់ តាំងនៅក្នុងឋានៈទាប ដោយលំដាប់ទេ ដោយពិត ខ្ញុំប្រាថ្នាសេចក្តីចម្រើនរបស់ព្រះពុទ្ធសាសនា ទើបពោលដូច្នោះ ។ បទថា* **តតិយម្បិ ខោ** *អធិប្បាយថា មិនមានអ្នកអាចនឹងពោលហាមព្រះតម្រាស់របស់ព្រះពុទ្ធដល់ ๓ ដង តែកេវដ្ដៈក្រាបទូលដល់ ๓ ដង ដោយគិតថា អាត្មាអញស្និទ្ធស្នាលនឹងព្រះដ៏មានព្រះភាគ ជាអ្នកមានមេត្តាប្រាថ្នាចំពោះប្រយោជន៍ ដូច្នេះ ។*

ឥទ្ធិប្បាដិហារ្យកថាជាដើម

[๑๔๑] *គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះចិន្តាថា ឧបាសកនេះ កាលតថាគតហាម ក៏នៅតែសូមរឿយៗ ណ្ហើយចុះ តថាគតនឹងសម្តែងទោសក្នុងការសម្តែងបាដិហារ្យដល់ឧបាសកនេះ ទើបត្រាស់ពាក្យជាដើមថា បាដិហារ្យ ๓ យ៉ាងនេះ ។ ក្នុងបទទាំងនោះ បទថា* **អមាហំ ភិក្ខុំ** *កាត់បទជា* **អមុំ អហំ ភិក្ខុំ** *។ បទថា* **គន្ធារិ** *អធិប្បាយថា វិជ្ជានេះ ឥសីឈ្មោះគន្ធារៈ*

ជាអ្នកធ្វើ ឬជាវិជ្ជាដែលកើតឡើងក្នុងដែនគន្ធារៈ ។ មានរឿងតំណាលមកថា ក្នុងដែនគន្ធារៈនោះ ពួកឥសីអាស្រ័យនៅច្រើន បណ្តាឥសីទាំងនោះ ឥសីម្នាក់ធ្វើវិជ្ជានេះឡើង ។ បទថា **អដ្ឋិយាមិ** *អធិប្បាយថា តថាគតនៅដោយការនឿយណាយ គឺហាក់បីដូចជាត្រូវបៀតបៀន ។ បទថា* **ហារាយាមិ** *គឺខ្មាស ។ បទថា* **ជិគុច្ឆាមិ** *គឺតថាគតកើតការខ្ពើមរអើម ដូចឃើញលាមក ។*

[๑๔๒] *បទថា* **បរេសត្តានំ** *គឺនៃសត្វទាំងឡាយពួកដទៃ ។ បទទី ๒ គឺ* **បរេបុគ្គលានំ** *ជាវេវចនៈរបស់បទនោះឯង ។ បទថា* **អាឯិសតិ** *គឺរមែងពោល ។ បទថា* **ចេតសិកំ** *សំដៅដល់ សោមនស្ស និងទោមនស្ស ។ បទថា* **យាវញ្ច តេ មនោ** *អធិប្បាយថា ចិត្តរបស់លោកតាំងនៅក្នុងសោមនស្សក្តី ទោមនស្សក្តី ប្រកបដោយកាមវិតក្កជាដើមក្តី ។ បទទី ๒ គឺជាវេវចនៈរបស់បទនោះឯង ។ បទថា* **ឥតិបិ តេ ចិត្តំ** *គឺចិត្តរបស់លោកមានយ៉ាងនេះ អធិប្បាយថា ចិត្តរបស់លោក គិតដល់រឿងនេះ និងរឿងនេះប្រព្រឹត្តទៅហើយ ។ បទថា* **មណិកា នាម វិជ្ជា** *លោកចង្អុលបង្ហាញថា មានវិជ្ជាមួយក្នុងលោក បានឈ្មោះយ៉ាងនេះថា* **ចិន្តាមណី** *បុគ្គលរមែងជ៏ងដល់ចិត្តរបស់អ្នកដទៃបាន ដោយវិជ្ជាចិន្តាមណីនោះ ។*

[๑๔๓-๑๔๔] *បទថា* **ឃវំ វិតក្កេ** *គឺត្រិះរិះឲ្យប្រព្រឹត្តទៅក្នុងផ្លូវនៃកុម្មវិតក្កជាដើម ។ បទថា* **មា ឃវំ វិតក្កយិត្ថ** *គឺកុំត្រិះរិះឲ្យប្រព្រឹត្តទៅក្នុងកាមវិតក្កជាដើម ។ បទថា* **ឃវំ មនសិការេ** *គឺធ្វើទុកក្នុងចិត្តដល់អនិច្ចសញ្ញាឬក្នុងទុក្ខសញ្ញាជាដើមណាមួយយ៉ាងនេះ ។ បទថា* **មា ឃវំ** *គឺកុំធ្វើទុកក្នុងចិត្ត*

ដោយន័យជាដើមថា ជារបស់ទៀង ដូច្នេះ ។ បទថា **ឥធំ** *គឺចូរលះបង់នូវតម្រេកដែលលាបដោយកាមគុណនេះ ។ បទថា* **ឥធំ ឧបសម្បជ្ជ** *អធិប្បាយថា គប្បីចូលដល់ គឺសម្រេច ចាក់ធ្លុះលោកុត្តរធម៌ បានដល់មគ្គ ๔ ផល ๔ នេះឯង ។ ព្រះមានព្រះភាគ ទ្រង់សម្តែងឫទ្ធិផ្សេងៗ ឈ្មោះថា ឥទ្ធិបាដិហារ្យ ។ ការដឹងចិត្តរបស់បុគ្គលដទៃ ហើយនិយាយ ឈ្មោះថា អាទេសនាបាដិហារ្យ ។ ការសម្តែងធម៌រឿយៗ របស់ព្រះសាវក និងរបស់ព្រះពុទ្ធ ឈ្មោះថា អនុសាសនីបាដិហារ្យ ។*

ក្នុងបាដិហារ្យទាំងនោះ ព្រះមហាមោគ្គល្លានសម្តែងអនុសាសនីបាដិហារ្យ ដោយឥទ្ធិបាដិហារ្យ ព្រះធម្មសេនាបតីសារីបុត្រសម្តែងអនុសាសនីបាដិហារ្យ ដោយអាទេសនាបាដិហារ្យ ។ កាលទេវទត្តកិកូបំបែកសង្ឃ បាននាំកិកូ ๕๐๐ រូបទៅហើយសម្តែងធម៌ដល់កិកូទាំងនោះ ដោយពុទ្ធលីលា ក្នុងគយាសីស-ប្រទេស កាលព្រះមានព្រះភាគ ទ្រង់បញ្ជូនព្រះអគ្គសាវក ๒ រូបទៅ ព្រះធម្មសេនាបតីសារីបុត្រជ្រាបវាសចិត្តរបស់កិកូទាំងនោះ ហើយសម្តែងធម៌ ។ កិកូទាំង ๕๐๐ ស្តាប់ធម៌ទេសនារបស់ព្រះថេរៈ ក៏សម្រេចសោតាបត្តិផល ។ តមក ព្រះមហាមោគ្គល្លានត្ថេរ បានសម្តែងឫទ្ធិផ្សេងៗ ហើយសម្តែងធម៌ដល់កិកូទាំងនោះ កិកូទាំងអស់ស្តាប់ធម៌របស់លោកហើយ បានសម្រេចអរហត្តផល ។ រួចហើយព្រះមហានាគទាំងពីរនាំកិកូ ๕๐๐ រូប ហោះតាមអាកាសមកដល់វិហារវេឡុវ័ន ។ ការសម្តែងធម៌រឿយៗ របស់ព្រះពុទ្ធទាំង-ឡាយ ជាអនុសាសនីបាដិហារ្យ ។ ក្នុងបាដិហារ្យទាំងនោះ ឥទ្ធិបាដិហារ្យ និងអាទេសនាបាដិហារ្យ ក៏នៅតិះដៀលបាន នៅមានទោស មិនតាំងនៅយូរ

ព្រោះមិនស្តិតស្ងៅបានយូរ ទើបមិននាំសត្វឲ្យផុតទុក្ខបាន ។ អនុសាសនី-ប្បាដិហារ្យប៉ុណ្ណោះ តិះដៀលមិនបាន មិនមានទោស តាំងនៅបានយូរ ព្រោះតាំងនៅបានយូរ ទើបនាំសត្វឲ្យផុតទុក្ខបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់តិះដៀលឥទ្ធិប្បាដិហារ្យ និងអាទេសនាប្បាដិហារ្យ ទ្រង់សរសើរអនុសាសនីប្បាដិហារ្យតែម្យ៉ាង ។

ភិក្ខុស្វែងរកឱរម្ភត់មហាភូតរូប

[๑๔๕-๑๔๖] *បទថា* **ភូតបុព្វំ** *នេះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ប្រារព្ធឡើង ។ ទ្រង់ប្រារព្ធឡើង ក៏ដើម្បីទ្រង់សម្តែងដល់ឥទ្ធិ-ប្បាដិហារ្យ និងអាទេសនាប្បាដិហារ្យ មិននាំសត្វឲ្យរួចចាកទុក្ខបាន និងដើម្បីទ្រង់សម្តែងដល់អនុសាសនីប្បាដិហារ្យប៉ុណ្ណោះ ដែលនាំសត្វឲ្យផុតពីទុក្ខបាន។ ម្យ៉ាងទៀត មានភិក្ខុមួយរូប ឈ្មោះមហាភូតបរិយេសកៈ ស្វែងរកមហាភូតរូប ត្រាច់ទៅដរាបដល់ព្រហ្មលោក មិនបានឱកាសដោះស្រាយបញ្ហា ទើបមកទូលសួរព្រះពុទ្ធ ហើយក៏អស់សង្ឃរ័យទៅ ។ ព្រោះហេតុអ្វី ។ ដើម្បីប្រកាសភាពជាធំក្រៃលែងរបស់ព្រះពុទ្ធទាំងឡាយ ។ ហេតុការណ៍យ៉ាងនេះបានបិទបាំងហើយ គ្រាតមក ព្រះដ៏មានព្រះភាគកាលទ្រង់បើកបង្ហាញ សម្តែងហេតុការណ៍នោះ ទើបត្រាស់ពាក្យជាដើមថា រឿងធ្លាប់មានមកហើយ ដូច្នេះ ។ បទថា* **កត្ត មុខោ** *អធិប្បាយថា បុគ្គលអាស្រ័យអ្វី សម្រេចអ្វី មហាភូត ๔ នោះ ទើបរលត់ដោយមិនមានសល់ ដោយអំណាចប្រព្រឹត្តទៅមិនបានក្នុងទីណា ក៏មហាភូតកថានេះ លោកពោលហើយក្នុងវិសុទ្ធិមគ្គដោយពិស្តារ ។ ព្រោះដូច្នោះ គួរស្វែងរកអំពីសុទ្ធិមគ្គនោះចុះ ។ បទថា* **ឧភយា ឯយោ មគ្គោ** *គឺ*

ឈ្មោះថា ផ្លូវទៅទេវលោកនោះ មិនមាន ។ បទនោះ ជាឈ្មោះរបស់ឥទ្ធិវិធញ្ញាណ ។ ពិតហើយ ផ្លូវនោះប្រព្រឹត្តទៅ ដោយអំណាចផ្លូវកាយ រមែងទៅកាន់ទេវលោក រហូតដល់ព្រហ្មលោកបាន ដោយផ្លូវនោះ ព្រោះដូច្នោះ ទើបលោកពោលថា ផ្លូវទៅទេវលោក ។ បទថា **ចាតុម្មហារាជិកា** សេចក្តីថា ភិក្ខុមិនទូលសួរព្រះមានព្រះភាគ សូម្បីទ្រង់ប្រថាប់នៅក្នុងទីជិត សម្គាល់ថា តាមធម្មតា ទេវតាដែលគេចោទគ្នា រមែងមានអានុភាពច្រើនដូច្នេះ ទើបចូលទៅរក ។ ពាក្យថា បពិត្រភិក្ខុ យើងទាំងឡាយនេះឯងមិនដឹងសំដៅដល់ពួកទេវតាត្រូវសួរបញ្ហាក្នុងពុទ្ធវិសយ រមែងមិនដឹង ទើបបានពោលយ៉ាងនោះ ។ លំដាប់នោះ ភិក្ខុនោះគំរាមពួកទេវតាថា ពួកលោកឆ្កួយ បញ្ហានេះរបស់យើងមិនបាន ក៏ចូរប្រាប់មកឲ្យឆាប់ទើបសួរហើយ សួរទៀត ។ ពួកទេវតាគិតថា ភិក្ខុរូបនេះគំរាមយើង យើងនឹងដោះលែងភិក្ខុនោះឲ្យរួចផុតអំពីពួកយើងទៅ ទើបបានពោលពាក្យជាដើមថា បពិត្រភិក្ខុ តែមានមហារាជ ៤ ព្រះអង្គ ខុតមថ្លៃថ្លាជាងយើងទាំងឡាយ ។ បទថា **អភិក្កន្តតរា** គឺល្អហួសប្រមាណ ។ បទថា **បណីតតរា** គឺខ្ពស់បំផុតដោយវណ្ណៈ យស និងភាពជាធំជាដើម ។ គប្បីជ្រាបសេចក្តីក្នុងគ្រប់វារៈដោយនយនេះ ។ សេចក្តីពិសេសមានដូចតទៅនេះថា បានឮថា សក្កទេវរាជទ្រង់ត្រិះរិះថា បញ្ហានេះជាពុទ្ធវិសយ អ្នកដទៃមិនអាចដោះស្រាយបាន ឯភិក្ខុនេះ រំលងព្រះសម្មាសម្ពុទ្ធដែលជាអគ្គបុគ្គលក្នុងលោកគ្រាច់សួរពួកទេវតា ដូចអ្នកវៀរភ្លើងកាន់យកពន្លឺអំពិលអំពែក និងដូចអ្នកលះបង់ស្ពារាយពោះ អញនឹងបញ្ជូនភិក្ខុនោះ ទៅកាន់សម្នាក់ព្រះសាស្តា ។ លំដាប់នោះ សក្កទេវរាជទ្រង់ត្រិះរិះទៀតថាភិក្ខុនោះ

ទៅឆ្ងាយណាស់ហើយ នឹងអស់សង្ស័យក្នុងសម្ពាក់របស់ព្រះសាស្តា មួយទៀត ធម្មតាបុគ្គលបែបនេះក៏មាន កាលធ្វើដំណើរទៅបានត្រឹមតែបន្តិចបន្តួច នឹងមានសេចក្តីលំបាកច្រើន តែខាងក្រោយ នឹងដឹង ដូច្នេះ ទើបពោលនឹងភិក្ខុនោះជាដើមថា បពិត្រភិក្ខុ ខ្ញុំព្រះករុណា ក៏មិនដឹងសេចក្តីនេះដែរ ដូច្នេះ ។ សូម្បីផ្លូវទៅព្រហ្មលោក ក៏ដូចគ្នានឹងផ្លូវទៅទេវលោក ។ ផ្លូវទៅទេវលោកក្តី ផ្លូវទៅព្រហ្មលោកក្តី ការចូលដល់ធម៌ក្តី ការតម្កល់មាំដោយខណៈចិត្តមួយក្តី ការប៉ាន់ស្មានក្តី ចិត្តទៅខ្ពស់ក្តី ការដឹងក្រៃលែងក្តី ទាំងអស់នេះ ជាឈ្មោះរបស់ឥទ្ធិវិធញ្ញាណនុ៎ះឯង ។

[๑๔๗] *បទថា* **បុព្វនិមិត្តំ** *លោកសម្តែងថា និមិត្តចំណែកដំបូងដែលនឹងមកដល់ ដូចអរុណោទ័យ មានព្រោះព្រះអាទិត្យរះឡើង ព្រោះដូច្នោះព្រហ្មនឹងមកក្នុងកាលឥឡូវនេះ ។ ពួកខ្ញុំដឹងត្រឹមនេះ ។ បទថា* **ចាតុរហោសិ** *ប្រែថា បានជ្រាកដហើយ ។*

[๑๔๘] *គ្រានោះឯង ព្រហ្ម កាលត្រូវភិក្ខុនោះសួរដើងថា សេចក្តីនេះមិនមែនជាវិស័យរបស់ខ្លួន ទើបគិតថា បើអញជ្រាប់ថា អញមិនដឹង ជនទាំងនេះ នឹងមើលងាយអញ បើអញនឹងពោលពាក្យណាមួយ ធ្វើដូចជាដឹង ភិក្ខុនេះមិនមានចិត្តជ្រាបដោយពាក្យព្យាករបស់អញ នឹងលើកពាក្យនិយាយរបស់អញ កាលអញជ្រាប់ថា បពិត្រភិក្ខុ ខ្ញុំជាព្រហ្ម ដូច្នេះជាដើម បុគ្គលណាមួយ ក៏នឹងមិនជឿពាក្យ បើដូច្នោះ អញនឹងជ្រាប់ពង្វែង បញ្ជូនភិក្ខុនេះឲ្យទៅគាល់ព្រះសាស្តា ដូច្នេះ ទើបពោលថា បពិត្រភិក្ខុ ខ្ញុំជាព្រហ្ម ដូច្នេះជាដើម ។*

[๑๔๙] បទថា **ឯកមន្តំ អបនេត្វា** ដូច្នេះ ព្រោះហេតុអ្វី ទើបបានធ្វើយ៉ាងនោះ ព្រោះតែសេចក្តីកាន់កាំង ។ បទថា **ឥហិទ្ធា បរិយេដ្ឋី** អធិប្បាយថា ដល់នូវការស្វែងរកបុគ្គលខាងក្រៅ រហូតដល់ព្រហ្មលោក ដូចអ្នកត្រូវការប្រេង ច្របាច់ខ្សាច់ ដូច្នោះ ។

[๑๕๐] បទថា **សក្កុណាំ** បានដល់ ក្អែក ឬស្វាំង ។ បទថា **ន ខោ ឯសោ ភិក្ខុ បញ្ហោ ឯវំ បុច្ឆិតព្ពោ** មានអធិប្បាយថា ព្រោះភិក្ខុគួរសួរបញ្ហាឲ្យត្រូវ ភិក្ខុនេះកាន់វត្តមិនមានចិត្តគ្រប់គ្រង សួរក្រៅបញ្ហា ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់បដិសេធ ។ បានឮថា ការសម្តែងទោសនៃពាក្យសួរ របស់អ្នកវង្វេង ក្នុងពាក្យសួរ ហើយឲ្យសិក្សាពាក្យសួរ ទើបឆ្លើយក្នុងកាលខាងក្រោយ ជាបដិបទារបស់ព្រះពុទ្ធទាំងឡាយ ។ ព្រោះហេតុអ្វី ព្រោះបុគ្គលមិនដឹងដើម្បីនឹងសួរ ទើបសួរ ឈ្មោះថា ជាអ្នកមិនឈ្លាស ។ ព្រះមានព្រះភាគទ្រង់ឲ្យសិក្សាបញ្ហា ទើបត្រាស់ថា អាបោធាតុ មិនតាំងនៅក្នុងទីណា ដូច្នេះ ជាដើម ។

[๑๕๑] បទថា **ន គាធតិ** គឺតាំងនៅមិនបាន មានអធិប្បាយថា មហាភូតរូបទាំង ๔ នេះ អាស្រ័យអ្វី ទើបតាំងនៅមិនបាន លោកសួរសំដៅដល់វត្តុមានចិត្តគ្រប់គ្រងប៉ុណ្ណោះ ។ បទថា **ឱយញ្ហ រស្សញ្ហ** លោកពោលដល់ឧបាទាយរូប ដោយសណ្ឋាន ។ បទថា **អនុំ ថូលំ** សំដៅដល់ តូចក្តីធំក្តី ។ លោកពោលត្រឹមតែទ្រង់ទ្រាយក្នុងឧបាទាយរូបប៉ុណ្ណោះ ដោយបទនេះ ។ បទថា **សុភាសុភំ** គឺឧបាទាយរូបដែលល្អ និងមិនល្អនុ៎ះឯង ក៏គឺ

ឧបាទាយរូបស្អាត និងមិនស្អាត មាន ឬមិនមាន ។ តែលោកពោលដល់ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍យ៉ាងនេះ ។ បទថា **នាមញ្ច រូបញ្ច** *គឺនាម និងរូប ដែលផ្សេងគ្នា មានវែងជាដើម ។ បទថា* **ឧបរុជ្ឈតិ** *ប្រែថា រមែងរលត់ទៅ ។*

[๑๕๒] *ព្រះដ៏មានព្រះភាគ ទ្រង់ចង្អុលបង្ហាញពាក្យសួរថា គួរសួរយ៉ាងនេះថា នាម និងរូបនោះ អាស្រ័យអ្វីទើបប្រព្រឹត្តទៅមិនបាន ដោយមិនមានសេសសល់ កាលទ្រង់ដោះស្រាយបញ្ហា ទើបត្រាស់ថា ក្នុងបញ្ហានោះ មានព្យាករដូច្នេះ ហើយត្រាស់ថា ធម្មជាតដែលដឹងច្បាស់ជាដើម ។*

បទថា **អនិទស្សនំ** *គឺធម្មជាតដែលគួរដឹងច្បាស់ ។ ជាឈ្មោះរបស់និព្វាន ។ និព្វាននោះ សម្តែងមិនបាន ព្រោះមិនមានការសម្តែង ។ និព្វានឈ្មោះថា គ្មានទីបំផុត ព្រោះមិនមានការកើត មិនមានការរលត់ មិនមានបែបភាពយ៉ាងដទៃរបស់អ្នកតាំងនៅ ។ បទថា* **បភំ** *គឺទឹកថ្លាស្អាត ។ បានឮថា បទនេះ ជាឈ្មោះរបស់កំពង់ទឹក ។ ជាទឹកដែលហូរ លោកធ្វើ* **ប** *អក្ខរៈឲ្យជា* **ក** *អក្ខរៈ កំពង់ឆ្នងរបស់និព្វាននោះ មាននៅគ្រប់កន្លែង ព្រោះដូច្នោះទើបឈ្មោះថា មានកំពង់ឆ្នងគ្រប់កន្លែង ។ ជនទាំងឡាយប្រាថ្នានឹងឆ្លងអំពីទីណាមួយរបស់មហាសមុទ្រ មានកំពង់ជាខាងដើមផ្លូវ រមែងមានកំពង់ខាងចុងយ៉ាងណា ជនទាំងឡាយប្រាថ្នានឹងឆ្លងឲ្យដល់ព្រះនិព្វាន ដោយឧបាយណាមួយ ក្នុងកម្មដ្ឋាន ๓๘ ជាកំពង់ ជាខាងដើមផ្លូវ កម្មដ្ឋានមិនមែនកំពង់របស់និព្វានមិនមាន ក៏យ៉ាងនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា មានកំពង់ឆ្នងដោយជុំវិញ ។ ក្នុងបទថា* **អាចោ** *នេះ លោកអាស្រ័យនិព្វាន*

ទើបពោលទាំងអស់នោះ ដោយនយជាដើមថា អាបោធាតុ ធម្មជាតដែលមានចិត្តគ្រប់គ្រង រមែងរលត់ ដោយមិនមានសេសសល់ គឺប្រព្រឹត្តទៅមិនបាន ព្រះមានព្រះភាគ កាលទ្រង់សម្តែងឧបាយរម្ងាប់មិនមានសេសសល់នៃធម្មជាតនោះ ទើបត្រាស់ថា នាម និងរូប តែងរលត់ឥតមានសេសសល់ក្នុងធម្មជាតនេះ ដូច្នេះ ។

បទថា **វិញ្ញាណស្ស** *គឺចារិមកវិញ្ញាណខ្លះ អកិសង្ខារវិញ្ញាណខ្លះ ។ ពិតហើយ ព្រោះចារិមកវិញ្ញាណរលត់ នាម និងរូបនោះ រមែងរលត់មិនមានសេសសល់ក្នុងធម្មជាតនេះ គឺរមែងដល់ការមិនមានបញ្ញត្តិ ដូចអណ្តាតប្រទីបដែលរលត់ ដូច្នោះ ព្រោះមិនកើតឡើង និងរលត់ទៅដោយមិនមានសេសសល់នៃអកិសង្ខារវិញ្ញាណ ទើបនាម និងរូបរលត់ដោយមិនកើតឡើង ដូចទ្រង់ត្រាស់ទុកថា ព្រោះរម្ងាប់អកិសង្ខារវិញ្ញាណ ដោយសោតាបត្តិ-មគ្គញ្ញាណ នាម និងរូបដែលគប្បីកើតក្នុងសង្សារវដ្ដ ដែលមិនមានខាងដើម និងទីបំផុតខាងចុង រៀរភពទាំង ៧ រមែងរលត់ដោយមិនមានសេសសល់ក្នុងធម្មជាតនេះ ដូច្នេះ ។ ទាំងអស់គប្បីជ្រាបតាមនយដែលទ្រង់ត្រាស់ហើយក្នុងមហានិទ្ទេសនោះឯង ។ បទដ៏សេសទាំងអស់ មានអត្ថងាយហើយ ។*

អដ្ឋកថា កេវដ្ដសូត្រ ក្នុងទីឃនិកាយ ឈ្មោះថា សុមង្គលវិលាសិនី ចប់ហើយ ដោយប្រការដូច្នេះ ៗ

កេវដ្ដសូត្រ ចប់

សូត្រធី ១១ ចប់

សុត្តន្តបិដក

លោហិច្ចសូត្រទី ១២

[១៥៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់ព្រះដំណើរទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយពួកភិក្ខុច្រើនប្រមាណ ៥០០ រូប ក៏បានទៅដល់ស្រុកឈ្មោះសាលវតិកា ។ ក៏សម័យនោះឯង ព្រាហ្មណ៍ឈ្មោះលោហិច្ច នៅអាស្រ័យក្នុងស្រុកសាលវតិកា ដែលជាស្រុកកុះករដោយសត្វ គឺមនុស្ស និងតិរច្ឆាន មានជ័រ សេះជាដើម បរិបូណ៌ដោយស្មៅ ឧស និងទឹក បរិបូណ៌ដោយស្រូវអង្កាជាព្រះរាជទ្រព្យ ដែលព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជទាន ជាព្រះរាជអំណោយ ជារង្វាន់ដ៏ប្រសើរ ។

[១៥៤] ជួនសម័យនោះឯង ទិដ្ឋិអាក្រក់មានសភាពដូច្នោះ ក៏កើតឡើងដល់លោហិច្ចព្រាហ្មណ៍ថា សមណៈ ឬព្រាហ្មណ៍ក្នុងលោកនេះគប្បីបាននូវកុសលធម៌ លុះបាននូវកុសលធម៌ហើយ មិនគប្បីប្រាប់ដល់អ្នកដទៃទេ ព្រោះថា អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន ដូចជាបុគ្គលកាត់ចំណងចាស់ ចងចំណងថ្មីដទៃវិញ យ៉ាងណាមិញ សេចក្តីនេះ ក៏យ៉ាងនោះដែរ អាត្មាអញ (យល់) ថា លោកធម៌ដ៏លាមកអ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន ។ តមក លោហិច្ចព្រាហ្មណ៍ បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្ត ចេញចាកសក្យត្រកូលទៅបួស ហើយទ្រង់ព្រះដំណើរទៅកាន់ចារិកក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃជាច្រើនប្រមាណ ៥០០ រូប បានដល់មក

ស្រុកសាលវតិកាហើយ កិត្តិសព្ទសរសើរព្រះគោតមដ៏ចម្រើននោះពីរោះ ឮ ខ្ចរខ្ចាយ សុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គ បានត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលមកកាន់កពថ្មីទៀត ទ្រង់បាន ត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គ ហើយញុំាង លោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្ស ដ៏សេស ឲ្យបានត្រាស់ដឹងផង ទ្រង់សម្តែងធម៌ពីរោះបទដើម បទកណ្តាល និងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ កិរិយាដែលបានឃើញ បានជួបនឹងព្រះ អរហន្តទាំងឡាយ មានសភាពដូច្នោះ ជាការប្រពៃណាស់ ។

[១៥៥] លំដាប់នោះឯង លោហិច្ចព្រាហ្មណ៍ បាននិយាយនឹងអ្នក ផ្ទួតទឹកឈ្មោះរោសិកៈថា ម្នាលរោសិកៈជាសម្លាញ់ អ្នកចូរមកអាយ អ្នកចូរ ទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរទូលសួរនូវសេចក្តីមិន មានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយ និងធម៌ជាគ្រឿងនៅជាសុខ ចំពោះព្រះសមណគោតមតាមពាក្យរបស់យើង ថា បពិត្រព្រះគោតមដ៏ចម្រើន លោហិច្ចព្រាហ្មណ៍ (ផ្តាំឲ្យ) ទូលសួរនូវ សេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយ និងធម៌ជាគ្រឿងនៅជាសុខចំពោះព្រះគោតមដ៏ចម្រើន រួចហើយ ចូរទូលយ៉ាងនេះថា សូមព្រះគោតមដ៏ចម្រើន ព្រមដោយកិក្ខុសង្ឃ ទទួលកត្ត

របស់លោហិច្ចព្រាហ្មណ៍ ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ។ អ្នកផ្ទះតទីកឈ្មោះ រោសិកៈ ទទួលពាក្យរបស់លោហិច្ចព្រាហ្មណ៍ថា បាទអ្នកម្ចាស់ ហើយក៏ដើរ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះ មានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះអ្នកផ្ទះតទីកឈ្មោះរោសិកៈ អង្គុយក្នុងទីដ៏សមគួរស៊ប់ហើយ ក៏បានយកសេចក្តីនេះក្រាបបង្គំទូលព្រះមាន ព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន លោហិច្ចព្រាហ្មណ៍ (ផ្តាំឲ្យ) ទូលសួរ នូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយ និងធម៌ជាគ្រឿងនៅជាសុខ ចំពោះព្រះមានព្រះភាគ ហើយឲ្យ ទូលនិមន្តព្រះអង្គយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមដោយភិក្ខុសង្ឃទទួលភត្ត របស់លោហិច្ចព្រាហ្មណ៍ ដើម្បីឆាន់ក្នុងថ្ងៃ ស្អែកនេះ ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។

[๑๕๖] លំដាប់នោះ អ្នកផ្ទះតទីកឈ្មោះរោសិកៈ ដឹងច្បាស់ថា ព្រះ មានព្រះភាគទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈក្រាបថ្វាយបង្គំលាព្រះ មានព្រះភាគ ធ្វើប្រទក្សិណរួចហើយ ដើរចូលទៅរកលោហិច្ចព្រាហ្មណ៍ លុះ ចូលទៅដល់ហើយ បាននិយាយប្រាប់សេចក្តីនុ៎ះ ចំពោះលោហិច្ចព្រាហ្មណ៍ថា ខ្ញុំបានទូលព្រះមានព្រះភាគនោះ តាមពាក្យរបស់អ្នកម្ចាស់ហើយថា បពិត្រ ព្រះអង្គដ៏ចម្រើន លោហិច្ចព្រាហ្មណ៍ឲ្យទូលសួរនូវសេចក្តីមិនមានអាពាធ មិនមាននរោគ ការក្រោកឡើងដោយរហ័សរហួន កម្លាំងកាយ និងធម៌ជា គ្រឿងនៅជាសុខ ចំពោះព្រះមានព្រះភាគ ហើយឲ្យនិមន្តព្រះអង្គយ៉ាងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគព្រមដោយភិក្ខុសង្ឃ ទទួលភត្ត របស់លោហិច្ចព្រាហ្មណ៍ ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ឯឥឡូវព្រះមានព្រះភាគ នោះ ក៏ទ្រង់បានទទួលនិមន្តន៍ស្រេចហើយ ។ លុះកន្លងរាត្រីនោះហើយ លោហិច្ចព្រាហ្មណ៍ ឲ្យតាក់តែងខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសា ក្នុងផ្ទះ របស់ខ្លួន រួចហើយ ហៅអ្នកផ្ងូតទឹកឈ្មោះរោសិកៈមកនិយាយថា ម្នាល រោសិកៈជាសម្លាញ់ អ្នកចូរមកអាយ អ្នកចូលទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរក្រាបទូលភត្តកាលចំពោះព្រះសមណគោតមថា បពិត្រព្រះគោតមដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ។ អ្នកផ្ងូតទឹកឈ្មោះរោសិកៈ ទទួលពាក្យរបស់លោហិច្ចព្រាហ្មណ៍ថា ជាទ អ្នក ដ៏ចម្រើន ហើយក៏ដើរចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយឈរក្នុងទីដ៏សមគួរ ។ លុះអ្នកផ្ងូត ទឹកឈ្មោះរោសិកៈ ឈរក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលនូវភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះ ជាកាលគួរ ហើយ ភត្តក៏សម្រេចហើយ ។

[๑๕๗] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និង ចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅក្នុងស្រុកឈ្មោះសាលវតិកានោះ ព្រមដោយភិក្ខុសង្ឃ ។ សម័យនោះឯង អ្នកផ្ងូតទឹកឈ្មោះរោសិកៈ ក៏ដើរ តាមក្រោយៗ នៃព្រះមានព្រះភាគ ។ វេលានោះ អ្នកផ្ងូតទឹកឈ្មោះរោសិកៈ បានយកសេចក្តីនេះ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន

ទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះ កើតទៀងដល់លោហិច្ចព្រាហ្មណ៍ថា សមណព្រាហ្មណ៍ក្នុងលោកនេះ គប្បីបាននូវកុសលធម៌ លុះបាននូវកុសលធម៌ហើយ មិនគប្បីប្រាប់ដល់អ្នកដទៃទេ ព្រោះថា អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន ដូចជាបុគ្គលកាត់ចំណងចាស់ហើយ ចងចំណងថ្មីដទៃវិញ យ៉ាងណាមិញ សេចក្តីនេះយ៉ាងនោះដែរ អាត្មាអញ (យល់) ថា លោកធម៌ដ៏លាមក អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគជួយដោះលោហិច្ចព្រាហ្មណ៍ ឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះចេញ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវោសិក: កិច្ចប៉ុណ្ណោះមិនមែនជាការៈនៃតថាគតទេ ម្នាលវោសិក: កិច្ចប៉ុណ្ណោះមិនសមគួរដល់តថាគតទេ ។ រួចព្រះមានព្រះភាគទ្រង់ព្រះដំណើរ ទៅកាន់លំនៅលោហិច្ចព្រាហ្មណ៍នោះ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ គ្រានោះឯង លោហិច្ចព្រាហ្មណ៍ បានអង្គាសថ្វាយខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯង ចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ គ្រាតែហាមឃាត់ ។

[๑๕๘] លុះព្រះមានព្រះភាគ ទ្រង់សោយស្រេចលែងលូកព្រះហស្តចេញក្នុងបាត្រហើយ លោហិច្ចព្រាហ្មណ៍ក៏កាន់យកអាសនៈមួយដ៏ទាប ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគទ្រង់សួរសេចក្តីនុ៎ះ ចំពោះលោហិច្ចព្រាហ្មណ៍ ដែលអង្គុយក្នុងទីដ៏សមគួរថា ម្នាលលោហិច្ច បានឮថា ទិដ្ឋិអាក្រក់យ៉ាងនេះ កើតទៀងដល់អ្នកថា សមណព្រាហ្មណ៍ក្នុងលោកនេះ គប្បី

បាននូវកុសលធម៌ លុះបាននូវកុសលធម៌ហើយ មិនគប្បីប្រាប់ដល់អ្នកដទៃទេ ព្រោះអ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបាន ដូចជាបុគ្គលកាត់ចំណងចាស់ចោលចេញហើយ ចងនូវចំណងថ្មីដទៃវិញ យ៉ាងណាមិញ សេចក្តីនេះក៏យ៉ាងនោះដែរ អាត្មាអញ (យល់) ថា លោកធម៌ដ៏លាមក អ្នកដទៃនឹងធ្វើអ្វីឲ្យអ្នកដទៃបានដូច្នេះ ពិតមែនឬ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងនោះមែន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលលោហិច្ច អ្នកសម្គាល់សេចក្តីនោះដូចម្តេច អ្នកអាស្រ័យនៅក្នុងស្រុកសាលវតិកាមិនមែនឬ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងនោះមែន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលលោហិច្ច ជនណានិយាយយ៉ាងនេះថា លោហិច្ចព្រាហ្មណ៍គ្រប់គ្រងស្រុកសាលវតិកា សួយណាដែលកើតឡើងក្នុងស្រុកសាលវតិកា លោហិច្ចព្រាហ្មណ៍ត្រូវបរិភោគសួយនោះតែម្នាក់ឯង មិនត្រូវឲ្យអ្នកដទៃទេ (បើ) ជននោះនិយាយយ៉ាងនេះ តើឈ្មោះថា អ្នកធ្វើសេចក្តីអន្តរាយ ដល់ពួកញាតិមិត្ត និងកម្មករ ដែលរស់នៅព្រោះអាស្រ័យនឹងអ្នក ឬក៏មិនមែនទេ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ឈ្មោះថាអ្នកធ្វើសេចក្តីអន្តរាយមែន ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា (បើ) ជននោះឈ្មោះថា អ្នកធ្វើសេចក្តីអន្តរាយ តើជននោះនឹងហៅថា អ្នកអនុគ្រោះដោយប្រយោជន៍ដល់ពួកញាតិមិត្តទាំងនោះ ឬមិនអនុគ្រោះដោយប្រយោជន៍ទេ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ហៅថា អ្នកមិនអនុគ្រោះដោយប្រយោជន៍ទេ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា (បើ) ជននោះមិនអនុគ្រោះដោយប្រយោជន៍ ហើយ នឹងហៅថា អ្នកតាំងចិត្តមេត្តាទៅរកញ្ញាតិមិត្តទាំងនោះ ឬហៅថា ជាសឹកសត្រូវ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ហៅថា សឹកសត្រូវ ។ ព្រះអង្គទ្រង់ត្រាស់ថា កាលបើចិត្តជាសឹកសត្រូវតាំងឡើងហើយ នឹងហៅថា ជននោះជាមិច្ឆាទិដ្ឋិ ឬជាសម្មាទិដ្ឋិ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ហៅថា ជាមិច្ឆាទិដ្ឋិ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលលោហិច្ច តថាគតតែងពោលនូវគតិ ២ យ៉ាង គឺនរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយចំពោះជនជាមិច្ឆាទិដ្ឋិ ។

[១៥៩] ព្រះមានព្រះភាគត្រាស់សួរថា ម្នាលលោហិច្ច អ្នកសម្គាល់សេចក្តីនោះដូចម្តេច ក្រែងព្រះបាទបសេនទិកោសល គ្រប់គ្រងដែនកាសី និងកោសលឬ ។ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពិតមែន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលលោហិច្ច ជនណានិយាយយ៉ាងនេះថា ព្រះបាទបសេនទិកោសល គ្រប់គ្រងដែនកាសី និងដែនកោសល សួយណាកើតឡើងក្នុងដែនកាសី និងកោសល ព្រះបាទបសេនទិកោសល ត្រូវបរិភោគសួយនោះតែមួយព្រះអង្គឯង មិនត្រូវប្រទានដល់ពួកជនដទៃទេ (បើ) ជននោះនិយាយយ៉ាងនេះ តើនឹងចាត់ជាអ្នកធ្វើសេចក្តីអន្តរាយដល់អ្នកទាំងឡាយ និងពួកជនដទៃ ដែលរស់នៅដោយសារព្រះបាទបសេន-ទិកោសលនោះ ឬមិនមែនទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ចាត់ជាអ្នកធ្វើ

សេចក្តីអន្តរាយ ។ (បើ) ចាត់ជាអ្នកធ្វើសេចក្តីអន្តរាយហើយ តើនឹងចាត់ជាអ្នកអនុគ្រោះដោយប្រយោជន៍ដល់ពួកជនទាំងនោះ ឬមិនចាត់ជាអ្នកអនុគ្រោះដោយប្រយោជន៍ទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនចាត់ជាអ្នកអនុគ្រោះដោយប្រយោជន៍ទេ ។ (បើ) មិនចាត់ជននោះថាជាអ្នកអនុគ្រោះដោយប្រយោជន៍ទេ តើនឹងចាត់ថា ជាអ្នកតាំងមេត្តាចិត្តទៅរកញាតិមិត្តទាំងនោះ ឬចាត់ថា ជាសឹកសត្រូវ ។ បពិត្រព្រះគោតមដ៏ចម្រើន ចាត់ថាជាសឹកសត្រូវ ។ កាលបើចិត្តជាសឹកសត្រូវកើតឡើងហើយ តើនឹងចាត់ជននោះជាមិច្ឆាទិដ្ឋិ ឬជាសម្មាទិដ្ឋិ ។ បពិត្រព្រះគោតមដ៏ចម្រើន ចាត់ថាជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ចៈ តថាគតតែងសម្តែងនូវគតិពីរយ៉ាង គឺនរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយចំពោះជនជាមិច្ឆាទិដ្ឋិ ។

[๒๖๐] ម្នាលលោហិច្ចៈ បានឮមកថា ជនណាមួយនិយាយយ៉ាងនេះថា លោហិច្ចព្រាហ្មណ៍នៅគ្រប់គ្រងស្រុកសាលវតិកា សួយណាដែលកើតឡើងក្នុងស្រុកសាលវតិកា លោហិច្ចព្រាហ្មណ៍ត្រូវបរិភោគសួយនោះតែម្នាក់ឯង មិនត្រូវឲ្យដល់ពួកជនដទៃទេ (បើ) ជននោះនិយាយយ៉ាងនេះ ឈ្មោះថាជាអ្នកធ្វើសេចក្តីអន្តរាយ ដល់ពួកញាតិមិត្ត និងកម្មករដែលរស់នៅដោយសារអ្នក កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយ ឈ្មោះថា ជាអ្នកមិនអនុគ្រោះដោយប្រយោជន៍ កាលបើមិនអនុគ្រោះដោយប្រយោជន៍ហើយ ចិត្តជាសឹកសត្រូវក៏កើតច្រាកជាឡើង កាលបើចិត្តជាសឹកសត្រូវកើតច្រាកជាឡើងហើយ បុគ្គលនោះឈ្មោះថា ជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ចៈ យ៉ាងហ្នឹងហើយ

(បើ) ជនណាមួយនិយាយយ៉ាងនេះថា សមណព្រាហ្មណ៍ក្នុងលោកនេះ គប្បីបានសម្រេចកុសលធម៌ លុះបានសម្រេចកុសលធម៌ហើយ មិនគប្បីប្រាប់ដល់បុគ្គលដទៃទេ ព្រោះថា បុគ្គលដទៃនឹងធ្វើអ្វីឲ្យបុគ្គលដទៃបាន ។ ជួចបុគ្គលកាត់ចំណងចាស់ចោលចេញ ។បេ។ នឹងធ្វើ ។ ជនដែលនិយាយយ៉ាងនេះ នោះឈ្មោះថា ជាអ្នកធ្វើសេចក្តីអន្តរាយដល់ពួកកុលបុត្រ អ្នកអាស្រ័យនូវធម្មវិនយ ដែលតថាគតបានប្រកាសស្រេចហើយ បានសម្រេចគុណវិសេសដ៏លើសលប់ មានសភាពយ៉ាងនោះ ទាំងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលខ្លះ ទាំងដល់ពួកកុល-បុត្រ (ដែលស្តាប់ធម្មទេសនារបស់ព្រះតថាគតហើយ តែមិនទាន់បានលុះអរិយភូមិនៅឡើយ) គ្រាន់តែបង្អោនចិត្តទៅកាន់ទេវលោក ដើម្បីកើតក្នុងទេវលោក កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយ ឈ្មោះថា ជាអ្នកមិនអនុគ្រោះដោយប្រយោជន៍ កាលបើមិនអនុគ្រោះដោយប្រយោជន៍ហើយ ចិត្តជាសត្រូវក៏កើតប្រាកដឡើង កាលបើចិត្តជាសត្រូវកើតប្រាកដហើយ ជននោះឈ្មោះថា ជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ច តថាគតតែងពោលនូវគតិ ២ យ៉ាង គឺនរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយ ចំពោះជនជាមិច្ឆាទិដ្ឋិ ។

[๑๖๑] ម្នាលលោហិច្ច បានឮមកថា ជនណាមួយនិយាយយ៉ាងនេះថា ព្រះបាទបសេនទិកោសល នៅគ្រប់គ្រងដែនកាសី និងកោសល សួយណាដែលកើតឡើងក្នុងដែនកាសី និងកោសល ព្រះបាទបសេនទិកោសលត្រូវ

សោយសួយនោះតែមួយព្រះអង្គឯង មិនត្រូវប្រទានដល់ពួកជនឯទៀតទេ ជន ដែលនិយាយយ៉ាងនេះ នោះឈ្មោះថា ជាអ្នកធ្វើសេចក្តីអន្តរាយ ដល់រាជ-បរិពារ គឺពួកអ្នករាល់គ្នា និងពួកជនឯទៀតដែលរស់នៅដោយសារ ព្រះបាទ បសេនទិកោសល កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយ ឈ្មោះថាជាអ្នក មិនអនុគ្រោះដោយប្រយោជន៍ កាលបើមិនអនុគ្រោះដោយប្រយោជន៍ហើយ ចិត្តជាសឹកសត្រូវឈ្មោះថា កើតជ្រុកជន់ឡើង កាលបើចិត្តជាសឹកសត្រូវកើត ជ្រុកជន់ហើយ ជននោះឈ្មោះថាជាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ច យ៉ាងហ្នឹងហើយ (បើ) ជនណាមួយនិយាយយ៉ាងនេះថា សមណៈ ឬព្រាហ្មណ៍ក្នុងលោក នេះ គប្បីបានសម្រេចកុសលធម៌ លុះបានសម្រេចកុសលធម៌ហើយ មិន គប្បីជ្រាបបុគ្គលឯទៀតទេ ព្រោះថា បុគ្គលឯទៀតនឹងធ្វើអ្វីឲ្យបុគ្គលឯទៀត បាន ។ ដូចជាបុគ្គលកាត់ចំណងចាស់ចោលចេញហើយ ចងចំណងថ្មីដទៃ ទៀតឡើងវិញជួច្នេះឯង ខ្ញុំយល់ថា លោកធម៌ជាអំពើជ័ណាមក ព្រោះហេតុ ថា បុគ្គលឯទៀតនឹងធ្វើអ្វីឲ្យបុគ្គលឯទៀតកើត ។ ជនដែលនិយាយយ៉ាងនេះ នោះឈ្មោះថា ជាអ្នកធ្វើសេចក្តីអន្តរាយដល់ពួកកុលបុត្រ ដែលអាស្រ័យ នូវធម្មវិនัย ដែលតថាគតសម្តែងហើយ បានសម្រេចគុណវិសេសដ៏លើស លុប មានសភាពយ៉ាងនេះហើយ ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលខ្លះ ធ្វើ ឲ្យជាក់ច្បាស់នូវសកទាគាមិផលខ្លះ ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលខ្លះ ធ្វើ ឲ្យជាក់ច្បាស់នូវអរហត្តផលខ្លះ ទាំងដល់ពួកកុលបុត្រ (ដែលបានស្តាប់ធម្ម-ទេសនារបស់តថាគតហើយ តែមិនទាន់បានលុះអរិយភូមិនៅឡើយ) គ្រាន់

តែបង្អោនចិត្តទៅកាន់ទេវលោក ដើម្បីកើតក្នុងទេវលោក កាលបើជាអ្នកធ្វើសេចក្តីអន្តរាយហើយឈ្មោះថាជាអ្នកមិនអនុគ្រោះដោយប្រយោជន៍ កាលបើមិនអនុគ្រោះដោយប្រយោជន៍ ចិត្តជាសឹកសត្រូវឈ្មោះថា កើតប្រាកដឡើង កាលបើចិត្តជាសឹកសត្រូវកើតឡើងហើយ ជននោះឈ្មោះថាមិច្ឆាទិដ្ឋិ ។ ម្នាលលោហិច្ច តថាគតតែងពោលនូវគតិ ២ យ៉ាង គឺនរក ១ កំណើតសត្វតិរច្ឆាន ១ គតិណាមួយ ចំពោះជនជាមិច្ឆាទិដ្ឋិ ។

[១៦២] ម្នាលលោហិច្ច គ្រូទាំង ៣ ពួកនេះ ដែលគួរដល់ការចោទប្រកាន់បានក្នុងលោក មួយទៀត ជនណាចោទប្រកាន់ពួកគ្រូដែលមានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការពិតប្រាកដ ប្រកបដោយធម៌ឥតទោសទេ គ្រូទាំង ៣ ពួកនោះ តើដូចម្តេចខ្លះ ម្នាលលោហិច្ច គ្រូពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់សាមញ្ញគុណណា ប្រយោជន៍នៃសាមញ្ញគុណនោះ គ្រូនោះមិនបានសម្រេចឡើយ ។ គ្រូនោះ មិនបានសម្រេចប្រយោជន៍ នៃសាមញ្ញគុណនោះហើយសម្តែងធម៌ដល់ពួកសាវកថា អំពើនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ ពួកសាវករបស់គ្រូនោះរមែងមិនស្តាប់ មិនផ្អៀងត្រចៀកស្តាប់ មិនតាំងចិត្តប្រុងស្តាប់ ដើម្បីឲ្យដឹងច្បាស់ឡើយ មានតែនាំគ្នាប្រព្រឹត្តគេចចេញចាកពាក្យប្រដៅរបស់គ្រូ ។ គ្រូនោះ អ្នកផងគួរចោទប្រកាន់យ៉ាងនេះថា លោកមានអាយុ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់សាមញ្ញគុណ

ณา (បើ) ប្រយោជន៍នៃសាមញ្ញគុណានោះ លោកមិនទាន់បានសម្រេចទេ លោកមិនទាន់បានសម្រេចប្រយោជន៍ នៃសាមញ្ញគុណានោះ ហើយសម្តែងធម៌ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ សាវ័កទាំងនោះ របស់លោក រមែងមិនស្តាប់ មិនផ្ទៀងត្រចៀកស្តាប់ មិនតាំងចិត្តប្រុងស្តាប់ ដើម្បីឲ្យដឹងច្បាស់ មានតែនាំគ្នាប្រព្រឹត្តគេចចេញចាកពាក្យប្រដៅរបស់គ្រូ បុរសចូលទៅរកស្ត្រីដែលមិនស្មគ្រ គឺស្ត្រីដែលមិនប្រាថ្នារួមសំវាសជាមួយ ឬចូលទៅឱបពីខាងក្រោយ សេចក្តីនេះឧបមាយ៉ាងណា បុគ្គលដែលនិយាយថា ខ្ញុំ (យល់) ថា លោកធម៌ជាធម៌លាមក បុគ្គលដទៃដូចម្តេច នឹងធ្វើអ្វីឲ្យបុគ្គលដទៃបាន ក៏យ៉ាងនោះដែរ ។ ម្នាលលោហិច្ច នេះឯងជាគ្រូទី ๑ ដែលគួរដល់ការចោទប្រកាន់បានក្នុងលោក បើអ្នកណាចោទប្រកាន់គ្រូមានសភាពដូច្នោះ ការចោទប្រកាន់នោះ ជាការពិតប្រាកដ ប្រកបដោយធម៌ឥតទោសទេ ។

[๑๖๓] *ម្នាលលោហិច្ច សេចក្តីតទៅទៀតថា គ្រូពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់សាមញ្ញគុណាណា ប្រយោជន៍នៃសាមញ្ញគុណានោះ គ្រូនោះ មិនទាន់បានសម្រេចនៅឡើយ ។ គ្រូនោះ មិនទាន់បានសម្រេចប្រយោជន៍នៃសាមញ្ញគុណានោះ ហើយសម្តែងធម៌ដល់ពួកសាវ័កថា អំពើនេះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយដូច្នេះ ។ សាវ័កទាំង*

នោះរបស់គ្រូនោះ ក៏ស្តាប់ ផ្អៀងត្រចៀកស្តាប់ តាំងចិត្តប្រុងស្តាប់ ដើម្បីដឹងច្បាស់ មិននាំគ្នាប្រព្រឹត្តគេចវេះចេញចាកពាក្យប្រដៅរបស់គ្រូទេ ។ គ្រូនោះ អ្នកផងគួរចោទប្រកាន់យ៉ាងនេះថា លោកមានអាយុចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដើម្បីប្រយោជន៍ដល់សាមញ្ញគុណណា ប្រយោជន៍នៃសាមញ្ញគុណនោះ លោកមិនទាន់បានសម្រេច លោកមិនទាន់បានសម្រេចប្រយោជន៍នៃសាមញ្ញគុណនោះទេ ហើយសម្តែងធម៌ដល់ពួកសាវ័កថា អំពើនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ដូច្នេះ ។ សាវ័កទាំងនោះរបស់គ្រូនោះ ក៏ស្តាប់ផ្អៀងត្រចៀកស្តាប់ តាំងចិត្តប្រុងស្តាប់ ដើម្បីដឹងច្បាស់ មិននាំគ្នាប្រព្រឹត្តគេចវេះចេញចាកពាក្យប្រដៅរបស់គ្រូទេ បុគ្គលលះបង់ស្រែរបស់ខ្លួនចេញហើយទៅសម្គាល់ស្រែរបស់បុគ្គលដទៃ ថាគួរជម្រះ (ស្មៅ) សេចក្តីនេះ មានឧបមាយ៉ាងណា បុគ្គលដែលនិយាយថា ខ្ញុំយល់ថា លោកធម៌ ជាធម៌លាមក បុគ្គលដទៃនឹងធ្វើអ្វីឲ្យបុគ្គលដទៃបាន ក៏យ៉ាងនោះដែរ ។ ម្នាលលោហិច្ចៈ នេះជាគ្រូទី ២ ដែលគួរដល់ការចោទប្រកាន់ក្នុងលោក បើបុគ្គលណាចោទប្រកាន់គ្រូមានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការពិតប្រាកដ ប្រកបដោយធម៌ឥតទោសទេ ។

[๑๖๔] ម្នាលលោហិច្ចៈ សេចក្តីតទៅទៀតថា គ្រូពួកខ្លះក្នុងលោកនេះ ចេញចាកផ្ទះទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់សាមញ្ញគុណណា ប្រ-យោជន៍នៃសាមញ្ញគុណនោះ គ្រូនោះ មិនទាន់បានសម្រេចនៅឡើយ ។ គ្រូ

នោះមិនទាន់បានសម្រេចសាមញ្ញគុណានោះ ហើយសម្តែងធម៌ដល់ពួកសាវក ថា អំពើនេះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្ត ទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយដូច្នេះ ។ សាវកទាំងនោះ របស់គ្រូ នោះ ក៏មិនស្តាប់ មិនផ្អៀងត្រចៀកស្តាប់ មិនតាំងចិត្តប្រុងស្តាប់ ដើម្បីឲ្យដឹងច្បាស់ទេ មានតែនាំគ្នាប្រព្រឹត្តគេចវេះ ចេញចាកពាក្យប្រដៅរបស់គ្រូ គ្រូ នោះគួរឲ្យអ្នកផងចោទប្រកាន់យ៉ាងនេះថា លោកមានអាយុចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់សាមញ្ញគុណណា ប្រយោជន៍នៃសាមញ្ញគុណានោះ លោកមិនបានសម្រេចនៅឡើយ លោកមិនទាន់សម្រេច សាមញ្ញគុណានោះ ហើយសម្តែងធម៌ដល់ពួកសាវកថា អំពើនេះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ អំពើនេះប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់ អ្នកទាំងឡាយដូច្នេះ ។ សាវកទាំងនោះរបស់គ្រូនោះ ក៏មិនស្តាប់ មិនផ្អៀង ត្រចៀកស្តាប់ មិនតាំងចិត្តប្រុងស្តាប់ ដើម្បីឲ្យដឹងច្បាស់ទេ មានតែប្រព្រឹត្ត គេចវេះចេញចាកពាក្យប្រដៅរបស់គ្រូ បុគ្គលកាត់ចំណងចាស់ចេញហើយ ចងចំណងថ្មីដទៃទៀតវិញ សេចក្តីនេះ មានឧបមាយ៉ាងណា បុគ្គលដែល និយាយថា ខ្ញុំយល់ថា លោកធម៌ជាធម៌លាមក បុគ្គលដទៃនឹងជួយធ្វើអ្វីដល់ បុគ្គលដទៃបាន ក៏យ៉ាងនោះដែរ ។ ម្នាលលោហិច្ច នេះជាគ្រូទី ៣ ដែលគួរ ដល់ការចោទប្រកាន់ក្នុងលោកបាន បើអ្នកណាចោទប្រកាន់គ្រូមានសភាព យ៉ាងនេះ ការចោទប្រកាន់នោះ ជាការពិតប្រាកដ ប្រកបដោយធម៌តទោស ទេ ។ ម្នាលលោហិច្ច គ្រូទាំង ៣ ពួកនេះឯង ដែលគួរដល់ការចោទប្រកាន់

ក្នុងលោកបាន បើអ្នកណាចោទប្រកាន់គ្រូទាំងឡាយ មានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការពិតជ្រាកដ ប្រកបដោយធម៌ ឥតទោសទេ ។

[๑๖๕] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ លោហិច្ចព្រាហ្មណ៍ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រូណាមួយដែលមិនគួរដល់ការចោទប្រកាន់ក្នុងលោក តើមានឬទេ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលលោហិច្ច គ្រូដែលមិនគួរដល់ការចោទប្រកាន់ក្នុងលោកមានដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះគ្រូដូចម្តេច ដែលមិនគួរដល់ការចោទប្រកាន់ក្នុងលោក ។ ម្នាលលោហិច្ច ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ។បេ។ (បណ្ឌិតគប្បីសម្តែងឲ្យពិស្តារដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។បេ។ ម្នាលលោហិច្ច ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។បេ។ បានដល់នូវបឋមជ្ឈាន ។ ម្នាលលោហិច្ច សាវ័កវមែងសម្រេចនូវគុណវិសេសដ៏លើសលុប មានសភាពយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។ម្នាលលោហិច្ច សាស្តានេះឯងមិនគួរដល់ការចោទប្រកាន់ក្នុងលោកឡើយ បើអ្នកណាចោទប្រកាន់សាស្តា មានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការមិនពិតជ្រាកដ មិនប្រកបដោយធម៌ ប្រកបដោយទោសវិញ ។បេ។ ភិក្ខុបានដល់នូវទុតិយជ្ឈាន ។ នូវតតិយជ្ឈាន ។ នូវចតុត្ថជ្ឈាន ។ ម្នាលលោហិច្ច សាវ័កដែលសម្រេចនូវគុណវិសេសលើសលុប មានសភាពយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។ ម្នាលលោហិច្ច សាស្តានេះឯង មិនគួរដល់ការចោទប្រកាន់ក្នុងលោកឡើយ បើបុគ្គលណា

ចោទប្រកាន់សាស្តាមានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការមិនពិតប្រាកដ មិនប្រកបដោយធម៌ ប្រកបដោយទោសវិញ ។បេ។ ភិក្ខុតម្រង់ផ្ងង់បង្អោនចិត្តទៅ ដើម្បីញ្ញាណទស្សនៈ ។ ម្នាលលោហិច្ចៈ សាវ័កដែលសម្រេចនូវគុណវិសេសដ៏លើសលុបយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។បេ។ ជីងច្បាស់ថា កិច្ចដទៃក្រៅពីនេះទៅទៀតមិនមានឡើយ ។ ម្នាលលោហិច្ចៈ សាវ័កដែលសម្រេចនូវគុណវិសេសដ៏លើសលុបយ៉ាងនេះ ក្នុងសំណាក់នៃសាស្តាណា ។ ម្នាលលោហិច្ចៈ សាស្តានេះឯង ដែលមិនគួរដល់ការចោទប្រកាន់ក្នុងលោកឡើយ បើបុគ្គលណាចោទប្រកាន់សាស្តា មានសភាពយ៉ាងនេះ ការចោទប្រកាន់នោះ ជាការមិនពិតប្រាកដ មិនប្រកបដោយធម៌ ប្រកបដោយទោសវិញ ។

[๑๖๖] *លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ លោហិច្ចព្រាហ្មណ៍ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន បុរសចាប់សក់បុរសផងគ្នា ដែលធ្លាក់ទៅក្នុងជ្រោះជ្រៅ ទាញឡើងលើគោកបានយ៉ាងណា ព្រះគោតមដ៏ចម្រើន ក៏ស្រង់ខ្ញុំព្រះអង្គ ដែលធ្លាក់ទៅក្នុងជ្រោះជ្រៅ គឺអបាយភូមិ យកមកដាក់លើគោក គឺឋានសួគ៌បាន យ៉ាងនោះដែរ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាគេផ្ងារវត្ថុដែលផ្កាប់ ឬដូចជាបើកនូវវត្ថុដែលកំបាំង ពុំនោះសោត ដូចជាគេប្រាប់ផ្លូវដល់អ្នក*

វង្វេងផ្លូវដូច្នោះឯង ។បេ។ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវព្រះរតនត្រ័យ ជាសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។បេ។

លោហិច្ចសូត្រទី ១២ ចប់

អដ្ឋកថា

លោហិច្ចសូត្រ

[១៥៣] *លោហិច្ចសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុត្តំ ។បេ។ កោសលំ** *ជាដើម ។*

តទៅនេះ ជាការអធិប្បាយបទ ដែលលំបាកក្នុងលោហិច្ចសូត្រនោះ បទថា **សាលវតិកា** *ជាឈ្មោះរបស់ស្រុកនោះ ។ បានឮមកថា ស្រុកនោះព័ទ្ធដោយដើមរាំងភ្នំ ដុះជាជួរទៅតាមលំដាប់ ដូចព័ទ្ធដោយរបង ព្រោះដូច្នោះទើបហៅថា* **ស្រុកសាលវតិកា** *។ បទថា* **លោហិច្ចោ** *ជាឈ្មោះព្រាហ្មណ៍នោះ ។*

[១៥៤-១៥៧] *បទថា* **ធាបកំ** *គឺឈ្មោះថា អាក្រក់ ព្រោះវៀរចាកការអនុគ្រោះអ្នកដទៃ ។ តែមិនមែនឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិណាមួយឡើយ ។ បទថា* **ឧប្បន្នំ ហោតិ** *គឺកើតឡើងហើយ បានដល់ មិនមែនត្រឹមតែកើតក្នុងចិត្តតែម្យ៉ាងប៉ុណ្ណោះ ។ បានឮថា លោហិច្ចព្រាហ្មណ៍នោះ និយាយយ៉ាងនោះសូម្បីក្នុងកណ្តាលបរិស័ទ តាមអំណាចរបស់ចិត្ត ។ បទទាំងឡាយថា* **កិញ្ហិ បរោ បរស្ស** *នេះ អធិប្បាយថា អ្នកដទៃនឹងនិយាយថា បុគ្គលដែលត្រូវគេទូន្មាននឹងធ្វើអ្វី ដល់អ្នកទូន្មាននោះបាន ខ្លួនឯងទ្រុះឯង គួរសក្ការៈ គោរពកុសលធម៌ដែលខ្លួនបានហើយ ។*

បទថា **រោសិកំ ន្ហាបិតំ អាមន្តេសិ** *សេចក្តីថា លោហិច្ចព្រាហ្មណ៍ហៅជាងកោរកាត់[១] ដែលបានឈ្មោះជាឥត្ថីលិង្គយ៉ាងនេះថា រោសិកា បានឮ*

១- *បិដកខ្មែរថា អ្នកផ្លូតទឹក ។*

ថា លោហិច្ចព្រាហ្មណ៍ ជ្រាបដល់ការយាងមក របស់ព្រះមានព្រះភាគហើយ គិតថា ការដែលអញទៅគាល់ព្រះសមុទ្ទដែលប្រថាប់ នឹងជាការៈ តែអញនឹងអារាធនាឲ្យទ្រង់យាងមកកាន់ផ្ទះ ហើយចូលគាល់ និងថ្វាយអាគន្តុកកិច្ចាតាមកម្លាំង ព្រោះដូច្នោះ ទើបលោហិច្ចព្រាហ្មណ៍ ហៅរោសិកា ជាងកោរកាត់នោះមក ។

បទថា **ឯដ្ឋិតោ ឯដ្ឋិតោ** *សេចក្តីថា រោសិកាជាងកោរកាត់ដើរតាមពីខាងក្រោយព្រះមានព្រះភាគ ដើម្បីស្រួលក្នុងការទូលសន្ទនា ។ បទថា* **វិវេចេតុ** *គឺរោសិកាក្រាបទូលព្រះមានព្រះភាគថា សូមព្រះមានព្រះភាគ ទ្រង់ដោះ គឺកម្ចាត់ទិដ្ឋិអាក្រក់ បានឮថា រោសិកានេះ ជាឧបាសក ជាមិត្តសម្លាញ់របស់លោហិច្ចព្រាហ្មណ៍ ព្រោះដូច្នោះ ទើបក្រាបទូលយ៉ាងនោះ ព្រោះប្រាថ្នាប្រយោជន៍ដល់លោហិច្ចព្រាហ្មណ៍ ។ ក្នុងបទថា* **អប្បេវ នាម សិយា** *នេះ ព្រះមានព្រះភាគទ្រង់បន្ទឹព្រះសូរសៀងដោយព្រះតម្រាស់ដំបូង ទ្រង់បន្ទឹព្រះសូរសៀងដដែលទៀត ដោយព្រះតម្រាស់ទីពីរ ។ ក្នុងបទនេះ គប្បីជ្រាបអធិប្បាយដូច្នេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីនេះថា ម្នាលរោសិកា តថាគតធ្វើទុក្ករកិរិយាច្រើនយ៉ាង និងបំពេញបារមីរហូតដល់អស់បួនអសង្ខ្យេយ្យ និងមួយសែនកប្ប ក៏ដើម្បីប្រយោជន៍នេះឯង តថាគតដឹងច្បាស់ដោយសព្វញ្ញុតញ្ញាណ ក៏ដើម្បីប្រយោជន៍នេះឯង ការកម្ចាត់ទិដ្ឋិអាក្រក់របស់លោហិច្ចព្រាហ្មណ៍មិនមែនជារឿងធ្ងន់របស់តថាគត ដូច្នេះ ឈ្មោះថា ទ្រង់បន្ទឹព្រះសូរសៀងដោយព្រះតម្រាស់ដំបូង ។ កាលទ្រង់សម្តែងសេចក្តីនេះថា ម្នាលរោសិកា ការមកក្តី ការអង្គុយក្តី ការសន្ទនាប្រាស្រ័យក្តី*

ក្នុងសម្នាក់របស់លោហិច្ចព្រាហ្មណ៍ ទាំងអស់នេះ ចូរលើកទុកសិនចុះ បុគ្គល ដូចលោហិច្ចព្រាហ្មណ៍ មានសេចក្តីសង្ស័យក្នុងបញ្ហារាប់សែនប្រការ តថាគត ក៏មានកម្ចាំងល្មមនឹងបន្ទោបង់សេចក្តីសង្ស័យបាន តែក្នុងការបន្ទោបង់ទិដ្ឋិ អាក្រក់របស់លោហិច្ចព្រាហ្មណ៍ត្រឹមតែម្នាក់ ដូចម្តេចនឹងជារឿងធ្ងន់របស់ តថាគត ដូច្នេះ ទើបទ្រង់បន្ទឺព្រះសូរសៀងដដែល ដោយព្រះតម្រាស់ទីពីរ ។

[១៥៨] បទថា **សមុឧយ សញ្ជាតិ** បានដល់ ការកើតឡើង នៃបច្ចយ គឺការកើតឡើងនៃភោគទ្រព្យ អធិប្បាយថា ទ្រព្យ និងស្រូវ ដែល កើតឡើងអំពីផលប្រយោជន៍នោះ ។ បទថា **យេ តំ ឧបជីវន្តិ** គឺជនទាំងឡាយ មានញាតិ បរិវារ ទាសៈ និងកម្មករជាដើម អាស្រយលោហិច្ចចិញ្ចឹមជីវិត ។ បទថា **អន្តរាយករោ** គឺដែលធ្វើអន្តរាយដល់លាភ ។ ពាក្យថា ប្រយោជន៍ ក្នុងបទថា **ហិតានុកម្ស៊ី** បានដល់ សេចក្តីចម្រើន ។ បុគ្គលរមែងអាណិត ព្រោះដូច្នោះ ឈ្មោះថា អ្នកអនុគ្រោះ សេចក្តីថា រមែងប្រាថ្នា លោកពោល អធិប្បាយថា ប្រាថ្នាសេចក្តីចម្រើន ឬមិនប្រាថ្នា ។

បទថា **និរយំ វា តិរច្ឆានយោនឹ វា** មានអធិប្បាយថា បើទិដ្ឋិ អាក្រក់នោះបរិបូណ៌ គឺពិតប្រាកដ រមែងកើតក្នុងនរកដោយចំណែកមួយ បើ មិនពិតប្រាកដ រមែងកើតក្នុងកំណើតតិរច្ឆាន ។

[១៥៩] ឥឡូវនេះ ព្រោះព្រះដ៏មានព្រះភាគ មានព្រះបំណងនឹងឲ្យ ព្រាហ្មណ៍កើតសេចក្តីតក់ស្ទុតក្រៃលែងឡើង ដូចជាសត្វទាំងឡាយតក់ស្ទុត ដោយអន្តរាយ ព្រោះលាភរបស់ខ្លួនឯង មិនមែនតក់ស្ទុតដោយអន្តរាយព្រោះ លាភរបស់អ្នកដទៃ ដូច្នោះ ទើបត្រាស់រឿងកើតឡើងជាលើកទីពីរថា ម្នាល

លោហិច្ចៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ដូច្នេះ ។

[๑๖๐-๑๖๑] *បទថា* **យេ ចិមេ** *បានដល់ កុលបុត្រទាំងនេះ ស្តាប់ព្រះធម៌ទេសនារបស់ព្រះតថាគតហើយ មិនអាចឈានចុះកាន់អរិយ-ភូមិបាន ។ បទថា* **ឥព្ភា គព្ភា, រូបេ** *សព្ទជាបឋមាវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ប្រែថា គកិដែលជាទិព្វ ។ ម្យ៉ាងទៀត ពាក្យថា គកិដែលជាទិព្វនេះជា ឈ្មោះរបស់ទេវលោក ๖ ជាន់ ។ បទថា* **បរិចារេន្តិ** *អធិប្បាយថា កុលបុត្រទាំងឡាយបំពេញបដិបទា ដើម្បីទៅកាន់ទេវលោក ឲ្យទាន រក្សាសីល ធ្វើការបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ចម្រើនភាវនា ឈ្មោះថា រមែងបរិហារ រមែងអប់រំ គឺរមែងយល់ ដល់ការប្រែប្លែល ។ បទថា* **ឥព្ភានំ ភវានំ អភិឥព្ភត្តិយា** *អធិប្បាយថា វិមានរបស់ទេវតាទាំងឡាយ ឈ្មោះថា ភពជាទិព្វ ដើម្បីទៅកើតក្នុងវិមានទាំងនោះ ។ ម្យ៉ាងទៀត បទថា* **ឥព្ភា គព្ភា** *សំដៅដល់បុណ្យពិសេស មានទានជាដើម ។ បទថា* **ឥព្ភា ភវា** *អធិប្បាយថា ភពទាំងឡាយជាវិបាកក្ខន្ធក្នុងទេវលោក កុលបុត្រទាំងឡាយធ្វើបុណ្យ ដើម្បីកើតក្នុងភពទាំងនោះ ។ បទថា* **តេសំ អន្តរាយករោ** *គឺធ្វើអន្តរាយដល់មគ្គ សម្បត្តិ ផលសម្បត្តិ និងសេចក្តីពិសេសនៃភពដែលជាទិព្វរបស់ជនទាំងនោះ ។*

សាស្តា ๓ ពួកដែលគួរចោទ

[๑๖๒] *ព្រះមានព្រះភាគ កាលទ្រង់ទម្លាយមានះរបស់ព្រាហ្មណ៍ ដែលខ្ឡែងទៅជរាបដល់ភវគ្គព្រហ្ម ដោយវិធីឧបមាដោយមិនកំណត់ ហើយទ្រង់សម្តែងដល់សាស្តា ๓ ពួក ដែលគួរចោទប្រកាន់ ទើបត្រាស់ព្រះតម្រាស់*

ថា ម្នាលលោហិច្ចៈ ត្រូទាំង ៣ ពួកនេះជាដើម ។

បទថា **សា ចោទនា** គឺការចោទប្រកាន់របស់អ្នកចោទប្រកាន់សាស្តា ទាំង ៣ ពួកនោះ ។ បទថា **ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ** គឺមិនចូលទៅតាំងចិត្ត ដើម្បីដឹងជុំវិញ គឺដើម្បីប្រយោជន៍ដល់ការដឹងទូទៅ ។ បទថា **រោក្ពម្មា** អធិប្បាយថា មិនធ្វើតាមពាក្យប្រៀនប្រដៅរបស់សាស្តានោះសព្វកាល ប្រព្រឹត្តគេចចេញចាកពាក្យទូន្មាននោះ ។ បទថា **ឧសក្ពន្ធិយា វា ឧសក្ពេយ្យា** គឺចូលទៅរកអ្នកដែលថយចេញ ត្រូវការស្ត្រីដែលគេមិនត្រូវការ អធិប្បាយថា ស្ត្រីម្នាក់ដែលមិនប្រាថ្នានៅរួមជាមួយ ខ្លួនឯងក៏នៅត្រូវការ ។ បទថា **បរម្មុខំ វា អាលិផ្តេយ្យា** អធិប្បាយថា បុរសទៅពីខាងក្រោយ ហើយឧបស្ត្រីដែល មិនចង់សូម្បីតែយើញ ឈរបែរខ្នងឲ្យ ។ បទថា **ឯវំ សម្បទមិទំ** អធិប្បាយ ថា កាលសាស្តានេះគិតថា ជនទាំងនេះជាសាវករបស់អញ ហើយទូន្មាន សាវកដែលប្រព្រឹត្តគេចចេញពីពាក្យទូន្មានដោយសេចក្តីលោភ ទើបតថាគត ពោលធម៌ គឺសេចក្តីលោភនេះថា មានឧបមេយ្យដូច្នោះ សាស្តានោះ គួរ ចោទប្រកាន់ថា លោកដូចជាបុរសដែលចូលទៅរកស្ត្រី ដែលកំពុងគេចចេញ ដូចបុរសឧបស្ត្រីដែលបែរខ្នងឲ្យ ដោយធម៌ គឺសេចក្តីលោភណា ធម៌ គឺ សេចក្តីលោភរបស់សាស្តានោះ ក៏យ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **កឺ ហិ បរោ បរស្ស ការិស្សតិ** អធិប្បាយថា សាស្តារមែងត្រូវចោទប្រកាន់ថា លោកទូន្មានអ្នកដទៃដោយធម៌ណា លោកចូរញ្ចុាំងខ្លួនឲ្យដល់ព្រមក្នុងធម៌នោះ ជាមុន គឺលោកចូរធ្វើខ្លួនឯងឲ្យត្រង់ ព្រោះបុគ្គលដទៃ នឹងធ្វើអ្វីឲ្យបុគ្គល ដទៃបាន ។

[๑๖๓] *បទថា* **និច្ឆាយិតព្វំ** *អធិប្បាយថា គួរជកស្មៅដែលបំផ្ទាញស្រូវ ហើយធ្វើឲ្យរៀបរយ ។*

[๑๖๔] *សេចក្តីនៃការចោទប្រកាន់លើកទី ๓ ថា បុគ្គលជទៃនឹងជួយធ្វើអ្វីដល់បុគ្គលជទៃបាន សេចក្តីថា បុគ្គលជទៃដែលត្រូវទូន្មានតាំងពីវេលាដែលមិនទទួលពាក្យទូន្មាន នឹងធ្វើអ្វីបានដល់អ្នកជទៃ គឺអ្នកដែលទូន្មាន អធិប្បាយថា សាស្តានោះ គួរចោទប្រកាន់យ៉ាងនេះថា ខ្ជួនទុ៎ះឯងគួរដល់ភាពជាអ្នកខ្វល់ខ្វាយតិច ទើបគួរវាប់អានបូជាធម៌ដែលខ្ជួនជីងច្បាស់ រហូតហើយមិនមែនឬ ។*

សាស្តាដែលមិនគួរចោទ

[๑๖๕] *បទថា* **ន ចោទនារហោ** *អធិប្បាយថា ព្រោះសាស្តានេះតាំងខ្ជួនក្នុងសេចក្តីសមរម្យហើយជាមុន ទើបសម្តែងធម៌ដល់សាវក ហើយសាវករបស់សាស្តានោះ ជាអ្នកជឿស្តាប់ បដិបត្តិតាមពាក្យទូន្មាន រមែងសម្រេចគុណវិសេសដ៏ធំក្រៃលែង ដូច្នោះ ទើបសាស្តានោះមិនគួរដល់ការចោទប្រកាន់ ។*

[๑๖๖] *បទថា* **នរកប្បថាតំ បបតន្តំ** *សេចក្តីថា ព្រោះខ្ញុំព្រះអង្គមានទិដ្ឋិអាក្រក់ ទើបធ្លាក់ទៅកាន់ជ្រោះ គឺនរក ។ បទថា* **ឧទ្ធរិត្វា ថលេ បតិដ្ឋាបេយ្យ** *សេចក្តីថា លោហិច្ចព្រាហ្មណ៍ពោលថា ខ្ញុំដែលព្រះដ៏មានព្រះភាគទ្រង់កាត់ទិដ្ឋិអាក្រក់ឲ្យហើយ ទ្រង់លើកឡើងពីជ្រោះ គឺអបាយដោយព្រះហស្ត គឺព្រះធម្មទេសនា ហើយជាក់ខ្ញុំលើគោក គឺស្ថានសួគ៌ ដូច្នេះ។*

ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ទាំងអស់ហើយ ដោយប្រការដូច្នេះ ។

អដ្ឋកថា លោហិច្ចសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ហើយ ដោយប្រការដូចេះ ៕

លោហិច្ចសូត្រ ចប់

សូត្រធី ๑๒ ចប់

សុត្តន្តបិដក

តេវិជ្ជសូត្រទី ๑๓

[๑๖๗] ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ប្រមាណ ๕๐๐ រូប បានទៅដល់ស្រុកព្រាហ្មណ៍ ឈ្មោះមនសាកតរបស់កោសលជនបទ ។ ឮថាព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងអម្ពវន ជិតឆ្នេរស្ទឹងអចិរវតី ក្នុងទិសខាងជើងនៃមនសាកតគ្រាម ជិតស្រុកមនសាកតនោះ ។

[๑๖๘] សម័យនោះ ពួកព្រាហ្មណមហាសាល ដែលមានឈ្មោះល្បីល្បាញច្រើននាក់ មកសំណាក់នៅក្នុងស្រុកមនសាកត ព្រាហ្មណ៍ទាំងនោះឈ្មោះអ្វីខ្លះ គឺឈ្មោះវង្កីព្រាហ្មណ៍ តារុក្ខព្រាហ្មណ៍ ឱក្កវសាតិ-ព្រាហ្មណ៍ ជាណុសោនិព្រាហ្មណ៍ តោទេយ្យព្រាហ្មណ៍ និងពួកព្រាហ្មណ-មហាសាលឯទៀត ដែលមានឈ្មោះល្បីល្បាញ ។ គ្រានោះ ពួកមាណពជាវាសេដ្ឋគោត្រ និងភារទ្វាជគោត្រ កំពុងនាំគ្នាដើរត្រសងចុះឡើងឲ្យស្រួលជើង (ដើម្បីបន្ទោបង់សេចក្តីរួយស្រពន់) ក៏កើតពាក្យជជែកគ្នាអំពីផ្លូវនិងមិនមែនផ្លូវឡើង ។ វាសេដ្ឋមាណពបាននិយាយយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្មបាន ផ្លូវនេះឯង ដែលឱក្កវ-សាតិព្រាហ្មណ៍បានសម្តែងប្រាប់ ។ ចំណែកខាងភារទ្វាជមាណព បាននិយាយ

យ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯងដែលតារុក្ខព្រាហ្មណ៍ បានសម្តែងប្រាប់ ។ ភាសេដ្ឋមាណពមិនអាចដើម្បីញុំាងការទ្វាជមាណព ឲ្យចូលចិត្តបាន ចំណែកការទ្វាជមាណពក៏មិនអាចដើម្បីញុំាងភាសេដ្ឋមាណព ឲ្យចូលចិត្តបានដែរ ។

[๑๖๙] *គ្រានោះ ភាសេដ្ឋមាណពបានប្រឹក្សានឹងការទ្វាជៈថា ម្នាលការទ្វាជៈ ព្រះសមណគោតមនេះឯងជាសក្យបុត្រ ចេញចាកសក្យត្រកូលមកទ្រង់ព្រះផ្នួស ឥឡូវនេះគង់នៅក្នុងអម្ពវន ជិតឆ្នេរស្ទឹងអចិរវតី ទិសខាងជើងនៃមនសាកតគ្រាម ក្បែរស្រុកមនសាកត កិត្តិសព្ទសរសើរព្រះសមណគោតមដ៏ចម្រើននោះ ពីរោះឮខ្ទរខ្ទាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ត្រាស់ដឹងទូវេញ្ញធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ។បេ។ ទ្រង់លែងវិលត្រឡប់មកកាន់កពថ្មីទៀត ម្នាលការទ្វាជៈ មកយើងទៅកព្រះសមណគោតម លុះចូលទៅដល់ហើយ យើងនឹងសួរសេចក្តីនុ៎ះចំពោះព្រះសមណគោតម (បើ) ព្រះសមណគោតមទ្រង់ដោះស្រាយ ដល់ពួកយើងយ៉ាងណា យើងនឹងចាំទូវសេចក្តីនោះយ៉ាងនោះ ។ ការទ្វាជមាណព បានទទួលស្តាប់ពាក្យរបស់ភាសេដ្ឋមាណពថា ម្នាលអ្នកដ៏ចម្រើនយ៉ាងហ្នឹងហើយ ។*

[๑๗๐] *គ្រានោះ ភាសេដ្ឋមាណព និងការទ្វាជមាណព ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះ*

សំណាលទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរពោលហើយ និងពាក្យដែលគួរពួកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវាសេដ្ឋមាណពអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន កាលដែលយើងខ្ញុំ កំពុងនាំគ្នាដើរត្រសងចុះឡើងឲ្យស្រួលជើង ក៏កើតសម្តីជជែកគ្នាអំពីផ្លូវ និងមិនមែនផ្លូវ ក្នុងទីហ្នឹង ខ្ញុំព្រះអង្គពោលយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯង ដែលបោក្ខរសាតិព្រាហ្មណ៍បានសម្តែងប្រាប់ ចំណែកខាងការទ្វាជមាណព បាននិយាយយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯងដែលតារុក្ខព្រាហ្មណ៍បានសម្តែងប្រាប់ បពិត្រព្រះគោតមដ៏ចម្រើន ការប្រកាន់ខុសគ្នាក៏មាន ការជជែកគ្នាក៏មាន ការពោលផ្សេងគ្នាក៏មាន អំពីផ្លូវ និងមិនមែនផ្លូវនេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋ បានឮថា អ្នកនិយាយយ៉ាងនេះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯងដែលបោក្ខរសាតិព្រាហ្មណ៍ បានសម្តែងប្រាប់ ឯការទ្វាជមាណពពោលយ៉ាងនេះថា នេះជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ផ្លូវនេះឯងដែលតារុក្ខព្រាហ្មណ៍ បានសម្តែងប្រាប់

ម្នាលវាសេដ្ឋ កាលបើដូច្នោះ អ្នកទាំងឡាយប្រកាន់ខុសគ្នា ព្រោះហេតុដូចម្តេច ជជែកគ្នាព្រោះហេតុដូចម្តេច ពោលពាក្យផ្សេងគ្នាព្រោះហេតុដូចម្តេច ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន (យើងខ្ញុំព្រះអង្គជជែកគ្នា) ព្រោះផ្លូវ និងមិនមែនផ្លូវ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ គឺពួកអទ្ធរិយព្រាហ្មណ៍ ពួកតិត្តិរិយព្រាហ្មណ៍ ពួកឆន្ទោក-ព្រាហ្មណ៍ ពួកពហ្វិរិធព្រាហ្មណ៍ បញ្ញត្តផ្លូវទាំងឡាយផ្សេងៗ គ្នា ក៏ពិតមែនហើយ តែថាផ្លូវទាំងអស់នោះ សុទ្ធតែស្រោចស្រង់សត្វ នាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្មបាន បពិត្រព្រះគោតមដ៏ចម្រើន ដូចផ្លូវដ៏ច្រើន ជិតស្រុក ឬជិតនិគម ទោះបីជាផ្លូវផ្សេងៗ គ្នាមែន ប៉ុន្តែផ្លូវនោះសុទ្ធតែមូលមកកាស្រុកទាំងអស់ ដូចម្តេចមិញ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ទាំងឡាយ គឺពួកអទ្ធរិយព្រាហ្មណ៍ ពួកតិត្តិរិយព្រាហ្មណ៍ ពួកឆន្ទោកព្រាហ្មណ៍ ពួកពហ្វិរិធព្រាហ្មណ៍ បញ្ញត្តផ្លូវទាំងឡាយផ្សេងៗ គ្នា ក៏ពិតមែនហើយ តែផ្លូវទាំងអស់នោះសុទ្ធតែជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្ម ដូច្នោះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ អ្នកនិយាយថា ផ្លូវរបស់ពួកព្រាហ្មណ៍ទាំងនោះ រមែងស្រោចស្រង់សត្វបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយថា ផ្លូវទាំងនោះ រមែងស្រោចស្រង់សត្វបាន ។ ម្នាលវាសេដ្ឋៈ អ្នកនិយាយថា ផ្លូវរបស់ពួកព្រាហ្មណ៍ទាំងនោះ រមែងស្រោចស្រង់សត្វបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយថា ផ្លូវ

ទាំងនោះ រមែងស្រោចស្រង់សត្វបាន ។ ម្នាលវាសេដ្ឋៈ អ្នកនិយាយថា ផ្លូវទាំងនោះ រមែងស្រោចស្រង់សត្វបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយថា ផ្លូវទាំងនោះ រមែងស្រោចស្រង់សត្វបាន ។

[๑๗๑] *ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ ចុះបណ្តាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ ទោះបីព្រាហ្មណ៍ម្នាក់ក្តី ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ ។ វាសេដ្ឋមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនោះមិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះបណ្តាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យម្នាក់ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះបណ្តាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យជាប្រធាន លើអាចារ្យដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋ ចុះបណ្តាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ តាំងអំពីតំណនៃអាចារ្យជាគម្រប់ ๗ មក ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះមិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះពួកឫសីជាន់មុនៗ ជាអ្នកតែងមន្ត អ្នករាយមន្តដល់ពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា ពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជាក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតាម*

បទមន្តបែបបុរាណនេះ ដែលពួកឫសីធ្លាប់ស្វាធ្យាយ ធ្លាប់បង្រៀន ធ្លាប់ប្រមូលទុកមកហើយ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំងឡាយពោលមកហើយ តែងបង្រៀនតាមបទមន្តដែលឫសីទាំងឡាយ បង្រៀនមកហើយ ឫសីទាំងនោះឈ្មោះអ្វីខ្លះ គឺឫសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គី ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សប ១ ភគុ ១ ឫសីទាំងនោះតើមាន (ឫសីណាមួយ) ពោលពាក្យនេះនឹងអ្នកថា ព្រហ្មនៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅត្រង់កន្លែងណា យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយឃើញព្រហ្មនុ៎ះដូច្នេះដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការស្គាល់ និងការឃើញនុ៎ះ មិនមានទេ ។

[๑๗๒] ព្រះមានព្រះភាគ ត្រាស់សួរថា ម្នាលវាសេដ្ឋៈ បណ្តាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើបានឮថា មាននរណាមួយ សូម្បីតែព្រាហ្មណ៍ម្នាក់ ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះ មិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះបណ្តាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យម្នាក់ ដែលឃើញព្រហ្មនេះផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះ មិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះបណ្តាពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ សូម្បីតែអាចារ្យ ជាប្រធានលើអាចារ្យ

ដែលឃើញនូវព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះ មិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះបណ្តាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយ តាំងអំពីតំណាអាចារ្យ ជាជីតារបស់អាចារ្យ ជាគម្រប់ ៧ ដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនេះ មិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះពួកឫសីជាន់មុនៗ ដែលជាអ្នកតែងមន្ត ជាអ្នកភាយមន្តដល់ពួកព្រាហ្មណ៍ ដែលបានសម្រេចត្រៃវិជ្ជា ពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជាក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតាមបទមន្តបុរាណនេះមកហើយ ដែលពួកឫសីធ្លាប់ស្វាធ្យាយ ធ្លាប់បង្រៀន ធ្លាប់ប្រមូលមក តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្តដែលឫសីទាំងឡាយពោលមកហើយ តែងបង្រៀនតាមបទមន្ត ដែលឫសីទាំងឡាយបង្រៀនមកហើយ ឫសីទាំងនោះឈ្មោះអ្វីខ្លះ គឺឫសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គី ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សប ១ ភគុ ១ ឫសីទាំងនោះ តើមាន (ឫសីណាមួយ) ពោលយ៉ាងនេះនឹងអ្នកថា ព្រហ្មនៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅក្នុងកន្លែងណា យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយឃើញព្រហ្មនុ៎ះដូច្នេះដែរឬទេ ។ ពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជានោះឯង តែងនិយាយយ៉ាងនេះថា យើងមិនស្គាល់ យើងមិនឃើញទេ តែយើងទាំងឡាយសម្តែងផ្លូវដើម្បីកើតជាមួយនឹងព្រហ្មនោះបានថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវ

ទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងពួកព្រហ្មបាន ។

[๑๗๓] *ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើដូច្នោះ កាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាកាសិតមិនបានសេចក្តីអស្ចារ្យទេឬ ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន កាលបើដូច្នេះ តាមដោយនូវពិត កាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាកាសិតមិនមានសេចក្តីអស្ចារ្យទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនស្គាល់ព្រហ្មណា មិនឃើញព្រហ្មណាទេ តែសម្តែងផ្លូវដើម្បីកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្មបាន ហេតុនុ៎ះនឹងយកជាការមិនបានទេ ។ ម្នាលវាសេដ្ឋៈ ដូចមនុស្សមានភ្នែកខ្វាក់ ដើរជាជួរតោងគ្នានិងគ្នា អ្នកដើរមុនក៏មើលមិនឃើញ អ្នកដើរកណ្តាលក៏មើលមិនឃើញ អ្នកដើរក្រោយក៏មើលមិនឃើញ ដូចម្តេចមិញ ម្នាលវាសេដ្ឋៈ កាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មានទំនងឧបមេយ្យ ដូចជាមនុស្សខ្វាក់ដើរជាជួរ អ្នកដើរមុនក៏មើលមិនឃើញ អ្នកដើរកណ្តាលក៏មើលមិនឃើញ អ្នកដើរក្រោយក៏មើលមិនឃើញ ដូច្នោះឯង កាសិតនេះរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានោះ ជាពាក្យគួរឲ្យអ្នកផងសើចចំអកបាន ជាកាសិតឱនថយ (លាមក) ជាកាសិតទទេ ជាកាសិតសោះសូន្យ មែនពិត ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់*

ហេតុនោះដូចម្តេច ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា រមែងឃើញព្រះចន្ទ្រ និងព្រះអាទិត្យ សូម្បីពួកជនឯទៀតច្រើននាក់ក៏ឃើញដែរ លុះដល់ព្រះចន្ទ្រ និងព្រះអាទិត្យ រះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា ក៏នាំគ្នាអង្វរការ សរសើរ ប្រណាមអញ្ជលី នមស្ការដើរក្រឡឹង ។ បពិត្រព្រះគោតមដ៏ចម្រើន ដូច្នោះមែនហើយ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តែងឃើញព្រះចន្ទ្រ និងព្រះអាទិត្យ សូម្បីពួកជនឯទៀតច្រើននាក់ក៏ឃើញដែរ លុះដល់ព្រះចន្ទ្រ និងព្រះអាទិត្យ រះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា ក៏នាំគ្នាអង្វរការសរសើរ ប្រណាមអញ្ជលី នមស្ការដើរក្រឡឹង ។

[๑๗๔] *ម្នាលវាសេដ្ឋៈ អ្នកសម្គាល់ហេតុនោះដូចម្តេច ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តែងឃើញព្រះចន្ទ្រ និងព្រះអាទិត្យ សូម្បីតែពួកជនឯទៀតច្រើននាក់ក៏ឃើញព្រះចន្ទ្រ និងព្រះអាទិត្យដែរ ព្រះចន្ទ្រ និងព្រះអាទិត្យរះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា ក៏នាំគ្នាអង្វរការសរសើរប្រណាមអញ្ជលី នមស្ការ ដើរក្រឡឹង ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ល្មមសម្តែងផ្លូវដើម្បីកើតជាមួយនឹងព្រះចន្ទ្រ ព្រះអាទិត្យទាំងនោះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រះចន្ទ្រ ព្រះអាទិត្យដូច្នេះមានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានទេ ។ ម្នាលវាសេដ្ឋៈ បានឮថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តែងឃើញព្រះចន្ទ្រ និងព្រះអាទិត្យ សូម្បីពួកជនឯទៀតច្រើននាក់ក៏ឃើញដែរ លុះដល់ព្រះចន្ទ្រ និងអាទិត្យរះឡើងអំពីទីណា អស្តង្គតទៅក្នុងទីណា*

ក៏នាំគ្នាអង្វរករ សរសើរ ប្រណម្យអញ្ជលី នមស្ការដើរក្រឡឹងពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនល្មមនឹងសម្តែងផ្លូវដើម្បីកើតជាមួយនឹងព្រះចន្ទ្រព្រះអាទិត្យទាំងនោះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រះចន្ទ្រ ព្រះអាទិត្យបានឡើយ ឮថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនទេ បានឮថា អាចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនទេ បានឮថា ពួកអាចារ្យជាប្រធានលើអាចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនទេ បានឮថាពួកបុព្វចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា តាំងអំពីតំណនៃអាចារ្យ ជាជីតារបស់អាចារ្យ ជាគម្រប់ ៧ ក៏មិនដែលបានឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ បានឮថា ពួកឫសីជាន់មុនៗដែលជាអ្នកតែងមន្ត ជាអ្នករាយមន្ត ដល់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតាមបទមន្តនេះ ជារបស់ចាស់ដែលពួកឫសីធ្លាប់ស្វាធ្យាយ ធ្លាប់បង្រៀន ធ្លាប់ប្រមូលទុកមកហើយ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំង-ទ្បាយពោលមកហើយ តែងបង្រៀនតាមបទមន្ត ដែលឫសីទាំងទ្បាយបង្រៀនមកហើយ ឫសីណាខ្លះ គឺឫសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាម-ទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ ឫសីទាំងនោះបានពោលយ៉ាងនេះនឹងអ្នកថា ព្រហ្ម

នៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅក្នុងកន្លែងណា យើងស្គាល់ទីនុ៎ះ យើងឃើញព្រហ្មនុ៎ះដូច្នេះដែរឬ ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ក៏ពោលយ៉ាងនេះថា យើងមិនដែលស្គាល់ ព្រហ្មណា មិនដែលឃើញព្រហ្មណាទេ ប៉ុន្តែយើងសម្តែងផ្លូវដើម្បីកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះឯងជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់ សត្វរមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្មបាន ។

[๑๗๕] ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើដូច្នោះ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាភាសិតមិនបានការទេ មិនមែនឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មែនពិតហើយ កាលបើដូច្នោះ ភាសិតរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាភាសិតមិនបានការណ៍ទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះមិនដែលស្គាល់ព្រហ្មណា មិនដែលឃើញព្រហ្មណាទេ ប៉ុន្តែហ៊ានសម្តែងផ្លូវ ដើម្បីកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្មនោះបាន ហេតុនេះ នឹងយកជាការណ៍ពុំបានឡើយ ។

[๑๗๖] ម្នាលវាសេដ្ឋៈ ដូចជាបុរសពោលយ៉ាងនេះថា ខ្ញុំប្រាថ្នាចង់បាននូវស្ត្រីដែលមានរូបល្អក្នុងជនបទនេះ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន ស្ត្រីមានរូបល្អក្នុងជនបទដែលអ្នកប្រាថ្នាចង់បាន តើអ្នកស្គាល់ស្ត្រីមានរូបល្អក្នុងជនបទនោះ ថាជានាងខត្តិយានី ឬនាង

ព្រាហ្មណ៏ ជានាងវេស្សី ឬជានាងសុទ្ទីដែរឬ ។ បុរសនោះកាលគេសួរដូច្នេះ ហើយ ក៏ច្រាប់ថា ខ្ញុំមិនស្គាល់ទេ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះ ថា នែបុរសដ៏ចម្រើន ស្ត្រីមានរូបល្អក្នុងជនបទដែលអ្នកច្រាថ្នាចង់បាន តើអ្នក ស្គាល់ស្ត្រីមានរូបល្អក្នុងជនបទនោះថា មានឈ្មោះយ៉ាងនេះ ឬមានគោត្រ យ៉ាងនេះ ខ្ពស់ ឬទាប ឬយ៉ាងកណ្តាល ខ្មៅ ឬប្រអែម ឬសម្បុរខ្មៅ ស្រស់ស្អាតថា នៅក្នុងស្រុកឯណោះ និគមឯណោះ ឬនគរឯណោះដែរឬ ។ បុរសនោះកាលគេសួរដូច្នេះហើយ ក៏ច្រាប់ថា ខ្ញុំមិនស្គាល់ទេ ។ ជនទាំង-ឡាយសួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកមិនស្គាល់ មិនឃើញ ស្ត្រីណា អ្នកច្រាថ្នាចង់បានស្ត្រីនោះឬ ។ បុរសនោះដែលគេសួរដូច្នេះហើយ ក៏ច្រាប់ថា បាទ ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាល បើដូច្នោះ ភាសិតរបស់បុរសនោះ ជាភាសិតមិនបានការណ៍ មិនមែនទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មែនពិតហើយ កាលបើយ៉ាងនេះ ភាសិតរបស់ បុរសនោះ ជាភាសិតមិនបានការណ៍ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ បានឮ ថា ពួកព្រាហ្មណ៏អ្នកត្រៃវិជ្ជា មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនទេ ។បេ។

[๑๗๗] ម្នាលវាសេដ្ឋៈ ដូចជាបុរសធ្វើជណ្តើរ បម្រុងឡើងប្រាសាទ ត្រង់ផ្លូវធំបែកជា ๔ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា ម្នាលបុរស ដ៏ចម្រើន អ្នកធ្វើជណ្តើរ បម្រុងឡើងប្រាសាទណា ចុះអ្នកស្គាល់ប្រាសាទ នោះថា (នៅ) ក្នុងទិសខាងកើត ឬទិសខាងត្បូង ឬទិសខាងលិច ឬទិស

ខាងជើង ប្រាសាទនោះខ្ពស់ ឬទាប ឬយ៉ាងកណ្តាលដែរឬ ។ បុរសនោះ កាលគេសួរដូច្នេះហើយ ក៏ប្រាប់ថា ខ្ញុំមិនដឹងទេ ។ ជនទាំងឡាយសួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកមិនដឹងមិនឃើញប្រាសាទណាទេ តែធ្វើជណ្តើរបម្រុងឡើងប្រាសាទនោះឬ ។ បុរសនោះ កាលគេសួរដូច្នេះហើយ ក៏ឆ្លើយថា បាទ ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់ហេតុនោះដូចម្តេច កាលបើដូច្នោះ សម្តីនៃបុរសនោះ មិនបានការណ៍មិនមែនឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មែនពិតហើយ កាលបើយ៉ាងនេះ សម្តីរបស់បុរសនោះ មិនបានការណ៍ទេ ។ ម្នាលវាសេដ្ឋៈ មែនហើយ បានឮថា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន បានឮថា ពួកអាចារ្យរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ បានឮថា ពួកអាចារ្យជាប្រធានលើអាចារ្យ របស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ បានឮថា ពួកបុព្វចារ្យរបស់ពួកព្រាហ្មណ៍តាំងពីតំណនៃអាចារ្យ ជាជីតារបស់អាចារ្យ ជាគម្រប់ ៧ ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ បានឮថា ពួកឫសីជាន់មុនៗ ដែលជាអ្នកតែងមន្ត ជាអ្នករាយមន្តដល់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតែបទមន្តបុរាណនេះ ដែលពួកឫសីធ្វើប់ស្វាធ្យាយ ធ្វើប់បង្រៀន ធ្វើប់ប្រមូលទុកមកហើយ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំង-ឡាយពោលមកហើយ តែងបង្រៀនតាមបទមន្តដែលឫសីទាំងឡាយបង្រៀន

មកហើយ ឫសីណាខ្លះ គឺឫសីឈ្មោះអជ្ជកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គី ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ សូម្បីឫសីទាំងនោះ ក៏មិនពោលយ៉ាងនេះថា ព្រហ្មនៅក្នុងទីណា ព្រហ្មមានសណ្ឋានយ៉ាងណា ព្រហ្មនៅក្នុងកន្លែងណា យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយឃើញព្រហ្មនុ៎ះដូច្នេះដែរឬទេ ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះក៏ពោលយ៉ាងនេះថា យើងមិនស្គាល់ព្រហ្មណា យើងមិនឃើញព្រហ្មណាទេ ប៉ុន្តែយើងសម្តែងផ្លូវដើម្បីទៅកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្មបាន ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើដូច្នោះ សម្តីរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាសម្តីមិនបានការណ៍ឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ពិតមែនហើយ កាលបើយ៉ាងនោះ សម្តីរបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាសម្តីមិនបានការណ៍ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ មិនស្គាល់ព្រហ្មណា មិនឃើញព្រហ្មណាទេ ប៉ុន្តែហ៊ានសម្តែងផ្លូវដើម្បីកើតជាមួយនឹងព្រហ្មនោះថា នេះឯងជាផ្លូវត្រង់ នេះជាផ្លូវទៀងទាត់ ជាទីស្រោចស្រង់សត្វ រមែងនាំអ្នកប្រតិបត្តិតាមផ្លូវនោះ ឲ្យទៅកើតជាមួយនឹងព្រហ្ម ហេតុនេះ យកជាការណ៍ពុំបានទេ ។

[១៧៨] ម្នាលវាសេដ្ឋៈ ដូចស្ទឹងអចិរវតីនេះ ពេញប្រៀបដោយទឹកល្មមក្អែកទំមាត់ប្រាំងឱនផឹកបាន គ្រានោះ មានបុរសអ្នកត្រូវការត្រើយខាង

នាយ អ្នកស្វែងរកត្រើយខាងនាយ អ្នកនឹងទៅត្រើយខាងនាយ អ្នកចង់ឆ្លងទៅត្រើយខាងនាយ បុរសនោះបានមកជល់ ក៏ឈរនៅត្រើយខាងអាយ ហើយស្រែកហៅត្រើយខាងនាយថា ម្នាលត្រើយខាងនាយ អ្នកចូរមករកត្រើយខាងអាយ ម្នាលត្រើយខាងនាយ អ្នកចូរមករកត្រើយខាងអាយ ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ត្រើយខាងនាយនៃស្ទឹងអចិ-រវតី (នោះ) មុខជានឹងមករកត្រើយខាងអាយ ព្រោះហេតុនៃបុរសនោះស្រែកហៅ ឬព្រោះហេតុនៃបុរសនោះអង្វរ ព្រោះហេតុសេចក្តីជ្រាថ្នា ឬព្រោះហេតុសេចក្តីត្រេកអរបានដែរឬ ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជាក៏ដូច្នោះដែរ គេប្រព្រឹត្តលះបង់ធម៌ ដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍ចេញ ហើយប្រព្រឹត្តសមាទានធម៌ដែលមិនមែនធ្វើបុគ្គលទៅជាព្រាហ្មណ៍វិញ ហើយពោលយ៉ាងនេះថា យើងហៅព្រះឥន្ទ្រ ហៅព្រះចន្ទ្រ ហៅព្រះវរុណ ហៅព្រះឈ្មោសាន ហៅព្រះបជាបតិ ហៅព្រះព្រហ្ម ហៅព្រះមហិន្ទ្រ ។ ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ប្រព្រឹត្តលះបង់ធម៌ ដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញហើយ ប្រព្រឹត្តសមាទានធម៌ ដែលមិនធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ លុះបែកធ្លាយកាយបន្ទាប់អំពីសេចក្តីស្លាប់ នឹងទៅកើតជាមួយនឹងពួកព្រហ្ម ព្រោះហេតុស្រែកហៅ ឬព្រោះហេតុសេចក្តីអង្វរ ព្រោះហេតុសេចក្តីជ្រាថ្នា ឬព្រោះហេតុសេចក្តីត្រេកអរ ហេតុដូច្នេះ នេះមិនដែលមានឡើយ ។

[๑๗๙] *ម្នាលវាសេដ្ឋៈ ដូចស្ទឹងអចិរវតីនេះ ពេញប្រៀបដោយទឹកល្មមតែក្អែកទំមាត់ប្រាំងផឹកបាន គ្រានោះ មានបុរសអ្នកត្រូវការត្រើយខាងនាយ អ្នកស្វែងរកត្រើយខាងនាយ អ្នកទៅត្រើយខាងនាយ អ្នកចង់ឆ្លងទៅត្រើយខាងនាយ បានមកជល់ (ស្ទឹងនោះ) ក៏យកខ្សែដ៏មាំមកចងដើមដៃទៅខាងក្រោយ (ចងស្ងាបសេក) យ៉ាងខ្ជាប់ទុកនៅត្រើយខាងអាយ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច បុរសនោះនឹងចេញពីត្រើយខាងអាយនៃស្ទឹងអចិរវតីទៅត្រើយខាងនាយ តើបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនបានទេ ។ ម្នាលវាសេដ្ឋៈ ដូច្នោះមែនហើយ ក្នុងវិន័យរបស់ព្រះអរិយៈលោកហៅកាមគុណទាំង ៥ នេះថា ខ្នោះក៏មាន ថាចំណងក៏មាន កាមគុណទាំង ៥ តើដូចម្តេចខ្លះ គឺរូបដែលគួរដឹងបានដោយចក្ខុ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកអរ សំឡេងដែលគួរដឹងបានដោយត្រចៀក ។បេ។ ក្លិនដែលគួរដឹងបានដោយច្រមុះ ។ រសដែលគួរដឹងបានដោយអណ្តាត ។ ផោដ្ឋព្វៈដែលគួរដឹងបានដោយកាយ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរត្រេកអរ ។ ម្នាលវាសេដ្ឋៈ ក្នុងវិន័យរបស់ព្រះអរិយៈ លោកហៅកាមគុណ ៥ នេះឯង ថាខ្នោះក៏មាន ថាចំណងក៏មាន ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ជាប់ដក់នៅ ជ្រប់នៅ លិចលង់នៅ ឃើញថាមិនមានទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួន តែងបរិភោគកាមគុណទាំង ៥ នេះឯង ។ ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានោះ*

ប្រព្រឹត្តលះបង់ធម៌ ដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍ចេញ ហើយប្រព្រឹត្ត សមាទានធម៌ ដែលមិនធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ ជាប់ជក់នៅ លិច លង់នៅ ឃើញថា មិនមានទោស មិនមានប្រាជ្ញាជាគ្រឿងរលាស់ខ្លួន តែង បរិភោគកាមគុណទាំង ៥ ជាអ្នកមានកាមច្ឆន្ទៈជាចំណង លុះបែកធ្លាយ កាយទៅ ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតជាមួយនឹងពួកព្រហ្ម ហេតុ នេះមិនគួរមានឡើយ ។

[๑๘๐] ម្នាលវាសេដ្ឋៈ ដូចស្ទឹងអចិរវតីនេះ ពេញប្រៀបដោយទឹក ល្មមក្អែកទំមាត់ប្រាំងផឹកបាន វេលានោះ មានបុរសអ្នកត្រូវការត្រើយ ខាងនាយ អ្នកស្វែងរកត្រើយខាងនាយ អ្នកទៅកាន់ត្រើយខាងនាយ អ្នកចង់ ឆ្លងទៅត្រើយខាងនាយ បានមកជល់ បុរសនោះ ក៏ទូរអស់ទាំងក្បាល ហើយដេកទៀបត្រើយខាងអាយ ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច បុរសនោះគួរចេញអំពីត្រើយខាងអាយ នៃស្ទឹងអចិរវតីទៅឯត្រើយ ខាងនាយបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនេះពុំគួរទៅបានទេ ។ ម្នាលវាសេដ្ឋៈ ក៏ដូច្នោះដែរ ក្នុងវិន័យរបស់ព្រះអរិយៈ លោកហៅនីវរណ-ធម៌ ៥ ប្រការនេះថា អាវរណៈ (គ្រឿងទប់) ក៏បានហៅថានីវរណៈ (គ្រឿង រារាំង) ក៏បាន ហៅថា ឱនាហនៈ (គ្រឿងទាញយឺត) ក៏បាន ហៅថា បរិយោហនៈ (គ្រឿងរួបរឹត) ក៏បាន នីវរណៈទាំង ៥ ប្រការ តើដូច ម្តេចខ្លះ គឺកាមច្ឆន្ទនីវរណៈ ๑ ព្យាបាទនីវរណៈ ๑ ថីនមិទ្ធនីវរណៈ ๑ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ๑ វិចិកិច្ឆានីវរណៈ ๑ ម្នាលវាសេដ្ឋៈ ក្នុងវិន័យរបស់

ព្រះអរិយៈ លោកហៅនីវរណៈទាំង ៥ ប្រការនេះឯងថា អាវរណៈក៏បាន ហៅថានីវរណៈក៏បាន ហៅថាឱនាហនៈក៏បាន ហៅថាបរិយោហនៈក៏បាន ។

[១៨១] *ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកបានត្រៃវិជ្ជា ត្រូវនីវរណៈទាំង ៥ នេះជោតក្រង ចងរឹត ចងក្រៀក ចាក់ស្រែះហើយ ។ ម្នាលវាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ប្រព្រឹត្តលះបង់ធម៌ដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍ចេញ ហើយប្រព្រឹត្តសមាទានធម៌ ដែលមិនធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍វិញ ព្រាហ្មណ៍ទាំងនោះ ត្រូវនីវរណៈទាំង ៥ ជោតក្រង ចងរឹត ចងក្រៀក ចាក់ស្រែះហើយ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតជាមួយនឹងពួកព្រហ្ម ហេតុនេះ មិនមានសោះឡើយ ។*

[១៨២] *ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អ្នកធ្លាប់បានឮពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យទាំងឡាយ និយាយថា ព្រហ្មមានស្ត្រីជាគ្រឿងជាប់ជំពាក់ ឬមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ទេ ។ វាសេដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ទេ ។ ព្រហ្មមានចិត្តចងពៀរ ឬមិនបានចងពៀរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិនមានចិត្តចងពៀរទេ ។ ព្រហ្មមានចិត្តប្រកបដោយព្យាបាទ ឬមិនមានចិត្តប្រកបដោយព្យាបាទទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិនមានចិត្តប្រកបដោយព្យាបាទទេ ។ ព្រហ្មមានចិត្តសៅហ្មង ឬមិនមានចិត្តសៅហ្មងទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មមិន*

มានចិត្តសៅហ្មងទេ ។ ព្រហ្មប្រព្រឹត្តទៅតាមអំណាចចិត្តបាន ឬប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មប្រព្រឹត្តទៅតាមអំណាចចិត្តបាន ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានស្ត្រីជាគ្រឿងជាប់ជំពាក់ ឬមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានស្ត្រីជាគ្រឿងជាប់ជំពាក់ (គ្រប់គ្រងស្រីដែរ) ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជាមានចិត្តចងពៀរ ឬមិនមានចិត្តចងពៀរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តចងពៀរ ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តប្រកបដោយព្យាបាទ ឬមិនមានចិត្តប្រកបដោយព្យាបាទទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តប្រកបដោយព្យាបាទ ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តសៅហ្មង ឬមានចិត្តមិនសៅហ្មងទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តសៅហ្មង ។ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ប្រព្រឹត្តទៅតាមអំណាចចិត្តបាន ឬប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ។

[១៨៣] ម្នាលវាសេដ្ឋៈ អើ បើថាព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ មានស្ត្រីជាគ្រឿងជាប់ជំពាក់ដូច្នេះ ឯព្រហ្មជាអ្នកមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ទេ ចុះបណ្តាពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលមានស្ត្រីជាគ្រឿងជាប់ជំពាក់ តើប្រៀបផ្ទឹមនឹងព្រហ្មដែលមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ សមគ្នា

ដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនុ៎ះ ប្រៀបធៀបមិនសមគ្នា ទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលមានស្ត្រី ជាគ្រឿងជាប់ជំពាក់ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ ក៏ទៅ កើតជាមួយនឹងព្រហ្ម ដែលមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ ហេតុដូច្នេះនេះ មិនដែលមានទេ ។ ម្នាលវាសេដ្ឋៈ បានឮដូច្នេះថា ពួកព្រាហ្មណ៍អ្នកត្រៃ វិជ្ជានោះ មានចិត្តចងពៀរ ចំណែកខាងព្រហ្ម មិនមានចិត្តចងពៀរទេ ប្រៀប ធៀបពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលមានចិត្តចងពៀរ ជាមួយនឹងព្រហ្មដែល មិនមានចិត្តចងពៀរ តើសមគ្នាដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរ នុ៎ះប្រៀបធៀបមិនបានទេ ។ ម្នាលវាសេដ្ឋៈ បានឮដូច្នេះថា ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជានោះ មានចិត្តប្រកបដោយព្យាបាទ ព្រហ្មមិនមានចិត្តប្រកបដោយ ព្យាបាទ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា មានចិត្តសៅហ្មង ព្រហ្មមិនមានចិត្ត សៅហ្មងទេ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ប្រព្រឹត្តទៅតាមអំណាចចិត្តមិនបានទេ ព្រហ្មប្រព្រឹត្តទៅតាមអំណាចចិត្តបាន ចុះបើប្រៀបធៀបពួកព្រាហ្មណ៍អ្នកត្រៃ វិជ្ជា ដែលប្រព្រឹត្តទៅតាមអំណាចចិត្តមិនបាន ជាមួយនឹងព្រហ្មដែលប្រព្រឹត្ត ទៅតាមអំណាចចិត្តបាន តើសមគ្នាដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនុ៎ះ ប្រៀបធៀបមិនបានទេ ។ ម្នាលវាសេដ្ឋៈ ត្រូវហើយ ម្នាល វាសេដ្ឋៈ ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជា ដែលប្រព្រឹត្តទៅតាមអំណាចចិត្តមិនបាន ទាំងនោះ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ នឹងទៅកើតជាមួយ នឹងព្រហ្មដែលប្រព្រឹត្តទៅតាមអំណាចចិត្តបាន ហេតុដូច្នេះនេះ មិនដែលមាន

ទេ ។ ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍អ្នកត្រៃវិជ្ជាទាំងនោះ ចូលទៅ (កាន់ទី មិនមែនផ្លូវដោយសម្គាល់ថាផ្លូវ) ក្នុងផ្លូវជាទីទៅកាន់ព្រហ្មលោក (ដូចជា) ចុះទៅ (កាន់ទីមានភក់ដោយសម្គាល់ថាទីរាបស្មើ) លុះចុះទៅហើយ ក៏ជល់នូវសេចក្តីបាក់បែក (នៃអវយវៈតូចធំ) សម្គាល់នូវការឆ្លងថា ស្រួលហើយ ក៏ឆ្លងទៅ ព្រោះហេតុនោះ ត្រៃវិជ្ជារបស់ពួកព្រាហ្មណ៍អ្នកត្រៃវិជ្ជានេះ អ្នកប្រាជ្ញតែងហៅថា ព្រៃធំ គឺត្រៃវិជ្ជាខ្វះ ហៅថា ព្រៃដែលគ្មានទឹក គឺត្រៃវិជ្ជាខ្វះ ហៅថា សេចក្តីវិនាស គឺត្រៃវិជ្ជាខ្វះ ។

[๑๘๔] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ វាសេដ្ឋមាណពក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថា ព្រះសមណគោតមស្គាល់ផ្លូវ ដើម្បីទៅកើតជាមួយនឹងព្រហ្មមែនឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច មនសាកតគ្រាម នៅក្នុងទីជិតនឹងទីនេះ មនសាកតគ្រាមមិនមែននៅក្នុងទីឆ្ងាយអំពីទីនេះទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងនោះហើយ មនសាកតគ្រាម នៅក្នុងទីជិតនឹងទីនេះ មនសាកតគ្រាមមិននៅក្នុងទីឆ្ងាយអំពីទីនេះទេ ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច បុរសដែលកើតហើយ ចម្រើនហើយក្នុងមនសាកតគ្រាមនេះ មានអ្នកផងសួរកផ្លូវនៃមនសាកតគ្រាម ចំពោះបុរសនោះ ដែលចេញទៅអំពីមនសាកតគ្រាមក្នុងខណៈនោះ ម្នាលវាសេដ្ឋៈ បុរសដែលកើតហើយ ចម្រើនហើយក្នុងមនសាកតគ្រាមនោះ កាលបើគេសួរកផ្លូវនៃមនសាកតគ្រាម សម្តីយឺតយូរ និង

អ័មអៀម តើមានខ្វះដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន សម្តីនេះមិនយ៉ឺតយូរ មិនអ័មអៀមទេ ។ សេចក្តីនោះព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះបុរសឯណោះកើតហើយ ចម្រើនហើយ ក្នុងមនសាកតគ្រាម បានជាបុរសនោះស្គាល់ផ្លូវទាំងអស់ ដែលទៅកាន់មនសាកតគ្រាម ដោយច្បាស់លាស់ ។ ម្នាលវាសេដ្ឋៈ បុរសដែលកើតហើយ ចម្រើនហើយ ក្នុងមនសាកតគ្រាមនោះ កាលបើមានអ្នកផង សួរកផ្លូវនៃមនសាកតគ្រាម គង់មានសម្តីយ៉ឺតយូរ និងអ័មអៀមខ្វះ ឯតថាគត កាលបើអ្នកផងសួរកផ្លូវទៅកាន់ព្រហ្មលោក ឬបដិបទា ជាទីទៅកាន់ព្រហ្មលោក មិនមានការប្រព្រឹត្តយ៉ឺតយូរ និងការអ័មអៀមឡើយ ម្នាលវាសេដ្ឋៈ តថាគតស្គាល់ទាំងព្រហ្ម ស្គាល់ទាំងព្រហ្មលោក ស្គាល់ទាំងបដិបទា ជាទីទៅកាន់ព្រហ្មលោក មិនតែប៉ុណ្ណោះសោត ព្រហ្មប្រតិបត្តិយ៉ាងណា ទើបបានទៅកើតក្នុងព្រហ្មលោក តថាគតក៏ស្គាល់ច្បាស់នូវសេចក្តីប្រតិបត្តិនោះ ។

[๑๘๕] *កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វាសេដ្ឋមាណពក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថា ព្រះសមណគោតមសម្តែងផ្លូវដើម្បីទៅកើតជាមួយនឹងព្រហ្មបាន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះគោតមដ៏ចម្រើន សម្តែងផ្លូវដើម្បីទៅកើតជាមួយនឹងព្រហ្ម សូមព្រះគោតមដ៏ចម្រើន ស្រោចស្រង់ព្រាហ្មណ៍ និងពពួកសត្វផងចុះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែង*

ប្រាប់ ។ វាសេដ្ឋមាណព បានទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ ថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលវាសេដ្ឋៈ ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ។បេ។ (បណ្ឌិតគប្បីសម្តែងឲ្យពិស្តារដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។បេ។ ម្នាលវាសេដ្ឋៈ ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។បេ។ កាលភិក្ខុនោះបានពិចារណាឃើញច្បាស់ នូវនីវរណៈ ៥ នេះក្នុងខ្លួន ដែលខ្លួនលះបង់ហើយ បាមោជ្ជ គឺសេចក្តីត្រេកអរយ៉ាងល្មមក៏កើតឡើង កាលបើបាមោជ្ជកើតឡើងហើយ បីតិក៏កើតឡើង កាលចិត្តប្រកបដោយបីតិកើតឡើងហើយ កាយក៏រមែងស្ងប់រម្ងាប់ កាលបើមានកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលបានសេចក្តីសុខហើយ ក៏រមែងតាំងនៅមាំ ។ ភិក្ខុនោះមានចិត្ត ប្រកបដោយមេត្តា រមែងផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ទាំងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង បានដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ទូលាយ ធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងពួង គ្រប់ទិសគ្រប់តំបន់ ។ ម្នាលវាសេដ្ឋៈ មនុស្សមានកម្លាំងផ្តុំសង្ខ អាចញ៉ាំងបុគ្គលឲ្យដឹងបាន គ្រប់ទិសទាំង ៤ ដោយមិនលំបាកយ៉ាងណា ម្នាលវាសេដ្ឋៈ កម្មជាកាមាវចរណា ក្នុងមេត្តាចេតោវិមុត្តិ ដែលបុគ្គលបានចម្រើនយ៉ាងនេះ កម្មជាកាមាវចរនោះ មិនបានកៀចក្រាញ នៅក្នុងរូបាវចរ និងអរូបាវចរនោះ គឺកម្មជាកាមាវចរនោះ មិនបានឋិតនៅក្នុងរូបាវចរ និងអរូបាវចរនោះឡើយ ក៏យ៉ាង

នោះឯង ។ ម្នាលវាសេដ្ឋៈ នេះឯងហៅថា ផ្លូវដើម្បីទៅកើតជាមួយនឹងព្រហ្ម ។

[๑๘๖] *ម្នាលវាសេដ្ឋៈ សេចក្តីតទៅទៀតថា ភិក្ខុមានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ។បេ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ๑ ទិសទី ๒ ទិសទី ๓ ទិសទី ๔ ទាំងទិសខាងលើ ទិសខាងក្រោម និងទិសទទឹងបានដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ទូលាយ ធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់គ្រប់ទិសគ្រប់តំបន់ ។ ម្នាលវាសេដ្ឋៈ មនុស្សដែលមានកម្លាំងផ្ទុំសង្ខ្ប អាចញ៉ាំងបុគ្គលឲ្យដឹងគ្រប់ទិសទាំង ๔ បានដោយមិនលំបាកយ៉ាងណា ម្នាលវាសេដ្ឋៈ កម្មជាកាមាវចរណា ក្នុងឧបេក្ខាចេតោវិមុត្តិដែលបុគ្គលបានចម្រើនយ៉ាងនេះ កម្មជាកាមាវចរនោះ មិនបានកៀចក្រាញនៅក្នុងរូបាវចរ និងអរូបាវចរនោះ គឺកម្មជាកាមាវចរនោះ មិនបានឋិតនៅក្នុងរូបាវចរ និងអរូបាវចរនោះឡើយ ក៏យ៉ាងនោះឯង ។ ម្នាលវាសេដ្ឋៈ នេះឯងជាផ្លូវដើម្បីកើតជាមួយនឹងពួកព្រហ្ម ។ ម្នាលវាសេដ្ឋៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ភិក្ខុមានមេត្តាព្រហ្មវិហារយ៉ាងនេះ ជាអ្នកមានស្ត្រីជាគ្រឿងជាប់ជំពាក់ ឬមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ទេ ។ ភិក្ខុនោះមានចិត្តចងពៀរ ឬមិនមានចិត្តចងពៀរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានចិត្តចងពៀរទេ ។ ភិក្ខុនោះមានចិត្តប្រកបដោយព្យាបាទ ឬមិនមានចិត្តប្រកបដោយព្យាបាទទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានចិត្តប្រកបដោយព្យាបាទទេ ។ ភិក្ខុនោះ*

มานจิตฺตสฺสาหงฺ ปุมานจิตฺตมินสฺสาหงฺเทฯ ปจิตฺรพฺระเกาตมชีจมฺรีน มินมานจิตฺตสฺสาหงฺเทฯ กิกฺขุนาะปฺรพฺรึตฺตเทาตามอำณาจจิตฺตปาน ปุมิน ปฺรพฺรึตฺตเทาตามอำณาจจิตฺตปานเทฯ ปจิตฺรพฺระเกาตมชีจมฺรีน ปฺรพฺรึตฺตเท តามอำณาจจิตฺตปานฯ มฺทาលวาสេដ្ឋៈ អើ បើថាកិក្ខុជាអ្នកមិនមានស្ត្រីជា គ្រឿងជាប់ជំពាក់ ព្រហ្មក៏ជាអ្នកមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ហើយ តើ ប្រៀបធៀបកិក្ខុដែលមិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ នឹងព្រហ្មដែលមិនមាន ស្ត្រីជាគ្រឿងជាប់ជំពាក់ សមគ្នាដែរឬ ฯ បពិត្រព្រះគោតមជីចម្រើន ប្រៀប ធៀបសមគ្នាហើយ ฯ មฺទាលวาสេដ្ឋៈ ត្រូវហើយ មฺទាលวาสេដ្ឋៈ កិក្ខុដែល មិនមានស្ត្រីជាគ្រឿងជាប់ជំពាក់ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តី ស្លាប់ទៅ នឹងទៅកើតជាមួយនឹងព្រហ្ម ដែលមិនមានស្ត្រី ជាគ្រឿងជាប់ជំពាក់ ហេតុដូច្នេះនេះ តែងមានជាប្រាកដ ฯ មฺទាលวาสេដ្ឋៈ បានឮដូច្នេះថា កិក្ខុ មិនមានចិត្តចងពៀរ ព្រហ្មក៏មិនមានចិត្តចងពៀរដែរ ฯបេฯ កិក្ខុមិនមាន ចិត្តប្រកបដោយព្យាបាទ ព្រហ្មក៏មិនមានចិត្តប្រកបដោយព្យាបាទដែរ ฯ កិក្ខុ មានចិត្តមិនសៅហ្មង ព្រហ្មក៏មានចិត្តមិនសៅហ្មងដែរ ฯ កិក្ខុប្រព្រឹត្តទៅតាម អំណាចចិត្តបាន ព្រហ្មក៏ប្រព្រឹត្តទៅតាមអំណាចចិត្តបានដែរ ប្រៀបធៀបកិក្ខុ ដែលប្រព្រឹត្តទៅតាមអំណាចចិត្តបាន នឹងព្រហ្មដែលប្រព្រឹត្តទៅតាមអំណាច ចិត្តបាន តើសមដែរឬទេ ฯ បពិត្រព្រះគោតមជីចម្រើន ប្រៀបធៀបសម គ្នាហើយ ฯ មฺទាលวาสេដ្ឋៈ ត្រូវហើយ មฺទាលวาสេដ្ឋៈ កិក្ខុប្រព្រឹត្តទៅតាម អំណាចចិត្តបាននោះ លុះបែកធ្លាយកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ នឹង

ទៅកើតជាមួយនឹងព្រហ្ម ដែលប្រព្រឹត្តទៅតាមអំណាចចិត្តបាន ហេតុដូច្នេះ នេះ តែងមានជាធ្រុកដ ។

[๑๘๗] លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ វាសេដ្ឋមាណព និងភារទ្វាជមាណព ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន កាសិតរបស់ព្រះអង្គ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន កាសិតរបស់ព្រះអង្គ ពីរោះណាស់ ធម៌ដែលព្រះអង្គទ្រង់សម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ (ក្តីច្បាស់ណាស់) បពិត្រព្រះគោតមដ៏ចម្រើន គួរនាដូចជាមនុស្ស ចាប់របស់ដែលផ្កាប់ចុះ ឲ្យផ្ងារឡើងបាន ពុំនោះដូចជាមនុស្ស បើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោតដូចជាមនុស្ស ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬក៏ដូចជាមនុស្សកាន់ប្រទីប ទ្រលំភ្លឺក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុមើលឃើញនូវរូបទាំងឡាយបាន យើងទាំងឡាយនោះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងជាទីរឭក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយ ថាជាឧបាសកដល់សរណគមន៍ស្មើដោយជីវិត ។

តេវិជ្ជសូត្រទី ๑๓ ចប់

បញ្ជីនៃសីលក្ខន្ធវគ្គនោះ មានសូត្រ ១៣ គឺ

ព្រហ្មជាលសូត្រ ១ សាមញ្ញផលសូត្រ ១ អម្ពដ្ឋសូត្រ ១ សោណទណ្ឌសូត្រ ១ កូដទន្តសូត្រ ១ មហាលិសូត្រ ១ ជាលិយសូត្រ ១ មហាសីហនាទសូត្រ ១ ចោដ្ឋបាទសូត្រ ១ សុភសូត្រ ១ កេវដ្ដសូត្រ ១ លោហិច្ចសូត្រ ១ តេវិជ្ជសូត្រ ១ ។

សីលក្ខន្ធវគ្គ ចប់

อัฏฐกถา

เตวิชชสูตร

[๑๖๗] เตวิชชสูตรมีคำว่าเป็นต้นว่า **เอวมฺเม สุตฺตํ ฯเปฯ โกสลเสสุ** เป็นเบื้องต้น ฯ ส่วนในที่นี้จักพรรณนาบทที่ยังไม่ได้กล่าวในพระสูตรนั้น ฯ

บทว่า **มนสากต** เป็นชื่อของนิคมนั้น ฯ บทว่า **อุตฺตเรน มนสากตสฺส** ความว่า ทิศเหนือแห่งนิคมมนสากตะ ฯ บทว่า **อมฺพวเน** ความว่า ในป่ามะม่วง ได้ยินว่า ภูมิภาคนั้นน่ารื่นรมย์ ข้างหลังเป็นป่าไม้ ข้างหน้าเป็นที่โล่ง ข้างบนเป็นป่า มีเมฆ และน้ำค้างโปรยปราย ดุจพื้นที่ลาดด้วยแผ่นกระดานแก้วมณี พระผู้มีพระภาคประทับอยู่ในอัมพวันนั้นด้วยสุขวิหารธรรมอันยิ่งกว่าวิเวก สมควรแก่พระพุทธเจ้าทั้งหลาย ฯ

[๑๖๘] บทว่า **อภิญฺญาตา อภิญฺญาตา** ความว่า เป็นผู้ที่ชนเป็นอันมากรู้จักในประเทศนั้นๆ เพราะประกอบด้วยคุณสมบัติ มีตระกูลเป็นต้น ฯ บทว่า **วาเสฏฺฐ** เป็นชื่อของพราหมณ์ผู้เป็นมหาศาลนั้น ฯ บทว่า พราหมณ์ผู้เป็นมหาศาลนั้น วาเสฏฐโคตรบ้าง ภารทวาชโคตรบ้าง ฯ บทว่า **อญฺเญ จ** ความว่า ชนเป็นอันมากจากชนบทต่างๆ มีอาทิอย่างนี้ว่า ชนเป็นอันมากจากชนบทกาสี โกศล ได้อาศัยอยู่ในนิคมมนสากตะนั้น ฯ เพราะเหตุว่า นิคมมนสากตะนั้นน่ารื่นรมย์ พราหมณ์ทั้งหลายจึงสร้างที่อยู่อาศัยในนิคมมนสากตะนั้น ตั้งอยู่ในฐานะเป็นที่ประชุมชนบท ฯ

ចូលទៅ នាំគ្នាទៅនៅក្នុងទីនោះ តាមលំដាប់ ។

បទថា **វាសេដ្ឋការទ្វាជានំ** *សេចក្តីថា វាសេដ្ឋមាណព ជាសិស្សរបស់ បោក្ខរសាតិព្រាហ្មណ៍ ភារទ្វាជមាណពជាសិស្សរបស់តារុក្ខព្រាហ្មណ៍ ។ បានឮថា មាណពទាំងពីរនោះបរិបូណ៌ដោយជាតិ សិក្សាចប់ត្រៃវេទហើយ ។ បទថា* **ជង្ឃវិហារំ** *គឺដើរចុះឡើងឲ្យស្រួលជើង ដើម្បីបន្ទោបង់ការចុកស្រេពន់ ព្រោះអង្គុយយូរពេកជាហេតុ ។ បានឮថា មាណពទាំងពីរនោះ អង្គុយទន្ទេញ មន្តរហូតអស់មួយថ្ងៃ ពេលល្ងាចទើបក្រោក ឲ្យមនុស្សកាន់ផ្ការម្រង គ្រឿងក្រអូប ប្រេង និងសំពត់ស្អាត ដែលជាគ្រឿងប្រើសម្រាប់ងូតទឹក ហែហមដោយបរិវារវៀងៗ ខ្លួន បំណងនឹងងូតទឹកទៅច្រាំងស្ទឹង ដើរទៅដើរមក លើផ្នូកខ្សាច់ពណ៌ដូចផែនប្រាក់ ។ ម្នាក់ដើរ ម្នាក់ទៀតដើរតាម ម្នាក់ទៀតក៏ដើរតាមម្នាក់ទៀត តគ្នាទៅ ដោយហេតុនោះ ទើបលោកពោលថា នាំគ្នាដើរត្រសង ។ បទថា* **មគ្គាមគ្គេ** *គឺក្នុងរឿងផ្លូវផង មិនមែនផ្លូវផង ។ អធិប្បាយថា មាណពទាំងពីរសន្ទនាគ្នាប្រារព្ធដល់រឿងផ្លូវ និងមិនមែនផ្លូវយ៉ាងនេះថា យើងនឹងបំពេញបដិបទាយ៉ាងណាហ្ន៎ ទើបអាចទៅកាន់ព្រហ្មលោក ដែលជាសុខបាន ដោយផ្លូវណា ។ បទថា* **អញ្ជសាយនោ** *ជាវេវចនៈរបស់ផ្លូវត្រង់ ឬផ្លូវត្រង់នោះឯង ។ បុគ្គលដើរ គឺរមែងមក ដោយផ្លូវនោះ ព្រោះដូច្នោះ ទើបផ្លូវនោះឈ្មោះថា ផ្លូវទៀងទាត់ ។ បទថា* **និយ្យានិកោ** *គឺកាលនាំចេញ រមែងនាំចេញទៅបាន អធិប្បាយថា កាលនឹងទៅ ក៏ទៅបាន ។ សួរថា ទៅណា ឆ្លើយថា ដើម្បីឲ្យអ្នកបដិបត្តិតាមនោះនៅរួមជាមួយព្រហ្មបាន អធិប្បាយថា*

អ្នកដែលទៅដើម្បីការនៅរួមនឹងព្រហ្ម ដើម្បីសេចក្តីប្រាកដក្នុងទីតែមួយ រមែងដើរតាមផ្លូវនោះ ។ បទថា **យ្វាយំ** *កាត់បទជា* **យោ អយំ ។** *បទថា* **អក្ខាតោ** *គឺពោល បានដល់ តារុក្ខព្រាហ្មសម្តែង ។ បទថា* **ព្រាហ្មណេន ចោក្ខរសាតិនា** *គឺវាសេដ្ឋមាណពអាងដល់អាចារ្យរបស់ខ្លួន ។ វាសេដ្ឋមាណពដើរអួត សរសើរវាទៈរបស់អាចារ្យខ្លួនតែម្យ៉ាង សូម្បីការទ្វាជៈក៏ដើរសរសើរវាទៈអាចារ្យរបស់ខ្លួនដូចគ្នា ។ ដោយហេតុនោះ ទើបលោកពោលថា វាសេដ្ឋមាណពមិនអាចដើម្បីញុំាងការទ្វាជមាណពឲ្យចូលចិត្តបានជាដើម ។*

[๑๖๙-๑๗๐] លំដាប់នោះ វាសេដ្ឋមាណពគិតថា ពាក្យរបស់យើងទាំងពីរ មិនជាផ្លូវនាំចេញបានពិត ដែលឈ្មោះថា អ្នកឈ្វាសក្នុងផ្លូវក្នុងលោកនេះ ដូចជាព្រះគោតមដ៏ចម្រើនមិនមាន ព្រះគោតមដ៏ចម្រើនប្រថាប់នៅមិនឆ្ងាយ ព្រះអង្គនឹងកម្ចាត់សេចក្តីសង្ស័យរបស់យើងបាន ដូចឈ្មួញអង្គុយកាន់ជញ្ជីងថ្លឹងដូច្នោះ ហើយទើបប្រាប់សេចក្តីនោះ ដល់ការទ្វាជមាណព ទាំងពីរនាក់ក៏នាំគ្នាទៅក្រាបទូលពាក្យចំពោះព្រះមានព្រះភាគ ។ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះ វាសេដ្ឋមាណព ។បេ។ ផ្លូវនេះឯងដែលតារុក្ខព្រាហ្មណ៍បានសម្តែងប្រាប់ ដូច្នេះជាដើម ។ បទថា **ឯត្ថ ភោ គោតម** *គឺក្នុងរឿងផ្លូវ និងមិនមែនផ្លូវនេះ ។*

ក្នុងបទថា **វិគ្គហោ វិវាទោ** *ជាដើម សេចក្តីថា ប្រកាន់ខុសកើតឡើងមុន ពោលខុសកើតឡើងខាងក្រោយ ។ បទទាំងពីរ ជាវាទៈផ្សេងអំពីវាទៈរបស់បណ្តាអាចារ្យផ្សេងៗ ។ ក្នុងបទថា* **អថ កិស្មិ បន** *សេចក្តីថា ព្រះ*

មានព្រះភាគត្រាស់ សួរថា អ្នកក៏លើកតម្កើងវាទៈអាចារ្យរបស់ខ្លួនប៉ុណ្ណោះ ដែលអះអាងបញ្ជាក់ថា នេះប៉ុណ្ណោះជាផ្លូវ សូម្បីការទ្វាជមាណព ក៏លើកតម្កើងវាទៈអាចារ្យរបស់ខ្លួនដូចគ្នា សេចក្តីសង្ស័យរបស់ម្នាក់ រមែងមិនមានក្នុងម្នាក់ បើដូច្នោះ ពួកអ្នកប្រកាន់ផ្សេងគ្នាក្នុងរឿងអ្វី ។ បទថា **មគ្គាមគ្គេ ភោ គោតម** *សេចក្តីថា បពិត្រព្រះគោតមដ៏ចម្រើន ក្នុងផ្លូវ និងមិនមែនផ្លូវ អធិប្បាយថា ក្នុងផ្លូវត្រង់ និងមិនមែនផ្លូវត្រង់ ។*

បានឮថា មាណពនោះ មិនពោលដល់ផ្លូវរបស់ព្រាហ្មណ៍ម្នាក់ថា មិនមែនផ្លូវ ឯផ្លូវអាចារ្យរបស់ខ្លួន ជាផ្លូវត្រង់យ៉ាងណា មាណពទាំងនោះមិនទទួលជឿរបស់អ្នកដទៃដូច្នោះ ព្រោះហេតុនោះ កាលនឹងសម្តែងសេចក្តីនោះ ទើបមាណពទាំងនោះក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ ... ក៏ពិតមែនហើយជាដើម ។ បទថា **សព្ពានិ តានិ** *លោកពោលដោយលិង្គវិបល្លាស (ខុសលិង្គ) អធិប្បាយថា* **សព្ពេ តេ** *ដូច្នេះ ។ បទថា* **ពហូនិ** *គឺ ៨ ផ្លូវ ឬ ១០ ផ្លូវ ។ បទថា* **នានាមគ្គានិ** *គឺផ្លូវដែលមកអំពីស្រុកស្ទឹង ស្រះ និងស្រែជាដើម ជិតគ្នាច្រើនផ្លូវ ទាំងធំ និងតូច ជាផ្លូវថ្មើរជើង និងផ្លូវរទេះជាដើម ហើយចូលស្រុក ។ បទថា* **និយ្យន្តីតិ វាសេដ្ឋ វាទេសិ** *សេចក្តីថា ព្រះដ៏មានព្រះភាគ ឲ្យវាសេដ្ឋមាណពចន្ទឹវាថា ៣ ដង ហើយឲ្យធ្វើប្តេជ្ញា ។ ព្រោះហេតុអ្វី ព្រោះពួកតិរ្ថិយប្តេជ្ញាហើយ ខាងក្រោយកាលត្រូវសង្កត់សង្កិន មើលងាយ វាសេដ្ឋមាណព នឹងមិនអាចធ្វើយ៉ាងនោះបាន ។*

[๑๗๒] *បទថា* **តេវ តេវិជ្ជា** *បានដល់ ពួកព្រាហ្មណ៍ចប់ត្រៃវេទ ។*

វ អក្ខរៈ ត្រឹមតែជាអាគមសន្ធិ ។

[១៧៣] *បទថា* **អន្ធវេណី** *ប្រែថា មនុស្សមានភ្នែកខ្វាក់ដើរជាជួរ អធិប្បាយថា មនុស្សខ្វាក់ភ្នែកម្នាក់ ចាប់ចុងឈើច្រត់ដែលមនុស្សភ្នែកល្អកាន់ មនុស្សដទៃៗ ក៏ចាប់មនុស្សខ្វាក់ភ្នែកតៗ គ្នាទៅ ដោយប្រការដូច្នេះ មនុស្សខ្វាក់ភ្នែក ៥០-៦០ នាក់ ចាប់បន្តគ្នាទៅដោយលំដាប់ ហៅថា ជួរនៃមនុស្សខ្វាក់ភ្នែក ។ បទថា* **បរំបរាសំសត្តា** *គឺតោងខ្នងគ្នានិងគ្នា ។ អធិប្បាយថា ត្រូវអ្នកភ្នែកល្អកាន់ឈើច្រត់គេចចេញទៅ ។ មានរឿងថា អ្នកលេងម្នាក់ឃើញពួកអ្នកខ្វាក់ភ្នែក ទើបឲ្យពួកអ្នកខ្វាក់ភ្នែកកើតសេចក្តីឧស្សាហៈ ដោយនិយាយថា នៅស្រុកឯណោះ រកវបស់ទំពា របស់ស៊ីបានងាយ កាលពួកអ្នកខ្វាក់ភ្នែក ពោលថា បពិត្រអ្នកម្ចាស់ បើដូច្នោះ សូមអ្នកនាំពួកខ្ញុំទៅកាន់ស្រុកនោះ ពួកខ្ញុំនឹងឲ្យវត្ថុនេះដល់លោក អ្នកលេងទទួលថ្លៃឈ្នួលហើយ ទើបចុះចេញអំពីផ្លូវក្នុងចន្លោះផ្លូវ ដើរវិលជុំវិញគល់ឈើធំ ទើបឲ្យពួកមនុស្សខ្វាក់ភ្នែក ចាប់ជាយសំពត់គ្នា តាមលំដាប់មុនក្រោយ ហើយប្រាប់ថា ខ្ញុំមានធុរៈ ពួកលោកចូរទៅមុន ហើយគេចចេញទៅ ។ ពួកមនុស្សខ្វាក់ភ្នែកទៅរហូត ដល់អស់មួយថ្ងៃ ក៏មិនជួបផ្លូវ នាំគ្នាទួញយំថា មនុស្សភ្នែកល្អទៅណា ផ្លូវនៅទីណា កាលមិនជួបផ្លូវ ក៏ស្លាប់ទាំងអស់គ្នាក្នុងទីនោះឯង ។ លោកពោលថា តោងខ្នងគ្នានិងគ្នា សំដៅដល់ពួកអ្នកសូមទានទាំងនោះ ។*

បទថា **ឋុរិមោបិ** *គឺបណ្តាព្រាហ្មណ៍ ១០ នាក់ សូម្បីតែម្នាក់ ក៏មើលមិនឃើញ ។ បទថា* **មជ្ឈិមោបិ** *មានន័យថា បណ្តាអាចារ្យ និងអាចារ្យ ក្នុង

កណ្តាល សូម្បីម្នាក់ក៏មើលមិនឃើញ ។ បទថា **បច្ចិមោបិ** *សេចក្តីថា បណ្តាព្រាហ្មណ៍ អ្នកចេះចប់ត្រៃវេទក្នុងកាលឥឡូវនេះ សូម្បីតែម្នាក់ក៏មិនឃើញ ។ បទថា* **ហាស្សកំយេវ** *ប្រែថា គួរសើចចំអកជាយពិត ។ បទថា* **ឆាមកំយេវ** *ប្រែថា ថោកទាបជាយពិត ។ ភាសិតនោះ ជាពាក្យទទេ ព្រោះមិនមានប្រយោជន៍ ។ ជាពាក្យសោះសូន្យ ព្រោះជាពាក្យមិនគួរឲ្យជឿបាន ។*

[๑๗๔] *ឥឡូវនេះ ព្រះដ៏មានព្រះភាគ ដើម្បីទ្រង់សម្តែងថា ព្រហ្មដែលព្រាហ្មណ៍អ្នកចប់ត្រៃវេទមិនធ្លាប់ឃើញ លើកទុកសិន ព្រាហ្មណ៍អ្នកចប់ត្រៃវេទ រមែងមើលឃើញព្រះចន្ទ និងព្រះអាទិត្យណាបាន តែមិនអាចនឹងសម្តែងផ្លូវ ដើម្បីការនៅរួមនឹងព្រះចន្ទ ព្រះអាទិត្យនោះបាន ទើបត្រាស់ពាក្យថា ម្នាលវាសេដ្ឋៈ អ្នកសម្គាល់ហេតុនោះដូចម្តេចជាដើម ។បណ្តាបទទាំងនោះ បទថា* **យតោ ចន្ទិមសុរិយា ឧគ្គច្ឆន្តិ** *គឺព្រះចន្ទ និងព្រះអាទិត្យរះឡើងក្នុងកាលណា ។ បទថា* **យត្ថ ច ឱគច្ឆន្តិ** *គឺដល់នូវការអស្តង្គតទៅក្នុងកាលណា ។ អធិប្បាយថា ជនទាំងឡាយ រមែងឃើញក្នុងវេលារះឡើង ក្នុងវេលាលិចទៅ ។បទថា* **អាយាចន្តិ** *គឺអង្វរយ៉ាងនេះថា សូមព្រះចន្ទដ៏ចម្រើនរះឡើង សូមព្រះអាទិត្យដ៏ចម្រើនរះឡើង ។ បទថា* **ថោមយន្តិ** *អធិប្បាយថា ជនទាំងឡាយរមែងពោលសរសើរថា ព្រះចន្ទសុភាព ព្រះអាទិត្យរៀបរយ ព្រះចន្ទមានរស្មីជាដើម ។ បទថា* **បញ្ជលិកា** *គឺផ្គងអញ្ជលី ។ បទថា* **មនស្ស-មានា** *គឺពោលថា* **ឧមោ ឧមោ** *ដូច្នេះ ។ បទថា* **យំ** *ក្នុងបទថា* **យំ បស្សន្តិ**

ត្រឹមតែនិបាត ។ ក្នុងបទថា **កិំបន ន កិរ** *គប្បី យើញសេចក្តីយ៉ាងនេះថា ក្នុងទីនេះ គួរនិយាយគ្នារឿងអ្វី បានឮថា ព្រាហ្មណ៍អ្នកបានត្រៃវេទ មិនដែលបានយើញព្រហ្មផ្ទាល់នឹងភ្នែកជាសាក្សីឡើយ ។*

ឧបមាអំពីស្ទឹងអចិរវតី

[១៧៨] *បទថា* **សមតិត្តិកា** *បានដល់ ពេញប្រាំង ។ បទថា* **កាកបេយ្យា** *អធិប្បាយថា ក្អែកឈរនៅលើប្រាំងណាមួយ ក៏អាចផឹកបាន ។ បទថា* **ចារំ តរិតុកាមោ** *គឺប្រាថ្នានឹងឆ្លងស្ទឹងទៅត្រើយម្ខាង ។ បទថា* **អម្ភោយ្យ** *គឺហៅ ។ បទថា* **ឃភិ ចារាចារំ** *អធិប្បាយថា បុរសនោះស្រែកហៅថា ម្នាលត្រើយនាយ អ្នកចូរមកត្រើយអាយ កាលបើដូច្នោះ អ្នកនឹងនាំខ្ញុំឆ្លងទៅបានដោយរហ័ស ខ្ញុំមានកិច្ចដែលនឹងត្រូវធ្វើឆាប់ៗ ។ ក្នុងបទថា* **យេ ធម្មា ព្រាហ្មណាការកា** *នេះ គប្បីជ្រាបថា ធម៌ដែលធ្វើឲ្យជាព្រាហ្មណ៍ បានដល់ សីល ៥ សីល ១០ កុសលកម្មបថ ១០ ។ ធម៌ដែលផ្សេងអំពីនោះ មិនមែនធម៌ដែលធ្វើឲ្យជាព្រាហ្មណ៍ឡើយ ។ បទថា* **ឥទ្ធម្ភាយាម** *កាត់បទជា* **ឥទ្ធំ អម្ភាយាម** *ប្រែថា ខ្ញុំហៅរកព្រះឥន្ទ្រ ។*

[១៧៩] *ព្រះមានព្រះភាគ លុះទ្រង់សម្តែងដល់ពាក្យស្រែកហៅរបស់ព្រាហ្មណ៍មិនមានប្រយោជន៍ ដែលទ្រង់រុងរឿងដូចព្រះអាទិត្យក្នុងផ្ទៃមហាសមុទ្រ ទ្រង់ចោមរោមដោយភិក្ខុ ៥០០ រូប ប្រថាប់គង់លើឆ្នេរស្ទឹងអចិរវតី កាលទ្រង់នាំស្ទឹងដទៃៗ មកប្រៀបធៀបទៀត ទើបត្រាស់ថា* **សេយ្យ-**

ជាតិ ជាដើម ។ បទថា **កាមគុណា** អធិប្បាយថា ឈ្មោះថា **កាម** ព្រោះអត្ថថា គប្បីត្រេកអរ ។ ឈ្មោះថា **គុណា** ព្រោះអត្ថថា ចង ។ **គុណា** សព្ទប្រព្រឹត្តទៅក្នុងអត្ថ ៤ យ៉ាង គឺជាន់ លំដាប់ អានិសង្ស និងចំណង ។ ប្រព្រឹត្តទៅក្នុងអត្ថថា **ជាន់** ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ តិចីវរំ ទ្វិគុណំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរ ៣ គឺ សង្ឃាដី ២ ជាន់ ឧត្តរាសង្គ (ចីពរ) ១ ជាន់ សង្ឃ៍ ១ ជាន់ ដូច្នេះ ។

ប្រព្រឹត្តទៅក្នុងអត្ថថា **លំដាប់** ឬ **ជំនាន់** ដូចក្នុងប្រយោគជាដើមថា **អច្ចេន្តិកាលា តរយន្តិ រត្តិយោ វយោគុណា អនុបទ្យំ ជហន្តិ** កាលទាំងឡាយតែងកន្ងងផុតទៅ រាត្រីទាំងឡាយ តែងឆ្ងងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះបង់នូវលំដាប់ ។

ប្រព្រឹត្តទៅក្នុងអត្ថថា **អានិសង្ស** ដូចក្នុងប្រយោគជាដើមថា **សត-គុណា ទក្ខិណា ថាដិកង្ខិតព្វា** ទក្ខិណាមានគុណ ១០០ ដែលបុគ្គលត្រូវបាន (ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន) ។

ប្រព្រឹត្តទៅក្នុងអត្ថថា **ចំណង** ដូចក្នុងប្រយោគជាដើមថា **អន្តំ អន្ត-គុណំ** ពោះវៀនធំ ពោះវៀនតូច និងប្រយោគមួយទៀតថា **កយិរា មាលា-គុណោ ពហូ** មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កាឲ្យច្រើនបាន ។ ក្នុងទីនេះលោកប្រាថ្នាយកចំណង ព្រោះដូច្នោះ ទើបពោលថា **គុណា**

ដោយអត្ថថា **ចំណាង** ។ បទថា **จกฺขุวิญฺเญยฺยา** គឺគប្បីឃើញដោយចក្ខុ-វិញ្ញាណ ។ គប្បីជ្រាបសេចក្តីក្នុងបទថា **សោតวิญฺเญยฺยา** ជាដើម ដោយឧបាយនេះ ។ បទថា **ឥដ្ឋា** សេចក្តីថា កាមគុណ ៥ ជាវត្ថុដែលគួរស្វែងរកក្តី មិនគួរស្វែងរកក្តី អធិប្បាយថា រមែងជាអារម្មណ៍ដែលមិនគួរប្រាថ្នា ។ បទថា **កន្តា** បានដល់ ជាទីតាំងនៃសេចក្តីប្រាថ្នា ។ បទថា **មនាបា** បានដល់ គួរជាទីពេញចិត្ត ។ បទថា **បិយรូបา** បានដល់ មានសេចក្តីស្រឡាញ់ជាប្រក្រតី ។ បទថា **กามูปสญฺหิตา** បានដល់ ចូលទៅទាក់ទងដោយកាម ធ្វើឲ្យជាអារម្មណ៍ ហើយកើតឡើង ។ បទថា **រជนิយา** គឺពេញចិត្ត អធិប្បាយថា ជាហេតុកើតនៃរាគៈ ។ បទថា **គធิตา** គឺត្រូវតម្រេកគ្របសង្កត់ ។ បទថា **มุจฺฉิตา** គឺត្រូវតណ្ហាមានប្រមាណក្រៃលែង ដែលដល់នូវអាការងប់ជ្រប់ គ្របសង្កត់ ។ បទថា **อชฺโฌสนฺนา** គឺលិចចុះ ជ្រាក់ចុះ គឺជាអ្នកដល់ការជ្រាក់ចុះថា នេះជាសារៈ ដូច្នេះ ។ បទថា **อนาทีนวทสฺสาวิโน** បានដល់ មិនសម្លឹងឃើញទោស ។ បទថា **นิสฺสรณំ** ក្នុងបទថា **อนิสฺสรณปญฺญา** នេះ បានដល់ បញ្ញាដែលវៀរចាកបញ្ញាជាគ្រឿងកំណត់ដឹង អធិប្បាយថា បញ្ញាវៀរចាកការបរិកោគ ដោយការពិចារណា ។

[๑๘๐] ក្នុងបទថា **អาวរณา** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ពាក្យថា **กามគุณา** ឈ្មោះថា **អาวรณา** ព្រោះជាគ្រឿងជាប់ស្អិត ។ ឈ្មោះថា **นิวรณา** ព្រោះជាគ្រឿងរារាំង ។ ឈ្មោះថា **นิยามนา** ព្រោះ

ជាគ្រឿងទាញយិត ។ **កាមគុណា** *ឈ្មោះថា* **បរិយោយាធា** *ព្រោះជាគ្រឿងរួបរឹត ។ សេចក្តីពិស្តារបស់នីវរណៈ មានកាមឆន្ទៈជាដើម គប្បីស្វែងរកអំពីវិសុទ្ធិមគ្គ ។*

[๑๘๑] *បទថា* **អាវុដា និវុដា ឱដ្ឋតា បរិយោនទ្ធា** *លោកពោលដោយអំណាចនៃកាមគុណ មានគ្រឿងយឺតយូរជាដើម ។*

[๑๘๒] *បទថា* **សបរិគ្គហា** *លោកពោលដល់ការជាប់ជំពាក់ក្នុងស្ត្រី ។ ក្នុងបទជាដើមថា* **អបរិគ្គហោ តោ គោតម** *នេះ លោកពោលការមិនជាប់ជំពាក់ជាមួយស្ត្រី ព្រោះមិនមានកាមច្ឆន្ទៈ ។ ឈ្មោះថា មិនមានពៀរដោយចិត្តគិតចងពៀរនឹងបុគ្គលណាម្នាក់ ព្រោះមិនមានព្យាបាទ ។ ឈ្មោះថា មិនមានព្យាបាទ ដោយព្យាបាទ ពោល គឺអាពាធផ្លូវចិត្ត ព្រោះមិនមានបឹនមិទ្ធៈ ។ ឈ្មោះថា មិនមានចិត្តសៅហ្មងដោយគ្រឿងសៅហ្មង មានឧទ្ធច្ចកុក្កុច្ចៈជាដើម ព្រោះមិនមានឧទ្ធច្ចកុក្កុច្ចៈ ឈ្មោះថា អ្នកមានចិត្តបរិសុទ្ធដោយល្អ ។ ឈ្មោះថា* **វសវត្តិ** *ព្រោះធ្វើចិត្តឲ្យនៅក្នុងអំណាច ព្រោះហេតុមិនមានវិចិកិច្ឆា និងមិនដូចជាព្រាហ្មណ៍អ្នកធ្លាក់នៅក្នុងអំណាចនៃចិត្ត គឺប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត ។*

[๑๘๓] *បទថា* **ឥធ ខោ បន** *គឺក្នុងផ្លូវនៃព្រហ្មលោកនេះ ។ បទថា* **អាសីទិត្វា** *គឺចូលទៅរកវត្តុមិនមែនផ្លូវ ថាជាផ្លូវ ។ បទថា* **សំសីទន្តិ** *គឺលិចចុះទៅ ដូចបុគ្គលជាន់កក់ ដោយសម្គាល់ថា ជាដីរាបស្មើ ។ បទថា* **សំសីទិត្វា វិសត្តំ ចាបុណន្តិ** *អធិប្បាយថា កាលលិច ដូចលិចក្នុងកក់យ៉ាងនេះ*

នេះហើយ រមែងដល់សេចក្តីលំបាក គឺការបាក់បែកនៃអវយវៈតូចធំ ។ បទ ថា **សុខតរំ មញ្ញេ តរន្តិ** *អធិប្បាយថា ជនទាំងឡាយគិតថា អញនឹងឆ្លង ដោយសម្គាល់ថា ស្ទឹងមានទឹកពេញស្មើច្រាំងក្អែកផឹកបាន ទើបព្យាយាម ទាំងដៃទាំងជើងសម្គាល់ថា ឆ្លងបានងាយ ស្រាំងក្អែក ដូចថ្ងៃបណ្តើរកូន ។ ព្រោះដូច្នោះ ជនទាំងឡាយ រមែងដល់សេចក្តីលំបាកនឹងបាក់បែកក្នុងអបាយ ដូចដៃ និងជើងជាដើម ដល់សេចក្តីលំបាកដោយការបាក់បែកដូច្នោះ គឺមិន បានសេចក្តីសុខ ឬសេចក្តីសប្បាយ ក្នុងលោកនេះឡើយ ។ បទថា* **តស្មា ឥធេត្តវិជ្ជានំ ព្រាហ្មណានំ** *សេចក្តីថា ព្រោះហេតុនោះ នេះជាបាវចនៈ គឺ ត្រៃវេទដែលសម្តែងដល់ផ្លូវ ដើម្បីការនៅរួមជាមួយព្រហ្ម របស់ព្រាហ្មណ៍ ទាំងឡាយអ្នកចប់ត្រៃវេទ ។*

បទថា **តេវិជ្ជាវឡញ្ជំ** *បានដល់ ព្រៃ គឺត្រៃវេទ ព្រៃធំដែលមិនមានស្រុក លោកពោលថា ព្រៃ ។ បទថា* **តេវិជ្ជាវនំ** *បានដល់ ព្រៃដែលមិនមានទឹក គ្របដណ្តប់ដោយដើមឈើដែលមានផ្លែផ្កាបរិភោគមិនបាន ។ លោកពោលថា ព្រះមានព្រះភាគត្រាស់ថា គេហៅថា ព្រៃធំ គឺត្រៃវេទ ដូច្នេះក៏មាន ទ្រង់ សំដៅដល់ព្រៃ ដែលបុគ្គលណាម្នាក់ មិនអាចនឹងគេច ឬបួរផ្លូវបាន ។ បទថា* **តេវិជ្ជាព្យសនំ** *ពាក្យនេះ ដូចគ្នានឹងសេចក្តីវិនាស ៥ យ៉ាងរបស់ត្រៃវេទ ។ លោកសម្តែងថា អ្នកចប់ត្រៃវេទ រមែងមិនមានសេចក្តីសុខ ព្រោះអាស្រ័យ ពាក្យទូន្មានជាគោល បានដល់ ត្រៃវេទ ដូចបុគ្គលដែលដល់នូវព្យសនៈ ព្រោះញាតិ រោគ កោគៈ ទិដ្ឋិ និងសីល រមែងមិនមានសេចក្តីសុខ ដូច្នោះ ។*

[๑๘๓] បទថា **ជាតសំវឌ្ឍោ** បានដល់ កើត និងធំធាត់ អធិប្បាយថា ព្រោះផ្លូវទៅស្រុកជិតខាងរបស់អ្នកដែលកើតក្នុងកន្លែងមួយ ហើយទៅធំធាត់ក្នុងទីដទៃ មិនប្រចក្សដោយប្រការទាំងពួង ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា កើតហើយ ធំធាត់ហើយ ដូច្នេះ ។ អ្នកដែលកើតហើយ ធំធាត់ហើយ តែចាកចេញទៅយូរ រមែងមិនប្រចក្សដោយប្រការទាំងពួង ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ចេញទៅហើយក្នុងពេលក្ងាមៗ នោះ ។ អធិប្បាយថា ចេញទៅក្នុងខណៈនោះឯង ។ បទថា **ឧជ្ជាយិតត្តំ** គឺយឺតយូរដោយសង្ស័យថា ផ្លូវនេះ ឬមិនមែនផ្លូវនេះហ្ន៎ ។ បទថា **វិត្តាយិតត្តំ** បានដល់ ការដល់ភាពជាអ្នកអល់អែក ដូចនរណាម្នាក់ កាលត្រូវសួរក្ងាមៗ ដល់រឿងដែលកើតទ្បើងយ៉ាងល្អិត បុគ្គលនោះដល់ភាពជាអ្នកមានសរីរៈរឹង ដូច្នោះ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងដល់ព្រះសព្វញ្ញុតញ្ញាណ មិនត្រូវជំទាស់ដោយបទថា មិនយឺតយូរ មិនក្រអឺមក្រអៀម ដូច្នេះ ។ លោកអធិប្បាយថា ការជំទាស់ញាណរបស់បុរសនោះ គប្បីមាន ដោយអំណាចត្រូវមារបណ្តាលចិត្តជាដើម ដោយហេតុនោះ បុរសនោះគប្បីយឺតយូរ ឬអឺមអៀម តែព្រះសព្វញ្ញុតញ្ញាណ មិនត្រូវជំទាស់ បុគ្គលណាម្នាក់មិនអាចធ្វើអន្តរាយចំពោះព្រះសព្វញ្ញុតញ្ញាណនោះបានទ្បើយ ។

[๑๘๕-๑๘๖] បទថា **ឱលុម្បតុ ភវំ គោតមោ** បានដល់ សូមព្រះគោតមដ៏ចម្រើនមេត្តាលើកទ្បើង ។ បទថា **ព្រាហ្មណិ ឃដំ** សំដៅដល់ កូនរបស់ព្រាហ្មណ៍ អធិប្បាយថា សូមព្រះគោតមដ៏ចម្រើន មេត្តាលើកព្រាហ្មណ៍

និងបុត្រារបស់ព្រាហ្មណ៍ឡើងអំពីផ្លូវអបាយ ហើយឲ្យតាំងនៅក្នុងផ្លូវព្រហ្ម-លោកចុះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគមានព្រះបំណងនឹងសម្តែងដល់ការកើតឡើងនៃព្រះពុទ្ធ ហើយទ្រង់សម្តែងផ្លូវទៅព្រហ្មលោក មានមេត្តា-វិហារធម៌ជាដើម ព្រមដោយបដិបទាជាខាងដើមដល់មាណព ទើបត្រាស់ពាក្យថា ម្នាលវាសេដ្ឋៈ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឥធ តថាគតោ** *ជាដើម ក្នុងសូត្រនេះ បានពោលពិស្តារហើយក្នុងសាមញ្ញផលសូត្រ ។ ប្រការដែលគួរពោលទាំងអស់ ក្នុងបទថា* **មេត្តាសហគតេន** *ជាដើម លោកពោលហើយ ក្នុងព្រហ្ម-វិហារកម្មដ្ឋានកថា ក្នុងវិសុទ្ធិមគ្គ ។*

បទថា **សេយ្យថាបិ ពលវា សង្ខធម្មោ** *ជាដើម មិនធ្លាប់មានក្នុងទីនេះ។ បណ្តាបទទាំងនោះ បទថា* **ពលវា** *គឺបរិបូណ៌ដោយកម្លាំង ។ បទថា* **សង្ខធម្មោ** *គឺអ្នកផ្លុំស័ង្ខ ។ បទថា* **កសិរេន** *បានដល់ មិនលំបាក គឺមិនលំបាក ។ អធិប្បាយថា ពិតហើយ អ្នកផ្លុំស័ង្ខទុព្ភលភាព សូម្បីផ្លុំស័ង្ខ ក៏មិនអាចឲ្យឮសំឡេងគ្រប់ទិសទាំង ៤ សំឡេងស័ង្ខរបស់បុគ្គលនោះមិនខ្លះខ្លាយទូទៅ តែសម្រាប់អ្នកមានកម្លាំងនឹងខ្លះខ្លាយទូទៅ ។ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា មនុស្សមានកម្លាំងជាដើម ។ កាលត្រាស់ថា* **មេត្តា** *ក្នុងបទថា* **មេត្តាយ ចេតោវិមុត្តិយា** *នេះ គួរទាំងឧបចារៈ ទាំងអប្បនា ។ តែកាលត្រាស់ថា* **ចេតោវិមុត្តិ** *គួរដល់អប្បនាតែម្យ៉ាង ។ បទថា* **យំ បមាណកតំ កម្មំ** *សេចក្តីថា ដែលឈ្មោះថា កម្មដែលល្មមប្រមាណ លោក*

ពោលថា ជាកាមាវចរកម្ម ។ កម្មដែលធ្វើមិនមានប្រមាណ លោកពោលថា ជារូបាវចរកម្ម និងអរូបាវចរកម្ម ។ លោកពោលថា កម្មដែលធ្វើមិនមានប្រមាណ ព្រោះកន្ទងប្រមាណហើយ ធ្វើឲ្យចម្រើនដោយអំណាចការផ្សាយទៅក្នុងទិសដោយចំពោះ និងមិនចំពោះ ។

បទថា **ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតិ** *អធិប្បាយថា កម្មដែលជាកាមាវចរនោះ មិនឈប់ មិនតាំងនៅក្នុងកម្ម ដែលជារូបាវចរ និងអរូបាវចរនោះ ។ លោកអធិប្បាយដូចម្តេច អធិប្បាយថា កម្មជាកាមាវចរនោះ មិនអាចជាប់នៅ ឬតាំងនៅក្នុងវាងកម្មដែលជារូបាវចរ និងអរូបាវចរនោះបាន ឬដើម្បីនឹងផ្សាយកម្មដែលជារូបាវចរ និងអរូបាវចរ ហើយរក្សាជល់ឱកាសរបស់ខ្លួនតាំងនៅបាន តាមការពិត កម្មដែលជារូបាវចរ និងអរូបាវចរនោះឯង នឹងផ្សាយទៅ ហើយរក្សាទុកនូវកាមាវចរកម្ម ជល់ឱកាសរបស់ខ្លួនតាំងនៅ ដូចអន្ទង់ទឹកធំ ជោរជន់ ទឹកបន្តិចបន្តួចចេញទៅ ក៏តាំងនៅដូច្នោះ រមែងហាមវិបាករបស់កម្មដែលជាកាមាវចរនោះ នាំចូលកាន់កាពជាអ្នកនៅរួមជាមួយព្រហ្មដោយខ្លួនឯង ដូច្នេះ ។*

បទថា **ឃរិយាវ** *គឺមានធម៌គ្រឿងនៅ មានមេត្តាជាដើម យ៉ាងនេះ ។*

បទថា **ឯតេ មយំ ភគវន្តំ** *នេះជាការជល់សរណៈលើកទីពីររបស់មាណពទាំងពីរនោះ ។ មាណពទាំងពីរនោះស្តាប់វាសេដ្ឋសូត្រ ក្នុងមជ្ឈិមបណ្ណាសកៈហើយ ជល់សរណៈជាលើកដំបូង ស្តាប់តេវិជ្ជសូត្រនេះហើយជល់សរណៈជាលើកទីពីរ កន្ទងទៅ ២-៣ ថ្ងៃ បានបព្វជ្ជា ហើយបាន*

ឧបសម្បទា ក៏សម្រេចអរហត្ត ក្នុងអគ្គញ្ញសូត្រ ពាក្យដ៏សេសក្នុងទីគ្រប់អន្ទៃ មានអត្ថងាយ យល់ហើយ ដូច្នេះឯង ។

អដ្ឋកថា តេវិជ្ជសូត្រ នៃទីឃនិកាយ ឈ្មោះ សុមង្គលវិលាសិនី ចប់ហើយដោយប្រការដូច្នេះ ។

ពណ៌នាអត្ថ នៃសីលក្ខន្ធវគ្គ ប្រជាប់ដោយសូត្រទាំង១ឣ យ ១៣ ចប់ហើយ ដោយប្រការដូច្នេះ ៗ

តេវិជ្ជសូត្រ ទី ១៣ ចប់

សីលក្ខន្ធវគ្គ ចប់

สุตฺตนฺตปิฎก ทีฆนิกาย

ตติยภาค มหาวคฺค

สูมนมสฺการ

ចំពោះព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

มหาปทานสุตฺรที ๑

[๑] ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកវេរិកុដិកា ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូប ត្រឡប់មកពីបិណ្ឌបាត (បានធ្វើភត្តកិច្ចស្រេចហើយ) ក្នុងវេលាក្រោយភត្ត ក៏អង្គុយប្រជុំគ្នាក្នុងសាលាសម្រាប់អង្គុយ ដែលគេធ្វើនៅជិតកវេរិមណ្ឌល ហើយក៏កើតជាធម្មីកថា គឺការនិយាយអំពីធម៌ប្រកបដោយបុព្វេនិវាសថា បុព្វេនិវាសដូច្នេះខ្លះ បុព្វេនិវាសដូច្នេះខ្លះ ។ ព្រះមានព្រះភាគទ្រង់បានឮពាក្យចរចានេះ របស់ភិក្ខុទាំងនោះ ដោយព្រះទិព្វសោតធាតុដ៏បរិសុទ្ធ កន្ទងបង់នូវសោតៈនៃមនុស្សសាមញ្ញ ។ ទើបព្រះមានព្រះភាគទ្រង់ក្រោកអំពីអាសនៈ ទ្រង់ចូលសំដៅទៅរោងកវេរិមណ្ឌល លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគគង់ស៊ប់ហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយ

ប្រជុំគ្នានិយាយពីរឿងអ្វី អន្តរាកថាដូចម្តេច ដែលអ្នកទាំងឡាយបញ្ឈប់ទៅវិញ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុទាំងនោះក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយត្រឡប់មកពីបិណ្ឌបាត (បានធ្វើភត្តកិច្ចស្រេចហើយ) ក្នុងវេលាក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងរោងកវរិមណ្ឌលនេះ ក៏កើតជាធម្មីកថាប្រកបដោយបុព្វេនិវាសថា បុព្វេនិវាសដូច្នេះខ្លះ បុព្វេនិវាសដូច្នេះខ្លះ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងជាអន្តរាកថាដែលខ្ញុំព្រះអង្គទាំងឡាយបញ្ឈប់ជ្បិតព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចង់ស្តាប់ធម្មីកថា ប្រកបដោយបុព្វេនិវាសដែរឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរដល់ការធ្វើធម្មីកថានុ៎ះហើយ បពិត្រព្រះសុគត កាលនេះ ជាកាលគួរដល់ធម្មីកថានុ៎ះហើយ គួរព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ដែលប្រកបដោយបុព្វេនិវាស ភិក្ខុទាំងឡាយស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគហើយ នឹងចងចាំទុក ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយចាំស្តាប់ ចូរប្រុងធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីកន្លួកប្បនេះ (ថយក្រោយទៅ) ៩១ កប្ប ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុ

ទាំងឡាយ រាប់អំពីកទ្បកប្បនេះទៅ ๓๑ កប្ប ព្រះសិខីមានព្រះភាគអរ-ហន្តសម្មាសម្ពុទ្ធទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកប្ប ๓๑ នោះដែរ ព្រះវេស្សភូមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើង ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងភទ្ទកប្បនេះឯង ព្រះកកុសន្ធៈមាន ព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងភទ្ទកប្បនេះដែរ ព្រះកោនាគមនៈមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងភទ្ទកប្បនេះដែរ ព្រះ កស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាល ភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោក ក្នុងភទ្ទកប្បនេះដែរ ។

[๒] *ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាខត្តិយជាតិទ្រង់កើតក្នុងខត្តិយត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះ សិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាខត្តិយជាតិទ្រង់កើតក្នុងខត្តិយ-ត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ជាខត្តិយជាតិទ្រង់កើតក្នុងខត្តិយត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈ មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណជាតិ ទ្រង់កើតក្នុងព្រាហ្មណ-ត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មា-សម្ពុទ្ធ ជាព្រាហ្មណជាតិទ្រង់កើតក្នុងព្រាហ្មណត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណជាតិ ទ្រង់កើតក្នុង*

ព្រាហ្មណត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតអរហន្តសម្មា-សម្ពុទ្ធ ជាខត្តិយជាតិ កើតក្នុងខត្តិយត្រកូល ។

[๓] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមាន ព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកស្សបគោត្រ ។ ម្នាល ភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកស្ស-បគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មា-សម្ពុទ្ធជាកស្សបគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតអរហន្ត-សម្មាសម្ពុទ្ធ ជាគោតមគោត្រ ។

[๔] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ๘ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ๗ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ๖ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះ ជន្មាយុ ๔ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ๓ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានព្រះជន្មាយុ ๒ ហ្មឺនឆ្នាំ ។

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ជន្មាយុរបស់តថាគតមានប្រមាណតិច ឆាប់រហ័ស បុគ្គល (ក្នុងសម័យនេះ) ដែលរស់នៅយ៉ាងយូរបានត្រឹម ១០០ ឆ្នាំ និងតិចជាង ១០០ ឆ្នាំ ឬច្រើនជាង ១០០ ឆ្នាំ ក៏មាន (ដោយតិច)។

[៥] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ គ្រាស់ដឹងក្រោមបាដលិព្រឹក្ស (ដើមជ្រៃទៀង) ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ គ្រាស់ក្រោមបុណ្ឌរីកព្រឹក្ស (ដើមស្វាយស) ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ គ្រាស់ក្រោមសាលព្រឹក្ស ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ គ្រាស់ក្រោមសិរីសព្រឹក្ស (ដើមច្រេស) ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធគ្រាស់ក្រោមឧទុម្ពរព្រឹក្ស (ដើមល្វា) ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធគ្រាស់ក្រោមដើមនិគ្រោធព្រឹក្ស (ដើមជ្រៃ)។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ តថាគត អរហន្តសម្មាសម្ពុទ្ធគ្រាស់ក្រោមអស្សត្ថព្រឹក្ស (ដើមពោធិ៍ចាយ) ។

[៦] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវកដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះខណ្ឌៈ ១ តិស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវកដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះអភិភូ ១ សម្ភវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវកដ៏

ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះសោនៈ ๑ ឧត្តរៈ ๑ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវកដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះវិធុរៈ ๑ សញ្ជីវៈ ๑ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវកដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះភិយ្យោសៈ ๑ ឧត្តរៈ ๑ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវកដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះតិស្សៈ ๑ ភារទ្វាជៈ ๑ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ តថាគត មានគូនៃសាវកដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះសារីបុត្ត ๑ មោគ្គល្លាន ๑ ។

[๗] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត (ប្រជុំសាវក) ๓ ដង គឺសាវកសន្និបាត មានភិក្ខុចំនួន ๖ លាន ๘ សែនរូបម្ខង សាវកសន្និបាត មានភិក្ខុ ๑ សែនរូបម្ខង សាវកសន្និបាត មានភិក្ខុ ๘ ហ្មឺនរូបម្ខង ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាតរបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទាំង ๓ ដងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត ๓ ដង គឺសាវកសន្និបាត មានភិក្ខុ ๑ សែនរូបម្ខង សាវកសន្និបាត មានភិក្ខុ ๘ ហ្មឺនរូបម្ខង សាវកសន្និបាតមានភិក្ខុ ๗ ហ្មឺនរូបម្ខង ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធទាំង ๓ ដងនេះ សុទ្ធតែជាខីណាស្រពទាំង

អស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគអរហន្ត សម្មាសម្ពុទ្ធ មានសាវកសន្និបាត ៣ ដង គឺសាវកសន្និបាត មានភិក្ខុ ៨ ហ្មឺនរូបម្ដង សាវកសន្និបាត មានភិក្ខុ ៧ ហ្មឺនរូបម្ដង សាវកសន្និបាត មានភិក្ខុ ៦ ហ្មឺនរូបម្ដង ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាតរបស់ព្រះវេស្សភូ មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធទាំង ៣ ដងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាតតែម្ដង មានភិក្ខុ ៤ ហ្មឺនរូប ។ ម្នាលភិក្ខុទាំងឡាយ សាវក-សន្និបាត របស់ព្រះកកុសន្ធៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធតែម្ដងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាតតែម្ដង មានភិក្ខុ ៣ ហ្មឺនរូប ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាត របស់ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធតែម្ដងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាតតែម្ដង មានភិក្ខុ ២ ហ្មឺនរូប ។ ម្នាលភិក្ខុទាំងឡាយ សាវក-សន្និបាតរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធតែម្ដងនេះ សុទ្ធតែជាខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត មានសាវកសន្និបាតតែម្ដង មានភិក្ខុ ១២៥០ រូប ។ ម្នាលភិក្ខុទាំងឡាយ សាវក-សន្និបាត របស់តថាគតតែម្ដងនេះ ក៏សុទ្ធតែជាខីណាស្រពទាំងអស់ ។

[๘] *ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ*

មានកិកុ្ខឈ្មោះអសោក:ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានកិកុ្ខឈ្មោះខេមង្ករ:ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវេស្សភូមានព្រះភាគអរហន្ត-សម្មាសម្ពុទ្ធ មានកិកុ្ខឈ្មោះឧបសន្ត: ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកកុសន្ធ:មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានកិកុ្ខឈ្មោះវុឍ្ឍិជ: ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកោនាគមន:មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានកិកុ្ខឈ្មោះសោត្ថិជ: ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានកិកុ្ខឈ្មោះសព្វមិត្ត: ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត មានកិកុ្ខឈ្មោះអានន្ទ ជាឧបដ្ឋាកអ្នកបម្រើដ៏ប្រសើរ ។

[៩] ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជា ទ្រង់ព្រះនាមពន្ធុម: ព្រះមាតាព្រះនាមពន្ធុ-មតីទេវី ជាព្រះរាជនេត្តី (មាតាបង្កើត) ព្រះនគរឈ្មោះពន្ធុមតី ជារាជ-ធានីនៃព្រះបាទពន្ធុម: ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះសិខីមាន ព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមអរុណ: ព្រះមាតាព្រះ នាមបភាវតីទេវី ជាព្រះរាជនេត្តី នគរឈ្មោះអរុណវតី ជារាជធានីនៃព្រះបាទ អរុណ: ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះវេស្សភូមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមសុប្បតីត: ព្រះមាតាព្រះនាម

ยสวตีเทวี ជាព្រះរាជនេត្តី នគរឈ្មោះអនោមៈ ជារាជធានីនៃព្រះបាទ
សុប្បតីតៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះកកុសន្ធៈមានព្រះភាគ
អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណ៍នាមអគ្គិទត្ត ព្រះមាតាជាព្រាហ្មណីនាម
វិសាខា ជាជនេត្តី ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រះរាជាព្រះ
នាមខេមៈ នគរឈ្មោះខេមវតី ជារាជធានីនៃព្រះបាទខេមៈ ។ ម្នាលភិក្ខុ
ទាំងឡាយ ព្រះបិតារបស់ព្រះកោនាគមនៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ
ជាព្រាហ្មណ៍នាមយញ្ញទត្ត ព្រះមាតាជាព្រាហ្មណីនាមឧត្តរា ជាព្រះជនេត្តី ។
ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង មានព្រះរាជាព្រះនាមសោភៈ នគរ
ឈ្មោះសោភវតី ជារាជធានីនៃព្រះបាទសោភៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រះ
បិតារបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រាហ្មណ៍នាម
ព្រហ្មទត្ត ព្រះមាតាជាព្រាហ្មណីនាមធនវតី ជាព្រះជនេត្តី ។ ម្នាលភិក្ខុទាំង-
ឡាយ សម័យនោះឯង ព្រះរាជាព្រះនាមកិកី នគរឈ្មោះពារាណសី ជា
រាជធានីនៃព្រះបាទកិកី ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ព្រះបិតារបស់
តថាគត ជាព្រះរាជាទ្រង់ព្រះនាមសុទ្ធោទនៈ ព្រះមាតាទ្រង់ព្រះនាមមាយា-
ទេវី ជាព្រះជនេត្តី ព្រះនគរឈ្មោះកបិលវត្ថុ ជារាជធានី ។ ព្រះមានព្រះភាគ
បានត្រាស់ពាក្យនេះហើយ លុះព្រះសុគតបានត្រាស់ពាក្យនេះចប់ហើយ ក៏
ទ្រង់ក្រោកចាកអាសនៈ ស្តេចចូលទៅកាន់ព្រះវិហារ ។

[១០] កាលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន ក្នុង
លំដាប់នោះ អន្តរាកថានេះក៏កើតឡើង ដល់ភិក្ខុទាំងនោះថា ម្នាលលោកមាន

អាយុទាំងឡាយ អស្សាវ្យណាស់ ម្នាលលោកមានអាយុទាំងឡាយ ហេតុនេះ មិនធ្លាប់ដែលមានឡើយ ព្រះតថាគតព្រះអង្គមានឫទ្ធិច្រើន មានអានុភាពច្រើន ណាស់ហ្ន៎ អម្បាលដូចព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេស ជាគ្រឿងញាំងសត្វឲ្យមានជំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញាំង សត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញាំងសត្វឲ្យវិលវល់ ទ្រង់ កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគតរឭកឃើញ ព្រះជាតិផង រឭកឃើញព្រះនាមផង រឭកឃើញព្រះគោត្រផង រឭកឃើញ ប្រមាណនៃព្រះជន្មាយុផង រឭកឃើញគូនៃសាវ័កផង រឭកឃើញសាវក-សន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ ព្រះមាន ព្រះភាគទាំងនោះ មានព្រះនាមយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មាន ព្រះគោត្រយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានសីលយ៉ាងនេះខ្លះ ព្រះ មានព្រះភាគទាំងនោះ មានធម៌យ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មាន ប្រាជ្ញាយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានវិហារធម៌យ៉ាងនេះខ្លះ ព្រះ មានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ ម្នាលអាវុសោទាំងឡាយ ធម្មធាតុណា ដែលព្រះតថាគតត្រាស់ដឹងហើយ ធម្មធាតុនុ៎ះ គឺព្រះតថាគត ត្រាស់ដឹងមែនឬ បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេស ជាគ្រឿងញាំងសត្វឲ្យមានជំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញាំង សត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញាំងសត្វឲ្យវិលវល់ ទ្រង់ កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រឭកឃើញ

ព្រះជាតិផង រឭកឃើញព្រះនាមផង រឭកឃើញព្រះគោត្រផង រឭកឃើញ ប្រមាណនៃជន្មាយុផង រឭកឃើញគូនៃសាវ័កផង រឭកឃើញសាវ័កសន្និបាត ផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាម យ៉ាងនេះខ្លះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌ យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះ ភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ឬថា ទេវតាទាំងឡាយ ក្រាបបង្គំទូលនូវ សេចក្តីនុ៎ះ ចំពោះព្រះតថាគតទេដឹង បានជាព្រះអតីតពុទ្ធទាំងឡាយ ដែល ទ្រង់ផ្តាច់ផ្តិល នូវកិលេសជាគ្រឿងញាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ ផ្តាច់ផ្តិល នូវកម្មជាគ្រឿងញាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជា គ្រឿងញាំងសត្វឲ្យវិលវល់ ទ្រង់កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅ ហើយ ក៏ព្រះតថាគតរឭកឃើញព្រះជាតិផង រឭកឃើញព្រះនាមផង រឭក ឃើញព្រះគោត្រផង រឭកឃើញប្រមាណនៃព្រះជន្មាយុផង រឭកឃើញគូ នៃសាវ័កផង រឭកឃើញសាវ័កសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះខ្លះ ។ មានព្រះគោត្រយ៉ាង នេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ នេះឯង ជាអន្តរកថា ដែលភិក្ខុទាំងនោះ (និយាយ) ហើយ បញ្ឈប់ទៅ ។

[๑๑] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុង សាយណ្ហសម័យ ស្តេចចូលទៅឯកុដិកវរិមណ្ឌល លុះចូលទៅដល់ហើយ

ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគគង់សឹប់ហើយ ទើបត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ប្រជុំគ្នា និយាយអ្វីហ្ន៎ អម្បាញ់មិញនេះ អន្តរាកថាដូចម្តេច ដែលអ្នកទាំងឡាយ បញ្ឈប់ទៅ ។ កាលបើ ព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះហើយ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន អន្តរាកថានេះ ក៏កើតឡើងដល់ខ្ញុំព្រះអង្គទាំងឡាយក្នុងទីនេះថា ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ហេតុមិនដែលមានក៏ទៅជាមាន ព្រះតថាគតទ្រង់មានឫទ្ធិច្រើន មានអានុភាពច្រើនណាស់ហ្ន៎ អម្បាលដូចព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្ម ជាគ្រឿងញាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្ម ជាគ្រឿងញាំងសត្វ ឲ្យវិលវល់ ទ្រង់កន្ធងនូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគតរឭកឃើញព្រះជាតិផង រឭកឃើញព្រះនាមផង រឭកឃើញព្រះគោត្រផង រឭកឃើញប្រមាណនៃព្រះជន្មាយុផង រឭកឃើញគូនៃសាវកផង រឭកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ ។បេ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ ម្នាលអាវុសោទាំងឡាយ ធម្មធាតុណា ដែលព្រះមានព្រះភាគត្រាស់ដឹងហើយដោយល្អ ធម្មធាតុនោះ ព្រះតថាគតត្រាស់ដឹងដោយល្អមែនឬ បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេស ជាគ្រឿងញាំងសត្វឲ្យមានដំណើរ

យើតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគតរឭកឃើញព្រះជាតិផង រឭកឃើញព្រះនាមផង រឭកឃើញព្រះគោត្រផង រឭកឃើញប្រមាណនៃព្រះជន្មាយុផង រឭកឃើញគូនៃសាវ័កផង រឭកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះខ្លះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ឬថា ទេវតាទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះតថាគតទេដឹង បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញុំាងសត្វឲ្យមានជំណើរយើតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្ម ជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏ព្រះតថាគត រឭកឃើញព្រះជាតិផង ទ្រង់រឭកឃើញព្រះនាមផង ។បេ។ រឭកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះខ្លះ ។បេ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ បពិត្រព្រះអង្គដ៏ចម្រើន អន្តរាកថានេះឯង ដែលខ្ញុំព្រះអង្គទាំងឡាយបញ្ឈប់ទៅ ព្រោះព្រះមានព្រះភាគស្តេចមកជល់ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មធាតុណា ដែលព្រះតថាគតត្រាស់ដឹងហើយដោយល្អ ធម្មធាតុ

*នុ៎ះ ព្រះតថាគតត្រាស់ដឹងឯងដោយល្អ ហើយបានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេស ជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវិល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏តថាគតរឭកឃើញព្រះជាតិផង រឭកឃើញព្រះនាមផង រឭកឃើញព្រះគោត្រផង រឭកឃើញប្រមាណនៃព្រះជន្មាយុផង រឭកឃើញគូនៃសាវ័កផង រឭកឃើញនូវសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះខ្លះ ។បេ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ទាំងពួកទេវតាក៏បានប្រាប់សេចក្តីនុ៎ះ ដល់តថាគតដែរ បានជាព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេស ជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏តថាគតរឭកឃើញព្រះជាតិផង រឭកឃើញព្រះនាមផង ។បេ។ រឭកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ មានព្រះនាមយ៉ាងនេះ ។បេ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយចង់ស្តាប់ធម្មីកថាដ៏ប្រកបដោយបុព្វនិវាស ឲ្យច្រើនជាងប្រមាណដែរឬទេ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរ ដើម្បីធ្វើនូវធម្មីកថានុ៎ះហើយ បពិត្រព្រះ

សុគត កាលនេះជាកាលគួរ ដើម្បីធ្វើនូវធម្មីកថានុ៎ះហើយ សូមព្រះមានព្រះភាគធ្វើនូវធម្មីកថា ដែលប្រកបដោយបុព្វេនិវាស ឲ្យច្រើនជាងប្រមាណចុះ ភិក្ខុទាំងឡាយបានស្តាប់ធម្មីកថារបស់ព្រះមានព្រះភាគហើយ ក៏នឹងចាំទុក ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយចាំស្តាប់ចុះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីកន្លួកប្បនេះ (ថយក្រោយទៅ) ៩១ កប្ប ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាខត្តិយជាតិ ទ្រង់កើតក្នុងខត្តិយ-ត្រកូល ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ មានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមដើមបាដលិព្រឹក្ស (ដើមជ្រៃ) ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មា-សម្ពុទ្ធ មានគូនៃសាវ័កដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះខណ្ឌៈ ១ តិស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវក-សន្និបាត ៣ ដង គឺសាវកសន្និបាត មានភិក្ខុ ៦ លាន ៨ សែនរូបម្តង សាវកសន្និបាតមានភិក្ខុ ១ សែនរូបម្តង សាវកសន្និបាតមានភិក្ខុ ៨ ហ្មឺនរូប

ម្ពង ។ ម្នាលភិក្ខុទាំងឡាយ សាវកសន្និបាតរបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទាំង ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះអសោកៈជាឧបដ្ឋាក អ្នកបម្រើដ៏ប្រសើ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមពន្ធុមៈ ព្រះមាតាព្រះនាមពន្ធុមតី ជាព្រះជនេត្តី នគរឈ្មោះពន្ធុមតី ជារាជធានីនៃព្រះបាទពន្ធុមៈ ។

[១២] ម្នាលភិក្ខុទាំងឡាយ កាលព្រះវិបស្សីពោធិសត្វ ច្យុតចាកឋានតុសិត ទ្រង់មានសតិសម្បជញ្ញៈ ចុះកាន់ផ្ទៃនៃព្រះមាតា ។ នេះជាធម្មតា (របស់ព្រះពោធិសត្វ) ក្នុងវេលាដែលចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

[១៣] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលពោធិសត្វ ច្យុតចាកស្ថានតុសិត ចុះកាន់ផ្ទៃនៃព្រះមាតា ។ គ្រានោះ ពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន ក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក៏កើតប្រាកដឡើងក្នុងលោក ដ៏កន្លងបង់នូវទេវានុភាពនៃទេវតាទាំងឡាយ ។ ឱកាសណាដែលចំហទេ នៅក្នុងទីបំផុតនៃលោក ឥតមានអ្វីបាំងរាំង មានតែអ័ព្ទងងឹត ព្រះចន្ទព្រះអាទិត្យទាំងនេះ សឹងមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ក៏ផ្សាយពន្លឺទៅមិនដល់ក្នុងទីណា ពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន កន្លងនូវទេវានុភាពនៃ

ទេវតាទាំងឡាយ ក៏កើតប្រាកដខ្សឺងក្នុងទីទាំងនោះ ។ ពួកសត្វណាដែលកើតខ្សឺងក្នុងទីទាំងនោះ សត្វអម្បាលនោះ ក៏ស្គាល់គ្នានិងគ្នាច្បាស់ដោយសារពន្លឺនោះថា អើហ្ន៎ មានពួកសត្វឯទៀតកើតក្នុងទីនេះដែរ ។ លោកធាតុទាំងមួយហ្មឺននេះ ក៏កក្រើករំពើក ញាប់ញ័រ ទាំងពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន ក៏កើតប្រាកដខ្សឺងក្នុងលោក កន្លងទេវានុភាពនៃទេវតាទាំងឡាយ ។ នេះជាធម្មតា (របស់ពោធិសត្វ) ក្នុងវេលាដែលចុះកាន់ផ្ទៃនៃព្រះមាតាន៎ុះ ។

[๑๔] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃព្រះមាតា មានទេវបុត្រ ๔ អង្គ តែងចូលទៅរក្សាក្នុងទិសទាំង ๔ ដោយគិតថា កុំឲ្យមនុស្ស និងអមនុស្សណានីមួយ បៀតបៀនព្រះពោធិសត្វ និងព្រះមាតានៃព្រះពោធិសត្វនោះបានឡើយ ។ នេះជាធម្មតាក្នុងវេលាដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតាន៎ុះ ។

[๑๕] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វ ជាអ្នកមានសីលដោយប្រក្រតី ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតាន៎ុះ ។

[๑๖] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វមិនមានចិត្តប្រកបដោយ

กามคุณក្នុងបុរសទាំងឡាយ ព្រះមាតានៃព្រះពោធិសត្វមិនដែលមានបុរសណាមួយ មានចិត្តត្រេកអរប្រព្រឹត្តកន្ទងបានឡើយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

[๑๗] *ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះពោធិសត្វតែងបានទូវកាមគុណទាំង ៥ ជាប្រក្រតី ។ ព្រះមាតានៃព្រះពោធិសត្វនោះ តែងស្កប់ស្កល់ប្រកបព្រម មានអ្នកផ្គាប់បម្រើដោយកាមគុណទាំង ៥ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។*

[๑๘] *ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា អាពាធណានីមួយ ក៏មិនកើតឡើងដល់ព្រះមាតានៃព្រះពោធិសត្វឡើយ ព្រះមាតានៃព្រះពោធិសត្វ មានតែសេចក្តីសុខជាប្រក្រតី មានកាយមិនបានលំបាក មួយទៀត មាតានៃព្រះពោធិសត្វតែងមើលឃើញព្រះពោធិសត្វ ហាក់ដូចជាបិតនៅក្រៅផ្ទៃ សព្វអវយវៈទាំងធំទាំងតូចមានឥន្ទ្រិយក៏មិនថោកថយ ។ ម្នាលភិក្ខុទាំងឡាយ កែវមណីពិទូរ្យដ៏ល្អ មានកំណើតដ៏បរិសុទ្ធ មានជ្រុង ๘ ដែលជាងថ្នៃល្អហើយ ដ៏ថ្លាស្អាតជ្រាសចាកមន្ទិល សមរម្យដោយអាការគ្រប់យ៉ាង ចេសពណ៌ខៀវក្តី ពណ៌លឿងក្តី ពណ៌ក្រហមក្តី ពណ៌សក្តី ពណ៌លឿងទុំក្តី ដែលគេដោតហើយក្នុងកែវនោះ បុរសដែលមានភ្នែក ដាក់កែវនោះលើដៃ ពិចារណាឃើញច្បាស់ថា កែវមណីពិទូរ្យនេះឯង ដ៏ល្អមានកំណើតបរិសុទ្ធ មានជ្រុង ๘ ដែលជាងបានថ្នៃ*

ល្អហើយ ដ៏ថ្លាស្អាតប្រាសចាកមន្ទិល សមរម្យដោយអាការគ្រប់យ៉ាង ចេស ពណ៌ខៀវក្តី ពណ៌លឿងក្តី ពណ៌ក្រហមក្តី ពណ៌សក្តី ពណ៌លឿងទុំក្តី ដែល គេដោតក្នុងកែវនោះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងកាល ដែលពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតា អាពាធណានីមួយ មិនដែលកើតឡើង ដល់ព្រះមាតាព្រះពោធិសត្វឡើយ ព្រះមាតានៃព្រះពោធិសត្វ ជាអ្នកមាន សេចក្តីសុខជាប្រក្រតី មានកាយមិនបានលំបាក មួយទៀត ព្រះមាតានៃព្រះ ពោធិសត្វ តែងមើលឃើញនូវព្រះពោធិសត្វ ហាក់ដូចជាស្ថិតនៅក្រៅផ្ទៃ ទាំងអវយវៈធំតូចទាំងអស់ មានឥន្ទ្រិយមិនថោកថយ មានឧបមេយ្យដូច្នោះ ឯង ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វចុះកាន់ផ្ទៃនៃព្រះមាតានុ៎ះ ។

[๑๙] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលព្រះពោធិសត្វ ប្រសូតមកបាន ๗ ថ្ងៃ ព្រះមាតានៃព្រះពោធិសត្វតែងធ្វើមរណកាលទៅកើត នៅស្ថានតុសិត ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃ នៃព្រះមាតានុ៎ះ ។

[๒๐] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺស្ត្រីទាំងឡាយជនៃតែង ទ្រទ្រង់គភ៌អស់ ៩ ខែខ្លះ ១០ ខែខ្លះ ទើបបានប្រសូត យ៉ាងណា ព្រះមាតា នៃព្រះពោធិសត្វមិនប្រសូតយ៉ាងនោះឡើយ ។ ព្រះមាតានៃព្រះពោធិសត្វតែង ទ្រទ្រង់គភ៌ពោធិសត្វអស់ ១០ ខែគត់ ទើបបានប្រសូត ។ នេះជាធម្មតា ក្នុង វេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៎ះ ។

[๒๑] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺស្ត្រីទាំងឡាយជនៃតែង

อฏฺฐ์ยสมฺโภลก์มาน เชกสมฺโภลก์มาน ย๊างณา ព្រះមาតានៃព្រះ ពោធិសត្វ ប្រសូតព្រះពោធិសត្វមិនមែនយ៉ាងដូច្នោះទេ ព្រះមាតានៃព្រះ ពោធិសត្វ រមែងស្ថិត (ឈរ) ប្រសូតព្រះពោធិសត្វ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតាន៎ុះ ។

[๒๒] *ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិ-សត្វប្រសូតចាកផ្ទៃនៃព្រះមាតា ទេវតាទាំងឡាយតែងទទួល (ព្រះពោធិសត្វ) មុន ទើបមនុស្សទាំងឡាយទទួលក្រោយ ។ នេះជាធម្មតា ក្នុងវេលាដែល ព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតាន៎ុះ ។*

[๒๓] *ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិ-សត្វប្រសូតចាកផ្ទៃនៃព្រះមាតា ព្រះពោធិសត្វមិនទាន់ចុះដល់ផែនដី មាន ទេវបុត្រទាំង ๔ ទទួលព្រះអង្គតម្កល់ក្នុងខាងមុខនៃព្រះមាតាថា បពិត្រព្រះ នាងទេវី សូមព្រះនាងមានចិត្តរីករាយចុះ បុត្ររបស់ព្រះនាងជាអ្នកមានសក្តិធំ ទ្រង់កើតឡើងហើយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វ ប្រសូត ចាកផ្ទៃនៃព្រះមាតាន៎ុះ ។*

[๒๔] *ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិ-សត្វប្រសូតចាកផ្ទៃនៃព្រះមាតាជ័ល្អល្អះ (ស្រស់បស់) ចេញមកមិនប្រឡាក់ ដោយទឹក (ភ្លោះ) មិនប្រឡាក់ដោយស្លេស្ម មិនប្រឡាក់ដោយឈាម មិន ប្រឡាក់ដោយអសោចិ៍ណានីមួយឡើយ ជាអ្នកស្អាតបរិសុទ្ធ ។ ម្នាលភិក្ខុ ទាំងឡាយ កែវមណី ដែលបុគ្គលដាក់ចុះលើកាសិកពស្ត្រ កែវមណី (នោះ)*

មិនប្រឡាក់នូវកាសិកពស្ត្រឡើយ កាសិកពស្ត្រក៏មិនប្រឡាក់នូវកែវមណីដែរ ហេតុអ្វីបានជាថាជូច្នោះ ព្រោះសំពត់ និងកែវមណីទាំងពីរជារបស់ស្អាត មានឧបមាជូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតាដ៏ល្អល្អះចេញមក មិនប្រឡាក់ដោយទឹក (ភ្លោះ) មិនប្រឡាក់ដោយស្លស្ម មិនប្រឡាក់ដោយឈាម មិនប្រឡាក់ដោយអសោចិ៍ ណានីមួយឡើយ ជាអ្នកស្អាតបរិសុទ្ធមានឧបមេយ្យជូច្នោះឯង ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៉ះ ។

[២៥] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលព្រះពោធិ-សត្វប្រសូតចាកផ្ទៃនៃព្រះមាតា មានធារទឹក ២ ហូរចុះមកអំពីអាកាស ធារទឹក ១ ត្រជាក់ ធារទឹក ១ ក្តៅ ធ្វើនូវការលាងជម្រះព្រះពោធិសត្វផង ព្រះមាតាផង ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតានុ៉ះ ។

[២៦] ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺកាលដែលព្រះពោធិ-សត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋាន (ឈរលើផែនដី) ដោយព្រះបាទជាន់ស៊ីប់ឆ្ពោះព្រះភក្ត្រទៅកាន់ទិសឧត្តរ ទ្រង់យាងឈានទៅបាន ៧ ជំហាន កាលដែលមហាជនកំពុងបាំងស្វេតច្ឆត្រថ្វាយ ក៏រមិលមើលនូវទិសទាំងពួងផង ទ្រង់ពោលនូវអាសភិវាចា គឺវាចាដ៏ឧត្តមផងថា អញជាបុគ្គលឧត្តង់ឧស់របស់លោក អញជាបុគ្គលធំបំផុតរបស់លោក អញជាបុគ្គលប្រសើរបំផុតរបស់លោក នេះជាកំណើតបំផុតរបស់អញ ឥឡូវនេះ ភពថ្មីតពីនេះទៅទៀតមិនមានឡើយ ។

នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតាន្ទុះ ។

[๒๗] *ម្នាលភិក្ខុទាំងឡាយ ទំនៀមនេះ គឺក្នុងកាលដែលពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតា គ្រានោះ ពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបានកើតប្រាកដឡើងក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្ម-លោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ ឱកាសណាដែលចំហទទេ នៅក្នុងទីបំផុតនៃលោក ឥតមានអ្វីបាំងរាំង មានតែអ័ព្ទងងឹតព្រះចន្ទ និងព្រះអាទិត្យមានឫទ្ធិយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ផ្សាយពន្លឺទៅមិនដល់ក្នុងទីណា ពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងទីទាំងនោះ កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ ពួកសត្វណាដែលកើតក្នុងទីទាំងនោះ សត្វអម្បាលនោះ ក៏ស្គាល់ច្បាស់នូវគ្នានិងគ្នាដោយសារពន្លឺនោះថា អើហ្ន៎ មានពួកសត្វដទៃ កើតក្នុងទីនោះដែរ ។ លោកធាតុ ๑ ហ្នឹងនេះ ក៏កក្រើករំពើកញាប់ញ័រ ទាំងពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោក កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។ នេះជាធម្មតា ក្នុងវេលាដែលព្រះពោធិសត្វប្រសូតចាកផ្ទៃនៃព្រះមាតាន្ទុះ ។*

[๒๘] *ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារប្រសូតមករួចហើយ រាជបុរសទាំងឡាយ ក៏ក្រាបបង្គំទូលព្រះបាទពន្ធុម:ថា បពិត្រព្រះសម្មតិទេព ព្រះរាជបុត្ររបស់ព្រះអង្គប្រសូតហើយ សូមព្រះអង្គទ្រង់ទតព្រះរាជបុត្រនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបាទពន្ធុម: ទ្រង់ទតឃើញព្រះ*

วิปสฺสีกุมาร លុះទ្រង់ឃើញហើយ ក៏ត្រាស់បង្គាប់ឲ្យហៅពួកព្រាហ្មណ៍ ជាហោរាមកហើយ មានព្រះរាជឱង្ការដូច្នេះថា ពួកព្រាហ្មណ៍ជាហោរាដ៏ចម្រើន ចូរមើលកុមារ (នេះ) ។ ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ជាហោរាក៏មើលនូវព្រះវិបស្សីកុមារនោះ លុះបានឃើញហើយ ក្រាបបង្គំទូលព្រះបាទពន្ធុមៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គមានព្រះហឫទ័យរីករាយ ព្រះរាជបុត្ររបស់ព្រះអង្គ មានសក្តិធំបានកើតឡើងហើយ បពិត្រមហារាជ ព្រះអង្គមានលាភហើយ បពិត្រមហារាជ ព្រះអង្គបានដោយល្អហើយ ព្រះរាជបុត្រដែលមានសភាពដូច្នេះ កើតឡើងក្នុងត្រកូលព្រះអង្គហើយ បពិត្រព្រះសម្មតិទេព ដ្បិតព្រះរាជកុមារនេះ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ឯមហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ រមែងមានគតិតែ ២ យ៉ាង មិនមានគតិដទៃទៀតទេ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ជាធម្មរាជប្រកបដោយធម៌ ជាក្សត្រឈ្នះសង្គ្រាម មានទីបំផុតទល់នឹងសមុទ្រទាំង ៤ មានជនបទដ៏មាំមួន ប្រកបដោយរតនៈ ៧ ប្រការ ឯរតនៈទាំង ៧ ប្រការរបស់ព្រះអង្គដូច្នេះ គឺចក្ករតន៍ (ចក្រកែវ) ហត្ថិរតន៍ (ដំរីកែវ) អស្សរតន៍ (សេះកែវ) មណិរតន៍ (កែវមណី) ឥត្ថីរតន៍ (ស្ត្រីកែវ) គហបតិរតន៍ (គហបតិកែវ) បរិនាយករតន៍ (នាយបរិនាយកកែវ) ជាគម្រប់ ៧ ព្រះអង្គមានព្រះរាជបុត្រច្រើនជាងពាន់ ជាអ្នកក្លៀវក្លា មានសភាពជាអ្នកព្យាយាម (ក្លាហាន) អាចញាំញីនូវសេនារបស់ស្តេចដទៃបាន ព្រះអង្គគ្របសង្កត់នូវផែនដីនេះ មានសាគរជា

ទីបំផុត ទ្រង់គ្រប់គ្រងដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើសស្ត្រាវុធ ឡើយ ប្រសិនបើទ្រង់ចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជា ព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកហើយ។ បពិត្រ ព្រះសម្មតិទេព ព្រះរាជកុមារនេះ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ដូចម្តេចខ្លះ មហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ រមែងមាន គតិតែ ២ យ៉ាង មិនមែនមានគតិដទៃទៀតឡើយ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិប្រកបដោយធម៌ ជាក្សត្រទ្រង់ធម៌ ជាក្សត្រឈ្នះ សង្គ្រាម មានទីបំផុតទល់នឹងសមុទ្រទាំង ៤ ព្រះអង្គមានជនបទដ៏មាំមួន ប្រកបដោយរតនៈ ៧ ប្រការ ឯរតនៈ ៧ ប្រការរបស់ព្រះអង្គដូច្នេះ គឺចក្ក-រតន៍ ។បេ។ ទ្រង់ឈ្នះគ្រប់សង្កត់ ប្រសិនបើព្រះកុមារនេះ ចេញចាកគេហ-ដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកហើយ ។

[๒๙] បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះមានព្រះបាទាប្រតិស្ឋាន ស៊ប់ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារដែលមានព្រះបាទាប្រតិស្ឋានស៊ប់ នេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរសនោះ ។បពិត្រព្រះសម្មតិទេព ចក្រទាំងឡាយកើតមានត្រង់ផ្ទៃព្រះបាទានៃព្រះរាជកុមារនេះ ប្រជាប់ដោយកាំ មួយពាន់ ព្រមទាំងខ្នងកង់ និងដុំមានចន្ទោះស្មើគ្នាគ្រប់អន្ទឺ បពិត្រព្រះ សម្មតិទេព ព្រះរាជកុមារដែលមានរូបចក្រកើតត្រង់ផ្ទៃនៃព្រះបាទាខាងក្រោម ប្រជាប់ដោយកាំមួយពាន់ ព្រមទាំងខ្នងកង់ និងដុំ មានចន្ទោះស្មើគ្នាគ្រប់អន្ទឺ

នេះ នេះឯងជាមហាបុរិសលក្ខណៈរបស់មហាបុរសនោះ ฯ

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះបណ្ហិ គឺ កែងព្រះបាទវែង ฯ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារ នេះ មានព្រះអង្គុលី គឺម្រាមព្រះហស្ត និងម្រាមព្រះបាទ វែង ฯ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានផ្ទៃ ព្រះហស្ត និងផ្ទៃព្រះបាទទន់ល្អន់ (ដូចជាដុំសំឡីដែលគេ ច្តចអស់មួយរយដង) ฯ បពិត្រព្រះសម្មតិទេព ព្រះរាជ-កុមារនេះ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទ ប្រទាក់ដោយ ក្រឡាដូចជាសំណាញ់ ฯ បពិត្រព្រះសម្មតិទេព ព្រះរាជ-កុមារនេះមានព្រះបាទ ដូចជាអណ្តែតឡើងខាងលើ (ហាក់ ដូចជាមិនជាប់គ្នានឹងខ្នងព្រះបាទ) ฯ បពិត្រព្រះសម្មតិ-ទេព ព្រះរាជកុមារនេះមានព្រះជង្ឃា គឺស្មង (រៀវ មូល ត្រសូល) ស្រដៀងនឹងស្មងសត្វទ្រាយ (ពុំនោះសោត ស្រដៀងនឹងបង្ហើមស្រូវ) ฯ បពិត្រព្រះសម្មតិទេព ព្រះ រាជកុមារនេះ កាលបើទ្រង់ព្រះសណ្ឋិត គឺទ្រង់ឈរមិន ឱនព្រះអង្គចុះ អាចសាបព្រះជាណុ គឺ ជង្គង់ ដោយផ្ទៃ ព្រះហស្តទាំង ๒ បាន ฯ បពិត្រព្រះសម្មតិទេព ព្រះរាជ-កុមារនេះ មានព្រះអង្គាវយវៈ ដែលគប្បីលាក់ឲ្យកំបាំង ដោយសំពត់ បិតនៅក្នុងស្រោម (ប្រហែលដូចជាអង្គ-

ជាតនៃដីរ ឬគោឈ្មោលជាដើម) ។ បពិត្រព្រះសម្មតិ-
ទេព ព្រះរាជកុមារនេះ មានព្រះឆវីវណ្ណ គឺសម្បុរ
(លឿងក្អែអន្ទង) ដូចជាសម្បុរនៃមាស ។ បពិត្រព្រះ
សម្មតិទេព ព្រះរាជកុមារនេះ មានព្រះឆវី គឺសម្បុរល្អិត
ផូរផង់រលើងស្រិលរអិលធូលីៗ ធ្លាក់មកត្រូវមិនជាប់ព្រះ
កាយ ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មាន
ព្រះលោមា គឺ រោមក្នុងរណ្តៅមួយៗ តែមួយសរសៃៗ
រាល់រណ្តៅ ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ
មានចុងព្រះលោមាងឡើងលើ ជាទក្ខិណាវដ្ត វិលវង់ព័ទ្ធ
ពេនទៅខាងស្តាំ មានពណ៌ខៀវស្រស់ ដូចជាពណ៌នៃផ្កា
អញ្ជន ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះមានព្រះ
កាយត្រង់ដូចជាកាយព្រហ្ម ។ បពិត្រព្រះសម្មតិទេព ព្រះ
រាជកុមារនេះមានព្រះមំសៈ គឺសាច់ ៧ អន្ទើ ពេញលេញ
(គឺត្រង់ខ្នងព្រះហស្តទាំង ២ ខ្នងព្រះបាទទាំង ២ ព្រះ
អង្សកូដ គឺចង្កេះស្មាទាំង ២ និងត្រង់ព្រះខន្ធប្បទេស
គឺព្រះក សរីរប្បទេសទាំង ៧ អន្ទើនេះ មានសាច់ពេញ
លេញល្អ ឥតមានឃើញសរសៃឡើយ) ។ បពិត្រព្រះ
សម្មតិទេព ព្រះរាជកុមារនេះ មានចំណែកកន្ទុះព្រះកាយ
ខាង ដើមស្រេជៀងគ្នានឹងចំណែកកន្ទុះកាយនៃរាជសីហ៍ ។

បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានចន្ទ្ទូរនៃព្រះ
បិដ្ឋិប្រទេសពេញបរិបូណ៌ គឺមានខ្នងពេញស្មើ ឥតមាន
ចន្ទ្ទូរផត ខូងត្រង់កណ្តាលឡើយ ។ បពិត្រព្រះសម្មតិទេព
ព្រះរាជកុមារនេះ មានទ្រង់ទ្រាយព្រះកាយ ប្រហែលនឹង
បរិមណ្ឌលនៃដើមជ្រៃ គឺមានកាយ និងព្យាមប្រវែងគ្នា
(ដូចជាជ្រៃមានប្រវែងដើម និងមែកមិនលើស មិនខ្វះ
ហួសគ្នាប៉ុន្មាន) ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារ
នេះមានព្រះខន្ធប្យទេស គឺព្រះសុរងមូលសម ។ បពិត្រ
ព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះប្រសាទ គឺ
សរសៃល្អិតធ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ ។
បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះហនុ គឺ
ចង្កាសណ្ឋានស្រដៀងនឹងចង្ការរាជសីហ៍ (ពេញបរិបូណ៌
ប្រហែលដូចព្រះចនុត្រង់ថ្ងៃ ១២ កើត) ។ បពិត្រព្រះ
សម្មតិទេព ព្រះរាជកុមារនេះ មានព្រះទន្ត គឺធ្មេញ ៤០
គត់ (ខាងលើ ២០ ខាងក្រោម ២០) ។ បពិត្រព្រះ
សម្មតិទេព ព្រះរាជកុមារនេះ មានព្រះទន្តរាបស្មើ (មិន
ប្រជួស ឬច្រពើសខ្ពស់ទាបឡើយ) ។ បពិត្រព្រះសម្មតិ-
ទេព ព្រះរាជកុមារនេះ មានរបៀបនៃព្រះទន្តជិតស្និទ្ធល្អ ។
បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះទាឋា គឺ

ព្រះចន្ទ្រមៈ (ទាំង ៤) សស្នាត (ភ្លឺរុងរឿងជាងពន្លឺផ្កាយព្រឹក) ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះជិវ្ហាដ៏ទន់ល្មមល្មៃ ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះសូរសៀង គឺសូរសព្ទសំឡេងក្រាងក្រអៅ ដូចជាសំឡេងនៃមហាព្រហ្ម កាលបើបញ្ចេញព្រះវាចា ឮពីរោះដូចជាសំឡេងនៃសត្វកវិក ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះនេត្រខៀវស្រស់ (ក្នុងទីដែលគួរខៀវ) ។ បពិត្រព្រះសម្មតិទេព ព្រះរាជ-កុមារនេះ មានដួងព្រះនេត្រ ស្រេជៀងនឹងដួងភ្នែកនៃគោ (មានដួងព្រះនេត្រទាំង ២ ថ្លាយង់ ស្រេជៀងនឹងដួងភ្នែកកូនគោសម្បុរក្រហម ដែលទើបនឹងសម្រាលមួយរំពេច) ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះឧណ្ណាលោម គឺរោមដុះត្រង់ចន្លោះព្រះភមូ (ចិញ្ចើម) មានសម្បុរសក្បុស ទន់ល្អន់ដូចជាសំឡី ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ មានព្រះសិរ្សៈហាក់ដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ (រុងរឿងដូចជាព្រះមហាក្សត្រ ដែលទ្រង់នូវក្បាំងព្រះភក្ត្រ) ។ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះ ដែលមានព្រះសិរ្សៈហាក់ដូចប្រដាប់ដោយក្បាំងស្រេចស្រាប់ ដោយហេតុណា ហេតុនេះ

ឯង ជាមហាបុរិសលក្ខណៈ របស់មហាបុរសនោះ ។

[๓๐] បពិត្រព្រះសម្មតិទេព ព្រះរាជកុមារនេះប្រកបដោយមហាបុរិសលក្ខណៈ ๓๒ ប្រការនេះឯង មហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ๓๒ ប្រការ រមែងមានគតិតែ ๒ យ៉ាង មិនមានគតិដទៃទៀតឡើយ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាក្សត្រទ្រង់ធម៌ ជាក្សត្រឈ្នះសង្គ្រាម មានទីបំផុតទល់នឹងសមុទ្រទាំង ๔ ព្រះអង្គមានជនបទដ៏មាំមួន ប្រកបដោយរតន: ๗ ប្រការ ឯរតន: ๗ ប្រការរបស់ព្រះអង្គ ដូច្នេះ គឺចក្រកែវ ដីរកែវ សេះកែវ កែវមណី ស្ត្រីកែវ គហបតិកែវ នាយបរិណាយកកែវ ជាគម្រប់ ๗ ព្រះអង្គមានព្រះរាជបុត្រច្រើនជាង៣ពាន់ ដ៏ក្លៀវក្លា មានសភាពជាអ្នកមានព្យាយាម អាចញាំញីនូវសេនារបស់ស្តេចដទៃបាន ព្រះអង្គគ្របសង្កត់នូវផែនដីនេះ ដែលមានសាគរជាទីបំផុត ទ្រង់គ្រប់គ្រងដោយធម៌ដ៏ស្មើ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើសស្ត្រាវុធឡើយ ប្រសិនបើទ្រង់ចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួសនឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកហើយ ។

[๓๑] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុម:ឲ្យព្រាហ្មណ៍ទាំងឡាយដែលជាហោរាស្ទង់ដណ្តប់សំពត់ថ្មីៗ ហើយឲ្យឆ្អែតស្កប់ស្កល់ដោយវត្ថុជាទីប្រាថ្នាទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទពន្ធុម:ទ្រង់ត្រាស់បង្គាប់ឲ្យមេដោះទាំងឡាយ បម្រើព្រះវិបស្សីកុមារ ។ ពួក

ស្ត្រីខ្ទះថ្វាយព្រះក្សីររស ស្ត្រីខ្ទះថ្វាយព្រះស្នាន (ផ្ទូតទឹក) ស្ត្រីខ្ទះថ្នាក់ថ្នម ស្ត្រីខ្ទះបីបមថ្នមព ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារ ប្រសូតមកហើយ រាជបុរសទាំងឡាយតែងបាំងនូវស្វេតច្ឆត្រទាំងថ្ងៃ ទាំងយប់ ដើម្បីកុំឲ្យត្រជាក់ ឬក្តៅ ស្មៅ ឬធូលី ឬទឹកសន្សើមពាល់ត្រូវបាន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលដែលព្រះវិបស្សីកុមារប្រសូតមកហើយ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើនគ្នា ។ ម្នាលភិក្ខុទាំងឡាយ ផ្ការឧប្បលក្តី ផ្ការឈូកក្រហមក្តី ផ្ការឈូសក្តី តែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើនគ្នា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមាររមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើនគ្នា ក៏មានឧបមេយ្យដូច្នោះឯង ។ មានតំណាលថា ព្រះវិបស្សីកុមារនោះ គេតែងដណ្តើមបីពផ្ទាស់ប្តូរគ្នា ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារប្រសូតមកហើយ មានសំឡេងស្រទន់ មានសំឡេងក្បោះក្បាយ មានសំឡេងផ្អែមល្ហែម មានសំឡេងគួរឲ្យអ្នកផងស្រឡាញ់ ។ ម្នាលភិក្ខុទាំងឡាយ សកុណជាតិឈ្មោះករវិក ដែលនៅលើភ្នំហេមពាន្តមានសំឡេងស្រទន់ មានសំឡេងក្បោះក្បាយ មានសំឡេងផ្អែមល្ហែម មានសំឡេងគួរឲ្យអ្នកផងស្រឡាញ់ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារក៏មានសំឡេងស្រទន់ មានសំឡេងក្បោះក្បាយ មានសំឡេងផ្អែមល្ហែម មានសំឡេងគួរឲ្យអ្នកផងស្រឡាញ់ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារ ប្រសូតមកហើយ មានចក្ខុដូចជាទិព្វកើតអំពីកម្មវិបាកកើតមានប្រាកដ អាច

មើលឃើញនូវទីឆ្ងាយចំនួនមួយយោជន៍ដោយជុំវិញបាន ទាំងវេលាថ្ងៃ ទាំងវេលាយប់ ។ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារដែលប្រសូតមកហើយ តែងសម្លឹងមើលមិនប៉ប្រិច ម្នាលភិក្ខុទាំងឡាយ ទេវតាទាំងឡាយដែលឋិតនៅក្នុងឋានត្រៃត្រឹង្ស តែងសម្លឹងមើលមិនប៉ប្រិច យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារក៏តែងសម្លឹងមើលមិនប៉ប្រិចយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារប្រសូតមកហើយ ព្រះនាមថា វិបស្សី ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈគង់ក្នុងទីជម្រះក្តី ទ្រង់ញុំាងព្រះវិបស្សីកុមារ ឲ្យគង់លើព្រះឧរុពិភាក្សាក្តីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មានតំណាលថា ក្នុងកាលនោះព្រះវិបស្សីកុមារ គង់នៅនាព្រះឧរុព្រះបិតា ពិចារណាទៅ ក៏ដឹងច្បាស់នូវសេចក្តីទាំងឡាយដោយញាណ ។ ព្រះវិបស្សីកុមារពិចារណាទៅហើយ ក៏ដឹងច្បាស់នូវក្តីដោយញាណ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះនាមថា វិបស្សី ក៏កើតឡើងដល់ព្រះវិបស្សីកុមារដោយសុសសាយទូទៅ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទពន្ធុមៈឲ្យជាងសង់ប្រាសាទ ៣ ខ្នងសម្រាប់ព្រះវិបស្សីកុមារ (គង់) គឺប្រាសាទ ១ សម្រាប់គង់ក្នុងវស្សានរដូវ ប្រាសាទ ១ សម្រាប់គង់ក្នុងហេមន្តរដូវ ប្រាសាទ ១ សម្រាប់គង់ក្នុងគិម្ហរដូវ មានកាមគុណ ៥ ផ្គត់ផ្គង់បម្រុងទុក ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងកាលនោះព្រះវិបស្សីកុមារមានសុទ្ធតែពួក (ស្ត្រី) ឥតមានបុរសបម្រើដោយតន្ត្រីទាំងឡាយ នៅលើប្រាសាទក្នុងវស្សានរដូវអស់

๔ ខែ មិនដែលចុះមកខាងក្រោមប្រាសាទឡើយ ฯ

ភាណវារៈទី ๑ ចប់

[๓๒] ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារ លុះកន្លងកាលច្រើនរយ ច្រើនពាន់ឆ្នាំទៅ ក៏ត្រាស់ហៅនាយសារថីមកថា ម្នាលនាយសារថី ជាសម្លាញ់ស្មើចិត្តអើយ ចូរឯងរៀបទីមនូវយានទាំងឡាយ ដែលល្អៗ យើងនឹងទៅកាន់ទីឧទ្យានមើលទីភូមិដ៏ល្អ ฯ ម្នាលភិក្ខុទាំងឡាយ ឯនាយសារថីក៏ទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ទីមនូវយានទាំងឡាយដែលល្អៗ រួចហើយ ក្រាបបង្គំទូលព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព យានទាំងឡាយល្អៗ ខ្ញុំព្រះអង្គទីមរួចហើយ ឥឡូវនេះសូមព្រះអង្គកំណត់នូវកាលដ៏គួរចុះ ฯ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីកុមារឡើងគង់យានដ៏ល្អ ចេញទៅកាន់ឧទ្យានដោយយានទាំងឡាយដែលល្អៗ ฯ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីកុមារកាលដែលស្តេចទៅកាន់ឧទ្យាន បានទតទៅឃើញបុរសចាស់ មានឆ្អឹងជំនីរដូចជាបង្គង់ មានខ្នងកោង មានឈើច្រត់ជាគ្រឿងទប់ទល់ កំពុងញាប់ញ័រ ក្រហល់ក្រហាយ មានវ័យកន្លងហើយ លុះឃើញហើយក៏ត្រាស់ហៅនាយសារថីមកថា ម្នាលនាយសារថីជាសម្លាញ់ស្មើចិត្តអើយ ចុះបុរសនេះធ្វើដូចម្តេច បានជាសក់គាត់មិនដូចជាសក់អ្នកឯទៀត ទាំងកាយគាត់ក៏មិនដូចកាយអ្នកឯទៀតដែរ ฯ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព នេះឯងហៅថា បុរសចាស់ ฯ ម្នាលនាយសារថីជាសម្លាញ់ស្មើចិត្តអើយ ចុះ

ដូចម្តេច បុរសនុ៎ះ បានជាឈ្មោះថា បុរសចាស់ ។ បពិត្រព្រះសម្មតិទេព ឯបុរសនេះ បានជាឈ្មោះថាបុរសចាស់ តពីនេះទៅនុ៎ះ គាត់នឹងមិនរស់នៅយូរប៉ុន្មានទេ ។ ម្នាលនាយសារថីជាសម្លាញ់ស្មើចិត្តអើយ ទុកជាអាត្មាអញត្រូវមានសេចក្តីចាស់ជាធម្មតា មិនកន្លងសេចក្តីចាស់ទៅបានទេឬដូចម្តេច ។ បពិត្រព្រះសម្មតិទេព មនុស្សទាំងអស់គ្នា ទោះព្រះអង្គក្តី យើងខ្ញុំទាំងឡាយក្តី សុទ្ធតែមានសេចក្តីចាស់ជាធម្មតា មិនកន្លងសេចក្តីចាស់ទៅបានទេ ។ ម្នាលនាយសារថីជាសម្លាញ់ស្មើចិត្តអើយ បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះល្មមប៉ុណ្ណឹងហើយ ឯងចូរត្រឡប់អំពីទីនេះទៅកាន់ខាងក្នុងបុរីវិញចុះ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីក៏ទទួលស្តាប់ព្រះបន្ទូល ព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់ទៅខាងក្នុងបុរីវិញទៅ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងកាលនោះព្រះវិបស្សីកុមារ លុះទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីព្រួយតូចព្រះទ័យសញ្ជប់សញ្ជឹងដោយព្រះតម្រិះថា ច្បីយ អើហ្ន៎ សេចក្តីចាស់តែងមានច្រកជដល់សត្វលោកដែលកើតហើយ ។

[๓๓] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះបាទពន្ធុមៈត្រាស់បង្គាប់ឲ្យរាជបុរសហៅនាយសារថីមកហើយ ទ្រង់មានព្រះបន្ទូលសួរថា នែនាយសារថីសម្លាញ់ស្មើចិត្តអើយ កុមារមានសេចក្តីត្រេកអរក្នុងឧទ្យានដែរឬ នែនាយសារថីសម្លាញ់ស្មើចិត្តអើយ កុមារមានចិត្តរីករាយក្នុងឧទ្យានដែរឬ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនមានសេចក្តី

ត្រេកអរក្នុងឧទ្យានទេ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនមានព្រះទ័យ រីករាយក្នុងឧទ្យានទេ ។ នែនាយសារថីសម្ងាញ់ស្មើចិត្តកាលដែលកុមារចេញ ទៅកាន់ឧទ្យាន បានឃើញអ្វីខ្លះដែរឬ ។ បពិត្រព្រះសម្មតិទេព កាលដែល ព្រះរាជកុមារស្តេចទៅកាន់ឧទ្យានបានទតឃើញបុរសចាស់ មានឆ្អឹងជំនីរដូច បង្គង់ មានខ្នងកោង មានឈើច្រត់ជាគ្រឿងទប់ទល់ កំពុងញ័ររន្ធត់ក្រហល់ ក្រហាយ មានវ័យកន្លងហើយ លុះទតឃើញហើយ ក៏មានព្រះបន្ទូលដូច្នេះ នឹងខ្ញុំព្រះអង្គថា នែនាយសារថីសម្ងាញ់ស្មើចិត្ត ចុះបុរសនោះដូចម្តេច បាន ជាសក់គាត់មិនដូចជាសក់អ្នកទាំងឡាយឯទៀត ទាំងកាយរបស់គាត់ក៏មិនដូច កាយអ្នកទាំងឡាយឯទៀតដែរ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិ-ទេព នុ៎ះឯងឈ្មោះថា បុរសចាស់ ព្រះរាជកុមារសួរទៀតថា នែនាយសារថី សម្ងាញ់ស្មើចិត្ត ចុះដូចម្តេចបុរសនុ៎ះ បានជាឈ្មោះថាចាស់ ខ្ញុំព្រះអង្គក្រាប បង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនោះបានជាឈ្មោះថាបុរសចាស់ ត ពីនេះទៅ គាត់នឹងមិនរស់នៅបានយូរប៉ុន្មានទេ ព្រះរាជកុមារសួរទៀតថា នែ នាយសារថីសម្ងាញ់ស្មើចិត្ត ទុកជាអាត្មាអញក៏មានសេចក្តីចាស់ជាធម្មតា មិន កន្លងនូវសេចក្តីចាស់ទៅបានទេឬដូចម្តេច ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រ ព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី ទោះយើងខ្ញុំទាំង-ឡាយក្តី សុទ្ធតែមានសេចក្តីចាស់ជាធម្មតា មិនកន្លងនូវសេចក្តីចាស់ទៅបាន ទេ្បីយ ព្រះរាជកុមារក៏មានព្រះបន្ទូលថា នែនាយសារថីសម្ងាញ់ស្មើចិត្ត បើ ដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះ ល្មមប៉ុណ្ណឹងហើយ ឯងចូរត្រឡប់អំពីទីនេះ

ទៅកាន់ខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គក៏ទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្ងៃវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់មកខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព ឯព្រះកុមារនោះ លុះទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខតូចព្រះទ័យ សញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ សេចក្តីចាស់តែងមានប្រាកដដល់សត្វលោកដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈ ទ្រង់មានព្រះតម្រិះដូច្នេះថា កុំឲ្យវិបស្សីកុមារខានសោយរាជ្យឡើយ កុំឲ្យវិបស្សីកុមារចេញចាកគេហដ្ឋានទៅបួសឡើយ កុំឲ្យពាក្យនៃពួកព្រាហ្មណ៍ជាហោរាទៀងឡើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទពន្ធុមៈទ្រង់ផ្គត់ផ្គង់បម្រុងកាមគុណ ៥ ឲ្យច្រើនឡើងទៀត ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារបានសោយរាជសម្បត្តិ ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារ ខានចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួស ធ្វើយ៉ាងណាឲ្យតែពាក្យនៃពួកព្រាហ្មណ៍ជាហោរាខុសទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ឮថា ក្នុងកាលនោះ ព្រះវិបស្សីកុមារឆ្អែតស្កប់ស្កល់មានគ្រប់ ព្រមដោយកាមគុណទាំង ៥ ។

[៣៤] ម្នាលភិក្ខុទាំងឡាយ លំដាប់តមក ព្រះវិបស្សីកុមារ (លុះកន្ទួងកាល) ច្រើនឆ្នាំទៅ ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលដែលព្រះវិបស្សីកុមារ ស្តេចទៅកាន់ឧទ្យានបានទតឃើញបុរសមានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ ដេកត្រាំក្នុងទឹកមូត្រ និងលាមករបស់ខ្លួន មានជនទាំងឡាយជនែលើកឲ្យក្រោកឡើង មានជនទាំងឡាយជនែផ្តេកឲ្យដេក លុះទតឃើញ

ហើយ គ្រាស់សួរនាយសារថីថា ម្នៃនាយសារថីសម្លាញ់ស្មើចិត្ត ចុះបុរសនេះធ្វើដូចម្តេច បានជាភ្នែករបស់គាត់មិនដូចភ្នែកពួកជនដទៃ ទាំងក្បាលរបស់គាត់ ក៏មិនដូចក្បាលនៃពួកជនដទៃ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះ ឈ្មោះថា បុរសឈើ ។ ម្នៃនាយសារថីសម្លាញ់ស្មើចិត្ត ចុះបុរសនុ៎ះ ព្រោះហេតុដូចម្តេច បានជាឈ្មោះថា បុរសឈើ ។ បពិត្រព្រះសម្មតិទេព បុរសនោះធ្វើដូចម្តេច នឹងឲ្យរួចចាកជំងឺនោះបាន (ព្រោះហេតុនោះ) បានជាឈ្មោះថា បុរសឈើ ។ ម្នៃនាយសារថីសម្លាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញ មានជំងឺជាធម្មតា មិនកន្ទងសេចក្តីឈឺចាប់ទៅបានទេឬដូចម្តេច ។ បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី ទោះយើងខ្ញុំទាំងឡាយក្តី សុទ្ធតែជាអ្នកមានជំងឺជាធម្មតា មិនកន្ទងសេចក្តីឈឺចាប់ទៅបានឡើយ ។ ម្នៃនាយសារថីសម្លាញ់ស្មើចិត្ត បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះ លួមប៉ុណ្ណឹងហើយ ឯងចូរប្រញាប់ចេញអំពីទីនេះ ត្រឡប់ទៅកាន់ខាងក្នុងបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីឧទ្យាននោះ ត្រឡប់មកកាន់ខាងក្នុងបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារលុះទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខតូចព្រះទ័យសញ្ជប់សញ្ជឹងថា ថ្លៃយ អើហ្ន៎ ជាតែងមានជ្រាកជ ព្យាធិតែងមានជ្រាកជ ដល់សត្វលោកដែលកើតហើយ ។

[๓๕] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទពន្ធុមៈទ្រង់មានព្រះបន្ទូលឲ្យហៅនាយសារថីមកហើយ ត្រាស់សួរដូច្នេះថា នែនាយសារថីសម្លាញ់ ស្មើចិត្ត កុមារមានសេចក្តីត្រេកអរក្នុងឧទ្យានដែរឬ នែនាយសារថីសម្លាញ់ ស្មើចិត្ត កុមារមានចិត្តរីករាយក្នុងឧទ្យានដែរឬ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនបានត្រេកអរក្នុងឧទ្យានទេ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនមានព្រះទ័យរីករាយក្នុងឧទ្យានទេ ។ នែនាយសារថីសម្លាញ់ស្មើចិត្ត ចុះកាលដែលកុមារទៅកាន់ឧទ្យាន បានឃើញអ្វីខ្លះ ។ បពិត្រព្រះសម្មតិទេព កាលដែលព្រះរាជកុមារស្តេចទៅកាន់ឧទ្យានបានឃើញបុរសមានអាពាធ ឈឺធ្ងន់ ដល់នូវសេចក្តីទុក្ខ ដេកនៅក្នុងទឹកមូត្រ និងលាមករបស់ខ្លួន ដែលជនទាំងឡាយដទៃកំពុងលើកឲ្យក្រោក ជនទាំងឡាយដទៃកំពុងផ្តេកឲ្យដេក លុះទតឃើញហើយ ក៏ទ្រង់ត្រាស់សួរខ្ញុំព្រះអង្គដូច្នេះថា ម្នែនាយសារថីជាសម្លាញ់ស្មើចិត្ត ចុះបុរសនេះធ្វើដូចម្តេច បានជាភ្នែករបស់គាត់មិនដូចភ្នែកពួកជនដទៃ ទាំងក្បាលរបស់គាត់ ក៏មិនដូចក្បាលពួកជនដទៃដែរ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ឯបុរសនុ៎ះ ឈ្មោះថា បុរសឈឺ ទើបព្រះរាជកុមារសួរទៀតថា នែនាយសារថីសម្លាញ់ស្មើចិត្ត ចុះបុរសនុ៎ះហេតុម្តេច បានជាឈ្មោះថា បុរសឈឺ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះធ្វើដូចម្តេចនឹងឲ្យរួចចាកជំងឺនោះបាន (ព្រោះហេតុនោះ) បានជាឈ្មោះថា បុរសឈឺ ទើបព្រះរាជកុមារសួរទៀតថា នែនាយសារថីជាសម្លាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញមានជំងឺជាធម្មតា មិន

កន្ទងសេចក្តីឈឺចាប់ទៅបានទេឬ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី ទោះយើងខ្ញុំទាំងឡាយក្តី សុទ្ធតែមានជំងឺជាធម្មតា មិនកន្ទងសេចក្តីឈឺចាប់ទៅបានទេ។ ឯព្រះរាជកុមារក៏មានព្រះបន្ទូលថា នែនាយសារថីសម្លាញ់ស្មើចិត្ត បើដូច្នោះ ការទៅក្នុងឧទ្យានក្នុងថ្ងៃនេះល្មមប៉ុណ្ណឹងហើយ ឯងចូរចេញអំពីទីនេះត្រឡប់ទៅកាន់ខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទទួលស្តាប់ព្រះបន្ទូលព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីឧទ្យាននោះ ត្រឡប់មកខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព លុះព្រះរាជកុមារនុ៎ះ ទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខតូចព្រះទ័យសញ្ជប់សញ្ជឹងថា ថ្លីយ អើហ្ន៎ ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដ ដល់សត្វលោកដែលកើតហើយ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទពន្ធុមៈ មានព្រះតម្រិះដូច្នេះថា កុំឲ្យវិបស្សីកុមារខានសោយរាជ្យឡើយ កុំឲ្យវិបស្សីកុមារបានចេញចាកគេហដ្ឋានទៅបួសឡើយ កុំឲ្យពាក្យនៃពួកព្រាហ្មណ៍ជាហោរាទៀងឡើយ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈផ្គត់ផ្គង់បម្រុងកាមគុណទាំង ៥ ច្រើនឡើងទៀត ធ្វើយ៉ាងណា ឲ្យតែព្រះវិបស្សីកុមារនៅសោយរាជសម្បត្តិបាន ធ្វើយ៉ាងណា ឲ្យតែព្រះវិបស្សីកុមារ ខានចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួស ធ្វើយ៉ាងណាឲ្យ តែពាក្យនៃពួកព្រាហ្មណ៍ជាហោរាខុសទៅវិញ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារ ទ្រង់ឆ្អែត

สัปปัสสัล ประกอบพร้อมด้วยกามคุณทั้ง ๕ ฯลฯ

[๓๖] ดูกรภิกษุทั้งหลาย ก็สมัยนั้นแล ท่านพระวิปัสสีกุมารเข้าไปสู่อุทยานด้วยรถอันประเสริฐ ได้ทอดพระเนตรเห็นหมู่ชนเป็นอันมาก กำลังประชุมกันทำเครื่องสักการะ ด้วยผ้าและของหอมหลากสี ครั้นแล้ว ได้ตรัสถามนายสารถีว่า ดูกรนายสารถีผู้เจริญ เหตุไรหมู่ชนเป็นอันมากนี้ จึงประชุมกันทำเครื่องสักการะด้วยผ้าและของหอมหลากสี ครั้นแล้ว เพื่อประโยชน์อะไร ฯ นายสารถีกราบทูลว่า ข้าแต่พระสมมติเทพ บุรุษผู้นี้ชื่อว่าผู้ตายแล้ว ฯ ดูกรนายสารถีผู้เจริญ ถ้าอย่างนั้น เธอจงนำรถเข้าไปยังที่ที่บุรุษนั้นตายแล้ว ฯ ดูกรภิกษุทั้งหลาย นายสารถีรับพระดำรัสของท่านพระวิปัสสีกุมารแล้ว ได้นำรถเข้าไปยังที่ที่บุรุษนั้นตายแล้ว ฯ ดูกรภิกษุทั้งหลาย ท่านพระวิปัสสีกุมาร ได้ทอดพระเนตรเห็นบุรุษผู้ตายแล้วนั้น ครั้นแล้ว ได้ตรัสถามนายสารถีว่า ดูกรนายสารถีผู้เจริญ ก็เหตุไรบุรุษนี้ จึงชื่อว่าผู้ตายแล้ว ฯ นายสารถีกราบทูลว่า ข้าแต่พระสมมติเทพ บุรุษนี้ชื่อว่าผู้ตายแล้ว เพราะเหตุว่า ในกาลบัดนี้ มารดาก็ดี บิดาก็ดี ญาติสาโลหิตทั้งหลายก็ดี ไม่ได้เห็นบุรุษนั้นแล้ว ทั้งบุรุษนั้นก็ไม่ได้เห็นมารดาบิดา และญาติสาโลหิตทั้งหลายเหมือนกัน ฯ

ហៃនាយសារថី ជាសម្ភាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញមានសេចក្តីស្ងាប់ជាធម្មតា មិនកន្ធងសេចក្តីស្ងាប់ទៅបាន ទោះព្រះបរមបពិត្រ (ជាព្រះវរបិតា) ក្តី ព្រះនាងទេវី (ជាព្រះវរមាតា) ក្តី ព្រះញាតិសាលោហិតទាំងឡាយជនៃក្តី លែងបានឃើញនូវអាត្មាអញ ទាំងអាត្មាអញក៏លែងបានឃើញនូវព្រះបរមបពិត្រ ព្រះនាងទេវី និងព្រះញាតិសាលោហិតទាំងឡាយជនៃដែរ ឬជួចម្តេច ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី យើងខ្ញុំទាំងឡាយក្តី សុទ្ធតែមានសេចក្តីស្ងាប់ជាធម្មតា មិនកន្ធងសេចក្តីស្ងាប់ទៅបានទេឬយ ទាំងព្រះបរមបពិត្រក្តី ព្រះនាងទេវីក្តី ព្រះញាតិសាលោហិតទាំងឡាយជនៃក្តី ក៏លែងបានឃើញព្រះអង្គ ទាំងព្រះអង្គសោត ក៏លែងបានឃើញព្រះបរមបពិត្រ ព្រះនាងទេវី និងព្រះញាតិសាលោហិតទាំងឡាយជនៃដែរ ។ ហៃនាយសារថី ជាសម្ភាញ់ស្មើចិត្ត បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះ ល្មមប៉ុណ្ណឹងហើយ ឯងចូរចេញអំពីទីនេះ ត្រឡប់ទៅកាន់ខាងក្នុងបុរីវិញចុះ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារ ដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់មកខាងក្នុងនៃបុរីវិញ ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារ លុះស្តេចទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខតូចព្រះទ័យសញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដ មរណៈតែងមានប្រាកដដល់សត្វលោកដែលកើតហើយ ។

[๓๗] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈទ្រង់ត្រាស់បង្គាប់ឲ្យរាជបុរសហៅនាយសារថីមកហើយ ទ្រង់មានព្រះបន្ទូលសួរដូច្នេះថា នែនាយសារថីជាសម្លាញ់ស្មើចិត្ត កុមារមានសេចក្តីត្រេកអរចំពោះឧទ្យានដែរឬ នែនាយសារថីជាសម្លាញ់ស្មើចិត្ត កុមារមានចិត្តរីករាយក្នុងឧទ្យានដែរឬ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនបានត្រេកអរចំពោះឧទ្យានទេ បពិត្រព្រះសម្មតិទេព ព្រះរាជកុមារមិនមានព្រះទ័យរីករាយក្នុងឧទ្យានទេ ។ នែនាយសារថីជាសម្លាញ់ស្មើចិត្ត ចុះកាលដែលកុមារចេញទៅកាន់ឧទ្យាន បានឃើញអ្វីខ្លះ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព កាលដែលព្រះរាជកុមារស្តេចទៅកាន់ឧទ្យាន បានទតពពួកមហាជនកំពុងប្រជុំគ្នា ធ្វើគ្រឿងសែងដោយសំពត់ទាំងឡាយមានពណ៌ក្រហមផ្សេងៗ លុះទតឃើញហើយ ទ្រង់មានព្រះបន្ទូលដូច្នេះនឹងខ្ញុំព្រះអង្គថា នែនាយសារថីជាសម្លាញ់ស្មើចិត្ត ពពួកមហាជននោះប្រជុំគ្នាធ្វើគ្រឿងសែងដោយសំពត់ទាំងឡាយ មានពណ៌ក្រហមផ្សេងៗ ដើម្បីអ្វី ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯងឈ្មោះថាធ្វើមរណកាលហើយ ទើបព្រះរាជកុមារបង្គាប់ខ្ញុំព្រះអង្គថា ម្នៃនាយសារថីជាសម្លាញ់ស្មើចិត្ត បើដូច្នោះ បុរសនោះធ្វើមរណកាលក្នុងទីណា ចូរបររថទៅក្នុងទីនោះ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គក៏ទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយក៏បររថសំដៅទៅទីដែលបុរសធ្វើមរណកាលនោះ (បឋមនៅ) បពិត្រព្រះសម្មតិ-

ទេព ព្រះរាជកុមារក៏បានទតឃើញបុរស ដែលធ្វើមរណកាលទៅកាន់លោកខាងមុខ លុះទតឃើញហើយ ទ្រង់មានព្រះបន្ទូលដូច្នេះនឹងខ្ញុំព្រះអង្គថា ម្នៃនាយសារថីជាសម្ងាញ់ស្មើចិត្ត ចុះបុរសនុ៎ះ ហេតុដូចម្តេចបានជាឈ្មោះថាធ្វើមរណកាល ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ឯបុរសនុ៎ះបានជាឈ្មោះថា ធ្វើមរណកាល (ព្រោះថា) ក្នុងកាលឥឡូវនេះ មាតាក្តី បិតាក្តី ញាតិសាលោហិតទាំងឡាយជនៃក្តី លែងបានឃើញបុរសនោះហើយ ទាំងបុរសនោះសោត ក៏លែងបានឃើញមាតាបិតា និងញាតិសាលោហិតទាំងឡាយជនៃដែរ ទើបព្រះរាជកុមារត្រាស់សួរទៀតថា ម្នៃនាយសារថីជាសម្ងាញ់ស្មើចិត្ត ចុះចំណែកអាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ទោះព្រះបរមបពិត្រក្តី ព្រះនាងទេវីក្តី ព្រះញាតិសាលោហិតទាំងឡាយជនៃក្តី លែងបានឃើញអាត្មាអញ ហើយទាំងអាត្មាអញសោត ក៏លែងបានឃើញព្រះបរមបពិត្រ ព្រះនាងទេវី និងញាតិសាលោហិតទាំងឡាយជនៃដែរឬ ខ្ញុំព្រះអង្គក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព មនុស្សទាំងឡាយគ្រប់គ្នា ទោះព្រះអង្គក្តី យើងខ្ញុំទាំងឡាយក្តី សុទ្ធតែមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន ទាំងព្រះបរមបពិត្រក្តី ព្រះនាងទេវីក្តី ព្រះញាតិសាលោហិតទាំងឡាយជនៃក្តី នឹងលែងបានឃើញព្រះអង្គ ទាំងព្រះអង្គសោត ក៏នឹងលែងបានឃើញព្រះបរមបពិត្រ ព្រះនាងទេវី ព្រះញាតិសាលោហិតទាំងឡាយជនៃដែរ ទើបព្រះរាជកុមារមានព្រះបន្ទូលថា ម្នៃនាយសារថីជាសម្ងាញ់ស្មើចិត្ត បើដូច្នោះ ការទៅឧទ្យាន

ក្នុងថ្ងៃនេះ ល្ងាចប៉ុណ្ណឹងហើយ ចូរចេញអំពីទីនេះ ត្រឡប់ទៅខាងក្នុងបុរីវិញចុះ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះអង្គ ព្រះករុណាវិសេស ហើយក៏ចេញអំពីទីនោះ ត្រឡប់មកខាងក្នុងបុរីវិញ បពិត្រព្រះសម្មតិទេព ឯព្រះរាជកុមារនោះ លុះស្តេចទៅដល់ខាងក្នុងបុរីហើយ ក៏មានសេចក្តីទុក្ខ តូចព្រះទ័យ សញ្ជប់សញ្ជឹងថា ថ្វីយ អើហ្ន៎ ជរាតែងមានប្រាកដ ព្យាធិតែងមានប្រាកដ មរណៈតែងមានប្រាកដ ដល់សត្វលោកដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទពន្ធុមៈទ្រង់មានព្រះតម្រិះដូច្នេះថា កុំឲ្យវិបស្សីកុមារខានសោយរាជ្យឡើយ កុំឲ្យវិបស្សីកុមារបានចេញចាកគេហដ្ឋាន ទៅបួសឡើយ កុំឲ្យពាក្យរបស់ពួកព្រាហ្មណ៍ជាហោរាពិតឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទពន្ធុមៈទ្រង់ផ្គត់ផ្គង់កាមគុណទាំង ៥ ច្រើនឡើងទៀត ធ្វើយ៉ាងណា ឲ្យតែព្រះវិបស្សីកុមារសោយរាជសម្បត្តិបាន ធ្វើយ៉ាងណាឲ្យតែព្រះវិបស្សីកុមារខានចេញចាកគេហដ្ឋានទៅបួស ធ្វើយ៉ាងណាឲ្យតែពាក្យរបស់ពួកព្រាហ្មណ៍ជាហោរាទៅជាពាក្យខុស ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងកាលនោះ ព្រះវិបស្សីកុមារទ្រង់ឆ្អែតស្កប់ស្កល់ប្រកបព្រមដោយកាមគុណទាំង ៥ ។

[๓๘] ម្នាលភិក្ខុទាំងឡាយ លំដាប់តមក ព្រះវិបស្សីកុមារលុះកន្លងឆ្នាំច្រើនរយ ច្រើនពាន់ទៅ ទ្រង់ហៅនាយសារថីមកថា ម្នាលនាយសារថីជាសម្លាញ់ស្មើចិត្ត ចូរឯងទីមយានទាំងឡាយដែលល្អៗ យើងនឹងទៅកាន់ឧទ្យាន

ដើម្បីមើលនូវទីល្អៗ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះអង្គ ព្រះគុណាវិសេស ហើយក៏ទឹមយានទាំងឡាយដែលល្អៗ រួចក្រាបបង្គំទូលដល់ព្រះវិបស្សីកុមារថា បពិត្រព្រះសម្មតិទេព យានទាំងឡាយដែលល្អៗ ខ្ញុំព្រះអង្គបានទឹមស្រេចហើយ ឥឡូវនេះសូមទ្រង់ជ្រាបនូវកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីកុមារទ្រង់ឡើងកាន់យានដ៏ល្អ ហើយស្តេចទៅកាន់ឧទ្យានដោយយានទាំងឡាយដ៏ល្អៗ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះវិបស្សីកុមារស្តេចទៅកាន់ឧទ្យានក៏បានទតឃើញបុរសមានសីសៈរលីង ជាអ្នកបួស ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ លុះឃើញហើយទ្រង់សួរនាយសារថីថា ម្នាលសារថីជាសម្លាញ់ស្មើចិត្ត ចុះបុរសនុ៎ះធ្វើដូចម្តេច បានជាក្បាលរបស់គាត់មិនដូចជាក្បាលពួកជនដទៃ ទាំងសំពត់របស់គាត់ក៏មិនដូចជាសំពត់ពួកជនដទៃដូច្នេះ ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះឯងឈ្មោះថា អ្នកបួស ។ ម្នាលសារថីជាសម្លាញ់ស្មើចិត្ត ចុះបុរសនោះ ហេតុដូចម្តេច បានជាឈ្មោះថាអ្នកបួស ។ នាយសារថីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនុ៎ះបានជាឈ្មោះថាអ្នកបួស ព្រោះប្រព្រឹត្តធម៌ដោយប្រពៃ ព្រោះប្រព្រឹត្តនូវធម៌ដ៏ស្មើដោយប្រពៃ ព្រោះប្រព្រឹត្តកុសលដោយប្រពៃ ព្រោះធ្វើអំពើបុណ្យដោយប្រពៃ ព្រោះមិនបានបៀតបៀនដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយប្រពៃ ។ ម្នាលសារថីជាសម្លាញ់ស្មើចិត្ត បុរសនោះ ឈ្មោះថា អ្នកបួស ព្រោះប្រព្រឹត្តធម៌ដោយប្រពៃ ព្រោះប្រព្រឹត្តធម៌ដ៏

ស្មើដោយប្រពៃ ព្រោះប្រព្រឹត្តកុសលដោយប្រពៃ ព្រោះធ្វើអំពើបុណ្យដោយប្រពៃ ព្រោះមិនបានបៀតបៀនដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយប្រពៃ ជាការស្រួលពិត ម្នាយសារថីជាសម្ងាញ់ស្មើចិត្ត បើដូច្នោះ ចូរអ្នកបររថទៅត្រង់ទីដែលអ្នកបួសនោះឋិតនៅចុះ ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះអង្គព្រះករុណាវិសេស ហើយក៏បររថទៅត្រង់អ្នកបួសនោះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីកុមារទ្រង់មានព្រះបន្ទូលសួរដូច្នេះនឹងអ្នកបួសនោះថា នែអ្នកជាសម្ងាញ់ស្មើចិត្ត ចុះអ្នកធ្វើដូចម្តេច បានជាក្បាលរបស់អ្នកមិនដូចជាក្បាលពួកជនដទៃ ទាំងសំពត់របស់អ្នកក៏មិនដូចជាសំពត់ពួកជនដទៃ ដូច្នេះ ។ អ្នកបួសថ្វាយព្រះពរថា បពិត្រព្រះសម្មតិទេព អាត្មាភាពហ្នឹងហើយ ដែលហៅថា អ្នកបួស ។ នែអ្នកជាសម្ងាញ់ស្មើចិត្ត ព្រោះហេតុដូចម្តេច បានជាអ្នក ឈ្មោះថា អ្នកបួស ។ បពិត្រព្រះសម្មតិទេព អាត្មាភាពហ្នឹងឯង បានជាឈ្មោះថា អ្នកបួស ព្រោះប្រព្រឹត្តធម៌ដោយប្រពៃ ព្រោះប្រព្រឹត្តធម៌ដ៏ស្មើដោយប្រពៃ ព្រោះប្រព្រឹត្តកុសលដោយប្រពៃ ព្រោះធ្វើអំពើបុណ្យដោយប្រពៃ ព្រោះមិនបានបៀតបៀនដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយប្រពៃ ។ ព្រះវិបស្សីកុមារមានព្រះរាជឱង្ការថា នែអ្នកជាសម្ងាញ់ស្មើចិត្ត អ្នកឈ្មោះថា អ្នកបួស ព្រោះប្រព្រឹត្តធម៌ដោយប្រពៃ ព្រោះប្រព្រឹត្តធម៌ដ៏ស្មើដោយប្រពៃ ព្រោះប្រព្រឹត្តកុសលដោយប្រពៃ ព្រោះធ្វើអំពើបុណ្យដោយប្រពៃ ព្រោះមិនបានបៀតបៀនដោយប្រពៃ ព្រោះអនុគ្រោះដល់សត្វដោយ

ប្រពៃ ជាការល្អណាស់ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះវិបស្សី-កុមារទ្រង់មានព្រះរាជឱង្ការនឹងនាយសារថីថា ម្នៃនាយសារថីជាសម្លាញ់ស្មើចិត្ត បើដូច្នោះ ចូរឯងនាំយករថចេញអំពីទីនេះ ត្រឡប់ទៅខាងក្នុងបុរីវិញចុះ ចំណែកអញនឹងកោរសក់ ពុកមាត់ ពុកចង្កា ស្បៀកជណ្តប់សំពត់កាសាយៈទាំងឡាយ លះគេហដ្ឋានបួសក្នុងទីនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នាយសារថីទទួលស្តាប់ព្រះបន្ទូលនៃព្រះវិបស្សីកុមារដោយពាក្យថា បពិត្រព្រះអង្គព្រះកុណាវិសេស ហើយក៏នាំយករថចេញអំពីទីនោះ ត្រឡប់ទៅខាងក្នុងបុរីវិញ ។ ព្រះវិបស្សីកុមារទ្រង់ជាក់ព្រះកេសា និងព្រះមស្សុ ទ្រង់កាសាវ-ពស្ត្រទាំងឡាយ លះគេហដ្ឋាន ទ្រង់ព្រះផ្នួសក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ឯពពួកមហាជនក្នុងពន្ធុមតីរាជធានី ប្រមាណ ៨ ហ្មឺន ៤ ពាន់នាក់ បានឮដំណឹងថា ព្រះវិបស្សីកុមារទ្រង់ជាក់ព្រះកេសា និងព្រះមស្សុ ទ្រង់កាសាវពស្ត្រទាំងឡាយ លះគេហដ្ឋាន ទ្រង់ព្រះផ្នួសហើយ ។ លុះពពួកមហាជនទាំងនោះ បានឮដំណឹងហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះវិបស្សីកុមារទ្រង់ជាក់ព្រះកេសា និងព្រះមស្សុ ទ្រង់កាសាវពស្ត្រទាំង-ឡាយ លះគេហដ្ឋាន ទៅទ្រង់ព្រះផ្នួសចំពោះធម្មវិន័យ និងបព្វជ្ជាណា ធម្ម-វិន័យ និងបព្វជ្ជានោះ មិនថោកទាបឡើយ អម្បាលព្រះវិបស្សីកុមារម្តេច ទ្រង់ជាក់ព្រះកេសា និងព្រះមស្សុ ទ្រង់កាសាវពស្ត្រទាំងឡាយ លះគេហ-ដ្ឋាន ទ្រង់ព្រះផ្នួសទៅហើយ ចុះយើងរាល់គ្នាម្តេចក៏មិនបួស ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ពពួកមហាជនទាំង ៨ ហ្មឺន ៤ ពាន់នាក់ ក៏កោរ

សក់ ពុកមាត់ ពុកចង្កា ស្បៀកជណ្តប់សំពត់កាសាយៈទាំងឡាយ ហើយ បួសតាមព្រះវិបស្សីពោធិសត្វ ដែលចេញចាកព្រះរាជនិវេសន៍ ទ្រង់ព្រះផ្នួស ក្នុងកាលនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ព្រះវិបស្សីពោធិសត្វមានពួកបរិសទ្យទាំងនោះហែហម ស្តេចទៅកាន់ចារិក ក្នុងស្រុក និគម ជនបទ រាជធានីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វទៅគង់ក្នុងទីស្ងាត់ ទ្រង់ពួនសម្ងំនៅ ក៏មានសេចក្តីត្រិះរិះក្នុងព្រះទ័យដូច្នេះថា អាត្មាអញដែលនៅច្របូកច្របល់នេះ ជាការមិនសមគួរទេ្បីយ គួរតែអាត្មាអញចេញចាកពួកទៅនៅតែម្នាក់ឯង ។ ម្នាលភិក្ខុទាំង-ឡាយ លុះសម័យជាខាងក្រោយមក ព្រះវិបស្សីពោធិសត្វចេញចាកពួកទៅគង់តែមួយព្រះអង្គ ។ ឯពួកបព្វជិតទាំង ៨ ហ្មឺន ៤ រូបនោះ ក៏បានទៅនៅដោយឡែកផ្សេង ។ ព្រះវិបស្សីពោធិសត្វ ក៏ចេញទៅនៅដោយឡែកផ្សេង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្វចូលទៅគង់សម្ងំ នៅក្នុងទីស្ងាត់ មានសេចក្តីត្រិះរិះក្នុងព្រះទ័យយ៉ាងនេះថា ឱសត្វលោកនេះ ដល់នូវសេចក្តីលំបាកណាស់តើ រមែងកើតហើយចាស់ៗ ហើយ ស្លាប់ៗ ហើយ ច្យុតៗ ហើយកើតឡើងទៀត ប៉ុន្តែមិនដឹងច្បាស់នូវធម៌ជាគ្រឿងរលាស់ខ្លួនចេញចាកទុក្ខនេះទេ្បីយ បើមិនដឹងច្បាស់នូវធម៌ជាគ្រឿងរលាស់ចេញចាកទុក្ខ គឺជរា និងមរណៈនេះហើយ កាលណាទេ្បីយនឹងធ្វើនូវការរលាស់ចេញចាកទុក្ខ គឺជរា និងមរណៈឲ្យច្រាកដឡើងបាន ។

[៣៩] *ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មាន*

សេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីហ្ន៎មានទៀង ទើបមានជរា និងមរណៈ ជរា និងមរណៈកើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលបើជាតិមានហើយ ទើបមានជរា និងមរណៈ ជរា និងមរណៈកើតមានព្រោះជាតិជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះទៀតថា កាលធម្មជាតអ្វីមានហ្ន៎ ទើបកើតមានជាតិ ជាតិកើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យ ដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលភពមាន ជាតិក៏មាន ជាតិកើតមាន ព្រោះភពជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ ភពទើបកើតមាន ភពកើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលឧបាទានកើតមាន ភពក៏កើតមាន ភពកើតមានព្រោះឧបាទានជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ ទើបឧបាទានកើតមាន ឧបាទានកើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលតណ្ហាកើតមាន ឧបាទានទើបកើតមាន ឧបាទានកើតមាន

ព្រោះតណ្ហាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ តណ្ហាទើបកើតមាន តណ្ហាកើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលវេទនាកើតមាន តណ្ហាទើបកើតមាន តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ វេទនាទើបកើតមាន វេទនាកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលផស្សៈកើតមាន វេទនាទើបកើតមាន វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ ផស្សៈទើបកើតមាន ផស្សៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលសឡាយតនៈកើតមាន ផស្សៈទើបកើតមាន ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ សឡាយតនៈទើបកើតមាន សឡាយតនៈកើតមាន ព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះ

ទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះប្រាជ្ញាថា កាលនាម រូបកើតមាន សឡាយតនៈទើបកើតមាន សឡាយតនៈកើតមាន ព្រោះនាម រូបជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីពោធិសត្វមាន សេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ នាមរូបទើបកើតមាន នាមរូប កើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះវិបស្សីពោធិសត្វ ទ្រង់ធ្វើទុកក្នុងព្រះទ័យដោយព្រះយោបល់ ក៏ទ្រង់ឈ្វេងយល់ដោយព្រះ ប្រាជ្ញាថា កាលវិញ្ញាណកើតមាន នាមរូបទើបកើតមាន នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សី-ពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមានហ្ន៎ វិញ្ញាណទើប កើតមាន វិញ្ញាណកើតមានព្រោះអ្វីជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះ វិបស្សីពោធិសត្វទ្រង់ធ្វើទុកក្នុងព្រះទ័យ ដោយព្រះយោបល់ ក៏ទ្រង់ឈ្វេង យល់ដោយព្រះប្រាជ្ញាថា កាលនាមរូបកើតមាន វិញ្ញាណទើបកើតមាន វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់ នោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា វិញ្ញាណនេះ តែង ត្រឡប់ទៅ ត្រឡប់មក មិនទៅហួសខាងនាយអំពីនាមរូបឡើយ ដោយហេតុ មានប្រមាណប៉ុណ្ណេះ ជាន់ជាសត្វកើតហើយចាស់ៗ ហើយស្លាប់ៗ ច្យុតៗ ហើយកើតឡើងទៀត វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យ នាមរូប កើតមានព្រោះ វិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជា បច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះ

ផស្សៈជាបច្ចយ តណ្ហាកើតមាន ព្រោះវេទនាជាបច្ចយ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ចយ ភពកើតមាន ព្រោះឧបាទានជាបច្ចយ ជាតិកើតមាន ព្រោះភពជាបច្ចយ ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ចយ សោកៈ បរិទេវៈ (សេចក្តីខ្សឹកខ្សួល) ទុក្ខ ទោមនស្ស និងឧបាយាសៈ (ទង្គឹះក្នុងចិត្ត) ក៏កើតមានព្រម ការកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុន កើតឡើងដល់ព្រះវិបស្សីពោធិសត្វថា កើតឡើង កើតឡើងហ្ន៎ ។

[๔๐] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបជរា និងមរណៈមិនមាន ជរា និងមរណៈរលត់ទៅព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលជាតិមិនមាន ជរា និងមរណៈក៏មិនមាន ការរលត់ទៅនៃជរា និងមរណៈ ព្រោះរលត់ជាតិដូច្នេះ ក៏កើតមានឡើងដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបជាតិមិនមាន ការរលត់ទៅនៃជាតិ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលបើភពមិនមាន ជាតិក៏មិនមាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភពដូច្នេះ កើតមានឡើងដល់ព្រះវិបស្សីពោធិសត្វ

ព្រោះទ្រង់ពិចារណា ដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបភពមិនមាន ការរលត់ទៅនៃភព ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលឧបាទានមិនមាន ភពក៏មិនមាន ការរលត់ទៅនៃភព ព្រោះរលត់ឧបាទានដូច្នេះ ក៏កើតមានឡើងដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណា ដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបឧបាទានមិនមាន ការរលត់ទៅនៃឧបាទាន ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលតណ្ហាមិនមាន ឧបាទានក៏មិនមាន ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហាដូច្នេះ ក៏កើតមានឡើងដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបតណ្ហាមិនមាន ការរលត់ទៅនៃតណ្ហា ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលវេទនាមិនមាន តណ្ហាក៏មិនមាន ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនាដូច្នេះ ក៏កើតមានឡើងដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎

ទើបវេទនាមិនមាន ការរលត់ទៅនៃវេទនា ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលផស្សៈមិនមាន វេទនាក៏មិនមាន ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈដូច្នេះ ក៏កើតឡើងដល់ព្រះវិបស្សីពោធិសត្ត ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្តមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្នឹ ទើបផស្សៈមិនមាន ការរលត់ទៅនៃផស្សៈ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលសឡាយតនៈមិនមាន ផស្សៈក៏មិនមាន ការរលត់ទៅនៃផស្សៈ ព្រោះរលត់សឡាយតនៈដូច្នេះ ក៏កើតឡើងដល់ព្រះវិបស្សីពោធិសត្ត ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្តមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្នឹ ទើបសឡាយតនៈមិនមាន ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលនាមរូបមិនមាន សឡាយតនៈក៏មិនមាន ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូបដូច្នេះ ក៏កើតមានឡើងដល់ព្រះវិបស្សីពោធិសត្ត ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្តមានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្នឹ ទើបនាមរូបមិនមាន ការរលត់ទៅនៃនាមរូប ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹង

ដោយព្រះប្រាជ្ញាថា កាលវិញ្ញាណមិនមាន នាមរូបក៏មិនមាន ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណដូច្នេះ ក៏កើតឡើងដល់ព្រះវិបស្សីពោធិសត្វ ព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះថា កាលធម្មជាតអ្វីមិនមានហ្ន៎ ទើបវិញ្ញាណមិនមាន ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ធម្មជាតអ្វី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ សេចក្តីត្រាស់ដឹងដោយព្រះប្រាជ្ញាថា កាលនាមរូបមិនមាន វិញ្ញាណក៏មិនមាន ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់នាមរូបដូច្នេះ ក៏កើតឡើងដល់ព្រះវិបស្សីពោធិសត្វព្រោះទ្រង់ពិចារណាដោយព្រះយោបល់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះវិបស្សីពោធិសត្វមានសេចក្តីត្រិះរិះដូច្នេះថា វិបស្សនាមគ្គនេះ អាត្មាអញបានត្រាស់ដឹងហើយ ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់នាមរូប ការរលត់ទៅនៃនាមរូប ព្រោះរលត់វិញ្ញាណ ការរលត់ទៅនៃសឡាយតនៈ ព្រោះរលត់នាមរូប ការរលត់ទៅនៃផស្សៈ ព្រោះរលត់សឡាយតនៈ ការរលត់ទៅនៃវេទនា ព្រោះរលត់ផស្សៈ ការរលត់ទៅនៃតណ្ហា ព្រោះរលត់វេទនា ការរលត់ទៅនៃឧបាទាន ព្រោះរលត់តណ្ហា ការរលត់ទៅនៃភព ព្រោះរលត់នៃឧបាទាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរា និងមរណៈរលត់ ព្រោះរលត់ជាតិ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសៈក៏រលត់ទៅ ការរលត់ទៅនៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុ ញាណ បញ្ញា វិជ្ជា ពន្លឺ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុន

ក៏កើតឡើងដល់ព្រះវិបស្សីពោធិសត្វថា រលត់ រលត់ហ្ន៎ ។

[៤១] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ លុះសម័យជាខាងក្រោយមក ព្រះវិបស្សីពោធិសត្វ ទ្រង់ពិចារណានូវការកើត និងការរលត់ទៅ ក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបយ៉ាងនេះ ការកើតឡើងនៃរូបយ៉ាងនេះ ការរលត់ទៅនៃរូបយ៉ាងនេះ វេទនាយ៉ាងនេះ ការកើតឡើងនៃវេទនាយ៉ាងនេះ ការរលត់ទៅនៃវេទនាយ៉ាងនេះ សញ្ញាយ៉ាងនេះ ការកើតឡើងនៃសញ្ញាយ៉ាងនេះ ការរលត់ទៅនៃសញ្ញាយ៉ាងនេះ សង្ខារទាំងឡាយយ៉ាងនេះ ការកើតឡើងនៃសង្ខារទាំងឡាយយ៉ាងនេះ ការរលត់ទៅនៃសង្ខារទាំងឡាយយ៉ាងនេះ វិញ្ញាណយ៉ាងនេះ ការកើតឡើងនៃវិញ្ញាណយ៉ាងនេះ ការរលត់ទៅនៃវិញ្ញាណយ៉ាងនេះ ។ កាលដែលព្រះវិបស្សីពោធិសត្វ ទ្រង់ពិចារណានូវកិរិយាកើតឡើង និងការរលត់ទៅក្នុងឧបាទានក្ខន្ធទាំង ៥ មិនយូរប៉ុន្មាន ព្រះទ័យនៃព្រះអង្គក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទាន ។

ទុតិយភាណវារៈ ចប់

[៤២] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា គួរតែតថាគតសម្តែងធម៌ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា ធម៌ដែលតថាគតត្រាស់ដឹងហើយនេះ ជាធម៌ជ្រាលជ្រៅ បុគ្គលឃើញបានដោយក្រ ត្រាស់ដឹងតាមបានដោយក្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ថ្លៃថ្លា ជាធម៌ដែលបុគ្គលត្រិះរិះយកឯងមិនបាន ជាធម៌ល្អិត មាន

តែបណ្ឌិតទើបដឹងបាន ក៏ពួកសត្វនេះមានអាល័យ គឺកាមគុណជាទីត្រេកអរ ត្រេកអរក្នុងកាមគុណ រីករាយក្នុងកាមគុណ បដិច្ចសមុប្បាទដែលមានកាម-គុណនេះជាបច្ច័យ បដិច្ចសមុប្បាទនេះជាហានៈ ដែលពួកសត្វមានកាមគុណជាទីត្រេកអរ ត្រេកអរក្នុងកាមគុណ រីករាយក្នុងកាមគុណ ឃើញបានដោយក្រ ធម៌ដែលជាគ្រឿងរម្ងាប់នូវសង្ខារទាំងពួង លះបង់នូវឧបក្កិលេសទាំងពួង អស់ទៅនៃតណ្ហា ប្រាសចាករាគៈ រលត់ (នូវកងទុក្ខ) និងព្រះនិព្វាន នេះឯងក៏ជាហានៈ ដែលពួកសត្វឃើញបានដោយក្រ បើទុកជាតថាគតសម្តែងធម៌ ពួកសត្វដទៃក៏មិនគប្បីដឹងច្បាស់បាន សេចក្តីលំបាកកាយនោះនឹងមានដល់តថាគត ការបៀតបៀនកាយនោះនឹងមានដល់តថាគត ។ ម្នាលភិក្ខុទាំងឡាយ មិនតែប៉ុណ្ណោះ មានសេចក្តីតំណាលថា គាថាទាំងឡាយនេះដ៏ចម្លែក ដែលព្រះពុទ្ធវិបស្សី ទ្រង់មិនធ្លាប់បានឮក្នុងកាលមុន ក៏ច្បាស់ប្រាកដដល់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធថា

> ឥឡូវនេះ តថាគតគួរនឹងសម្តែងធម៌ ដែលតថាគតបានត្រាស់ដឹងដោយកម្រ សត្វទាំងឡាយដែលរាគៈ ទោសៈ គ្របសង្កត់ ក៏មិនងាយនឹងត្រាស់ដឹងធម៌នេះបានឡើយ ។ សត្វទាំងឡាយអ្នកត្រេកត្រអាលដោយរាគៈ ដែលគំនរនៃឆងឹត គឺអវិជ្ជាកំពុងចាក់ស្រែះ មុខជានឹងមិនឃើញធម៌ដែលនាំសត្វឲ្យដល់នូវព្រះនិព្វាន ជាធម៌ល្អិតសុខុមជ្រាលជ្រៅ ដែលសត្វឃើញដោយកម្រ ។

[๔๓] ម្នាលភិក្ខុទាំងឡាយ កាលព្រះវិបស្សីមានព្រះភាគអរហន្ត សម្មាសម្ពុទ្ធ ពិចារណាឃើញដោយសេចក្តីត្រិះរិះដូច្នេះហើយ ព្រះហឫទ័យឱនទៅរកសេចក្តីខ្ជិលច្រអាយតិច មិនឱនទៅរកការសម្តែងធម៌ឡើយ ។

[๔๔] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្ម ๑ រូប បានដឹងនូវបរិវិតក្ក ក្នុងព្រះហឫទ័យនៃព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ដោយចិត្តរបស់ខ្លួនហើយ ទើបគិតរំពឹងដូច្នេះថា ឱសត្វលោក វិនាសតើ ឱសត្វលោកវិនាសតើ ព្រោះព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ មានព្រះហឫទ័យឱនទៅរកសេចក្តីខ្ជិលច្រអាយតិច មិនឱនទៅរកការសម្តែងធម៌ឡើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្មនោះ ក៏បាត់អំពីព្រហ្មលោក មកប្រតិស្ឋានក្នុងទីចំពោះព្រះភក្ត្រនៃព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ប្រៀបដូចបុរសមានកម្លាំងលាចេញនូវកំភួនដៃដែលបត់ចូល ឬបត់ចូលនូវកំភួនដៃដែលលាចេញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្មធ្វើនូវសំពត់បាំងកៀងស្មាម្ខាង លុតចុះនូវមណ្ឌលនៃជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលីចំពោះព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ក៏ក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌ សូមព្រះសុគតទ្រង់សម្តែងធម៌ (ដ្បិត) សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលី គឺរាគាទិក្កិលេស ក្នុងចក្ខុស្រាលស្តើងក៏មាន តែមិនបានស្តាប់ធម៌ មុខជានឹងសាបសូន្យមិនខាន ពួកសត្វដែលបម្រុងនឹងត្រាស់ដឹងធម៌ ក៏គង់មាន

ដែរ ។ ម្នាលភិក្ខុទាំងឡាយ កាលមហាព្រហ្មក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ក៏ត្រាស់ដូច្នេះនឹងមហាព្រហ្មនោះ ថា ម្នាលព្រហ្ម តថាគតមានសេចក្តីត្រិះរិះថា គួរតែតថាគតសម្តែងធម៌ដូច្នេះ ដែរ ។ ម្នាលព្រហ្ម តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ធម៌ដែលតថាគតត្រាស់ដឹងហើយនេះ ជាធម៌ជ្រាលជ្រៅ សត្វឃើញបានដោយក្រ ត្រាស់ដឹងបានដោយក្រ ជាធម៌រម្ងាប់ទុក្ខ ជាធម៌ថ្លៃថ្លា ជាធម៌ដែលបុគ្គលត្រិះរិះយកឯងមិនបាន ជាធម៌ល្អិត មានតែបណ្ឌិតទើបដឹងបាន ពួកសត្វនេះមានអាល័យ គឺ កាមគុណជាទីត្រេកអរ ត្រេកអរក្នុងកាមគុណ រីករាយក្នុងកាមគុណ បដិច្ចសមុប្បាទដែលមានកាមគុណនេះជាបច្ច័យ បដិច្ចសមុប្បាទនេះ ជាហានៈដែលពួកសត្វមានកាមគុណជាទីត្រេកអរ ត្រេកអរក្នុងកាមគុណ រីករាយក្នុងកាមគុណ ឃើញបានដោយក្រ ធម៌ដែលជាគ្រឿងរម្ងាប់នូវសង្ខារទាំងពួង លះបង់នូវឧបក្កិលេសទាំងពួង អស់ទៅនៃតណ្ហា ប្រាសចាកវាគៈ រម្ងាត់ (នូវកងទុក្ខ) និងព្រះនិព្វាន នេះឯងជាហានៈដែលពួកសត្វឃើញបានដោយក្រ បើទុកជាតថាគតសម្តែងធម៌ ពួកសត្វដទៃ មិនគប្បីអាចដឹងច្បាស់បាន សេចក្តីលំបាកកាយនោះ នឹងមានដល់តថាគត ការបៀតបៀននោះនឹងមានដល់តថាគត ។ ម្នាលព្រហ្ម មិនតែប៉ុណ្ណោះ មានសេចក្តីតំណាលថា គាថាទាំងឡាយនេះ ចម្លែកដែរ ដែលតថាគតមិនធ្លាប់បានឮក្នុងកាលមុន ក៏ច្បាស់ប្រាកដដល់តថាគតថា

ឥឡូវនេះ តថាគតគួរសម្តែងធម៌ ដែលតថាគត បាន

ตฺรัสรู้ดีแล้วโดยประการใด ฯลฯ กำลังทำให้แจ้งชัดอยู่ ฯ

ดูก่อนพราหมณ์ ก็ตถาคตพิจารณาเห็นดังนี้แล้ว จิตของตถาคตก็น้อมไปเพื่อความเกษมจากโยคะ ไม่น้อมไปเพื่อการแสดงธรรม ฯ ดูก่อนภิกษุทั้งหลาย มหาพราหมณ์นั้น ได้กราบทูลอนุโมทนาถึงสองครั้ง ฯลฯ ดูก่อนภิกษุทั้งหลาย มหาพราหมณ์นั้น ได้กราบทูลพระวิปัสสีมีพระภาค อรหันตสัมมาสัมพุทธ ดังนี้ว่า ขอพระมีพระภาคเจ้าโปรดทรงทราบ ขอพระสุคตโปรดทรงทราบ (ซึ่งกาล) สัตว์ทั้งหลายในโลกนี้ ที่มีธุลี คือกิเลสเล็กน้อย เกิดในจักษุ แต่ไม่ได้สดับธรรม มีความเสื่อมเป็นธรรมดา ย่อมมีแน่ ฯ ดูก่อนภิกษุทั้งหลาย ลำดับนั้น พระวิปัสสีมีพระภาค อรหันตสัมมาสัมพุทธ ทรงรับคำของมหาพราหมณ์แล้ว ก็ทรงตรวจดูหมู่สัตว์โลก ด้วยพุทธจักษุ เพื่ออาศัยความกรุณาในสัตว์ทั้งหลาย ฯ ดูก่อนภิกษุทั้งหลาย ครั้นพระวิปัสสีมีพระภาค อรหันตสัมมาสัมพุทธ ทรงตรวจดูหมู่สัตว์โลก ด้วยพุทธจักษุ ได้ทรงเห็นสัตว์ทั้งหลายพวกที่มีธุลี คือราคะกิเลสเล็กน้อย เกิดในจักษุ พวกที่มีธุลี คือกิเลสใหญ่ เกิดในจักษุ พวกที่มีอินทรีย์แก่กล้า พวกที่มีอินทรีย์อ่อน พวกที่มีอาการดี พวกที่มีอาการชั่ว พวกที่สอนให้รู้ได้ง่าย พวกที่สอนให้รู้ได้ยาก พวกที่มีปกติเห็นโลกหน้าและโทษ พวกที่ไม่มีปกติเห็นอย่างนั้น ครั้นแล้วได้ตรัสกะพราหมณ์ชั้นผู้ใหญ่ ฯ ดอกอุบลชนิดหนึ่งๆ คือ

ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹកនៅឡើយ ផ្កាជលជាតពួកខ្លះ គឺផ្កាព្រលឹតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក ផ្កាជលជាតពួកខ្លះ គឺផ្កាព្រលឹតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ដែលដុះក្នុងទឹក ចម្រើនក្នុងទឹក ដុះខ្ពស់ឡើងជាងទឹក មិនជាប់ប្រឡាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ប្រមើលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ក៏ទ្រង់ឃើញនូវសត្វទាំងឡាយពួកខ្លះមានធូលី គឺរាគាទិក្កិលេសតិចក្នុងចក្ខុ ខ្លះមានធូលី គឺរាគាទិក្កិលេសច្រើនក្នុងចក្ខុ ខ្លះមានឥន្ទ្រិយក្លៀវក្លា ខ្លះមានឥន្ទ្រិយទន់ ខ្លះមានអាការល្អ ខ្លះមានអាការអាក្រក់ ខ្លះពន្យល់បានដោយងាយ ខ្លះពន្យល់បានដោយក្រ ខ្លះមានកព្វ ខ្លះឥតកព្វ ខ្លះជាអ្នកឃើញនូវទោស ក្នុងបរលោកជាសភាវៈគួរខ្លាច ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ មហាព្រហ្មបានដឹងបរិវិតក្កក្នុងហឫទ័យរបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដោយចិត្តរបស់ខ្លួនហើយ ក៏ក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដោយគាថាទាំងឡាយថា

[๔๕] *បុរសមានចក្ខុ ឈរលើកំពូលភ្នំថ្មសុទ្ធ*
មើលឃើញប្រជុំជន ដោយជុំវិញ មានឧបមាយ៉ាងណា

มิញ បពិត្រព្រះអង្គ៌អ្នកមានប្រាជ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គ៌ជាអ្នកមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ស្តេចឡើងកាន់ប្រាសាទ គឺព្រះធម៌ ប្រមើលមើលនូវប្រជុំជនអ្នកច្របូកច្របល់ដោយសេចក្តីសោក ដែលជាតិ ជរាកំពុងគ្របសង្កត់ មានឧបមេយ្យយ៉ាងនោះ ។ បពិត្រព្រះអង្គ៌អ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម អ្នកដឹកនាំពួកវេនេយ្យសត្វ អ្នកឥតបំណុល សូមព្រះអង្គ៌ក្រោកឡើង ត្រាច់ទៅក្នុងលោក សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌ សត្វទាំងឡាយដែលបម្រុងនឹងត្រាស់ដឹងធម៌ ក៏មានដែរ ។

[៤៦] ម្នាលភិក្ខុទាំងឡាយ កាលមហាព្រហ្មក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់នឹងមហាព្រហ្មនោះ ដោយព្រះគាថាដូច្នេះថា

ទ្វារនៃព្រះនិព្វាន គឺអរិយមគ្គបើកដល់អ្នកហើយ សត្វទាំង-ឡាយណា មានសោតបសាទ សត្វទាំងនោះ ចូរបញ្ចេញនូវសទ្ធាមកចុះ ម្នាលព្រហ្ម តថាគតសម្គាល់នូវសេចក្តីនឿយលំបាក បានជាមិនទាន់សម្តែងធម៌ដ៏ឧត្តម ដែលតថាគតសូត្រហើយ ក្នុងសំណាក់មនុស្សទាំងឡាយ ។

[៤៧] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មហាព្រហ្មជ្រាបថា អាត្មា

អញ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ បានប្រទានឧកាស ដើម្បីនឹងសម្តែងធម៌ដូច្នេះហើយ ក៏ថ្វាយបង្គំលាព្រះវិបស្សីមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ ធ្វើប្រទក្សិណ ហើយក៏បាត់អំពីទីនោះទៅ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីមានព្រះភាគអរហន្ត សម្មាសម្ពុទ្ធ ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាមុនហ្នឹ អ្នកណាអាចដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា ព្រះរាជបុត្រព្រះនាមខណ្ឌ: និងកូនបុរោហិតឈ្មោះតិស្ស:នេះ ជាបណ្ឌិត ជាអ្នកឈ្លាសវៃ ជាអ្នកមានប្រាជ្ញា មានធូលី គឺរាគាទិក្កិលេសតិចក្នុងចក្ខុ អាស្រ័យនៅក្នុងរាជធានីឈ្មោះពន្ធុមតី ជាយូរអង្វែងហើយ បើដូច្នោះ គួរតែតថាគតសម្តែងធម៌ដល់រាជបុត្រព្រះនាមខណ្ឌ: និងកូនបុរោហិតឈ្មោះតិស្ស:ជាមុនចុះ ជនទាំងនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលភិក្ខុទាំងឡាយ រៀលានោះ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់បាត់អំពីទីជិតនៃពោធិព្រឹក្ស ទៅប្រាកដឯខេមមិគទាយវ័ន ក្នុងនគរពន្ធុមតីរាជធានី មានឧបមាដូចជាបុរសមានកម្លាំងលានូវកំភួនដៃដែលបត់ចូលឬបត់ចូលនូវកំភួនដៃដែលលាដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ហៅទាយបាលមកថា ម្នាលសម្លាញ់ទាយបាល អ្នកចូរមកនេះ អ្នកចូរទៅកាន់ពន្ធុមតីរាជធានីហើយ និយាយយ៉ាងនេះនឹងរាជបុត្រនាមខណ្ឌ: និងកូនបុរោហិតឈ្មោះ

តិស្សៈថា ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្តេចមកដល់នគរ
ពន្ធុមតីរាជធានីហើយ ឥឡូវទ្រង់គង់នៅក្នុងខេមមិគទាយវន ព្រះអង្គចង់ជួប
នឹងអ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯទាយបាលបានទទួលព្រះពុទ្ធ
តម្រាស់ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ដោយពាក្យថា បពិត្រ
ព្រះអង្គដ៏ចម្រើន ព្រះករុណាដូច្នេះហើយ ក៏ចូលទៅកាន់ពន្ធុមតីរាជធានី បាន
និយាយនឹងព្រះខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រដូច្នេះថា ព្រះវិបស្សី
មានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្តេចមកដល់នគរពន្ធុមតីរាជធានីហើយ
ឥឡូវទ្រង់គង់នៅក្នុងខេមមិគទាយវន ព្រះអង្គចង់ជួបនឹងអ្នកទាំងឡាយ ។
ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រ ក៏
បង្គាប់ឲ្យទឹមយានល្អៗ ហើយឡើងកាន់យានល្អៗ ចេញចាកពន្ធុមតីរាជធានី
ដោយយានល្អៗ បរសំដៅទៅរកខេមមិគទាយវន រហូតដល់កន្លែងសម្រាប់
ជាក់យាន លុះដល់ហើយក៏ចុះអំពីយាន ដើរទៅដោយជើងទេ ចូលសំដៅ
ទៅរកព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ
ក៏ថ្វាយបង្គំព្រះវិបស្សី មានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ហើយអង្គុយក្នុងទីដ៏
សមគួរ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្តែងអនុ-
បុព្វីកថា ដល់ជនទាំង ២ នាក់នោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១
សគ្គកថា ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុង
ការចេញបួស ១ ។ លុះព្រះមានព្រះភាគបានជ្រាបថា ជនទាំង ២ នាក់
នោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់

ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គទ្រង់ប្រកាសធម្មទេសនាដែលព្រះ
ពុទ្ធទាំងឡាយតែងលើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច ๑ សមុទ-
យសច្ច ๑ និរោធសច្ច ๑ មគ្គសច្ច ๑ ក្នុងកាលណោះ ฯ ធម្មតាសំពត់
ស្អាត ប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយប្រពៃ មានឧបមាដូច
ម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏
កើតឡើងដល់ខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រ ក្នុងទីអង្គុយនោះថា
ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែង
រលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ฯ ជនទាំងពីរនោះ បាន
ឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានត្រាស់ដឹងអរិយសច្ចធម៌
បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់
ដល់នូវភាវៈជាបុគ្គលក្លាហាន មិនបាច់ជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃ
ព្រះបរមសាស្តា ទើបក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្ម-
សម្ពុទ្ធវិញ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គ
ដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែង
ហើយ ដោយអនេកបរិយាយ ដូចជាគេផ្ងារបស់ដែលផ្កាប់ ឬដូចជាបើក
បង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចជាប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះ
សោត ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្ស
មានភ្នែកភ្លឺ នឹងមើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន
យើងខ្ញុំព្រះអង្គទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ជា

สรณะ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ម្នាលភិក្ខុទាំងឡាយ ខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្ត ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយប្រកាសទោសនៃសង្ខារទាំងឡាយដ៏លាមកសៅហ្មង និងអានិសង្សក្នុងបព្វជ្ជា ។ កាលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ណែនាំពន្យល់ជនទាំង ២ នោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ មិនយូរប៉ុន្មាន ចិត្ត (របស់ជនទាំងពីរនោះ) ក៏រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។

[๔๙] ម្នាលភិក្ខុទាំងឡាយ ពួកមហាជនក្នុងនគរពន្ធុមតីរាជធានី ចំនួន ๘ ហ្មឺន ๔ ពាន់នាក់ បានឮដំណឹងថា ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្តេចមកដល់ពន្ធុមតីរាជធានីហើយ ឥឡូវទ្រង់គង់នៅនាខេមមិគទាយវ័ន បានឮថា ព្រះខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រ បានដាក់កេសា និងមស្សុ ហើយស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួសក្នុងសំណាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ លុះពួកមហាជនទាំងនោះ បានឮហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ធម្មវិនយ និងបព្វជ្ជាដែលព្រះខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រដាក់កេសា និង

មស្សុ ស្បៀកជណ្តប់សំពត់កាសាយៈ ចេញចាកគេហដ្ឋានទៅបួសនោះ ប្រាកដជាមិនមែនចោកទាបទេ ប៉ុនអម្បាលព្រះខណ្ឌរាជបុត្ត និងតិស្ស-បុរោហិតបុត្ត ម្តេចជាក់កេសា និងមស្សុ ហើយស្បៀកជណ្តប់សំពត់កាសាយៈ ចេញចាកគេហដ្ឋានទៅបួស ចុះពួកយើងនៅចាំអ្វីទៀត ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងវេលានោះ ពួកមហាជនចំនួន ៨ ហ្មឺន ៤ ពាន់នោះ ចេញចាក ពន្ធុមតីរាជធានី នាំគ្នាដើរសំដៅទៅរកឧទ្យានមិគទាយវ័ន ជាទីដែលព្រះវិបស្សី មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធគង់នៅ លុះទៅដល់ហើយ ក៏ថ្វាយបង្គំព្រះ វិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ រួចអង្គុយក្នុងទីសមគួរ ។ ព្រះ វិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្តែងអនុបុព្វីកថា ដល់ពួក មហាជននោះ អនុបុព្វីកថានោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុង បព្វជ្ជា ១ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ពួកមហាជនទាំងនោះ មានចិត្ត ស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ឡើង មានចិត្ត ជ្រះថ្លាក្នុងកាលណា ក៏ទ្រង់ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលណោះ ។ ធម្មតាសំពត់សស្អាត ដែល ប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយប្រពៃ មានឧបមាដូចម្តេច មិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិលក៏កើត ឡើងដល់ពួកមហាជនទាំង ៨ ហ្មឺន ៤ ពាន់នាក់នោះ ក្នុងទីអង្គុយនោះឯង

ថា ធម្មជាតណានីមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ ឯពួកមហាជនទាំងនោះ បានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានត្រាស់ដឹងអរិយសច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ ឆ្ងងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាវៈជាបុគ្គលក្លាហាន មិនបាច់ជឿពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះបរមសាស្តា ទើបក្រាបទូលព្រះវិបស្សី មានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយ ដូចជាគេផ្ងារបស់ដែលផ្កាប់ ឬដូចជាបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចជាប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សដែលមានភ្នែកភ្លឺ នឹងមើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះសូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំសូមបាននូវបព្វជ្ជា និងឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ម្នាលភិក្ខុទាំងឡាយ ពួកមហាជនទាំង ៨ ហ្មឺន ៤ ពាន់នាក់នោះ ក៏បានបព្វជ្ជា និងឧបសម្បទា ក្នុងសំណាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ជនទាំងនោះ ឲ្យឃើញជាក់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយប្រកាសទោសរបស់

សង្ខារដ៏លាមកសៅហ្មង និងអានិសង្សក្នុងព្រះនិព្វាន ។ កាលដែលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ពួកមហាជនទាំងនោះ ឲ្យឃើញជាក់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ មិនយូរប៉ុន្មាន ចិត្ត (របស់មហាជនទាំងនោះ) ក៏រួចស្រឡះចាកអាសវធម៌ទាំង-ឡាយ ព្រោះមិនប្រកាន់មាំ ។

[៥០] ម្នាលភិក្ខុទាំងឡាយ បព្វជិតទាំង ៨ ហ្មឺន ៤ ពាន់រូបនោះ បានឮដំណឹងថា ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ស្តេចមកដល់ពន្ធុមតីរាជធានី ហើយទ្រង់គង់នៅក្នុងខេមមិគទាយវ័ន ទ្រង់សម្តែងធម៌ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ បព្វជិតទាំង ៨ ហ្មឺន ៤ ពាន់រូបនោះ ក៏នាំគ្នាទៅកាន់ក្រុងពន្ធុមតីរាជធានី រួចហើយក៏ដើរសំដៅទៅរកខេមមិគទាយវ័ន ត្រង់កន្លែងដែលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធគង់នៅ លុះទៅដល់ហើយ ក៏ថ្វាយបង្គំព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ហើយអង្គុយក្នុងទីសមគួរ ។ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់អនុបុព្វីកថាដល់ពួកបព្វជិតទាំងនោះ អនុបុព្វីកថានោះ គឺទ្រង់ប្រកាសទានកថា ១ សីលកថា ១ សគ្គកថា ១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង ១ អានិសង្សក្នុងនេក្ខម្មៈ ១ ។ លុះព្រះមានព្រះភាគទ្រង់ជ្រាបថាបព្វជិតទាំងនោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ក៏ទ្រង់ប្រកាសធម្មទេសនាដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច ១

សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ក្នុងកាលណោះ ។ ធម្មតា សំពត់សស្អាត ដែលប្រាសចាកពណ៌ខ្មៅ គួរទទួលទឹកជ្រលក់ដោយប្រពៃ មានឧបមាដូចម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ពួកបព្វជិតទាំង ៨ ហ្មឺន ៤ ពាន់នោះ ក្នុងទីអង្គុយនោះថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ ពួកបព្វជិតទាំងនោះ បានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានត្រាស់ដឹងអរិយសច្ចធម៌ បានចុះចិត្តស៊ីប់ក្នុងអរិយសច្ចធម៌ ឆ្ងងផុតចាកសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាវៈជាបុគ្គលក្លាហាន មិនបាច់ជឿពាក្យបុគ្គលដទៃ ក្នុងសាសនារបស់ព្រះបរមសាស្តា ទើបក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ដោយអនេកបរិយាយ ដូចជាគេផ្ទាររបស់ដែលផ្ទាប់ ឬដូចជាបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចគេកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សដែលមានភ្នែកភ្លឺ មើលឃើញនូវរូបទាំងឡាយបានបពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនេះសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឆផង ថាជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំសូមបាននូវបព្វជ្ជា និងឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ម្នាល

*ភិក្ខុទាំងឡាយ ពួកបព្វជិតទាំង ๘ ហ្នឹង ๔ ពាន់នោះ ក៏បាននូវបព្វជ្ជា និង
ឧបសម្បទា ក្នុងសំណាក់នៃព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។
ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់បព្វជិតទាំងនោះ
ឲ្យឃើញជាក់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយ
ប្រកាសទោសរបស់សង្ខារដ៏លាមកសៅហ្មង និងអានិសង្សក្នុងនេក្ខម្ម: ។
កាលដែលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ពួក
បព្វជិតទាំងនោះ ឲ្យឃើញជាក់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយ
ធម្មីកថាហើយ មិនយូរប៉ុន្មាន ចិត្ត (របស់បព្វជិតទាំងនោះ) ក៏បានរួច
ស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។*

[๕๑] *សម័យនោះឯង មានភិក្ខុសង្ឃច្រើនចំនួន ๖ លាន ๘ សែន
រូប នៅអាស្រ័យក្នុងពន្ធុមតីរាជធានី ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង
ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធទ្រង់គង់ក្នុងទីស្ងាត់ សម្ងំក្នុងព្រះ
កម្មដ្ឋាន មានព្រះតម្រិះក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា ឥឡូវនេះ ពួក
ភិក្ខុដែលនៅអាស្រ័យក្នុងពន្ធុមតីរាជធានី ច្រើនដល់ទៅ ๖ លាន ๘ សែន
រូប បើដូច្នោះ គួរតែតថាគតអនុញ្ញាតភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ
អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បី
សេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន
ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ អ្នក
ទាំងឡាយចូរកុំទៅពីរូប តាមផ្លូវ ๑ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-*

ទ្បាយចូរសម្តែងធម៌ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងទ្បាយក្នុងលោកនេះ ដែលមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះតែងានស្តាប់ធម៌ហើយ នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងត្រាស់ដឹងធម៌ក៏មាន មួយទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំៗ ហើយ អ្នកទាំងទ្បាយត្រូវចូលមកកាន់ពន្ធុមតីរាជធានីដើម្បីសម្តែងបាតិមោក្ខ ។ ម្នាលភិក្ខុទាំងទ្បាយ លំដាប់នោះ មហាព្រហ្ម ១ អង្គ ដឹងនូវសេចក្តីត្រិះរិះក្នុងព្រះហឫទ័យ របស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដោយចិត្តរបស់ខ្លួនហើយ ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ប្រៀបដូចបុរសមានកម្លាំងលាន្ទូវកំភួនដៃដែលបត់ចូល ឬបត់ចូលន្ទូវកំភួនដៃដែលលាចេញ ។ ម្នាលភិក្ខុទាំងទ្បាយ លំដាប់នោះ មហាព្រហ្មនោះធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណមអញ្ជលីថ្វាយបង្គំព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ហើយក្រាបបង្គំទូលព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ភិក្ខុសង្ឃដែលនៅអាស្រ័យក្នុងពន្ធុមតីរាជធានីច្រើនណាស់ ចំនួន ៦ លាន ៨ សែនរូប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់អនុញ្ញាតភិក្ខុទាំងទ្បាយថា ម្នាលភិក្ខុទាំងទ្បាយ អ្នកទាំងទ្បាយ ចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍

ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និង មនុស្សទាំងឡាយ អ្នកទាំងឡាយចូរកុំទៅពីរបួបតាមផ្លូវ ១ ឡើយ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និង ព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយក្នុងលោកនេះ ដែលមាន ធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះតែងស្តាប់ធម៌ នឹង សាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងត្រាស់ដឹងធម៌គង់មាន បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំៗ ហើយ ភិក្ខុទាំងឡាយ នឹងចូលមកកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិ-មោក្ខ យ៉ាងណា យើងខ្ញុំក៏នឹងធ្វើយ៉ាងនោះ ។ ម្នាលភិក្ខុទាំងឡាយ មហា ព្រហ្មនោះ បានពោលនូវពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ថ្វាយបង្គំ លាព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្វើប្រទក្សិណហើយ ក៏បាត់ អំពីទីនោះទៅ ។

[៥២] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ចេញអំពីទីសម្រាកនៅវេលាសាយណ្ហសម័យហើយ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតចូលទៅនៅក្នុងរហោ-ស្ថាន ជាទីសម្រាក មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ឥឡូវនេះ ភិក្ខុសង្ឃដែលនៅអាស្រ័យក្នុងពន្ធុមតីរាជធានីច្រើនណាស់ ចំនួន ៦ លាន

៨ សែនរូប បើដូច្នោះ គួរតែតថាគតអនុញ្ញាតដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ អ្នកទាំង-ឡាយ ចូរកុំទៅពីរូបតាមផ្លូវ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសម្តែងធម៌ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ឲ្យបរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលី គឺរាគាទិក្កិលេសតិចក្នុងចក្ខុក៏មាន សត្វទាំងនោះតែមិនបានស្តាប់ធម៌នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងត្រាស់ដឹងធម៌គង់មាន មួយទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំៗ ហើយ អ្នកទាំងឡាយត្រូវចូលមកកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មានមហាព្រហ្ម ១ អង្គ ដឹងនូវសេចក្តីត្រិះរិះក្នុងចិត្តនៃតថាគត ដោយចិត្តរបស់ខ្លួនហើយ ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខតថាគត ប្រៀបដូចបុរសអ្នកមានកម្លាំង លាចេញនូវកំភួនដៃដែលបត់ចូល ឬបត់ចូលនូវកំភួនដៃដែលលាចេញ ម្នាលភិក្ខុទាំងឡាយ ក្នុងវេលានោះ មហាព្រហ្មនោះធ្វើសំពត់ឧត្តរ-សង្គធ្វើងស្មាម្ខាង ប្រណម្យអញ្ជលី ថ្វាយបង្គំចំពោះតថាគត ហើយពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ដំណើរនុ៎ះយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ភិក្ខុសង្ឃ

ដែលនៅអាស្រ័យក្នុងពន្ធមតីរាជធានីច្រើនណាស់ ចំនួន ៦ លាន ៨ សែន រូប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាតភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ អ្នកទាំងឡាយចូរកុំទៅពីរូបតាមផ្លូវ ១ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយក្នុងលោកនេះ ដែលមានធូលី គឺរាគាទិក្កិលេសតិចក្នុងចក្ខុក៏មាន សត្វទាំងនោះ តែមិនបានស្តាប់ធម៌នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុងនឹងត្រាស់ដឹងធម៌គង់មាន បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត កាលបើវេលាកន្លងទៅបាន ៦ ឆ្នាំៗ ហើយ ភិក្ខុទាំងឡាយនឹងចូលមកកាន់ពន្ធមតីរាជធានី ដើម្បីសម្តែងជាតិមោក្ខ យ៉ាងណា យើងខ្ញុំក៏នឹងធ្វើយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ មហាព្រហ្មនោះ បានពោលពាក្យនេះ លុះពោលពាក្យនេះរួច ក៏ថ្វាយបង្គំលាតថាគត ធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។ ព្រះវិបស្សីទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និង

มនុស្សទាំងឡាយ អ្នកទាំងឡាយ ចូរកុំទៅពីរូបតាមផ្លូវ ๑ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ឲ្យមានលម្អបទដើម បទកណ្តាល និងបទចុង ចូរប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ប្រកបដោយអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ទាំងអស់ ពួកសត្វក្នុងលោកនេះដែលមានធូលី គឺរាគាទិក្កិលេសតិចក្នុងចក្ខុក៏មាន សត្វទាំងនោះ តែមិនបានស្តាប់ធម៌នឹងសាបសូន្យ (ចាកមគ្គផល) ពួកសត្វដែលបម្រុង ត្រាស់ដឹងធម៌គង់មាន ម្នាលភិក្ខុទាំងឡាយ តែថាកាលបើកន្លងទៅបាន ៦ ឆ្នាំៗ ហើយ អ្នកទាំងឡាយត្រូវមកកាន់ពន្ធមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ពួកភិក្ខុច្រើនតែចេញទៅកាន់ចារិក ក្នុងជនបទតែមួយថ្ងៃប៉ុណ្ណោះ ។

[๕๓] សម័យនោះឯង ក្នុងជម្ពូទ្វីបមានអាវាសច្រើន ចំនួន ๘ ហ្មឺន ๔ ពាន់ ។ ដល់កន្លងទៅបាន ๑ ឆ្នាំ ពួកទេវតាក៏បន្ទឺសូរសេពូថា បពិត្រលោកអ្នកនិទ្ទុក្ខទាំងឡាយ កាលកន្លងទៅបាន ๑ ឆ្នាំហើយ ឥឡូវនៅសល់តែ ๕ ឆ្នាំទៀតទេ លុះអំណឹះទៅ ๕ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ๒ ឆ្នាំ ពួកទេវតាបន្ទឺសូរសេពូថា បពិត្រលោកអ្នកនិទ្ទុក្ខទាំងឡាយ កាលកន្លងទៅបាន ๒ ឆ្នាំហើយ ឥឡូវនៅសល់តែ ๔ ឆ្នាំទៀតទេ លុះអំណឹះទៅ ๔ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកាលកន្លងទៅបាន ๓ ឆ្នាំ ពួកទេវតាបន្ទឺសូរសេពូថា បពិត្រលោកអ្នកនិទ្ទុក្ខទាំងឡាយ កាលកន្លងទៅបាន ๓ ឆ្នាំហើយ ឥឡូវនៅសល់តែ ๓ ឆ្នាំ

ទៀតទេ លុះអំណឹះទៅ ๓ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធុ-មតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ๔ ឆ្នាំ ពួកទេវតាបន្ទឹសួរសេចក្តីថា បពិត្រលោកអ្នកនិទ្ទុក្ខទាំងឡាយ កាលកន្លងទៅបាន ๔ ឆ្នាំហើយ ឥឡូវនៅសល់តែ ๒ ឆ្នាំទៀតទេ លុះអំណឹះទៅ ๒ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ๕ ឆ្នាំ ពួកទេវតាបន្ទឹសួរសេចក្តីថា បពិត្រលោកអ្នកនិរទុក្ខទាំង-ឡាយ កាលកន្លងទៅបាន ๕ ឆ្នាំហើយ ឥឡូវនៅសល់តែ ๑ ឆ្នាំទៀតទេ លុះអំណឹះទៅ ๑ ឆ្នាំទៀត លោកទាំងឡាយត្រូវចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខ ។ លុះកន្លងទៅបាន ๖ ឆ្នាំ ពួកទេវតាបន្ទឹសួរសេចក្តីថា បពិត្រលោកអ្នកនិទ្ទុក្ខទាំងឡាយ កាលកន្លងទៅបាន ๖ ឆ្នាំហើយ ឥឡូវដល់វេលាត្រូវលោកទាំងឡាយ ចូលទៅកាន់ពន្ធុមតីរាជធានី ដើម្បីសម្តែងបាតិមោក្ខហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ភិក្ខុទាំងនោះមានពួកភិក្ខុ-ខ្លះ ចូលទៅកាន់ពន្ធុមតីរាជធានី ដោយអានុភាពនៃឫទ្ធិរបស់ខ្លួន ពួកខ្លះចូលទៅកាន់ពន្ធុមតីរាជធានី ដោយអានុភាពនៃឫទ្ធិទេវតាទាំងឡាយ តែមួយថ្ងៃដើម្បីនឹងសម្តែងបាតិមោក្ខ ។

[๕๔] ម្នាលភិក្ខុទាំងឡាយ មានសេចក្តីតំណាលថា ក្នុងសម័យនោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្តែងបាតិមោក្ខក្នុងជំនុំសង្ឃយ៉ាងនេះថា

អធិវាសនខន្តី ពោល គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ខ្ពង់

ព្រះពុទ្ធទាំងឡាយតែងត្រាស់ថា ព្រះនិញ្វានជាធម៌ដ៏ឧត្តម
បព្វជិតអ្នកសម្ងាប់សត្វដទៃ បៀតបៀនសត្វដទៃ មិន
ឈ្មោះថា សមណៈទ្បើយ ។
ការមិនធ្វើអំពើបាបទាំងពួង ការបំពេញកុសល ការញ្ចាំង
ចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំង ៣ នេះ ជាពាក្យប្រដៅរបស់
ព្រះពុទ្ធទាំងឡាយ ។
ការមិនពោលតិះដៀល ការមិនបៀតបៀន ការសង្រួមក្នុង
បាតិមោក្ខ ភាវៈជាអ្នកដឹងប្រមាណក្នុងភត្ត ទីដេក ទីអង្គុយ
ដ៏ស្ងាត់ ការបំពេញព្យាយាមក្នុងអធិចិត្ត ទាំង ៦ នេះ ជា
ពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

[៥៥] ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យមួយ តថាគតនៅទៀបដើម
សាលរាជ ក្នុងសុភវន ជិតក្រុងឧក្កដ្ឋា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះ
យ៉ាងនេះកើតឡើងក្នុងចិត្តរបស់តថាគត ដែលនៅក្នុងទីស្ងាត់ ជាទីសម្រាក
នោះថា ជាន់សុទ្ធាវាសណា ដែលតថាគតមិនធ្លាប់នៅអាស្រ័យ ជាន់សុទ្ធាវាស
នោះ បុគ្គលមិនងាយនឹងបាន លើកលែងតែពួកទេវតាដែលនៅក្នុងជាន់
សុទ្ធាវាស ជាយូរអង្វែងមកហើយនេះចេញ បើដូច្នោះគួរតែតថាគតទៅរកពួក
ទេវតាដែលនៅក្នុងជាន់សុទ្ធាវាសនោះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ
តថាគតចៀសចេញអំពីដើមសាលរាជ ក្នុងសុភវន ជិតក្រុងឧក្កដ្ឋា ទៅប្រាកដ
ក្នុងទេវលោកឈ្មោះអវិហា ប្រៀបដូចបុរសមានកម្លាំង លាចេញនូវកំភួនដៃ

ដែលបត់ចូល ឬបត់ចូលទូវកំភួនដៃដែលលាចេញ ។ ម្នាលភិក្ខុទាំងឡាយ ពពួកទេវតាទាំងនោះ មានពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតាទាំងនោះឈរក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ រាប់អំពីកប្បនេះ (ថយក្រោយទៅ) ៩១ កប្ប ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងក្នុងលោក បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាខត្តិយជាតិ ទ្រង់ព្រះសម្ភពក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាកោណ្ឌញ្ញគោត្រ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ត្រាស់ក្រោមដើមបាដលិព្រឹក្ស (ដើមច្រនៀង) បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានគូនៃសាវកដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះខណ្ឌៈ ១ តិស្សៈ ១ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានសាវកសន្និបាត ៣ ដង គឺសាវកសន្និបាតមុខ មានភិក្ខុ ៦ លាន ៨ សែនរូប សាវកសន្និបាតមុខ មានភិក្ខុ ១ សែនរូប សាវកសន្និបាតមុខ មានភិក្ខុ ៨ ហ្មឺនរូប បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានសាវកសន្និបាតទាំង ៣ ដង

នេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សី
មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះអសោក:ជាឧបដ្ឋាកអ្នកបម្រើ
ដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ
អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជា ទ្រង់ព្រះនាមពន្ធុម: ព្រះមាតាព្រះនាមពន្ធុមតី-
ទេវី ជាព្រះមាតាបង្កើត ព្រះនគរនៃព្រះបាទពន្ធុម: ឈ្មោះពន្ធុមតី ជារាជធានី
បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ចេញ
ទៅទ្រង់ព្រះផ្នួសយ៉ាងនេះ បព្វជ្ជាយ៉ាងនេះ ការព្យាយាមយ៉ាងនេះ ការបាន
ត្រាស់យ៉ាងនេះ មានព្រះធម្មចក្កប្បវត្តន:យ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ
យើងខ្ញុំទាំងនោះប្រព្រឹត្តទូវព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះវិបស្សីមានព្រះ
ភាគ ហើយនឿយណាយចាកសេចក្តីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ
ទើបបានមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ
មានទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់
ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ
លុះពួកទេវតាទាំងនោះឈរក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងតថាគត
ថា បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ រាប់អំពីកប្បនេះទៅមុខ ៣១ កប្ប ព្រះសិខី
មានព្រះភាគ ។បេ។ បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ ពួកខ្ញុំព្រះអង្គទាំងនោះបាន
ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះសិខីមានព្រះភាគ ។បេ។ បពិត្រព្រះ
អង្គអ្នកនិទុ៌ក្ខ ក្នុង ៣១ កប្បនោះឯង ព្រះវេស្សភូមានព្រះភាគ ។បេ។
បពិត្រព្រះអង្គអ្នកនិទុ៌ក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុង

សំណាក់នៃព្រះវេស្សភូមានព្រះភាគ ។បេ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ក្នុងកទូកប្បនេះ ព្រះកកុសន្ធៈ ។ ព្រះកោនាគមនៈ ។ ព្រះកស្សបមានព្រះភាគ ។បេ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ពួកខ្ញុំព្រះអង្គទាំងនោះបានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះកកុសន្ធៈ ។ ក្នុងសំណាក់នៃព្រះកោនាគមនៈ ។ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះកស្សបមានព្រះភាគ ហើយនឿយណាយចាកសេចក្តីពេញចិត្តនឹងកាមក្នុងកាមទាំងឡាយ ទើបបានមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ មានទេវតាច្រើនរយច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឈរក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ឥឡូវនេះ ក្នុងកទូកប្បនេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតឡើងហើយក្នុងលោក បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគជាខត្តិយជាតិ ទ្រង់ព្រះសម្ភពក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគជាគោតមគោត្រ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ មានព្រះជន្មាយុតិចតួចស្តួចស្តើងណាស់ បុគ្គល (ក្នុងសម័យនេះ) ដែលរស់នៅយ៉ាងយូរបានត្រឹម ១០០ ឆ្នាំ និងតិចជាង ១០០ ឆ្នាំ ឬលើសពី ១០០ ឆ្នាំ ក៏មានខ្លះដែរ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគត្រាស់ក្រោមដើមអស្សត្ថព្រឹក្ស បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគមានគូនៃសាវក ជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះព្រះសារីបុត្ត ១ ព្រះមោគ្គល្លាន ១ បពិត្រ

ព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ ព្រះអង្គមានសាវកសន្និបាតតែម្តង មានភិក្ខុ ១២៥០ អង្គ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ មានសាវក-សន្និបាតតែម្តងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ មានភិក្ខុឈ្មោះអានន្ទជាអ្នកបម្រើ ជាអ្នកបម្រើដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះបិតារបស់ព្រះមានព្រះភាគ ជាព្រះរាជាព្រះនាមសុទ្ធោទនៈ ព្រះមាតាព្រះនាមមាយាទេវី ជាព្រះមាតាបង្កើត មានព្រះនគរកបិលវត្ថុ ជាព្រះរាជធានី បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ មានអភិនិស្ក្រមណ៍យ៉ាងនេះ មានបព្វជ្ជាយ៉ាងនេះ មានព្យាយាមយ៉ាងនេះ មានការត្រាស់ដឹងយ៉ាងនេះ មានព្រះធម្មចក្កប្បវត្តនៈយ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយរឿយណាយចាក សេចក្តីពេញចិត្តនឹងកាមក្នុងកាមទាំង-ឡាយ ទើបមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចូលទៅរកពួកទេវតាក្នុងជាន់អតប្បា ព្រមទាំងពួកទេវតាក្នុងជាន់អវិហា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចូលទៅរកពួកទេវតាក្នុងជាន់សុទស្សា ព្រមទាំងទេវតាក្នុងជាន់អវិហា និងពួកទេវតាក្នុងជាន់អតប្បា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចូលទៅរកពួកទេវតាក្នុងជាន់សុទស្សី ព្រមទាំងពួកទេវតាក្នុងជាន់អវិហា និងពួកទេវតាក្នុងជាន់អតប្បា និងពួកទេវតាក្នុងជាន់សុទស្សា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ តថាគតចូលទៅរកពួកទេវតាក្នុងជាន់អកនិដ្ឋា ព្រមទាំងពួកទេវតា ក្នុងជាន់អវិហា និង

ពួកទេវតាក្នុងជាន់អតប្បា និងពួកទេវតាក្នុងជាន់សុទស្សា និងពួកទេវតាក្នុងជាន់សុទស្សី ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ មានពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឈរនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ រាប់អំពីកន្លួកប្បនេះទៅ ៩១ កប្បនោះ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតហើយក្នុងលោក ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជាខត្តិយជាតិ ទ្រង់ព្រះសម្ភពក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាកោណ្ឌញ្ញគោត្រ បពិត្រព្រះអង្គអ្នកនិទ្ទុក ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះវិបស្សីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងក្រោមដើមបាដលិព្រឹក្ស បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានគូនៃសាវក ជាគូដ៏ប្រសើរជាគូដ៏ចម្រើន ឈ្មោះខណ្ឌៈ ១ តិស្សៈ ១ បពិត្រព្រះអង្គអ្នកនិរទុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត ៣ ដង គឺសាវកសន្និបាតម្តងមានភិក្ខុ ៦ លាន ៨ សែនរូប សាវកសន្និបាតម្តង មានភិក្ខុ ១ សែនរូប សាវកសន្និបាតម្តង មានភិក្ខុ ៨ ហ្មឺនរូប បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានសាវកសន្និបាត ៣ ដងនេះ

สุទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិរទុក្ខ ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានភិក្ខុឈ្មោះអសោកៈ ជាឧបដ្ឋាក ជាអ្នកបម្រើដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទុ្ក្ខ ព្រះបិតារបស់ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជាព្រះរាជាទ្រង់ព្រះនាមពន្ធុមៈ ព្រះមាតាព្រះនាមពន្ធុមតីទេវី ជាព្រះមាតាបង្កើត នគរនៃព្រះបាទពន្ធុមៈ ឈ្មោះពន្ធុមតីរាជធានី បពិត្រព្រះអង្គអ្នកនិទុ្ក្ក ព្រះវិបស្សីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មានអកិនិស្ក្រមណ៍យ៉ាងនេះ មានបព្វជ្ជាយ៉ាងនេះ មានព្យាយាមយ៉ាងនេះ មានការត្រាស់ដឹងយ៉ាងនេះ មានព្រះធម្មចក្កប្បវត្តនៈយ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទុ្ក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះវិបស្សីមានព្រះភាគ នៀយណាយចាកសេចក្តីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ ទើបមកកើតក្នុងទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ មានពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឈរក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នកនិទុ្ក្ខ រាប់ពីកន្លះកប្បនេះទៅ ៣១ កប្បនោះ ព្រះសិខីមានព្រះភាគ ។បេ។ បពិត្រព្រះអង្គ អ្នកនិទុ្ក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសិខីមានព្រះភាគ ។បេ។ បពិត្រព្រះអង្គអ្នកនិទុ្ក្ខ ក្នុង ៣១ កប្បនោះឯង ព្រះវេស្សភូមានព្រះភាគ ។បេ។ បពិត្រព្រះអង្គអ្នកនិទុ្ក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្ម-

ចរិយធម៌ក្នុងសំណាក់ព្រះវេស្សភូមានព្រះភាគ ។បេ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ក្នុងភទ្ទកប្បនេះឯង ព្រះកកុសន្ធៈ ។ ព្រះកោនាគមនៈ ។ ព្រះកស្សបមាន ព្រះភាគ ។បេ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្ត ព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះកកុសន្ធៈ ។ ក្នុងសំណាក់ព្រះកោនាគមនៈ ។ បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះកស្សបមានព្រះភាគ នឿយ ណាយចាកសេចក្តីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ ទើបមកកើតក្នុង ទីនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងពួកទេវតាទាំងនោះ ពួកទេវតាច្រើនរយ ច្រើនពាន់ ចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកទេវតាទាំងនោះ ឈរ ក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គអ្នក និទ្ទុក្ខ ឥឡូវនេះឯង ក្នុងភទ្ទកប្បនេះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់កើតក្នុងលោក បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ ជាខត្តិយជាតិ ទ្រង់ព្រះសម្ភពក្នុងខត្តិយត្រកូល បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគជា គោតមគោត្រ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមាន ព្រះភាគ មានព្រះជន្មាយុ តិចតួចស្ទួងស្តើងណាស់ បុគ្គលដែលរស់នៅយ៉ាងយូរបានត្រឹម ១០០ ឆ្នាំ នឹងថយចុះពី ១០០ ឆ្នាំ ឬលើសពី ១០០ ឆ្នាំក៏មានខ្លះដែរ បពិត្រព្រះអង្គ អ្នកនិទ្ទុក្ខ ព្រះមានព្រះភាគត្រាស់ក្រោមដើមអស្សត្ថព្រឹក្ស បពិត្រព្រះអង្គអ្នក និទ្ទុក្ខ ព្រះមានព្រះភាគមានគូនៃសាវក ជាគូដ៏ប្រសើរ ជាគូដ៏ចម្រើន ឈ្មោះ ព្រះសារីបុត្ត ១ ព្រះមោគ្គល្លាន ១ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ

មានសាវកសន្និបាតតែម្តង មានភិក្ខុ ១២៥០ រូប បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ មានសាវកសន្និបាតតែម្តងប៉ុណ្ណោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ មានភិក្ខុឈ្មោះអានន្ទជាឧបដ្ឋាក ជាអ្នកបម្រើដ៏ប្រសើរ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះបិតារបស់ព្រះមានព្រះភាគ ជាព្រះរាជា ព្រះនាមសុទ្ធោទនៈ ព្រះមាតាព្រះនាមមាយាទេវី ជាព្រះមាតាបង្កើត មាននគរកបិលវត្ថុ ជាព្រះរាជធានី បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះមានព្រះភាគ ព្រះអង្គមានអភិនិស្ក្រមណ៍យ៉ាងនេះ មានបព្វជ្ជាយ៉ាងនេះ មានព្យាយាមយ៉ាងនេះ មានការត្រាស់ដឹងយ៉ាងនេះ មានព្រះធម្មចក្កប្បវត្តនៈយ៉ាងនេះ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ យើងខ្ញុំទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះមានព្រះភាគ នឿយណាយចាកសេចក្តីពេញចិត្តនឹងកាម ក្នុងកាមទាំងឡាយ ទើបមកកើតក្នុងទីនេះ ។

[៥៦] *ម្នាលភិក្ខុទាំងឡាយ ធម្មធាតុនុ៎ះ តថាគតដឹងដោយប្រការដូច្នេះ ព្រោះតែតថាគតដឹងច្បាស់នូវធម្មធាតុ បានជាព្រះអតីតពុទ្ធទាំងឡាយ ទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញ៉ាំងសត្វ ឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ ក៏តថាគតរឭកឃើញព្រះជាតិផង រឭកឃើញព្រះនាមផង រឭកឃើញព្រះគោត្រផង រឭកឃើញប្រមាណនៃព្រះជន្មាយុផង រឭកឃើញគូនៃសាវកផង រឭកឃើញសាវកសន្និបាតផងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះ*

មានព្រះនាមយ៉ាងនេះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះដូច្នេះផង ។ ទាំងពួកទេវតាក៏បានប្រាប់សេចក្តីនេះចំពោះតថាគត ព្រះអតីតពុទ្ធទាំងឡាយ ដែលទ្រង់ផ្តាច់ផ្តិលនូវកិលេសជាគ្រឿងញាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញាំងសត្វឲ្យវិលវល់ ទ្រង់កន្ធងបង់នូវទុក្ខទាំងពួង ទ្រង់បរិនិព្វានទៅហើយ តថាគតក៏រឭកឃើញព្រះជាតិផង រឭកឃើញព្រះនាមផង រឭកឃើញព្រះគោត្រផង រឭកឃើញប្រមាណនៃជន្មាយុផង រឭកឃើញគូនៃសាវ័កផង រឭកឃើញសាវក-សន្និបាតផងថា ព្រះមានព្រះភាគទាំងឡាយនោះ ព្រះអង្គមានព្រះជាតិយ៉ាងនេះ មានព្រះនាមយ៉ាងនេះ ។ មានព្រះគោត្រយ៉ាងនេះ ។ មានសីលយ៉ាងនេះ ។ មានធម៌យ៉ាងនេះ ។ មានប្រាជ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះ ដូច្នេះផង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះសូត្រនេះ (ចប់) ហើយ ភិក្ខុទាំងនោះ មានចិត្តរីករាយ ត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

មហាបទានសូត្រទី ១ ចប់

អដ្ឋកថា

មហាបទានសូត្រ

[១] *មហាបទានសូត្រ មានពាក្យផ្តើមថា ខ្ញុំបានស្តាប់មកហើយ យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកវេរិកុដិកា ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។*

តទៅនេះជាពណ៌នាបទតាមលំដាប់ ក្នុងមហាបទានសូត្រនេះ ពាក្យថា **កវេរិ** *ក្នុងបទថា* **កវេរិកុដិកាយំ** *ជាឈ្មោះដើមថ្ងាន់ កវេរិមណ្ឌបតាំង នៅជិតទ្វារកុដិនោះ ព្រោះដូច្នោះ ទើបលោកហៅថា កវេរិកុដិ ដូចលោកហៅថា កោសម្ពកុដិ ព្រោះមានដើមកោសម្ពៈ (ដើមក្រចកស្វាំង) តាំងនៅជិតទ្វារ ។*

បានឮថា ខាងក្នុងព្រះវិហារជេតពន មានកុដិធំ ៤ ខ្នង គឺកវេរិកុដិ កោសម្ពកុដិ គន្ធកុដិ សឡឡឃរៈកុដិ (កុដិធ្វើពីដើមស្រល់) ។ មួយខ្នងៗ សម្រេចដោយការបរិច្ចាគទ្រព្យ ១ សែនៗ ។ ទាំង ៤ ខ្នង នោះ ព្រះបាទបសេនទិទ្រង់សាងសឡឡឃរៈកុដិ កុដិដែលសល់ ៣ ទៀត អនាថបិណ្ឌិកសេដ្ឋីជាអ្នកសាង ព្រោះហេតុនេះ ទើបព្រះមានព្រះភាគប្រថាប់នៅក្នុងកវេរិកុដិ ដែលអនាថបិណ្ឌិកគហបតីបានសាងទិព្វព្រឹក្ស ដូចទេវវិមាន តម្កល់ទុកលើសសរទាំងឡាយ ។

បទថា **បច្ឆាភត្តំ** *សេចក្តីថា កាលភិក្ខុឆាន់អាហារមួយពេល និងមិនមែនឆាន់ខាងក្រោយអាហារ ឆាន់ពីព្រឹកព្រលឹម សូម្បីឆាន់ខាងក្នុងថ្ងៃត្រង់ ក៏ឈ្មោះថា បច្ឆាភត្តដូចគ្នា ។ តែក្នុងទីនេះលោកបំណងយកបច្ឆាភត្ត ក្រោយអាហារតាមប្រក្រតី ។*

បទថា **បិណ្ឌចាតប្បដិក្ពន្តានំ** សេចក្តីថា កាលភិក្ខុត្រឡប់អំពីបិណ្ឌបាត ឆាន់អាហាររួចហើយក្រោកឡើង ។ បទថា **ការេរិមណ្ឌលមាឡេ** សេចក្តីថា ក្នុងសាលាអង្គុយ ដែលសាងទុកមិនឆ្ងាយពីការេរិមណ្ឌបន្ទុំះឯង ។ បានញ្ចថា ការេរិមណ្ឌបនោះ នៅក្នុងចន្ងោះព្រះគន្ធកុដិនិងសាលា ព្រោះដូច្នោះ គន្ធកុដិក្តី ការេរិកុដិក្តី សាលាក្តី លោកហៅថា ការេរិមណ្ឌល ។

បទថា **បុព្វេនិវាសប្បដិសំយុត្តា** សេចក្តីថា ធម្មីកថាប្រកបដោយ បុព្វេសន្និវាស ពោល គឺខន្ធសន្តានដែលអាស្រ័យនៅក្នុងជាតិមុន ចែកចេញ យ៉ាងនេះ គឺមួយជាតិខ្ងះ ពីរជាតិខ្ងះ ដែលប្រព្រឹត្តទៅហើយ ។ បទថា **ធម្មី** គឺ ប្រកបដោយធម៌ ។ បទថា **ឧធចាធិ** សេចក្តីថា បុព្វេនិវាសញ្ញាណរបស់ព្រះ ទសពល គួរអស្ចារ្យពិត ។ សួរថា ឈ្មោះថា បុព្វេនិវាសនរណារព្រកបាន នរណារព្រកមិនបាន ឆ្លើយថា តិរ្ថិយរព្រកបាន ព្រះសាវក ព្រះបច្ចេកពុទ្ធរព្រក បាន ។ សួរថា តិរ្ថិយពួកណារព្រកបាន ឆ្លើយថា តិរ្ថិយពួកណាដល់ភាព ជាអ្នកប្រសើរ ជាកម្មវាទី តិរ្ថិយទាំងនោះ ក៏រព្រកបានរហូតដល់ត្រឹម ៤០ កប្បប៉ុណ្ណោះ ក្រៃលែងជាងនោះមិនបាន ។ ព្រះសាវករព្រកបាន ១ សែន កប្ប[1] ។ ព្រះអគ្គសាវកទាំងពីររព្រកបាន ១ អសង្ខេយ្យ និង ១ សែនកប្ប ។ ព្រះបច្ចេកពុទ្ធរព្រកបាន ២ អសង្ខេយ្យ និង ១ សែនកប្ប ។ តែព្រះពុទ្ធទាំង-

---

១- សេចក្តីនេះហាក់ដូចជំទាស់ក្នុងអបទាន ព្រោះក្នុងសង្គមនទាថេរិយាបទានទី ៤ បិដកខ្មែរ លេខ ៧៦ ទំព័រ ៧ បានពោលថា ព្រះថេរីព្រះនាមសង្គមនទានេះ នាងជាព្រះថេរីសាមញ្ញ តែអាច រព្រកជាតិបានរហូតដល់ ៣ អសង្ខេយ្យ និង ១ សែនកប្ប គឺក្នុងសាសនារបស់ព្រះសម្ពុទ្ធព្រះនាម កោណ្ឌញ្ញៈ ព្រោះព្រះពុទ្ធកោណ្ឌញ្ញៈទ្រង់កើតឡើងក្នុងលោក ក្រោយអំពីព្រះពុទ្ធទីបង្គរបរិនិព្វានទៅ ១ អសង្ខេយ្យកប្ប ។

ឡាយ មិនមានកំណត់ប៉ុណ្ណោះ ប៉ុណ្ណោះទៀយ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់រឭកតាមដែលទ្រង់ប្រាថ្នា តិរ្ថិយទាំងឡាយរឭកបានតាមលំដាប់ខន្ធ ផុតលំដាប់ហើយ មិនអាចរឭកបានទៀយ ។ តិរ្ថិយទាំងឡាយ ទោះបីរឭកបានតាមលំដាប់ក៏ដល់នូវភាពជាអ្នកមិនមានការជឿង រមែងមិនឃើញការប្រព្រឹត្តទៅរបស់ខន្ធ ដូចសត្វធ្លាក់ចុះក្នុងសំណាញ់ និងអ្នកពិការ ធ្លាក់ក្នុងរណ្តៅ ។ តិរ្ថិយទាំងនោះ ធ្លាក់ហើយក្នុងទីនោះ រមែងយល់ឃើញថា ត្រឹមប៉ុណ្ណោះឯង ក្រៃលែងជាងនេះមិនមាន ដោយហេតុនេះ ការរឭកដល់បុព្វេសន្និវាសរបស់ពួកតិរ្ថិយ ក៏ដូចជាអ្នកខ្វាក់ភ្នែក ដើរទៅដោយចុងឈើច្រត់ ។ ធម្មតាអ្នកខ្វាក់ភ្នែក កាលនៅមានអ្នកកាន់ចុងឈើច្រត់ រមែងដើរទៅបាន កាលមិនមានក៏អង្គុយនៅទីនោះឯង យ៉ាងណា ពួកតិរ្ថិយក៏ដូច្នោះដែរ អាចរឭកបានតាមលំដាប់ខន្ធ រៀរលំដាប់ចេញហើយ មិនអាចរឭកបាន ។ ព្រះសាវ័កទាំងឡាយក៏រឭកតាមលំដាប់ខន្ធបាន លុះដល់ភាពជាអ្នកមិនមានការជឿង រមែងមិនឃើញការប្រព្រឹត្តទៅរបស់ខន្ធ ។ សូម្បីដូច្នេះ ឈ្មោះថា កាលដែលមិនមាននៃខន្ធទាំងឡាយរបស់សត្វដែលអន្ទោលទៅកាន់វដ្តៈទាំងនោះ រមែងមិនមានតែក្នុងអសញ្ញភព រមែងប្រព្រឹត្តទៅ ៥០០ កប្ប ព្រោះដូច្នោះ សត្វទាំងឡាយឈានកន្ទងកាលប្រមាណប៉ុណ្ណោះ តាំងនៅក្នុងពាក្យទូន្មានដែលព្រះពុទ្ធទាំង-ឡាយទ្រង់ប្រទានហើយ រមែងរឭកដល់ខាងមុខបាន ដូចភិក្ខុសោភិតៈដូច្នោះ ។ មួយវិញទៀត ព្រះអគ្គសាវ័កទាំងពីរ និងព្រះបច្ចេកពុទ្ធទាំងឡាយ ពិចារណាមើលចុតិ និងបដិសន្ធិហើយ រមែងរឭកបាន ។ កិច្ច គឺចុតិ និងបដិសន្ធិរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនមាន ។ ព្រះពុទ្ធទាំងឡាយ ចង់ឃើញហានៈណាមួយរមែងទ្រង់ឃើញហានៈ នោះៗ ឯង ។ មួយទៀត តិរ្ថិយ

ទាំងឡាយ កាលវព្រកជល់បុព្វេសន្និវាស រមែងវព្រកជល់វត្ថុដែលខ្លួនឃើញ ហើយ ធ្លើហើយ ស្តាប់ហើយប៉ុណ្ណោះ ។ ព្រះសាវ័កទាំងឡាយ និងព្រះបច្ចេកពុទ្ធទាំងឡាយក៏ដូច្នោះ ។ តែព្រះពុទ្ធទាំងឡាយ ទ្រង់វព្រកជល់វត្ថុទាំងអស់នោះឯង ដែលព្រះអង្គ ឬអ្នកដទៃឃើញហើយ ធ្លើហើយ ស្តាប់ហើយ ។ បុព្វេនិវាសញ្ញាណរបស់ពួកតិរ្ថិយ ដូចពន្លឺអំពិលអំពែក របស់ព្រះសាវ័កទាំងឡាយ ដូចពន្លឺប្រទីប របស់ព្រះអគ្គសាវ័ក ដូចពន្លឺផ្កាយព្រឹក្ស របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ដូចពន្លឺព្រះចន្ទ របស់ព្រះពុទ្ធទាំងឡាយ ដូចពន្លឺសុរិយមណ្ឌលពាន់ដួង ។ ព្រះពុទ្ធនោះ មិនកំណត់ប្រមាណប៉ុណ្ណោះថា រយជាតិ ពាន់ជាតិ សែនជាតិ ឬរយកប្ប ពាន់កប្ប សែនកប្ប កាលព្រះអង្គទ្រង់វព្រកជល់វត្ថុណាមួយ រមែងមិនខុស មិនទើសទាក់ដោយពិត ការនឹកគិតជាប់គ្នា រមែងតជាប់គ្នាតាមសេចក្តីប្រាថ្នា ការពិចារណា និងចិត្តុប្បាទនុ៎ះឯង បុព្វេនិវាសញ្ញាណ រមែងស្ទុះទៅមិនទើសទាក់ ដូចកូនសរដែលស្ទុះទៅយ៉ាងធាប់រហ័ស ក្នុងគំនរស្មៅកឈើដែលពុកផុយ និងដូចឥន្ទវជិរៈដែលគប់ទៅលើកំពូលភ្នំសិនេរុ ដូច្នោះ ។

បទថា **អហោ មហន្តំ ភគវតោ បុព្វេនិវាសញ្ញាណំ** *សេចក្តីថា ការសន្ធនាកើតឡើង គឺប្រព្រឹត្តទៅហើយ ប្រារព្ធព្រះមានព្រះភាគដោយប្រការដូច្នេះ ដើម្បីសម្តែងសេចក្តីទាំងអស់នោះដោយសង្ខេប ទើបលោកពោលក្នុងបាលីត្រឹមតែថា* **ឥតិបិ បុព្វេនិវាសោ ឥតិបិ បុព្វេនិវាសោ ។** *ក្នុងបទទាំងនោះ បទថា* **ឥតិបិ** *ប្រែថា សូម្បីយ៉ាងនេះ ។*

សេចក្តីណាដែលគួរពោលទុកក្នុងបាលីនេះថា **អសេ្សាសិ ខោ ភគវា**

ឯបេ អថ ភគវា អនុប្សត្តោ លោកពោលហើយក្នុងអដ្ឋកថា ព្រហ្មជាល-សូត្រនោះឯង តទៅនេះ សេចក្តីនោះ ជាសេចក្តីផ្សេងគ្នា ។ ក្នុងសូត្រនោះ ព្រះមានព្រះភាគ ទ្រង់ញ្ញដោយព្រះសព្វញ្ញុតញ្ញាណ ។ ក្នុងសូត្រនេះ បានស្តាប់ដោយទិព្វសោត ។ មួយទៀត ក្នុងសូត្រនោះ សន្ធនាដល់គុណ និងទោស ។ ក្នុងសូត្រនេះ សន្ធនាដល់បុព្វេនិវាសញ្ញាណ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា ភិក្ខុទាំងនេះសរសើរគុណ ប្រារព្ធបុព្វេនិវាសញ្ញាណរបស់តថាគត តែមិនដឹងនូវការសម្រេច នៃបុព្វេនិវាសញ្ញាណរបស់តថាគតឡើយ ណ្ហើយចុះ តថាគតនឹងសម្តែងដល់ការសម្រេចនៃបុព្វេនិវាសញ្ញាណនោះ ហើយសម្តែងដល់ពួកភិក្ខុទាំងនេះ ទើបយាងមកប្រថាប់ត្រង់ពុទ្ធាសនៈដ៏ប្រសើរដែលតាមប្រក្រតី តម្កល់ទុកដើម្បីព្រះពុទ្ធគង់សម្តែងធម៌ ដែលខណៈនោះ ភិក្ខុទាំងឡាយក្រាលថ្វាយ មានព្រះពុទ្ធបំណងទ្រង់សម្តែងធម្មីកថា ទាក់ទងនឹងបុព្វេនិវាសញ្ញាណដល់ភិក្ខុទាំងនោះ ក្នុងទីបំផុតនៃពាក្យសួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ អ្នកទាំងឡាយអង្គុយប្រជុំគ្នា និយាយអំពីរឿងអ្វីនិងពាក្យធ្វើយតាំងពីដើមថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងរោងករេរិមណ្ឌលនេះ ក៏កើតការសន្ធនាធម៌ឡើង ទាក់ទងនឹងបុព្វេនិវា-សញ្ញាណថា បុព្វេនិវាស បុព្វេនិវាស ដូច្នេះ ទើបត្រាស់ពាក្យជាដើមថា ពួកអ្នកប្រាថ្នានឹងស្តាប់ឬ ។

ក្នុងបទទាំងនោះ បទថា **ឥច្ចេយ្យាថ ឆោ** ប្រែថា អ្នកទាំងឡាយចង់ស្តាប់ធម្មីកថាប្រកបដោយបុព្វេនិវាសដែរឬ ។ លំដាប់នោះ ភិក្ខុទាំងឡាយ

មានចិត្តត្រេកអរ កាលនឹងអារាធនាចំពោះព្រះមានព្រះភាគ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគដល់វេលាហើយ ដែលព្រះអង្គនឹងទ្រង់ធ្វើធម្មីកថានេះ ។ ក្នុងបទទាំងនោះ បទថា **ឯតស្ស** *គឺការធ្វើធម្មីកថានេះ ។*

លំដាប់នោះ ព្រះមានព្រះភាគទទួលពាក្យអារាធនារបស់ភិក្ខុទាំងនោះ ទ្រង់មានព្រះបំណងនឹងសម្តែង ទើបទ្រង់បបួលភិក្ខុទាំងនោះឲ្យផ្ទៀងត្រចៀកស្តាប់ និងតាំងចិត្តស្តាប់ដោយល្អ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ ហើយទ្រង់មានព្រះបំណងនឹងប្រកាសការរឭកដល់ផ្លូវដែលកាត់ផ្តាច់ហើយ មិនទូទៅទៅដល់ជនពួកដទៃ ទើបត្រាស់ពាក្យថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីភទ្ទកប្បនេះ ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **យំ វិបស្សី** *គឺព្រះមានព្រះភាគព្រះនាមថា វិបស្សីក្នុងកប្បណា ។ ពិតហើយ* **យំ** *សព្ទនេះ ប្រើក្នុងបឋមាវិភត្តិ ក្នុងបទទាំងឡាយជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលព្រះមានព្រះភាគ នូវសេចក្តីដែលខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះមុខ បានទទួលក្នុងទីចំពោះមុខ នៃពួកទេវតាជាន់តាវត្តិង្ស ។ ប្រើក្នុងទុតិយាវិភត្តិ ក្នុងបទទាំងឡាយជាដើមថា ខ្ញុំបានសួរនូវធម៌ណា ព្រះអង្គក៏បានសម្តែងធម៌នោះ ដល់ខ្ញុំរួចហើយ ខ្ញុំសូមសួរធម៌ផ្សេងទៀត សូមព្រះអង្គសម្តែងធម៌នោះដល់ខ្ញុំ ឲ្យទាន ដូច្នេះ ។ ប្រើក្នុងតតិយាវិភត្តិ ក្នុងបទទាំងឡាយជាដើមថា ព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គគប្បីកើតឡើង មិនមុនមិនក្រោយ ក្នុងលោកធាតុតែមួយ គឺចក្កវាឡមួយ ដោយហេតុណា ហេតុនោះមិនមែនជាហេតុ មិនមែនជាបច្ច័យ គឺថា ហេតុនោះ មិនមានឡើយ ។ តែក្នុងបទនេះ គប្បីជ្រាបថា*

ប្រើក្នុងសត្តមីវិភត្តិ។ ព្រោះដូច្នោះ ទើបលោកពោលថា **យស្មឹ កប្បេ** ប្រែថា ក្នុងកប្បណា ។

បទថា **ឧឌ្ឍាធិ** សេចក្តីថា ញុំាងលោកធាតុ ១ ម៉ឺន ឲ្យបន្ទឺកើតទ្បឺងហើយ ។ បទថា **ភទ្ទកប្បេ** សេចក្តីថា ក្នុងសុទ្ធរកប្ប គឺក្នុងសារកប្ប ព្រោះមានព្រះពុទ្ធទ្រង់កើតទ្បឺង ៥ ព្រះអង្គ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សរសើរកប្បនេះ ទើបត្រាស់យ៉ាងនេះ ។

បានឮមកថា តាំងពីព្រះមានព្រះភាគនៃយើង ទ្រង់បំពេញអភិនីហារ មកក្នុងចន្លោះនេះ កប្បដែលមានព្រះពុទ្ធកើតទ្បឺង ៥ អង្គមិនមាន ។ ក៏ប៉ុន្តែមុនអភិនីហារបស់ព្រះមានព្រះភាគនៃយើង ព្រះពុទ្ធ ៤ ព្រះអង្គ គឺព្រះតណ្ហង្ករ ១ ព្រះមេធង្ករ ១ ព្រះសរណង្ករ ១ ព្រះទីបង្ករ ១ ទ្រង់កើតទ្បឺងហើយ ក្នុងកប្បតែមួយជាមួយគ្នា ។ ក្នុងចំណែកដែលផុតអំពីព្រះពុទ្ធទាំងនោះហើយ កប្បសូន្យទទេចាកព្រះពុទ្ធ ដល់ទៅមួយអសង្ខ្យៃយ្យានោះឯង ។ ក្នុងទីបំផុតនៃមួយអសង្ខ្យៃយ្យកប្ប ព្រះពុទ្ធព្រះនាមថា កោណ្ឌញ្ញៈតែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់កើតទ្បឺងក្នុងកប្បមួយ ។ តអំពីនោះ មកទៀតក៏សូន្យចាកព្រះពុទ្ធ អស់មួយអសង្ខ្យៃយ្យកប្បទៀត ។ ក្នុងទីបំផុតនៃមួយអសង្ខ្យៃយ្យកប្បនោះ ព្រះពុទ្ធ ៤ ព្រះអង្គ គឺព្រះសុមង្គលៈ ១ ព្រះសុមនៈ ១ ព្រះរេវតៈ ១ ព្រះសោភិតៈ ១ ទ្រង់កើតទ្បឺងក្នុងកប្បមួយជាមួយគ្នា ។ បន្ទាប់ពីនោះ ក៏សូន្យចាកព្រះពុទ្ធអស់មួយអសង្ខ្យៃយ្យកប្ប ។ ក្នុងទីបំផុតនៃមួយអសង្ខ្យៃយ្យកប្បនោះ ព្រះពុទ្ធ ៣ ព្រះអង្គ គឺព្រះអនោមទស្សី ១ ព្រះបទុមៈ ១ ព្រះនារទៈ ១ ទ្រង់កើតទ្បឺងក្នុងកប្បមួយជាមួយគ្នា ។ អំពីនោះ ក៏

សូន្យចាកព្រះពុទ្ធ អស់មួយអសង្ខេយ្យ ។ ក្នុងទីបំផុតអសង្ខេយ្យកប្បនោះ ព្រះដ៏មានព្រះភាគព្រះនាមថា ព្រះបទុមុត្តរ: តែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់កើតឡើងក្នុងកប្បមួយ ។ បន្ទាប់អំពីអស់សាសនាព្រះបទុមុត្តរ:មក ចំនួន ៧ ម៉ឺនកប្ប (បើរាប់អំពីភទ្ទកប្បនេះទៅ ៣ ម៉ឺនកប្ប) មានព្រះពុទ្ធពីរព្រះអង្គ គឺព្រះសុមេធ: ១ ព្រះសុជាត: ១ ទ្រង់ឡើងក្នុងកប្បនោះ ។ ក្រោយអស់សាសនាព្រះសុជាតសម្ពុទ្ធទៅ កន្ថងមកទៀត ២ ម៉ឺន ៨ ពាន់ ២ រយកប្ប (បើរាប់អំពីភទ្ទកប្បនេះទៅ ១៨០០ កប្ប) មានព្រះពុទ្ធ ៣ ព្រះអង្គ គឺព្រះបិយទស្សី ១ ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១ កើតឡើងក្នុងកប្បនោះ ។ បន្ទាប់ពីនោះមកចំនួន ១៧០៦ កប្ប (បើរាប់ពីភទ្ទកប្បនេះទៅ ៩៤ កប្ប) មានព្រះសម្ពុទ្ធព្រះនាមសិទ្ធត្ថមួយព្រះអង្គប៉ុណ្ណោះ កើតឡើងក្នុងកប្បនោះ ។ ក្នុងកប្បបន្ទាប់មក គឺកប្បជាប់គ្នានោះឯង (បើរាប់ពីភទ្ទកប្បនេះទៅ ៩២ កប្ប) មានព្រះពុទ្ធ ២ ព្រះអង្គ គឺព្រះតិស្ស: ១ ព្រះបុស្ស: ១ ឡើងឡើងក្នុងកប្បនោះ ។ បន្ទាប់ពីកប្បនោះមក គឺកប្បជាប់គ្នានោះឯង (បើរាប់ពីភទ្ទកប្បនេះទៅ ៩១ កប្ប) ព្រះពុទ្ធវិបស្សីមួយអង្គប៉ុណ្ណោះ កើតឡើងក្នុងកប្បនោះ ។ តអំពីនោះមក ៥៩ កប្ប (បើរាប់ពីភទ្ទកប្បនេះទៅ ៣១ កប្ប) មានព្រះពុទ្ធ ២ ព្រះអង្គ គឺព្រះសិខី ១ ព្រះវេស្សភូ ១ កើតឡើងក្នុងកប្បនោះ ។ ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធ ៤ ព្រះអង្គ គឺព្រះកកុសន្ធ: ព្រះកោនាគមន: ព្រះកស្សប ព្រះសម្មាសម្ពុទ្ធនៃយើងកើតឡើង ឯព្រះមេត្តេយ្យ ទ្រង់នឹងកើតឡើងជាខាងក្រោយ ។ កប្បនេះជាសុន្ទរកប្ប ជាសារកប្ប ព្រោះមានព្រះពុទ្ធទ្រង់កើតឡើង ៥ ព្រះអង្គ ដោយប្រការយ៉ាងនេះ ដូច្នោះ កាលព្រះមានព្រះភាគ ទ្រង់សរសើរកប្បនេះ ទើបត្រាស់យ៉ាងនេះ ។

សួរថា ប្រការដែលថា ព្រះពុទ្ធប្រមាណប៉ុណ្ណោះ ទ្រង់ឧប្បត្តិកឡើង ហើយក្តី នឹងទ្រង់ឧប្បត្តិកឡើងក្តីក្នុងកប្បនេះ រមែងជាការប្រាកដដល់ព្រះពុទ្ធ ទាំងឡាយប៉ុណ្ណោះឬ ឬថា រមែងប្រាកដសូម្បីដល់អ្នកដទៃផងដែរ ឆ្លើយថា រមែងប្រាកដដល់អ្នកដទៃផងដែរ ។ សួរថា ដល់នរណា ឆ្លើយថា ដល់ព្រហ្មជាន់សុទ្ធាវាស ។

ពិតហើយ ក្នុងកាលតាំងនៅនៃកប្ប កាលលោកសន្និវាសតាំងនៅរហូត មួយអសង្ខ្យេយ្យ ភ្លៀងចាប់ផ្តើមធ្លាក់ដើម្បីឲ្យលោកតាំងនៅ ។ រមែងដូចជាទឹក សន្សើម ធ្លាក់ក្នុងទីបំផុតដែនពីដើមនោះឯង ។ តពីនោះ ក៏មានជាតំណក់ទឹក ប្រមាណប៉ុនគ្រាប់កន្ធក់ ប៉ុនគ្រាប់ល្ង ប៉ុនគ្រាប់អង្ករ ប៉ុនគ្រាប់សណ្តែកបាយ ប៉ុនគ្រាប់សណ្តែករាជមាស ប៉ុនផ្លែពុទ្រា ប៉ុនផ្លែកន្ធតព្រៃ ប៉ុនផ្លែល្ពៅ ប៉ុនផ្លែត្រឡាច ប៉ុនផ្លែឃ្លោក ជាខ្សែទឹកចម្រើនឡើងដោយលំដាប់មួយឧសភៈ ពីរឧសភៈ កន្ទុះគាវុត មួយគាវុត កន្ទុះយោជន៍ មួយយោជន៍ ពីរយោជន៍ បីយោជន៍ ១០ យោជន៍ ។បេ។ សែនយោជន៍ជាប្រមាណ តាំងនៅបរិបូណ៌ក្នុងចន្លោះសែនកោដិចក្រវាល ដរាបដល់អកនិដ្ឋព្រហ្មលោក ។ លំដាប់នោះ ទឹកនោះស្រកចុះដោយលំដាប់ កាលទឹកស្រកចុះ ទេវលោកទាំងឡាយ រមែងតាំងនៅក្នុងទីរបស់ទេវលោកជាប្រក្រតី ។ ការកកើតនៃទេវលោកទាំងនោះ លោកពោលហើយ ក្នុងបុព្វេនិវាសកថា ក្នុងវិសុទ្ធិមគ្គ ។

ហានៈរបស់មនុស្សលោក ដូចកាលទឹកចូលទៅ ហើយបិទមាត់ធម្មក្រកជិត ទឹកនោះក៏នៅបានដោយអំណាចខ្យល់ ។ ផែនដីរមែងតាំងនៅបានដូចស្លឹកឈូកនៅលើផ្ទៃទឹក ។ ទីមហាពោធិបល្ល័ង្ក កាលលោកវិនាស ក៏វិនាសក្រោយ កាលលោកតាំងឡើង ក៏ប្រាកដឡើងមុន ។ ក្នុងទីពោធិបល្ល័ង្កនោះ ឈូកមួយ

គុម្ព រមែងកើតឡើង ជាបុព្វនិមិត្ត ប្រសិនបើក្នុងកប្បនោះ ទីពោធិបល្ល័ង្កនោះ ព្រះពុទ្ធនឹងទ្រង់ឧប្បត្តិ ផ្កាឈូករមែងកើតឡើង បើទ្រង់មិនឧប្បត្តិ ផ្កាឈូកនឹងមិនកើត ។ មួយទៀត កាលផ្កាឈូកកើត បើព្រះពុទ្ធមួយអង្គនឹងឧប្បត្តិ ក៏កើតផ្កាតែមួយ ។ បើព្រះពុទ្ធនឹងឧប្បត្តិ ២ អង្គ ៣ អង្គ ៤ អង្គ ៥ អង្គ ផ្កាឈូកក៏កើត ៥ ផ្កា ។ មួយទៀត ផ្កាឈូកទាំងនោះ ជាផ្កាមានចង្កោមជាប់គ្នាក្នុងទងតែមួយនុ៎ះឯង សុទ្ធាវាសព្រហ្មទាំងឡាយបបួលគ្នាថា លោកអ្នកនិទ្ទុក្ខទាំង-ឡាយ ពួកយើងចូរមក នឹងឃើញបុព្វនិមិត្ត ហើយនាំគ្នាមកកាន់មហាពោធិបល្ល័ង្កស្ថាន ។ ក្នុងកប្បដែលព្រះពុទ្ធទាំងឡាយទ្រង់មិនឧប្បត្តិ ផ្កាឈូកក៏មិនមាន ។ ពួកទេវតាទាំងឡាយ ឃើញគុម្ពឈូកមិនមានផ្កា ក៏មានសេចក្តីសង្វេគថា ម្នាលគ្នាយើង លោកនឹងឆាប់តឈឹងហ្ន៎ សត្វទាំងឡាយត្រូវឆាប់តគ្រប់សង្កត់ នឹងពេញក្នុងអបាយ ទេវលោក ៦ ព្រហ្មលោក ៩ នឹងទំនេរ បើឃើញផ្កាឈូកក្នុងវេលារីក នាំគ្នាសប្បាយចិត្តថា កាលព្រះសព្វញ្ញូពោធិសត្វទ្រង់ឈានចុះកាន់គភ៌ព្រះមាតា ប្រសូត ត្រាស់ដឹង ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ទ្រង់ធ្វើយមកបាដិហារ្យ ចុះអំពីទេវលោក ទ្រង់ជាក់អាយុសង្ខារ ស្តេចរម្ងាប់ខន្ធបរិនិព្វាន ពួកយើងនឹងឃើញបាដិហារ្យដែលធ្វើឲ្យម៉ឺនចក្រវាលញាប់ញ័រ អបាយទាំង ៤ នឹងវិនាសសាបសូន្យ ទេវលោក ៦ ព្រហ្មលោក ៩ នឹងបរិបូណ៌ ក៏នាំគ្នាបន្ទុំឧទានទៅកាន់ព្រហ្មលោករបស់ខ្លួន រៀងៗ ខ្លួន ។ ម្យ៉ាងទៀត ផ្កាឈូក ៥ កើតឡើងហើយក្នុងកប្បនេះ ។ សុទ្ធាវាសព្រហ្មទាំង-ឡាយ កាលឃើញផ្កាឈូកទាំងនោះ ក៏ដឹងសេចក្តីនេះថា ព្រះពុទ្ធ ៤ ព្រះអង្គទ្រង់ឧប្បត្តិកហើយ អង្គទី ៥ នឹងឧប្បត្តិកតទៅ ដូច្នេះ ដោយអានុភាពនៃនិមិត្តទាំងនោះ ព្រោះហេតុនោះ ទើបលោកពោលថា សេចក្តីនោះ ជាការ

ប្រាកដដល់អ្នកដទៃ ដូច្នេះ ព្រោះហេតុនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងបុព្វេនិវាស ដោយអំណាចកំណត់កប្ប ដោយនយជាដើមថា ម្នាលភិក្ខុទាំង-ឡាយ រាប់អំពីនេះទៅ ដូច្នេះ ។ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងដោយអំណាចការកំណត់ជាតិជាដើម របស់ព្រះពុទ្ធទាំងនោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ ព្រះវិបស្សីមានព្រះភាគ ដូច្នេះ ។

អធិប្បាយ ការកំណត់អាយុជាដើម

[២-៤] *ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់អាយុ ដូច្នេះ បទទាំងពីរនេះថា* **បរិត្តំ លហុកំ** *ជាវេវចនៈរបស់អាយុតិចនុ៎ះឯង ។ ព្រោះថា អាយុណាតិច អាយុនោះ រមែងជារបស់បន្តិចបន្តួច និងស្ដួចស្ដើង ។ បទថា* **អប្បំ វា កិយ្យា** *គឺអាយុច្រើនជាង ១០០ ឆ្នាំ មានតិច ។ គ្រានៅមិនដល់ ១០០ ឆ្នាំ រមែងរស់នៅ ២០ ឆ្នាំ ៣០ ឆ្នាំ ៤០ ឆ្នាំ ៥០ ឆ្នាំ ឬ ៦០ ឆ្នាំ ។ តែអ្នកអាយុវែងយ៉ាងនេះ លំបាកវាកបានណាស់ បានឮថា អ្នកឯណោះនៅយូរយ៉ាងនេះ គួរនាំគ្នាទៅមើលក្នុងទីនោះៗ ។ បណ្តាអ្នកមានអាយុវែងនោះ ឧបាសិកាវិសាខានៅបាន ១២០ ឆ្នាំ ពោក្កវសាតិព្រាហ្មណ៍ ព្រហ្មាយុព្រាហ្មណ៍ សេលព្រាហ្មណ៍ ពាវរីព្រាហ្មណ៍ ព្រះអានន្ទត្ថេរ ព្រះមហាកស្សបត្ថេរ ក៏មានអាយុ ១២០ ដូចគ្នា តែព្រះអនុរុទ្ធត្ថេរ នៅដល់ ១៥០ ឆ្នាំ ព្រះពាកុលត្ថេរនៅដល់ ១៦០ ឆ្នាំ ភិក្ខុរូបនេះ មានអាយុវែងជាងគេទាំងអស់ ។ សូម្បីលោកក៏នៅមិនដល់ ២០០ ឆ្នាំ ។ ព្រះពោធិសត្វទាំងឡាយ មានព្រះវិបស្សីជាដើម ចុះកាន់បដិសន្ធិ ក្នុងគភ៌ព្រះមាតា ដោយអសង្ខារិកចិត្ត សហគតៈដោយសោមនស្ស និងសម្បយុត្តដោយញាណ ដែលជាចំណែក*

ខាងដើមនៃមេត្តា កាលបដិសន្ធិដោយចិត្តនោះ នឹងមានអាយុមួយអសង្ខ្យៃយ្យ ។ ដោយហេតុនេះ ទើបព្រះពុទ្ធទាំងពួង មានព្រះជន្មាយុមួយអសង្ខ្យៃយ្យ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះអង្គទាំងនោះ មិនតាំងនៅដល់អសង្ខ្យៃយ្យ ឆ្លើយថា វិបត្តិនៃរដូវ និងកោជន ពិតហើយ អាយុរមែងសាបសូន្យខ្លះ រមែងចម្រើនខ្លះ ដោយអំណាចនៃឧតុ និងកោជន ។ ក្នុងសេចក្តីនោះ កាលណាព្រះរាជាទាំងឡាយ មិនប្រកបដោយធម៌ កាលនោះ ឧបរាជ សេនាបតី សេដ្ឋី សកលនគរ សកលរដ្ឋ ក៏មិនប្រកបដោយធម៌ដូចគ្នា ។ កាលនោះ អាកូ-ទេវតានៃជនទាំងនោះ កុម្មទេវតាជាមិត្តរបស់ទេវតាទាំងនោះ អាកាសដ្ឋក-ទេវតា ជាមិត្តរបស់កុម្មទេវតា ឧណ្ហវលាហកទេវតា ជាមិត្តរបស់អាកាស-ដ្ឋកទេវតា អព្ភវលាហកទេវតា ជាមិត្តរបស់ឧណ្ហវលាហកទេវតាទាំងនោះ សីតវលាហកទេវតា ជាមិត្តរបស់អព្ភវលាហកទេវតាទាំងនោះ វស្សវលា-ហកទេវតា ជាមិត្តរបស់សីតវលាហកទេវតាទាំងនោះ ចាតុម្មហារាជិកាទេវតា ជាមិត្តរបស់វស្សវលាហកទេវតាទាំងនោះ តាវត្តិង្សទេវតា ជាមិត្តរបស់ចាតុ-ម្មហារាជិកាទេវតាទាំងនោះ យាមាទេវតា ជាមិត្តរបស់តាវត្តិង្សទេវតាទាំងនោះ ជាដើម ដរាបដល់ភវគ្គព្រហ្ម រៀវព្រះអរិយសាវកទេវតាទាំងអស់ សូម្បីព្រហ្មបរិស័ទ ក៏ជាអ្នកមិនប្រកបដោយធម៌ ។ ព្រះចន្ទ ព្រះអាទិត្យ រមែងដើរទៅទាបខ្ពស់ៗ ព្រោះទេវតាទាំងនោះមិនប្រកបដោយធម៌ ។ ខ្យល់រមែងមិនបក់ទៅតាមផ្លូវខ្យល់ ។ កាលខ្យល់មិនបក់ទៅតាមផ្លូវខ្យល់ រមែងធ្វើឲ្យវិមានដែលតាំងនៅលើអាកាសញ័ររញ្ជួយ ។ កាលវិមានញ័ររញ្ជួយ ពួកទេវតាក៏មិនមានចិត្តនឹងទៅលេងកីឡា កាលទេវតាមិនមានចិត្តនឹងទៅលេងកីឡា រដូវត្រជាក់ រដូវក្តៅ រមែងមិនប្រព្រឹត្តទៅតាមរដូវកាល ។ កាលរដូវមិន

ប្រព្រឹត្តទៅតាមវដ្តវារកាល ភ្លៀងរមែងមិនធ្លាក់ដោយល្អ គ្រាខ្លះ ធ្លាក់ គ្រាខ្លះ មិនធ្លាក់ ក្នុងទីកន្លែងខ្លះ ធ្លាក់ ក្នុងទីកន្លែងខ្លះ មិនធ្លាក់ ក៏កាលធ្លាក់ រមែងធ្លាក់ ខណៈសាបព្រោះ ខណៈបែកពន្លកខណៈបែកដើម ខណៈចេញកួរខណៈជាក់ទឹកដោះជាដើម រមែងធ្លាក់មិនជាឧបការៈដល់ស្រូវឡើយ និងរាំងស្ងួតអស់កាលយូរ ដោយហេតុនោះ ទើបស្រូវទុំមិនព្រមគ្នា ប្រាសចាកសម្បត្តិ មានភ្ជិនពណ៌ និងរសជាដើម ។ សូម្បីក្នុងបាយដែលដាក់ក្នុងភាជនៈតែមួយជាមួយគ្នា បាយមួយចំណែកឆៅ មួយចំណែកជ្រាយ មួយចំណែកខ្ទោច ។ បរិភោគបាយនោះចូលទៅ រមែងដល់អាការ ៣ យ៉ាងក្នុងផ្ទៃ ។ សត្វទាំងឡាយជាអ្នកមានរោគច្រើន និងមានអាយុតិច ដោយហេតុនោះ អាយុរមែងសាបសូន្យដោយអំណាចនៃវដ្ត និងភោជនដោយប្រការដូច្នេះ ដោយពិត ។

ទេវតាទាំងពួង រហូតដល់ព្រហ្មលោក រមែងជាអ្នកប្រកបដោយធម៌ ដោយន័យដែលមានក្នុងខាងដើមថា កាលណាព្រះរាជាជាអ្នកប្រកបដោយធម៌ កាលនោះ សូម្បីសេនាបតី និងឧបរាជ ក៏ជាអ្នកប្រកបដោយធម៌ ដូច្នេះ ព្រោះពួកទេវតាទាំងនោះ តាំងនៅក្នុងធម៌ ព្រះចន្ទ និងព្រះអាទិត្យ រមែងធ្វើដំណើរទៅដោយស្មើ ។ ខ្យល់រមែងបក់ទៅតាមផ្លូវរបស់ខ្យល់ រមែងមិនធ្វើឲ្យវិមានដែលតាំងនៅលើអាកាសញ័រពេញ ។ កាលវិមានមិនញ័រពេញ ពួកទេវតាក៏មានចិត្តលេងកីឡា ។ វដ្តវារមែងប្រព្រឹត្តទៅតាមកាលយ៉ាងនេះ ។ ភ្លៀងរមែងធ្លាក់ដោយប្រពៃ ជំនួយដល់ស្រូវ តាំងពីខណៈសាបព្រោះ ធ្លាក់តាមវេលា ដោយហេតុនោះ ស្រូវទុំព្រមគ្នា មានភ្ជិនក្រអូប មានពណ៌ល្អ មានរសឆ្ងាញ់ មានឱជា ។ ភោជនដែលផ្សំដោយស្រូវនោះ បរិភោគហើយ ក៏ដល់ការរលួយងាយ សត្វទាំងឡាយជាអ្នកមិនមានរោគ មានអាយុវែង ដោយហេតុ

នោះ ។ អាយុរមែងចម្រើនដោយអំណាចដូវ និងភោជន ដោយប្រការដូច្នេះ ។ ក្នុងបណ្តាព្រះមានព្រះភាគទាំងនោះ ព្រះមានព្រះភាគព្រះនាម **វិបស្សី** *ទ្រង់កើតឡើងក្នុងសម័យដែលសត្វមានអាយុ ៨០០០០ ឆ្នាំ* **ព្រះសិខី** *ទ្រង់កើតឡើងក្នុងសម័យដែលសត្វមានអាយុ ៧០០០០ ឆ្នាំ ដូច្នោះ លោកកំណត់អាយុនេះ ហាក់ដូចជាសាបសូន្យទៅដោយលំដាប់ តែមិនមែនសាបសូន្យយ៉ាងនោះ ។ គប្បីជ្រាបថា អាយុចម្រើន ចម្រើនហើយវិនាស ។ សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ក្នុងកប្បនេះ ព្រះមានព្រះភាគ ព្រះនាមថា* **ककुसन्ध** *ទ្រង់កើតឡើងក្នុងសម័យ ដែលសត្វមានអាយុ ៤០០០០ ឆ្នាំ កំណត់អាយុ ៥ ចំណែក តាំងនៅ ៤ ចំណែក កាលដល់ចំណែកទី ៥ ក៏បរិនិព្វាន ។ អាយុនោះវិនាសដល់កាលកិរិយានៃអាយុ ១០ ឆ្នាំ ហើយចម្រើនឡើងទៀតជា ១ អសង្ខ្យេយ្យ តពីនោះក៏វិនាស តាំងនៅក្នុងសម័យដែលសត្វមានអាយុ ៣០០០០ ឆ្នាំ ។ កាលនោះ ព្រះមានព្រះភាគ ព្រះនាមថា* **កោនាគមន** *ទ្រង់កើតឡើង ។ កាលព្រះកោនាគមន:និព្វានហើយយ៉ាងនោះ អាយុនោះថយចុះដល់អាយុ ១០ ឆ្នាំស្ងាប់ ហើយចម្រើនឡើងទៀតរហូតដល់ ១ អសង្ខ្យេយ្យ តាំងនៅក្នុងខណ:ដែលសត្វមានអាយុ ២០០០០ ឆ្នាំ ។ កាលនោះ ព្រះមានព្រះភាគព្រះនាម* **កស្សប** *ទ្រង់កើតឡើង ។ កាលព្រះកស្សបនោះបរិនិព្វានយ៉ាងនោះហើយ អាយុនោះ ក៏ថយចុះដល់ ១០ ឆ្នាំស្ងាប់ ហើយចម្រើនឡើងទៀតដល់ ១ អសង្ខ្យេយ្យ ហើយថយចុះ រហូតដល់អាយុ ១០០ ឆ្នាំស្ងាប់ ។ ពេលនោះ ព្រះសម្មាសម្ពុទ្ធនៃយើង ទ្រង់កើតឡើង ។ អាយុមិនបានវិនាសចុះដោយលំដាប់យ៉ាងនោះ គប្បីជ្រាបថា ចម្រើនចម្រើនហើយ*

ទើបវិនាស ។ ក្នុងសេចក្តីនោះ គប្បីជ្រាបថា ប្រការដែលកាលបើមនុស្ស ទាំងឡាយមានអាយុចម្រើន ព្រះពុទ្ធរមែងទ្រង់កើតឡើងនោះឯង ជាកំណត់ អាយុរបស់ព្រះពុទ្ធទាំងនោះ ។ ការកំណត់អាយុចប់ប៉ុណ្ណោះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងការកំណត់ស្ថានទីត្រាស់ដឹង ដូច្នេះ

[๕] *បទថា* **ចាជលិយា ម្ហូលេ** *គឺខាងក្រោមដើមច្រនៀង ។ ដើម ច្រនៀងនោះ មានកំពស់ ๑๐๐ ហត្ថ គឺថ្ងៃនោះ ដើមលូតឡើងទៅ ๕๐ ហត្ថ មែក ๕๐ ហត្ថ ។ មួយទៀត ដើមច្រនៀងនោះ ក្នុងថ្ងៃនោះ មានផ្កាភ្ជាប់ជា ចង្កោម គ្របជណ្តប់ពាសពេញតាំងពីគល់ដល់ចុង ។ ក្អិនទិព្វបក់ផាត់ទៅ ។ មិនមែនមានផ្កាតែដើមច្រនៀងនេះមួយប៉ុណ្ណោះទេដែលរីក ។ ដើមច្រនៀង ទាំងអស់ ក្នុងម៉ឺនចក្រវាលក៏រីក ។ មិនមែនច្រនៀងតែម្យ៉ាងរីកនោះទេ ។ បណ្តាដើមឈើទាំងអស់ ក្នុងម៉ឺនចក្រវាលក៏រីក ឈូកគុម្ពមានផ្ការីកត្រង់គុម្ព ឈូកថ្នាំងមានផ្ការីកត្រង់ថ្នាំង ឈូកមែកមានផ្ការីកត្រង់មែក ឈូកវល្លិ មាន ផ្ការីកត្រង់វល្លិ ឈូកអាកាសមានផ្ការីកក្នុងអាកាស ឈូកក្រហមដុះទម្លុះផែនដី ឡើងមក ។ មហាសមុទ្រ ក៏ដេរដាសទៅដោយបទុម ๕ ប្រភេទ និងដោយ ឈូកស ឈូកក្រហម ។ ទាំងម៉ឺនចក្រវាល បានមានពពួកផ្កាឈើដូចជាទង់ ដេរដាសទៅដោយកម្រងផ្កា ជាប់គ្នានឹងគំនរផ្កាដែលជ្រុះក្នុងទីនោះៗ ព្រោង ព្រាត ទៅដោយផ្កាឈើពណ៌ផ្សេងៗ ហាក់ដូចជាសួននន្ទវន ចិត្តលតាវន មិស្សកវន និងបារុសកវន ។ ដូចជាលើកទង់ឡើងក្នុងកណ្តាប់ចក្រវាលនៃ ទិសខាងកើត ទៅទល់នឹងកណ្តាប់ចក្រវាលនៃទិសខាងលិច ។ និងដូចលើក ទង់ឡើង ក្នុងកណ្តាប់ចក្រវាលនៃទិសខាងលិច ទិសខាងត្បូង ទិសខាងជើង*

ទៅទល់នឹងមាត់កណ្តាប់ចក្រវាលនៃទិសខាងត្បូង ។ ប្រាកដជាចក្រវាលដែលបរិបូណ៌ដោយសិរីដល់គ្នានិងគ្នាយ៉ាងនេះ ។ បទថា **អភិសម្ពុទ្ធោ** *សេចក្តីថា ចាក់ផ្ទុះគុណ សេចក្តីចម្រើន សិរីដែលជាពុទ្ធ គឺត្រាស់ដឹងក្រៃលែងនូវអរិយសច្ច ៤ ។ សូម្បីក្នុងបទទាំងឡាយជាដើមថា ម្នាលភិក្ខុទាំងឡាយ ព្រះសិខីមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធត្រាស់ក្រោមដើមបុណ្ឌរីកព្រឹក្ស (ដើមស្វាយស) គប្បីជ្រាបពណ៌នាដោយនយនេះឯង ។*

បទថា **បុណ្ឌរីកោ** *ក្នុងទីនេះ គឺដើមស្វាយសមានរសផ្អែម ។ ដើមស្វាយសនេះ ក៏មានកម្ពស់ និងទំហំដូចគ្នា ។ មួយទៀត ក្នុងថ្ងៃនោះ ដើមស្វាយនោះ ក៏គ្របដណ្តប់ទៅដោយផ្កាដែលជាទិព្វ និងមានក្លិនក្រអូប ។ មិនមែនផ្កាតែម្យ៉ាង ក៏មានផ្លែផង ។ ស្វាយនោះម្ខាងផ្លែខ្ចី ម្ខាងផ្លែកណ្តាល ម្ខាងផ្លែស្រគាល ម្ខាងផ្លែទុំមានរសឆ្ងាញ់ មានឱជាដូចជាក់ទិព្វឱជាចូលទៅសំយុងចុះរយោង ។ ដើមស្វាយនោះយ៉ាងណា ក្នុងម៉ឺនចក្រវាលក៏យ៉ាងនោះ ដើមឈើដែលចេញផ្កាក៏បានប្រដាប់ដោយផ្កា ដើមឈើដែលចេញផ្លែ ក៏បានប្រដាប់ដោយផ្លែ ។*

បទថា **សាលោ** *គឺដើមរាំងក្នុំ ។ ដើមរាំងក្នុំនោះ ក៏មានកម្ពស់ និងទំហំដូចគ្នា ។ គប្បីជ្រាបផ្កា សិរី និងសេចក្តីចម្រើនយ៉ាងនោះដូចគ្នា ។ សូម្បីក្នុងដើមច្រេស ក៏នយនេះដូចគ្នា ។ ក្នុងដើមល្វាមិនមានផ្កា ការដុះលូតលាស់នៃផ្លែល្វានេះ មានន័យដូចពោលហើយ ក្នុងដើមស្វាយនោះឯង ។ ក្នុងដើមជ្រៃ ក្នុងដើមពោធិ៍បាយ ក៏ដូចគ្នាដែរ ។ បល្ល័ង្ករបស់ព្រះពុទ្ធគ្រប់ព្រះអង្គក៏ដូចគ្នា ។ តែដើមឈើដទៃអំពីគ្នា ។ ក្នុងបណ្តាដើមឈើទាំងនោះ ព្រះពុទ្ធទាំងឡាយ*

ត្រាស់ដឹង ពោល គឺបានមគ្គញ្ញាណ ๔ ក្រោមដើមឈើណាមួយ ដើមឈើ នោះៗលោកហៅថា **ពោធិ ។** *នេះឈ្មោះថា កំណត់ស្ថានទីត្រាស់ដឹង ។*

[๖] *គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់សាវក ។ បទថា* **ទ្វេភតិស្សំ** *គឺសាវកឈ្មោះថា* **ទ្វេភ** *និង* **តិស្ស ។** *លោកទាំងពីរនោះ ព្រះទ្វេភៈ រួមបិតាតែមួយ ជាបួនព្រះតិស្សៈជាបុរោហិត ។ ព្រះទ្វេភៈសម្រេចដល់ទីបំផុតនៃបញ្ញាបារមី ព្រះតិស្សៈសម្រេចទីបំផុតនៃសមាធិបារមី ។បទថា* **អគ្គំ** *អធិប្បាយថា ជាបុគ្គលឧត្តម ព្រោះជាអ្នកមានគុណមិនដូចគ្នានឹងបុគ្គលដ៏សេស វៀរលែងតែព្រះមានព្រះភាគព្រះនាមថា វិបស្សីចេញ ។ បទថា* **ភទ្ទយុគំ** *អធិប្បាយថា ឈ្មោះថា គូដ៏ចម្រើន ព្រោះជាបុគ្គលដ៏កំពូល ។ បទថា* **អភិភូសម្ភវំ** *គឺសាវកឈ្មោះថា* **អភិភូ** *និង* **សម្ភវ** *លោកទាំងពីរនោះ ព្រះអភិភូសម្រេចទីបំផុតនៃបញ្ញាបារមី ចេញអំពីក្រុងអរុណាវតីជាមួយនឹងព្រះមានព្រះភាគព្រះនាមថាសិខី ទៅកាន់ព្រហ្មលោក ហើយសម្តែងបាដិហារ្យច្រើនយ៉ាងដល់ព្រហ្មបរិស័ទ សម្តែងធម៌ផ្សាយទៅទូទាំងមុខលោកធាតុ ធ្វើឲ្យឆងឹតឈឹង ហើយក៏ធ្វើឲ្យមានពន្លឺ ដល់អ្នកដែលកើតសង្វេគថា នេះអ្វី ហើយអធិដ្ឋានថា សូមឲ្យជនទាំងពួងចូរឃើញរូបរបស់យើង និងចូរបានឮសំឡេងរបស់យើងដូច្នេះ បានពោលពីរគាថាថា អ្នកទាំងឡាយចាប់ផ្តើមបាន ដូច្នេះជាដើម ឲ្យបានឮសំឡេង ។ ព្រះសម្ភវៈបានសម្រេចទីបំផុតនៃសមាធិបារមី ។*

បទថា **សោណុត្តរំ** *គឺព្រះសាវកឈ្មោះថា* **សោណ** *និង* **ឧត្តរ ។** *ក្នុងលោកទាំងពីរនោះ ព្រះសោណៈសម្រេចបញ្ញាបារមី ព្រះឧត្តរៈសម្រេចសមាធិបារមី ។*

បទថា **វិធុរសញ្ជីវំ** *គឺព្រះសាវ័កឈ្មោះថា* **វិធុរ** *និង* **សញ្ជីវ** *ក្នុងលោកទាំងពីរនោះ ព្រះវិធុរៈសម្រេចបញ្ញាបារមី ។ ព្រះសញ្ជីវៈសម្រេចសមាធិបារមី ជាអ្នកប្រាថ្នាចូលសមាបត្តិ ព្យាយាមដោយយកម្ចាំងសមាបត្តិ ក្នុងទីសម្រាកពេលយប់ សម្រាកពេលថ្ងៃ កុដិ ល្អាង និងមណ្ឌបជាដើម ចូលនិរោធក្នុងព្រៃ រហូតដល់អស់ថ្ងៃមួយ ។ អ្នកធ្វើការងារក្នុងព្រៃជាដើមយល់ថាលោកមរណភាព ទើបនាំគ្នាដុតលោក ។ ព្រះសញ្ជីវៈនោះ កាលចេញចាកសមាបត្តិតាមកំណត់ ឃ្លុំដណ្តប់ចីវរចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ អាស្រ័យហេតុនោះឯង ទើបជនទាំងឡាយ ស្គាល់លោកថា ព្រះសញ្ជីវៈដូច្នេះ ។*

បទថា **កិយ្យាសុត្តរំ** *គឺព្រះសាវ័កឈ្មោះថា* **កិយ្យាស** *និង* **ឧត្តរ** *។ ក្នុងលោកទាំងពីរនោះ ព្រះកិយ្យាសៈជាអ្នកកំពូលដោយបញ្ញា ព្រះឧត្តរៈជាអ្នកកំពូលដោយសមាធិ ។*

បទថា **តិស្សភារទ្វាជំ** *គឺព្រះសាវ័កឈ្មោះថា* **តិស្ស** *និង* **ភារទ្វាជ** *។ ក្នុងលោកទាំងពីរនោះ ព្រះតិស្សៈបានសម្រេចបញ្ញាបារមី ព្រះភារទ្វាជៈបានសម្រេចសមាធិបារមី ។*

បទថា **សារីបុត្តមោគ្គល្លានំ** *គឺព្រះសាវ័កឈ្មោះថា* **សារីបុត្រ** *និង* **មោគ្គល្លាន** *។ ក្នុងលោកទាំងពីរនោះ ព្រះសារីបុត្របានជាអ្នកកំពូលខាងបញ្ញា ព្រះមោគ្គល្លានបានជាអ្នកកំពូលខាងសមាធិ ។ នេះឈ្មោះថា កំណត់គូអគ្គសាវ័ក ។*

[๗] គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់ការប្រជុំសាវ័ក ។ ការប្រជុំគ្រា

ដំបូង របស់ព្រះមានព្រះភាគព្រះនាមថាវិបស្សី បានប្រកបដោយអង្គ ៤ គឺ ភិក្ខុទាំងអស់ជាឯហិភិក្ខុ ភិក្ខុទាំងអស់មានបាត្រ និងចីវរកើតឡើងដោយឫទ្ធិ ភិក្ខុទាំងអស់មិនបានណាត់គ្នាទេ ភិក្ខុទាំងនោះ មកប្រជុំគ្នាក្នុងថ្ងៃឧបោសថ ១៥ កើត ។

លំដាប់នោះ ព្រះសាស្តាប្រថាប់ចាប់ផ្តិត ញុាំងភិក្ខុឲ្យធ្វើឧបោសថ ។ គ្រាទី ២ គ្រាទី ៣ ក៏នយនេះឯង ។ក្នុងការប្រជុំទាំងអស់ របស់ព្រះពុទ្ធទាំងឡាយ ដ៏សេស ក៏ដូច្នោះ ។ តែព្រះមានព្រះភាគនៃយើងទាំងឡាយ បានធ្វើការប្រជុំក្នុងបឋមពោធិកាលប៉ុណ្ណោះ ព្រោះហេតុអ្វី ព្រះសូត្រនេះ លោកពោលហើយក្នុងភាគដទៃ ព្រោះដូច្នោះ ទើបលោកពោលថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគត មានសាវកសន្និបាតតែម្តង ដូច្នោះ ទើបការប្រជុំចប់ ។

ក្នុងបទថា **អឌ្ឍតេរសានិ ភិក្ខុសតានិ** សេចក្តីថា ភិក្ខុ ១២៥០ រូប គឺ បុរាណជដិល ១០០០ រូប បរិវារព្រះអគ្គសាវក ២៥០ រូប ។ ក្នុងបណ្តាភិក្ខុទាំងនោះគួរពោលដល់រឿងតាំងពីអភិនីហារបស់ព្រះអគ្គសាវកទាំងពីរហើយ សម្តែងដល់បព្វជ្ជា ។ មួយទៀត បណ្តាបព្វជិតទាំងនោះ ព្រះមហាមោគ្គល្លាន សម្រេចអរហត្តក្នុងថ្ងៃទី ៧ ។ ព្រះធម្មសេនាបតី កាលព្រះមានព្រះភាគទ្រង់សម្តែងវេទនាបរិគ្គហសូត្រ ជាធម្មយោគៈ ដែលត្រៀមដល់ទីយនខ-បរិព្វាជកជាក្មួយ ក្នុងល្អាងសូករខាតា នាភ្នំគិជ្ឈកូដ ក្នុងថ្ងៃទី ១៥ បញ្ចូនញាណទៅដើម្បីដឹងតាម ដោយរព្រឹកទៅតាមទេសនា បានសម្រេចសាវក-បារមីញាណ ។

ព្រះមានព្រះភាគ ជ្រាបដល់ការសម្រេចអរហត្តរបស់ព្រះថេរៈហើយ

ស្តេចយាងតាមអាកាស ទៅប្រាកដក្នុងព្រះវិហារវេឡុវ័ន ។ ព្រះថេរៈត្រិះរិះថា ព្រះមានព្រះភាគស្តេចយាងទៅណាហ្ន៎ កាលជ្រាបសេចក្តីដែលព្រះអង្គប្រតិស្ឋាននៅក្នុងព្រះវិហារវេឡុវ័ន សូម្បីលោកខ្លួនឯង ក៏ហោះតាមអាកាស ទៅប្រាកដក្នុងព្រះវិហារវេឡុវ័នដូចគ្នា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ប្រកាសបាតិមោក្ខ (ឱវាទបាតិមោក្ខ) ព្រះមានព្រះភាគ ទ្រង់សំដៅដល់ការប្រជុំនោះ ទើបត្រាស់ថា ភិក្ខុ ១២៥០ រូបជាដើម ។ នេះគឺកំណត់ការប្រជុំរបស់ព្រះសាវក ។

[៨] *គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់ឧបដ្ឋាកដូច្នេះ បទថា* **អានន្ទោ** *លោកពោលសំដៅដល់ព្រះអានន្ទត្ថេរ ជាឧបដ្ឋាកជាប្រចាំ ព្រោះថា ក្នុងបឋមពោធិកាល ព្រះមានព្រះភាគទ្រង់មិនមានឧបដ្ឋាកជាប្រចាំឡើយ ។ គ្រាខ្លះ ព្រះនាគសមាលៈកាន់បាត្រ និងចីវរតាមទ្រង់ ។ គ្រាខ្លះ ព្រះនាគិតៈ ។ គ្រាខ្លះ ព្រះឧបវាណៈ ។ គ្រាខ្លះ ព្រះសុនក្ខត្តៈ ។ គ្រាខ្លះ ចុន្ទសមណុទ្ទេសៈ ។ គ្រាខ្លះ ព្រះសាគតៈ ។ គ្រាខ្លះ ព្រះមេឃិយៈ ។*

ក្នុងបណ្តាលោកទាំងនោះ គ្រាខ្លះ ព្រះមានព្រះភាគស្តេចចារិកផ្លូវឆ្ងាយជាមួយនឹងព្រះនាគសមាលត្ថេរ ស្តេចដល់ផ្លូវបែកជាពីរ ។ ព្រះថេរៈចៀសចេញចាកផ្លូវ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងទៅតាមផ្លូវនេះ ។ ពេលនោះ ព្រះមានព្រះភាគត្រាស់នឹងព្រះថេរៈនោះថា មកភិក្ខុ យើងទៅផ្លូវនេះ ។ ព្រះថេរៈនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទទួលបាត្រ និងចីវរបស់ព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងទៅតាមផ្លូវនេះ ហើយប្រុងជាក់បាត្រ និងចីវរលើផែនដី ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ចំពោះ

ព្រះថេរៈនោះថា ម្នាលភិក្ខុ យកមកឲ្យតថាគតចុះ ទ្រង់ក៏ទទួលបាត្រ និងចីវរ ហើយយាងទៅ ។ កាលភិក្ខុនោះទៅផ្លូវមួយទៀត ពួកចោរដណ្តើមយកបាត្រ និងចីវរ និងវាយក្បាល ។ ភិក្ខុនោះគិតថា ឥឡូវនេះ ព្រះមានព្រះភាគជាទីពឹងរបស់អញមិនមានអ្នកដទៃ ហើយបានមកគាល់ព្រះមានព្រះភាគទាំងដែលឈាមហូរ ។ កាលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មានរឿងអ្វី ទើបក្រាបទូលរឿងដែលកើតឡើងនោះ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ កុំគិតថ្វីឡើយ តថាគតហាមអ្នកព្រោះឃើញហេតុនោះហើយ ទ្រង់លួងលោមភិក្ខុនោះ ។

ពេលខ្ទះ ព្រះមានព្រះភាគស្តេចទៅកាន់ជន្តុគ្រាម ក្នុងបាចីវង្សមិគទាយវន ជាមួយនឹងព្រះមេឃិយត្ថេរ ។ សម្ប៊ីក្នុងទីនោះ ព្រះមេឃិយៈទៅបិណ្ឌបាតក្នុងជន្តុគ្រាម ឃើញព្រៃស្វាយគួរឥតរាយនៅត្រង់ច្រាំងស្ទឹង ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់ទទួលបាត្រ និងចីវររបស់ព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងបំពេញសមណធម៌នៅឯព្រៃស្វាយនោះ សូម្បីត្រូវព្រះមានជោគទ្រង់ហាមដល់ ៣ ដង ក៏នៅតែទៅទាល់តែបាន កាលត្រូវអកុសលវិតក្កគ្របសង្កត់ ទើបត្រឡប់មកក្រាបទូលហេតុដែលកើតឡើងនោះឲ្យទ្រង់ជ្រាប ។ ព្រះមានព្រះភាគត្រាស់ចំពោះព្រះមេឃិយៈថា តថាគតកំណត់ដឹងហេតុនេះដល់អ្នកហើយ បានជាហាមអ្នក ហើយស្តេចយាងទៅកាន់នគរសាវត្ថី ដោយលំដាប់ ។

ក្នុងនគរសាវត្ថីនោះ ព្រះមានព្រះភាគ ចោមរោមដោយពួកភិក្ខុ ប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលក្រាលទុកក្នុងបរិវេណគន្ធកុដិ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតចាស់ហើយ ភិក្ខុរូបខ្ទះ

កាលតថាគតប្រាប់ថា តថាគតទៅតាមផ្លូវនេះ បានចេញទៅផ្លូវដទៃ រួចខ្លះ ជាក់ជាត្រ និងចីវរបស់តថាគតទុកលើផែនដី ពួកអ្នកចូរជ្រើសរើសភិក្ខុមួយរូប ជាឧបដ្ឋាកឲ្យនៅប្រចាំរបស់តថាគត ។ ភិក្ខុទាំងឡាយ កើតធម្មសង្វេគលំដាប់នោះ ព្រះសារីបុត្រក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតាំងសេចក្តីប្រាថ្នាទុកចំពោះព្រះអង្គ បំពេញបារមីរហូតអស់ ១ អសង្ខ្យេយ្យ និង ១ សែនកប្ប ធម្មតាឧបដ្ឋាកមានបញ្ញាច្រើន ដូចខ្ញុំព្រះអង្គ សមគួរមិនមែនឬ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះអង្គ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ហាមព្រះសារីបុត្រថា កុំឡើយ សារីបុត្រ អ្នកនៅក្នុងទិសណា ទិសនោះមិនទទេទេ ឱវាទរបស់អ្នក ដូចគ្នានឹងឱវាទរបស់ព្រះពុទ្ធទាំងឡាយ អ្នកមិនត្រូវធ្វើនាទីឧបដ្ឋាកតថាគតឡើយ ។ ព្រះមហាសាវក ៨០ រូប ចាប់តាំងពីព្រះមហាមោគ្គល្លានជាដើម បានក្រោកឡើងដោយទំនងដូចគ្នា ។ ព្រះមានព្រះភាគ ទ្រង់ហាមសាវកទាំងអស់នោះ ។ តែព្រះអានន្ទត្ថេរ អង្គុយនៅស្ងៀម ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះអានន្ទត្ថេរនោះយ៉ាងនេះថា លោកម្ចាស់អានន្ទ ពួកភិក្ខុក្រាបទូលសូមតំណែងឧបដ្ឋាក សូម្បីលោកក៏ចូរក្រាបទូលសូមខ្លះ ដូច្នេះ ។ ព្រះអានន្ទត្ថេរនោះពោលថា លោកដ៏មានអាយុទាំងឡាយ ឈ្មោះថា កិច្ចឧបដ្ឋាក ដែលក្រាបទូលសូមហើយ នឹងបានមកដូចម្តេច ព្រះសាស្តាទ្រង់មិនឃើញខ្ញុំទេឬ បើព្រះអង្គនឹងពេញព្រះទ័យ ទ្រង់នឹងប្រាប់ថា អានន្ទ ចូរឧបដ្ឋាកតថាគត ដូច្នេះ ។ ពេលនោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទមិនគួរឲ្យអ្នកដទៃបង្ខិតបង្ខំទេ នឹងដឹងដោយខ្លួនឯង ហើយឧបដ្ឋាកតថាគត ។ តអំពីនោះ ភិក្ខុច្រើនរូបពោល

ថា លោកម្ចាស់អានន្ទ សូមលោកម្ចាស់ក្រោកឡើងចុះ ចូរក្រាបទូលសូមតំណែងឧបដ្ឋាកចំពោះព្រះទសពល ។ ព្រះថេរៈក្រោកឡើងក្រាបទូលសូមពរ ៨ ប្រការ គឺពរដែលហាម ៤ ប្រការ ពរអនុញ្ញាត ៤ ប្រការ ។ គប្បីជ្រាបពរដែលហាម ៤ ប្រការ ។ ព្រះអានន្ទត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគ មិនប្រទានចីវរដែលប្រណីត ដែលព្រះអង្គបានមកដល់ខ្ញុំព្រះអង្គ និងមិនប្រទានបិណ្ឌបាត និងមិនឲ្យនៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ ទទួលនិមន្តន៍ហើយ នឹងមិនទៅរួមជាមួយព្រះអង្គ ដោយប្រការដូច្នេះ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះមានព្រះភាគ ដូច្នេះ ។ កាលព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ អ្នកឃើញទោសអ្វីក្នុងសេចក្តីនេះ ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គបានវត្តុទាំងនេះ នឹងមានអ្នកពោលទោសដល់ខ្ញុំព្រះអង្គថា ព្រះអានន្ទប្រើចីវរដែលប្រណីត ដែលព្រះទសពលបានហើយ ឆាន់បិណ្ឌបាតនៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ ទៅកាន់ទីនិមន្តន៍រួមជាមួយព្រះអង្គ កាលបានលាភនេះ ទើបឧបដ្ឋាកព្រះតថាគត កាលឧបដ្ឋាកយ៉ាងនេះនឹង ធ្ងន់លំបាកអ្វី ។ ព្រះអានន្ទត្ថេរ ក្រាបទូលសូមពរដែលហាម ៤ ប្រការនេះ ។

គប្បីជ្រាបពរអនុញ្ញាត ៤ ប្រការដូច្នេះ ព្រះអានន្ទត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគស្តេចទៅកាន់ទីនិមន្តន៍ ដែលខ្ញុំព្រះអង្គទទួល បើខ្ញុំព្រះអង្គបានគាល់ព្រះមានព្រះភាគក្នុងខណៈដែលបរិស័ទមកដល់ហើយអំពីក្រៅដែន ក្រៅជនបទ ដើម្បីគាល់ព្រះមានព្រះភាគ ខណៈណាសេចក្តីសង្ស័យកើតឡើងដល់ខ្ញុំព្រះអង្គ ខណៈនោះ ខ្ញុំព្រះអង្គនឹងបានចូលគាល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ណាកំចាំងអំពី

ខ្ញុំព្រះអង្គ កាលទ្រង់ត្រឡប់មកហើយ សូមទ្រង់សម្តែងធម៌នោះដល់ខ្ញុំព្រះអង្គ ដោយប្រការដូច្នេះ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះមានព្រះភាគ ដូច្នេះ ។ កាលព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ អ្នកឃើញអានិសង្សអ្វីក្នុងសេចក្តីនេះ ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រទាំងឡាយ អ្នកមានសទ្ធាក្នុងសាសនានេះ កាលមិនបានឱកាសអំពីព្រះមានព្រះភាគ រមែងពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះអានន្ទ ថ្ងៃស្អែកនេះ មេត្តាទទួលភិក្ខាក្នុងផ្ទះរបស់ពួកខ្ញុំ ព្រមដោយព្រះមានព្រះភាគ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគទ្រង់មិនទៅក្នុងទីនោះ ខ្ញុំព្រះអង្គនឹងមិនបានឱកាស ដើម្បីចង្អុលបង្ហាញចំពោះបរិស័ទ ក្នុងខណៈដែលគេប្រាថ្នាដើម្បីបន្ទោបង់សេចក្តីសង្ស័យ នឹងមានអ្នកពោលថា ព្រះអានន្ទជាឧបដ្ឋាកព្រះទសពល គ្រាន់តែប៉ុណ្ណោះ ព្រះមានព្រះភាគ ទ្រង់ក៏មិនធ្វើការអនុគ្រោះដល់ព្រះអានន្ទ ដូច្នេះម្យ៉ាងវិញទៀត ជនទាំងឡាយនឹងសួរខ្ញុំព្រះអង្គ កំពុងពីព្រះមានព្រះភាគថា បពិត្រព្រះអានន្ទ ព្រះមានព្រះភាគទ្រង់សម្តែងគាថានេះ សូត្រនេះ ជាតកនេះ ក្នុងទីណា ដូច្នេះ បើខ្ញុំព្រះអង្គនឹងចង្អុលបង្ហាញសេចក្តីនោះមិនបាន នឹងមានអ្នកពោលទោសថា លោកមិនលះព្រះមានព្រះភាគ ដូចស្រមោលអនុរូលតាមប្រាណអស់កាលយូរ ព្រោះហេតុអ្វីគ្រាន់តែរឿងប៉ុណ្ណោះលោកក៏មិនដឹងដូច្នេះ ដោយហេតុនោះ ខ្ញុំព្រះអង្គប្រាថ្នានឹងពោលធម៌ ដែលព្រះអង្គទ្រង់សម្តែងក្នុងទីកំពុងម្តងទៀត ។ ព្រះអានន្ទក្រាបទូលសូមពរអនុញ្ញាត ៤ ប្រការនេះ ។

ព្រះមានព្រះភាគ ទ្រង់ក៏ប្រទានដល់ព្រះអានន្ទនោះ ។ ព្រះអានន្ទ កាលទទួលពរទាំង ៨ ប្រការនេះហើយ ក៏បានជាឧបដ្ឋាកប្រចាំ ដោយប្រការ

ដូច្នេះ ។ ព្រះអានន្ទ សម្រេចផលនៃបារមីដែលបំពេញមក រហូតដល់អស់ ១ សែនកប្បដើម្បីតំណែងនោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ឥឡូវនេះ ភិក្ខុអានន្ទជាឧបដ្ឋាករបស់តថាគត បានជាឧបដ្ឋាកដ៏កំពូល ដូច្នេះ ។ សំដៅដល់សភាពដែលព្រះអានន្ទនេះ ជាឧបដ្ឋាកប្រចាំនោះ ។ នេះ ជាការកំណត់ឧបដ្ឋាក ។

[៩] *ការកំណត់បិតាមានអត្ថន័យយល់ទាំងអស់ហើយ ។*

បទថា **វិហារំ ចារិសិ** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ចូលទៅកាន់វិហារ ព្រោះហេតុអ្វី បានឮថា ព្រះមានព្រះភាគ កាលត្រាស់ដូច្នោះហើយ ទ្រង់ត្រិះរិះថា តថាគតសម្រេចដល់ទីបំផុត ដែលរកចន្លោះមិនបានហើយ មិន-ទាន់បានពោលដល់វង្សរបស់ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គឡើយ ក៏កាល តថាគតចូលទៅកាន់វិហារ ភិក្ខុទាំងនោះ បានប្រារព្ធដល់បុព្វេនិវាសញ្ញាណ ដោយប្រមាណដ៏ក្រៃលែង ហើយនឹងពោលដល់គុណ បើដូច្នោះ តថាគត នឹងពោលដល់ពុទ្ធវង្ស ដែលរកចន្លោះមិនបាន ឲ្យភិក្ខុទាំងឡាយសម្រេចដល់ ទីបំផុតហើយ នឹងសម្តែង ដូច្នេះ ទ្រង់ឲ្យឱកាសភិក្ខុទាំងឡាយសន្ធនាគ្នា ទើប ស្តេចក្រោកចាកអាសនៈ ចូលកាន់ព្រះវិហារ ។ ព្រះមានព្រះភាគ ត្រាស់ កំណត់ឯណាទាំង ៩ វារៈនេះ មកហើយក្នុងការកំណត់នោះ គឺកំណត់កប្ប កំណត់ជាតិ កំណត់គោត្រ កំណត់អាយុ កំណត់ការត្រាស់ដឹង កំណត់គូ-សាវក កំណត់ការប្រជុំសាវក កំណត់ឧបដ្ឋាក កំណត់បិតា ។ វារៈច្រើនយ៉ាង មិនទាន់មកដល់ តែនឹងនាំមកសម្តែង ។*

ពិតហើយ កាលបុត្រសមគួរដល់ត្រកូល និងវង្សមួយរបស់ព្រះពោធិសត្វ

ទាំង៦ឡាយកើតហើយ គួរចេញបួស នេះឯងជាវង្ស នេះជាបវេណី ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា តាំងអំពីការយាងចុះកាន់គភ៌នៃមាតារបស់ព្រះពោធិសត្វ ដែលជាព្រះសព្វញ្ញូទាំង៦ឡាយ មានបាដិហារ្យច្រើនយ៉ាង ដូចបានពោលហើយខាងដើម ប្រសិនបើនគរកំណើត មាតា បិតា ភរិយា បុត្រ របស់ព្រះពោធិសត្វទាំងនោះ មិនច្រាកដ នគរកំណើត បិតា បុត្ររបស់បុគ្គលនេះ ក៏មិនច្រាកដ បុគ្គលនេះប្រហែលជាទេវតា សក្កទេវរាជ មារ ឬព្រហ្ម និង៦សម្គាល់ថា បាដិហារ្យ ដូច្នេះ របស់ទេវតាទាំង៦ឡាយ មិនគួរអស្ចារ្យ គប្បីសម្គាល់ដល់បាដិហារ្យដែលមិនគួរស្តាប់ មិនគួរជឿ ។ តអំពីនោះ ការត្រាស់ដឹង៦មិនគប្បីមាន កាលមិនមានការត្រាស់ដឹង ការកើតឡើង៦របស់ព្រះពុទ្ធក៏មិនមានប្រយោជន៍ ពាក្យទូន្មាន ក៏មិននាំឲ្យរួចផុតចាកទុក្ខ ព្រោះដូច្នោះ កាលបុត្រសមគួរដល់ត្រកូល និង៦វង្ស របស់ព្រះពោធិសត្វទាំង៦ឡាយកើត គួរចេញបួស នេះឯង៦ជាវង្ស នេះជាប្រពៃណី ព្រោះដូច្នោះ គួរនាំវារៈច្រើនយ៉ាង មកសម្តែង៦ដោយអំណាចនៃបុត្រជាដើម ។

ក្នុង៦សម្ពហុលវារៈ គប្បីជ្រាបបុត្រទាំង ๗ តាមលំដាប់របស់ព្រះពុទ្ធទាំង ๗ ព្រះអង្គនេះមុន គឺ៦សមវត្តក្ខន្ធៈ អតុលៈ សុប្បពុទ្ធ ឧត្តរៈ សត្ថវាហៈ វិជិតសេនៈ ភហុល ជាទី ๗ ក្នុង៦បណ្តាបុត្រទាំង៦នោះ កាលភហុលប្រសូត ពួកភាជបុរសនាំសំបុត្រប្រាប់ដំណឹង៦ មកជាក់លើព្រះហស្តរបស់ព្រះមហាបុរស ។ លំដាប់នោះ សេចក្តីស្នេហាក្នុង៦ព្រះឱរស ធ្វើឲ្យព្រះវរកាយគ្រប់ចំណែករបស់ព្រះមហាបុរសជ្រួតជ្រាប ។ ព្រះមហាបុរសត្រិះរិះថា កាលបុត្រកើត៦តែមួយម្នាក់ សេចក្តីស្នេហាក្នុង៦បុត្រ កើត៦មានច្រាកដដល់ម៉្លេះ បើអញមានបុត្រជាង ๑๐๐๐ នាក់ ក្នុង៦បុត្រទាំង៦នោះ សូម្បីម្នាក់ កើត៦ទុវចំណង៦ដោយស្នេហាបន្ថែម

ច្រើនទ្បើងយ៉ាងនេះ បេះដូងពិតជាបែកធ្លាយមិនខាន ព្រោះហេតុនោះ ទើប ព្រះអង្គត្រាស់ថា អន្ទាក់កើតហើយ ចំណងកើតហើយ ។ ក្នុងថ្ងៃនោះឯង ព្រះមហាបុរសទ្រង់លះបង់រាជសម្បត្តិ ទ្រង់ចេញព្រះផ្នួស ។ ក្នុងការកើតបុត្រ របស់ព្រះពោធិសត្វគ្រប់អង្គ មានន័យនេះឯង នេះការកំណត់បុត្រ ។

បុត្រទាំង ៧ នោះ មានមាតាទាំងនេះ គឺ ព្រះនាងសុត្តនា ព្រះនាង សព្វកាមា ព្រះនាងសុចិត្តា ព្រះនាងរោចនី ព្រះនាងរុចគតិនី ព្រះនាងសុនន្ទា និងព្រះនាងពិម្ពាជាអគ្គទី ៧ ។ ឯព្រះនាងពិម្ពាទេវី កាលរាហុលកុមារប្រសូត បានប្រាកដឈ្មោះថា រាហុលមាតា ។ នេះការកំណត់ភរិយា ។

ព្រះពោធិសត្វ ២ អង្គ គឺព្រះវិបស្សី ព្រះកកុសន្ធៈ ស្តេចទ្បើងរថ ទឹមដោយសេះអាជានេយ្យ យាងចេញមហាភិនេស្ក្រមណ៍ ។ ព្រះពោធិសត្វ ២ អង្គ គឺ ព្រះសិខី ព្រះកោនាគមនៈ ប្រថាប់លើ កដីរដ៏ប្រសើរ ទ្រង់ចេញ ព្រះផ្នួស ។ ព្រះវេស្សភូពោធិសត្វប្រថាប់វមាស ទ្រង់ចេញព្រះផ្នួស ។ ព្រះ កស្សប ប្រថាប់លើផ្ទៃមហាប្រាសាទ ញ៉ាំងអានាបានចតុត្ថជ្ឈានឲ្យកើត ចេញ ចាកឈានហើយ ធ្វើឈាននោះឲ្យជាបាទ ទ្រង់អធិដ្ឋានថា ប្រាសាទចូរទៅចុះ ក្នុងពោធិមណ្ឌល ប្រាសាទក៏ទៅតាមអាកាស ហើយចុះក្នុងពោធិមណ្ឌល ។ ព្រះមហាបុរសចុះអំពីប្រាសាទនោះ ប្រថាប់លើផែនដី ទ្រង់អធិដ្ឋានថា ប្រាសាទចូរទៅតាំងនៅក្នុងទីដើម ។ ប្រាសាទនោះ ក៏ទៅតាំងនៅក្នុងទីដើម ។ ព្រះមហាបុរស ទ្រង់ក៏ប្រកបសេចក្តីព្យាយាមរហូតដល់អស់ ៧ ថ្ងៃ គង់ត្រង់ ពោធិបល្ល័ង្ក បានត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ។ ឯព្រះពោធិសត្វរបស់ យើងទាំងឡាយ ទ្រង់គង់លើសេះកណ្ឌកៈ ទ្រង់ចេញព្រះផ្នួស ។ នេះជាការ កំណត់យាន ។

វិហាររបស់ព្រះមានព្រះភាគ ព្រះនាមថា វិបស្សី តាំងនៅក្នុងស្ថានទី ប្រមាណមួយយោជន៍ ។ របស់ព្រះសិខី ៣ គាវុត ។ របស់ព្រះវេស្សភូ កន្ទះយោជន៍ របស់ព្រះកកុសន្ធៈមួយគាវុត របស់ព្រះកោនាគមនៈ កន្ទះគាវុត របស់ព្រះកស្សប ២០ ឧសភៈ ។ វិហាររបស់ព្រះមានព្រះភាគនៃយើង តាំងបើវាស់ដោយរង្វាស់ប្រក្រតី ស្ថិតនៅក្នុងទី ១៦ ករីស បើវាស់ដោយរង្វាស់ព្រះរាជា ស្ថិតនៅក្នុងទី ៨ ករីស ។ នេះជាការកំណត់ព្រះវិហារ ។

សេដ្ឋីទាំងឡាយឲ្យជាងធ្វើឥដ្ឋមាស បណ្តាយ ១ ហត្ថ ទទឹង ១ ចំអាម កម្រាស់ ៨ ធ្នាប់ ក្រាលដោយចំណែកទទឹង ហើយទិញដីសាងអារាមថ្វាយព្រះមានព្រះភាគព្រះនាមថាវិបស្សី ។ ក្រាលដោយផាលមាស ទិញដីសាងអារាមថ្វាយព្រះមានព្រះភាគព្រះនាមថាសិខី ។ ឲ្យជាងធ្វើជើងដីរមាស ក្រាលដោយទទឹង ទិញដីសាងអារាមថ្វាយព្រះមានព្រះភាគព្រះនាមថាវេស្សភូ ។ ក្រាលដោយឥដ្ឋមាស តាមន័យដែលពោលហើយ ទិញដីសាងអារាមថ្វាយព្រះមានព្រះភាគព្រះនាមថាកកុសន្ធៈ ។ ក្រាលដោយអណ្តើកមាស តាមន័យដែលពោលហើយ ទិញដីសាងអារាមថ្វាយព្រះមានព្រះភាគព្រះនាមថាកោនាគមនៈ ។ ក្រាលដោយមាសដុំ ទិញដីសាងអារាមថ្វាយចំពោះព្រះមានព្រះភាគព្រះនាមថាកស្សប ។ និងក្រាលដោយទទឹងនៃកហាបណៈ ដែលជាគ្រឿងសម្គាល់ ទិញដីសាងអារាមថ្វាយព្រះមានព្រះភាគនៃយើងទាំងឡាយ ។ នេះជាកំណត់ក្នុងការកាន់យកផ្ទៃដីសាងវិហារ ។

ឧបដ្ឋាកដែលទិញដី សាងវិហារថ្វាយព្រះមានព្រះភាគ ព្រះនាមថាវិបស្សី ឈ្មោះបុនព្វសុមិត្ត ។ ថ្វាយព្រះមានព្រះភាគព្រះនាមថាសិខី ឈ្មោះសិរីវឌ្ឍ ។ថ្វាយព្រះវេស្សភូ ឈ្មោះសោត្ថិយ ។ ថ្វាយព្រះកកុសន្ធៈ ឈ្មោះ

អច្ចុត ។ ថ្វាយព្រះកោនាគមនៈ ឈ្មោះ ឧគ្គៈ ។ ថ្វាយព្រះកស្សប ឈ្មោះ សុមនៈ ។ ថ្វាយព្រះមានព្រះភាគនៃយើងទាំងឡាយ ឈ្មោះសុទត្តៈ (អនាថបិណ្ឌិក) ។ ឧបដ្ឋាកទាំងអស់នោះ បានជាសេដ្ឋី គហបតីមហាសាល ។ នេះជាកំណត់ឧបដ្ឋាក ។

នៅមានស្ថានទីដទៃទៀត ៤ កន្លែង ដែលជាស្ថានទីមិនឃៀងឃាត គឺពោធិបល្ល័ង្ករបស់ព្រះពុទ្ធទាំងឡាយ មិនឃៀងឃាត រមែងមានក្នុងទីតែមួយប៉ុណ្ណោះ ។ ការសម្តែងធម្មចក្រក្នុងព្រៃឥសិបតនមិគទាយវ័ន មិនឃៀងឃាត គឺមិនខុសកន្លែងគ្នាឡើយ ។ ការប្រតិស្ឋានព្រះបាទគ្រាដំបូង ត្រង់ទ្វារនគរសង្កស្សៈ ពេលទ្រង់ចុះចាកទេវលោក មិនឃៀងឃាតគ្នាឡើយ ។ ទីតាំងជើងគ្រែ ៤ ក្នុងព្រះគន្ធកុដិ ក្នុងជេតវនមហាវិហារក៏មិនឃៀងឃាត នោះឯង ។ តែវិហារមានតូចខ្លះធំខ្លះ ។ សូម្បីវិហារ ក៏មិនឃៀងឃាត ។ តែនគរឃៀងឃាត គឺខុសកន្លែងគ្នាបាន ។ កាលណានគរនៅផ្នែកខាងកើត កាលនោះវិហារនៅផ្នែកខាងលិច ។ កាលណានគរនៅផ្នែកខាងត្បូង កាលនោះវិហារនៅផ្នែកខាងជើង ។ កាលណានគរនៅផ្នែកខាងលិច កាលនោះ វិហារនៅផ្នែកខាងកើត ។ កាលណានគរនៅផ្នែកខាងជើង កាលនោះ វិហារនៅផ្នែកខាងត្បូង ។ ឥឡូវនេះ នគរនៅផ្នែកខាងជើង វិហារនៅផ្នែកខាងត្បូង ។

ម្យ៉ាងទៀត ព្រះពុទ្ធគ្រប់ព្រះអង្គមានសេចក្តីផ្សេងគ្នា ៥ យ៉ាង គឺផ្សេងគ្នាដោយអាយុ ផ្សេងគ្នាដោយប្រមាណ ផ្សេងគ្នាដោយត្រកូល ផ្សេងគ្នាដោយសេចក្តីព្យាយាម ផ្សេងគ្នាដោយរស្មី ។

ព្រះពុទ្ធអង្គខ្លះមានព្រះជន្មាយុវែង ព្រះពុទ្ធអង្គខ្លះមានព្រះជន្មាយុខ្លី ឈ្មោះថា ផ្សេងគ្នាដោយអាយុ ។ ពិតហើយ ព្រះពុទ្ធព្រះនាមថាទីបង្ករ មានព្រះ

ជន្មាយុប្រមាណមួយសែនឆ្នាំ ។ ព្រះមានព្រះភាគនៃយើង មានព្រះជន្មាយុប្រមាណ ១០០ ឆ្នាំ ។ ព្រះពុទ្ធអង្គខ្លះមានព្រះកាយខ្ពស់ អង្គខ្លះមានព្រះកាយទាបឈ្មោះថា ផ្សេងគ្នាដោយប្រមាណ ។ ពិតហើយ ព្រះពុទ្ធទីបង្គរកម្ពស់ ៨០ ហត្ថ ព្រះពុទ្ធសុមនៈកម្ពស់ ៩០ ហត្ថ តែព្រះមានព្រះភាគនៃយើង កម្ពស់ ១៨ ហត្ថ ។ ព្រះអង្គខ្លះ ទ្រង់កើតឡើងក្នុងត្រកូលក្សត្រ អង្គខ្លះ ទង់កើតឡើងក្នុងត្រកូលព្រាហ្មណ៍ ឈ្មោះថា ផ្សេងគ្នាដោយត្រកូល ។ សេចក្តីព្យាយាមរបស់ព្រះពុទ្ធអង្គខ្លះ មានវេលាខ្លី ដូចព្រះមានព្រះភាគព្រះនាមថាកស្សប ព្រះអង្គខ្លះព្យាយាមយូរ ដូចព្រះមានព្រះភាគនៃយើង ឈ្មោះថា ផ្សេងគ្នាដោយសេចក្តីព្យាយាម ។ ព្រះរស្មីចេញអំពីព្រះវរកាយរបស់ព្រះមានព្រះភាគ ព្រះនាមថាសុមង្គល ប្រមាណមួយម៉ឺនលោកធាតុ ។ របស់ព្រះមានព្រះភាគនៃយើង ប្រមាណមួយព្យាមដោយជុំវិញ ឈ្មោះថា ផ្សេងគ្នាដោយរស្មី ។

ក្នុងសេចក្តីផ្សេងគ្នានោះ ផ្សេងគ្នាដោយរស្មី ជាប់ទាក់ទងនឹងព្រះពុទ្ធបំណង ។ ព្រះពុទ្ធអង្គណា ទ្រង់មានព្រះបំណងប៉ុនណា រស្មីអំពីព្រះវរកាយរបស់ព្រះពុទ្ធអង្គនោះ រមែងផ្សាយទៅប៉ុណ្ណោះ ។ រស្មីអំពីព្រះវរកាយរបស់ព្រះមានព្រះភាគព្រះនាមថា សុមង្គល រមែងផ្សាយទៅម៉ឺនលោកធាតុជានិច្ចដូច្នេះបាន ដោយព្រះពុទ្ធបំណង ។ តែឈ្មោះថា សេចក្តីផ្សេងគ្នាក្នុងគុណ គឺការគ្រាស់ដឹងមិនមាន ។ បុរាណបណ្ឌិតសម្តែងរឿងដទៃទៀត ដូចជាកំណត់សហជាតិ និងកំណត់នក្ខត្តរបស់ព្រះមានព្រះភាគនៃយើងទាំងឡាយ ។

បុគ្គល និងវត្ថុដែលកើតព្រមនឹងព្រះសព្វញ្ញុពោធិសត្វមាន ៧ គឺ រាហុលមាតា ព្រះអានន្ទត្ថេរ ព្រះឆន្ន សេះកណ្ឋកៈ កំណប់ទ្រព្យ មហាពោធិព្រឹក្ស ព្រះកាឡុទាយី ។ ម្យ៉ាងទៀត ព្រះមហាបុរសទ្រង់បដិសន្ធិក្នុង

ព្រះគភ៌របស់ព្រះមាតា ស្តេចចេញមហាភិនេស្ក្រមណ៍ ទ្រង់សម្តែងព្រះធម្មចក្រ ទ្រង់ធ្វើយមកប្បាដិហារ្យ ក្នុងឧត្តរាសាឡ្ហនក្ខត្តឫក្ស (១៥ កើតខែអាសាឍ) ប្រសូត ត្រាស់ដឹង និងបរិនិព្វាន ដោយវិសាខនក្ខត្តឫក្ស ។ ប្រជុំព្រះសាវ័ក និងទ្រង់ដាក់អាយុសង្ខារ ដោយមាឃនក្ខត្តឫក្ស ។

ស្តេចចុះចាកទេវលោក ដោយអស្សយុជនក្ខត្តឫក្ស (១៥ កើត ខែអស្សុជ) គប្បីនាំមកសម្តែងត្រឹមតែប៉ុណ្ណេះ ។ នេះឈ្មោះថា ការកំណត់សម្ពហុលវារៈ ។

[๑๐] *ឥឡូវនេះ គប្បីជ្រាបសេចក្តីក្នុងបទថា* **អថខោ តេសំ ភិក្ខូនំ** *ជាដើម ភិក្ខុទាំងនោះកើតសេចក្តីចម្ងៃចិត្តក្រៃលែងណាស់ថា លោកដ៏មានអាយុ ព្រះមានព្រះភាគទ្រង់ពោលដល់ការចូលកាន់បដិសន្ធិ តាំងពីចុតិ ការបញ្ចូនញាណបញ្ជ្រោស់ថយក្រោយ តាំងពីបដិសន្ធិទៅដល់ចុតិ ដែលជាផ្លូវនៃបុព្វេនិវាស សេចក្តីនេះអស្ចារ្យណាស់ ដូចទ្រង់ចង្អុលស្នាមជើងក្នុងអាកាស ហើយទើបពោលថា ម្នាលអ្នកមានអាយុទាំងឡាយ គួរអស្ចារ្យណាស់ កាលនឹងសម្តែងហេតុដទៃទៀត ទើបពោលថា* **យត្រ ហិ នាម តថាគតោ** *ជួបច្នេះ ។ បទថា* **យត្រ ហិ នាម** *ជានិបាត ប្រើក្នុងអត្ថថា គួរអស្ចារ្យ ។ អធិប្បាយថា ព្រះតថាគត ព្រះអង្គណាហ្ន៎ ។ ក្នុងបទថា* **ឥន្ទ្រិយបរោ** *នេះ សេចក្តីថា កិលេសទាំង ๓ យ៉ាងនេះ គឺ តណ្ហា មានៈ ទិដ្ឋិ ឈ្មោះថាធម៌ធ្វើឲ្យយឺតយូរ ។ បទថា* **ឥន្ទ្រិយវដ្ដមេ** *នេះ លោកពោលវដ្ដៈ គឺកុសលកម្ម និងអកុសលកម្មថា* **វដ្ដម ។** *បទថា* **បរិយាឥន្ទ្រិយវដ្តេ** *ជាវេវចនៈរបស់បទថា* **ឥន្ទ្រិយវដ្ដមេ** *នោះឯង អធិប្បាយថា គ្របសង្កត់វដ្ដៈ គឺកម្មទាំងអស់បានហើយ ។*

បទថា **សព្វទុក្ខវីតិវត្តេ** *បានដល់ កន្ទងទុក្ខ ពោល គឺវិបាកវដ្ដៈទាំងអស់ ។ បទថា* **អនុសញ្ញិសញ្ញតិ** *នេះ ជាពាក្យពោលដល់អនាគត ដោយអំណាចនៃនិបាតថា* **យត្រហិ** *ដូច្នេះ ។ ក្នុងបទនេះ គប្បីជ្រាបការអធិប្បាយដោយអំណាចនៃអតីត ។ ពិតហើយ ព្រះដ៏មានព្រះភាគ ទ្រង់រឭកដល់ព្រះពុទ្ធទាំងឡាយនោះហើយ មិនមែនរឭកដល់ក្នុងកាលឥឡូវនេះ ។ បទថា* **ឯវំ-សីលា** *សេចក្ដីថា មានសីលយ៉ាងនេះ ដោយមគ្គសីល ផលសីល លោកិយ-សីល លោកុត្តរសីល ។ បទថា* **ឯវំធម្មា** *សេចក្ដីថា ធម៌ជាចំណែកសមាធិនុ៎ះឯង លោកបំណងយកក្នុងបទនេះ អធិប្បាយថា មានសមាធិយ៉ាងនេះ ដោយមគ្គសមាធិ ផលសមាធិ លោកិយសមាធិ លោកុត្តរសមាធិ ។ បទថា* **ឯវំបញ្ញា** *សេចក្ដីថា មានបញ្ញាយ៉ាងនេះ ដោយអំណាចនៃមគ្គប្បញ្ញាជាដើម ។*

បទថា **ឯវិហារី** *អធិប្បាយថា បើមានពាក្យសួរថា ក្នុងបទនេះ ព្រោះធម៌ចំណែកសមាធិ លោកកាន់យកខាងក្រោយ ជាការកាន់យកវិហារធម៌ផង ព្រោះហេតុអ្វី ទើបកាន់យកធម៌ដែលកាន់យកហើយទៀតហ្ន៎ ឆ្លើយថា នេះមិនមែនជាការកាន់យក ។ ព្រោះបទនេះ ទ្រង់ត្រាស់ដើម្បីសម្ដែងដល់និរោធ-សមាបត្តិ ព្រោះដូច្នោះ ព្រះមានព្រះភាគទាំងឡាយ មានធម៌ជាគ្រឿងនៅ គឺនិរោធសមាបត្តិ គប្បីជ្រាបសេចក្ដីក្នុងបទនេះយ៉ាងនេះ ។*

បទថា **ឯវំ វិមុត្តា** *សេចក្ដីថា ការរួចផុតក្នុងបទនេះមាន ៥ យ៉ាង គឺ រួចផុតដោយគ្របសង្កត់(វិក្ខម្ភនវិមុត្តិ) រួចផុតដោយខណៈ(តទង្គវិមុត្តិ) រួចផុតដោយដាច់ខាត(សមុច្ឆេទវិមុត្តិ) រួចផុតដោយការស្ងប់(បដិបស្សទ្ធិវិមុត្តិ) រួចផុតដោយការរលាស់ចេញ(និស្សរណវិមុត្តិ) ។*

ក្នុងវិមុត្តិទាំងនោះ សមាបត្តិ ៨ ចាត់ជាវិក្ខម្ភនវិមុត្តិ ព្រោះរួចផុតចាកនីវរណៈជាដើម ដែលគ្របសង្កត់បាន ។ អនុបស្សនា ៧ មានអនិច្ចានុ-បស្សនាជាដើម ចាត់ជាតទង្គវិមុត្តិ ព្រោះកំណត់ដោយអំណាចជាសត្រូវរបស់ធម៌នោះៗ ឯង ព្រោះរួចផុតចាកនិច្ចសញ្ញាជាដើមទាំងនោះ ។ អរិយមគ្គ ៤ ចាត់ជាសមុច្ឆេទវិមុត្តិ ព្រោះរួចផុតចាកកិលេសដោយកាត់ដាច់ហើយ ។ សាមញ្ញផល ៤ ចាត់ជាបដិបស្សទ្ធិវិមុត្តិ ព្រោះកើតឡើងក្នុងទីបំផុតនៃការស្ងប់កិលេសដោយអានុភាពមគ្គ ។ និព្វានចាត់ជានិស្សរណវិមុត្តិ ព្រោះរួចផុតគឺព្រោះប្រាសចាក គឺព្រោះតាំងនៅឆ្ងាយចាកកិលេសទាំងពួង ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីក្នុងបទនេះថា រួចផុតហើយយ៉ាងនេះ ដោយអំណាចនៃវិមុត្តិទាំង ៥ នេះ ។

[១១] បទថា **បដិសល្ងានា វុដ្ឋិតោ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ចេញអំពីភាពជាអ្នកប្រថាប់នៅតែមួយព្រះអង្គ ។ សួរថា បន្តជាប់គ្នាយ៉ាងណា អំពីបទថា **ឥតោ សោ ភិក្ខវេ** ដូច្នេះ ។ ឆ្លើយថា ព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ផ្តើមដោយបទទាំងពីរនេះថា ម្នាលភិក្ខុទាំងឡាយ ធម្ម-ធាតុណា ដែលព្រះតថាគតត្រាស់ដឹងហើយដោយល្អ ធម្មធាតុន៉ុះ ព្រះតថាគតត្រាស់ដឹងឯងដោយល្អហើយ និងបទមួយទៀតថា ទាំងពួកទេវតាក៏បាន ប្រាប់សេចក្តីន៉ុះដល់តថាគតដែរ ដូច្នេះ ។

ក្នុងបទទាំងពីរនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងបទក្រាបទូលរបស់ទេវតាពិចារណាដល់កោលាហលរបស់ទេវចារឹក ក្នុងពេលចប់ព្រះសូត្រ ។ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះ ដោយអំណាចការបន្តជាប់គ្នា អំពី

បទធម្មជាតុ ។ ក្នុងបទទាំងនោះ គប្បីជ្រាប ១១ បទ មានបទថា **ខត្តិយោ ជាតិយា** *ជាដើម ដោយនយដែលពោលហើយក្នុងនិទានកណ្ឌ ។*

[๑๒] *បទថា* **วิปสฺสี** *ក្នុងបទជាដើមថា ម្នាលភិក្ខុទាំងឡាយ កាលព្រះវិបស្សីពោធិសត្វ ជាឈ្មោះរបស់ព្រះពោធិសត្វអង្គនោះ ។ ម្យ៉ាងទៀត ទ្រង់បានឈ្មោះនោះ ព្រោះជាអ្នកឈ្វាសក្នុងការឃើញអត្តច្រើនយ៉ាង ។*

បទថា **โพธิสตฺโต** *គឺសត្វអ្នកឈ្វាស សត្វអ្នកត្រាស់ដឹង ម្យ៉ាងទៀត សត្វអ្នកចូលចិត្ត គឺមានការជាប់ជំពាក់នៅក្នុងមគ្គ ๔ ពោល គឺពោធិ ឈ្មោះថា ពោធិសត្វ ។ ក្នុងបទថា* **สเตา สมฺปชาโน** *នេះ បទថា* **สเตา** *គឺស្មារតីនុ៎ះឯង ។ បទថា* **สมฺปชาโน** *គឺញាណ អធិប្បាយថា ព្រះពោធិសត្វទ្រង់ធ្វើសតិឲ្យតាំងមាំ កំណត់ដោយញាណ ស្តេចចុះកាន់ព្រះគភ៌របស់ព្រះមាតា ។ បទថា* **ตุสิตา** *លោកសម្តែងភាពដែលព្រះពោធិសត្វច្យុតដោយបទនេះ ក្នុងបាលីមិនបានសម្តែងដល់លំដាប់នៃការឈានចុះ ព្រោះលំដាប់នៃការឈានចុះនោះ លោកលើកទ្បើងកាន់អដ្ឋកថា ដូច្នោះគប្បីជ្រាបយ៉ាងនេះ ។ ពិតហើយ ព្រះពោធិសត្វគ្រប់ព្រះអង្គ ទ្រង់បំពេញបារមី ๓๐ ទ្រង់បរិច្ចាគមហាបរិច្ចាគ ๕ ទ្រង់សម្រេចនូវទីបំផុតនៃញាតត្ថចរិយា លោកត្ថចរិយា ពុទ្ធចរិយា ទ្រង់តាំងនៅក្នុងអត្តភាពទី ๓ ដូចព្រះវេស្សន្តរ ទ្រង់ឲ្យមហាទាន ๗ លើក ទ្រង់ញុាំងផែនដីឲ្យញាប់ញ័រ ๗ លើក ទ្រង់ធ្វើកាលកិរិយាហើយបដិសន្ធិក្នុងតុសិតភព ក្នុងវារៈនៃចិត្តទី ๒ ។ សូម្បីព្រះពោធិសត្វព្រះនាមថា វិបស្សី ក៏ទ្រង់ធ្វើកាលកិរិយាយ៉ាងនោះដូចគ្នា បដិសន្ធិក្នុងសួគ៌ជាន់តុសិត ទ្រង់ប្រតិស្ឋាននៅក្នុងសួគ៌ជាន់តុសិតនោះ រហូត ๕๗ កោដិ និង ๖ លាន*

ឆ្នាំ ។ ក្នុងកាលដទៃ ព្រះពោធិសត្វទាំងឡាយ ទ្រង់ឧប្បត្តិកក្នុងទេវលោក ដែលសត្វមានអាយុវែង តែងមិនតាំងនៅជរាបត្រប់អាយុនោះទេ ។ ព្រោះហេតុអ្វី ។ ព្រោះធ្វើបារមីឲ្យពេញបានដោយយកម្រក្នុងទីនោះ ។ ព្រះពោធិសត្វទាំងនោះ ធ្វើអធិមុត្តកាលកិរិយា (អធិដ្ឋានឲ្យអស់អាយុ) ហើយមកកើតក្នុងស្ថានរបស់មនុស្សនេះឯង ។ បារមីទាំងឡាយរបស់ព្រះវិបស្សីពោធិសត្វនោះ អាចញុំាងព្រះសព្វញ្ញុតញ្ញាណ ឲ្យកើតដោយអត្តភាពតែមួយ ក្នុងឥឡូវនេះបាន យ៉ាងណា ក្នុងគ្រានោះ ព្រះវិបស្សីពោធិសត្វ បានតាំងនៅក្នុងសួគ៌ជាន់តុសិតនោះ ជរាបត្រប់អាយុ ព្រោះបារមីពេញហើយ ដោយប្រការទាំងពួង ដូច្នោះ ។ ពួកទេវតានឹងចុតិក្នុង ៧ ថ្ងៃ ដោយគណនាថ្ងៃនៃពួកមនុស្ស ដូច្នោះ ។ បុព្វនិមិត្ត ៥ តែងកើតឡើង គឺផ្កាស្វិតស្រពោន សំពត់សៅហ្មង ញើសហូរអំពីក្លៀកទាំងពីរ ពណ៌សម្បុរសៅហ្មង ទេវតាមិនតាំងនៅក្នុងទេវាសនៈ ។

ក្នុងបទទាំងនោះ បទថា **มาลา** បានដល់ ផ្កាដែលប្រដាប់ក្នុងថ្ងៃបដិសន្ធិ ។ បានឮថា ផ្កាទាំងនោះ មិនស្វិតរហូត ៥៧ កោដិ ៦ លានឆ្នាំ តែក្នុងពេលនោះស្វិតស្រពោន ។ ក្នុងសំពត់ទាំងឡាយ ក៏មាននយនេះឯង ។ អស់កាលប្រមាណប៉ុណ្ណេះ ពួកទេវតាមិនជឹងត្រជាក់ មិនជឹងក្តៅ ។ ក្នុងកាលនោះ ញើសហូរអំពីសរីរៈជាតំណក់ៗ ។ អស់កាលប្រមាណប៉ុណ្ណេះ ក្នុងសរីរៈរបស់ទេវតាទាំងនោះ រមែងមិនប្រាកដវណ្ណៈផ្សេងគ្នាដោយអំណាចធ្មេញបាក់ និងសក់ស្កូវជាដើមឡើយ ។ ទេពធីតាប្រាកដដូចមានអាយុ ១៦ ទេវបុត្រប្រាកដដូចមានអាយុ ២០ ។ តែក្នុងវេលាជិតចុតិ អត្តភាពរបស់

ទេវបុត្រទាំងនោះ ទ្រុឌទ្រោម ។ ម្យ៉ាងទៀត អស់កាលប្រមាណប៉ុណ្ណោះ ទេវបុត្រទាំងនោះ មិនមានសេចក្តីអផ្សុកក្នុងទេវលោក ។ តែក្នុងវេលាជិតស្លាប់ ជាកដង្ហើមមិនចេញ រសាប់រសល់ មិនត្រេកអរក្នុងអាសនៈរបស់ខ្លួន ។

បុព្វនិមិត្តទាំង ៥ នេះ រមែងប្រាកដដល់ទេវតាអ្នកមានសក្តិធំប៉ុណ្ណោះ មិនប្រាកដដល់ទេវតាទាំងពួង ដូចនិមិត្ត មានឧក្កាបាត ផែនដីញ័រ និង ចន្ទ្រគ្រាសជាដើម រមែងប្រាកដដល់ព្រះរាជា និងអមាត្យរបស់ព្រះរាជាជាដើមដែលមានបុណ្យច្រើនប៉ុណ្ណោះ មិនប្រាកដដល់មនុស្សទាំងពួង ដូច្នោះ ។ ដូចជាមានអ្នកហោរាសាស្ត្រ រមែងដឹងបុព្វនិមិត្តក្នុងមនុស្សទាំងឡាយ បុគ្គលទាំងពួងមិនដឹង យ៉ាងណា ពួកទេវតាទាំងពួង រមែងមិនដឹងនិមិត្តទាំងនោះ តែបណ្ឌិតប៉ុណ្ណោះដឹងបាន ដូច្នោះ ។ ទេវបុត្រពួកណាកើតក្នុងទេវលោកនោះ ដោយកុសលកម្មតិច កាលបើទេវបុត្រទាំងនោះកើត គេខ្លាចថា ឥឡូវនេះ នរណានឹងដឹងពួកយើងកើតទីណា ទេវបុត្រដែលមានបុណ្យច្រើន រមែងមិនខ្លាចថា ពួកយើងអាស្រ័យទានដែលយើងឲ្យ សីលដែលយើងរក្សាភាវនាដែលយើងចម្រើន នឹងសោយសម្បត្តិក្នុងទេវលោកខាងលើ ។

សូម្បីព្រះពោធិសត្វព្រះនាមថា វិបស្សី ទ្រង់ឃើញបុព្វនិមិត្តទាំងនោះ ហើយទ្រង់មិនខ្លាចថា ឥឡូវនេះ យើងនឹងជាព្រះពុទ្ធក្នុងអត្តភាពបន្ទាប់ទៅ ។ កាលបើដូច្នោះ កាលនិមិត្តទាំងនោះប្រាកដដល់ព្រះអង្គ ពួកទេវតាក្នុងម៉ឺនចក្រវាល នាំគ្នាមកប្រជុំទូលអាយាចនាថា បពិត្រលោកអ្នកនិទុក្ខ ព្រះអង្គទ្រង់បំពេញបារមី ១០ ទ្រង់មិនបានប្រាថ្នាសក្កសម្បត្តិ មារសម្បត្តិ ព្រហ្មសម្បត្តិ សម្បត្តិស្តេចចក្រពត្តិ តែព្រះអង្គទ្រង់ប្រាថ្នាភាពជាពុទ្ធៈ ទ្រង់បំពេញបារមី

ដើម្បីនាំសត្វចេញចាកលោក ឥឡូវនេះ កាលនោះ មកដល់ព្រះអង្គហើយ ជាសម័យដើម្បីភាពជាពុទ្ធៈហើយ ។

លំដាប់នោះ ព្រះមហាសត្វ ទ្រង់មិនបានទទួលពាក្យប្តេជ្ញារបស់ទេវតាទាំងនោះ ទ្រង់ពិចារណាមើលមហាវិលោកនៈ ៥ ប្រការ ដោយទ្រង់កំណត់ កាល ទ្វីប ប្រទេស ត្រកូល និងអាយុរបស់ព្រះមាតា ។ ក្នុងមហាវិលោកនៈ ៥ នោះ ព្រះមហាសត្វទ្រង់ពិចារណាមើល កាលមុនថា ដល់កាលឬនៅហ្ន៎ ។ កាលអាយុរបស់សត្វចម្រើនច្រើនជាង ១ សែនឆ្នាំ ក៏មិនមែនជាកាល ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះក្នុងកាលនោះ ជាតិ ជរា និងមរណៈ មិនប្រាកដដល់សត្វទាំងឡាយ ។ ឈ្មោះថា ព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ ដែលធ្វើឲ្យផុតចាកព្រះត្រៃលក្ខណ៍ ក៏មិនមាន ។ កាលព្រះពុទ្ធទាំងឡាយត្រាស់ថា **ទុក្ខំ អនិច្ចំ អនត្តា** *ដូច្នេះ សត្វទាំងឡាយក៏និងពោលថា ព្រះពុទ្ធត្រាស់អ្វី ហើយមិនសម្គាល់ថា គួរស្តាប់ គួរជឿ ។ តពីនោះ ក៏មិនមានការត្រាស់ដឹង កាលមិនមានការត្រាស់ដឹង ពាក្យទូន្មាន ក៏មិននាំសត្វឲ្យចេញចាកទុក្ខ ព្រោះដូច្នោះ ទើបមិនមែនជាកាល ។ កាលសត្វមានអាយុតិចជាង ១០០ ឆ្នាំ ក៏មិនមែនកាល ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះក្នុងកាលនោះ សត្វទាំងឡាយមានកិលេសក្រាស់ ។ ឱវាទដែលឲ្យដល់សត្វដែលមានកិលេសក្រាស់រមែងមិនតាំងនៅក្នុងឋានៈជាឱវាទ ដូចឈើច្រត់គូសទៅក្នុងទឹក ស្នាមទឹកបាត់ទៅមួយរំពេច ព្រោះដូច្នោះ ទើបមិនមែនជាកាល ។ កាលអាយុសត្វតាំងនៅ ១ សែនឆ្នាំ ចុះមកដល់ ១០០ ឆ្នាំ ឈ្មោះថា កាល ។ ក្នុងកាលនោះ មនុស្សទាំងឡាយមានអាយុ ៨០០០០ ឆ្នាំ ។ គ្រានោះ ព្រះ*

มហាសត្វទ្រង់ឃើញថា ដល់កាលដែលគួរនឹងកើតហើយ ។ បន្ទាប់អំពីនោះ ព្រះមហាសត្វទ្រង់ពិចារណាមើល ទ្វីប ទ្រង់ឃើញទ្វីប ៤ មួយអន្ទេដោយទ្វីបជាបរិវារ ទ្រង់ឃើញថា ក្នុងទ្វីប ៣ ព្រះពុទ្ធទាំងឡាយមិនកើត កើតតែក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។ ជម្ពូទ្វីបមានទំហំប្រមាណ ១០០០០ យោជន៍ ។ ទ្រង់ពិចារណាមើលប្រទេសថា ព្រះពុទ្ធទាំងឡាយ តែងកើតក្នុងប្រទេសណាហ្ន៎ ទ្រង់ឃើញមជ្ឈិមប្រទេស ។ លោកពោលដល់មជ្ឈិមប្រទេសទុកក្នុងវិនយ ដោយនយជាដើមថា ក្នុងទិសខាងកើតមាននិគមឈ្មោះកជង្គលៈ ប្រទេសនោះដោយផ្នែកបណ្តោយប្រមាណ ៣០០ យោជន៍ ដោយផ្នែកទទឹងប្រមាណ ១៥០ យោជន៍ ដោយជុំវិញប្រមាណ ៩០០ យោជន៍ ។ ពិតហើយ ក្នុងប្រទេសនោះ ព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះអគ្គសាវក ព្រះមហាសាវក ស្តេចចក្រពត្តិ និងក្សត្រ ព្រាហ្មណ៍ គហបតី សេដ្ឋី អ្នកមានសក្តិធំពួកដទៃ រមែងកើត ។ម្យ៉ាងទៀត ក្នុងប្រទេសនេះ មាននគរឈ្មោះពន្ធុមតី ព្រះមហាសត្វទ្រង់សម្រេចព្រះហឫទ័យថា អាត្មាអញគួរទៅកើតក្នុងនគរនោះ ។ តអំពីនោះ ទ្រង់ពិចារណាមើលត្រកូល ទ្រង់ឃើញត្រកូលហើយថា ធម្មតាព្រះពុទ្ធទាំងឡាយ តែងកើតក្នុងត្រកូលដែលមនុស្សលោកលើកតម្កើង ឥឡូវនេះ ត្រកូលក្សត្រដែលមនុស្សលោកលើកតម្កើងហើយ អញនឹងកើតក្នុងត្រកូលនោះ ព្រះរាជាព្រះនាមថាពន្ធុមៈ នឹងជាព្រះបិតារបស់អញ ដូច្នេះ ។ តពីនោះ ទ្រង់ពិចារណាមើលមាតា ទ្រង់ឃើញថា ធម្មតាព្រះពុទ្ធមាតាមិនមែនជាស្រីឡេះឡោះទេ មិនមែនជាអ្នកលេងសុរា បំពេញជាវមីមកហើយអស់ ១ សែនកប្ប តាំងពីកើតមកមាន សីល ៥ មិនដាច់ ឯ

ស្ត្រីដូចព្រះនាងពន្ធុមតីទេវីនេះ នឹងជាមាតារបស់អញ ដូច្នេះ ។ ទ្រង់រំពឹងថា ព្រះនាងពន្ធុមតីទេវី នឹងមានព្រះជន្មាយុប៉ុនណា ទ្រង់ឃើញថា នឹងមានព្រះជន្មាយុ ១០ ខែ និង ៧ ថ្ងៃ ។

ព្រះពោធិសត្វ ទ្រង់ពិចារណាមើលមហាវិលោកនៈ ៥ នេះ ត្រាស់ថា នែអ្នកនិទ្ទុក្ខទាំងឡាយ ជាកាលដែលសមគួររបស់យើងដើម្បីភាពជាព្រះពុទ្ធហើយ កាលទ្រង់ធ្វើការសង្គ្រោះដល់ពួកទេវតា ប្រទានប្តេជ្ញាថា ពួកអ្នកចូរនាំគ្នាត្រឡប់ទៅចុះ ទ្រង់បញ្ជូនទេវតាទាំងនោះ ហើយហែហមដោយទេវតាជាន់តុសិត ស្តេចចូលទៅកាន់សួននន្ទវនក្នុងតុសិតទេវលោក ។ ក្នុងទេវ-លោកទាំងអស់ ក៏មានសួននន្ទវនដូចគ្នា ។ ពួកទេវតានាំគ្នាទូលជាសាតៀនថា សូមព្រះអង្គចុតិអំពីទេវលោកនេះ ទៅកាន់មនុស្សសុគតិចុះ ហើយទូលឲ្យរឭកដល់ឱកាសដែលទ្រង់បំពេញកុសលកម្មមកក្នុងកាលមុន ។ ព្រះពោធិសត្វនោះ ចោមរោមទៅដោយពួកទេវតា អ្នកឲ្យរឭកដល់កុសលយ៉ាងនេះ ទ្រង់ទៅនៅក្នុងសួននន្ទវននោះ ទ្រង់ចុតិហើយ ។ កាលចុតិយ៉ាងនេះហើយ រមែងជឹងថា អាត្មាអញចុតិ មិនជឹងចុតិចិត្ត បដិសន្ធិហើយទើបជឹង តែមិនជឹងបដិសន្ធិចិត្តទៀតនោះឯង តែជឹងយ៉ាងនេះថា អាត្មាអញបដិសន្ធិក្នុងទីនេះន៎ុះឯង ។ តែព្រះថេរៈពួកខ្លះពោលថា គួរមានការនឹកគិតដោយបរិយាយព្រះពោធិសត្វនឹងជឹងវារៈចិត្ត ទីពីរ ទីបី ។ តែព្រះមហាសិវត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា បដិសន្ធិរបស់ព្រះពោធិសត្វ មិនដូចបដិសន្ធិរបស់សត្វដទៃ ព្រោះថា សតិសម្បជញ្ញៈរបស់ព្រះពោធិសត្វទាំងនោះដល់ទីបំផុតហើយ តែព្រោះមិនអាចធ្វើចិត្តជួងនោះ ដោយចិត្តជួងនោះបាន ដូច្នោះ ទើបមិនជឹង

ចុតិចិត្ត តែក្នុងខណៈចុតិនុ៎ះឯង រមែងដឹងថា អាត្មាអញចុតិ មិនដឹងបដិ-សន្ធិចិត្ត ដឹងត្រឹមតែថា អាត្មាអញបានបដិសន្ធិក្នុងទីឯណោះ ដូច្នេះ ។ ក្នុងកាលនោះ ម៉ឺនលោកធាតុ រមែងញាប់ញ័រ ។ ព្រះពោធិសត្វមានសតិសម្ប-ជញ្ញៈយ៉ាងនេះ ទ្រង់ចុះកាន់គភ៌មាតា ទ្រង់បដិសន្ធិដោយមហាវិបាកចិត្ត ដូចនឹងកុសលចិត្តដែលជាអសង្ខារិក សហគតៈដោយសោមនស្ស សម្បយុត្ត ដោយញាណដែលជាចំណែកខាងដើមនៃមគ្គា ក្នុងបដិសន្ធិចិត្ត ១៩ ដួង ។ ម្យ៉ាងទៀត ព្រះមហាសិវត្ថេរពោលថា ចិត្តសហគតៈដោយឧបេក្ខា ។ ព្រះពោធិសត្វអង្គនោះ ក៏បានបដិសន្ធិដោយឧត្តរាសាឡ្ហនក្ខត្តឫក្ស ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ដូចព្រះមានព្រះភាគនៃយើង ដូច្នោះ ។

បានឮថា ក្នុងគ្រានោះ ចាប់ផ្តើមពីថ្ងៃទី ៧ នៃអាសាឡ្ហបុណ្ណមី ព្រះមាតារបស់ព្រះពោធិសត្វ ទ្រង់លេងនក្ខត្តកីឡា ទ្រង់ប្រជាប់ដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម មិនមានការផឹកសុរា ព្រះនាងក្រោកពីព្រលឹមក្នុងថ្ងៃទី ៧ ព្រះនាងស្រោចស្រប់ដោយទឹកក្រអូប ព្រះនាងតាក់តែងដោយគ្រឿងប្រជាប់គ្រប់ប្រភេទ សោយព្រះក្រយាហារដ៏ប្រសើរ ព្រះនាងអធិដ្ឋានអង្គឧបោសថយាងចូលកាន់បន្ទប់សិរី ផ្ទំលើព្រះសិរីសេយ្យាសនៈ ព្រះនាងចូលកាន់និទ្រាបានទតឃើញព្រះសុបិននេះ ។

ក្នុងព្រះសុបិននោះថា ស្តេចមហារាជទាំង ៤ បានលើកព្រះពុទ្ធមាតា ព្រមដោយព្រះទីនាំង ទៅកាន់អនោតត្តស្រះ ឲ្យស្រង់ទឹក ឲ្យព្រះនាងស្បែកដណ្តប់ដោយសំពត់ទិព្វ ឲ្យព្រះនាងលាបស្រឡាបដោយទិព្វគន្ធៈ ប្រជាប់ដោយទិព្វបុប្ផ មិនឆ្ងាយអំពីនោះ មានភ្នំប្រាក់ ខាងលើភ្នំប្រាក់នោះ មានវិមានមាស ឲ្យព្រះពុទ្ធមាតាបែរព្រះសិរសាទៅទិសខាងកើត ផ្ទំក្នុងវិមានមាសនោះ ។

គ្រានោះ ព្រះពោធិសត្វជាជំរីសផូរផង់ មិនឆ្ងាយអំពីនោះ មានភ្នំមាសមួយ ព្រះពោធិសត្វទ្រង់ទៅត្រង់ភ្នំមាសនោះហើយ ទ្រង់ចុះអំពីភ្នំមាសឡើងភ្នំប្រាក់ ហើយចូលទៅកាន់វិមានមាស ធ្វើប្រទក្សិណព្រះមាតាហើយ ហាក់ដូចជាហែកព្រះឧទរចំហៀងខាងស្តាំ ចូលទៅកាន់ព្រះគភ៌ ។ ភ្លាមនោះ ព្រះទេវីភ្ញាក់ឡើង ក្រាបទូលព្រះសុបិននោះចំពោះព្រះរាជា ។

លុះភ្លឺហើយ ព្រះរាជាត្រាស់បង្គាប់ឲ្យហៅប្រធានព្រាហ្មណ៍ប្រមាណ ៦៤ នាក់ ឲ្យក្រាលអាសនៈដែលមានតម្លៃច្រើនលើផ្ទៃលាបដោយរបស់ខៀវ ធ្វើមង្គលសក្ការៈដោយលាជជាដើម កាលព្រាហ្មណ៍ទាំងឡាយអង្គុយក្នុងទីនោះហើយ ទ្រង់នាំថាសមាស ថាសប្រាក់ដែលពេញទៅដោយបាយាសយ៉ាងល្អ ផ្សំដោយទឹកដោះថ្លា ទឹកឃ្មុំ និងដុំស្ករត្នោត គ្របដោយថាសមាស ថាសប្រាក់ទៀត ជូនដល់ព្រាហ្មណ៍ទាំងនោះ ។ ទ្រង់ឲ្យព្រាហ្មណ៍ទាំងនោះ ឆ្អែតស្កប់ស្កល់ដោយវត្ថុដទៃ មានសំពត់ថ្មី មេគោក្រហម និងទានជាដើម ។ ព្រះរាជាត្រាស់ប្រាប់ព្រះសុបិននោះ ដល់ព្រាហ្មណ៍ទាំងនោះ ដែលឆ្អែតស្កប់ស្កល់ដោយសេចក្តីប្រាថ្នាទាំងពួង ហើយត្រាស់សួរសុបិននោះ តើដូចម្តេច ។ ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ ទ្រង់កុំព្រះវិតក្កឡើយ ព្រះទេវីព្រះនាងទ្រង់ព្រះគភ៌ហើយ ម៉ាងទៀត ព្រះគភ៌នោះជាបុរស មិនមែនស្ត្រី ព្រះអង្គនឹងមានព្រះឱរស ព្រះឱរសនោះ បើគ្រប់គ្រងផ្ទះ នឹងជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាធម្មរាជា បើចេញបួសនឹងជាព្រះពុទ្ធអ្នកបើកលោក ។ គប្បីជ្រាបលំដាប់ពណ៌នាសេចក្តីក្នុងបទនេះថា ព្រះពោធិសត្ត ទ្រង់ចុះកាន់ព្រះគភ៌ព្រះមាតា ដូច្នេះ ។ បទថា **អយមេត្ត ធម្មតា** សេចក្តីថា ប្រការនេះ

ជាធម្មតា ក្នុងការចុះកាន់ព្រះគភ៌ព្រះមាតានេះ ។ លោកអធិប្បាយថា នេះជា សេចក្តីពិត នេះជានិយាម ដូច្នេះ ។

ឈ្មោះថា និយាមនេះ មាន ៥ យ៉ាង គឺកម្មនិយាម ឧតុនិយាម ពីជនិយាម ចិត្តនិយាម ធម្មនិយាម ។ ក្នុងនិយាមទាំង ៥ នោះ ការឲ្យផលនៃកុសលដែល គួរប្រាថ្នា ការឲ្យផលនៃអកុសលដែលមិនគួរប្រាថ្នា ឈ្មោះថា **កម្មនិយាម ។** *ដើម្បីសម្តែងកម្មនិយាមនោះ គួរពោលដល់រឿងក្នុងគាថាដូច្នេះថា* **ឯ អន្ត-លិក្ខេ** *(ក្នុងធម្មបទ) ដូច្នេះជាដើម ។*

មានរឿងតំណាលថា ស្រីម្នាក់ឈ្មោះនឹងប្តី ប្រាថ្នានឹងចងកសម្លាប់ខ្លួន ទើបស៊កកចូលទៅក្នុងអន្ទាក់ខ្សែ ។ បុរសម្នាក់កំពុងសំលៀងកាំបិត ឃើញស្រី នោះ បំណងនឹងកាត់ខ្សែ ទើបវត់ទៅលួងលោមស្រីនោះថា ប្អូនស្រីកុំខ្លាច ប្អូន ស្រីកុំខ្លាច ។ ខ្សែដូចជាអាសិរពិសកំពុងរឹតកស្ត្រីនោះ ។ បុរសនោះខ្លាច ប្រញាប់គេចចេញទៅ ។ ស្រីនោះស្លាប់ក្នុងទីនោះឯង ។ គួរសម្តែងដល់រឿង ទាំងឡាយជាដើមយ៉ាងនេះក្នុងទីនេះ ។

ក្នុងជនបទនោះៗ ក្នុងកាលនោះៗ ការបេះផ្កា និងផ្លែឈើជាដើម ដោយ កាត់តែម្តងប៉ុណ្ណោះ ខ្យល់បក់ ខ្យល់មិនបក់ កម្តៅថ្ងៃខ្លាំងក្លា កម្តៅថ្ងៃតិច ភ្លៀងធ្លាក់ ភ្លៀងមិនធ្លាក់ ផ្កាឈូកពេលថ្ងៃរីក ពេលយប់ក្តោប យ៉ាងនេះជា ដើម ជា **ឧតុនិយាម ។**

ផ្លែស្រូវសាលី រមែងជាផលអំពីពូជស្រូវសាលីតែម្យ៉ាង រសផ្អែម រមែង ជាផលអំពីពូជផ្អែម រសល្វីង រមែងជាផលអំពីពូជល្វីង នេះជា **ពីជនិយាម ។**

ធម៌ គឺចិត្ត និងចេតសិកជួងមុនៗ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ

នៃធម៌ គឺចិត្ត និងចេតសិកជួងក្រោយៗ ព្រោះដូច្នោះ ការកើតឡើងនៃសម្ប-ជិច្ឆន្នៈជាដើម ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម នេះជា **ចិត្តនិយាម ។**

ការប្រព្រឹត្តទៅនៃសេចក្តីញាប់ញ័រក្នុងមុខនៃលោកធាតុ ក្នុងការស្តេចចុះកាន់ព្រះគភ៌ព្រះមាតានៃព្រះពោធិសត្វទាំងឡាយ នេះឈ្មោះថា **ធម្មនិយាម ។** *ក្នុងទីនេះលោកបំណងយកធម្មនិយាម ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ពាក្យជាដើមថា នេះជា* **ធម្មតា** *ដូច្នេះ ។*

[១៣] *ក្នុងបទទាំងនោះ បទថា* **កុច្ឆឹ ឱក្កមតិ** *នេះ មានសេចក្តីថា ព្រះពោធិសត្វស្តេចចុះកាន់ព្រះគភ៌ ។ កាលព្រះពោធិសត្វនោះ ស្តេចចុះហើយយ៉ាងនេះ មិនមែនកំពុងស្តេចចុះទេ ។ បទថា* **អប្បមាណោ** *សេចក្តីថា មានប្រមាណច្រើន គឺបរិបូណ៌ ។ បទថា* **អប្បមាណោ** *នេះ ជាវេវចនៈនឹងបទថា* **ឧឡារោ ។** *ពាក្យថា* **ឧឡារោ** *ក្នុងទីខ្លះមានអត្ថថា ខត្តមក្រៃលែង ដូចក្នុងប្រយោគជាដើមថា អាចេលក៍ទាំងនោះ ជួនកាល ទំពាស៊ីនូវខាទនីយៈទាំងឡាយដ៏ខត្តមក្រៃលែង លោកពោលថា ខត្តមយ៉ាងក្រៃលែង ។ ក្នុងទីខ្លះមានអត្ថថា ខ្ពង់ខ្ពស់ ដូចក្នុងប្រយោគជាដើមថា ម្តេចក៏វប្ផាយនៈដ៏ចម្រើនពោលសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏ខ្ពង់ខ្ពស់ដល់ម្ល៉ះដូច្នេះ ។ តែក្នុងទីនេះ លោកបំណងយកភាពធំទូលាយ ។ ក្នុងបទថា* **ទេវានំ ទេវានុភាវំ** *នេះ មានសេចក្តីថា អានុភាពរបស់ទេវតា គឺសំពត់ស្បៃកមានរស្មីផ្សាយទៅ ១២ យោជន៍ រាងកាយក៏ដូច្នោះ គ្រឿងប្រដាប់ក៏ដូច្នោះ វិមានក៏ដូច្នោះ ព្រះពោធិសត្វកន្ទងហួសទេវានុភាពនោះ ដូច្នេះ ។*

បទថា **លោកន្តរិកា** *សេចក្តីថា ចន្លោះនីមួយៗ ក្នុងរវាងចក្រវាលទាំង ៣ រមែងមានក្នុងទីបំផុតលោក ដូចចន្លោះត្រង់កណ្តាលកង់រទេះ ៣ ដែលជាក់ផ្តុំគ្នា ឬថាស ៣ ដែលជាក់ផ្តុំគ្នា ដូច្នោះ ។ លោកន្តរនរកនោះ ដោយចំណែកខាងទទឹង ៨០០០ យោជន៍ ។ បទថា* **អឃា** *គឺបើកជានិច្ច ។ បទថា* **អសំវុតា** *សេចក្តីថា សូម្បីខាងក្រោមក៏មិនមានគាំងទុក ។ បទថា* **អន្ធការា** *គឺងងឹតឈឹង ។ បទថា* **អន្ធការតិមិសា** *សេចក្តីថា ប្រកបដោយអ័ព្ទដែលធ្វើសេចក្តីងងឹតផុតវិស័យចក្ខុវិញ្ញាណ ។ បានឮថា ចក្ខុវិញ្ញាណរមែងមិនកើតក្នុងទីនោះ ។ បទថា* **ឯវំ មហិទ្ធិកា** *សេចក្តីថា ព្រះចន្ទ និងព្រះអាទិត្យ រមែងប្រាកដក្នុងទ្វីប ៣ ដោយបំភ្លឺមួយដងប៉ុណ្ណោះ យ៉ាងនេះឈ្មោះថា ព្រះចន្ទ និងព្រះអាទិត្យមានឫទ្ធិច្រើន ។ ព្រះចន្ទ និងព្រះអាទិត្យកម្ចាត់ភាពងងឹតរហូត ១ លាន ៨ សែនយោជន៍ ក្នុងទិសនីមួយៗ ហើយក្តីយ៉ាងនេះ ឈ្មោះថា ព្រះចន្ទ និងព្រះអាទិត្យ មានអានុភាពច្រើន ។ បទថា* **អាភាយ ឆានុភោន្តិ** *សេចក្តីថា ពន្លឺរបស់ខ្លួនមិនអាច ។ បានឮថា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ គោចរត្រង់កណ្តាលភ្នំកណ្តាប់ចក្រវាល ។ ឯលោកន្តរនរកហួសភ្នំកណ្តាប់ចក្រវាលទៅ ព្រោះដូច្នោះ ទើបព្រះចន្ទ និងព្រះអាទិត្យទាំងនោះ មិនមានពន្លឺក្នុងទីនោះ ។*

បទថា **យេបិ តត្ថ សត្តា** *សេចក្តីថា សត្វពួកណាកើតហើយ ក្នុងលោកន្តរមហានរកនោះ ។ សួរថា សត្វទាំងនោះធ្វើកម្មអ្វី ទើបកើតក្នុងលោកន្តរមហានរកនោះ ឆ្លើយថា ធ្វើកម្មឆ្ងន់ គឺគ្រោតគ្រោត ។ សត្វទាំងនោះធ្វើខុសចំពោះមាតាបិតា និងសមណព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌ និងកម្មដ៏

សាហាវ មានសម្ងាប់សត្វជាដើមរាល់ៗ ថ្ងៃ រមែងកើតក្នុងលោកន្តរនរកនោះ ដូចអភយចោរ និងនាគចោរជាដើម ក្នុងតម្ពបណ្ណិទ្វីប រាងកាយរបស់សត្វ ទាំងនោះមានកម្ពស់ ៣ គាវុត មានក្រចកវែងដូចក្រចកសត្វប្រចៀវ សត្វ ទាំងនោះ គោងនៅត្រង់ភ្នំកណ្តាប់ចក្រវាលដោយក្រចក ដូចជ្រើងគោងនៅលើ ដើមឈើដូច្នោះ កាលណាសត្វទាំងនោះវារទៅប៉ះត្រូវដៃរបស់គ្នានិងគ្នា កាល នោះក៏សម្គាល់ថា អញជួបអាហារហើយ ទើបរត់ដេញទៅជុំវិញៗ ហើយក៏ ធ្លាក់ទៅលើទឹកទ្រលោក កាលឲ្យល់បក់ត្រូវក៏ដាច់ធ្លាក់ចូលទៅក្នុងទឹក ដូចផ្លែ ស្រគំ ពេលធ្លាក់ចូលទៅហើយ ក៏រលាយដូចជុំម្សៅ ធ្លាក់ចូលទៅក្នុងទឹក ដែលប្រៃខ្លាំង ។ បទថា **អញ្ញេបិ កិរ ភោ សន្តិ សត្តា** សេចក្តីថា សត្វ ទាំងឡាយ រមែងឃើញគ្នាក្នុងថ្ងៃនោះថា ឧហ្នៃ សូម្បីសត្វពួកដទៃ ក៏កើត ក្នុងទីនេះ សោយទុក្ខដូចពួកយើងសោយទុក្ខដ៏ធំក្រៃលែងដូច្នោះ ។ ពន្លឺនេះ មិនតាំងនៅយូរ តាំងនៅត្រឹមតែហុតបបរម្តង ផ្សាយចេញទៅ ដូចពន្លឺផ្លេក បន្ទោរ ត្រឹមតែមួយផ្ទាត់ម្រាមដៃប៉ុណ្ណោះ កាលសត្វទាំងឡាយនិយាយថា នេះអ្វី ក៏បាត់ទៅ ។ បទថា **សកម្បតិ** គឺញាប់ញ័រទៅដោយជុំវិញ ។ ពីរ បទតទៅ ជាវេវចនៈរបស់បទមុនន្ទុ៉ះឯង ។ បទថា **អប្បមាណោ ច** ជាដើម លោកពោលសេចក្តីសរុបតទៅ ។

[១៤] បទថា **ចត្តារោ** ក្នុងបទនេះថា ទេវបុត្រ ៤ អង្គ ចូលទៅ រក្សាទិសទាំង ៤ លោកពោលសំដៅដល់ស្តេចមហារាជ ៤ អង្គ ។ ក្នុងម៉ឺន ចក្រវាល ចែកចេញក្នុង ១ ជា ៤ ក៏ជាបួនម៉ឺនចក្រវាល ។ ក្នុងបួនម៉ឺន ចក្រវាលនោះ ក្នុងចក្រវាលនេះ ស្តេចមហារាជកាន់ព្រះខ័នចូលទៅរក្សាព្រះ

ពោធិសត្វ ចូលទៅកាន់បន្ទប់សិរី ញ៉ាំងពួកយក្ខជាដើមថា ពួកបិសាចលេងធូលី ដែលរាវរំងទប់ស្កាត់ តាំងពីទ្វារបន្ទប់ឲ្យចៀសចេញទៅ ហើយធ្វើការរក្សារហូតដល់ចក្រវាល ។

សួរថា ការរក្សានេះដើម្បីប្រយោជន៍អ្វី ទោះបីចាប់ផ្តើមតាំងពីកាលនៃកលលៈ ក្នុងបដិសន្ធិក្ខណៈ ពួកមារសែនកោដិ លើកភ្នំសិនេរុមួយសែនកោដិ គប្បីមកដើម្បីធ្វើអន្តរាយព្រះពោធិសត្វ ឬព្រះមាតាព្រះពោធិសត្វ អន្តរាយទាំងអស់ គប្បីបាត់ទៅមិនមែនឬ ឆ្លើយថា សូម្បីរឿងនេះ ព្រះមានព្រះភាគក៏ត្រាស់ទុកហើយ ក្នុងការធ្វើព្រះលោហិតឲ្យពុះពងថា ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស (គួរធ្វើបានឡើយ) ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វានដោយសេចក្តីព្យាយាមរបស់អ្នកដទៃទេ ព្រោះដូច្នោះ អន្តរាយដល់ជីវិតនៃព្រះតថាគតទាំងនោះ រមែងមិនមានដោយសេចក្តីព្យាយាមរបស់អ្នកដទៃយ៉ាងនេះឯង ។ ពួកទេវបុត្របានរក្សាដើម្បីការពារភ័យក្តី សេចក្តីតក់ស្លុតក្តី ដែលគប្បីកើតដល់ព្រះមាតារបស់ព្រះពោធិសត្វ ព្រោះឃើញរូប ឬឮសំឡេងរបស់អមនុស្ស ម្រឹគ បក្សី ដែលមានរូបពិការគួរខ្ពើម គួរខ្លាច ។ ម្យ៉ាងទៀត ពួកទេវបុត្រកើតសេចក្តីគោរពដោយតេជៈនៃបុណ្យរបស់ព្រះពោធិសត្វ សូម្បីបានប្រកាសសេចក្តីគោរពរៀងៗ ខ្លួនទើបបានធ្វើយ៉ាងនោះ ។

សួរថា ស្តេចមហារាជទាំង ៤ នេះ ចូលទៅឈរខាងក្នុងបន្ទប់ បង្ហាញខ្លួន ឬមិនបង្ហាញខ្លួនដល់ព្រះមាតារបស់ព្រះពោធិសត្វ ឆ្លើយថា មិនបង្ហាញ

ក្នុងវេលាព្រះនាងស្រង់ទឹក តាក់តែងព្រះវរកាយ បរិភោគព្រះក្រយាហារ និងវេលាបន្ទោបង់ជាដើម តែបង្ហាញខ្លួនក្នុងវេលាព្រះមាតាយាងចូលបន្ទប់សិរី ហើយផ្ទំលើព្រះសិរីសេយ្យាសនៈ ។ ក្នុងទីនោះឈ្មោះថា ការឃើញអមនុស្សរមែងជាភ័យចំពោះមុខរបស់មនុស្សក៏ពិត ។ សូម្បីដូច្នោះ ព្រះមាតារបស់ព្រះពោធិសត្វឃើញអមនុស្សទាំងនោះ ដោយបុញ្ញានុភាពរបស់ខ្លួន និងរបស់ព្រះឱរស ទើបមិនខ្លាច ។ ព្រះទ័យរបស់ព្រះមាតានោះ រមែងកើតក្នុងអមនុស្សទាំងនោះ ដូចអ្នកថែរក្សាខាងក្នុងព្រះនគរតាមប្រក្រតី ។

[១៥] បទថា **បកតិយា សីលវតី** សេចក្តីថា ជាអ្នកដល់ព្រមដោយសីល ដោយសភាវៈនោះឯង ។ បានឮថា កាលព្រះពុទ្ធមិនទាន់កើតឡើង ពួកមនុស្សទាំងឡាយអង្គុយប្រហោង តែងថ្វាយបង្គំសមាទានសីលក្នុងសម្នាក់របស់ពួកតាបស និងបរិព្វាជក ។ សូម្បីព្រះមាតារបស់ព្រះពោធិសត្វនៃយើង ក៏ទទួលសីលក្នុងសម្នាក់របស់ឥសីឈ្មោះកាលទេវិល ។ តែកាលព្រះពោធិសត្វស្តេចកាន់ព្រះគភ៌ មិនអាចអង្គុយក្នុងបាទមូលបុគ្គលដទៃបាន សូម្បីអង្គុយទទួលសីលលើអាសនៈស្មើគ្នា ក៏ជាអាការមើលងាយ ព្រោះដូច្នោះ ទើបលោកពោលថា ព្រះមាតាព្រះពោធិសត្វ ទ្រង់ទទួលសីល ដោយព្រះអង្គឯង ។

[១៦] បទថា **បុរិសេសុ** សេចក្តីថា ចិត្តប្រាថ្នាក្នុងបុរស ក្នុងមនុស្សណាមួយ សូម្បីព្រះបិតាព្រះពោធិសត្វជាដើម រមែងមិនកើតដល់ព្រះមាតាព្រះពោធិសត្វ ។ សូម្បីអ្នកមានសិល្បៈឈ្ងាស ក៏មិនអាចនឹងគូររូប ព្រះមាតាព្រះពោធិសត្វក្នុងស្លឹករឹតជាដើមបាន ។ ដែលបុគ្គលណាមួយ មិនអាច

ពោលបានថា ព្រោះឃើញរូបនោះ រាគៈរមែងមិនកើតដល់បុរស ។ ប្រសិនបើបុរសមានចិត្តតម្រេក ប្រាថ្នានឹងចូលទៅរកព្រះមាតាព្រះពោធិសត្វនោះ ជើងក៏មិននាំទៅ រមែងចងជាប់ដូចច្រវាក់ទិព្វ ព្រោះដូច្នោះ ទើបលោកពោលពាក្យថា ព្រះមាតានៃព្រះពោធិសត្វ មិនដែលមានបុរសណាមួយ មានចិត្តត្រេកអរប្រព្រឹត្តកន្លងបានឡើយជាដើម ។

[๑๗] *បទថា* **បញฺจนฺนំ กามคุณานំ** *សេចក្តីថា ក្នុងបទមុន លោកពោលដល់ការហាមវត្ថុ ដោយអំណាចសេចក្តីប្រាថ្នាក្នុងបុរស ក្នុងបទនេះថា* **กามคุณภูตสญฺญิตํ** *ក្នុងបទនេះ លោកសម្តែងដល់ការបានអារម្មណ៍ ។ បានពួថា ក្នុងកាលនោះ ព្រះរាជាទាំងឡាយដោយជុំវិញស្តាប់ថា ព្រះឱរសបែបនេះ ទ្រង់ឧប្បត្តិកក្នុងព្រះគភ៌របស់ព្រះទេវី ទ្រង់បញ្ជូនបណ្ណាការ ដែលជាទីតាំងនៃសេចក្តីត្រេកអរក្នុងទ្វារ ๕ ដោយអំណាចអាករណៈមានតម្លៃច្រើន និងតន្ត្រីជាដើម ។ ឈ្មោះថា ការកំណត់ប្រមាណនៃលាភ និងសក្ការៈ មិនមានដល់ព្រះពោធិសត្វ និងដល់មាតារបស់ព្រះពោធិសត្វ ព្រោះកម្មដែលសន្សំ ។*

[๑๘] *បទថា* **อกิลนฺตกายา** *សេចក្តីថា ព្រះមាតាព្រះពោធិសត្វនោះ មិនមានសេចក្តីលំបាកណាមួយ ដូចស្ត្រីទាំងឡាយដទៃ លំបាកដោយធ្ងន់គភ៌ ដៃ និងជើង រមែងដល់ការហើមជាដើមឡើយ ។*

បទថា **ตโรกุจฺฉิคตํ** *គឺទ្រង់នៅខាងក្នុងព្រះគភ៌ ។ បទថា* **ปสฺสติ** *សេចក្តីថា ព្រះមាតាព្រះពោធិសត្វកន្លងកាល មានកលលៈជាដើម ទ្រង់ឃើញព្រះពោធិសត្វ ចូលដល់កាពជាអ្នកមានអវយវៈតូចធំ និងឥន្ទ្រិយ*

បរិបូណ៌កើតហើយ ។ សួរថា ព្រះនាងឃើញដើម្បីអ្វី ឆ្លើយថា ដើម្បីនៅសប្បាយ ។ ដូចមាតាអង្គុយ ឬដេកជាមួយបុត្រ លើកដៃ ឬជើងរបស់បុត្រនោះ សំយុងចុះ គិតថា អញនឹងឲ្យបុត្រវឹងមាំ សម្ងឹងមើលបុត្រដើម្បីនៅសប្បាយ យ៉ាងណា សូម្បីព្រះមាតារបស់ព្រះពោធិសត្វក៏ដូច្នោះ គិតថា ទុក្ខណាកើតដល់គភ៌ក្នុងខណៈដែលមាតាឈរ ដើរទៅមក និងអង្គុយជាដើម និងក្នុងការលេបអាហារក្តៅ ត្រជាក់ ប្រៃ ល្វីង ហឺរជាដើមរបស់មាតា ទុក្ខនោះនឹងមានដល់បុត្ររបស់អញឬទេហ្ន៎ ដូច្នេះ ហើយសម្ងឹងមើលព្រះពោធិ-សត្វ ដើម្បីនៅយ៉ាងសប្បាយ ព្រះនាងឃើញព្រះពោធិសត្វអង្គុយពត់ក្អែន ។ សត្វពួកជង្ហែនៅខាងក្នុងខទរ មានខ្នងបែរមកពោះ និងមានពោះបែរទៅខ្នងអាស្រ័យឆ្អឹងខ្នង ជាក់ចង្កាលើប្រអប់ដៃទាំងពីរ អង្គុយដូចស្វាក្នុងទីប្រហោងឈើ កាលក្បៀងធ្លាក់ យ៉ាងណា ព្រះពោធិសត្វមិនដូច្នោះទេ ។ ព្រះពោធិ-សត្វអង្គុយយកខ្នងទៅខាងខ្នងព្រះមាតា អង្គុយពត់ក្អែនបែរព្រះភក្ត្រទៅទិសខាងកើត ដូចធម្មកថិកអង្គុយលើធម្មាសនៈ ។ កម្មដែលព្រះអង្គទ្រង់ធ្វើមកក្នុងកាលមុន ទើបធ្វើឲ្យវត្ថុរបស់ព្រះពោធិសត្វបរិសុទ្ធ ។ កាលវត្ថុបរិសុទ្ធ ព្រះលក្ខណៈ គឺព្រះឆវីល្អិតរមែងកើតទ្បើង ព្រះតេជោក្នុងព្រះខទរមិនអាចនឹងបិទបាំងព្រះឆវីនោះបាន ។ កាលព្រះមាតាទ្រង់ក្រឡេកមើល រមែងជ្រាកដដូចតាំងនៅខាងក្រៅ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់ធ្វើសេចក្តីនោះ ឲ្យជាក់ច្បាស់ដោយឧបមា ទើបត្រាស់ពាក្យជាដើមថា **សេយ្យថាបិ** *ដូច្នេះ ។ ព្រះពោធិសត្វប្រថាប់នៅខាងក្នុងព្រះគភ៌ ទ្រង់មិនឃើញព្រះមាតាទេ ។ ព្រោះចក្ខុវិញ្ញាណ រមែងមិនកើតទ្បើងខាងក្នុងផ្ទៃ ។*

[១៩] បទថា **កាលំ ករោតិ** សេចក្តីថា មិនមែនដោយអស់អាយុ ព្រោះការប្រសូតជាបច្ច័យ ព្រោះថា កន្លែងដែលព្រះពោធិសត្វប្រថាប់នៅ ដូចគ្នានឹងចេតិយ និងកុដិ មិនគួរដល់អ្នកដទៃប្រើប្រាស់ ។ មួយវិញទៀត បុគ្គលណាមួយ មិនអាចនឹងនាំព្រះមាតាព្រះពោធិសត្វ ទៅតាំងនៅក្នុងឋានៈជាអគ្គមហេសីអ្នកដទៃបាន ដូច្នោះ ទើបព្រះជន្មាយុរបស់ព្រះមាតាព្រះពោធិសត្វមានប្រមាណប៉ុណ្ណោះ ព្រោះដូច្នោះ ទើបព្រះនាងសោយព្រះវិលាល័យក្នុងកាលនោះ ។ សួរថា ព្រះមាតាព្រះពោធិសត្វ សោយព្រះវិលាល័យក្នុងវ័យណា ឆ្លើយថា ក្នុងមជ្ឈិមវ័យ ព្រោះថា ក្នុងអត្តភាពរបស់សត្វទាំងឡាយក្នុងបឋមវ័យ ឆន្ទរាគៈរមែងមានកម្លាំង ព្រោះហេតុនោះ ទើបស្ត្រីដែលតាំងគភ៌ក្នុងពេលនោះ មិនអាចនឹងរក្សាគភ៌បាន ។ គភ៌រមែងឈឺចាប់ច្រើន ។ តែគ្រាកន្លងហួសពីរចំណែកនៃមជ្ឈិមវ័យ ក្នុងចំណែកទីបី វត្ថុរមែងជារបស់បរិសុទ្ធ ។ ទារកដែលកើតក្នុងវត្ថុបរិសុទ្ធ រមែងមិនមានរោគ ។ ព្រោះដូច្នោះ ព្រះមាតារបស់ព្រះពោធិសត្វសោយសម្បត្តិក្នុងបឋមវ័យ ប្រសូតក្នុងចំណែកទីបីរបស់មជ្ឈិមវ័យ ហើយសោយព្រះវិលាល័យ ដូច្នោះ ប្រការនេះ ជាធម្មតាក្នុងរឿងនេះ ។

[២០-២១] **វា** សព្ទ ក្នុងបទនេះថា **នវ វា ទស វា** គប្បីជ្រាបដោយអំណាចជាគ្រឿងកំណត់ គប្បីជ្រាបការសង្គ្រោះពាក្យជាដើមយ៉ាងនេះថា ៧ ខែ ៨ ខែ ១១ ខែ ឬ ១២ ខែ ។ ក្នុងបទទាំងនោះ ទារកកើតក្នុង ៨ ខែ នៅមានជីវិតរស់ តែទ្រាំត្រជាក់ និងក្តៅមិនបាន កើតក្នុង ៧ ខែ រមែងមិនមានជីវិត ដ៏សេសនៅមានជីវិតរស់បាន ។

[២២] បទថា **දෙවා පඨමං පටිග්ගණ්හන්ති** សេចក្ដីថា ព្រហ្មជាន់សុទ្ធាវាស ជាព្រះខីណាស្រព រមែងទទួល ។ សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា អាចារ្យពួកខ្លះពោលថា ទទួលគ្រឿងតែងខ្លួនក្នុងពេលប្រសូត ។ តែសេចក្ដីនោះត្រូវជំទាស់ហើយ ទើបពោលសេចក្ដីនេះថា ក្នុងកាលនោះ ព្រះមាតាព្រះពោធិសត្វ ទ្រង់ស្លៀកសំពត់ប្រដាប់ដោយមាស ដូចភ្នែកត្រី មានពីរជាន់គ្របរហូតដល់ព្រះបាទ បានប្រថាប់ឈរ ខណៈនោះ ព្រះមាតាព្រះពោធិសត្វបានប្រសូតព្រះឱរស ដូចទឹកហូរចេញចាកធម្មក្រក លំដាប់នោះ ពួកទេវតាមានភេទជាព្រហ្មតាមប្រក្រតី ចូលទៅទទួលដោយសំណាញ់មាសមុន ស្ដេចមហារាជទាំង ៤ បានយកកម្រាលធ្វើដោយស្បែកខ្លាជំបង ទទួលអំពីព្រះហស្តរបស់ព្រហ្មទាំងនោះ បន្ទាប់ពីនោះ ទើបពួកមនុស្សទទួលដោយសំពត់ពីរជាន់ ព្រោះដូច្នោះ ទើបលោកពោលថា ទេវតាទាំងឡាយទទួលមុន ពួកមនុស្សទទួលជាខាងក្រោយ ដូច្នេះ ។

[២៣] បទថា **ចត្តារោ នំ ទេវបុត្តា** សេចក្ដីថា មហារាជ ៤ អង្គ ។ បទថា **បដិគ្គហេត្វា** សេចក្ដីថា ទទួលដោយកម្រាលធ្វើដោយស្បែកខ្លាជំបង ។ បទថា **មហេសក្ខោ** សេចក្ដីថា មានតេជះច្រើន មានយសច្រើន ដល់ព្រមដោយលក្ខណៈ ។

[២៤] បទថា **វិសទោ វ និក្ខមតិ** សេចក្ដីថា ស្ដេចមិនប្រសូតដូចសត្វពួកដទៃ ដែលជាប់នៅទ្វារប្រសូត កៀបហើយកៀបទៀត ទើបប្រសូត ។ អធិប្បាយថា ស្ដេចប្រសូតដោយមិនទើសទាក់ ។ បទថា **ឧទ្ទេន** ប្រែថា ដោយទឹក ។ បទថា **កេនចិ អសុចិនា** សេចក្ដីថា ព្រះពោធិសត្វ មិនដូចជា

สตฺตพฺภกฺขเณ ตฺรวฺยลฺปกฺปงฺคิลมานเชงฺเฆฬฺลิงฺเคลิ มานกฺษฺมาลจุ:กฺรោម ตฺรង់ទฺวารប្រសូត ដូចធ្លាក់ចុះទៅកាន់ជ្រោះជ្រៅ ១០០ ជំហរបុរស ដូចជ័រត្រូវ ទាញចេញពីប្រហោងរន្ធុកទ្វារ សោយទុក្ខធំ ប្រឡាក់ដោយអសុចិផ្សេងៗ ហើយប្រសូតដូច្នោះ ។ ពិតហើយ ខ្យល់កម្មជវាត មិនអាចធ្វើព្រះពោធិសត្វ ឲ្យមានជើងឡើងលើ មានក្បាលចុះក្រោមបាន ព្រះពោធិសត្វនោះ ដូចព្រះធម្មកថិកចុះអំពីធម្មាសន: និងដូចបុរសចុះអំពីជណ្តើរ ទ្រង់សណ្តកព្រះហស្តទាំងពីរ និងព្រះបាទទាំងពីរប្រថាប់ឈរ មិនប្រឡាក់ដោយអសុចិណាមួយ ដែលមាននៅក្នុងព្រះគភ៌របស់ព្រះមាតាឡើយ ។

[๒๕] *បទថា* **อุทกสฺส ธารา** *គឺធ្លាវទឹក ។ ក្នុងធ្លាវទឹកនោះ ទឹកត្រជាក់ហូរអំពីក្អមមាស ទឹកក្តៅហូរអំពីក្អមប្រាក់ ។ មួយទៀត លោកពោលបទនេះ ដើម្បីសម្តែងទឹកផឹក និងទឹកបរិភោគ និងធ្លាវទឹកជាទីលេង មិនទូទៅដោយទឹកដទៃ នៃធ្លាវទឹកទាំងនោះ ដែលមិនប្រឡាក់ដោយអសុចិណាមួយលើផែនដី ។ មិនមានការកំណត់ទឹក ដែលនាំមកដោយក្អមមាស និងក្អមប្រាក់ដទៃ និងទឹកដែលហូរទៅកាន់ស្រះបោក្ខរណី មានហង្សវដក:ជាដើមនោះ ឡើយ ។*

[๒๖-๒๗] *បទថា* **สมฺปติชาโต** *គឺប្រសូតបានមួយរំពេច ។ តែក្នុងបាលី លោកសម្តែងហាក់ដូចគ្រាន់តែចេញចាកព្រះគភ៌របស់ព្រះមាតា តែក៏មិនគួរឃើញយ៉ាងនោះ ។ ព្រោះព្រហ្មទាំងឡាយ ទទួលព្រះពោធិសត្វនោះ ពេលទ្រង់ប្រសូត ដោយបណ្តាញមាសជាមុន ។ ស្តេចមហារាជទាំង ๔ ទទួលដោយកម្រាលធ្វើដោយស្បែកខ្លាដំបង អំពីដៃរបស់ព្រហ្មទាំងនោះ ។*

មនុស្សទាំងឡាយទទួលដោយសំពត់ពីរជាន់ ពីដៃរបស់ស្តេចមហារាជទាំង ៤ ។ ព្រះពោធិសត្វផុតពីដៃមនុស្សទាំងឡាយ ហើយប្រតិស្ឋានលើផែនដី ។ បទថា **សេតម្ហិ ឆត្តេ អនុធារិយមានេ** សេចក្តីថា កាលទេវតាបាំងស្វេតច្ឆត្រទិព្វតាមទ្រង់ ។ ក្នុងបទនេះ សូម្បីគ្រឿងរាជកកុធភណ្ឌ ៥ មានព្រះខ័នជាដើម ដែលជាបរិវារនៃឆត្រនោះ ក៏ប្រាកដឡើងភ្លាម ។ តែក្នុងបាលីលោកពោលដល់ឆត្រ ដូចព្រះរាជាក្នុងខណៈស្តេចព្រះរាជដំណើរ ។ ក្នុងបញ្ចរាជកកុធភណ្ឌនោះ ឆត្រប៉ុណ្ណោះប្រាកដ អ្នកកាន់ឆត្រមិនប្រាកដ ។ ដូចគ្នានេះដែរ ព្រះខ័ន ផ្ចិតស្លឹកត្នោត ផ្ចិតរោមកន្ទុយក្ងោក ផ្ចិតវាលវីជនី និងក្បាំងព្រះភក្ត្ររមែងប្រាកដ អ្នកកាន់មិនប្រាកដ ។ បានឮថា ទេវតាទាំងឡាយ មិនប្រាកដរូបកាន់វត្ថុទាំងអស់នោះ ។ សេចក្តីនេះ លោកក៏ពោលថា

ពួកទេវតាបាំងឆត្រមានឆ្អឹងច្រើន មានមណ្ឌលមួយពាន់
ឮដ៏អាកាសមានដងមាស ផ្ចិតចាមរមាសគ្រវីទៅមក តែ
មិនឃើញអ្នកកាន់ផ្ចិតចាមរ និងឆត្រ ដូច្នេះ ។

បទថា **សព្វា ច ទិសា** នេះ លោកពោលដូចព្រះពោធិសត្វប្រថាប់ឈរ ក្រោយអំពីស្តេចឈានព្រះបាទ ៧ ជំហានហើយ ទ្រង់ក្រឡេកមើលទិសទាំងអស់ មិនគួរឃើញយ៉ាងនោះឡើយ ។ សេចក្តីពិត ព្រះពោធិសត្វទ្រង់ផុតពីដៃរបស់ពួកមនុស្សហើយ ប្រតិស្ឋានលើផែនដី ទ្រង់ក្រឡេកមើលទិសខាងកើត ។ ច្រើនពាន់ចក្រវាល បានជាទីទួលតែមួយដូចគ្នា ។ ក្នុងពេលនោះ ពួកទេវតា និងមនុស្សបូជាដោយផ្កា និងគ្រឿងក្រអូបជាដើម នាំគ្នាពោលថា បពិត្រមហាបុរស ក្នុងលោកនេះ មនុស្សដូចព្រះអង្គក៏មិនមាន នឹង

រកមនុស្សក្រៃលែងជាងព្រះអង្គបានអំពីណា ។ ព្រះពោធិសត្វទ្រង់ក្រឡេកមើលទិសធំ ៤ ទិសតូច ៤ ទិសខាងក្រោម ខាងលើ ទ្រង់មិនឃើញបុគ្គលដូចព្រះអង្គ ទ្រង់ត្រិះរិះថា នេះទិសខាងជើង ហើយទ្រង់បែរព្រះភក្ត្រទៅទិសខាងជើង ទើបស្តេចយាងដោយព្រះបាទ ៧ ជំហាន ។ គប្បីជ្រាបសេចក្តីក្នុងបទនេះ យ៉ាងនេះ ។ បទថា **អាសភី** *គឺឧត្តម ។ បទថា* **អគ្គោ** *គឺជាកំពូលរបស់ជនទាំងអស់ ដោយគុណទាំងឡាយ ។ ២ បទទៀត ជាវេវចនៈរបស់បទនេះ ។*

ព្រះពោធិសត្វទ្រង់ព្យាករព្រះអរហត្ត ដែលព្រះអង្គត្រូវបានសម្រេចក្នុងអត្តភាពនេះ ដោយបទទាំងពីរថា នេះជាជាតិចុងក្រោយរបស់អញ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ដូច្នេះ ។

ក្នុងបទនេះ គប្បីជ្រាបថា ការប្រតិស្ឋានលើផែនដី ដោយព្រះបាទជាន់ស៊ប់ ជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ ការបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ជាបុព្វនិមិត្តនៃការយាងទៅគ្របសង្កត់មហាជន ការឈាន ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺពោជ្ឈង្គ ៧ ការបាំងស្វេតច្ឆត្រទិព្វ ជាបុព្វនិមិត្តនៃការបានឆត្រដ៏ប្រសើរ គឺ វិមុត្តិ ការបានរាជកកុធភណ្ឌ ៥ ជាបុព្វនិមិត្តនៃការរួចផុតដោយវិមុត្តិ ៥ ការរមិលមើលនូវទិសទាំងពួង ជាបុព្វនិមិត្តនៃការបានអនាវរណញ្ញាណ ការបន្ទឺនូវអាសភិវាចា ជាបុព្វនិមិត្តនៃការប្រព្រឹត្តទៅនៃធម្មចក្រ ដែលមិនទាន់ប្រព្រឹត្តទៅ ការបន្ទឺសីហនាទថា នេះជាជាតិចុងក្រោយរបស់អញជាបុព្វនិមិត្តនៃការបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ដូច្នេះ ។ ភារៈទាំងនេះមកហើយក្នុងបាលី តែច្រើនភារៈមិនទាន់មក គួរនាំមកសម្តែង ។

ពិតហើយ ក្នុងថ្ងៃព្រះមហាបុរសប្រសូត មុនលោកធាតុញាប់ញ័រ ទេវតាក្នុងមុនលោកធាតុ នាំគ្នាមកប្រជុំក្នុងចក្រវាលតែមួយ ។ ទេវតាទទួលមុន ។ ពួកមនុស្សទទួលខាងក្រោយ ។ ពិណដែលមានខ្សែរឹតល្អ ស្គរដែលពាសស្បែក មិនមានអ្នកណាប្រគំ ក៏ប្រគំឡើងឯង ។ ប៉ម និងទីឃុំឃាំងជាដើមរបស់ពួកមនុស្សជាក់បែកជាបំណែកតូចធំ ។ រោគទាំងពួងស្ងប់អស់ទៅ ដូចស្នឹមមាសដែលលាងដោយរបស់ជូរ ។ អ្នកខ្វាក់ភ្នែកអំពីកំណើតក៏ឃើញរូប ។ អ្នកថ្លង់អំពីកំណើតបានឮសំឡេង ។ អ្នកពិការក៏មានកម្លាំងបរិបូណ៌ សតិរបស់មនុស្សឆ្កួតពីកំណើត និងមនុស្សគ្រ ក៏តាំងមាំបាន ។ ទូកដែលត្រាច់ទៅប្រទេសផ្សេងៗ ក៏ជល់កំពង់ដោយសប្បាយ ។ រតនៈដែលតាំងនៅលើអាកាស និងតាំងនៅលើផែនដី បានបញ្ចេញពន្លឺក្នុងភាពជាធំក្រៃលែងដោយខ្លួនឯង ។ អ្នកមានពៀរ ក៏មានមេត្តាចិត្តចំពោះគ្នា ។ ភ្លើងក្នុងអវីចីរលត់ ។ ពន្លឺក្នុងលោកន្តរនរកក៏កើតឡើង ទឹកក្នុងស្ទឹងមិនហូរ ។ ទឹកក្នុងមហាសមុទ្រក៏មានរសផ្អែម ។ ខ្យល់មិនបក់ ។ បក្សីដែលហើរនៅលើអាកាស ដែលនៅលើភ្នំ និងដើមឈើ បានធ្លាក់ចុះទៅលើផែនដី ។ ព្រះចន្ទក្លឹកក្រៃលែងណាស់ ។ ព្រះអាទិត្យមិនក្តៅមិនត្រជាក់ ប្រាសចាកមន្ទិល បានបរិបូណ៌តាមរដូវ ។ ពួកទេវតាប្រតិស្ឋាននៅក្នុងទ្វារវិមានរៀងៗខ្លួន លេងកីឡាយ៉ាងសប្បាយរីករាយដោយការទះដៃ ហួចគ្រវីសំពត់ជាដើម ។ ភ្លៀងក៏បានធ្លាក់ចុះមកអំពីទិសទាំង ៤ ។ សេចក្តីស្រេកឃ្លានមិនបានបៀតបៀនមហាជន ។ ទ្វារ និងបង្ហួចទាំង-ឡាយបើកឯង ។ ឈើផ្កា ឈើផ្លែ ក៏ចេញផ្កា ចេញផ្លែ មុនលោកធាតុ មានទង់ផ្កាពាសពេញទាំងអស់ ។

ក្នុងសេចក្តីនេះ គប្បីជ្រាបដូច្នេះថា មុនលោកធាតុញាប់ញ័រ ជាបុព្វ-
និមិត្តនៃការបានសព្វញ្ញុតញ្ញាណរបស់មហាបុរសនោះ ការប្រជុំក្នុងចក្រវាលតែ
មួយរបស់ទេវតាទាំងឡាយ ជាបុព្វនិមិត្តនៃការប្រជុំដោយសភាពដូចគ្នានេះ
ឯង ក្នុងកាលញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ហើយទទួលព្រះធម៌ ការទទួល
របស់ពួកទេវតាគ្រាជំបូង ជាបុព្វនិមិត្តនៃការបានរូបាវចរជ្ឈាន ៤ ការទទួល
របស់ពួកមនុស្សជាខាងក្រោយ ជាបុព្វនិមិត្តនៃការបានអរូបាវចរជ្ឈាន ៤
ពិណដែលរឹតខ្សែស្អេញដោយខ្លួនឯង ជាបុព្វនិមិត្តនៃការបានអនុបុព្វវិហារធម៌
ស្គរដែលពាសស្បែកព្រំពង់ដោយខ្លួនឯង ជាបុព្វនិមិត្តនៃការបានព្រះធម្មកេរ៉ដ៏ធំ
ប៉ម និងទីឃុំឃាំងជាដើមបាក់បែកដោយខ្លួនឯង ជាបុព្វនិមិត្តនៃការកាត់ដាច់
នូវអស្មិមានៈ មហាជនជាសះស្បើយពីរោគ ជាបុព្វនិមិត្តនៃការបានអរិយសច្ច
៤ មនុស្សខ្វាក់ភ្នែកពីកំណើតឃើញរូបបាន ជាបុព្វនិមិត្តនៃការបានទិព្វចក្ខុ
មនុស្សត្រចៀកថ្លង់បានឮសំឡេង ជាបុព្វនិមិត្តនៃការបានទិព្វសោត មនុស្ស
ពិការមានកម្ចាំង ជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ មនុស្សឆ្កួតពីកំណើត
និងមនុស្សគ មានសតិ និងនិយាយបាន ជាបុព្វនិមិត្តនៃការបានសតិបដ្ឋាន
៤ ទូកត្រាច់ទៅប្រទេសផ្សេងៗ ដល់កំពង់ដោយសប្បាយ ជាបុព្វនិមិត្តនៃការ
បានបដិសម្ភិទា ៤ ការដែលរតនៈបញ្ចេញពន្លឺដោយភាពជាធំក្រៃលែងរបស់
ខ្លួន ជាបុព្វនិមិត្តនៃពន្លឺព្រះធម៌ដែលព្រះពោធិសត្វនឹងប្រកាសដល់សត្វលោក
អ្នកមានពៀរគ្នា មានមេត្តាចិត្តចំពោះគ្នា ជាបុព្វនិមិត្តនៃការបានព្រហ្មវិហារ ៤
ភ្លើងក្នុងអវីចីរលត់ ជាបុព្វនិមិត្តនៃការរលត់ភ្លើង ១១ កង លោកន្តរនរកភ្លឺ
ជាបុព្វនិមិត្តនៃការកម្ចាត់កាពងងឹត គឺអវិជ្ជា ហើយឃើញនូវពន្លឺនៃញាណ ទឹក

ក្នុងស្ទឹងមិនហូរ ជាបុព្វនិមិត្តនៃការបានវេសារជ្ជធម៌ ๔ ទឹកមហាសមុទ្រមានរសផ្អែម ជាបុព្វនិមិត្តនៃការមានរសតែមួយ ដោយរស គឺព្រះនិព្វាន ការដែលខ្យល់មិនបក់ ជាបុព្វនិមិត្តនៃការទម្លាយទិដ្ឋិ ๖๒ បក្សីទាំងឡាយចុះមកដី ជាបុព្វនិមិត្តនៃមហាជនអ្នកស្តាប់ឱវាទ ហើយដល់សរណៈស្មើដោយជីវិត ការដែលព្រះចន្ទមានពន្លឺក្រៃលែង ជាបុព្វនិមិត្តនៃសេចក្តីល្អរបស់មនុស្សសត្វជាច្រើន ការដែលព្រះអាទិត្យរៀកម្តៅ និងត្រជាក់ ជាបុព្វនិមិត្តនៃការកើតសេចក្តីសុខតាមផ្លូវកាយ និងចិត្ត ព្រោះឧតុជាទីសប្បាយ ការដែលពួកទេវតាប្រតិស្ឋាននៅក្នុងទ្វារវិមាន រីករាយដោយការទះដៃជាដើម ជាបុព្វនិមិត្តនៃការដល់ភាពជាព្រះពុទ្ធហើយ ទ្រង់បន្ទឺឧទាន ការដែលភ្លៀងធ្លាក់ក្នុងទិសទាំង ๔ ជាបុព្វនិមិត្តនៃការធ្លាក់នៃភ្លៀង គឺ ព្រះធម៌ដ៏ធំ ការមិនមានសេចក្តីស្រេកបៀតបៀន ជាបុព្វនិមិត្តនៃការបានទឹកអម្រឹត គឺកាយគតាសតិ ការមិនមានសេចក្តីឃ្លានបៀតបៀន ជាបុព្វនិមិត្តនៃភាពជាអ្នកដល់សេចក្តីសុខ ដោយវិមុត្តិសុខ ការដែលទ្វារ និងបង្អួចបើកឯង ជាបុព្វនិមិត្តនៃការបើកទ្វារ គឺមគ្គមានអង្គ ๘ ការដែលដើមឈើចេញផ្កា និងផ្លែ ជាបុព្វនិមិត្តនៃផ្កា គឺវិមុត្តិរីក និងភាពជាអ្នកពេញដោយការ: គឺសាមញ្ញផល ការដែលម្ទឹនលោកធាតុ មានទង់ផ្កាពាសពេញ ជាបុព្វនិមិត្តនៃភាពជាអ្នកមានទង់ផ្កា គឺអរិយៈ ។ នេះឈ្មោះថា សម្ពហុលការៈ ។

ក្នុងរឿងនេះ ជនទាំងឡាយសួរបញ្ហាថា ពេលដែលព្រះមហាបុរសប្រថាប់ឈរលើផែនដីហើយ ទ្រង់បែរព្រះភក្ត្រទៅទិសឧត្តរ យាងទៅ ទ្រង់បានបន្ទឺអាសភិវាចា ទ្រង់យាងលើផែនដីឬ ឬថា ទ្រង់ទៅតាមអាកាស ទ្រង់ទៅ

ប្រាកដ ឬមិនប្រាកដ ទ្រង់អាក្រាតព្រះកាយទៅ ឬតាក់តែងព្រះកាយ ទ្រង់ទៅដោយភាពជាកុមារ ឬជាមនុស្សចាស់ សូម្បីខាងក្រោយក៏បានជាដូច្នោះឬ ឬថា ជាទារកដដែលទៀត ។ បញ្ហានេះ តាំងឡើងខាងក្រោមលោហប្រាសាទ ព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក បានដោះស្រាយហើយ ។

មានរឿងតំណាលមកថា ក្នុងរឿងនេះ ព្រះថេរៈបានពោលដល់សេចក្តីនោះច្រើន ដោយអំណាចការពោលដល់ជោគល្អ ជោគអាក្រក់ កម្មចាស់ និងការមិនប្រកាន់ខ្លួន ព្រោះភាពជាធំហើយក្នុងទីបំផុត បានព្យាករណ៍យ៉ាងនេះថា ព្រះមហាបុរសយាងទៅលើផែនដី តែបានប្រាកដដល់មហាជន ហាក់ដូចជាយាងទៅតាមអាកាស ព្រះអង្គយាងទៅ តែដូចមិនប្រាកដដល់មហាជន ទ្រង់យាងទៅដោយអាក្រាតព្រះកាយ តែប្រាកដដល់មហាជនដូចតាក់តែងព្រះកាយ ស្តេចទៅដោយភាពជាកុមារ តែប្រាកដដល់មហាជន ដូចមានព្រះជន្ម ១៦ ព្រះវស្សា តែខាងក្រោយបានជាទារកដូចដើម មិនជាកំលោះនោះទេដូច្នេះ ។ មួយទៀត បរិស័ទរបស់ព្រះថេរៈនោះ បាននាំគ្នាពេញចិត្តថា ព្រះថេរៈដោះស្រាយបញ្ហាល្អដូចព្រះពុទ្ធ ។ លោកន្តរិកវារៈ មានន័យដូចដែលបានពោលហើយ ។ ធម្មតា លោកពោលហើយតាំងពីដើម ។ គប្បីជ្រាបថា ធម្មតាទាំងអស់នេះ រមែងមានចំពោះព្រះពោធិសត្វគ្រប់ព្រះអង្គ ។

ពោលអំពីមហាលក្ខណៈ ๓๒ ប្រការ

[๒๘] បទថា **អទ្ទសា ខោ** សេចក្តីថា ព្រះរាជាពន្ធុមៈបានទតឃើញព្រះកុមារ ដែលស្នំឲ្យផ្ងើលើគ្រឿងទ្រពីរជាន់នាំមកគាល់ ។ បទថា **មហាបុរិ-សស្ស** សេចក្តីថា នៃបុរសអ្នកធំក្រៃលែងដោយអំណាច ជាតិ គោត្រ ត្រកូល

ប្រទេសជាដើម ។ បទថា **ទ្វេ គតិយោ** *គឺសេចក្តីសម្រេចពីរយ៉ាង ។* **គតិ** *សព្ទនេះ មានអត្ថ ៤ យ៉ាង គឺដំណើរដែលសត្វគប្បីទៅ អធ្យាស្រ័យ ទីពឹង សេចក្តីសម្រេច ។*

គតិ *សព្ទប្រព្រឹត្តទៅក្នុងអត្ថថា ដំណើរដែលសត្វគប្បីទៅ មាននរកជាដើម ដូចក្នុងប្រយោគជាដើមថា* **បញ្ច ខោ ឥមា សារីបុត្ត គតិយោ** *ម្នាលសារីបុត្ត គតិនេះមាន ៥ ប្រការ ដូច្នេះ ។*

រមែងប្រព្រឹត្តទៅក្នុងអត្ថថា អធ្យាស្រ័យ ដូចក្នុងប្រយោគជាដើមថា **ឥមេសំ ខោ អហំ ភិក្ខូនំ សីលវន្តានំ កល្យាណធម្មានំ នេវ បជានាមិ អាគតឹ វា គតឹ វា** *អាត្មាអញមិនបានដឹងដំណើរមក និងដំណើរទៅរបស់ពួកភិក្ខុដែលមានសីល មានកល្យាណធម៌ទាំងនេះសោះឡើយ ដូច្នេះ ។*

រមែងប្រព្រឹត្តទៅក្នុងអត្ថថា ទីពឹង ដូចក្នុងប្រយោគជាដើមថា **និព្ពានំ អរហតោ គតិ** *ព្រះនិព្វានជាទីពឹងរបស់ព្រះអរហន្ត ដូច្នេះ ។*

រមែងប្រព្រឹត្តទៅក្នុងអត្ថថា សេចក្តីសម្រេច ដូចក្នុងប្រយោគជាដើមថា **អបិច ត្យាហំ ព្រហ្មេ គតិញ្ច បជានាមិ ឧតិញ្ច បជានាមិ ឃវំ មហិទ្ធិកោ ពកោ ព្រហ្មា** *ម្នាលព្រហ្ម ប៉ុន្តែតថាគតស្គាល់សេចក្តីសម្រេចរបស់អ្នក ស្គាល់អានុភាពរបស់អ្នកហើយថា ពកព្រហ្ម មានឫទ្ធិច្រើនយ៉ាងនេះ ដូច្នេះ ។ ក្នុងទីនេះ គប្បីជ្រាប* **គតិ** *សព្ទនោះ ក្នុងអត្ថថា សេចក្តីសម្រេច ។ បទថា* **អនញ្ញា** *សេចក្តីថា ឈ្មោះថា សេចក្តីសម្រេចក្នុងគតិដទៃ មិនមាន ។ បទថា* **ធម្មិកោ** *សេចក្តីថា ប្រកបដោយកុសលធម៌ ១០ រៀរការដល់អគតិ ។ បទថា*

ធម្មរាជា នេះ ជាវេវចនៈរបស់បទមុននោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា ជាធម្មរាជា ព្រោះបានរាជសម្បត្តិដោយធម៌ ។ បទថា **ចាតុរន្តោ** សេចក្តីថា ភាពជាអ្នកមានឥស្សរៈក្នុងផែនដី មានមហាសមុទ្រ ៤ ជាព្រំដែន ដោយអំណាចសមុទ្រ ៤ មានសមុទ្រ ទិសខាងកើតជាដើម ។ បទថា **វិជិតាវី** គឺមានការឈ្នះសង្គ្រាម អធិប្បាយថា សូម្បីជនបទដល់ភាពជាជនបទដែលស្ថិតស្ថេរមាំមួន ព្រោះដួចោះ ទើបព្រះកុមារដល់ភាពជាអ្នកមានព្រះរាជ-អាណាចក្រវែងមាំ ។ ពិតហើយ កាលព្រះរាជាកាច បៀតបៀនលោកដោយជកពន្ធ និងជាក់អាជ្ញាជាដើម ពួកមនុស្សនាំគ្នាលះបង់ចោលមជ្ឈិមជនបទ ទៅអាស្រ័យនៅតាមភ្នំ និងមាត់សមុទ្រជាដើម ចិញ្ចឹមជីវិតរស់នៅឯជាយដែន ។ ពួកមនុស្សត្រូវចោរចិត្តកាចបៀតបៀនដោយការប្លន់ ទើបនាំគ្នាលះបង់ជាយដែន ទៅរកស៊ីចិញ្ចឹមជីវិត ក្នុងជនបទរបស់មនុស្សដែលខ្សត់ខ្សាយ ។ ជនបទក្នុងការឃុំគ្រងបែបនេះ រមែងមិនដល់នូវការវែងមាំ ។ កាលបើព្រះកុមារនេះ សោយរាជសម្បត្តិ ជនបទរបស់ព្រះអង្គនឹងស្តុកស្តម្ភ ដូចជាក់ផ្ចាំងថ្មទុកលើផែនដី ហើយទ្បោមព័ទ្ធដោយផ្ចាំងដែក ព្រាហ្មណ៍អ្នកទស្សទាយទាំង-ទ្បាយ កាលបង្ហាញដូច្នេះ ទើបពោលថា ព្រះកុមារដល់ភាពជាអ្នកមានព្រះរាជាណាចក្រវែងមាំដូច្នេះ ។ រតនៈក្នុងបទថា ប្រកបដោយរតនៈ ៧ នេះ ដោយអត្ថ គឺញុំងសេចក្តីត្រេកអរឲ្យកើត ។ ម្យ៉ាងវិញទៀត

វត្ថុណាធ្វើចិត្តឲ្យត្រេកអរក្រៃលែង ជារបស់មានតម្លៃច្រើន
កាត់ថ្លៃពុំបាន សូម្បីការឃើញក៏ឃើញបានដោយកម្រ ជា
គ្រឿងបរិភោគ ប្រើប្រាស់របស់បុគ្គលមិនចោកឋយ

ព្រោះដូច្នោះ ទើបរបស់នោះ ឈ្មោះថា រតនៈ ។

ម្យ៉ាងទៀត ចាប់ផ្តើមតាំងពីកាលដែលចក្កវត្តនៈកើតឡើង ទេវស្តាន គឺកន្លែងសម្រាប់បូជារបស់ទេវតាជាទៃមិនមាន ជនទាំងពួង រមែងធ្វើការបូជាចក្កវត្តនៈនោះឯងដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម និងការធ្វើការក្រាបថ្វាយបង្គំជាដើម ព្រោះដូច្នោះ ទើបរតនៈប្រព្រឹត្តទៅដោយអត្តថា គួរត្រេកអរ ។

ការកាត់ថ្លៃថា ទ្រព្យមានប្រមាណប៉ុណ្ណេះ ជាតម្លៃរបស់ចក្កវត្តនៈនោះមិនមាន ព្រោះដូច្នោះ ទើបរតនៈនោះប្រព្រឹត្តទៅ ដោយអត្តថា មានតម្លៃច្រើន ។

ម្យ៉ាងទៀត ចក្កវត្តនៈ មិនដូចរតនៈដទៃដែលមាននៅក្នុងលោក ព្រោះដូច្នោះ ទើបរតនៈប្រព្រឹត្តទៅដោយអត្តថា កាត់ថ្លៃមិនបាន ។

ព្រោះស្តេចចក្រពត្តិកើតឡើង ក្នុងកប្បដែលព្រះពុទ្ធទាំងឡាយកើតឡើង ។ តែព្រះពុទ្ធទាំងឡាយកើតឡើងក្នុងកប្បខ្លះប៉ុណ្ណោះ ដូច្នោះ ទើបរតនៈ ប្រព្រឹត្តទៅដោយអត្តថា ឃើញបានដោយកម្រ ។

រតនៈនោះ រមែងកើតដល់សត្វដ៏វិសេសក្រៃលែងដោយជាតិ រូប ត្រកូល និងកាពជាធំជាដើម មិនកើតដល់អ្នកដទៃ ព្រោះដូច្នោះ ទើបរតនៈ ប្រព្រឹត្តទៅដោយអត្ត គឺថាជាគ្រឿងបរិភោគ ប្រើប្រាស់របស់បុគ្គលមិនថោកថយ ។

ម្យ៉ាងទៀត សូម្បីរតនៈដ៏សេស ក៏ដូចចក្កវត្តនៈនុ៎ះឯង ព្រះមហាបុរសទ្រង់ប្រកបដោយរតនៈទាំង ៧ នេះ ដោយភាពជាបរិវារ និងដោយភាពជាឧបករណ៍នៃភោគៈទាំងពួង ព្រោះដូច្នោះ ទើបមហាបុរស ឈ្មោះថា បរិបូណ៌

ដោយវតន: ៧ ។

ឥឡូវនេះ ដើម្បីសម្តែងវតន:ទាំងនោះដោយសរុប ទើបត្រាស់ថា **តស្ស-មានិ** *ជាដើម ។*

ក្នុងវតន:ទាំងនោះ នេះជាការអធិប្បាយដោយសង្ខេប ក្នុងបទថា ចក្ក-វតន:ជាដើម ចក្កវតន:កាលកើត អាចជណ្តើមយកសិរីសម្បត្តិរបស់ទ្វីបធំ ទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារបាន ។ ហត្ថិវតន: អាចហោះទៅកាន់ វេហាស៍ ចុះមកកាន់ផែនដី ដែលមានសាគរជាទីបំផុតមុនអាហារនោះឯង ។ អស្សវតន: ក៏ដូច្នោះដែរ ។ កាលមានសេចក្តីងងឹតប្រកបដោយអង្គ ៤ កែវ មណីអាចកម្ចាត់សេចក្តីងងឹត ប្រមាណមួយយោជន៍ឲ្យក្តីបាន ។ ឥត្ថីវតន: ជាអ្នកមានការប្រព្រឹត្តជាទីពេញចិត្ត រៀរទោស ៦ យ៉ាង ។ គហបតិវតន: អាចឃើញរណ្តៅទ្រព្យ ដែលនៅខាងក្នុងផែនដីប្រមាណមួយយោជន៍បាន ។ បរិនាយកកែវ ពោល គឺបុត្រដ៏ប្រសើរបំផុត អាចកើតក្នុងព្រះគភ៌របស់ព្រះ អគ្គមហេសី ហើយគ្រងរាជសម្បត្តិ បានទាំងអស់ រមែងប្រាកដ ។

បទថា **បភោសមាសុំ** *គឺច្រើនជាងពាន់ ។ បទថា* **សូរា** *គឺក្លាហាន ។ បទថា* **វីរង្គរូចា** *គឺមានរូបឆោមទ្រង់ទ្រាយសមជាវីរបុរស ។ បទនេះ ជា ឈ្មោះរបស់សេចក្តីព្យាយាម ។ ឈ្មោះថា* **វីរង្គរូចា** *ព្រោះមានរូបរាង សមរម្យ ជាវីរបុរស ។ មានទ្រង់ទ្រាយសមជាវីរបុរស គឺមានសេចក្តី ព្យាយាមជាទីកើត មានសេចក្តីព្យាយាមជាសភាវ: សម្រេចដោយសេចក្តី ព្យាយាម ជាអ្នកមិនខ្វិលច្រអូស ។ លោកអធិប្បាយថា សូម្បីច្បាំងរហូត ដល់អស់មួយថ្ងៃ ក៏មិនហត់នឿយ ។*

บทว่า **สาครปริยนฺตํ** *เสจกฺตีว่า มานมหาสมุทฺรชาทีปีปุต ธฺเวีกฺ์ จกฺรวาลเวฺยชาพฺรีปฺรเทลฺเตางฺนาเว ฯ บทว่า* **อทณฺเฑน** *เสจกฺตีว่า ปุคฺคลณา พินัยอฺกมินปานธฺเวีขุส ๑๐๐ ขฺุ ๑๐๐๐ ขฺุ ปุคฺคลนาุ เณฺาุะว่า ปฺเวีอำณาจเดายอาชฺา คือทฺเพฺย ฯ ปุคฺคลณาจเญพากฺยปงฺคาปฺเวีขฺปหาร นิงฺจากปุคฺคลนาุ เณฺาุะว่า ปฺเวีอำณาจเดายอาชฺา คือสสฺตฺรา เตพฺระ ภาชาอคฺนีุ ทฺเงฺลุะอาชฺาเตางฺพีรนีุ ทฺเงฺคฺรปฺคฺรงฺมินจำเปาจฺปฺเวีอาชฺา ฯ บทว่า* **อสฺเสน** *เสจกฺตีว่า ปุคฺคลณาปฺเวีสสฺตฺรามานมุขเตฺมางฺชาเดีม เปเตเปนอฺกชไท ปุคฺคลนาุ เณฺาุะว่า ปฺเวีอำณาจเดายสสฺตฺรา ฯ เตพฺระภาชาอคฺนีุ ทฺเงฺมินเธฺเีณาเมรปสฺปุคฺคลณาเมฺาก์ ตฺรีมเตสตฺวุยตูจ ผีกปาน เฺยเกีตเฺวีงฺเดายสสฺตฺรา ทฺเงฺปานทฺทูลกาเรสฺวาคมนฺอำพีพฺระภา เดีลชาสตฺรเวฺย๊างฺนีุะว่า ปพิตฺรเมหาภช สูมพฺระอคฺนีสฺเตจยางฺเมก เดายจมฺจุ ชูเถฺ อธิปฺปายยา ทฺเงฺชณฺีเมผีนชีชูจเพลเหีย ทฺเงฺ คฺรปฺคฺรง ทฺเงฺปฺราปปฺราเม เรเตปานชาเมฺาสฺคฺรปฺคฺรง ฯ กาลปฺราปฺชลฺ เสจกฺตีสเมฺรจคีคติ ทีเมวยเย๊างฺนีุเหีย เชีเมฺยินิงฺปฺราปฺเสจกฺตีสเมฺรจ คีคติทีพีร เทีปเพเลพากฺยว่า* **สเจ เหา ปน** *ชูเถฺชาเชีเม ฯ กฺุงปททำงฺ นาุ ปทว่า* **ฯวฺชฺชโน** *เพฺระมานเคฺรืองฺปิทจำงฺกากำงฺ เพเล คือกคะ: เทาสะ: เมาหะ: มานะ: ทิฏฺิ กิเลส ตณฺหาเบีกเหีย คือกเมฺาต์ปานเหีย ฯ ปาลีว่า* **ฯวฺชฺชโน** *ชูเถฺุกีมาน อธิปฺปายกีมานนัยชูจคฺา ฯ*

[๒๙-๓๐] *กาลปฺราปฺสเจกฺตีสเมฺรจ คือคติทีพีรเย๊างฺนีุเหีย เชีเมฺยีสเมฺืงฺลกฺขณะ:เดีลชานิมิตฺตนีคติทำงฺนาุ ทฺเปเพลพากฺยชาเชีเม*

ថា **អយំ ហិ ឧៗ កុមារោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សុបតិដ្ឋិតចាឧោ** សេចក្តីថា ព្រះរាជកុមារមិនដូចជាអ្នកដទៃ កាលអ្នកដទៃដាក់ជើងចុះលើផែនដី ចុងជើង ឬកែងជើងរមែងដល់ផែនដីមុន តែនៅប្រាកដប្រហោងកណ្តាល សូម្បីកាលលើកឡើងចំណែកមួយក្នុងចុងជើងជាដើមនោះឯង ក៏លើកឡើងមុន ។ ផ្ទៃព្រះបាទទាំងមូលរបស់ព្រះរាជកុមារនោះ រមែងជាន់ផែនដីដោយទ្រង់ដាក់ព្រះបាទតែម្តងដូចផ្ទៃស្បែកជើងមាសដូច្នោះ ទ្រង់លើកព្រះបាទឡើង អំពីផែនដីក៏ដោយទំនងដូចគ្នានុ៉ះឯង ព្រោះដូច្នោះ ទើបព្រះរាជកុមារនេះ ជាអ្នកមានព្រះបាទរាបស្មើគ្នា ។

បទថា **ចក្ការនិ** លោកពោលក្នុងបាលីថា ក្នុងផ្ទៃព្រះបាទទាំង ២ មានចក្រ ២ កើតឡើង ចក្រទាំងនោះមានកាំ មានកង់ និងដុំ ។ គប្បីជ្រាបសេចក្តីវិសេសនេះ ដោយបទនេះថា បរិបូណិដោយអាការទាំងពួង ។ បានព្ចថាដុំរបស់ចក្រទាំងនោះ ប្រាកដត្រង់កណ្តាលផ្ទៃព្រះបាទ ។ ក្បាច់រង្វង់កំណត់ដោយដុំរមែងប្រាកដ រង្វង់របស់មុខដុំរមែងប្រាកដ ទទឹកប្រាកដ កាំប្រាកដ ក្បាច់ត្រង់ដុំដែលភ្ជាប់នឹងកាំទាំងឡាយប្រាកដ ខ្នងកង់ប្រាកដ ខ្នងកង់កែវមណីប្រាកដ ។ នេះមកក្នុងបាលីស្រាប់ហើយ ។ តែសម្ពហុលវារៈនៅមិនទាន់មក ។ សម្ពហុលវារៈនោះ គប្បីជ្រាបយ៉ាងនេះ ។ រូបលំពែង រូបកញ្ចក់ រូបផ្តានួនស្រី រូបខ្សែក រូបសង្វារ រូបថាសមាស រូបមច្ចាគូ រូបតាំង រូបកង្វេរ រូបប្រាសាទ រូបសសរខឿន រូបស្វេតច្ចត្រ រូបព្រះខ័ន រូបផ្ចិតស្ទឹកត្នោត រូបផ្ចិតកន្ទុយក្វោក រូបផ្ចិតវាលវីជនី រូបមកុដ រូបកែវមណី រូបបាត្រ

រូបកម្រងផ្ការម្ជិះ រូបឧប្បលខៀវ រូបឧប្បលក្រហម រូបឧប្បលស រូបផ្ការឈូកក្រហម រូបផ្ការឈូកស រូបឆ្នាំងពេញដោយទឹក រូបថាសពេញដោយទឹក រូបមហាសមុទ្រ រូបភ្នំចក្រវាល រូបព្រៃហិមពាន្ត រូបភ្នំសិនេរុ រូបព្រះចន្ទព្រះអាទិត្យ រូបផ្ការយនក្ខត្តឬក្ស រូបទ្វីបធំទាំង ៤ រូបទ្វីបតូច ២០០០ ដោយហោចសំដៅដល់បរិវាររបស់ស្តេចចក្រពត្តិ ជាបរិវាររបស់ចក្កលក្ខណៈនុ៉ះឯង ។ បទថា **អាយតបណ្ហិ** សេចក្តីថា មានកែងព្រះបាទវែង គឺមានកែងព្រះបាទបរិបូណិ អធិប្បាយថា កែងព្រះបាទរបស់ព្រះមហាបុរស មិនដូចជាចុងជើងរបស់អ្នកដទៃដែលវែងស្មងជើង តាំងនៅក្នុងទីបំផុតកែងជើង ដូចជាកាត់កែងជើងតាំងនៅ ដូច្នោះ ។ តែកែងព្រះបាទរបស់ព្រះមហាបុរស ព្រះបាទមាន ៤ ចំណែក ចុងព្រះបាទមាន ២ ចំណែក ស្មងតាំងនៅក្នុងចំណែកទី ៣ កែងព្រះបាទក្នុងចំណែកទី ៤ ដូចគ្នានឹងកូនយ្ជីស្បែក ធ្វើដោយសំពត់កម្ពលពណិក្រហម ដូចស្រែះដោយចុងម្ជុលហើយតម្ពល់ទុក ។

បទថា **ជីឃង្គុលិ** សេចក្តីថា ម្រាមព្រះហស្តរបស់ព្រះមហាបុរស មិនដូចម្រាមរបស់អ្នកដទៃ ដែលម្រាមខ្ជះវែង ម្រាមខ្ជះខ្ជី ។ តែម្រាមរបស់ព្រះមហាបុរស ម្រាមព្រះហស្ត និងព្រះបាទវែងដូចរបស់ពានរ ខាងគល់ធំហើយរៀវទៅដោយលំដាប់ដល់ចុងម្រាម ដូចជាលម្អិតមនោសិលាដែលគេច្របាច់ដោយប្រេង ហើយលញ់ ដូច្នេះ ព្រោះដូច្នោះ ទើបលោកពោលថា មានម្រាមព្រះហស្តវែង ដូច្នេះ ។

បទថា **មុឧុតលុនហត្ថចាធោ** សេចក្តីថា មានព្រះហស្ត និងព្រះបាទទន់ ដូចសំឡីកប្បាសដែលគេថ្ពេចអស់ ១០០ ដង យកមកតាំងទុកក្នុងទឹក

ដោះថ្ងា ។ ក្នុងវេលាព្រះជន្មចម្រើន ព្រះហស្ត និងព្រះបាទក៏ទន់ល្មៃដូច កាលប្រសូត ។ ព្រះហស្ត និងព្រះបាទរបស់ព្រះពោធិសត្វនោះទន់ ព្រោះដូច្នោះ ទើបព្រះពោធិសត្វមានព្រះហស្ត និងព្រះបាទទន់ ។

បទថា **ជាលហត្ថបាទោ** *សេចក្តីថា ចន្លោះព្រះអង្គុលី ស្បែកមិនជាប់គ្នា ។ ព្រោះអ្នកមានដៃជាប់គ្នាជាជួរដូច្នេះ ត្រូវកម្ចាត់ដោយបុរសទោស សូម្បីបួសក៏មិនបាន ។ ព្រះមហាបុរសមានម្រាមព្រះហស្ត ៤ ធ្នាប់ ព្រះបាទ ៥ ជិតស្និទ្ធដូចតែមួយ ។ ព្រោះព្រះអង្គុលីទាំងឡាយជិតស្និទ្ធដូចជាតែមួយ ទើបព្រះអង្គុលីទាំងឡាយតម្រៀបគ្នាស្និទ្ធ មានលក្ខណៈដូចបាយដំណើបតាំងនៅ ។ ព្រះហស្ត និងព្រះបាទរបស់ព្រះពោធិសត្វនោះ ដូចគ្នានឹងបង្គងក្រឡាសំណាញ់ ដែលជាងអ្នកឈ្លាសធ្វើហើយ ព្រោះដូច្នោះ ទើបលោកពោលថា មានបាតព្រះហស្ត និងបាតព្រះបាទ មានឆ្នូតដូចក្រឡាសំណាញ់ ។*

ព្រោះកព្រះបាទតាំងនៅខាងលើ ទើបព្រះបាទរបស់ព្រះពោធិសត្វនោះដូចសង្ឃ៍ផ្តាប់ ព្រោះដូច្នោះ ទើបព្រះពោធិសត្វមានព្រះបាទដូចសង្ឃ៍ផ្តាប់ ។ ពិតហើយ កជើងរបស់អ្នកជនៃនៅត្រង់ខ្នងជើង ព្រោះដូច្នោះ ទើបជើងរបស់អ្នកទាំងនោះ ជាប់គ្នាដូចជាប់ដោយគន្លឹះ ត្រឡប់ទៅមក មិនបានតាមសប្បាយ កាលដើរទៅបាតជើងមិនប្រាកដ ។ តែកព្រះបាទរបស់ព្រះមហាបុរសទ្បើងទៅ តាំងនៅខាងលើ ព្រោះដូច្នោះ ព្រះវរកាយផ្នែកខាងលើរបស់ព្រះមហាបុរស តាំងពីព្រះនាភីទ្បើងទៅ ទើបមិនបានញាប់ញ័រទ្បើយ ដូចព្រះសុវណ្ណបដិមា ប្រតិស្ឋាននៅក្នុងទូក ។ ព្រះវរកាយ ផ្នែកខាងក្រោមរមែងកម្រើក ។ ព្រះបាទត្រឡប់ទៅមកបានសប្បាយ ។ កាលជនទាំងឡាយ

ឈរខាងមុខខ្លះ ខាងក្រោយខ្លះ សូម្បីក្នុងខាងទាំងពីរក៏ឃើញបាតព្រះបាទច្បាស់ជា ។ តែមិនច្បាស់ដូចឈរខាងក្រោយដែរ ។

បទថា **ឯណិជង្ឃោ** *គឺមានស្មងរៀវដូចសត្វទ្រាយ អធិប្បាយថា មានស្មងបរិបូណ៌ បូកលាបដោយព្រះមំសៈពេញ មិនមែនសាច់ត្រគាកជាប់ដោយភាពតែមួយ ប្រកបដោយស្មង ដូចគ្នានឹងជង្ហើមស្រូវសាលី ជង្ហើមស្រូវដំណើប ដែលមំសៈតាំងនៅស្មើគ្នា ដោយជុំវិញហើយ មូលក្បុំល្អ ។*

បទថា **អនោនមន្តោ** *គឺមិនឱនចុះ ។ លោកសម្តែងដល់ព្រះមហាបុរសនោះមិនគម មិនតឿ ដោយបទនេះ ។ មនុស្សដ៏សេសជាមនុស្សគម ឬជាមនុស្សតឿ ។ មនុស្សគម កាយចំណែកខាងលើមិនបរិបូណ៌ មនុស្សតឿ កាយចំណែកខាងក្រោមមិនបរិបូណ៌ អ្នកទាំងនោះ ព្រោះកាយមិនបរិបូណ៌ កាលមិនឱនចុះ ទើបមិនអាចសូបអង្អែលជង្គង់បាន ។ តែព្រះមហាបុរស ព្រោះព្រះវរកាយ ទាំងចំណែកខាងលើ ចំណែកខាងក្រោមបរិបូណ៌ ទើបអាចសូបកន្ទាលជង្គង់បាន ។*

បទថា **កោសោហិតវត្ថគុយ្ហោ** *សេចក្តីថា ព្រះមហាបុរសមានព្រះគុយ្ហៈ លាក់នៅក្នុងស្រោម ដូចស្រោមឈូកមាស ដូចគុយ្ហៈនៃគោ និងជ័រជាដើម ព្រោះហេតុនោះ ទើបព្រះមហាបុរស មានព្រះគុយ្ហៈលាក់នៅក្នុងស្រោមៗបទ ថា* **វត្ថគុយ្ហំ** *លោកពោលអង្គជាតគួរបិទបាំងដោយសំពត់ ។*

បទថា **សុវណ្ណវណ្ណោ** *សេចក្តីថា ព្រះមហាបុរស ដូចនឹងរូបជុំមាសដែលលាយឡំដោយពណ៌ក្រហម ហើយខាត់ដោយចន្ទមន្ថា ហើយលាយដោយដីក្រហមតាំងទុក ។ ដោយបទនេះ ដើម្បីសម្តែងភាពដែលព្រះវរកាយ*

របស់ព្រះមហាបុរសនោះ ស្មិទ្ធល្អិតផូរផង់ហើយ ទើបសម្តែងព្រះឆវីវណ្ណ លោកពោលថា ព្រះមហាបុរសមានព្រះឆវីវណ្ណដូចមាស ដូច្នេះ ។ ម្យ៉ាងទៀត បទនេះជាវេវចន:របស់បទមុន ។

បទថា **រជោជល្ជំ** គឺធូលី ឬមន្ទិល ។ បទថា **ន ឧបលិម្ឃតិ** សេចក្តីថា មិនជាប់ គឺរមៀលដូចតំណក់ទឹករមៀលអំពីស្លឹកឈូក ។ ព្រះពុទ្ធទាំងពួងទ្រង់ធ្វើការជម្រះព្រះហស្តជាដើម ដើម្បីកំណត់រដូវ និងដើម្បីផលបុណ្យរបស់ពួកទាយក ។ ម្យ៉ាងទៀត ទ្រង់ធ្វើដោយបដិបទានោះឯង ។ ប្រការនេះ លោកពោលថា ភិក្ខុនឹងចូលទៅកាន់សេនាសន: គួរជម្រះជើងហើយ សឹមចូលទៅ ។

បទថា **ឧទ្ធគ្គលោមោ** សេចក្តីថា ព្រះមហាបុរស មានព្រះលោមជាតិមានចុងងឡើងលើ ចុងវិលជាទក្ខិណាវដ្ត តាំងនៅ មុខគួរឲ្យចង់មើល ព្រោះដូច្នោះ ព្រះមហាបុរសមានព្រះលោមជាតិមានចុងងឡើងលើ ។

បទថា **ព្រហ្មុជុគត្តោ** សេចក្តីថា ព្រះមហាបុរស មានព្រះវរកាយត្រង់ដូចកាយព្រហ្ម គឺមានព្រះវរកាយខ្ពស់ត្រង់ឡើងទៅនោះឯង ។ សេចក្តីពិតដោយច្រើន សត្វទាំងឡាយ រមែងបង្អោនទៅក្នុងទីទាំងបី គឺត្រង់ក ចង្កេះ និងជង្គង់ទាំងពីរ ។ សត្វទាំងនោះ កាលឡិនទៅ ចង្កេះរមែងទៅខាងក្រោយ ។ ក្នុងទីទាំងពីរនោះ រមែងឡិនទៅខាងមុខ ។ សត្វពួកខ្លះ មានរាងកាយខ្ពស់ កាយរមែងកោងទៅមុខ ពួកខ្លះ ងើយមុខត្រាច់ទៅ ដូចដើររាប់ផ្តាយ ។ សត្វពួកខ្លះ មានសាច់ និងឈាមតិច ដូចជាអ្នកមានរោគចុកពោះ ។ ពួកខ្លះដើរទៅឈ្វោកខាងមុខ ដងខ្ជួនញ័រ ។ អាចារ្យទាំងឡាយពោលថា ព្រះមហាបុរសនេះ ទ្រង់ជំណើរព្រះវរកាយត្រង់នោះឯង មានប្រមាណស្មើនឹងចំណែក

កម្ពស់ដូចជាសសរមាស ដែលលើកឡើងក្នុងទេវនគរ ។ ម្យ៉ាងទៀត គប្បីជ្រាបថា សេចក្តីនេះលោកពោលសំដៅដល់ មហាបុរិសលក្ខណៈរបស់ព្រះមហាបុរស កាលដែលប្រសូតនៅមិនទាន់បរិបូណ៌ ដោយប្រការទាំងពួង នឹងចម្រើនក្នុងឱកាសតទៅ ។

បទថា **សត្តុស្សទោ** *សេចក្តីថា ព្រះមហាបុរសមានព្រះមំសៈពេញបរិបូណ៌ដោយល្អក្នុងទី ៧ ស្ថាន គឺខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទទាំងពីរ ចង្ការស្មាទាំងពីរ និងព្រះសូរង ព្រោះដូច្នោះ ទើបព្រះមហាបុរស ឈ្មោះថាមានព្រះមំសៈពេញក្នុងទី ៧ ស្ថាន ។ តែរបស់មនុស្សពួកជទៃ ត្រង់ខ្នងដៃនិងខ្នងជើងជាដើម ច្រោកជសរសៃឈាមជាក្រឡាសំណាញ់ ចង្ការស្មា និងកច្រោកជចុងឆ្អឹង ។ មនុស្សទាំងនោះ រមែងច្រោកជដូចប្រេត ។ ព្រះមហាបុរសមិនច្រោកជយ៉ាងនោះ ។ ព្រះមហាបុរស មានព្រះសូរង ដូចស្តារមាសដែលគេក្រឡឹង ដោយខ្នងព្រះហស្តជាដើម មានសរសៃឈាមជាក្រឡាសំណាញ់លាក់ ព្រោះមានព្រះមំសៈពេញបរិបូណ៌ក្នុងទី ៧ ស្ថាន រមែងច្រោកជដូចរូបសិលា និងរូបសួន ។*

បទថា **សីហបុព្វទ្ធកាយោ** *សេចក្តីថា ព្រះមហាបុរសមានពាក់កណ្តាលកាយខាងលើ ដូចពាក់កណ្តាលកាយខាងមុខរបស់រាជសីហ៍ ព្រោះដូច្នោះ ទើបព្រះមហាបុរស ឈ្មោះថា មានចំណែកព្រះវរកាយខាងមុខ ដូចពាក់កណ្តាលកាយខាងមុខនៃរាជសីហ៍ ព្រោះថា កាយខាងមុខរបស់រាជសីហ៍បរិបូណ៌ កាយខាងក្រោយមិនបរិបូណ៌ ។ ព្រះវរកាយទាំងអស់ របស់ព្រះមហាបុរសបរិបូណ៌ ដូចកាយខាងមុខរបស់រាជសីហ៍ ។ សូម្បីព្រះវរកាយ*

របស់មហាបុរស ក៏ដូចកាយរបស់រាជសីហ៍ មិនតាំងនៅខ្ពស់ៗ ទាបៗ ដោយអំណាចនៃការប៉ោងខ្លឹង និងផតចុះជាដើម តែវែងក្នុងទីគួរវែង ខ្លីក្នុងទីគួរខ្លី មាំមួន រៀវ ទូលាយ មូលជាដើម ។ ដូចដែលព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូបកាយរបស់ព្រះមហាបុរស គួរជាទីត្រេកអរពេកណាស់ ដែលកម្ម និងវិបាកធ្វើឲ្យប្រាកដ ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាវែង អវយវៈចំណែកនោះរមែងតាំងនៅវែង ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាខ្លី អវយវៈចំណែកនោះរមែងតាំងនៅខ្លី ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាធំ អវយវៈចំណែកនោះ រមែងតាំងនៅធំ ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាតូចអវយវៈចំណែកនោះ រមែងតាំងនៅតូច ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាក្រាស់ អវយវៈចំណែកនោះ រមែងតាំងនៅក្រាស់ ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាមូល អវយវៈចំណែកនោះ រមែងតាំងនៅមូល ដូច្នេះ ។ អត្តភាពរបស់ព្រះមហាបុរសសន្សុំទុកដោយទានចិត្ត បុញ្ញចិត្ត រៀបចំទុកដោយបារមី ១០ ដោយប្រការដូច្នេះ ។ សិប្បៈទាំងពួង ឬអ្នកមានឫទ្ធិទាំងពួងក្នុងលោក មិនអាចសាងរូបឲ្យដូចបាន ។

បទថា **បិតន្តរំសោ** *សេចក្តីថា ក្នុងចន្លោះចំណែកទាំងពីរ លោកពោលថា* **អន្តរំសោ** ។ *ព្រះមហាបុរសមានព្រះអង្សាពេញ គឺបរិបូណ៌ ព្រោះហេតុនោះ ទើបព្រះមហាបុរសមានចន្លោះព្រះអង្សាពេញ ។ សេចក្តីពិត ឋានៈនោះរបស់មនុស្សពួកជទៃ ខ្នងផត និងពោះទាំងពីរប្រាកដចំពោះខ្លួន ។ តែរបស់ព្រះមហាបុរសផ្ទៃព្រះមំសា តាំងពីពាក់កណ្តាលព្រះអង្គ ដរាបដល់ព្រះសូរងខ្លឹងទៅ បិទព្រះបិដ្ឋិ តាំងនៅដូចផែនក្តារមាស ដែលលើកបញ្ឈរ ។*

បទថា **និគ្រោធបរិមណ្ឌលោ** *គឺព្រះមហាបុរសមានបរិមណ្ឌលដូចដើមនិគ្រោធ អធិប្បាយថា ព្រះមហាបុរសព្រះវរកាយ គឺកម្ពស់ និងព្យាម មានប្រមាណស្មើគ្នាដូចដើមនិគ្រោធ មានដើម និងមែកស្មើគ្នា ព្រោះថា ទោះជា ៥០ ហត្ថក្តី ១០០ ហត្ថក្តី រមែងមានប្រមាណស្មើគ្នា ទាំងកម្ពស់ និងទទឹង ។ កម្ពស់ និងព្យាមរបស់មនុស្សជទៃមិនស្មើគ្នា ព្រោះដូច្នោះឯង ទើបលោកពោលថា* **យាវតកฺวสฺส กายោ** *ជាដើម ។* **យาวตกฺวสฺส** *កាត់បទជា* **យาวตโก อสฺส** *សេចក្តីថា ព្រះវរកាយរបស់ព្រះមហាបុរសស្មើនឹងព្យាមរបស់ព្រះមហាបុរស ព្យាមរបស់ព្រះមហាបុរស ស្មើនឹងកាយរបស់ព្រះមហាបុរស ។*

បទថា **សมវฏฺฏกฺขนฺโธ** *គឺព្រះមហាបុរស មានជង្ឃកស្មើស្រឡះ ។ បុគ្គលខ្លះ មានជង្ឃកវែង រៀច ក្រាស់ ដូចសត្វក្រៀល កុក ជ្រូក រលាននិយាយ សរសៃជាក្រឡាសំណាញ់រមែងប្រាកដ សំឡេងចេញមកស្អកស្អា យ៉ាងណា របស់ព្រះមហាបុរសមិនដូច្នោះឡើយ ។ ជង្ឃព្រះសូរងរបស់ព្រះមហាបុរសដូចគ្នានឹងស្គរមាសដែលគេក្រឡឹងល្អហើយ ។ រលាត្រាស់សរសៃជាក្រឡាសំណាញ់ មិនប្រាកដ ព្រះសូរសៀងខ្វាំងរំពងដូចសំឡេងផ្គរលាន់ ។*

ក្នុងបទថា **รสគฺคสคฺคี** *នេះ មានវិគ្គហៈថា សរសៃប្រសាទនាំរសទៅ ឈ្មោះថា* **รสคฺคสา** *។ បទនេះ ជាឈ្មោះរបស់សរសៃប្រសាទ ដែលនាំរសអាហារទៅ ។ សរសៃប្រសាទនាំរសអាហាររបស់ព្រះមហាបុរសនោះដ៏ប៉ាងប្រសើរ ព្រោះហេតុនោះ ទើបព្រះមហាបុរសជាអ្នកមានចុងសរសៃប្រសាទសម្រាប់នាំរសអាហារដ៏ប្រសើរ ។ បានឮថា ព្រះមហាបុរសមានសរសៃ*

ប្រសាទសម្រាប់នាំរសអាហារប្រមាណ ៧០០០ សារសៃ មានចុងឡើងខាងលើ ហើយរួមចូលត្រង់បំពង់ព្រះសូរងនុ៎ះឯង ។ ព្រះក្រយាហារសូម្បីប៉ុនគ្រាប់ល្ងតាំងនៅក្នុងចុងព្រះជិវ្ហា រមែងផ្សាយទូទៅពេញព្រះវរកាយគ្រប់ចំណែក ។ ដោយហេតុនោះឯង កាលព្រះមហាបុរស ទ្រង់ផ្តើមតាំងសេចក្តីព្យាយាមដ៏ធំក្រៃលែង បានញ៉ាំងព្រះវរកាយឲ្យប្រព្រឹត្តទៅបាន ដោយបាយមួយគ្រាប់ជាដើមខ្លះដោយត្រឹមតែបន្លែជ្រក់មួយទូកដៃខ្លះ ។ តែចំពោះមនុស្សជទៃមិនមានយ៉ាងនោះ ទើបរសឱជាមិនផ្សាយទូទៅពេញរាងកាយ ។ ព្រោះហេតុនោះ ទើបជនទាំងនោះមានរោគច្រើន ។

បទថា **សីហាហនុ** *មានវិគ្គហៈថា ព្រះហនុរបស់ព្រះមហាបុរស ដូចចង្ការរបស់រាជសីហ៍ ព្រោះហេតុនោះ ទើបព្រះមហាបុរសមានព្រះហនុ ដូចចង្ការាជសីហ៍ ។ ក្នុងបទនោះអធិប្បាយថា រាជសីហ៍មានចង្កាកំណាត់ក្រោមបរិបូណ៌ កំណាត់លើមិនបរិបូណ៌ តែព្រះមហាបុរស បរិបូណ៌ទាំងពីរ ដូចចង្កាខាងក្រោមរបស់រាជសីហ៍ ដូចជាព្រះចន្ទក្នុងថ្ងៃ ១២ កើត ។ លំដាប់នោះ ព្រាហ្មណ៍អ្នកព្យាករទាំងឡាយ សម្លឹងមើលចុងព្រះហនុ សង្កេតក្នាមថា ត្រង់ព្រះហនុទាំងនេះ ព្រះទន្ត ៤០ គឺខាងក្រោម ២០ ខាងលើ ២០ និងតាំងនៅស្មើគ្នាយ៉ាងស្និទ្ធ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះកុមារនេះមានព្រះទន្ត ៤០ គត់ ដូច្នេះជាដើម ។ ក្នុងបទនោះ មានអធិប្បាយដូច្នេះ មនុស្សពួកជទៃ មានធ្មេញគ្រប់បរិបូរណ៌ ក៏មានត្រឹម ៣២ ។ តែព្រះរាជ-កុមារនេះ មាន ៤០ ម្យ៉ាងទៀត របស់មនុស្សពួកជទៃ ធ្មេញខ្លះខ្ពស់ ខ្លះទាបខ្លះមិនស្មើគ្នា ។ តែរបស់ព្រះកុមារនេះ ស្មើគ្នា ដូចសង្ឃដែលជាងដែកកាត់*

ដូច្នោះ ។ ធ្មេញរបស់មនុស្សពួកជដៃ ឃ្មាតឆ្ងាយ ដូចធ្មេញក្រពើ កាលទំពាត្រី និងសាច់ រមែងសៀតនឹងចន្លោះធ្មេញ ។ តែព្រះទន្តរបស់ព្រះកុមារនេះ ជិតស្និទ្ធដូចជួរកែវពិរះ ដែលគេតាំងលើផែនក្តារមាស និងដូចពេលដែលគេគូរដោយខ្មៅដៃ ម្យ៉ាងទៀត ធ្មេញរបស់មនុស្សពួកជដៃ មានធ្មេញចំពើស ព្រោះហេតុនោះ ធ្មេញចង្កឹមខ្លះ ពណ៌ខ្មៅ ខ្លះមិនមានពណ៌ ។ តែព្រះរាជ-កុមារនេះ មានព្រះទាឋៈសស្អាត និងព្រះទាឋៈប្រកបដោយស្មើរុងរឿង ក្រៃលែងជាងផ្កាយព្រឹក្ស ។ បទថា **បហូតជិវฺโห** *គឺព្រះរាជកុមារមានព្រះជិវ្ហាធំ អធិប្បាយថា អណ្តាតរបស់មនុស្សពួកជដៃ ក្រាស់ខ្លះ តូចខ្លះ ខ្ចីខ្លះ រឹងខ្លះ មិនស្មើខ្លះ តែព្រះជិវ្ហារបស់មហាបុរស ទន់ វែង ធំ សម្បូណ៌ដោយពណ៌ ។ ព្រះរាជកុមារនេះ កាលកម្ចាត់សេចក្តីសង្ស័យរបស់អ្នកដែលមកដើម្បីស្វែងរកលក្ខណៈនោះ ព្រោះព្រះជិវ្ហាទន់ ទើបទ្រង់លៀនព្រះជិវ្ហានោះដូចរបស់រឹងដែលស្អាតហើយ លូកចូលប្រហោងព្រះនាសិកទាំងពីរបាន ព្រោះព្រះជិវ្ហាវែង ទើបទ្រង់មូរព្រះជិវ្ហាស៊កព្រះកាណ៌ទាំងពីរបាន ព្រោះព្រះជិវ្ហាធំ ទើបទ្រង់ចិទព្រះនលាដទាំងអស់ដល់ទីបំផុតចុងព្រះកេសា ទ្រង់ប្រកាសដល់ព្រះជិវ្ហានោះទន់ វែង និងធំយ៉ាងនេះ ទើបទ្រង់កម្ចាត់សេចក្តីសង្ស័យរបស់ព្រាហ្មណ៍អ្នកព្យាករទាំងនោះបាន ។ បទថា* **បហូតជិវฺโห** *លោកពោលសំដៅដល់ព្រះជិវ្ហា ដែលដល់ព្រមដោយលក្ខណៈទាំង ៣ យ៉ាងនេះ ។*

បទថា **ព្រហฺสฺสโร** *សេចក្តីថា មនុស្សពួកជដៃ រមែងមានសំឡេងជាប់ខ្លះ បែកខ្លះ ។ សំឡេងដូចក្អែកខ្លះ ។ តែព្រះរាជកុមារនេះ ទ្រង់ប្រកបដោយសំឡេងដូចសំឡេងរបស់មហាព្រហ្ម ។ ព្រោះថា មហាព្រហ្ម មានសំឡេង*

ច្បាស់ ព្រោះមិនលាយដោយទឹកប្រមាត់ និងស្លេស្ម ។ កម្មដែលព្រះមហាបុរសទ្រង់ធ្វើហើយ រមែងជម្រះវត្ថុនៃសំឡេងនោះ ព្រោះវត្ថុបរិសុទ្ធ សំឡេងប្រាកដឡើងតាំងពីព្រះនាភី ជាសំឡេងបរិសុទ្ធ ប្រកបដោយអង្គ ៨ រមែងប្រាកដច្បាស់ ។ ព្រះរាជកុមារត្រាស់ដូចសំឡេងសត្វករវិក ព្រោះហេតុនោះ ទើបព្រះរាជកុមារត្រាស់មានសំនៀងដូចសំឡេងសត្វករវិក ។ អធិប្បាយថា ព្រះរាជកុមារមានព្រះសូរសៀងក្រអៅពីរោះ ដូចសំឡេងសត្វករវិក ដែលគួរសរសើរ ។ បទថា **អភិនីលនេត្តោ** *សេចក្តីថា ព្រះរាជកុមារមានព្រះនេត្រមិនខ្មៅទាំងអស់ ។ ព្រះនេត្ររបស់ព្រះរាជកុមារនោះ ប្រកបដោយពណ៌ខៀវបរិសុទ្ធក្រៃលែង ដូចគ្នានឹងផ្កាត្រកៀត ក្នុងទីដែលគួរខៀវ ។ ក្នុងទីដែលគួរលឿង ក៏មានពណ៌លឿង ដូចគ្នានឹងផ្កាកណិការ ។ ក្នុងទីដែលគួរក្រហម ក៏មានពណ៌ក្រហមដូចគ្នានឹងផ្កាច្បា ។ ក្នុងទីដែលគួរស ក៏មានពណ៌ដូចផ្កាយព្រឹក្ស ។ ក្នុងទីគួរខ្មៅ ក៏មានពណ៌ខ្មៅដូចគ្នានឹងផ្នែផ្នាំដោះក្របី ព្រះនេត្រប្រាកដដូចគ្នានឹងសីហបញ្ជរកែវ ដែលផ្សាយចេញហើយ ក្នុងវិមានមាស ។*

បទថា **បឍុមំ** *ក្នុងបទថា* **គោបឍុមោ** *នេះ លោកបំណងយកកែវភ្នែកទាំងមូល ។ គ្រាប់ភ្នែករបស់កូនគោខ្មៅ ជាធាតុក្រាស់ របស់កូនគោក្រហមថ្លាផូរផង់ អធិប្បាយថា ព្រះរាជកុមារមានកែវភ្នែកដូចនឹងកូនគោក្រហម ដែលទើបនឹងកើតបានមួយស្រេបក់ ។ ពិតហើយ គ្រាប់ភ្នែករបស់មនុស្សពួកដទៃមិនបរិសុទ្ធ ប្រកបដោយភ្នែកលៀនចេញមកខ្លះ លិបចូលទៅខ្លះ ដូចគ្នានឹងភ្នែកសត្វ មានដំរី និងកណ្តុរជាដើម ។ តែព្រះនេត្ររបស់ព្រះមហាបុរសសន្សំទុកដោយសេចក្តីស្រេទន់ស្និទ្ធខ្មៅល្អិត ដូចកែវមណីមូល ដែលគេខាត់*

ហើយតម្ពល់ទុក ។

បទថា **ឧណ្ណា** គឺព្រះឧណ្ណាលោម ។ បទថា **ភមុកន្តរេ** សេចក្តីថា ព្រះឧណ្ណាលោម កើតក្នុងទីបំផុតព្រះនាសិក កណ្តាលចិញ្ចើមទាំងពីរ និងឡើងទៅកើតត្រង់កណ្តាលព្រះនលាដ ។ បទថា **ឧជាតា** សេចក្តីថា បរិសុទ្ធ គឺមានពណ៌ស្មើដោយផ្ការយព្រឹក្ស ។ បទថា **មុឧុ** សេចក្តីថា ព្រះឧណ្ណាលោម ដូចនឹងសរសៃកប្បាសដែលថ្ពេចបាន ១០០ ដង ដែលគេដាក់ចុះទៅក្នុងទឹកដោះថ្លា តាំងទុក ។ បទថា **តូលសន្ថិភា** គឺស្មើដោយសំឡីរកា និងសំឡីគ ។ នេះជាសេចក្តីប្រៀប ព្រោះភាពសរបស់សំឡី ។ កាលចាប់ចុងសរសៃព្រះលោមា ហើយទាញចេញ នឹងបានប្រមាណកន្ទះព្រះពាហា កាលលែងទៅសរសៃព្រះលោមាក៏នឹងមូរជាទក្ខិណាវដ្ត មានចុងខាងលើតាំងនៅ ព្រះឧណ្ណា-លោមនោះ រមែងរុងរឿងទៅដោយសិរី ជាទីចាប់ចិត្តក្រៃលែងណាស់ ដូចពពុះទឹកប្រាក់ តាំងនៅត្រង់កណ្តាលក្តារមាស ដូចខ្សែទឹកដោះហូរចេញអំពីឆ្នាំងមាស និងដូចផ្ការយព្រឹក្សលើផ្ទៃមេឃ ជះសាចដោយពន្លឺអរុណ ។

បទថា **ឧណ្ហីសសីសោ** នេះ លោកពោលអាស្រ័យអំណាចប្រយោជន៍ ២ យ៉ាង គឺព្រះនលាដបរិបូណ៌ និងព្រះសិរសាបរិបូណ៌ អធិប្បាយថា ព្រោះថា ផ្ទៃព្រះមំសៈរបស់ព្រះមហាបុរសនោះ ប៉ាងឡើងតាំងពីសៀតផ្ការាងស្តាំប្រក់ព្រះនលាដទាំងអស់ ពេញបរិបូណ៌ទៅដល់សៀតផ្ការាងឆ្វេង ស្រស់ល្អដូចផែនឧណ្ហីស គ្រឿងប្រដាប់របស់ព្រះរាជា ។ បានញ្ចថា ជនទាំងឡាយឃើញលក្ខណៈនេះរបស់ព្រះមហាបុរស បានធ្វើផ្ទាំងព្រះឧណ្ហីស សម្រាប់ព្រះរាជាទាំងឡាយ ។ នេះជាន័យមួយប្រការ ។ ជនពួកដទៃមានក្បាល មិន

បរិបូណ៌ ។ អ្នកខ្លះមានក្បាលដូចស្វា អ្នកខ្លះមានក្បាលដូចផ្លែឈើ អ្នកខ្លះមានក្បាលដូចដីរ អ្នកខ្លះមានក្បាលដូចឆ្នាំង អ្នកខ្លះមានក្បាលដូចញាកភ្នំ ។ តែព្រះមហាបុរសមានព្រះសិរសាដូចនឹងពពុះទឹក បរិបូណ៌ល្អ ដូចដេរដោយចុងម្ជុលតម្កល់ទុក ។ ក្នុងពីរនយ័នោះ ក្នុងនយ័ដំបូង ព្រះរាជកុមារមានព្រះសិរសា ដូចព្រះសិរសាប្រជាប់ដោយក្បាំងមុខ ព្រោះហេតុនោះ ទើបព្រះរាជកុមារ ឈ្មោះថា មានព្រះសិរសាដូចប្រជាប់ដោយក្បាំងមុខ ។ ក្នុងនយ័ទីពីរ ព្រះរាជកុមារមានព្រះសិរសាជាបរិមណ្ឌលក្នុងទីទាំងពួង ដូចឧណ្ហីស ព្រោះហេតុនោះ ទើបឈ្មោះថា មានព្រះសិរសាជាបរិមណ្ឌល ដូចឧណ្ហីស ។

[๓๑] *បទថា* **សព្វកាមេហិ** *នេះ លោកពោលថា ព្រះរាជាពន្ធុម:ឲ្យពួកព្រាហ្មណ៍មើលលក្ខណ:ហើយ លៀងភោជនក្នុងកាលជាក្រោយ ។ តែមិនគួរឃើញយ៉ាងនោះ ។ គប្បីជ្រាបថា ព្រះរាជាពន្ធុម:ទំនុកបម្រុងលៀងភោជនពួកព្រាហ្មណ៍ ហោរ ជរាបផ្អែតស្កប់ស្កល់ជាមុនហើយ ទើបឲ្យពិនិត្យមើលលក្ខណ:ជាខាងក្រោយ ។ សេចក្តីពិស្តារបស់រឿងនោះ លោកពោលទុកហើយក្នុងការឈានចុះកាន់ព្រះគភ៌ ។ បទថា* **ទាយេន្តិ** *គឺឲ្យបៅដោះ ។ បានឮថា ព្រះរាជាពន្ធុម: បញ្ជាឲ្យមេដោះ ៦០ នាក់ ផ្សំទឹកដោះមានរសផ្អែមប្រាសចាកទោសទំនុកបម្រុងព្រះពោធិសត្វ ។ សូម្បីមេដោះដ៏សេស សុទ្ធជាអ្នកឈ្វាសក្នុងការងារនោះៗ មួយផ្នែកៗ ៦០ ដូចគ្នា ។ បញ្ជាឲ្យប្រុសៗ ៦០ នាក់ ធ្វើនាទីបម្រើមេដោះទាំងនោះ ។ បញ្ជាឲ្យតាំងអមាត្យ ៦០ នាក់ ចាំមើលការធ្វើ និងមិនធ្វើរបស់ប្រុសៗ នោះ ។ ដោយប្រការដូច្នេះ មានឧបដ្ឋាក ๓๖๐ នាក់ គឺពួកស្ត្រី ๒๔๐ នាក់ ពួកប្រុសៗ ๑๒๐ នាក់ ។ បទថា* **សេតច្ឆត្តំ**

គឺធត្រទិព្វពណ៌ស ។ ធត្រទិព្វពណ៌ស ជារបស់ដែលត្រកូលឲ្យតាំងនៅក្នុងបន្ទប់សិរីនោះឯង ។ គប្បីជ្រាបសេចក្តីថា កុំគ្របសង្កត់ឡើយ ក្នុងបទជាដើមថា **មា ឆំ សីតំ វា** ជូច្នេះ ។

បទថា **ស្វាស្សុសុធំ** កាត់បទជា **សោ អស្សុ សុធំ** ។ បទថា **អផ្ពេឆេវ អផ្ពំ** សេចក្តីថា ព្រះរាជកុមារនោះ ដែលបុគ្គលផ្ទាស់ប្តូរគ្នាព ផ្ទាស់ប្តូរគ្នាបីត្រកង ។ បទថា **បរិហរិយតិ** សេចក្តីថា នាំទៅ គឺពទៅ ។

បទថា **មញ្ជុស្សរោ** គឺព្រះរាជកុមារមានព្រះសូរសៀងមិនគ្រលរ ។ បទថា **វគ្គុស្សរោ** គឺព្រះរាជកុមារមានព្រះសូរសៀងពេញទៅដោយកាពឈ្ជាស ។ បទថា **មធុរស្សរោ** គឺព្រះរាជកុមារមានព្រះសូរសៀងគួរពេញចិត្ត ។ បទថា **បេមនីយស្សរោ** គឺព្រះរាជកុមារ មានព្រះសូរសៀង ធ្វើឲ្យកើតសេចក្តីស្រឡាញ់ ។ សេចក្តីនេះ ជាអធិប្បាយក្នុងបទនោះ ព្រោះសត្វករវិកមានសំឡេងពីរោះ បានព្ចមកថា កាលសត្វករវិកចឹកស្វាយទុំ មានរសឆ្ងាញ់ដោយចំពុះ ហើយផឹករសដែលហូរចេញមក ទទះស្ទាបស្រែក បណ្តាសត្វជើង ៤ ផ្តើមឈានទៅមុខទ្រេតទ្រោតដូចស្រវឹង ។ បណ្តាសត្វជើង ៤ កំពុងស៊ីអាហារ ក៏ចោលស្មៅដែលចូលទៅក្នុងមាត់ ដើម្បីស្តាប់សំឡេងនោះ ។ បណ្តាម្រឹគកាចដែលកំពុងដេញតាមពួកម្រឹគតូចៗ ក៏ដាក់ជើងដែលលើកឡើង ឈរស្ងៀម ។ បណ្តាម្រឹគដែលត្រូវដេញតាម ក៏លះសេចក្តីភ័យខ្ជាចស្ទាប់ ឈរស្ងៀម ។ បណ្តាសត្វកំពុងហើរ នៅលើអាកាសក៏សំកាំងស្ទាបឈប់ស្តាប់សំឡេង ។ បណ្តាត្រីក្នុងទឹក ក៏កម្រើកព្រុយឈប់ស្តាប់សំឡេងនោះ។ សត្វករវិកមានសំឡេងពីរោះយ៉ាងនេះ ។

ព្រះនាងអសន្ធិមិត្តា ព្រះទេវីរបស់ព្រះបាទធម្មាសោករាជ ក៏បានត្រាស់សួរព្រះសង្ឃថា បពិត្រលោកម្ចាស់ សំឡេងរបស់បុគ្គលណា ដូចគ្នានឹងសំឡេងរបស់ព្រះសម្ពុទ្ធ មានដែរឬហ្ន៎ ។ ព្រះសង្ឃថ្វាយព្រះពរថា ថ្វាយព្រះពរ មាន គឺសំឡេងរបស់សត្វកវិក ។ ព្រះនាងសួរថា លោកម្ចាស់ សត្វទាំងនោះនៅទីណា ព្រះសង្ឃថ្វាយព្រះពរថា នៅក្នុងព្រៃហិមពន្ត ព្រះទេវីទូលព្រះរាជាថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់ ចង់ឃើញសត្វកវិក ។ ព្រះរាជាទ្រង់អធិដ្ឋានថា សត្វកវិកចូរមកទុំក្នុងទ្រុងនេះ ហើយលែងទ្រុងមាសទៅ ។ ទ្រុងមាសបានទៅតាំងនៅខាងមុខសត្វកវិកមួយ ។ សត្វកវិកនោះគិតថា ទ្រុងមាសមកតាមការត្រាស់បង្គាប់របស់ព្រះរាជា អញមិនអាចជំទាស់បាន ហើយក៏ទុំនៅក្នុងទ្រុងនោះ ។ ទ្រុងមាសបានមកតាំងនៅខាងមុខព្រះកក្ត្រៃរបស់ព្រះរាជា អមាត្យទាំងឡាយមិនអាចឲ្យសត្វកវិកបញ្ចេញសំឡេងបាន ។ លំដាប់នោះ ព្រះរាជាត្រាស់ថា នែអ្នកទាំងឡាយ សត្វកវិកទាំងនេះ បញ្ចេញសំឡេងដូចម្តេច ។ ពួកអមាត្យក្រាបទូលថា បពិត្រសម្មតិទេព សត្វកវិកទាំងនេះ ឃើញពួកញាតិ ទើបបញ្ចេញសំឡេង ។ លំដាប់នោះ ព្រះរាជាត្រាស់ឲ្យយកកញ្ចក់ដាក់ជុំវិញសត្វកវិកនោះ ។ សត្វកវិកនោះ កាលឃើញស្រមោលរបស់ខ្លួន សម្គាល់ថា ញាតិរបស់អញមកហើយ ទើបទន្ទេះស្ងាបស្រែក ដូចផ្ទុំកែវមណី ដោយសំឡេងដ៏ទន់គ្រលួច ។ ពួកមនុស្សក្នុងសកលនគរទ្រេតទ្រោត ដូចអ្នកស្រវឹង ព្រះនាងអសន្ធិមិត្តាត្រិះរិះថា សំឡេងរបស់សត្វតិរច្ឆាននេះ អាចពីរោះយ៉ាងនេះ ព្រះសូរសៀងរបស់ព្រះមានព្រះភាគទ្រង់សម្រេចសិរី គឺព្រះសព្វញ្ញុតញ្ញាណ តើដូចម្តេចទៅហ្ន៎ ញុំាងព្រះបីតិឲ្យ

កើត មិនលះបីតិនោះ បានតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយបរិវារ ៧០០គប្បីជ្រាបថា សំឡេងសត្វករវិកពីរោះយ៉ាងនេះ ។ តែព្រះសូរសៀងរបស់ព្រះវិបស្សីរាជកុមារពីរោះជាងនោះ រាប់រយរាប់ពាន់ដង ។

បទថា **កម្មវិបាកជំ** គឺមិនសម្រេចដោយភាវនា ។ មំសចក្ខុដូចគ្នានឹងចក្ខុរបស់ទេវតាទាំងឡាយ ដោយអំណាចផលរបស់កម្ម សូម្បីល្ងមួយគ្រាប់ដែលធ្វើគ្រឿងសម្គាល់ទុកហើយ ដាក់ចូលទៅក្នុងផ្នាំងល្ង ក៏អាចលើកឡើងឲ្យបាន ដូច្នេះ ។

ក្នុងបទថា **វិបស្សី** នេះ ជាអត្ថរបស់វាចា ។ ឈ្មោះថា **វិបស្សី** ព្រោះឃើញច្បាស់ដោយវៀរចាកការបិទភ្នែក ថ្ងៃក្តី យប់ក្តី ឃើញដោយភ្នែកដែលបើក ។ ក្នុងវារៈទីពីរ ។ ឈ្មោះថា **វិបស្សី** ព្រោះជ្រើសរើសមើល ។ អធិប្បាយថា ពិចារណាមើល ។

បទថា **អត្ថេ បនាយតិ** សេចក្តីថា ដឹង ឃើញ ណែនាំ ឬពិចារណាអត្ថរបស់ក្តី ។ បានឮថា ថ្ងៃមួយ កាលព្រះរាជាប្រថាប់លើសាលាសម្រាប់វិនិច្ឆ័យ ទ្រង់ពិចារណាក្តី មេដោះនាំព្រះមហាបុរសដែលប្រដាប់តាក់តែងព្រះអង្គហើយ មកដាក់លើព្រះហស្ត កាលព្រះរាជា ទ្រង់ទទួលព្រះរាជកុមារនោះដាក់លើភ្លៅ ហើយទ្រង់ក្រសោបថើប ពួកអ្នកពិចារណាបានកាត់ក្តីអ្នកដែលជាម្ចាស់របស់ មិនឲ្យជាម្ចាស់របស់ ព្រះពោធិសត្វទ្រង់ថ្លែងព្រះសូរសៀងសម្តែងការមិនពេញព្រះទ័យ ។ ព្រះរាជាត្រាស់ថា ពួកអ្នកពិចា-រណាក្តីនេះដូចម្តេច ។ ពួកអមាត្យសម្លឹងមើលមិនឃើញមនុស្សដទៃ ព្រោះខ្លួនវិនិច្ឆ័យក្តីខុស គិតថា អញនឹងកាត់ក្តីយ៉ាងនេះ ។ ពួកចៅក្រមកាត់ក្តីឲ្យ

ម្ចាស់ទ្រព្យជាម្ចាស់ទ្រព្យសាជាថ្មី ហើយពិចារណាមើលថា ព្រះរាជកុមារ ទ្រង់ជ្រាបឬទេហ្ន៎ ទើបទ្រង់ធ្វើយ៉ាងនេះ បានកាត់ក្តីអ្នកជាម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យទៀត។ ព្រះពោធិសត្វ ទ្រង់បញ្ចេញព្រះសូរសៀងយ៉ាងនោះទៀត។ ពេលនោះ ព្រះរាជាទ្រង់ត្រិះរិះថា ព្រះរាជកុមារជាមហាបុរស រមែងដឹងតាំងពីនោះមក ទ្រង់មិនបានប្រមាទឡើយ ។ លោកពោលថា ព្រះកុមារ ទ្រង់ពិចារណាក្តី សំដៅដល់សេចក្តីនេះ ។

ក្នុងបទថា ***វស្សិកំ*** *ជាដើម សេចក្តីថា ស្ថានទីនៅយ៉ាងមានសេចក្តីសុខ ក្នុងរដូវភ្លៀង ឈ្មោះថា វស្សិក ។ ប្រាសាទសម្រាប់ប្រថាប់ក្នុងរដូវភ្លៀង ក្រៅពីនេះក៏មានន័យនេះដូចគ្នា ។ សេចក្តីនេះ ក្នុងបទនេះមានអត្ថជាពាក្យនិយាយ ។ ការនៅក្នុងរដូវភ្លៀងឈ្មោះវស្សៈ អ្នកសមគួរដល់រដូវភ្លៀងនោះឈ្មោះវស្សិកៈ ។ ក្នុងបទក្រៅនេះ ក៏មានន័យនេះឯង ។ ក្នុងប្រាសាទ ៣ ខ្នងនោះ ប្រាសាទដែលប្រថាប់ក្នុងរដូវភ្លៀង មិនខ្ពស់ពេក មិនទាបពេក ។ ទ្វារ និងបង្អួចរបស់ប្រាសាទនោះ ក៏មិនច្រើនពេក មិនតិចពេក ។ មួយទៀត កម្រាលផែនដី កម្រាលរបស់ទំពា និងរបស់បរិភោគក្នុងប្រាសាទនេះរួមគ្នា ។ ក្នុងប្រាសាទសម្រាប់ប្រថាប់ ក្នុងរដូវរងា សសរជញ្ជាំងក៏ទាប ។ ទ្វារ និងបង្អួចតិចមានប្រយោជន៍ជាសប្បាយ ។ ដើម្បីចូលទៅរកការអប់កម្តៅ គួរនាំជញ្ជាំង និងធ្នើរចេញ ក្នុងប្រាសាទនេះកម្រាលផែនដី សំពត់ស្បៀក សំពត់ជណ្តប់ គួរជាសំពត់កម្ពលជាដើម ជួយឲ្យកើតការអប់កម្តៅ ។ របស់ទំពា និងរបស់បរិភោគធ្ងាញ់ និងឈ្ងាយរសហើរ ។ ក្នុងប្រាសាទសម្រាប់ប្រថាប់ ក្នុងរដូវក្តៅ សសរ និងជញ្ជាំងខ្ពស់ ។ ក្នុងប្រាសាទនេះ ទ្វារ និងបង្អួច មានក្រឡា*

សំណាញ់ច្រើន ។ កម្រាលផែនដីជាដើម គួរសម្រេចដោយសំពត់ពីរជាន់ ។ របស់ទំពា និងរបស់បរិភោគ គួរជារបស់ត្រជាក់មានរសឆ្ងាញ់ ។ មួយទៀត ក្នុងប្រាសាទនេះ ជនទាំងឡាយតម្កល់ពាងថ្មីក្នុងទីជិតបង្អួច ដាក់ទឹកដរាបពេញ ហើយដាំឈូកខៀវជាដើម ។ ខ្សែទឹកហូរដូចភ្ជៀងធ្លាក់ តាមផ្ទៃទីដែលជនទាំងឡាយធ្វើទទឹក ។ បទថា **និប្បុរិសេហិ** គឺមិនមានប្រុស អធិប្បាយថាប្រាសាទនេះ មិនមែនអ្នកតន្ត្រីតែម្យ៉ាងប៉ុណ្ណោះទេដែលមិនមានប្រុស ស្ថានទីទាំងអស់ ក៏មិនមានមនុស្សប្រុសដូចគ្នា ។ អ្នកយាមទ្វារ ក៏ជាស្រី ។ អ្នកធ្វើការរក្សា មានងូតទឹកជាដើម ក៏ជាស្រីទាំងអស់ ។ បានញ្ចថា ព្រះរាជាទ្រង់ត្រិះរិះថា សេចក្តីរង្កៀសនឹងបុរស ព្រោះឃើញបុរស រមែងកើតឡើងដល់អ្នកសោយឥស្សរិយសម្បត្តិ និងសុខសម្បត្តិបែបនោះ សេចក្តីរង្កៀសនឹងបុរសនោះ កុំគប្បីមានដល់បុត្ររបស់យើងឡើយ ដូច្នេះ ទើបទ្រង់តាំងមនុស្សស្រីប៉ុណ្ណោះក្នុងកិច្ចទាំងអស់ ។

ភាណវារធី ៧ ចប់

អធិប្បាយ អំពីធេវធូត

[៣២-៣៥] គប្បីជ្រាបក្នុងភាណវារៈទីពីរដូច្នេះ បទថា **គោចានសិវដ្ឋំ** គឺមានឆ្អឹងជំនីកោងដូចបង្កង់ ។ បទថា **ភត្តំ** សេចក្តីថា មានខ្នងកោងក្នុងទីទាំង ៣ គឺត្រង់ក ចង្កេះ និងជង្គង់ទាំង ២ ។ បទថា **ធណ្ឌបរាយនំ** គឺទៅដោយឈើច្រត់ មានឈើច្រត់ជាទីពឹង ។ បទថា **អាតុរំ** គឺរសាប់រសល់ព្រោះជរា ។ បទថា **គតយោព្វនំ** គឺកន្ធងវ័យកំលោះ តាំងនៅក្នុងបច្ឆិមវ័យ ។

បទថា **ឥស្សា** *សេចក្តីថា ព្រះរាជកុមារហែហមដោយពួកពលប្រមាណកន្លះយោជន៍ បានធ្វើការរក្សាយ៉ាងល្អ ទ្រង់ទតឃើញបុរសនោះ ដែលព្រហ្មជាន់សុទ្ធាវាស និងព្រហ្មជាខីណាស្រព សម្តែងប្រាកដខាងមុខរថ ដោយអានុភាពរបស់ព្រះអង្គ ក្នុងឱកាសដែលរថនៅខាងមុខ ពួកពលនៅខាងក្រោយ ។ បានឮថា មហាព្រហ្មជាន់សុទ្ធាវាសត្រិះរិះថា ព្រះមហាបុរស ទ្រង់ជាប់ក្នុងកាមគុណទាំង ៥ ដូចជីវជាប់កក់ អញនឹងញុំាងសតិឲ្យកើតដល់មហាបុរសនោះ ដូច្នេះ ទើបកាឡាខ្លួនជាបុរសនោះ ។ ម្យ៉ាងទៀត ព្រះពោធិសត្វក្តីសារថីក្តី ក៏ទតឃើញ ឃើញបុរសដែលមហាព្រហ្មនិម្មិតហើយយ៉ាងនេះ ។ ពិតហើយ សូម្បីព្រហ្មទាំងឡាយបានសម្តែងបុរសនោះ ក៏ដើម្បីការមិនប្រមាទរបស់ព្រះពោធិសត្វ និងដើម្បីការសន្ទនារបស់សារថី ។ ព្រះរាជកុមារត្រាស់សួរថា បុគ្គលនេះជាអ្វី ។ សារថីទូលថា បពិត្រព្រះអង្គ បុគ្គលនេះជាមនុស្សចាស់ ។ សួរថា សេចក្តីនេះ លោកពោលដូចម្តេច ឆ្លើយថា ព្រះរាជកុមារត្រាស់សួរថា នែ៎សារថី ខ្ញុំមិនធ្លាប់ឃើញបុរសបែបនេះមកអំពីមុនឡើយ ។ បទថា* **តេនហិ** *សេចក្តីថា បើដូច្នោះ សូម្បីយើងក៏នឹងគប្បីមានសក់បែបនេះ មានកាយបែបនេះ ។ ពាក្យថា បើដូច្នោះ ការទៅឧទ្យានក្នុងថ្ងៃនេះ ល្មមប៉ុណ្ណឹងហើយ សេចក្តីថា ព្រះរាជកុមារត្រាស់ថា ថ្ងៃនេះ យើងល្មមហើយសម្រាប់ការក្រសាលឧទ្យាន យើងត្រឡប់ទៅវិញចុះ ដូច្នេះ ទ្រង់ស្ងុតព្រះហឫទ័យ ត្រាស់អនុរូបដល់សេចក្តីសង្វេគ ។*

បទថា **អន្តេបុរំ គតោ** *សេចក្តីថា ព្រះរាជកុមារទ្រង់លះបង់ស្ត្រី គង់តែមួយព្រះអង្គឯងក្នុងបន្ទប់ដ៏មានសិរី ។ បទថា* **យត្រ ហិ នាម** *សេចក្តីថា*

កាលមានជាតិ ជរាវមែងប្រាកដ ចូរតិះដៀលស្អប់ខ្ពើមជាតិ ជាតិ ឈ្មោះថា ជាវត្ថុគួរខ្ពើម ព្រោះហេតុនោះ ព្រះរាជកុមារគង់ជីកឫសគល់របស់ជាតិ ដូចត្រូវកូនសរដំបូងចាក់ព្រះហឫទ័យ ដូច្នោះ ។

បទថា **សារថឹ អាមន្តាបេត្វា** *សេចក្តីថា បានឮថា ព្រះរាជាតាំងពីពួកព្រាហ្មណ៍អ្នកព្យាករក្រាបទូល ទ្រង់ផ្ទៀងព្រះសោតស្តាប់សព្វកាល ។ ព្រះរាជាទ្រង់បានឮថា ព្រះរាជកុមារនោះ ប្រពាតព្រះឧទ្យាន ត្រឡប់ក្នុងចន្លោះផ្លូវ ទើបទ្រង់ឲ្យហៅសារថីមក ។ ក្នុងបទថា* **មា ហោវ ភោ** *ជាដើម សេចក្តីថា ព្រះរាជាទ្រង់ត្រិះរិះយ៉ាងនេះថា ឱរសរបស់អញ ចូរគ្រងរាជសម្បត្តិ ចូរកុំបួស ពាក្យរបស់ពួកព្រាហ្មណ៍ ចូរកុំពិត ដូច្នេះ ។*

បទថា **អទ្ទសា ភោ** *សេចក្តីថា ព្រះរាជកុមារបានទតឃើញបុរសដែលសុទ្ធាវាសមហាព្រហ្មនិម្មិត ដោយនយដែលពោលហើយក្នុងខាងដើមនោះឯង ។ បទថា* **អាពាធិកំ** *សេចក្តីថា មានការឈឺចាប់ដោយអាពាធផ្សេងៗ ដែលទម្លាយឥរិយាបថ ។ បទថា* **ទុក្ខិតំ** *គឺជល់ទុក្ខ ដោយទុក្ខគឺរោគ ។ បទថា* **ពាឡ្ហគិលានំ** *គឺឈឺធ្ងន់ ។ បទថា* **បលិបន្នំ** *គឺលិចចុះ ។ ក្នុងបទនេះថា* **ជរា បញ្ញាយិស្សតិ ព្យាធិ បញ្ញាយិស្សតិ** *សេចក្តីថា កាលមានជាតិ ជរាព្យាធិទាំងពីរនេះ រមែងប្រាកដ ជាតិគួរខ្ពើម មិនមានជាតិនឹងត្រចះត្រចង់ ព្រោះហេតុនោះ ព្រះរាជកុមារប្រថាប់អង្គុយជីកឫសគល់របស់ជាតិ ដូចត្រូវកូនសរទីពីរមុត ។*

[๓๖-๓๗] បទថា **វិលាតំ** *គឺគ្រឿងស្នែង ។ បទថា* **បេតំ** *គឺលះបង់ទៅអំពីលោកនេះ ។ បទថា* **កាលកតំ** *គឺស្លាប់ អធិប្បាយថា ដែលមនុស្ស*

យើងធ្វើវត្ថុទាំងពួង រហូតអស់កាលដែលរស់នៅ រួចហើយក៏ស្លាប់ ។ ព្រហ្ម
ទាំងឡាយនិម្មិតរឿងនេះដល់ព្រះរាជកុមារ ដោយន័យមុនន៉ុះឯង ។ ក្នុងបទ
ថា **យត្រ ហិ នាម** នេះ ក៏មានអធិប្បាយថា កាលបើជាតិមាន ជរា ព្យាធិ
មរណៈទាំង ៣ នេះ រមែងប្រាកដ ជាតិជារបស់គួរខ្ពើម កាលជាតិមិនមាន
ក៏រួចផុត ព្រោះហេតុនោះ ព្រះរាជកុមារប្រថាប់អង្គុយជីកឬសគល់របស់ជាតិ
ដូចត្រូវកូនសរទី ៣ មុត ។

[៣៨] បទថា **ភណ្ឌុំ** គឺត្រងោល ។ ព្រហ្មទាំងឡាយនិម្មិត រឿងនេះ
ដល់ព្រះរាជកុមារ ដោយន័យមុននោះឯង ។

ក្នុងបទថា **សាធុ ធម្មចរិយា** ជាដើម សេចក្តីថា សារថីទូលព្រះរាជ-
កុមារថា បពិត្រទេវៈ ភាពជាអ្នកប្រព្រឹត្តធម៌នេះ ជាសេចក្តីល្អ ដូច្នេះ គប្បី
ជ្រាបការប្រកបបទនីមួយៗ យ៉ាងនេះថា **បញ្ចណិតោ** ដូច្នេះ ។ ម្យ៉ាងទៀត
បទទាំងអស់នេះជាវេវចនៈរបស់កុសលកម្មបថ ១០ នោះឯង ។ ក្នុងទីបំផុត
បទថា **អវិហឹសា** ជាបុព្វភាគរបស់ករុណា ។ បទថា **អនុកម្បា** ជាបុព្វភាគ
របស់មេត្តា ។ បទថា **តេនហិ** ជានិបាត ចុះក្នុងអត្ថថា បញ្ជូនត្រឡប់ ព្រោះ
ព្រះរាជកុមារទតឃើញបព្វជិតហើយ មានព្រះហឬទ័យបង្អោនទៅក្នុងបព្វជ្ជា ។
លំដាប់នោះ ព្រះកុមារមានព្រះបំណងដើម្បីត្រាស់នឹងសារថីនោះ កាលនឹង
ទ្រង់បញ្ជូនសារថីឲ្យត្រឡប់ ទើបត្រាស់ពាក្យជាដើមថា **តេនហិ** ដូច្នេះ ។

បទថា **អថខោ ភិក្ខវេ** សេចក្តីថា ព្រះរាជកុមារទ្រង់ស្តាប់ពាក្យជាដើម
ថា ការប្រព្រឹត្តធម៌ជាសេចក្តីល្អរបស់បព្វជិត និងពាក្យដទៃច្រើនទៀត ដែល
ជាធម្មកថាប្រកបដោយទោសរបស់អ្នកនៅគ្រប់គ្រងផ្ទះ ដែលចង្អៀតចង្អល់

ដោយបុត្រ និងភរិយា ដែលពួកមហាជនរក្សាហើយ និងប្រកបដោយអានិសង្សនៃវិវេក របស់បព្វជិតដែលនៅក្នុងព្រៃតាមសប្បាយ មានចិត្តដូចជាម្រឹគហើយ មានព្រះបំណងនឹងបព្វជ្ជា ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ទើបវិបស្សីកុមារ បានហៅសារថីមក ។ ឈ្មោះថា ការឃើញទេវទូតទាំង ៤ នេះ ហើយបួស ជាវង្ស ជាបែបផែន ជាប្រពៃណីរបស់ព្រះពោធិសត្វគ្រប់ព្រះអង្គ ។ ម្យ៉ាងទៀត ព្រះពោធិសត្វអង្គដទៃ ក៏រមែងឃើញអស់កាលយូរ ដូចព្រះវិបស្សីកុមារ អង្គនេះទ្រង់ឃើញហើយអស់កាលយូរ ។ តែព្រះពោធិ-សត្វនៃយើង ទ្រង់ឃើញទេវទូតទាំង ៤ ក្នុងថ្ងៃតែមួយប៉ុណ្ណោះ ក៏ស្តេចចេញមហាភិនេស្ក្រមណ៍ ទ្រង់បព្វជ្ជាត្រង់ច្រាំងស្ទឹងអនោមា បន្ទាប់ពីនោះ ស្តេចយាងដល់ក្រុងរាជគ្រឹះ ក្នុងទីនោះ ព្រះរាជាពិម្ពិសារទូលសួរថា លោកបណ្ឌិត លោកបួសដើម្បីអ្វី ទ្រង់ត្រាស់ថា

> *បពិត្រមហារាជ អាត្មាឃើញមនុស្សចាស់ មនុស្សឈឺ ដល់នូវសេចក្តីទុក្ខ និងឃើញមនុស្សស្លាប់ ព្រោះអស់អាយុ និងបានឃើញអ្នកបួសស្បែកដណ្តប់សំពត់កាសាយៈ ព្រោះហេតុនោះ ទើបអាត្មាបួស ។*

បទថា **សុត្វាន តេសំ** *សេចក្តីថា មហាជន ៨៤០០០ នាក់នោះ បានស្តាប់ហើយមានការត្រិះរិះដូច្នេះ ។ បទថា* **ឱរកោ** *គឺខុសឆ្គង ឬអាក្រក់ ។ បទថា* **អនុបព្វជីសុ** *គឺបួសតាម ។ សួរថា ព្រោះហេតុអ្វី ទើបក្នុងទីនេះលោកមិនពោលដូចដែលលោកពោលខាងដើមថា ព្រះរាជកុមារស្តេចចេញអំពីរាជធានីពន្ធុមតី ព្រមដោយខណ្ឌៈ និងតិស្សៈចេញបួសតាម ឆ្លើយថា ព្រោះ*

ចេញទៅហើយ ទើបបានស្តាប់ ។ បានឮថា មហាជនទាំងអស់នេះ ជាបុរសឧបដ្ឋាករបស់ព្រះវិបស្សីកុមារ ។ មហាជនទាំងនោះមកឧបដ្ឋាក តាំងអំពីព្រឹកព្រលឹម កាលមិនឃើញព្រះរាជកុមារ ទើបនាំគ្នាបរិភោគអាហារព្រឹក លុះបរិភោគអាហារព្រឹកស្រេចហើយ ទើបមកសួរថា ព្រះរាជកុមារទៅណា លុះស្តាប់ថា ព្រះរាជកុមារស្តេចទៅព្រះឧទ្យាន ទើបនាំគ្នាចេញទៅ ដោយគិតថា ពួកយើងនឹងគាល់ព្រះរាជកុមារក្នុងព្រះឧទ្យាននោះ លុះឃើញសារថីត្រឡប់បានស្តាប់ពាក្យរបស់សារថីនោះថា ព្រះរាជកុមារទ្រង់បព្វជ្ជាហើយ ទើបដោះអាភរណៈគ្រប់យ៉ាងទុកក្នុងទីដែលបានស្តាប់ហើយនុ៎ះឯង ឲ្យមនុស្សនាំសំពត់កាសាយៈពណ៌លឿងអំពីផ្សារមកហើយ កោរសក់ និងពុកមាត់ ហើយបួសដោយហេតុដូច្នេះ ទើបក្នុងទីនេះមិនពោលថា ចេញអំពីរាជធានីពន្ធុមតី ព្រោះចេញអំពីនគរហើយ ទើបបានស្តាប់ខាងក្រៅនគរ ។

បទថា **ចារិកំ ចរតិ** *សេចក្តីថា ព្រះវិបស្សីពោធិសត្វសាងមណ្ឌបធំក្នុងទីដែលទៅហើយ ត្រៀមទានមកទទួលនិមន្តន៍ក្នុងថ្ងៃស្អែក ទទួលភិក្ខាដែលមហាជនអារាធនា ត្រាច់ចារិកទៅរហូតអស់ ៤ ខែ ។ បទថា* **អាកិណ្ណោ** *គឺត្រូវបៀហមដោយគណៈនេះ ។ សួរថា វិតក្កនេះ កើតឡើងដល់ព្រះពោធិ-សត្វក្នុងកាលណា ឆ្លើយថា ក្នុងថ្ងៃ ១៤ កើត ព្រោះថ្ងៃស្អែកនេះ ជាថ្ងៃពេញបូណ៌មី ខែពិសាខ ។ បានឮថា កាលនោះព្រះពោធិសត្វ ទ្រង់ត្រិះរិះថា ជនទាំងនេះ ក្នុងកាលមុន បៀហមអញ ដែលជាគ្រហស្តត្រាច់ទៅ យ៉ាងណា ឥឡូវនេះ ក៏យ៉ាងនោះទៀត ប្រយោជន៍អ្វីដោយគណៈនេះ ទ្រង់រង្គៀសដោយការច្របូកច្របល់ នៅលាយឡំនឹងគណៈ ទ្រង់ត្រិះរិះថា អញនឹងទៅក្នុងថ្ងៃនេះ*

ឯង ហើយទ្រង់ត្រែះរិះទៀតថា ថ្ងៃនេះមិនទាន់ដល់វេលា បើអញនឹងទៅឥឡូវនេះ ជនទាំងនេះក៏នឹងដឹង អញនឹងទៅក្នុងថ្ងៃស្អែក ។ ម្យ៉ាងទៀត ក្នុងថ្ងៃនោះ អ្នកស្រុកក្នុងស្រុក ដូចជាអ្នកស្រុកឧរុវេលា បាននិមន្តព្រះពោធិសត្វដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ អ្នកស្រុកទាំងនោះ ត្រៀមបាយាសសម្រាប់បព្វជិត ៨៤០០០ រូប និងសម្រាប់មហាបុរស ។ ខណៈនោះ មហាបុរសបានឆាន់អាហារជាមួយបព្វជិតទាំងនោះក្នុងស្រុកនោះ ស្អែកឡើង ទើបទៅកាន់លំនៅ ។ ទីនោះ ពួកបព្វជិតបានប្រណិបត្តន៍មហាបុរសម្រេចហើយ ក៏ចូលទៅកាន់ទីសម្រាកពេលយប់ និងពេលថ្ងៃរៀងៗ ខ្លួន ។ ព្រះពោធិសត្វ ក៏ចូលទៅប្រថាប់ក្នុងបណ្ណសាលា ទ្រង់ពិចារណាថា

កាលបើដល់វេលាថ្ងៃត្រង់ បក្សីទាំងឡាយនឹងមកប្រជុំគ្នា ព្រៃធំនឹងមានសំឡេងគឹកកង កំយានោះ នឹងប្រាកដដល់អាត្មាអញ ។

ក្នុងកាលមានភ័យដល់អ្នកត្រេកអរក្នុងសេចក្តីស្ងាត់ ក្នុងកាលមានសេចក្តីរីករាយដល់សត្វទាំងពួងបែបនេះ ព្រះពោធិសត្វទ្រង់ត្រែះរិះថា នេះដល់វេលាហើយ ទើបទ្រង់បិទទ្វារបណ្ណសាលា បែរព្រះកគ្រៃទៅកាន់ពោធិមណ្ឌល ។ ក្នុងកាលដទៃ ព្រះពោធិសត្វគ្រាច់ទៅក្នុងទីនោះ ទ្រង់ឃើញពោធិមណ្ឌល ។ តែព្រះហឫទ័យព្រះពោធិសត្វនោះ មិនធ្លាប់បង្អោនទៅដើម្បីប្រថាប់គង់ឡើយ ។ តែថ្ងៃនោះ ព្រះញាណរបស់ព្រះពោធិសត្វចាស់ក្លា ព្រោះដូច្នោះ កើតចិត្តដើម្បីទតពោធិមណ្ឌល ដែលតាក់តែងហើយស្តេចឡើងទៅ ។ ព្រះពោធិសត្វនោះ ស្តេចចូលទៅដោយចំណែកទិសខាងត្បូង ទ្រង់ប្រទក្ខិណ ក្រាលបល្ល័ង្ក ទំហំ ១៤ ហត្ថ ក្នុងទិសខាងកើត ទ្រង់អធិដ្ឋានសេចក្តីព្យាយាមប្រកបដោយអង្គ ៤

ទ្រង់ប្រថាប់គង់ តាំងប្តេជ្ញាថា អាត្មាអញមិនក្រោកអំពីទីនេះ ដរាបណាដែលតួអញមិនបានត្រាស់ជាព្រះពុទ្ធ ។ លោកពោលបទនេះថា ព្រះពោធិសត្វតែមួយព្រះអង្គ ចៀសចេញចាកគណៈ សំដៅដល់ការចៀសចេញចាកនៃព្រះពោធិសត្វអង្គនេះ ។ បទថា **អញ្ញេនេវ តានិ** សេចក្តីថា បានឮថា បព្វជិតពួកនោះ មកឧបដ្ឋាកព្រះពោធិសត្វពេលល្ងាច ហើយអង្គុយជុំវិញបណ្ណសាលា ពោលថា ហួសវេលាច្រើនទៅហើយ ពួកលោកគប្បីចូលទៅសង្កេតការណ៍ កាលបើកទ្វារបណ្ណសាលា មិនឃើញព្រះពោធិសត្វនោះ ក៏មិនបានតាមរកឲ្យដឹងថា ព្រះពោធិសត្វយាងទៅណា ។ ពួកបព្វជិតគិតថា មហាបុរស ទ្រង់នឿយណាយក្នុងការនៅរួមជាមួយគណៈ ប្រហែលជាមានបំណងប្រថាប់នៅតែមួយព្រះអង្គឯង ពួកយើងនឹងឃើញព្រះពោធិសត្វ ពេលបានជាព្រះពុទ្ធហើយនោះឯង ហើយនាំគ្នាត្រឡប់ទៅខាងក្នុងជម្ពូទីប ចៀសចេញទៅកាន់ចារិក ។

បទថា **វាសូបគតស្ស** សេចក្តីថា ចូលទៅនៅមួយរាត្រីក្នុងពោធិមណ្ឌល ។ បទថា **រហោគតស្ស** គឺទៅក្នុងទីកំបាំង ។ បទថា **បដិសល្លីនស្ស** គឺពួនសម្ងំ ដោយអំណាចនៃភាពជាបុគ្គលម្នាក់ឯង ។ បទថា **កិច្ឆំ** គឺលំបាក ។ ពីរបទនេះ គឺ **ចរតិ ច ឧបរដ្ឋតិ ច** លោកពោលសំដៅដល់ចុតិ និងបដិសន្ធិតៗ ទៅ ។ ក្នុងបទថា **ជរាមរណស្ស** នេះ សេចក្តីថា ព្រោះព្រះពោធិសត្វកាលទ្រង់ព្រះផ្នួស ទតឃើញមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់នុ៎ះឯង ទើបទ្រង់ព្រះផ្នួស ដូច្នោះ ជរា និងមរណៈនុ៎ះឯង រមែងប្រាកដដល់ព្រះពោធិសត្វនោះ ដោយហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា **ជរា-**

មរណាស្ស ដូច្នេះ ។

[៣៩] ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សី ពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះ ទ្រង់ធ្វើជរា និងមរណៈ ឲ្យជាមូល តាំងមាំ ចំពោះហើយ ដូចធ្លាក់ចុះអំពីភវគ្គព្រហ្ម ។ បទថា **យោនិសោមនសិការា** សេចក្តីថា ធ្វើទុកក្នុងចិត្តដោយឧបាយ គឺធ្វើទុកក្នុងចិត្ត ។ អធិប្បាយថា ពិតហើយ កាលធ្វើទុកក្នុងចិត្តនូវលក្ខណៈ មានការមិនទៀងជាដើម ដោយលក្ខណៈ មានការមិនទៀងជាដើម ឈ្មោះថា អ្នកធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ។ មួយទៀត យោនិសោមនសិការនេះ ជាចំណែកណាមួយរបស់បណ្តាអភិសម័យទាំងនោះ ព្រោះការប្រព្រឹត្តទៅ ដោយអំណាចនៃប្រាជ្ញាពិចារណាឃើញទាំងការកើត ទាំងការរលត់ថា កាលអ្វីមានហ្ន៎ ជាតិជាដើម រមែងមាន កាលអ្វីមិនមាន ជាតិជាដើមរមែងមិនមាន ដូច្នេះ ព្រោះដូច្នោះ ការត្រាស់ដឹងដោយបញ្ញា បានប្រាកដដល់ព្រះពោធិសត្វនោះ ព្រោះធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃអំពីនេះ គឺដោយការធ្វើទុកក្នុងចិត្តដោយឧបាយនេះ ដូច្នោះ កាលវត្ថុណាមាន ជរា មរណៈ រមែងមាន ការរួមគ្នាចូលជាមួយនឹងហេតុ គឺជរា និងមរណៈនោះ បានប្រាកដដល់ព្រះបញ្ញារបស់ព្រះពោធិ-សត្វ ។ សួរថា ជរា និងមរណៈនោះមាន ព្រោះអ្វី ឆ្លើយថា ព្រោះជាតិ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា កាលជាតិមាន ទើបជរាមរណៈមាន ការរួមគ្នាចូលនឹងបញ្ញា កំណត់ហេតុនៃជរា និងមរណៈ បានប្រាកដដល់ព្រះពោធិសត្វ នេះជាអធិប្បាយក្នុងសេចក្តីនេះ ។ គប្បីជ្រាបបទទាំងអស់ដោយទំនងនេះ ។ ក្នុងបទថា កាលនាមរូបកើតមាន ទើបវិញ្ញាណកើតមាននេះ

សេចក្តីថា គួរនឹងពោលថា កាលសង្ខារមាន ទើបវិញ្ញាណមាន និងកាលអវិជ្ជាមាន ទើបសង្ខារមាន សូម្បីទាំងពីរនោះ កាន់យកមិនបាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអវិជ្ជា និងសង្ខារជាអតីតភព ។ វិបស្សនានេះ មិនចំពោះតែអវិជ្ជា និងសង្ខារទាំងនោះ ។ ពិតហើយ ព្រះមហាបុរស ទ្រង់តាំងមាំហើយដោយអំណាចនៃបច្ចុប្បន្ន ។ ដែលអ្នកមិនឃើញអវិជ្ជា និងសង្ខារមិនអាចជាព្រះពុទ្ធបាន មិនមែនឬ ។ ពិតជាមិនអាចបាន តែធម៌ទាំងនោះ ដែលមហាបុរសនេះឃើញហើយ ដោយអំណាចនៃកព ឧបាទាន និងតណ្ហា ។ ក្នុងទីនេះ គួរពោលដល់បដិច្ចសមុប្បាទដោយពិស្តារ ។

បដិច្ចសមុប្បាទនោះ លោកពោលហើយក្នុងវិសុទ្ធិមគ្គ ។

បទថា **បច្ចុទាវត្តតិ** *គឺត្រឡប់ទៅត្រឡប់មក ។ ក្នុងបទនេះ វិញ្ញាណត្រឡប់ទៅត្រឡប់មកដូចម្តេច វិញ្ញាណនោះ បានដល់ បដិសន្ធិវិញ្ញាណខ្លះ វិបស្សនាវិញ្ញាណខ្លះ ក្នុងវិញ្ញាណទាំងពីរនោះ បដិសន្ធិវិញ្ញាណ ត្រឡប់ទៅត្រឡប់មក ព្រោះបច្ច័យ ។ វិបស្សនាវិញ្ញាណ ត្រឡប់ទៅត្រឡប់មក ព្រោះអារម្មណ៍ ។ សូម្បីទាំងពីរ ក៏មិនផុតពីនាមរូប ជនៃចាកនាមរូប ប្រព្រឹត្តទៅមិនបាន ។ ក្នុងបទទាំងឡាយមានជាដើមថា* **ឯត្តាវតា ជាយេថ វា** *សេចក្តីថា លោកសម្តែងបទទាំង ៥ ព្រមដោយចុតិ និងបដិសន្ធិដទៃៗ សេចក្តីថា កាលវិញ្ញាណជាបច្ច័យដល់នាមរូប និងកាលនាមរូបជាបច្ច័យដល់វិញ្ញាណ សូម្បីទាំងពីរ ក៏ជាបច្ច័យដល់គ្នានិងគ្នា ដោយហេតុត្រឹមតែប៉ុណ្ណេះ សត្វលោក គប្បីកើតខ្លះ គប្បីចាស់ខ្លះ គប្បីស្លាប់ខ្លះ គប្បីចុតិខ្លះ គប្បីបដិសន្ធិខ្លះ ក្រៅអំពីនេះ យ៉ាងដទៃ នៅមានទៀតឬ សត្វគប្បីកើតខ្លះ ។បេ។ គប្បីបដិសន្ធិខ្លះ*

នេះប៉ុណ្ណោះមិនមែនឬ សត្វរមែងកើត ฯลฯ និងរមែងបដិសន្ធិ កាលនឹងពន្យល់សេចក្តីដែលលោកពោលពាក្យនោះទៀតថា **ฌตฺวาวตา** *ទើបពោលថា ព្រោះនាមរូបជាបច្ច័យ ទើបមានវិញ្ញាណ ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប តអំពីនោះ ដើម្បីនឹងសម្តែងជាតិ ជរា និងមរណៈតទៅ ដែលមាននាមរូបជាឫសគល់ ព្រោះវិញ្ញាណជាបច្ច័យ ដោយអំណាចបច្ចយាការដោយអនុលោម ទើបពោលពាក្យជាដើមថា ព្រោះនាមរូបជាបច្ច័យ ទើបមានសឡាយតនៈ ។ ក្នុងបទទាំងឡាយនោះ បទថា* **กេวลสฺส ทุกฺขกฺขนฺธสฺส สมุทโย โหติ** *សេចក្តីថា ការកើតឡើងនៃកងទុក្ខទាំងមូល មានប្រកេទជាដើមថា ជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសៈរមែងមាន ។ ព្រះមហាបុរសបានឃើញការកើតនៃវដ្តទុក្ខទាំងអស់ ដោយប្រការដូច្នេះ ។*

បទថា **สมุทโย สมุทโยติ โข** *សេចក្តីថា កើតឡើង កើតឡើងដូច្នេះឯង ។ បទថា* **อนนุสฺสุเตสุ** *សេចក្តីថា មិនបានស្តាប់មកហើយ គឺមិនធ្លាប់ស្តាប់មកហើយ ។*

ក្នុងបទទាំងឡាយថា **จกฺขุ อุทปาทิ** *ជាដើម សេចក្តីថា បញ្ញាឃើញការកើតនេះ លោកពោលថា ជាចក្ខុ ដោយអត្ថថា ឃើញ ជាញាណ ដោយអត្ថថា ធ្វើឲ្យដឹង ជាបញ្ញា ដោយអត្ថថា ដឹងទូទៅ ជាវិជ្ជា ដោយអត្ថថា ចាក់ធ្លុះកើតឡើងហើយ ជាអាលោក ដោយអត្ថថា ភ្លឺស្វាង ដូច្នេះ ។ ដូចលោកពោលហើយថា ចក្ខុកើតឡើងហើយ ដោយអត្ថថា ឃើញ ញាណកើតឡើងហើយ ដោយអត្ថថា ធ្វើឲ្យដឹង បញ្ញាកើតឡើងហើយ ដោយអត្ថថា ដឹងទូទៅ*

វិជ្ជាកើតឡើងហើយ ដោយអត្ថថា ចាក់ផ្ទុះ ពន្លឺកើតឡើងហើយ ដោយអត្ថថា ភ្លឺស្វាង ។ ចក្ខុជាហេតុ ដោយអត្ថថា ឃើញជាផល ញាណជាហេតុ ដោយអត្ថថា ដឹងជាផល បញ្ញាជាហេតុ ដោយអត្ថថា ដឹងទូទៅជាផល វិជ្ជាជាហេតុ ដោយអត្ថថា ចាក់ផ្ទុះជាផល ពន្លឺជាហេតុ ដោយអត្ថថា ភ្លឺស្វាងជាផល ដូច្នេះ ។ លោកពោលដោយបទត្រឹមតែប៉ុណ្ណេះឬ ។ លោកពោលត្រឹមតែឲ្យកំណត់ដឹងបច្ច័យថា កាលវត្ថុនេះមាន វត្ថុនេះរមែងមាន ដូច្នេះ ។ ម្យ៉ាងទៀត លោកសម្តែងដល់តរុណវិបស្សនា ដែលជាផ្ទូវបដិបត្តិ ។

[៤០] បទថា **អធិគតោ ទោ ម្យាយំ** សេចក្តីថា មគ្គនេះ ដែលតថាគតចាក់ផ្ទុះហើយ ។ បទថា **មគ្គោ** គឺវិបស្សនាមគ្គ ។ បទថា **ពោធាយ** សេចក្តីថា ដើម្បីដឹងអរិយសច្ច ៤ ឬដើម្បីដឹងនិព្វាន ។ ម្យ៉ាងទៀត ឈ្មោះថា **ពោធិ** ព្រោះដឹង ។ នេះជាឈ្មោះរបស់អរិយមគ្គ ។ ដែលលោកពោលថា ដើម្បីប្រយោជន៍ដល់អរិយមគ្គនោះខ្លះ ។ ព្រោះអរិយមគ្គ មានវិបស្សនាមគ្គជាមូល ។ ឥឡូវនេះ កាលពន្រឹកសេចក្តីនៃមគ្គនោះ ទើបពោលពាក្យជាដើមថា **យធិធំ នាមរូបនិរោធា** ដូច្នេះ ។ មួយទៀត ក្នុងបទនេះ លោកពោលដល់និព្វានប៉ុណ្ណោះ ដោយបទបឋមាវិភត្តិថា **វិញ្ញាណនិរោធោ** ជាដើម ដោយប្រការដូច្នេះ មហាបុរសទ្រង់បានឃើញការរលត់ គឺការមិនកើតឡើងនៃវដ្តទុក្ខទាំងមូល ។

បទថា **និរោធោ និរោធោតិ ទោ** សេចក្តីថា មិនកើត មិនកើតនោះឯង ។ បទថា **ចក្ខុ** ជាដើម មានសេចក្តីដូចលោកពោលហើយនុ៉ះឯង តែក្នុងទីនេះ ដោយបទទាំងអស់នេះ លោកពោលត្រឹមតែឲ្យដឹងដល់ការរលត់

ប៉ុណ្ណោះថា កាលវត្ថុនេះមិនមាន វត្ថុនេះរមែងមិនមាន ដូច្នេះ ។ ម្យ៉ាងទៀត លោកពោលដល់វិបស្សនាចាស់ក្លា ដែលនឹងឲ្យដល់ការរួចផុត ។

[៤១] បទថា **អបរេន សមយេន** សេចក្តីថា ព្រះពោធិសត្វទ្រង់ដឹងបច្ចុយ និងការរលត់នៃបច្ចុយយ៉ាងនេះ ក្នុងសម័យដទៃអំពីនោះ ។ បទថា **ឧចាធានក្ខន្ធេសុ** គឺក្នុងខន្ធដែលជាបច្ចុយនៃឧបាទាន ។ បទថា **ឧទយព្វ-យានុបស្សី** សេចក្តីថា ពិចារណាឃើញការកើត និងការរលត់ ដែលឃើញហើយគ្រាជំបូងនុ៉ះឯង ។ បទថា **វិហាសិ** សេចក្តីថា ព្រះពោធិសត្វទ្រង់ចម្រើនវិបស្សនា ដែលជាហេតុឲ្យដល់ការរួចផុតដល់កំពូល ។ លោកពោលសេចក្តីនេះ ព្រោះហេតុអ្វី ព្រោះព្រះពោធិសត្វទាំងឡាយ ទ្រង់បំពេញបារមីក្នុងបច្ចិមភព ស្តេចចេញមហាភិនេស្ក្រមណ៍ក្នុងថ្ងៃ ព្រះឌ្ឋរសប្រសូត ទ្រង់ព្រះផ្ទួស ទ្រង់ប្រកបដោយសេចក្តីព្យាយាម ស្តេចឡើងកាន់ពោធិបល្ល័ង្ក ទ្រង់កម្ចាត់មារ និងសេនាក្នុងបឋមយាម ទ្រង់រព្ចកដល់ខន្ធដែលធ្លាប់នៅអាស្រ័យក្នុងភពមុនក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងបច្ចិមយាម ទ្រង់ពិចារណាបច្ចយាការ ទ្រង់ចេញពីចតុត្ថជ្ឈាន កំណត់ខ្យល់ដង្ហើមចេញចូល ទ្រង់សម្ថឹងពិនិត្យក្នុងខន្ធ ៥ ទ្រង់ឃើញលក្ខណៈ ៥០ ដោយអំណាចការកើត និងការវិនាស ទ្រង់ចម្រើនវិបស្សនាដរាបដល់គោត្រភូញាណ ហើយទ្រង់ចាក់ធ្លុះនូវពុទ្ធគុណទាំងអស់ ដោយអរិយមគ្ត ។ ម្យ៉ាងទៀត មហាបុរសអង្គនេះក៏បានបំពេញបារមីហើយ ។ ព្រះអង្គទ្រង់ធ្វើតាមលំដាប់ទាំងអស់ ដូចដែលពោលហើយ ក្នុងបច្ចិមយាម ទ្រង់ចេញចាកចតុត្ថជ្ឈាន កំណត់ខ្យល់ដង្ហើមចេញចូល ទ្រង់ពិចារណាក្នុងខន្ធ ៥ ទ្រង់ប្រារព្ធការឃើញច្បាស់ការកើត និង

ការរលត់ មានប្រការដូចដែលពោលហើយ ។ លោកពោលដល់ការយើញច្បាស់ ដែលនឹងឲ្យដល់ការរួចផុតនេះ ដើម្បីសម្តែងដល់ការយើញច្បាស់នូវការកើត និងការរលត់នោះ ។

ក្នុងបទទាំងនោះ បទថា **ឥតិ រូបំ** សេចក្តីថា រូបនេះ រូបមានប្រមាណប៉ុណ្ណេះ រូបក្រៅពីនេះមិនមាន ព្រោះហេតុនោះ ទើបលោកពោលដល់ការកំណត់រូប ដែលមិនមានចំណែកសល់ ដោយអំណាចនៃ លក្ខណៈ រសបច្ចុប្បដ្ឋាន និងបទដ្ឋាន ធ្វើសភាវៈនៃការបែកធ្លាយទៅ និងប្រភេទនៃការអាស្រ័យកើតជាដើម ។ លោកពោលការយើញហេតុកើតនៃរូប ដែលកំណត់ទុកយ៉ាងនេះ ដោយបទនេះថា **ឥតិ រូបស្ស សមុឧយោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ឥតិ** សេចក្តីថា យ៉ាងនេះជាហេតុកើត ។ គប្បីជ្រាបសេចក្តីពិស្តារបស់បទ **សមុឧយោ** នោះ យ៉ាងនេះថា ព្រោះអវិជ្ជាកើត ទើបរូបកើត ព្រោះតណ្ហាកើត ទើបរូបកើត ព្រោះកម្មកើត ទើបរូបកើត ព្រោះអាហារកើត ទើបរូបកើត ព្រោះហេតុនោះ សូម្បីយើញលក្ខណៈនៃការកើត ក៏រមែងយើញហេតុកើតរបស់រូបក្ខន្ធ ។ ក្នុងការរលត់ ក៏គប្បីជ្រាបសេចក្តីពិស្តារយ៉ាងនេះថា ព្រោះអវិជ្ជារលត់ ទើបរូបរលត់ ។បេ។ យើញលក្ខណៈនៃការប្រែប្រួលហើយ ក៏រមែងយើញការរលត់នៃរូបក្ខន្ធ ។ ក្នុងបទទាំង-ឡាយថា **ឥតិ វេឧនា** ជាដើម ក៏មានសេចក្តីថា វេទនានេះ វេទនាមានប្រមាណប៉ុណ្ណេះ វេទនាដ៏សេសអំពីនេះ រមែងមិនមាន សញ្ញានេះ សង្ខារទាំងនេះ វិញ្ញាណនេះ វិញ្ញាណមានប្រមាណប៉ុណ្ណេះ វិញ្ញាណដ៏សេសអំពីនេះ រមែងមិនមាន ដូច្នេះ លោកពោលកំណត់វេទនា សញ្ញា សង្ខារ និងវិញ្ញាណ

មិនមានសល់ ដោយអំណាចនៃលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋាន ធ្វើ សភាវៈនៃការសោយអារម្មណ៍ ការរឭកជាតិ ការគាក់តែង និងការយល់ និង ប្រភេទនៃសុខជាដើម រូបសញ្ញាជាដើម ផស្សៈជាដើម ចក្ខុវិញ្ញាណជាដើម ឲ្យជាខាងដើម ។ ប៉ុន្តែលោកពោលដល់ការឃើញហេតុកើតនៃវេទនា សញ្ញា សង្ខារ និងវិញ្ញាណទាំងឡាយ ដែលកំណត់យ៉ាងនេះ ដោយបទថា **ឥតិ វេទនាយ សមុទយោ** *ជាដើម ។ បទថា* **ឥតិ** *ក្នុងបទនោះ ក៏មានសេចក្តីថា យ៉ាងនេះជាហេតុកើតដូច្នេះ ។ សេចក្តីពិស្តារបស់បទទាំងនោះថា ព្រោះ អវិជ្ជាកើត ទើបវេទនាកើត គប្បីជ្រាបដោយនយដែលពោលហើយ ក្នុងរូប នោះឯង ។ តែមានសេចក្តីប្លែកដូច្នេះថា ក្នុងខន្ធ ៣ មិនគួរពោលថា ព្រោះ អាហារកើត គួរពោលថា ព្រោះផស្សៈកើត ។ ក្នុងវិញ្ញាណក្ខន្ធ គួរពោលថា ព្រោះនាមរូបកើត ។ បទថា* **ឯវោ** *គប្បីប្រកបដោយអំណាចនៃបទទាំង នោះឯង ។ នេះជាសេចក្តីសង្ខេប ក្នុងបទនេះ ។ សេចក្តីវិនិច្ឆ័យការកើត និងការរលត់ យ៉ាងពិស្តារបរិបូណ៌ដោយប្រការទាំងពួង លោកបានពោល ហើយក្នុងវិសុទ្ធិមគ្គ ។ ពាក្យថា* **តស្ស បញ្ចសុ ឧបាទានក្ខន្ធេសុ ឧទយព្ព-យានុបស្សិនោ វិហរតោ** *សេចក្តីថា កាលព្រះវិបស្សីពោធិសត្វនោះ ពិចា-រណាឃើញការកើត និងការរលត់ដោយអំណាចលក្ខណៈ ៥០ ក្នុងឧបាទា-នក្ខន្ធ ៥ មានរូបទាំងនេះជាដើម កាលវិបស្សនាញាណចម្រើនហើយតាម លំដាប់ ចិត្តមិនប្រកាន់មាំ ព្រោះមិនកើត រមែងរួចផុតចាកកិលេសទាំងឡាយ ពោល គឺអាសវៈរលត់ស្និទ្ធដោយអនុប្បាទនិរោធ ។ ចិត្តនោះ ឈ្មោះថា រួច ផុតក្នុងមគ្គក្ខណៈ ឈ្មោះថា រួចផុតហើយក្នុងផលក្ខណៈ ឬថា រួចផុតហើយ*

ហើយនឹងរួចផុតក្នុងមគ្គក្ខណៈ ជាការរួចផុតហើយ ក្នុងខណៈផលនុ៎ះឯង ។ ដោយហេតុត្រឹមតែប៉ុណ្ណេះឯង មហាបុរសទ្រង់រួចផុតហើយ អំពីគ្រឿងចង ទាំងពួង មានព្រះសន្ដានរីករាយ ដូចបទុមត្រូវពន្លឺព្រះអាទិត្យ ដូច្នោះ មានព្រះតម្រិះបរិបូណ៌ ប្រថាប់ក្នុងពោធិបល្ល័ង្ក ទ្រង់ធ្វើមគ្គញ្ញាណ ๔ ផលញ្ញាណ ๔ បដិសម្ភិទា ๔ ញាណកំណត់កំណើត ๔ ញាណកំណត់គតិ ๕ អសា-ធារណញ្ញាណ ๖ និងព្រះពុទ្ធគុណទាំងមូល ឲ្យនៅក្នុងកណ្ដាប់ព្រះហស្ដ ។ ទ្រង់ធ្វើទុកក្នុងព្រះទ័យយ៉ាងនេះថា

កាលតថាគត មិនទាន់បានជួបប្រទះ (ពោធិញ្ញាណវេលាតែ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្ដភាព ក៏អន្ទោល ទៅកាន់សង្សារវដ្ដ មានជាតិដ៏ច្រើន សេចក្ដីកើតជាទុក្ខ រឿយៗ ។ នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្ដភាព តថាគត ឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀត មិន បានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគត កាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ ចោលហើយ ចិត្ដរបស់តថាគត ដល់ព្រះនិព្វាន ដែលមាន សង្ខារក្រោសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្សយតណ្ហា ទាំងឡាយហើយ ។

ទ្រង់រុងរឿងដូចព្រះអាទិត្យក្នុងសរទកាល និងដូចព្រះចន្ទក្នុងថ្ងៃ ๑๕ កើត ។

ភាណវារៈ ๒ ចប់

ព្រហ្មយាចកកថា

[៤២] *គប្បីជ្រាបក្នុងគាណាវារទី ៣ ដូច្នេះ បទថា* **យន្ធនាមាំ ធម្មំ ទេសេយ្យំ** *សេចក្តីថា ធ្វើដូចម្តេចហ្ន៎ តថាគតនឹងសម្តែងធម៌ ។ សួរថា វិតក្កនេះកើតទ្បើងហើយកាលណា ឆ្លើយថា កើតទ្បើងក្នុងសប្តាហ៍ទី ៨ របស់ព្រះពុទ្ធ ។*

បានឮថា ព្រះមានព្រះភាគព្រះនាមថាវិបស្សីនោះ បានជាព្រះពុទ្ធហើយ គង់ត្រង់ពោធិបល្ល័ង្កអស់ ១ សប្តាហ៍ ប្រថាប់ឈរសម្លឹងមើលពោធិបល្ល័ង្ក អស់ ១ សប្តាហ៍ ទ្រង់ចង្រ្កមក្នុងផ្ទះកែវអស់ ១ សប្តាហ៍ ប្រថាប់គង់ពិចារណាព្រះធម៌ក្នុងផ្ទះកែវអស់ ១ សប្តាហ៍ ប្រថាប់គង់ក្នុងអជបាលនិគ្រោធ ១ សប្តាហ៍ ប្រថាប់គង់ត្រង់គល់មុចលិន្ទ ១ សប្តាហ៍ ប្រថាប់គង់នៅរាជាយតនៈ ១ សប្តាហ៍ ស្តេចក្រោកចាករាជាយតនៈនោះ លុះព្រះអង្គយាងមកក្នុងសប្តាហ៍ទី ៨ ប្រថាប់គង់ត្រង់អជបាលនិគ្រោធទៀត វិតក្កនេះ និងវិតក្កក្រៅអំពីនេះ ដែលព្រះពុទ្ធប្រព្រឹត្ត និងប្រព្រឹត្តមកយ៉ាងស្មើ កើតទ្បើងហើយដល់ព្រះពុទ្ធទាំងពួង ។

ក្នុងបទទាំងទ្បាយនោះ បទថា **អធិគតោ** *គឺចាក់ផ្ទុះហើយ ។ បទថា* **ធម្មោ** *បានដល់ ធម៌ គឺអរិយសច្ច ៤ ។ បទថា* **គម្ភីរោ** *នេះ ជាឈ្មោះនៃការបដិសេធភាពជារបស់រាក់ ។ បទថា* **ទុទ្ទសោ** *សេចក្តីថា ជាធម៌ដែលឃើញបានដោយក្រ ជាធម៌ដែលបុគ្គលឃើញដោយលំបាក គឺមិនអាចឃើញដោយងាយ ព្រោះជាធម៌ជ្រាលជ្រៅ ។ ព្រោះជាធម៌ ដែលឃើញបានលំបាក ទើបជាធម៌ដែលត្រាស់ដឹងតាមលំបាក ដែលបុគ្គលគប្បីត្រាស់ដឹងដោយលំបាក គឺមិនអាចត្រាស់ដឹងបានដោយងាយ ។ បទថា* **សន្តោ** *គឺរលត់ឥតសេសសល់*

ហើយ ។ បទថា **ปณีตโต** *គឺមិនក្តៅក្រហាយ ទាំងពីរបទនេះ លោកពោលសំដៅដល់លោកុត្តរនុ៎ះឯង ។ បទថា* **อตกฺกาวจโร** *សេចក្តីថា មិនគួរប៉ាន់ស្មាន គឺមិនគួរឈមចុះដោយការត្រិះរិះ គួរប៉ាន់ស្មានដោយញាណប៉ុណ្ណោះ ។ បទថា* **นิปุณา** *គឺល្អិត ។ បទថា* **ปณฺฑิตเวทนียา** *សេចក្តីថា ដែលបណ្ឌិតអ្នកបដិបត្តិបដិបទាដ៏ប្រពៃគប្បីដឹងបាន ។ បទថា* **อาลยรามา** *សេចក្តីថា សត្វទាំងឡាយ រមែងជាប់ក្នុងកាមគុណ ៥ ព្រោះដូច្នោះ សត្វទាំងនោះ លោកពោលថា* **อาลยา ។** *សត្វទាំងឡាយ រមែងនៅជាមួយនឹងការជាប់ពាក់ព័ន្ធក្នុងតណ្ហាវិបរិត ១០៨ ព្រោះដូច្នោះ ទើបលោកពោលថា* **อาลยา ។** *សត្វទាំងឡាយ រមែងត្រេកអរដោយអាល័យទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា* **อาลยารามา** *គឺមានអាល័យជាទីត្រេកអរ ។ សត្វទាំងឡាយ ត្រេកអរហើយក្នុងអាល័យ ព្រោះដូច្នោះ ទើបឈ្មោះថា* **อาลยรตา** *គឺត្រេកអរហើយក្នុងអាល័យ ។ សត្វទាំងឡាយរីករាយហើយដោយល្អក្នុងអាល័យទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា* **อาลย-สมฺมุทิตา** *គឺរីករាយហើយក្នុងអាល័យ ។ សត្វទាំងឡាយ រមែងត្រេកអរដោយអាល័យក្នុងកាម និងអាល័យក្នុងតណ្ហាទាំងនេះ ជាអ្នករីករាយត្រេកអរក្នុងសង្ឃារាវដ្ត ដូចព្រះរាជាស្តេចប្រពាតព្រះរាជឧទ្យាន ដែលបរិបូណ៌ដោយវុក្ខជាតិ ដែលពេញទៅដោយផ្កា និងផ្លែជាដើម ដែលតាក់តែងយ៉ាងល្អ ទ្រង់រីករាយមនោរម្យ រីករាយក្អើតក្អើន ដោយសម្បត្តិនោះៗ ទ្រង់មិននឿយណាយ ទ្រង់មិនប្រាថ្នានឹងត្រឡប់សូម្បីល្ងាច ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីអាល័យ ២ យ៉ាង ដូចទីឧទ្យាន*

ដល់សត្វទាំងនោះ ទើបត្រាស់ថា **អាលយរាមា** គឺមានអាល័យជាទីត្រេកអរ ជួច្នេះជាដើម ។ បទថា **យទិទំ** ជានិបាត ។ គប្បីជ្រាបសេចក្តីយ៉ាងនេះថា បទថា **យំ ឥទំ** សំដៅដល់ហានៈរបស់បទនោះ ។ បទថា **យោ អយំ** សំដៅដល់បដិច្ចសមុប្បាទ ។ បច្ច័យរបស់បទទាំងពីរនេះថា **ឥទប្បច្ចយតា បដិច្ចសមុប្បាទោ** ឈ្មោះថា **ឥទប្បច្ចយា** គឺធម៌នេះជាបច្ច័យរបស់ធម៌នេះ ។ ឈ្មោះថា **ឥទប្បច្ចយតា** និង **បដិច្ចសមុប្បាទោ** ព្រោះភាពដែលធម៌នេះ ជាបច្ច័យរបស់ធម៌នេះ និងបច្ច័យដែលជាទីអាស្រ័យគ្នាកើតឡើង ។ បទនេះជាឈ្មោះរបស់អវិជ្ជាជាដើម ដែលជាបច្ច័យនៃសង្ខារជាដើម ។ បទទាំងអស់ថា **សព្ពសង្ខារសមថោ** ជាដើម ជានិព្វានតែម្យ៉ាង ។ ព្រោះសេចក្តីអន្ទះអន្ទែងនៃសង្ខារទាំងពួង អាស្រ័យនិព្វាននោះ រមែងស្ងប់ រមែងរម្ងាប់ ជួច្នោះ ទើបលោកពោលថា **សព្ពសង្ខារសមថោ** គឺជាទីរម្ងាប់នៃសង្ខារទាំងពួង ជួច្នេះ ។ ម្យ៉ាងទៀត ព្រោះកិលេសទាំងពួងជាការលះបង់ទៅបាន តណ្ហាទាំងពួងអស់ទៅ កិលេសរាគៈទាំងពួងប្រាសទៅ ទុក្ខទាំងពួងរលត់ទៅ ព្រោះអាស្រ័យនិព្វាននោះ ជួច្នោះ ទើបលោកពោលថា **សព្ពូបធិប្បដិនិស្សគ្គោ** គឺជាទីលះបង់កិលេសទាំងពួង **តណ្ហាក្ខយោ** គឺជាទីអស់ទៅនៃតណ្ហា **វិរាគោ** គឺប្រាសចាកតម្រេក **និរោធោ** គឺរម្ងាប់ទុក្ខ ជួច្នេះ ។ តណ្ហានោះ រមែងនាំទៅគឺរួបរឹតភព ដោយភព ឬកម្ម និងផលកម្ម ព្រោះជួច្នោះ ទើបលោកពោលថា តណ្ហាធ្វើការរួបរឹត ។ ឈ្មោះនិព្វាន ព្រោះចេញចាកគ្រឿងរួបរឹតនោះ ។ បទថា **សោ មមស្ស កិលមថោ** សេចក្តីថា ការសម្តែងធម៌ដល់អ្នកមិនដឹង គប្បីជាសេចក្តីលំបាករបស់តថាគត ។ ដែលលោកពោលថា គប្បីជាសេចក្តី

លំបាកផ្លូវកាយ និងគប្បីជាការបៀតបៀនផ្លូវកាយ ។ តែទុក្ខទាំងពីរនេះ មិនមានក្នុងព្រះហឫទ័យរបស់ព្រះពុទ្ធទាំងឡាយ ។

បទថា **អបិស្សុ** *ជានិបាត ក្នុងអត្ថថា កពូន ។ និបាតនោះ សម្តែងថា មិនមែនមានវិតក្កនេះតែម្យ៉ាង សូម្បីគាថាទាំងនេះ ក៏ជាក់ច្បាស់ហើយ ។ ក្នុងបទទាំងឡាយថា* **វិបស្សី** *ជាដើម សេចក្តីថា ព្រះវិបស្សីមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ។*

បទថា **អនច្ឆរិយា** *គឺអស្ចារ្យតិច ។ បទថា* **បដិកំសុ** *សេចក្តីថា ធម៌ជាគោចរទាំងឡាយបានកើតដល់ញាណ ពោល គឺបដិភាណ ដល់ភាពជាធម៌ គប្បីបរិវិតក្ក ។*

បទថា **កិច្ឆេន** *សេចក្តីថា ដោយលំបាក គឺមិនមែនដើម្បីបដិបត្តិលំបាក។ ព្រោះមគ្គ ៤ ក៏រមែងជាការបដិបត្តិងាយរបស់ព្រះពុទ្ធទាំងឡាយ ។ បទនេះ លោកពោលសំដៅដល់បដិបត្តិ ដើម្បីបានគុណវិសេសរបស់អ្នកដែលនៅមានរាគៈ មានទោសៈ និងមានមោហៈ ក្នុងវេលាបំពេញបារមីនោះឯង ឲ្យវត្តជាដើមយ៉ាងនេះ គឺកាត់ក្បាលដែលប្រដាប់តាក់តែងហើយ យកឈាមចេញចាកក ខ្វះគ្រាប់ភ្នែកទាំងពីរខាង ដែលបន្តក់ថ្នាំយ៉ាងល្អ លះបង់បុត្រជាអ្នកបន្តវង្សត្រកូល លះបង់ភរិយាដែលមានការប្រព្រឹត្តជាទីពេញចិត្ត ឲ្យដល់សូមទាំងឡាយ ដែលនាំគ្នាមក និងសូម្បីយ៉ាងដទៃ មានការកាត់ និងទម្លាយក្នុងអត្តភាព ដូចជាខន្តិវាទីតាបសជាដើម ។* **ហ** *អក្ខរៈ ក្នុងបទថា* **ហាលំ** *នេះ ត្រឹមតែជានិបាត ប្រែថា គួរ ។ បទថា* **បកាសិតុំ** *គឺដើម្បីសម្តែង គឺកាលអ្នកសម្រេចធម៌បានលំបាកយ៉ាងនេះ ក៏មិនគួរសម្តែង គឺគួរសម្តែងជាមួយនឹងអ្នក*

ឈ្មាស លោកអធិប្បាយថា ប្រយោជន៍អ្វីដោយការសម្តែង ។ បទថា **រាគ-ទោសបរេតេហិ** គឺត្រូវរាគ: ទោស:គ្របសង្កត់ ឬរាគ: ទោស:ជាប់តាមទៅ ។ បទថា **បដិសោតគាមឹ** សេចក្តីថា សច្ចធម៌ ៤ ដែលដល់ហើយយ៉ាងនេះថា ជាធម៌បញ្ចោសក្រសៃនៃសេចក្តីទៀងជាដើម គឺការមិនទៀង ជាទុក្ខ មិនមានតួខ្លួន និងមិនស្អាត ។ បទថា **រាគរត្តា** សេចក្តីថា ត្រូវកាមរាគ: ភវរាគ: និងទិដ្ឋិរាគ:ជ្រលក់ ។ បទថា **ន ឧក្ខន្តិ** សេចក្តីថា សត្វទាំង-ឡាយនឹងមិនយើញតាមសេចក្តីពិតថា ជារបស់មិនទៀង ជាទុក្ខ មិនមានតួខ្លួន មិនស្អាត ដូច្នេះ អ្នកណាហ្នឹ នឹងអាចឲ្យអ្នកដែលមិនយើញទាំងនោះ កាន់យកយ៉ាងនេះបាន ។ បទថា **តមោក្ខន្ធេន អាវុតា** សេចក្តីថា ត្រូវគំនរអវិជ្ជារួបរឹត ។

[៤៣] បទថា **អប្បោស្សុក្ពតាយ** សេចក្តីថា ព្រោះទ្រង់មិនប្រាថ្នានឹងសម្តែងដោយភាពជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ។ ព្រោះហេតុអ្វី ទើបព្រះហប្ចទ័យរបស់ព្រះអង្គបង្អោនទៅយ៉ាងនេះហ្នឹ ព្រះអង្គទ្រង់ធ្វើសេចក្តីប្រាថ្នាថា តថាគតរួចផុតហើយ នឹងដោះសត្វ តថាគតឆ្លងបានហើយ នឹងឲ្យសត្វឆ្លងដែរ នឹងបានជាប្រយោជន៍អ្វី ដោយអញអ្នកដឹងច្បាស់នូវធម៌ក្នុងលោកនេះហើយ នឹងមិនឲ្យអ្នកដទៃដឹងដែរ អញសម្រេចសព្វញ្ញុតញ្ញាណហើយ នឹងញ្ចាំងសត្វ ព្រមទាំងទេវតាឲ្យឆ្លងរួចផុតទៅ ដូច្នេះ មិនមែនឬ ហើយទ្រង់បំពេញបារមី ដរាបបានសម្រេចព្រះសព្វញ្ញុតញ្ញាណ ។ ប្រការនោះ ជាសេចក្តីពិត តែចិត្តរបស់ទ្រង់បង្អោនទៅយ៉ាងនោះ ដោយអានុភាពនៃការពិចារណា ។ ពិតហើយ កាលព្រះអង្គសម្រេចសព្វញ្ញុតញ្ញាណហើយ ទ្រង់

ពិចារណាជល់ភាពដែលសត្វទាំងឡាយ នៅជាប់ស្អិតដោយកិលេស និង សភាពនៃព្រះធម៌ជាធម៌ជ្រាលជ្រៅ សភាពនៃសត្វទាំងឡាយ នៅជាប់ស្អិត ដោយកិលេស និងសភាពនៃព្រះធម៌ជាធម៌ជ្រាលជ្រៅ ប្រាកដដោយអាការ ទាំងពួង ព្រោះដូច្នោះ កាលព្រះអង្គទ្រង់ត្រែះរិះថា សត្វទាំងនេះឯង ពេញទៅ ដោយកិលេស សៅហ្មងក្រៃលែងពេកណាស់ ត្រូវរាគៈជ្រលក់ ត្រូវទោសៈ គ្របសង្កត់ វង្វេងទៅដោយមោហៈ ដូចកុណ្ឌីទឹកពេញទៅដោយទឹកផ្អូម ដូច ថាសពេញទៅដោយតក្កៈ ដូចផ្ទាំងសំពត់សាច់រឹង ប្រឡាក់ទៅដោយខ្វាញ់រាវ និងប្រេង ដូចដៃប្រឡាក់ទៅដោយថ្នាំបន្តក់ភ្នែក បុគ្គលទាំងនោះនឹងដឹងច្បាស់ ចាក់ធ្លុះបានដូចម្តេចហ្ន៎ ដូច្នេះ ទើបចិត្តបង្អោនទៅយ៉ាងនោះ ដោយអានុភាពនៃ ការប្រកាន់របស់កិលេស និងការពិចារណា ។ ម្យ៉ាងទៀត ព្រះធម៌នេះជ្រាល ជ្រៅ ដូចទឹកទ្រទុកនូវផែនដីបាន ឃើញដោយលំបាក ដូចគ្រាប់ស្ពៃដែល ត្រូវភ្ជុំបាំង នឹងដឹងតាមបានលំបាក ដូចការប្រៀបចុងរោមសត្វដោយចុងរបស់ រោមសត្វ ឲ្យប្រៀបជា ១០០ ចម្រៀក ។ ពិតហើយ តថាគតព្យាយាម ដើម្បីដឹងច្បាស់នូវធម៌នេះ មិនមែនមិនបានឲ្យទាន មិនមែនមិនបានរក្សាសីល មិនមែនមិនបានបំពេញបារមីនោះទេ សូម្បីកាលតថាគតកម្ចាត់មារ និងសេនា ដូចមិនមានសេចក្តីឧស្សាហ៍ ផែនដីក៏មិនញាប់ញ័រ កាលតថាគតរឭកដល់ខន្ធ ដែលធ្លាប់នៅអាស្រ័យក្នុងជាតិមុន ក្នុងបឋមយាម ក៏មិនញាប់ញ័រ កាល តថាគតជម្រះទិព្វចក្ខុ ក្នុងមជ្ឈិមយាម ក៏មិនញាប់ញ័រ តែកាលតថាគតដឹង ច្បាស់ចាក់ធ្លុះនូវបដិច្ចសមុប្បាទ ក្នុងបច្ឆិមយាម ផែនដីមុឺនលោកធាតុ បាន ញាប់ញ័រហើយ ដោយប្រការដូច្នេះអម្បាលជនដូចតថាគតគង់ដឹងច្បាស់ គឺ

ចាក់ធ្លុះនូវធម៌នេះដោយញាណ ដ៏ខ្ជាំងក្លាបានដោយលំបាកដល់ម្ល៉េះហើយ ចំណង់បើមហាជនក្នុងលោក នឹងដឹងច្បាស់ នឹងចាក់ធ្លុះនូវធម៌នោះ បានដូចម្តេច ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះហឫទ័យរបស់ព្រះអង្គបង្អោនទៅហើយយ៉ាងនោះ ដោយអានុភាពនៃភាពដែលព្រះធម៌ ជាធម៌ជ្រាលជ្រៅ និងដោយការពិចារណា ដូច្នេះ ។ ម្យ៉ាងទៀត កាលព្រហ្មទូលអារាធនា ព្រះហឫទ័យរបស់ព្រះអង្គ ក៏បង្អោនទៅយ៉ាងនេះ ព្រោះមានព្រះបំណងនឹងសម្តែង ។ ពិតហើយ ព្រះមានព្រះភាគទ្រង់រមែងជ្រាបថា កាលចិត្តរបស់តថាគតបង្អោនទៅ ព្រោះភាពដែលតថាគត ជាអ្នកមានសេចក្តីប្រាថ្នាតិច មហាព្រហ្មអារាធនាតថាគតដើម្បីឲ្យសម្តែងធម៌ សត្វទាំងនេះ ជាអ្នកគោរពព្រហ្ម កាលដឹងថា មានដំណឹងថា ព្រះសាស្តាមិនមានព្រះបំណងនឹងសម្តែងធម៌ដល់ពួកយើង ពេលនោះ មហាព្រហ្មអារាធនាព្រះអង្គឲ្យសម្តែងហើយ អ្នកដ៏ចម្រើនទាំងឡាយ ព្រះធម៌ស្ងប់ហ្ន៎ ប្រណីតហ្ន៎ នឹងតាំងចិត្តស្តាប់ ដូច្នេះ ។ គប្បីជ្រាបថា អាស្រ័យហេតុនេះ ទើបព្រះហឫទ័យរបស់ព្រះអង្គបង្អោនទៅដើម្បីភាពជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅ ដើម្បីសម្តែងធម៌ ។

[៤៤] *ក្នុងបទថា* **អញ្ញតរស្ស** *នេះ លោកពោលថា* **អញ្ញតរោ** *ក៏ពិត តែគប្បីជ្រាបថា នុ៎ះ គឺមហាព្រហ្មជាធំក្នុងចក្រវាលនេះ ។ បទថា* **ឆស្សុតិ វត ភោ លោកោ** *សេចក្តីថា បានឮថា មហាព្រហ្មនោះ បន្ទឺសំឡេងនេះ ដោយពួកព្រហ្មក្នុងមុនលោកធាតុស្តាប់ហើយ ទាំងអស់ប្រជុំគ្នា ។ បទថា* **យត្រ ហិ នាម** *គឺក្នុងលោកណា ។ បទថា* **បុរតោ ចាតុរហោសិ** *សេចក្តីថា មហាព្រហ្មបានប្រាកដ មួយអន្ទឹដោយព្រហ្មទាំង ១ ម៉ឺននោះ ។*

បទថា **អប្បរជក្ខជាតិកា** *សេចក្តីថា ធូលី គឺរាគៈ ទោសៈ និងមោហៈ ស្រាលស្តើង គឺបន្ទិចបន្តួចក្នុងភ្នែកដែលសម្រេចដោយបញ្ញា សភាពយ៉ាងនេះ របស់សត្វទាំងឡាយនោះ នៅមាន ព្រោះហេតុនោះ សត្វទាំងឡាយឈ្មោះថា* **អប្បរជក្ខជាតិកា** *គឺមានកិលេសដូចធូលីក្នុងភ្នែកតិច ។ បទថា* **អស្សវនតា** *គឺព្រោះមិនបានស្តាប់ ។ បទថា* **ភវិស្សន្តិ** *សេចក្តីថា លោកពោលថា សត្វទាំងឡាយសន្សំបុណ្យទុកហើយដល់ភាពចាស់ក្លាក្នុងព្រះពុទ្ធអង្គមុនៗ ដោយអំណាចបុញ្ញកិរិយាវត្ថុ ១០ ទន្ទឹងព្រះធម៌ទេសនាតែម្យ៉ាង ដូចបទុមជាតិទន្ទឹងពន្លឺព្រះអាទិត្យ ជាអ្នកគួរឈមចុះកាន់អរិយភូមិ ក្នុងកាលចប់គាថា ៤ បទ មិនមែនតែម្នាក់ មិនមែនពីរនាក់ មានច្រើនសែននាក់នឹងជាអ្នកដឹងធម៌ ដូច្នេះ ។*

បទថា **អជ្ឈេសនំ** *គឺអាវជនាយ៉ាងនេះ ៣ ដង ។ បទថា* **ពុទ្ធចក្ខុនា** *សេចក្តីថា ដោយប្រាជ្ញាកំណត់ដឹងភាពទន់ខ្លី និងចាស់ក្លានៃឥន្ទ្រិយរបស់សត្វទាំងឡាយ និងដោយអាសយានុសយញ្ញាណ ។ បទថា* **ពុទ្ធចក្ខុ** *ជាឈ្មោះនៃញាណទាំងពីរនេះ។ បទថា* **សមន្តចក្ខុ** *ជាឈ្មោះនៃព្រះសព្វញ្ញុតញ្ញាណ ។ បទថា* **ធម្មចក្ខុ** *ជាឈ្មោះនៃមគ្គញ្ញាណ ៣ ។ ក្នុងបទថា* **អប្បរជក្ខេ** *ជាដើម សេចក្តីថា សត្វដែលមានធូលី មានរាគៈជាដើមក្នុងបញ្ចចក្ខុតិច ដោយន័យដែលពោលនោះឯង ។ ឈ្មោះថា* **អប្បរជក្ខា** *គឺមានកិលេសប្រាកដដូចធូលីក្នុងចក្ខុតិច ។ សត្វដែលមានធូលី មានរាគៈជាដើមនោះ ក្នុងបញ្ចចក្ខុច្រើន ឈ្មោះថា* **មហារជក្ខា** *គឺមានកិលេស ដូចធូលីក្នុងភ្នែកច្រើន ។ សត្វដែលមានឥន្ទ្រិយ មានសទ្ធាជាដើម ចាស់ក្លា ឈ្មោះថា* **តិក្ខិន្ទ្រិយា** *គឺមានឥន្ទ្រិយចាស់ក្លា ។ សត្វដែលមានឥន្ទ្រិយទាំងនោះទន់ខ្លី ឈ្មោះថា* **មុទុន្ទ្រិយា**

គឺមានឥន្ទ្រិយទន់ខ្លី ។ សត្វដែលមានអាការ មានសទ្ធាជាដើមទាំងនោះល្អ ឈ្មោះថា **ស្វាការា** *គឺមានអាការល្អ ។ សត្វដែលកំណត់ហេតុដែលពោល អាចឲ្យដឹងបានងាយ ឈ្មោះថា* **សុវិញ្ញាបយា** *គឺឲ្យដឹងច្បាស់បានងាយ ។ សត្វដែលឃើញបរលោក និងទោស ដោយភាពជាភ័យ ឈ្មោះថា* **បរលោកវជ្ជភយទស្សាវិនោ** *គឺច្រើនឃើញបរលោក និងទោស ដោយភាពជាភ័យ ។ ក្នុងបាលីអត្ថដូច្នេះថា*

បុគ្គលដែលមានសទ្ធា មានកិលេសដូចធូលីក្នុងភ្នែកតិច បុគ្គលដែលមិនមានសទ្ធា មានកិលេសដូចធូលីក្នុងភ្នែកច្រើន បុគ្គលដែលប្រារព្ធសេចក្តីព្យាយាម មានកិលេសដូចធូលីក្នុងភ្នែកតិច បុគ្គលដែលខ្ជិលច្រអូស មានកិលេសដូចធូលីក្នុងភ្នែកច្រើន បុគ្គលដែលមានសតិតាំងមាំ មានកិលេសដូចធូលីក្នុងភ្នែកតិច បុគ្គលដែលមិនមានស្មារតី មានកិលេសដូចធូលីក្នុងភ្នែកច្រើន បុគ្គលដែលមានចិត្តតាំងមាំ មានកិលេសដូចធូលីក្នុងភ្នែកតិច បុគ្គលដែលមានចិត្តមិនតាំងមាំ មានកិលេសដូចធូលីក្នុងភ្នែកច្រើន បុគ្គលដែលមានបញ្ញា មានកិលេសដូចធូលីក្នុងភ្នែកតិច បុគ្គលដែលមានបញ្ញាថោកថយ មានកិលេសដូចធូលីក្នុងភ្នែកច្រើន ដូចគ្នានេះដែរ បុគ្គលដែលមានសទ្ធា មានឥន្ទ្រិយចាស់ក្លា ។បេ។ បុគ្គលដែលមានបញ្ញាច្រើន ឃើញលោកជំទៃ និងទោស ដោយភាពជាភ័យ បុគ្គលដែលមានបញ្ញាថោកថយ មិនឃើញលោកជំទៃ និងទោស ដោយភាពជាភ័យ ។

បទថា **លោកោ** *បានដល់ ខន្ធលោក ធាតុលោក អាយតនលោក សម្បត្តិភវលោក វិបត្តិភវលោក សម្បត្តិ និងវិបត្តិភវលោក វិបត្តិសម្បត្តិភវ-*

លោក លោក ១ គឺសត្វទាំងឡាយទាំងពួងតាំងនៅបានដោយអាហារ លោក ២ គឺនាម និងរូប លោក៣ គឺវេទនា ៣ លោក ៤ គឺអាហារ ៤ លោក ៥ គឺឧបាទានក្ខន្ធ ៥ លោក ៦ គឺអាយតនៈខាងក្នុង ៦ លោក ៧ គឺ ភូមិជាទីតាំងនៃវិញ្ញាណ ៧ លោក ៨ គឺលោកធម៌ ៨ លោក ៩ គឺភពជាទីនៅរបស់សត្វ ៩ លោក ១០ គឺអាយតនៈ ១០ លោក ១២ គឺអាយតនៈ ១២ លោក ១៨ គឺធាតុ ១៨ ។

បទថា **វជ្ជំ** *បានដល់ កិលេសគ្រប់ប្រភេទជាទោស ទុច្ចរិតគ្រប់ប្រភេទជាទោស អកិសង្វារគ្រប់ប្រភេទជាទោស កម្ម គឺការទៅកាន់ភពគ្រប់ប្រភេទជាទោស ដោយប្រការដូច្នេះ ទាំងក្នុងលោកនេះ ទាំងទោសនេះ ជាការប្រាកដអត្តដោយសភាពជាភ័យយ៉ាងខ្លាំងក្លា ដូចពេជ្ឈឃាតងាជាវ ព្រះសាស្តា ព្រះនាមថាវិបស្សី ទ្រង់ដឹង ទ្រង់ឃើញ ទ្រង់ដឹងក្រៃលែង ទ្រង់ចាក់ធ្លុះនូវឥន្ទ្រិយទាំង ៥ នេះ ដោយអាការទាំង ៥០ នេះ នេះជាប្រជ្ញារបស់ព្រះតថាគត ដែលកំណត់ដឹងភាពទន់ខ្លី និងភាពចាស់ក្លានៃឥន្ទ្រិយរបស់សត្វទាំងឡាយ ។*

បទថា **ឧប្បលិនិយំ** *គឺក្នុងគុម្ពឈូក ។ ក្នុងបទក្រៅនេះ ក៏មាននយនេះដូចគ្នា ។ បទថា* **អន្តោនិមុគ្គទោសីនិ** *គឺផ្កាឈូកដទៃណាលិចនៅក្នុងទឹក ដែលទឹកចិញ្ចឹម ។ បទថា* **ឧទកំ អច្ចុគ្គម្ម តិដ្ឋន្តិ** *គឺឈូកពួកខ្លះ តាំងខ្ពើងផុតអំពីទឹក ។ ក្នុងបទនោះ អធិប្បាយថា ឈូកពួកខ្លះតាំងខ្ពើងផុតទឹក រង់ចាំតែសម្ផស្សព្រះអាទិត្យ ហើយរីកក្នុងថ្ងៃនេះ ។ ឈូកខ្លះតាំងនៅស្មើទឹក នឹងរីកក្នុងថ្ងៃស្អែក ។ ពួកខ្លះលិចនៅខាងក្នុងទឹក ដែលទឹកចិញ្ចឹមទុកនឹងរីក*

ក្នុងថ្ងៃទី ៣ ។ តែនៅមានផ្កាឈូកជាដើម ដែលមានពោគជទៃ មិនលូតផុតអំពីទឹក ហើយផ្កាឈូកពួកណានឹងមិនរីក នឹងជាអាហារនៃត្រី និងអណ្តើកតែម្យ៉ាង ផ្កាឈូកទាំងនោះ លោកមិនគប្បីនាំខ្លើងកាន់បាលី បានសម្តែងទុកច្បាស់ហើយ ។ បុគ្គល ៤ ពួក គឺឧគ្ឃដិតញ្ញូ វិបចិតញ្ញូ នេយ្យៈ បទបរមៈ ក៏ប្រៀបដូចផ្កាឈូកទាំង ៤ នេះឯង ។ ក្នុងបុគ្គល ៤ ពួកនោះ បុគ្គលដែលត្រាស់ដឹងធម៌ ដំណាលគ្នានឹងលោកលើកខ្លើងសម្តែង ឈ្មោះថា **ឧគ្ឃដិតញ្ញូ** ។ បុគ្គលដែលត្រាស់ដឹងធម៌ កាលលោកចែកសេចក្តីនៃពាក្យសង្ខេបដោយពិស្តារ ឈ្មោះថា **វិបចិតញ្ញូ** ។ បុគ្គលដែលត្រាស់ដឹងធម៌ដោយលំដាប់ដោយការប្រារព្ធព្យាយាមទន្ទេញចាំ ដោយការសាកសួរ ដោយធ្វើទុកក្នុងចិត្ត ដោយឧបាយដ៏ប្រពៃ ដោយគប់រក សមាគមនឹងកល្យាណមិត្ត ឈ្មោះថា **នេយ្យ** ។ បុគ្គលដែលមិនត្រាស់ដឹងធម៌បានក្នុងជាតិនោះ សូម្បីរៀនច្រើន ចាំច្រើន ទូន្មានច្រើន ឈ្មោះថា **បទបរម** ។ ក្នុងបទនោះ ព្រះមានព្រះភាគទ្រង់ពិចារណាមើលលោកធាតុទាំង ១ ម៉ឺន ដូចជាផ្កាឈូកជាដើម ទ្រង់បានឃើញហើយថា បុគ្គលពួកឧគ្ឃដិតញ្ញូ ដូចផ្កាឈូក នឹងរីកក្នុងថ្ងៃនេះ បុគ្គលពួកវិបចិតញ្ញូ ដូចផ្កាឈូកនឹងរីកក្នុងថ្ងៃស្អែកនេះ បុគ្គលពួកនេយ្យៈ ដូចផ្កាឈូកនឹងរីកក្នុងថ្ងៃទី ៣ បុគ្គលពួកបទបរមៈ ដូចផ្កាឈូកដែលជាអាហារនៃត្រី និងអណ្តើក ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់ពិចារណាមើល ទ្រង់បានឃើញដោយអាការទាំងពួងយ៉ាងនេះថា សត្វមានកិលេសដូចធូលីក្នុងភ្នែកតិចមានប្រមាណប៉ុណ្ណេះ សត្វមានកិលេសដូចធូលីក្នុងភ្នែកច្រើន មានប្រមាណប៉ុណ្ណេះ សូម្បីក្នុងសត្វទាំងនោះ ពួកដែលជាឧគ្ឃដិតញ្ញូ មានប្រមាណប៉ុណ្ណេះ

ดังนี้ ฯ ในสูตร ๔ พวกนั้น การแสดงธรรมของพระผู้มีพระภาค ย่อมสำเร็จประโยชน์แก่บุคคล ๓ พวก ในอัตภาพนี้นั่นเทียว ฯ พวกสุดท้าย ย่อมมีวาสนาเพื่อประโยชน์ในอนาคต ฯ

ลำดับนั้น พระผู้มีพระภาคทรงประกาศพระธรรมเทศนา ที่นำมาซึ่งประโยชน์แก่บุคคลทั้ง ๔ พวกนี้แล้ว ทรงทำอัตภาพเป็นที่พึ่งพิงได้ ทรงแสดงให้ยิ่งขึ้นไป ทรงจำแนกสูตรทั้งปวง ในนิกาย ๓ ให้เป็นส่วนๆ ด้วยอำนาจแห่งเคยยสูตร และอเคยยสูตร สูตรที่ตรัสไว้ด้วยคาถาและสูตรที่ตรัสไว้ดีแล้วนั้น คือ สูตรพวกใดพวกหนึ่งที่ประกอบด้วยองค์ ๕ คือ วิปัลลาส ๓ กิเลส ๓ ไม่มีศรัทธา ไม่มีความเพียร มีปัญญาทราม เป็นผู้ไม่ควรเพื่อจะเข้าไปนั่งใกล้ในที่ประชุมชนผู้ตั้งมั่นในสัมมาทิฏฐิ ในธรรมทั้งหลายที่เป็นกุศล ชื่อว่าเป็นผู้มีปกติเห็นผิดโดยส่วนเดียว สูตรทั้งหลายนั้น ชื่อว่าเป็นเคยยสูตร เคยยสูตรเป็นอย่างไร สูตรที่ประกอบด้วยองค์ ๕ คือ วิปัลลาส ๓ กิเลส ๓ ฯลฯ สูตรทั้งหลายนี้ ชื่อว่าเป็นเคยยสูตร ดังนี้ ฯ ในบทนั้น พระผู้มีพระภาคทรงละเคยยสูตรทั้งหมด ทรงกำหนดเคยยสูตรด้วยพระญาณ ทรงจำแนกให้เป็น ๖ ส่วน คือ สูตรพวกวาคจริต ประมาณเท่านี้ สูตรพวกโทสจริต โมหจริต วิตักกจริต สัทธาจริต พุทธิจริต มีประมาณเท่านี้ๆ ฯ ครั้นทรงจำแนกอย่างนี้แล้ว จึงตรัสว่า ตถาคตย่อมแสดงธรรม ดังนี้ ฯ

พราหมณ์ ลุกขึ้นจากอาสนะแล้ว ได้กราบทูลพระผู้มีพระภาคด้วยคาถา ชื่อว่าเป็นคาถา ฯ

พระผู้มีพระภาคตรัสว่า **อถโข สา ภิกฺเว มหาพฺรหฺมา** ดังนี้เป็นต้น

ទ្រង់សំដៅដល់សេចក្តីនេះ ។ ក្នុងបទទាំងនោះ បទថា **អជ្ឈភាសិ** *កាត់បទជា* **អធិ អភាសិ** *អធិប្បាយថា បានក្រាបទូលប្រារព្ធឲ្យក្រៃលែងឡើង ។*

[៤៥] *បទថា* **សេលេ យថា បព្ភតមុទ្ធនិដ្ឋិតោ** *គឺដូចបុគ្គលឈរលើភ្នំថ្មសុទ្ធ ។ ពិតហើយ កាលបុគ្គលឈរលើកំពូលភ្នំនោះ ក៏មិនមានកិច្ចជាដើមថា ចំអើត និងអើតកជើម្បីមើល ។ បទថា* **តជ្ជបមំ** *សេចក្តីថា ប្រៀបផ្ទឹមដោយវត្ថុនោះ គឺប្រៀបផ្ទឹមដោយភ្នំថ្មសុទ្ធ ។ ឯសេចក្តីសង្ខេបក្នុងរឿងនេះមានដូច្នេះថា បុរសមានភ្នែក ឈរលើកំពូលភ្នំថ្មសុទ្ធ គប្បីឃើញពួកជនដោយជុំវិញយ៉ាងណា បពិត្រព្រះមានព្រះភាគ ព្រះអង្គជាអ្នកមានបញ្ញាស្អាតមានចក្ខុដោយជុំវិញដោយសព្វញ្ញុតញ្ញាណក៏ដូច្នោះ ទ្រង់ឡើងកាន់ប្រាសាទសម្រេចដោយធម៌ សម្រេចដោយបញ្ញា ជាអ្នកប្រាសចាកសេចក្តីសោក ដោយព្រះអង្គឯង ទ្រង់ត្រិះរិះ ទ្រង់ពិចារណា ទ្រង់ប្រមើលមើល ពួកជនដែលច្រឡូកច្រឡំទៅដោយសេចក្តីសោក ត្រូវជាតិ ជរាគ្របសង្កត់ហើយ ។*

ក្នុងបទនេះមានអធិប្បាយដូច្នេះថា ដូចជាមនុស្សទាំងឡាយ ធ្វើទីជីដ៏ធំជុំវិញជើងភ្នំ ហើយសាងខ្ទមក្នុងជួរផ្ទៃដីសមគួរដល់ការសង់ក្នុងទីដីនោះ អុជភ្លើងក្នុងវេលាយប់ ម្យ៉ាងទៀត ទីដីនោះ គប្បីមានសភាពងងឹតប្រកបដោយអង្គ ៤ ខណៈនោះ កាលបុរសអ្នកមានភ្នែក ឈរលើកំពូលភ្នំនោះ សម្លឹងមើលផ្ទៃដី ផ្ទៃដីមិនប្រាកដ ទីដីសង់ខ្ទមមិនប្រាកដ ខ្ទមមិនប្រាកដ ពួកមនុស្សដែលដេកក្នុងខ្ទមនោះមិនប្រាកដ ប្រាកដត្រឹមតែពន្លឺភ្លើងក្នុងខ្ទមទាំង-ឡាយប៉ុណ្ណោះ យ៉ាងណា កាលព្រះតថាគតទ្រង់ឡើងកាន់ធម្មប្រាសាទ ទ្រង់ត្រួតមើលពួកសត្វ សត្វទាំងឡាយដែលមិនបានធ្វើសេចក្តីល្អ សូម្បីអង្គុយ

នៅក្បែរព្រះជានុខាងស្តាំ ក្នុងទីកន្លែងជាមួយគ្នា ក៏ដូច្នោះ មិនមកដល់គន្ធៈ នៃពុទ្ធចក្ខុ ព្រួញដែលបាញ់ទៅក្នុងវេលាយប់ តែសត្វទាំងឡាយដែលធ្វើ សេចក្តីល្អ ជាវេនេយ្យបុគ្គល សូម្បីឈរនៅឆ្ងាយពីព្រះតថាគតនោះ រមែង មកកាន់គន្ធៈបាន។ សត្វទាំងនោះ រមែងដូចជាពន្លឺភ្លើង និងដូចភ្នំហិមពាន្ត។ សមដូចដែលទ្រង់ត្រាស់ថា

ពួកសប្បុរសរមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហិមពាន្ត ដូច្នោះ ពួក អសប្បុរស (ទុកជាឋិតនៅ) ក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែល បុគ្គលបាញ់ក្នុងវេលាយប់ ដូច្នោះ។

បទថា **ឧជ្ជេហិ** *សេចក្តីថា ព្រហ្មក្រាបទូលអារាធនាដល់ការយាងចារិក ដើម្បីប្រោសសម្តែងធម៌របស់ព្រះមានព្រះភាគ។ គប្បីជ្រាបក្នុងបទថា* **វីរ** *ជាដើមថា ព្រះមានព្រះភាគព្រះនាមថាវីរៈ ព្រោះព្រះអង្គមានសេចក្តីព្យាយាម ឈ្មោះថា ជាអ្នកឈ្នះសង្គ្រាម ព្រោះព្រះអង្គទ្រង់ឈ្នះទេវបុត្តមារ មច្ចុមារ និងកិលេសមារ ឈ្មោះថា ជាអ្នកនាំពពួកជន ព្រោះព្រះអង្គទ្រង់ឆ្លងជាតិ-កន្តារជាដើមបាន គឺព្រោះព្រះអង្គអាចណែនាំ ហើយនាំពពួកជនទៅបាន ឈ្មោះថា ជាអ្នកមិនមានបំណុល ព្រោះមិនមានបំណុល គឺកាមធនៈ ដូច្នេះ។*

[๔๖] *បទថា* **អចារុតា** *គឺបើក។ បទថា* **អមតស្ស ទ្វារា** *បានដល់ អរិយមគ្គ។ ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រោះតថាគតបានបើកទ្វារ និព្វាន ពោល គឺអមតៈតាំងទុកហើយ។ បទថា* **បមុញ្চន្តុ សទ្ធំ** *សេចក្តីថា អ្នកមានសោតទាំងពួង ចូរបញ្ចេញ គឺបញ្ចេញសទ្ធារបស់ខ្លួនចុះ។ ក្នុងពីរ បទក្រោយ មានសេចក្តីថា ព្រោះថា តថាគតជាអ្នកជឿ លំបាកដោយកាយ*

និងវាចា ទើបមិនបានពោលធម៌ដ៏ប្រណីត គឺធម៌ដ៏ឧត្តមនេះ ដែលតថាគត ធ្វើឲ្យស្អាត់ជំនាញ គឺប្រព្រឹត្តទៅដោយល្អហើយ ក៏ឥឡូវនេះជនទាំងពួង ចូរ បង្អោនកាជនៈ គឺសទ្ធាចូលទៅចុះ តថាគតនឹងញ៉ាំងមនោរថរបស់ជនទាំងនោះ ឲ្យបរិបូណ៌ ដូច្នេះ ។

[៤៨-៥០] *បទថា* **ពោធិរុក្ខមូលេ** *សេចក្តីថា ព្រះមានព្រះភាគ ព្រះ នាមថាវិបស្សី បានបាត់ព្រះកាយត្រង់ដើមអជបាលនិគ្រោធ មិនឆ្ងាយអំពី ពោធិព្រឹក្ស ។ បទថា* **ខេមេ មិគទាយេ** *សេចក្តីថា ឥសិបតនមិគទាយវ័នក្នុង សម័យនេះ ក្នុងសម័យនោះជាឧទ្យាន ឈ្មោះថា* **ខេម** *សួននោះលោកឲ្យ ឈ្មោះថា* **មិគទាយវន** *ព្រោះជាទីដែលលោកឲ្យអភ័យ ដើម្បីការរស់នៅដល់ ម្រឹគទាំងឡាយ ។ លោកពោលថា* **ខេមេ មិគទាយេ** *សំដៅដល់ឧទ្យាននោះ ។ សូម្បីព្រះពុទ្ធព្រះអង្គដទៃៗ ក៏ដូចព្រះមានព្រះភាគព្រះនាមវិបស្សី យាងទៅ ដើម្បីសម្តែងធម៌ជាគ្រាដំបូង ទ្រង់បានទៅតាមអាកាស ហើយចុះក្នុងទីនោះ ដូចគ្នា ។ តែព្រះសាស្តានៃយើង ទតឃើញឧបនិស្សយរបស់ឧបកាជីវក ទ្រង់ ជ្រាបថា ឧបក:ដើរមកផ្លូវនេះ ឃើញតថាគត នឹងសន្ទនាជាមួយតថាគត ហើយទៅ តែកាលឧបក:នៀយណាយ នឹងមករកតថាគតទៀត ហើយនឹង ធ្វើឲ្យជាក់ច្បាស់នូវអរហត្តដូច្នេះ ទើបទ្រង់យាងដោយព្រះបាទទេ អស់ផ្លូវ ១៨ យោជន៍ ។*

បទថា **ឆាយចាលំ អាមន្តេសិ** *សេចក្តីថា ព្រះមានព្រះភាគទតមើល អ្នកថែរក្សាឧទ្យានមីគទាយវ័នច្រើនដង រួចហើយ គ្រាស់ហៅឲ្យចូលទៅរក គ្រាស់បង្គាប់ឲ្យទៅប្រាប់ខណ្ឌរាជបុត្រ និងតិស្សបុរោហិតបុត្រថា លោកដ៏*

ចម្រើន ព្រះតថាគតនៃយើងយាងមកហើយ ។

បទថា **អនุปุพฺพิกถំ** *សេចក្តីថា ព្រះមានព្រះភាគត្រាស់កថាតាមលំដាប់យ៉ាងនេះ គឺទានកថា សីលក្នុងលំដាប់ទាន សួគ៌ក្នុងលំដាប់សីល មគ្គក្នុងលំដាប់សួគ៌ ។ កថាបដិសំយុត្តដោយគុណរបស់ទាន មានជាដើមយ៉ាងនេះថា ក្នុងបទទាំងនោះ បទថា* **ทานกถំ** *សេចក្តីថា ឈ្មោះថា ទាននេះ ជាហេតុនៃសេចក្តីសុខទាំងឡាយ ជាប្រភពកើតនៃសម្បត្តិទាំងឡាយ ជាទីតាំងនៃភោគៈទាំងឡាយ ជាទីជ្រកកោន ជាទីអាស្រ័យ ជាគតិ ជាគ្រឿងឧបការៈរបស់អ្នកដែលដល់សេចក្តីស្ងប់វិសេស ទីពឹង ទីតាំង អារម្មណ៍ ទីជ្រកកោន ទីអាស្រ័យ គតិ ការឧបការៈដូចគ្នានឹងទាន រមែងមិនមានក្នុងលោកនេះ និងក្នុងលោកខាងមុខ ។ ពិតហើយ ទាននេះ ឈ្មោះថា ដូចសីហាសនៈសម្រេចដោយកែវ ព្រោះអត្ថថា ជាទីពឹង ឈ្មោះថា ដូចផែនដីធំ ព្រោះអត្ថថា ជាទីតាំង ឈ្មោះថា ដូចខ្សែវែត ព្រោះអត្ថថា ជាគ្រឿងតោងស្អិត ឈ្មោះថា ដូចទូក ព្រោះអត្ថថា ឆ្លងទៅចាកទុក្ខ ឈ្មោះថា ដូចភាពខ្ជាំងក្លាក្នុងសង្គ្រាម ព្រោះអត្ថថា ជាគ្រឿងលួងលោមចិត្ត ឈ្មោះថា ដូចនគរដែលតាក់តែងល្អហើយ ព្រោះអត្ថថា ការពារភ័យ ឈ្មោះថា ដូចបទុម ព្រោះអត្ថថា មិនជាប់ដោយមន្ទិល គឺសេចក្តីកំណាញ់ជាដើម ឈ្មោះថា ដូចភ្លើង ព្រោះអត្ថថា ដុតកិលេសទាំងនោះ ឈ្មោះថា ដូចអាស៊ីវិស ព្រោះអត្ថថា ចូលទៅជិតបានលំបាក ឈ្មោះថា ដូចសីហៈ ព្រោះអត្ថថា មិនតក់ស្លុត ឈ្មោះថា ដូចជ័រ ព្រោះអត្ថថា មានកម្លាំង ឈ្មោះថា ដូចគោឈ្មោលពណិស ព្រោះអត្ថថា ការយើញជាមង្គលក្រៃលែង ឈ្មោះថា ដូចស្តេចសេះវលាហកៈ ព្រោះអត្ថថា*

ឲ្យដល់កូមិកាគដែលរួចផុតភ័យ ។ ពិតហើយ ទាន រមែងឲ្យសក្តសម្បត្តិក្នុងលោក រមែងឲ្យមារសម្បត្តិ ព្រហ្មសម្បត្តិ ចក្រពត្តិសម្បត្តិ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ អភិសម្ពោធិញ្ញាណ ។ ព្រោះការឲ្យទាន ទើបអាចសមាទានសីលបាន ដូច្នោះ ទើបព្រះអង្គត្រាស់សីលកថា ក្នុងលំដាប់ទាននោះ ។ បទថា **សីលកថំ** *សេចក្តីថា កថាបដិសំយុត្តដោយគុណរបស់សីល មានជាដើមយ៉ាងនេះថា ឈ្មោះថា សីលនេះ ជាទីពឹង ជាទីតាំង ជាអារម្មណ៍ ជាគ្រឿងការពារ ជាទីអាស្រ័យ ជាគតិ ជាគ្រឿងគាំទ្រ ពិតហើយ ទីពឹង ទីតាំង អារម្មណ៍ គ្រឿងការពារ ទីអាស្រ័យ គតិ គ្រឿងឧបការៈ ដូចគ្នានឹងសីល រមែងមិនមាន ដល់សម្បត្តិក្នុងលោកនេះ និងលោកខាងមុខ គ្រឿងប្រជាប់ដូចសីល រមែងមិនមាន ផ្កា ដូចផ្កា គឺសីល រមែងមិនមាន ក្លិន ដូចក្លិនសីល រមែងមិនមាន ពិតហើយ លោក ព្រមទាំងទេវលោក សម្លឹងមើលការប្រជាប់ដោយគ្រឿងប្រជាប់ គឺសីល ការតាក់តែងដោយផ្កា គឺសីល ការលាបស្រឡាបដោយក្លិន គឺសីល រមែងមិនដល់សេចក្តីឆ្អែត ។ ដើម្បីសម្តែងថា អ្នកបានសួគ៌ ព្រោះអាស្រ័យសីលនេះ ។ ទើបព្រះអង្គត្រាស់សគ្គកថា ក្នុងលំដាប់សីល ។*

បទថា **សគ្គកថំ** *សេចក្តីថា កថាបដិសំយុត្ត ដោយសួគ៌ មានជាដើមយ៉ាងនេះថា ឈ្មោះថា សួគ៌នេះ គួរប្រាថ្នា គួរជ្រេករាយ គួរពេញចិត្ត កីឡាដែលជាទិព្វសម្បត្តិ រមែងបានក្នុងសួគ៌នេះជានិច្ច ពួកទេវតាជាន់ចាតុម្មហារាជិកា រមែងបានទិព្វសុខ និងទិព្វសម្បត្តិ រហូតដល់អស់ ៩ លានឆ្នាំ ពួកទេវតាជាន់តាវត្តិង្ស រមែងបានទិព្វសុខ និងទិព្វសម្បត្តិ រហូតដល់អស់ ៣ កោដិឆ្នាំ*

និង ๖ លានឆ្នាំ ។ ពិតហើយ កាលព្រះពុទ្ធទាំងឡាយត្រាស់ដល់សគ្គសម្បត្តិ ព្រះឱស្ឋនឹងមិនគ្រប់គ្រាន់ ។ ដូចព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីពោលនូវសគ្គកថា ដោយបរិយាយមិនមែនតិច ដូច្នេះជាដើម ។ ព្រះសាស្តាទ្រង់លួងលោម ដោយត្រាស់ដល់សូគិយ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងថា សូម្បីស្ថានសួគ៌នេះ ក៏មិនទៀង មិនយឺនយូរ មិនគួរធ្វើសេចក្តីប្រាថ្នាដោយសេចក្តីពេញចិត្តក្នុងស្ថានសួគ៌នេះ ដូចប្រជាប់ជីរហើយ កាត់ប្រមោយជីរនោះ ទើបត្រាស់ដល់ទោស សេចក្តីអាក្រក់ សេចក្តីសៅហ្មង របស់កាមទាំងឡាយ ដោយនយជាដើមថា

កាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនោះមានច្រើនពេក ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អាទីនវោ** *គឺទោស ។ បទថា* **កិការោ** *គឺអាក្រក់លាមក ។ បទថា* **សង្កិលេសោ** *សេចក្តីថា ភាពសៅហ្មង ក្នុងសង្ឃារបស់សត្វទាំងឡាយ កើតមានព្រោះកាមទាំងឡាយនោះ ។ ដូចលោកពោលថា អើហ្ន៎ ពួកសត្វសៅហ្មងណាស់ អើហ្ន៎ ពួកសត្វសៅហ្មងណាស់[1] ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់បង្ហាញទោសរបស់កាមយ៉ាងនេះហើយ ទ្រង់ប្រកាស អានិសង្សក្នុងនេក្ខម្មៈ អធិប្បាយថា ទ្រង់ប្រកាសគុណរបស់បព្វជ្ជា ។ បទដ៏សេស មានន័យដូចពោលហើយ ក្នុងអដ្ឋកថាអម្ពដ្ឋសូត្រ និងមានអត្ថងាយយល់ហើយ ។*

បទថា **អលត្ថំ** *គឺបានហើយដូចម្តេច ។ បានហើយដោយភាពជាឯហិ-*

๑- បិដកខ្មែរ អង្គុលីមាលសូត្រថា អើហ្ន៎ ពួកសត្វលំបាកណាស់ ។

កិក្ខុ ។ បានឮថា ព្រះមានព្រះភាគទ្រង់ពិចារណាមើលការសន្សំបាត្រ និងចីវរ សម្រេចដោយឫទ្ធិ ទ្រង់ឃើញការថ្វាយចីវរជាដើម ក្នុងជាតិមិនតិច របស់ពួកជនទាំងនោះ ទើបត្រាស់ពាក្យជាដើមថា អ្នកទាំងឡាយចូរជាកិក្ខុចុះ ដូច្នេះ ។ ពួកជនទាំងនោះមានសីសៈត្រងោល ស្បៀកជណ្តប់សំពត់កាសាយៈ មានកិក្ខុបរិក្ខារ ៨ ពាក់ក្នុងរាងកាយ អង្គុយថ្វាយបង្គំនមស្ការព្រះមានព្រះភាគ ដូចព្រះថេរៈមានវស្សា ២០ ។ ក្នុងបទថា **សន្ធសេ្សសិ** *ជាដើម សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងដល់ប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ។ កាលទ្រង់សម្តែងដល់ប្រយោជន៍ក្នុងលោកនេះ ទ្រង់សម្តែងថា* **អនិច្ចំ ទុក្ខំ អនត្តា** *ដូច្នេះ ទ្រង់សម្តែងខន្ធទាំងឡាយ ធាតុទាំងឡាយ អាយតនៈទាំងឡាយ បដិច្ចសមុប្បាទ កាលទ្រង់សម្តែងការកើតឡើងនៃរូបក្ខន្ធ ទ្រង់សម្តែងដល់លក្ខណៈ ៥ កាលទ្រង់សម្តែងសេចក្តីសាបសូន្យនៃវេទនាខន្ធជាដើម ក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងលក្ខណៈ ៥០ ដោយអំណាចការកើតឡើង និងការសាបសូន្យ ។ កាលទ្រង់សម្តែងដល់ប្រយោជន៍លោកខាងមុខ ទ្រង់សម្តែងដល់កំណើតនរក តិរច្ឆាន ប្រេតវិស័យ អសុរកាយ ទ្រង់សម្តែងវិបាកនៃកុសល ៣ យ៉ាង សម្បត្តិនៃទេវលោក ៦ ជាន់ ព្រហ្មលោក ៩ ជាន់ ។*

បទថា **សមាទបេសិ** *សេចក្តីថា ឲ្យកាន់យកកល្យាណធម៌ មានបារិសុទ្ធិសីល ៤ ធុតង្គ (១៣) កថាវត្ថុ ១០ ជាដើម ។*

បទថា **សមុត្តេជេសិ** *គឺឲ្យអាចហានដោយល្អ ឲ្យឧស្សាហ៍ក្រៃលែងឡើងៗ ។ ព្រះមានព្រះភាគទ្រង់ញុំាងសេចក្តីភ័យខ្លាច ឲ្យភ័យខ្លាច ប្រយោជន៍*

ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ត្រាស់ធ្វើដូចសម្រេចហើយ ។ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ធ្វើឲ្យសត្វភ័យតក់ស្លុតភ័យខ្លាចហើយ ត្រាស់ដល់ប្រយោជន៍ក្នុងលោកនេះ ដែលមានប្រភេទដូចជាកម្មករណៈ ៣២ និងមហាភ័យ ២៥ រមែងធ្វើឲ្យកើតសេចក្តីភ័យតក់ស្លុត ដូចត្រូវចងដៃក្រពាត់ទៅក្រោយយ៉ាងណែន ហើយវាយ ១០០ ដង បណ្តើរតាមផ្លូវបែកជា ៤ នាំចេញទៅតាមទ្វារខាងត្បូង ដូចជាក់សីសៈត្រង់ជ្រញ៉ូសម្រាប់សម្ងាប់ ដូចជោតដោយលំពែង និងដូចត្រូវដីរបុះប្រេងជាន់ ។ និងកាលទ្រង់ពោលដល់ប្រយោជន៍ក្នុងលោកខាងមុខ រមែងដូចជាកើតក្នុងនរកជាដើម និងដូចសោយសម្បត្តិក្នុងទេវលោក ។ បទថា **សម្បហំសេតិ** *គឺឲ្យរីករាយដោយគុណដែលខ្លួនបានហើយ អធិប្បាយថា ទ្រង់ពោលធ្វើឲ្យមានអានិសង្សច្រើន ។*

បទថា **សង្ខារានំ អាធីនវំ** *សេចក្តីថា ត្រាស់ដល់ទោសរបស់កាមទាំងឡាយ ដើម្បីសម្រេចបឋមមគ្គ ។ តែក្នុងបទនេះ ដើម្បីសម្រេចមគ្គថ្នាក់ខ្ពស់ ទើបទ្រង់ប្រកាសទោសរបស់សង្ខារទាំងឡាយ និងសភាពនៃសង្ខារទាំងឡាយលាមក និងសេចក្តីលំបាក ដែលមានសង្ខារជាបច្ច័យ ដោយនយជាដើមថា*

ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនទៀង មិនស្ថិតស្ថេរ មិនត្រេះត្រចង់ ម្នាលភិក្ខុទាំងឡាយ ក៏យ៉ាងនេះ ត្រឹមតែល្មមដើម្បីសេចក្តីនឿយណាយក្នុងសង្ខារទាំងឡាយ ត្រឹមតែល្មមដើម្បីប្រាសចាកតម្រេក ត្រឹមតែល្មមដើម្បីការរួចផុត ដូច្នេះ ។

ទ្រង់ប្រកាសអានិសង្សក្នុងនិព្វានដោយនយជាដើមថា ម្នាលភិក្ខុទាំងឡាយ

ឈ្មោះថា និព្វាននេះ មាននៅក្នុងនេក្ខម្មៈដូចគ្នា ជាធម៌ប្រណីត ជាគ្រឿងការពារ ជាទីអាស្រ័យ ដូច្នេះ ។

បទថា **មហាជនកាយោ** សេចក្តីថា ពួកមហាជន អ្នកជាឧបដ្ឋាករបស់កុមារទាំងពីរនោះឯង ។ បទថា **ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច** សេចក្តីថា ពួកជនទាំងនោះ បានពោលវាចា ពីរដង (គឺពោលដល់ព្រះពុទ្ធមួយដង ព្រះធម៌មួយដង) ជាសរណៈ ព្រោះមិនទាន់មានព្រះសង្ឃ ។ បទថា **អលត្ថំ** គឺបានហើយ ដោយភាពជាឯហិកិក្ខុ ដោយនយដែលពោលហើយក្នុងពេលមុន ។ សូម្បីក្នុងគ្រាដែលបួសហើយ ក្នុងលំដាប់អំពីនេះ ក៏មាននយនេះឯង ។

[៥១-៥២] បទថា **បរិបក្កោ ឧទបាទិ** សេចក្តីថា ការត្រិះរិះកើតឡើងក្នុងកាលណា ។ កើតឡើងកាលកន្លង ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ អំពីការត្រាស់ដឹង ។

បានឮថា ព្រះមានព្រះភាគ ទ្រង់ធ្វើការប្រោសព្រះជនកហើយ ។ ព្រះរាជាក៏ទ្រង់ត្រិះរិះថា ឱរសច្ឆរបស់អញចេញបួស បានត្រាស់ជាព្រះពុទ្ធហើយ ឱរសទីពីរបស់អញ ចេញបួសបានជាអគ្គសាវក កូនបុរោហិតបានជាទុតិយសាវក ម្យ៉ាងទៀត ភិក្ខុទាំងឡាយដ៏សេសនេះ ក្នុងកាលជាគ្រហស្ថ ក៏បានហែហមឱរសរបស់អញត្រាច់ទៅ ភិក្ខុទាំងនេះ កាលមុនជាការៈរបស់អញ សូម្បីឥឡូវនេះក៏នៅជាការៈរបស់អញនុ៎ះឯង អញនឹងទំនុកបម្រុងភិក្ខុទាំងនោះដោយបច្ច័យ ៤ អញនឹងមិនឲ្យឱកាសដល់អ្នកដទៃដូច្នេះ ។ ព្រះរាជាបង្គាប់ឲ្យសាងកំពែងធ្វើដោយឈើដើមគគីរ ទាំងពីរខាង តាំងពីខ្ងងទ្វារ

ព្រះវិហារដរាបដល់ទ្វារក្រុងរាជគ្រឹះ[1] *ជាំងដោយកន្ទេលផែង ប្រក់ដោយសំពត់ និងបិទជាំងខាងលើ ទ្រង់ឲ្យធ្វើពិតាន មានកម្រងផ្កាច្រើនប្រភេទប្រមាណប៉ុនៗ ដើមត្នោតសំយុងចុះមក វិចិត្រដោយផ្កាយមាស ខាងក្រោមទីផ្ទៃក្រាលដោយកម្រាលដែលស្អាតល្អ បង្គាប់ឲ្យរៀបចំផ្កាក្នុងលំជាប់កូន និងកូនក្នុងលំជាប់ផ្កា ដរាបពេញក្អមទឹក ក្នុងសួនផ្កា ក្នុងខាងទាំងពីរ ខាងក្នុងដើម្បីឲ្យនៅក្នុងផ្លូវ តែមួយទាំងអស់ ហើយបង្គាប់ឲ្យក្រាបទូលវេលាចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ហែហមដោយពួកភិក្ខុ យាងទៅក្រុងរាជគ្រឹះខាងក្នុងវាំងននោះឯង សោយភត្តស្រេចហើយ យាងត្រឡប់មកព្រះវិហារ ។ បុគ្គលជនៃណាមួយ រមែងមិនបានសូម្បីត្រឹមតែឃើញការថ្វាយភិក្ខាក្តី ការបូជាក្តី ការស្តាប់ធម៌ក្តី នឹងមានអំពីណាហ្ន៎ ។ អ្នកនគរគិតគ្នាថា ថ្ងៃនេះ កាលព្រះសាស្តា ទ្រង់កើតឡើងក្នុងលោកហើយ ពួកយើងមិនបានដើម្បីត្រឹមតែឃើញរអស់ ៧ ឆ្នាំ ៧ ខែ នឹងពោលទៅថ្វីដល់ការថ្វាយភិក្ខា ការបូជា ឬការស្តាប់ធម៌ ព្រះរាជាទ្រង់ស្រឡាញ់ហួងហែងថា ព្រះពុទ្ធរបស់អញ ព្រះធម៌របស់អញ ព្រះសង្ឃរបស់អញ ហើយទ្រង់ទំនុកបម្រុងត្រឹមតែមួយអង្គឯង ព្រះសាស្តាកាលទ្រង់កើតឡើង ក៏កើតឡើងដើម្បីប្រយោជន៍ដើម្បីអនុគ្រោះដល់លោក ព្រមទាំងទេវលោក ពិតហើយ នរករបស់ព្រះរាជាមិនគប្បីក្តៅរបស់ពួកអ្នកជនៃ និងប្រាកដដូចគុម្ពឧប្បលខៀវ ព្រោះដូច្នោះពួកយើងនឹងក្រាបទូលព្រះរាជា ប្រសិនបើព្រះរាជាទ្រង់មិនឲ្យព្រះសាស្តាដល់ពួកយើង ប្រសិនបើទ្រង់មិនឲ្យពួកយើង សូម្បីត្រូវច្បាំងជាមួយព្រះរាជា ក៏នឹងនាំសង្ឃទៅ ហើយធ្វើបុណ្យ មានទានជាដើម តែអ្នកនគរជាអ្នកបរិសុទ្ធគង់

១- ក្រុងពន្ធុមតីទេដឹង ។

មិនអាចធ្វើយ៉ាងនោះ ពួកយើងនឹងកាន់យកបុរសដ៏ចម្រើនណាមួយ ដូច្នេះ អ្នកនគរទាំងនោះ ចូលទៅរកសេនាបតី ប្រាប់សេចក្តីនោះដល់សេនាបតី ហើយពោលថា លោកជាបក្ខពួករបស់យើងមិនមែនឬ ឬជាបក្ខពួករបស់ព្រះរាជា ។ សេនាបតីនោះពោលថា យើងជាបក្ខពួករបស់ពួកអ្នក តែថ្ងៃដំបូងគួរឲ្យយើងមុន ថ្ងៃជាខាងក្រោយ ទើបដល់វារៈរបស់ពួកអ្នក ។ ពួកអ្នកនគរទាំងនោះទទួលពាក្យនោះ ។ សេនាបតីនោះ ចូលទៅគាល់ព្រះរាជាទូលថា បពិត្រព្រះអង្គ អ្នកនគរ គេនាំគ្នាខឹងក្រោធនឹងព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា ក្រោធរឿងអ្វី ។ សេនាបតីទូលថា បានឮថា ព្រះអង្គប៉ុណ្ណោះទ្រង់ទំនុកបម្រុងព្រះសាស្តា ពួកគេមិនបានឡើយ បើអ្នកនគរបានក្នុងឥឡូវនេះខ្លះ ពួកគេក៏នឹងមិនក្រោធ បើមិនបាន ពួកគេនឹងច្បាំងជាមួយព្រះអង្គ ។ ព្រះរាជាត្រាស់ថា នេះនែបា យើងនឹងច្បាំង យើងនឹងមិនឲ្យពួកសង្ឃ ។ សេនាបតីទូលថា បពិត្រព្រះអង្គ អ្នកនគរ ជាទាសៈរបស់ព្រះអង្គ ពួកទូលបង្គំនឹងច្បាំងជាមួយព្រះអង្គ ។ ព្រះរាជាត្រាស់ថា ពួកបាឯងនឹងចាប់អ្នកណាច្បាំង ។ បាឯងជាសេនាបតីមិនមែនឬ ។ សេនាបតីទូលថា បពិត្រព្រះអង្គ ទូលបង្គំវៀរអ្នកនគរចេញហើយ មិនអាចនឹងច្បាំងបាន ។ តអំពីនោះ ព្រះរាជាទ្រង់ជ្រាបថា អ្នកនគរមានកម្លាំងច្រើន សូម្បីសេនាបតីក៏ជាបក្ខពួកអ្នកនគរដែរ ហើយត្រាស់ថា ពួកអ្នកនគរចូរឲ្យពួកកិកូដល់យើង អស់ ៧ ឆ្នាំ ៧ ខែតទៅ ពួកអ្នកនគរមិនព្រមទទួល ព្រះរាជាទ្រង់បន្ថយមក ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ។ សូម្បីឲ្យថយយ៉ាងនេះ អ្នកនគរក៏មិនព្រមទទួល ។ ព្រះរាជាទ្រង់សូម ៧ ថ្ងៃ ។ ពួកអ្នកនគរគិតគ្នាថា ឥឡូវនេះ ពួកយើងមិនគួរបីងរីងរួស

នឹងព្រះរាជា ទើបអនុញ្ញាត ។ ព្រះរាជាទ្រង់ត្រៀមអាហារទាន ដែលព្រះអង្គ ត្រៀមទុកហើយ ដល់ ៧ ឆ្នាំ ៧ ខែ នៅសល់ត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ទ្រង់ ឲ្យទានរហូតអស់ ៦ ថ្ងៃ តែមនុស្សពួកខ្លះមិនទាន់ឃើញទាននោះ ក្នុងថ្ងៃទី ៧ ត្រាស់ហៅអ្នកនគរមកត្រាស់ថា ពួកអ្នកអាចឲ្យទានបែបនេះបានឬ ។ ពួកអ្នក នគរក៏នាំគ្នាក្រាបទូលថា ទាននោះអាស្រ័យពួកខ្ញុំព្រះអង្គនុ៎ះឯង ទើបកើតឡើង ចំពោះព្រះអង្គមិនមែនឬ ក្រាបទូលថា ពួកខ្ញុំព្រះអង្គនឹងអាច ។ ព្រះរាជាទ្រង់ ជូតព្រះអស្សុជលដោយខ្នងព្រះហស្ត ថ្វាយបង្គំព្រះមានព្រះភាគ ហើយទូល ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតហើយថា ខ្ញុំព្រះអង្គនឹងមិនធ្វើភិក្ខុ ៦ លាន ៨ សែនរូប ឲ្យជាការៈរបស់អ្នកដទៃ នឹងទំនុកបម្រុងដោយបច្ច័យ ៤ រហូតដល់អស់ជីវិត ឥឡូវនេះ ខ្ញុំព្រះអង្គអនុញ្ញាតដល់អ្នកនគរហើយ ព្រោះ អ្នកនគរនាំគ្នាក្រោធថា ពួកយើងមិនបានថ្វាយទាន តាំងពីថ្ងៃស្អែកនេះ សូម លោកម្ចាស់ទាំងឡាយ ធ្វើការអនុគ្រោះដល់អ្នកនគរទាំងនោះចុះ ។ លុះដល់ថ្ងៃ ទីពីរ សេនាបតីត្រៀមមហាទាន ហើយពោលថា ថ្ងៃនេះ ពួកលោកចូរកុំឲ្យ មិនឲ្យអ្នកដទៃណាថ្វាយ សូម្បីតែភិក្ខាបានឡើយ បានតាំងបុរសទុកដោយ ជុំវិញ ។ ក្នុងថ្ងៃនោះ ភរិយាសេដ្ឋីទ្រហឹងនិយាយចំពោះកូនស្រីថា នែកូន បើបិតារបស់កូននៅមានជីវិត ថ្ងៃនេះ ម្តាយគង់នឹងញ៉ាំងព្រះទសពលឲ្យ សោយមុន ។ កូនស្រីពោលនឹងម្តាយថា សូមម៉ែកុំគិតថ្លីឡើយ ខ្ញុំនឹងឲ្យពួក ភិក្ខុ មានព្រះពុទ្ធជាប្រធាន សោយភិក្ខារបស់ពួកយើងមុន ។ តពីនោះ ក្នុង ថាសមាសមានតម្លៃប្រមាណមួយសែន ពេញទៅដោយបាយាសមិនមានទឹក នាងបានផ្សំទឹកដោះថ្លា ទឹកឃ្មុំ ដុំស្ករត្នោតជាដើម យកថាសដទៃគ្របថាស

មាស រុំព័ទ្ធថាសនោះ ដោយកម្រងផ្កាម្ទិះ ធ្វើស្រោជៀងខ្សែក្រងផ្កា ក្នុងវេលាព្រះមានព្រះភាគយាងចូលកាន់ស្រុក នាងលើកឡើងឯង ចោមរោមដោយពួកបរិវារ ចេញអំពីផ្ទះ ។ ក្នុងចន្លោះផ្លូវ ពួកអ្នកបម្រើរបស់សេនាបតីពោលថា នែនាង នាងកុំមកតាមផ្លូវនេះ ។ ធម្មតាស្ត្រីអ្នកមានបុណ្យច្រើន រមែងមានវាចាគួរពេញចិត្ត ។ កាលអ្នកបម្រើរបស់សេនាបតីទាំងនោះ និយាយរឿយៗ ក៏មិនអាចហាមវាចារបស់នាងបាន ។ នាងពោលថា លោកពូ លោកអ៊ំ អ្នកមីង ព្រោះហេតុអ្វី ទើបពួកលោកមិនឲ្យខ្ញុំទៅ ។ អ្នកបម្រើទាំងនោះពោលថា សេនាបតីតាំងយើងទុកថា ពួកអ្នកចូរកុំឲ្យអ្នកមួយ ដទៃថ្វាយរបស់ទំពារបស់បរិភោគបាន ។ នាងពោលថា ក៏ពួកលោកឃើញរបស់ទំពា របស់បរិភោគក្នុងដៃរបស់ខ្ញុំឬ ។ អ្នកបម្រើឆ្លើយថា ពួកយើងឃើញកម្រងផ្កា ។ នាងសួរថា សេនាបតីរបស់ពួកលោកមិនឲ្យធ្វើសូម្បីការបូជាដោយកម្រងផ្កាឬ ។ អ្នកបម្រើឆ្លើយថា មិនមែនដូច្នោះទេ ឲ្យថ្វាយបាន ។ នាងពោលថា បើដូច្នោះ ពួកលោកចូរចៀសទៅចុះ ហើយចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់ទទួលកម្រងផ្កានេះចុះ ។ ព្រះមានព្រះភាគ ទ្រង់ក្រឡេកមើលអ្នកបម្រើរបស់សេនាបតីម្នាក់ ឲ្យទទួលកម្រងផ្កា ។ នាងថ្វាយបង្គំព្រះមានព្រះភាគហើយ តាំងសេចក្តីប្រាថ្នាថា កាលខ្ញុំម្ចាស់ត្រូវកើតក្នុងភពតូចភពធំ សូមកុំមានជីវិតតក់ស្លុតឡើយ សូមឲ្យខ្ញុំជាទីស្រឡាញ់ ជាទីពេញចិត្ត និងសូមឲ្យមានឈ្មោះថា សុមនាក្នុងទីដែលកើត ដូចកម្រងផ្កាម្ទិះចុះ ហើយព្រះសាស្តាត្រាស់ថា ចូរនាងមានសេចក្តីសុខចុះ ហើយនាងថ្វាយបង្គំ ធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រះមានព្រះ

ភាគទ្រង់យាងទៅផ្ទះសេនាបតី គង់ត្រង់អាសនៈដែលគេក្រាលទុក សេនាបតីកាន់បបរចូលទៅថ្វាយ ។ ព្រះសាស្តាទ្រង់បិទបាត្រ ។ សេនាបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកកិកូអង្គុយហើយ ។ ព្រះសាស្តាត្រាស់ថា ពួកតថាគតមានបិណ្ឌបាតមួយ ដែលបានក្នុងចន្លោះផ្លូវ ។ សេនាបតីនាំកម្រងផ្ការចេញ បានឃើញបិណ្ឌបាត ហើយពោលថា មាតុគ្រាមពោលនឹងខ្ញុំថា លោកនេះផ្ការទេ នាងបញ្ឆោតខ្ញុំព្រះអង្គហើយ ។ បាយាសគ្រប់គ្រាន់ដល់កិកូទាំងអស់ តាំងពីព្រះមានព្រះភាគជាដើម ។ សូម្បីសេនាបតី ក៏បានថ្វាយទេយ្យធម៌របស់ខ្លួន ។ ព្រះសាស្តាសោយភត្តាហារស្រេចហើយ ត្រាស់មង្គលហើយយាងត្រឡប់ ។ សេនាបតីសួរថា ស្ត្រីថ្វាយបិណ្ឌបាតនោះឈ្មោះអ្វី ។ អ្នកបម្រើប្រាប់ថា ជាកូនស្រីសេដ្ឋី ។ សេនាបតីគិតថា ស្រីនេះមានបញ្ញាកាលស្រីបែបនេះនៅក្នុងផ្ទះ ឈ្មោះថា សម្បត្តិ គឺសួគ៌របស់បុរសនឹងរកបានមិនលំបាក ទើបនាំស្រីនោះមកតាំងទុកក្នុងតំណែងជាបងស្រី ។ ថ្ងៃស្អែក អ្នកនគរនាំគ្នាថ្វាយទាន បានប្រារព្ធដើម្បីថ្វាយដោយឆ្ងាស់គ្នាយ៉ាងនេះ ព្រះរាជាក៏ទ្រង់ថ្វាយក្នុងថ្ងៃស្អែក ។ ព្រះរាជាទ្រង់តាំងចារបុរសទុកហើយ ទ្រង់ថ្វាយឲ្យក្រៃលែងជាងទានដែលអ្នកនគរថ្វាយ ។ សូម្បីអ្នកនគរក៏ធ្វើយ៉ាងនោះដូចគ្នា ថ្វាយក្រៃលែងជាងទានដែលព្រះរាជាទ្រង់ថ្វាយ ។ ស្រីវាំងនាំងឡាយក្នុងក្រុងរាជគ្រឹះ ពោលនឹងសាមណេរកំលោះថា លោកម្ចាស់សាមណេរទាំងឡាយ និមន្តទទួលទាន ដែលមិនបានធ្វើដោយដៃ ដែលជូតត្រង់សំពត់ជូតខ្លួនរបស់គហបតីទាំងឡាយ ហើយលាងជម្រះទឹកមាត់ និងសម្បារជាដើមរបស់កុមារតូចៗធ្វើឲ្យជាទានស្អាតប្រណីត ។ ថ្ងៃស្អែក សូម្បីអ្នកនគរទាំង-

ទ្បាយ ក៏ពោលនឹងសាមណេរកំលោះទាំងឡាយថា លោកម្ចាស់សាមណេរ ទាំងឡាយនិមន្តទទួលទាន ដែលមិនធ្វើដោយអង្ករ ទឹកដោះស្រស់ ទឹកដោះជូរ និងទឹកដោះថ្លា ដែលបានមកពីក្នុងក្រុង ក្នុងស្រុក និងនិគមជាដើម មិនបានធ្វើដោយការទម្លាយនូវស្នង ក្បាល និងខ្នងរបស់អ្នកជនៃ ហើយនាំមកថ្វាយ ធ្វើដោយទឹកដោះថ្លា និងទឹកដោះស្រស់សុទ្ធជាដើមនោះឯង ។ លុះកន្លងទៅ ๗ ឆ្នាំ ๗ ខែ និង ๗ ថ្ងៃ យ៉ាងនេះហើយ ពេលនោះ វិតក្កនេះបានកើតឡើង ដល់ព្រះមានព្រះភាគ ។ ដូចលោកពោលថា កន្លងទៅ ๗ ឆ្នាំ ๗ ខែ ๗ ថ្ងៃ អំពីថ្ងៃត្រាស់ដឹង វិតក្កបានកើតឡើងហើយ ដូច្នេះ ។ បទថា **អញ្ញតរោ មហាព្រហ្មា** *សេចក្តីថា ព្រហ្មទូលអារាធនាឲ្យទ្រង់សម្តែងព្រះធម៌ ។*

[๕๓] *បទថា* **จตุราสีติអាវาสสหสฺสานิ** *គឺវិហារ ๘๔๐๐๐ ។ វិហារទាំងអស់នោះ ជាវិហារធំទទួលកិក្ខុបានដល់ ๑ លាន ๒ សែនរូប បានដូចគ្នានឹងមហាវិហារអភយគិរី ចេតិយបព្វត និងចិត្តលបព្វត ។*

[๕๔] *បទថា* **ขฺวสฺสุ ปรมํ ตโถ** *សេចក្តីថា ខ្ញុំ គឺសេចក្តីអត់ធន់ជាគប:យ៉ាងក្រៃលែង ។ បទថា* **ตีตกฺขา** *ជាវេវចន:របស់ខន្តីនោះឯង អធិប្បាយថា អធិវាសនក្ខន្តិ ពោល គឺសេចក្តីអត់ធន់ជាគប:យ៉ាងក្រៃលែង ។ បទថា* **นิพฺพานํ ปรมំ** *សេចក្តីថា ព្រះពុទ្ធទាំងឡាយត្រាស់ថា និព្វានជាធម៌យ៉ាងក្រៃលែង ដោយអាការទាំងពួង ។ បទថា* **น หิ ปพฺพชิโต ปรูปฆาตี** *សេចក្តីថា បុគ្គលណា ចូលទៅប្រទូស្ត រុកកួន និងបៀតបៀនអ្នកជនៃ ព្រោះវៀរចាកអធិវាសនខន្តី បុគ្គលនោះមិនឈ្មោះថា ជាបព្វជិត ។ បាទទី ๔ ជាវេវចន:របស់បទនោះឯង ។ បទថា* **น สมโณ โหติ** *ជាវេវចន:របស់*

របស់បទនេះថា **ន ហិ បព្វជិតោ ។** បទថា **បរំ វហោឥយន្តោ** ជាវេវចន: របស់បទថា **បរូបឃាតី ។** ម្យ៉ាងទៀត បទថា **បរូបឃាតី** គឺទម្លាយសីល ។ ព្រោះសីល ទ្រង់ត្រាស់ថា **បរំ** ដោយអត្ថថា ខ្ពស់បំផុត អធិប្បាយថា បុគ្គលណាជាសមណ: បៀតបៀនសត្វដទៃណាមួយ ឈ្មោះថា ចូលទៅប្រទូស្តអ្នកដទៃ គឺធ្វើសីលរបស់ខ្លួនឲ្យវិនាស អ្នកនោះមិនឈ្មោះថា ជាបព្វជិត ។ ម្យ៉ាងទៀត បុគ្គលណាចូលទៅប្រទូស្តអ្នកដទៃ ព្រោះមិនមានអធិវាសនខន្តីសម្លាប់សត្វដទៃដោយហោចទៅ សូម្បីរបោម និងមូស បុគ្គលនោះមិនឈ្មោះថា ជាបព្វជិត ។ ព្រោះហេតុអ្វី ។ ព្រោះនៅវៀរមន្ទិលមិនបាន ។ ដូចដែលលោកពោលថា ព្រោះវៀរចាកមន្ទិលរបស់ខ្លួនបាន ព្រោះដូច្នោះ ទើបលោកពោលថា បព្វជិតដូច្នេះ នេះគឺលក្ខណ:របស់បព្វជិត ។

បុគ្គលណាមិនប្រទូស្ត មិនសម្លាប់ តែបៀតបៀនដោយអាជ្ញាជាដើម បុគ្គលនោះនៅបៀតបៀនអ្នកដទៃ មិនឈ្មោះថា ជាសមណ: ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនស្ងប់អំពីការបៀតបៀន ដូចលោកពោលថា បុគ្គលដែលហៅថា សមណ: ព្រោះស្ងប់រម្ងាប់នូវបាប ដូច្នេះ នេះគឺលក្ខណ: របស់សមណ: ។ គប្បីជ្រាបក្នុងគាថាទីពីរដូច្នេះ បទថា **សព្វចាបស្ស** បានដល់ អកុសល គ្រប់ប្រភេទ ។ បទថា **អការណំ** គឺមិនឲ្យកើតឡើង ។ បទថា **កុសលស្ស** បានដល់ កុសលដែលមានក្នុងភូមិ ៤ ។ បទថា **ឧបសម្បទា** គឺបានចំពោះ ។ បទថា **សចិត្តបរិយោទបនំ** គឺញ្ចុំងចិត្តរបស់ខ្លួនឲ្យភ្លឺ ។ បទនោះ រមែងបានប្រាកដ ដោយភាពជាព្រះអរហន្ត ដោយប្រការដូច្នេះ ។ បព្វជិតគួរលះបង់បាបទាំងពួង ដោយសីលសំវរ: ញ្ចុំងកុសលឲ្យដល់ព្រម

ដោយសមថៈ និងវិបស្សនាទាំងឡាយ ញុំាងចិត្តឲ្យផូរផង់ដោយអរហត្តផល នេះជាពាក្យទូន្មាន គឺជាឱវាទ គឺជាពាក្យជាសំគៀនរបស់ព្រះពុទ្ធទាំងឡាយ ។

គប្បីជ្រាបក្នុងគាថាទីបី បទថា **អនុបវាទោ** *គឺមិនចូលទៅពោលប្រទូស្តដល់បុគ្គលណាមួយដោយវាចា ។ បទថា* **អនុបឃាតោ** *គឺមិនប្រទូស្តដោយកាយ ។ បទថា* **ចាតិមោក្ខេ** *ចែកសព្ទជា* **ប អតិ មោក្ខ** *ប្រែថា ការរួចផុតទូទៅក្រៃលែង គឺសីលខ្ពស់បំផុត រមែងរក្សាដោយភាពវិសេស គឺសុគតិ និងរមែងឲ្យផុតពីភ័យ គឺទុគ្គតិ ឬរមែងរក្សាសុគតិ រមែងឲ្យផុតទុគ្គតិ ព្រោះដូច្នោះ សីលនោះទ្រង់ត្រាស់ថា* **ចាតិមោក្ខំ** *សង្រួមក្នុងបាតិមោក្ខនោះ ។*

បទថា **មត្តញ្ញុតា** *គឺដឹងប្រមាណ ដោយអំណាចការទទួល និងការបរិភោគ ។ បទថា* **បន្តញ្ច សយនាសនំ** *សេចក្តីថា វៀរការច្រៀតបៀតទីដេក និងទីអង្គុយ ។ ក្នុងបទនោះគប្បីជ្រាបថា គឺលោកពោលដល់សេចក្តីសន្តោសក្នុងបច្ច័យ ៤ ដោយបច្ច័យ ២ ប៉ុណ្ណោះ ។ បទថា* **ឯតំ พุทฺธาน สาสนំ** *សេចក្តីថា ការមិនពោលតិះដៀល មិនចូលទៅបៀតបៀនអ្នកដទៃ ការសង្រួមក្នុងបាតិមោក្ខ ភាពជាអ្នកស្គាល់ប្រមាណក្នុងការទទួល និងការបរិភោគ ការសេពសេនាសនៈដ៏ស្ងាត់ ព្រោះជាអ្នកជំនាញក្នុងសមាបត្តិ ៨ នេះជាពាក្យទូន្មាន ជាឱវាទ ជាពាក្យជាសំគៀនរបស់ព្រះពុទ្ធទាំងឡាយ ។ គប្បីជ្រាបគាថាទាំងនេះ ជាគាថាសម្តែងមាតិកាធម៌របស់ព្រះពុទ្ធទាំងឡាយ ។*

[๕๕-๕๖] ដោយហេតុមានប្រមាណប៉ុណ្ណោះ ដើម្បីទ្រង់ប្រកាសដល់ភាពដែលព្រះអង្គទ្រង់ដឹងច្បាស់ចាក់ធ្លុះនូវធម្មធាតុ ដែលទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតចាក់ធ្លុះធម្មធាតុនេះហើយ ដូច្នេះ ទើបទ្រង់ប្រកាស

ការទូលអាវជនារបស់ទេវតា ដែលលោកពោលថា ឥទ្ធ្យានេះ ទេវតាទាំង-ទ្បាយក៏បានប្រាប់សេចក្តីនុ៎ះដល់ព្រះតថាគត ដូច្នេះ ទើបត្រាស់ពាក្យជាដើមថា **ឯកមិទាហំ** *ក្នុងសម័យមួយ តថាគត ... ដូច្នេះ ដោយពោលពិស្តារតាមការប្រព្រឹត្តទៅ នៃរឿង៉ាវរបស់ព្រះមានព្រះភាគព្រះនាមថាវិបស្សីនេះ ។ ក្នុងបទទាំងនោះបទថា* **សុភវនេ** *ក្នុងព្រៃដែលមានឈ្មោះយ៉ាងនោះ ។ បទថា* **សាលរាជមូលេ** *បានដល់ គល់ឈើធំ ដែលជាស្តេចនៃឈើ ។* **កាមច្ឆន្ទំ វិរាជេត្វា** *សេចក្តីថា កម្ចាត់ដោយអំណាចដកឫសចេញ ដោយអនាគាមិមគ្គ ពួកទេវតាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរនៅក្នុងព្រះសាសនា បាននាំគ្នាក្រាបទូលដល់ព្រះពុទ្ធដ៏សេស ដូចក្រាបទូលចំពោះព្រះវិបស្សី ។ តែបាលីមកដោយអំណាចនៃព្រះវិបស្សី និងព្រះមានព្រះភាគនៃយើង ។*

ក្នុងទេវតាទាំងនោះ ទេវតាឈ្មោះថា **អវិហា** *ព្រោះមិនលះ គឺមិនសាបសូន្យអំពីសម្បត្តិរបស់ខ្លួន ។ ទេវតាឈ្មោះ* **អតប្បា** *ព្រោះមិនជុតរោលសត្វណាមួយ ។ ឈ្មោះ* **សុទស្សា** *ព្រោះមើលល្អស្អាតគួរជ្រះថ្លា ។ ឈ្មោះ* **សុទស្សី** *ព្រោះគួរមើលរបស់អ្នកបានឃើញ ។ ឈ្មោះ* **អកនិដ្ឋា** *ព្រោះជាធំដោយគុណទាំងពួង និងដោយសម្បត្តិក្នុងភព មិនមែនតិចក្នុងភពនេះ ។ គួរប្រជុំភាណវារទាំងទ្បាយទុកក្នុងទីនេះ ។ ក្នុងសូត្រនេះ លោកពោល ៣ ភាណវារ ដោយអំណាចរឿង៉ាវរបស់ព្រះមានព្រះភាគព្រះនាមថា វិបស្សី លោកពោលដោយរឿង៉ាវ របស់ព្រះសិខីជាដើម ក៏ដូចព្រះវិបស្សី ។ តែបាលីលោកពោលដោយសង្ខេប ។ ព្រះមានព្រះភាគនៃយើងត្រាស់ ២១ ភាណវារ ដោយអំណាចព្រះពុទ្ធ ៧ ព្រះអង្គ ដោយប្រការដូច្នេះ ទេវតាជាន់*

អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា ក៏ពោលយ៉ាងនោះ ។ សូម្បីទាំងអស់ក៏មាន ២៦០០ កាណាវារ ។ ព្រះសូត្រដទៃក្នុងពុទ្ធវចនៈព្រះត្រៃបិដក មិនមានចំនួន ២៦០០ កាណាវារ ។ គប្បីជ្រាបថា ព្រះសូត្រនេះឈ្មោះថា **សុតន្តរាជសូត្រ ។**

ព្រះមានព្រះភាគកាលទ្រង់កំណត់អនុសន្ធិទាំងពីរ បន្ទាប់អំពីនេះ ទើបត្រាស់ថា **ឥតិ ខោ ភិក្ខវេ** *ដូច្នេះជាដើម ។ បទទាំងអស់នោះ មានអត្ថងាយយល់ហើយនោះឯង ។*

អដ្ឋកថា មហាបទានសូត្រក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ហើយ ដោយប្រការដូច្នេះ ៗ

មហាបទានសូត្រ ចប់

សូត្រទី ๑ ចប់

สุตฺตนฺตปิฎก

มหานิทานสูตรที่ ๒

[๕๗] ข้าพเจ้าได้สดับมาอย่างนี้ ฯ สมัยหนึ่ง พระผู้มีพระภาคเจ้าประทับอยู่ในหมู่บ้านของชาวกุรุ ในแคว้นกุรุชนบท ฯ ครั้งนั้นแล ท่านพระอานนท์เข้าไปเฝ้าพระผู้มีพระภาคเจ้าถึงที่ประทับ ครั้นแล้วได้ถวายบังคมพระผู้มีพระภาคเจ้า แล้วนั่งในที่สมควร ฯ ครั้นท่านพระอานนท์นั่งในที่สมควรแล้ว ได้กราบทูลพระผู้มีพระภาคเจ้าดังนี้ว่า ข้าแต่พระองค์ผู้เจริญ อัศจรรย์จริงหนอ ข้าแต่พระองค์ผู้เจริญ น่าพิศวงจริงหนอ ปฏิจจสมุปบาทนี้ลึกซึ้งด้วย มีความลึกซึ้งปรากฏด้วย แต่ข้าพระองค์ย่อมเห็นปฏิจจสมุปบาทนี้ชัดเจนเหมือนความเป็นผู้ไม่ลึกซึ้งเลย ฯ พระผู้มีพระภาคเจ้าตรัสว่า ดูก่อนอานนท์ เธออย่ากล่าวอย่างนี้เลย ดูก่อนอานนท์ เธออย่ากล่าวอย่างนี้เลย ปฏิจจสมุปบาทนี้ลึกซึ้งด้วย มีความลึกซึ้งปรากฏด้วย ฯ ดูก่อนอานนท์ เพราะไม่รู้ ไม่แทงตลอด ไม่ถูกต้องธรรมนี้ ไม่ได้ตรัสรู้ ไม่ได้ตรัสรู้ตาม หมู่สัตว์นี้จึงเป็นเหมือนปอสาวที่ยุ่งเหยิง เหมือนด้ายที่ยุ่งเหยิง เหมือนหญ้าปล้องและหญ้ามุงกระต่ายที่ยุ่งเหยิง ย่อมไม่ล่วงพ้นอบาย ทุคติ วินิบาต สังสารวัฏไปได้ ฯ ดูก่อนอานนท์ เมื่อมีคนถามว่า ชรา มรณะมีเพราะเหตุอะไรเป็นปัจจัย ชรา มรณะมีเพราะเหตุนี้เป็นปัจจัย ฯ เมื่อถูกถามอย่างนี้ ควรตอบว่า ชรา มรณะมีเพราะชาติเป็นปัจจัย ฯ เมื่อถูกถามต่อไปว่า

ជរា និងមរណៈកើតមានព្រោះអ្វីជាបច្ច័យ គប្បីព្រាប់គេថា ជរា និងមរណៈ កើតមានព្រោះជាតិជាបច្ច័យ ។ ម្នាលអានន្ទ កាលបើមានគេសួរថា ជាតិ កើតមានព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីព្រាប់គេថា មាន ។ បើគេ សួរទៀតថា ជាតិកើតមានព្រោះអ្វីជាបច្ច័យ គប្បីព្រាប់គេថា ជាតិកើតមាន ព្រោះភពជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា ភពកើតមានព្រោះធម៌ នេះជាបច្ច័យមានដែរឬ គប្បីព្រាប់គេថា មាន ។ បើគេសួរទៀតថា ភពកើត មានព្រោះអ្វីជាបច្ច័យ គប្បីព្រាប់គេថា ភពកើតមានព្រោះឧបាទានជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា ឧបាទានកើតមានព្រោះធម៌នេះជាបច្ច័យមាន ដែរឬ គប្បីព្រាប់គេថា មាន ។ បើគេសួរទៀតថា ឧបាទានកើតមានព្រោះអ្វី ជាបច្ច័យ គប្បីព្រាប់គេថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ។ ម្នាល អានន្ទ បើមានគេសួរថា តណ្ហាកើតមានព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីព្រាប់គេថា មាន ។ បើគេសួរទៀតថា តណ្ហាកើតមានព្រោះអ្វីជាបច្ច័យ គប្បីព្រាប់ថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ។ ម្នាលអានន្ទ បើមាន គេសួរថា វេទនាកើតមាន ព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីព្រាប់គេ ថា មាន ។ បើគេសួរទៀតថា វេទនាកើតមានព្រោះអ្វីជាបច្ច័យ គប្បីព្រាប់គេ ថា វេទនាកើតមានព្រោះផស្សៈជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា ផស្សៈកើតមាន ព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីព្រាប់គេថា មាន ។ បើគេសួរទៀតថា ផស្សៈកើតមានព្រោះអ្វីជាបច្ច័យ គប្បីព្រាប់គេថា ផស្សៈ កើតមានព្រោះនាមរូបជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា នាមរូប

កើតមានព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា នាមរូបកើតមានព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ។ ម្នាលអានន្ទ បើមានគេសួរថា វិញ្ញាណកើតមានព្រោះធម៌នេះជាបច្ច័យ មានដែរឬ គប្បីប្រាប់គេថា មាន ។ បើគេសួរទៀតថា វិញ្ញាណកើតមាន ព្រោះអ្វីជាបច្ច័យ គប្បីប្រាប់គេថា វិញ្ញាណកើតមានព្រោះនាមរូបជាបច្ច័យ ។ ម្នាលអានន្ទ វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈកើតមាន ព្រោះនាមរូបជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតមានព្រម ដោយប្រការដូច្នេះឯង ។ កងទុក្ខទាំងអស់នេះ រមែងកើតឡើងយ៉ាងនេះ ។

[๕๘] *ពាក្យថា ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ច័យនេះ ពិតជាតថាគតសម្តែងហើយដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតត្រូវដឹងតាមទំនងដែលជរាមរណៈកើតមានព្រោះជាតិជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើជាតិមិនមានដល់សត្វណាមួយ ក្នុងភពណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួងហើយ គឺថា ជាតិមិនមានដល់ពួកទេវតា ដើម្បីភាវៈជាទេវតាក្តី ដល់ពួកគន្ធព្វ ដើម្បី*

ភាវៈជាគន្ធព្វក្តី ដល់ពួកយក្ស ដើម្បីភាវៈជាយក្សក្តី ដល់ពួកភូត ដើម្បីភាវៈជាភូតក្តី ដល់ពួកមនុស្ស ដើម្បីភាវៈជាមនុស្សក្តី ដល់ពួកសត្វជើងបួន ដើម្បីភាវៈជាសត្វជើងបួនក្តី ដល់ពួកសត្វស្លាប ដើម្បីភាវៈជាសត្វស្លាបក្តី ដល់ពួកសត្វលូនវារ ដើម្បីភាវៈជាសត្វលូនវារក្តី ។ ម្នាលអានន្ទ ជាតិមិនមានដល់សត្វនោះៗ ដោយប្រការដូច្នោះឯង ។ កាលបើជាតិមិនមានដោយប្រការទាំងពួង ព្រោះជាតិរលត់ហើយ បើដូច្នេះ តើជរាមរណៈគប្បីមានប្រាកដដែរឬ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ជាតិនេះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃជរាមរណៈ ។ ពាក្យថា ជាតិកើតមាន ព្រោះភពជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតត្រូវដឹងតាមទំនង ដែលជាតិកើតមាន ព្រោះភពជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើភពមិនមានហើយដល់សត្វណាមួយ ក្នុងភពណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង គឺកាមភព ១ រូបភព ១ អរូបភព ១ ។ កាលបើភពមិនមាន ដោយប្រការទាំងពួង ព្រោះភពរលត់ហើយ បើដូច្នេះ តើជាតិគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ភពនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យ នៃជាតិ ។ ពាក្យថា ភពកើតមានព្រោះឧបាទានជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ

ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតត្រូវដឹងតាមទំនងដែលភពកើតមាន ព្រោះ ឧបាទានជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើឧបាទានមិនមាន ហើយ ដល់សត្វណាមួយ ក្នុងភពណាៗ ដោយអាការទាំងពួង ដោយ សភាវៈទាំងពួង គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្ត-វាទុបាទាន ១ ។ កាលបើឧបាទានមិនមាន ដោយប្រការទាំងពួង ព្រោះ ឧបាទានរលត់ហើយ បើដូច្នេះ តើភពគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះ អង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ឧបាទាននេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃភព ។ ពាក្យ ថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែង ហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិត ត្រូវដឹងតាមទំនងដែលឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យនេះចុះ ។ ម្នាល អានន្ទ សេចក្តីពិតថា បើតណ្ហាមិនមានហើយដល់សត្វណាមួយ ក្នុងភព ណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង គឺរូបតណ្ហា ១ សទ្ទ-តណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ។ កាលបើតណ្ហាមិនមានដោយប្រការទាំងពួង ព្រោះតណ្ហារលត់ហើយ បើ ដូច្នេះ តើឧបាទានគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុ នុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង តណ្ហានេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃឧបាទាន ។ ពាក្យថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ នេះប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។

ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតត្រូវដឹងតាមទំនងដែលតណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើវេទនាមិនមានហើយ ដល់សត្វណាមួយ ក្នុងកពណាៗ ដោយអាការទាំងពួង ដោយសការៈទាំងពួង គឺវេទនាកើតអំពីចក្ខុសម្ផស្ស ១ វេទនាកើតអំពីសោតសម្ផស្ស ១ វេទនាកើតអំពីឃានសម្ផស្ស ១ វេទនាកើតអំពីជិវ្ហាសម្ផស្ស ១ វេទនាកើតអំពីកាយសម្ផស្ស ១ វេទនាកើតអំពីមនោសម្ផស្ស ១ ។ កាលបើវេទនាមិនមានដោយប្រការទាំងពួង ព្រោះវេទនារលត់ហើយ បើដូច្នេះ តើតណ្ហាគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង វេទនានេះ ទើបជាហេតុជានិទាន ជាសមុទ័យ ជាបច្ច័យនៃតណ្ហា ។

[๕๙] ម្នាលអានន្ទ តណ្ហាកើតមាន ព្រោះអាស្រ័យវេទនា ការស្វែងរកកើតមាន ព្រោះអាស្រ័យតណ្ហា លាភកើតមានព្រោះអាស្រ័យការស្វែងរក វិនិច្ឆ័យ គឺសេចក្តីត្រិះរិះកើតមានព្រោះអាស្រ័យលាភ ឆន្ទរាគៈគឺសេចក្តីប្រាថ្នាជ្រះថ្លាកើតមានព្រោះអាស្រ័យវិនិច្ឆ័យ សេចក្តីចូលចិត្តមាំកើតមានព្រោះអាស្រ័យឆន្ទរាគៈ សេចក្តីហួងហែងកើតមាន ព្រោះអាស្រ័យសេចក្តីប្រកាន់មាំ សេចក្តីកំណាញ់កើតមានព្រោះអាស្រ័យសេចក្តីហួងហែង ការរក្សាមាំកើតមាន ព្រោះអាស្រ័យសេចក្តីកំណាញ់ អកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះទាស់ទែងវិវាទ ពាក្យថា ឯងមិនដឹង ពាក្យញុះញង់ ពាក្យកុហក កើតមានព្រោះអាស្រ័យការរក្សាមាំ គឺថា

มានការរក្សាមាំ ជាហេតុ ពាក្យនេះជ្រាកដជាតថាគតសម្តែងហើយ ដោយ ប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតគួរដឹងតាម ទំនងដែលអកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះទាស់ទែងវិវាទ ពាក្យថា ឯង មឹង ពាក្យញុះញង់ ពាក្យកុហក រមែងកើតមានព្រោះការរក្សាមាំជាហេតុនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការរក្សាមាំមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណាៗ ដោយអាការទាំងពួង ដោយសការៈទាំងពួង ។ កាលបើការរក្សាមាំ មិនមានដោយប្រការទាំងពួង ព្រោះការរក្សាមាំរលត់ហើយ បើដូច្នេះ តើអកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ការឈ្លោះទាស់ទែងវិវាទ ពាក្យថា ឯង មឹង ពាក្យញុះញង់ ពាក្យកុហក គប្បីកើតមានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះ ការរក្សាមាំនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃកិរិយាកើតមាននៃអកុសលធម៌ដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសាស្ត្រាវុធ ការឈ្លោះទាស់ទែង វិវាទ ពាក្យថា ឯង មឹង ពាក្យញុះញង់ ពាក្យកុហក ។ ពាក្យថា ការរក្សាមាំកើតមាន ព្រោះអាស្រ័យសេចក្តីកំណាញ់នេះ ជ្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលការរក្សាមាំកើតមានព្រោះអាស្រ័យសេចក្តីកំណាញ់នេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើសេចក្តីកំណាញ់មិនមានហើយ ដល់សត្វណាមួយ ក្នុងភពណាៗ

ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើសេចក្តីកំណាញ់មិនមានដោយប្រការទាំងពួង ព្រោះសេចក្តីកំណាញ់រលត់ហើយ បើដូច្នេះ តើការរក្សាមាំ គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង សេចក្តីកំណាញ់នេះ ទើបជាហេតុជានិទាន ជាសមុទ័យ ជាបច្ចុយនៃការរក្សាមាំ ។ ពាក្យថា សេចក្តីកំណាញ់កើតមាន ព្រោះអាស្រ័យការហួងហែងនេះ ប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលសេចក្តីកំណាញ់កើតមាន ព្រោះអាស្រ័យការហួងហែងនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការហួងហែងមិនមានហើយដល់សត្វណាមួយក្នុងភពណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួងទេ ។ កាលបើការហួងហែងមិនមាន ដោយប្រការទាំងពួង ព្រោះការហួងហែងរលត់ហើយ បើដូច្នេះ តើសេចក្តីកំណាញ់ គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ការហួងហែងនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ចុយនៃសេចក្តីកំណាញ់ ។ ពាក្យថា សេចក្តីហួងហែងកើតមាន ព្រោះអាស្រ័យសេចក្តីប្រកាន់មាំនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនង ដែលការហួងហែងកើតមានព្រោះអាស្រ័យសេចក្តីប្រកាន់មាំនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើសេចក្តីប្រកាន់មាំមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណាៗ ដោយ

អាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើសេចក្តីប្រកាន់មាំមិនមាន ដោយប្រការទាំងពួង ព្រោះសេចក្តីប្រកាន់មាំរលត់ហើយ បើដូច្នេះ តើការហួងហែងគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង សេចក្តីប្រកាន់មាំនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃការហួងហែង ។ ពាក្យថា សេចក្តីប្រកាន់មាំកើតមាន ព្រោះអាស្រ័យឆន្ទរាគៈនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរជឿតាមទំនងដែលសេចក្តីប្រកាន់មាំកើតមាន ព្រោះអាស្រ័យឆន្ទរាគៈនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើឆន្ទរាគៈមិនមានហើយ ដល់សត្វណាមួយ ក្នុងកពណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើឆន្ទរាគៈមិនមានដោយប្រការទាំងពួង ព្រោះឆន្ទរាគៈរលត់ហើយ បើដូច្នេះ តើសេចក្តីប្រកាន់មាំគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ឆន្ទរាគៈនេះ ទើបជាហេតុជានិទាន ជាសមុទ័យ ជាបច្ច័យនៃសេចក្តីប្រកាន់មាំ ។ ពាក្យថា ឆន្ទរាគៈកើតមាន ព្រោះអាស្រ័យការវិនិច្ឆ័យនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតត្រូវជឿតាមទំនងដែលឆន្ទរាគៈកើតមាន ព្រោះអាស្រ័យការវិនិច្ឆ័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការវិនិច្ឆ័យមិនមានហើយ ដល់សត្វណាមួយ ក្នុងកពណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ។ កាលបើការ

วิនิច្ឆ័យមិនមានដោយប្រការទាំងពួង ព្រោះការវិនិច្ឆ័យរលត់ហើយ បើដូច្នេះ តើឆន្ទរាគៈគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ការវិនិច្ឆ័យនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃឆន្ទរាគៈ ។ ពាក្យថា ការវិនិច្ឆ័យកើតមាន ព្រោះអាស្រ័យលាកនេះ ប្រាកដជាតថាគតសម្តែង ហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលការវិនិច្ឆ័យកើតមាន ព្រោះលាកនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើលាកមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណាៗ ដោយអាការទាំងពួង ដោយសការៈទាំងពួង ។ កាលបើលាកមិនមាន ដោយប្រការទាំងពួង ព្រោះលាករលត់ហើយ បើដូច្នេះ តើការវិនិច្ឆ័យគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង លាកនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃការវិនិច្ឆ័យ ។ ពាក្យថា លាកកើតមាន ព្រោះអាស្រ័យការស្វែងរកនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលលាកកើតមាន ព្រោះអាស្រ័យការស្វែងរកនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើការស្វែងរកមិនមានហើយ ដល់សត្វណាមួយ ក្នុងភពណាៗ ដោយអាការទាំងពួង ដោយសការៈទាំងពួង ។ កាលបើការស្វែងរកមិនមានដោយប្រការទាំងពួង ព្រោះការស្វែងរករលត់ហើយ បើដូច្នេះ តើលាភគប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន

ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ការស្វែងរកនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃលាភ ។ ពាក្យថា ការស្វែងរកកើតមាន ព្រោះអាស្រ័យតណ្ហា នេះជ្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលការស្វែងរកកើតមាន ព្រោះអាស្រ័យតណ្ហានេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើតណ្ហាមិនមានហើយជាប់សត្វណាមួយ ក្នុងភពណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង តណ្ហានោះ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ កាលបើតណ្ហាមិនមានដោយប្រការទាំងពួង ព្រោះតណ្ហារលត់ហើយ បើដូច្នេះ តើការស្វែងរកគប្បីមានជ្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមាន ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង តណ្ហានេះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃការស្វែងរក ។

[๖๐] ម្នាលអានន្ទ ធម៌ ២ យ៉ាង (វដ្តមូលតណ្ហា ១ សមុទាចារតណ្ហា ១) នេះ ទុកជាមានចំណែក ២ ដូច្នោះ មានទីប្រជុំដោយបច្ច័យតែ ១ ដោយវេទនាជាបច្ច័យ ដោយប្រការដូច្នេះឯង ។ ពាក្យថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យនេះ ជ្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតគួរដឹងតាមទំនងដែលវេទនាកើតមាន ព្រោះផស្សៈជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើផស្សៈមិនមានហើយ ជាប់សត្វណាមួយក្នុងភពណាៗ ដោយអាការទាំងពួង ដោយសភាវៈទាំងពួង ផស្សៈនោះ គឺចក្ខុសម្ផស្ស ១ សោតសម្ផស្ស ១ ឃាន-

สมฺผสฺส ๑ ชิวฺหาสมฺผสฺส ๑ กายสมฺผสฺส ๑ มโนสมฺผสฺส ๑ ฯ กาล
បើផស្សៈមិនមានដោយប្រការទាំងពួង ព្រោះផស្សៈរលត់ហើយ បើដូច្នេះ
តើវេទនាគប្បីមានប្រាកដដែរឬ ฯ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមាន
ទេ ฯ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ផស្សៈនេះ ទើបជាហេតុ ជានិទាន
ជាសមុទ័យ ជាបច្ចัយនៃវេទនា ฯ ពាក្យថា ផស្សៈកើតមានព្រោះនាមរូបជា
បច្ចัយនេះ ប្រាកដជាតថាគតសម្តែងហើយដោយប្រការដូច្នេះ ฯ ម្នាលអានន្ទ
ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលផស្សៈកើតមាន ព្រោះ
នាមរូបជាបច្ចัយនេះចុះ ฯ ម្នាលអានន្ទ បញ្ញត្តិនៃនាមកាយកើតឡើងដោយ
អាការណា ដោយលិង្គណា ដោយនិមិត្តណា ដោយឧទ្ទេសណា កាលបើ
អាការនោះ លិង្គនោះ និមិត្តនោះ ឧទ្ទេសនោះ មិនមានហើយ បើដូច្នេះ តើ
អធិវចនសมฺผสฺส គឺមនោសម្ផស្ស គប្បីមានប្រាកដក្នុងរូបកាយដែរឬ ฯ
បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ฯ ម្នាលអានន្ទ បញ្ញត្តិនៃរូបកាយ
តែងកើតឡើងដោយអាការណា ដោយលិង្គណា ដោយនិមិត្តណា ដោយ
ឧទ្ទេសណា កាលបើអាការនោះ លិង្គនោះ និមិត្តនោះ ឧទ្ទេសនោះ មិនមាន
ហើយ បើដូច្នេះ តើបដិឃសម្ផស្ស គឺសម្ផស្សដែលកើតឡើងព្រោះធ្វើរូបក្ខន្ធ
ដែលប្រកបដោយសេចក្តីថ្នាំងថ្នាក់ ឲ្យជាទីនៅក្នុងនាមកាយ គប្បីមានប្រាកដ
ដែរឬ ฯ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ฯ ម្នាលអានន្ទ បញ្ញត្តិ
នៃនាមកាយ និងរូបកាយ តែងមានដោយអាការណា ដោយលិង្គណា ដោយ
និមិត្តណា ដោយឧទ្ទេសណា កាលបើអាការនោះ លិង្គនោះ និមិត្តនោះ

ឧទ្ទេសនោះ មិនមានហើយ បើដូច្នេះ តើអធិវចនសម្ផស្ស ឬបដិឃសម្ផស្ស គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ បញ្ញត្តិនៃនាមរូបតែងមានដោយអាការណា ដោយលិង្គណា ដោយនិមិត្តណា ដោយឧទ្ទេសណា កាលបើអាការនោះ លិង្គនោះ និមិត្តនោះ ឧទ្ទេសនោះ មិនមានហើយ បើដូច្នេះ តើផស្ស:គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង នាមរូបនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃផស្ស: ។ ពាក្យថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយអាការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះបណ្ឌិតគួរដឹងតាមទំនងដែលនាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ សេចក្តីពិតថា បើវិញ្ញាណនឹងមិនចុះស៊ប់ គឺមិនប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិក្នុងផ្ទៃនៃមាតាហើយ បើដូច្នេះ តើនាមរូបនឹងជាច់សូន្យទៅក្នុងផ្ទៃនៃមាតាបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ចុះបើវិញ្ញាណចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតា ហើយរលត់ទៅវិញ នាមរូបនឹងកើតចំពោះក្នុងការ:នៃបញ្ចក្ខន្ធ ដែលបរិបូណ៌នេះបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ចុះបើវិញ្ញាណរបស់មនុស្សក្មេង គឺក្មេងប្រុស ឬក្មេងស្រីរលត់ទៅដោយអំណាចចុតិ នាមរូបនឹងដល់នូវសេចក្តីចម្រើនដុះដាលធំធាត់ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុនោះ វិញ្ញាណនេះ ទើបជាហេតុ

ជានិទាន ជាសមុទ័យ ជាបច្ចយនៃនាមរូប ។ ពាក្យថា វិញ្ញាណកើតមាន ព្រោះនាមរូបជាបច្ច័យនេះ ប្រាកដជាតថាគតសម្តែងហើយ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ព្រោះហេតុនោះ ពាក្យនុ៎ះ បណ្ឌិតគួរដឹងតាមទំនងដែលវិញ្ញាណកើតមានព្រោះនាមរូបជាបច្ច័យនេះចុះ ។ ម្នាលអានន្ទ ចុះបើវិញ្ញាណមិនបានទីតម្កល់ក្នុងនាមរូបហើយ កិរិយាកើតឡើងនៃគំនរបស់ទុក្ខ គឺជាតិ ជរា និង មរណៈ គប្បីមានប្រាកដដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នេះ នាមរូបនេះ ទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃវិញ្ញាណ ។ ម្នាលអានន្ទ នាមរូបគប្បីកើតចាស់ស្ងាប់ ឬច្យុត ឬចាប់បដិសន្ធិ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។គន្ធងនៃឈ្មោះក្តី គន្ធងនៃភាសាក្តី គន្ធងនៃបញ្ញត្តិក្តី ហេតុដែលគួរដឹងដោយបញ្ញត្តិក្តី វដ្ដៈក្តី រមែងប្រព្រឹត្តទៅដោយហេតុមានប្រមាណប៉ុណ្ណោះ។ ឯង ។ ខន្ធបញ្ចកៈរមែងប្រាកដដោយការបញ្ញត្តនូវឈ្មោះ (មានវេទនា និងសញ្ញាជាដើម) នាមរូបនេះ រមែងប្រព្រឹត្តទៅជាមួយនឹងវិញ្ញាណ ។

[๖๑] ម្នាលអានន្ទ ចុះបុគ្គលកាលបញ្ញត្តខ្លួន តែងបញ្ញត្តដោយហេតុមានប៉ុន្មានប្រការ ។ ម្នាលអានន្ទ ក៏បុគ្គលកាលបញ្ញត្តខ្លួនដែលមានរូប និងមានប្រមាណតិចថា ខ្លួនរបស់អញមានរូប និងមានប្រមាណតិចក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមានរូប និងមិនមានទីបំផុតថា ខ្លួនរបស់អញមានរូប និងមិនមានទីបំផុតក៏មាន ។ ម្នាលអានន្ទ ក៏បុគ្គលកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូប និងមាន

ប្រមាណតិចថា ខ្លួនរបស់អញមិនមានរូប និងមានប្រមាណតិចក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលបញ្ចុតខ្លួន តែងបញ្ចុតខ្លួនដែលមិនមានរូប និងមិនមានទីបំផុតថា ខ្លួនរបស់អញមិនមានរូប និងមិនមានទីបំផុតក៏មាន ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ ពួកនោះ បុគ្គលណា កាលបញ្ចុតខ្លួន តែងបញ្ចុតខ្លួនដែលមានរូប និងមានប្រមាណតិច បុគ្គលនោះ កាលបញ្ចុតខ្លួន តែងបញ្ចុតខ្លួនដែលមានរូប និងមានប្រមាណតិច ក្នុងកាលឥឡូវនេះក្តី បុគ្គលនោះកាលនឹងបញ្ចុតខ្លួន តែងបញ្ចុតខ្លួនដែលមានរូប និងមានប្រមាណតិច ដែលកើតក្នុងលោកជ្រួចក្តី ឬក៏បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេចឬបំបែរឲ្យជាសភាវៈដែលពិតទៅវិញក្តី ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមានរូបថា មានបរិត្តគ្គានុទិដ្ឋិ (សេចក្តីយល់ឃើញថាខ្លួនមានប្រមាណតិច) ដោកនៅមិនជាច់ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ នោះ បុគ្គលណាកាលបញ្ចុតខ្លួន តែងបញ្ចុតខ្លួនដែលមានរូប និងមិនមានទីបំផុត បុគ្គលនោះ កាលបញ្ចុតខ្លួន តែងបញ្ចុតខ្លួនដែលមានរូប និងមិនមានទីបំផុត ក្នុងកាលឥឡូវនេះក្តី បុគ្គលនោះកាលបញ្ចុតខ្លួន តែងបញ្ចុតខ្លួនដែលមានរូប និងមិនមានទីបំផុត ដែលកើតនៅក្នុងលោកជ្រួចក្តី ឬក៏បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិតថា អាត្មាអញ នឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមានរូបថា មាន

អនន្តត្តានុទិដ្ឋិ (សេចក្តីយល់ឃើញថាខ្លួនមិនមានទីបំផុត) ដេកនៅមិនដាច់ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ ពួកនោះ បុគ្គលណាកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូប និងមានប្រមាណតិច បុគ្គលនោះកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូប និងមានប្រមាណតិច ក្នុងកាលឥឡូវនេះក្តី បុគ្គលនោះកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូប និងមានប្រមាណតិច ដែលកើតក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមិនមានរូបថា មានបរិត្តត្តានុទិដ្ឋិ ដេកនៅមិនដាច់ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៤ ពួកនោះ បុគ្គលណាកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូប និងមិនមានទីបំផុត បុគ្គលនោះកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូប និងមិនមានទីបំផុតក្នុងកាលឥឡូវនេះក្តី បុគ្គលនោះកាលបញ្ញត្តខ្លួន តែងបញ្ញត្តខ្លួនដែលមិនមានរូប និងមិនមានទីបំផុត ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គល ដែលមិនមានរូបថា មានអនន្តត្តានុទិដ្ឋិដេកនៅមិនដាច់ ។ ម្នាលអានន្ទ បុគ្គលកាលបញ្ញត្តខ្លួន តែងបញ្ញត្តដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

[៦២] *ម្នាលអានន្ទ ចុះបុគ្គលកាលមិនបញ្ចត្តខ្លួន តែងមិនបញ្ចត្ត ដោយហេតុមានប៉ុន្មានប្រការ ។ ម្នាលអានន្ទ បុគ្គលកាលមិនបញ្ចត្តខ្លួន តែង មិនបញ្ចត្តខ្លួនដែលមានរូប និងមានប្រមាណតិចថា ខ្លួនរបស់អញមានរូប និង មានប្រមាណតិចក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលមិនបញ្ចត្តខ្លួន តែងមិនបញ្ចត្តខ្លួនដែលមានរូប និងមិនមានទីបំផុតថា ខ្លួនរបស់អញមានរូប និង មិនមានទីបំផុតក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលមិនបញ្ចត្តខ្លួន តែងមិនបញ្ចត្តខ្លួនដែលមិនមានរូប និងមានប្រមាណតិចថា ខ្លួនរបស់អញ មិនមានរូប និងមានប្រមាណតិចក៏មាន ។ ម្នាលអានន្ទ ឬក៏បុគ្គលកាលមិន បញ្ចត្តខ្លួន តែងមិនបញ្ចត្តខ្លួនដែលមិនមានរូប និងមិនមានទីបំផុតថា ខ្លួន របស់អញមិនមានរូប និងមិនមានទីបំផុតក៏មាន ។ ម្នាលអានន្ទ បណ្តា បុគ្គលទាំង ៤ ពួកនោះ បុគ្គលណាកាលមិនបញ្ចត្តខ្លួន តែងមិនបញ្ចត្តខ្លួន ដែលមានរូប និងមានប្រមាណតិច បុគ្គលនោះកាលមិនបញ្ចត្តខ្លួន តែងមិន បញ្ចត្តខ្លួនដែលមានរូប និងមានប្រមាណតិចក្នុងកាលឥឡូវនេះក្តី បុគ្គលនោះ កាលមិនបញ្ចត្តខ្លួន តែងមិនបញ្ចត្តខ្លួនដែលមានរូប និងមានប្រមាណតិច ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅ វិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវ បុគ្គលដែលមានរូបថា បរិត្តត្តានុទិដ្ឋិមិនដេកនៅរឿយៗ ទេ ។ ម្នាលអានន្ទ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាកាលមិនបញ្ចត្តខ្លួន តែងមិនបញ្ចត្ត*

ខ្លួនដែលមានរូប និងមិនមានទីបំផុត បុគ្គលនោះកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមានរូប និងមិនមានទីបំផុតក្នុងកាលឥឡូវនេះក្តី ឬបុគ្គលនោះកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមានរូប និងមិនមានទីបំផុតដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះ មិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមានរូបថា អនន្តត្តានុទិដ្ឋិមិនដេកនៅរឿយៗ ទេ ។ ម្នាលអានន្ទ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមិនមានរូប និងមានប្រមាណតិច បុគ្គលនោះកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមិនមានរូប និងមានប្រមាណតិច ក្នុងកាលឥឡូវនេះក្តី ឬបុគ្គលនោះកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមិនមានរូប និងមានប្រមាណតិច ដែលកើតនៅក្នុងលោកដូច្នេះក្តី ឬក៏បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមិនមានរូបថា បរិត្តត្តានុទិដ្ឋិមិនដេកនៅរឿយៗ ទេ ។ ម្នាលអានន្ទ បណ្តាបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមិនមានរូប និងមិនមានទីបំផុត បុគ្គលនោះកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមិនមានរូប និងមិនមានទីបំផុតក្នុងកាលឥឡូវនេះក្តី ឬបុគ្គលនោះកាលមិនបញ្ចាត្តខ្លួន តែងមិនបញ្ចាត្តខ្លួនដែលមិនមាន

រូប និងមិនមានទីបំផុត ដែលកើតនៅក្នុងលោកដូច្នោះក្តី ឬក៏បុគ្គលនោះមិនមានសេចក្តីត្រិះរិះដូច្នេះថា សភាវៈដែលមិនពិត អាត្មាអញនឹងសម្រេច ឬបំបែរឲ្យជាសភាវៈពិតទៅវិញក្តី ។ ម្នាលអានន្ទ កាលបើហេតុយ៉ាងនេះមានហើយ គួរនឹងពោលនូវបុគ្គលដែលមិនមានរូបថា អនន្តត្តានុទិដ្ឋិមិនដេកនៅរឿយៗ ទេ ។ ម្នាលអានន្ទ បុគ្គលកាលមិនបញ្ញត្តខ្លួន តែងមិនបញ្ញត្តដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

[៦៣] *ម្នាលអានន្ទ បុគ្គលកាលពិចារណានូវខ្លួន តែងពិចារណាដោយហេតុមានប៉ុន្មានប្រការ ។ ម្នាលអានន្ទ បុគ្គលកាលពិចារណានូវខ្លួន តែងពិចារណាខ្លួនដែលមានវេទនាថា វេទនាជាខ្លួនរបស់អញក៏មាន ថាវេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញមិនបានទទួលអារម្មណ៍ក៏មាន ។ ថាវេទនាមិនមែនជាខ្លួនរបស់អញ ព្រោះថា ខ្លួនរបស់អញមិនបានទទួលអារម្មណ៍ ខ្លួនរបស់អញតែងទទួលវេទនា វេទនាធម៌ជាខ្លួនរបស់អញពិតក៏មាន ម្នាលអានន្ទ បុគ្គលកាលពិចារណានូវខ្លួន តែងពិចារណាដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៣ ពួកនោះ បុគ្គលណាពោលយ៉ាងនេះថា វេទនាជាខ្លួនរបស់បុគ្គលនោះ អ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុសោ វេទនានេះមាន ៣ យ៉ាង គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ បណ្តាវេទនាទាំង ៣ នេះ អ្នកពិចារណាឃើញច្បាស់នូវវេទនាណាថាជាខ្លួន ។ ម្នាលអានន្ទ សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួល*

អទុក្ខមសុខវេទនាទេ សម័យនោះ រមែងទទួលតែសុខវេទនាមួយយ៉ាង ។ ម្នាលអានន្ទ សម័យណា បុគ្គលទទួលទុក្ខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះ រមែងទទួលតែទុក្ខវេទនាមួយយ៉ាង ។ ម្នាលអានន្ទ សម័យណា បុគ្គលទទួលអទុក្ខម-សុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ រមែងទទួល តែអទុក្ខមសុខវេទនាមួយយ៉ាង ។ ម្នាលអានន្ទ សុខវេទនាក្តី ជាធម្មជាតិមិនទៀង ជាធម្មជាតិដែលបច្ច័យតាក់តែងកើតឡើងព្រោះអាស្រ័យ (នឹងបច្ច័យនោះៗ) មានកិរិយាអស់ទៅ វិនាសទៅ សាបរលាបទៅ រលត់ទៅជាធម្មតា ។ ម្នាលអានន្ទ ទុក្ខវេទនាក្តី ជាធម្មជាតិមិនទៀង ជាធម្មជាតិដែលបច្ច័យតាក់តែងកើតឡើង ព្រោះអាស្រ័យ (នឹងបច្ច័យនោះៗ) មានកិរិយាអស់ទៅ វិនាសទៅ សាបរលាបទៅ រលត់ទៅជាធម្មតា ។ ម្នាលអានន្ទ អទុក្ខមសុខវេទនាក្តី ជាធម្មជាតិមិនទៀង ជាធម្មជាតិដែលបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យ (នឹងបច្ច័យនោះៗ) មានកិរិយាអស់ទៅ វិនាសទៅ សាបរលាបទៅ រលត់ទៅជាធម្មតា ។ កាលបុគ្គលនោះទទួលសុខវេទនា រមែងដឹងច្បាស់ថា នេះខ្លួនរបស់អញ កាលបើសុខវេទនានោះរលត់ទៅហើយក៏ដឹងច្បាស់ថា ខ្លួនរបស់អញរលត់ទៅហើយ ។ កាលបុគ្គលនោះទទួលទុក្ខវេទនា រមែងដឹងច្បាស់ថា នេះខ្លួនរបស់អញ កាលបើទុក្ខវេទនានោះរលត់ទៅហើយ ក៏ដឹងច្បាស់ថា ខ្លួនរបស់អញរលត់ទៅហើយ ។ កាលបុគ្គលនោះ ទទួលអទុក្ខមសុខវេទនា រមែងដឹងច្បាស់ថា នេះ

ខ្ញុំនរបស់អញ កាលបើអទុក្ខមសុខវេទនានោះរលត់ទៅហើយ ក៏ដឹងច្បាស់ ថា ខ្ញុំនរបស់អញរលត់ទៅហើយ ។ បុគ្គលណាពោលយ៉ាងនេះថា វេទនា ជាខ្ញុំនរបស់អញ បុគ្គលនោះកាលពិចារណានូវខ្ញុំន តែងពិចារណាខ្ញុំនដែល មិនទៀង លាយច្រឡំដោយសុខ និងទុក្ខ មានកិរិយាកើតឡើង និងវិនាស ទៅជាធម្មតា ក្នុងបច្ចុប្បន្នដូចសេចក្តីដែលបានសម្តែងមកនេះឯង ។ ម្នាល អានន្ទ ព្រោះហេតុដូច្នោះ បុគ្គលក្នុងលោកនេះ មិនគួរនឹងពិចារណានូវខ្ញុំន នេះថា វេទនាជាខ្ញុំនរបស់អញដោយឧបាយនេះឡើយ ។ ម្នាលអានន្ទ បណ្តា បុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៣ ពួកនោះ បុគ្គលណាពោលយ៉ាងនេះថា វេទនា មិនមែនជាខ្ញុំនរបស់អញ ព្រោះថា ខ្ញុំនរបស់អញមិនបានទទួលអារម្មណ៍ បុគ្គលនោះអ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុសោ ការទទួលអា-រម្មណ៍ដោយប្រការទាំងពួង រមែងមានក្នុងសុទ្ធរូបក្ខន្ធណា សេចក្តីដឹងខ្ញុំនថា អាត្មាអញមាន គប្បីមានក្នុងសុទ្ធរូបក្ខន្ធនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះ បុគ្គលក្នុងលោកនេះ មិនគួរនឹងពិចារណានូវខ្ញុំននេះថា វេទនាមិនមែនជាខ្ញុំនរបស់អញ ព្រោះថា ខ្ញុំនរបស់អញមិនទទួលអារម្មណ៍ ដោយឧបាយនេះឡើយ ។ ម្នាលអានន្ទ បណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៣ ពួកនោះ បុគ្គលណាពោលយ៉ាងនេះថា វេទនាមិនមែនជាខ្ញុំនរបស់អញ ព្រោះថា ខ្ញុំនរបស់អញ មិនបានទទួលអា-រម្មណ៍ទេ ខ្ញុំនរបស់អញ រមែងទទួលវេទនា ឯវេទនាជាធម៌ជាខ្ញុំនរបស់អញ ។ បុគ្គលនោះអ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុសោ វេទនាទាំងឡាយ

คปฺปิรเลต์มิនเสสสลเ់ដោយអាការទាំងពួង ដោយសភាវៈទាំងពួង កាល
បើវេទនាមិនមានដោយប្រការទាំងពួង ព្រោះវេទនារលត់ហើយ សេចក្តីដឹង
ខ្លួនថា អាត្មាអញមានដូច្នេះ គប្បីមានក្នុងរូបក្ខន្ធនោះដែរឬ ។ បពិត្រព្រះអង្គ
ដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុដូច្នោះ បុគ្គលក្នុង
លោកនេះ មិនគួរនឹងពិចារណាន្ទូវខ្លួននេះថា វេទនាមិនមែនជាខ្លួនរបស់អញ
ព្រោះថា ខ្លួនរបស់អញមិនបានទទួលអារម្មណ៍ទេ ខ្លួនរបស់អញរមែងទទួល
វេទនា ឯវេទនាធម៌ ជាខ្លួនរបស់អញ ពិតដោយឧបាយនេះឡើយ ។

[៦៤] ម្នាលអានន្ទ កាលបើភិក្ខុមិនបានពិចារណាន្ទូវវេទនាថាជាខ្លួន
ក៏មិនបានពិចារណាន្ទូវខ្លួនថា មិនបានទទួលអារម្មណ៍ ក៏មិនពិចារណាថា ខ្លួន
ទទួលវេទនា វេទនាធម៌ជាខ្លួនរបស់អញដូច្នេះឡើយ ។ ភិក្ខុនោះកាលពិចារណា
យ៉ាងនេះ រមែងមិនប្រកាន់នូវធម្មជាតនីមួយក្នុងលោក (មានខន្ធលោកជា
ដើម) កាលបើមិនប្រកាន់ហើយ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត
ហើយ រមែងបរិនិព្វានចំពោះខ្លួនឯង តែងដឹងច្បាស់ថា កំណើតរបស់អញ
អស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡស-
កិច្ចអាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះ
ទៀតមិនមានឡើយ ។ ម្នាលអានន្ទ ភិក្ខុដែលរួចស្រឡះ (ចាកអាសវៈ)
យ៉ាងនេះហើយ បើបុគ្គលណានិយាយយ៉ាងនេះថា ទិដ្ឋិរបស់ភិក្ខុនោះថា សត្វ
ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតទៀត ពាក្យនោះរបស់បុគ្គលនោះមិន
គួរទេ ។ ថាទិដ្ឋិរបស់ភិក្ខុនោះ ថាសត្វខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងមិន

កើតទៀត ពាក្យនោះរបស់បុគ្គលនោះមិនគួរទេ ។ ថាទិដ្ឋិរបស់ភិក្ខុនោះថា សត្វខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតទៀតក៏មាន មិនកើតទៀតក៏មាន ពាក្យនោះរបស់បុគ្គលនោះក៏មិនគួរ ។ ថាទិដ្ឋិរបស់ភិក្ខុនោះ ថាសត្វខាងមុខអំពីសេចក្តីស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ពាក្យនោះរបស់បុគ្គលនោះ ក៏មិនគួរ ។ សេចក្តីនោះព្រោះហេតុដូចម្តេច ។ ម្នាលអានន្ទ ឈ្មោះ និងគន្ធៈនៃឈ្មោះក្តី ភាសា និងគន្ធៈនៃភាសាក្តី បញ្ញត្តិ និងគន្ធៈនៃបញ្ញត្តិក្តី បញ្ញា និងខន្ធបញ្ចកៈដែលគួរដឹងដោយបញ្ញាក្តី វដ្តៈក្តី តែងប្រព្រឹត្តទៅដោយកំណត់ត្រឹមណាៗ វដ្តៈក៏ប្រព្រឹត្តទៅដោយកំណត់ត្រឹមណោះៗ ដែរ ភិក្ខុរួចស្រឡះហើយ ព្រោះដឹងនូវសភាវៈមានឈ្មោះជាដើមនោះ បើបុគ្គលណាពោលនូវភិក្ខុដែលរួចស្រឡះហើយ ព្រោះដឹងនូវសភាវៈមានឈ្មោះជាដើមនោះថា ភិក្ខុនោះមិនដឹង មិនឃើញ ទិដ្ឋិរបស់ភិក្ខុនោះដូច្នេះ ពាក្យនោះរបស់បុគ្គលនោះមិនគួរទេ ។

[๖๕] *ម្នាលអានន្ទ វិញ្ញាណដ្ឋិតិ (ទីតម្កល់នៃវិញ្ញាណ) នេះមាន ๗ អាយតនៈមាន ๒ ។ វិញ្ញាណដ្ឋិតិទាំង ๗ នោះ តើដូចម្តេច ។ ម្នាលអានន្ទ ពួកសត្វដែលមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្ស ទេវតាពួកខ្លះ និងសត្វតិរច្ឆានៈពួកខ្លះ នេះជាវិញ្ញាណដ្ឋិតិទី ๑ ។ ម្នាលអានន្ទ ពួកសត្វដែលមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម ដែលកើតដោយបឋមជ្ឈាន និងពួកសត្វដែលកើតក្នុងអបាយភូមិទាំង ๔ នេះ ជាវិញ្ញាណដ្ឋិតិទី ๒ ។ ម្នាលអានន្ទ ពួកសត្វ*

ដែលមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាដែលនៅក្នុងអាភ-
ស្សរភពនេះ ជាវិញ្ញាណដ្ឋិតិទី ៣ ។ ម្នាលអានន្ទ ពួកសត្វដែលមានកាយ
ដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាដែលនៅក្នុងសុភកិណ្ហភព នេះជា
វិញ្ញាណដ្ឋិតិទី ៤ ។ ម្នាលអានន្ទ ពួកសត្វដែលកន្ទងនូវរូបសញ្ញា ដល់នូវ
សេចក្តី វិនាសនៃបដិឃសញ្ញា និងមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា
ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកាសានញ្ចាយតនជ្ឈាន (ដោយ
ធ្វើទុកក្នុងចិត្ត) ថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិញ្ញាណដ្ឋិតិទី ៥ ។
ម្នាលអានន្ទ ពួកសត្វដែលកន្ទងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការ
ទាំងពួង ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត)
ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិញ្ញាណដ្ឋិតិទី ៦ ។ ម្នាលអានន្ទ
ពួកសត្វដែលកន្ទងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយ
ចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួច
ក៏មិនមានដូច្នេះ នេះជាវិញ្ញាណដ្ឋិតិទី ៧ ។ ឯអាយតន:ទាំងពីរ គឺអសញ្ញិ-
សត្តាយតន: (ជាទី ១) នេវសញ្ញានាយសញ្ញាយតន:ជាទី ២ ។ ម្នាល
អានន្ទ បណ្តាវិញ្ញាណដ្ឋិតិទាំង ៧ នោះ វិញ្ញាណដ្ឋិតិទី ១ ណាដែលថា ពួក
សត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្ស ទេវតាពួកខ្លះ និង
សត្វវិនិបាតិក:ពួកខ្លះ ម្នាលអានន្ទ កិកុ្ខណា ដឹងច្បាស់នូវវិញ្ញាណដ្ឋិតិនោះ
ផង ដឹងច្បាស់នូវហេតុជាទីកើតនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវសេចក្តី
រលត់នៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវអានិសង្សនៃវិញ្ញាណដ្ឋិតិនោះផង

ដឹងច្បាស់នូវទោសនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវកិរិយារលាស់ចោលនូវវិញ្ញាណដ្ឋិតិនោះផង កិកូនោះ គួរត្រេកអរនឹងវិញ្ញាណដ្ឋិតិនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនគួរទេ ។បេ។ ម្នាលអានន្ទ បណ្តាវិញ្ញាណដ្ឋិតិទាំង ៧ នោះ វិញ្ញាណដ្ឋិតិទី ៧ ណា ដែលថា ពួកសត្វកន្ទងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួចក៏មិនមានដូច្នេះ ម្នាលអានន្ទ កិកូណា ដឹងច្បាស់នូវវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវហេតុជាទីកើតនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវសេចក្តីរលត់នៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវអានិសង្សនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវទោសនៃវិញ្ញាណដ្ឋិតិនោះផង ដឹងច្បាស់នូវកិរិយារលាស់ចោលនូវវិញ្ញាណដ្ឋិតិនោះផង កិកូនោះគួរត្រេកអរ នឹងវិញ្ញាណដ្ឋិតិនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនគួរទេ ។ ម្នាលអានន្ទ បណ្តាអាយតន:ទាំង ២ នោះ អសញ្ញិសត្តាយតន:ណា ម្នាលអានន្ទ កិកូណា ដឹងច្បាស់នូវអាយតន:នោះផង ដឹងច្បាស់នូវហេតុជាទីកើតនៃអាយតន:នោះផង ដឹងច្បាស់នូវសេចក្តីរលត់នៃអាយតន:នោះផង ដឹងច្បាស់នូវអានិសង្សនៃអាយតន:នោះផង ដឹងច្បាស់នូវទោសនៃអាយតន:នោះផង ដឹងច្បាស់នូវកិរិយារលាស់ចោលនូវអាយតន:នោះផង កិកូនោះគួរត្រេកអរនឹងអាយតន:នោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនគួរទេ ។ ម្នាលអានន្ទ បណ្តាអាយតន:ទាំង ២ នោះ នេវសញ្ញានាសញ្ញាយតន:ណា ម្នាលអានន្ទ កិកូណាដឹងច្បាស់នូវអាយតន:

นោះផង ជឹងច្បាស់នូវហេតុជាទីកើតនៃអាយតនៈនោះផង ជឹងច្បាស់នូវសេចក្តីរលត់នៃអាយតនៈនោះផង ជឹងច្បាស់នូវអានិសង្សនៃអាយតនៈនោះផង ជឹងច្បាស់នូវទោសនៃអាយតនៈនោះផង ជឹងច្បាស់នូវកិរិយារលាស់ចោលនូវអាយតនៈនោះផង កិកូនោះគួរត្រេកអរនឹងអាយតនៈនោះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនគួរទេ ។ ម្នាលអានន្ទ កាលណាបើកិកូជឹងច្បាស់នូវហេតុជាទីកើតផង នូវសេចក្តីរលត់ផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចោលផង នូវវិញ្ញាណដ្ឋិតិទាំង ៧ និងអាយតនៈទាំង ២ នេះ តាមសេចក្តីពិតមែន ឈ្មោះថា រួចស្រឡះព្រោះមិនប្រកាន់ ម្នាលអានន្ទ កិកូនេះឯងតថាគតហៅថា បញ្ញាវិមុត្តបុគ្គល ។

[៦៦] ម្នាលអានន្ទ វិមោក្ខនេះ មាន ៨ យ៉ាង ។ វិមោក្ខទាំង ៨ នោះ តើដូចម្តេច ។ គឺបុគ្គលមានរូបជ្ឈាន តែងឃើញរូប គឺកសិណទាំងឡាយមាននីលកសិណជាដើម នេះជាវិមោក្ខទី ១ ។ បុគ្គលមិនមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុងមានសក់ជាដើមរបស់ខ្លួន តែងឃើញរូបខាងក្រៅ គឺកសិណមាននីលកសិណជាដើម នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈានក្នុងវណ្ណកសិណ ដែលបរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ បុគ្គលដែលកន្លងនូវរូបសញ្ញាដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា ទាំងមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយចូលទៅកាន់អាកាសានញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ បុគ្គលដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈានដោយប្រការ

ទាំងពួង ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ បុគ្គលដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ បុគ្គលដែលកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញា និងវេទនា) នេះជាវិមោក្ខទី ៨ ។ ម្នាលអានន្ទ វិមោក្ខមាន ៨ ប្រការនេះឯង ។ ម្នាលអានន្ទ កាលណាបើភិក្ខុចូលកាន់វិមោក្ខទាំង ៨ នេះ ជាអនុលោមខ្លះ បដិលោមខ្លះ ទាំងអនុលោមបដិលោមខ្លះ ចូលបាន ចេញបាន តាមសេចក្តីប្រាថ្នា ក្នុងឱកាសណា តាមសេចក្តីប្រាថ្នានូវសមាបត្តិណា តាមសេចក្តីប្រាថ្នានូវកំណត់ប៉ុន្មាន ក៏រមែងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ចំពោះចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលអានន្ទ ភិក្ខុនេះ តថាគតហៅថា ឧភតោភាគវិមុត្តបុគ្គល គឺ បុគ្គលដែលរួច

ដោយចំណែកពីរ ។ ម្នាលអានន្ទ ឧកតោភាគវិមុត្តិដទៃ ដែលលើសលុបជាង ឬថ្លៃថ្នាជាងឧកតោភាគវិមុត្តិនេះ មិនមានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ ។ ព្រះអានន្ទមានអាយុ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគជាម្ចាស់ ។

មហានិទានសូត្រទី ២ ចប់

អដ្ឋកថា

មហានិទានសូត្រ

[៥៧] មហានិទានសូត្រមានពាក្យផ្តើមថា **ឯវមេ សុតំ ។បេ។ កុរូសុ** ដូច្នេះ ។

តទៅនេះ ជាពណ៌នាបទដែលលំបាកក្នុងព្រះសូត្រនោះ បទថា **កុរូសុ វិហរតិ** សេចក្តីថា ព្រះរាជកុមារអ្នកជនបទ ឈ្មោះថា **កុរុ** ទីប្រថាប់របស់ព្រះរាជកុមារនោះជាជនបទមួយ លោកពោលថា **កុរូសុ** ដោយសព្វដែលបន្តែមចូលមក ក្នុងជនបទឈ្មោះកុរុសុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ក្នុងរជ្ជកាលព្រះបាទមន្ធាតុ ពួកមនុស្សក្នុងទ្វីប ៣ បានឮមកថា ជម្ពូទ្វីប ជាទីកើតរបស់ឧត្តមបុរស រាប់ពីព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះមហាសាវក និងស្តេចចក្រពត្តិ ជាទ្វីបឧត្តម គួរពីរភាយក្រៃលែងណាស់ ទើបនាំគ្នាមកជាមួយស្តេចចក្រពត្តិមន្ធាតុរាជ អ្នកបង្វិលចក្រកែវ ហើយទៅកាន់ទ្វីបទាំង ៤ លំជាប់នោះ ព្រះរាជាត្រាស់សួរបរិនាយកកែវថា នៅមានទីរីករាយជាងមនុស្សលោក ឬទេហ្ន៎ បរិនាយកកែវក្រាបទូលថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ទើបព្រះអង្គត្រាស់យ៉ាងនោះ ទ្រង់មិនឃើញអានុភាពរបស់ព្រះចន្ទ និងព្រះអាទិត្យ ឬហានៈរបស់ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ គួរពីរភាយជាងនេះមិនមែនឬ ព្រះរាជាបានទ្រង់បង្ហោះចក្រកែវទៅក្នុងទីនោះ ។

មហារាជទាំង ៤ បានស្តាប់ថា ព្រះបាទមន្ធាតុរាជយាងមកហើយ គិតថា ព្រះរាជាទ្រង់នូវឫទ្ធិច្រើន អញមិនអាចនឹងច្បាំងបាន ទើបប្រគល់រាជ-សម្បត្តិរបស់ខ្លួនឲ្យ ព្រះបាទមន្ធាតុរាជទ្រង់ទទួលរាជសម្បត្តិនោះហើយ ត្រាស់

សួរតទៅថា នៅមានទីគួរវីកវាយក្រៃលែងជាងនេះទៀតដែរឬទេ លំដាប់នោះ មហារាជទាំងនោះ ក្រាបទូលអំពីភពតាវត្តិង្សដល់ព្រះអង្គថា បពិត្រព្រះអង្គ ភពតាវត្តិង្សគួរវីកវាយជាងនេះ មហារាជទាំង ៤ នេះ ជាអ្នកនៅបម្រើរបស់ សក្កទេវរាជក្នុងភពនោះ ឈរត្រង់ផែនដីរបស់អ្នករក្សាទ្វារ សក្កទេវរាជមាន ឬទ្ធិច្រើន មានអានុភាពច្រើន សក្កទេវរាជនោះ មានស្ថានទីសម្រាប់បម្រើ ទាំងនេះ គឺវេជយន្តប្រាសាទកម្ពស់ ១០០០ យោជន៍ ទេវសភា ឈ្មោះ សុធម្មាកម្ពស់ ៥០០ យោជន៍ វេជយន្តរថកម្ពស់ ១៥០ យោជន៍ ដំរីឯរាវណ ក៏ដូចគ្នា សួនន្ទវន ចិត្តលតាវន បារុសកវន មិស្សកវន ប្រដាប់ដោយដើម ឈើទិព្ធ ១០០០ ដើម ដើមរលួសផ្អុងជាបារិច្ឆត្តកព្រឹក្សកម្ពស់ ១០០០ យោជន៍ ខាងក្រោមដើមនោះ មានទីប្រថាប់បណ្ឌុកម្ពលសិលាសន: បណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្ពស់ ១៥ យោជន៍ មានពណ៌ដូចផ្កាជ័យព្រឹក្ស ព្រោះភាពទន់របស់បណ្ឌុកម្ពលសិលាសន:នោះ កាលសក្កទេវរាជគង់ ព្រះ វរកាយពាក់កណ្តាលលិចចុះទៅ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ មានព្រះ បំណងនឹងយាងទៅក្នុងសក្កទេវលោកនោះ ចក្រកែវបានហោះឡើងទៅហើយ ចក្រកែវនោះតាំងនៅលើអាកាសព្រមទាំងសេនាប្រកបដោយអង្គ ៤ តអំពីនោះ ចក្រកែវ ក៏បានចុះកណ្តាលទេវលោកទាំងពីរ ប្រតិស្ឋាននៅលើផែនដី មួយ អន្ទើដោយសេនាប្រកបដោយអង្គ ៤ មានបរិនាយកកែវជាប្រធាន ព្រះរាជាតែ មួយព្រះអង្គប៉ុណ្ណោះ ស្តេចទៅកាន់តាវត្តិង្សពិភព ។ សក្កទេវរាជដឹងថា ព្រះ បាទមន្ធាតុរាជយាងមកហើយ ក៏ធ្វើការទទួលព្រះបាទមន្ធាតុរាជនោះ ត្រាស់ ថា បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ បពិត្រមហារាជ សម្បត្តិនេះ

*ជារបស់ព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គទ្រង់គ្រប់គ្រងចុះ ហើយទ្រង់បែងចែករាជសម្បត្តិ មួយអន្ទៅដោយស្រីរបាំ ឲ្យជាពីរចំណែក បានប្រទានឲ្យមួយចំណែក កាលព្រះរាជាមន្ធាតុ ទ្រង់ប្រថាប់នៅលើភពតាវត្តិង្សប៉ុណ្ណោះ កាពជាមនុស្សក៏បានបាត់ទៅ កាពជាទេវតា បានប្រាកដក្នុម បានឮថា កាលព្រះរាជាប្រថាប់ក្នុងបណ្ឌុកម្ពលសិលាសនៈ ជាមួយសក្កទេវរាជ ពួកទេវតាមិនបានសង្កេតព្រះរាជានោះថា ការផ្សេងគ្នា រមែងប្រាកដដោយប៉ប្រិចភ្នែក[1] រមែងកាន់ច្រឡំក្នុងសេចក្តីផ្សេងគ្នារបស់សក្កទេវរាជ និងរបស់ព្រះរាជានោះ ព្រះរាជាមន្ធាតុរាជ ទ្រង់សោយទិព្វសម្បត្តិ ក្នុងភពតាវត្តិង្សនោះ ទ្រង់គ្រងរាជសម្បត្តិដរាបដល់សក្កទេវរាជទ្រង់ឧប្បត្តិក និងចុតិដល់ទៅ ៣៦ អង្គ ទ្រង់មិនឆ្អែតដោយកាម កាលចុតិអំពីភពតាវត្តិង្សហើយ ក៏ធ្លាក់ចុះក្នុងព្រះឧទ្យានរបស់ព្រះអង្គ ព្រះវរកាយត្រូវសម្ផស្សខ្យល់ និងកម្តៅថ្ងៃ ស្តេចក៏បានសោយទិវង្គតទៅ ។ កាលចក្រកែវតាំងនៅលើផែនដី បរិនាយកកែវឲ្យគូរស្នាមព្រះបាទរបស់ព្រះបាទមន្ធាតុរាជត្រង់ផែនមាស ហើយប្រកាសរាជសម្បត្តិថា នេះគឺរាជសម្បត្តិរបស់ព្រះបាទមន្ធាតុរាជ សូម្បីពួកមនុស្សដែលមកអំពីទ្វីបទាំង ៣ នោះ ក៏មិនអាចនឹងត្រឡប់ទៅវិញបាន ទើបចូលទៅរកបរិនាយកកែវអង្វរថា បពិត្រព្រះអង្គ ពួកខ្ញុំមកដោយអានុភាពរបស់ព្រះរាជា ឥឡូវនេះមិនអាចត្រឡប់ទៅវិញបាន សូមទ្រង់ឲ្យទីលំនៅដល់ពួកខ្ញុំផងចុះ បរិនាយកកែវបានឲ្យជនបទមួយៗ ដល់មនុស្សទាំងនោះ ក្នុងប្រទេសនោះ ប្រទេសដែលពួកមនុស្សមកអំពីបុព្វវិទេហទ្វីបអាស្រ័យនៅ បានឈ្មោះថា **វិទេហរាជ** តាមគ្រឿង*

១- ព្រះបាទមន្ធាតុ ចេះប៉ប្រិចភ្នែក ព្រះឥន្ទ មិនប៉ប្រិចភ្នែកឡើយ ។

សម្គាល់ពីដើមនោះឯង ប្រទេសដែលពួកមនុស្សមក អំពីអមរគោយានទ្វីប អាស្រ័យនៅ បានឈ្មោះថា **អបរន្ត្ជនបទ** ប្រទេសដែលពួកមនុស្សមកអំពីឧត្តរកុរុទ្វីបអាស្រ័យនៅ បានឈ្មោះថា **ក្ករុរដ្ឋ** លោកពោលជាពហុវចនៈ ប្រាថ្នាយកស្រុក និងនិគមជាដើមច្រើន ព្រោះហេតុនោះ ទើបលោកពោលថា **ក្ករូសុ វិហរតិ ។**

ក្នុងបទថា **កម្មាសធម្មំ** នេះ អាចារ្យពួកខ្លះ ពណ៌នាសេចក្តីដោយផ្លាស់ **ធ** ជា **ឧ ។** ឈ្មោះថា **កម្មាសធម្ម** ព្រោះកម្មាស ត្រូវទូន្មានក្នុងហេតុនេះ ។ បទថា **កម្មាសោ** លោកពោលថា **កម្មាសចាឧ** ជាមនុស្សស៊ីមនុស្ស ។ បានញ្ញមកថា ជំហៅកើតឡើងត្រង់ជើងរបស់កម្មាសបាទនោះ ក្នុងទីដែលមុតដង្គត់ បានពងឡើង ដូចគ្នានឹងដើមចិត្រមូលភ្លើង ព្រោះដូច្នោះ កម្មាសបានប្រាកដឈ្មោះថា **កម្មាសចាឧ ។** កម្មាសបាទ ត្រូវទូន្មានក្នុងឧកាសនោះ ទើបបានឈប់ពីការស៊ីមនុស្ស ។ សួរថា អ្នកណាទូន្មាន ឆ្លើយថា ព្រះមហាសត្ត ។ ពោលក្នុងជាតកណា ។ អាចារ្យពួកខ្លះពោលថា ក្នុងមហាសុត្ត-សោមជាតក ។ តែព្រះថេរៈទាំងនេះពោលថា ក្នុងជយទិសជាតក ។ គ្រានោះ កម្មាសបាទត្រូវបានព្រះមហាសត្វទូន្មាន ដូចដែលព្រះពោធិសត្វពោលថា

ក្នុងកាលមួយ តថាគតជាព្រះបរមឧរសាធិរាជ របស់ព្រះបាទជយទិសជាព្រះរាជាធិបតីនៃបញ្ចាលរដ្ឋ បានលះបង់ជីវិតដើម្បីដោះព្រះរាជបិតាហើយម្យ៉ាងទៀត តថាគតបានឲ្យព្រះបាទបោរិសាទ ដែលជាអ្នកមានព្រះបាទាពពាលជ្រះថ្លាហើយ ដូច្នេះ ។

តែអាចារ្យពួកខ្លះពណ៌នាដោយ ឆ អក្ខរៈប៉ុណ្ណោះ បានឮថា កុរុធម្មរបស់អ្នកដែនកុរុ កើតភាពសៅហ្មងខ្លឹងហើយក្នុងដែននោះ ព្រោះដូច្នោះ ទីនោះជាទីមានធម៌ព្រះពាលកើតខ្លឹងហើយ ទើបលោកហៅថា **កម្មាសធម្ម** *កម្មាសធម្មៈនេះ ជាឈ្មោះរបស់និគម ដែលអ្នកកុរុនៅអាស្រ័យក្នុងទីនោះ ព្រោះហេតុអ្វី ទើបលោកមិនពោលដោយសត្តមីវិភត្តិ ព្រោះមិនមែនឱកាសជាទីនៅ បានឮថា ឱកាសជាទីនៅក្នុងនិគមនោះ របស់ព្រះមានព្រះភាគ មិនមែនជាព្រះវិហារទេ តែឃ្លាតពីនិគមដែលមានព្រៃធំ ក្នុងភូមិភាគ ដែលគួរវែកវាយ សម្បូណ៌ដោយទឹកឯណាមួយ ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងទីនោះ ទ្រង់ធ្វើនិគមនោះឲ្យជាគោចរគ្រាម ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុងបទនេះថា ព្រះមានព្រះភាគប្រថាប់នៅក្នុងកុរុជនបទ មាននិគមរបស់អ្នកកុរុ ឈ្មោះ* **កម្មាសធម្ម** *ទ្រង់ធ្វើនិគមនោះឲ្យជាគោចរគ្រាម ។*

បទថា **អាយស្មា** *នេះ ជាពាក្យពោលដោយសេចក្តីស្រឡាញ់ ជាពាក្យពោលដោយសេចក្តីគោរព ។ បទថា* **អានន្ទោ** *ជាឈ្មោះរបស់ព្រះថេរៈអង្គនោះ ។ បទថា* **ឯកមន្តំ** *សម្តែងដល់ភាពជាបុំសកលិង្គ ដូចក្នុងបទជាដើមថា ព្រះចន្ទ និងព្រះអាទិត្យចរទៅមិនស្មើ ដូច្នេះ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីក្នុងបទនេះយ៉ាងនេះថា ព្រះអានន្ទអង្គុយហើយ ដោយអាការដែលព្រះអានន្ទអង្គុយ រមែងអង្គុយហើយក្នុងទីសមគួរមួយ ឬថា បទនេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។*

បទថា **ឯសីទិ** *គឺចូលទៅហើយ ពិតហើយ បណ្ឌិតទាំងឡាយ ចូលទៅរកអ្នកដែលនៅក្នុងទីស្ថានដែលជាទីគោរព រមែងអង្គុយក្នុងទីមួយដ៏សមគួរ*

ព្រោះជាអ្នកឈ្វាសក្នុងការអង្គុយ ក៏ព្រោះព្រះអានន្ទនេះ ជាបណ្ឌិតមួយរូប ក្នុងបណ្តាបណ្ឌិតទាំងនោះ ព្រោះដូច្នោះ ទើបអង្គុយហើយក្នុងទីមួយដ៏សមគួរ តើអង្គុយដូចម្តេច ទើបឈ្មោះថា អង្គុយក្នុងទីមួយដ៏សមគួរ គឺអង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង គឺអង្គុយឆ្ងាយពេក ១ អង្គុយជិតពេក ១ អង្គុយលើខ្យល់ ១ អង្គុយទីខ្ពស់ ១ អង្គុយត្រង់មុខពេក ១ អង្គុយខាងក្រោយពេក ១ ។ ព្រោះអង្គុយឆ្ងាយពេក បើចង់សួរក៏ត្រូវនិយាយដោយសំឡេងខ្លាំង អង្គុយជិតពេក នឹងត្រូវធ្វើសេចក្តីច្រៀតបៀតគ្នា អង្គុយក្នុងទីលើខ្យល់ រមែងបៀតបៀនដោយកិន អង្គុយក្នុងទីខ្ពស់ រមែងសម្តែងការមិនគោរព អង្គុយចំពីមុខ បើប្រាថ្នានឹងមើល នឹងត្រូវសម្លឹងមើលទល់ភ្នែកគ្នានឹងគ្នា អង្គុយខាងក្រោយពេក បើប្រាថ្នានឹងមើល នឹងត្រូវអើតកមើល ព្រោះដូច្នោះ ព្រះអានន្ទនេះ ក៏ធ្វើប្រទក្សិណព្រះដ៏មានព្រះភាគ ៣ ដុំ ហើយថ្វាយបង្គំដោយសេចក្តីគោរព វៀរទោសនៃការអង្គុយ ៦ យ៉ាង ចូលទៅខាងក្នុងនៃព្រះពុទ្ធវស្មី មាន ៦ ពណ៌ ក្នុងទីចំពោះមុខនៃមណ្ឌលព្រះជានុខាងស្តាំ ព្រះអានន្ទដែលជាភណ្ឌាគារិកនៃព្រះធម៌ បានអង្គុយហើយ ដូចចុះកាន់រសលក្ត ដែលថ្លាស្អាត ដូចដណ្តប់ផ្ទាំងមាស ដូចចូលទៅកាន់កណ្តាលពិតាននៃផ្ទាឧប្បលក្រហម ព្រោះដូច្នោះ ទើបលោកពោលថា ព្រះអានន្ទអង្គុយហើយក្នុងចំណែកម្ខាង សួរថា ព្រះអានន្ទនេះ ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងពេលណា ព្រោះហេតុអ្វី ឆ្លើយថា ក្នុងពេលល្ងាច ព្រោះហេតុ គឺការសួរបញ្ហារឿងបច្ចយាការ ក្នុងថ្ងៃនោះ ព្រះអានន្ទគ្រាច់ទៅកាន់ស្រុកកម្មាសធម្មៈដើម្បីបិណ្ឌបាត ដូចចូលទៅកាន់ស្រុកដែលមានកណ្ហៈ ១០០០ ក្នុងទ្វារផ្ទះ ដើម្បីអនុគ្រោះត្រកូល ត្រឡប់

អំពីបិណ្ឌបាតហើយ មើលថែប្រណិបត្តន៍ព្រះសាស្តា កាលព្រះសាស្តាយាងចូលទៅកាន់ព្រះគន្ធកុដិ ថ្វាយបង្គំព្រះសាស្តាហើយ ទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កាលកូនសិស្សទាំងឡាយមើលថែប្រណិបត្តន៍ ហើយត្រឡប់ទៅវិញ បានបោសសម្អាតទីសម្រាកពេលថ្ងៃ ក្រាលកម្រាលស្បែក ដងទឹកអំពីពាងលាងដៃ និងជើងឲ្យត្រជាក់ អង្គុយពត់ភ្នែន ចូលសមាបត្តិថ្នាក់សោតាបត្តិផល កាលចេញពីសមាបត្តិតាមដែលកំណត់ហើយ ក៏ចុះកាន់ញាណក្នុងបច្ចយាការ ។

ព្រះអានន្ទនោះ ដល់បទទីបំផុតតាំងពីបទដើមថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារដូច្នេះ តាំងពីបទដើមរហូតដល់បទចុងបំផុត ផ្តើមពីបទកណ្តាលរហូតដល់បទចុងបំផុតទាំងពីរ ផ្តើមពីបទចុងបំផុតទាំងពីរ ដល់បទកណ្តាលពិចារណាបច្ចយាការ ១២ បទ ៣ ដង កាលពិចារណាយ៉ាងនេះ បច្ចយាការក៏ជាក់ច្បាស់ក្រៃលែង ប្រាកដដូចជាងាយសែនងាយ បន្ទាប់ពីនោះព្រះអានន្ទត្រិះរិះថា បច្ចយាការនេះ ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ថា ជ្រាលជ្រៅ និងប្រាកដជារបស់ជ្រាលជ្រៅ កាលអាត្មាអញជាសាវក តាំងនៅហើយក្នុងសេចក្តីដឹងរឿងដែលងាយ និងប្រាកដជាក់ច្បាស់ជាសេចក្តីងាយនោះ ជាការងាយប្រាកដដល់អញប៉ុណ្ណោះឬ ដល់អ្នកដទៃផងដែរ លំដាប់នោះ ព្រះថេរៈមានសេចក្តីត្រិះរិះថា បើដូច្នោះ អញនឹងនាំបញ្ហានេះ ទៅទូលសួរព្រះមានព្រះភាគៗ នឹងធ្វើរឿងនេះឲ្យជាអត្ថុប្បត្តិហេតុ ហើយនឹងត្រាស់ព្រះសុត្តន្តពួកមួយ នឹងទ្រង់សម្តែងដល់អញពិតប្រាកដ ដូចទ្រង់លើកកំពស់សាលិន្ទសិនេរុឡើងដូច្នោះ ពិតហើយ ព្រះញាណដែលព្រះពុទ្ធទាំងឡាយ ទ្រង់ដល់ហាន: ៤

យ៉ាងនេះ គឺការបញ្ញត្តព្រះវិន័យ លំដាប់ផែនដី[1] បច្ចយាការ លំដាប់សម័យ ញាណគឹកកងជាកោលាហលធំក្រៃលែង ព្រះមានព្រះភាគទ្រង់ចូលដល់ព្រះ ញាណ រមែងប្រាកដភាពជាពុទ្ធញ្ញាណដែលធំក្រៃលែង ទេសនាជាសេចក្តី ជ្រាលជ្រៅ កម្ចាត់ដោយព្រះត្រៃលក្ខណ៍ បដិសំយុត្តដោយភាពជារបស់ សូន្យ ដូច្នេះ ព្រះអានន្ទនោះ តាមប្រក្រតីក្នុងមួយថ្ងៃចូលទៅគាល់ព្រះមាន ព្រះភាគ ១០០ ដងខ្លះ ១០០០ ដងខ្លះ ក៏ពិត រមែងមិនចូលទៅគាល់ដោយ មិនមានហេតុ តែថ្ងៃនោះ ព្រះអានន្ទនាំបញ្ហានេះទៅហើយ គិតថា អញនឹង អង្គុយជិតព្រះពុទ្ធ ដូចគន្ធហត្ថី ហើយស្តាប់ព្រះសូរសៀងគឹកកងដោយព្រះ ញាណ នឹងអង្គុយជិតព្រះពុទ្ធដូចសីហៈ ស្តាប់ការបន្ទឺព្រះសូរសៀងដូចសីហៈ ដោយព្រះញាណ នឹងអង្គុយជិតព្រះពុទ្ធ ដូចសិន្ធព ហើយនឹងឃើញការ ឈានទៅកាន់ផ្លូវនៃព្រះញាណ ដូច្នេះហើយ ក្រោកចាកទីសម្រាកពេលថ្ងៃ បត់កម្រាលស្បែក កាន់ទៅគាល់ព្រះមានព្រះភាគក្នុងវេលាល្ងាច ព្រោះហេតុ នោះ ទើបលោកពោលថា ព្រះអានន្ទចូលទៅគាល់ដោយហេតុ គឺការសួរបញ្ហា ជាប់ទាក់ទងនឹងបច្ចយាការ ក្នុងវេលាល្ងាច ដូច្នេះ ។

យាវ សព្ទ ក្នុងបទថា **យាវគម្ភីរោ** នេះ ប្រព្រឹត្តទៅក្នុងអត្ថថា លើស ប្រមាណ អធិប្បាយថា កន្ទងប្រមាណ ជ្រាលជ្រៅក្រៃលែង ។ បទថា **គម្ភីរាវភាសោ** សេចក្តីថា ប្រាកដ គឺឃើញជារបស់ជ្រៅ ព្រោះថា ធម៌មួយ ងាយដោយពិត តែជារបស់ជ្រាលជ្រៅ ដូចទឹកចាស់ មានពណ៌ខ្មៅ ដោយ អំណាចរសរបស់ស្ទឹកឈើស្អុយ ទឹកនោះ សូម្បីត្រឹមជង្គង់ ក៏ប្រាកដដូចជា

---

[1] - ជាលីថា កុម្ចន្តរំ ។

មានជម្រៅ ១០០ ជួរបុរស បទមួយជ្រោលជ្រៅ ជ្រោកជជារបស់ងាយដូច ទឹកថ្ងា ក្នុងមណិគង្គា ព្រោះថា ទឹកនោះសូម្បី ១០០ ជួរបុរស ក៏ជ្រោកជដូច នៅត្រឹមជង្គង់ បទមួយងាយ ជ្រោកជជារបស់ងាយ ដូចទឹកក្នុងភាជនៈ មាន ពាងជាដើម បទមួយងាយ ជ្រោកជជារបស់ជ្រោលជ្រៅ រមែងឃើញដូចទឹក ក្នុងមហាសមុទ្រ នាជើងភ្នំសិនេរុ ទឹកនុ៎ះឯង រមែងបានឈ្មោះ ៤ យ៉ាង យ៉ាងនេះ តែសេចក្តីនេះ មិនមានក្នុងបដិច្ចសមុប្បាទ ព្រោះបដិច្ចសមុប្បាទនេះ រមែងបានឈ្មោះតែម្យ៉ាងប៉ុណ្ណោះថា ជ្រោលជ្រៅ និងជ្រោកជជារបស់ជ្រោល ជ្រៅ ដូច្នេះ បដិច្ចសមុប្បាទ សូម្បីមានសភាពបែបនេះ តែជ្រោកជដល់អាត្មា អញ ដូចងាយសែនងាយ ព្រះអានន្ទកាលប្រកាសសេចក្តីចម្អែកចិត្តរបស់ ខ្លួនយ៉ាងនេះថា បពិត្រព្រះអង្គចម្រើន គួរអស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ ចម្រើន ចម្អែកណាស់ ដូច្នេះ ទើបទូលសួរបញ្ហា ហើយអង្គុយស្ងៀម ។

ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ព្រះអានន្ទនោះហើយ ទ្រង់ត្រិះរិះ ថា អានន្ទពោលបញ្ហាដែលជាពុទ្ធវិស័យថា ជារបស់ងាយសម្រាប់ខ្លួន ដូច លូកដៃដើម្បីចាប់កវគ្គព្រហ្ម ដូចព្យាយាមដើម្បីទម្លាយភ្នំសិនេរុ ហើយនាំរំអិល ចេញ ដូចជ្រាបថ្នាំនឹងឆ្លងមហាសមុទ្រដោយមិនមានទូក និងដូចព្យាយាមត្រឡប់ ផែនដី កាន់យកឱជារបស់ផែនដី ដូច្នេះហើយ ត្រាស់ថា **មា ហោរំ** *ជាដើម ។*

ហ *អក្ខរៈ ក្នុងបទថា* **មា ហោរំ** *នោះ ត្រឹមតែជានិបាត អធិប្បាយថា អ្នកកុំ ពោលយ៉ាងនោះ មួយទៀត ព្រះមានព្រះភាគ កាលនឹងញុំាងព្រះអានន្ទឲ្យ លះបង់ខ្លះ ឲ្យអស់សេចក្តីត្រេកអរខ្លះ ទើបត្រាស់ថា* **មា ហោរំ** *ដូច្នេះ ក្នុងបទ នោះ ព្រះមានព្រះភាគកាលញុំាងព្រះអានន្ទឲ្យលះបង់ ទើបត្រាស់ថា ម្នាល*

អានន្ទ អ្នកជាអ្នកមានបញ្ញាច្រើន មានសេចក្តីឈ្លាស ព្រោះហេតុនោះ បដិច្ច-សមុប្បាទជ្រាលជ្រៅ និងប្រាកដជារបស់ជ្រាលជ្រៅ អ្នកមិនគួរយល់ថា បដិច្ចសមុប្បាទសូម្បីជ្រាលជ្រៅ ក៏ប្រាកដជារបស់ងាយដល់អ្នក ទាំងជារបស់ងាយដល់អ្នកដទៃផង ដូច្នេះ ។

ក្នុងរឿងនោះអាចារ្យទាំងឡាយ រមែងពោលដល់ឧបមា ៤ ប្រការ ជនទាំងឡាយសម្លឹងមើលថ្មរបស់អ្នកប្រជាល់ ក្នុងចន្លោះអ្នកប្រជាល់ធំ អ្នកធំខ្ពស់ អ្នកសម្ផស្សនឹងរសអាហារដែលល្អរហូតដល់ ៦ ខែ ធ្វើការបញ្ចេញកម្លាំងលើកថ្មរបស់អ្នកប្រជាល់ ដែលសម្តែងក្នុងពេលមានមហោស្រព អ្នកទៅកាន់យុទ្ធភូមិ ត្រូវអ្នកប្រជាល់ពោលថា នេះអ្វី ថ្មរបស់អ្នកប្រជាល់ ពួកលោកចូរនាំថ្មនោះមក កាលជនទាំងឡាយនិយាយថា ពួកយើងលើកមិនរួចទេ បុរសនោះក៏ទៅដោយខ្លួនឯង ពោលថា ទម្ងន់របស់ថ្មនេះ មានត្រង់ណា ហើយលើកថ្ម ២ ដុំឡើង ដោយដៃទាំង ២ ហើយគ្រវែងទៅជូចលេងកូនប៊ូល ហើយក៏ទៅ ក្នុងរឿងនោះ គួរនិយាយបានថា ថ្មរបស់អ្នកប្រជាល់ ជារបស់ស្រាលដល់អ្នកប្រជាល់ មិនស្រាលដល់ពួកអ្នកដទៃ ពិតហើយ ព្រះអានន្ទដល់ព្រមហើយដោយអភិនីហារអស់សែនកប្ប ដូចអ្នកប្រជាល់ដែលសម្ផស្សនឹងរសអាហារដ៏ល្អរហូតដល់អស់ ៦ ខែ ថ្មរបស់អ្នកប្រជាល់ជារបស់ស្រាល ព្រោះអ្នកប្រជាល់ជាអ្នកមានកម្លាំងច្រើន យ៉ាងណា បដិច្ចសមុប្បាទជារបស់ងាយ ព្រោះព្រះថេរៈជាអ្នកមានបញ្ញាច្រើន ដូច្នោះ មិនគួរពោលថា បដិច្ច-សមុប្បាទ ងាយដល់ពួកអ្នកដទៃផងទេ ។

ម្យ៉ាងទៀត ក្នុងមហាសមុទ្រ ត្រីឈ្មោះតិមិទំហំ ២០០ យោជន៍ ឈ្មោះ

តិមិង្គលៈ ទំហំ ៣០០ យោជន៍ ឈ្មោះតិមិតិមិង្គលៈ ទំហំ ៤០០ យោជន៍ ឈ្មោះតិមិរមិង្គលៈ ទំហំ ៥០០ យោជន៍ ។ ត្រី ៤ ប្រភេទនេះ គឺត្រីអានន្ទ ត្រីតិមិន្ទៈ ត្រីអជ្ឈារោហៈ ត្រីមហាតិមិ ទំហំ ១០០០ យោជន៍ ក្នុងបទនោះ អាចារ្យទាំងឡាយ សម្តែងដល់ត្រីឈ្មោះតិមិរមិង្គលៈតែម្យ៉ាង បានពួថា កាលត្រីតិមិរមិង្គលៈនោះ កម្រើកព្រុយស្តាំ ទឹករលកវាយយកទៅដល់ ៥០០ យោជន៍ កម្រើកព្រុយឆ្វេង កន្ទុយ ក្បាល ក៏ដូចគ្នា តែបើត្រីឈ្មោះតិមិរមិង្គលៈនោះ កម្រើកព្រុយទាំងពីរខាង យកកន្ទុយបក់ទឹក គ្រវីក្បាលទៅមក ប្រារព្ធដើម្បីនឹងលេងទឹកក្នុងទី ៧-៨ រយយោជន៍ រមែងក្តៅពុះ ដូចទឹកដែលដាក់ក្នុងកាជនៈ ដែលលើកឡើងពីចង្រ្កាន ដូច្នោះ ទឹកក្នុងទីប្រមាណ ៣០០ យោជន៍ មិនអាចនឹងលិចផុតខ្នងបាន គេគប្បីពោលយ៉ាងនេះថា ជនទាំងឡាយនាំគ្នានិយាយថា មហាសមុទ្រនេះជ្រៅ តើជ្រៅមកអំពីណា ពួកយើងមិនបានទឹកសូម្បីត្រឹមតែលិចខ្នង ព្រោះមហាសមុទ្រនោះជ្រៅណាស់ ក្នុងសេចក្តីនោះ គួរពោលថា សម្រាប់ត្រីឈ្មោះតិមិរមិង្គលៈលិចទៅទាំងខ្លួន មហាសមុទ្រពក់ សម្រាប់ពួកត្រីតូចៗ ដទៃវិញ មហាសមុទ្រមិនពក់ឡើយ គួរពោលថា សម្រាប់ព្រះថេរៈ អ្នកចូលដល់ញាណ បដិច្ចសមុប្បាទជារបស់ពក់ សម្រាប់ពួកអ្នកដទៃមិនពក់យ៉ាងនោះដូចគ្នា ។

ម្យ៉ាងទៀត ស្តេចគ្រុឌទំហំប្រមាណ ១៥០ យោជន៍ ស្ងាបស្តាំរបស់ស្តេចគ្រុឌប្រមាណ ៥០ យោជន៍ ស្ងាបឆ្វេងក៏ដូចគ្នា កន្ទុយប្រមាណ ៦០ យោជន៍ កប្រមាណ ៣០ យោជន៍ ចំពុះ ៩ យោជន៍ ជើងទាំងពីរប្រមាណ ១២ យោជន៍ កាលស្តេចគ្រុឌនោះសម្តែងខ្យល់របស់ស្តេចគ្រុឌ ទី ៧-៨ រយយោជន៍

មិនល្មមគ្រប់គ្រាន់ គេគប្បីពោលយ៉ាងនេះថា គេទាំងឡាយនិយាយគ្នាថា អាកាសនេះមិនមានទីបំផុត អាកាសនេះមិនមានទីបំផុតអំពីណា ពួកយើងមិនបាន សូម្បីឱកាសដែលនឹងទុកស្ថាប ព្រោះអាកាសនោះមិនមានទីបំផុត ក្នុងសេចក្តីនោះគប្បីពោលថា អាកាសរបស់ស្តេចគ្រុឌគួរចូលទៅដល់ទាំងខ្លួនតូចចង្អៀត របស់ពួកសត្វតូចៗ ជាទៃ មិនតូចចង្អៀត គប្បីពោលថា បដិច្ច-សមុប្បាទរបស់ព្រះថេរៈអ្នកចូលដល់ញាណនុ៎ះឯងភក់ របស់អ្នកជាទៃ មិនភក់យ៉ាងនោះដូចគ្នា ។

ម្យ៉ាងទៀត រាហូអសុរិន្ទ តាំងពីចុងសក់ដល់បាទជើង មានកម្ពស់ ៤៨០០ យោជន៍ ចន្លោះដៃទាំងពីរខាងរបស់រាហូអសុរិន្ទ ប្រវែង ១២០០ យោជន៍ កម្រាស់ គឺទទឹងខ្លួន ៦០០ យោជន៍ ផ្ទៃបាតដៃបាតជើង ២០០ យោជន៍ ច្រមុះ ៣០០ យោជន៍ មាត់ក៏ដូចគ្នា ថ្នាំងម្រាមដៃមួយថ្នាំងៗ ៥០ យោជន៍ ចន្លោះចញ្ចើម ក៏ដូចគ្នា ថ្ងាស ៣០០ យោជន៍ ក្បាលទំហំ ៩០០ យោជន៍ កាលរាហូអសុរិន្ទនោះ ជាក់ជើងចុះទៅក្នុងមហាសមុទ្រ ទឹកមានប្រមាណត្រឹមក្បាលជង្គង់ រាហូគប្បីពោលយ៉ាងនេះថា ជនទាំងឡាយនាំគ្នាពោលថា មហាសមុទ្រនេះជ្រៅ មានជ្រៅឯណា ពួកយើងមិនបានទឹក សូម្បីត្រឹមតែលិចជង្គង់ ព្រោះមហាសមុទ្រនោះជ្រៅ សម្រាប់រាហូដែលចុះទៅទាំងខ្លួន ក្នុងមហាសមុទ្រនោះភក់ សម្រាប់ពួកអ្នកជាទៃមិនភក់ គប្បីពោលថា បដិច្ចសមុប្បាទរបស់ព្រះថេរៈ ដែលចូលដល់ញាណ ជារបស់ងាយ ឯអ្នកជាទៃមិនងាយទេ ដូច្នេះ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលដូច្នោះ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនោះ ដូច្នេះ ទ្រង់សំដៅដល់សេចក្តីនោះ ។ ពិត

ហើយ បដិច្ចសមុប្បាទ សូម្បីជ្រៅ ដែលប្រាកដថា ជារបស់ងាយ ដល់ព្រះ
ថេរៈដោយហេតុ ៤ ប្រការ ហេតុ ៤ ប្រការ តើដូចម្តេច ដោយការដល់
ព្រមដោយឧបនិស្សយក្នុងជាតិមុន ដោយការនៅក្នុងសម្នាក់គ្រូ ដោយភាព
ជាព្រះសោតាបន្ន ដោយភាពជាពហុស្សូត ។ បានព្ថថា រាប់ត្រឡប់ពីភទ្ទ-
កប្បនេះទៅ ១ សែនកប្ប ព្រះសាស្តាព្រះនាមថាបទុមុត្តរៈ ទ្រង់កើតឡើងក្នុង
លោក នគររបស់ព្រះអង្គឈ្មោះហង្សវតី ព្រះរាជបិតាព្រះនាមថា អានន្ទ
ព្រះរាជមាតាព្រះនាមថា សុមេធាទេវី ព្រះពោធិសត្វមានព្រះនាមថា ឧត្តរ-
កុមារ ព្រះពោធិសត្វនោះ ក្នុងថ្ងៃដែលព្រះឱរសប្រសូត ស្តេចចេញមហាភិ-
នេស្ក្រមណ៍ ទ្រង់ព្រះផ្ទូស ទ្រង់ប្រកបសេចក្តីព្យាយាម សម្រេចព្រះសព្វញ្ញុ-
តញ្ញាណដោយលំដាប់ ទ្រង់បន្ទឺឧទានថា **អនេកជាតិសំសារំ** ដូច្នេះជាដើម
ញ្ចុំងសប្តាហ៍មួយឲ្យកន្ទងទៅត្រង់ពោធិបល្ល័ង្ក ហើយទ្រង់ត្រិះរិះថា តថាគត
នឹងជាន់លើផែនដី ដូច្នេះហើយ ទ្រង់ដាក់ព្រះបាទចុះ រំពេចនោះ មហាបទុម
ទម្ងាយផែនដីផុសឡើងហើយ ត្របករបស់បទុមនោះ ៩០ ហត្ត កេសរ ៣០
ហត្ត ផ្ទែឈូក ១២ ហត្ត លម្អងប្រមាណ ៩ ក្អម ព្រះសាស្តាមានកម្ពស់ ៥៨
ហត្ត ចន្ទោះព្រះពាហាទាំងពីររបស់ព្រះអង្ត ១៨ ហត្ត ព្រះនលាដ ៥ ហត្ត
ព្រះហស្ត និងព្រះបាទទាំងពីរ ១១ ហត្ត កាលព្រះសាស្តាទ្រង់ជាន់ ដល់ផ្ទែ
ឈូក ១២ ហត្ត ដោយព្រះបាទ ១១ ហត្ត លម្អងប្រមាណ ៩ ក្អម ហុយឆ្ងាយ
ឡើងកាន់សរីរប្រទេសប្រមាណ ៥៨ ហត្ត បាចសាចដូចលម្អិតនៃមនោ-
សិលា អាស្រ័យហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ប្រាកដព្រះនាមថា
ព្រះបទុមុត្តរៈ ។ ព្រះអង្គមានអគ្គសាវ័ក ២ រូប គឺព្រះទេវីលៈ និងព្រះសុជាត

อคฺคสาวิกา ๒ รูป คือนางอมิตา และนางอสมา อุปฏฺฐากเฬ่าพระสุมนะ ฯ
พระมีพระภาคพระนามว่าปทุมุตฺตระ มีภิกษุหนึ่งแสนอสงไขยเป็นบริวาร ทรงทำ
การอนุเคราะห์พระชนก ประทับอยู่ในราชธานีหังสวดี ฯ ส่วนพระกนิฏฐ-
ภาดาของพระปทุมุตฺตระ พระนามว่าสุมนกุมาร พระราชาได้พระราชทานสุวรรณ-
ภูมิประเทศ แก่พระราชกุมาร ในที่ประมาณ ๒๐๐๐ โยชน์[๑] ห่างจากหังสวดี-
นคร พระสุมนกุมารนั้น เวลาต่อมา เสด็จมาเฝ้าพระชนก และพระ-
ศาสดา วันหนึ่ง ได้ทูลขอพระราชบิดา พระราชบิดาได้ตรัสว่า ดีแล้ว
พระราชบิดาตรัสถามว่า ดีแล้ว พระราชกุมารทรงส่งข่าวไปถวายพระราช-
บิดา ตรัสบอกว่า ดีแล้ว พระราชบิดาทรงส่งข่าวตอบมาว่า
เราตามหาเจ้าอยู่ในที่นั้นเพื่ออะไร พระราชกุมารนั้น เสด็จเข้าไปสู่ป่าแล้ว
ได้ทรงสังหารโจรทั้งหลาย แล้วจึงส่งข่าวไปถวายพระราชบิดาว่า โจรสังหาร
แล้ว พระราชบิดาทรงพระโสมนัส ตรัสว่า โอรสของเราจงมา
ด้วยยานช้างเถิด พระโอรสนั้น มีอมาตย์ประมาณ ๑๐๐๐ ในที่ใกล้ทาง
พระองค์ทรงได้ปรึกษากับอมาตย์ทั้งหลายนั้นว่า พระชนกของเราทรงพระ-
โสมนัส เพราะพระชนกนี้ได้พรจากเรา เราจักนำอะไรไปดี
อมาตย์พวกหนึ่งทูลว่า ขอพระองค์ทูลขอที่ดิน เหล่า ชนบท-
กัลยาณี ๗ คน มีอีกพวกหนึ่งทูลว่า พระองค์เป็นโอรสของพระเจ้าแผ่นดิน
ทรัพย์ของพระองค์ได้มีไม่น้อย มีอีกพวกหนึ่งทูลว่า พระองค์ได้ทรัพย์แล้ว
ก็ควรละทิ้งทรัพย์ทั้งหมดนั้นไป พระองค์ควรขอบุญเท่านั้น เพราะ
ผู้ใหญ่ เมื่อพระราชาพระราชทานพร ขอจงทรงได้รับพรเพื่อทำนุบำรุง

๑- *ในที่อื่นว่า ๑๒๐ โยชน์ ฯ*

ព្រះមានព្រះភាគព្រះនាមថាបទុមុត្តរ: រហូតអស់ ៣ ខែចុះ ព្រះរាជកុមារនោះ
ត្រាស់ថា ពួកលោកជាកល្យាណមិត្តរបស់យើង យើងមិនមានសេចក្តីគិត
ដូច្នេះទ្បើយ ពួកលោកធ្វើឲ្យយើងកើតសេចក្តីគិត យើងនឹងធ្វើយ៉ាងនោះ
ហើយយាងទៅគាល់ព្រះជនក ព្រះជនកទ្រង់អោប ហើយជប់ត្រង់ព្រះសិរសា
ត្រាស់ថា កូនសម្ងាញ់ ឪពុកនឹងឲ្យពរដល់កូន ដូច្នេះ ព្រះរាជកុមារទូលថា
បពិត្រព្រះបិតា បុត្រសូមនូវការទំនុកបម្រុងព្រះមានព្រះភាគដោយបច្ចយ ៤
រហូតអស់ ៣ ខែ ប្រាថ្នាធ្វើជីវិតមិនឲ្យសោះសូន្យ សូមព្រះបិតាព្រះរាជទាន
ពរនេះដល់បុត្រចុះ ព្រះរាជាត្រាស់ថា កូនសម្ងាញ់ បិតាមិនអាចឲ្យពរនោះ
បានទេ បិតានឹងឲ្យពរដទៃ ព្រះសុមនរាជកុមារទូលថា បពិត្រព្រះបិតា ធម្មតា
ក្សត្រទាំងឡាយ មិនមានព្រះតម្រាស់បែកជាពីរទ្បើយ សូមព្រះបិតាព្រះរាជ-
ទានពរនោះដល់បុត្រចុះ បុត្រមិនត្រូវការពរដទៃទេ ព្រះរាជបិតាត្រាស់ថា កូន
សម្ងាញ់ ធម្មតាព្រះពុទ្ធទាំងឡាយមានព្រះហឬទ័យដឹងបានលំបាក បើព្រះមាន
ព្រះភាគទ្រង់នឹងមិនប្រាថ្នា យើងនឹងឲ្យពរបានដូចម្តេច ព្រះសុមនរាជកុមារ
នោះទូលថា បពិត្រព្រះបិតា បុត្រនឹងជ្រាបព្រះហឬទ័យរបស់ព្រះមានព្រះភាគ
ដូច្នេះហើយ យាងទៅកាន់ព្រះវិហារ ។

ដោយសម័យនោះ ព្រះមានព្រះភាគ កាលសោយព្រះក្រយាហារ
ហើយ ស្តេចបានចូលគន្ធកុដិ ព្រះសុមនរាជកុមារនោះ បានទៅកាន់សម្នាក់
របស់ភិក្ខុទាំងឡាយ ដែលអង្គុយនៅក្នុងបារាំ ភិក្ខុទាំងនោះ ពោលនឹងព្រះ
សុមនរាជកុមារថា ព្រះរាជបុត្រ ព្រះអង្គយាងមកដើម្បីអ្វី ព្រះសុមនរាជ-
កុមារត្រាស់ថា ដើម្បីគាល់ព្រះមានព្រះភាគ សូមលោកម្ចាស់ទាំងឡាយ

បង្ហាញព្រះមានព្រះភាគដល់ខ្ញុំចុះ ភិក្ខុទាំងឡាយពោលថា ព្រះរាជបុត្រ ពួកអាត្មាមិនបានឃើញព្រះសាស្តា ក្នុងខណៈដែលប្រាថ្នាហើយប្រាថ្នាទៀត ព្រះសុមនរាជកុមារត្រាស់ថា បពិត្រលោកម្ចាស់ អ្នកណាហ្ន៎បានឃើញ ភិក្ខុទាំង-ឡាយពោលថា ព្រះរាជបុត្រ ព្រះសុមនត្តេរបានឃើញ ព្រះសុមនរាជកុមារ ត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រះថេរៈនៅទីណា ហើយត្រាស់សួរដល់ទី ដែលព្រះថេរៈគង់ ទើបស្តេចទៅថ្វាយបង្គំ ហើយត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំចង់គាល់ព្រះមានព្រះភាគ សូមលោកម្ចាស់មេត្តាបង្ហាញដល់ខ្ញុំចុះ ព្រះថេរៈ ពោលថា ព្រះរាជបុត្រយាងមកចុះ ហើយនាំសុមនរាជកុមារ ទៅកាន់ទី បរិវេណព្រះគន្ធកុដិ ព្រះថេរៈឡើងទៅកាន់ព្រះគន្ធកុដិ លំដាប់នោះ ព្រះមាន ព្រះភាគត្រាស់សួរថា សុមនៈ អ្នកមកព្រោះអ្វី ព្រះថេរៈក្រាបទូលថា បពិត្រ ព្រះអង្គដ៏ចម្រើន រាជឱរសមកគាល់ព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរក្រាលអាសនៈចុះ ព្រះថេរៈបានក្រាលអាសនៈហើយ ព្រះ មានព្រះភាគប្រថាប់លើអាសនៈដែលក្រាលហើយ ព្រះរាជឱរសថ្វាយបង្គំព្រះ មានព្រះភាគហើយ ទ្រង់បានធ្វើបដិសណ្ឋារៈ ព្រះមានព្រះភាគត្រាស់សួរថា អ្នកមកតាំងពីពេលណា រាជបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាល ទ្រង់ចូលគន្ធកុដិ តែភិក្ខុទាំងឡាយពោលថា ពួកអាត្មាក៏មិនបានឃើញព្រះមាន ព្រះភាគ ក្នុងខណៈដែលប្រាថ្នាហើយប្រាថ្នាទៀតឡើយ បញ្ជូនខ្ញុំព្រះអង្គឲ្យ មករកព្រះថេរៈ តែព្រះថេរៈបានបង្ហាញត្រឹមតែពាក្យមួយប៉ុណ្ណោះ បពិត្រ ព្រះអង្គដ៏ចម្រើន ព្រះថេរៈប្រហែលជាអ្នកប្រាសប្រាណ ក្នុងសាសនារបស់ ព្រះអង្គទេដឹង ព្រះអង្គត្រាស់ថា ត្រូវហើយកុមារ ភិក្ខុនោះ ជាអ្នកប្រាស

ប្រាណ ក្នុងសាសនារបស់តថាគត ព្រះរាជកុមារក្រាបទូលថា បពិត្រព្រះអង្គ ដ៏ចម្រើន ភិក្ខុទាំងឡាយធ្វើអ្វី ទើបជាអ្នកប្រាសប្រាណ ក្នុងសាសនារបស់ ព្រះពុទ្ធទាំងឡាយ ព្រះសាស្តាត្រាស់ថា រាជកុមារ បុគ្គលឲ្យទាន សមាទាន សីល រក្សាឧបោសថ និងបានជាអ្នកប្រាសប្រាណក្នុងសាសនារបស់ព្រះពុទ្ធ ទាំងឡាយ ព្រះរាជកុមារក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គប្រាថ្នា ជាអ្នកប្រាសប្រាណក្នុងព្រះពុទ្ធសាសនាដូចព្រះថេរៈ សូមព្រះអង្គទ្រង់ទទួល និមន្តន៍នៅចាំវស្សាអស់កាល ៣ ខែ ដល់ខ្ញុំព្រះអង្គចុះ ព្រះមានព្រះភាគ ទ្រង់ពិចារណាមើលថា ការទៅក្នុងទីនោះ នឹងមានប្រយោជន៍ឬហ្ន៎ ទ្រង់ឃើញ ថា មាន ទើបត្រាស់ថា រាជកុមារ ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុង សុញ្ញាគារ ព្រះកុមារក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គជ្រាប ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងហើយ ហើយក្រាបទូលថា បពិត្រព្រះ អង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងត្រឡប់ទៅមុន ហើយសាងទីប្រថាប់ កាលខ្ញុំព្រះ អង្គបញ្ជូនដំណឹងមកហើយ សូមទ្រង់យាងទៅ មួយអន្លើដោយភិក្ខុ ១ សែន រូប កាលទទួលប្តេជ្ញាហើយ ទើបយាងទៅគាល់ព្រះជនក ក្រាបទូលថា បពិត្រព្រះបិតា ព្រះមានព្រះភាគ ទ្រង់ឲ្យប្តេជ្ញាដល់ទូលបង្គំហើយ កាលទូល បង្គំបញ្ជូនដំណឹងមក សូមព្រះបិតាយាងព្រះមានព្រះភាគទៅផង ដូច្នេះហើយ ថ្វាយបង្គំព្រះជនក យាងចេញទៅសាងព្រះវិហារក្នុងទី ១ យោជន៍មួយៗ ស្តេចទៅផ្លូវឆ្ងាយដល់ ២០០០ យោជន៍ ទ្រង់ជ្រើសរើសស្ថានទីសាងវិហារ ក្នុងនគរបស់ព្រះអង្គ ទតឃើញឧទ្យានរបស់កុដុម្ពីឈ្មោះសោភៈ ទ្រង់ទិញមួយ សែន ទ្រង់លះបង់មួយសែនសាងព្រះវិហារ ក្នុងព្រះវិហារនោះ សុមនរាជ-

กุมาร ទ្រង់សាងព្រះគន្ធកុដិថ្វាយព្រះមានព្រះភាគ និងកុដិសម្រាប់ពួនសម្ងំ និងមណ្ឌបដើម្បីជាទីសម្រាកពេលយប់ និងពេលថ្ងៃរបស់កិក្ខុដ៏សេស ធ្វើ កំពែងព័ទ្ធជុំវិញ និងសាងខ្ញោងទ្វារសម្រេចហើយ ទើបបញ្ជូនដំណឹងឲ្យព្រះ ជនក ទ្រង់ជ្រាបថា កិច្ចរបស់បុត្រសម្រេចហើយ សូមព្រះបិតាទ្រង់យាងព្រះ សាស្តាមកចុះ ។ ព្រះរាជាទ្រង់អង្គាសព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ កិច្ចរបស់សុមនៈសម្រេចហើយ គេទន្ទឹងការយាងទៅ របស់ព្រះអង្គ ដូច្នេះ ព្រះមានព្រះភាគមានភិក្ខុមួយសែនជាបរិវារ ប្រថាប់នៅ ក្នុងព្រះវិហារទាំងឡាយក្នុងទី ១ យោជន៍មួយៗ ស្តេចទៅហើយ ព្រះរាជ-កុមារទ្រង់ស្តាប់ថា ព្រះសាស្តាស្តេចយាងមក ទើបយាងទៅទទួលអស់ផ្លូវ មួយយោជន៍ ទ្រង់បូជាដោយរបស់ក្រអូប និងផ្កាជាដើម ទូលអារាធនាព្រះ មានព្រះភាគ ឲ្យស្តេចយាងចូលទៅកាន់ព្រះវិហារ ហើយទូលថា

បពិត្រព្រះមហាមុនី សូមទ្រង់ទទួលអារាមឈ្មោះសោភណៈ ដែល ខ្ញុំព្រះអង្គទិញមកដោយទ្រព្យមួយសែន សាងដោយទ្រព្យមួយសែនទៀត ហើយវេរព្រះវិហារថ្វាយ ។

សុមនរាជកុមារនោះ ក្នុងថ្ងៃចូលវស្សាថ្វាយទាន ហើយត្រាស់ហៅឱរស និងជាយារបស់ព្រះអង្គ និងអមាត្យទាំងឡាយមក ត្រាស់ថា ព្រះសាស្តា អង្គនេះ មកកាន់សម្នាក់របស់យើងអំពីចម្ងាយ ម្យ៉ាងទៀត ធម្មតាព្រះពុទ្ធ ទាំងឡាយ ជាអ្នកជ្ងន់ក្នុងធម៌ មិនសម្ញឹងចំពោះអាមិស ព្រោះដូច្នោះ ខ្ញុំនឹង ស្មៀកជណ្តប់សំពត់សាដក ២ ផ្ទាំង សមាទានសីល នៅក្នុងទីនេះឯង រហូត ដល់អស់ ៣ ខែនេះ ពួកអ្នកទាំងឡាយ ចូរថ្វាយទានដល់ព្រះខីណាស្រព

មួយសែនរូប ដោយទំនងនេះឯងអស់កាល ៣ ខែចុះ ។

សុមនរាជកុមារនោះ គង់នៅក្នុងកន្លែងដែលមានចំណែកស្មើគ្នានឹងទីនៅរបស់ព្រះសុមនត្ថេរ ទ្រង់ឃើញវត្តបដិបត្តិដែលព្រះថេរៈធ្វើចំពោះព្រះមានព្រះភាគទាំងអស់ ទើបត្រិះរិះថា ព្រះថេរៈនេះជាអ្នកប្រាសប្រាណដោយចំណែកតែមួយក្នុងទីនេះ អញគួរប្រាថ្នាឋានន្តរបស់ព្រះថេរៈនេះចុះ កាលជិតដល់ថ្ងៃបវារណា ស្តេចចូលទៅកាន់ស្រុក ទ្រង់បរិច្ចាគទានធំអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់តាំងត្រៃចីវរទុកក្នុងទីជិតជើងរបស់ភិក្ខុមួយសែនរូប ថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្យឯណាដែលខ្ញុំព្រះអង្គធ្វើហើយ ចាប់តាំងពីការសាងព្រះវិហារ ដែលមានក្នុងចន្លោះមួយយោជន៍ៗ តាមផ្លូវ បុណ្យនោះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសគ្គសម្បត្តិ មារ-សម្បត្តិ និងព្រហ្មសម្បត្តិទេ ប្រាថ្នាតែតំណែងឧបដ្ឋាករបស់ព្រះពុទ្ធ ទើបបានធ្វើ ព្រោះដូច្នោះ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ក៏នឹងគប្បីបានជាឧបដ្ឋាករបស់ព្រះពុទ្ធ ក្នុងអនាគតដូចព្រះសុមនត្ថេរ ហើយក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ព្រះមានព្រះភាគ ទ្រង់ពិចារណាមើលថា ចិត្តជំរៃលែងរបស់កុលបុត្រនឹងសម្រេចឬទេហ្ន៎ ទ្រង់ជ្រាបថា ក្នុងអនាគតក្នុងកប្បទី ១ សែន បន្ទាប់ពីកប្បនេះទៅ ព្រះពុទ្ធព្រះនាមថា គោតមទ្រង់នឹងកើតឡើង សុមនៈនេះ នឹងជាឧបដ្ឋាករបស់ព្រះពុទ្ធអង្គនោះ ទើបទ្រង់ត្រាស់ថា

សេចក្តីប្រាថ្នា ដែលតម្កល់ទុកទាំងអស់នោះឯង ចូរ
សម្រេចដល់អ្នក សេចក្តីត្រិះរិះត្រូវទាំងឡាយ ចូរពេញ
ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើតចុះ ដូច្នេះ ។

ព្រះកុមារទ្រង់ស្តាប់ដូច្នោះ ទើបត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ

រមែងមានព្រះតម្រាស់មិនបែកជាពីរដូច្នេះ ក្នុងថ្ងៃទីពីរនុ៎ះឯង ទ្រង់ទទួលបាត្រ និងចីវររបស់ព្រះមានព្រះភាគអង្គនោះហើយ បានធ្វើដូចជាទ្រង់យាងទៅតាមក្រោយ ព្រះរាជកុមារនោះថ្វាយទានក្នុងពុទ្ធុប្បាទនោះ រហូតដល់អស់មួយសែនឆ្នាំ ទ្រង់ទៅកើតក្នុងស្ថានសួគ៌ ក្នុងកាលសាសនារបស់ព្រះពុទ្ធកស្សប ក៏បានថ្វាយសំពត់សាជកសាច់ល្អ កាលទទួលបាត្ររបស់ព្រះថេរៈ ដែលត្រាច់ទៅបិណ្ឌបាតហើយ ទ្រង់បានធ្វើការបូជា បានទៅកើតក្នុងសួគ៌ទៀត ចុតិអំពីនោះហើយ បានជាស្តេចនគរពារាណសី ទ្រង់សាងបណ្ណសាលាថ្វាយព្រះបច្ចេកពុទ្ធ ៨ អង្គ តាំងឆ្នាំងទឹកថ្វាជូចកែវមណីទុក ទ្រង់បានធ្វើការទំនុកបម្រុងដោយបច្ច័យ ៤ រហូតអស់ ១ ម៉ឺនឆ្នាំ ហេតុទាំងនេះ ប្រាកដច្បាស់ហើយ ។

ព្រះសុមនរាជកុមារនោះ ទ្រង់បរិច្ចាគទានតែម្យ៉ាង រហូតដល់អស់មួយសែនកប្ប ទ្រង់កើតក្នុងតុសិតភពជាមួយនឹងព្រះពោធិសត្វនៃយើង លុះចុតិអំពីតុសិតភពនោះ បានបដិសន្ធិក្នុងព្រះដំណាក់របស់ព្រះបាទសក្យៈ ព្រះនាមថា អមិតោទនៈ កាលព្រះមានព្រះភាគ ទ្រង់ចេញព្រះផ្នួសដោយលំដាប់ បានសម្រេចសម្មាសម្ពោធិញ្ញាណហើយ ទ្រង់យាងទៅកាន់នគរកបិលពស្តុ លើកទីមួយ ហើយស្តេចចេញចាកក្រុងកបិលពស្តុ កាលព្រះរាជកុមារទាំងឡាយនាំគ្នាទ្រង់ព្រះផ្នួស ដើម្បីជាបរិវាររបស់ព្រះមានព្រះភាគ ស្តេចចេញព្រមនឹងស្តេចសក្យៈទាំងឡាយ មានព្រះកទ្ទិយៈជាដើម ទ្រង់ព្រះផ្នួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ មិនយូរប៉ុន្មាន បានស្តាប់ធម្មកថា ក្នុងសម្នាក់របស់ព្រះបុណ្ណមន្តានីបុត្តហើយ តាំងនៅក្នុងសោតាបត្តិផល ព្រះថេរៈនេះ ជា

អ្នកដល់ព្រមដោយឧបនិស្សយ ក្នុងជាតិមុនដោយប្រការដូច្នេះ ។ បដិច្ច-សមុប្បាទ សូម្បីជ្រាលជ្រៅ ក៏ច្បាកដដូចជារបស់ងាយ ព្រោះសេចក្តីដល់ព្រមដោយឧបនិស្សយក្នុងជាតិមុនរបស់ព្រះថេរៈនោះ ។

កេចិអាចារ្យពោលដល់ការរៀន ការស្តាប់ ការសាកសួរ និងការចាំក្នុងសម្នាក់គ្រូទាំងឡាយរឿយៗ ដោយបទថា **តិត្តវាសោ** *គឺការនៅក្នុងសម្នាក់គ្រូ ការនៅក្នុងសម្នាក់គ្រូនោះរបស់ព្រះថេរៈ បរិសុទ្ធយ៉ាងក្រៃលែង ដោយហេតុនោះ បដិច្ចសមុប្បាទនេះ សូម្បីជ្រាលជ្រៅ ក៏ច្បាកដដល់ព្រះថេរៈដូចជារបស់ងាយ មួ៉ាងទៀត បច្ចយាការច្បាកដជារបស់ងាយរបស់ព្រះសោតាបន្ន ព្រះថេរៈនេះ បានជាព្រះសោតាបន្នហើយ ។*

ការកំណត់នាមរូប រមែងច្បាកដដល់លោកដែលជាពហូសូត ដូចគ្រែនិងតាំង រមែងច្បាកដ កាលប្រទីបបំភ្លឺឲ្យភ្លឺក្នុងបន្ទប់ដេកប្រមាណ ៤ ហត្ថ ព្រះថេរៈនេះ ជាឯតទគ្គៈជាងពហូសូតទាំងឡាយ បច្ចយាការសូម្បីជ្រាលជ្រៅ ក៏ច្បាកដដល់ព្រះថេរៈនោះ ដូចជារបស់ងាយ ដោយអានុភាពនៃភាពជាពហូសូត ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីងាយ និងសេចក្តីជ្រាលជ្រៅរបស់បដិច្ចសមុប្បាទនោះ បដិច្ចសមុប្បាទ ឈ្មោះថា ជារបស់ជ្រាលជ្រៅដោយអាការ ៤ យ៉ាង គឺជ្រៅដោយអត្ថ ជ្រៅដោយធម៌ ជ្រៅដោយទេសនា ជ្រៅដោយបដិវេធ ក្នុងការជ្រាលជ្រៅ ៤ យ៉ាងនោះ បដិច្ចសមុប្បាទ ជារបស់ជ្រាលជ្រៅ មានអត្ថថា មាន និងកើតឡើង ព្រោះជាតិជាបច្ច័យនៃជរា និងមរណៈ ជារបស់ជ្រាលជ្រៅ មានអត្ថថា មាន និងកើតឡើង ព្រោះអវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ព្រោះហេតុនោះ នេះឈ្មោះថា **អត្ថគម្ភីរ** *បដិច្ច-*

สมุปฺปาทชฺฌาลเชฺชเนยฺยอตฺต ฯ ปฏิจฺจสมุปฺปาทชาวปสฺสชฺฌาลเชฺช ปเรฺย มานอตฺต คือวิชฺชาชาปจฺจยานีสงฺขารทีฆทฺธาย ชฺฌาลเชฺช ปเรฺยมานอตฺต คี ชาติชาปจฺจยานีชร นิมรณ: นีเรฺยกฺขาติ **ธมฺมคฺคี** *ปฏิจฺจสมุปฺปาท ชฺฌาลเชฺชเนยฺยธมฺ ฯ กฺขนฺธสุตฺตนฺเต ทฺวีสมฺเปนฺตปฏิจฺจสมุปฺปาทเนยฺย อนุโลม กฺขนฺธสุตฺตนฺเต เนยฺยปฏิโลม กฺขนฺธสุตฺตนฺเต ทฺวีนฺนมฺปิ อนุโลม นิ ปฏิโลม กฺขนฺธสุตฺตนฺเต เนยฺยอนุโลม ปเนยฺยปฏิโลมตีนฺนมฺปิ ปฏฺฐาน กณฺฑ กฺขนฺธสุตฺตนฺเตนฺเยยอนุโลม ปเนยฺยปฏิโลมตีนฺนมฺปิ ปฏฺฐานมูล กฺขนฺธสุตฺตนฺเต มานสนฺธิ ๓ สงฺเขป ๔ กฺขนฺธสุตฺตนฺเต มานสนฺธิ ๒ สงฺเขป ๓ กฺขนฺธสุตฺตนฺเต มานสนฺธิ ๑ สงฺเขป ๒ นีเรฺยกฺขาติ* **เทสนาคฺคี** *คือชฺฌาล เชฺชเนยฺยเทสนา ฯ*

ปเรฺยนฺตเรน ปฏิจฺจสมุปฺปาทชาวปสฺสชฺฌาลเชฺช มานอตฺถา มินเนฺตน อปสฺเสน อนิจฺจา ชาวปสฺสชฺฌาลเชฺช มานอตฺถา ตาวกาลิเกน ปริปีฬนสงฺขารทีฆทฺธาย มานภาค: นิวิภาค: มานอตฺถา ชาวปสฺส สูนฺย การมินทฺวลฺลาภาย การมินมฺพาตปากฏี นิวิการปฺปกติยาปิสนฺธิ- วิญฺญาณ มานอตฺถา เกวลปเรม การปกฺขคฺคาหา การมินปกฺขคฺคาหา การปงฺคนฺเตน ปฏิการปกฺขคฺคาหายปสฺสนาปมุข มานอตฺถา ชาอธิปตี ชาทฺวาร นิวิเสฏฺฐปสฺส โลก นิวิชาธมฺมานอารมฺมณปสฺสายตน: ๖ มานอตฺถา ผสฺสาหาร ปเรฺยต ปเรฺยต นิวิปฺปฏิปสฺสผสฺส: มานอตฺถา การเสวยอารมฺมณ นิวิรส นิว การเสวยวตฺถุคฺคานชีวิต คีกาพชาสุข ชาทุกฺข นิวิกณฺฑลฺๆ ปสฺสเวทนา มานอตฺถาเตกอรเกรลีนวิกงฺขลเกรลีน ขฺยาทีก สุนิว คีตณฺหา มหา-

សមុទ្រ គឺតណ្ហា ពេញបានលំបាករបស់តណ្ហា មានអត្ថថា កាន់យក ទទួល តោង ស្អាបអង្អែល កន្ទងទៅបានលំបាករបស់ឧបាទាន មានអត្ថថា ប្រមូលតាក់តែង និងការបន្សាត់ទៅក្នុងកំណើត គតិ ឋិតិ និងនិវាសស្ថានទាំងឡាយ របស់ភព មានអត្ថថា ការប្រាកដនៃជាតិ សញ្ជាតិ ការឈានចុះ ការកើតឡើងរបស់ជាតិ មានអត្ថថា អស់ទៅ សូន្យទៅ បែកធ្លាយទៅ និងប្រែប្រួលនៃជរា និងមរណៈដោយប្រការយ៉ាងនេះ សភាវៈនៃអវិជ្ជាជាដើមណា ធម៌ទាំងឡាយមានអវិជ្ជាជាដើម ជាការចាក់ផ្ទុះនូវលក្ខណៈ ដែលមានរសដោយបដិវេធណាសភាវៈ និងបដិវេធនោះ ជារបស់ជ្រាលជ្រៅ ព្រោះហេតុនោះ គប្បីជ្រាបថា នេះជា **បដិវេធគម្ភីរ** *គឺជ្រាលជ្រៅដោយការចាក់ផ្ទុះ ។*

បដិច្ចសមុប្បាទទាំងអស់នោះ ប្រាកដដល់ព្រះថេរៈដូចជារបស់ងាយ ដោយហេតុនោះ ព្រះមានព្រះភាគ កាលនឹងញុំាងព្រះអានន្ទឲ្យបំបាត់ការគិត ទើបត្រាស់ថា **មา เหวำ** *ដូច្នេះជាដើម ក៏ក្នុងសេចក្តីនេះ មានអធិប្បាយថា ម្នាលអានន្ទ អ្នកជាបុគ្គលមានបញ្ញាច្រើន មានបញ្ញាឈ្ងាស ដោយហេតុនោះ បដិច្ចសមុប្បាទ សូម្បីជារបស់ជ្រាលជ្រៅ រមែងប្រាកដដល់អ្នក ដូចជារបស់ងាយ ព្រោះដូច្នោះ អ្នកកុំគប្បីពោលយ៉ាងនេះថា បដិច្ចសមុប្បាទនេះ ប្រាកដជារបស់ងាយដល់អាត្មាអញប៉ុណ្ណោះឬ ឬថា សូម្បីដល់អ្នកដទៃដែរ ដោយក្នុងបទដែលលោកពោលថា* **អបសาเทนฺโต** *នោះ មានអធិប្បាយថា ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះថា កាលបើដូច្នោះ បដិច្ចសមុប្បាទនេះ រមែងប្រាកដដល់អញដូចជារបស់ងាយៗ ប្រសិនបើបដិច្ចសមុប្បាទនេះ រមែងប្រាកដដល់អ្នកដូចជារបស់ងាយៗ សោត ព្រោះហេតុអ្វី ទើបអ្នកមិនបានជា*

សោតាបន្នតាមធម្មតារបស់ខ្លួន អ្នកតាំងនៅក្នុងនយដែលតថាគតឲ្យហើយ ទើបសម្រេចសោតាបត្តិមគ្គ ម្នាលអានន្ទនិព្វាននេះប៉ុណ្ណោះ ជារបស់ជ្រាលជ្រៅ តែបច្ចយាការជារបស់ងាយរបស់អ្នក បើដូច្នោះ ព្រោះហេតុអ្វី អ្នកមិនដកកិលេសទាំង ៤ នេះ គឺកាមរាគសំយោជន: បដិឃសំយោជន: យ៉ាងគ្រោតគ្រាត កាមរាគានុសយ បដិឃានុសយយ៉ាងគ្រោតគ្រាត ឲ្យបានហើយធ្វើឲ្យច្បាស់នូវសកទាគាមិផល អ្នកមិនដកកិលេស ៤ ដែលជាប់ទាក់ទងជាមួយហេតុនោះឲ្យបាន ហើយធ្វើឲ្យច្បាស់នូវអនាគាមិផល អ្នកមិនដកកិលេស ៨ នេះ គឺសញ្ញោជន: ៥ មានរូបរាគ:ជាដើម ភវរាគានុសយ មានានុសយ អវិជ្ជានុសយឲ្យបាន ហើយមិនធ្វើឲ្យច្បាស់នូវព្រះអរហត្តទៅ ។ ម្យ៉ាងទៀត ព្រោះហេតុអ្វី ទើបអ្នកមិនសម្រេចសាវកបារមីញាណ ដូចព្រះសារីបុត្រ និងព្រះមោគ្គល្លាន ដែលបំពេញបារមីអស់ ១ អសង្ខ្យេយ្យ និង ១ សែនកប្ប និងអ្នកមិនសម្រេចបច្ចេកពោធិញ្ញាណ ដូចព្រះបច្ចេកពុទ្ធទាំងឡាយ ដែលបំពេញបារមីរហូត ២ អសង្ខ្យេយ្យ និង ១ សែនកប្ប ឬប្រសិនបើ បដិច្ចសមុប្បាទនោះប្រាកដជារបស់ងាយដោយប្រការទាំងពួងដល់អ្នក បើដូច្នោះ ព្រោះហេតុអ្វី ទើបអ្នកមិនធ្វើឲ្យច្បាស់នូវព្រះសព្វញ្ញុតញ្ញាណ ដូចព្រះពុទ្ធទាំងឡាយដែលបំពេញបារមីមកហើយ អស់ ៤ អសង្ខ្យេយ្យ ៨ អសង្ខ្យេយ្យ ឬ ១៦ អសង្ខ្យេយ្យ ១ សែនកប្ប អ្នកជាបុគ្គលមិនមានប្រយោជន៍អ្វីដោយការសម្រេចគុណវិសេសទាំងនេះ អ្នកចូរសម្ងឹងមើលសេចក្តីខុសភ្លាត់របស់អ្នកដោយសព្វគ្រប់ចុះថា សាវកដូចអ្នកតាំងនៅក្នុងសេចក្តីជឿងសើៗ រមែងនិយាយដល់បច្ចយាការដែលជ្រាលជ្រៅក្រៃលែងថា ប្រាកដជារបស់ងាយដល់អញដូច្នេះ

ពាក្យនិយាយនេះ របស់អ្នកនោះ ជាពាក្យនិយាយផ្ទុយគ្នានឹងព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ ពាក្យដែលកិក្ខុដូចអ្នកនឹងគប្បីពោលផ្ទុយគ្នា នឹងព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ មិនសមគួរដូច្នេះ ម្នាលអានន្ទ កាលតថាគតព្យាយាមដើម្បីសម្រេចបច្ចយាការនេះ កន្លងទៅអស់ ៤ អសង្ខ្យេយ្យ និង ១ សែនកប្ប ឈ្មោះថា ទានដែលតថាគតមិនឲ្យហើយ ដើម្បីសម្រេចបច្ចយាការ មិនមាន ឈ្មោះថា បារមីដែលតថាគតមិនបំពេញហើយមិនមាន កាលតថាគតកម្ចាត់មារព្រមទាំងសេនា ដូចមិនដកដង្ហើម ដោយគិតថា ថ្ងៃនេះតថាគតនឹងសម្រេចបច្ចយាការ មហាប្រឹថពីនេះមិនញាប់ញ័រ សូម្បីត្រឹមតែ ២ ផ្នាប់ កាលតថាគតសម្រេចបុព្វេនិវាសក្នុងបឋមយាម សម្រេចទិព្វចក្ខុក្នុងមជ្ឈិមយាម ក៏ដូចគ្នា តែក្នុងបច្ឆិមយាម ពេលជិតភ្លឺ ពេលតថាគតឃើញថា អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ដោយអាការ ៩ យ៉ាង ដូច្នេះប៉ុណ្ណោះ លោកធាតុ ១ ម៉ឺនបពេញសំឡេងកងរំពង រាប់ពាន់សំឡេង ដូចជួងត្រូវគោះដោយដំបងដែក ញាប់ញ័រដូចតំណក់ទឹកលើស្បឹកឈូក កាលត្រូវខ្យល់ដូច្នោះ ម្នាលអានន្ទ បដិច្ចសមុប្បាទនេះ ជារបស់ជ្រាលជ្រៅដល់ម៉្លេះផង ប្រាកដជាជារបស់ជ្រាលជ្រៅផង ម្នាលអានន្ទ ការមិនដឹងតាម មិនសម្រេចធម៌នេះ រមែងមិនកន្លងផុតសង្សារទៅបានឡើយ ដូច្នេះ ។

បទថា **ឯត្តស្ស ធម្មស្ស** *គឺនៃបច្ច័យធម៌នោះ ។ បទថា* **អនន្តពោធា** *គឺមិនដឹងតាម ដោយអំណាចញាតប្បរិញ្ញា គឺការកំណត់ដឹងហើយ ។ បទថា* **អបដិវេធា** *គឺមិនចាក់ធ្លុះដោយអំណាចនៃការពិចារណា ការលះ និងការកំណត់ដឹង ។ បទថា* **តន្តាកុលកជាតា** *គឺកើតជាអ្នកជំពាក់ ដូចអំបោះ*

អធិប្បាយថា សត្វទាំងឡាយខុសភ្លាត់ក្នុងបច្ចយាការនេះ រមែងជាអ្នកវឹកវរ ជំពាក់រាក់រិន មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ដូចអំបោះជាងតម្បាញរក្សាទុកមិនល្អ ត្រូវកណ្តុរកាត់ រមែងស្ទុគស្ទាញក្នុងទីនោះៗ ទើបជាការលំបាក ដែលនឹងធ្វើចុងឲ្យស្មើចុង ធ្វើដើមឲ្យស្មើដើមបាន ព្រោះមិនដឹងថា នេះចុងនេះដើម ដូច្នោះ ក្នុងការជំពាក់រាក់រិន ចាក់កណ្តាញ់របស់ផ្នែកខាងនោះ បុគ្គលដាក់អំបោះទុកក្នុងការងាររបស់បុរសចំពោះខ្លួន ក៏គប្បីធ្វើឲ្យត្រង់បាន សត្វទាំងឡាយដទៃ រៀរព្រះពោធិសត្វទាំងពីរចេញ ឈ្មោះថា អាចធ្វើបច្ចយាការឲ្យត្រង់បានតាមធម្មតារបស់ខ្លួនមិនមាន សត្វទាំងឡាយនេះ ខុសភ្លាត់ក្នុងបច្ចយទាំងឡាយ មិនអាចធ្វើបច្ចយឲ្យត្រង់បាន រមែងជំពាក់រាក់រិន ជាកំណួចដោយអំណាចទិដ្ឋិ ៦២ ដូចអំបោះជំពាក់ផ្សំដោយទឹកបាយ បុគ្គលជំដោយផ្តៅជ្រលក់មក្លឿ ចងជាកំណួចក្នុងទីនោះៗ ដូច្នោះ ក៏សត្វពួកណាមួយអាស្រ័យទិដ្ឋិទាំងឡាយ មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ។ បទថា **គុណគណ្ឋិកជាតា** គឺអំបោះផ្សំទឹកបាយរបស់ជាងតម្បាញ លោកពោលថា ជាកំណួចដូចដុំអំបោះ អាចារ្យពួកខ្លះពោលថា សម្បុករបស់សកុណីនោះ ឈ្មោះថា គុណៈ (គ្រឿងចង) ដូច្នេះក៏មាន របស់ជំពាក់ទាំងពីរយ៉ាងនោះ គប្បីប្រកបដោយន័យមុននោះឯងថា ជាការលំបាក ដែលនឹងធ្វើចុងឲ្យស្មើចុង ធ្វើដើមឲ្យស្មើដើមបាន ដូច្នេះ ។ បទថា **មុញ្ជបព្វជភ្ជតា** គឺដូចជាស្មៅជំណេកទន្សាយ និងដូចស្មៅយាប្ជង ពួកសត្វនេះ មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ជាអ្នកមានកំណួចដោយអំណាចរបស់ទិដ្ឋិ រមែងមិនផុតពីអបាយ ទុគ្គតិ វិនិបាត សង្សារ ដូចកាន់ខ្សែដែលគេជំស្មៅទាំងនោះ ហើយធ្វើជាខ្សែ

កាលខ្សែរចាស់ ក៏ទីងធ្លាក់ចុះក្នុងទីណាមួយ ទើបជាការលំបាកដែលនឹងធ្វើឲ្យ ចុងស្មើចុង ធ្វើគល់ឲ្យស្មើគល់បាន ព្រោះមិនដឹងថា នេះចុង នេះគល់នៃខ្សែ ទាំងនោះ ដូច្នោះ បុគ្គលជាក់ខ្សែនោះទុកក្នុងការងាររបស់បុរសចំពោះខ្លួន គប្បី ធ្វើឲ្យត្រង់បាន សត្វដទៃវៀរព្រះពោធិសត្វពីរពួកចេញ ឈ្មោះថា អាចធ្វើ បច្ចយាការឲ្យត្រង់តាមធម្មតារបស់ខ្លួន រមែងមិនមាន ។

ក្នុងបទទាំងនោះ បទថា **អបាយោ** *បានដល់ នរក កំណើតតិរច្ឆាន ប្រេតវិស័យ និងអសុរកាយទាំងឡាយ ពិតហើយ ទាំងអស់នោះ លោក ពោលថា អបាយ ព្រោះមិនមានសេចក្តីចម្រើន ពោល គឺ វុឌ្ឍិ ។ ម្យ៉ាងទៀត ឈ្មោះថា* **ទុគ្គតិ** *ព្រោះជាផ្លូវទៅនៃទុក្ខ ឈ្មោះថា* **វិនិបាត** *ព្រោះធ្លាក់អំពីការ តាំងខ្ពើងនៃសេចក្តីសុខ ។ចំណែកអាចារ្យក្រៅពីនេះ ពោលថា លំដាប់នៃខន្ធ ធាតុ និងអាយតនៈ នៅប្រព្រឹត្តទៅមិនដាច់ លោកពោលថា សង្សារ ។ ពួក សត្វ រមែងមិនផុត គឺមិនឈានកន្លង សូម្បីសភាពទាំងអស់នោះ លំដាប់នោះ ឯង ពួកសត្វកាន់យកចុតិ និងបដិសន្ធិរឿយៗ យ៉ាងនេះ គឺតពីចុតិដល់បដិ- សន្ធិ តពីបដិសន្ធិដល់ចុតិ រមែងវិលវល់ក្នុងភពទាំង ៣ ក្នុងកំណើតទាំង ៤ ក្នុងគតិទាំង ៥ ក្នុងវិញ្ញាណដ្ឋិតិទាំង ៧ ក្នុងសត្តាវាសទាំង ៩ ដូចទូកត្រូវ ខ្យល់បក់បោតទៅក្នុងមហាសមុទ្រ និងដូចគោដែលត្រូវទឹមក្នុងឈើយន្ត ដោយ ប្រការដូច្នេះ គប្បីជ្រាបសេចក្តីទាំងអស់នេះថា ព្រះមានព្រះភាគ កាលនឹង ញុំាងព្រះអានន្ទ ឲ្យបំបាត់សេចក្តីគិត ទើបត្រាស់ហើយ ។*

[៥៨] ឥឡូវនេះ ព្រោះសូត្រនេះ ព្រះមានព្រះភាគទ្រង់ផ្តើមដោយ បទទាំងពីរនេះឯងថា ម្នាលអានន្ទ ព្រោះមិនបានត្រាស់ដឹង ព្រោះមិនបានចាក់

ឆ្កុះនូវធម៌ទុំៈឯង ទើបពួកសត្វនេះ កើតទៅជាស្មុគ្រស្មាញដូចអំបោះរបស់ជាងតម្បាញ ដូច្នេះ កាលទ្រង់ប្រោរព្ធទេសនា ដើម្បីឃើញសេចក្តីជ្រាលជ្រៅរបស់បច្ចយាការ ដោយបន្តជាប់អំពីមុនថា ម្នាលអានន្ទ បដិច្ចសមុប្បាទនេះជ្រាលជ្រៅ ទើបត្រាស់ពាក្យជាដើមថា ជរា និងមរណៈកើតមាន ព្រោះធម៌នេះជាបច្ច័យ ដូច្នេះ ។

បច្ច័យនៃជរា និងមរណៈនេះ ឈ្មោះថា **ឥទប្បច្ចយ** *(មានធម៌នេះ ជាបច្ច័យ) ព្រោះដូច្នោះ ទើបជរា និងមរណៈ មានធម៌នេះជាបច្ច័យ ម្នាលអានន្ទ មានបុគ្គលដែលជាបណ្ឌិតសួរហើយយ៉ាងនេះថា បច្ច័យរបស់ជរា និងមរណៈមានឬ ជរា និងមរណៈគប្បីមានវត្ថុណាជាបច្ច័យ មិនគួរបដិបត្តិ ដោយអាការដែលគប្បីជាអ្នកស្ងៀមចំពោះបញ្ហា ព្រោះកាលមានអ្នកពោលថា ទុំៈជីវៈ ទុំៈសរីរៈ ហើយគួរកំណត់ទុក ឬគួរនឹងពោលថា សេចក្តីនេះ ព្រះតថាគតទ្រង់មិនព្យាករ ដូច្នេះ គួរពោលដល់បុគ្គលនោះថា មានដោយចំណែកតែមួយប៉ុណ្ណោះ ដូចជាកាលមានអ្នកពោលថា ចក្ខុទៀង ឬមិនទៀង គួរពោលដោយចំណែកតែមួយប៉ុណ្ណោះថា មិនទៀង កាលមានអ្នកពោលទៀតថា ជរា និងមរណៈមានអ្វីជាបច្ច័យ ជរា និងមរណៈ រមែងមានព្រោះបច្ច័យអ្វី ដូច្នេះ គួរពោលដល់បុគ្គលនោះដូច្នេះថា ជរា និងមរណៈ មានជាតិជាបច្ច័យ អធិប្បាយថា គួរពោលយ៉ាងនេះ ក្នុងបទទាំងអស់មានន័យយ៉ាងនេះ ។ ពាក្យនេះថា ផស្សៈ មាននាមរូបជាបច្ច័យ ព្រោះកាលពោលថា មានសឡាយតនៈជាបច្ច័យ ជាការទទួលសម្ផស្សដែលជាផល ៦ មានចក្ខុសម្ផស្សជាដើម តែក្នុងទីនេះ ព្រះមានព្រះភាគ មានបំណងសម្តែងសេចក្តីវិសេសរបស់បច្ច័យ ដែល*

កើតឡើងទទួលខ្លះ មិនទទួលខ្លះ ដោយបទនេះថា មានសឡាយតនៈជាបច្ច័យ ដូច្នេះ និងបច្ច័យដែលវិសេសជនៃរបស់ផស្សៈច្រើនជាងសឡាយតនៈ ដូច្នោះ គប្បីជ្រាបថា ទ្រង់ត្រាស់ហើយ សួរថា ដោយវារៈនេះ ព្រះមានព្រះភាគ ត្រាស់អ្វី ឆ្លើយថា ត្រាស់ហេតុនៃបច្ច័យទាំងឡាយ ពិតហើយ ព្រះសូត្រនេះ លោកពោលថា មហានិទាន ព្រោះធ្វើបច្ច័យទាំងឡាយ ឲ្យមិនមានបច្ច័យ មិនឲ្យមានការពាក់ព័ន្ធ មិនឲ្យមានការកន្ទើង ទើបពោល ឥឡូវនេះ ដើម្បីសម្តែងបច្ច័យទាំងនោះ ជាបច្ច័យពិត មិនជនៃ ទើបត្រាស់ពាក្យជាដើមថា ជរា និងមរណៈ មានជាតិជាបច្ច័យ តថាគតអធិប្បាយពាក្យនេះ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បរិយាយេន** *គឺ ដោយហេតុ ។ បទថា* **សព្ពេន សព្ពំ សព្ពថា សព្ពំ** *ទាំងពីរបទនេះជានិបាត អធិប្បាយបទនោះថា ប្រសិនបើឈ្មោះថា ជាតិទាំងអស់ មិនគប្បីមានដោយអាការទាំងអស់ មិនគប្បីមានដោយសការៈទាំងអស់ ដូច្នេះ សូម្បីក្នុងកពជាដើម គប្បីជ្រាបដោយន័យនេះឯង ។ បទថា* **កស្សចិ** *នេះ ជាពាក្យមិនពិតប្រាកដ គឺដល់បុគ្គលណាម្នាក់ ក្នុងទេវលោកជាដើម សូម្បីបទនេះថា* **កិម្ហិចិ** *ក៏ជាពាក្យមិនពិតប្រាកដដូចគ្នា គឺក្នុងទីណាមួយ ក្នុងកពទាំង ៩ មានកាមកពជាដើម ។ បទថា* **សេយ្យថីទំ** *ជានិបាត ប្រើក្នុងអត្ថថា កំណត់ក្នុងសេចក្តីមិនពិតប្រាកដ និងពង្រីកសេចក្តីសង្ខេបចេញទៅ បទនោះមានអធិប្បាយថា តថាគតនឹងពង្រីកសេចក្តីនៃបទដែលតថាគត ពោលទុកដល់បុគ្គលណាម្នាក់ ក្នុងទីណាមួយ កាលព្រះមានព្រះភាគទ្រង់ពង្រីកសេចក្តីនោះ ទើបត្រាស់ពាក្យជាដើមថា ដើម្បី*

ការ:ជាទេវតា ។

ក្នុងបទទាំងនោះ បទថា **ទេវានំ វា ទេវត្តាយ** *សេចក្តីថា ពួកទេវតា លោកពោលថា* **ទេវា** *ដោយកំណើតនៃខន្ធ ដើម្បីភាពជាទេវតានៃទេវតាទាំងឡាយ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួងដោយនយនេះឯងថា ប្រសិនបើជាតិមិនមានគ្រប់ទីទាំងពួង ដូច្នេះ ។ ក្នុងបទទាំងនេះ បទថា* **ទេវា** *គឺឧប្បត្តិទេព ។ បទថា* **គន្ធព្វា** *គឺទេវតាដែលស្ថិតនៅតាមគល់ឈើ និងដើមឈើជាដើម ។ បទថា* **យក្ខា** *គឺពួកអមនុស្ស ។ បទថា* **ភូតា** *គឺសត្វពួកណាមួយដែលកើតហើយ ។ បទថា* **បក្ខិនោ** *គឺបក្សីពួកណាមួយ មានឆ្អឹងជាស្បាបក្តី មានស្បែកជាស្បាបក្តី មានរោមជាស្បាបក្តី ។ បទថា* **សិរីសបា** *គឺសត្វពួកណាមួយ លូនវារទៅលើផែនដី ។ បទថា* **តេសំ តេសំ** *គឺបណ្តាទេវតានិងគន្ធព្វជាដើមនោះៗ ។ បទថា* **តថត្តាយ** *គឺដើម្បីភាពជាទេវតា និងគន្ធព្វជាដើម ។ បទថា* **ជាតិនិរោធា** *សេចក្តីថា ព្រោះប្រាសចាកជាតិ ព្រោះមិនមានជាតិ ។*

បទទាំងអស់មានជាដើមថា **ហេតុ** *នេះជាវេវចន:របស់* **ការណា** *នោះឯង ពិតហើយ ព្រោះហេតុ រមែងប្រាថ្នា រមែងប្រព្រឹត្តទៅដើម្បីផលរបស់ខ្លួន ដូច្នោះ ទើបលោកពោលថា ហេតុ ដូច្នេះ ព្រោះប្រគល់ផលនោះឲ្យ ដូចប្រគល់ឲ្យដោយពាក្យថា អ្នកទាំងឡាយចូរទទួលផលនេះចុះ ដូច្នេះ ដូច្នោះ ទើបលោកពោលនិទាន ព្រោះផលរមែងតាំងឡើង គឺរមែងកើតឡើងអំពីហេតុនោះ និងអាស្រ័យហេតុនោះ រមែងដល់ គឺរមែងប្រព្រឹត្តទៅ ដូច្នោះ ទើប*

លោកពោលថា **សមុទយ** *និង* **បច្ចយ** *ដូច្នេះ ក្នុងបទទាំងអស់ក៏មាននយ នេះដូចគ្នា ។ ម្យ៉ាងទៀត បទថា* **យទិទំ** *ក្នុងបទនេះថា* **យទិទំ ជាតិ** *ដូច្នេះ ជានិបាត គប្បីជ្រាបសេចក្តីនៃនិបាតនោះ ដោយអនុរូបដល់លិង្គក្នុងបទទាំង អស់ ក្នុងទីនេះ មានអធិប្បាយបទនេះ យ៉ាងនេះថា* **យា ឯសា** *ដូច្នេះ ។ ពិតហើយ ការកើតនៃជរា និងមរណៈ រមែងជាបច្ចយនៃទីបំផុតរបស់ ឧបនិស្សយ ។*

លោកធ្វើការកំណត់ឱកាសក្នុងបទនៃភព ដោយបទនេះថា **កិម្ហិចិ** *ក្នុង បទនោះ គប្បីជ្រាបថា កាមភពខាងក្នុង ធ្វើទីបំផុតអវីចីខាងក្រោម ធ្វើទេវ- លោកជាន់បរនិម្មិតវសវត្តីខាងលើ ក្នុងឧបបត្តិភពក៏នយនេះ តែក្នុងបទនេះ គួរជាកម្មភព ព្រោះកម្មភពនោះ ជាបច្ចយនៃទីបំផុតរបស់ឧបនិស្សយនៃជាតិ សូម្បីក្នុងបទនៃឧបាទានជាដើម គប្បីជ្រាបថា លោកធ្វើការកំណត់ឱកាស ដោយបទនេះថា* **កិម្ហិចិ** *ដូច្នេះ ។*

ក្នុងបទថា **ឧបាទានប្បច្ចយា ភវោ** *សេចក្តីថា កាមុបាទានជាបច្ចយនៃ កម្មភព ៣ និងឧបបត្តិភព ៣ បទដ៏សេសក៏យ៉ាងនោះ គប្បីជ្រាបភព ២៤ មានឧបាទានជាបច្ចយ កម្មភព ១២ រមែងបានក្នុងបទនេះដោយត្រង់ ឧបាទាន នៃកម្មភពទាំងនោះ ជាបច្ចយនៃទីបំផុតរបស់សហជាតខ្លះ នៃទីបំផុតរបស់ ឧបនិស្សយខ្លះ ។*

បទថា **រូបតណ្ហា** *គឺចំណង់ក្នុងរូបារម្មណ៍ ក្នុងសទ្ទតណ្ហាជាដើម ក៏មាន នយនេះ តណ្ហានេះ រមែងជាបច្ចយនៃទីបំផុតរបស់សហជាតខ្លះ នៃទីបំផុត របស់ឧបនិស្សយខ្លះ របស់ឧបាទាន ។*

ក្នុងបទថា **ឯស បច្ចយោ តណ្ហាយ យទិទំ វេទនា** សេចក្តីថា វិបាក-វេទនា រមែងជាបច្ចយរបស់ទីបំផុតនៃឧបនិស្សយរបស់តណ្ហា វេទនាដទៃក៏ជាបច្ចយដោយប្រការដទៃ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់សម្តែងតណ្ហាខាងដើម ដែលមានវដ្តៈជាមូល ឥឡូវនេះ កាលទ្រង់សម្តែងដល់តណ្ហា ដែលជាការផ្សាយឡើងពាសពេញ ដោយបទទាំងឡាយ ៩ ដូចបុគ្គលវាយត្រង់ខ្នង ឬចាប់ត្រង់សក់ ហើយច្រានអ្នកដែលកំពុងស្រែកសូមជីវិតចេញពីផ្ទូវ ទើបត្រាស់ពាក្យជាដើមថា ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង ពាក្យនេះ គឺព្រោះអាស្រ័យវេទនា ទើបកើតតណ្ហា ដូច្នេះ ។

[៥៩] ក្នុងបទទាំងនោះ បទថា **តណ្ហា** សេចក្តីថា តណ្ហាមាន ២ យ៉ាង គឺ **ឯសនាតណ្ហា** និង **ឯសិតតណ្ហា** បុគ្គលដើរទៅកាន់ផ្ទូវពពែ និងផ្ទូវចម្រូងជាដើម ហើយស្វែងរកភោគៈទាំងឡាយដោយតណ្ហាណា តណ្ហានេះ ឈ្មោះថា **ឯសនាតណ្ហា** តណ្ហាណា កាលបុគ្គលស្វែងរកបានហើយ តណ្ហានេះ ក៏ឈ្មោះថា **ឯសិតតណ្ហា** ទាំងពីរពាក្យនោះ ក៏ជាឈ្មោះរបស់តណ្ហា ដែលមានការផ្សាយឡើងនោះឯង ព្រោះដូច្នោះ តណ្ហា ២ យ៉ាងនេះ អាស្រ័យវេទនា ទើបឈ្មោះថា កើតតណ្ហា ។ បទថា **បរិយេសនា** គឺការស្វែងរកអារម្មណ៍ មានរូបជាដើម ព្រោះថា ការស្វែងរកនោះ រមែងជាការរញកដល់តណ្ហា ។ បទថា **លាភោ** គឺការបានអារម្មណ៍ មានរូបជាដើម ព្រោះថា ការបាននោះ រមែងជាការរញកដោយការស្វែងរក ។

វិនិច្ឆ័យមាន ៤ យ៉ាង គឺញាណ តណ្ហា ទិដ្ឋិ និងវិតក្ក ។ ក្នុងវិនិច្ឆ័យ

ទាំងនោះ គប្បីដឹងវិនិច្ឆ័យដែលជាសេចក្តីសុខ លុះដឹងវិនិច្ឆ័យដែលជាសុខ ហើយ គប្បីព្យាយាមរកសេចក្តីសុខខាងក្នុង នេះ គឺញាណវិនិច្ឆ័យ ។ សេចក្តីវិបរិតនៃតណ្ហា ១០៨ មកហើយយ៉ាងនេះថា បទថា **វិនិច្ឆយោ** បានដល់វិនិច្ឆ័យ ២ យ៉ាង គឺតណ្ហាវិនិច្ឆ័យ និងទិដ្ឋិវិនិច្ឆ័យ ឈ្មោះថា តណ្ហាវិនិច្ឆ័យ ។ ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិវិនិច្ឆ័យ ។ វិតក្កដែលលោកពោលថា វិនិច្ឆ័យ ក្នុងទីនេះ មកហើយក្នុងសក្កប្បញ្ហសូត្រនេះថា បពិត្រទេវានមិន្ទ ឆន្ទៈ មានវិតក្ក ជាដើមហេតុ ។ ដូច្នេះ មនុស្សទាំងឡាយបានលាភហើយ រមែងកាត់ក្តីថា គួរពេញចិត្ត និងមិនគួរពេញចិត្ត ល្អ និងមិនល្អ ដោយវិតក្កតែម្យ៉ាង បុគ្គលត្រិះរិះថា អញនឹងមានលាភប៉ុណ្ណេះ ដើម្បីរូបារម្មណ៍ អញនឹងមានលាភប៉ុណ្ណោះ ដើម្បីអារម្មណ៍ មានសទ្ទារម្មណ៍ជាដើម នឹងមានដល់អញប៉ុណ្ណេះ នឹងមានដល់អ្នកដទៃប៉ុណ្ណេះ អញនឹងប្រើប្រាស់ប៉ុណ្ណោះ អញនឹងរក្សាទុកប៉ុណ្ណេះ ដូច្នេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អាស្រ័យលាភ ទើបវិនិច្ឆ័យ ។

បទថា **ឆន្ទរាគោ** សេចក្តីថា រាគៈដែលខ្សោយ និងរាគៈដែលមានកម្លាំង រមែងកើតឡើងក្នុងវត្ថុដែលត្រិះរិះហើយ ដោយអកុសលវិតក្ក បទនេះ ជាតណ្ហាក្នុងទីនេះ ។ បទថា **ឆន្ទោ** ជាឈ្មោះរបស់រាគៈយ៉ាងខ្សោយ ។ បទថា **អជ្ឈោសានំ** គឺចុះកាន់ក្នុងការយើញយ៉ាងខ្លាំងថា អញ របស់អញ ដូច្នេះ ។ បទថា **បរិគ្គហោ** គឺធ្វើការប្រកាន់ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បទថា **មច្ឆរិយំ** សេចក្តីថា ព្រោះទ្រាំមិនបាន ចំពោះភាពជារបស់ទូទៅដល់អ្នកដទៃ ដោយហេតុនោះឯង ទើបបុរាណាចារ្យទាំងឡាយ ពោលអត្ថនៃពាក្យរបស់បទ

នោះ យ៉ាងនេះថា ទ្រង់ត្រាស់ថា **មច្ចរិយំ** *ព្រោះការតាំងចិត្តថា វត្ថុអស្ចារ្យនេះ ចូរជារបស់អញតែម្នាក់ ចូរកុំជារបស់អ្នកដទៃឡើយ ដូច្នេះ ។ បទថា* **អារក្ខោ** *គឺការការពារយ៉ាងល្អដោយអំណាចការបិទទ្វារ និងជាក់ទុកក្នុងហឫទ័យជាដើម ។*

ឈ្មោះថា **អធិករណា** *ព្រោះអត្ថថា ធ្វើឲ្យក្រៃលែង បទនេះជាឈ្មោះរបស់ហេតុ ។ បទថា* **អារក្ខាធិករណំ** *ជាការៈនបុំសកៈ អធិប្បាយថា ហេតុនៃការការពារក្នុងការកាន់ជំបងជាដើម ការកាន់ជំបង ដើម្បីហាមអ្នកដទៃ ឈ្មោះថា* **ទណ្ឌាទានំ** *ការកាន់កាំបិត មានមុខតែម្ខាងជាដើម ឈ្មោះថា* **សត្ថាទានំ** *បទថា* **កលហោ** *គឺឈ្មោះផ្ទួរកាយខ្លះ ឈ្មោះផ្ទួរវាចាខ្លះ សេចក្តីពិរោធមានមកមុនៗ ឈ្មោះថា* **វិគ្គហោ** *គឺជម្លោះ មានមកពេលក្រោយៗ ឈ្មោះថា* **វិវាទ** *គឺការប្រកែកប្រណាំង ។ បទថា* **តុវំ តុវំ** *ជាពាក្យមិនគោរព គឺនិយាយថា អា មឹង ឯង ហង ។*

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីសម្តែងតណ្ហា ដែលជាការផ្សាយទៅពាសពេញនោះ ដោយបដិលោមនយ ទើបទ្រង់ប្រារព្ធបទថា **អារក្ខាធិករណំ** *ទ្រង់សម្តែងបញ្ចាស ។ ក្នុងបទទាំងនោះ បទថា* **កាមតណ្ហា** *បានដល់ ការប្រាថ្នាក្នុងរូបជាដើម ដែលកើតឡើងហើយ ដោយអំណាចរាគៈដែលប្រកបដោយកាមគុណ ៥ ។ បទថា* **ភវតណ្ហា** *គឺរាគៈសហគតដោយសស្សតទិដ្ឋិ ។ បទថា* **វិភវតណ្ហា** *គឺរាគៈសហគតដោយឧច្ឆេទទិដ្ឋិ ។*

[๖๐] *បទថា* **ឥមេ ទ្វេ ធម្មា** *ធម៌ទាំង ២ យ៉ាងនេះ គឺតណ្ហាមានវត្ថុៈជាឫសគល់ និងតណ្ហាដែលផ្សាយទៅ ។ បទថា* **ទ្វយេន** *សេចក្តីថា*

ធម៌ទាំង ២ យ៉ាងនេះ សូម្បីដល់កាពតែមួយ ដោយលក្ខណៈរបស់តណ្ហា រមែងជាការរួមក្នុងទីតែមួយជាមួយគ្នានឹងវេទនា ដោយចំណែក ២ ដោយអំណាចតណ្ហា មានវដ្តៈជាឫសគល់ និងតណ្ហាដែលផ្សាយទៅ អធិប្បាយថា ធម៌ទាំងឡាយនោះ មានបច្ចយរួមគ្នា ដោយមានវេទនាជាបច្ចយ ។ ពិតហើយ **សមោសរណា** *គឺការរួមគ្នាមាន ៣ យ៉ាង គឺ* **ទិសរណា សមោសរណា** *ការប្រជុំរួមគ្នា ១* **សហជាត សមោសរណា** *ការរួមសហជាត ១* **បច្ចយ សមោសរណា** *ការរួមបច្ចយ ១ ក្នុង* **សមោសរណា** *ទាំងនោះ ពាក្យនេះថា គ្រានោះឯង ការប្រជុំអ្នកស្រុកទាំងអស់នោះ រមែងមានឡើង ដូច្នេះ ឈ្មោះថា* **ទិសរណា សមោសរណា** *។ ពាក្យនេះថា ម្នាលអាវុសោ ធម៌ទាំងអស់មានឆន្ទៈជាមូល ធម៌ទាំងអស់កើតអំពីមនសិការ ធម៌ទាំងអស់ប្រជុំកើតអំពីផស្សៈ ធម៌ទាំងអស់ប្រជុំចុះក្នុងវេទនា នេះឈ្មោះថា* **សហជាត សមោសរណា** *។ បទនេះថា ការរួមគ្នាជាមួយនឹងវេទនា ដោយ ២ ចំណែក នេះឈ្មោះថា* **បច្ចយ សមោសរណា** *។*

ផស្សៈទាំងអស់ មានចក្ខុសម្ផស្សជាដើម ជាផស្សៈដែលជាផលតែម្យ៉ាង ក្នុងផស្សៈទាំងនោះ វៀរផស្សៈដែលជាផលនៃលោកុត្តរ ៤ ផស្សៈដ៏សេស រមែងជាផស្សៈ ៣២ ។ ក្នុងបទនេះថា **យទិទំ ផស្សោ** *ដោយច្រើន ផស្សៈរមែងជាបច្ចយនៃវេទនា ។ ទ្រង់ត្រាស់អាការទាំងឡាយ ក្នុងបទថា* **យេហិ អានន្ទ អាការេហិ** *ជាដើម ជាសភាពមិនដូចគ្នានៃវេទនាជាដើម ទ្រង់សម្តែងអាការទាំងនោះដោយល្អ ឈ្មោះថា* **លិង្គ** *ព្រោះដល់ការសាបសូន្យ ទ្រុឌទ្រោម*

ឈ្មោះថា **និមិត្ត** *ព្រោះហេតុ គឺជីងរឿងនោះៗ ឈ្មោះថា* **ឧទ្ទេស** *ព្រោះគួរសម្តែងយ៉ាងនោះៗ ព្រោះដូច្នោះ ក្នុងបទនេះ មានអធិប្បាយដូច្នេះថា*

ម្នាលអានន្ទ ការបញ្ញត្តិនាមកាយ ដែលជាទីប្រជុំរបស់នាម រមែងមានដោយអាការ លិង្គ និមិត្ត ឧទ្ទេស កាលមានឧទ្ទេសនៃវេទនាថា វេទនាក្នុងអាការជីង ក្នុងការជីងភេទ ក្នុងការជីងនិមិត្ត កាលមានឧទ្ទេសនៃសញ្ញាថា សញ្ញាក្នុងអាការជីងព្រម ក្នុងការជីងលិង្គព្រម ក្នុងការជីងនិមិត្តព្រម កាលមានឧទ្ទេសនៃសង្ខារទាំងឡាយថា ចេតនានៃសង្ខារទាំងឡាយ ក្នុងអាការនៃចេតនា ក្នុងលិង្គនៃចេតនា ក្នុងនិមិត្តនៃចេតនា កាលមានឧទ្ទេសនៃវិញ្ញាណថា វិញ្ញាណក្នុងការជីងច្បាស់នូវលិង្គ ក្នុងការជីងច្បាស់នូវនិមិត្ត ដូច្នេះ ឈ្មោះថា បញ្ញត្តិនាមកាយថា នេះជានាមកាយ កាលមិនមានអាការជាដើម ក្នុងវេទនាជាដើម ដែលជាហេតុឲ្យបញ្ញត្តនាមកាយ ការសម្ផស្សត្រឹមតែឈ្មោះក្នុងរូបកាយ គប្បីប្រាកដបានដែរឬ មនោសម្ផស្សឯណា ដែលជាវេវចនៈរបស់ការសម្ផស្សត្រឹមតែឈ្មោះក្នុងមនោទ្វារ ធ្វើខន្ធ ៤ ឲ្យជាវត្ថុហើយ ទើបកើតឡើង មនោសម្ផស្សនោះ គប្បីប្រាកដក្នុងរូបកាយ គប្បីធ្វើបសាទទាំង ៥ ឲ្យជាវត្ថុហើយ គប្បីកើតឡើងបានដែរឬ ដូច្នេះ ។

លំដាប់នោះ ព្រះអានន្ទ កាលមិនព្រមទទួលការកើតឡើងនៃសម្ផស្សនោះអំពីរូបកាយ ដូចកាលមិនមានជើមស្វាយ ក៏មិនទទួលការកើតឡើងរបស់ផ្លែស្វាយទុំអំពីជើមព្រីង ដូច្នោះ ទើបក្រាបទូលថា **នោ ហេតំ ភន្តេ** *ដូច្នេះ ។*

ក្នុងបញ្ហាទី ២ គប្បីជ្រាបសេចក្តីនៃអាការជាដើម ដោយអំណាចអាការនៃការបែកធ្លាយ ភេទនៃការបែកធ្លាយ និមិត្តនៃការបែកធ្លាយ និងដោយ

អំណាចនៃការលើកឡើងថា រូប ដូច្នេះ ។ បទថា **បដិឃសម្ផស្សោ** *គឺការសម្ផស្ស ធ្វើរូបក្ខន្ធដែលប្រព្រឹត្តទៅជាមួយ ដោយការប៉ះខ្ទប់ឲ្យជាវត្ថុ ហើយកើតឡើង ក្នុងបទនេះ ព្រះថេរៈកាលមិនទទួលការកើតឡើងនៃសម្ផស្សនោះ អំពីនាមកាយ ដូចកាលមិនមានដើមព្រឹង ក៏មិនទទួលការកើតឡើងនៃផ្លែព្រឹង ទុំអំពីដើមស្វាយ ដូច្នោះ ទើបក្រាបទូលថា* **នោ ហោតំ ភន្តេ** *ដូច្នេះ ។*

ក្នុងបញ្ហាទី ៣ ទ្រង់ត្រាស់ដូចបញ្ហាទាំងពីរនុ៎ះឯង ក្នុងបញ្ហាទី ៣ នោះ ព្រះថេរៈកាលមិនទទួលការកើតឡើងនៃផស្សៈទាំងពីរ ក្នុងការមិនមាននៃនាមរូប ដូចមិនទទួលការកើតឡើងនៃផ្លែស្វាយទុំ និងផ្លែព្រឹងទុំលើអាកាស ដូច្នោះ ទើបក្រាបទូលថា **នោ ហោតំ ភន្តេ** *ដូច្នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងបច្ច័យតែមួយយ៉ាងៗ នៃផស្សៈទាំងពីរយ៉ាងនេះ ឥឡូវនេះ ដើម្បីទ្រង់សម្តែងភាពដែលផស្សៈទាំងពីរនោះ ជាបច្ច័យនៃនាមរូបដោយមិនផ្សេងគ្នា ទើបទ្រង់ប្រារព្ធបញ្ហាទី ៤ ថា* **យេហិ អានន្ទ អាការេហិ** *ដូច្នេះ ។*

បទថា **យតិទំ នាមរូបំ** *គឺនាមរូបនេះ អធិប្បាយថា នាមរូបក្នុងទ្វារទាំង ៦ នេះ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដូច្នេះ ។ ពិតហើយ ចក្ខុជាដើម និងរូបាយតនៈជាដើម ក្នុងចក្ខុទ្វារជាដើម ជារូប ធម៌ដែលប្រកបជាមួយគ្នាជានាម ផស្សៈនោះមាន ៥ យ៉ាងនេះ ដោយប្រការដូច្នេះ ព្រោះនាមរូបជាបច្ច័យ ទើបមានផស្សៈ សូម្បីក្នុងមនោទ្វារ ហាទយវត្ថុ និងរូប រមែងជាអារម្មណ៍ ជារូប សម្បយុត្តធម៌ និងវត្ថុមិនមានរូប រមែងជាអារម្មណ៍ ជានាម ដោយប្រការដូច្នេះ ។ មនោសម្ផស្ស ក៏គប្បីជ្រាបថា ព្រោះមាននាមរូបជាបច្ច័យ ទើបកើតផស្សៈ តែនាមរូបដោយច្រើន រមែងជាបច្ច័យនៃផស្សៈនោះ ។*

បទថា **ន ឱក្កមិស្សថ** *សេចក្តីថា វិញ្ញាណនឹងមិនប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ដូចចូលទៅហើយប្រព្រឹត្តទៅ ។ បទថា* **សមុច្ឆិស្សថ** *សេចក្តីថា កាលបដិសន្ធិវិញ្ញាណមិនមាន នាមរូបចំណែកដ៏សេសបរិសុទ្ធ ជានាមរូបដែលកាត់ផ្តាច់ដោយការលាយឡំ ប្រព្រឹត្តទៅដោយភាពជាកលលៈជាដើម ក្នុងផ្ទៃរបស់មាតាបានដែរឬ ។ បទថា* **ឱក្កមិត្វា វោក្កមិស្សថ** *សេចក្តីថា វិញ្ញាណនឹងឈមចុះដោយអំណាចបដិសន្ធិ ហើយកន្ទងទៅ គឺរលត់ទៅដោយអំណាចចុតិ ។ ការរលត់នៃវិញ្ញាណនោះ រមែងមិនមានដោយការរលត់នៃចិត្តនុ៎ះឯង បន្ទាប់ពីនោះ វិញ្ញាណ រមែងមិនមានដោយការរលត់នៃចិត្តដួងទី ២ និងទី ៣ ។ ពិតហើយ កម្មជ្ជរូបគ្រប់ ៣០ ដែលតាំងឡើងព្រមនឹងបដិសន្ធិចិត្ត រមែងកើត កាលកម្មជ្ជរូបទាំងនោះ តាំងនៅនុ៎ះឯង ភវង្គចិត្ត ១៦ កើតឡើងហើយ រមែងរលត់ទៅ ។ មិនមានអន្តរាយដល់ទារកដែលបដិសន្ធិក្នុងចន្លោះនោះ ឬដល់មាតារបស់ទារកនោះ ព្រោះអន្តរាយនេះ ឈ្មោះថា មិនមានឱកាស ។ ប្រសិនបើរូបដែលប្រាកដឡើងជាមួយបដិសន្ធិចិត្ត អាចជាបច្ច័យដល់ភវង្គចិត្តដួងទី ១៧ បាន ការប្រព្រឹត្តទៅ រមែងប្រព្រឹត្តទៅជាបវេណីតទៅ ។ ប្រសិនបើមិនអាច ការប្រព្រឹត្តទៅរមែងមិនប្រព្រឹត្តទៅជាបវេណីរមែងមិនបន្ត ឈ្មោះថា កន្ទងទៅ ។ ទ្រង់សំដៅដល់ការកន្ទងទៅនោះ ទើបត្រាស់ថា* **ឱក្កមិត្វា វោក្កមិស្សថ** *ដូច្នេះ ។ បទថា* **ឥត្តត្តាយ** *គឺដើម្បីភាពជាយ៉ាងនេះ អធិប្បាយថា កាលខន្ធ ៥ បរិបូណ៌ហើយយ៉ាងនេះ ។*

បទថា **ឧហារេស្សថ សតោ** *គឺនៅក្នុងខ្ទីនុ៎ះឯង ។ បទថា* **វោច្ឆិជ្ជិស្សថ** *គឺជាច់ការបន្ត ។ បទថា* **វុឌ្ឍីវិរុឡ្ហីវេបុល្លំ** *សេចក្តីថា កាលវិញ្ញាណជាច់ការ*

បន្ត នាមរូបបរិសុទ្ធនឹងតាំងឡើងហើយ ដល់នូវសេចក្តីចម្រើនក្នុងបឋមវ័យ ការដុះដាលល្អក្នុងមជ្ឈិមវ័យ ការធំធាត់ក្នុងបច្ឆិមវ័យខ្លះបានដែរឬ អធិប្បាយថា នាមរូបនឹងដល់នូវការចម្រើន ដល់នូវការដុះដាលល្អ ដល់នូវការធំធាត់ ដោយមានអាយុដល់ ១០ ឆ្នាំ ២០ ឆ្នាំ ។បេ។ ១០០០ ឆ្នាំ បានដែរឬទេ ។

បទថា **តស្មាតិហានន្ទ** *សេចក្តីថា ព្រោះវិញ្ញាណនុ៎ះឯងជាបច្ច័យនៃនាមរូបនោះ ក្នុងការកាន់យកបដិសន្ធិ ក្នុងផ្ទៃមាតាខ្លះ ក្នុងខណៈនៅក្នុងផ្ទៃខ្លះ ក្នុងខណៈចេញចាកផ្ទៃខ្លះ ក្នុងវេលាមានអាយុ ១០ ឆ្នាំ ប្រព្រឹត្តទៅខ្លះ ដូច្នោះនេះជាហេតុ នេះជាបច្ច័យនៃនាមរូប គឺវិញ្ញាណ វិញ្ញាណរមែងជាបច្ច័យ នៃនាមរូប ដូចបុគ្គលពោលដល់នាមរូបយ៉ាងនេះ ដោយសេចក្តីថា លោកឈ្មោះនាម លោកឈ្មោះរូប លោកឈ្មោះនាមរូប ដូច្នេះ អ្នកណាធ្វើនាមរូបនោះ យើងធ្វើមែនឬ បើថា កាលយើងជាបុរេចារិក មិនកាន់យកបដិសន្ធិក្នុងផ្ទៃរបស់មាតា លោកគប្បីជានាម គប្បីជារូប ឬគប្បីជានាមរូប ពួកយើងគប្បីដឹងកម្ចាំងរបស់លោក ដូចព្រះរាជា កាលទ្រង់គំរាមប្រជារាស្ត្ររបស់ព្រះអង្គ គប្បីត្រាស់ថា អ្នកឯងជាឧបរាជ អ្នកឯងជាសេនាបតី ដូច្នេះ អ្នកណាតែងតាំងអ្នកឯង យើងតែងតាំងអ្នកឯងមិនមែនឬ ប្រសិនបើយើងមិនតែងតាំងអ្នកឯង អ្នកឯងនឹងគប្បីជាឧបរាជ ឬគប្បីជាសេនាបតីតាមធម្មតារបស់ខ្លួន យើងគប្បីដឹងកម្ចាំងរបស់អ្នកឯង ដូច្នោះ ឯវិញ្ញាណនេះ ដោយច្រើនរមែងជាបច្ច័យនៃនាមរូប ។*

បទថា **ទុក្ខសមុទយសម្ភវោ** *គឺការកើតឡើងនៃគំនរទុក្ខ ។ បទថា* **យទិទំ នាមរូបំ** *សេចក្តីថា នាមរូបនេះ នេះជាហេតុ នេះជាបច្ច័យ សូម្បី*

នាមរូប ក៏ដូចបុគ្គលពោលដល់វិញ្ញាណយ៉ាងនេះ ដោយសេចក្តីថា លោកជាបដិសន្ធិវិញ្ញាណ អ្នកណាធ្វើបដិសន្ធិវិញ្ញាណ យើងធ្វើមិនមែនឬ បើលោកមិនអាស្រ័យខន្ធ ៣ និងហទយវត្ថុ នឹងគប្បីឈ្មោះថា បដិសន្ធិវិញ្ញាណ យើងគប្បីឃើញភាពដែលលោក ជាបដិសន្ធិវិញ្ញាណដូច្នេះ ។ ឧបមាដូចរាជបុរសទាំងឡាយ គប្បីទូលចំពោះព្រះរាជាដែលទ្រង់គំរាមថា ព្រះអង្គជាព្រះរាជាអ្នកណាតែងតាំងព្រះអង្គ ពួកទូលបង្គំតែងតាំងព្រះអង្គមិនមែនឬ ប្រសិនបើទូលបង្គំមិនតាំងនៅក្នុងតំណែងឧបរាជ ក្នុងតំណែងសេនាបតី ព្រះអង្គគប្បីជាព្រះរាជាតែមួយព្រះអង្គឯងប៉ុណ្ណោះ ពួកខ្ញុំព្រះអង្គគប្បីឃើញភាពជាព្រះរាជារបស់ព្រះអង្គ ដូច្នេះ ឯនាមរូបនេះ ដោយច្រើនរមែងជាបច្ច័យនៃវិញ្ញាណ ។ បទថា **ฌตฺวาตา เอวา** *សេចក្តីថា កាលវិញ្ញាណជាបច្ច័យនៃនាមរូប កាលនាមរូបជាបច្ច័យនៃវិញ្ញាណ បើធម៌ទាំងពីរប្រព្រឹត្តទៅ ដោយអំណាចនៃភាពជាបច្ច័យដល់គ្នានិងគ្នា ដោយហេតុមានប្រមាណប៉ុណ្ណោះ វិញ្ញាណ និងនាមរូបទើបនៅតែកើត ចាស់ ស្លាប់ ចុតិ ឬឧប្បត្តិ ជាតិជាដើម ឬចុតិ បដិសន្ធិដទៃៗ គប្បីជ្រាកដ ។*

បទថា **អธิวจนปถา** *សេចក្តីថា គន្ថនៃវោហារ ដែលមិនឃើញសភាពរបស់ពាក្យជាដើមថា សិរីវឌ្ឍកៈ ធនវឌ្ឍកៈ តាំងឡើងត្រឹមតែហៅឈ្មោះប៉ុណ្ណោះ ។ បទថា* **นิรุตฺติปถา** *សេចក្តីថា ជាគន្ថនៃវោហារ ដែលប្រព្រឹត្តទៅដោយអំណាចការអាងហេតុ នៃពាក្យជាដើមថា បុគ្គលមានសតិព្រោះរឭកបាន បុគ្គលមានសម្បជញ្ញៈ ព្រោះដឹងខ្លួន ។ បទថា* **បญฺญตฺติปถา** *សេចក្តីថា គន្ថនៃវោហារដែលប្រព្រឹត្តទៅដោយអំណាចនៃការឲ្យដឹងដោយ*

ប្រការផ្សេងៗ របស់ពាក្យមានជាដើមថា អ្នកដឹង អ្នកឈ្លាស អ្នកមានបញ្ញា អ្នកជំនាញ អ្នកជំទាស់ សូម្បីខន្ធទាំងឡាយដែលជាវត្ថុនៃឈ្មោះជាដើម ក៏លោកពោលដោយបទទាំង ៣ ដោយប្រការដូច្នេះ ។ បទថា **បញ្ញាវចរំ** *សេចក្តីថា គប្បីគិតគ្នេរ គឺគប្បីដឹងដោយបញ្ញា ។ បទថា* **វដ្តំ វដ្តតិ** *គឺសង្សារ-វដ្តរមែងប្រព្រឹត្តទៅ ។ បទថា* **ឥត្ថត្តំ** *គឺភាពជាយ៉ាងនេះ ពាក្យនេះ ជាឈ្មោះរបស់ខន្ធបញ្ចកៈ ។ បទថា* **បញ្ញាបនាយ** *គឺដើម្បីបញ្ញត្តឈ្មោះ អធិប្បាយថា ខន្ធបញ្ចកៈ ក៏រមែងប្រាកដដោយហេតុត្រឹមតែប៉ុណ្ណោះ ដើម្បីបញ្ញត្តនាមដោយបទថា* **វេទនា សញ្ញា** *ជាដើម ។ បទថា* **យទិទំ នាមរូបំ សហ វិញ្ញាណេន** *សេចក្តីថា នេះ គឺនាមរូប និងវិញ្ញាណ រមែងប្រព្រឹត្តទៅ ព្រោះជាបច្ច័យដល់គ្នានិងគ្នា លោកអធិប្បាយអំពីហេតុត្រឹមតែប៉ុណ្ណោះ ដូច្នេះ នេះជាពាក្យដែលត្រូវនាំចេញទៅ ក្នុងបទនេះ ។*

[๖๑] *ដោយប្រការដូច្នេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអនុសន្ធិនៃបទថា ម្នាលអានន្ទ ក៏បដិច្ចសមុប្បាទនេះ ជារបស់ជ្រាលជ្រៅ និងប្រាកដជារបស់ជ្រាលជ្រៅ ដូច្នេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងអនុសន្ធិនៃបទថា* **តណ្ហាកុលកជាតា** *ដូច្នេះ ទ្រង់ប្រារព្ធទេសនាមានជាដើមថា* **កិត្តាវតា ច** *ដូច្នេះ ។ ក្នុងបទទាំងនោះ ក្នុងបទថា* **រូបី វា ហិ អានន្ទ បរិត្តំ អត្តានំ** *ដូច្នេះ សេចក្តីថា អ្នកដែលបញ្ញត្តអត្តាមានរូបបន្តិចបន្តួច រមែងប្រកាន់ថា កសិណនិមិត្តដែលនៅមិនទាន់ចម្រើន ជាអត្តា ដូច្នេះ មួយទៀត បុគ្គលដែលបញ្ញត្តអត្តានោះថា ពេលខ្លះខៀវ ពេលខ្លះលឿង ដូច្នេះ រមែងជា*

អ្នកមានប្រក្រតីបានកសិណផ្សេងៗ បុគ្គលដែលបញ្ញត្តអត្តា មានរូបមិនមានទីបំផុត រមែងប្រកាន់ថា កសិណនិមិត្តដែលចម្រើនហើយ ជាអត្តា ដូច្នេះ ឬបុគ្គលដែលបញ្ញត្តអត្តា មិនមានរូបបន្តិចបន្តួច បើកកសិណនិមិត្តដែលមិនទាន់ចម្រើនហើយ កាន់យកឱកាសដែលនិមិត្តពាល់ត្រូវហើយ ឬខន្ធ ๔ ដែលប្រព្រឹត្តទៅក្នុងនិមិត្តនោះ ឬត្រឹមតែវិញ្ញាណក្នុងខន្ធទាំង ๔ នោះប៉ុណ្ណោះថា ជាអត្តាដូច្នេះ បុគ្គលដែលបញ្ញត្តអត្តា មិនមានរូប មិនមានទីបំផុត បើកកសិណនិមិត្តដែលចម្រើនហើយ រមែងកាន់យកឱកាសដែលនិមិត្តពាល់ត្រូវហើយ ឬខន្ធដែលប្រព្រឹត្តទៅក្នុងនិមិត្តនោះ ឬត្រឹមតែវិញ្ញាណក្នុងខន្ធទាំង ๔ នោះប៉ុណ្ណោះថា ជាអត្តា ដូច្នេះ ។

បទថា **តត្រ** *ក្នុងបទថា* **តត្រាឧទ្ធុ** *នេះ គឺក្នុងទិដ្ឋិ ๔ យ៉ាងនោះ ។ បទថា* **ឯតរហិ វា** *គឺក្នុងកាលឥឡូវនេះ មិនមែនដទៃអំពីនេះទ្រង់ត្រាស់ពាក្យនេះដោយអំណាចឧច្ឆេទទិដ្ឋិ ។ បទថា* **តថាភាវឹ វា** *គឺសភាពរស់នៅក្នុងលោក ដែលនៅយ៉ាងនោះ ទ្រង់ត្រាស់ពាក្យនេះ ដោយអំណាចសស្សតទិដ្ឋិ ។ បទថា* **អតថំ វា បន សន្ធំ** *គឺសភាវៈដែលមិនទៀងពិត កំពុងមានក្តី ។ បទថា* **តថត្តាយ** *គឺដើម្បីសេចក្តីទៀងពិត ។ បទថា* **ឧបកប្បេស្សាមិ** *គឺអាត្មាអញនឹងឲ្យដល់ព្រម ព្រះមានព្រះភាគទ្រង់សម្តែងការជំទាស់ដោយបទនេះ ព្រោះបុគ្គលមានវាទៈថា សូន្យគិតហើយថា អញនឹងញុំាងអត្តាដែលមិនទៀងពិត សូម្បីសេចក្តីពិត មិនសូន្យរបស់បុគ្គលមានវាទៈថា ទៀង ឲ្យសម្រេច ដើម្បីសភាពដែលទៀងពិត គឺមានសភាពសូន្យ ហើយអញនឹងឲ្យបុគ្គលមានវាទៈថា ទៀង ជីងហើយ នឹងឲ្យបុគ្គលនោះកាន់យកវាទៈថា*

สูន្យតែម្យ៉ាង សូម្បីអ្នកមានវាទៈថា ទៀង ក៏គិតហើយថា អញនឹងញុំាង អត្តាដែលមិនទៀងពិត សូម្បីសេចក្តីពិត មិនទៀង ឲ្យសម្រេចដើម្បីមាន សភាពទៀងពិត គឺដើម្បីសភាពដែលទៀង នឹងញុំាងអ្នកមានវាទៈថា សូន្យ ឲ្យដឹងហើយ ឲ្យបុគ្គលនោះកាន់យកវាទៈថា ទៀងតែម្យ៉ាង ដូច្នេះ ។ បទថា **ឯវំ សន្តំ ខោ** សេចក្តីថា ឲ្យបញ្ញត្តអត្តាដែលមានរូបបន្តិចបន្តួច មានយ៉ាងនេះ ។ បទថា **រូបី** គឺមានប្រក្រតីបានរូបជាកសិណ ។ បទថា **បរិត្តន្តានុទិដ្ឋិ អនុ-សេតិ** សេចក្តីថា ការយើញនេះថា អត្តាបន្តិចបន្តួច រមែងដេកត្រាំក្នុងសន្តាន គប្បីជ្រាបការយើញនោះថា ការយល់ឃើញនោះ រមែងមិនដេកត្រាំ ដូច វល្លិ និងលតា គឺឈ្មោះថា រមែងដេកត្រាំក្នុងសន្តាន ដោយអត្ថថា លះមិន បាន ។ បទថា **ឥច្ចាលំ វចនាយ** សេចក្តីថា គួរដើម្បីពោលថា ការយើញ បែបនេះ រមែងដេកត្រាំក្នុងបុគ្គលនោះ ក្នុងបទទាំងអស់ក៏មានន័យនេះឯង ។ ក្នុងបទថា **អរូបី** នេះ គឺមានប្រក្រតីបានអរូបជាកសិណ គប្បីជ្រាបសេចក្តី យ៉ាងនេះថា មានអរូបក្ខន្ធ ជាគោចរក្តី ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់សម្តែងដល់អ្នក ប្រកាន់ដោយទិដ្ឋិ ១៦ ពួក ដោយសេចក្តីថា ពួកអ្នកមានលាភ ៤ ពួកកូន សិស្សរបស់អ្នកមានលាភ ៤ ពួកអ្នកមានការយើញខុស ៤ កូនសិស្សរបស់ ពួកអ្នកមានការយើញខុស ៤ ។

[៦២] លុះព្រះមានព្រះភាគ ទ្រង់សម្តែងដល់បុគ្គលដែលបញ្ញត្តអត្តា យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់បុគ្គលដែលមិនបញ្ញត្តអត្តា ទើបត្រាស់ពាក្យជាដើមថា **កិត្តាវតា ច អានន្ទ** ដូច្នេះ ។ សួរថា ពួកណា

មិនបញ្ញត្តិ ឆ្លើយថា សេចក្តីពិត ព្រះអរិយបុគ្គលទាំងអស់ប៉ុណ្ណោះ មិនបញ្ញត្ត មួយទៀត ព្រះអរិយបុគ្គលដែលជាពហូសូតទ្រទ្រង់បិដក ៣ បិដក ២ បិដក ១ ដោយហោចវិនិច្ឆយនិកាយតែមួយដោយល្អ បុគ្គលដែលសម្តែងធម៌តាមដែលបានរៀនខ្លះ បុគ្គលប្រារព្ធវិបស្សនាខ្លះ រមែងមិនបញ្ញត្ត ព្រោះលោកទាំងនោះមានសញ្ញាថា កសិណដែលមានចំណែក ប្រៀបធៀបក្នុងកសិណ ដែលមានចំណែកប្រៀបធៀបដូច្នេះ អធិប្បាយថា អរូបក្ខន្ធ ក្នុងអរូបក្ខន្ធនោះឯង ។

[๖๓] ព្រះមានព្រះភាគ ទ្រង់សម្តែងដល់បុគ្គលដែលមិនបញ្ញត្តយ៉ាងនេះហើយ ឥឡូវនេះ ព្រោះបុគ្គលដែលពិចារណាឃើញដោយអំណាចទិដ្ឋិ រមែងបញ្ញត្ត ឯការពិចារណាឃើញនេះ រមែងមាន ព្រោះនៅមិនទាន់លះសក្កាយទិដ្ឋិមានវត្ថុ ๒๐ ដូច្នោះ ដើម្បីទ្រង់សម្តែងដល់សក្កាយទិដ្ឋិមានវត្ថុ ๒๐ នោះ ទើបត្រាស់ទៀតថា **កិត្តាវតា ច អានន្ទ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ ទ្រង់ត្រាស់សក្កាយទិដ្ឋិដែលមានវេទនាខន្ធជាវត្ថុ ដោយបទនេះថា* **វេទនំ វា ហិ** *ដូច្នេះ ។ ទ្រង់ត្រាស់សក្កាយទិដ្ឋិ ដែលមានរូបក្ខន្ធជាវត្ថុ ដោយបទនេះថា* **អប្បដិសំវេទនោ មេ អត្តា** *អត្តារបស់អញមិនសោយវេទនា ដូច្នេះ ។ ទ្រង់ត្រាស់សក្កាយទិដ្ឋិដែលមានសញ្ញា សង្ខារ វិញ្ញាណជាវត្ថុ ដោយបទនេះថា អត្តារបស់អញសោយវេទនា ព្រោះអត្តារបស់អញមានវេទនាជាធម្មតា ដូច្នេះ ខន្ធទាំង ๓ នេះ នៅសោយវេទនា ព្រោះសម្បយុត្តដោយវេទនា ម្យ៉ាងទៀត អត្តាមានវេទនាជាធម្មតា គឺមិនមានការប្រកបជាសភាវៈ រមែងមានដល់ខន្ធទាំង ๓ នោះ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងទោសក្នុងទិដ្ឋិទាំងនោះ ទើបត្រាស់ថា* **តត្រានន្ទ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ*

បទថា **តត្រ** *គឺក្នុងទិដ្ឋិទាំង ៣ នោះ ទ្រង់ត្រាស់បទ ជាដើមថា* **យស្មឹ អានន្ទ សមយេ** *ដូច្នេះ ដើម្បីចង្អុលទោសជាដើម យ៉ាងនេះថា ជួនកាលមាន ជួនកាលមិនមាន នៃអត្តារបស់បុគ្គលដែលពិចារណាឃើញថា វេទនាជាអត្តា ។ ក្នុងបទថា* **អនិច្ចា** *ជាដើម សេចក្តីថា វេទនា ឈ្មោះថា ជារបស់មិនទៀង ព្រោះមានហើយមិនមាន ឈ្មោះថា ដែលបច្ច័យតាក់តែង ព្រោះតាក់តែងឡើង ដោយហេតុនោះៗ ឈ្មោះថា អាស្រ័យគ្នាកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ ហើយកើតឡើងដោយហេតុដ៏ប្រពៃ បទទាំងអស់មានបទថា* **ខយោ** *ជាដើម ជាវេវចន:របស់ការបែកធ្លាយ ពិតហើយ វត្តុណា រមែងបែកធ្លាយ វត្តុនោះ រមែងអស់ទៅខ្លះ សាបសូន្យទៅខ្លះ ប្រែប្រួលទៅខ្លះ រលត់ទៅខ្លះ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់បទជាដើមថា* **ខយធម្មា** *ដូច្នេះ ។ បទថា* **ព្យគា មេ** *អធិប្បាយថា អត្តារបស់អញដល់ការសាបសូន្យ ទ្រុឌទ្រោម គឺប្រាសទៅ រលត់ទៅ ដូច្នេះ ។ ពុទ្ធវចន:ថា* **ឯសោ មេ អត្តា** *រមែងមានដល់បុគ្គលតែម្នាក់ប៉ុណ្ណោះ ក្នុងកាលទាំង ៣ ក្តី និងមិនមានដល់បុគ្គលដែលមានទិដ្ឋិក្តី ព្រោះធម្មតាវិស័យ រមែងមិនមានជានិច្ចដល់ដង្គត់ឈើ ដែលគេរក្សាក្នុងគំនរអង្ការ ដូចស្វាព្រៃ រមែងកាន់យកវត្តុដទៃ រមែងចោលវត្តុដទៃ ។ បទថា* **អនិច្ចំ សុខំ ទុក្ខំ រោកិល្លំ** *សេចក្តីថា បុគ្គលកាលពិចារណាឃើញវេទនានោះៗ ដោយពិសេសថាជាអត្តា រមែងពិចារណាឃើញអត្តាមិនទៀង ជាសុខ និងជាទុក្ខ កាលពិចារណាឃើញវេទនាដោយមិនពិសេសថាជាអត្តា រមែងពិចារណាឃើញអត្តាមានអាការជាច្រើន មានការកើតឡើង និងសូន្យទៅជាធម្មតា ។ ពិតហើយ វេទនាមាន ៣ យ៉ាង និងមានការកើតឡើង មានការ*

សូន្យទៅជាធម្មតា ឯបុគ្គលនោះ រមែងពិចារណាឃើញវេទនានោះ ថាជាអត្តា ដោយប្រការដូច្នេះ ទើបអត្តារបស់បុគ្គលនោះ មិនទៀង និងការកើតឡើងនៃវេទនាទាំងឡាយច្រើន រមែងដល់ក្នុងខណៈតែមួយ តែបុគ្គលនោះ រមែងជឿតាមអត្តានោះឯងថា មិនទៀង មិនមានវេទនាជាច្រើន កើតឡើងក្នុងខណៈតែមួយ ព្រះមានព្រះភាគ ទ្រង់សំដៅដល់សេចក្តីនេះ ទើបត្រាស់ថា ព្រោះហេតុនោះឯង សេចក្តីនេះ ទើបមិនគួរពិចារណាឃើញថា វេទនាជាអត្តារបស់អញ ដោយពាក្យដូចពោលហើយនេះ ដូច្នេះ ។ បទថា **យត្ត បនា-វុសោ** *សេចក្តីថា ក្នុងរូបក្ខន្ធសុទ្ធ ក៏មិនមានការសោយអារម្មណ៍ ដោយប្រការទាំងពួង ។ បទថា* **អបិ នុ ខោ តត្ត** *សេចក្តីថា ក្នុងរូបក្ខន្ធនោះ គឺក្នុងដើមត្នោត ឬក្នុងបង្អួចដែលវៀរវេទនាហើយ គប្បីកើតអហង្ការថា ជាអញយ៉ាងនេះទៀតឬ ។ បទថា* **តស្មាតិហានន្ទ** *សេចក្តីថា ព្រោះរូបក្ខន្ធសុទ្ធតាំងឡើងហើយ មិនទាន់ពោលថាជាអញ ដូច្នោះ ទើបសេចក្តីនេះ មិនគួរពិចារណាឃើញថា វេទនាជាអត្តារបស់អញ ដោយពាក្យដូចពោលហើយនេះ ក្នុងរូបក្ខន្ធនឹងនៅកើតអហង្ការថា នេះជាអញបានឬ ព្រោះដូច្នោះ ក្នុងវេទនាទាំងនោះ ក្នុងខន្ធ ៣ សូម្បីខន្ធតែមួយ គួរនឹងពោលយ៉ាងនេះថា នេះជាអញ ដូច្នេះបានឬ ម្យ៉ាងទៀត អធិប្បាយថា កាលខន្ធទាំង ៣ នោះរលត់ព្រមនឹងវេទនា ព្រោះវេទនារលត់ នឹងគប្បីកើតអហង្ការថា នេះជាអញ ឬអញជានេះ ដូច្នេះបានឬ លំដាប់នោះ ព្រះអានន្ទកាលមិនព្រមទទួលសេចក្តីនោះ ដូចបុគ្គលមិនព្រមទទួលនូវការមុតរបស់ស្នែងទន្សាយ ដូច្នោះ ទើបក្រាបទូលថា* **នោ ហោតំ ភន្តេ** *ដូច្នេះ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះ*

ភាគត្រាស់ដល់អ្វី ត្រាស់ដល់វដ្ដៈ ពិតហើយ ព្រះមានព្រះភាគកាលត្រាស់ដល់រឿងវដ្ដៈ ក្នុងកន្លែងខ្លះ ត្រាស់អវិជ្ជាជាមាតិកា កន្លែងខ្លះ ត្រាស់តណ្ហាជាមាតិកា កន្លែងខ្លះ ត្រាស់ទិដ្ឋិជាមាតិកា ក្នុងមាតិកាទាំងនោះ ត្រាស់អវិជ្ជាជាមាតិកាយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជា មិនប្រាកដទេ អវិជ្ជាមិនមានក្នុងកាលមុនអំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយទៀតហេតុនោះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អវិជ្ជានេះ តថាគតពោលយ៉ាងនេះតែថា អវិជ្ជា រមែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ ដូច្នេះក៏មាន ។

ត្រាស់តណ្ហាជាមាតិកាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់តវតណ្ហាមិនប្រាកដទេ តវតណ្ហាមិនមានក្នុងកាលមុន អំពីកាលនេះ ឬថា កើតឡើងក្នុងខាងក្រោយទៀតហេតុនោះ ម្នាលភិក្ខុទាំងឡាយ ក៏ពាក្យថា តវតណ្ហានេះ តថាគតពោលយ៉ាងនេះ តែថា តវតណ្ហា រមែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ ។

ត្រាស់ទិដ្ឋិជាមាតិកាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់តវទិដ្ឋិមិនប្រាកដទេ តវទិដ្ឋិ មិនមានក្នុងកាលមុន អំពីកាលនេះ ឬថាកើតឡើងក្នុងខាងក្រោយទៀតហេតុនោះ ម្នាលភិក្ខុទាំងឡាយ ក៏ពាក្យថា តវទិដ្ឋិនេះ តថាគតពោលយ៉ាងនេះ តែថា តវទិដ្ឋិ រមែងប្រាកដ ព្រោះមានរបស់នេះជាបច្ច័យ ដូច្នេះ ។

ក្នុងភវទិដ្ឋិនេះ ក៏ឈ្មោះថា គ្រាស់ដោយទិដ្ឋិជាមាតិកាដូចគ្នា ពិតហើយ បុគ្គលមានទិដ្ឋិ ប្រកាន់វេទនា មានសុខវេទនាជាដើមជាអត្តា លុះចុតិអំពីភពនោះៗ ក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួង ដោយអំណាចការប្រកាន់ ថាអញ ថារបស់អញ ហើយទៅកើតក្នុងភពនោះៗ រមែងសុះទៅកាន់ភូមិរឿយៗ ដូចសំពៅត្រូវខ្យល់បោកបក់ក្នុងមហាសមុទ្រ មិនអាចងើកក្បាលឡើងអំពីវដ្ដៈបានឡើយ ។

[๖๔] *ដោយប្រការដូច្នេះ ព្រះមានព្រះភាគត្រាស់ដល់វដ្ដៈ ដោយកថាមគ្គត្រឹមតែប៉ុណ្ណោះ ដល់បុគ្គលមានទិដ្ឋិវង្វេងក្នុងបច្ចយាការហើយ ឥឡូវនេះ កាលត្រាស់ដល់ព្រះនិព្វាន ទើបត្រាស់ថា* **យតោ ខោ អានន្ទ ភិក្ខុ** *ដូច្នេះជាដើម ។*

ព្រះមានព្រះភាគ ព្រោះព្រះអង្គទ្រង់ឈ្វាសក្នុងទេសនា ទ្រង់មិនប៉ះពាល់ដល់វិវដ្ដកថា ចំពោះបុគ្គលដែលរវើរវាយដោយអំណាចនវកម្មជាដើម អ្នកលះបង់ចោលកម្មដ្ឋាន ហើយកាលទ្រង់ប្រារព្ធដោយអំណាចបុគ្គលដែលមានប្រក្រតីនៅដោយសតិប្បដ្ឋាន ដែលជាការកបុគ្គល ទើបត្រាស់ថា កាលបើភិក្ខុមិនបានពិចារណានូវវេទនាថាជាខ្លួន ដូច្នេះ ។

ពិតហើយ ភិក្ខុបែបនេះ រមែងមិនពិចារណាឃើញវេទនា ថាជាអត្តា រមែងមិនពិចារណាឃើញធម៌ពួកដទៃ ព្រោះការប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ដោយអំណាចនៃសម្មសនញ្ញាណ ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយន័យថា រូបឯណាមួយដែលជាអតីតក្តី អនាគតក្តី បច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ប្រណីតក្តី ឆ្ងាយក្តី ជិតក្តី ភិក្ខុ

រមែងកំណត់រូបទាំងពួង ដោយភាពជារបស់មិនទៀងពិចារណាម្តង រមែងកំណត់ដោយភាពជាទុក្ខពិចារណាម្តង រមែងកំណត់ដោយភាពជាអនត្តាពិចារណាម្តង ដូច្នេះ ។ ភិក្ខុនោះ កាលមិនពិចារណារឿយៗ យ៉ាងនេះថា វត្ថុឯណានីមួយក្នុងលោក មិនគួរប្រកាន់មាំ ដូច្នេះ ធម៌ណាមួយក្នុងធម៌ទាំងឡាយមានរូបជាដើម ក្នុងលោក មានខន្ធលោកជាដើម មិនគួរប្រកាន់មាំថា ជាអត្តា ឬកើតក្នុងអត្តា ដូច្នេះ ។ បទថា **អនុបាទិយំ ច ន បរិតស្សតិ** *សេចក្តីថា ភិក្ខុកាលមិនប្រកាន់មាំ រមែងមិនតក់ស្លុត សូម្បីដោយសេចក្តីតក់ស្លុត គឺតណ្ហាទិដ្ឋិ និងមាន ។ បទថា* **អបរិតស្សំ** *គឺកាលមិនតក់ស្លុត ។ បទថា* **បច្ចត្តញ្ញេវ បរិនិព្ពាយតិ** *សេចក្តីថា រមែងបរិនិព្វានដោយការរលត់កិលេសដោយខ្លួនឯង ។ ព្រះមានព្រះភាគត្រាស់ថា* **ឥណា ជាតិ** *ដូច្នេះជាដើម ដើម្បីទ្រង់សម្តែងដល់ការប្រព្រឹត្តទៅនៃបច្ចវេក្ខណៈ របស់អ្នកបរិនិព្វានហើយយ៉ាងនេះ ។*

បទថា **ឥតិ សា ទិដ្ឋិ** *សេចក្តីថា ទិដ្ឋិរបស់ព្រះអរហន្តដែលរួចផុតហើយ យ៉ាងនេះឈ្មោះថា ទិដ្ឋិយ៉ាងនេះ ពាលីថា* **ឥតិស្ស ទិដ្ឋិ** *ដូច្នេះក៏មានអធិប្បាយថា បុគ្គលនោះជាអ្នកឆ្ងាយចាកកិលេស ជាអ្នករួចផុតហើយយ៉ាងនោះ គប្បីមានទិដ្ឋិយ៉ាងនេះ ។ បទថា* **តទកល្លំ** *គឺសេចក្តីនោះ មិនសមគួរ ។ ព្រោះហេតុអ្វី ។ ព្រោះកាលបើយ៉ាងនោះ គួរពោលថា ព្រះអរហន្ត រមែងមិនដឹងអ្វីៗ កាលដឹងយ៉ាងនេះហើយ មិនគួរពោលនឹងព្រះអរហន្តដែលរួចផុតហើយថា មិនដឹងអ្វីមួយ ។ ដោយហេតុនោះឯង ក្នុងទីបំផុតនៃនយទាំង ៤ យ៉ាង ព្រះមានព្រះភាគ ទើបត្រាស់ថា* **តំ កិស្ស ហេតុ** *ដូច្នេះ ។*

បទថា **យាវតានន្តុ អធិវចនំ** *សេចក្តីថា មានវោហារ ពោល គឺឈ្មោះ ជរាបណា ។ បទថា* **យាវតា អធិវចនបថោ** *គឺជាផ្លូវនៃឈ្មោះប្រព្រឹត្តទៅ ជរាបណា ខន្ធ អាយតៈ ឬធាតុ នៅមានជរាបនោះ ។ ក្នុងទីទាំងអស់ ក៏មាន នយដូច្នេះ ។ បទថា* **បញ្ញាវចរំ** *គឺខន្ធបញ្ចកៈដែលកំណត់ដឹងដោយបញ្ញា ។ បទថា* **តទភិញ្ញា** *គឺព្រោះដឹងក្រៃលែងនូវវដ្តៈនោះ ។ ដោយហេតុមាន ប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់សម្តែងអ្វី ។ ទ្រង់សម្តែងអនុសន្ធិ របស់បទថា ស្មុគស្មាញដូចជាតម្បាញ ។*

អធិប្បាយ វិញ្ញាណដ្ឋិតិ ๗

[๖๕] *ឥទ្បូវនេះ បុគ្គលដែលលោកពោលថា មិនបញ្ញត្តព្រោះទៅ ឈ្មោះថា រួចផុតអំពីចំណែកទាំងពីរ ម្យ៉ាងទៀត បុគ្គលដែលលោកពោលថា មិនពិចារណាឃើញព្រោះទៅ ឈ្មោះថា ផុតដោយបញ្ញា ដូច្នោះ ដើម្បីទ្រង់ សម្តែងបទសរុប និងឈ្មោះរបស់ភិក្ខុទាំង ๒ ពួក ដែលពោលហើយទាំង នោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលអានន្ទ វិញ្ញាណដ្ឋិតិនេះមាន ๗ ។*

ក្នុងបទទាំងនោះ បទថា **សត្តា** *លោកពោលដោយអំណាចបដិសន្ធិ ។ វិញ្ញាណដ្ឋិតិ ๔ លោកពោលដោយអំណាចនៃអារម្មណ៍ និងមកក្នុងសង្គីតិ-សូត្រ ។ ឈ្មោះថា វិញ្ញាណដ្ឋិតិ ព្រោះមានវិញ្ញាណតាំងនៅ ។*

បទថា **វិញ្ញាណដ្ឋិតិ** *នេះ ជាឈ្មោះរបស់ទីតាំងនៅនៃវិញ្ញាណ ។ បទ ថា* **ទ្វេ អាយតនានិ** *គឺទីនៅអាស្រ័យ និងទីតាំង ๒ ។ បទថា* **អាយតន** *ក្នុងទីនេះ លោកបំណងយកទីនៅអាស្រ័យ ។ ដោយហេតុនោះឯង លោកនឹង*

พោលដល់អាយតនៈ ๒ គឺអសញ្ញីសត្តាយតនៈ ទីនៅរបស់សត្វដែលមិនមាន សញ្ញា នេវសញ្ញានាសញ្ញាយតនៈ ទីនៅរបស់សត្វមានសញ្ញាក៏មិនមែន មិន មានសញ្ញាក៏មិនមែន ។ សួរថា ព្រោះហេតុអ្វី ទើបលោកកាន់យកអាយតនៈ ទាំងអស់នេះ ឆ្លើយថា ដើម្បីរក្សាវដ្តៈ ។ ពិតហើយ វដ្តៈ រមែងមិនដល់ការ រក្សា ដោយអំណាចវិញ្ញាណដ្ឋិតិដែលបរិសុទ្ធ ឬដោយអំណាចអាយតនៈ បរិសុទ្ធ តែរមែងដល់ការរក្សាដោយអំណាចភព កំណើត គតិ និងសត្តាវាស ព្រោះដូច្នោះ ទើបលោកកាន់យកអាយតនៈទាំងអស់នេះ ។ ឥឡូវនេះ ព្រះ សាស្តា កាលទ្រង់ចែកសេចក្តីនោះដោយលំដាប់ ទើបត្រាស់ថា **កតមา សត្ត** *ដូច្នេះជាដើម ។*

ក្នុងបទទាំងនោះ បទថា **សេយ្យថាបិ** *ជានិបាតក្នុងអត្ថថា ឧបមា ប្រែថា ដូច អធិប្បាយថា ដូចជាមនុស្ស ដូច្នេះ ។ ពិតហើយ ក្នុងចក្រវាលដែល មិនមានប្រមាណ ដូចមួយមិនមានពីរ ដោយអំណាចនៃវណ្ណៈ និងសណ្ឋាន ជាដើម របស់មនុស្សដែលមិនមានប្រមាណ ។ សេចក្តីប្លែកគ្នាដោយអាការ ជាដើមថា ការសម្លឹងមើល ការក្រឡេកមើល ការនិយាយ ការសើច ការដើរ និងការឈរ រមែងមានត្រឹមនេះ បងប្អូនជាកូនក្មេះក្នុងទីណាមួយ រមែងដូចគ្នា ដោយវណ្ណៈ ឬដោយទ្រង់ទ្រាយ ព្រោះដូច្នោះ ទើបលោកពោលថា* **ឯកត្ត-កាយា** *តែបដិសន្ធិវិញ្ញាណរបស់សត្វទាំងនោះមានហេតុ ៣ ខ្លះ មានហេតុ ២ ខ្លះ មិនមានហេតុខ្លះ ព្រោះដូច្នោះ ទើបលោកពោលថា មានសញ្ញាផ្សេងគ្នា ។ បទថា* **ឯកច្ចេ ច ទេវា** *គឺទេវតាជាន់ឆកាមាវចរ ។ ក្នុងទេវតាទាំងនោះ ពួក ខ្លះមានខ្លួនខៀវ ពួកខ្លះមានវណ្ណៈលឿងជាដើម ។ តែសញ្ញារបស់ទេវតាទាំង*

នោះ មានហេតុ ៣ ខ្ញុះ មានហេតុ ២ ខ្ញុះ មិនមានហេតុខ្ញុះ ។ បទថា **ឯកាចេ ច វិនិចាតិកា** សេចក្តីថា វេមានិកប្រេត មានយក្ខិណីឈ្មោះខត្តរមាតា បិយង្ករ-មាតា បុស្សមិត្តា ធម្មគ្គុត្តាជាដើម ដែលជាអ្នកលិចចុះក្នុងអបាយ ៤ កាយ របស់ប្រេតទាំងនោះផ្សេងៗ គ្នា ដោយអំណាចពណ៌ មានពណ៌លឿង ពណ៌ស ពណ៌ខ្មៅ ពណ៌មាស ពណ៌ស្រអាប់ជាដើម និងដោយអំណាចការស្គម ធាត់ ខ្ពស់ និងទាប ។ សូម្បីសញ្ញាក៏មានដោយអំណាចតិហេតុក: ទ្វិហេតុក: និងអហេតុក: ដូចមនុស្សទាំងឡាយដែរ ។ ប្រេតទាំងនោះ មិនមានសក្តិធំ ដូចទេវតា មានសក្តិតូចដូចមនុស្សកំព្រា របស់បរិភោគ សំពត់ រកបាន ដោយលំបាក ត្រូវទុក្ខបៀតបៀន ។ ពួកខ្ញុះ បានទទួលទុក្ខខាងរនោច បាន ទទួលសុខខាងខ្នើត ព្រោះដូច្នោះ ទើបលោកពោលថា វិនិបាតិក: ព្រោះជា អ្នកធ្លាក់ទៅអំពីការសន្សំសេចក្តីសុខ ។ ក្នុងប្រេតទាំងនេះ សូម្បីការត្រាស់ ដឹងធម៌ ក៏រមែងមាន បានដល់ ប្រេតពួកតិហេតុក: ។ យក្ខិណីឈ្មោះ បិយង្ករមាតា បានស្តាប់ព្រះអនុរុទ្ធត្ថេរ ស្វាធ្យាយធម៌នៅក្នុងវេលាទៀបភ្លឺ ជាស់តឿនបុត្រតូចយ៉ាងនេះថា

> ម្នាលបិយង្ករ: ឯងកុំមាត់កឡើយ ដ្បិតភិក្ខុកំពុងសម្តែង ធម្មបទ ប្រសិនបើយើងដឹងច្បាស់នូវធម្មបទហើយ ប្រតិបត្តិ តាមដើម្បីជាប្រយោជន៍ ប្រយោជន៍នឹងមានដល់យើង ។ យើងនឹងសង្រួមក្នុងសត្វទាំងឡាយ យើងកុំពោលនូវពាក្យ សម្បជាមុសាវាទ យើងគួរសិក្សានូវមារយាទរបស់ខ្លួនឲ្យ ល្អ ទើបយើងរួចអំពីកំណើតបិសាចបាន ដូច្នេះហើយ បាន

สมฺเปจฺจ สោតาปตฺติผลกฺขณนฺเตเยว ฯ

បទថា **ព្រហ្មកាយិកា** *បានដល់ ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្មា ។ បទថា* **បឋមាភិនិព្ពត្តា** *បានដល់ ពួកទេវតាទាំងអស់នោះ កើតដោយបឋមជ្ឈាន ។ ក្នុងបណ្តាទេវតាទាំងនោះ ព្រហ្មបារិសជ្ជា កើតហើយដោយគុណបន្តិចបន្តួច ។ ព្រហ្មបារិសជ្ជាទាំងនោះ អាយុប្រមាណ ៣ ចំណែករបស់កប្ប ព្រហ្មបុរោហិត កើតហើយដោយគុណជាកណ្តាល អាយុប្រមាណកន្លះកប្ប កាយរបស់ព្រហ្មបុរោហិតនោះល្អស្អាតជាង ។ មហាព្រហ្មកើតដោយគុណដ៏ប្រណីត អាយុប្រមាណ ១ កប្ប ។ កាយរបស់ទេវតាទាំងនោះ ល្អស្អាតក្រៃលែង ។ ដោយប្រការដូច្នេះ គប្បីជ្រាបថា ទេវតាទាំងនោះ មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ព្រោះកាយផ្សេងគ្នា ព្រោះសញ្ញាដូចគ្នា ដោយអំណាចបឋមជ្ឈាន ។ សត្វទាំងឡាយ ក្នុងអបាយ ៤ ក៏ដូចទេវតាទាំងនោះ ។*

ក្នុងនរក អត្តភាពរបស់សត្វពួកខ្លះមួយគាវុត ពួកខ្លះកន្លះយោជន៍ ពួកខ្លះមួយយោជន៍ តែអត្តភាពរបស់កិកូទេវទត្ត ១០០ យោជន៍ ។ ក្នុងតិរច្ឆានទាំងឡាយ ពួកខ្លះតូច ពួកខ្លះធំ ។ ក្នុងប្រេតវិស័យ ពួកខ្លះ ៦០ ហត្ថ ពួកខ្លះ ៧០ ហត្ថ ពួកខ្លះ ៨០ ហត្ថ ពួកខ្លះសម្បុរល្អ ពួកខ្លះសម្បុរមិនល្អ ។ កាលញ្ចិកាសុរក៏ដូច្នោះ ។ ម្យ៉ាងទៀត ក្នុងបណ្តាប្រេតទាំងនេះ ទីឃបិដ្ឋិក-ប្រេត កម្ពស់ដល់ទៅ ៦០ យោជន៍ ។ តែសញ្ញារបស់ប្រេតទាំងអស់ ជាអហេតុកៈ ផ្នែកខាងអកុសលវិបាក ។ ដោយប្រការដូច្នេះ សត្វក្នុងអបាយរមែងរាប់បានថា មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូច្នេះ ។

បទថា **អាភស្សរា** *សេចក្តីថា រស្មីអំពីសរីរៈរបស់ទេវតាទាំងនោះ ដូច អណ្តាតគប់ភ្លើង ផ្សាយចេញជាច់ៗ ហើយជ្រាក់ ព្រោះហេតុនោះ ទើបឈ្មោះ ថា* **អាភស្សរា** *។ ក្នុងព្រហ្មទាំងនោះ ព្រហ្មដែលចម្រើនគុណបន្តិចបន្តួច មាន ២ ឈាន គឺទុតិយជ្ឈាន និងតតិយជ្ឈាន ក្នុងចតុក្កនយ និងបញ្ចកនយ កើតឡើងហើយ ឈ្មោះថា* **បរិត្តាភា** *។ ប្រមាណអាយុរបស់ព្រហ្មបរិត្តាភា ទាំងនោះ ២ កប្ប ។ អ្នកចម្រើនគុណ កណ្តាលកើតឡើងហើយ ឈ្មោះថា* **អប្បមាណាភា** *។ ប្រមាណអាយុរបស់ព្រហ្មអប្បមាណាភាទាំងនោះ ៤ កប្ប ។ អ្នកចម្រើនគុណប្រណីតពិត កើតឡើងហើយ ឈ្មោះថា* **អាភស្សរា** *។ ប្រមាណអាយុរបស់អាភស្សរាទាំងនោះ ៨ កប្ប ។ ក្នុងទីនេះ លោកកំណត់ យកទេវតាទាំងអស់នោះ ដោយអំណាចការកំណត់យ៉ាងខ្ពស់ ។ កាយរបស់ ទេវតាទាំងនោះ មានភាពល្អស្អាតដូចគ្នាពិត ។ តែសញ្ញាត្រឹមតែមិនមានវិតក្ក តែមានវិចារៈ ឬមិនមានទាំងវិតក្ក មិនមានទាំងវិចារៈ ព្រោះហេតុនោះ ទើប ផ្សេងគ្នា ។*

បទថា **សុភកិណ្ហា** *គឺផ្សាយឆៀវឆ្ងាត់ដោយលម្អ អធិប្បាយថា មាន សេចក្តីណែនក្រាស់ជាប់តគ្នា ដោយពន្លឺនៃរស្មីក្នុងសរីរៈដ៏ល្អ តែរស្មីនៃទេវតា សុភកិណ្ហាទាំងនោះមិនជាច់ៗ ហើយផ្សាយទៅ ដូចរស្មីរបស់ទេវតាអាភស្សរា ។ តែក្នុងបញ្ចកនយ ទេវតាកើតជាបរិត្តសុភា ។ ទេវតាអប្បមាណសុភា ។ ទេវតាសុភកិណ្ហា មានអាយុ ១៦ កប្ប ៣២ កប្ប ៦០ កប្ប ដោយអំណាច ចតុត្ថជ្ឈានខ្សោយ កណ្តាល និងប្រណីត ។ ដោយប្រការដូច្នេះ ទេវតាទាំង អស់នោះ គប្បីជ្រាបថា មានកាយដូចគ្នា និងមានសញ្ញាដូចគ្នា ដោយសញ្ញា

នៃចតុត្ថជ្ឈាន ដូច្នេះ ។ មួយទៀត សូម្បីទេវតាវេហប្ផលា ក៏រួមបូលនឹងវិញ្ញាណដ្ឋិតិទី ៤ ដូចគ្នា ។ សត្វមិនមានសញ្ញា ព្រោះមិនមានវិញ្ញាណ មិនសង្គ្រោះបូលក្នុងវិញ្ញាណដ្ឋិតិនេះ តែសង្គ្រោះបូលក្នុងសត្តាវាស ។ ទេវតាសុទ្ធាវាស តាំងនៅក្នុងចំណែកវិវដ្ដៈ មិនកំណត់កាលទាំងពួង ក៏មិនកើតក្នុងលោកដែលសូន្យចាកព្រះពុទ្ធ ១ សែនកប្បខ្វះ ១ អសង្ខ្យៃកប្បខ្វះ កាលព្រះពុទ្ធទ្រង់កើតឡើងក្នុងចន្លោះ ១៦០០០ កប្បនោះឯងទើបកើត រមែងដូចគ្នានឹងទីតាំងបន្ទាយរបស់ព្រះមានព្រះភាគ ដែលញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅហើយ ព្រោះដូច្នោះ ទើបទេវតាសុទ្ធាវាស មិនសង្គ្រោះបូលនឹងវិញ្ញាណដ្ឋិតិ មិនសង្គ្រោះបូលនឹងសត្តាវាស ។ តែព្រះមហាសិវត្ថេរពោលថា សុទ្ធាវាស-ព្រហ្ម ក៏នៅតែសង្គ្រោះបូលនឹងវិញ្ញាណដ្ឋិតិទី ៤ សត្តាវាសទី ៤ នោះឯង ដោយព្រះសូត្រនេះថា

ម្នាលសារីបុត្ត សង្ឃរណា ដែលតថាគត មិនធ្លាប់អន្ទោលទៅដោយកាលវែងនោះ រឿរលែងតែទេវលោក ឈ្មោះសុទ្ធាវាសទាំងឡាយចេញសង្ឃរន្ទុះឯង បុគ្គលមិនងាយរកបានឡើយ ដូច្នេះ ។ យើញដោយព្រះសូត្រនោះ ព្រោះព្រះសូត្រលោកមិនហាម ។

សេចក្ដីនៃបទជាដើមថា **សព្វសោ រូបសញ្ញានំ** *លោកពោលហើយក្នុងវិសុទ្ធិមគ្គ ។ នេវសញ្ញានាសញ្ញាយតនៈ មានវិញ្ញាណក៏មិនមែន មិនមានវិញ្ញាណក៏មិនមែន ព្រោះសូម្បីវិញ្ញាណល្អិត ដូចសភាពល្អិតរបស់សញ្ញា ព្រោះដូច្នោះ ទើបលោកមិនពោលក្នុងវិញ្ញាណដ្ឋិតិ ហើយពោលក្នុងអាយតនៈ ។ បទថា* **តត្រ** *គឺក្នុងវិញ្ញាណដ្ឋិតិទាំងនោះ ។ បទថា* **តញ្ច បជានាតិ** *គឺរមែង*

ជីវិតវិញ្ញាណដ្ឋិតិនោះ ។ បទថា **តស្សា ច សមុទយំ** *សេចក្តីថា រមែងដឹងការកើតឡើងនៃវិញ្ញាណដ្ឋិតិនោះ ដោយនយជាដើមថា ព្រោះអវិជ្ជាកើត ទើបរូបកើត ដូច្នេះ ។ បទថា* **តស្សា ច អត្ថង្គមំ** *សេចក្តីថា រមែងដឹងការរលត់នៃវិញ្ញាណដ្ឋិតិនោះ ដោយនយជាដើមថា ព្រោះអវិជ្ជារលត់ ទើបរូបរលត់ ដូច្នេះ ។ បទថា* **អស្សាទំ** *សេចក្តីថា រមែងដឹងនូវការពេញចិត្តរបស់វិញ្ញាណដ្ឋិតិនោះយ៉ាងនេះថា សេចក្តីសុខ សោមនស្ស រមែងកើតឡើងព្រោះអាស្រ័យរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា នេះ គឺសេចក្តីពេញចិត្តនៃវិញ្ញាណ ។ បទថា* **អាទីនវំ** *សេចក្តីថា រមែងដឹងទោសនៃវិញ្ញាណដ្ឋិតិនោះយ៉ាងនេះថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលទៅជាធម្មតា នេះគឺ ទោសនៃវិញ្ញាណ ។ បទថា* **និស្សរណំ** *សេចក្តីថា ការនាំចេញនូវឆន្ទរាគៈ ការលះឆន្ទរាគៈ ក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា នេះ គឺឧបាយជាគ្រឿងនាំចេញទៅនៃវិញ្ញាណនោះ រមែងដឹងវិញ្ញាណដ្ឋិតិនោះយ៉ាងនេះ ។ បទថា* **កល្លំ នុ តេន** *សេចក្តីថា ភិក្ខុនោះគួរជល់ការត្រេកអរនូវវិញ្ញាណដ្ឋិតិនោះ ថាអញ ថារបស់អញ ដោយអំណាចនៃតណ្ហា មានះ និងទិដ្ឋិទៀតឬ ។ គប្បីជ្រាបសេចក្តីក្នុងទីទាំងពួងដោយឧបាយនេះ ។ តែគប្បីប្រកបសមុទយៈជាដើម ដោយអំណាចនៃខន្ធទាំងឡាយ ๔ ក្នុងទីដែលមិនមានរូប ដោយអំណាចនៃខន្ធមួយក្នុងទីដែលមិនមានវិញ្ញាណ ។ ម្យ៉ាងទៀត ក្នុងទីនេះ មិនគប្បីប្រកបបទនេះថា ព្រោះអាហារកើត ព្រោះអាហាររលត់ ដូច្នេះ ។*

បទថា **យតោ ខោ អានន្ទ ភិក្ខុ** *សេចក្តីថា ម្នាលអានន្ទ កាលណាភិក្ខុ ។*

បទថា **អនុបាទា វិមុត្តោ** *សេចក្តីថា ជាអ្នករួចផុត ព្រោះមិនប្រកាន់មាំ ដោយឧបាទាន ៤ ។ បទថា* **បញ្ញាវិមុត្តោ** *សេចក្តីថា ជាអ្នករួចផុតដោយបញ្ញា ។ អធិប្បាយថា មិនធ្វើឲ្យច្បាស់នូវវិមោក្ខ ៨ តែធ្វើនាមកាយ និងរូបកាយ ឲ្យប្រព្រឹត្តទៅមិនបាន ដោយកម្លាំងបញ្ញានោះឯង ឈ្មោះថា ជាអ្នករួចផុតហើយ ។ ភិក្ខុដែលរួចផុតហើយនោះ មាន ៥ យ៉ាង គឺ ជាសុក្ខ-វិបស្សកៈ និងតាំងនៅក្នុងបឋមជ្ឈានជាដើមយ៉ាងណាមួយ ហើយសម្រេចអរហត្ត ដូចដែលលោកពោលសេចក្តីនេះថា បុគ្គលជាបញ្ញាវិមុត្តិតើដូចម្តេច បុគ្គលខ្លះ ក្នុងលោកនេះ មិនបានវិមោក្ខ ៨ ដោយនាមកាយទេ អាសវៈរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាបញ្ញាវិមុត្តិ ដូច្នេះ ។*

ពោលអំពីវិមោក្ខ ៨

[៦៦] *ព្រះមានព្រះភាគ ទ្រង់សម្តែងបទសរុប និងនាមរបស់កិក្ខុមួយរូបយ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងដល់កិក្ខុក្រៅអំពីនេះ ទើបត្រាស់ថា* **អដ្ឋ ខោ ឥមេ** *ដូច្នេះជាដើម ។*

ក្នុងបទទាំងនោះ បទថា **វិមោក្ខោ** *សួរថា ឈ្មោះថា វិមោក្ខ ដោយអត្ថដូចម្តេច ឆ្លើយថា ដោយអត្ថថា រួចផុត សួរថា វិមោក្ខនេះ មានអត្ថថារួចផុតដូចម្តេច ឆ្លើយថា មានអត្ថថា រួចផុតដោយល្អអំពីធម៌ជាសត្រូវ និងរួចផុតដោយល្អ ដោយអំណាចសេចក្តីត្រេកអរក្នុងអារម្មណ៍ ។ លោកអធិប្បាយថា វិមោក្ខ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ព្រោះអស់សេចក្តីសង្ស័យ ដោយសេចក្តីមិនប្រកាន់ ដូចទារកអ្នកបញ្ចេញអវយវៈតូចធំដែក*

លើក្លៅរបស់បិតា ។ សេចក្តីនេះមិនមានក្នុងវិមោក្ខពេលខាងក្រោយ តែមានក្នុងផ្នែកខាងដើមទាំងអស់ ។

ក្នុងបទថា **រូបី រូបានិ បស្សតិ** *នេះ សេចក្តីថា រូប ជារូបជ្ឈានដែលធ្វើឲ្យកើតឡើង ដោយអំណាចនីលកសិណជាដើម ក្នុងសក់ជាដើមខាងក្នុង ឈ្មោះថា* **រូបី** *។ ព្រោះមានរូបជ្ឈាន ដោយបទនេះ លោកសម្តែងរូបាវចរជ្ឈាន ៤ ដល់បុគ្គលដែលធ្វើឈានឲ្យកើតក្នុងកសិណទាំងឡាយ ដែលមានវត្ថុខាងក្នុង ។ បទថា* **អជ្ឈត្តំ អរូបសញ្ញី** *គឺមិនមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុង សេចក្តីថា មិនធ្វើរូបាវចរជ្ឈានឲ្យកើតក្នុងអាការ ៣២ មានសក់ជាដើមរបស់ខ្លួន ។ បទថា* **ពហិទ្ធា រូបានិ បស្សតិ** *សេចក្តីថា រមែងឃើញជារូប មាននីលកសិណជាដើម ខាងក្រៅដោយញាណចក្ខុ ។ ដោយបទនេះ លោកធ្វើបរិកម្មខាងក្រៅហើយ សម្តែងរូបាវចរជ្ឈាន ៤ នៃឈានដែលធ្វើឲ្យកើតហើយខាងក្រៅ ។ លោកសម្តែងឈានក្នុងវណ្ណកសិណ មានពណ៌ខៀវជាដើម ដែលបរិសុទ្ធល្អហើយ ដោយបទនេះថា* **សុភន្តេវ អធិមុត្តោ ហោតិ** *ដូច្នេះ ក្នុងបទនោះ មិនមានការធ្វើទុកក្នុងចិត្តថា ស្អាតក្នុងអប្បនាខាងក្នុងក៏ពិតមែន តែព្រោះបុគ្គលដែលធ្វើកសិណដែលស្អាតបរិសុទ្ធហើយនោះ រមែងជាអ្នកគួរពោលបានថា អ្នកដែលបង្អោនចិត្តជឿថា កសិណជារបស់ស្អាតដូច្នេះ ដូច្នោះ ទើបលោកសម្តែងយ៉ាងនេះ ។ តែក្នុងបដិសម្ភិទាមគ្គ លោកពោលថា វិមោក្ខ ក្នុងពាក្យថា បុគ្គលដែលបង្អោនចិត្តជឿថា កសិណស្អាតដូចម្តេច ភិក្ខុក្នុងធម្មវិន័យនេះ មានចិត្តសហគតៈដោយមេត្តា ផ្សាយទៅកាន់ទិសមួយ ។បេ។ ព្រោះជាអ្នកចម្រើនមេត្តា ទើបសត្វទាំងឡាយ មិនជាអ្នកគួរ*

สฺนปฺ มานจิตฺตสหคตะเจ้ายกรุณา มุทิตา อุเปกฺขา ผฺรายไปกานฺทิสมួย ฯเปฯ เพฺราะเปนอฺนกเจมฺรีนอุเปกฺขา เทีบสตฺวทังฺคผฺรายเปนปุคฺคลมินคួรสฺนปฺ วิโมกฺขกฺนังบทถา อฺนกเดิลบเงฺกานจิตฺตเช฿ถา กสิณ เปนรบสฺอาตยังนេះ ដូចេះ ។

ក្នុងបទថា **សព្វសោ រូបសញ្ញានំ** ជាដើម បទទាំងអស់ដែលគួរពោល លោកពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ បទថា **អយំ អដ្ឋមោ វិមោក្ខោ** សេចក្តីថា នេះឈ្មោះថា វិមោក្ខ ដែលខ្ពស់បំផុតប្រការទី ៨ ព្រោះខន្ធ ៤ បរិសុទ្ធ ដោយប្រការទាំងពួង ព្រោះកាពដែលរួចផុតហើយ ។ បទថា **អនុលោមំ** គឺតាំងអំពីបទដើម ដរាបដល់បទចុងក្រោយ ។ បទថា **បដិលោមំ** គឺតាំងអំពីបទចុង ដរាបដល់បទដើម ។ បទថា **អនុលោមបฺปฏิលោมំ** នេះ លោកពោលដោយអំណាចនៃសមាបត្តិមិនតាំងមាំ ព្រោះជំនាញពេក វិលទៅ ផ្លូវនោះផ្លូវនេះ ។ បទថា **យត្ថិចฺฉกំ** គឺសម្តែងដល់ឱកាស សេចក្តីថា ប្រាថ្នា ក្នុងឱកាសណាមួយ ។ បទថា **យទิจฺฉกំ** គឺសម្តែងដល់សមាបត្តិ បានដល់ ប្រាថ្នាសមាបត្តិណាមួយ ។ បទថា **យาวតิจฺฉกំ** គឺសម្តែងដល់ការកំណត់ផ្លូវ ឆ្ងាយ បានដល់ ប្រាថ្នាផ្លូវឆ្ងាយប្រមាណត្រឹមណា ។ បទថา **สมาปជฺชติ** គឺ ចូលកាន់សមាបត្តិនោះៗ ។ បទថា **วุฏฺฐาติ** គឺចេញចាកសមាបត្តិនោះ ហើយ តាំងនៅ ។ បទថา **อุภโตภาควิมุตฺโต** សេចក្តីថា រួចផុតដោយចំណែក ទាំងពីរ គឺរួចផុតពីរូបកាយដោយអរូបសមាបត្តិ ផុតពីនាមកាយដោយមគ្គ ។ ដូចដែលលោកពោលដូចេះថា

ម្នាលឧបសីវៈ អណ្តាតភ្លើង ដែលត្រូវកម្ទាំងខ្យល់បក់ រមែងរលត់ទៅ មិនដល់នូវការរាប់ (ថាទៅក្នុងទីណាទេ) យ៉ាងណាមិញ មុនីរួចស្រឡះហើយ ចាកនាមកាយ រមែងរលត់ទៅ មិនដល់នូវការរាប់ (ថាទៅក្នុងទីណា) យ៉ាងនោះដែរ ។

ភិក្ខុនេះរួចផុតហើយ ដោយចំណែកទាំងពីរ ចេញចាកអាកាសានញ្ចាយតនៈជាដើមណាមួយ ហើយសម្រេចអរហត្ត និងជាអនាគាមី ចេញចាកនិរោធហើយ សម្រេចអរហត្ត រួមជា ៥ យ៉ាង ។ តែអាចារ្យពួកខ្លះពោលថា ព្រោះសូម្បីរូបាវចរចតុត្ថជ្ឈាន ក៏សហគតៈដោយឧបេក្ខា មានអង្គពីរ សូម្បីអរូបាវចរជ្ឈានក៏ដូច្នោះដែរ ដូច្នោះ ភិក្ខុចេញចាករូបាវចរចតុត្ថជ្ឈាន សូម្បីសម្រេចអរហត្ត ក៏ឈ្មោះថា ឧភតោភាគវិមុត្តិ ដូច្នេះ ។ បញ្ហាឧភតោភាគវិមុត្តិនេះ តាំងឡើងខាងក្រោមលោហប្រាសាទ អាស្រ័យពណ៌នារបស់ព្រះចូឡសុមនត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក អស់កាលយូរ ទើបដោះស្រាយបាន ។

មានរឿងថា ក្នុងគិរីវិហារ អន្តេវាសិករបស់ព្រះថេរៈស្តាប់បញ្ហានោះអំពីមាត់របស់ភិក្ខុ ដែលកាន់បិណ្ឌបាតិកវត្តមួយរូប ហើយពោលថា នែអាវុសោ កាលអាចារ្យរបស់ខ្ញុំអធិប្បាយធម៌ខាងក្រោមលោហប្រាសាទ ដែលបុគ្គលណាមួយ មិនធ្លាប់ស្តាប់ហើយ ទើបពួកភិក្ខុសួរថា លោកដ៏ចម្រើន ព្រះថេរៈបានពោលដូចម្តេច អន្តេវាសិកឆ្លើយថា នែអាវុសោព្រះថេរៈបានពោលថា រូបាវចរចតុត្ថជ្ឈានសហគតៈដោយឧបេក្ខា មានអង្គពីរ គ្របសង្កត់

កិលេសបានក៏ពិត តែរូបាវចរចតុត្ថជ្ឈាន រមែងកម្រើកក្នុងឋានៈនៃរូបារម្មណ៍ ជាចំណែកជិតនៃកិលេសទាំងឡាយ ព្រោះធម្មតាកិលេសទាំងនេះ ចូលទៅអាស្រ័យអារម្មណ៍ ក្នុងនីលកសិណជាដើមណាមួយ ក្នុងកពជាន់ក្រោមទាំង ៥ រមែងកម្រើក មួយទៀត រូបាវចរជ្ឈាន រមែងមិនឈានទៅកាន់អារម្មណ៍នោះ ព្រោះដូច្នោះ ភិក្ខុផ្ចាស់រូបដោយប្រការទាំងពួង ហើយគ្របសង្កត់កិលេសដោយអំណាចអរូបជ្ឈានហើយ ទើបសម្រេចអរហត្ត ជាឧភតោភាគវិមុត្តិ ដូច្នេះ ឯព្រះថេរៈកាលពោលពាក្យនេះហើយ ទើបនាំសូត្រនេះមកថា

បុគ្គលជាឧភតោភាគវិមុត្តិ តើដូចម្តេច បុគ្គលខ្លះក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ អាសវៈរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថាបុគ្គល ជាឧភតោភាគវិមុត្តិ ដូច្នេះ ។

បទថា **ឥមាយ ច អានន្ទ ឧភតោភាគវិមុត្តិយា** *សេចក្តីថា ម្នាលអានន្ទ ឧភតោភាគវិមុត្តិដទៃអំពីឧភតោភាគវិមុត្តិនេះ ។ បទដ៏សេស មានអត្ថងាយយល់ទាំងអស់ហើយ ។*

មហានិទានសូត្រ ចប់

សូត្រទី ២ ចប់

សុត្តន្តបិដក

មហាបរិនិព្វានសូត្រទី ៣

[៦៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះរាជាជាធំក្នុងដែនមគធៈ ព្រះនាមអជាតសត្តុវេទេហីបុត្ត មានព្រះបំណងនឹងយាត្រាទៅញាំញីដែនវជ្ជី ។ ព្រះអង្គមានព្រះបន្ទូលយ៉ាងនេះថា អញនឹងផ្តិលផ្តាច់អ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ (មានបំណងនឹងយាត្រាទៅជិះជាន់) ដែនវជ្ជី នឹងបំផ្លាញដែនវជ្ជី នឹងធ្វើដែនវជ្ជីឲ្យដល់នូវសេចក្តីវិនាស ។ គ្រានោះ ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធ-រាជ ត្រាស់ហៅវស្សការព្រាហ្មណ៍ដែលជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ ចូរអ្នកមកនេះ ចូរអ្នកទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះមានព្រះភាគដោយត្បូងតាមពាក្យខ្ញុំ រួចទូលសួរអំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយគ្រប់ឥរិយាបថ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយព្រះសិរ្ស៍ ហើយផ្តាំមកក្រាបបង្គំទូលសួរអំពីអាការមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័ស ព្រះកាយពល និងការគង់នៅស្រួលគ្រប់ឥរិយាបថ មួយទៀត ចូរក្រាបទូលយ៉ាងនេះតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជ មានព្រះ

បំណងនឹងយាត្រាទៅញាំញីដែនវជ្ជី ព្រះអង្គមានបន្ទូលយ៉ាងនេះថា អញនឹងផ្តិលផ្តាច់អ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ (មានបំណងនឹងយាត្រាទៅជិះជាន់) ដែនវជ្ជី នឹងបំផ្លាញដែនវជ្ជី នឹងធ្វើដែនវជ្ជីឲ្យដល់នូវសេចក្តីវិនាស ប៉ុន្តែបើព្រះមានព្រះភាគទ្រង់ព្យាករដល់អ្នកយ៉ាងណា ត្រូវអ្នកត្រាប់ត្រងរងព្រះពុទ្ធដីកានោះ ឲ្យជាក់ច្បាស់ហើយមកប្រាប់ខ្ញុំវិញ ព្រោះព្រះតថាគតទាំងឡាយមិនដែលមានបន្ទូលខុសទេ ។ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈទទួលព្រះរាជឱង្ការព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយទើបឲ្យរៀបចំយានទាំងឡាយដែលល្អៗ ហើយឡើងជិះយានដែលល្អៗ បរចេញអំពីក្រុងរាជគ្រឹះ ទៅដោយយានដែលល្អៗ បរសំដៅទៅកាន់ភ្នំគិជ្ឈកូដ ទៅដោយយានកំណត់ត្រឹមទីដែលបរយានទៅបាន រួចចុះអំពីយានដើរទៅដោយជើងទេ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យពាក់ទាក់ សំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរវីកវាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជ ថ្វាយបង្គំព្រះបាទានៃព្រះគោតមដ៏ចម្រើនដោយព្រះសិរ្ស៍ ហើយផ្តាំឲ្យទូលសួរអំពីអាការមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស ព្រះកាយពល និងការគង់នៅស្រួលគ្រប់ឥរិយាបថ

បពិត្រព្រះគោតមដ៏ចម្រើន ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជ មានព្រះបំណងនឹងស្តេចទៅញាំញីដែនវជ្ជី ព្រះអង្គមានបន្ទូលយ៉ាងនេះថា អញនឹងផ្តិលផ្តាច់អ្នកដែនវជ្ជីទាំងនេះ ដែលមានឫទ្ធិធំយ៉ាងនេះ មានអានុភាពធំយ៉ាងនេះ អញ (មានបំណងនឹងយាត្រាទៅជិះជាន់) ដែនវជ្ជី នឹងបំផ្លាញដែនវជ្ជី នឹងធ្វើដែនវជ្ជីឲ្យដល់នូវសេចក្តីវិនាស ។

[៦៨] *សម័យនោះឯង ព្រះអានន្ទមានអាយុឋិតនៅអំពីខាងក្រោយព្រះមានព្រះភាគ កំពុងព័ត (បក់) ថ្វាយព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នកបានឮថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើនដូច្នេះដែរឬ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកស្តេចក្នុងដែនវជ្ជី មានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើនដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកស្តេចក្នុងដែនវជ្ជីនឹងមានការប្រជុំគ្នារឿយៗ មានការប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកស្តេចក្នុងដែនវជ្ជី សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជីដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជីដូច្នេះដែរ ។ ម្នាលអានន្ទ*

បើពួកវជ្ជីក្សត្រិយ៍នឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកលែងប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចក្នុងដែនវជ្ជីអស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍មិនបញ្ញត្តច្បាប់ (ដែលពួកស្តេចពីដើម) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជីអំពីបុរាណដែលបានបញ្ញត្តរួចហើយយ៉ាងណាដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍មិនបញ្ញត្តច្បាប់ (ដែលពួកស្តេចពីដើម) មិនបានបញ្ញត្ត មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាមប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជី អំពីបុរាណដែលបានបញ្ញត្តរួចហើយ យ៉ាងណាដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍នឹងមិនបញ្ញត្តច្បាប់ ដែលស្តេចពីដើមមិនបានបញ្ញត្តហើយ មិនដកច្បាប់ដែលបានបញ្ញត្តរួចហើយ កាន់តាម ប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជីអំពីបុរាណ ដែលបានបញ្ញត្តរួចហើយ យ៉ាងណា អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍ធ្វើសក្ការៈ គោរព រាប់អាន បូជាពួកវជ្ជីក្សត្រិយ៍ ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ដែលគួរស្តាប់របស់ពួកក្សត្រិយ៍ ដែលមានព្រះជន្មច្រើនទាំងនោះដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍ តែងធ្វើសក្ការៈ

គោរព រាប់អាន បូជា ពួកវជ្ជីក្សត្រិយ៍ដែលមានព្រះជន្មច្រើន ជាងវជ្ជី-ក្សត្រិយ៍ទាំងឡាយ ទាំងជឿពាក្យដែលគួរស្តាប់របស់ពួកក្សត្រិយ៍ ដែលមានព្រះជន្មច្រើនទាំងនោះថា ជាពាក្យគួរស្តាប់ដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍នឹងធ្វើសក្ការៈ គោរព រាប់អាន បូជា ពួកវជ្ជីក្សត្រិយ៍ដែលមានព្រះជន្មច្រើនជាងវជ្ជីក្សត្រិយ៍ទាំងឡាយ ទាំងជឿពាក្យគួរស្តាប់របស់ពួកក្សត្រិយ៍ ដែលមានព្រះជន្មច្រើនទាំងនោះ អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍មិនកំហែង បង្ខំពួកស្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឲ្យនៅរួមដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍មិនកំហែង បង្ខំពួកស្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឲ្យនៅរួមដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍នឹងមិនកំហែង បង្ខំពួកស្រីក្នុងត្រកូល ពួកកុមារីក្នុងត្រកូលឲ្យនៅរួមអស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថាពួកវជ្ជីក្សត្រិយ៍តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជី របស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរក្តី ខាងក្រៅនគរក្តី និងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើ ដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួក

*វជ្ជីក្សត្រិយ៍តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជីរបស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរក្តី ខាងក្រៅនគរក្តី នឹងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះឲ្យសាបសូន្យទៅដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍ នឹងធ្វើសក្ការៈ គោរព រាប់អាន បូជាចេតិយក្នុងដែនវជ្ជីរបស់ពួកអ្នកដែនវជ្ជី ដែលនៅខាងក្នុងនគរក្តី ខាងក្រៅនគរក្តី និងមិនធ្វើគ្រឿងបូជាប្រកបដោយធម៌ ដែលគេធ្លាប់ថ្វាយ ធ្លាប់ធ្វើដល់ចេតិយទាំងនោះ ឲ្យសាបសូន្យទៅ អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលអានន្ទ អ្នកបានឮថា ពួកវជ្ជីក្សត្រិយ៍ បានចាត់ចែងត្រឹមត្រូវនូវការការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងអរហន្តទាំងឡាយដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយ ដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខ ក្នុងដែនរបស់យើងដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដំណឹងនេះថា ពួកវជ្ជីក្សត្រិយ៍បានចាត់ចែងដោយត្រឹមត្រូវនូវការការពារ និងការគ្រប់គ្រងប្រកបដោយធម៌ក្នុងព្រះអរហន្តទាំងឡាយ ដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខ ក្នុងដែនរបស់យើងដូច្នេះដែរ ។ ម្នាលអានន្ទ បើពួកវជ្ជីក្សត្រិយ៍នឹងចាត់ចែងដោយ

ត្រឹមត្រូវនូវការរក្សាការពារ និងការគ្រប់គ្រងប្រកបដោយធម៌ ក្នុងព្រះអរហន្ត ទាំងឡាយដោយបំណងថា ធ្វើម្តេចហ្ន៎ ព្រះអរហន្តទាំងឡាយ ដែលមិនទាន់មក ក៏សូមឲ្យមកកាន់ដែនរបស់យើង ព្រះអរហន្តទាំងឡាយដែលមកស្រាប់ហើយ ក៏សូមឲ្យគង់នៅជាសុខក្នុងដែនរបស់យើង អស់កាលត្រឹមណា ម្នាលអានន្ទ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

[๖๙] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទឹងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈថា ម្នាលព្រាហ្មណ៍ សម័យមួយ តថាគតនៅក្នុងសារន្ទទចេតិយ ទៀបក្រុងវេសាលី តថាគតបានសម្តែងអបរិហានិយ-ធម៌ទាំង ๗ នេះ របស់ពួកវជ្ជីក្សត្រិយ៍ ក្នុងសារន្ទទចេតិយនោះឯង ម្នាលព្រាហ្មណ៍ អបរិហានិយធម៌ទាំង ๗ នេះ តាំងនៅក្នុងពួកវជ្ជីក្សត្រិយ៍ ឬថាពួកវជ្ជីក្សត្រិយ៍នឹងប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ๗ នេះ អស់កាលត្រឹមណា ម្នាលព្រាហ្មណ៍ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ កាលបើព្រះមានព្រះភាគ មានព្រះបន្ទូលយ៉ាងនេះហើយ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីចម្រើនតែងមានប្រាកដ សេចក្តីសាបសូន្យមិនមានដល់ពួកវជ្ជីក្សត្រិយ៍ ដែលប្រកបដោយអបរិហានិយធម៌ សូម្បីតែមួយៗ ចាំបាច់និយាយទៅថ្ងៃដល់ទៅគ្រប់អបរិហានិយធម៌ទាំង ๗ បពិត្រព្រះគោតមដ៏

ចម្រើន មួយទៀត ព្រះបាទអជាតសត្តុវេទេហីបុត្តមាគធរាជ មិនគប្បីចាប់ ពួកវជ្ជីក្សត្រិយ៍ដោយការច្បាំងបានទេ រៀរលែងតែការលួងលោមយកចិត្ត ឬការធ្វើឲ្យបែកគ្នា បពិត្រព្រះគោតមដ៏ចម្រើន ណ្ហើយចុះ ខ្ញុំព្រះអង្គសូម លាទៅឥឡូវនេះ ខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ ព្រះអង្គ ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកចូរសម្គាល់នូវកាលគួរនឹងទៅក្នុងវេលានេះចុះ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធ: ត្រេកអររីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសន:ចេញទៅ ។

[៧០] កាលដែលវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធ: ចេញទៅមិនយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មាន អាយុថា ម្នាលអានន្ទ អ្នកចូរទៅឲ្យភិក្ខុទាំងអស់ ដែលនៅអាស្រ័យក្នុងក្រុង រាជគ្រឹះប្រជុំគ្នាក្នុងឧបដ្ឋានសាលា ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះបន្ទូល ព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយប្រជុំភិក្ខុសង្ឆទាំង អស់ ដែលនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ក្នុងឧបដ្ឋានសាលា ហើយក៏ចូល ទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះ ភាគ រួចឋិតនៅក្នុងទីសមគួរ ។ ព្រះអានន្ទដ៏មានអាយុ លុះឋិតនៅក្នុងទីដ៏ សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ ចម្រើន ភិក្ខុសង្ឆប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះ ភាគ សម្គាល់នូវកាលគួរនឹងស្តេចទៅក្នុងកាលឥឡូវនេះ ។ លំដាប់នោះ ព្រះ មានព្រះភាគ ទ្រង់ក្រោកអំពីអាសន:ហើយស្តេចចូលទៅកាន់ឧបដ្ឋានសាលា

លុះ ចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលទុក ។ លុះព្រះមានព្រះភាគគង់នៅហើយ ក៏ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ៧ ប្រការដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងឡាយនោះ ក៏ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រជុំគ្នារឿយៗ ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកទីប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនបញ្ញត្តសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ មិនដកសិក្ខាបទដែលតថាគតបញ្ញត្តហើយ កាន់តាម ប្រព្រឹត្តតាមសិក្ខាបទដែលតថាគតបញ្ញត្តហើយ យ៉ាងណា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងធ្វើសក្ការៈ គោរព រាប់អាន បូជាពួកភិក្ខុ ជាថេរៈអ្នកដឹងរាត្រី (ច្រើន) បួស

*ឃ្លរ ជាបិតានៃសង្ឃ ជាបរិនាយករបស់សង្ឃ (ជាអ្នកណែនាំសង្ឃ) ទាំង
ឯាប់អានជឿពាក្យដែលគួរស្តាប់របស់ភិក្ខុជាថេរៈទាំងនោះ អស់កាលត្រឹមណា
ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តី
សាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ
បើពួកភិក្ខុនីឯមិនលុះក្នុងអំណាចតណ្ហា ជាធម្មជាតិនាំសត្វទៅក្នុងភពថ្មីទៀត
ដែលកើតឡើងហើយ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តី
ចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់
កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីឯមានសេចក្តីប្រាថ្នា
ក្នុងសេនាសនៈទាំងឡាយ ដែលតាំងនៅក្នុងព្រៃ អស់កាលត្រឹមណា ម្នាល
ភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាប
សូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួក
ភិក្ខុនីឯប្រុងស្មារតីក្នុងខ្លួនថា ធ្វើម្តេចហ្ន៎ ពួកសព្រហ្មចារី មានសីលធម៌ជា
ទីស្រឡាញ់ ដែលមិនទាន់មកដល់ ក៏សូមឲ្យនិមន្តមក ពួកសព្រហ្មចារីមាន
សីលធម៌ជាទីស្រឡាញ់ ដែលមកដល់ហើយ សូមឲ្យនៅជាសុខដូច្នេះ អស់
កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួក
ភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាល
ភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងភិក្ខុទាំង-
ឡាយ ឬថា ភិក្ខុទាំងឡាយនឹងប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ
អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដ*

ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

[៧១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ៧ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់កាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងនោះទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុមិនជាអ្នកមានការងារជាទីត្រេកអរ មិនត្រេកអរក្នុងការងារ មិនប្រកបរឿយៗនូវការៈជាអ្នកមានការងារជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីងមិនជាអ្នកមានការនិយាយ (តិរច្ឆានកថា) ជាទីត្រេកអរ មិនត្រេកអរក្នុងការនិយាយ (តិរច្ឆានកថា) មិនប្រកបរឿយៗ នូវការៈជាអ្នកមានការនិយាយ (តិរច្ឆានកថា) ជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីងមិនជាអ្នកមានសេចក្តីជេកលក់ជាទីត្រេកអរ មិនត្រេកអរក្នុងសេចក្តីជេកលក់ មិនប្រកបរឿយៗ នូវការៈជាអ្នកមានសេចក្តីជេកលក់ជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីងមិន

ជាអ្នកមានគ្នីគ្នាជាទីត្រេកអរ មិនត្រេកអរក្នុងការមានគ្នីគ្នា មិនប្រកបរឿយៗ នូវការៈជាអ្នកមានគ្នីគ្នាជាទីត្រេកអរ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីងមិនមានសេចក្តីប្រាថ្នាអាក្រក់ មិនលុះក្នុងអំណាចសេចក្តីប្រាថ្នាអាក្រក់ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីងមិនមានមិត្តអាក្រក់ មិនមានសម្ភាញ់អាក្រក់ មិនជាអ្នកងាកទៅរកបុគ្គលអាក្រក់ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីងមិនដល់នូវសេចក្តីបន្ធូរបន្ថយព្យាយាមក្នុងចន្លោះ ដោយការគ្រាស់ដឹងនូវគុណវិសេសត្រឹមតែជាន់ក្រោម អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នីងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

[๗๒] *ម្នាលភិក្ខុទាំងឡាយ តថាគតនីងសម្តែងអបរិហានិយធម៌ ๗*

ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់កាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្តីជឿ ។បេ។ មានចិត្តប្រកបដោយសេចក្តីខ្មាសខ្ពើមបាប ។ មានសេចក្តីខ្លាចបាប ។ ជាពហុស្សូត ។ ប្រារព្ធសេចក្តីព្យាយាម ។ ជាអ្នកមានស្មារតីខ្ជាប់ខ្ជួន ។ ជាអ្នកមានប្រាជ្ញាអស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះនឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

[๗๓] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ๗ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់កាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងចម្រើនសតិ-សម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹងគឺសេចក្តីរឭក) ។បេ។ ចម្រើនធម្មវិចយសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបញ្ញាជាគ្រឿងពិចា-

วณา) ฯ จម្រើនវីរិយសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺ ព្យាយាម) ฯ จម្រើនបីតិសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺ សេចក្តីឆ្អែតស្កប់ក្នុងធម៌) ฯ จម្រើនបស្សទ្ធិសម្ពោជ្ឈង្គ (ហេតុនៃធម៌ជា គ្រឿងត្រាស់ដឹង គឺសេចក្តីស្ងប់រម្ងាប់) ฯ จម្រើនសមាធិសម្ពោជ្ឈង្គ (ហេតុ នៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីតម្កល់ចិត្តមាំ) ฯจម្រើនឧបេក្ខាសម្ពោជ្ឈង្គ (ហេតុនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីព្រងើយក្នុងសុខ និងទុក្ខ) អស់ កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួក ភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ฯ ម្នាល ភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ๗ នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួក ភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ๗ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុ ទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិន មានឡើយ (អស់កាលត្រឹមណោះ) ฯ

[๗๔] *ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ๗ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើ ទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ฯ ពួកភិក្ខុទាំងនោះ ទទួល ព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ฯ ព្រះមាន ព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងចម្រើនអនិច្ច-សញ្ញា (សេចក្តីសម្គាល់ដែលកើតជាមួយនឹងអនិច្ចានុបស្សនា) ฯបេฯ จម្រើនអនត្តសញ្ញា (សេចក្តីសម្គាល់ដែលកើតជាមួយនឹងអនត្តានុបស្សនា) ฯ*

จម្រើនអសុភសញ្ញា (សេចក្តីសម្គាល់នូវអាការ ๓๒ ថាមិនស្អាត) ។ จម្រើនអាទីនវសញ្ញា (សេចក្តីសម្គាល់នូវកាយថា មានទោស) ។ จម្រើនបហានសញ្ញា (សេចក្តីសម្គាល់ក្នុងការលះនូវអកុសលវិតក្ក) ។ จម្រើនវិរាគសញ្ញា (សេចក្តីសម្គាល់ក្នុងព្រះនិព្វានដែលប្រាសចាកតម្រេក) ។ จម្រើននិរោធសញ្ញា (សេចក្តីសម្គាល់ក្នុងព្រះនិព្វានជាគ្រឿងរលត់ទុក្ខ) អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ๗ នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ๗ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

[๗๕] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ๖ ដទៃទៀត ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងតម្កល់កាយកម្ម ប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់

កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនីឯប្រុងតម្កល់វចីកម្ម ប្រកបដោយមេត្តា ។បេ។ ប្រុងតម្កល់មនោកម្មប្រកបដោយមេត្តាក្នុងសព្រហ្ម-ចារីទាំងឡាយ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើលាភទាំងឡាយណា ដែលប្រកបដោយធម៌ ដែលបានមកដោយធម៌ដោយហោចទៅ សូម្បីវត្ថុដែលគេដាក់ចុះក្នុងបាត្រ ពួកភិក្ខុមិនមានការបរិភោគដោយមិនបាច់ចែករំលែកដោយលាភទាំងឡាយ មានសភាពយ៉ាងនោះ គឺជាអ្នកមានការបរិភោគជាសាធារណៈ ជាមួយនឹងសព្រហ្មចារីទាំងឡាយដែលមានសីល អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ សីលទាំងឡាយណាមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ជាសីលរបស់មនុស្សអ្នកជា (មិនជាខ្ញុំតណ្ហា) អ្នកប្រាជ្ញតែងសរសើរ ជាសីលមិនបានជ្រោកជ្រាកដោយតណ្ហា និងទិដ្ឋិ ជាសីលញុំាងសមាធិឲ្យប្រព្រឹត្តទៅបាន ពួកភិក្ខុជាអ្នកមានសីលស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយមានសភាពយ៉ាងនោះ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិណាដែលឥត

ទោស ជាទីស្រោចស្រង់សត្វប្រព្រឹត្តទៅ ដើម្បីអស់សេចក្តីទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ពួកភិក្ខុជាអ្នកមានទិដ្ឋិស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិមានសភាពយ៉ាងនោះ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៦ នេះ នឹងឋិតនៅក្នុងពួកភិក្ខុ ឬពួកភិក្ខុប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៦ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។ កាលដែលព្រះមានព្រះភាគគង់លើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះនោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើនដល់ភិក្ខុទាំងឡាយ យ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីល រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញា រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃពិត គឺ កាមាសវៈ (ធម៌ជាគ្រឿងត្រាំ គឺកាម) ភវាសវៈ (ធម៌ជាគ្រឿងត្រាំ គឺភព) អវិជ្ជាសវៈ (ធម៌ជាគ្រឿងត្រាំ គឺអវិជ្ជា) ។

[๗๖] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងក្រុងរាជគ្រឹះ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទ មានអាយុថា ម្នាលអានន្ទ មកយើងនឹងទៅកាន់ឱទ្យានឈ្មោះអម្ពលដ្ឋិកា ។ ព្រះអានន្ទមាន

อายุ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់អម្ពលដ្ឋិកាឧទ្យាន មួយអន្ទើដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់ក្នុងរាជាគារកៈ (ព្រះរាជដំណាក់) នៅនាអម្ពលដ្ឋិកាឧទ្យាននោះ ។ កាលព្រះមានព្រះភាគគង់ក្នុងរាជាគារកៈក្នុងអម្ពលដ្ឋិកាឧទ្យាននោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីល រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញា រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃពិត គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[๗๗] លុះព្រះមានព្រះភាគ ទ្រង់គង់ក្នុងអម្ពលដ្ឋិកាឧទ្យាន តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ស្រុកនាឡន្ទា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់ស្រុកនាឡន្ទា មួយអន្ទើដោយភិក្ខុសង្ឃជាច្រើន ។ ព្រះមានព្រះភាគទ្រង់គង់ក្នុងបាវារិកម្ពវន ទៀបក្រុងនាឡន្ទានោះ ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ ព្រះសារីបុត្តមានអាយុ លុះអង្គុយនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះ

មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគ ដោយហេតុយ៉ាងនេះថា សមណៈ ឬព្រាហ្មណ៍ដទៃជាអ្នកត្រាស់ដឹងក្រៃលែងជាងព្រះមានព្រះភាគ ក្នុងសម្ពោធិញ្ញាណ មិនមានក្នុងអតីតកាល មិនមានក្នុងអនាគតកាល ឬមិនមានក្នុងបច្ចុប្បន្នកាលនេះទេ ។ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលថា ម្នាលសារីបុត្ត អាសភិវាចាដែលអ្នកនិយាយនេះលើសលុបពេក សីហនាទដែលអ្នកប្រកាន់ហើយ បន្ទឺឡើងហើយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគដោយហេតុយ៉ាងនេះថា សមណៈ ឬព្រាហ្មណ៍ដទៃ ជាអ្នកត្រាស់ដឹងក្រៃលែងជាងព្រះមានព្រះភាគ ក្នុងសម្ពោធិញ្ញាណ មិនមានក្នុងអតីតកាល មិនមានក្នុងអនាគតកាល ឬមិនមានក្នុងបច្ចុប្បន្នកាលនេះទេ ដូច្នេះជាសម្តីដោយខ្លែក ម្នាលសារីបុត្ត ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលមានក្នុងអតីតកាល ព្រះមានព្រះភាគទាំងអស់នោះ អ្នកបានកំណត់ដឹងច្បាស់នូវចិត្តដោយចិត្តរបស់ខ្លួនថា ព្រះមានព្រះភាគទាំងនោះ មានសីលយ៉ាងនេះដូច្នេះផង មានធម៌យ៉ាងនេះ ។ មានបញ្ញាយ៉ាងនេះ ។ មានធម៌ជាគ្រឿងនៅយ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ មានចិត្តរួចស្រឡះហើយចាកអាសវៈយ៉ាងនេះ ដូច្នេះដែរឬ ។ ព្រះសារីបុត្តមានអាយុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះខ្ញុំព្រះអង្គកំណត់ដឹងមិនបានទេ ។ ម្នាលសារីបុត្ត ព្រះមានព្រះភាគទាំង-ឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលនឹងមានក្នុងអនាគតកាល ព្រះមានព្រះភាគទាំងអស់នោះ អ្នកបានកំណត់ដឹងច្បាស់នូវចិត្ត ដោយចិត្តរបស់ខ្លួនថា

ព្រះមានព្រះភាគទាំងនោះ និងមានសីលយ៉ាងនេះដូច្នេះផង និងមានធម៌យ៉ាងនេះ ។ និងមានបញ្ញាយ៉ាងនេះ ។ និងមានធម៌ជាគ្រឿងនៅយ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ និងមានចិត្តរួចស្រឡះចាកអាសវៈយ៉ាងនេះ ដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះខ្ញុំព្រះអង្គកំណត់ដឹងមិនបានទេ ។ ម្នាលសារីបុត្ត តថាគតជាអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ អ្នកបានកំណត់ដឹងច្បាស់នូវចិត្តដោយចិត្តរបស់ខ្លួនថា ព្រះមានព្រះភាគមានសីលយ៉ាងនេះដូច្នេះផង មានធម៌យ៉ាងនេះ ។ មានបញ្ញាយ៉ាងនេះ ។ មានធម៌ជាគ្រឿងនៅយ៉ាងនេះ ។ ព្រះមានព្រះភាគមានចិត្តរួចស្រឡះហើយចាកអាសវៈយ៉ាងនេះដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះខ្ញុំព្រះអង្គកំណត់ដឹងមិនបានទេ ។ ម្នាលសារីបុត្ត បើអ្នកគ្មានញាណជាគ្រឿងកំណត់ដឹងចិត្តរបស់ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលមានក្នុងអតីតកាល អនាគតកាល បច្ចុប្បន្នកាលទាំងនុ៎ះទេ ម្នាលសារីបុត្ត ម្តេចទៀបក៏អ្នកពោលអាសភិវាចាដ៏លើសលុបនេះក្នុងកាលឥឡូវនេះ អ្នកប្រកាន់បន្ទឹឡើងហើយនូវសីហនាទដោយមាំមួនថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគដោយហេតុយ៉ាងនេះថា សមណៈ ឬព្រាហ្មណ៍ដទៃ ជាអ្នកត្រាស់ដឹងក្រៃលែងជាងព្រះមានព្រះភាគ ក្នុងសម្ពោធិញ្ញាណ មិនមានក្នុងអតីតកាល មិនមានក្នុងអនាគតកាល ឬមិនមានក្នុងបច្ចុប្បន្នកាលនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្មានញាណ ជាគ្រឿងកំណត់ដឹងនូវចិត្តរបស់ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលមានក្នុងអតីតកាល អនាគតកាល និងបច្ចុប្បន្នកាលទេ តែ

ថា ខ្ញុំព្រះអង្គដឹងច្បាស់តាមទំនងធម៌ បពិត្រព្រះអង្គដ៏ចម្រើន ប្រៀបដូចទីក្រុង ដែលតាំងនៅក្នុងទីបំផុតដែនរបស់ស្តេច ដែលមានទ្វារមាំ មានកំផែង និង ខ្ញាងទ្វារដ៏មាំមួន មានទ្វារតែមួយ ក្នុងទីក្រុងនោះ មានអ្នកចាំយាមទ្វារ ជា បណ្ឌិតឈ្លាសវៃ មានប្រជ្ញា ឃាត់ហាមពួកមនុស្សដែលមិនស្គាល់ ឲ្យតែ ពួកមនុស្សដែលស្គាល់ចូលទៅ នាយទ្វារនោះ ក៏ដើរទៅតាមផ្លូវដើម្បីពិនិត្យ មើលជុំវិញទីក្រុងនោះ ក៏មិនឃើញនូវទីកំផែង ឬចន្ទោះកំផែង ដោយហោច ទៅ សូម្បីតែប្រហោងល្មមសត្វធ្នាចេញបាន ក៏មិនឃើញឡើយ នាយទ្វារ នោះ ក៏មានសេចក្តីយល់យ៉ាងនេះថា ពួកសត្វណានីមួយដែលមានកាយធំ ចូលមកកាន់ទីក្រុងនេះក្តី ចេញទៅក្តី ពួកសត្វទាំងអស់នោះ គង់ចូល ឬ ចេញតាមទ្វារនេះ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់ តាមទំនងធម៌ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលមានក្នុងអតីតកាល ព្រះមាន ព្រះភាគទាំងអស់នោះ បានលះនីវរណធម៌ទាំង ៥ ដែលជាឧបក្កិលេស របស់ចិត្ត ជាធម៌ធ្វើប្រជ្ញាឲ្យថយកម្លាំង ទ្រង់មានព្រះហឫទ័យតម្កល់មាំល្អ ក្នុងសតិប្បដ្ឋានទាំង ៤ ចម្រើនពោជ្ឈង្គទាំង ៧ ដោយពិត ទ្រង់ត្រាស់ដឹង ហើយនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះ មានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលនឹងមានក្នុងអនា-គតកាល ព្រះមានព្រះភាគទាំងអស់នោះ នឹងលះនូវនីវរណធម៌ទាំង ៥ ដែល ជាឧបក្កិលេសរបស់ចិត្ត ជាធម៌ធ្វើប្រជ្ញាឲ្យថយកម្លាំង មានព្រះហឫទ័យ

តម្កល់មាំល្អក្នុងសតិប្បដ្ឋានទាំង ๔ ចម្រើនពោជ្ឈង្គទាំង ๗ ដោយពិត ហើយនឹងបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធក្នុងបច្ចុប្បន្នកាលនេះ ក៏លះនីវរណធម៌ទាំង ๕ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម៌ធ្វើប្រាជ្ញាឲ្យថយកម្លាំង ទ្រង់មានព្រះហឫទ័យតម្កល់មាំល្អ ក្នុងសតិប្បដ្ឋានទាំង ๔ ចម្រើនពោជ្ឈង្គទាំង ๗ ដោយពិត ហើយត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។ ព្រះមានព្រះភាគគង់ក្នុងបាវាទិកម្ពវ័ន ទៀបស្រុកនាឡន្ទានោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើនដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ តែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយពិត គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[๗๘] *គ្រាដែលព្រះមានព្រះភាគគង់នៅក្នុងស្រុកនាឡន្ទា តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ជាដលិគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគស្តេចទៅដល់ជាដលិគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ ពួកឧបាសកនៅក្នុងជាដលិគ្រាម បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់ស្តេចមកដល់ជាដលិគ្រាមហើយ ។ ទើបពួកឧបាសកនៅក្នុងជាដលិគ្រាមនាំគ្នាចូលទៅ*

គាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលផ្ទះសំណាក់របស់យើងខ្ញុំព្រះអង្គទាំង-ឡាយ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ ឯពួកឧបាសកនៅក្នុងបាដលិគ្រាមបានដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចូលទៅកាន់ផ្ទះសំណាក់ លុះចូលទៅដល់ហើយ ក៏ក្រាលផ្ទះសំណាក់ឲ្យមានកម្រាលក្រាលសព្វកន្លែង ហើយតាក់តែងអាសនៈ តម្កល់ក្អមទឹក រៀបចំប្រទីបប្រេង រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏ឋិតនៅក្នុងទីសមគួរ ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម លុះឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ផ្ទះសំណាក់ យើងខ្ញុំព្រះអង្គបានក្រាលកម្រាលសព្វកន្លែងហើយ អាសនៈទាំងឡាយ យើងខ្ញុំព្រះអង្គបានតាក់តែងហើយ ក្អមទឹកយើងខ្ញុំព្រះអង្គបានតម្កល់ទុកហើយ ប្រទីបប្រេងយើងខ្ញុំព្រះអង្គបានរៀបចំហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះ ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ស្តេចចូលទៅកាន់ផ្ទះសំណាក់ ព្រមដោយភិក្ខុសង្ឃ លុះស្តេចទៅដល់ហើយ ទ្រង់ជម្រះព្រះបាទា ហើយស្តេចចូលទៅកាន់ផ្ទះ

สំណាក់ ទ្រង់គង់បែរព្រះភក្ត្រទៅទិសខាងកើត ផ្អែកនឹងសសរកណ្តាល ។ ឯភិក្ខុសង្ឃក៏លាងបាទារាល់រូប ចូលទៅកាន់ផ្ទះសំណាក់ ហើយអង្គុយបែរមុខទៅទិសខាងកើត អែបនឹងជញ្ជាំងខាងលិច គាល់ព្រះមានព្រះភាគ ។ ពួកឧបាសកនៅក្នុងបាដលិគ្រាម បានលាងជើងរួចហើយ ចូលទៅកាន់ផ្ទះសំណាក់ អង្គុយបែរមុខទៅទិសខាងលិច អែបនឹងជញ្ជាំងខាងកើត គាល់ព្រះមានព្រះភាគដែរ ។

[๗๙] លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងពួកឧបាសកអ្នកបាដលិគ្រាមថា ម្នាលគហបតិទាំងឡាយ ទោសនៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិនេះមាន ៥ ប្រការ ។ ទោសទាំង ៥ ប្រការនោះ តើដូចម្តេច ។ ម្នាលគហបតិទាំងឡាយ បុគ្គលទ្រុស្តសីល វិបត្តិចាកសីលក្នុងលោកនេះ តែងដល់នូវសេចក្តីវិនាសនៃភោគៈដ៏ធំ មានសេចក្តីប្រមាទជាហេតុ នេះជាទោសទី ๑ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតិទាំងឡាយ មួយទៀត កិត្តិសព្ទដ៏អាក្រក់នៃបុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងផ្សាយទៅសព្វទិស នេះជាទោសទី ๒ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតិទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ទោះចូលទៅរកបរិសទ្យណាៗ គឺខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ជាអ្នកមិនក្លៀវក្លា ចូលទៅទាំងអៀនអន់ នេះជាទោសទី ๓ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតិទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ជាបុគ្គលវង្វេងធ្វើមរណកាល នេះជាទោស

ទី ៤ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតិទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល លុះបែកធ្លាយរាងកាយទៅ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក នេះជាទោសទី ៥ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតិទាំងឡាយ ទោសនៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិមាន ៥ ប្រការនេះឯង ។

[៨០] *ម្នាលគហបតិទាំងឡាយ អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទានេះ មាន ៥ ប្រការ ។ អានិសង្ស ៥ ប្រការនោះ តើដូចម្តេចខ្លះ ។ ម្នាលគហបតិទាំងឡាយ បុគ្គលមានសីល ដល់ព្រមដោយសីល ក្នុងលោកនេះ រមែងបានគំនរទ្រព្យដ៏ធំ ដែលមានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សទី ១ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតិទាំងឡាយ មួយទៀត កិត្តិសព្ទដ៏ពីពោះរបស់បុគ្គលមានសីល ដល់ព្រមដោយសីល តែងផ្សាយទៅសព្វទិស នេះជាអានិសង្សទី ២ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតិទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ទោះចូលទៅរកបរិស័ទណាៗ គឺខត្តិយបរិសទ្បក្តី ព្រាហ្មណបរិសទ្បក្តី គហបតិបរិសទ្បក្តី សមណបរិសទ្បក្តី ជាបុគ្គលមានសេចក្តីក្លៀវក្លា ចូលទៅដោយការមិនអៀនអន់ នេះជាអានិសង្សទី ៣ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតិទាំងឡាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ជាបុគ្គលមិនវង្វេងធ្វើមរណកាល នេះជាអានិសង្សទី ៤ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតិទាំង-*

ទ្បាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល លុះបែកធ្លាយ
រាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតក្នុងលោក គឺមនុស្ស សុគតិ
និងឋានសួគ៌ នេះជាអានិសង្សទី ៥ នៃបុគ្គលមានសីល នៃសីលសម្បទា ។
ម្នាលគហតីទាំងឡាយ អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទា មាន
៥ ប្រការនេះឯង ។

[៨១] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ញុាំងពួកឧបាសកអ្នកបាដលិ-
គ្រាម ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យក្លៀវក្លា ឲ្យរីករាយ ដោយធម្មីកថា
អស់រាត្រីជាច្រើន ហើយទ្រង់បញ្ជូនទៅដោយព្រះពុទ្ធដីកាថា ម្នាលគហតិ
ទាំងឡាយ រាត្រីអស់ហើយ ចូរអ្នកទាំងឡាយសម្គាល់នូវកាលដ៏សមគួរក្នុង
កាលឥឡូវនេះចុះ ។ ពួកឧបាសកអ្នកបាដលិគ្រាម ទទួលព្រះបន្ទូលនៃព្រះ
មានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក្រោកអំពីអាសនៈ
ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។ កាលដែល
ពួកឧបាសកអ្នកបាដលិគ្រាមចេញទៅមិនយូរប៉ុន្មាន ព្រះមានព្រះភាគ ក៏ទ្រង់
ស្តេចចូលទៅកាន់ផ្ទះស្ងាត់ ។

[៨២] សម័យនោះឯង សុនីធៈ និងវស្សការព្រាហ្មណ៍ ជាមហា-
មាត្យ ក្នុងដែនមគធៈ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ដើម្បីការពារពួក
ស្តេចក្នុងដែនវជ្ជី ។ សម័យនោះឯង ទេវតាច្រើនពួកចំនួនមួយពាន់ៗ គន់
មើលទីដីសង់ផ្ទះក្នុងបាដលិគ្រាម ។ ពួកទេវតាដែលមានសក្តិធំ គន់មើលទីដី
សង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យទាំងឡាយ ដែល

មានសក្តិធំ ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ពួកទេវតាដែលមានសក្តិយ៉ាងកណ្តាល គន់មើលទីជ័សង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេចនិងរាជមហាមាត្យទាំងឡាយ ដែលមានសក្តិយ៉ាងកណ្តាល ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ពួកទេវតាដែលមានសក្តិទាប គន់មើលទីជ័សង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យទាំងឡាយដែលមានសក្តិទាប ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ។ ព្រះមានព្រះភាគបានទតឃើញពួកទេវតាទាំងនោះ ចំនួនមួយពាន់ៗ កំពុងគន់មើលទីជ័សង់ផ្ទះ ក្នុងបាដលិគ្រាមដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្ទងបង់នូវចក្ខុជារបស់មនុស្សសាមញ្ញ ។ ទើបព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នកណាហ្ន៎ នាំគ្នាសាងក្រុងក្នុងបាដលិគ្រាម ។ ព្រះអានន្ទមានអាយុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សុនីធៈ និងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ នាំគ្នាសាងក្រុងក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សក្កទេវរាជបានប្រឹក្សាជាមួយនឹងពួកទេវតាដែលឋិតនៅក្នុងឋានតាវត្តិង្ស យ៉ាងណាមិញ ម្នាលអានន្ទ សុនីធៈ និងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ នាំគ្នាសាងក្រុងក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចវជ្ជី ក៏ដូច្នោះដែរ ម្នាលអានន្ទ ក្នុងទីនេះតថាគតបានឃើញពួកទេវតាជាច្រើនទាំងពាន់ៗ កំពុងគន់មើលទីជ័សង់ផ្ទះ ក្នុងបាដលិគ្រាមដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្ទងបង់នូវចក្ខុជារបស់មនុស្សសាមញ្ញ ពួកទេវតា

ដែលមានសក្តិធំ គន់មើលទីជីសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យទាំងឡាយដែលមានសក្តិធំ ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ពួកទេវតាដែលមានសក្តិយ៉ាងកណ្តាល គន់មើលទីជីសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យទាំងឡាយ ដែលមានសក្តិយ៉ាងកណ្តាល ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ពួកទេវតាដែលមានសក្តិទាប គន់មើលទីជីសង់ផ្ទះក្នុងប្រទេសណា ចិត្តរបស់ស្តេច និងរាជមហាមាត្យទាំងឡាយដែលមានសក្តិទាប ក៏ឱនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ម្នាលអានន្ទ ទីប្រជុំនៃមនុស្សជាអរិយៈមាននៅកំណាត់ត្រើមណា ផ្លូវឈ្មួញមាននៅកំណាត់ត្រើមណា នគរនេះនឹងបានជានគរប្តូរថ្លើង មានឈ្មោះថា ក្រុងបាដលិបុត្ត ហាក់ជាកន្លែងសម្រាប់ស្រោយបង្ហូចទ្រព្យកំណាត់ត្រើមណោះ ម្នាលអានន្ទ តែក្រុងបាដលិបុត្រនឹងមានសេចក្តីអន្តរាយ ៣ យ៉ាង គឺអន្តរាយដោយភ្លើង ១ ដោយទឹក ១ ដោយការបែកគ្នា ១ ។

[៨៣] គ្រានោះ សុនីធៈ និងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរវីរកាយ និងពាក្យដែលគួរឮរួចហើយ ក៏បានឋិតនៅក្នុងទីសមគួរ ។ សុនីធៈ និងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ លុះឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះគោតមដ៏ចម្រើន ព្រមដោយភិក្ខុសង្ឃ ទទួលភត្តរបស់យើង

ខ្ញុំទាំងឡាយ ដើម្បីធាន់ក្នុងថ្ងៃនេះ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លុះសុនីធៈនិងវស្សការព្រាហ្មណ៍ជាមហាមាត្យ ក្នុងដែនមគធៈ ដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួន លុះចូលទៅដល់ហើយ បានតាក់តែងខាទនីយភោជនីយាហារដ៏ផ្ងៃតផ្ងង់ក្នុងលំនៅរបស់ខ្លួន រួចហើយទើបឲ្យគេក្រាបទូលភត្តកាលដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់លំនៅរបស់សុនីធៈ និងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលបម្រុង ។ ទើបសុនីធៈ និងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារដ៏ផ្ងៃតផ្ងង់ដោយដៃខ្លួនឯង ត្រាតែភិក្ខុសង្ឃហាមឃាត់ ។ លំដាប់នោះ សុនីធៈ និងវស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ (កំណត់ដឹងថា) ព្រះមានព្រះភាគទ្រង់សោយស្រេចហើយ ដាក់ព្រះហស្តចុះអំពីបាត្រហើយ ក៏កាន់យកអាសនៈទាបមួយ ហើយអង្គុយក្នុងទីសមគួរ ។ លុះសុនីធៈ និងវស្សការព្រាហ្មណ៍ជាមហាមាត្យ ក្នុងដែនមគធៈ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់អនុមោទនាដោយគាថាទាំងឡាយនេះថា

[៨៤] *បុគ្គលជាបណ្ឌិត សម្រេចទីនៅក្នុងប្រទេសណា*

បានញុំាងបុគ្គលអ្នកមានសីលទាំងឡាយ អ្នកសង្រួម អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ឲ្យបរិភោគភោជនាហារ ក្នុងប្រទេសនុ៎ះ ។ បានឧទ្ទិសទក្ខិណាទាន ដល់ពួកទេវតាដែលឋិតនៅក្នុងប្រទេសនោះ ពួកទេវតាទាំងនោះ ដែលបណ្ឌិតបានបូជាហើយ ក៏តែងបូជាតបវិញ ដែលបណ្ឌិតរាប់អានហើយ ក៏តែងរាប់អានបណ្ឌិតនោះវិញ ។ តែងអនុគ្រោះបណ្ឌិតនោះ ព្រោះទក្ខិណានុប្បទាននោះ ដូចជាមាតាអនុគ្រោះកូន ដែលកើតអំពីទ្រូង បុរសដែលទេវតាអនុគ្រោះហើយ រមែងជួបប្រទះនូវសេចក្តីចម្រើនសព្វកាល ។

[៨៥] *លុះព្រះមានព្រះភាគទ្រង់អនុមោទនាដោយគាថាទាំងនេះដល់សុនីធៈ និងវស្សការព្រាហ្មណ៍ ដែលជាមហាមាត្យ ក្នុងដែនមគធៈហើយ ទ្រង់ក្រោកអំពីអាសនៈចេញទៅ ។ សម័យនោះឯង សុនីធៈ និងវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ បានដើរតាមព្រះមានព្រះភាគអំពីខាងក្រោយៗ ដោយតាំងចិត្តថា ថ្ងៃនេះ ព្រះសមណគោតមទ្រង់ស្តេចចេញតាមទ្វារណា ទ្វារនោះ នឹងបានឈ្មោះថា គោតមទ្វារ ទ្រង់ស្តេចឆ្លងទន្លេគង្គាត្រង់កំពង់ណា កំពង់នោះនឹងបានឈ្មោះថា គោតមតិត្ថៈ ។ ព្រះមានព្រះភាគទ្រង់ស្តេចចេញតាមទ្វារណា ទ្វារនោះក៏បានឈ្មោះថា គោតមទ្វារ ចាប់ដើមតាំងអំពីនោះមក ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្តេចចូលទៅត្រង់ទន្លេ*

គង្គានោះ ។ សម័យនោះឯង ទន្លេគង្គាកំពុងពេញប្រៀបល្មមសត្វក្អែកទំលើមាត់ច្រាំងឱនផឹកទឹកបាន ។ មនុស្សទាំងឡាយដែលច្រូច្ចានឹងឆ្លងអំពីត្រើយម្ខាង ទៅកាន់ត្រើយម្ខាង ពួកខ្លះក៏សែ្វងរកទូក ពួកខ្លះក៏សែ្វងរកផៃ ពួកខ្លះក៏ចងក្បួន ។ លំដាប់នោះ ព្រះមានព្រះភាគស្រាប់តែបាត់ព្រះអង្គ អំពីត្រើយទន្លេគង្គាខាងអាយទៅប្រាកដព្រះអង្គក្នុងត្រើយខាងនាយ ព្រមទាំងភិក្ខុសង្ឃជួចជាបុរសដែលមានកម្លាំងលាកំភួនដៃដែលបត់ហើយ ឬបត់កំភួនដៃដែលលាហើយ ។ ព្រះមានព្រះភាគទ្រង់ទតឃើញមនុស្សទាំងនោះ ពួកខ្លះកំពុងសែ្វងរកទូក ពួកខ្លះកំពុង សែ្វងរកផៃ ពួកខ្លះកំពុងចងក្បួន បំណងនឹងឆ្លងអំពីត្រើយម្ខាងទៅត្រើយម្ខាង ។ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវហេតុនុ៎ះហើយ ក៏ទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

> *ជនទាំងឡាយណា ឆ្លងទន្លេ និងស្ទឹង គឺតណ្ហាដែលជ្រាលជ្រៅធំទូលាយបាន ជនទាំងឡាយនោះ រមែងធ្វើស្ពាន គឺអរិយមគ្គ លះបង់ទីទំនាបដែលពេញដោយទឹក ឆ្លងផុតទៅបាន ចំណែកជនឆ្កួតាលុះតែចងក្បួន ទើបឆ្លងទៅបាន ឯពួកជនជាអ្នកប្រាជ្ញ (មិនបាច់ក្បួន) ក៏ឆ្លងទៅបាន ។*

ពុទ្ធកាណាវរទី ១ ចប់

[៨៦] *លំដាប់នោះ ព្រះមានព្រះភាគទ្រង់គ្រាស់នឹងព្រះអានន្ទមាន*

អាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់កោដិគ្រាម ។ ព្រះអានន្ទមាន អាយុទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ស្តេចទៅដល់កោដិគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់ក្នុងកោដិគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសង្សារវដ្ត) អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ចទាំង ៤ ។ អរិយសច្ចទាំង ៤ នោះ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខសមុទយអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខនិរោធ-អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះ នូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះ

ហើយ ទុក្ខសមុទយអរិយសច្ចដែលបុគ្គលបានត្រាស់ដឹង បានចាក់ថ្កុះហើយ ទុក្ខនិរោធអរិយសច្ចដែលបុគ្គលបានត្រាស់ដឹង បានចាក់ថ្កុះហើយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលបុគ្គលបានត្រាស់ដឹង បានចាក់ថ្កុះហើយ ភវតណ្ហា គឺសេចក្តីប្រាថ្នាក្នុងភពក៏សូន្យទៅ ខ្សែ គឺតណ្ហា ដែលអាចនាំសត្វអំពីភពមួយទៅភពមួយ ក៏អស់ទៅ ភពថ្មីក្នុងកាលឥឡូវនេះ ក៏មិនមានទៀយ ។ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះហើយ ព្រះសុគតលុះត្រាស់ពាក្យនេះហើយ ព្រះសាស្តាទ្រង់ត្រាស់ពាក្យជួរច្នេះដទៃអំពីពាក្យនោះថា

[៨៧] *ការត្រាច់រង្គាត់ទៅអស់កាលជាអង្វែង ក្នុងជាតិនោះៗ ឯង ក៏ព្រោះតែមិនបានឃើញនូវអរិយសច្ចទាំង ៤ តាមពិត ។ ឯអរិយសច្ចទាំង ៤ នោះ បើបុគ្គលបានឃើញហើយ ខ្សែ គឺតណ្ហាដែលអាចនាំសត្វអំពីភពមួយទៅភពមួយ ក៏ជាច់ហើយ ឫសគល់របស់ទុក្ខ ក៏ពុករលួយហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះ មិនមានទៀយ ។*

[៨៨] *បានឮថា កាលព្រះមានព្រះភាគគង់នៅក្នុងកោដិគ្រាមនោះ ឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលជួរច្នេះ សមាធិជួរច្នេះ បញ្ញាជួរច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែង*

រួចស្រឡះចាកអាសវៈទាំងឡាយដោយប្រពៃ គឺកាមាសវៈ ភវាសវៈ អវិជ្ជា-សវៈ ។

[๘๙] *លុះព្រះមានព្រះភាគទ្រង់គង់នៅក្នុងកោដិគ្រាម តាមសមគួរជល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់នាទិកគ្រាម ។ ព្រះអានន្ទមានអាយុទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ស្តេចទៅជល់នាទិកគ្រាមនោះ ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងផ្ទះសំណាក់ដែលធ្វើដោយឥដ្ឋ ក្នុងនាទិកគ្រាមនោះ ។ លំដាប់នោះ ព្រះអានន្ទមានអាយុចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅជល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះអានន្ទមានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះសាឡ្ហៈ ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់សាឡ្ហភិក្ខុនោះដូចម្តេច បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីឈ្មោះនន្ទា ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ភិក្ខុនីនោះដូចម្តេច បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះសុទត្ត ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសកនោះដូចម្តេច បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាឈ្មោះសុជាតា ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសិកានោះដូចម្តេច បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះកកុធៈ ធ្វើមរណកាលក្នុង*

នាទិកគ្រាម គតិរបស់ឧបាសកនោះដូចម្តេច បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះការឡិម្ភៈ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះនិកដៈ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះកដិស្សហៈ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះតុដ្ឋៈ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះសន្តុដ្ឋៈ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះភដៈ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកឈ្មោះសុភដៈ ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសកនោះដូចម្តេច បរលោកដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ សាឡ្ហកិកុបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ក្នុងបច្ចុប្បន្ន ម្នាលអានន្ទ នន្ទាកិកុនី ជាឱបបាតិកសត្វបរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម (អនាគាមី) ម្នាលអានន្ទ សុទត្តឧបាសក ជាសកទាគាមី ត្រឡប់មកកាន់លោកនេះម្តងទៀត នឹងធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដោយមានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ម្នាលអានន្ទ សុជាតាឧបាសិកា ជាសោតាបន្នបុគ្គល ជាបុគ្គលលែងធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងទៅខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ម្នាលអានន្ទ កកុធឧបាសក ជាឱបបាតិកសត្វ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែង

วิลត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជន: ๕ ជាចំណែកខាងក្រោម ម្នាលអានន្ទ ការឡិម្ពឧបាសក ฯបេฯ ម្នាលអានន្ទ និកដឧបាសក ฯ ម្នាលអានន្ទ កដិស្សហឧបាសក ฯ ម្នាលអានន្ទ តុដ្ឋឧបាសក ฯ ម្នាលអានន្ទ សន្តុដ្ឋឧបាសក ฯ ម្នាលអានន្ទ ភជឧបាសក ฯ ម្នាលអានន្ទ សុភជ-ឧបាសក ជាឱបបាតិកសត្វ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជន: ๕ ជាចំណែកខាងក្រោម ម្នាលអានន្ទ ពួកឧបាសកជាង ๕๐ នាក់ ដែលធ្វើមរណកាលក្នុងនាទិកគ្រាម សុទ្ធតែជាឱបបាតិកសត្វ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជន: ๕ ជាចំណែកខាងក្រោម ម្នាលអានន្ទ ពួកឧបាសក ๙๖ នាក់ ដែលធ្វើមរណកាលក្នុងនាទិកគ្រាម សុទ្ធតែជាសកទាគាមី ត្រឡប់មកកាន់លោកនេះម្តងទៀត នឹងធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជន: ๓ មានរាគៈ ទោសៈ មោហៈស្រាលស្តើង ម្នាលអានន្ទ ពួកឧបាសក ๕๑๐ នាក់ ដែលធ្វើមរណកាលក្នុងនាទិកគ្រាម សុទ្ធតែជាសោតាបន្នបុគ្គល ជាបុគ្គលលែងធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ព្រោះអស់ទៅនៃសំយោជន: ๓ ម្នាលអានន្ទ សត្វដែលជាមនុស្សធ្វើមរណកាលដោយហេតុណា ហេតុនោះ មិនជាអស្ចារ្យទេ ព្រោះកាលបើមនុស្សនោះៗធ្វើមរណកាលហើយ អ្នកទាំងឡាយមុខជានឹងមករកតថាគត ហើយសួរនូវដំណើរនុ៎ះ ម្នាលអានន្ទ នេះជាសេចក្តីលំបាកដល់តថាគតណាស់ ម្នាលអានន្ទ

ព្រោះហេតុនោះ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើប្រាថ្នា នឹងព្យាករ ក៏គប្បីព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បេត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គលលែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅក្នុងខាងមុខ ដូច្នេះ តថាគតនឹងសម្តែងធម្មបរិយាយនោះ ឈ្មោះធម្មាទាសៈ (ធម៌ដូចកញ្ចក់ដុះ) ម្នាលអានន្ទ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើត្រូវការនឹងព្យាករ ក៏គប្បីព្យាករខ្លួនឯងដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បេត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅក្នុងខាងមុខដូច្នេះ ចុះធម្មបរិយាយឈ្មោះធម្មាទាសៈនោះ តើដូចម្តេច ម្នាលអានន្ទ អរិយសាវ័កក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង ដោយប្រពៃ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់ដល់នូវសុន្ទរស្ថាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់កំពង់ទៀតដូច្នេះ អរិយសាវ័កប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយប្រពៃ ជាធម៌ដែល

អរិយបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរនឹងហៅថា អ្នកចូរចូលមកមើលដូច្នេះបាន ជាធម៌ដែលអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានខគ្ឃដិ-តញ្ញូបុគ្គលជាដើម គប្បីដឹងដោយជាក់ច្បាស់ក្នុងចិត្តនៃខ្លួនដូច្នេះ អរិយសាវ័ក ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះសង្ឃថា ពួកនៃសាវ័ករបស់ព្រះមានព្រះភាគប្រតិបត្តិដោយប្រពៃ ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយត្រង់ ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកនៃសាវ័ករបស់ព្រះមានព្រះភាគប្រតិបត្តិដោយសមគួរ ព្រះសង្ឃទាំងអស់នោះ បើរាប់ជាគូនៃបុរសមាន ៤ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួកនៃសាវ័ករបស់ព្រះមានព្រះភាគនុ៎ះ លោកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា លោកគួរទទួលនូវអាគន្តុកទាន លោកគួរទទួលនូវទក្ខិណាទាន ជាបុគ្គលដែលសត្វលោកគប្បីធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកដូច្នេះ អរិយសាវ័កប្រកបហើយ ដោយសីលជាទីគាប់ចិត្តរបស់ព្រះអរិយៈ ជាសីលមិនជាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរបស់មនុស្សអ្នកជា ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលមិនជ្រោកជ្រាកដោយតណ្ហា និងទិដ្ឋិ ជាសីលញុំងសមាធិឲ្យប្រព្រឹត្តទៅបាន ម្នាលអានន្ទ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើត្រូវការនឹងព្យាករ ក៏គប្បីព្យាករខ្លួនឯងដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បេត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្ន-

បុគ្គល លែងធ្លាក់ចុះហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខ ដូច្នេះ ធម្មបរិយាយនេះឯង ហៅថា ធម្មទាសៈ ។ បានឮថា ព្រះមានព្រះភាគ គង់ក្នុងផ្ទះសំណាក់ធ្វើដោយឥដ្ឋ ក្នុងនាទិកគ្រាមនោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយដោយប្រពៃ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[๙๐] លុះព្រះមានព្រះភាគទ្រង់គង់នៅក្នុងនាទិកគ្រាម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងវេសាលី ។ ព្រះអានន្ទមានអាយុទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ស្តេចទៅដល់ក្រុងវេសាលី ព្រមដោយភិក្ខុសង្ឃជាច្រើនរូប ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់ក្នុងអម្ពបាលិវន ទៀបក្រុងវេសាលីនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានសតិ និងសម្បជញ្ញៈ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុមានសតិនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាកាយក្នុងកាយជាប្រក្រតី ជាអ្នកមានព្យាយាមជាគ្រឿងដុតកម្តៅកិលេសដ៏ងខ្ជួន មានសតិ កម្ចាត់បង់នូវអភិជ្ឈា

និងទោមនស្សក្នុងលោក គឺកាយ ឬឧបាទានក្ខន្ធ ។ ក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុពិចារណាធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមជាគ្រឿងដុតកម្ចាត់កិលេស ដឹងខ្លួន មានសតិ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសតិយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសម្បជញ្ញៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាឈានទៅមុខ និងការឈានថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាក្រឡេកមើលទៅមុខ និងក្រឡេកមើលទៅខាង ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាអង្គុញ និងកិរិយាលាតលាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាទ្រទ្រង់សង្ឃាដិ និងបាត្រចីវរ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាស៊ី ផឹក ទំពា ក្រៃបជញ្ជាប់ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ និយាយ និងការស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសម្បជញ្ញៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានសតិ និងសម្បជញ្ញៈ នេះជាពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។

[៩១] *ស្រីផ្កាមាស ឈ្មោះអម្ពបាលី បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់ស្តេចមកដល់ក្រុងវេសាលីហើយ ទ្រង់គង់នៅក្នុងអម្ពវនរបស់អាត្មាអញ ទៀបក្រុងវេសាលី ។ ទើបស្រីផ្កាមាស ឈ្មោះអម្ពបាលី ឲ្យគេរៀបចំយានទាំងឡាយដ៏ថ្លៃថ្លា ហើយឡើងជិះលើយានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលី*

ដោយយានដ៏ថ្លៃថ្លា បវេសំដៅទៅកាន់អារាមរបស់ខ្លួន ទៅដោយយានកំណត់ត្រឹមទីដែលបវេយានទៅបាន រួចចុះអំពីយានដើរទៅដោយជើងទេ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះស្រីផ្កាមាសឈ្មោះអម្ពបាលី អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ ស្រីផ្កាមាសឈ្មោះអម្ពបាលី លុះព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តខ្ញុំម្ចាស់ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ នាងអម្ពបាលីជាស្រីផ្កាមាសដឹងថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចេញទៅ ។

[៩២] *ពួកស្តេចលិច្ឆវីអ្នកនៅក្នុងក្រុងវេសាលី បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់ស្តេចមកដល់ក្រុងវេសាលីហើយ ទ្រង់គង់នៅក្នុងអម្ពបាលិវន ទៀបក្រុងវេសាលី ។ ទើបស្តេចលិច្ឆវីទាំងនោះ ឲ្យគេរៀបចំយានទាំងឡាយដ៏ថ្លៃថ្លា ហើយឡើងគង់លើយានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលីដោយយានដ៏ថ្លៃថ្លា ។ បណ្តាស្តេចលិច្ឆវីទាំងនោះ ស្តេចលិច្ឆវីពួកខ្លះ ជាពួកខៀវ មានសម្បុរខៀវ មានសំពត់ខៀវ មានគ្រឿងប្រដាប់ក៏ខៀវ ស្តេចលិច្ឆវី*

*ពួកខ្ញុះ ជាពួកលឿង មានសម្បុរលឿង មានសំពត់លឿង មានគ្រឿងប្រដាប់ក៏លឿង ស្តេចលិច្ឆវីពួកខ្ញុះ ជាពួកក្រហម មានសម្បុរក្រហម មានសំពត់ក្រហម មានគ្រឿងប្រដាប់ក៏ក្រហម ស្តេចលិច្ឆវីពួកខ្ញុះជាពួកស មានសម្បុរស មានសំពត់ស មានគ្រឿងប្រដាប់ក៏ស ។ លំដាប់នោះ នាងអម្ពបាលីផ្កាមាស បំប៉ះភ្លៅដោយភ្លៅ បំប៉ះកង់ដោយកង់ បំប៉ះនឹមដោយនឹម (នៃយាន) របស់ពួកស្តេចលិច្ឆវីកំលោះៗ ។ ឯស្តេចលិច្ឆវីទាំងនោះ មានបន្ទូលនឹងនាងអម្ពបាលីផ្កាមាសយ៉ាងនេះថា ម្នាលមេអម្ពបាលី ហេតុអ្វីក៏នាងបំប៉ះភ្លៅដោយភ្លៅ បំប៉ះកង់ដោយកង់ បំប៉ះនឹមដោយនឹម (នៃយាន) របស់ពួកស្តេចលិច្ឆវីកំលោះៗ ។ នាងអម្ពបាលីឆ្លើយថា បពិត្រព្រះអយ្យបុត្តទាំងឡាយ បានជាខ្ញុំម្ចាស់ធ្វើយ៉ាងនោះ ព្រោះខ្ញុំម្ចាស់បាននិមន្តព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃដើម្បីឆាន់ភត្តក្នុងថ្ងៃស្អែក ។ ពួកស្តេចលិច្ឆវីមានបន្ទូលថា ម្នាលមេអម្ពបាលី នាងចូរឲ្យភត្តនេះមកយើង ដោយតម្លៃចំនួន ១ សែនកហាបណៈចុះ ។ នាងអម្ពបាលីឆ្លើយថា បពិត្រព្រះអយ្យបុត្តទាំងឡាយ ទុកជាព្រះអង្គប្រទានក្រុងវេសាលីព្រមទាំងជនបទដល់ខ្ញុំម្ចាស់ ក៏ខ្ញុំម្ចាស់មិនព្រមថ្វាយនូវភត្តដ៏ប្រសើរយ៉ាងនេះឡើយ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះផ្ចាត់ម្រាមព្រះហស្តហើយពោលថា ម្នាលគ្នាយើង ពួកយើងនាងអម្ពបាលីឈ្នះបានហើយតើហ្ន៎ ម្នាលគ្នាយើង ពួកយើងត្រូវនាងអម្ពបាលីបញ្ឆោតបានហើយហ្ន៎ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះក៏បរយានទៅកាន់អម្ពបាលិវន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញស្តេចលិច្ឆវីទាំងនោះមកអំពីចម្ងាយ លុះទតឃើញហើយ

ក៏ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមិនដែលឃើញពួកទេវតានៅក្នុងឋានតាវត្តិង្ស ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ចូរមើលលិច្ឆវិបរិសទ្យ ចូរសង្កេតមើលលិច្ឆវិបរិសទ្យ ពិនិត្យមើលលិច្ឆវិ-បរិសទ្យ ដែលប្រហែលគ្នានឹងទេវតានៅក្នុងឋានតាវត្តិង្ស ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ក៏ទៅដោយយាន កំណត់ត្រឹមទីដែលបរយានទៅបាន ហើយចុះអំពីយាន ស្តេចទៅដោយព្រះបាទា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះស្តេចលិច្ឆវីទាំងនោះ គង់ក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ ស្តេចលិច្ឆវីទាំងនោះ លុះព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងព្រះភិក្ខុសង្ឃ ទទួលភត្តរបស់យើងខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលលិច្ឆវីទាំងឡាយ តថាគតបានទទួលភត្តរបស់នាងអម្ពបាលីផ្កាមាស ដើម្បីឆាន់ក្នុងថ្ងៃស្អែករួចទៅហើយ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះផ្ចាត់ព្រោមព្រះហស្តហើយពោលថា ម្នាលគ្នាយើង ពួកយើងឲ្យនាងអម្ពបាលីឈ្នះបានហើយតើហ្ន៎ ម្នាលគ្នាយើង ពួកយើងឲ្យនាងអម្ពបាលីបញ្ឆោតបានហើយហ្ន៎ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគហើយ ក៏ក្រោកចាកអាសនៈ

ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ នាងអម្ពបាលីផ្កាមាសតាក់តែងខាទនីយភោជនីយាហារដ៏ថ្លៃថ្លាក្នុងអាវាមរបស់ខ្លួន ហើយឲ្យបម្រើទៅក្រាបទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ និងបាត្រចីវរ អំពីព្រលឹម ស្តេចសំដៅទៅកាន់ទីអង្គាសចង្ហាន់របស់នាងអម្ពបាលីផ្កាមាស ព្រមដោយភិក្ខុសង្ឃ លុះស្តេចទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ គ្រានោះ នាងអម្ពបាលីផ្កាមាស បានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពីសាដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ គ្រាតែហាមឃាត់ ។ លំដាប់នោះ នាងអម្ពបាលីផ្កាមាសកំណត់ដឹងថា ព្រះមានព្រះភាគ ទ្រង់សោយស្រេចហើយ លែងលុកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។ នាងអម្ពបាលីផ្កាមាស លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយអាវាមនេះដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលនូវអាវាម ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ញុំាងនាងអម្ពបាលីផ្កាមាស ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ស្តេចចេញទៅ ។ បានឮថា ព្រះមានព្រះភាគដែលទ្រង់គង់ក្នុងអម្ពបាលិវន ទៀបក្រុងវេសាលីនោះ ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់ភិក្ខុទាំងឡាយយ៉ាងនេះថា

สีลขนฺโธ สมาธิขนฺโธ ปญฺญาขนฺโธ สมาธิ ยทริยสีลา มหปฺผลา โหติ มหานิสงฺสา ปญฺญา ยทริยสมาธิา มหปฺผลา โหติ มหานิสงฺสา จิตฺตํ ยทริยปญฺญา สมฺมเทว อาสวา วิมุจฺจติ เสยฺยถีทํ กามาสวา ภวาสวา อวิชฺชาสวา ฯ

[๙๓] *อถ โข ภควา ตสฺมึ ปาวารเก อมฺพวเน ยถาภิรนฺตมาวสิตฺวา เยน กุสินารา ตทวสริ ฯ อถ โข ภควา อายสฺมนฺตมานนฺทมามนฺเตสิ เอหานนฺท ยาม กุสินารนฺติ ฯ เอวมาวุโสติ โข อายสฺมา อานนฺโท ภควโต ปจฺจสฺโสสิ ฯ อถ โข ภควา มหตา ภิกฺขุสงฺเฆน สทฺธึ เยน กุสินารา ตทวสริ ฯ ตตฺร สุทํ ภควา กุสินารายํ อนฺตรา จ ยมกสาลานญฺจ อุปวตฺตเน มลฺลานํ สาลวเน ปจฺเจกสาเล นิปชฺชิ ทกฺขิเณน ปสฺเสน สีหเสยฺยํ กปฺเปนฺโต ปาเทน ปาทมจฺจาธาย สโต สมฺปชาโน อุฏฺฐานสญฺญญฺจ มนสิกโรนฺโต ฯ*

ตตฺร สุทํ อายสฺมา อานนฺโท ภิกฺขูนญฺเญว ปจฺจุคฺคมนา ปจฺจุคฺคนฺตฺวา ภิกฺขูหิ ปจฺฉาสมเณหิ ปจฺฉาสมณกิจฺจานิ กโรนฺโต ภิกฺขูนญฺเญว ปุรโต ปุรโต คจฺฉติ ฯ ตตฺร สุทํ อายสฺมา อานนฺโท ภิกฺขูนญฺเญว ปุรโต ปุรโต คจฺฉนฺโต ภิกฺขูหิ ปจฺฉาสมเณหิ ปจฺฉาสมณกิจฺจานิ กโรนฺโต ภควนฺตเมว ปจฺจุคฺคมนา ปจฺจุคฺคนฺตฺวา ภควนฺตเมว ปุรโต ปุรโต คจฺฉติ ฯ ตตฺร สุทํ อายสฺมา อานนฺโท ภควนฺตเมว ปุรโต ปุรโต คจฺฉนฺโต ภควนฺตเมตทโวจ ฯ

ตตฺร สุทํ ภควา ภิกฺขู อามนฺเตสิ ฯ

កាលព្រះមានព្រះភាគ ទ្រង់គង់ចាំព្រះវស្សា ក៏មានព្រះអាពាធខ្លាំងក្លាកើតឡើង វេទនាដ៏មានកម្លាំងស្ទើរនឹងដល់មរណៈក៏ប្រព្រឹត្តទៅ ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់មានសតិ និងសម្បជញ្ញៈ មិនឲ្យទុក្ខវេទនាបៀតបៀនបាន ទ្រង់អត់សង្កត់ (ដោយអធិវាសនខន្តី) ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតមិនបានប្រាប់ពួកភិក្ខុអ្នកបម្រើ និងមិនបានប្រាប់ភិក្ខុសង្ឃហើយបរិនិព្វាន ដោយហេតុណា ហេតុនោះមិនសមគួរដល់តថាគតឡើយ បើដូច្នោះ គួរតែតថាគតគ្របសង្កត់អាពាធនេះ ដោយសេចក្តីព្យាយាម ហើយអធិដ្ឋានជីវិតសង្ខារសម្រេចតរិយោបថសិនចុះ។ ទើបព្រះមានព្រះភាគទ្រង់គ្របសង្កត់អាពាធនោះ ដោយសេចក្តីព្យាយាម ហើយទ្រង់អធិដ្ឋានទូវជីវិតសង្ខារ ។ អាពាធនៃព្រះមានព្រះភាគនោះ ក៏រម្ងាប់ទៅក្នុងកាលនោះឯង ។ លុះព្រះមានព្រះភាគ សះស្បើយអំពីព្រះអាពាធហើយ ទើបនឹងស្បើយចាកពីអាពាធមិនយូរប៉ុន្មាន ទ្រង់ស្តេចចេញអំពីវិហារ ទៅគង់លើអាសនៈ ដែលគេបានក្រាលទុកត្រង់មុខវិហារ ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគ ទ្រង់បានសេចក្តីសប្បាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគអត់ធន់បាន បពិត្រព្រះអង្គដ៏ចម្រើន ក៏កាយរបស់ខ្ញុំព្រះអង្គហាក់ដូចជា

ស្រយុតស្រយង់ពេកណាស់ សូម្បីទិសទាំងឡាយក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ សូម្បីធម៌ទាំងឡាយ ក៏មិនច្បាស់លាស់ដល់ខ្ញុំព្រះអង្គ ព្រោះហេតុដែលព្រះមានព្រះភាគទ្រង់ព្រះអាពាធ បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែខ្ញុំព្រះអង្គមានសេចក្តីសង្ឃឹមខ្លះថា ព្រះមានព្រះភាគមិនទាន់សម្តែងធម៌នីមួយដ៏ប្លែក ប្រាវព្ធនឹងភិក្ខុសង្ឃដរាបណាទេ ព្រះមានព្រះភាគនឹងមិនទាន់បរិនិញ្ចានដរាបនោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ភិក្ខុសង្ឃនៅនឹកប៉ុនប៉ងអ្វីក្នុងតថាគតទៀត ម្នាលអានន្ទ ធម៌ដែលតថាគតសម្តែងហើយ ធ្វើមិនឲ្យមានខាងក្នុងខាងក្រៅ ម្នាលអានន្ទ កណ្តាប់ដៃនៃអាចារ្យមិនមានក្នុងធម៌ទាំងឡាយ របស់តថាគតទេ ម្នាលអានន្ទ អ្នកណាមានគំនិតយ៉ាងនេះថា អាត្មាអញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះក្តី ថាភិក្ខុសង្ឃជាអ្នកអាងនូវអាត្មាអញដូច្នេះក្តី ម្នាលអានន្ទ អ្នកនោះសមជាពោលពាក្យណាមួយ ប្រាវព្ធនឹងភិក្ខុសង្ឃមិនខាន ។ ម្នាលអានន្ទ តថាគតមិនមានគំនិតយ៉ាងនេះថា អាត្មាអញនឹងគ្រប់គ្រងភិក្ខុសង្ឃដូច្នេះ ឬថាភិក្ខុសង្ឃជាអ្នកអាងនូវអាត្មាអញដូច្នេះសោះឡើយ ។ ម្នាលអានន្ទ ព្រះតថាគតនឹងពោលពាក្យណាមួយ ប្រាវព្ធនឹងភិក្ខុសង្ឃ ធ្វើអ្វីទៀត ។ ម្នាលអានន្ទ ឥឡូវនេះ តថាគតគ្រាំគ្រាហើយ ចម្រើនហើយ ចាស់ហើយ កន្លងអាយុកាលដល់បច្ឆិមវ័យហើយ វ័យតថាគតបាន ៨០ ឆ្នាំហើយ ។ ម្នាលអានន្ទ រទេះចាស់ដែលបរទៅបាន ព្រោះការអបដោយឬស្សី យ៉ាងណាមិញ ម្នាលអានន្ទ កាយរបស់តថាគតនឹងប្រព្រឹត្តទៅបានដូចជារទេះអបដោយឬស្សីយ៉ាងនោះឯង ។ ម្នាលអានន្ទ សម័យណា ដែលព្រះតថាគតចូលចេតោសមាធិ

(សេចក្តីតាំងចិត្តមាំ) ដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង ព្រោះរំលត់វេទនាពួកខ្លះ ម្នាលអានន្ទ សម័យនោះ កាយនៃព្រះតថាគតក៏បានសេចក្តីសប្បាយគ្រាន់បើ ។ ម្នាលអានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយចូរយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក កុំយករបស់ដទៃជាទីរឭក ចូរយកធម៌ជាទីពឹង យកធម៌ជាទីរឭក កុំយករបស់ដទៃជាទីរឭកឡើយ ។ ម្នាលអានន្ទ ភិក្ខុយកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយករបស់ដទៃជាទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយករបស់ដទៃជាទីរឭកនោះ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមដុតកម្តៅកិលេស មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក គឺកាយ ឬឧបាទានក្ខន្ធចេញ ។ ក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមដុតកម្តៅកិលេស មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ម្នាលអានន្ទ យ៉ាងនេះឯង ភិក្ខុឈ្មោះថា យកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយករបស់ដទៃជាទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយករបស់ដទៃជាទីរឭក ។ ម្នាលអានន្ទ ក្នុងកាលឥឡូវនេះក្តី អំណើះឥតនិងតថាគតទៅក្តី ភិក្ខុណាមួយ យកខ្លួនជាទីពឹង យកខ្លួនជាទីរឭក មិនយករបស់ដទៃជាទីរឭក យកធម៌ជាទីពឹង យកធម៌ជាទីរឭក មិនយករបស់ដទៃជាទីរឭកឡើយ ម្នាលអានន្ទ មួយទៀត ភិក្ខុណាមួយជាអ្នកប្រាថ្នានូវសិក្ខា ភិក្ខុទាំងនោះ និងតាំងនៅក្នុងគុណដ៏ប្រសើរ

បំផុត របស់តថាគតដែរ ។

គាមកណ្ឌក្នុងមហាបរិនិព្វានសូត្រ ចប់

ពុទ្ធកាណវារៈទី ២ ចប់

[៩៤] *លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ និងបាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅទ្រង់បិណ្ឌបាត ក្នុងក្រុងវេសាលី លុះទ្រង់គ្រាច់ទៅបិណ្ឌបាត ក្នុងក្រុងវេសាលីហើយ ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្តហើយ ទ្រង់គ្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈទៅ យើងនឹងចូលទៅសម្រាកក្នុងវេលាថ្ងៃឯចាបាលចេតិយ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះកុរុណាព្រះអង្គ ហើយក៏កាន់និសីទនៈទៅតាមៗ ខាងក្រោយព្រះមានព្រះភាគ។ គ្រានោះ ព្រះមានព្រះភាគស្តេចចូលទៅកាន់ចាបាលចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ ចំណែកខាងព្រះអានន្ទមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលអានន្ទ ក្រុងវេសាលីជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ពចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយជាទីគួរត្រេកអរ ចាបាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយៗ ហើយ ធ្វើឲ្យ*

ដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បុគ្គលនោះបើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ។ ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏មិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនបានអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកទេវតា និងមនុស្សដូច្នេះសោះ ព្រោះមារចូលមកជ្រែកគំនិត ។ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលជាគម្រប់ ២ ដងផង ។បេ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទមានអាយុជាគម្រប់ ៣ ដងផងថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយជាទីគួរត្រេកអរ គោតមកចេតិយជាទីគួរត្រេកអរ សត្តម្ព-ចេតិយជាទីគួរត្រេកអរ ពហុបុត្តចេតិយជាទីគួរត្រេកអរ សារន្ទទចេតិយ ជាទី

គួរត្រេកអរ បាវាលចេតិយជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅគប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទ ៤ ព្រះតថាគតបានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ ព្រះតថាគតនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់ ១ អាយុកប្ប ឬលើសជាង ១ អាយុកប្បក៏បាន ។ ទុកជាព្រះមានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏នៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បានឡើយ ហើយមិនបានអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគឋិតនៅអស់ ១ អាយុកប្ប សូមព្រះសុគតឋិតនៅអស់ ១ អាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះឡើយ ព្រោះមារចូលមកជ្រែកគំនិត ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់គ្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នកចូរទៅចុះ អ្នកចូរដឹងនូវកាលដែលគួរនឹងទៅ ក្នុងកាលឥឡូវនេះចុះ ។ ព្រះអានន្ទមានអាយុ

ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះកុរុណាព្រះអង្គ រួចក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយអង្គុយទៀបគល់ឈើមួយ ក្នុងទីមិនឆ្ងាយ ។

[៩៥] កាលបើព្រះអានន្ទមានអាយុ ចេញទៅហើយមិនយូរប៉ុន្មានគ្រានោះ ក្រុងមារមានចិត្តបាប ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីសមគួរ ។ លុះក្រុងមារមានចិត្តបាបឋិតនៅក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគតដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀនទូវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុហើយ សម្តែងធម៌ប្រកបដោយបាដិហារ្យ ជារបណាទេ តថាគតនឹងមិនទាន់បរិនិព្វានជារបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុជាសាវ័ករបស់ព្រះមានព្រះភាគ បានឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌

ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើកចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកភិក្ខុនីជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មានទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យដរាបណាទេ តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងកាលឥឡូវនេះ ពួកភិក្ខុនីជាសាវិការបស់ព្រះមានព្រះភាគ បានឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ហើយ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត

តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនទូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិន ដោយល្អតាមពាក្យសម ហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យបានហើយ បពិត្រព្រះអង្គ ដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមាន ព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួកឧបាសកជា សាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌នៅមិនទាន់ មាន ទាំងមិនទាន់រៀនទូវាទៈ នៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ ទាំងមិនទាន់សង្កត់សង្កិនទូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែល សមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យដរាបណាទេ តថាគតក៏ នឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ពួកឧបាសកជាសាវ័ករបស់ព្រះមានព្រះភាគ ឈ្លាសវាងវៃ ក្លៀវក្លា ជាពហុ-សូត្រ ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្ត តាមធម៌ហើយ ទាំងបានរៀនទូវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិនទូវ បរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាម

ពាក្យដែលសមហេតុ ហើយសម្តែង ធម៌ប្រកបដោយជាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹង បរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ពួក ឧបាសិកា ជាសាវិការបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុ-សូ្រត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្ត តាមធម៌នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់ សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិន ដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយជាដិហារ្យ ជារបណាទេ តថាគតក៏នឹងមិនទាន់បរិនិព្វានជារបនោះ ដូច្នេះ បពិត្រព្រះអង្គ ដ៏ចម្រើន ក៏ឥឡូវនេះ ពួកឧបាសិកាជាសាវិកា របស់ព្រះមានព្រះភាគបាន ឈ្លាសវាងវៃ ក្លៀវក្លា ជាពហុសូ្រត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ហើយ ទាំងបានរៀននូវវាទៈនៃអាចារ្យ របស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយ បានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ច ដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយជាដិហារ្យបានហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូម

ព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ បានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា និងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀត ពួកទេវតា និងមនុស្សមិនទាន់ចេះសម្តែងបានដោយប្រពៃដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះមានព្រះភាគនេះខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតា និងមនុស្សចេះសម្តែងបានដោយល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ។ កាលបើក្រែងមារក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏បានត្រាស់កាសិតនេះទៅនឹងក្រែងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារឰដ៏ជាវាលចេតិយ ។ លុះព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ក៏កក្រើកផែនដីយ៉ាងធំ គួរ

ឲ្យភ្ញកភ្ញីក ព្រឺព្រួចរោម ទាំងផ្គរក៏លាន់ញ្ញឡឺង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវដំណើរនោះហើយ ក៏បន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

[๙๖] ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញ នូវព្រះនិព្វានដែលមានគុណថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់នូវសង្ខារដែលនាំសត្វទៅកាន់ភពផង ទ្រង់ត្រេកអរនូវអារម្មណ៍ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងមាំហើយ (ដោយអំណាចសមថៈ) ផង ទ្រង់បានទម្លាយនូវបណ្តាញ គឺកិលេសដែលកើតមាននៅក្នុងខ្លួន ដូចជាក្រោះ ។

[๙๗] លំដាប់នោះ ព្រះអានន្ទមានអាយុមានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុជាអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុចម្លែកពេកណាស់ ការកក្រើកផែនដីនេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើ គួរឲ្យភ្ញកភ្ញីកឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ញ្ញឡឺង មានហេតុដូចម្តេច មានបច្ច័យដូចម្តេច ហ្ន៎ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំម្ល៉ៃ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានហេតុជាអស្ចារ្យ បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដ៏ប្លែក បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចម្រើន

ការកក្រើកផែនដីនេះធំពេកណាស់ គួរឲ្យភ្ញកភ្ញឹក ឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮខ្លាំង បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេច ហ្ន៎ ដែលនាំឲ្យកក្រើកផែនដីយ៉ាងធំម្ល៉ះ ។

[៩៨] *ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ឯហេតុបច្ច័យដែលនាំឲ្យកក្រើកផែនដីនេះមាន ៨ យ៉ាង ។ ហេតុបច្ច័យទាំង ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ មហាប្រឹថពីនេះ ប្រតិស្ឋាននៅលើទឹក ឯទឹកប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាននៅលើអាកាស ម្នាលអានន្ទ សម័យដែលមានខ្យល់ធំបក់ ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឲ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដីឲ្យកក្រើកដែរ នេះជាហេតុ ជាបច្ច័យទី ១ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ សមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានឫទ្ធិ ជាន់នូវការស្ងាត់ជំនាញក្នុងចិត្ត ឬទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ បុគ្គលនោះបានចម្រើនបឋវីសញ្ញា ឲ្យមានកម្លាំងតិច ចម្រើនអាបោសញ្ញាឲ្យមានកម្លាំងច្រើន បុគ្គលនោះរមែងធ្វើផែនដីនេះ ឲ្យកក្រើករំពើករំភើបញាប់ញ័របាន នេះជាហេតុជាបច្ច័យទី ២ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វច្យុតចាកពួកទេវតាដែលឋិតនៅក្នុងស្ថានតុសិត មានសតិ និងសម្បជញ្ញៈ យាងចុះកាន់ព្រះមាតុឧទរ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ នេះជាហេតុជាបច្ច័យទី ៣ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះពោធិសត្វមានសតិ និងសម្បជញ្ញៈ ទ្រង់ប្រសូត*

ចាកព្រះមាតុឧទរ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៤ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៥ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគតញុំាងអនុត្តរធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៦ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគតមានសតិ និងសម្បជញ្ញៈ ជាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៧ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលនោះ ផែនដីនេះតែងកក្រើករំពើករំភើបញាប់ញ័រ នេះជាហេតុ ជាបច្ច័យទី ៨ ដែលនាំឲ្យកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំមាន ៨ យ៉ាងនេះឯង ។

[๙๙] ម្នាលអានន្ទ បរិសទ្យនេះមាន ៨ ពួក ។ បរិសទ្យទាំង ៨ ពួក តើដូចម្តេច ។ គឺខត្តិយបរិសទ្យ ព្រាហ្មណបរិសទ្យ គហបតិបរិសទ្យ សមណបរិសទ្យ ចាតុម្មហារាជិកបរិសទ្យ តាវត្តិង្សបរិសទ្យ មារបរិសទ្យ ព្រហ្មបរិសទ្យ ។ ម្នាលអានន្ទ ចំណែកតថាគតចូលទៅកាន់ខត្តិយបរិសទ្យ

ជាច្រើនរយ រមែងស្គាល់ច្បាស់ ។ ក្នុងខត្តិយបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ចូលទៅសាកច្ចាជាមួយផង ។ សម្បុររបស់ជនទាំងនោះ ក្នុងពួកបរិសទ្យនោះយ៉ាងណា សម្បុររបស់តថាគតយ៉ាងនោះដែរ សំឡេងរបស់ជនទាំងនោះយ៉ាងណា សំឡេងរបស់តថាគតយ៉ាងនោះដែរ ។ មួយទៀត តថាគតបានញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ជនទាំងនោះមិនស្គាល់តថាគតថា ជនដែលកំពុងនិយាយនេះតើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ តថាគតលុះញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បាត់រូបទៅ កាលដែលតថាគតបាត់រូបទៅហើយ ឯជនទាំងនោះ នៅតែមិនស្គាល់តថាគតថា ជនដែលបាត់ទៅហើយនេះតើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ម្នាលអានន្ទ តថាគតចូលទៅកាន់ព្រាហ្មណបរិសទ្យជាច្រើនរយ រមែងស្គាល់ច្បាស់ ។បេ។ គហបតិបរិសទ្យ ។បេ។ សមណបរិសទ្យ ។បេ។ ចាតុម្មហារាជិកបរិសទ្យ ។បេ។ តាវត្តិង្សបរិសទ្យ ។បេ។ មារ-បរិសទ្យ ។បេ។ ព្រហ្មបរិសទ្យ ។ ក្នុងព្រហ្មបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ចូលទៅសាកច្ចាជាមួយផង ។ សម្បុររបស់ព្រហ្មទាំងនោះ ក្នុងព្រហ្មបរិសទ្យនោះយ៉ាងណា សម្បុររបស់តថាគតក៏យ៉ាងនោះដែរ សំឡេងរបស់ព្រហ្មទាំងនោះយ៉ាងណា សំឡេងរបស់តថាគតក៏យ៉ាងនោះដែរ ។ មួយទៀត តថាគតបានញុំាងព្រហ្មទាំងនោះឲ្យឃើញច្បាស់

ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា កាលដែលតថាគត កំពុងនិយាយ ចំណែកខាងព្រហ្មទាំងនោះមិនស្គាល់តថាគតថា ជនដែលកំពុងនិយាយនេះជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ លុះតថាគតញុំាងព្រហ្មទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ជាត់រូបទៅ កាលដែលតថាគតជាត់រូបទៅហើយ ចំណែកព្រហ្មទាំងនោះ នៅតែមិនស្គាល់តថាគត ថាជនដែលជាត់ទៅហើយនេះតើជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ម្នាលអានន្ទ បរិសទ្យមាន ៨ ពួកនេះឯង ។

[๑๐๐] ម្នាលអានន្ទ អភិភាយតនៈ (ហេតុជាគ្រឿងគ្របសង្កត់នូវបច្ចនិកធម៌) នេះមាន ៨ ប្រការ ។ អភិភាយតនៈ ៨ ប្រការតើដូចម្តេច ។ បុគ្គលពួក ๑ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានពណ៌ល្អ ឬមានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ๑ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានពណ៌ល្អ ឬមានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ๒ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានពណ៌ល្អ ឬមានពណ៌អាក្រក់ គ្របសង្កត់នូវរូប

ទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញ ឃើញដូច្នេះ នេះជាអភិកាយតនៈទី ៣ ។ បុគ្គលពួកមួយ មិនមានសេចក្តី សម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មាន ពណ៌ល្អ ឬមានពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តី សម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិកាយតនៈ ទី ៤ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញ នូវរូបខាងក្រៅដែលជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមាន ពណ៌ខៀវ មានពន្លឺខៀវ ប្រៀបដូចផ្កាកឫាសខៀវ មានពណ៌ខៀវ ជាទីចង្អុល ប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ពុំនោះសោត រូបនោះ ប្រៀបដូច សំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ដទាំងពីរខាង ហៅថា សំពត់ខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ យ៉ាង ណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញ នូវរូបខាងក្រៅ ជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ ខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជា អភិកាយតនៈទី ៥ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង ប្រៀបដូចផ្កាកណិការលឿង មានពណ៌ លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោត

รูปនោះ ប្រៀបដូចសំពត់ កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ដទាំងពីរខាង ហៅថា សំពត់លឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ប្រៀបដូចផ្កាច្បាក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត រូបនោះ ប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ដទាំងពីរខាង ហៅថា សំពត់ក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅជារូបស មានពណ៌ស ជា

ទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺស ប្រៀបដូចផ្កាយព្រឹកដែលស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺស ពុំនោះសោត រូបនោះ ប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ដទាំងពីរខាង ហៅថា សំពត់ស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មាន ពន្លឺស យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ហើយឃើញនូវរូបខាងក្រៅ ជារូបស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះ មានពណ៌ស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តី សម្គាល់យ៉ាងនេះថា អាត្មាអញជឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអកិកាយតនៈទី ៨ ។ ម្នាលអានន្ទ អកិកាយតនៈ មាន ៨ ប្រការ នេះឯង ។

[๑๐๑] *ម្នាលអានន្ទ វិមោក្ខ (ធម៌ជាគ្រឿងរួចចាកអាសវៈ) នេះ មាន ៨ ប្រការ ។ វិមោក្ខ ៨ ប្រការតើដូចម្តេច ។ បុគ្គលបាននូវរូបជ្ឈាន រមែងឃើញនូវរូប គឺកសិណទាំងឡាយ មាននីលកសិណជាដើម នេះជា វិមោក្ខទី ១ ។ បុគ្គលមិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង រមែងឃើញនូវរូប ខាងក្រៅទាំងឡាយ គឺកសិណមាននីលកសិណជាដើម នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈានក្នុងវណ្ណកសិណដែលបរិសុទ្ធ នេះជាវិមោក្ខ ទី ៣ ។ បុគ្គលដែលកន្លងនូវរូបសញ្ញា ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ហើយបានដល់នូវ អាកាសានញ្ចាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ*

នេះជាវិមោក្ខទី ៤ ។ បុគ្គលដែលកន្ងងនូវអាកាសានញ្ចាយតនជ្ឈាន ដោយ ប្រការទាំងពួង ហើយបានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្ត ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ បុគ្គលដែលកន្ងងនូវ វិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញា-យតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខ ទី ៦ ។ បុគ្គលដែលកន្ងងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ បុគ្គល ដែលកន្ងងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយ បានដល់នូវសញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញា និងវេទនា) នេះ ជាវិមោក្ខទី ៨ ។ ម្នាលអានន្ទ វិមោក្ខមាន ៨ ប្រការនេះឯង ។

[១០២] ម្នាលអានន្ទ សម័យមួយ តថាគតបានត្រាស់ជាដំបូង បាន គង់នៅក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលា-ប្រទេសឯណោះ ។ ម្នាលអានន្ទ គ្រានោះឯង ក្រុងមារមានចិត្តបាបចូលទៅ រកតថាគត លុះចូលទៅដល់ហើយបានឱតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះក្រុងមារមានចិត្តបាបឱតនៅក្នុងទីដ៏សមគួរហើយ បាននិយាយយ៉ាងនេះ នឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ម្នាលអានន្ទ កាលបើ ក្រុងមារ បាននិយាយយ៉ាងនេះហើយ តថាគតក៏បានពោលពាក្យនេះទៅនឹង

ក្រុងមារមានចិត្តបាបថា ម្នាលមារមានចិត្តបាប ពួកភិក្ខុជាសាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរ ដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើង ហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគតក៏មិនបានបរិនិព្វានដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកភិក្ខុនី ជាសាវិកា របស់តថាគតដែលឈ្លាសវាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀន នូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគតមិនទាន់បរិនិព្វាន ដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកឧបាសក ជាសាវ័ករបស់តថាគតដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់

សង្ខិនទូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយ ល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគតមិនទាន់បរិនិព្វាន ដរាបនោះ ។ ម្នាលមារមានចិត្តបាប ពួកឧបាសិកា ជាសាវិការបស់តថាគតដែលឈ្លាស វាងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្ត តាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយច្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិនទូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយបាដិហារ្យបាន ដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ ។ ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ចាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀត ពួកទេវតា និងមនុស្សមិនទាន់ចេះសម្តែងបានដោយប្រពៃដរាបណាទេ តថាគត ក៏មិនទាន់បរិនិព្វានដរាបនោះ ។ ម្នាលអានន្ទ ថ្ងៃនេះ ក្រុងមារមានចិត្តបាប បានចូលមករកតថាគត ក្នុងបាវាលចេតិយ អម្បាញ់មិញនេះឯង បានឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះមារមានចិត្តបាប បានឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគបរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាល

គួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះ ព្រះមានព្រះភាគបានត្រាស់ព្រះវាចានេះថា ម្នាលមារមានចិត្តបាប ពួកភិក្ខុជា សាវ័ករបស់តថាគតនៅមិនទាន់មានជរាបណាទេ តថាគតក៏មិនទាន់បរិនិព្វាន ជរាបនោះ ។ ពួកភិក្ខុនីជាសាវិការបស់តថាគត នៅមិនទាន់មានជរាបណា ។ ពួកឧបាសក ជាសាវ័ករបស់តថាគតនៅមិនទាន់មានជរាបណា ។ ពួកឧបា-សិកាជាសាវិការបស់តថាគត នៅមិនទាន់មានជរាបណា ។ ព្រហ្មចារ្យរបស់ តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ជរាបណា មួយទៀត ពួក ទេវតា និងមនុស្សមិនទាន់ចេះសម្តែងបានដោយប្រពៃជរាបណា (តថាគតក៏ មិនទាន់បរិនិព្វានជរាបនោះ) ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះព្រហ្មចារ្យ របស់ព្រះមានព្រះភាគ បានខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅ សព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួក ទេវតា និងមនុស្សចេះសម្តែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះមានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះ ភាគហើយ ។ ម្នាលអានន្ទ កាលបើក្រុងមារ បាននិយាយយ៉ាងនេះហើយ តថាគតក៏បានពោលពាក្យនេះទៅនឹងក្រុងមារមានចិត្តបាបថា ម្នាលមារមាន ចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគតមិន ឃ្លាតប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ម្នាល

អានន្ទ ក្នុងថ្ងៃនេះ តថាគតមានសតិសម្បជញ្ញៈ បានជាក់អាយុសង្ខារ ក្នុងបាវាលចេតិយអម្បាញ់មិញនេះឯង ។ កាលបើព្រះមានព្រះភាគ មានពុទ្ធ-តម្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បានក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគតឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រ-យោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ ឥឡូវនេះ កុំឡើយ អ្នកកុំអង្វរតថាគតឡើយ ម្នាលអានន្ទ ឥឡូវនេះ មិនមែនជាកាលគួរអោរាធនាតថាគតទេ ។ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលជាគម្រប់ពីរដងផង ។បេ។ ព្រះអានន្ទមានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់បីដងផង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគតឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ អ្នកជឿពោធិញ្ញាណរបស់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។ ម្នាលអានន្ទ កាលបើអ្នកជឿដែរ ហេតុអ្វីក៏អ្នកនៅតែទទូចតថាគតដល់ទៅ ៣ ដង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកានេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានត្រងរងក្នុងទី

ចំពោះព្រះភក្ត្រថា ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ អ្នកជឿឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជឿ ។ ម្នាលអានន្ទ ហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ព្រោះតថាគតបានធ្វើនិមិត្តជាឱឡារិក បានធ្វើឱកាស ជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនយល់សេចក្តីច្បាស់លាស់បាន មិនអាចធនាតថាគតថា សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអាចធនាតថាគត តថាគតគប្បីឃាត់វាចារបស់អ្នកត្រឹមតែពីរលើក តែដល់ទៅបីលើក តថាគតគប្បីទទួល ម្នាលអានន្ទ ព្រោះហេតុនោះ នេះជា

អំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

[๑๐๓] *ម្នាលអានន្ទ សម័យមួយ តថាគតគង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះឯណោះ ម្នាលអានន្ទ ក្នុងទីនោះឯង តថាគតបានពោលនឹងអ្នកថា ម្នាលអានន្ទ ក្រុងរាជគ្រឹះជាទីគួរត្រេកអរ ភ្នំគិជ្ឈកូដជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ๔ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ កាលបើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ๔ តថាគតបានចម្រើនហើយ បានធ្វើរឿយៗ ហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ កាលបើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតបានធ្វើនិមិត្តជាឱឡារិក ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនយល់សេចក្តីច្បាស់លាស់បាន មិនអាចធនាតថាគតថា សូមព្រះមានព្រះភាគ ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលអានន្ទ បើអ្នកអាចធនា*

តថាគតៗ គប្បីឃាត់វាចារបស់អ្នកត្រឹមតែពីរលើក តែដល់បីលើក តថាគត គប្បីទទួល ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

[๑๐๔] ម្នាលអានន្ទ សម័យមួយ តថាគតនៅក្នុងគោតមនិគ្រោធ ជិតក្រុងរាជគ្រឹះនោះឯង ។បេ។ តថាគតនៅជិតជ្រោះជាទីទម្លាក់នូវចោរ ទៀប ក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងសត្តបណ្ណគុហា (គុហាដែលសន្ធត ដោយដើមសត្តបណ្ណព្រឹក្ស) ខាងភ្នំវេភារៈ ជិតក្រុងរាជគ្រឹះនោះឯង ។ តថាគត នៅក្នុងកាឡសិលា (ថ្មខ្មៅ) ខាងភ្នំឥសិគិលិ ទៀបក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងសប្បសោណ្ឌិកបព្ភារៈ (ញកមានត្រពាំងទឹកជាទីនៅនៃពស់) ក្នុងសីតវន (ព្រៃត្រជាក់) ទៀបក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុង តបោទារាម (អារាមជិតស្ទឹងឈ្មោះតបោទា) ជិតក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងវេឡុវនកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះឯង ។តថាគត នៅក្នុងជីវកម្ពវន ជិតក្រុងរាជគ្រឹះនោះឯង ។ តថាគតនៅក្នុងមទ្ទកុច្ឆិមិគទា-យវន ជិតក្រុងរាជគ្រឹះនោះឯង ។ ម្នាលអានន្ទ តថាគតនៅក្នុងទីអម្បាលនោះ បានប្រាប់អ្នកថា ម្នាលអានន្ទ ក្រុងរាជគ្រឹះ ជាទីគួរត្រេកអរ ភ្នំគិជ្ឈកូដ ជាទី គួរត្រេកអរ គោតមនិគ្រោធ ជាទីគួរត្រេកអរ ជ្រោះសម្រាប់ទម្លាក់នូវចោរ ជាទីគួរត្រេកអរ សត្តបណ្ណគុហា ខាងភ្នំវេភារៈ ជាទីគួរត្រេកអរ កាឡ-សិលាខាងភ្នំឥសិគិលិ ជាទីគួរត្រេកអរ សប្បសោណ្ឌិកបព្ភារៈ ក្នុងសីតវន ជាទីគួរត្រេកអរ តបោទារាម ជាទីគួរត្រេកអរ វេឡុវនកលន្ទកនិវាបស្ថាន ជា

ទីគួរត្រេកអរ ជីវកម្ពវន ជាទីគួរត្រេកអរ មទ្ទុកុច្ឆិមិគទាយវន ជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះបើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនអាចនឹងយល់ សេចក្តីច្បាស់លាស់បាន មិនអាចនាតថាគតថា សូមព្រះមានព្រះភាគ ទ្រង់ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ទ្រង់ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអាចនាតថាគតៗ គប្បីឃាត់ពាក្យអ្នកត្រឹមតែ ២ ដងប៉ុណ្ណោះ គង់នឹងទទួលអាចនាក្នុងវារៈជាគម្រប់ ៣ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ។

[១០៥] *ម្នាលអានន្ទ សម័យមួយ តថាគតនៅក្នុងឧទេនចេតិយ ទៀបក្រុងវេសាលីនេះឯង ។ កាលតថាគតនៅក្នុងឧទេនចេតិយនោះ បានប្រាប់អ្នកថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បានឡើយ មិនអាចនាតថាគតថា សូមព្រះមានព្រះភាគ ទ្រង់ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគតទ្រង់ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអាចនាតថាគតៗ គប្បីយាត់ពាក្យអ្នកត្រឹមតែ ២ ដង*

ប៉ុណ្ណោះ គង់នឹងទទួលអាយុធម៌ក្នុងវារៈជាគម្រប់ ๓ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ฯ

[๑๐๖] ម្នាលអានន្ទ សម័យមួយ តថាគតនៅក្នុងគោតមកចេតិយ ជិតក្រុងវេសាលីនេះឯង ฯបេฯ តថាគតនៅក្នុងសត្តម្ពចេតិយ ជិតក្រុងវេសាលីនេះឯង ฯ តថាគតនៅក្នុងពហុបុត្តចេតិយ ជិតក្រុងវេសាលីនេះឯង ฯ តថាគតនៅក្នុងសារន្ទទចេតិយ ជិតក្រុងវេសាលីនេះឯង ฯ ម្នាលអានន្ទ ក្នុងកាលឥឡូវនេះ តថាគតនៅក្នុងបាវាលចេតិយ ក្នុងថ្ងៃនេះ បានប្រាប់អ្នកថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរត្រេកអរ ពហុបុត្ត-ចេតិយ ជាទីគួរត្រេកអរ សារន្ទទចេតិយ ជាទីគួរត្រេកអរ បាវាលចេតិយ ជាទីគួរត្រេកអរ ម្នាលអានន្ទ ឥទ្ធិបាទទាំង ๔ បើបុគ្គលណាមួយបានចម្រើនហើយ បានធ្វើច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ បើប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ฯ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ๔ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ បានធ្វើឲ្យជាទីនៅហើយ បានតាំងទុករឿយៗ ហើយ បានសន្សំទុកហើយ បានប្រារព្ធដោយល្អហើយ ម្នាលអានន្ទ បើតថាគតប្រាថ្នានឹងឋិតនៅ គប្បីឋិតនៅអស់

មួយអាយុកប្ប ឬលើសជាងមួយអាយុកប្បក៏បាន ម្នាលអានន្ទ កាលបើតថាគតធ្វើនិមិត្តជាឱឡារិក ធ្វើឱកាសជាឱឡារិកយ៉ាងនេះហើយ ក៏អ្នកនៅតែមិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនអាចធនាតថាគតថា សូមព្រះមានព្រះភាគ ទ្រង់ឋិតនៅអស់មួយអាយុកប្ប សូមព្រះសុគត ទ្រង់ឋិតនៅអស់មួយអាយុកប្ប ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដូច្នេះសោះ ម្នាលអានន្ទ បើអ្នកអាចធនាតថាគតៗ គប្បីឃាត់ពាក្យអ្នកត្រឹមតែ ២ ដង ប៉ុណ្ណោះ គង់នឹងទទួលអាចធនាក្នុងវារៈជាគម្រប់ ៣ ដងមិនខាន ម្នាលអានន្ទ ព្រោះហេតុដូច្នោះ នេះជាអំពើទាស់របស់អ្នកហើយ នេះជាកំហុសរបស់អ្នកហើយ ម្នាលអានន្ទ ក្រែងតថាគតប្រាប់អ្នកជាមុនហើយយ៉ាងនេះថា សេចក្តីព្រាត់ប្រាស សេចក្តីវិនាស សេចក្តីប្រែប្រួលចាកសត្វ និងសង្ខារ ជាទីស្រឡាញ់ជាទីពេញចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ មិនព្រាត់ប្រាសក្នុងខន្ធប្រវត្តិនេះ អំពីទីណា ធម្មជាតណា កើតឡើងហើយ មានហើយ សង្ខារតាក់តែងហើយ តែងមានសេចក្តីវិនាសទៅជាធម្មតា ធម្មជាតនោះឯង បុគ្គលនឹងពោលឃាត់ថា កុំវិនាសដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ ។ ម្នាលអានន្ទ មួយទៀត ធម្មជាតណា ដែលតថាគតទាត់ចោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះបង់ចោលហើយ បន្សាត់ចោលហើយ

อายุสงฺขารตถาคตដាក់ចុះហើយ វាចាតថាគតពោលដោយពិតថា បរិនិព្វាន នៃតថាគតមិនយូរឡើយ កន្លង ๓ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វាន ហើយ តថាគតនឹងត្រឡប់មកកាន់ធម្មជាតនោះវិញទៀត ព្រោះហេតុនៃជីវិត ប៉ុណ្ណោះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ ម្នាលអានន្ទ មក យើងនឹងទៅកាន់កូដាគារសាលា នាព្រៃមហាវន ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ក៏ស្តេចចូលទៅកាន់កូដាគារសាលា នាព្រៃមហាវន មួយ អន្ទើដោយព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះ អានន្ទមានអាយុថា ម្នាលអានន្ទ អ្នកចូរទៅឲ្យពួកភិក្ខុទាំងប៉ុន្មាន ដែល អាស្រ័យនៅក្នុងក្រុងវេសាលីទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះ អង្គ ហើយក៏ឲ្យពួកភិក្ខុទាំងប៉ុន្មាន ដែលអាស្រ័យនៅក្នុងក្រុងវេសាលីទាំង អស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏ សមគួរ ។ លុះព្រះអានន្ទមានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាប បង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នា ហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ជ្រាបនូវកាលគួរក្នុងកាល ឥឡូវនេះ ។

[๑๐๗] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់ឧបដ្ឋាន-*

សាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅតាំងអស់កាលជ័យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំង-ឡាយណា ដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយៗ ដោយប្រការដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលជ័យូរ មួយទៀត សាសន-ព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ តើដូចម្តេច ។ អ្វីខ្លះ ។ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គ ប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បី

តាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសន-ព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណាដែលតថាគតសម្តែងហើយ ដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងជាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយ ចូរញុំាងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះមានព្រះភាគ ទ្រង់មានបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា

> *[១០៨] ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។ ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិត*

របស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

ព្រះសាស្តា ទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា

វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគតមានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយៗ ចុះ ។ ភិក្ខុណា មិនប្រមាទហើយនៅក្នុងធម៌វិន័យនេះ (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខាន ។

ពុទ្ធកាណវារទី ៣ ចប់

[១០៩] *គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ជាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរចូលទៅបិណ្ឌបាត ក្នុងក្រុងវេសាលី លុះស្តេចទៅបិណ្ឌបាត ក្នុងក្រុងវេសាលីហើយ ទ្រង់ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយភត្ត ទ្រង់ងាកក្រឡេកមើលនូវក្រុងវេសាលី ដូចជាដំរីដែលក្រឡេកបែរមើល (នូវទីខាងក្រោយ) ហើយត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ តថាគតឃើញក្រុងវេសាលីម្តងនេះជាបច្ឆិមទស្សនៈ (ការឃើញទីបំផុត) ម្នាលអានន្ទ មក យើងនឹងទៅកាន់កណ្ឌគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។*

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់កណ្ឌគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងកណ្ឌគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគបានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំង-ឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអនេ្ទាលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសង្សារវដ្ត) អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវធម៌ទាំង ៤ យ៉ាង ។ ធម៌ទាំង ៤ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអនេ្ទាលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសីល ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអនេ្ទាលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសមាធិ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអនេ្ទាលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអនេ្ទាលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយវិមុត្តិ ។ ម្នាលភិក្ខុទាំងឡាយ អរិយសីលនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយសមាធិដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយបញ្ញាដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ អរិយវិមុត្តិដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា គឺ

សេចក្តីប្រាថ្នាក្នុងកព ក៏សូន្យទៅ ខ្យែ គឺតណ្ហា ដែលអាចនាំសត្វអំពីកព មួយទៅកពមួយក៏អស់ទៅ កពថ្មីទៀត ក៏មិនមានក្នុងកាលឥឡូវនេះឡើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់ត្រាស់ដូច្នេះតទៅទៀតថា

> *[๑๑๐] ធម៌ទាំងនេះ គឺសីល សមាធិ បញ្ញា និងវិមុត្តិ ដ៏ប្រសើរ ព្រះគោតមព្រះអង្គមានយស បានត្រាស់ដឹងហើយ ព្រះពុទ្ធទ្រង់ត្រាស់ដឹងយ៉ាងនេះហើយ ទើបសម្តែងធម៌ប្រាប់ចំពោះភិក្ខុទាំងឡាយ ព្រះសាស្តាមានចក្ខុ ទ្រង់ធ្វើនូវព្រះនិព្វានជាទីបំផុត នៃកងទុក្ខ ទ្រង់បរិនិព្វានហើយ ។*

[๑๑๑] បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកណ្ឌគ្រាមនោះ ទ្រង់ធ្វើធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃចាកអាសវៈទាំងឡាយ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[๑๑๒] គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកណ្ឌគ្រាមតាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ហត្ថិគ្រាម អម្ពគ្រាម ជម្ពុគ្រាម និងកោគ-

นคร ฯ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ฯ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅដល់កោគនគរ ព្រមដោយភិក្ខុសង្ឃជាច្រើនអង្គ ฯ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអានន្ទចេតិយ ជិតកោគនគរនោះ ฯ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងមហាប្រទេសទាំង ๔ នេះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ฯ ភិក្ខុទាំងនោះទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ฯ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

[๑๑๓] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ខ្ញុំបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់ការសិតរបស់ភិក្ខុនោះឡើយ ฯ លុះអ្នកទាំងឡាយ មិនទាន់ត្រេក-អរ មិនទាន់ឃាត់ហើយ ត្រូវរៀនទូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយស្វាបសួងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យ ฯ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយស្វាបសួងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិន័យទៅហើយ មិនប្រជុំចុះ គឺមិនមានក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិន័យផងទេ ฯ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្ត ក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះទេ ជា

ពាក្យដែលភិក្ខុនេះរៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ត្រូវចោលពាក្យទុ៎ះចេញ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ សូបសូងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិនយទៅហើយ ក៏ប្រជុំចុះក្នុងព្រះសូត្រផង ប្រាកដក្នុងព្រះវិនយផង ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះ ដែលភិក្ខុនេះរៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាប្រទេសជាបឋមនេះចុះ ។

[១១៤] *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ព្រះសង្ឃនៅក្នុងអាវាសឯណោះ មានទាំងភិក្ខុជាថេរៈ មានទាំងភិក្ខុជាប្រធាន ខ្ញុំបានស្តាប់បានទទួលចំពោះមុខព្រះសង្ឃនោះថា នេះជាធម៌ នេះជាវិនយ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់នូវភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ ហើយត្រូវរៀននូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយសូងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិនយ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ សូងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិនយទៅហើយ មិនប្រជុំចុះក្នុងព្រះសូត្រផង មិនប្រាកដក្នុងព្រះវិនយផងទេ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគទេ ជាពាក្យដែលភិក្ខុសង្ឃនោះរៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ*

ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីចោលពាក្យទុ៎ះចេញ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយ សូងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិនយទៅហើយ ក៏ប្រជុំចុះក្នុងព្រះសូត្រផង ប្រាកដក្នុងព្រះវិនយផង ។ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះ ដែលព្រះសង្ឃនោះរៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាប្រទេសជាគម្រប់ពីរនេះចុះ ។

[๑๑๕] ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងអាវាសឯណោះ សុទ្ធតែជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិនយ ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់បានទទួលចំពោះមុខព្រះថេរៈទាំងនោះថា នេះជាធម៌ នេះជាវិនយ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរនឹងភាសិតរបស់ភិក្ខុនោះឡើយ ។បេ។ បទ និងព្យញ្ជនៈ មិនប្រាកដក្នុងព្រះវិនយ ។ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះមិនមែនជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះទេ ជាពាក្យដែលព្រះថេរៈទាំងនោះ រៀនខុសដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីចោលពាក្យទុ៎ះចេញ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយសូងមើលក្នុងព្រះសូត្រ ។បេ។ ប្រាកដក្នុងព្រះវិនយ ។ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះថា នេះជាព្រះពុទ្ធដីការបស់

ព្រះមានព្រះភាគនោះ ដែលព្រះថេរៈទាំងនោះ រៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសជាគម្រប់ ៣ នេះចុះ ។

[๑๑๖] *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គប្បីពោលយ៉ាងនេះថា ភិក្ខុជាថេរៈនៅក្នុងអាវាសឯណោះ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិនัย ទ្រទ្រង់មាតិកា ខ្ញុំបានស្តាប់ បានទទួលចំពោះមុខព្រះថេរៈអង្គនោះថា នេះជាធម៌ នេះជាវិនัย នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំអាលត្រេកអរ កុំអាលឃាត់នូវភាសិតរបស់ភិក្ខុនោះឡើយ ។ លុះអ្នកទាំងឡាយ មិនទាន់ត្រេកអរ មិនទាន់ឃាត់ហើយ គប្បីរៀននូវបទ និងព្យញ្ជនៈទាំងនោះឲ្យចាំល្អ ហើយសូងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិនัយ ។ បទ និងព្យញ្ជនៈទាំងនោះ កាលបើអ្នកទាំងឡាយសូងមើលក្នុងព្រះសូត្រ ប្រៀបធៀបមើលក្នុងព្រះវិនัយទៅហើយ មិនប្រជុំចុះក្នុងព្រះសូត្រផង មិនជ្រាកដក្នុងព្រះវិនัយផងទេ ។ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្តក្នុងពាក្យនេះ ។បេ។ ថានេះជាព្រះពុទ្ធដីការបស់ព្រះមានព្រះភាគនោះ ដែលព្រះថេរៈទាំងនោះរៀនត្រូវល្អហើយដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីចាំទុកនូវមហាបទេសជាគម្រប់ ๔ នេះចុះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីចាំទុកនូវមហាបទេសទាំង ๔ នេះឯង ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងអានន្ទចេតិយ ជិតភោគនគរនោះឯង ទ្រង់ធ្វើធម្មី-*

កថាជាច្រើនដល់ភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះដោយប្រពៃចាកអាសវៈទាំងឡាយ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

[๑๑๗] *គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងភោគនគរ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងបាវា ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរទៅដល់ក្រុងបាវា ព្រមដោយភិក្ខុសង្ឃជាច្រើន ។ បានឮថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងអម្ពវន (ព្រៃស្វាយ) របស់នាយចុន្ទកម្មារបុត្ត (កូនជាងមាស) ទៀបក្រុងបាវានោះ ។ នាយចុន្ទកម្មារបុត្ត បានឮដំណឹងថា ព្រះមានព្រះភាគស្តេចមកដល់ក្រុងបាវា ឥឡូវនេះទ្រង់គង់នៅក្នុងអម្ពវនរបស់អាត្មាអញ ទៀបក្រុងបាវា ។ គ្រានោះ នាយចុន្ទកម្មារបុត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។លុះនាយចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគក៏ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាយចុន្ទកម្មារបុត្ត កាលដែលព្រះមានព្រះភាគទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា*

ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូម ព្រះមានព្រះភាគ មួយអន្ទើដោយភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បី ឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លុះនាយចុន្ទកម្មារបុត្ត ជានដឹងច្បាស់ថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ ហើយ ក៏ក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ ទើបនាយចុន្ទកម្មារបុត្ត ក៏ឲ្យគេ ចាត់ចែងខាទនីយភោជនីយាហារមានរសដ៏ពីសា ព្រមទាំងសូករមទ្ទវៈដ៏ច្រើន ក្នុងផ្ទះរបស់ខ្លួនហើយ ឲ្យគេទៅក្រាបទូលភត្តកាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយ ស្តេចចូលទៅកាន់លំនៅរបស់នាយចុន្ទកម្មារបុត្ត ព្រមដោយភិក្ខុសង្ឃ លុះ ចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមាន ព្រះភាគទ្រង់គង់រួចហើយ ក៏ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទ សូករមទ្ទវៈណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសតថាគតដោយសូករ-មទ្ទវៈនោះចុះ ឯខាទនីយភោជនីយាហារដទៃណា ដែលអ្នកតាក់តែងហើយ ចូរអ្នកអង្គាសភិក្ខុសង្ឃដោយខាទនីយភោជនីយាហារនោះចុះ ។ នាយចុន្ទ-កម្មារបុត្ត ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះ អង្គ ហើយក៏អង្គាសព្រះមានព្រះភាគ ដោយសូករមទ្ទវៈដែលខ្លួនតាក់តែង ហើយ អង្គាសភិក្ខុសង្ឃដោយខាទនីយភោជនីយាហារដទៃ ដែលខ្លួនតាក់តែង

ហើយ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់នឹងនាយចុន្ទកម្មារបុត្តថា ម្នាលនាយចុន្ទ សូករមទ្ទវៈណារបស់អ្នកដែលនៅសល់ អ្នកចូរកប់នូវសូករមទ្ទវៈនោះក្នុងរណ្តៅទៅ ម្នាលនាយចុន្ទ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារ-លោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញបុគ្គលណាមួយ ដែលបរិភោគនូវសូករមទ្ទវៈនោះហើយ សូករមទ្ទវៈនោះគប្បីដល់នូវកិរិយារលួយទៅដោយល្អទេ្បីយ រៀវលែងតែតថាគតចេញ ។ នាយចុន្ទកម្មារបុត្តទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គហើយ ក៏កប់សូករមទ្ទវៈដែលនៅសល់នោះក្នុងរណ្តៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាយចុន្ទកម្មារបុត្ត អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគក៏ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈស្តេចចេញទៅ ។ លុះព្រះមានព្រះភាគ ទ្រង់ធាន់កត្តរបស់នាយចុន្ទកម្មារបុត្តរួចហើយ ព្រះអាពាធដ៏ខ្លាំងក៏កើតទេ្បីង វេទនាដ៏ក្បៀវក្បាកើតអំពីលោហិតប្បក្ខន្ទិកាពាធ (អាពាធចុះព្រះលោហិត) ជិតនឹងដល់នូវមរណៈ ក៏ប្រព្រឹត្តទៅ ។ បានឮថា ព្រះមានព្រះភាគមានព្រះសតិ និងសម្ប-ជញ្ញៈ មិនបានលំបាក ទ្រង់អត់សង្កត់នូវវេទនានោះបាន ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងកុសិនារា ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលនៃព្រះ

មានព្រះភាគថា ព្រះកុរុណាព្រះអង្គ ។

[១១៨] ខ្ញុំបានឮថា ព្រះពុទ្ធជាអ្នកជ្រាជ្រ ទ្រង់សោយភត្ត របស់នាយចុន្ទកម្មារបុត្ត ហើយមានព្រះអាពាធជាទម្ងន់ ជិតនឹងមរណៈ ។ ព្យាធិដ៏ក្លា កើតជល់ព្រះសាស្តា ដែលសោយភត្ត ដោយសូករមទ្ទវៈ ព្រះមានព្រះភាគ ទ្រង់មានអាពាធ ចុះព្រះលោហិតរឿយៗ ទើបមានព្រះពុទ្ធតម្រាស់ថា តថាគត នឹងទៅកាន់ក្រុងកុសិនារា ។

(គាថាទាំងនេះ ព្រះសង្គីតិកាចារ្យទាំងឡាយ សម្តែងហើយ ក្នុងកាលធ្វើសង្គីតិ) ។

[១១៩] គ្រានោះ ព្រះមានព្រះភាគទ្រង់ចៀសចេញអំពីផ្លូវ ហើយទ្រង់ចូលទៅកាន់ម្លប់ឈើមួយលុះចូលដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដិ មានជាន់ ៤ ឲ្យតថាគតដោយធាប់ ម្នាលអានន្ទ តថាគតល្វើតល្វែណាស់ តថាគតអង្គុយចុះសិន ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះកុរុណាព្រះអង្គ ហើយក៏ក្រាលសង្ឃាដិមានជាន់ ៤ ថ្វាយ ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគគង់រួចហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយធាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងផាន់ទឹកបន្តិច ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទ

មានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញ្ញនេះ រនេះចំនួន ៥០០ គេបរឆ្លងទៅហើយ ទឹកនោះតិច កង់រនេះក៏កិន ល្អក់រឹកវរ ហូរមក បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងកកុធៈនៅជិតនេះ មានទឹកថ្លា មានទឹកមានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករង មានកំពង់ក៏ស្រួល ជាទីគួរត្រេកអរ ក្នុងស្ទឹងនុ៎ះ ព្រះមានព្រះភាគនឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ស្រួលក៏បាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុជាគម្រប់ពីរដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹកមកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញ្ញនេះ រនេះចំនួន ៥០០ គេបរឆ្លងទៅហើយ ទឹកនោះតិច កង់រនេះក៏កិន ល្អក់រឹកវរ ហូរមក បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងកកុធៈនៅជិតនេះ មានទឹកថ្លា មានទឹកមានរសជាតិស្រួល មានទឹកត្រជាក់ មានទឹករង មានកំពង់ក៏ស្រួល ជាទីគួរត្រេកអរ ក្នុងស្ទឹងនុ៎ះ ព្រះមានព្រះភាគនឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយឲ្យត្រជាក់ស្រួលក៏បាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុជាគម្រប់បីដងទៀតថា ម្នាលអានន្ទ ចូរអ្នកទៅដងទឹក មកឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កាន់បាត្រដើរតម្រង់ទៅស្ទឹងនោះ ។ លំដាប់នោះ

ស្ទឹងតូច ដែលកង់កិន ល្អក់វឹកវរ ហូរមកនោះ កាលដែលព្រះអានន្ទមានអាយុ ចូលទៅដល់ហើយ ក៏ត្រឡប់ទៅជាវង់ថ្ងា មិនល្អក់ហូរមកវិញ ។ ទើបព្រះអានន្ទ មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ ហេតុនេះជាអស្ចារ្យពេកណាស់ ឱហ្ន៎ ហេតុនេះចម្លែកពេកណាស់ ស្ទឹងតូចនេះឯងដែលកង់កិនល្អក់វឹកវរ ហូរមក កាលបើអាត្មាអញចូលមកជល់ ក៏ត្រឡប់ទៅជាទឹកវង់ថ្ងាស្អាតមិនល្អក់ ហូរមកវិញ ព្រោះព្រះតថាគតមានឫទ្ធិធំ មានអានុភាពធំ ។ ព្រះអានន្ទក៏ជង់ទឹកដោយបាត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅជល់ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ស្ទឹងតូចដែលកង់កិន ល្អក់វឹកវរ កំពុងហូរមកនោះ កាលដែលខ្ញុំព្រះអង្គចូលទៅជល់ហើយ ក៏ត្រឡប់ទៅជាទឹកវង់ថ្ងាស្អាត មិនល្អក់ ហូរមកវិញ ព្រោះព្រះអង្គមានឫទ្ធិធំ មានអានុភាពធំ សូមព្រះមានព្រះភាគ ទ្រង់សោយព្រះសុទ្ធរស សូមព្រះសុគត ទ្រង់សោយព្រះសុទ្ធរស ។ លំដាប់នោះ ព្រះមានព្រះភាគក៏ទ្រង់សោយព្រះសុទ្ធរស ។

[๑๒๐] *សម័យនោះឯង មល្លបុត្ត (ព្រះរាជបុត្តនៃមល្លក្សត្រិយ៍) ព្រះនាមបុក្កុសៈ ជាសាវ័ករបស់អាឡារគាបស កាលាមគោត្ត ចេញអំពីក្រុងកុសិនារា ដើរទៅតាមផ្លូវឆ្ងាយ សំដៅទៅកាន់ក្រុងបាវា ។ បុក្កុសមល្លបុត្តបានឃើញព្រះមានព្រះភាគ គង់ក្រោមម្លប់ឈើមួយ លុះឃើញហើយ ក៏ចូល*

ទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមាន ព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ បុក្កុសមល្លបុត្ត លុះគង់ក្នុងទីសមគួរ ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ អស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ចម្លែកពេក ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពួកបព្វជិតតែងនៅដោយវិហារធម៌ដ៏ស្ងប់ រម្ងាប់ បពិត្រព្រះអង្គដ៏ចម្រើន មានរឿងពីដើមថា អាឡារតាបស កាលាម-គោត្ត ដើរទៅកាន់ផ្លូវឆ្ងាយ ហើយចេញអំពីផ្លូវ ចូលទៅអង្គុយសម្រាក នៅ ក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ នៅជិតផ្លូវ បពិត្រព្រះអង្គដ៏ចម្រើន កាល នោះ មានរទេះចំនួន ៥០០ កន្ទុងហួសទៅក្បែរៗ នឹងអាឡារតាបស កាលាមគោត្ត បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ មានបុរសម្នាក់ដើរមកតាម ក្រោយពួករទេះនោះ ចូលសំដៅទៅរកអាឡារតាបសកាលាមគោត្ត លុះចូល ទៅដល់ហើយ បាននិយាយពាក្យនេះនឹងអាឡារតាបសកាលាមគោត្តថា បពិត្រ តាបសដ៏ចម្រើន លោកម្ចាស់បានឃើញរទេះចំនួន ៥០០ កន្ទុងហួសទៅ ហើយដែរឬ (អាឡារតាបសឆ្លើយថា) ម្នាលអាវុសោ យើងមិនបាន ឃើញទេ (បុរសនោះសួរទៀតថា) បពិត្រតាបសដ៏ចម្រើន ចុះលោក ម្ចាស់ បានឮសូរសំឡេងដែរឬ ម្នាលអាវុសោ យើងមិនបានឮសូរសំឡេងទេ បពិត្រតាបសដ៏ចម្រើន ចុះលោកម្ចាស់សិងលក់ឬអ្វី ម្នាលអាវុសោ យើង មិនបានដេកលក់ទេ បពិត្រតាបសដ៏ចម្រើន ចុះលោកម្ចាស់មានសញ្ញាដែរឬ ម្នាលអាវុសោ អើ យើងមានសញ្ញាដែរ បពិត្រតាបសដ៏ចម្រើន លោកម្ចាស់

មានសញ្ញានៅភ្រាក់រពក មិនបានឃើញរទេះចំនួន ៥០០ កន្ធងហួសទៅក្បែរៗ ខ្លួន ទាំងមិនបានឲសូរ បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះសង្ឆាដិរបស់លោកម្ចាស់ ប្រឡាក់ដោយធូលីដែរឬ ម្នាលអាវុសោ ប្រឡាក់ដែរ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ បុរសនោះ មានសេចក្តីត្រិះរិះដូច្នេះថា ឧហ្នឹ ហេតុនេះ អស្ចារ្យពេកណាស់ ឧហ្នឹ ហេតុនេះចម្លែកពេកណាស់ ពួកបព្វជិតតែងនៅ ដោយវិហារធម៌ដ៏ស្ងប់រម្ងាប់ ព្រោះថា តាបសមានសញ្ញានៅភ្រាក់រពក តែមិនបានឃើញរទេះចំនួន ៥០០ កន្ធងហួសទៅក្បែរៗ ខ្លួន ។ ទាំងមិនបានឲសូរ ហើយបុរសនោះ ក៏កើតសេចក្តីជ្រះថ្លាក្រៃលែង ក្នុងអាឡារតាបសកាលាម-គោត្ត ហើយចៀសចេញទៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលបុក្កុសៈ អ្នកសម្គាល់ហេតុនោះដូចម្តេច បុគ្គលណាមួយ មានសញ្ញានៅភ្រាក់រពក មិនបានឃើញរទេះចំនួន ៥០០ ដែលកន្ធងហួសទៅក្បែរៗ ខ្លួន ទាំងមិនបានឲសូរ បុគ្គលណាមួយ មានសញ្ញានៅភ្រាក់រពក កាលដែលភ្លៀងកំពុងបង្អុរចុះ កាលដែលភ្លៀងកំពុង ធ្វើសំឡេងឈូធរ កាលដែលផ្លេកបន្ទោរកំពុងភ្លឺច្រវាត់ កាលដែលរន្ទះកំពុងបាញ់ ក៏មិនបានឃើញ ទាំងមិនបានឲសូរ (បណ្តាហេតុរបស់បុគ្គលទាំងពីរនោះ) ហេតុណាហ្នឹ ដែលធ្វើបានដោយកម្រ ឬដែលមានដោយកម្រជាងគេ ។ បុក្កុសមល្ជបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន រទេះ ៥០០ ក្តី រទេះ ៦០០ ក្តី រទេះ ៧០០ ក្តី រទេះ ៨០០ ក្តី រទេះ ៩០០ ក្តី រទេះ ១០០០ ក្តី ។បេ។ រទេះ ១ សែនក្តី នឹងធ្វើប្រយោជន៍ដូចម្តេច បុគ្គលណាមួយ មានសញ្ញានៅភ្រាក់រពក កាលដែលភ្លៀងកំពុងបង្អុរចុះ កាលដែល

ភ្លៀងកំពុងធ្លើសំឡេងឈូឆរ កាលដែលផ្គេកបន្ទោរកំពុងភ្លឺច្រវាត់ កាលដែលរន្ទះកំពុងបាញ់ ក៏មិនបានឃើញ ទាំងមិនបានឮសូរ ហេតុនេះឯងរបស់បុគ្គលនោះជាហេតុដែលធ្វើបានដោយកម្រផង ដែលមានដោយកម្រផងដោយពិត ។

[១២១] *ម្នាលបុក្កុសៈ សម័យមួយ តថាគតនៅក្នុងរោងលានស្មូវទៀបស្រុកអាតុមាឯណោះ ។ ក៏សម័យនោះឯង ភ្លៀងកំពុងបង្អុរចុះ ភ្លៀងកំពុងធ្លើសំឡេងឈូឆរ ផ្គេកបន្ទោរកំពុងភ្លឺច្រវាត់ រន្ទះកំពុងបាញ់ មានអ្នកស្រែជាបងប្អូនទីងគ្នាពីរនាក់ និងគោ ៤ ត្រូវរន្ទះបាញ់ស្លាប់ ជិតរោងលានស្មូវ ។ ម្នាលបុក្កុសៈ កាលនោះឯង ពួកមហាជនចេញចាកស្រុកអាតុមាចូលទៅកាន់ទីនៃបុរសអ្នកស្រែពីរនាក់បងប្អូន និងគោទាំង ៤ ដែលរន្ទះបាញ់ស្លាប់នោះ ។ ម្នាលបុក្កុសៈ សម័យនោះឯង តថាគតចេញអំពីលានស្មូវដើរចង្រ្កមទៅក្នុងទីវាល ជិតទ្វាររោងលានស្មូវ ។ ម្នាលបុក្កុសៈ កាលនោះមានបុរសម្នាក់ចេញអំពីពួកមហាជននោះ ចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីសមគួរ ។ ម្នាលបុក្កុសៈ លុះបុរសនោះឋិតនៅក្នុងទីសមគួរហើយ តថាគតក៏និយាយដូច្នេះថា ម្នាលអាវុសោ ពួកមហាជននោះប្រជុំគ្នាអំពីរឿងអ្វី ។ បុរសនោះឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ កាលដែលភ្លៀងកំពុងបង្អុរចុះ កាលដែលភ្លៀងកំពុងធ្លើសំឡេងឈូឆរ កាលដែលផ្គេកបន្ទោរកំពុងភ្លឺច្រវាត់ កាលដែលរន្ទះកំពុងបាញ់ ក៏បាញ់ត្រូវអ្នកស្រែពីរនាក់ជាបងប្អូន និងគោទាំង ៤ ស្លាប់ទៅ ពួកមហាជននោះប្រជុំគ្នា ព្រោះហេតុនេះឯង បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះ*

អង្គទ្រង់គង់នៅក្នុងទីណា ។ តថាគតឆ្លើយថា ម្នាលអាវុសោ តថាគតនៅក្នុងភេងលានស្រូវនេះ ។ បុរសនោះ ក្រាបបង្គំទូលសួរថា ចុះព្រះអង្គបានទ្រង់ទតឃើញឬទេ ។ តថាគតឆ្លើយថា ម្នាលអាវុសោ តថាគតមិនបានឃើញទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គបានឮសូរសំឡេងទេ ។ ម្នាលអាវុសោ តថាគតមិនបានឮសូរសំឡេងទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គផ្តិលក់ឬអ្វី ។ ម្នាលអាវុសោ តថាគតមិនបានលក់ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គមានសញ្ញាដែរឬ ។ ម្នាលអាវុសោ តថាគតមានសញ្ញាដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គមានសញ្ញានៅក្រាក់រឭក កាលដែលភ្លៀងកំពុងបង្អុរចុះ កាលដែលភ្លៀងកំពុងធ្លើសំឡេងឈូឆរ កាលដែលផ្ទេកបន្ទោរកំពុងភ្លឺច្រវាត់ កាលដែលរន្ទះកំពុងបាញ់ ទ្រង់មិនបានឃើញ ទាំងមិនបានឮសូរសំឡេងទេឬ ។ អើអាវុសោ ។ ម្នាលបុក្កុសៈ គ្រានោះ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ហេតុនេះ ជាអស្ចារ្យពេកណាស់ ឱហ្ន៎ ហេតុនេះចម្លែកពេកណាស់ ឱហ្ន៎ ពួកបព្វជិតតែងនៅដោយវិហារធម៌ដ៏ស្ងប់រម្ងាប់មែន ព្រោះថា បុគ្គលដែលមានសញ្ញានៅក្រាក់រឭក កាលដែលភ្លៀងកំពុងបង្អុរចុះ កាលដែលភ្លៀងកំពុងធ្លើសំឡេងឈូឆរ កាលដែលផ្ទេកបន្ទោរកំពុងភ្លឺច្រវាត់ កាលដែលរន្ទះកំពុងបាញ់ ឥតបានឃើញទាំងមិនបានឮសូរសោះ ។ បុរសនោះ ក៏កើតសេចក្តីជ្រះថ្លាដោយក្រៃលែងចំពោះតថាគត ហើយធ្វើប្រទក្សិណ ដើរចេញទៅ ។ លុះព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ បុក្កុសមល្លបុត្ត ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះ

ថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីជ្រះថ្លាណារបស់ខ្ញុំព្រះអង្គ ដែលកើតឡើងក្នុងអាឡារគាបសកាលាមគោត្ត ខ្ញុំព្រះអង្គនេះរោយចោលនូវសេចក្តីជ្រះថ្លានោះ ក្នុងទីមានខ្យល់ច្រើនផង បណ្តែតចោលក្នុងស្ទឹង ដែលមានខ្សែទឹកហូរហាស់ផង បពិត្រព្រះអង្គដ៏ចម្រើន កាសិតរបស់ព្រះអង្គ ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន កាសិតរបស់ព្រះអង្គ ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលផ្ងារឡើងនូវរបស់ដែលគេផ្តាច់ក្តី បើកឡើងនូវរបស់ដែលគេគ្របទុកក្តី ចង្អុលប្រាប់ផ្លូវដល់បុរសដែលវង្វេងផ្លូវក្តី ទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា អ្នកមានចក្ខុនឹងបានឃើញរូបក្តី យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ ចាប់ដើមអំពីថ្ងៃនេះតទៅ សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរ-ណាគមន៍ ស្មើដោយជីវិត ។ គ្រានោះ បុក្កុសមល្លបុត្ត ហៅបុរសម្នាក់ថា ម្នាលនាយ ចូរអ្នកទៅយកសំពត់ដែលមានសាច់ម៉ដ្ត ១ គូ មានសម្បុរដូចមាសសិង្គី ដែលខ្ញុំគួរប្រើប្រាស់ (ម្តងៗ) មកដោយឆាប់ ។ បុរសនោះទទួលបន្ទូលបុក្កុសមល្លបុត្តថា ព្រះករុណាម្ចាស់ ហើយក៏ទៅយកសំពត់ដែលមានសាច់ម៉ដ្ត ១ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្តងៗ) នោះ ។ ទើបបុក្កុសមល្លបុត្ត បង្ហោនូវសំពត់ដែលមានសាច់ម៉ដ្ត ១ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្តងៗ) នោះ ចំពោះ

ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ដែលមានសាច់ម៉ដ្ដ ๑ គូ មានសម្បុរដូចមាសសិង្គីនេះ ជាសំពត់ដែលខ្ញុំព្រះអង្គប្រើប្រាស់ (ម្ដងៗ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទទួលនូវសំពត់នោះ ដោយអាស្រ័យនូវសេចក្ដីអនុគ្រោះដល់ខ្ញុំព្រះអង្គចុះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលបុក្កុសៈ បើដូច្នោះ អ្នកចូរឲ្យសំពត់ ๑ មកតថាគត ឲ្យសំពត់ ๑ ទៅអានន្ទចុះ ។ បុក្កុសមល្លបុត្ត ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ថ្វាយសំពត់ ๑ ទៅព្រះមានព្រះភាគ ប្រគេនសំពត់ ๑ ទៅព្រះអានន្ទមានអាយុ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ញុំាងបុក្កុសមល្លបុត្ត ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ គ្រានោះ បុក្កុសមល្លបុត្ត កាលដែលព្រះមានព្រះភាគ ទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណាចេញទៅ ។

[๑๒๒] *លុះបុក្កុសមល្លបុត្ត ចេញទៅមិនទាន់យូរប៉ុន្មាន ព្រះអានន្ទដ៏មានអាយុ ក៏យកសំពត់ដែលមានសាច់ម៉ដ្ដ ๑ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្ដងៗ) នោះ ទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគ ។ ឯសំពត់ដែលព្រះអានន្ទយកទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគនោះ (ក៏អាប់សម្បុរ) ច្រោកដូចជារងើកភ្លើង ដែលច្រោសចាកអណ្ដាតភ្លើង ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុ*

នេះចម្ងៃកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះឆវីវណ្ណរបស់ព្រះតថាគត ស្អាតបរិសុទ្ធផូរផង់ជាល់ម្ល៉ោះ បពិត្រព្រះអង្គដ៏ចម្រើន សំពត់ដែលមានសាច់ ម៉ដ្ត ១ គូ មានសម្បុរដូចមាសសិង្គី ដែលគួរប្រើប្រាស់ (ម្តង។) នេះ ដែលខ្ញុំព្រះអង្គយកទៅបំពាក់ព្រះកាយនៃព្រះមានព្រះភាគ (ក៏អាប់សម្បុរ) ប្រាកដដូចជារងើកភ្លើង ដែលប្រាសចាកអណ្តាតភ្លើង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ហេតុនេះយ៉ាងនេះឯង ម្នាលអានន្ទ កាយតថាគត ស្អាត ឆវីវណ្ណក៏បរិសុទ្ធ ផូរផង់ក្រៃពេក ក្នុងកាលទាំងពីរ កាលទាំងពីរតើ ដូចម្តេច ម្នាលអានន្ទ កាលតថាគតបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ-ញ្ញាណ ក្នុងរាត្រីណា ១ កាលតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វាន-ធាតុក្នុងរាត្រីណា ១ ម្នាលអានន្ទ កាយតថាគតស្អាត ឆវីវណ្ណក៏បរិសុទ្ធ ផូរផង់ក្រៃពេកក្នុងកាលទាំងពីរនេះឯង ម្នាលអានន្ទ ក្នុងយាមជាទីបំផុតនៃ រាត្រីនេះឯង បរិនិព្វានទីងមានដល់តថាគត ក្នុងចន្លោះនៃដើមសាលព្រឹក្ស ទាំងគូ ក្នុងសាលវនរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុងកុសិ-នារា ម្នាលអានន្ទ មក យើងនឹងទៅកាន់ស្ទឹងកកុធៈ ។ ព្រះអានន្ទដ៏មាន អាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[១២៣] *បុក្កុសមល្លបុត្ត ថ្វាយនូវសំពត់ មានសាច់ ម៉ដ្តមួយគូ មានសម្បុរដូចមាសសិង្គី (ចំពោះព្រះសាស្តា) ព្រះសាស្តា ដែលព្រះអានន្ទនោះថ្វាយ ឲ្យទ្រង់សាជក ហើយ ក៏មានសម្បុរដូចព្រះចន្ទល្អរុងរឿង ។*

[១២៤] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់ស្ទឹងកកុធៈ ព្រមដោយភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ស្តេចចុះកាន់ស្ទឹងកកុធៈ ស្រង់ផង សោយផង ហើយស្តេចត្រឡប់ឡើងវិញ ក៏ចូលទៅរកអម្ពវន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់ហៅព្រះចុន្ទកៈមានអាយុមកថា ម្នាលចុន្ទកៈ ចូរអ្នកក្រាលសង្ឃាដិមានជាន់ ៤ ឲ្យតថាគតដោយឆាប់ ម្នាលចុន្ទកៈ តថាគតល្វិតល្វៃណាស់ តថាគតនឹងសិង ។ ព្រះចុន្ទកៈមានអាយុទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ក្រាលសង្ឃាដិមានជាន់ ៤ ថ្វាយ ។ ទើបព្រះមានព្រះភាគ ទ្រង់សម្រេចសីហ-សេយ្យាផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំ ទ្រង់មានព្រះសតិ និងសម្បជញ្ញៈ ធ្វើទុកក្នុងព្រះទ័យនូវឧដ្ឋានសញ្ញា (សេចក្តីសម្គាល់ថា នឹងក្រោកឡើងវិញ) ។ ឯព្រះចុន្ទកៈមានអាយុ ក៏អង្គុយចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ក្នុងទីនោះឯង ។*

[១២៥] *ព្រះពុទ្ធទ្រង់ស្តេចទៅកាន់ស្ទឹងកកុធៈ ដែលមានទឹកថ្លា មានទឹកមានរសជាតិ មានទឹកស្អាត ព្រះតថាគតជាសាស្តា ឥតមានបុគ្គលប្រៀបផ្ទឹម ក្នុងលោក ទ្រង់មិនលំបាកព្រះកាយ ស្តេចចុះ (កាន់ស្ទឹង) ។ ព្រះសាស្តាទ្រង់ស្រង់ផង ទ្រង់សោយផងនូវទឹកនោះ ហើយគង់ក្នុងទីកណ្តាលនៃពួកភិក្ខុ ដែលគាល់ព្រះមានព្រះភាគជាសាស្តា ជាមហេសី (អ្នកស្វែងរកគុណធំ) ព្រះអង្គ*

ញុំងធម៌ឲ្យប្រព្រឹត្តទៅក្នុងសាសនានេះ ទ្រង់ស្តេចចូលទៅកាន់អម្ពវន ។ ទ្រង់ត្រាស់ហៅចុន្ទកភិក្ខុមកថា អ្នកចូរក្រាលសង្ឃាដិមានជាន់ ៤ ឲ្យតថាគតដេកយ៉ាប់ តថាគតនឹងសិង ព្រះចុន្ទកភិក្ខុនោះ កាលដែលព្រះសាស្តា មានព្រះអង្គចម្រើនហើយ ទ្រង់ត្រាស់បង្គាប់ហើយ ក៏ក្រាលសង្ឃាដិមានជាន់ ៤ ថ្វាយដោយប្រញាប់ ព្រះសាស្តាមិនលំបាកព្រះកាយ ទ្រង់ផ្ងុំហើយ ឯព្រះចុន្ទកភិក្ខុ ក៏អង្គុយគាល់ចំពោះព្រះភក្ត្រក្នុងទីនោះ ។

[១២៦] *គ្រានោះ ព្រះមានព្រះភាគ បានត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ បើមានបុគ្គលណាមួយ ញុំងសេចក្តីក្តៅក្រហាយស្តាយក្រោយ ឲ្យកើតឡើង ដល់ចុន្ទកម្មារបុត្តថា ម្នាលអាវុសោចុន្ទៈ អ្នកពេញហៅជាមនុស្សឥតលាភ អត្តភាពជាមនុស្ស ក៏អ្នកបានដោយអាក្រក់ ព្រោះព្រះតថាគតសោយបច្ឆិមបិណ្ឌបាតរបស់អ្នកហើយទ្រង់បរិនិព្វាន ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់សេចក្តីក្តៅក្រហាយស្តាយក្រោយ របស់ចុន្ទកម្មារបុត្តយ៉ាងនេះថា ម្នាលអាវុសោចុន្ទៈ អ្នកពេញហៅជាមនុស្សមានលាភ អត្តភាពជាមនុស្សអ្នកបានដោយប្រពៃហើយ ព្រោះថាព្រះតថាគតទ្រង់សោយបច្ឆិមបិណ្ឌបាតរបស់អ្នកហើយ ទ្រង់បរិនិព្វាន ម្នាលអាវុសោចុន្ទៈ ពាក្យនេះយើងបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដូច្នេះថា ចង្ហាន់បិណ្ឌបាតទាំងពីរនេះ មានផលស្មើៗ គ្នា មានវិបាកស្មើៗ គ្នា មានផលច្រើន*

ផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ ចង្ហាន់បិណ្ឌបាតទាំងពីរ តើដូចម្តេច ។ គឺព្រះតថាគត ទ្រង់សោយចង្ហាន់បិណ្ឌបាតណាហើយ ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ១ ព្រះតថាគតទ្រង់សោយចង្ហាន់បិណ្ឌបាតណាហើយ ទ្រង់បរិនិព្វានដោយអនុបាទិសេស-និព្វានធាតុ ១ ចង្ហាន់បិណ្ឌបាតទាំងពីរនេះឯង មានផលស្មើៗ គ្នា មានវិបាកស្មើៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ បុញ្ញកម្មដែលញុំាងអាយុឲ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្តមានអាយុ ក៏បានសន្សំហើយ បុញ្ញកម្មដែលញុំាងសម្បុរឲ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្តមានអាយុ ក៏បានសន្សំហើយ បុញ្ញកម្មដែលញុំាងសេចក្តីសុខឲ្យប្រព្រឹត្តទៅ ។បេ។ ញុំាងយសឲ្យប្រព្រឹត្តទៅ ។បេ។ ញុំាងឋានសួគ៌ឲ្យប្រព្រឹត្តទៅ ។បេ។ ញុំាងការៈជាធំឲ្យប្រព្រឹត្តទៅ ចុន្ទកម្មារបុត្តមានអាយុ ក៏បានសន្សំហើយ ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់សេចក្តីក្តៅក្រហាយ ស្តាយក្រោយរបស់ចុន្ទកម្មារ-បុត្ត យ៉ាងនេះឯង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ទ្រង់បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា

[๑๒๗] បុណ្យរមែងចម្រើនដល់អ្នកឲ្យទាន វេរាមិនចម្រើនដល់បុគ្គលអ្នកសង្រួម បុគ្គលអ្នកឈ្លាស (បរិបូណ៌ដោយញាណ) រមែងលះបង់នូវអំពើលាមកបាន បុគ្គលនោះក៏បរិនិព្វាន ព្រោះអស់រាគៈ ទោសៈ មោហៈ ។

ពុទ្ធកាណវារទី ๔ ចប់

[១២៨] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ស្តេចទៅកាន់ត្រើយខាងនាយ នៃស្ទឹងហិរញ្ញវតី នឹងចូលទៅកាន់សាលវ័នរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ព្រមដោយភិក្ខុសង្ឃជាច្រើន លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នករៀបចំគ្រែឲ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ ឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសិង ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយរៀបចំគ្រែ ឲ្យមានក្បាលដំណេក បែរទៅទិសខាងជើង ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូថ្វាយ គ្រានោះ ព្រះមានព្រះភាគមានព្រះសតិសម្បជញ្ញៈ ទ្រង់សម្រេចសីហសេយ្យា ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេង តម្រួតលើព្រះបាទស្តាំ ។

[១២៩] សម័យនោះឯង សាលព្រឹក្សទាំងគូ ក៏មានផ្ការីកស្គុះស្គាយទាំងអស់ (តាំងពីគល់ដល់ចុង) ដោយអកាលបុប្ផ (ផ្កាពុំជួកាល) សាលព្រឹក្សទាំងគូនោះ ក៏រោយរាយ បាចសាច (នូវផ្កា) លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត សូម្បីមន្ទារវបុស្ប (ផ្កាមន្ទារវៈ) ជាទិព្វ

ក៏ធ្លាក់ចុះមកអំពីអាកាស ផ្កាទាំងនោះ ក៏រោយរាយ បាចសាច លើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងលម្អិតខ្ញីមចន្ទន៍ជាទិព្វ ក៏ធ្លាក់ចុះមកអំពីអាកាស លម្អិតទាំងនោះក៏រោយរាយ បាចសាចលើសរីរៈព្រះតថាគត ដើម្បីបូជាព្រះតថាគត ។ ទាំងតូរ្យតន្ត្រីជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ទាំងចម្រៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាព្រះតថាគត ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ សាលព្រឹក្សទាំងគូ មានផ្កាវែកស្គុះស្គាយទាំងអស់ (តាំងអំពីគល់ដរាបដល់ចុង) ដោយអកាលបុប្ផ រោយរាយ បាចសាចលើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងផ្កាមន្ទារវៈជាទិព្វ ធ្លាក់ចុះអំពីអាកាស ផ្កាទាំងនោះ រោយរាយ បាចសាច លើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងលម្អិតខ្ញីមចន្ទន៍ជាទិព្វ ធ្លាក់ចុះអំពីអាកាស លម្អិតទាំងនោះ រោយរាយ បាចសាច លើសរីរៈតថាគត ដើម្បីបូជាតថាគត ទាំងតូរ្យតន្ត្រីជាទិព្វក៏លាន់ឮឯអាកាស ដើម្បីបូជាតថាគត ទាំងចម្រៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាតថាគត ម្នាលអានន្ទ ព្រះតថាគតមិនបានឈ្មោះថា បរិសទ្យធ្វើសក្ការៈក្តី គោរពក្តី រាប់អានក្តី បូជាក្តី និងកោតក្រែងក្តី ដោយហេតុមានប្រមាណប៉ុណ្ណេះឡើយ ម្នាលអានន្ទ បុគ្គលណាមួយទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ម្នាលអានន្ទ ព្រោះហេតុនោះ បរិសទ្យក្នុងសាសនានេះ គប្បី

សិក្សាថា យើងទាំងឡាយ នឹងប្រតិបត្តិនូវធម៌ សមគួរដល់ធម៌ ប្រតិបត្តិ ដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បី សិក្សាយ៉ាងនេះឯង ។

[๑๓๐] *សម័យនោះឯង ឧបវាណភិក្ខុមានអាយុបិតនៅចំពោះព្រះ កក្តែនៃព្រះមានព្រះភាគ កំពុងបក់ថ្វាយព្រះមានព្រះភាគ ។ គ្រានោះ ព្រះ មានព្រះភាគ ទ្រង់បណ្តេញឧបវាណមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀស ចេញ អ្នកកុំបិតនៅខាងមុខតថាគតឡើយ ។ គ្រានោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះឧបវាណមានអាយុនេះ ជាឧបដ្ឋាកធ្លាប់នៅជិត ដើរជិតព្រះមានព្រះភាគ ជាយូរហើយ ទើបតែក្នុងបច្ឆិមកាល (នេះ) ព្រះមានព្រះភាគទ្រង់បណ្តេញឧបវាណមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀស ចេញ អ្នកកុំបិតនៅខាងមុខតថាគតឡើយ ដូច្នេះ មានហេតុដូចម្តេច មាន បច្ច័យដូចម្តេច បានជាព្រះមានព្រះភាគ ទ្រង់បណ្តេញឧបវាណមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំបិតនៅ ខាងមុខតថាគតឡើយ ។ ទើបព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះ អង្គដ៏ចម្រើន ព្រះឧបវាណមានអាយុ នេះជាឧបដ្ឋាកនៅជិត ដើរជិតព្រះមាន ព្រះភាគជាយូរហើយ ទើបតែក្នុងបច្ឆិមកាល (នេះ) ព្រះមានព្រះភាគទ្រង់ បណ្តេញឧបវាណមានអាយុថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំបិតនៅ ខាងមុខតថាគតឡើយ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេច បានជាព្រះមានព្រះភាគទ្រង់បណ្តេញឧបវាណមានអាយុ*

ថា ម្នាលភិក្ខុ អ្នកចូរចៀសចេញ អ្នកកុំបីតនៅខាងមុខតថាគតឡើយ ដូច្នេះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ទេវតាក្នុងលោកធាតុទាំង ១០ ប្រជុំគ្នា ដើម្បីមើលតថាគតដោយច្រើន ម្នាលអានន្ទ សាលវនៃរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា មានចំនួន ១២ យោជន៍ដោយជុំវិញ មានកំណត់ត្រឹមណា ប្រទេសនោះ សូម្បីគ្រាន់តែល្មមចាក់ដោយចុងបំផុតនៃសក់ ដែលទេវតាមានសក្តិធំ មិនបានពាល់ត្រូវមិនមានឡើយ ម្នាលអានន្ទ ពួកទេវតាពោលទោសថា ពួកយើងមកអំពីចម្ងាយ ដើម្បីឃើញព្រះតថាគតៗ ជាព្រះអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោក មានម្តងៗ ក្នុងបច្ឆិមយាម នៃរាត្រីថ្ងៃនេះឯង បរិនិព្វានឹងមានដល់ព្រះតថាគត ក៏ភិក្ខុមានសក្តិធំនេះ មកឈរកាំងនៅចំព្រះកក្រៃនៃព្រះមានព្រះភាគ ពួកយើងមិនបានឃើញព្រះតថាគតក្នុងបច្ឆិមកាលឡើយ ។ ព្រះអានន្ទក្រាបបង្គំទូលសួរថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ចុះពួកទេវតាធ្វើទុក្ខក្នុងចិត្តដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មានពួកទេវតា (ខ្លះ) សម្គាល់ផែនដីក្នុងអាកាស (និម្មិតផែនដីក្នុងអាកាស) រំសាយកេសា កន្ទក់កន្ទេញ ផ្គងនូវកំហួនដៃឡើង កន្ទក់កន្ទេញ ផ្តល់ខ្នងបម្រះនទៀលទៅមក បីដូចជាមានជើងជាប់ហើយថា ព្រះមានព្រះភាគនឹងបរិនិព្វានឆាប់ម៉្លេះ ព្រះសុគតនឹងបរិនិព្វានឆាប់ម៉្លេះ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក នឹងសូន្យបាត់ទៅឆាប់ម៉្លេះ ម្នាលអានន្ទ មានពួកទេវតា (ខ្លះ) សម្គាល់ផែនដីក្នុងផែនដី (និម្មិតផែនដីប្រក្រតីឲ្យជាផែនដីទឹព្ធ) រំសាយកេសា កន្ទក់កន្ទេញ ផ្គងកំហួនដៃឡើង កន្ទក់កន្ទេញ ផ្តល់ខ្នងបម្រះនទៀលទៅមក បី

ដូចមានជើងជាច់ហើយថា ព្រះមានព្រះភាគ នឹងបរិនិព្វានឆាប់ពេកណាស់ ព្រះសុគត នឹងបរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក នឹងសូន្យឫតទៅឆាប់ពេកណាស់ ឯពួកទេវតាណា ដែលមិនមានរាគៈ ពួកទេវតានោះ មានសតិ និងសម្បជញ្ញៈ អត់សង្កត់សេចក្តីសោកបានដោយគិតថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុងខន្ធបវត្តិនេះអំពីណា ។

[๑๓๑] ព្រះអានន្ទ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ពួកភិក្ខុនៅចាំវស្សា ក្នុងទិសទាំងឡាយ រួចហើយតែងមកដើម្បីគាល់ព្រះតថាគត យើងខ្ញុំព្រះអង្គតែងបានជួបនឹងពួកភិក្ខុអ្នកចម្រើនដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចម្រើន លុះអំណឹះឥតនឹងព្រះមានព្រះភាគទៅ យើងខ្ញុំព្រះអង្គ នឹងលែងបានជួប លែងបានចូលទៅអង្គុយជិតពួកភិក្ខុ អ្នកចម្រើនដោយចិត្តហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សំវេជនីយដ្ឋាន (ទីដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធានេះ ๔ កន្លែង ។ សំវេជនីយដ្ឋាន ๔ កន្លែងតើដូចម្តេច ។ ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្ត អ្នកមានសទ្ធាដោយរឭកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះដូច្នេះ ๑ ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីដូច្នេះ ๑ ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរឭក

ឃើញថា ព្រះតថាគតបានសម្តែងនូវអនុត្តរធម្មចក្ក ក្នុងទីនេះដូច្នេះ ๑ ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរឭកឃើញថា ព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងទីនេះដូច្នេះ ๑ ម្នាលអានន្ទ នេះឯង សំវេជនីយដ្ឋានដែលគួរឃើញ ๔ កន្លែងរបស់កុលបុត្តអ្នកមានសទ្ធា ម្នាលអានន្ទ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកមានសទ្ធា នឹងមក ដោយរឭកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះដូច្នេះក្តី ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតសម្តែងនូវអនុត្តរធម្មចក្កក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះ ដូច្នេះក្តី ម្នាលអានន្ទ ពួកជនណាមួយ នឹងបានដើរមកកាន់ទីចារិកនៃចេតិយ ក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅ ពួកជនទាំងអស់នោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្សសុគតិ និងឋានសួគ៌ ។

[๑๓๒] *ព្រះអានន្ទក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គទាំងឡាយ ត្រូវប្រតិបត្តិក្នុងមាតុគ្រាមដូចម្តេច ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ត្រូវកុំមើល ។ បពិត្រព្រះមានព្រះភាគ កាលបើមើលហើយ គប្បីប្រតិបត្តិដូចម្តេច ។ ម្នាលអានន្ទ ត្រូវកុំនិយាយរក ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើនិយាយរកហើយ គប្បីប្រតិបត្តិដូចម្តេចទៀត ។ ម្នាលអានន្ទ គប្បីតាំងសតិឲ្យមាំ ។*

[๑๓๓] *បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គទាំងឡាយ ត្រូវប្រតិបត្តិក្នុងសរីរៈព្រះតថាគត ដូចម្តេច ។ ម្នាលអានន្ទ អ្នកទាំងឡាយកុំខ្វល់ខ្វាយដើម្បីបូជាសរីរៈតថាគតឡើយ ម្នាលអានន្ទ អ្នកទាំងឡាយចូរខំព្យាយាមក្នុងប្រយោជន៍របស់ខ្លួនចុះ ចូរខ្នឹឃ្នាត សង្វាតក្នុងប្រយោជន៍របស់ខ្លួនចុះ កុំប្រមាទក្នុងប្រយោជន៍របស់ខ្លួន ចូរមានព្យាយាម មានចិត្តបញ្ជូនទៅ (កាន់ព្រះនិព្វាន) ចុះ ម្នាលអានន្ទ គង់តែមានខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី ជ្រះថ្លាក្នុងតថាគត គេនឹងធ្វើការបូជាសរីរៈតថាគតមិនខាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងឡាយនោះ គប្បីប្រតិបត្តិក្នុងសរីរៈព្រះតថាគតដូចម្តេច ។ ម្នាលអានន្ទ ជនទាំងឡាយតែងប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជ យ៉ាងណាមិញ ជនទាំងនោះ គប្បីប្រតិបត្តិក្នុងសរីរៈតថាគតយ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងនោះ ប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជដូចម្តេច ។ ម្នាលអានន្ទ ជនទាំងឡាយរុំសរីរៈព្រះចក្រពត្តិរាជដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡីរួចហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំសរីរៈនៃចក្រពត្តិរាជដោយសំពត់ ៥០០ គូ ដោយទំនងនេះហើយ តម្កល់ក្នុងមណ្ឌុសមាសដែលជាក់ប្រេង ហើយគ្របដោយមណ្ឌុសមាសដទៃ រួចធ្វើជើងថ្ករ ហើយថ្វាយព្រះភ្លើង ចំពោះសរីរៈព្រះចក្រពត្តិរាជ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ហើយគេធ្វើស្តូបនៃព្រះចក្រពត្តិរាជក្នុងផ្លូវធំបែកជា ៤ ម្នាលអានន្ទ ជនទាំងឡាយប្រតិបត្តិក្នុងសរីរៈព្រះរាជាចក្រពត្តិយ៉ាងនេះឯង ម្នាលអានន្ទ ជនទាំងឡាយ*

ប្រតិបត្តិក្នុងសរីរៈព្រះចក្រពត្តិរាជ យ៉ាងណាមិញ ជនទាំងនោះ គប្បីប្រតិបត្តិក្នុងសរីរៈតថាគត គប្បីធ្វើស្តូបរបស់តថាគត ក្នុងផ្លូវធំបែកជា ៤ យ៉ាងនោះចុះ ពួកជនណានឹងលើកទ្បើងនូវកម្រងផ្កាក្តី គ្រឿងក្រអូបក្តី គ្រឿងលម្អិតក្តី ឬនឹងថ្វាយបង្គំ ឬធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ អំពើនោះ របស់ជនទាំងនោះ នឹងនាំមកនូវប្រយោជន៍ និងសេចក្តីសុខអស់កាលយូរ ។

[๑๓๔] ម្នាលអានន្ទ ថ្លូបារហបុគ្គល (បុគ្គលដែលគួរដល់ស្តូប) នេះ មាន ๔ ពួក ។ ថ្លូបារហបុគ្គល ๔ ពួក តើដូចម្តេចខ្លះ ។ គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាថ្លូបារហបុគ្គល ๑ ព្រះបច្ចេកពុទ្ធ ជាថ្លូបារហបុគ្គល ๑ សាវ័ករបស់ព្រះតថាគត ជាថ្លូបារហបុគ្គល ๑ ព្រះចក្រពត្តិរាជ ជាថ្លូបារហបុគ្គល ๑ ។ ម្នាលអានន្ទ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ជាថ្លូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លាក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់សុគតិលោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាថ្លូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលអានន្ទ ព្រះបច្ចេកសម្ពុទ្ធ ជាថ្លូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើន ធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះបច្ចេកពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លា

ក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ ព្រះបច្ចេកសម្ពុទ្ធ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលអានន្ទ សាវ័ករបស់ព្រះតថាគត ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើនធ្វើចិត្តឲ្យជ្រះថ្លា ដោយសម្គាល់ថា នេះជាស្តូបនៃសាវ័ករបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លាក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ សាវ័ករបស់ព្រះតថាគត ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលអានន្ទ ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលអានន្ទ ពួកជនជាច្រើនធ្វើចិត្តឲ្យជ្រះថ្លាដោយសម្គាល់ថា នេះជាស្តូបរបស់ព្រះធម្មរាជ ដែលទ្រង់ធម៌នោះ ពួកជនទាំងនោះ លុះធ្វើចិត្តឲ្យជ្រះថ្លា ក្នុងស្តូបនោះ លុះបែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺសុគតិ ឋានសួគ៌ ម្នាលអានន្ទ ព្រះចក្រពត្តិរាជ ជាថូបារហបុគ្គល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលអានន្ទ ថូបារហបុគ្គលមាន ๔ ពួកនេះឯង ។

[๑๓๕] *គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅកាន់វិហារ ក៏តោងនូវឈើមានសណ្ឋានដូចក្បាលស្វា (ត្រដោកទ្វារ) ឈរយំរៀបរាប់ថា ឱ*

អាត្មាអញ ជាសេក្ខបុគ្គល មានកិច្ចគួរធ្វើតទៅទៀតនៅឡើយ ក៏ព្រះសាស្តា
របស់អាត្មាដែលជាអ្នកអនុគ្រោះដល់អាត្មាអញ នឹងទ្រង់បរិនិព្វាន ។ គ្រានោះ
ព្រះមានព្រះភាគទ្រង់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អានន្ទ
ទៅណា ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទមាន
អាយុ ចូលទៅកាន់រោងសម្រាប់សម្រាកកាយ គោងត្រដោកទ្វារ ឈរយំ
រៀបរាប់ឯណោះថា ឱអាត្មាអញ នៅជាសេក្ខបុគ្គល មានកិច្ចគួរធ្វើតទៅ
ទៀតនៅឡើយ ព្រះសាស្តារបស់អាត្មា ដែលជាអ្នកអនុគ្រោះដល់អាត្មាអញ
នឹងទ្រង់បរិនិព្វាន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ហៅភិក្ខុ ១ រូបមក
ថា ម្នាលភិក្ខុ អ្នកចូរទៅហៅអានន្ទ តាមពាក្យតថាគតថា ម្នាលអាវុសោ
អានន្ទ ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅអ្នក ។ ភិក្ខុនោះទទួលព្រះបន្ទូលនៃព្រះ
មានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកព្រះអានន្ទមានអាយុ
លុះចូលទៅដល់ហើយ ក៏និយាយទៅនឹងព្រះអានន្ទមានអាយុដូច្នេះថា ម្នាល
អាវុសោអានន្ទ ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅអ្នក ។ ព្រះអានន្ទមានអាយុ
ទទួលពាក្យរបស់ភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់នូវព្រះមាន
ព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយ
អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ
ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ណ្ហ៎ីយ អ្នកកុំសោយសោក
កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ តថាគតបានប្រាប់អ្នកជាមុនហើយយ៉ាងនេះ
ថា សេចក្តីព្រាត់ប្រាស វិនាស ប្រែប្រួល ចាកសត្វ និងសង្ខារ ជាទីស្រឡាញ់

ជាទីគាប់ចិត្តទាំងអស់ តែងមានជាធម្មតា ព្រោះហេតុនោះ បុគ្គលគប្បីបានទូរ
សេចក្តីមិនព្រាត់ប្រាសនោះ ក្នុងខន្ធបញ្ចវត្តិនេះមកអំពីណា ធម្មជាតណាដែល
កើតហើយ ដែលមានហើយ ដែលបច្ច័យតាក់តែងហើយ មានសេចក្តីទ្រោម
ទ្រុឌទៅជាធម្មតា ធម្មជាតនោះ បុគ្គលនឹងពោលឃាត់ថា កុំទ្រោមទ្រុឌទៅ
ដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ ម្នាលអានន្ទ ខ្លួនអ្នកបាន
បម្រើតថាគត មកជាយូរអង្វែងហើយ ដោយកាយកម្ម ប្រកបដោយមេត្តា
នាំមកនូវប្រយោជន៍ និងសេចក្តីសុខ មិនមានចំណែកពីរ ជាកម្មប្រមាណ
មិនបានដោយវចីកម្មប្រកបដោយមេត្តា នាំមកនូវប្រយោជន៍ និងសេចក្តីសុខ
មិនមានចំណែកពីរ ជាកម្មប្រមាណមិនបាន ដោយមនោកម្ម ប្រកបដោយ
មេត្តា នាំមកនូវប្រយោជន៍ និងសេចក្តីសុខ មិនមានចំណែកពីរ ជាកម្ម
ប្រមាណមិនបាន ម្នាលអានន្ទ ខ្លួនអ្នកជាបុគ្គលបានធ្វើបុណ្យទុកហើយ ចូរ
ប្រកបព្យាយាមឲ្យរឿយៗ ចុះ នឹងបានជាបុគ្គលមិនមានអាសវៈដោយឆាប់ ។
ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ព្រះមាន
ព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ ដែលមានក្នុងអតីតកាល ពួក
ភិក្ខុជាឧបដ្ឋាករបស់ព្រះមានព្រះភាគទាំងនោះ មានកំណត់ដូច្នេះឯង ដូច
អានន្ទរបស់តថាគតដែរ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះមានព្រះភាគ
ទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ នឹងមានមកក្នុងអនាគតកាល ពួកភិក្ខុ
ជាឧបដ្ឋាករបស់ព្រះមានព្រះភាគទាំងនោះ មានកំណត់ដូច្នេះឯង ដូចអានន្ទ
របស់តថាគតដែរ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិតតែងដឹងដូច្នេះថា កាល

នេះ ជាកាលគួរនឹងចូលទៅគាល់ព្រះតថាគត កាលនេះ ជាកាលគួរបស់ពួក ភិក្ខុ កាលនេះ ជាកាលគួរបស់ពួកភិក្ខុនី កាលនេះ ជាកាលគួរបស់ពួក ឧបាសក កាលនេះ ជាកាលគួរបស់ពួកឧបាសិកា កាលនេះ ជាកាលគួរ បស់ព្រះរាជា និងរាជមហាមាត្យ កាលនេះ ជាកាលគួរបស់ពួកតិរ្ថិយ កាលនេះ ជាកាលគួរបស់ពួកតិត្ថិយសាវក ។

[๑๓๖] ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភុតធម៌ (ធម៌ជាអស្ចារ្យចម្លែក) ទាំងឡាយ ๔ យ៉ាងនេះ មាននៅក្នុងអានន្ទ ។ ធម៌ទាំង ๔ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បើបរិសទ្យចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុបរិសទ្យនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិសទ្យនោះ ក៏មានសេចក្តីត្រេកអរ ដោយកាសិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិសទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុ ទាំងឡាយ បើភិក្ខុនីបរិសទ្យចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុនីបរិសទ្យនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុនីបរិសទ្យនោះ ក៏មានសេចក្តីត្រេកអរដោយកាសិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀមទៅ ម្នាលភិក្ខុ ទាំងឡាយ បើឧបាសកបរិសទ្យចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសកបរិសទ្យ នោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុង ទីនោះ ឧបាសកបរិសទ្យនោះ ក៏មានសេចក្តីត្រេកអរដោយកាសិត ម្នាលភិក្ខុ ទាំងឡាយ ឧបាសកបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្ងៀម

ទៅ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកាបរិសទ្យ ចូលទៅដើម្បីជួបនឹងអានន្ទ ឧបាសិកាបរិសទ្យនោះ រមែងមានសេចក្តីត្រេកអរដោយការបានជួប បើអានន្ទ និយាយធម៌ក្នុងទីនោះ ឧបាសិកាបរិសទ្យនោះ ក៏មានសេចក្តីត្រេកអរ ដោយកាសិត ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទស្បៃមៅ ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភូតធម៌ទាំងឡាយ ๔ យ៉ាងនេះឯង មាននៅក្នុងអានន្ទ ។ ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភូតធម៌ទាំងឡាយ ๔ យ៉ាងនេះ មាននៅក្នុងព្រះចក្រពត្តិរាជ ម្នាលភិក្ខុទាំងឡាយ បើខត្តិយបរិសទ្យ ចូលទៅដើម្បីគាល់ព្រះចក្រពត្តិរាជ ខត្តិយបរិសទ្យនោះ រមែងមានសេចក្តីត្រេកអរដោយការបានជួប បើព្រះចក្រពត្តិរាជមានព្រះបន្ទូលក្នុងទីនោះ ខត្តិយបរិសទ្យនោះ ក៏មានសេចក្តីត្រេកអរដោយកាសិត ម្នាលភិក្ខុទាំងឡាយ ខត្តិយបរិសទ្យមិនទាន់ឆ្អែតនៅឡើយ ស្រាប់តែព្រះចក្រពត្តិរាជស្បៃមៅ។ ម្នាលភិក្ខុទាំងឡាយ បើព្រាហ្មណបរិសទ្យ ។ គហបតិបរិសទ្យ ។ សមណបរិសទ្យ ចូលទៅដើម្បីគាល់ព្រះចក្រពត្តិរាជ សមណបរិសទ្យនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានគាល់ បើព្រះចក្រពត្តិរាជ មានព្រះបន្ទូលក្នុងទីនោះ សមណបរិសទ្យនោះ មានសេចក្តីត្រេកអរ ដោយកាសិត ម្នាលភិក្ខុទាំងឡាយ សមណបរិសទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែព្រះចក្រពត្តិរាជស្បៃមៅ ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភូតធម៌ទាំងឡាយ ๔ យ៉ាងនេះ មាននៅក្នុងអានន្ទដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បើភិក្ខុបរិសទ្យ ចូលទៅដើម្បីជួបនឹងអានន្ទ ភិក្ខុបរិសទ្យនោះ រមែងមានសេចក្តីត្រេកអរដោយ

ការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ភិក្ខុបរិសទ្យនោះ ក៏មានសេចក្តីត្រេកអរដោយកាសិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិសទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទសៀមទៅ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីបរិសទ្យ ។ ឧបាសកបរិសទ្យ ។ ឧបាសិកាបរិសទ្យចូលទៅ ដើម្បីជួបនឹងអានន្ទ ឧបាសិកាបរិសទ្យនោះ រមែងមានសេចក្តីត្រេកអរ ដោយការបានជួប បើអានន្ទនិយាយធម៌ក្នុងទីនោះ ឧបាសិកាបរិសទ្យនោះ ក៏មានសេចក្តីត្រេកអរ ដោយកាសិត ម្នាលភិក្ខុទាំងឡាយ ឧបាសិកាបរិសទ្យ មិនទាន់ឆ្អែតនៅឡើយ ក៏ស្រាប់តែអានន្ទសៀមទៅ ម្នាលភិក្ខុទាំងឡាយ អច្ឆរិយព្ភូតធម៌ទាំង ៤ យ៉ាងនេះឯង មាននៅក្នុងអានន្ទ ។

[១៣៧] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ កុំបរិនិព្វាន (ក្នុងនគរកុសិនារា) ជានគរតូច ជានគរទួល ជាសាខានគរនេះឡើយ បពិត្រព្រះអង្គដ៏ចម្រើន មានមហានគរដទៃ គឺនគរចម្បា រាជគ្រឹះ សាវត្ថី សាកេត កោសម្ពី ពារាណសី សូមព្រះមានព្រះភាគ បរិនិព្វានក្នុងនគរទាំងនុ៎ះ ខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតិមហាសាល ជាប្រើនក្នុងនគរទាំងនោះ មានសេចក្តីជ្រះថ្លាក្នុងព្រះតថាគត គេនឹងធ្វើការបូជាព្រះសរីរៈព្រះតថាគត ។ ម្នាលអានន្ទ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំនិយាយថា នគរកុសិនារានេះ ជានគរតូច ជានគរទួល ជាសាខានគរយ៉ាងនេះឡើយ ម្នាលអានន្ទ កាលពីដើមមានព្រះ

ចក្រពត្តិរាជ ព្រះនាមមហាសុទស្សនៈ ជាធម្មរាជ ទ្រង់ធម៌ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានជនបទមាំមួន ប្រកបដោយរតនៈទាំង ៧ ប្រការ ម្នាលអានន្ទ ទីក្រុងកុសិនារានេះ ជារាជធានីឈ្មោះកុសាវតី របស់ព្រះមហាសុទស្សនរាជ មានបណ្តោយ ១២ យោជន៍ អំពីទិសខាងកើត ទៅទិសខាងលិច មានទទឹង ៧ យោជន៍ អំពីទិសខាងជើង ទៅទិសខាងត្បូង ម្នាលអានន្ទ កុសាវតីរាជធានី ជាក្រុងស្តុកស្តម្ភ សម្បូណ៌ពោរពាស (ដោយទំនិញ) មានជនច្រើន មានមនុស្សដេរដាស ទាំងបរិបូណ៌ដោយភិក្ខាហារ ម្នាលអានន្ទ រាជធានីឈ្មោះអាឡកមន្ទា របស់ពួកទេវតាជារាជធានីស្តុកស្តម្ភ សម្បូណ៌ពោរពាស មានជនច្រើន មានយក្ខដេរដាស ទាំងបរិបូណ៌ដោយភិក្ខាហារ យ៉ាងណាមិញ ម្នាលអានន្ទ កុសាវតីរាជធានី ក៏ជាក្រុងស្តុកស្តម្ភ សម្បូណ៌ពោរពាស (ដោយទំនិញ) មានជនច្រើន មានមនុស្សដេរដាស ទាំងបរិបូណ៌ដោយភិក្ខាហារ យ៉ាងនោះដែរ ម្នាលអានន្ទ កុសាវតីរាជធានី មិនដែលស្ងាត់ ដោយសូរសំឡេង ១០ យ៉ាង ទាំងថ្ងៃទាំងយប់ គឺសូរសំឡេងដំរី សូរសំឡេងសេះ សូរសំឡេងរថ សូរសំឡេងស្គរ សូរសំឡេងសម្ភោរ សូរសំឡេងពិណ សូរសំឡេងចម្រៀង សូរសំឡេងរគាំង សូរសំឡេងរនាត និងសូរសំឡេងជាគម្រប់ ១០ ថា អ្នកទាំងឡាយចូរស៊ី ចូរផឹក ចូរទំពា ម្នាលអានន្ទ អ្នកចូរទៅក្នុងក្រុងកុសិនារា ហើយថ្វាយដំណឹងដល់ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារាថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ក្នុងបច្ឆិមយាម នៃរាត្រីថ្ងៃនេះ ព្រះតថាគតនឹងបរិនិព្វាន បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូម

អ្នកទាំងឡាយអញ្ជើញទៅ បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយ អញ្ជើញទៅ កុំឲ្យមានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយថា ព្រះតថាគត ទ្រង់បរិនិព្វានក្នុងគាមក្ខេត្តរបស់យើងទាំងឡាយហើយ យើងទាំងឡាយមិនបានឃើញព្រះតថាគត ក្នុងកាលជាបំផុតដូច្នេះឡើយ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរ មិនមានភិក្ខុជាគម្រប់ពីរ ចូលទៅក្នុងក្រុងកុសិនារ ។ សម័យនោះឯង ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារ កំពុងប្រជុំគ្នាក្នុងសណ្ឋាគារជ្ឈាន (សាលាសម្រាប់បង្រៀនវិជ្ជា ក្នុងរាជត្រកូល) ដោយកិច្ចនីមួយ ។ ព្រះអានន្ទមានអាយុ ក៏ចូលទៅកាន់សណ្ឋាគារជ្ឈានរបស់ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារនោះ លុះចូលទៅដល់ហើយ ក៏ថ្វាយដំណឹងដល់ពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះតថាគតនឹងបរិនិព្វាន បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ បពិត្រវាសិដ្ឋគោត្រទាំងឡាយ សូមអ្នកទាំងឡាយអញ្ជើញទៅ កុំឲ្យមានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយថា ព្រះតថាគត ទ្រង់បរិនិព្វាន ក្នុងគាមក្ខេត្តរបស់យើងទាំងឡាយហើយ យើងទាំងឡាយមិនបានឃើញព្រះតថាគត ក្នុងកាលជាបំផុតដូច្នេះឡើយ ។ ពួកមល្លក្សត្រ និងពួកបុត្ររបស់មល្លក្សត្រ និងសុណិសារបស់មល្លក្សត្រ និងភរិយារបស់មល្លក្សត្រ លុះឮពាក្យនេះរបស់ព្រះអានន្ទមានអាយុហើយ ក៏កើតទុក្ខតូចព្រះទ័យ

ពោរពេញដោយសេចក្តីទុក្ខក្នុងព្រះទ័យ ខ្លះក៏រំសាយកេសាកន្ទុក់កន្ទេញផ្តង កំភួនដៃ កន្ទុក់កន្ទេញ ផ្តួលខ្ជួនចុះ បម្រះនទៀលទៅមក ដូចជាមានជើងជាច់ហើយថា ព្រះមានព្រះភាគនឹងបរិនិព្វាន ឆាប់ពេកណាស់ ព្រះសុគតនឹងបរិនិព្វាន ឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក នឹងបាត់ទៅឆាប់ពេកណាស់ ។ លំដាប់នោះ ពួកមល្លក្សត្រ និងពួកបុត្តរបស់មល្លក្សត្រ និងសុណិសារបស់មល្លក្សត្រ និងភរិយារបស់មល្លក្សត្រ កើតទុក្ខ តូចព្រះទ័យ ពោរពេញដោយសេចក្តីទុក្ខក្នុងព្រះទ័យ ក៏នាំគ្នាចូលទៅរកព្រះអានន្ទមានអាយុ ក្នុងសាលវនរបស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុង ។ ទើបព្រះអានន្ទមានអាយុមានសេចក្តីត្រិះរិះដូច្នេះថា បើអាត្មាអញនឹងឲ្យពួកមល្ល-ក្សត្រ ដែលនៅក្នុងក្រុងកុសិនារា ថ្វាយបង្គំព្រះមានព្រះភាគម្នាក់ម្តងៗ ពួកមល្លក្សត្រដែលនៅក្នុងក្រុងកុសិនារា នឹងថ្វាយបង្គំព្រះមានព្រះភាគមិនទាន់ហើយស្រេច រាត្រីនេះក៏នឹងក្តីឡើងមិនខាន បើដូច្នោះគួរតែអាត្មាអញជាក់ឲ្យពួកមល្លក្សត្រ ដែលនៅក្នុងក្រុងកុសិនារាថ្វាយបង្គំព្រះមានព្រះភាគ តាមវង្សនៃត្រកូលៗ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន មល្លក្សត្រឈ្មោះនេះ ព្រមទាំងបុត្រភរិយាបរិសទ្យ និងអាមាត្យ សូមបង្អោនសិរ្សៈថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះអានន្ទមានអាយុក៏ជាក់ឲ្យពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថ្វាយបង្គំព្រះមានព្រះភាគ តាមវង្សនៃត្រកូលៗ ដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន មល្លក្សត្រឈ្មោះនេះ ព្រមទាំងបុត្រ ភរិយា បរិសទ្យ និង អមាត្យ សូមបង្អោនសិរ្សៈថ្វាយបង្គំព្រះបាទានៃព្រះមាន

ព្រះភាគ ។ ទើបព្រះអានន្ទមានអាយុឲ្យពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថ្វាយបង្គំព្រះមានព្រះភាគ ក្នុងបឋមយាមតាមទំនងនេះ ។

[๑๓๘] *សម័យនោះឯង មានបរិព្វាជកឈ្មោះសុភទ្ទ នៅក្នុងក្រុងកុសិនារា ។ សុភទ្ទបរិព្វាជកបានឮដំណឹងថា ព្រះសមណគោតមនឹងបរិនិព្វានក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ។ គ្រានោះ សុភទ្ទបរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យនេះ អាត្មាអញបានឮមកអំពីពួកបរិព្វាជក ជាមនុស្សចាស់ទុំ ជាអាចារ្យតៗ គ្នាមក តែងនិយាយថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយជងមួយកាល ក៏ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតមនឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះកើតឡើងដល់អាត្មាអញ ទាំងអាត្មាអញមានសេចក្តីជ្រះថ្លា ក្នុងព្រះសមណ-គោតមដែរ អាត្មាអញគួរលះបង់នូវសេចក្តីសង្ស័យនេះបានយ៉ាងណា ព្រះសមណគោតមអាចនឹងសម្តែងធម៌ដល់អាត្មាអញយ៉ាងនោះបាន ។ គ្រានោះ សុភទ្ទបរិព្វាជកក៏ចូលទៅរកព្រះអានន្ទមានអាយុ ក្នុងសាលវនរបស់ពួកមល្ល-ក្សត្រ ដែលជាទីចូលទៅក្នុងក្រុង លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ពាក្យនេះ ខ្ញុំបានឮមកអំពីពួកបរិព្វាជកជាមនុស្សចាស់ទុំ ជាអាចារ្យតៗ គ្នាមក តែងនិយាយថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយជងមួយកាល ក៏ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតមនឹងបរិនិព្វាន មួយទៀត សេចក្តីសង្ស័យនេះកើតឡើងដល់ខ្ញុំ ខ្ញុំក៏មានសេចក្តីជ្រះថ្លា ក្នុងព្រះ*

សមណគោតមដែរ ខ្ញុំគួរលះបង់នូវសេចក្តីសង្ស័យនេះបានយ៉ាងណា ព្រះសមណគោតមអាចនឹងសម្តែងធម៌ដល់ខ្ញុំយ៉ាងនោះបាន បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំសូមឲ្យបានគាល់ព្រះសមណគោតមផង ។ លុះសុភទូបរិព្វាជកនិយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បានពោលទៅនឹងសុភទូបរិព្វាជកដូច្នេះថា ម្នាលអាវុសោសុភទូ កុំឡើយ អ្នកកុំបៀតបៀនព្រះតថាគត ព្រះមានព្រះភាគទ្រង់លំបាកព្រះអង្គណាស់ ។ សុភទូបរិព្វាជកបាននិយាយជាគម្រប់ពីរដងផង ។បេ។ សុភទូបរិព្វាជកបាននិយាយនឹងព្រះអានន្ទមានអាយុជាគម្រប់បីដងផងដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ពាក្យនេះ ខ្ញុំបានឮមកអំពីពួកបរិព្វាជកជាមនុស្សចាស់ទុំ ជាអាចារ្យតៗ គ្នាមក តែងនិយាយថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ តែងកើតឡើងក្នុងលោកមួយដងមួយកាល ក៏ក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះ ព្រះសមណគោតមនឹងបរិនិព្វានមួយទៀត សេចក្តីសង្ស័យនេះកើតឡើងដល់ខ្ញុំ ខ្ញុំក៏មានសេចក្តីជ្រះថ្លាក្នុងព្រះសមណគោតមដែរ ខ្ញុំគួរលះបង់នូវសេចក្តីសង្ស័យនេះបាន យ៉ាងណា ព្រះសមណគោតមអាចនឹងសម្តែងធម៌ដល់ខ្ញុំយ៉ាងនោះបាន បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំសូមឲ្យបានគាល់ចំពោះព្រះសមណគោតមផង ។ ព្រះអានន្ទមានអាយុបានពោលទៅនឹងសុភទូបរិព្វាជក ជាគម្រប់បីដងទៀតដូច្នេះថា ម្នាលអាវុសោសុភទូ កុំឡើយ អ្នកកុំបៀតបៀនព្រះតថាគត ព្រះមានព្រះភាគទ្រង់លំបាកព្រះអង្គណាស់ ។ ព្រះមានព្រះភាគទ្រង់ព្រះសណ្តាប់កថាសល្លាបៈនេះរបស់ព្រះអានន្ទមានអាយុ ជាមួយនឹងសុភទូបរិព្វាជក ។ទើបព្រះមានព្រះភាគ

ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ កុំឡើយ អ្នកកុំឃាត់
សុភទ្ទ ម្នាលអានន្ទ សុភទ្ទចូរបានឃើញតថាគតចុះ សុភទ្ទនឹងសួរនូវសេចក្តី
ណាមួយនឹងតថាគត គាត់ចង់ដឹងនូវសេចក្តីនោះមែន ទើបគាត់មកសួរតថាគត
មិនមែនគាត់សួរចង់ប៉ៀតប៉ៀនទេ ប៉ើសុភទ្ទនេះសួរហើយ តថាគតសម្តែងធម៌
ណា គាត់នឹងបានដឹងធម៌នោះឆាប់ភ្លាម ។ ទើបព្រះអានន្ទមានអាយុពោលទៅ
នឹងសុភទ្ទបរិព្វាជក ដូច្នេះថា ម្នាលអាវុសោសុភទ្ទ ព្រះមានព្រះភាគទ្រង់ប៉ើក
ឧកាសដល់អ្នកហើយ អ្នកចូរទៅចុះ ។ គ្រានោះ សុភទ្ទបរិព្វាជកក៏ចូលទៅ
រកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះ
សំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និង
ពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសុភទ្ទបរិព្វាជកអង្គុយ
ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតម
ដ៏ចម្រើន សមណព្រាហ្មណ៍ណា ជាពួកគណៈ ជាគណាចារ្យល្បីល្បាញ
មានយស អ្នកធ្វើលទ្ធិដូចកំពង់ ដែលជនច្រើនគ្នាគេសន្ទតថា ល្អ ដូចយ៉ាង
គ្រូឈ្មោះបូរណកស្សប មក្ខលិគោសាល អជិតកេសកម្ពល បកុធកច្ចាយនៈ
សញ្ជយវេលដ្ឋបុត្ត និគណ្ឋនាដបុត្ត ពួកជនទាំងនោះ សុទ្ធតែត្រាស់ដឹងដូចជា
ពាក្យប្តេជ្ញារបស់ខ្លួនមែន ឬសុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ មិន
បានត្រាស់ដឹងខ្លះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសុភទ្ទ ណ្ហើយចុះ ពាក្យ
ដែលអ្នកនិយាយថា ពួកជនទាំងនោះ សុទ្ធតែត្រាស់ដឹងដូចជាពាក្យប្តេជ្ញារបស់
ខ្លួនមែន ឬសុទ្ធតែមិនបានត្រាស់ដឹងទេ ឬក៏ត្រាស់ដឹងខ្លះ មិនបានត្រាស់ដឹងខ្លះ

ដូច្នេះនេះ ចូរលើកទុកសិនចុះ ម្នាលសុភទ្ទ តថាគតនឹងសម្តែងធម៌ដល់អ្នក អ្នកចូរស្តាប់ធម៌នោះ ចូរតាំងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ សុភទ្ទ បរិព្វាជក ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើប ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលសុភទ្ទ អរិយមគ្គមានអង្គ ៨ មិន មានក្នុងធម្មវិន័យណា សមណៈទី ១ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈ ទី ២ ក្តី មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៣ ក្តី មិនមានក្នុងធម្ម-វិន័យនោះ សមណៈទី ៤ ក្តី ក៏មិនមានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ លុះតែអរិយមគ្គប្រកបដោយអង្គ ៨ មានក្នុងធម្មវិន័យណា សមណៈ (ទី ១) ក្តី ទើបមានក្នុងធម្មវិន័យនោះ សមណៈទី ២ ក្តី មានក្នុងធម្មវិន័យ នោះ សមណៈទី ៣ ក្តី មានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក្តី ក៏មាន ក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុង ធម្មវិន័យនេះឯង ម្នាលសុភទ្ទ សមណៈ (ទី ១) ក៏មានតែក្នុងសាសនា នេះ សមណៈ ទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មានតែ ក្នុងសាសនានេះ សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ (វាទៈ នៃគ្រូដទៃ) អំពីសំណាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ (នេះ) ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ លោកនឹងមិនបាន សូន្យចាកពួកអរហន្តទេ ។

[๑๓๙] ម្នាលសុភទ្ទ កាលតថាគតមានវ័យ ២៩ ឆ្នាំ បានបួសហើយ ជាអ្នកស្វែងរកនូវកុសល (សព្វញ្ញុតញ្ញាណ) ម្នាលសុភទ្ទ កាលណាបើ

តថាគតបួសបានជាង ៥០ ឆ្នាំ ហើយញុំាងប្រទេស គឺវិបស្សនាមគ្គឲ្យប្រ-ព្រឹត្តទៅជាប្រក្រតី ដើម្បីធម៌ដែលគួរត្រាស់ដឹង គឺអរិយមគ្គ ព្រោះហេតុនោះ សមណៈ (ទី ១) ខាងក្រៅអំពីសាសនានៃតថាគតនេះ មិនមានទេីយ ។

សមណៈទី ២ ក្តី មិនមាន សមណៈទី ៣ ក្តី មិនមាន សមណៈទី ៤ ក្តី ក៏មិនមានដែរ បរប្បវាទអំពីសំណាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ (នេះ) ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះ គប្បីនៅដោយប្រពៃ លោកនឹងមិនបានសូន្យចាកពួកអរហន្តទេីយ ។

[១៤០] លុះព្រះមានព្រះភាគ មានព្រះពុទ្ធតម្រាស់យ៉ាងនេះហើយ សុភទ្ទបរិព្វាជកក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលផ្ងារឡើងនូវរបស់ដែលគេផ្កាប់ចុះក្តី បើកនូវរបស់ដែលគេគ្របក្តី ចង្អុលប្រាប់ផ្លូវដល់បុរសដែលវង្វេងផ្លូវក្តី ទ្រោលប្រទីបបំភ្លឺ ក្នុងទីងងឹតដោយគិតថា អ្នកមានចក្ខុនឹងបានឃើញរូបក្តី យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសុភទ្ទ បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយ ហើយប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ

បុគ្គលនោះរមែងនៅបរិវាសអស់កំណត់ ៤ ខែសិន លុះកន្លង ៤ ខែហើយ ទើបពួកភិក្ខុជាអារទ្ធចិត្ត (អ្នកមានចិត្តត្រេកអរ) ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីភិក្ខុភាវៈបាន តែថា សភាវៈនៃបុគ្គលដែលផ្សេងគ្នា តថាគតដឹងច្បាស់ហើយ ក្នុងរឿងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកបុគ្គលធ្លាប់ជាអន្យ-តិ្ថរិយហើយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះ រមែងនៅបរិវាសអស់កំណត់ ៤ ខែ លុះកន្លង ៤ ខែហើយ ទើបពួកភិក្ខុជាអារទ្ធចិត្ត ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីភិក្ខុភាវៈបាន ខ្ញុំព្រះអង្គនឹងនៅបរិវាស អស់កំណត់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំហើយ សូមពួកភិក្ខុជាអារទ្ធចិត្ត ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីភិក្ខុភាវៈចុះ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ បើដូច្នោះចូរអ្នកបំបួសសុភទ្ទបរិព្វាជក ផងចុះ ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបសុភទ្ទបរិព្វាជកពោលនឹងព្រះអានន្ទមានអាយុដូច្នេះថា នែអាវុសោអានន្ទ លោកម្ចាស់ពេញហៅជាមានលាភ នែអាវុសោអានន្ទ អត្តភាពជាមនុស្ស លោកម្ចាស់ក៏បានដោយល្អហើយ ព្រោះថាព្រះសាស្តាបានអភិសេកលោកម្ចាស់ ដោយការអភិសេកជាអន្តេវាសិកក្នុងទីចំពោះព្រះភក្ត្រ ក្នុងសាសនានេះ ។ សុភទ្ទបរិព្វាជកបានបព្វជ្ជា បានឧបសម្បទាក្នុងសម្នាក់នៃព្រះមានព្រះភាគស្រេចហើយ ។ ឯសុភទ្ទមានអាយុ លុះបានឧបសម្បទារួចភ្លាម ក៏ចេញទៅតែម្នាក់ឯង មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ពួកកុលបុត្តដែលចេញចាកផ្ទះមក

កាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយបានដល់នូវអនុត្តរធម៌នោះជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ដោយមិនយូរប៉ុន្មាន ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ក៏ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចារ្យក៏បានអប់រំហើយ សោឡសកិច្ចក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ សុភទ្ទភិក្ខុមានអាយុ ក៏ជាអរហន្តមួយអង្គដែរ ។ សុភទ្ទភិក្ខុនោះ ជាបច្ឆិមសក្ខិសាវក របស់ព្រះមានព្រះភាគ ។

ពុទ្ធកាណវារទី ៥ ចប់

[១៤១] *គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យប្រដៅដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ គ្រូរបស់យើងឈ្មោះថា មិនមានឡើយ ម្នាលអានន្ទ សេចក្តីនេះ អ្នកកុំចូលចិត្តយ៉ាងនេះឡើយ ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតតអំពីតថាគតទៅ ធម៌ និងវិន័យនោះជាគ្រូរបស់អ្នកទាំងឡាយ ម្នាលអានន្ទ ក៏ក្នុងកាលសព្វថ្ងៃនេះ ពួកភិក្ខុហៅគ្នានឹងគ្នាដោយពាក្យថា អាវុសោ អំណើះតតនឹងតថាគតទៅ អ្នកទាំងឡាយ កុំហៅយ៉ាងនេះទៀតឡើយ ម្នាលអានន្ទ ភិក្ខុចាស់ជាង ត្រូវហៅភិក្ខុថ្មីជាង ដោយនាមក៏បាន ដោយគោត្រក៏បាន ដោយពាក្យថា អាវុសោ ក៏បាន ចំណែកភិក្ខុថ្មីជាង*

ត្រូវហៅភិក្ខុចាស់ជាងថា ភន្តេ ក៏បាន ថា អាយស្មា ក៏បាន ម្នាលអានន្ទ លុះអំណើះឥតនឹងតថាគតទៅ បើសង្ឃមានប្រាថ្នានឹងដកសិក្ខាបទ ចូរដកសិក្ខាបទដែលតូច និងតូចដោយលំដាប់ចុះ ម្នាលអានន្ទ អំណើះឥតនឹងតថាគតទៅ សង្ឃត្រូវដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុផងចុះ ។ ព្រះអានន្ទក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រហ្មទណ្ឌតើដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ឆន្នភិក្ខុចង់ពោលនូវពាក្យណា ពោលនូវពាក្យនោះចុះ ប៉ុន្តែពួកភិក្ខុមិនត្រូវនិយាយ មិនត្រូវទូន្មាន មិនត្រូវប្រដៅឆន្នភិក្ខុនោះទេ ។

[១៤២] លំដាប់នោះ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា គប្បីមានសូម្បីដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសាកសួរ (តថាគតចុះ) កុំឲ្យអ្នកទាំងឡាយ មានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយថា ព្រះសាស្តាមាននៅចំពោះមុខនៃយើងរាល់គ្នាៗ មិនបានជាយកចិត្តទុកដាក់ដើម្បីសាកសួរព្រះមានព្រះភាគក្នុងទីចំពោះព្រះភក្ត្រសោះ ។ កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ភិក្ខុទាំងនោះក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយជាគម្រប់ពីរដង ។បេ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយជាគម្រប់បីដងថា ម្នាលភិក្ខុទាំងឡាយ បើសេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា គប្បីមាន សូម្បីដល់ភិក្ខុមួយរូប ម្នាលភិក្ខុទាំងឡាយ អ្នក

ទាំងឡាយ ចូរសាកសួរ (តថាគតចុះ) កុំឲ្យអ្នកទាំងឡាយ មានសេចក្តីក្តៅក្រហាយ ស្តាយក្នុងកាលជាខាងក្រោយថា ព្រះសាស្តាមាននៅចំពោះមុខនៃយើងរាល់គ្នាៗ មិនបានជាយកចិត្តទុកដាក់ដើម្បីសាកសួរព្រះមានព្រះភាគក្នុងទីចំពោះព្រះភក្ត្រសោះ ។ ភិក្ខុទាំងនោះ ក៏នៅតែស្ងៀមជាគម្រប់បីដង ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ទីងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើមានសេចក្តីសង្ស័យ អ្នកទាំងឡាយមិនហ៊ានសាកសួរ (តថាគត) ព្រោះសេចក្តីគោរពក្នុងសាស្តា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសម្ងាញ់ចូរប្រាប់ដល់ភិក្ខុជាសម្ងាញ់ផងចុះ ។ លុះព្រះមានព្រះភាគមានព្រះពុទ្ធដីកាយ៉ាងនេះហើយ ភិក្ខុទាំងនោះក៏នៅស្ងៀម ។ គ្រានោះ ព្រះអានន្ទមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ជាអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះ ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាយ៉ាងនេះ ក្នុងភិក្ខុសង្ឃនេះ ព្រោះថា សេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា មិនមានដល់ភិក្ខុ សូម្បីមួយរូប ក្នុងភិក្ខុសង្ឃនេះឡើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកនិយាយដោយសេចក្តីជ្រះថ្លា ម្នាលអានន្ទ ញាណតថាគត ក៏ដឹងពិតក្នុងសេចក្តីនេះថា សេចក្តីសង្ស័យក្តី សេចក្តីងឿងឆ្ងល់ក្តី ក្នុងព្រះពុទ្ធ ឬព្រះធម៌ ឬព្រះសង្ឃ ក្នុងមគ្គ ឬបដិបទា មិនមានដល់ភិក្ខុសូម្បីមួយរូប ក្នុងភិក្ខុសង្ឃនេះឡើយ ម្នាលអានន្ទ ព្រោះថា បណ្តាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុណាដែលមានគុណធម៌យ៉ាងទាប

បំផុត កិកូនោះ គង់ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជានិយតបុគ្គល មានការត្រាស់ដឹង ប្រព្រឹត្តទៅក្នុងខាងមុខ ។

[១៤៣] *គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញុាំងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។ នេះជាបច្ឆិមវាចារបស់ព្រះតថាគត ។*

[១៤៤] *លំដាប់នោះ ព្រះមានព្រះភាគទ្រង់ចូលកាន់បឋមជ្ឈាន ចេញអំពីបឋមជ្ឈាន ហើយចូលកាន់ទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈានហើយចូលកាន់តតិយជ្ឈាន ចេញអំពីតតិយជ្ឈាន ហើយចូលកាន់ចតុត្ថជ្ឈាន ចេញអំពីចតុត្ថជ្ឈានហើយ ចូលកាន់អាកាសានញ្ចាយតនសមាបត្តិ ចេញអំពីអាកាសានញ្ចាយតនសមាបត្តិហើយ ចូលកាន់វិញ្ញាណញ្ចាយតនសមាបត្តិ ចេញអំពីវិញ្ញាណញ្ចាយតនសមាបត្តិហើយ ចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិហើយ ចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ចូលកាន់សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញា និងវេទនា) ។ គ្រានោះ ព្រះអានន្ទមានអាយុ ពោលទៅនឹងព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រអនុរុទ្ធដ៏ចម្រើន ព្រះមានព្រះភាគបរិនិព្វានហើយឬ ។ ព្រះអនុរុទ្ធតបថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគមិនទាន់បរិនិព្វានទេ ព្រះអង្គទ្រង់ចូលកាន់*

สญฺญาเวทยิตนิโรธ ฯ คฺราโนะ ព្រះមានព្រះភាគទ្រង់ចេញចាកសញ្ញាវេទ-
យិតនិរោធសមាបត្តិហើយ ចូលមកកាន់នេវសញ្ញានាសញ្ញាយតន-
សមាបត្តិវិញ ចេញអំពីនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ចូលមក
កាន់អាកិញ្ចញ្ញាយតនសមាបត្តិវិញ ចេញអំពីអាកិញ្ចញ្ញាយតនសមាបត្តិ
ហើយ ចូលមកកាន់វិញ្ញាណញ្ចាយតនសមាបត្តិវិញ ចេញអំពីវិញ្ញា-
ណញ្ចាយតនសមាបត្តិហើយ ចូលមកកាន់អាកាសានញ្ចាយតនសមាបត្តិ
វិញ ចេញអំពីអាកាសានញ្ចាយតនសមាបត្តិហើយ ចូលមកកាន់ចតុត្ថ-
ជ្ឈានវិញ ចេញអំពីចតុត្ថជ្ឈានហើយ ចូលមកកាន់តតិយជ្ឈានវិញ ចេញ
អំពីតតិយជ្ឈានហើយ ចូលមកកាន់ទុតិយជ្ឈានវិញ ចេញអំពីទុតិយ-
ជ្ឈានហើយ ចូលមកកាន់បឋមជ្ឈានវិញ ចេញអំពីបឋមជ្ឈានហើយ ក៏
ចូលកាន់ទុតិយជ្ឈានទៀត ចេញអំពីទុតិយជ្ឈានហើយ ក៏ចូលកាន់តតិយជ្ឈាន
ទៀត ចេញអំពីតតិយជ្ឈានហើយ ក៏ចូលកាន់ចតុត្ថជ្ឈានទៀត ฯ លុះព្រះ
មានព្រះភាគទ្រង់ចេញចាកចតុត្ថជ្ឈានហើយ ក៏ទ្រង់បរិនិព្វានក្នុងចន្លោះនោះ ฯ

[๑๔๕] *កាលព្រះមានព្រះភាគបរិនិព្វានហើយ ការកក្រើកនៃផែនដី*
ធំគួរស្បើម គួរព្រឺរោម ក៏កើតមាន ទាំងផ្គរក៏លាន់ឮគគ្រឹកគគ្រេង ព្រមនឹង
ការបរិនិព្វាន ฯ

[๑๔๖] *កាលព្រះមានព្រះភាគបរិនិព្វានហើយ សហម្បតិព្រហ្មក៏*
ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា

ព្រះសាស្តា ដែលឥតបុគ្គលប្រៀបស្មើ ច្រាកដដូច្នេះ ព្រះ

តថាគតជាសម្ពុទ្ធបរិបូណ៌ហើយដោយកម្លាំង ទ្រង់បរិនិព្វាន ហើយ ក្នុងលោកណា ពួកសត្វទាំងអស់ មុខជានឹងជាក់ ចុះនូវភាវៈក្នុងលោក (នោះ) មិនមានឡើយ ។

[១៤៧] *កាលព្រះមានព្រះភាគបរិនិព្វានហើយ ព្រះឥន្ទ្រជាធំជាង ទេវតា ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា*

សង្ខារទាំងឡាយ មិនទៀងហ្ន៎ មានកិរិយាកើតឡើង និង ការសូន្យទៅជាធម្មតា លុះកើតឡើងហើយ ក៏រលត់ទៅ វិញ កិរិយារម្ងាប់នូវសង្ខារទាំងនោះបាន ទើបនាំមកនូវ សេចក្តីសុខ ។

[១៤៨] *កាលព្រះមានព្រះភាគបរិនិព្វានហើយ ព្រះអនុរុទ្ធមានអាយុ ក៏ពោលនូវគាថាទាំងនេះ ព្រមនឹងការបរិនិព្វានថា*

ព្រះមុនីនាថអង្គណា ដែលមិនមានតណ្ហា ទ្រង់ប្រារព្ធនូវ អនុបាទិសេសនិព្វានហើយ ទ្រង់ធ្វើមរណកាល អស្សាស-បស្សាសៈនៃព្រះមុនីនាថជាតាទិបុគ្គល ដែលមានព្រះទ័យ ខ្ជាប់ខ្ជួននោះមិនមានហើយ ។ ព្រះមុនីនាថ ទ្រង់អត់សង្កត់ វេទនាបានដោយចិត្តមិនរួញរា សេចក្តីរលត់នៃចិត្តក៏កើត មាន បីដូចជាការរលត់នៃប្រទីប ។

[១៤៩] *កាលព្រះមានព្រះភាគបរិនិព្វានហើយ ព្រះអានន្ទមានអាយុ ក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា*

กาលដែលព្រះសម្ពុទ្ធ ប្រកបដោយហេតុប្រសើរទាំងពួង ទ្រង់បរិនិព្វានហើយ សេចក្តីញាប់ញ័រក្តី សេចក្តីព្រឺរោមក្តី ក៏កើតមានច្រើនដ ។

[๑๕๐] *កាលព្រះមានព្រះភាគបរិនិព្វានហើយ ភិក្ខុទាំងឡាយណា ដែលមិនទាន់ច្រើសចាករាគៈ មាននៅក្នុងទីនុ៎ះ ភិក្ខុទាំងនោះ ពួកខ្លះក៏ផ្គងខ្លឹងនូវកំភួនដៃហើយកន្ទក់កន្ទេញ ផ្តួលខ្លួនបម្រះនៀលទៅមក ហាក់ដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគតទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោកប្រញាប់ជាត់ទៅពេកណាស់ ។ ឯពួកភិក្ខុណា ដែលច្រើសចាករាគៈហើយ ភិក្ខុទាំងនោះ មានសតិ និងសម្បជញ្ញៈ អត់សង្កត់ដោយគិតថា សង្ខារទាំងឡាយមិនទៀងពិត ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុងខន្ធប្បវត្តិនេះអំពីណា ។*

[๑๕๑] *លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ច្រាប់ពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ណ្ហើយ អ្នកទាំងឡាយ កុំសោយសោក កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ សេចក្តីនេះ ព្រះមានព្រះភាគទ្រង់បានសម្តែងមកអំពីមុនហើយថា សេចក្តីព្រាត់ច្រើស វិនាសប្រែប្រួលចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីមិនព្រាត់ច្រើសនោះក្នុងខន្ធប្បវត្តិនេះអំពីណា ធម្មជាតណា ដែលកើតហើយ ដែលមានហើយ*

ដែលបច្ច័យតាក់តែងហើយ មានសេចក្តីទ្រុឌទ្រោមជាធម្មតា ធម្មជាតនោះឯង បុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ ម្នាលអាវុសោទាំងឡាយ ទេវតាទាំងឡាយ នឹងពោលទោសមិនខាន ។ ព្រះអានន្ទសួរថា បពិត្រអនុរុទ្ធដ៏ចម្រើន ចុះពួកទេវតាធ្វើទុកក្នុងចិត្តដូចម្តេច ។ ព្រះអនុរុទ្ធមានថេរវាចាថា ម្នាលអាវុសោអានន្ទ មានពួកទេវតា (ខ្លះ) ដែលសម្គាល់ គឺនិមិត្តផែនដីក្នុងអាកាស រំសាយសក់កន្ទក់កន្ទេញផ្គងឡើងនូវកំពួនដៃកន្ទក់កន្ទេញ ផ្តួលខ្លួនចុះបម្រះនៀលទៅមកបីដូចជាមានជើងជាច់ហើយថា ព្រះមានព្រះភាគ ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគត ទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់ប្រញាប់បាត់បង់ពេកណាស់ ម្នាលអាវុសោអានន្ទ មានពួកទេវតា (ខ្លះ) ដែលសម្គាល់នូវនិមិត្ត គឺផែនដី លើផែនដី រំសាយសក់កន្ទក់កន្ទេញ ។បេ។ បាត់ទៅ ។ ពួកទេវតាណា ដែលប្រាសចាករាគៈ ទេវតាទាំងនោះ មានសតិសម្បជញ្ញៈ អត់សង្កត់ដោយគិតថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ ក្នុងខន្ធបញ្ចវត្តិនេះអំពីណា ។ គ្រានោះ ព្រះអនុរុទ្ធមានអាយុ និងព្រះអានន្ទមានអាយុធ្វើធម្មីកថា អស់រាត្រីដែលនៅសល់នោះ ។ ទើបព្រះអនុរុទ្ធមានអាយុ ពោលនឹងព្រះអានន្ទមានអាយុថា ម្នាលអាវុសោអានន្ទ អ្នកចូរចូលទៅកាន់ក្រុងកុសិនារា ហើយថ្វាយដំណឹងដល់ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារាថា បពិត្រវាសិដ្ឋគោត្រទាំងឡាយ ព្រះមានព្រះភាគបរិនិព្វានហើយ ឥឡូវអ្នកទាំងឡាយ ចូរសម្គាល់នូវកាលគួរ

ចុះ ។ ព្រះអានន្ទមានអាយុទទួលវាចានៃព្រះអនុរុទ្ធមានអាយុថា អើលោកម្ចាស់ ហើយក៏ស្លៀកស្បង់កាន់យកបាត្រ និងចីវរក្នុងបុព្វណ្ហសម័យ មិនមានកិច្ចជាគម្រប់ពីរឡើយ ចូលទៅកាន់ក្រុងកុសិនារ ។

[១៥២] ក្នុងសម័យនោះឯង ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារកំពុងប្រជុំគ្នា ក្នុងសណ្ឋាគារដ្ឋាន ដោយកិច្ចនីមួយ ។ ទើបព្រះអានន្ទមានអាយុ ចូលទៅកាន់សណ្ឋាគារដ្ឋានរបស់ពួកមល្លក្សត្រិយ៍អ្នកក្រុងកុសិនារនោះ លុះចូលទៅដល់ហើយ ថ្វាយដំណឹងដល់ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារថា បពិត្រវាសិដ្ឋទាំងឡាយ ព្រះមានព្រះភាគបរិនិព្វានហើយ ឥឡូវនេះ សូមទ្រង់ទាំងឡាយ សម្គាល់នូវកាលគួរចុះ ។ ពួកមល្លក្សត្រិយ៍ ពួកបុត្ររបស់មល្លក្សត្រិយ៍ ព្រះសុណិសារបស់មល្លក្សត្រិយ៍ និងភរិយារបស់មល្លក្សត្រិយ៍ ឮពាក្យនេះរបស់ព្រះអានន្ទមានអាយុ ហើយក៏កើតទុក្ខតូចព្រះទ័យ ឆ្អែតដោយសេចក្តីទុក្ខក្នុងចិត្ត ខ្វះរំសាយសក់ កន្ទក់កន្ទេញ ផ្គងកំភួនដៃកន្ទក់កន្ទេញ ផ្តួលខ្លួនចុះបម្រះនៀលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសុគតទ្រង់បរិនិព្វាន ឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ជាត់បង់ទៅឆាប់ពេកណាស់ ។ គ្រានោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារ បង្គាប់ពួករាជបុរសថា ម្នាលនាយ បើដូច្នោះ ចូរអ្នកទាំងឡាយ ប្រមូលគ្រឿងក្រអូប និងកម្រងផ្កា និងគ្រឿងតូរ្យតន្ត្រីទាំងអស់ ដែលមានក្នុងក្រុងកុសិនារ ។ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារ នាំយកគ្រឿងក្រអូប និងកម្រងផ្កា និងគ្រឿងតូរ្យតន្ត្រីនិងសំពត់ ៥០០គូ ចូល

ទៅគាល់ព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុងសាលវនៃរបស់ពួកមល្លក្សត្រិយ៍ ដែលជាទីចូលទៅក្នុងក្រុង លុះចូលទៅដល់ហើយ ក៏ធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈនៃព្រះមានព្រះភាគដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ហើយធ្វើពិតានសំពត់ តាក់តែងរោងបារាំយ៉ាងនេះ ពេញអស់ ១ ថ្ងៃនោះ ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា មានសេចក្តីត្រិះរិះដូច្នេះថា កាលនេះជ្រុលវេលាហើយ នឹងថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុងថ្ងៃនេះមិនទាន់ទេ ចាំថ្ងៃស្អែក សឹមយើងនឹងថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា នាំគ្នាធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះភាគដោយរបាំ ចម្រៀង ភ្លេងប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ហើយធ្វើពិតានសំពត់ តាក់តែងរោងបារាំទាំងឡាយ ហើយញុំងថ្ងៃជាគម្រប់ពីរឲ្យកន្លងទៅទៀត ញុំងថ្ងៃជាគម្រប់បីឲ្យកន្លងទៅទៀត ញុំងថ្ងៃជាគម្រប់បួនឲ្យកន្លងទៅទៀត ញុំងថ្ងៃជាគម្រប់ប្រាំ ឲ្យកន្លងទៅទៀត ញុំងថ្ងៃជាគម្រប់ ៦ ឲ្យកន្លងទៅទៀត លុះថ្ងៃជាគម្រប់ ៧ ទើបពួកមល្លក្សត្រិយ៍ អ្នកក្រុងកុសិនារា មានសេចក្តីត្រិះរិះយ៉ាងនេះថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈនៃព្រះមានព្រះភាគដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ហើយហែទៅតាមទិសខាងត្បូងក្រៅក្រុង ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគអំពីខាងត្បូងនៃក្រុង ។

[๑๕๓] *ក្នុងសម័យនោះឯង មល្លក្សត្រិយ៍ ๘ អង្គ ដែលជាប្រធាន*

ជម្រះសីស:ហើយ ទ្រង់សំពត់ថ្មី គិតគ្នាថា យើងនឹងលើកព្រះសរីរៈនៃព្រះមានព្រះភាគដូច្នេះ តែមិនអាចនឹងលើកបានបាន ។ ទើបពួកមល្លក្សត្រិយ៍អ្នកក្រុងកុសិនារា ពោលនឹងព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន មានហេតុដូចម្តេច មានបច្ចัយដូចម្តេច បានជាមល្លក្សត្រិយ៍ជាប្រធានទាំង ៨ អង្គនេះ ជម្រះសីស:ហើយទ្រង់សំពត់ថ្មី គិតគ្នាថា យើងនឹងលើកព្រះសរីរៈនៃព្រះមានព្រះភាគដូច្នេះ តែមិនអាចនឹងលើកបានបាន ។ ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ទ្រង់ទាំងឡាយផ្សេង បំណងរបស់ពួកទេវតាផ្សេង ។ ពួកមល្លក្សត្រិយ៍សួរទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបំណងរបស់ពួកទេវតាតើដូចម្តេច ។ ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ទ្រង់ទាំងឡាយថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះភាគដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ហើយហៅទៅតាមទិសខាងត្បូងក្រៅក្រុង ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ អំពីខាងត្បូងនៃក្រុង បពិត្រវាសិដ្ឋទាំងឡាយ ឯបំណងរបស់ពួកទេវតាថា យើងរាល់គ្នានឹងធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះភាគដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ដែលជាទិព្វ ហើយហៅទៅខាងជើងតាមទិសខាងជើងនៃក្រុង ហើយចូលទៅកាន់ក្រុងតាមទ្វារខាងជើង ហើយហៅទៅត្រង់កណ្តាលតាមទីកណ្តាលនៃក្រុង ហើយចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុង

มกุฎพนฺธนเจติย របស់មល្លក្សត្រិយ៍ ខាងកើតនៃក្រុង ។ ពួកមល្លក្សត្រិយ៍ ទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន បំណងរបស់ពួកទេវតាយ៉ាងណា ការ ថ្វាយព្រះភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក៏សូមឲ្យសម្រេចយ៉ាងនោះចុះ ។ សម័យនោះឯង ក្រុងកុសិនារាពាសពេញដោយផ្កាមន្ទារវៈ ដោយគំនរប្រមាណ ត្រឹមជង្គង់រហូតដល់ទីជាចន្លោះនៃផ្ទះ និងទុសម្រាប់បង្អែរទូវគូថៈ និងកន្លែង សម្រាប់ចោលទូវសំវាម ។ គ្រានោះ ពួកទេវតា និងពួកមល្លក្សត្រិយ៍ អ្នក ក្រុងកុសិនារា នាំគ្នាធ្វើសក្ការៈគោរពរាប់អានបូជាព្រះសរីរៈ នៃព្រះមានព្រះ ភាគ ដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ ជារបស់ទិព្វខ្លះ របស់មនុស្សខ្លះ ហើយហៅទៅខាងជើងតាមទិសខាងជើង នៃក្រុង ហើយចូលទៅកាន់ក្រុងតាមទ្វារខាងជើង ហើយហៅទៅត្រង់កណ្តាល តាមទីកណ្តាលនៃក្រុង ហើយចេញទៅតាមទ្វារខាងកើត ហើយថ្វាយព្រះ ភ្លើងព្រះសរីរៈនៃព្រះមានព្រះភាគ ក្នុងមកុដពន្ធនចេតិយ របស់ពួកមល្លក្ស-ត្រិយ៍ ខាងកើតនៃក្រុង ។ លំដាប់នោះ ពួកមល្លក្សត្រិយ៍អ្នកក្រុងកុសិនារា ពោលនឹងព្រះអានន្ទមានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងទាំង-ឡាយ នឹងប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះតថាគតដូចម្តេច ។ ព្រះអានន្ទតបថា បពិត្រវាសិដ្ឋទាំងឡាយ ពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជ យ៉ាងណា ពួកមហាបពិត្រ គប្បីប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះតថាគត យ៉ាង នោះចុះ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈនៃ ព្រះចក្រពត្តិរាជដូចម្តេច ។ បពិត្រវាសិដ្ឋទាំងឡាយ ពួកឥស្សរជនរុំសរីរៈនៃ

ព្រះចក្រពត្តិរាជ ដោយសំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយ
សំឡី លុះរុំដោយសំឡីហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំសរីរៈនៃ
ព្រះចក្រពត្តិរាជដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ក្នុងព្រះ
មឈូសមាសដែលជាក់ប្រេង ហើយគ្របដោយមឈូសមាសជទៃ ហើយធ្វើ
ជើងថ្ពរ ទើបថ្វាយព្រះភ្លើងនូវសរីរៈនៃព្រះចក្រពត្តិរាជ ដោយគ្រឿងក្រអូប
គ្រប់យ៉ាង ហើយគេធ្វើព្រះស្ពូបនៃព្រះចក្រពត្តិរាជក្នុងផ្លូវធំបែកជា ៤ បពិត្រ
វាសិដ្ឋទាំងឡាយ ពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រពត្តិរាជ យ៉ាង
នេះឯង បពិត្រវាសិដ្ឋទាំងឡាយ ពួកឥស្សរជនប្រតិបត្តិក្នុងសរីរៈនៃព្រះចក្រ-
ពត្តិរាជ យ៉ាងណាមិញ ពួកមហាបពិត្រគប្បីប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះ
តថាគត គប្បីធ្វើព្រះស្ពូបរបស់ព្រះតថាគតក្នុងផ្លូវធំបែកជា ៤ យ៉ាងនោះចុះ
ពួកជនណា នឹងលើកឡើងនូវផ្ការកម្រងក្តី គ្រឿងក្រអូបក្តី គ្រឿងលម្អិតក្តី ឬ
នឹងថ្វាយបង្គំ ឬធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះស្ពូបនោះ អំពើនោះ នឹងនាំមកនូវប្រ-
យោជន៍ និងសេចក្តីសុខដល់ជនទាំងនោះ អស់កាលយូរអង្វែង ។ គ្រានោះ
ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា បង្គាប់រាជបុរសថា ម្នាលនាយ បើដូច្នោះ
ចូរអ្នកទាំងឡាយ ប្រមូលសំឡីរបស់ពួលមល្លជនមក ។ លំដាប់នោះ ពួក
មល្លក្សត្រ អ្នកក្រុងកុសិនារា នាំគ្នារុំព្រះសរីរៈនៃព្រះមានព្រះភាគ ដោយ
សំពត់ថ្មី លុះរុំដោយសំពត់ថ្មីរួចហើយ ទើបរុំដោយសំឡី លុះរុំដោយសំឡី
ហើយ ក៏រុំដោយសំពត់ថ្មី (ថែមទៀត) រុំព្រះសរីរៈនៃព្រះមានព្រះភាគ
ដោយសំពត់ ៥០០ គូ ដោយទំនងនេះ ហើយតម្កល់ក្នុងព្រះមឈូសមាស

ដែលដាក់ប្រេងហើយគ្របដោយមឈូសមាសដទៃ ហើយធ្វើជើងថ្ពរ ទើបថ្វាយព្រះភ្លើងនូវព្រះសរីរៈនៃព្រះមានព្រះភាគ ដោយគ្រឿងក្រអូបគ្រប់យ៉ាង ។

[១៥៤] សម័យនោះឯង ព្រះមហាកស្សបមានអាយុ និមន្តតាមផ្លូវឆ្ងាយ មកអំពីក្រុងបាវា ទៅកាន់ក្រុងកុសិនារា ជាមួយនឹងភិក្ខុសង្ឆជាច្រើនប្រមាណ ៥០០ រូប ។ លំដាប់នោះ ព្រះមហាកស្សបមានអាយុចៀសចាកផ្លូវ ទៅគង់ក្រោមម្លប់ឈើ ១ ។ ក៏សម័យនោះឯង មានអាជីវកម្នាក់ កាន់ផ្តាមនូារវៈអំពីក្រុងកុសិនារា ដើរតាមផ្លូវឆ្ងាយទៅកាន់ក្រុងបាវា ។ ព្រះមហាកស្សបមានអាយុបានឃើញអាជីវកនោះ ដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលទៅនឹងអាជីវកនោះដូច្នេះថា ម្នាលអាវុសោ អ្នកដឹងដំណឹងព្រះសាស្តារបស់យើងខ្លះដែរ ។ អាជីវកតបថា អើអាវុសោ ខ្ញុំដឹងដែរ ព្រះសមណ-គោតម បរិនិព្វានទៅ ៧ ថ្ងៃ គម្រប់នឹងថ្ងៃនេះហើយ ផ្តាមនូារវៈនេះ ខ្ញុំយកមកអំពីទីបរិនិព្វានរបស់ព្រះសមណគោតមនោះ ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុណាដែលមិនទាន់ប្រាសចាករាគៈ ពួកភិក្ខុនោះ ខ្លះក៏ផ្គងកំភួនដៃ កនូក់កនូញ ដួលបម្រះនៀលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសុគត ទ្រង់បរិនិព្វានឆាប់ពេកណាស់ ព្រះសម្ពុទ្ធមានចក្ខុក្នុងលោក ទ្រង់បាត់ទៅឆាប់ពេកណាស់ ។ ឯពួកភិក្ខុណាដែលប្រាសចាករាគៈហើយ ពួកភិក្ខុនោះ ក៏មានសតិសម្បជញ្ញៈ អត់សង្កត់ថា សង្ខារទាំងឡាយមិនទៀង ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ក្នុងខន្ធប្បវត្តិនេះ មកអំពីណា ។

[១៥៥] សម័យនោះឯង ភិក្ខុបួសចាស់ឈ្មោះសុភទ្ធ អង្គុយក្នុងកណ្តាលបរិសទ្យនោះ ។ លំដាប់នោះ ភិក្ខុបួសចាស់ឈ្មោះសុភទ្ធ ពោលទៅនឹងពួកភិក្ខុទាំងនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ព្រោះថា ពួកយើង មហាសមណៈនោះតែងបៀតបៀនថា អំពើនេះគួរដល់អ្នក អំពើនេះមិនគួរដល់អ្នក ក៏ឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើអំពើនោះបាន មិនប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន ។ គ្រានោះ ព្រះមហាកស្សបហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ ណ្ហើយអ្នករាល់គ្នា កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ ពាក្យនេះព្រះមានព្រះភាគ បានសម្តែងជាមុនហើយថា សេចក្តីព្រាត់ប្រាសវិនាសប្រែប្រួលចាកសត្ត និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់តែងមានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីមិនព្រាត់ប្រាសនោះ ក្នុងខន្ធប្បវត្តិនេះ មកអំពីណា ធម្មជាតណា ដែលកើតហើយ មានហើយ ដែលបច្ចុយតាក់តែងហើយ សឹងមានសេចក្តីទ្រុឌទ្រោមទៅជាធម្មតា ធម្មជាតនោះ បុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមដូច្នេះ (ដោយហេតុណា) ហេតុនេះ មិនមានឡើយ ។

[១៥៦] សម័យនោះឯង ពួកមល្លក្សត្រ ៤ អង្គ ដែលជាប្រធានទ្រង់ជម្រះសីសៈ ហើយទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងធួលនូវជើងថ្ពរនៃព្រះមានព្រះភាគ ដូច្នេះ តែមិនអាចនឹងធួលឲ្យធេះបាន ។ ទើបពួកមល្ល-

ក្សត្រិយ៍ អ្នកក្រុងកុសិនារា បានពោលទៅនឹងព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន មានហេតុដូចម្តេច មានបច្ច័យដូចម្តេច បានជាពួកមល្លក្សត្រិយ៍ ជាប្រធានទាំង ៤ អង្គនេះ ជម្រះសីស:ហើយទ្រង់សំពត់ថ្មីគិតគ្នាថា យើងនឹងឆ្លៀជើងថ្ល នៃព្រះមានព្រះភាគ ដូច្នេះ តែមិនអាចនឹងឆ្លៀឲ្យឆេះបាន ។ ព្រះអនុរុទ្ធតបថា បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ពួកទេវតាផ្សេងគ្នា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបំណងរបស់ពួកទេវតាដូចម្តេច ។ បពិត្រវាសិដ្ឋទាំងឡាយ បំណងរបស់ពួកទេវតាថា ព្រះមហាកស្សបមានអាយុនេះ កំពុងនិមន្តតាមផ្លូវឆ្ងាយចេញអំពីក្រុងបាវា មកកាន់ក្រុងកុសិ-នារា ជាមួយនឹងភិក្ខុសង្ឃជាច្រើន ប្រមាណ ៥០០ រូប ព្រះមហាកស្សបមានអាយុ មិនទាន់បានថ្វាយបង្គំនូវព្រះបាទា នៃព្រះមានព្រះភាគ ដោយដៃរបស់ខ្លួនដរាបណា ជើងថ្លព្រះមានព្រះភាគក៏មិនទាន់ឆេះដរាបនោះ ។ ពួកមល្លក្សត្រិយ៍តបថា បពិត្រលោកម្ចាស់ដ៏ចម្រើន បំណងរបស់ពួកទេវតាយ៉ាងណា ការថ្វាយព្រះភ្លើងនូវព្រះសរីរៈនៃព្រះមានព្រះភាគ ក៏សូមឲ្យសម្រេចយ៉ាងនោះចុះ ។ គ្រានោះ ព្រះមហាកស្សបមានអាយុ ចូលទៅកាន់ជើងថ្ល នៃព្រះមានព្រះភាគក្នុងមកុដពន្ធនចេតិយ របស់ពួកមល្លក្សត្រ ទៀបក្រុងកុសិនារានោះ លុះចូលទៅដល់ហើយ ក៏ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ធ្វើប្រទក្សិណជើងថ្ល ៣ ជុំហើយ បើកអំពីខាងព្រះបាទ ថ្វាយបង្គំព្រះបាទា នៃព្រះមានព្រះភាគ ដោយសិរ្ស: ។ ឯពួកភិក្ខុទាំង ៥០០ រូបនោះ ក៏ធ្វើចីវរឆៀងស្មាម្ខាងហើយ ប្រណម្យអញ្ជលី ធ្វើប្រទក្សិណ ៣ ជុំ ហើយ

ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគ ដោយសិរ្សៈ ។ កាលដែលព្រះមហាកស្សបមានអាយុ និងពួកភិក្ខុទាំង ៥០០ រូបនោះ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគរួចហើយ ជើងថ្ងាព្រះមានព្រះភាគក៏ឆេះឯង ។ ព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែលភ្លើងឆេះហើយ អាការណា ទោះព្រះឆវីក្តី ព្រះចម្មៈក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការនោះ ក៏ឆេះអស់ មិនមានផេះ និងកំញ្ចាមធ្យូងឡើយ សល់នៅតែព្រះសរីរធាតុសុទ្ធ ។ សប្បិ ឬប្រេង ដែលភ្លើងឆេះ ក៏មិនមានផេះកំញ្ចាម យ៉ាងណាមិញ ព្រះសរីរៈរបស់ព្រះមានព្រះភាគដែលភ្លើងឆេះហើយ អាការណា ទោះព្រះឆវីក្តី ព្រះចម្មៈក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការនោះ ក៏ឆេះអស់ មិនមានផេះ និងកំញ្ចាមឡើយ សល់នៅតែព្រះសរីរធាតុសុទ្ធ ក៏យ៉ាងនោះដែរ ។ បណ្តាសំពត់ទាំង ៥០០ គូនោះ សំពត់ពីរ គឺសំពត់ជាន់ក្នុងបំផុត ១ សំពត់ជាន់ក្រៅបំផុត ១ ក៏ឆេះអស់ ។ លុះសរីរៈព្រះមានព្រះភាគ ដែលត្រូវភ្លើងឆេះហើយ ជាទឹកក៏បង្អុរអំពីអាកាស រំលត់ជើងថ្ងានៃព្រះមានព្រះភាគ ។ ទាំងមានទឹកខ្ទុះចេញអំពីដើមសាលព្រឹក្ស រម្ងាប់ជើងថ្ងានៃព្រះមានព្រះភាគ ។ ទើបពួកមល្លក្សត្រ អ្នកក្រុងកុសិនារារម្ងាប់ជើងថ្ងា នៃព្រះមានព្រះភាគដោយទឹកក្រអូបទាំងពួង ។ គ្រានោះ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារា ក៏ធ្វើនូវការបញ្ឈរលំពែង រួចព័ទ្ធដោយកំពែងជុំ ហើយធ្វើសក្ការៈ គោរព រាប់អាន បូជា ព្រះសរីរធាតុរបស់ព្រះមានព្រះភាគដោយរបាំ ចម្រៀង ភ្លេង ប្រគំ ផ្កាកម្រង និងគ្រឿងក្រអូបទាំងឡាយ អស់ ៧ ថ្ងៃ ក្នុងសណ្ឋាគារដ្ឋាន ។

[១៥៧] *ព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត បញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកនៃព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ ពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី ទ្រង់បានឮថា ព្រះមានព្រះភាគទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី បញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ ពួកក្សត្រសក្យៈ អ្នកក្រុងកបិលវត្ថុ ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រសក្យៈ អ្នកក្រុងកបិលវត្ថុ បញ្ជូនរាជទូតទៅកាន់សំណាក់ នៃពួកមល្លក្សត្រអ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគជាញាតិផ្ទាល់របស់យើង យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ។ ពួកក្សត្រពូលិ អ្នកក្រុងអល្លកប្បៈ ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រពូលិ អ្នកក្រុងអល្លកប្បៈ បញ្ជូនរាជទូតទៅកាន់*

សំណាក់នៃពួកមល្លក្សត្រ អ្នកនៅក្នុងក្រុងកុសិនារាថា ព្រះមានព្រះភាគ ជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ពួកក្សត្រកោឡិយៈ អ្នកក្រុងរាមគ្រាម ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រកោឡិយៈ អ្នករាមគ្រាមបញ្ជូនរាជទូតទៅកាន់សំណាក់នៃមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ព្រាហ្មណ៍ដែលនៅក្នុងដែនវេដ្ឋទីបៈ បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយក្នុងក្រុងកុសិនារា ។ ទើបព្រាហ្មណ៍ដែលនៅក្នុងដែនវេដ្ឋទីបៈ បញ្ជូនទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគជាក្សត្រ យើងក៏ជាព្រាហ្មណ៍ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ពួកមល្លក្សត្រអ្នកក្រុងបាវា ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់បរិ-និព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកមល្លក្សត្រ អ្នកក្រុងបាវាបញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុនៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃ

ព្រះមានព្រះភាគ ។ លុះពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ពោលពាក្យយ៉ាងនេះហើយ ពួកមល្លក្សត្រអ្នកក្រុងកុសិនារា បាននាំគ្នាទៅនឹងពួកគណៈទូតទាំងនោះដូច្នេះថា ព្រះមានព្រះភាគទ្រង់បរិនិព្វានហើយ ក្នុងគាមក្ខេត្តរបស់យើង យើងនឹងមិនឲ្យនូវចំណែកព្រះសរីរធាតុនៃព្រះមានព្រះភាគឡើយ ។

[๑๕๘] កាលបើពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះហើយ ទើបទោណព្រាហ្មណ៍និយាយទៅនឹងពួកគណៈទូតទាំងនោះ ដូច្នេះថា

លោកទាំងឡាយដ៏ចម្រើន សូមស្តាប់ពាក្យរបស់ខ្ញុំមួយម៉ាត់សិន ព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជាខន្តិវាទ (អ្នកពោលសរសើរគុណនៃខន្តី) មែនពិត ការប្រហារគ្នា (ច្បាំងគ្នា) ព្រោះតែចំណែកនៃព្រះសរីរធាតុរបស់ឧត្តមបុគ្គលនេះ មិនប្រពៃឡើយ ។ បពិត្រលោកទាំងឡាយដ៏ចម្រើន យើងទាំងអស់គ្នា (គួរតែ) ស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកព្រះសរីរធាតុឲ្យជា ๘ ចំណែក ព្រះស្តូបទាំងឡាយ សូមផ្សាយទៅក្នុងទិសទាំងឡាយចុះ ពួកជនច្រើន គង់ជ្រះថ្លាចំពោះព្រះសម្ពុទ្ធដ៏មានចក្ខុ មិនលែង ។

[๑๕๙] ពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ទទួលពាក្យថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរចែកព្រះសរីរធាតុនៃព្រះមានព្រះភាគ ឲ្យជា ๘ ចំណែកស្មើគ្នាចុះ ។ ទោណព្រាហ្មណ៍ ក៏ទទួលពាក្យរបស់ពួកគណៈទូតទាំង

នោះ ដោយពាក្យថា អើអ្នកដ៏ចម្រើន អើអ្នកដ៏ចម្រើន ហើយក៏ចែកព្រះសរីរ-ធាតុនៃព្រះមានព្រះភាគឲ្យជា ๘ ចំណែកស្មើភាគគ្នា ហើយនិយាយនឹងពួកគណៈទូតទាំងនោះដូច្នេះថា លោកទាំងឡាយដ៏ចម្រើន សូមលោកទាំងឡាយដ៏ចម្រើន ឲ្យតុម្ពានេះដល់ខ្ញុំចុះ ខ្ញុំនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះតុម្ព ។ ពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ក៏បានឲ្យតុម្ពដល់ទោណព្រាហ្មណ៍ ។

[๑๖๐] *ឯពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ទ្រង់បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ។ ទើបពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន ក៏បញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកព្រះសរីរធាតុ នៃព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ។ ពួកមល្លក្សត្រតបថា ចំណែកព្រះសរីរធាតុរបស់ព្រះមានព្រះភាគ មិនមានទេ ព្រះសរីរធាតុទាំង-ឡាយ របស់ព្រះមានព្រះភាគ យើងចែកគ្នាអស់ហើយ ចូរអ្នកទាំងឡាយនាំយកព្រះអង្គារ (ធ្យូង) អំពីកន្លែងដែលថ្វាយព្រះភ្លើងនេះទៅចុះ ។ ពួកក្សត្រមោរិយៈទាំងនោះ ក៏នាំយកព្រះអង្គារអំពីកន្លែង ដែលថ្វាយព្រះភ្លើងនោះទៅ ។*

[๑๖๑] *គ្រានោះ ព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត ទ្រង់បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងក្រុងរាជគ្រឹះ ។ ឯពួកក្សត្រលិច្ឆវី អ្នកក្រុងវេសាលី ក៏បានធ្វើព្រះស្តូបផង ការ*

បូជាផង ចំពោះព្រះសរីរធាតុ នៃព្រះមានព្រះភាគ ក្នុងក្រុងវេសាលី ។ ពួកក្សត្រអ្នកក្រុងកបិលវត្ថុ ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរ-ធាតុនៃព្រះមានព្រះភាគ ក្នុងក្រុងកបិលវត្ថុ ។ ពួកក្សត្រថូលិ អ្នកក្រុងអល្ល-កប្ប: ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមាន ព្រះភាគ ក្នុងក្រុងអល្លកប្ប: ។ ពួកក្សត្រកោឡិយ: អ្នករាមគ្រាម ក៏បាន ធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុង រាមគ្រាម ។ ព្រាហ្មណ៍អ្នកវេដ្ឋទីប: ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងដែនវេដ្ឋទីប: ។ ពួកមល្លក្សត្រ អ្នកក្រុងបាវា ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃ ព្រះមានព្រះភាគ ក្នុងក្រុងបាវា ។ ពួកមល្លក្សត្រ អ្នកក្រុងកុសិនារ ក៏បាន ធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះសរីរធាតុនៃព្រះមានព្រះភាគ ក្នុងក្រុង កុសិនារ ។ ទោណព្រាហ្មណ៍ក៏បានធ្វើព្រះស្តូបផង ការបូជាផង ចំពោះព្រះ តុម្ព ។ ពួកក្សត្រមោរិយ:អ្នកក្រុងបិប្ផលិវន ក៏បានធ្វើព្រះស្តូបផង ការបូជា ផង ចំពោះព្រះអង្គារ ក្នុងក្រុងបិប្ផលិវន ។ រួមព្រះស្តូបតម្កល់ព្រះសរីរធាតុ ទាំងអស់ មាន ៨ ជាគម្រប់ ៩ នឹងព្រះស្តូបដែលតម្កល់ព្រះតុម្ព ជាគម្រប់ ១០ នឹងព្រះស្តូបដែលតម្កល់ព្រះអង្គារ ឯធាតុនិធាន (ទីបញ្ចុះព្រះធាតុ) នេះ ធ្លាប់មានមកហើយយ៉ាងនេះ ។

[๑๖๒] ព្រះសរីរធាតុរបស់ព្រះសម្ពុទ្ធដ៏មានចក្ខុ មានចំនួន ๘ ទោណ ព្រះសារីរធាតុ ๗ ទោណ ជនទាំងឡាយ ធ្វើសក្ការ:បូជា ក្នុងជម្ពូទីប ព្រះ

สรีรธาตุรปสฺ ฺพระสมฺพุทฺธ ชาปุรสฺสเจ็ปฺรเสรีรฺตฺนเจ็ดฺสฺ ๑ โทณาทฺไต ตูก นาคราชทฺเจ็สกฺการปูชา กฺนฺงรามคฺราม ฯ ฺพระทาฒา (จกฺขุม) ๑ ตูก เทวตานำยกเทฺปูชา ฺพระทาฒา ๑ ทฺไต ตูกชนทฺเจ็สกฺการปูชากฺนฺงคนฺธารปุรี ฺพระทาฒา ๑ ทฺไต ตูกชนทฺเจ็สกฺการปูชา กฺนฺงเจ็นรปสฺสฺเตจกาลิงฺค ฺพระ ทาฒา ๑ ทฺไต ตูกนาคราชนำยกเทฺทเจ็สกฺการปูชา ฯ เหตุเตฺตชะนี ฺพระสรีรธาตุรปสฺ ฺพระมานฺพระกาคโนะฺงฺง มหาปฺรเถวีนี้ กฺปานปฺรชาบฺ เจ็ยคฺเรืองปูชาวิเสส ฺงฺพระสรีรธาตุรปสฺ ฺพระสมฺพุทฺธมานจกฺขุนี้ คือตูก สตฺวเจ็ลฺบาบฺทเจ็ยูวคฺเรืองสกฺการ: ชั้เลืองสลุบทำฺงฺบายย ปานทเจ็สกฺการ: เจ็ยลฺหายหายย้ำฺงนี้ ฯ สฺเตจเทวตา สฺเตจนาค นิฺงสฺเตจมนุสฺส ปาน ปูชาหายยจำพาะฺพระสมฺพุทฺธชาหฺมาสฺ ทำฺงตูกมนุสฺสอฺนกปฺรเสรี กฺปานเทฺจการ ปูชาฺพระอคฺคหายยชูเถาะเจ็ย เพาะเหตุโนะ อฺนกทำฺงฺบายย จูรผฺตฺงอญลี เฺบืง ถฺายยปงฺคฺพระพุทฺธชาหฺมาสฺโนะจุ เพาะถา ฺพระพุทฺธชาหฺมาสฺทำฺงฺบายย ชาปุคฺคลรกปานกฺร เจ็ยรยโนกปฺยทำฺงฺบายย ฯ ฺพระทนฺตทำฺง ๔๐ คสฺกฺตี เกสากฺตี ฺพระเลามากฺตี ทำฺงอสฺ ตูกเทวตาเจ็ลโนกฺนฺงจกฺรวาลตๆ คฺนา นำยกเทฺมยๆ ฺนกสฺ ฯ

- ๔กำบฺ ตฺรูเจ็ ๑กุฑว: , ๔กุฑว: ตฺรูเจ็ ๑ปตฺต: , ๔ปตฺต: ตฺรูเจ็ ๑อาฬฺหก: , ๔อาฬฺหก: ตฺรูเจ็ ๑ โทณ: , ๑โทณ: ตฺรูเจ็ ๑๖ นาฬิโตจ ฯ ๒นาฬิโตจ ตฺรูเจ็ ๑นาฬิธำรปสฺอฺนกมคธ: , ๑นาฬิธำรปสฺอฺนกมคธ: ตฺรูเจ็ ๑ คีฬูกฺราม (๑ โทณ: ตฺรูเจ็ ๘ คีฬู , ๘ โทณ: ตฺรูเจ็ ๖๔ คีฬูกฺราม) ฯ

มหาปรินิพฺพานสุตฺตที่ ๓ จบ

អដ្ឋកថា

មហាបរិនិព្វានសូត្រ

និទានកថា

[๖๗] *មហាបរិនិព្វានសូត្រ មានពាក្យផ្តើមថា* **ឯវមេ សុតំ** *ជាដូច្នេះ ។ ពណ៌នាសេចក្តីតាមលំដាប់បទក្នុងមហាបរិនិព្វានសូត្រនោះដូច្នេះ បទថា* **គិជ្ឈ-កូដេ** *សេចក្តីថា លើភ្នំឈ្មោះថា* **គិជ្ឈកូដ** *ព្រោះមានហ្វូង សត្វត្មាតនៅលើកំពូល ឬមានកំពូលស្រដៀងសត្វត្មាត ។ បទថា* **អភិយាតុកាមោ** *បានដល់ស្តេចមានព្រះបំណងនឹងចេញទ័ពជណ្តើមដែនវជ្ជី ។ បទថា* **វជ្ជី** *បានដល់ពួកស្តេចវជ្ជី ។ បទថា* **ឯវមហិទ្ធិកេ** *បានដល់ ប្រកបដោយរាជឫទ្ធិដ៏ធំយ៉ាងនេះ ។ ព្រះបាទអជាតសត្តុ ត្រាស់ដល់ការៈដែលស្តេចវជ្ជីទាំងនោះសាមគ្គីគ្នា ដោយព្រះតម្រាស់នេះ ។ បទថា* **ឯវមហានុភាវេ** *បានដល់ ប្រកបដោយអានុភាពច្រើនយ៉ាងនេះ ។ ព្រះបាទអជាតសត្តុ ត្រាស់ដល់ការៈដែលស្តេចវជ្ជីទាំងនោះ ទ្រង់សិក្សាហត្ថិសិល្បៈជាដើម ដែលលោកសំដៅយកពោលថា (ព្រះអានន្ទដ៏មានអាយុ) ក៏បានឃើញពួកលិច្ឆវីកុមារច្រើននាក់កំពុងធ្វើគ្រឿងក្រោះក្នុងផ្ទះ ជាទីរៀននូវសិល្បៈ កំពុងបាញ់សរតាមរន្ធចន្ទោងដ៏តូច អំពីចម្ងាយឲ្យចេញទៅតៗ គ្នា មិនឲ្យជាប់ឡើយ ។ បទថា* **ឧច្ឆេជ្ជាមិ** *គឺនឹងកាត់ផ្តាច់ ។ បទថា* **វិនាសេស្សាមិ** *គឺនឹងធ្វើឲ្យដល់សេចក្តីមិនប្រាកដ ។ ក្នុងពាក្យថា* **អនយព្យសនំ** *នេះ សេចក្តីចម្រើនមិនមាន ហេតុនោះ ទើបឈ្មោះថា* **អនយ** *។ ពាក្យថា* **អនយ** *នេះជាឈ្មោះរបស់សេចក្តីមិនចម្រើន ។*

សេចក្តីមិនចម្រើននោះ រមែងកម្ចាត់ចោលនូវប្រយោជន៍ និងសេចក្តីសុខ ហេតុនោះ ទើបឈ្មោះថា **ព្យសន** ។ ពាក្យថា **ព្យសន** នេះ ជាឈ្មោះនៃ សេចក្តីវិនាស មានវិនាសញាតិជាដើម ។ បទថា **អាចាធេស្សាមិ** ប្រែថា នឹងឲ្យដល់ ។

បានញ្ចថា ព្រះបាទអជាតសត្តុនោះ ត្រាស់ចំពោះការប្រយុទ្ធយ៉ាងនេះ ក្នុងឥរិយាបថមានឈរ និងអង្គុយជាដើម ទើបបញ្ជាកងទ័ពយ៉ាងនេះថា ពួក អ្នកចូរត្រៀមចេញទ័ព ។ ព្រោះហេតុអ្វី ។ បានញ្ចថា ត្រង់តំបន់បដ្តនគ្រាម នៃទន្ទេគង្គា ព្រះបាទអជាតសត្តុទ្រង់មានអំណាចកន្ទះយោជន៍ ពួកស្តេច លិច្ឆវីមានអំណាចកន្ទះយោជន៍ ។ អធិប្បាយថា ក៏ក្នុងតំបន់នេះ ជាទីកន្ទែង ដែលធ្លាក់នៅខាងក្រោមអំណាចឃុំគ្រង ។ ម្យ៉ាងទៀត ក្នុងទីនោះវត្ថុដែលមាន តម្លៃច្រើនធ្លាក់អំពីជើងភ្នំ ។ កាលព្រះបាទអជាតសត្តុ ទ្រង់ជ្រាបដូច្នោះហើយ ទ្រង់ព្រះតម្រិះថា ទៅថ្ងៃនេះ ទៅថ្ងៃស្អែកនេះ ទើបត្រៀមភ្លាម ពួកស្តេចលិច្ឆវី ទ្រង់មានសាមគ្គីគ្នា ទើបនាំគ្នាទៅមុន ដណ្តើមរបស់មានតម្លៃជាច្រើនអស់ ។ ព្រះបាទអជាតសត្តុស្តេចទៅដល់ក្រោយ ទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ខឹង ក្រោធ យាងទៅ ។ ស្តេចលិច្ឆវីទាំងនោះ ក៏ធ្វើយ៉ាងនោះឯងសូម្បីក្នុងឆ្នាំត មក ។ ព្រោះហេតុនោះ ទើបព្រះបាទអជាតសត្តុ ទ្រង់ចងអាឃាតដ៏ខ្លាំងក្លា ទ្រង់បានធ្វើយ៉ាងនោះក្នុងគ្រានោះ ។ តពីនោះ ទ្រង់ត្រិះរិះថា ឈ្មោះថា ការ ប្រយុទ្ធនឹងគណៈស្តេចជារឿងធ្ងន់ ឈ្មោះថា ការច្បាំងដែលឥតប្រយោជន៍ សូម្បីតែម្តងក៏មិនត្រូវមាន តែកាលប្រឹក្សានឹងបណ្ឌិតត្រឹមតែម្នាក់ រមែងមិនខុស ភ្លាត់ ក៏បណ្ឌិតដូចព្រះសាស្តាមិនមាន ទាំងព្រះសាស្តា ក៏ប្រថាប់នៅក្នុងវិហារ

ជិតៗ នេះឯង ។ ណ្ហើយចុះ អញនឹងបញ្ជូនមនុស្សទៅទូលសួរ បើអញទៅ ឯង នឹងមានប្រយោជន៍អ្វី ព្រះសាស្តាក៏នឹងទ្រង់តុណ្ហីភាព កាលមិនជាប្រ-យោជន៍ដូច្នេះ ព្រះសាស្តានឹងត្រាស់ថា ព្រះរាជាស្តេចទៅក្នុងទីនោះ នឹងមានប្រយោជន៍អ្វី ។ ទើបព្រះរាជាបញ្ជូនវស្សការព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍ទៅ ហើយ ក៏ក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគ ។ ដោយហេតុនោះ ទើបលោកពោលថា **អថ ខោ រាជា ។បេ។ អាចាទេស្សាមិ វជ្ជឹ** ដូច្នេះ ។

អធិប្បាយ អបរិហានីយធម៌

[៦៨] បទថា **ភគវន្តំ វីជយមានោ** សេចក្តីថា ព្រះថេរៈឈរព័ត ថ្វាយព្រះមានព្រះភាគតាមទំនៀម តែព្រះមានព្រះភាគ ទ្រង់នឹងត្រជាក់ ឬទ្រង់ក្តៅ ក៏មិនមែន ។ ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍ហើយ ទ្រង់មិនប្រឹក្សានឹងព្រាហ្មណ៍នោះ ត្រឡប់មានព្រះបំណងប្រឹក្សានឹងព្រះថេរៈ ទើបត្រាស់បទថា **កិន្តិ តេ អានន្ទ សុតំ** ដូច្នេះជាដើម ។ បទថា **អភិណ្ហ-សន្និចាតា** សេចក្តីថា ប្រជុំគ្នាមួយថ្ងៃ ៣ ដងខ្លះ ប្រជុំគ្នាជាចន្ទោះខ្លះ ឈ្មោះថា ប្រជុំគ្នារឿយៗ ។ បទថា **សន្និចាតពហុលា** សេចក្តីថា កាលមិនឈប់ សម្រាកថា កាលម្សិលមិញ ក៏ប្រជុំគ្នាហើយ ទាំងថ្ងៃមុនក៏ប្រជុំគ្នាហើយ ថ្ងៃនេះ នឹងប្រជុំគ្នាធ្វើអ្វីទៀត ឈ្មោះថា ច្រើនដោយការប្រជុំ ។ បទថា **យាវកីវញ្ច** ប្រែថា អស់កាលត្រឹមណា ។ បទថា **វុឌ្ឍិយេវ អានន្ទ វជ្ជីនំ ចាជិកង្ខា នោ បរិហានិ** សេចក្តីថា ព្រោះកាលមិនប្រជុំគ្នារឿយៗ មិនស្តាប់ដំណឹងដែលមក អំពីគ្រប់ទិស គ្រប់ផ្លូវ ក៏មិនដឹងរឿងវឹកវរដែលកើតឡើងអំពីខេត្ត ស្រុក ឬ

និគមឯណោះ ឬក្រុមចោរជួបជុំក្នុងទីឯណោះ ។ សូម្បីពួកចោរដឹងថា ពួកស្តេចនាំគ្នាប្រមាទ ទើបប្លន់ស្រុក និងនិគមជាដើម ធ្វើជនបទឲ្យវិនាស ។ ពួកស្តេចរមែងសាបសូន្យដោយប្រការដូច្នេះ ។ តែកាលប្រជុំគ្នារឿយៗ ដឹងដំណឹងនោះៗ បន្ទាប់អំពីនោះ ក៏បញ្ជូនកម្លាំងទៅបង្ក្រាបចំណែកដែលមិនមែនមិត្ត សូម្បីចោរទាំងឡាយដឹងថា ពួកស្តេចមិនប្រមាទ ពួកយើងក៏មិនអាចនឹងប្រមូលគ្នាជាពួកត្រាច់ទៅបាន ហើយក៏បែកគ្នាទៅ ។ ស្តេចទាំងឡាយរមែងចម្រើនដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សេចក្តីចម្រើនតែងមានប្រាកដដល់ពួកវជ្ជីក្សត្រិយ៍ សេចក្តីសាបសូន្យមិនមានឡើយ ។ បណ្តាបទទាំងនោះ បទថា **ចាដិកង្ខា** *ប្រែថា គប្បីប្រាថ្នា អធិប្បាយថា គប្បីឃើញយ៉ាងនេះថា សេចក្តីចម្រើននឹងមានពិតប្រាកដ ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សមគ្គា** *ដូច្នេះជាដើមថា កាលស្តេចប្រជុំលាន់ឮឡើង ពួកស្តេចលិច្ឆវីធ្វើការបណ្តោះបណ្តែថា ថ្ងៃនេះ យើងមានកិច្ច ថ្ងៃនេះមានមង្គល ដូច្នេះ ឈ្មោះថា មិនព្រមព្រៀងគ្នាប្រជុំ ។ តែពេលបានឮសំឡេងស្តេរ កំពុងបរិភោគក្តី កំពុងតែងខ្លួនក្តី កំពុងស្លៀកសំពត់ក្តី បរិភោគបានពាក់កណ្តាលក្តី តែងខ្លួនបានពាក់កណ្តាលក្តី កំពុងស្លៀកសំពត់ក្តី ក៏ចូលប្រជុំ ឈ្មោះថា ព្រមព្រៀងគ្នាប្រជុំ ។ ចំណែកចូលប្រជុំហើយ ក៏គិតក៏ប្រឹក្សាគ្នា ធ្វើកិច្ចដែលគួរធ្វើ មិនឈប់ប្រជុំមុនក្រោយ ឈ្មោះថា ព្រមព្រៀងគ្នាលើកលែងប្រជុំ ។ កាលមិនលះការប្រជុំគ្នាយ៉ាងនេះហើយ ពួកដែលទៅមុនមានសេចក្តីគិតយ៉ាងនេះថា ពួកយើងបានឮតែនិយាយគ្នាក្រៅ*

ការ ឥឡូវនេះ នឹងនិយាយតែសាច់ការ ។ តែកាលលើកលែងប្រជុំព្រមគ្នា ក៏ឈ្មោះថា ព្រមព្រៀងគ្នាលើកលែងប្រជុំ ។ មួយទៀតបានឮថា សេចក្តីវឹកវរ ឬក្រុមចោរប្រជុំគ្នា នៅខេត្ត ស្រុក ឬនិគម ក្នុងទីឯណោះ កាលសាកសួរគ្នាថា អ្នកណានឹងទៅធ្វើការបង្ក្រាបបច្ចាមិត្តហ្ន៎ ក៏ជណ្តើមគ្នា ពោលថា ខ្ញុំមុនខ្ញុំមុន ហើយនាំគ្នាទៅក្តី ឈ្មោះថា ព្រមព្រៀងលើកលែងប្រជុំ ។ តែកាលការងារបស់ស្តេចមួយអង្គ ត្រូវវៀរទៅ ពួកស្តេចដ៏សេស ក៏បញ្ជូនបុត្រ និងបងប្អូនទៅជួយការងារបស់ស្តេចអង្គនោះ មិននិយាយចំពោះស្តេចដែលជាអាគន្តុកៈថា មេត្តាស្តេចទៅដំណាក់របស់ស្តេចអង្គឯណោះចុះ បើសង្គ្រោះព្រមគ្នាទាំងអស់ក្តី និងកាលការងារមង្គល រោគ ឬសុខ ទុក្ខ ដូច្នោះ យ៉ាងដទៃកើតទ្បើងដល់ស្តេចអង្គនោះ ក៏នាំគ្នាទៅជួយក្នុងរឿងនោះទាំងអស់ក្តី ឈ្មោះថា ព្រមព្រៀងគ្នាធ្វើកិច្ច ដែលអ្នកវជ្ជគប្បីធ្វើ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អប្បញ្ញត្តំ** *ដូច្នេះជាដើមថា មិនតាំងកាសុី ពន្ធ ឬពលី ឬអាជ្ញាដែលមិនធ្លាប់ធ្វើ ឈ្មោះថា មិនបញ្ញត្តច្បាប់ដែលមិនបានបញ្ញត្ត ។ ចំណែកប្រើច្បាប់ ដែលមានមកពីបុរាណបវេណី ឈ្មោះថា មិនដកច្បាប់ដែលលោកបានបញ្ញត្តហើយ ។ កាលបុគ្គលត្រូវគេចាប់មកបង្ហាញថាជាចោរ មិនព្រមវិនិច្ឆ័យ បញ្ជាឲ្យជាក់ទោសដោយជាច់ខាតតែម្តង ឈ្មោះថា មិនកាន់តាមប្រព្រឹត្តតាមច្បាប់ក្នុងដែនវជ្ជីអំពីបុរាណ ។ កាលស្តេចទាំងនោះបញ្ញត្តច្បាប់ដែលមិនទាន់បញ្ញត្ត ពួកអ្នកដែលត្រូវបៀតបៀនដោយកាសុីថ្មីៗ ជាដើមដ៏ងថា អាត្មាអញត្រូវបៀតបៀន អ្នកណា នឹងនៅក្នុងដែនរបស់ស្តេចទាំងនេះបានហើយក៏នាំគ្នាទៅកាន់ជាយដែន ធ្វើជាចោរខ្លះ ជាបក្ខពួករបស់ចោរខ្លះ ប្លន់*

ជនបទ ។ កាលពួកស្តេចដកច្បាប់បញ្ញត្តិ មិនរក្សាការ៉ីជាដើម ដែលមានមក តាមប្រពៃណី ឃ្វាំងក៏សាបសូន្យទៅ តអំពីនោះ កងទ័ព ដំរី សេះ និង រេហ៍ពល កាលមិនបានវត្ថុជាប់ជានិច្ច សូម្បីអ្នកធ្វើការងារដែលជិតស្និទ្ធជា ដើម ក៏នឹងសាបសូន្យកម្លាំងចិត្តកម្លាំងកាយ ពួកគេក៏មិនគួរនឹងច្បាំង មិនគួរ នឹងធ្វើឲ្យចម្រើនលូតលាស់បាន ។ កាលមិនប្រព្រឹត្តវជ្ជីធម៌ដែលបុរាណធ្លាប់ ប្រព្រឹត្ត មនុស្សក្នុងព្រំដែនក៏នឹងនាំគ្នាក្រោធថា ពួកស្តេចធ្វើកូន ឪពុក ធ្វើបង ប្អូនរបស់អញ ដែលមិនមែនជាចោរ ថាជាចោរ កាប់សម្លាប់គ្នាហើយ នាំគ្នា អូសទៅជាយដែន ធ្វើចោរខ្លះ ធ្វើជាបក្ខពួករបស់ចោរខ្លះ ប្លន់ជនបទ ។ ពួកស្តេច រមែងសាបសូន្យ ដោយអាការយ៉ាងនេះ ។ តែកាលពួកស្តេចបញ្ញត្តច្បាប់ ដែលបញ្ញត្តហើយ ពួកមនុស្សក៏នឹងនាំគ្នារីករាយត្រេកអរថា ពួកស្តេចធ្វើតែ ច្បាប់ដែលមកតាមប្រពៃណី ដូច្នេះហើយ ក៏នឹងនាំគ្នាធ្វើការងារផ្សេងៗ មាន កសិកម្ម និងពាណិជ្ជកម្មជាដើម ឲ្យកើតភោគផលបរិបូណ៌ ។ កាលមិនដក ច្បាប់ដែលបានបញ្ញត្ត ហើយរក្សាពន្ធជារជាដើម ដែលមានមកតាមប្រពៃណី ឃ្វាំងក៏ចម្រើន តអំពីនោះ ទ័ពដំរី សេះ និងពលទាហាន កាលបានវត្ថុ ជាប់ជានិច្ច អ្នកធ្វើការងារដែលជិតស្និទ្ធ សម្បូរដោយកម្លាំងចិត្ត កម្លាំងកាយ ហើយគួរច្បាំងបាន គួរនឹងញុំាងសេចក្តីចម្រើនបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចោរាណំ វជ្ជិធម្មំ** នេះ ដូច្នេះ បានឮថា ពួកស្តេចវជ្ជីពីមុនមិនត្រាស់ថា កាលមនុស្សត្រូវគេនាំមក សម្តែងថា អ្នកនេះ ជាចោរ ពួកលោកចូរចាប់ចោរនោះ ហើយប្រគល់ឲ្យមហាមាត្យ ផ្នែកខាង វិនិច្ឆ័យ ។ ចំណែកអមាត្យទាំងនោះ វិនិច្ឆ័យហើយ ប្រសិនបើមិនមែនចោរ

ក៏ដោះលែងទៅ បើជាចោរក៏មិននិយាយពាក្យណាមួយដោយខ្លួនឯង ហើយប្រគល់ឲ្យមហាមាត្រដែលជាចៅក្រម ។ មហាមាត្រដែលជាចៅក្រមវិនិច្ឆ័យហើយ បើមិនមែនចោរ ក៏ដោះលែងទៅ បើជាចោរ ក៏ប្រគល់ឲ្យដល់មហាមាត្រ ផ្នែកដែលឈ្មោះថា គណៈវិនិច្ឆ័យ ។ គណៈវិនិច្ឆ័យទាំងនោះ វិនិច្ឆ័យហើយ បើមិនមែនចោរក៏ដោះលែងទៅ បើជាចោរ ក៏ប្រគល់ឲ្យមហាមាត្រ ៨ ត្រកូល ។ មហាមាត្រ ៨ ត្រកូលនោះ ក៏ធ្វើយ៉ាងនោះដូចគ្នា ហើយប្រគល់ឲ្យសេនាបតី ។ សេនាបតីក៏ប្រគល់ឲ្យដល់ឧបរាជ ឧបរាជក៏ប្រគល់ថ្វាយចំពោះព្រះរាជា ។ព្រះរាជាវិនិច្ឆ័យហើយ បើថា មិនមែនចោរ ក៏ដោះលែងទៅ បើថាជាចោរ ក៏ទីឆបញ្ជាឲ្យស្មៀនអានច្បាប់បវេណី ក្នុងច្បាប់បវេណីនោះ សរសេរថា អ្នកណាធ្វើខុសច្បាប់នេះ អ្នកនោះនឹងត្រូវមានទោសយ៉ាងនេះ ។ ព្រះរាជាទ្រង់នាំការធ្វើរបស់អ្នកនោះ មកធៀបនឹងបទច្បាប់នោះហើយ ទ្រង់ដាក់ទោសតាមសមគួរដល់កំហុសនោះ ដូច្នោះ កាលពួកស្តេចកាន់រាជ្ជធម៌ដែលព្រះរាជាបុរាណធ្លាប់ប្រព្រឹត្តមក មនុស្សទាំងឡាយ រមែងមិនតិះដៀល ។ ពួកស្តេចទាំងឡាយ រមែងធ្វើការងារតាមប្រពៃណីបុរាណ ស្តេចទាំងនោះ រមែងមិនមានទោស រមែងមានទោសតែយើងប៉ុណ្ណោះ ព្រោះដូច្នោះ ទើបមិនប្រមាទក្នុងការងារ ។ ស្តេចទាំងឡាយ រមែងចម្រើនដោយអាការយ៉ាងនេះ ។ ដោយហេតុនេះ ទើបព្រះមានព្រះភាគត្រាស់ថា សេចក្តីចម្រើនតែងមានច្រាកដដល់ពួកវជ្ជីក្សត្រ សេចក្តីសាបសូន្យមិនមានឡើយ ។

បទថា **សក្ការោន្តិ** បានដល់ កាលធ្វើសក្ការៈដល់ស្តេចវជ្ជីទាំងនោះ យ៉ាងណាមួយ រមែងធ្វើតែល្អៗ ប៉ុណ្ណោះ ។ បទថា **គរុករោន្តិ** បានដល់ ធ្វើការ

លើកសរសើរភាពជាអ្នកគួរគោរព ។ បទថា **មาเนนฺติ** *បានដល់ ស្រឡាញ់ ដោយចិត្ត ។ បទថា* **ปูเชนฺติ** *បានដល់ សម្តែងការគោរព ។ បទថា* **สោតพฺพំ มญฺเญนฺติ** *បានដល់ ទៅប្រណិប័តន៍មួយថ្ងៃ ២-៣ដង រមែងសម្គាល់ពាក្យរបស់ស្តេចវជ្ជីទាំងនោះថា គួរស្តាប់ គួរជឿ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីនោះដូច្នេះ ។ ជនពួកណាមិនធ្វើសក្ការៈដល់ស្តេចចាស់យ៉ាងនេះ និងមិនទៅប្រណិប័តន៍ស្តេចទាំងនោះ ដើម្បីស្តាប់ឱវាទ ជនទាំងនោះ ត្រូវស្តេចទាំងនោះបោះបង់ចោល មិនឲ្យឱវាទ ដាក់ចិត្តតែខាងលេងសប្បាយ ក៏រមែងសាបសូន្យចាកភាពជាព្រះរាជា ។ ចំណែកស្តេចពួកណា បដិបត្តិតាមយ៉ាងនោះ ស្តេចដែលចាស់ រមែងទូន្មានប្រពៃណីបុរាណដល់ស្តេចទាំងនោះថា វត្តនេះ គួរធ្វើ វត្តនេះមិនគួរធ្វើ សូម្បីដល់សម័យធ្វើសង្គ្រាម ក៏រមែងសម្តែងឧបាយថា គួរចូលទៅយ៉ាងនេះ គួរចេញទៅយ៉ាងនេះ ។ ស្តេចទាំងនោះទទួលឱវាទ បដិបត្តិតាមឱវាទ អាចរក្សារាជប្រពៃណីបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកវជ្ជីក្សត្រ សេចក្តីសាបសូន្យមិនមានឡើយ ។ បទថា* **กุลิตฺถิโย** *បានដល់ ស្រីមេផ្ទះរបស់ត្រកូល ។ បទថា* **กุลกุมาริโย** *បានដល់ ធីតារបស់ស្រីមេផ្ទះទាំងនោះ អ្នកមិនទាន់បានជាឥស្សរៈ ។ ក្នុងបទថា* **ขิกฺกสฺส ปสยฺห** *នេះ បទថា* **ขิกฺกสฺส** *ក្តី* **ปสยฺห** *ក្តី នេះជាឈ្មោះនៃអាការកំហែងបង្ខំ ។ សាសនិកជនសូត្រថា* **ขิกฺกสฺส** *ដូច្នេះក៏មាន ។ ក្នុងបទទាំងនោះ បទថា* **ขิกฺกสฺส** *ប្រែថា អូសទាញ ។ បទថា* **ปสยฺห** *គឺគ្របសង្កត់ ។ កាលស្តេចទាំងនោះធ្វើយ៉ាង*

នេះ ពួកមនុស្សក្នុងដែន ក៏នាំគ្នាក្រោធថា ពួកស្តេចទាំងនេះចាប់កូន និងមែ៉ ក្នុងផ្ទះរបស់អញខ្លះ ចាប់កូនស្រីដែលអញយកមាត់បឺតសម្បារជាដើម ចិញ្ចឹម ធំធាត់មកដោយកម្លាំងញើសឈាម ឲ្យនៅក្នុងផ្ទះរបស់ខ្លួនខ្លះ ហើយចូលទៅ ក្នុងចុងដែនធ្វើជាចោរខ្លះ ជាបក្ខពួកចោរខ្លះ ប្លន់ជនបទ ។ តែកាលមិនធ្វើ យ៉ាងនោះ ពួកមនុស្សក្នុងដែន ក៏ខ្វល់ខ្វាយតិច ធ្វើការងាររបស់ខ្លួន រមែង ធ្វើឃ្លាំងឲ្យចម្រើន ។ គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ក្នុង សេចក្តីនេះ ដោយប្រការដូច្នេះ ។

បទថា **វដ្ឋិំ វដ្ឋិចេតិយានិ** *សេចក្តីថា ទីកន្លែងរបស់យក្ខ ឈ្មោះថា ចេតិយ ព្រោះអត្ថថា គេធ្វើយ៉ាងស្អាតក្នុងដែន គឺវដ្ដរបស់ពួកស្តេចវជ្ជី ។ បទថា* **អព្ភន្តរានិ** *គឺតាំងនៅខាងក្នុងព្រះនគរ ។ បទថា* **ពាហិរានិ** *គឺតាំងនៅ ខាងក្រៅព្រះនគរ ។ បទថា* **និន្នបុព្វំ** *ប្រែថា ដែលគេធ្លាប់ថ្វាយ ។ បទថា* **កតបុព្វំ** *គឺដែលគេធ្លាប់ធ្វើ ។ បទថា* **នោ បរិហាបេស្សន្តិ** *សេចក្តីថា នឹង មិនឲ្យថយចុះ ធ្វើដូចអំពីដើមនុ៎ះឯង ។ ពិតហើយ កាលស្តេចវជ្ជីដកពលីកម្ម ដែលត្រឹមត្រូវតាមធម៌ ពួកទេវតា រមែងមិនធ្វើការរក្សាដែលចាត់ចែងយ៉ាងល្អ ទាំងមិនអាចនឹងញ៉ាំងទុក្ខ ដែលមិនទាន់កើតឲ្យកើតឡើង ធ្វើរោគក្អក រោគ ក្នុងក្បាលជាដើម ដែលកើតឡើងហើយឲ្យកម្រើក កាលមានសង្គ្រាមក៏មិន ជួយ តែកាលពួកស្តេចវជ្ជីមិនដកពលីកម្ម ទេវតាទាំងឡាយ រមែងធ្វើការរក្សា ដែលចាត់ចែងយ៉ាងល្អ សូម្បីមិនអាចធ្វើសេចក្តីសុខដែលនៅមិនកើត ឲ្យកើត ឡើង តែក៏កម្ចាត់រោគក្អក រោគក្នុងក្បាលជាដើម ដែលកើតឡើងហើយបាន ផង ជួយក្នុងពេលមានសង្គ្រាមផង គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តី*

សាបសូន្យ ក្នុងសេចក្តីនេះ ដូចពោលមកនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ធម្មិកា រក្ខាវរណគុត្តិ** ដូច្នេះ ឈ្មោះថា **អាវរណ** ព្រោះរារាំងដោយប្រការដែលវត្ថុមិនគួរប្រាថ្នា មិនទាន់មកដល់ ។ ឈ្មោះថា **គុត្តិ** ព្រោះយុំគ្រងដោយប្រការដែលវត្ថុ គួរប្រាថ្នាមានហើយ មិនទាន់វិនាស ឈ្មោះថា រក្សាដូចគ្នា ។ ក្នុងពាក្យនោះ ការរក្សាដោយគំនរភ្ជើងជុំវិញ មិនឈ្មោះថា **ធម្មិកា រក្ខាវរណគុត្តិ** ដើម្បីបព្វជិតឡើយ តែការធ្វើដោយមិនកាប់ដើមឈើក្នុងព្រៃជិតវិហារ មិនចាប់ម្រឹគដោយអន្ទាក់ មិនចាប់ត្រីក្នុងស្រះបោក្ខរណី ឈ្មោះថា **ធម្មិកា រក្ខាវរណគុត្តិ** ។ ដោយបទថា **កិន្តិ អនាគតា ៩** នេះ លោកសួរសេចក្តីក្នុងចិត្តរបស់ស្តេចវជ្ជីទាំងនោះថា មានចិត្តសន្តានប្រាកដយ៉ាងនេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះដូច្នេះថា ស្តេចវជ្ជីពួកណា មិនប្រាថ្នាការមករបស់ព្រះអរហន្តទាំងឡាយ ដែលនៅមិនទាន់មក ស្តេចវជ្ជីទាំងនោះ ឈ្មោះថា ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លា កាលបព្វជិតមកដល់ហើយ ក៏មិនទៅទទួល មិនទៅសួរសុខទុក្ខ មិនធ្វើបដិ-សណ្ឋារៈ មិនសួរបញ្ហា មិនស្តាប់ធម៌ មិនឲ្យទាន មិនស្តាប់អនុមោទនា មិនចាត់ចែងទីនៅអាស្រ័យ កាលបើដូច្នោះ សំឡេងតិះដៀលស្តេចវជ្ជីទាំងនោះ ក៏នឹងខ្ចរខ្ចាយទៅថា ស្តេចឈ្មោះឯណោះមិនជឿ មិនជ្រះថ្លា កាលបព្វជិតមកដល់ក៏មិនទទួល ។បេ។ មិនចាត់ចែងទីនៅអាស្រ័យ ។ ពួកបព្វជិតស្តាប់រឿងនោះហើយ សូម្បីឆ្ងងទ្វារព្រះនគររបស់ស្តេចអង្គនោះ ក៏មិនចូលទៅកាន់ព្រះនគរ ។ ពួកព្រះអរហន្តដែលមិនទាន់មក ក៏រមែងមិនមក ដោយប្រការដូច្នេះ ។ កាលលំនៅជាផាសុក សម្រាប់ព្រះអរហន្តដែលមកហើយមិនមាន

ពួកព្រះអរហន្តដែលមិនទាន់មកដល់ក៏គិតថា ពីមុនអញគិតនឹងមក តែអ្នកណាហ្ន៎ នឹងនៅបាន ដោយសេចក្តីមិនត្រេកអរបស់ស្តេចទាំងនេះ ដូច្នេះហើយ ក៏នាំគ្នាចេញទៅ ។ ដោយប្រការដូចពោលមកនេះ កាលពួកព្រះអរហន្តដែលមិនទាន់មក ក៏មិនមក ដែលមកហើយ ក៏លំបាកនៅក្នុងអាវាសនោះ ដែលមិនជាទីនៅសម្រាប់បព្វជិត បន្ទាប់អំពីនោះ ការរក្សារបស់ទេវតាក៏មិនមាន កាលបើដូច្នោះ ពួកអមនុស្សក៏បានឱកាស ។ ពួកអមនុស្សក៏ដេរដាស តែងធ្វើជំងឺដែលមិនទាន់កើត ឲ្យកើតឡើង ។បុណ្យដែលមានទីតាំងដូចការឃើញ ការសួរបញ្ហា ពួកលោកអ្នកមានសីលជាដើម ក៏មិនមកដល់ ។ តែកាលពោលដោយបរិយាយផ្ទុយគ្នា បុណ្យដែលជាចំណែកស ដែលផ្ទុយគ្នានឹងបាបចំណែកខ្មៅ តាមដែលពោលហើយ តែងកើតព្រម គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ក្នុងសេចក្តីនេះ ដូចពោលមកដូច្នេះ ។

[๖๙] *ព្រះមានព្រះភាគ ត្រាស់ពាក្យនេះថា* **ฬกมิทามหំ** *ក៏ដើម្បីទ្រង់ប្រកាសភាវៈនៃវជ្ជីសូត្រនេះ ដែលទ្រង់សម្តែងហើយ ដល់ពួកស្តេចវជ្ជីក្នុងកាលមុន ។ បណ្តាបទទាំងនោះ បទថា* **สารนฺเท เจติเย** *គឺវិហារដែលមានឈ្មោះយ៉ាងនេះ បានឮថា កាលព្រះពុទ្ធមិនទាន់កើតឡើង លំនៅរបស់សារន្ធទយក្ខក្នុងទីនោះ បានជាចេតិយ ។ គ្រានោះ ពួកស្តេចវជ្ជី ឲ្យសាងវិហារថ្វាយចំពោះព្រះមានព្រះភាគក្នុងទីនោះ ។ វិហារនោះ ក៏រាប់បានថា សារន្ធទចេតិយនុ៎ះឯង ព្រោះទ្រង់សាងត្រង់ទីសារន្ធទចេតិយ ។ បទថា* **อกรณีโยติ** *ប្រែថា មិនគប្បីធ្វើ អធិប្បាយថា មិនគួរកាន់យក ។ បទថា* **ยตฺถิทนฺ** *នេះ ត្រឹមតែជានិបាត ។ បទថា* **ยุทฺธสฺส** *ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថ*

ตติยาวิกตฺติ สេចក្តីថា បុគ្គលណាមួយ មិនអាចប្រឈមមុខដើម្បីច្បាំងបាន ។ បទថា **អញ្ញត្រ อุปลาปนาย** *បានដល់ វៀរលែងតែការលួងលោម អធិប្បាយថា ការបញ្ជូនគ្រឿងបណ្ណាការ មានដំរី សេះ រថ ប្រាក់ និងមាស ជាដើមសង្គ្រោះគ្នា ដោយពោលថា ល្មមហើយ សម្រាប់ការទាស់ទែងគ្នា ពួកយើងសាមគ្គីគ្នាឥឡូវនេះចុះ ដូច្នេះ ឈ្មោះថា ការលួងលោម ។ ការសង្គ្រោះគ្នាយ៉ាងនេះ ក៏អាចជិតជិតគ្នាបាន ដោយការស្និទ្ធស្នាលតែម្យ៉ាង ។ បទថា* **អញ្ញត្រ ភេទนាย** *បានដល់ វៀរលែងតែធ្វើឲ្យបែកគ្នាជាពីរចំណែក ដោយពាក្យនេះ លោកសម្តែងថា ធ្វើការបំបែកនូវគ្នានឹងគ្នា ទើបចាប់ពួកស្តេចវជ្ជីទាំងនោះបាន ។ ព្រាហ្មណ៍យល់អត្ថនៃព្រះតម្រាស់របស់ព្រះមានព្រះភាគហើយ ទើបពោលពាក្យនេះ ។ សួរថា ក៏ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍បានអត្ថនៃព្រះតម្រាស់នេះឬ ។ ឆ្លើយថា ទ្រង់ជ្រាបបាន ។ សួរថា កាលទ្រង់ជ្រាបហេតុអ្វី ទើបត្រាស់ ។ ឆ្លើយថា ព្រោះទ្រង់អនុគ្រោះ ។ បានឮថា ព្រះមានព្រះភាគនោះ ទ្រង់តម្រិះថា សូម្បីកាលតថាគតមិនសម្តែង ២-៣ ថ្ងៃ ព្រាហ្មណ៍នឹងទៅចាប់ស្តេចវជ្ជីទាំងនោះ តែកាលតថាគតសម្តែង ព្រាហ្មណ៍កាលនឹងទម្លាយសាមគ្គី ក៏ត្រូវប្រើវេលាដល់ ៣ ឆ្នាំ នឹងមានជីវិតរស់នៅ ត្រឹមតែប៉ុណ្ណោះក៏ប្រសើរហើយ ព្រោះថា ពួកស្តេចវជ្ជីរស់នៅបានត្រឹមនេះ ក៏នឹងធ្វើបុណ្យជាទីពឹងរបស់ខ្លួនបាន ។ បទថា* **អភินន្ទิត្វា** *ប្រែថា ត្រេកអរហើយដោយចិត្ត ។ បទថា* **អនុមោទិត្វា** *បានដល់ ត្រេកអរដោយវាចាថា បពិត្រព្រះគោតមដ៏ចម្រើន ពាក្យនេះជាពាក្យសុភាសិតពិត ។ បទថា* **បក្ក្រាមិ** *បានដល់ ទៅកាន់រាជសម្នាក់ ។ លំដាប់នោះ ព្រះរាជា (អជាតសត្តុ)*

ត្រាស់សួរព្រាហ្មណ៍នោះថា អាចារ្យ ព្រះមានព្រះភាគត្រាស់ថា ដូចម្តេច ។ ព្រាហ្មណ៍ទូលថា ព្រះតម្រាស់របស់ព្រះសមណគោតមចង្អុរបង្ហាញថា បុគ្គលណាម្នាក់ មិនអាចចាប់ពួកស្តេចវជ្ជីបាន តែអាចចាប់បានដោយការលួងលោម ១ ដោយការធ្វើឲ្យបែកសាមគ្គី ១ ។ ព្រះរាជាត្រាស់សួរព្រាហ្មណ៍នោះថា ជំរីសេះ ជាដើមរបស់យើង នឹងវិនាសដោយការលួងលោម យើងនឹងចាប់ពួកស្តេចវជ្ជី ដោយការទម្លាយសាមគ្គីប៉ុណ្ណោះ យើងនឹងធ្វើដូចម្តេច ។ ព្រាហ្មណ៍ទូលថា បពិត្រមហារាជ បើយ៉ាងនោះ សូមប្រារព្ធដែនវជ្ជី លើករឿងឡើងត្រាស់ក្នុងទីប្រជុំ បន្ទាប់អំពីនោះ ខ្ញុំព្រះអង្គនឹងទូលថា មហារាជ ព្រះអង្គទ្រង់ប្រាថ្នាអ្វីដោយសម្បត្តិរបស់ស្តេចទាំងនោះ ស្តេចទាំងនោះចូរធ្វើកសិកម្ម និងពាណិជ្ជកម្មជាដើម ចិញ្ចឹមជីវិតចុះ ហើយធ្វើជាគេចចេញទៅ បន្ទាប់អំពីនោះ ព្រះអង្គគប្បីត្រាស់ថា ហេតុអ្វីហ្ន៎ ទើបព្រាហ្មណ៍នេះ ជំទាស់រឿងដែនវជ្ជីដែលប្រារព្ធ ។ នៅពេលថ្ងៃ ខ្ញុំព្រះអង្គនឹងបញ្ជូនគ្រឿងបណ្ណាការទៅថ្វាយស្តេចវជ្ជីទាំងនោះ សូម្បីព្រះអង្គក៏ចូរឲ្យចាប់ខ្ញុំព្រះអង្គនោះ លើកទោសរបស់ខ្ញុំព្រះអង្គ មិនធ្វើការយុំយាំង និងវាយជាដើម គ្រាន់តែការក្បាលតែម្យ៉ាងនិទ្រិសចេញអំពីព្រះនគរទៅ កាលបើដូច្នោះ ខ្ញុំព្រះអង្គនឹងពោលថា ខ្ញុំព្រះអង្គឲ្យសាងកំផែង និងគូទឹកក្នុងព្រះនគររបស់ព្រះអង្គ ខ្ញុំព្រះអង្គនឹងដឹងដល់ស្ថានទីរឹងមាំ និងទន់ខ្សោយ និងស្ថានទីរាក់ និងជ្រៅ ឥឡូវនេះ ខ្ញុំព្រះអង្គនឹងធ្វើព្រះនគរនោះឲ្យតាំងនៅមិនយូរឡើយ ព្រះអង្គស្តាប់ពាក្យនោះ គប្បីត្រាស់បណ្តេញឲ្យទៅ ដូច្នេះ ។ ព្រះរាជាក៏បានធ្វើគ្រប់ប្រការ ។

ពួកស្តេចលិច្ឆវី ទ្រង់ស្តាប់នូវនិទ្រិសព្រាហ្មណ៍នោះហើយ ត្រាស់ថា

ព្រាហ្មណ៍អួតអាង អ្នកទាំងឡាយកុំឲ្យព្រាហ្មណ៍នោះឆ្លងទន្លេគង្គាទៅបាន ។ បណ្តាស្តេចលិច្ឆវីទាំងនោះ កាលស្តេចលិច្ឆវីពួកខ្លះ ពោលថា បានឮថា ព្រាហ្មណ៍នោះត្រូវគេធ្វើយ៉ាងនេះ ព្រោះគេនិយាយប្រាសចពួកយើង ស្តេចវជ្ជីមួយពួកទៀតពោលថា នែលោកកុំបានឲ្យព្រាហ្មណ៍ចូលមក ។ ព្រាហ្មណ៍នោះទៅជួបពួកស្តេចលិច្ឆវី ត្រូវសួរថា លោកបានធ្វើខុសអ្វី ទើបប្រាប់រឿងនោះ ។ ពួកស្តេចលិច្ឆវីពោលថា ព្រាហ្មណ៍ធ្វើខុសបន្តិចបន្តួច មិនគួរដាក់ទោសធ្ងន់យ៉ាងនេះ ហើយទើបសួរថា ក្នុងនគរនោះលោកមានតំណែងជាអ្វី ។ ព្រាហ្មណ៍ឆ្លើយថា ទូលបង្គំ ជាអមាត្យផ្នែកវិនិច្ឆ័យ ។ ស្តេចលិច្ឆវីត្រាស់ថា លោកចូរតាំងនៅក្នុងតំណែងនោះចុះ ។ ព្រាហ្មណ៍នោះ ក៏ធ្វើកិច្ចវិនិច្ឆ័យយ៉ាងល្អ ។ រាជកុមារទាំងឡាយ នាំគ្នាសិក្សាសិល្បៈក្នុងសម្នាក់របស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នោះ ទ្រទ្រង់នូវគុណ ថ្ងៃមួយ នាំស្តេចលិច្ឆវីមួយអង្គទៅទីកន្លែងមួយ សួរថា ក្មេងៗ ធ្វើស្រែឬ ។ ស្តេចលិច្ឆវីមួយអង្គឆ្លើយថា អើ ធ្វើស្រែ សួរថា ទឹមគោពីរឬ ឆ្លើយថា អើ ទឹមគោពីរ ។ ព្រាហ្មណ៍ពោលយ៉ាងនេះហើយក៏ត្រឡប់ទៅ ។ បន្ទាប់អំពីនោះ ទើបស្តេចលិច្ឆវីអង្គដទៃសួរស្តេចលិច្ឆវីអង្គនោះថា អាចារ្យនិយាយអ្វី មិនជឿពាក្យស្តេចលិច្ឆវីអង្គនោះប្រាប់ គិតថា ស្តេចលិច្ឆវីអង្គនោះ មិនប្រាប់អញ តាមសេចក្តីពិត ក៏បែកគ្នានឹងស្តេចលិច្ឆវីអង្គនោះ ។ សូម្បីក្នុងថ្ងៃដទៃៗ ព្រាហ្មណ៍ក៏នាំស្តេចលិច្ឆវីមួយអង្គទៅទីកន្លែងមួយសួរថា ទ្រង់សោយជាមួយអ្វី ហើយក៏ត្រឡប់ ។ ស្តេចលិច្ឆវីអង្គដទៃមិនជឿ ក៏បែកគ្នាយ៉ាងនោះដូចគ្នា ។ សូម្បីក្នុងថ្ងៃតៗ មក ព្រាហ្មណ៍ក៏នាំស្តេចលិច្ឆវីមួយអង្គទៀត ទៅទីកន្លែងមួយ ហើយសួរថា បានឮ

ថា ទ្រង់ក្រីក្រណាស់ឬ ។ ព្រះរាជកុមារ សួរថា អ្នកណានិយាយយ៉ាងនេះ ។ ព្រាហ្មណ៍ឆ្លើយថា ស្តេចលិច្ឆវីឈ្មោះនោះ ។ ព្រាហ្មណ៍ក៏នាំស្តេចលិច្ឆវីអង្គ ដទៃៗ ទៅទីកន្លែងមួយ ហើយសួរថា បានឮថា ទ្រង់ខ្វាចណាស់ឬ ។ ព្រះរាជកុមារសួរថា អ្នកណាពោលយ៉ាងនោះ ។ ព្រាហ្មណ៍ឆ្លើយថា ស្តេចលិច្ឆវីឈ្មោះនោះ ។ ព្រាហ្មណ៍ពោលពាក្យដែលស្តេចលិច្ឆវីមួយអង្គទៀតមិនបានពោល ចំពោះស្តេចលិច្ឆវីមួយអង្គទៀត ដោយអាការយ៉ាងនេះ ៣ ឆ្នាំ ទើបបំបែកស្តេចលិច្ឆវីទាំងនោះចេញអំពីគ្នា ហើយធ្វើដោយប្រការដែលស្តេចលិច្ឆវីទាំង ២ ចំណែក មិនដើរផ្លូវមួយជាមួយគ្នា ទើបឲ្យវាយស្គរហៅប្រជុំ ។ ពួកស្តេចលិច្ឆវីនិយាយគ្នាថា អ្នកជាធំចូរប្រជុំគ្នា អ្នកខ្វាចចូរប្រជុំគ្នាចុះ ហើយក៏មិនប្រជុំគ្នា ។ ទើបព្រាហ្មណ៍បញ្ជូនដំណឹងថ្វាយព្រះរាជាថា ឥឡូវនេះ ដល់វេលាហើយ សូមទ្រង់ធាប់យាងមកចុះ ។ ព្រះរាជាស្តាប់ហើយ ក៏បញ្ជាឲ្យវាយស្គរហៅពលទាហាន ស្តេចលើកទ័ពចេញទៅ ។ អ្នកនគរវេសាលី ក៏វាយស្គរប្រកាសថា ពួកយើងនឹងមិនព្រមឲ្យព្រះរាជាឆ្ងងទន្លេគង្គា ។ អ្នកនគរវេសាលីស្តាប់ប្រកាសនោះហើយ ក៏និយាយថា អ្នកជាធំចូរនាំគ្នាទៅចុះ ដូច្នេះជាដើម ហើយក៏មិនទៅប្រជុំគ្នា ។ អ្នកនគរវេសាលី ក៏វាយស្គរប្រកាសថា ពួកយើងនឹងមិនឲ្យព្រះរាជាចូលព្រះនគរ នឹងបិទទ្វារឲ្យជិត មិនទៅប្រជុំសូម្បីតែម្នាក់ ។ ព្រះរាជាស្តេចចូលតាមទ្វារដែលបើក ទ្រង់ធ្វើពួកស្តេចវជ្ជីទាំងអស់ឲ្យដល់សេចក្តីវិនាស ហើយយាងទៅ ។

[๗๐] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អថខោ ភគវា អចិរបក្កន្តេ** ដូច្នេះជាដើម បទថា **សន្និចាតេត្វា** សេចក្តីថា ព្រះអានន្ទហៅប្រជុំថា លោក

អ្នកមានអាយុទាំងឡាយ ចូរបញ្ជូនលោកអ្នកមានឫទ្ធិ ទៅកាន់វិហារឆ្ងាយៗចូរ ទៅប្រជុំគ្នាឯងត្រង់វិហារជិតៗ ព្រះមានព្រះភាគ មានព្រះបំណងនឹងប្រជុំពួក លោក ។ បទថា **អបរិហានិយេ** *សេចក្តីថា មិនធ្លាហេតុនៃសេចក្តីចម្រើនឲ្យ សាបសូន្យ ។ បទថា* **ឆម្មេ ឧទេសេស្សាមិ** *សេចក្តីថា តថាគតនឹងពោលឲ្យ ជាក់ច្បាស់ ដូចជាលើកព្រះចន្ទ ១ ពាន់ ព្រះអាទិត្យ ១ ពាន់ទ្បើង ដូចជា អុជប្រទីបប្រេង ១ ពាន់ ត្រង់ជ្រុងទាំង ៤ នៃផ្ទះ ។ បណ្តាបទទាំងនោះ បទ ថា* **អភិណ្ហសន្និបាតា** *នេះ ក៏ដូចគ្នាដែលពោលទុកហើយក្នុងការប្រជុំរបស់ ស្តេចវជ្ជីនុ៎ះឯង ។ មួយទៀត ព្រោះហេតុដែលមិនប្រជុំគ្នារឿយៗ ភិក្ខុទាំង-ឡាយ ក្នុងធម្មវិនัយនេះ មិនបានឮដំណឹង ដែលមកក្នុងទិសផ្សេងៗ តពីនោះ សីមារបស់វត្តនោះ ក៏មានការវិកវេ ឧបោសថ និងបវារណា ក៏រៀរភិក្ខុទាំង-ឡាយក្នុងទីឯណោះ ធ្វើអនេសនកម្ម មានវេជ្ជកម្ម និងទូតកម្មជាដើម ជាអ្នក ច្រើនដោយវិញ្ញត្តិ មិនស្គាល់កិច្ចជាដើមថា ចិញ្ចឹមជីវិតដោយអនេសនកម្ម មាន ការឲ្យផ្តាជាដើម ។ សូម្បីភិក្ខុអាក្រក់ទាំងឡាយដឹងថា សង្ឃធ្វេសប្រហែស ក៏រួមគ្នាជាក្រុម រមែងធ្វើសាសនាឲ្យសាបសូន្យអន់ថយ ។ តែព្រោះប្រជុំគ្នា រឿយៗ ភិក្ខុទាំងឡាយរមែងបានឮរឿងនោះៗ ។ បន្ទាប់អំពីនោះ ក៏បញ្ជូនភិក្ខុ សង្ឃទៅធ្វើសីមាឲ្យត្រង់ ធ្វើឧបោសថ និងបវារណាជាដើម ឲ្យប្រព្រឹត្តទៅ ។ បញ្ជូនភិក្ខុដែលរាប់បញ្ចូលក្នុងអរិយវង្ស ទៅក្នុងទីដែលច្រើនទៅដោយពួក ភិក្ខុមិច្ឆាជីវៈ ឲ្យពោលអរិយវង្ស ឲ្យពួកព្រះវិនយធរធ្វើនិគ្គហៈភិក្ខុអាក្រក់ ទាំងឡាយ ភិក្ខុអាក្រក់ទាំងឡាយដឹងថា សង្ឃមិនធ្វេសប្រហែស ពួកយើង មិនអាចរួមជាពួកក្រុមបានទេ ក៏ចៀសចេញទៅ ។ គប្បីជ្រាបសេចក្តីសាប*

สูนฺย និង*សេចក្តីចម្រើន* ក្នុង*សេចក្តីនេះ* ដោយ*ប្រការដូច្នេះ* ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សមគ្គា** *ជាដើមដូច្នេះថា កាលគេវាយស្គរ ឬវាយជួងប្រកាសថា សង្ឃចូរប្រជុំគ្នា ព្រោះបំណងនឹងបង្ហាញកតិការវត្ត ព្រោះបំណងនឹងឲ្យឱវាទ ដើម្បីបដិបត្តិព្រះចេតិយ បដិបត្តិទីលានពោធិព្រឹក្ស ឬដើម្បីប្រគំរោងឧបោសថ ធ្វើនូវការបណ្តោះបណ្តែថា ខ្ញុំមានកិច្ចដោយចីវរ ខ្ញុំដុតជាត្រ ខ្ញុំមានការកសាង ឈ្មោះថា មិនព្រមព្រៀងគ្នាប្រជុំ ។ ចំណែកភិក្ខុទាំងឡាយ វៀរកិច្ចទាំងអស់នោះប្រជុំគ្នា ដោយការស្រែកប្រកាសតែមួយដងប៉ុណ្ណោះ ដោយការដាក់ចិត្តថា ខ្ញុំមុន ខ្ញុំមុន ឈ្មោះថា ព្រមព្រៀងគ្នាប្រជុំ ។ មួយទៀត ប្រជុំគ្នាហើយ គិតប្រឹក្សាគ្នាធ្វើកិច្ចដែលគួរធ្វើ មិនព្រមព្រៀងគ្នាលើកការប្រជុំ មិនឈ្មោះថា ព្រមព្រៀងគ្នាលើកការប្រជុំ ។ បណ្តាភិក្ខុទាំង-ឡាយដែលលើកការប្រជុំគ្នាហើយយ៉ាងនេះ ពួកភិក្ខុដែលទៅមុន គិតយ៉ាងនេះថា ពួកយើងស្តាប់តែរឿងក្រៅការ ឥឡូវនេះ នឹងនិយាយគ្នាតែសាច់ការ តែកាលលើកការប្រជុំព្រមព្រៀងគ្នា ក៏ឈ្មោះថា ព្រមព្រៀងគ្នាលើកការប្រជុំ មួយទៀត ភិក្ខុទាំងឡាយស្តាប់ថា សីមារបស់វិហារក្នុងទីឈ្មោះឯណោះ វឹកវរ ឧបោសថ និងបវារណា ក៏វៀរភិក្ខុអាក្រក់ ភិក្ខុអ្នកធ្វើអនេសនកម្ម មានវេជ្ជកម្មជាដើម ក្នុងទីឈ្មោះនោះមានច្រើន កាលភិក្ខុទាំងនោះពោលថា អ្នកណានឹងទៅធ្វើការនិគ្គហៈភិក្ខុទាំងនោះ ទើបនិយាយទទួលថា ខ្ញុំមុន ខ្ញុំមុន ហើយក៏ទៅ ឈ្មោះថា ព្រមព្រៀងគ្នាលើកការប្រជុំ ។ ភិក្ខុទាំងឡាយ ជួបភិក្ខុអាគន្តុកៈ មិនពោលពាក្យណាមួយថា សូមទៅបរិវេណនេះ សូមទៅបរិវេណនោះ ធ្វើវត្តដោយខ្លួនឯងក្តី ជួបភិក្ខុដែលមានបាត្រចីវរចាស់ ស្វែងរកបាត្រ

ចីវរ ដោយភិក្ខុចារវត្តដើម្បីភិក្ខុនោះក្តី សែ្វងរកគិលានភេសជ្ជៈ ដើម្បីភិក្ខុឈឺ ក្តី មិននិយាយចំពោះភិក្ខុឈឺអ្នកមិនមានទីពឹងថា ចូរទៅបរិវេណឯណោះចុះ ចូរទៅបរិវេណឯណោះចុះក្តី បដិបត្តិក្នុងបរិវេណរៀងៗ ខ្លួនក្តី មានគម្ពីរនៅ សល់សូម្បីមួយ ក៏សង្គ្រោះភិក្ខុអ្នកមានបញ្ញា ឲ្យភិក្ខុនោះលើកគម្ពីរនោះឡើង ក្តី ឈ្មោះថា ព្រមព្រៀងគ្នា ធ្វើកិច្ចរបស់សង្ឃ ដែលគប្បីធ្វើ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អប្បញ្ញត្តំ** *ដូច្នេះជាដើមថា ភិក្ខុទាំងឡាយ បញ្ញត្តកតិកាវត្ត ឬសិក្ខាបទថ្មីដែលមិនត្រូវតាមធម៌ឈ្មោះថា បញ្ញត្តបទដែល ព្រះពុទ្ធមិនបានបញ្ញត្ត ដូចពួកភិក្ខុក្រុងសាវត្ថី ក្នុងរឿងលាយក្បាច់សន្ថតចាស់ ។ ពួកភិក្ខុដែលពោលពាក្យប្រៀនប្រដៅក្រៅធម៌ ក្រៅវិនយ ឈ្មោះថា ដកសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្តហើយ ដូចពួកភិក្ខុវជ្ជីបុត្រក្នុងនគរវេសាលី កាលព្រះមានព្រះភាគបរិនិព្វានបាន ១០០ ឆ្នាំ ។ ចំណែកពួកភិក្ខុប្រព្រឹត្ត កន្ទងល្មើសអាបត្តិតូចៗ ឈ្មោះថា មិនសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ តាមដែលទ្រង់បញ្ញត្ត ដូចជាភិក្ខុអស្សជិបុនព្វសុក ។ ចំណែកភិក្ខុទាំងឡាយ មិនបញ្ញត្តកតិកាវត្ត ឬសិក្ខាបទថ្មី ពោលពាក្យប្រៀនប្រដៅអំពីធម្មវិនយ មិន ដកនូវសិក្ខាបទតូចៗ ឈ្មោះថា មិនបញ្ញត្តសិក្ខាបទដែលទ្រង់មិនបញ្ញត្ត មិន ដកនូវសិក្ខាបទដែលទ្រង់បញ្ញត្តហើយ សមាទានប្រព្រឹត្តក្នុងសិក្ខាបទតាម ដែលទ្រង់បញ្ញត្ត ដូចព្រះឧបសេន ព្រះយសកាកណ្ឌកបុត្រ និងព្រះមហា កស្សប អ្នកតម្កល់បែបផែននេះថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទ ទាំងឡាយរបស់ពួកយើង ជាចំណែករបស់គ្រហស្ថមាន សូម្បីពួកគ្រហស្ថ ទាំងឡាយក៏ដឹងថា វត្ថុនេះគួរដល់សមណសក្យបុត្ត វត្ថុនេះមិនគួរដល់លោក*

បើពួកយើងទាំងឡាយដកនូវសិក្ខាបទតូចៗ សោត ក៏នឹងមានអ្នកពោលទោសបានថា សិក្ខាបទដែលព្រះសមណគោតមបញ្ញត្តហើយ ដល់សាវកទាំងឡាយតាំងនៅបានត្រឹមតែប្រមាណមួយផ្សែងក្លើង សាវកទាំងនេះ សិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដែលព្រះសាស្តារបស់សាវកទាំងនេះតាំងនៅ ព្រះសាស្តារបស់សាវកទាំងនេះបរិនិព្វានហើយ ឥឡូវនេះ សាវកទាំងនេះ ក៏មិនព្រមសិក្សាក្នុងសិក្ខាបទទាំងឡាយ ដូច្នេះ ប្រសិនបើការព្រមព្រៀងរបស់សង្ឆដល់ហើយ សង្ឆមិនគប្បីបញ្ញត្តសិក្ខាបទ ដែលទ្រង់មិនបានបញ្ញត្តហើយ មិនគប្បីដកសិក្ខាបទដែលទ្រង់បញ្ញត្តហើយ គប្បីសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ តាមដែលទ្រង់បញ្ញត្ត ។ បទថា **វុឌ្ឍិយេវ** បានដល់សេចក្តីចម្រើនដោយគុណ មានសីលជាដើម មិនសាបសូន្យឡើយ ។

បទថា **ថេរា** បានដល់ អ្នកដល់ភាពជាបុគ្គលរឹងមាំ គឺប្រកបដោយគុណដែលធ្វើនូវភាពរឹងមាំ ។ ឈ្មោះថា **រត្តញ្ញា** ព្រោះដឹងរាត្រីច្រើន ។ ឈ្មោះថា **ចិរប្បព្វជិតា** ព្រោះបួសមកយូរ ។ ឈ្មោះថា **សង្ឆបិតរោ** ព្រោះតាំងនៅក្នុងឋានៈជាបិតារបស់សង្ឆ ។ ឈ្មោះថា **សង្ឆបរិណាយកា** ព្រោះរក្សាសង្ឆ ព្រោះតាំងនៅក្នុងឋានៈជាបិតា ជាប្រធានបដិបត្តិក្នុងបទ គឺសិក្ខា ៣ ។ ភិក្ខុពួកណា មិនធ្វើសក្ការៈដល់ព្រះថេរៈទាំងនោះជាដើម មិនទៅប្រណិបត្ត៍មួយថ្ងៃ ២-៣ ដង ដើម្បីទទួលឧវាទ ព្រះថេរៈទាំងនោះ រមែងមិនឲ្យឧវាទ មិនពោលរឿងបវេណី មិនឲ្យសិក្សាធម្មបរិយាយ ដែលជាសារៈដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ ត្រូវព្រះថេរៈទាំងនោះលះបង់ចោលហើយ រមែងសាបសូន្យចាកគុណទាំងឡាយ មានយ៉ាងនេះជាដើម គឺចាកធម្មក្ខន្ធ មានសីលខន្ធ

ជាដើម និងចាកអរិយទ្រព្យ ๗ ។ ចំណែកភិក្ខុពួកណា ធ្វើសក្ការៈ ទៅ
ប្រណិបត្តន៍ព្រះថេរៈទាំងនោះជាដើម ព្រះថេរៈទាំងនោះ រមែងឲ្យឱវាទដល់
ភិក្ខុទាំងនោះថា លោកគប្បីឈានទៅយ៉ាងនេះ គប្បីឈានថយយ៉ាងនេះ គប្បី
សម្ងឹងមើលទៅមុខយ៉ាងនេះ គប្បីសម្ងឹងមើលទៅខាងនេះ គប្បីបត់ចូលយ៉ាង
នេះ គប្បីលាចេញយ៉ាងនេះ គប្បីទ្រង់ចាត្រ និងចីវរយ៉ាងនេះ រមែងទូន្មាន
នូវបវេណី រមែងឲ្យសិក្សាធម្មបរិយាយដែលជាសារៈ ទូន្មានដោយធុតង្គ ១៣
កថាវត្ថុ ១០ ។ ភិក្ខុទាំងនោះ នៅក្នុងឱវាទរបស់ព្រះថេរៈទាំងនោះ ចម្រើន
ដោយគុណ មានសីលជាដើម រមែងសម្រេចសាមញ្ញផលដោយលំដាប់ ។
គប្បីជ្រាបសេចក្តីសាបសូន្យ និងសេចក្តីចម្រើនក្នុងសេចក្តីនេះ ដោយប្រការ
ដូច្នេះ ។ ការឲ្យកើតទៀត ឈ្មោះថា ភពថ្មី ភពថ្មីនោះ ជាប្រក្រតីរបស់តណ្ហា
នោះ ហេតុនោះ ទើបតណ្ហានោះ ឈ្មោះថា **បោនោព្ភវិកា** អធិប្បាយថា ឲ្យ
កើតទៀត ។ នៃតណ្ហាដែលឲ្យភពថ្មីនោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឯ
វំ គច្ឆិស្សន្តិ** ដូចគេទៅនេះ ភិក្ខុពួកណាទទួលបិណ្ឌបាតរបស់ឧបដ្ឋាកហើយ
អំពីស្រុកមួយទៅស្រុកមួយ ព្រោះហេតុនៃបច្ច័យ ๔ ភិក្ខុទាំងនោះ ឈ្មោះថា
នៅក្នុងអំណាចរបស់តណ្ហានោះ ។ ចំណែកភិក្ខុដែលមិនបដិបត្តិយ៉ាងនោះ
ឈ្មោះថា មិននៅក្នុងអំណាចនៃតណ្ហា ។ សេចក្តីសាបសូន្យ និងសេចក្តី
ចម្រើនក្នុងសេចក្តីនោះ ប្រាកដច្បាស់ហើយ ។ បទថា **អារញ្ញកេសុ** បានដល់
ព្រៃចម្ងាយ ๕๐๐ ជួរធ្នូយ៉ាងជិត ។ បទថា **សាបេក្ខា** បានដល់ មានតណ្ហា
មានអាល័យ ។ សូម្បីភិក្ខុមិនទាន់សម្រេចឈានក្នុងសាសនៈជិតស្រុក លុះ
ចេញចាកឈាននោះ បានឮសំឡេងស្រី ប្រុស និងក្មេងស្រីជាដើមជាហេតុ

សាបសូន្យគុណវិសេសដែលកិកុនោះសម្រេចហើយ តែលោកដេកក្នុងព្រៃ លុះភ្ញាក់ឡើង ក៏បានឮតែសំឡេងរាជសីហ៍ ខ្លា និងសត្វក្រោកជាដើម កាលលោកបានបីតិក្នុងព្រៃហើយ ពិចារណាបីតិនោះឯង តាំងនៅក្នុងផលដ៏ប្រសើរព្រោះដួច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សរសើរកិកុអ្នកសម្ងំនៅក្នុងព្រៃប៉ុណ្ណោះ ក្រៃលែងជាងកិកុដែលមិនសម្រេចឈាននៅក្នុងសេនាសនៈស្រុក ។ ព្រោះដួច្នោះ ព្រះមានព្រះភាគ ទ្រង់អាស្រ័យអំណាចប្រយោជន៍នោះឯង ទើបត្រាស់ថា បើពួកកិកុមានសេចក្តីប្រាថ្នាក្នុងសេនាសនៈទាំងឡាយ ដែលតាំងនៅក្នុងព្រៃ ។

បទថា **បច្ចត្តំយេវ សតិ ឧបដ្ឋបេស្សន្តិ** *បានដល់ នឹងតាំងសតិទុកខាងក្នុងរបស់ខ្លួន ។ បទថា* **បេសលា** *ប្រែថា ដែលគួរស្រឡាញ់ ។ ពួកកិកុម្ខាស់ទីកន្លែង មិនប្រាថ្នាឲ្យសព្រហ្មចារីមកក្នុងទីនេះ ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លា រមែងមិនធ្វើសាមីចិកម្ម មានការក្រោកទទួល ទទួលបាត្រ ចីវរ ក្រាលអាសនៈ បក់ដោយផ្ទិតស្លឹកត្នោតជាដើម ដល់ពួកកិកុដែលមកដល់ហើយ ។ គ្រានោះ សំឡេងតិះដៀលកិកុទាំងនោះ ក៏ខ្ចរខ្ចាយទៅថា ពួកកិកុវត្តឯណោះមិនមានសទ្ធា មិនជ្រះថ្លា មិនធ្វើវត្តបដិបត្តិដល់ពួកកិកុអ្នកចូលទៅវត្ត ។ បព្វជិតទាំងឡាយ ស្តាប់រឿងនោះហើយ ក៏កន្ទងទ្វារវត្ត មិនព្រមចូលវត្ត ។ ពួកកិកុដែលនៅមិនទាន់មក រមែងមិនមក ដោយប្រការដូច្នេះ ។ ចំណែកពួកកិកុដែលមកហើយ កាលមិនមានវត្តនៅជាសុខ ពួកកិកុដែលមិនជ័ងមកហើយ ក៏គិតមុនថា នឹងនៅ តែក៏ត្រូវត្រឡប់ចេញទៅ ដោយឃើញថា ពួកយើងនាំគ្នាមកហើយ តែដោយការមិននាំមកនេះរបស់កិកុម្ខាស់អាវាស*

ទាំងនេះ នរណានឹងនៅបាន ។ កាលបើដូច្នោះ វត្តនោះ ភិក្ខុដទៃៗ ក៏មកនៅមិនបាន ។ បន្ទាប់អំពីនោះ ពួកភិក្ខុម្ចាស់អាវាស កាលមិនបានជួបពួកភិក្ខុអ្នកមានសីល ក៏បណ្តែតបណ្តាយ មិនបានភិក្ខុដែលជួយបន្ទោបង់សេចក្តីសង្ស័យ ឬអ្នកឲ្យសិក្សាធម្មបរិយាយ ឬស្តាប់ធម៌ដ៏ពីរោះ ភិក្ខុម្ចាស់អាវាសទាំងនោះ ក៏មិនបានទទួលធម៌ ដែលមិនទាន់បានទទួល មិនបានធ្វើការស្វាធ្យាយធម៌ដែលទទួលហើយ ដូច្នោះ ទើបភិក្ខុម្ចាស់អាវាសទាំងនោះ មានតែសេចក្តីសាបសូន្យទៅតែម្យ៉ាង មិនមានសេចក្តីចម្រើនឡើយ ។ ចំណែកភិក្ខុពួកណាបំណងនឹងឲ្យសព្រហ្មចារីមក ភិក្ខុទាំងនោះមានសទ្ធា មានសេចក្តីជ្រះថ្លា ធ្វើការទទួលដល់សព្រហ្មចារីដែលមកហើយជាដើម រៀបចំសេនាសនៈឲ្យ នាំទៅបិណ្ឌបាត បន្ទោបង់សេចក្តីសង្ស័យ បានស្តាប់ធម៌ដ៏ពីរោះ កាលដូច្នោះ កិត្តិសព្ទរបស់ភិក្ខុទាំងនោះ ក៏ខ្ចរខ្ចាយទៅថា ពួកភិក្ខុក្នុងវត្តឯណោះ មានសទ្ធាជ្រះថ្លា ដល់ព្រមដោយវត្ត សង្គ្រោះយ៉ាងនេះ ភិក្ខុទាំងឮធ្យាយបានស្តាប់រឿងនោះហើយ សូម្បីឆ្ងាយ ក៏នាំគ្នាទៅ ពួកភិក្ខុម្ចាស់អាវាសធ្វើវត្តដល់អាគន្តុកភិក្ខុទាំងនោះ មកជិតៗ ហើយថ្វាយបង្គំអាគន្តុកភិក្ខុដែលចាស់ជាង ហើយអង្គុយ កាន់យកអាសនៈក្នុងជិតៗ អាគន្តុកៈអ្នកខ្ចីជាង ហើយសួរថា លោកម្ចាស់ទាំងឡាយនឹងនៅក្នុងវត្តនេះ ឬនឹងទៅ កាលអាគន្តុកៈឆ្លើយថា នឹងទៅ ក៏ពោលថា សេនាសនៈសប្បាយ ភិក្ខាក៏រកបានងាយ មិនព្រមឲ្យទៅ ។ បើអាគន្តុកៈជាវិនយធរ ក៏ស្វាធ្យាយវិន័យក្នុងសម្នាក់របស់ព្រះវិន័យធរ បើអាគន្តុកៈ ទ្រទ្រង់ព្រះសូត្រជាដើម ក៏ស្វាធ្យាយធម៌នោះៗ ក្នុងសម្នាក់របស់ព្រះធម្មធរនោះ នៅក្នុងឱកាសរបស់អាគន្តុកភិក្ខុដែល

ជាព្រះថេរៈ រមែងសម្រេចអរហត្ត មួយអន្ទើដោយបដិសម្ភិទា ។ ពួកអាគន្តុកភិក្ខុគិតនឹងនៅត្រឹមតែ ២ ថ្ងៃ ទើបពោលថា ពួកយើងនាំគ្នាមក ហើយក៏នឹងនៅត្រឹមតែ ១០-១២ ថ្ងៃ ព្រោះភិក្ខុទាំងនេះ មានការនៅរួមយ៉ាងសប្បាយ ។ គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ដោយប្រការដូច្នេះ ។

[๗๑] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តកៈទី ๒ ដូច្នេះ ភិក្ខុឈ្មោះថា **កម្មារាម** ព្រោះមានការងារជាទីត្រេកអរ ។ ឈ្មោះថា **កម្មរត** ព្រោះត្រេកអរក្នុងការងារ ។ បទថា **កម្មារាមតំ អនុយុត្តា** សេចក្តីថា ប្រកបហើយ ប្រកបទូទៅហើយ ប្រកបតាមហើយ ។ ក្នុងបទទាំងនោះ ការងារដែលគប្បីធ្វើ ហៅថា **កម្ម** ។ គឺអ្វីខ្លះ ។ គឺដួចកាត់ចីវរ ធ្វើចីវរ ជួយគ្នាធ្វើវត្តុមានបំពង់ម្ជុល ស្មៅកបាត្រ ខ្សែយោគ វត្តពួន្ធចង្កេះ ជើងបាត្រ ទ្រនាប់ជើង និងអម្បាសជាដើម ។ ពិតហើយ ភិក្ខុរបស់ខ្លះ កាលធ្វើកិច្ចទាំងនេះ រមែងធ្វើពេញ ๑ ថ្ងៃវាល់ល្ងាច ។ លោកសំដៅយកសេចក្តីនោះ ទើបហាម ដូច្នេះ ។ ចំណែកភិក្ខុណាធ្វើកិច្ចទាំងនោះ ក្នុងវេលាធ្វើកិច្ចទាំងនោះប៉ុណ្ណោះ ក្នុងវេលាខ្ទេស ក៏រៀនខ្ទេស ក្នុងវេលាស្វាធ្យាយ ក៏ស្វាធ្យាយ វេលាបោសលានព្រះចេតិយ ក៏ធ្វើវត្តលើលានព្រះចេតិយ ក្នុងវេលាមនសិការ ក៏ធ្វើមនសិការ ភិក្ខុនោះមិនឈ្មោះថា មានការងារជាទីត្រេកអរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ន ភស្សារាមា** នេះ ដូច្នេះ ភិក្ខុណាកាលធ្វើការជ្រាស្រ័យចរចា ដោយរឿងមនុស្សស្រី-ប្រុសជាដើម ឲ្យវេលាកន្លងអស់ថ្ងៃ និងយប់ ជជែកគ្នាដូច្នេះមិនចប់ ភិក្ខុនេះ ឈ្មោះថា មានការជជែកមក

ជាទីត្រេកអរ ។ ចំណែកភិក្ខុណា និយាយធម៌ ដោះស្រាយបញ្ហា ឈ្មោះថា មិនមានការនិយាយមកជាទីត្រេកអរ ភិក្ខុនេះឈ្មោះថា ជជែកគ្នាតិច ជជែកគ្នាមានទីបញ្ចប់ ព្រោះហេតុអ្វី ព្រោះព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រជុំគ្នាហើយ ត្រូវធ្វើកិច្ច ២ យ៉ាង គឺពាក្យប្រកបដោយធម៌ ១ ភាពជាអ្នកស្ងប់ស្ងៀមនៅដ៏ប្រសើរ ១ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ន ឯឡាវាទា** នេះ ដូច្នេះ ភិក្ខុណាដើរក្តី អង្គុយក្តី ដេកក្តី ត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ ក៏លក់បានទាំងអស់ ភិក្ខុនេះឈ្មោះថា មានការដេកលក់ជាទីត្រេកអរ ចំណែកភិក្ខុណា មានចិត្តធ្លាក់ចុះកវង្គ ព្រោះការឈឺចាប់តាមផ្លូវកាយជាកាយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ តថាគតត្រឡប់មកអំពីបិណ្ឌបាតក្នុងវេលាបច្ឆាភត្ត ហើយក្រាលនូវសង្ឃាដីមានជាន់ ៤ ហើយធ្លាប់សិងដោយចំហៀងខាងស្តាំ មានសតិ និងសម្បជញ្ញៈ ចុះស៊ប់កាន់កិរិយាលក់ ក្នុងខែជាទីបំផុតនៃគិម្ហរដូវ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ន សង្គណិការាមា** នេះ ដូច្នេះ ភិក្ខុណាមានសម្ងាញ់ ១ រូប ២ រូប ៣ រូប ៤ រូប នៅច្របូកច្របល់យ៉ាងនេះ មិនបានទទួលសេចក្តីត្រេកអរតែម្នាក់ឯង ភិក្ខុនេះឈ្មោះថា មានការច្រឡូកច្រឡំជាទីត្រេកអរ ។ ចំណែកភិក្ខុណាមានសេចក្តីត្រេកអរ ក្នុងឥរិយាបថទាំង ៤ តែម្នាក់ឯង ភិក្ខុនេះ គប្បីជ្រាបថា មិនមែនជាអ្នកមានសេចក្តីច្រឡូកច្រឡំជាទីត្រេកអរ ។ ពួកភិក្ខុដែលប្រកបដោយសេចក្តីប្រាថ្នា ការលើកតម្កើងគុណដែលមិនមាន ជាអ្នកទ្រុស្តសីល ឈ្មោះថា ជាអ្នកប្រាថ្នាលាមកក្នុងពាក្យថា

น ปาปิจฺฉา *เนาะ ฯ*

คปฺปีชฺราปวินิจฺฉัยกฺนุงปาปมิตฺตชาเมีย ดูเจ็ะ ณฺฮ็วะถา **ปาปมิตฺต** *เพฺราะ มานมิตฺตอาเกฺรก์ ฯ ณฺฮ็วะถา* **ปาปสหาย** *เพฺราะมานสมฺพาญ์อาเกฺรก์ เพฺราะเตฺวชามูยกฺนากฺนุงฌานปถทำง ๔ ฯ ณฺฮ็วะถา* **ปาปสมฺปยุตฺต** *เพฺราะชา ปุคฺคลอาเกฺรก์กฺนุงพวกภิกฺขุอาเกฺรก์ เพฺราะชาอฺนกเตาะทน์ตามภิกฺขุอาเกฺรก์เนาะ ฯ ปทถา* **ฉินฺนตฺตโกโน** *ปานดั่ล มานปฺรมาณทาป มานปฺรมาณติจ ฯ ปทถา* **อนฺตรา** *ปานดั่ล กฺนุงรางมินทาน์สเมฺรจชาเพฺรอะหนฺตเนาะ ฯ ปทถา* **ฉินฺนสีสานิ** *ปานดั่ล เวียเสจกฺตีพฺยาเมาะญฺรกถา ลุมปุ๎ณฺฑีงเหาะย ดายเหตุเตฺรมปุ๎ณฺฮ็วะ ปานดั่ล ปญฺจปฺก็จ ฯ โลกอธิปฺปายดูเจ็ะถา ภิกฺขุทำงฌายมินดั่ลทีปุตดายผล เตฺรมเตมานสีลปริสุทฺธ เตฺรมเตวิปสฺสนา เตฺรมเตฌาน เตฺรมเตชาเพฺรอะสาตาปนฺน เตฺรมเตชาเพฺรอะสกทาคามี ปเตฺรมเตชาเพฺรอะอนาคามีเตฺรมณา ภิกฺขุทำงฌาย คปฺปีชฺราปฺถาเตเสจกฺตีจเมฺรีนเตมฺ๊างง มินสาปสูนฺยเอฺหย ฯ*

[๗๒] *คปฺปีชฺราปวินิจฺฉัยกฺนุงสตฺตก:ที ๓ ดูเจ็ะ ปทถา* **สทฺธา** *ปาน ดั่ล ดั่ลเพฺรมดายสทฺธา ฯกฺนุงปทเสจกฺตีถา* **สทฺธา** *เนาะ สทฺธามาน ๔ กี อาคมนียสทฺธา อธิคมสทฺธา ปสาทสทฺธา ฆิกปฺปนสทฺธา ฯ ปณฺฑาสทฺธา ทำง ๔ เนาะ อาคมนียสทฺธา เรมงมานดั่ลเพฺราะพោធิสตฺวชาสพฺพญ ฯ อธิคมสทฺธา เรมงมานดั่ลเพฺราะอริยปุคฺคลทำงฌาย ฯ กาลปุคฺคลเพาะล ถา* **พุทฺโธ ธมฺโม สงฺโฆ** *กเจฺระชา ณฺฮ็วะถา ปสาทสทฺธา ฯ จำณกกาเรดาก์*

ចិត្តជឿ ឈ្មោះថា ឱកប្បនសទ្ធា ។ ការជឿទាំង ២ នេះ លោកប្រាថ្នាយកក្នុងទីនេះ ។ ពិតហើយ ភិក្ខុដែលប្រកបដោយសទ្ធានោះ ជាអ្នកបង្អោនទៅក្នុងសទ្ធា ក៏ដូចព្រះវក្កលិត្ថេរ ។ សេចក្តីពិត ព្រះវក្កលិត្ថេរ ជាការធ្វើចេតិយង្គណវត្ត ឬពោធិយង្គណវត្ត បំពេញវត្តគ្រប់យ៉ាង មានឧបជ្ឈាយវត្ត និងអាចរិយវត្តជាដើម ។ បទថា **ហិរិមនា** *បានដល់ អ្នកមានចិត្តប្រកបដោយហិរិ ដែលមានលក្ខណៈខ្ពើមបាប ។ បទថា* **ឱត្តប្បី** *បានដល់ អ្នកប្រកបដោយឧត្តប្បៈ ដែលមានលក្ខណៈខ្លាចបាប ។ ក្នុងបទថា* **ពហុស្សុតា** *នេះ ពហុស្សុតមាន ២ គឺបរិយត្តិពហុស្សុត បដិវេធពហុស្សុត ។ បិដក ៣ ឈ្មោះថា បរិយត្តិ ។ ការចាក់ធ្លុះសច្ចៈ ឈ្មោះថា បដិវេធ ។ ក្នុងទីនេះ លោកបំណងយកបរិយត្តិ ។ ភិក្ខុដែលមានសុតៈច្រើន ឈ្មោះថា ពហុស្សុត ។ ភិក្ខុពហូសូតនេះ មាន ៤ គឺនិស្សយមុត្តកៈ បរិសូបដ្ឋាបកៈ ភិក្ខុនោវាទកៈ សព្វត្ថពហូសូត ។ ក្នុងពហូសូត ៤ ពួកនោះ ពហូសូត ៣ ពួក គប្បីកាន់យកបានតាមន័យ ដែលលោកពោលហើយក្នុងឱវាទវគ្គ ក្នុងអដ្ឋកថាវិនយ ឈ្មោះសមន្តបាសាទិកា ។ ពួកសព្វត្ថពហុស្សុត ដូចជាព្រះអានន្ទត្ថេរ ។ ពួកសព្វត្ថពហុស្សុតនោះ លោកបំណងយកក្នុងទីនេះ ។ ឈ្មោះថា* **អារទ្ធវីរិយា** *បានដល់ ពួកភិក្ខុដែលប្រារព្ធសេចក្តីព្យាយាមតាមផ្លូវកាយ និងចិត្ត ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកណា បន្ទោបង់សេចក្តីច្របូកច្របល់ ដោយនៅតែម្នាក់ឯង ក្នុងឥរិយាបថទាំង ៤ ដោយអារម្ភវត្ថុ ៨ ភិក្ខុទាំងនោះ ឈ្មោះថា ប្រារព្ធសេចក្តីព្យាយាមផ្លូវកាយ ។ ភិក្ខុពួកណាបន្ទោបង់សេចក្តីច្រឡូកច្រឡំតាមផ្លូវចិត្ត នៅតែម្នាក់ឯង ដោយសមាបត្តិ ៨ មិនព្រមឈរក្នុងកាលកិលេសកើត*

ក្នុងខណៈដើរ មិនព្រមអង្គុយ ក្នុងកាលកិលេសកើតក្នុងខណៈឈរ មិនព្រមដេក ក្នុងកាលកិលេសកើតក្នុងខណៈអង្គុយ គ្របសង្កត់កិលេសដែលកើតឡើងហើយ កើតឡើងទៀត ភិក្ខុទាំងនោះ ឈ្មោះថា ប្រារព្ធសេចក្តីព្យាយាមតាមផ្លូវចិត្ត ។

បទថា **ឧបដ្ឋិតស្សតិ** បានដល់ រឭកជល់ តាមរឭកជល់កិច្ចដែលធ្វើហើយ សូម្បីយូរជាដើម ដូចព្រះមហាគតិម្ពអភយត្ថេរ ព្រះទីឃភាណកអភយត្ថេរ និងព្រះតិបិដកចូឡាភយត្ថេរ បានឮថា ព្រះមហាគតិម្ពអភយត្ថេរ ឃើញសត្វក្អែកកំពុងឈរបែរចំពុះទៅរកមធុបាយាសដែលជាមង្គលក្នុងថ្ងៃទី ៥ រាប់អំពីថ្ងៃខួនកើត ក៏ស្រែកយំមានសំឡេង ហុំ ហុំ ។ តមក កាលព្រះថេរៈត្រូវពួកភិក្ខុសួរថា លោកម្ចាស់ លោករឭកបានអំពីកាលណា ទើបពោលថា អ្នកមានអាយុ តាំងពីស្រែកយំឡើងក្នុងថ្ងៃទី ៥ រាប់អំពីខួនកើត ។ មាតារបស់ព្រះទីឃភាណកអភយត្ថេរ បង្អោនខួនចុះបំណាងនឹងបើប តាំងអំពីថ្ងៃទី ៩ រាប់អំពីព្រះថេរៈកើត ។ ផ្ទងសក់របស់នាងក៏របូត បន្ទាប់អំពីនោះ ផ្កាម្ជុះប្រមាណមួយនាឡិ ក៏ធ្លាក់ទៅលើទ្រូងរបស់ទារកធ្វើឲ្យកើតទុក្ខ ។ កាលលោកជាព្រះថេរៈត្រូវពួកភិក្ខុសួរថា លោកម្ចាស់រឭកបានតាំងអំពីកាលណា ឆ្លើយថា តាំងអំពីថ្ងៃទី ៩ រាប់ពីខួនកើត ។ ព្រះតិបិដកចូឡាភយត្ថេរពោលថា យើងបិទទ្វារ ៣ ខាងក្នុងអនុរាធបុរី ឲ្យមនុស្សចេញទ្វារមួយ ហើយសួរថា លោកឈ្មោះអ្វី អ្នកឈ្មោះអ្វី ដល់ពេលល្ងាចក៏មិនសួរទៀតទេ អាចចាំឈ្មោះរបស់មនុស្សទាំងនោះបាន ។ លោកសំដៅយកភិក្ខុបែបនោះ ទើបពោលថា **ឧបដ្ឋិតស្សតិ** ។

បទថា **បញ្ញាវន្តោ** បានដល់ ប្រកបដោយបញ្ញា កំណត់ការកើតរលត់របស់

បញ្ចក្ខន្ធជាអារម្មណ៍ ។ ម្យ៉ាងទៀត ដោយពីរបទនេះ លោកពោលដល់សម្មាសតិ និងវិបស្សនាបញ្ញា ដែលជាហេតុឧបត្ថម្ភដល់វិបស្សនារបស់ពួកភិក្ខុដែលចម្រើនវិបស្សនា ។

[៧៣] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តកៈទី ៤ ដូច្នេះ សម្ពោជ្ឈង្គ គឺសតិ ឈ្មោះថា សតិសម្ពោជ្ឈង្គ ។ គ្រប់បទទាំងអស់ ក៏ន័យនេះ ។ ក្នុងសម្ពោជ្ឈង្គ សតិសម្ពោជ្ឈង្គ មានការប្រាកដជាលក្ខណៈ ធម្មវិចយសម្ពោជ្ឈង្គ មានការជ្រើសរើសជាលក្ខណៈ វីរិយសម្ពោជ្ឈង្គ មានការផ្គងចិត្តជាលក្ខណៈ បីតិសម្ពោជ្ឈង្គ មានការជ្រួតជ្រាបទៅជាលក្ខណៈ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់ជាលក្ខណៈ សមាធិសម្ពោជ្ឈង្គ មានការមិនរាយមាយជាលក្ខណៈ ឧបេក្ខាសម្ពោជ្ឈង្គ មានការពិចារណាជាលក្ខណៈ ។ បទថា **ភាវេស្សន្តិ** សេចក្តីថា ភិក្ខុទាំងឡាយតាំងសតិសម្ពោជ្ឈង្គដោយហេតុ ៤ តាំងធម្មវិចយសម្ពោជ្ឈង្គដោយហេតុ ៦ តាំងវីរិយសម្ពោជ្ឈង្គដោយហេតុ ៩ តាំងបីតិសម្ពោជ្ឈង្គដោយហេតុ ១០ តាំងបស្សទ្ធិសម្ពោជ្ឈង្គដោយហេតុ ៧ តាំងសមាធិសម្ពោជ្ឈង្គដោយហេតុ ១០ តាំងឧបេក្ខាសម្ពោជ្ឈង្គដោយហេតុ ៥ នឹងធ្វើឲ្យចម្រើន ។ លោកពោលសម្ពោជ្ឈង្គ លាយគ្នាទាំងលោកិយ និងលោកុត្តរ ប្រកបដោយវិបស្សនា និងមគ្គផល ដោយបទនេះ ។

[៧៤] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តកៈទី ៥ ដូច្នេះថា សញ្ញាដែលកើតឡើងព្រមនឹងអនិច្ចានុបស្សនា ឈ្មោះថា **អនិច្ចសញ្ញា** ។ សូម្បីក្នុងអនត្តសញ្ញាជាដើម ក៏ន័យនេះ ។ គប្បីជ្រាបថា សញ្ញា ៧ នេះ ជាលោកិយវិបស្សនាក៏មាន សញ្ញា ២ ក្នុងទីនេះ ជាលោកុត្តរវិបស្សនាក៏មាន ដោយបាលី

ដែលមកថា ការរម្ងាប់នូវសង្ខារទាំងពួង ការលះបង់នូវកិលេសទាំងពួង ការអស់ទៅនូវតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាទីស្ងប់ ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។

[๗๔] *គប្បីជ្រាបវិនិច្ឆ័យក្នុងឆក្កៈដូច្នេះ បទថា* **មេត្តំ កាយកម្មំ** *បានដល់ កាយកម្មដែលគប្បីធ្វើដោយមេត្តាចិត្ត ។ ក្នុងវចីកម្ម និងមនោកម្ម ក៏មាននយដូចគ្នា ។ កម្មទាំង ๓ នេះ មកដោយភាពជារបស់ភិក្ខុទាំងឡាយ សូម្បីក្នុងពួកគ្រហស្ថក៏ប្រើបាន ពិតហើយ សម្រាប់ពួកភិក្ខុ ការបំពេញធម៌ គឺអភិសមាចារដោយមេត្តាចិត្ត ឈ្មោះថា មេត្តាកាយកម្ម ។ សម្រាប់គ្រហស្ថ កិច្ចមានយ៉ាងនេះជាដើម គឺការទៅថ្វាយបង្គំព្រះចេតិយ ថ្វាយបង្គំពោធិព្រឹក្ស និមន្តសង្ឃ ការជូបពួកភិក្ខុចូលស្រុក ទៅបិណ្ឌបាត ហើយទទួលបាត្រ ក្រាលអាសនៈ ដើរតាម លាបប្រេង ឈ្មោះថា មេត្តាកាយកម្ម ។ សម្រាប់ពួកភិក្ខុ ការទូន្មាន អាចារៈ បញ្ញត្តិ សិក្ខាបទ និងកម្មដ្ឋាន ការសម្តែងធម៌ សូម្បីព្រះត្រៃបិដក ពុទ្ធវចនៈ ដោយមេត្តាចិត្ត ឈ្មោះថា មេត្តាវចីកម្ម ។ ចំពោះគ្រហស្ថ ក្នុងវេលាពោលពាក្យជាដើមថា ពួកយើងទៅថ្វាយបង្គំព្រះចេតិយ ទៅថ្វាយបង្គំពោធិព្រឹក្ស ធ្វើការស្តាប់ធម៌ ឲ្យធ្វើការបូជាដោយផ្ការឈើ ផ្សែងក្រអូប ទៀន សមាទានប្រព្រឹត្តសុចរិត ๓ ប្រគេនសលាកភត្តជាដើម ប្រគេនសំពត់ងូតទឹកភ្លៀង ថ្ងៃនេះប្រគេនបច្ច័យ ๔ ដល់សង្ឃ និមន្តសង្ឃ ថ្វាយរបស់ទំពាជាដើម ក្រាលអាសនៈ តម្កល់ទឹកផាន់ ទទួលសង្ឃ នាំមក ឲ្យគង់លើអាសនៈដែលក្រាលទុក កើតឆន្ទៈ ឧស្សាហៈ ធ្វើការខ្វល់ខ្វាយ ឈ្មោះថា មេត្តាវចីកម្ម ។ ចំពោះភិក្ខុក្រោកឡើងពីព្រឹកព្រលឹម បដិបត្តិសរីរៈ*

និងធ្វើវត្តត្រង់លានព្រះចេតិយជាដើម អង្គុយលើអាសនៈដែលស្អាត់ គិតថា សូមភិក្ខុទាំងឡាយក្នុងវត្តនេះបានសុខ កុំមានពៀរ កុំបៀតបៀនគ្នាជាដើម ឈ្មោះថា មេត្តាមនោកម្ម ។ សម្រាប់គ្រហស្ថគិតថា សូមលោកម្ចាស់បានសុខ កុំមានពៀរ កុំបៀតបៀនគ្នា ឈ្មោះថា មេត្តាមនោកម្ម ។ បទថា **អាវិ ចេវ រហោ ច** *បានដល់ ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ។ ក្នុងបទនោះ ការរួមគ្នាក្នុងចីវរកម្មជាដើម សម្រាប់ភិក្ខុទាំងឡាយ ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ តែសម្រាប់ព្រះថេរៈ សាមីចិកម្មទាំងអស់ មានការលាងជើង និងបក់ផ្ទៃតជាដើម ក៏ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ មិនធ្វើការមើលងាយក្នុងភិក្ខុទាំងនោះ ហើយរក្សាទុកជាក់វត្ថុ មានគ្រឿងឈើជាដើម ដែលភិក្ខុ ២ ចំណែករក្សាទុកមិនល្អ ដូចដែលខ្ជនរក្សាទុកមិនល្អ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។ ការពោលលើកតម្កើងយ៉ាងនេះថា លោកម្ចាស់ទេវត្ថេរ លោកម្ចាស់តិស្សត្ថេរ ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ ។ ការដែលភិក្ខុសាកសួរដល់អ្នកដែលមិនមាននៅក្នុងវត្ត ពោលពាក្យដែលគួរស្រឡាញ់ថា ព្រះថេរៈទៅណា ព្រះតិស្សត្ថេរទៅណា កាលណានឹងមក ដូច្នេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ការបើកភ្នែកដែលថ្លាផូរផង់ ដោយសេចក្តីប្រាថ្នាល្អ និងសេចក្តីព្រួយបារម្ភ សម្លឹងមើលដោយទឹកមុខផូរផង់ ឈ្មោះថា មេត្តាមនោកម្មចំពោះមុខ ។ ការតាំងចិត្តថា សូមលោកម្ចាស់ទេវត្ថេរ លោកម្ចាស់តិស្សត្ថេរ ជាបុគ្គលមិនមានរោគ មិនមានអាពាធ ឈ្មោះថា មេត្តាមនោកម្មកំបាំងមុខ ។ បទថា* **លាភា** *បានដល់ បច្ច័យដែលបានមក មានចីវរជាដើម ។ បទថា* **ធម្មិកា** *សេចក្តីថា រៀរមិច្ឆាជីវៈ មានការប្រកបបញ្ឆោតជាដើម កើតដោយ*

กิกฺขาจารวตฺต ដោយធម៌ដែលស្មើ ។ បទថា **អนฺตมสោ បตฺตปริยาปนฺนมตฺตมฺปิ** *សេចក្តីថា ដោយយ៉ាងទាបទីបំផុត សូម្បីត្រឹមតែកិក្ខា ២-៣ វែក ដែលជាប់ក្នុងបាត្រ គឺដែលនៅខាងក្នុងបាត្រ ។ ក្នុងបទថា* **អប្បដิវิภตฺตភោគี** *នេះ បដិវិភត្តមាន ២ យ៉ាង គឺអាមិសបដិវិភត្ត បុគ្គលបដិវិភត្ត ។ ក្នុង ២ យ៉ាងនោះ ការបែងចែកដោយចិត្តគិតយ៉ាងនេះថា អញនឹងឲ្យប៉ុណ្ណេះ នឹងមិនឲ្យប៉ុណ្ណេះ ឈ្មោះថា អាមិសបដិវិភត្ត ។ ការបែងចែកដោយចិត្ត គិតយ៉ាងនេះថា អញនឹងឲ្យអង្គឯណោះ មិនឲ្យដល់អង្គឯណោះ ដូច្នេះ ឈ្មោះថា បុគ្គល-បដិវិភត្ត ។ កិក្ខុមិនធ្វើទាំង ២ យ៉ាង បរិភោគបច្ចัยដែលនៅមិនទាន់បានបែងចែក ឈ្មោះថា អប្បដิវิภตฺตภោគี ។ ក្នុងបទថា* **สีลวนฺเตหิ สพฺรหฺมจารีหิ สาธารณภោគี** *នេះ ជាលក្ខណៈរបស់កិក្ខុអ្នកបរិភោគទូទៅ ។ កិក្ខុបានលាភណាៗ ដែលប្រណីត ឲ្យលាភនោះដល់ពួកគ្រហស្ថដោយមុខ គឺការទាក់លាភដោយលាភក៏មិនមែន បរិភោគដោយខ្លួនឯងក៏មិនមែន ។ កាលទទួល ក៏ចាត់ទុកថា ចូរទូទៅដល់សង្ឃ ឃើញលាភដែលគេវាយជួនហើយបរិភោគដូចរបស់សង្ឃ ។ សួរថា នរណាបំពេញ នរណាមិនបំពេញ សារាណីយធម៌នេះ ឆ្លើយថា កិក្ខុដែលទ្រុស្តសីលមិនបំពេញ ព្រោះកិក្ខុដែលមានសីល មិនព្រមទទួលរបស់របរកិក្ខុនោះ ។ ចំណែកកិក្ខុអ្នកមានសីលបរិសុទ្ធ បំពេញវត្តមិនដាច់ ។ វត្តក្នុងសេចក្តីនោះ មានឧទាហរណ៍ដូច្នេះថា*

កិក្ខុណា ឲ្យដោយចំពោះដល់មាតាបិតា ឬអាចារ្យ និងឧបជ្ឈាយ៍ជាដើម កិក្ខុនោះ រមែងឲ្យវត្តដែលគួរឲ្យ កិក្ខុនោះ មិនមានសារាណីយធម៌ ឈ្មោះថា បដិបត្តិដោយសេចក្តីកង្វល់ ។ ពិតហើយ សារាណីយធម៌គួរដល់

បុគ្គលដែលផុតសេចក្តីកង្វល់ប៉ុណ្ណោះ ។ ឯភិក្ខុនោះ កាលឲ្យដោយចំពោះគប្បីឲ្យដល់ភិក្ខុឈឺ ភិក្ខុអ្នករក្សាភិក្ខុមានជំងឺ ដល់អាគន្តុកភិក្ខុ ភិក្ខុដែលត្រៀមនឹងទៅ និងភិក្ខុបួសថ្មី អ្នកមិនដឹងការទទួលសង្ឃាដី និងបាត្រ ។ គួរឲ្យដល់ជនទាំងនោះ ចំណែកដ៏សេសមិនឲ្យតិចតួច តាំងពីថេរាសនៈ ហើយគប្បីឲ្យស្មើដែលភិក្ខុនីងទទួលបាន ។ កាលចំណែកដែលនៅសល់មិនមាន គ្រាប់ទៅបិណ្ឌបាតទៀត ឲ្យវត្តុដែលប្រណីតៗ តាំងពីថេរាសនៈ ហើយបរិភោគចំណែកដែលនៅសល់ ។ មិនគួរឲ្យដល់ភិក្ខុទ្រុស្តសីល ព្រោះព្រះបាលីថា **សីលវន្តេហិ** *ដូច្នេះ ។ សាវណីយធម៌នេះ បំពេញបានលំបាក សម្រាប់បរិស័ទដែលមិនទាន់បានសិក្សា បំពេញមិនលំបាកសម្រាប់បរិស័ទ ដែលបានសិក្សាហើយ ។ ភិក្ខុណាបានរបស់ដោយផ្លូវដទៃ ភិក្ខុនោះ រមែងមិនកាន់យក ។ សូម្បីកាលមិនបានដោយផ្លូវដទៃ ក៏ទទួលតែគួរដល់ប្រមាណប៉ុណ្ណោះ មិនទទួលច្រើនពេក ។ សាវណីយធម៌នេះ ១២ ឆ្នាំ ទើបបរិបូណ៌ សម្រាប់ភិក្ខុដែលគ្រាប់បិណ្ឌបាតរឿយៗ ហើយឲ្យរបស់ដែលបានមក ដោយប្រការដូច្នេះមិនគិចជាងនោះ ។ បើភិក្ខុបំពេញសាវណីយធម៌គ្រប់ឆ្នាំទី ១២ ដាក់បាត្រដែលពេញដោយអាហារទុកក្នុងរោងធាន់ហើយ ទៅស្រង់ទឹក ព្រះសង្ឃត្តេរសួរថា នុ៎ះបាត្ររបស់អ្នកណា កាលភិក្ខុដទៃឆ្លើយថា របស់ភិក្ខុដែលបំពេញសាវណីយធម៌ ទើបពោលថា នាំបាត្រនោះមកចុះ ហើយចែកចាយអាហារក្នុងបាត្រទាំងអស់ ហើយធាន់ ដាក់តែបាត្រទទេទុកទីនោះ ភិក្ខុនោះឃើញបាត្រទទេ កើតទោមនស្សថា ភិក្ខុទាំងឡាយធាន់មិនបន្សល់ទុកឲ្យអញខ្លះសាវណីយធម៌ក៏បែក ។ ត្រូវបំពេញ ១២ ឆ្នាំ សាជាថ្មី ។ សាវណីយធម៌*

ដូចគ្នានឹងតិត្តិយបរិវាស កាលជាច់មួយដង ក៏ត្រូវបំពេញជាថ្មី ។ ចំណែកភិក្ខុណាកើតសេចក្តីសប្បាយចិត្តថា នេះជាលាភរបស់អញហ្ន៎ អញបានដោយល្អហើយហ្ន៎ ដែលអញមិនត្រូវប្រាប់ដល់វត្តុដែលមាននៅក្នុងបាត្រ សព្រហ្មចារីក៏នាំគ្នាឆាន់ ឈ្មោះថា សារាណីយធម៌នោះពេញហើយ ។ ភិក្ខុដែលមានសារាណីយធម៌ពេញយ៉ាងនេះហើយ រមែងមិនមានសេចក្តីច្រណែន មិនមានសេចក្តីកំណាញ់ ។ ភិក្ខុនោះ រមែងជាទីស្រឡាញ់របស់មនុស្សទាំង-ឡាយ និងរមែងរកបច្ច័យបានងាយ ។ របស់ដែលនៅក្នុងបាត្រ ដែលគេប្រគេនដល់ភិក្ខុនោះ រមែងមិនអស់ទៅ ។ លោករមែងបានតែរបស់ដ៏ប្រសើរក្នុងទីដែលគេចែករបស់ ។ កាលជួបនូវភ័យ ឬសេចក្តីស្រេកឃ្លាន ពួកទេវតាក៏ជួយទ្រទ្រង់ទ្រាយ ។ ក្នុងសេចក្តីនោះ មានរឿងនេះជាឧទាហរណ៍ដូចតទៅនេះ

រឿងភិក្ខុបំពេញសារាណីយធម៌

បានឮថា ព្រះតិស្សត្ថេរ នៅក្នុងលេណគិរិ អាស្រ័យមហាគីរីគ្រាម ។ ព្រះមហាថេរៈ ៥០ អង្គ ទៅកាន់នាគទ្វីប បំណាងនឹងថ្វាយបង្គំព្រះចេតិយត្រាច់បិណ្ឌបាតក្នុងសិរិគ្រាម មិនបានវត្តុអ្វីមួយឡើយ ក៏នាំគ្នាចេញទៅ ។ ព្រះថេរៈ កាលចូលទៅជួបព្រះថេរៈទាំងនោះហើយ សួរថា លោកម្ចាស់បានអាហារហើយឬ ព្រះថេរៈទាំងនោះឆ្លើយថា ពួកខ្ញុំនាំគ្នាទៅទីចារិកហើយ ។ ព្រះថេរៈដឹងថា ព្រះថេរៈទាំងនោះមិនបានអាហារ ទើបពោលថា លោកម្ចាស់មេត្តារង់ចាំនៅត្រង់នេះសិន ទម្រាំខ្ញុំមក ព្រះថេរៈទាំងនោះឆ្លើយថា ពួកខ្ញុំមានដល់ទៅ ៥០ អង្គ មិនបានត្រឹមតែទឹកសើមបាត្រ ។ ព្រះថេរៈនិយាយថា លោកម្ចាស់ ធម្មតា ភិក្ខុប្រចាំអារាម រមែងជាអ្នកអាច កាលមិនបាន ក៏

ស្គាល់កិក្ខុដែលជាសម្ភាញ់ផ្លូវកិក្ខាចារ ។ ព្រះថេរៈទាំងឡាយនាំគ្នាមកហើយ ។ ព្រះថេរៈក៏ចូលមកស្រុក ។ មហាឧបាសិកាក្នុងស្រុកជិតៗ ក៏រៀបចំទឹកដោះ និងអាហារធ្វើចាំព្រះថេរៈ ពេលព្រះថេរៈមកដល់ទ្វារស្រុក ក៏ថ្វាយពេញបាត្រ ។ ព្រះតិស្សត្ថេរនោះ នាំបិណ្ឌបាតទៅកាន់សម្នាក់ព្រះថេរៈទាំងឡាយ ពោលនឹងព្រះសង្ឃត្ថេរថា សូមលោកម្ចាស់ទទួលចុះ ។ ព្រះថេរៈសម្លឹងមើលមុខព្រះថេរៈដទៃៗ ដោយគិតថា ពួកយើងដល់ប៉ុណ្ណោះមិនបានអ្វីឡើយ តែព្រះថេរៈអង្គនេះទៅតែមួយរំពេចក៏ត្រឡប់មក សេចក្តីនេះដូចម្តេចហ្ន៎ ។ ព្រះតិស្សៈដឹងដោយអាការដែលសម្លឹងមើលប៉ុណ្ណោះពោលថា លោកម្ចាស់ ពួកលោកកុំកង្វល់ចិត្តឡើយ សូមទទួលបិណ្ឌបាតដែលបានមកដោយស្មើចុះ ហើយក៏ប្រគេនអាហារល្មមនឹងសេចក្តីត្រូវការដល់ព្រះថេរៈគ្រប់រូបតាំងពីដើម ខ្លួនឯងក៏បានធាន់គ្រប់គ្រាន់ ។ កាលធាន់ស្រេចហើយ ព្រះថេរៈទាំងឡាយសួរព្រះតិស្សៈនោះថា អ្នកមានអាយុ សម្រេចលោកុត្តរធម៌តាំងពីកាលណា ។ ព្រះតិស្សត្ថេរឆ្លើយថា លោកុត្តរធម៌របស់ខ្ញុំ មិនមានទេលោកម្ចាស់ ។ ព្រះថេរៈទាំងនោះសួរថា អ្នកមានអាយុបានឈានឬ ។ ព្រះថេរៈឆ្លើយថា សូម្បីយ៉ាងនេះក៏មិនមាន ។ ព្រះថេរៈទាំងនោះសួរថា អ្នកមានអាយុគួរអស្ចារ្យណាស់ហ្ន៎ ។ ព្រះតិស្សត្ថេរឆ្លើយថា លោកម្ចាស់ ខ្ញុំបំពេញសាវណីយធម៌ តាំងពីវេលាដែលសាវណីយធម៌របស់ខ្ញុំនោះសម្រេចហើយ សូម្បីមានកិក្ខុមួយសែនរូបវត្តុដែលនៅក្នុងបាត្រក៏មិនអស់ទៅ ។ ព្រះថេរៈទាំងនោះស្តាប់ហើយ ក៏នាំគ្នាពោលថា សាធុ សាធុ សប្បុរស ធម៌នេះរបស់លោក សមគួរហើយ ។ ក្នុងបទថា **បត្តគតំ ន ឋីយតិ** *របស់ដែលនៅក្នុងបាត្រមិនអស់ទៅនេះ មានរឿង*

ប៉ុណ្ណេះ ។ ម្យ៉ាងទៀត ព្រះថេរៈអង្គនេះឯង ទៅកាន់ទីឲ្យទាននៅគិរិកណ្ឌ មហាបូជាត្រង់ចេតិយបព៌ត សួរថា ក្នុងទាននេះអ្វីជាវត្ថុដ៏ប្រសើរ ។ ឆ្លើយថា សំពត់សាដក ២ ផ្ទាំង លោកម្ចាស់ ។ ព្រះថេរៈនិយាយថា សំពត់សាដក ទាំង ២ ផ្ទាំងនោះ នឹងត្រូវបានដល់ខ្ញុំ ។ អមាត្យបានស្តាប់ដូច្នោះហើយ ទើបក្រាបទូលដល់ព្រះរាជាថា កិក្ខុកំលោះមួយរូបនិយាយយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា កិក្ខុកំលោះមានចិត្តគិតយ៉ាងនេះ តែសំពត់សាដកសាច់ល្អិតគួរដល់ព្រះមហាថេរៈទាំងឡាយ ទើបតាំងទុកដោយបំណងប្រគេនព្រះថេរៈទាំង-ឡាយ ។ ព្រះរាជាកាលប្រគេនក្នុងកាលកិក្ខុសង្ឃឈររៀងគ្នា សំពត់សាដក ២ ផ្ទាំង ដែលជាក់ទុកជិតៗ ក៏មិនឡើងកាន់ព្រះហស្ត ឡើងតែសំពត់ផ្ទាំងជទៃៗ តែក្នុងវេលាដែលថ្វាយកិក្ខុកំលោះ សំពត់សាដក ២ ផ្ទាំងនោះ ឡើងកាន់ព្រះហស្តរបស់ព្រះរាជា ។ ទ្រង់ជាក់ក្នុងដៃរបស់កិក្ខុកំលោះនោះ មើលមុខរបស់អមាត្យ ឲ្យកិក្ខុកំលោះអង្គុយថ្វាយទាន ទ្រង់លះសង្ឃ ហើយប្រថាប់ជិតកិក្ខុកំលោះ ត្រាស់ថា លោកម្ចាស់ លោកសម្រេចធម៌កាលណា ។ កិក្ខុកំលោះនោះ មិនទូលដល់គុណដែលមិនមានសូម្បីផ្លែវអម ទូលថា ថ្វាយព្រះពរ លោកុត្តរធម៌របស់អាត្មាភាពមិនមានទេ ។ ព្រះរាជាត្រាស់ថា ពីមុនលោកម្ចាស់បាននិយាយទុកមិនមែនឬ ព្រះថេរៈទូលថា ថ្វាយព្រះពរ ពិតហើយ អាត្មាភាពបំពេញសារាណីយធម៌ តាំងពីវេលាដែលធម៌នោះរបស់អាត្មាភាពពេញហើយ វត្ថុដ៏ប្រសើរ ក៏មកដល់ក្នុងស្ថានទីចែក ។ ព្រះរាជាត្រាស់ថា សាធុ សាធុ លោកម្ចាស់ គុណធម៌នេះរបស់លោកម្ចាស់សមគួរពិត ហើយក៏ស្តេចត្រឡប់ ។ ក្នុងបទថា **ភាជនីយដ្ឋានេ អគ្គភណ្ឌំ ចាបុណាតិ** វត្ថុដ៏

ប្រសើរនឹងមកដល់ក្នុងស្ថានទីចែកចាយនេះ មានរឿងដូចពោលមកនេះ ។

ម្យ៉ាងទៀត មនុស្សនៅកាតរគ្រាម ក្នុងព្រាហ្មណគិស្សកយនគរ មិនពោលលាដល់ព្រះនាគថេរី នាំគ្នាចៀសចេញទៅ ។ រៀលាជិតភ្លឺ ព្រះថេរីនិយាយចំពោះពួកភិក្ខុនីក្រមុំថា កូមិស្រុកស្វាត់ពេកណាស់ នាងនាំគ្នាទៅមើលមើល៍ ។ ភិក្ខុនីក្រមុំទាំងនោះទៅមើល ក៏ដឹងថា អ្នកស្រុកនាំគ្នាភៀសខ្លួនទៅអស់ហើយ ទើបមកប្រាប់ដល់ព្រះថេរី ។ ព្រះថេរីនោះស្តាប់ហើយ ក៏ពោលថា ពួកនាងកុំគិតថា អ្នកស្រុកទាំងនោះភៀសខ្លួនទៅឡើយ ចូរធ្វើសេចក្តីព្យាយាមក្នុងការរៀនសូត្របាលីអដ្ឋកថា និងយោនិសោមនសិការរបស់ខ្លួនប៉ុណ្ណោះ រៀលាភិក្ខាចារក៏ដណ្តប់សំពត់រួមគ្នា ១២ រូប រួមទាំងខ្លួនឯង ឈរត្រង់គល់ជិតទ្វារស្រុក ទេវតាដែលស្ថិតនៅត្រង់ជើមឈើ ក៏ប្រគេនបិណ្ឌបាតដល់ភិក្ខុនី ១២ រូប ហើយពោលថា បពិត្រអ្នកនាងម្ចាស់ កុំទៅទីដទៃឡើយ សូមនៅទីនេះជានិច្ចចុះ ។ តែព្រះថេរីមានបួនប្រុសឈ្មោះព្រះនាគត្ថេរ ព្រះថេរៈគិតថា មានភ័យធំ អញមិនអាចនៅក្នុងទីនេះបាន នឹងទៅត្រើយនាយ មានភិក្ខុ ១២ រួមទាំងខ្លួន ចេញពីលំនៅរបស់ខ្លួន មកកាន់កាតរគ្រាម ដោយបំណងថា នឹងជួបព្រះថេរី ហើយសឹមទៅ ។ ព្រះថេរីជ្រាបថា ពួកព្រះថេរៈនាំគ្នាមកហើយ ទើបទៅសម្នាក់របស់ព្រះថេរៈទាំងនោះ សួរថា មានការអ្វីលោកម្ចាស់ ។ ព្រះថេរៈក៏ប្រាប់រឿងនោះ ។ ព្រះថេរីប្រាប់ថា ថ្ងៃនេះ សូមលោកម្ចាស់ទាំង-ឡាយនៅក្នុងវត្តនេះមួយថ្ងៃសិនហើយ ស្អែកនេះសឹមទៅ ។ ព្រះថេរៈទាំងឡាយក៏នាំគ្នាទៅកាន់វត្ត ។ ស្អែកឡើងព្រះថេរីត្រាច់បិណ្ឌបាត ត្រង់គល់ឈើ ចូលទៅរកព្រះថេរៈនិយាយថា សូមលោកម្ចាស់ឆាន់បិណ្ឌបាតនេះចុះ ។ ព្រះថេរៈ

ពោលថា នឹងគួរឬព្រះថេរី ហើយក៏ឈរស្ងៀម ។ ព្រះថេរីពោលថា លោកម្ចាស់ បិណ្ឌបាតនេះ បានមកដោយធម៌ កុំរង្កៀស សូមឆាន់ចុះ ។ ព្រះថេរៈនិយាយថា គួរឬ ។ ព្រះថេរីចាប់បាត្របាន ក៏បោះទៅក្នុងអាកាស ។ បាត្រក៏តាំងនៅក្នុងអាកាស ។ ព្រះថេរៈក៏ពោលថា ព្រះថេរី កត្តសូម្បីតាំងនៅក្នុងទីកម្ពស់ ๗ ដើមត្នោត ក៏ជាកត្តសម្រាប់កិក្ខុនីនុ៎ះឯង ហើយពោលទៀតថា ឈ្មោះថា ភ័យ មិនមែនមានគ្រប់កាល កាលភ័យស្ងប់ ខ្ញុំក៏ពោលដល់អរិយវង្ស ត្រូវនាងជាស់តឿនដោយចិត្តថា នែលោកអ្នកកាន់បិណ្ឌបាតិកធុតង្គ ពួកលោកមេត្តាឆាន់អាហារបស់កិក្ខុនីបែបនេះរឿយៗ ចុះ ដូច្នេះ ខ្ញុំមិនអាចជួយបាន ពួកនាងចូរជាអ្នកមិនប្រមាទចុះ ហើយចេញដំណើរទៅ ។ សូម្បីវុក្ខទេវតាក៏គិតថា បើព្រះថេរៈឆាន់បិណ្ឌបាតអំពីដៃព្រះថេរី អញនឹងមិននាំព្រះថេរៈនោះត្រឡប់ បើព្រះថេរៈមិនឆាន់ ក៏នឹងនាំត្រឡប់ ឈរមើលព្រះថេរៈទៅ ចុះអំពីដើមឈើនិយាយថា សូមលោកម្ចាស់ ឲ្យបាត្រមកលោកម្ចាស់ ហើយទទួលបាត្រនាំព្រះថេរៈមកត្រង់គល់ឈើនោះឯង ក្រាលអាសនៈប្រគេនបិណ្ឌបាត ឲ្យព្រះថេរៈដែលឆាន់ស្រេចហើយ ប្តេជ្ញាទំនុកបម្រុងកិក្ខុនី ๑๒ រូប កិក្ខុ ๑๒ រូប ๗ ឆ្នាំ ។ ក្នុងបទនេះថា **ទេវតា ឧស្សុក្កំ អាបជ្ជន្តិ** *ទេវតារមែងជួយជ្រោមជ្រែង មានរឿងដូចពោលមកនេះ ។ ពិតហើយ ក្នុងសេចក្តីនោះ ព្រះថេរីក៏បានជាអ្នកបំពេញសាវណីយធម៌ ។*

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អខណ្ឌានិ** *ដូច្នេះជាដើមថា កិក្ខុណាមានសិក្ខាបទជាប់ក្នុងខាងដើម ឬទីបំផុត ក្នុងអាបត្តិទាំង ๗ កង សីលរបស់កិក្ខុនោះ ឈ្មោះថា ជាប់ ដូចសំពត់ជាប់ត្រង់ជាយ ។ កិក្ខុណា មានសិក្ខាបទជាប់*

ត្រង់កណ្តាល សីលរបស់ភិក្ខុនោះ ឈ្មោះថា ជ្រុះ ដូចសំពត់ជ្រុះត្រង់កណ្តាល ។ ចំណែកភិក្ខុណាមានសិក្ខាបទ ២-៣ សិក្ខាបទជាប់តាមលំដាប់ សីលរបស់ភិក្ខុនោះ ឈ្មោះថា ពព្រុស ដូចមេគោមានពណ៌ខ្មៅ លាយពណ៌ក្រហមជាដើម ដោយពណ៌ដែលផ្សេងគ្នា នៅត្រង់ខ្នងខ្លះ ពោះខ្លះ ។ ភិក្ខុណាមានសិក្ខាបទជាច់ឆ្ងោះៗ សីលរបស់ភិក្ខុនោះ ឈ្មោះថា ពពាល ដូចមេគោមានពណ៌អុជផ្សេងៗ ក្នុងចន្លោះៗ ។ ចំណែកភិក្ខុណា មានសិក្ខាបទមិនជាច់ សីលទាំងនោះរបស់ភិក្ខុនោះ ឈ្មោះថា មិនជាច់ មិនជ្រុះ មិនពព្រុស មិនពពាល ។ សីលនោះ ឈ្មោះថា ជាអ្នកគ្មានបំណុល ព្រោះធ្វើឲ្យផុតពីភាពជាទាសតណ្ហា ត្រឡប់ជាគ្មានបំណុល ឈ្មោះថា វិញ្ញូជនសរសើរហើយ ព្រោះវិញ្ញូជន មានព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ ឈ្មោះថា ដែលកិលេសមិនពាល់ត្រូវ ព្រោះតណ្ហា និងទិដ្ឋិមិនពាល់ត្រូវហើយ និងព្រោះបុគ្គលណា មិនអាចប្រមាទមើលងាយថា លោកធ្លាប់ត្រូវអាបត្តិឈ្មោះនេះ ។ លោកហៅថា ប្រព្រឹត្តទៅដើម្បីសមាធិ ព្រោះញុំាងឧបចារសមាធិ ឬអប្បនាសមាធិឲ្យប្រព្រឹត្តទៅ ។ បទថា **សីលាសាមញ្ញគតា វិហរិស្សន្តិ** បានដល់ នឹងមានសីល ស្មើនឹងភិក្ខុអ្នកនៅក្នុងចំណែកនៃទិសនោះឯង ។ ពិតហើយ សីលរបស់ព្រះសោតាបន្នជាដើម រមែងស្មើនឹងសីលរបស់ព្រះសោតាបន្នជាដើម ពួកជនៃអ្នកនៅក្នុងចន្លោះសមុទ្រក្តី ក្នុងទេវលោកក្តី ។ សេចក្តីផ្សេងគ្នាក្នុងសីល ដែលប្រកបដោយមគ្គផលមិនមាន ។ លោកសំដៅយកប្រការនោះ ទើបពោលពាក្យនេះ ។

បទថា **យាយំ ទិដ្ឋិ** បានដល់ សម្មាទិដ្ឋិដែលសម្បយុត្តដោយមគ្គ ។ បទថា **អរិយា** បានដល់ មិនមានទោស ។ បទថា **និយ្យាតិ** បានដល់ នាំទុក្ខ

ចេញទៅ ។ បទថា **តក្ការស្ស** *បានដល់ អ្នកធ្វើយ៉ាងនោះ ។ បទថា* **សព្ព-ទុក្ខក្ខាយ** *បានដល់ ដើម្បីការអស់ទុក្ខក្នុងវដ្តៈទាំងពួង ។ បទថា* **ទិដ្ឋិ-សាមញ្ញគតា** *សេចក្តីថា នឹងជាអ្នកចូលដល់ភាពជាអ្នកមានទិដ្ឋិស្មើគ្នា ។ បទថា* **វុឌ្ឍិយេវ** *សេចក្តីថា សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ។ បទថា* **ឯតទេវ ពហុលំ** *សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់ប្រទានឱវាទដល់ភិក្ខុទាំងឡាយ ទើបទ្រង់ធ្វើធម្មីកថាយ៉ាងនេះឯងរឿយៗ ព្រោះជិតបរិនិព្វាន ។ បទថា* **ឥតិ សីលំ** *គឺសីលយ៉ាងនេះសីលប៉ុណ្ណេះ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបថា ចតុប្បារិសុទ្ធិសីល ឈ្មោះថាសីល ។ ចិត្តេកគ្គតា ឈ្មោះថា សមាធិ ។ វិបស្សនា ឈ្មោះថា បញ្ញា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា* **សីលបរិភាវិតោ** *ដូច្នេះថា ភិក្ខុទាំងឡាយតាំងនៅក្នុងសីលណា រមែងកើតសមាធិដែលសម្បយុត្តដោយមគ្គ សមាធិដែលសម្បយុត្តដោយផល សមាធិនោះ ដែលសីលនោះអប់រំហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ភិក្ខុទាំងឡាយតាំងនៅក្នុងសមាធិណា រមែងកើតបញ្ញា ដែលសម្បយុត្តដោយមគ្គ បញ្ញាដែលសម្បយុត្តដោយផល បញ្ញានោះ ដែលសមាធិនោះអប់រំហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ភិក្ខុទាំងឡាយ តាំងនៅក្នុងបញ្ញាណា រមែងកើតមគ្គចិត្ត ផលចិត្ត ចិត្តនោះ ដែលបញ្ញានោះអប់រំហើយ រមែងរួចផុតពីអាសវៈទាំងឡាយ ដោយប្រពៃនោះឯង ។*

[๗๖] *បទថា* **យថាភិរន្តំ** *សេចក្តីថា ឈ្មោះថា ការមិនត្រេកអរក្រៃលែង សេចក្តីភ័យតក់ស្លុតរបស់ព្រះពុទ្ធជាដើមមិនមាន ។ តែលោក*

อธิប្បាយថា តាមសេចក្តីពេញចិត្ត តាមអធ្យាស្រ័យ ។ បទថា **អាយាម** *ប្រែថា មកទៅជាមួយគ្នាចុះ ជាឋ:ថា* **អយាម** *ក៏មាន អធិប្បាយថា ទៅជាមួយគ្នា ។ ព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទអ្នកជាប់តាមទៅជិតៗ ថា អានន្ទ ។ ចំណែកព្រះថេរ:ប្រាប់ភិក្ខុទាំងឡាយថា អ្នកមានអាយុ ចូរត្រៀមកាន់បាត្រ ចីវរ ព្រះមានព្រះភាគ ទ្រង់ព្រះបំណងយាងទៅទីឯណោះ ។ រឿងការយាងមកអម្ពលដ្ឋិកាវែន ងាយយល់ទាំងអស់ហើយ ។*

[๗๗] *បទថា* **អថ ខោ អាយស្មា សារីបុត្តោ** *ជួបច្នេះជាដើម លោកពោលពិស្តារហើយ ក្នុងសម្បសាទនីយសូត្រ ។*

[๗๘] *បទថា* **ចាតុលិគាមេ អាវសថាគារំ** *បានដល់ ផ្ទះសម្នាក់សម្រាប់អ្នកត្រាច់មក ។ បានឮថា ក្នុងចាតុលិគ្រាម សម្ងាញ់របស់ព្រះរាជាពីរព្រះអង្គនាំគ្នាមកជានិច្ច នាំក្រុមគ្រួសារចេញចាកស្រុក មកសម្រាកមួយខែខ្លះ កន្លះខែខ្លះ ។ មនុស្សទាំងនោះត្រូវរុកកួនជានិច្ច ក៏គិតគ្នាថា ក្នុងវេលាដែលអ្នកទាំងនោះនាំគ្នាមក ក៏មានទីនៅ ដូច្នេះហើយ ទើបសាងសាលាធំ កណ្តាលព្រះនគរ សាងទីរក្សាវត្តុទុកមួយចំណែក សាងទីនៅអាស្រ័យទុកមួយចំណែករបស់សាលានោះ ។ មនុស្សទាំងនោះ បានជ្រាបថា ព្រះមានព្រះភាគយាងមកហើយ ក៏មើលឃើញប្រយោជន៍យ៉ាងនេះថា ពួកយើងក៏គប្បីទៅយាងព្រះមានព្រះភាគមក ព្រះអង្គយាងមកដល់ទីនៅរបស់ពួកយើងដោយព្រះអង្គឯង ហើយថ្ងៃនេះ ពួកយើងនឹងអារាធនាព្រះមានព្រះភាគត្រាស់សម្តែងមង្គលក្នុងទីសម្រាក ព្រោះដូច្នោះ ទើបនាំគ្នាពោលយ៉ាងនេះ ។ បទថា* **យេនាវសថាគារំ** *សេចក្តីថា បានឮថា មនុស្សទាំងនោះ មិនដឹងព្រះហឫទ័យ*

របស់ព្រះមានព្រះភាគថា ធម្មតាព្រះពុទ្ធទាំងឡាយ មានព្រះអធ្យាស្រ័យពេញចិត្តក្នុងព្រៃ ត្រេកអរក្នុងព្រៃ នឹងទ្រង់ប្រាថ្នា ឬមិនប្រាថ្នាប្រថាប់នៅក្នុងស្រុក ទើបមិនចាត់ចែងផ្ទះសម្រាក នាំគ្នាគិតថា ឥឡូវនេះ ពួកយើងដឹងព្រះហឫទ័យរបស់ព្រះមានព្រះភាគហើយ នឹងនាំគ្នាទៅចាត់ចែងជាមុន ដូច្នោះ ទើបនាំគ្នាទៅកាន់អាវសថាគារ ។ បទថា **សព្វសន្ថរិតំ** *ប្រែថា ក្រាលនូវកម្រាលគ្រប់យ៉ាង ។*

[๗๙-๘๐] *បទថា* **ទុស្សីលោ** *បានដល់ បុគ្គលមិនមានសីល ។ បទថា* **សីលវិបន្នោ** *បានដល់ មានសីលវិបត្តិ មានសំវរៈបែកធ្លាយ ។ បទថា* **បមាទាធិករណំ** *បានដល់ ព្រោះសេចក្តីប្រមាទជាហេតុ ។ ព្រះសូត្រនេះប្រើសម្រាប់គ្រហស្ថ សូម្បីបព្វជិតក៏ប្រើបាន ។ ពិតហើយ គ្រហស្ថចិញ្ចឹមជីវិតដោយការប្រឹងប្រែង សិក្សាសិល្បៈ មិនថា ជាកសិកម្ម ពាណិជ្ជកម្ម ភ្ជាំងភ្ជាត់ទៅដោយការធ្វើបាណាតិបាតជាដើម ក៏មិនអាចធ្វើសិល្បៈនោះៗ ឲ្យសម្រេចតាមកាល កាលបើដូច្នោះ ឬសគល់របស់គេក៏វិនាស ។ តែក្នុងវេលាក្រលំបាក រមែងធ្វើបាណាតិបាត និងអទិន្នាទាន នឹងសាបសូន្យកោគៈយ៉ាងធំ ព្រោះអំណាចទោស ។ ចំណែកបព្វជិតទ្រុស្តសីល រមែងដល់សេចក្តីសាបសូន្យចាកសីលចាកពុទ្ធវចនៈ ចាកឈាន និងចាកអរិយទ្រព្យ ๗ ព្រោះសេចក្តីប្រមាទជាហេតុ ។ សម្រាប់គ្រហស្ថនោះ កិត្តិសព្ទអាក្រក់ រមែងខ្ចរខ្ចាយទៅកណ្តាលបរិស័ទ ๔ ថា អ្នកឯណោះ កើតក្នុងត្រកូលឯណោះ ទ្រុស្តសីល មានបាបធម៌ លះបង់ទាំងលោកនេះ និងលោកខាងមុខ មិនថ្វាយទាន សូម្បីត្រឹមតែសលាកភត្ត ។ ឬសម្រាប់បព្វជិត កិត្តិសព្ទអាក្រក់ក៏ផ្សាយ*

ទៅយ៉ាងនេះថា ភិក្ខុឈ្មោះនោះ មិនអាចរក្សាសីលបាន មិនអាចរៀនព្រះ ពុទ្ធវចនៈបាន ចិញ្ចឹមជីវិតដោយអនេសនកម្ម មានវេជ្ជកម្មជាដើម ប្រកប ដោយអគារវៈ ៦ ។ បទថា **អវិសារទោ** សេចក្តីថា គ្រហស្ថមានសេចក្តី ខ្វាចថា កាលមុននេះ បុគ្គលពួកខ្ញុះនឹងដឹងរឿងកម្មរបស់អញ ដូច្នោះ ក៏នឹង សង្កត់សង្កិនអញ ឬបង្ហាញអញចំពោះរាជត្រកូលក្នុងទីប្រជុំ នៃមនុស្សច្រើន ជាប្រាកដ ទើបចូលទៅមិនក្ងៀវក្ងា សំយុងក ឌិនមុខចុះ អង្គុយយកមេដៃធ្ពឹះដី ទោះបីជាអ្នកក្លាហាន ក៏មិនអាចនិយាយចរចាបាន ។ ចំណែកបព្វជិត មាន សេចក្តីខ្វាចថា ភិក្ខុជាច្រើនប្រជុំគ្នា អង្គខ្ញុះនឹងដឹងកម្មរបស់អញពិត ដូច្នោះ នឹងវៀរឧបោសថខ្ញុះ បវារណាខ្ញុះដល់អញ នឹងទាញអញឲ្យឃ្លាតចាកភេទ សមណៈ ទើបចូលទៅរក សូម្បីជាអ្នកក្លាហាន ក៏មិនអាចនិយាយស្តីបាន ។ ចំណែកភិក្ខុអង្គខ្ញុះ ទ្រុស្តសីល ក៏ត្រាច់ទៅដូចជាអ្នកមិនទ្រុស្តសីល ភិក្ខុនោះ ក៏រមែងជាអ្នកធ្នាំធ្ពងដោយអធ្យាស្រ័យតែម្តង ។ បទថា **សម្ទ្ធុឡ្ហោ ការលំ ការោតិ** សេចក្តីថា កាលភិក្ខុដែលទ្រុស្តសីលនោះដេកលើគ្រែសម្រាប់ស្លាប់ ទីដែលធ្លាប់ប្រព្រឹត្តក្នុងកម្ម គឺទ្រុស្តសីល រមែងមកប្រាកដ ។ ភិក្ខុទ្រុស្តសីល នោះ បើកភ្នែកក៏ឃើញលោកនេះ បិទភ្នែកក៏ឃើញបរលោក អបាយ ៤ ក៏ ប្រាកដដល់ភិក្ខុទ្រុស្តសីលនោះ ។ ភិក្ខុទ្រុស្តសីលនោះ ហាក់ដូចជាត្រូវដោយ លំពែង ១០០ ដើម ចាក់ត្រង់ក្បាល លោកនឹងស្រែកថា ជួយផង ជួយផង មរណៈទៅ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សម្ទ្ធុឡ្ហោ ការលំ ការោតិ** វង្វេងក្នុងពេលធ្វើមរណៈកាល ដូច្នេះ បទទី ៥ មានអត្ថងាយ យល់ហើយ ។ រឿងអានិសង្ស ក៏គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាតាមដែល

ពោលទុកហើយ ។

[៨១] បទថា **ពហុធេវ រត្តឹ ធម្មិយា កថាយ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ឲ្យរីករាយហើយ ឲ្យឃើញច្បាស់ហើយ ឲ្យសមាទានហើយ ឲ្យអាចហ៊ានហើយ ឲ្យចូលដល់សេចក្តីអស់ និងសេចក្តីសាបសូន្យហើយ រហូតដល់អស់រាត្រីជាច្រើន ហើយទ្រង់បញ្ជូនទៅដោយធម្មកថា ដែលផុតចាកបាលីយ៉ាងដទៃ និងដោយកថាអនុមោទនា ការថ្វាយផ្ទះសម្នាក់ ដូចជាទ្រង់នាំឆ្ងងអាកាសគង្គា ដូចជាទ្រង់ច្របាច់ផ្ងិតឃ្មុំធំ ទំហំមួយយោជន៍ ឲ្យមហាជនផឹកទឹកឃ្មុំ ដូច្នោះ ។ បទថា **អភិក្ពន្តា** បានដល់ កន្ងងទៅហើយ អស់ទៅហើយ ។ បទថា **សុញ្ញាគារំ** សេចក្តីថា ដែលឈ្មោះថា ផ្ទះស្ងាត់ ដែលចែកជាចំណែកមួយដទៃផ្សេង មិនមាន ។ តែក្នុងទីនោះឯង ពួកអ្នកស្រុកបាដលិគ្រាម ព័ទ្ធទុកដោយកំពែង គឺវាំងនន្នុងចំណែកម្ខាង ហើយចាត់គ្រែដោយប្រាថ្នាថា ព្រះសាស្តានឹងទ្រង់សម្រាកក្នុងទីនេះ ។ ព្រះមានព្រះភាគទ្រង់សម្រេចសីហសេយ្យាលើគ្រែនោះ ដោយមានព្រះពុទ្ធបំណងថា ផ្ទះសម្រាកនេះ តថាគតប្រើប្រាស់ហើយ ដោយឥរិយាបថទាំង ៤ កុសលនោះ នឹងមានផលច្រើនដល់អ្នកស្រុកបាដលិគ្រាមទាំងនោះ ដូច្នេះ ។ លោកសំដៅយកផ្ទះសម្នាក់នោះ ទើបពោលថា **សុញ្ញាគារំ ចាវិសិ** ដូច្នេះ ។

[៨២] បទថា **សុនីធវស្សការា** បានដល់ ព្រាហ្មណ៍ ២ នាក់ គឺសុនីធៈម្នាក់ វស្សការម្នាក់ ។ បទថា **មហាមត្តា** បានដល់ អមាត្យធំ គឺមហាមាត្ររបស់ស្តេចនគរមគធៈ ម្យ៉ាងទៀត ឈ្មោះថា មហាមាត្យដែនមគធៈ ព្រោះមហាមាត្រក្នុងដែនមគធៈ ប្រកបដោយឋានន្តរ គឺឥស្សរិយយសធំ ។

បទថា **ចាជលិគាមេ នគរំ** បានដល់ កសាងបាដលិគ្រាមធ្វើឲ្យជានគរ ។ បទថា **វជ្ជីនំ បដិពាហាយ** បានដល់ ដើម្បីផ្តាច់ផ្ទូវ ពង្រីកខ្ទូនរបស់រាជវង្ស ដែនវជ្ជី ។ បទថា **សហស្សេវ** បានដល់ តែមួយពួក រាប់ជាពាន់ៗ ។ បទថា **វត្ថូនិ** បានដល់ ទីសាងផ្ទះ ។ បទថា **ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ** សេចក្តីថា ចិត្តរបស់មហាមាត្យអ្នកមានវិជ្ជាទាយ មើលផ្ទៃដីបង្អោនទៅ ដើម្បីសាងគ្រឹះស្ថានសម្រាប់ព្រះរាជា និងមហាមាត្ររបស់ព្រះរាជា ។ បានឲ្ថថា មហាមាត្រទាំងនោះ ប្រើអានុភាពនៃសិល្ប:របស់ខ្ទូន មើលឃើញខាងក្រោមផែនដីប្រមាណ ៦០ ហត្ថថា ទីនេះនាគហួងហែងទុក ទីនេះយក្ខស្ថិតនៅ ទីនេះភូតស្ថិតនៅ មានថ្ម ឬដង្គត់ ។ រៀលានោះ អមាត្យទាំងនោះ រាយសិល្ប: សាងឡើងបាន ដូចប្រឹក្សាជាមួយទេវតាទាំងឡាយ ។ ម្យ៉ាងទៀត ទេវតាស្ថិតនៅក្នុងរាងកាយរបស់អមាត្យទាំងនោះ បង្អោនចិត្តទៅដើម្បីសាងគ្រឹះស្ថានក្នុងទីនោះៗ ពេលគេបោះបង្គោលចុះក្នុងជ្រុងទាំង ៤ ទើបទេវតាទាំងនោះ ស្ថិតត្រង់ផែនដី ។ ទេវតាអ្នកមានសទ្ធា ធ្វើយ៉ាងនោះ ដល់ត្រកូលអ្នកមានសទ្ធា ទេវតាអ្នកមិនមានសទ្ធា ក៏ធ្វើយ៉ាងនោះដល់ត្រកូលអ្នកមិនមានសទ្ធា ។ ព្រោះហេតុអ្វី ។ ព្រោះអ្នកមានសទ្ធា មានការគិតយ៉ាងនេះថា មនុស្សទាំង-ឡាយក្នុងលោកនេះ លុះសាងផ្ទះហើយជាដំបូង និមន្តភិក្ខុសង្ឆឲ្យគង់ ឲ្យពោលតែមង្គល កាលបើដូច្នេះ ពួកយើងក៏នឹងបានឃើញអ្នកមានសីល ស្តាប់ធម្មកថា ការដោះស្រាយបញ្ហា និងអនុមោទនា មនុស្សឲ្យទានហើយនឹងឲ្យចំណែកបុណ្យដល់យើង ។ បទថា **តាវត្តឹសេហិ** សេចក្តីថា សំឡេងផ្សាយទៅថា ពួកមនុស្សក្នុងត្រកូលឯណោះ អាស្រ័យមនុស្សដែលជាបណ្ឌិតម្នាក់

ក្នុងត្រកូលមួយ រមែងជាបណ្ឌិត ឬភិក្ខុក្នុងវិហារឯណោះ អាស្រ័យភិក្ខុដែលជាពហូសូតមួយរូប ក្នុងវិហារមួយ រមែងជាពហូសូតមួយរូប ក្នុងវិហារមួយ រមែងជាពហូសូត យ៉ាងណា ។ សំឡេងផ្សាយទៅថា ទេវតាជាន់តាវត្តិង្ស អាស្រ័យសក្កទេវរាជ និងវិស្សកម្មទេវបុត្រ រមែងជាបណ្ឌិត ដូច្នោះដែរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **តាវត្តឹសេហិ** អធិប្បាយថា រមែងសាង ដូចប្រឹក្សាជាមួយទេវតាជាន់តាវត្តិង្ស ។ បទថា **យាវតា អរិយំ អាយតនំ** សេចក្តីថា ឈ្មោះថា ដែលជាទីប្រជុំរបស់មនុស្សផៅពង្សអរិយក: មានប្រមាណប៉ុនណា ។ បទថា **យាវតា វណិប្បថោ** សេចក្តីថា ឈ្មោះថា ស្ថានទីទិញលក់ដោយគំនរវត្ថុ ដែលពួកឈ្ងួញនាំមក ឬស្ថានទីរស់នៅរបស់ពួកឈ្ងួញទាំងឡាយ មានប្រមាណប៉ុនណា ។ បទថា **ឥធំ អគ្គនគរំ** សេចក្តីថា អគ្គនគរនេះ នឹងជាក្រុងចម្រើន ជាក្រុងធំ សម្រាប់ពួកអរិយក: និងពួកឈ្ងួញនោះៗ ។ បទថា **បុដភេទនំ** បានដល់ ទីស្រាយបង្វេចទ្រព្យ ។ លោកអធិប្បាយថា ជាទីស្រាយបង្វេចទ្រព្យនៃម្ចាស់ទ្រព្យផ្សេងៗ ។ អធិប្បាយថា ជនទាំងឡាយ មិនបានទ្រព្យក្នុងសកលជម្ពូទ្វីប ក៏នឹងបានក្នុងទីនេះឯង បុគ្គលមិនទៅធ្វើជំនួញក្នុងទីដទៃ ក៏នឹងទៅក្នុងទីនេះ ព្រោះដូច្នោះ ពួកគេនឹងស្រាយបង្វេចទ្រព្យ ក្នុងទីនេះប៉ុណ្ណោះ ។ លោកសម្តែងថា ពិតហើយ រាល់ៗ ថ្ងៃមូលតម្លៃនឹងកើតឡើង ៥ សែនយ៉ាងនេះ គឺត្រង់ទ្វារព្រះនគរទាំងបួន ៤ សែនត្រង់កណ្តាល ព្រះនគរ ១ សែន ។

រា សព្ទក្នុងបទថា **អគ្គិតោ រា** មានអត្ថស្មើគ្នានឹង **ច** សេចក្តីថា នឹងវិនាសដោយភ្លើងក្តី ដោយទឹកក្តី ឬដោយការបែកគ្នាជា ២ ចំណែកក្តី អធិប្បាយ

ថា ចំណែកមួយវិនាសដោយភ្លើង មិនអាចនឹងរម្ងាប់បាន ចំណែកមួយស្តឹងគង្គាកួចយកទៅ ចំណែកមួយនឹងវិនាសទៅដោយការបែកគ្នានឹងគ្នារបស់ពួកមនុស្ស អ្នកបែកគ្នាដោយអំណាចបិសុណាវាចា ដែលពោលថា អ្នកនេះមិននិយាយនឹងអ្នកនោះ អ្នកនោះមិននិយាយនឹងអ្នកនេះ ។

[๘๓] កាលព្រះមានព្រះភាគត្រាស់ដូច្នេះហើយ វេលាជិតភ្លឺ ទ្រង់យាងទៅកាន់ច្រាំងស្តឹងគង្គា ទ្រង់ជម្រះព្រះកក្រើហើយ ប្រថាប់គង់រង់ចាំកាលកិក្ខាចារ ។ ចំណែកមហាមាត្យឈ្មោះសុនីធៈ និងវស្សការ គិតថា ព្រះរាជារបស់ពួកយើង ជាឧបដ្ឋាករបស់ព្រះសមណគោតម ព្រះអង្គនឹងត្រាស់សួរពួកយើងថា បានឮថា ព្រះសាស្តាទ្រង់យាងទៅបាដលិគ្រាម ពួកលោកបានចូលគាល់ព្រះអង្គឬទេ កាលក្រាបទូលថា ទូលបង្គំចូលគាល់ ទើបត្រាស់សួរទៀតថា ពួកលោកបាននិមន្តឬទេ កាលក្រាបទូលថា មិនបាននិមន្ត នឹងលើកទោសពួកយើង មួយទៀតសោត ពួកយើងក៏នឹងសាងព្រះនគរក្នុងទីដែលមិនទាន់បានសាង ឯក្នុងទីដែលព្រះសមណគោតមយាងទៅហើយ ពួកសត្វកាឡកណ្ណី នឹងគេចចេញទៅ ទើបគិតថា ពួកយើងនឹងឲ្យព្រះអង្គត្រាស់វត្តុដែលជាមង្គលដល់ព្រះនគរ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តាទូលអារាធនា ព្រោះដូច្នោះ ទើបលោកពោលថា **អថខោ សុនីធវស្សការា** ជាដើម ។

បទថា **បុព្វណ្ហសមយំ** ប្រែថា ក្នុងវេលាព្រឹក ។ បទថា **និវាសេត្វា** ប្រែថា ទ្រង់ស្បៃកអន្តរវាសក ចងវត្តពន្ធចង្កេះតាមធម្មទំនៀម ចូលស្រុក ។ បទថា **បត្តចីវរមាទាយ** ប្រែថា ទ្រង់កាន់បាត្រ និងចីវរ នៅជិតព្រះអង្គ ។

[៨៤] បទថា **សីលវន្តេត្ថ** កាត់បទជា **សីលវន្តេ ឯត្ថ** ។ បទថា **សញ្ញតេ** បានដល់ អ្នកសង្រួមដោយកាយវាចាចិត្ត ។ បទថា **តាសំ ទក្ខិណាមាទិសេ** សេចក្តីថា គប្បីឧទ្ទិសបច្ច័យ ៤ ដែលថ្វាយសង្ឃ គឺគប្បីឲ្យចំណែកបុណ្យដល់ទេវតាប្រចាំផ្ទះទាំងនោះ ។ បទថា **បូជិតា បូជយន្តិ** សេចក្តីថា ទេវតារមែងរក្សាដោយល្អ ដោយបង្គាប់ថា មនុស្សទាំងនេះ សូម្បីមិនមែនញាតិរបស់យើង ក៏គង់ឲ្យចំណែកបុណ្យដល់ពួកយើងយ៉ាងនេះ ព្រោះដូច្នោះពួកលោកចូរចាត់ការរក្សាដោយល្អ ។ បទថា **មានិតា មានយន្តិ** សេចក្តីថា ទេវតាទាំងឡាយ ដែលពួកមនុស្សរាប់អាន ដោយការធ្វើពលីកម្មតាមកាលសមគួរ ទើបរាប់អាន គឺកម្ចាត់អន្តរាយដែលកើតឡើង ដោយឃើញថា មនុស្សទាំងនេះ មិនមែនញាតិរបស់ពួកយើង ក៏គង់ធ្វើពលីកម្មដល់ពួកយើងក្នុងរវាង ៤ ខែ ៦ ខែ ។ បទថា **តតោ នំ** បានដល់ តពីនោះ ទេវតាក៏រមែងអនុគ្រោះបុគ្គលបណ្ឌិតនោះ ។ បទថា **ឱរសំ** បានដល់ ដាក់ទុកត្រង់ទ្រូងឲ្យចម្រើនធំធាត់ អធិប្បាយថា រមែងអនុគ្រោះ ដូចមាតាអនុគ្រោះបុត្រដែលកើតពីទ្រូង ព្យាយាមកម្ចាត់អន្តរាយដែលកើតឡើង ដូច្នោះ ។ បទថា **ភទ្រានិ បស្សតិ** ប្រែថា ឃើញវត្ថុដែលល្អ ។

[៨៥] បទថា **ឧឡុម្បំ** បានដល់ ពាហនៈដែលគេភ្ជាប់ស្នៀតសាងទុក ដើម្បីទៅត្រើយនាយ គឺផែ ។ បទថា **កុល្លំ** បានដល់ ពាហនៈដែលគេប្រើវល្លិជាដើមចង គឺក្បូន ។ បទថា **អណ្ណវំ** ក្នុងគាថា ថា **យេ តរន្តិ អណ្ណវំ** នេះ ជាឈ្មោះនៃទីដែលមានទឹកជ្រៅ និងទូលំទូលាយ ដោយកំណត់យ៉ាង

ชิตบំផុតប្រមាណមួយយោជន៍ ។ ក្នុងបទថា **สรំ** *នេះ លោកប្រាថ្នាយកស្ទឹង ។ មានពាក្យអធិប្បាយថា អ្នកដែលឆ្លងស្រះ គឺតណ្ហា ដែលជ្រៅផង ជំផង សាងស្ពាន ពោល គឺអរិយមគ្គ លះភក់ គឺរណ្តៅពេញដោយទឹកដែលប៉ះពាល់មិនបានឆ្លងទៅ ចំណែកបុគ្គលនេះ ត្រូវការនឹងឆ្លងស្ទឹង តូចតាចនេះក៏ត្រូវចង់ក្បួន ចំណែកបុគ្គលមានបញ្ញា គឺព្រះពុទ្ធ និងពុទ្ធសាវក មិនចាំបាច់ប្រើក្បួន ក៏ឆ្លងបាន ។*

បឋមភាណវារ ចប់

អរិយសច្ចកថា

[๘๖] *បទថា* **โกฏิคฺคาโม** *បានដល់ ស្រុកដែលសាងទុកខាងចុងប្រាសាទរបស់ព្រះបាទមហាបនាទ: ។ បទថា* **อริยสจฺจานំ** *បានដល់ សច្ចៈដែលធ្វើឲ្យបានជាព្រះអរិយៈ ។ បទថា* **อนนุโพธา** *បានដល់ ព្រោះមិនត្រាស់ដឹង គឺមិនដឹង ។ បទថា* **อปฺปฏิเวธา** *ប្រែថា ព្រោះមិនចាក់ធ្លុះ ។ បទថា* **สนฺธาวิตំ** *បានដល់ អន្ទោលទៅ ដោយចេញពីភពទៅកាន់ភព ។ បទថា* **สំสริตំ** *បានដល់ អន្ទោលទៅមកៗ រឿយៗ ។ បទថា* **มมญฺเจว តุมฺหากญฺจ** *ប្រែថា ដែលតថាគត និងអ្នកទាំងឡាយ ។ នយមួយទៀត គប្បីជ្រាបសេចក្តីក្នុងអត្ថនេះយ៉ាងនេះថា បទថា* **สนฺธาวิตំ สំสริตំ** *ប្រែថា ការសុះទៅ អន្ទោលទៅ មានហើយ ដល់តថាគត និងអ្នកទាំងឡាយ ។*

[๘๗] *បទថា* **สំสริตพฺพำ** *ប្រែថា អន្ទោលទៅ ។ បទថា* **ภวเนตฺติ สมฺภตา** *បានដល់ ខ្សែ គឺតណ្ហាដែលអាចនាំសត្វចាកភព ទៅកាន់ភព*

ដែលតថាគត និងអ្នកទាំងឡាយកម្ចាត់ហើយ កាត់ហើយ ធ្វើមិនឲ្យប្រព្រឹត្ត ទៅហើយដោយល្អ ។

[๘๙] *បទថា* **ญาติกา** *បានដល់ ស្រុកពីរបស់បុត្រនៃឪពុកមា និងអ៊ំទាំងពីរ អាស្រ័យស្រះតែមួយ ។ បទថា* **ญาติเก** *បានដល់ ពួកញាតិ ក្នុងស្រុកមួយ ។ បទថា* **คิญฺชกาวสเถ** *បានដល់ ផ្ទះសម្ចាក់ធ្វើដោយឥដ្ឋ ។ បទថា* **ฉินฺนาคิยานํ** *បានដល់ ចំណែកខាងក្រោម អធិប្បាយថា ធ្វើឲ្យបដិសន្ធិ ក្នុងកាមភពប៉ុណ្ណោះ ។ ម្យ៉ាងទៀត ឆិន្នាគិយសញ្ញោជនៈ ដែលគប្បីលះ ដោយមគ្គទាំង ๓ ដែលបានឈ្មោះថា* **ฉินฺนํ** *។ ក្នុងសញ្ញោជនៈទាំងនោះ សញ្ញោជនៈ ๒ នេះ គឺកាមឆន្ទៈ ព្យាបាទៈ ដែលគ្រប់សង្កត់មិនបានដោយ សមាបត្តិ ឬលះបង់មិនបានដោយមគ្គ មិនឲ្យទៅកាន់រូបភព និងអរូបភព ខាងលើ ។ សញ្ញោជនៈ ๓ មានសក្កាយទិដ្ឋិជាដើម នាំសត្វដែលកើតក្នុង ភពនោះ ឲ្យមកកើតក្នុងភពនេះទៀត ព្រោះដូច្នោះ ទើបសញ្ញោជនៈទាំង ๓ ឈ្មោះថា* **ฉินฺนาคิยสญฺโญชน ។** *បទថា* **อนาวตฺติธมฺมา** *បានដល់ មានការ មិនត្រឡប់មកដោយបដិសន្ធិជាសភាវៈ ។ ក្នុងបទថា* **ราคโทสโมหานํ ตนุตฺตา** *នេះ គប្បីជ្រាបភាពដែលរាគៈ ទោសៈ មោហៈស្រាលស្តើងដោយ អាការទាំង ๒ យ៉ាង គឺដោយការកើតឡើងម្តងម្កាល និងមានបរិយុដ្ឋាន-កិលេសតិច ។ កិលេសមានរាគៈជាដើម រមែងមិនកើតឡើងរឿយៗ ដល់ ព្រះសកទាគាមី ដូចបុថុជ្ជនឡើយ តែកើតឡើងម្តងម្កាល កាលកើតឡើង មិនកើតឡើងច្រើនដូចបុថុជ្ជន កើតឡើងតិចៗ ដូចភាជនៈជាក់ត្រី តែព្រះ មហាសិវត្ថេរអ្នករចនាគម្ពីរទីឃនិកាយ ពោលថា ព្រោះព្រះសកទាគាមីនៅ*

មានបុត្រធីតា និងនៅមានអ្នកស្និទ្ធ ដូច្នោះ ទើបនៅមានកិលេសក្រាស់ តែ ពាក្យនេះ លោកពោលដល់កិលេសក្នុងកពស្រាលស្តើង ។ ពាក្យនោះ ក្នុង អដ្ឋកថាលោកជំទាស់ ព្រោះលោកពោលថា ព្រះសោតាបន្ន វៀរកព ៧ ចេញ កិលេសដែលស្រាលស្តើងក្នុងកពទី ៨ មិនមាន ចំណែកព្រះសកទាគាមី វៀរកពពីរចេញ មិនមានកិលេសស្រាលស្តើងក្នុងកពទាំង ៥ ឯព្រះអនាគាមី វៀររូបកព អរូបកព មិនមានកិលេសស្រាលស្តើងក្នុងកាមកព ព្រះខីណា-ស្រព មិនមានកិលេសស្រាលស្តើងក្នុងកពណាមួយឡើយ ។ ពាក្យថា **ឥមំ លោកំ** *នេះ ទ្រង់សំដៅយកកាមាវចរលោក ក្នុងសេចក្តីនេះ មានអធិប្បាយ ដូចតទៅនេះថា*

បើព្រះអរិយបុគ្គល ដែលសម្រេចសកទាគាមិផល ក្នុងមនុស្សលោក ហើយកើតឡើងក្នុងទេវលោក រមែងធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រការនេះ ល្អ យ៉ាងនេះ តែកាលអាចត្រឡប់មកកាន់មនុស្សលោកហើយ រមែងធ្វើឲ្យជាក់ ច្បាស់នូវអរហត្ត ចំណែកអរិយបុគ្គលដែលសម្រេចសកទាគាមិផល ក្នុង ទេវលោក បើមកកើតក្នុងមនុស្សលោក រមែងធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន សេចក្តីនេះ ល្អយ៉ាងនេះ តែកាលអាចទៅកាន់ទេវលោក រមែងធ្វើឲ្យជាក់ ច្បាស់នូវអរហត្តដោយពិត ។ ការធ្លាក់ទៅដោយមិនមានសល់ ឈ្មោះថា វិនិបាត ក្នុងបទថា **អវินิបาตธมฺโม** *នេះ អធិប្បាយថា ការធ្លាក់ទៅដោយ មិនមានសល់របស់ព្រះសោតាបន្ននោះ ជាធម៌មិនអាចប្រព្រឹត្តទៅបាន ហេតុ នោះ ព្រះសោតាបន្ននោះ ឈ្មោះថា មានការមិនធ្លាក់ចុះជាធម្មតា គឺមានការ មិនធ្លាក់ទៅ ដោយឥតសេសសល់ ក្នុងអបាយ ๔ ជាសភាវៈ ។ បទថា*

ฉินฺนโต បានដល់ ខៀងដោយធម្មនិយាយ ។ បទថា **สมฺโพธิปรายโน** សេចក្តីថា សម្ពោធិ ពោល គឺមគ្គ ៣ ក្នុងខាងលើ ជាទីទៅ ជាដំណើរ ជាទីពឹងអាស្រ័យរបស់បុគ្គលនោះ គឺដែលបុគ្គលនោះ គប្បីសម្រេចពិតប្រាកដខាងមុខ ហេតុនោះ បុគ្គលនោះ ឈ្មោះថា មានសម្ពោធិជាទីទៅខាងមុខ ។

ដោយបទថា **วิโลสยาเวสา** ទ្រង់សម្តែងថា ម្នាលអានន្ទ នោះជាសេចក្តីលំបាកកាយរបស់តថាគត តថាគតពិចារណាមើលដោយញាណគតិញាណឧប្បត្តិ ញាណអភិសម្បរាយៈរបស់ពួកសត្វនោះៗ ។ តែសេចក្តីលំបាកចិត្ត មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ បទថា **ธมฺมาธาสึ** បានដល់ កញ្ចក់ គឺធម៌ ។ បទថា **เยน** បានដល់ អ្នកប្រកបដោយកញ្ចក់ធម៌ដទៃណា ។ បទថា **อิฬาจายคุคฺคตินิวินิจาเตา** នេះ លោកពោលដោយវេវចនៈរបស់នរកជាដើមប៉ុណ្ណោះ ។ ពិតហើយ នរកជាដើម ឈ្មោះថា អបាយ ព្រោះប្រាសចាកអយៈ គឺសេចក្តីចម្រើន ឈ្មោះថា ទុគ្គតិ ព្រោះជាទីដំណើរទៅ ជាទីពឹងអាស្រ័យនៃទុក្ខ ឈ្មោះថា វិនិបាត ព្រោះជាទីធ្លាក់ទៅដោយមិនមានសល់របស់ពួកជនអ្នកធ្វើអាក្រក់ ។ បទថា **อเวจฺจปฺปสาเทน** បានដល់ ដោយសេចក្តីជ្រះថ្លាដែលមិនញាប់ញ័រ ព្រោះដឹងដល់ព្រះពុទ្ធគុណតាមសេចក្តីពិតនុ៎ះឯង ។ សូម្បីក្នុងពីរបទខាងដើម ក៏នយនេះដូចគ្នា ។ ចំណែកសេចក្តីពិស្តារបស់ពាក្យថា **สตฺถิ เสา ภควา** ជាដើម បានពោលហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **อริยกนฺเตหิ** បានដល់ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ព្រះអរិយៈទាំងឡាយ ។ សីល ៥ ឈ្មោះថា ជាទីប្រាថ្នារបស់ព្រះអរិយៈទាំងឡាយ ព្រោះលោកមិនលះបង់សូម្បីក្នុងភពដទៃ ។ លោក

สំដៅដល់សីល ๕ នោះ ទើបពោលពាក្យនេះ ។ តែក្នុងទីនេះ បានដល់សំវរៈទាំងអស់ ។ ពាក្យថា **សោតាបន្នោហមស្មិ** នេះ ជាមាតិកានៃទេសនាប៉ុណ្ណោះ ។ តែសូម្បីព្រះសកទាគាមីជាដើម រមែងព្យាករ ដោយន័យជាដើមថា **សកទាគាមីហមស្មិ** អញជាសកទាគាមី ដូច្នេះ ។ ការព្យាករណ៍នៃព្រះអរិយសាវកទាំងពួង ក្នុងឋានៈដែលគួរ ដោយមិនខុសសិក្ខាបទ (វិនយ) ដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ។

[๙๐] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **វេសាលិយំ វិហរតិ** នេះ ដូច្នេះ គប្បីជ្រាបសេចក្តីដែលក្រុងវេសាលីជានគរបរិបូណ៌ ។ ដោយន័យដែលបានពោលហើយក្នុងខន្ធកវិនយថា **តេន ខោ បន សមយេន វេសាលី ឥទ្ធាចេវ ហោតិ ផីតា ច** ដូច្នេះ ។ បទថា **អម្ពបាលិវនេ** បានដល់ ក្នុងព្រៃស្វាយដែលជាឧទ្យានរបស់នាងអម្ពបាលីគណិកា ។ បទថា **សតោ ភិក្ខវេ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ផ្តើមសតិប្បដ្ឋានទេសនាក្នុងទីនេះដោយពិសេស ដើម្បីឲ្យសតិប្រាកដក្នុងការទស្សនាអម្ពបាលិវន ។ ក្នុងបទទាំងនោះ ឈ្មោះថា **សតោ** ព្រោះរឭកបាន ឈ្មោះថា **សម្បជានោ** ព្រោះដឹងខ្លួន អធិប្បាយថា គប្បីជាអ្នកប្រកបដោយសតិសម្បជញ្ញៈ ។ ខ្ញុំនឹងពោលពាក្យដែលគួរពោលក្នុងពាក្យជាដើមថា **កាយេ កាយានុបស្សី** ក្នុងមហាសតិប្បដ្ឋានសូត្រ ។

[๙๒] បទថា **ឥលា** ជាដើមនេះ ពោលរួមពណ៌ទាំងអស់ ។ ឯបទថា **ឥលាវណ្ណា** ជាដើម ជាការសម្តែងចែកពណ៌នោះឯង ។ ក្នុងពាក្យនោះ លោកពោលពាក្យនេះទុក ព្រោះពណ៌ទាំងនោះ មិនមែនពណ៌ខៀវជាប្រក្រតី

ព្រោះផ្សំដោយពណ៌ខៀវ ។ បទថា **នីលវត្ថា** *សេចក្តីថា សំពត់ធម្មតា សំពត់សម្បកឈើ និងសំពត់សូត្រជាដើម ។ ឈ្មោះថា ខៀវសម្រាប់សំពត់ទាំងនោះ ។ បទថា* **នីលាលង្ការា** *បានដល់ ប្រដាប់ដោយមណីខៀវ ផ្កាខៀវ ។ សូម្បីវេរបស់ស្តេចលិច្ឆវីទាំងនោះ ក៏រលេចដោយមណីខៀវ ដេរប៉ាក់ដោយសំពត់ខៀវ មានទង់ខៀវ ប្រកបដោយទាហានពាក់ក្រោះខៀវ អាភរណៈខៀវ ទឹមដោយសេះខៀវ សូម្បីជង្ឃខ្សែតីក៏ខៀវដូចគ្នា ។ សេចក្តីគ្រប់បទ គប្បីជ្រាបដោយនយនេះ ។ បទថា* **បដិវេដ្ឋេសិ** *ប្រែថា ប៉ះ ។ បទថា* **ឥ** *ក្នុងពាក្យថា* **កឹ ឥ អម្ពចាលិ** *ជាពាក្យហៅ ។ លោកអធិប្បាយថា មេអម្ពបាលី តើហេតុអ្វី បាឋៈថា* **កិញ្ចិ** *ក៏មាន ។ ក្នុងពាក្យនេះក៏មានសេចក្តីដូចគ្នា ។ បទថា* **សាហារំ** *បានដល់ មួយអន្ទៀដោយជនបទ ។ បទថា* **អង្គុលី ផោដេសុំ** *បានដល់ ផ្ចាត់ម្រាមដៃ ។ បទថា* **អម្ពកាយ** *បានដល់ មាយាស្រី ។ បទថា* **យេសំ** *ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ លោកអធិប្បាយថា ដែលកិកូពួកណាមិនឃើញហើយ ។ បទថា* **ឱលោកេថ** *បានដល់ ចូរមើលចុះ ។ បទថា* **អវលោកេថ** *បានដល់ ចូរមើលរឿយៗ បទថា* **ឧបសំហរថ** *បានដល់ បង្អោនចូលមក ។ អធិប្បាយថា ពួកអ្នកចូរបង្អោននាំមកប្រៀបធៀបជាមួយបរិស័ទរបស់ស្តេចលិច្ឆវីនេះ ដូចជាទេវតាជាន់តាវត្តិង្ស ដោយចិត្តរបស់ពួកអ្នក ចូរមើល ប្រៀបធៀបនឹងពួកទេវតាជាន់តាវត្តិង្សថា ស្តេចលិច្ឆវីទាំងនេះក៏ដូចពួកទេវតាជាន់តាវត្តិង្សដែលល្អស្អាត គួរជ្រះថ្លា មានពណ៌ផ្សេងៗ គ្នា មានពណ៌ខៀវជាដើម ដូច្នោះ ។ សួរថា ហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់*

ហាមអាយតនៈខាងក្នុងមានចក្ខុជាដើម កាន់យកនូវនិមិត្តក្នុងអាយតនៈខាងក្រៅ មានរូបជាដើម ដោយសូត្រច្រើនរយសូត្រ តែក្នុងសូត្រនេះ ទ្រង់ត្រឡប់ប្រកបភិក្ខុទុកក្នុងការកាន់យកនូវនិមិត្តដោយឧស្សាហៈធំ ។ ឆ្លើយថា ព្រោះទ្រង់ប្រាថ្នាប្រយោជន៍ ។

បានឮថា ភិក្ខុពួកខ្លះក្នុងក្រុងវេសាលីនោះ មានសេចក្តីព្យាយាមជួរថយ ។ ព្រះមានព្រះភាគ កាលទ្រង់ប្រើសម្បត្តិរបស់ទេវតាជាន់តាវត្តិង្សលួងលោម ទើបត្រាស់ដើម្បីឲ្យភិក្ខុទាំងនោះកើតឧស្សាហៈក្នុងសមណធម៌ថា កាលភិក្ខុធ្វើសមណធម៌ដោយសេចក្តីមិនប្រមាទ ក៏បានឥស្សរិយសម្បត្តិបែបនេះដោយងាយ ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដើម្បីសេចក្តីជាក់ច្បាស់នៃអនិច្ចលក្ខណៈក៏បាន ។ សេចក្តីពិត មិនយូរប៉ុន្មានឡើយ ស្តេចលិច្ឆវីទាំងអស់នេះ ក៏នឹងជល់នូវសេចក្តីវិនាស ដោយអំណាចរបស់ព្រះបាទអជាតសត្តុ ។ គ្រានោះ ព្រះមានព្រះភាគ ត្រាស់ដើម្បីសេចក្តីជាក់ច្បាស់នៃអនិច្ចលក្ខណៈ ដោយព្រះពុទ្ធបំណងថា ពួកភិក្ខុដែលឈរមើលសិរីរាជសម្បត្តិរបស់ស្តេចលិច្ឆវីទាំងនោះ នឹងបានចម្រើនអនិច្ចលក្ខណៈថា សេចក្តីវិនាសនៃសិរីសម្បត្តិបែបនោះនឹងប្រាកដហើយ ក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។ ក្នុងបទថា **អធិវาเสตุ** សួរថា ហេតុអ្វី ទើបពួកស្តេចលិច្ឆវីទាំងដែលដឹងថា ព្រះមានព្រះភាគទទួលនិមន្តន៍នាងអម្ពបាលីហើយ ទើបនិមន្តទៀត ។ ឆ្លើយថា ព្រោះទ្រង់មិនជឿ និងព្រោះជាធម្មទំនៀម ។ ពួកស្តេចលិច្ឆវីទាំងនោះគិតថា ស្រីអ្នកលេងនោះ មិននិមន្ត និយាយថា និមន្ត ។ ឈ្មោះថា ការទៅនិមន្តក្នុងវេលាទៅស្តាប់ធម៌ ជាទំនៀមរបស់មនុស្សនុ៎ះឯង ។

ព្រះមានព្រះភាគទ្រង់មានអាពាធខ្លាំងក្លា

[៨៣] បទថា **វេឡុវគាមកោ** បានដល់ ស្រុកវេឡុវៈ ជិតក្រុងវេសាលី ។ មិត្ត គឺមិត្ត ក្នុងបទថា **យថាមិត្តំ** ជាដើម ។ បទថា **សន្ទិដ្ឋា** គឺមិត្តដែលត្រឹមតែជួបឃើញគ្នាក្នុងទីនោះៗ ឈ្មោះថា មិត្តដែលធ្លាប់ឃើញគ្នា មិនមែនមិត្តជិតស្និទ្ធ ។ បទថា **សម្ភត្តា** បានដល់ មិត្តដែលសេពគប់គ្នាមកដោយល្អ ជាមិត្តជិតស្និទ្ធ អធិប្បាយថា ចូរពួកអ្នកចូលទៅចាំវស្សាក្នុងទីដែលពួកភិក្ខុបែបនោះមាន ។ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ ព្រោះមានព្រះពុទ្ធបំណងឲ្យភិក្ខុទាំងនោះនៅជាសុខ ។ សេចក្តីពិតសេនាសនៈក្នុងវេឡុវគ្រាម មិនល្មមដល់ភិក្ខុទាំងនោះ ទាំងភិក្ខាមានតិចចំណែកជុំវិញក្រុងវេសាលី សេនាសនៈក៏មានច្រើន ទាំងភិក្ខាក៏រកបានងាយព្រោះដូច្នោះ ទើបព្រះអង្គត្រាស់យ៉ាងនេះ ។ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបមិនត្រាស់ថា ពួកអ្នកគង់នៅជាសប្បាយ ។ ដើម្បីទ្រង់អនុគ្រោះភិក្ខុទាំងនោះ ។ បានឮថា ព្រះអង្គទ្រង់ព្រះតម្រិះថា តថាគតនៅបានត្រឹមតែ ១០ ខែ ក៏នឹងបរិនិព្វាន ។ បើភិក្ខុទាំងនេះនឹងនៅឆ្ងាយ ក៏មិនអាចឃើញតថាគត ក្នុងវេលាបរិនិព្វាន បើដូច្នោះ ភិក្ខុទាំងនោះក៏នឹងកើតសេចក្តីក្តៅក្រហាយថា ព្រះសាស្តាកាលបរិនិព្វាន ក៏មិនប្រទានសូម្បីត្រឹមតែសតិដល់ពួកយើង បើពួកយើងដឹង ក៏មិនគប្បីនៅឆ្ងាយយ៉ាងនេះ មិនត្រាស់ថា ភិក្ខុទាំងឡាយនៅជុំវិញក្រុងវេសាលី ក៏នឹងមកស្តាប់ធម៌បានមួយខែ ៨ ដង នឹងបានទទួលឱវាទរបស់ព្រះមានព្រះភាគ ។

បទថា **ឱរោ** គឺគ្រោតគ្រោត ។ បទថា **អាពាធោ** បានដល់ រោគដែលជាសត្រូវ ។ បទថា **ពាឡ្ហា** ប្រែថា ខ្លាំងក្លា ។ បទថា **មរណន្តិកា** បានដល់

អាចឲ្យដល់ការស្ងាប់ គឺហៀបនឹងបរិនិព្វាន ។ បទថា **สเตา สมฺปชาโน อธิวาเสสิ** *សេចក្តីថា បានដល់តាំងសតិឲ្យមាំ កំណត់ដោយខន្តិញ្ញាណ ។ បទថា* **อวิหญฺญมาโน** *បានដល់ មិនធ្វើអាការរសាប់រសល់ ដោយបណ្តាយតាមវេទនា មិនត្រូវវេទនាបៀតបៀន ទ្រង់មិនមានទុក្ខក្តៅក្រហាយឡើយ អត់ទ្រាំបាន ។ បទថា* **อนามนฺตฺวา** *បានដល់ ទ្រង់មិនឲ្យឧបដ្ឋាកដឹង ។ បទថា* **อนปโลเกตฺวา** *គឺទ្រង់មិនលាកិកុសង្ឃ ។ លោកអធិប្បាយថា មិនប្រទានឱវាទានុសាសនី ។ បទថា* **วิริเยน** *បានដល់ ដោយសេចក្តីព្យាយាមខាងដើម និងដោយសេចក្តីព្យាយាម ដែលសម្បយុត្តដោយផលសមាបត្តិ ។ បទថា* **ปฏิปฺปณาเมตฺวา** *ប្រែថា បណ្តេញ ។ សូម្បីជីវិត ក៏ឈ្មោះថា ជីវិតសង្ខារ ក្នុងបទថា* **ជีวิตสงฺขาเร** *នេះ ។ ជីវិតដែលធម៌ណាតាក់តែងដល់ជាប់ ក៏បន្តតាំងនៅ សូម្បីធម៌ដែលជាផលសមាបត្តិនោះ ក៏ឈ្មោះថា ជីវិតសង្ខារ ។ ធម៌គឺផលសមាបត្តិនោះ លោកបំណងយកក្នុងទីនេះ ។ បទថា* **อธิฏฺฐาย** *បានដល់ អធិដ្ឋានឲ្យប្រព្រឹត្តទៅហើយ ។ សេចក្តីសង្ខេបក្នុងសេចក្តីនេះ មានដូច្នេះថា តថាគតគប្បីចូលផលសមាបត្តិ ដែលអាចឲ្យជីវិតតាំងនៅបាន ។ សួរថា ព្រះមានព្រះភាគ ទ្រង់មិនចូលផលសមាបត្តិ ក្នុងកាលមុនអំពីនេះឬ ឆ្លើយថា ចូល តែផលសមាបត្តិនោះ ជាខណិកសមាបត្តិ ។ ពិតហើយ ខណិកសមាបត្តិ រមែងគ្របសង្កត់វេទនាចំពោះខាងក្នុងសមាបត្តិបាននោះឯង ។ ពេលចេញចាកសមាបត្តិ វេទនារមែងគ្របសង្កត់រាងកាយទៀត ដូចចក់ដែលញែកព្រោះឈើ ឬអំបែងធ្លាក់ចុះទៅ ត្រឡប់គ្របទឹកដូចដើម ។ មួយទៀត សមាបត្តិរបស់អ្នកធ្វើពួក ๗ នៃរូប និងពួក ๗ នៃអរូប ឲ្យអស់ឬសគល់*

ដុះហើយ ចូលដោយអំណាចនៃមហាវិបស្សនា ឈ្មោះថា រមែងគ្របសង្កត់ បានដោយល្អ ។ ប្រៀបដូចចកដែលបុរសចុះទឹកហើយ យកដៃ និងជើងវាច ចេញដោយល្អ ដល់រៀលាយូរ ទើបនឹងគ្របទឹក យ៉ាងណា អ្នកដែលចេញ ចាកផលសមាបត្តិនោះ អស់រៀលាយូរ ទើបវេទនាកើតឡើង ដូច្នោះ ។ ដូច្នោះ ទើបព្រះមានព្រះភាគ ដូចជាទ្រង់តាំងវិបស្សនាថ្មីៗ ក្នុងព្រះមហាពោធិបល្ល័ង្ក ក្នុងថ្ងៃនោះ ទ្រង់ដាក់ចុះដោយអាការ ១៤ ធ្វើពួក ៧ នៃរូប ពួក ៧ នៃអរូប មិនឲ្យមានឬសគល់ ហើយទ្រង់មិនសោយវេទនា ដោយមហាវិបស្សនា ចូលសមាបត្តិដោយទ្រង់ប្រាថ្នាថា សូមវេទនាកុំកើតរហូតដល់អស់ ១០ ខែ ។ វេទនាដែលទ្រង់គ្របសង្កត់ដោយសមាបត្តិ ទើបមិនកើតរហូតដល់អស់រៀលា ១០ ខែ ។ វេទនាដែលទ្រង់គ្របសង្កត់ដោយសមាបត្តិ ទើបមិនកើតសព្វ កាល ។ បទថា **តិលានា វុដ្ឋិតោ** បានដល់ ប្រឈួនហើយជាវិញ ។ បទថា **មធុរកជាតោ វិយ** បានដល់ ដូចបុរសដេកផ្ទារលើលំពែងដែលកើតភាវៈធ្ងន់ និងរឹង ។ បទថា **ន បក្ខាយន្តិ** បានដល់ មិនច្បាស់ គឺមិនប្រាកដដោយវាចា ផ្សេងៗ ។ ដោយបទថា **ធម្មាបិ មំ នប្បដិភន្តិ** លោកសម្តែងថា ធម៌ គឺ សតិប្បដ្ឋាន មិនប្រាកដដល់ខ្ញុំព្រះអង្ត ។ តែធម៌ គឺព្រះបាលី ព្រះថេរៈស្ទាត់ ជំនាញល្អហើយ ។ បទថា **ឧធាហរតិ** បានដល់ មិនប្រទានបច្ចិមឧវាទ ។ ព្រះអានន្ទសំដៅយកបច្ចិមឧវាទនោះ ។ បទថា **អនន្តរំ អាពាហិរំ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា តថាគតមិនធ្វើ ២ យ៉ាង ដោយធម៌ ឬបុគ្គល ហើយនឹងសម្តែងធម៌ប៉ុណ្ណេះ ដល់បុគ្គលដទៃក៏ទេ ឈ្មោះថា ទ្រង់ធ្វើធម៌ឲ្យជា ខាងក្នុង ។ ទ្រង់ត្រិះរិះថា តថាគត នឹងសម្តែងធម៌ប៉ុណ្ណេះដល់បុគ្គលដទៃ ឈ្មោះ

ថា ទ្រង់ធ្វើជមិខាងក្រៅ ។ មួយទៀត ទ្រង់ត្រិះរិះថា តថាគតនឹងសម្តែងដល់បុគ្គលនេះ ឈ្មោះថា ទ្រង់ធ្វើបុគ្គលខាងក្នុង ។ កាលទ្រង់ត្រិះរិះថា តថាគតនឹងមិនសម្តែងដល់បុគ្គលនេះ ឈ្មោះថា ទ្រង់ធ្វើបុគ្គលខាងក្រៅ ។ អធិប្បាយថា ទ្រង់មិនធ្វើយ៉ាងនោះសម្តែង ។ ដោយបទថា **អាចរិយមុដ្ឋិ** ទ្រង់សម្តែងថា ឈ្មោះថា កណ្តាប់ដៃរបស់អាចារ្យ រមែងមានដល់សាស្តាខាងក្រៅព្រះពុទ្ធសាសនា ។ ពួកសាស្តាខាងក្រៅ មិនពោលដល់បុគ្គលណាមួយ ក្នុងវេលាជាកំលោះ ដេកលើគ្រែសម្រាប់ស្លាប់ ក្នុងវេលាបច្ឆិមវ័យ ក៏ពោលដល់អន្តេវាសិក ដែលទីស្រឡាញ់ពេញចិត្ត ដោយវិធីណា កិច្ចណាមួយដែលតថាគតបរិហារ តាំងទុកក្នុងកណ្តាប់ដៃថា តថាគតនឹងពោលពាក្យនេះ ក្នុងវេលាចាស់ជរា ក្នុងវេលាបច្ឆិមវ័យ រមែងមិនមានដល់តថាគតដោយវិធីនោះ ។ បទថា **អហំ ភិក្ខុសង្ឃំ** សេចក្តីថា តថាគតប៉ុណ្ណោះនឹងបរិហារភិក្ខុសង្ឃ ។ បទថា **មមុទ្ទេសិកោ** សេចក្តីថា តថាគតជាទីពឹងនៃភិក្ខុសង្ឃនោះ ព្រោះអត្ថថា ភិក្ខុសង្ឃគប្បីអាងតថាគត ហេតុនោះ ភិក្ខុសង្ឃនោះ ឈ្មោះថា មានតថាគតជាទីពឹង អធិប្បាយថា ភិក្ខុសង្ឃចូរលើកសរសើរតថាគតប៉ុណ្ណោះ ពេញចិត្តចំពោះតថាគត កាលតថាគតបរិនិព្វានទៅ ឬមិនមានពួកភិក្ខុហើយ ឬមានការប្រព្រឹត្តទៅ ឬថា ភិក្ខុសង្ឃណាមួយ នឹងមានសេចក្តីគិតដូចដែលពោលមកនេះ ។ បទថា **ន ឯវំ ហោតិ** សេចក្តីថា សេចក្តីនោះ មិនដូច្នោះ ព្រោះសេចក្តីច្រណែន និងសេចក្តីកំណាញ់ តថាគតកម្ចាត់ចេញហើយក្នុងពោធិបល្ល័ង្កនុ៎ះឯង ។ បទថា **សកី** កាត់ជា **សោ កិ** ។ បទថា **អសីតិកោ** ប្រែថា មានអាយុ ៨០ វស្សា ។ ពាក្យនេះ ត្រាស់កាល

ទ្រង់សម្តែងភាវ: ដែលដល់បច្ចិមវ័យដោយលំដាប់ ។ បទថា **ឥជ្ឈមិស្សកេន** បានដល់ អបដោយឬស្សីសម្រាប់ជួសជុល មានការចងអបកាំកង់ជាដើម ។ បទថា **មញ្ញោ** បានដល់ ញ្ញាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដូចរទេះចាស់ ទៅបានដោយអបឬស្សី ។ លោកសម្តែងថា ព្រះតថាគតសម្រេចឥរិយាបថ ៤ ដោយគ្រឿងចង គឺអរហត្តផល ។ ឥឡូវនេះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ថា **យស្មឹ អានន្ទ សមយេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សព្វនិមិត្តានំ** បានដល់ កលាប: មានរូបនិមិត្តជាដើម ។ បទថា **ឯកច្ចានំ ឥធនានំ** បានដល់ វេទនាដែលជាលោកិយ ។ ដោយបទថា **តស្មាតិហានន្ទ** ទ្រង់សម្តែងថា ព្រោះហេតុដែលសេចក្តីសប្បាយ រមែងមានដោយផល សមាបត្តិវិហារ ដូច្នោះ សូម្បីពួកភិក្ខុក៏ចូរនៅយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ សេចក្តីសុខចុះ ។ បទថា **អត្តធីចា** សេចក្តីថា ពួកអ្នកចូរធ្វើខ្លួនឲ្យជាទីពឹងអាស្រ័យ ដូចកោះកណ្តាលមហាសមុទ្រចុះ ។ បទថា **អត្តសរណា** បានដល់ ចូរជាអ្នកមានខ្លួនជាគតិប៉ុណ្ណោះ កុំមានរបស់ដទៃជាគតិឡើយ ។ សូម្បីក្នុងបទថា **ធម្មធីចា ធម្មសរណា** ក៏មានន័យដូចគ្នា ។ បទថា **តមតគ្តេ** មានធមិនោះជាកំពូល **ត** អក្ខរ:ត្រង់កណ្តាល លោកពោលដោយបទសន្ធិ ។ លោកពោលអធិប្បាយថា ម្នាលអានន្ទ ពួកភិក្ខុរបស់តថាគតនោះ កាត់ការប្រកបដោយសភាពខ្ពស់បំផុតទាំងអស់ យ៉ាងនេះថា ពួកភិក្ខុទាំងនេះក៏ខ្ពង់ខ្ពស់ ទាំងនេះក៏ខ្ពង់ខ្ពស់ ហើយនឹងនៅក្នុងធមិដ៏ប្រសើរយ៉ាងក្រៃលែង គឺក្នុងភាវ: ខ្ពង់ខ្ពស់ បានដល់ នឹងមានធមិដ៏ខត្តមក្រៃលែងសម្រាប់ភិក្ខុទាំងនោះ ភិក្ខុពួកណាមួយ ជាអ្នកប្រាថ្នាការសិក្សា គឺភិក្ខុទាំងអស់នោះ មានសតិប្បដ្ឋាន ៤ ជា

อารมฺมณ์ นีฯมานธมฺมีปฺปเสวีร ฯ ทฺรงฺสวุปเทสนา ฮฺวปฺลฺกำพูล คี ปฺระอรหนฺตโนะฯน ฯ

ทุติยภาณวารกถา จบ

อคฺคสาวกปรินิพฺพานกถา

[๙๔] บทว่า **เวสาลึ ปิณฺฑาย ปาวิสิ** ทฺรงฺจูลกฺรุงฺเวสาลี เดือมฺปีปิณฺฑปาต ฯ สูรฺวา ทฺรงฺจูลเฑาคาลณา ฆฺเลียว่า กฺนุงฺเวลาทฺรงฺ เจญฺจากอุกฺกเวลคามเฑาคานฺกฺรุงฺเวสาลี ฯ ปานฬฺว่า ปฺระมานปฺระคาค ทฺรงฺจำวสฺสาเฮียย เจญฺจากเวฬุวคาม เฮียยทฺรงฺตฺรฬฺปฺลฺบฺตามผฺลูวเดล ยาฯมกเฮียย เดายพุทฺธบำณฯว่า นีฯยาฯเฑาคานฺกฺรุงฺสาวตฺถี ดลฺกฺรุงฺสาวตฺถีเดายลำดับ ทฺรงฺจูลคานฺวตฺตเชตพน ฯ ปฺระธมฺมเสนาบตี ฆฺเลียวตฺต ดลฺปฺระมานปฺระคาคเฮียย จูลคานฺทีสมฺรากพลถฺงู ฯ คาลพวกอเนฺต-วาสิกฆฺเลียวตฺตกฺนุงฺวิหารเชตพนโนะ ตฺรฬฺปฺลฺบฺเฑาเฮียย โลกก็เฉาสสมฺนาตที สมฺรากพลถฺงู กฺราลผฺจำนสฺเสก ลาฯเชีฯ อคฺคุยพตฺกฺเนน จูลผล สมาบตฺติ ฯ คาลโลกเจญฺจากอำพีผลสมาบตฺติโนะตามกำณาตฺเฮียย เกีตบวิเตกฺกย๊าฯนะว่า ปฺระพุทฺธทำฯฒฺยายบรินิพฺพานมุน ปฺหอคฺคสาวกนิพฺพานมุนหฺนฺ ฯ ก็ชีฯว่า อคฺคสาวกบรินิพฺพานมุน ฯ เดือบพินิตฺยเมือลอายุสงฺขารบสฺวอน ก็ชีฯว่า อายุสงฺขารบสฺวอน นีฯปฺรเพฺรตฺเตเฑาบานตฺรือมเตี ๗ ถฺงูปุ๊ณฺณาะ เดือบตฺรัะอิะว่า อาตฺมาอเญนีฯบรินิพฺพานกฺนุงฺทีณาหฺนฺ ฯ ก็คิตเรืยๆ ว่า ปฺระราหุลบรินิพฺพานกฺนุงฺฮานตาวตฺตึสฺ ปฺระอญฺญาโกณฺฑญฺญะ ตฺรงฺสฺระฉนฺทนฺต อาตฺมาอญ

នឹងបរិនិព្វានក្នុងទីណា ។ ក៏កើតសតិប្រារព្ធមាតាឡើងថា មាតារបស់អាត្មាអញ ជាមាតារបស់ព្រះអរហន្ត ៧ អង្គ ក៏មិនជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ មាតានោះ មានឧបនិស្ស័យឬទេហ្ន៎ ក៏រឭកឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គ ពិចារណាថា មាតានឹងសម្រេចដោយទេសនារបស់អ្នកណា ក៏ដឹងថា នឹងសម្រេចដោយទេសនារបស់អាត្មាអញ មិនមែនរបស់អ្នកដទៃឡើយ បើអាត្មាអញគប្បីជាអ្នកខ្វល់ខ្វាយតិចសោត មនុស្សទាំងឡាយ ក៏នឹងពោលទោសអាត្មាអញថា ព្រះសារីបុត្រ ជាទីពឹងបានដល់ជនដទៃៗ ។ ពិតហើយ ក្នុងថ្ងៃទេសនាសមចិត្តសូត្ររបស់លោក ទេវតា ១ សែនកោដិ ក៏សម្រេចអរហត្ត ទេវតាដែលសម្រេចមគ្គ ៣ រាប់មិនបាន និងក្នុងទីដទៃប្រាកដថា មានការសម្រេចច្រើនណាស់ ម្ល៉ាងទៀត ព្រោះធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះថេរៈ ត្រកូលដល់ ៨០០០០ កើតក្នុងឋានសួគ៌ ឥឡូវនេះ ព្រះថេរៈមិនអាចកម្ចាត់សូម្បីត្រឹមតែមិច្ឆាទិដ្ឋិរបស់មាតាបាន ព្រោះដូច្នោះ ទើបដាក់ចិត្តថា អាត្មាអញនឹងដោះមាតាចេញអំពីមិច្ឆាទិដ្ឋិ ហើយនឹងបរិនិព្វានក្នុងបន្ទប់តូចដែលអាត្មាអញកើត ត្រិះរិះតទៅទៀតថា អាត្មាអញនឹងលាព្រះមានព្រះភាគទៅក្នុងថ្ងៃនេះឯង ទើបហៅព្រះចុន្ទត្ថេរមកថា ចុន្ទ មកយើងនឹងទៅ អ្នកចូរប្រាប់ភិក្ខុបរិស័ទ ៥០០ អង្គ របស់ខ្ញុំថា អាវុសោ សូមលោកកាន់បាត្រ និងចីវរ ព្រះធម្មសេនាបតី បំណងនឹងទៅនាលកគ្រាម ។ ព្រះថេរៈបានធ្វើយ៉ាងនោះ ។ ភិក្ខុទុកជាក់សេនាសនៈ កាន់បាត្រ ចីវរ មកកាន់សម្នាក់ព្រះថេរៈ ។ ព្រះថេរៈក៏ទុកជាក់សេនាសនៈ ចោសសម្អាតទីសម្រាកពេលថ្ងៃ ឈរត្រង់ទ្វារ សម្លឹងមើលទីសម្រាកពេលថ្ងៃ ត្រិះរិះថា ឥឡូវនេះ ជាការឃើញគ្រាចុង

ក្រោយ មិនមានការត្រឡប់មក ។ ព្រះថេរៈដែលភិក្ខុ ៥០០ អង្គ ចោមរោម ហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ពោលពាក្យជាគាថា ចំពោះព្រះមានព្រះភាគថា

ធិន្នោធានិ ភវិស្សាមិ លោកនាថ មហាមុនិ
គមនាគមនំ នត្ថិ បច្ចិមា វន្ទនា អយំ។
ជីវិតំ អប្បកំ មយ្ហំ ឥតោ សត្តាហមច្ចយេ
និក្ខិបេយ្យាមហំ ទេហំ ការវោរោបនំ យថា។
អនុជានាតុ មេ ភន្តេ (ភគវា) អនុជានាតុ សុគតោ
បរិនិព្វានកាលោ មេ ឱស្សដ្ឋោ អាយុសង្ខរោ ។

បពិត្រព្រះមហាមុនីលោកនាថ ឥឡូវនេះ ខ្ញុំព្រះអង្គកាត់អស់ហើយ មិនមានការទៅការមក នេះជាការថ្វាយបង្គំលាលើកចុងក្រោយ ជីវិតរបស់ខ្ញុំ ព្រះអង្គតិច តទៅនេះ កន្លងទៅ ៧ ថ្ងៃ ខ្ញុំព្រះអង្គនឹងដាក់ចុះនូវសរីរៈ ដូចដាក់ ភារៈចុះ សូមព្រះមានព្រះភាគ មេត្តាអនុញ្ញាត សូមព្រះសុគតមេត្តាអនុញ្ញាត ដល់ខ្ញុំព្រះអង្គផងចុះ នេះជាវេលាបរិនិព្វាន ខ្ញុំព្រះអង្គដាក់អាយុសង្ខារហើយ។

ព្រោះហេតុដែលពួកមិច្ឆាទិដ្ឋិ ពេញចិត្តលើកទោសថា កាលព្រះសាស្តា ត្រាស់ថា ចូរបរិនិព្វានចុះ ក៏ហាក់ដូចជាពណ៌នាគុណនៃសេចក្តីស្លាប់ កាល ត្រាស់ថា កុំបរិនិព្វានឡើយ ក៏ហាក់ដូចជាពោលគុណរបស់វដ្តសង្សារ ព្រោះ ដូច្នោះ ទើបព្រះពុទ្ធទាំងឡាយ មិនត្រាស់ពាក្យទាំងពីរ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់នឹងព្រះថេរៈថា ម្នាលសារីបុត្រ អ្នកនឹងបរិនិព្វាន ទីណា ។ កាលព្រះថេរៈក្រាបទូលថា ក្នុងបន្ទប់តូច ឯនាលកគ្រាម ដែនមគធៈ

ខ្ញុំព្រះអង្គនឹងបរិនិព្វាន ក្នុងបន្ទប់នោះ ។ ទើបព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្រ ឥឡូវនេះ អ្នកសម្គាល់កាលដ៏សមគួរចុះ វេលានេះ ការឃើញកិក្ខុដែលមានសភាពដូច្នេះ សម្រាប់បងប្អូនរបស់អ្នកនឹងរកបានដោយក្រ ព្រោះដូច្នោះ អ្នកចូរសម្តែងធម៌ដល់បងប្អូនទាំងនោះចុះ ។

ព្រះថេរៈជឹងថា ព្រះសាស្តាទ្រង់មានព្រះបំណងនឹងឲ្យអញសម្តែងឫទ្ធិផ្សេងៗ មុននឹងសម្តែងធម៌ ទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយហោះកម្ពស់ ๗ ដើមតោត ត្រឡប់ចុះមកថ្វាយបង្គំ ហើយឈរកណ្តាលអាកាសកម្ពស់ ๗ ដើមតោត សម្តែងឫទ្ធិផ្សេងៗ ច្រើនយ៉ាង ហើយសម្តែងធម៌ ។ អ្នកនគរទាំងអស់ប្រជុំគ្នា ។ ព្រះថេរៈចុះមក ហើយថ្វាយបង្គំព្រះមានព្រះភាគ ក្រាបទូលថា ជល់វេលាទៅរបស់ខ្ញុំព្រះអង្គហើយ ។ ព្រះមានព្រះភាគប្រថាប់លើធម្មាសនៈ ទ្រង់ព្រះត្រិះរិះថា នឹងឲ្យសារីបុត្រសម្តែងឫទ្ធិ ហើយទើបក្រោកអំពីធម្មាសនៈ ស្តេចបែរព្រះភក្ត្រទៅកាន់ព្រះគន្ធកុដិ ហើយប្រថាប់ឈរលើបល្ល័ង្កកែវមណី ។ ព្រះថេរៈធ្វើប្រទក្សិណ ๓ ជុំ ហើយថ្វាយបង្គំក្នុងទិសទាំង ๔ ក្រាបទូលថា រាប់ថយអំពីកប្បនេះទៅ បាន ๑ អសង្ខ្យៃយ្យ ๑ សែនកប្ប ខ្ញុំព្រះអង្គ ក្រាបទៀបបាទមូលរបស់ព្រះអនោមទស្សីសម្មាសម្ពុទ្ធ ប្រាថ្នានឹងជួបព្រះអង្គ សេចក្តីប្រាថ្នានោះរបស់ខ្ញុំព្រះអង្គសម្រេចហើយ ខ្ញុំព្រះអង្គឃើញទ្រង់ហើយ នុ៎ះជាការឃើញគ្រាដំបូង នេះជាការឃើញគ្រាចុងក្រោយ នឹងមិនមានការឃើញព្រះអង្គទៀតឡើយ ហើយផ្គងអញ្ជលីដ៏រុងរឿងដោយទសនខសមោធាន ហើយត្រឡប់ថយក្រោយទៅដរាបផុតទស្សនវិស័យ តាំងពីឥឡូវនេះទៅ ដែលឈ្មោះថា ការទៅការមកក្នុងឋានៈណាមួយៗ ដោយអំណាចចុតិបដិសន្ធិមិន

មាន ដូច្នេះហើយ ទើបថ្វាយបង្គំលាទៅ ។ ផែនមហាប្រឹថពី ក៏ញ័រដរាបដល់ទឹកទ្រផែនដី ។ ព្រះមានព្រះភាគក៏ត្រាស់ចំពោះពួកភិក្ខុដែលឈរជុំវិញថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរទៅតាមបងប្រុសរបស់ពួកអ្នកចុះ ។ ភិក្ខុទាំងឡាយនាំគ្នាទៅដរាបដល់ខ្លោងទ្វារ ។ ព្រះថេរៈពោលថា អាវុសោឈប់ចុះ ពួកអ្នកចូរជាអ្នកមិនប្រមាទចុះ ហើយឲ្យភិក្ខុទាំងនោះត្រឡប់វិញ ចំណែកខ្លួនលោកក៏ទៅព្រមនឹងបរិស័ទ ។ ពួកមនុស្សក៏នាំគ្នាដើរតាមយំរៀបរាប់ថា ពីមុនលោកម្ចាស់ចារិកទៅ ក៏ត្រឡប់មក តែលើកនេះទៅបាត់ មិនត្រឡប់មក ។ ព្រះថេរៈពោលថា អាវុសោ ពួកអ្នកកុំប្រមាទ សង្ខារទាំងឡាយយ៉ាងនេះឯង ហើយឲ្យមនុស្សទាំងនោះត្រឡប់ ។ គ្រានោះ ព្រះសារីបុត្រ អនុគ្រោះមនុស្សរហូតដល់អស់ ៧ ថ្ងៃ ក្នុងចន្លោះផ្លូវ ដល់នាលកគ្រាម ក្នុងវេលាល្ងាច ហើយឈប់សម្រាកត្រង់ដើមជ្រៃ ជិតទ្វារស្រុក ។ គ្រានោះ ក្មួយប្រុសរបស់ព្រះថេរៈ ឈ្មោះថា ឧបរេវតៈទៅក្រៅស្រុក ជួបព្រះថេរៈចូលទៅរកហើយឈរសំពះ ។ ព្រះថេរៈនិយាយជាមួយក្មួយប្រុសថា យាយរបស់ឯងនៅក្នុងផ្ទះឬ ។ ក្មួយប្រុសក៏ឆ្លើយថា ព្រះករុណា ។ ព្រះថេរៈប្រាប់ថា ឯងចូរទៅប្រាប់ថាអាត្មាមកទីនេះហើយ កាលបើយាយសួរថា ព្រោះហេតុអ្វី ចូរប្រាប់ថា បានឮថា លោកនឹងសម្រាកក្នុងស្រុកនេះមួយថ្ងៃ ចូររៀបចំបន្ទប់តូចដែលអាត្មាកើត និងចាត់ចែងទីនៅសម្រាប់ភិក្ខុ ៥០០ អង្គ ។ ក្មួយទៅប្រាប់ថា បពិត្រលោកយាយ លោកអ៊ំនិមន្តមក ។ យាយសួរថា ឥឡូវនេះនៅឯណា ។ ចៅឆ្លើយថា នៅជិតទ្វារស្រុក យាយក៏សួរថា មកតែមួយអង្គ ឬមានភិក្ខុដទៃមកផង ។ ចៅក៏ឆ្លើយថា មានភិក្ខុ ៥០០ អង្គមកផង ។ កាលជីដូនសួរថា មក

ធ្វើអ្វី ។ ចៅក៏ប្រាប់រឿងនោះ ។ ព្រាហ្មណ៍គិតថា ហេតុដូចម្តេចហ្ន៎ ទើបត្រូវបង្គាប់ឲ្យចាត់ស្ថានទីនៅសម្រាប់ភិក្ខុយ៉ាងច្រើនដល់ម្ល៉េះ កូនអញបួសតាំងពីកំលោះ ចង់មកជាគ្រហស្ថកាលចាស់ ទើបរៀបចំបន្ទប់ដែលលោកបានកើតឲ្យធ្វើទីនៅសម្រាប់ភិក្ខុ ៥០០ អង្គ អុជប្រទីបទុកទទួលព្រះថេរៈ ។ ព្រះថេរៈនឹងភិក្ខុទាំងឡាយ ឡើងទៅកាន់ប្រាសាទ ចូលទៅកាន់បន្ទប់ដែលកើតហើយអង្គុយ និងបញ្ជូនភិក្ខុទាំងឡាយទៅដោយពោលថា ចូរនាំគ្នាទៅកាន់ទីនៅរបស់ពួកលោកចុះ ។ ពេលភិក្ខុទាំងឡាយទៅហើយ អាពាធខ្លាំងក្លាក៏កើតឡើងដល់ព្រះថេរៈ ។ រោគចុះឈាមកើត វេទនាហៀបនឹងស្លាប់ ។ កាជនៈមួយត្រង កាជនៈមួយនាំចេញ ។ ព្រាហ្មណ៍គិតថា ការប្រព្រឹត្តទៅនៃបុត្ររបស់អញ មិនជាទីពេញចិត្ត ក៏ឈរផ្អែកទ្វារបន្ទប់របស់ខ្លួន ។ ស្តេចមហារាជទាំង ៤ ពិចារណាថា ព្រះធម្មសេនាបតីនៅទីណា ក៏ដឹងថា ដេកលើគ្រែដែលបរិនិព្វាន ក្នុងបន្ទប់តូចកាលដែលលោកកើតក្នុងនាលកគ្រាម អញនឹងទៅមើលជាបច្ឆិមទស្សនៈ ហើយនាំគ្នាមកឈរសំពះ ។ ព្រះថេរៈសួរថា លោកជាអ្នកណា ទេវតាឆ្លើយថា បពិត្រលោកម្ចាស់ ពួកខ្ញុំជាមហារាជ ។ ព្រះថេរៈ សួរថា មកធ្វើអ្វី ។ ឆ្លើយថា មកជាគិលានុបដ្ឋាក ។ ព្រះថេរៈបញ្ជូនទៅដោយពាក្យថា ណ្ហើយចុះ គិលានុបដ្ឋាកមានហើយ សូមលោកទៅចុះ ។ កាលស្តេចមហារាជទៅហើយ សក្កទេវរាជជាស្តេចទេវតា ក៏មកដោយន័យនោះដូចគ្នា ។ កាលសក្កទេវរាជយាងទៅហើយ ស្តេចសុយាមៈជាដើម និងមហាព្រហ្មក៏នាំគ្នាមក ។ ព្រះថេរៈក៏ពោលនឹងទេវតា និងព្រហ្មទាំងនោះឲ្យទៅវិញយ៉ាងនោះដូចគ្នា ។

ព្រាហ្មណ៍ឃើញពួកទេវតាមក និងទៅ គិតថា ជនទាំងនោះ ជាអ្នកណាហ្ន៎ ទើបមកថ្វាយបង្គំហើយថ្វាយបង្គំទៀតនូវកូនរបស់អញ ហើយក៏ទៅទើបទៅកាន់ទ្វារបន្ទប់របស់ព្រះថេរៈ ព្រះសារីបុត្រសួរថា អ្នកណាមក ព្រះចុន្ទត្តេរច្រាប់រឿងនោះ ហើយពោលថា មហាឧបាសិកាមក ។ ព្រះថេរៈសួរថា ហេតុដូចម្តេចទើបមកខុសកាល ។ ព្រាហ្មណ៍ឆ្លើយថា មកសួរសុខទុក្ខកូនឯង ហើយសួរថា លោកកូន តើអ្នកណាមកពីដំបូង ។ ព្រះថេរៈឆ្លើយថា ឧបាសិកា ស្តេចមហារាជទាំង ៤ មកពីដំបូង ។ ព្រាហ្មណ៍សួរថា លោកកូនកូនឯងជាធំជាងមហារាជទាំង ៤ ឬ ព្រះថេរៈឆ្លើយថា ឧបាសិកា មហារាជទាំងនោះក៏ដូចក្មេងវត្ត ទ្រង់កាន់ព្រះខ័នរក្សា តាំងពីព្រះសាស្តារបស់អាត្មាទ្រង់ចុះចាប់បដិសន្ធិ ។ ព្រាហ្មណ៍សួរថា កាលមហារាជទាំងនោះ ត្រឡប់ទៅហើយ អ្នកណាមកទៀត ។ ព្រះថេរៈឆ្លើយថា សក្កទេវរាជ ព្រាហ្មណ៍សួរថា កូនឯងជាធំជាងសក្កទេវរាជទៀតឬ ។ ព្រះថេរៈឆ្លើយថា ឧបាសិកា សក្កទេវរាជនោះក៏ដូចសាមណេរកាន់វត្ត កាលព្រះសាស្តារបស់អាត្មាចុះមកអំពីតាវត្តិង្ស ក៏ទ្រង់កាន់បាត្រ និងចីវរចុះមក ។ ព្រាហ្មណ៍សួរថា កាលសក្កទេវរាជនោះត្រឡប់ហើយ អ្នកណាមានពន្លឺអស្ចារ្យមក ។ ព្រះថេរៈឆ្លើយថា ឧបាសិកា អ្នកនោះ ឈ្មោះថា មហាព្រហ្មជាន់សុទ្ធាវាស ទាំងជាអ្នកមានបុញ្ញគុណ ទាំងជាគ្រូរបស់ព្រោមផងដែរ ។ ព្រាហ្មណ៍សួរថា កូនឯងក៏នៅតែជាធំជាងមហាព្រហ្មនោះទៀតឬ ។ ព្រះថេរៈឆ្លើយថា ពិតហើយឧបាសិកា បានឮថា ក្នុងថ្ងៃដែលព្រះសាស្តារបស់អាត្មាប្រសូត មហាព្រហ្មទាំង ៤ នេះ យកបាតាញ្ជមាសមកទទួលព្រះមហាបុរស កាលនោះ ព្រាហ្មណ៍គិតថា កូនរបស់

អញ្ញមានអានុភាពដល់ម្ល៉េះ ព្រះមានព្រះភាគសាស្តារបស់កូន និងមានអានុ-ភាពច្រើនប៉ុនណាហ្ន៎ ។ បីតិ ៥ យ៉ាង កើតឡើងផ្សាយពេញសរីរៈយ៉ាង ធាប់រហ័ស ។ ព្រះថេរៈគិតថា មាតារបស់អញកើតបីតិសោមនស្ស ឥឡូវនេះ ជាកាលសមគួរដែលនឹងសម្តែងធម៌ ទើបពោលថា មហាឧបាសិកាគិតអ្វី ។ ព្រាហ្មណីពោលថា កូនរបស់ខ្ញុំមានគុណដល់ម្ល៉េះ ព្រះសាស្តានៃកូនខ្ញុំនឹងមាន គុណច្រើនប៉ុនណាហ្ន៎ ដូច្នោះ ទើបម៉ែគិតយ៉ាងនេះ ។ ព្រះថេរៈពោលថា មហាឧបាសិកា សម័យព្រះសាស្តានៃយើងប្រសូតក្តី ចេញមហាភិនេស្ក្រមណ៍ក្តី ត្រាស់ដឹងក្តី ប្រកាសព្រះធម្មចក្កក្តី លោកធាតុ ๑ ម៉ឺនក៏ញាប់ញ័រ ដែលឈ្មោះថា អ្នកស្មើដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈមិនមាន ហើយពោលព្រះធម៌ទេសនាដែលប្រកបដោយពុទ្ធគុណយ៉ាងពិស្តារ ថា **ឥតិបិ សោ ភគវា ...** *ជាដើម ។ កាលចប់ព្រះធម៌ទេសនារបស់បុត្រជាទីស្រឡាញ់ ព្រាហ្មណីក៏តាំងនៅក្នុងសោតាបត្តិផល ហើយពោលនឹងបុត្រថា បាឧបតិស្ស: ហេតុអ្វី ទើបកូនឯងធ្វើយ៉ាងនេះ កូនឯងមិនឲ្យអមតធម៌នេះ ដល់ម៉ែអស់កាលមានប្រមាណប៉ុណ្ណេះ ។ ព្រះថេរៈគិតថា ឥឡូវនេះ តម្លៃទឹកដោះ និងថាយច្រចាប់ ដែលសារីព្រាហ្មណីមាតារបស់អញបានឲ្យ ក៏បានតបស្នងសងដោយហេតុមានប្រមាណប៉ុណ្ណេះ ទើបបញ្ជូនព្រាហ្មណីទៅ ដោយពោលថា ទៅចុះមហាឧបាសិកា ហើយសួរព្រះពុទ្ធថា ជិតភ្លឺហើយឬនៅ ។ ព្រះពុទ្ធឆ្លើយថា ជិតភ្លឺហើយលោកម្ចាស់ ។ ព្រះថេរៈប្រាប់ថា បើយ៉ាងនោះ ចូរប្រជុំភិក្ខុសង្ឃចុះ ។ ព្រះពុទ្ធឆ្លើយថា សង្ឃប្រជុំគ្នាហើយ ។ ព្រះថេរៈពោលថា ចូរលើកខ្ញុំឡើងឲ្យអង្គុយ ។ ព្រះពុទ្ធក៏គ្រាហ៍ឡើងឲ្យអង្គុយ ។ ព្រះ*

ថេរៈហៅភិក្ខុទាំងឡាយថា អាវុសោ លោកទាំងឡាយ នៅជាមួយខ្ញុំមកអស់ ៤៤ ឆ្នាំ មិនពេញចិត្តក្នុងកាយកម្ម ឬវចីកម្មបស់ខ្ញុំ យ៉ាងណា សូមអាវុសោ អត់នូវទោសនោះផងចុះ ។ ភិក្ខុទាំងឡាយពោលថា លោកម្ចាស់ ពួកខ្ញុំគ្រាច់ទៅ មិនលះបង់លោកម្ចាស់ ដូចស្រមោលអស់កាលមានប្រមាណប៉ុណ្ណោះឈ្មោះថា កម្មដែលមិនពេញចិត្ត មិនមានដល់ពួកខ្ញុំ តែសូមលោកម្ចាស់ អត់នូវទោសដល់ពួកខ្ញុំផងចុះ ។ កាលពន្លឺអរុណក្រោកដ ព្រះថេរៈញុំាងមហា-ប្រឹថពីឲ្យញាប់ញ័រ ហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ទេវតា និងមនុស្សជាច្រើន នាំគ្នាធ្វើសក្ការៈក្នុងស្ថានទីបរិនិព្វាន ។

ព្រះបុនូកាន់បាត្រចីវរ និងសំពត់ខ្ចប់ព្រះធាតុទៅកាន់វត្តជេតពន នាំព្រះអានន្ទត្ថេរចូលគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់កាន់សំពត់តម្រងទឹកដែលជាក់ព្រះធាតុ ពោលគុណរបស់ព្រះថេរៈ ដោយគាថា ៥០០ ទ្រង់បង្គាប់ឲ្យសាងព្រះធាតុចេតិយ បានប្រទានសញ្ញាដល់ព្រះអានន្ទត្ថេរដើម្បីយាងទៅកាន់ក្រុងរាជគ្រឹះ ។ ព្រះថេរៈក៏ប្រាប់ភិក្ខុទាំងឡាយ ។ ចំណែកព្រះមានព្រះភាគ មានភិក្ខុសង្ឃជាបរិវារ យាងទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងវេលាយាងទៅកាន់ក្រុងរាជគ្រឹះនោះ ។ ព្រះមហាមោគ្គល្លានត្ថេរ ក៏បរិនិព្វាន ។ ព្រះមានព្រះភាគទ្រង់កាន់យកព្រះធាតុ របស់ព្រះមហាមោគ្គល្លាននោះ បង្គាប់ឲ្យសាងចេតិយហើយ ចេញចាកក្រុងរាជគ្រឹះ បែរព្រះភក្ត្រទៅកាន់ស្ទឹងគង្គា យាងដល់ស្រុកឧក្កវេលគ្រាម ដោយលំដាប់ ។ ត្រង់មាត់ច្រាំងស្ទឹងគង្គា ក្នុងឧក្កវេលគ្រាមនោះ ទ្រង់មានភិក្ខុសង្ឃជាបរិវារគង់ក្នុងទីនោះ ទ្រង់សម្តែងព្រះសូត្រដែលជាប់ដោយការបរិនិព្វានរបស់ព្រះសារីបុត្រ និងព្រះមោគ្គល្លាន

ចេញចាកឧក្កវេលគ្រាម យាងដល់ក្រុងវេសាលី ។ កាលយាងចូលទៅយ៉ាងនោះ គ្រានោះ ព្រះមានព្រះភាគ ក្នុងវេលាព្រឹក ទ្រង់ស្បៀកស្បង់ កាន់បាត្រនិងចីវរ យាងចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី ។ កថាសម្តែងតាមលំដាប់ក្នុងរឿងនេះ មានដូចពោលមកដូច្នេះ ។

ក្នុងបទថា **ឯសីឧំ** *នេះ លោកបំណងយកផ្ទាំងស្បែក ។ បទថា* **ឧទេនចេតិយំ** *លោកពោលដល់វត្ត ដែលសាងត្រង់ទីចេតិយរបស់ឧទេនយក្ខ ។ ក្នុងគោតមកចេតិយជាដើមក៏នយនេះដូចគ្នា ។ បទថា* **ភាវិតា** *ប្រែថា ចម្រើនហើយ ។ បទថា* **ពហុលីកតា** *ប្រែថា ធ្វើរឿយៗ ។ បទថា* **យានីកតា** *ប្រែថា ធ្វើដូចយានដែលទឹមហើយ ។ បទថា* **វត្ថុកតា** *ប្រែថា ធ្វើដូចផែនដី ព្រោះអត្ថថា ជាទីតាំង ។ បទថា* **អនុដ្ឋិតា** *ប្រែថា តម្កល់ទុកហើយ ។ បទថា* **បរិចិតា** *ប្រែថា សាងទុកដោយជុំវិញ គឺធ្វើឲ្យចម្រើនដោយល្អ ។ បទថា* **សុសមារទ្ធា** *ប្រែថា ចាប់ផ្តើមដោយល្អ ។ ព្រះមានព្រះភាគ កាលត្រាស់ដោយមិនកំណត់ ដូចពោលមកដូច្នេះហើយ កាលទ្រង់សម្តែងមិនកំណត់ទៀត ទើបត្រាស់ថា* **តថាគតស្សាបិ** *ជាដើម ។*

គប្បីជ្រាបវិនិច្ឆ័យរឿងនេះដូច្នេះ បទថា **កប្បំ** *បានដល់ អាយុកប្ប ។ ព្រះតថាគត កាលធ្វើអាយុប្រមាណរបស់ពួកមនុស្ស ក្នុងកាលនោះៗ ឲ្យបរិបូណ៌ គប្បីតាំងនៅ ។ បទថា* **កប្បាវសេសំ វា** *បានដល់ ច្រើនជាងមួយរយឆ្នាំ ដែលត្រាស់ថា* **អប្បំ វា ភិយ្យោ** *តិចជាង ១០០ ឆ្នាំ ឬច្រើនជាងនោះ ។ ចំណែកព្រះមហាសិវត្ថេរពោលថា ឈ្មោះថា ការបន្ទឺក្នុងហាន:ដែលមិន*

សមគួរនៃព្រះពុទ្ធទាំងឡាយ មិនមាន ។ ពិតហើយ ព្រះអង្គទ្រង់គ្របសង្កត់ វេទនាស្ទើរតែស្ងាប់ ដែលកើតឡើងក្នុងវេឡុវគ្រាម សូម្បី ១០ ខែ បានយ៉ាងណា ទ្រង់ចូលសមាបត្តិនោះរឿយៗ ទ្រង់គ្របសង្កត់វេទនា បានដល់ ១០ ខែ ក៏គប្បីទ្រង់តាំងនៅបាន រហូតដល់អស់ភទ្ទកប្បនេះបាន ដូច្នោះ ។ សួរថា ព្រោះហេតុអ្វី ទើបទ្រង់មិនតាំងនៅ ឆ្លើយថា ព្រោះដែលឈ្មោះថា សរីរៈ ដែលមានចិត្តគ្រប់គ្រង ត្រូវវិរោធិប្បច្ចយ មានធ្មេញបាក់ជាដើម គ្របសង្កត់សេចក្តីពិត ព្រះពុទ្ធទាំងឡាយ មិនទាន់ដល់ភាវៈនៃវិរោធិប្បច្ចយ មានធ្មេញបាក់ជាដើម រមែងបរិនិព្វានក្នុងវេលាដែលទ្រង់ជាទីស្រឡាញ់ ជាទីពេញចិត្ត របស់មហាជននោះឯង ។ មួយទៀត កាលព្រះមហាសាវកដែលត្រាស់ដឹងតាមព្រះពុទ្ធ បរិនិព្វានហើយ ក៏គប្បីតាំងនៅដូចជង្គត់ឈើមួយដើម ស្តេចយាងទៅជាមួយភិក្ខុកំលោះ និងសាមណេរជាបរិវារ ក៏ត្រូវគេមើលងាយថា ៤ បរិស័ទទាំងឡាយរបស់ព្រះពុទ្ធ ព្រោះដូច្នោះ ទើបទ្រង់មិនតាំងនៅ ។ កាលត្រូវពោលយ៉ាងនេះ ព្រះអង្គក៏ទ្រង់ពេញព្រះទ័យ ។ បទថា **អាយុកប្បា** នេះ លោកកំណត់ទុកក្នុងអដ្ឋកថាហើយ ។

ក្នុងបទថា **យថា តំ មារេន បរិយុដ្ឋិតចិត្តោ** នេះ បទថា **តំ** ត្រឹមតែជានិបាត អធិប្បាយថា បុថុជ្ជនដទៃណា ត្រូវមារបណ្តាលចិត្ត គ្របសង្កត់ចិត្ត មិនអាចដឹងច្បាស់បាន យ៉ាងណា ព្រះអានន្ទក៏មិនអាចដឹងច្បាស់ដូច្នោះដែរ ។ សេចក្តីពិត មាររមែងបណ្តាលចិត្តរបស់បុគ្គលដែលលះវិបល្ងាស ៤ មិនទាន់បាន គ្រប់ៗ ប្រការ ។ ព្រះថេរៈក៏លះវិបល្ងាស ៤ មិនទាន់បាន ដោយហេតុនោះ ទើបមារគ្របសង្កត់ចិត្តលោក ។ សួរថា មារនោះ កាលបណ្តាល

จิตฺต ធ្វើយ៉ាងណា ឆ្លើយថា មារសម្តែងអារម្មណ៍ គឺរូប ឬឲ្យបានឮអារម្មណ៍ គឺសំឡេងដែលគួរខ្ជាប បន្ទាប់ពីនោះ ពួកសត្វឃើញរូប ឬបានឮសំឡេងនោះ ហើយ ក៏ជាត់សតិ ហើយហាមាត់ ។ មារក៏លូកដៃចូលក្នុងមាត់របស់សត្វទាំងនោះ ហើយច្រជាច់បេះដូង ។ បន្ទាប់ពីនោះ ពួកសត្វក៏សន្លប់ ។ តែសម្រាប់ព្រះថេរៈ ដូចម្តេចមារអាចស៊កដៃចូលក្នុងមាត់ព្រះថេរៈបាន បានតែសម្តែងអារម្មណ៍ដែលគួរខ្ជាប ។ ព្រះថេរៈឃើញមារនោះ ក៏មិនដឹងច្បាស់នូវឱកាស គឺនិមិត្ត ។ សួរថា ព្រះមានព្រះភាគកាលទ្រង់ជ្រាប ត្រាស់ហៅជល់ ៣ ដង ដើម្បីប្រយោជន៍អ្វី ។ ឆ្លើយថា ដើម្បីទ្រង់បន្ទោបង់សេចក្តីសោក ដោយការលើកទោសទុកខាងមុខថា កាលតថាគត ត្រូវអ្នកអាវជនាថា ព្រះមានព្រះភាគមេត្តាតាំងនៅចុះ ។ អ្នកធ្វើមិនល្អយ៉ាងនោះ អ្នកធ្វើខុសយ៉ាង នេះ ។

មារាយาចนกถา

[๙๕] *ឈ្មោះថា មារក្នុងបទថា* **มาโร ปาปิมา** *នេះ ឈ្មោះថា មារព្រោះប្រកបសត្វទុកក្នុងសេចក្តីវិនាស ធ្វើឲ្យស្លាប់ ។ បទថា* **ปาปิมา** *ជាវេវចនៈ របស់ពាក្យថា មារនុ៎ះឯង ។ ពិតហើយ មារនោះ លោកហៅថា មារព្រោះប្រកបដោយបាបធម៌ ។ សូម្បីបទថា* **กณฺโห อนฺตก ยมุจิ បមตฺตពนฺธุ** *ក៏ជាឈ្មោះរបស់មារនោះដូចគ្នា ។ បទថា* **ภาสิตา เม ปเทสา** *សេចក្តីថា មារនេះ ជាប់តាមមកតាំងពីពោធិមណ្ឌលដ្ឋានក្នុងសប្តាហ៍ទី ๘ តាំងអំពីព្រះមានព្រះភាគ ទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណ ពោលថា ព្រះមានព្រះភាគទ្រង់សម្រេចប្រយោជន៍របស់ព្រះអង្គ ដែលព្រះអង្គទ្រង់បំពេញព្រះបារមីមកដោយលំដាប់ហើយ ទ្រង់បានសម្រេចព្រះសម្មាសម្ពោធិញ្ញាណហើយ ព្រះអង្គនឹង*

ប្រមើលមើលលោកធ្វើអ្វី ទើបអារាធនាថា ឥទ្ឋវនេះ សូមព្រះមានព្រះភាគទ្រង់បរិនិព្វានទៅក្នុងថ្ងៃនេះចុះ ព្រះអង្គ តែព្រះមានព្រះភាគត្រាស់បដិសេធដល់មារនោះថា តថាគតនឹងមិនបរិនិព្វាន ដូច្នេះជាដើម ។ មារសំដៅយកសេចក្តីនោះ ទើបពោលថា **ភាសិតា ខោ បនេសា ភន្តេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **វិយត្តា** បានដល់ ឈ្លាសដោយមគ្គ ។ ភិក្ខុទាំងឡាយត្រូវណែនាំយ៉ាងនោះដូចគ្នា ក្បៀវក្បាក៏យ៉ាងនោះ ។ បទថា **ពហុស្សុតា** ឈ្មោះថា ពហូសូត ព្រោះមានសុតៈច្រើនដោយព្រះត្រៃបិដក ។ ឈ្មោះថា **ធម្មធរ** ព្រោះទ្រទ្រង់ធម៌ទុំៈឯង ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនេះ យ៉ាងនេះថា ជាពហូសូតដោយបរិយត្តិ ១ ជាពហូសូតដោយបដិវេធ ១ ឈ្មោះថា **ធម្មធរ** ព្រោះទ្រទ្រង់ធម៌ គឺបរិយត្តិ និងបដិវេធទុំៈឯង ។ បទថា **ធម្មានុធម្មប្បដិបន្នា** បានដល់ បដិបត្តិវិបស្សនាធម៌ ដែលសមគួរដល់អរិយធម៌ ។ បទថា **សាមីចិប្បដិបន្នា** បានដល់ បដិបត្តិបដិបទាដែលសមគួរ ។ បទថា **អនុធម្ម-ចារិនោ** ប្រែថា មានប្រក្រតីប្រព្រឹត្តធម៌ដ៏សមគួរ ។ បទថា **សកំ អាចរិយកំ** បានដល់ វាទៈអាចារ្យរបស់ខ្លួន ។ បទទាំងអស់មានបទថា **អាចិក្ខិស្សន្តិ** ជាដើម ជាវេវចនៈនៃគ្នានឹងគ្នា ។ បទថា **សហេតុនេ** បានដល់ ពាក្យដែលមានហេតុមានការណ៍ ។ បទថា **សប្បាដិហារិយំ** សេចក្តីថា នឹងសម្តែងធម៌ដរាបដល់ធម៌ដែលនាំសត្វចេញចាកទុក្ខ ។ បទថា **ព្រហ្មចរិយំ** បានដល់ សាសនព្រហ្មចរិយៈទាំងអស់ ដែលសង្គ្រោះដោយសិក្ខា ៣ ។ បទថា **ឥទ្ធុំ** បានដល់ សម្រេចដោយអំណាចឈានជាដើម ។ បទថា **ផីតំ** បានដល់ ដល់

នូវសេចក្តីចម្រើនដែលដល់ព្រមដោយអភិញ្ញា ដូចផ្កាដែលរីកពេញបរិបូណ៌ ហើយជាដើម ។ បទថា **វិត្ថារិកំ** សេចក្តីថា បានដល់ ផ្សាយទៅដោយប្រតិស្ថាន នៅក្នុងចំណែកនៃទិសនោះៗ ។ បទថា **ពាហុជញ្ញំ** បានដល់ ជនជាច្រើនដ៏ងប្បាស់ ចាក់ធ្លុះការត្រាស់ដឹងរបស់មហាជន ។ បទថា **បុថុភូតំ** បានដល់ ដល់សេចក្តីក្រាស់ដោយអាការទាំងពួង ។ សួរថា ក្រាស់ដូចម្តេច ឆ្លើយថា ក្រាស់ជាងទេវតា និងមនុស្ស ប្រកាសដោយល្អហើយ អធិប្បាយថា ទេវតា និងមនុស្សដែលជាវិញ្ញូជន មានប្រមាណត្រឹមណា ទេវតា និងមនុស្សទាំងអស់នោះ ប្រកាសល្អហើយ ។ បទថា **អប្បោស្សុក្កោ** បានដល់ ប្រាសចាកសេចក្តីអាល័យ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមារមានចិត្តបាប តាំងពីសប្តាហ៍ទី ៨ អ្នកគ្រាច់ទៅមក អារាធនាថា សូមព្រះមានព្រះភាគ សូមព្រះសុគត បរិនិព្វានឥឡូវនេះចុះ ។ ឥឡូវនេះ តាំងពីថ្ងៃនេះទៅ អ្នកចូរលើកឧស្សាហៈ កុំព្យាយាម ឲ្យតថាគតបរិនិព្វានឡើយ ។

បទថា **សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ធ្វើសតិតាំងមាំដោយល្អ កំណត់ដោយព្រះញាណ ដាក់អាយុសង្ខារ ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់មិនបានដាក់អាយុសង្ខារ ដូចយកដៃចោលដុំដី ។ ទ្រង់ព្រះចិន្តាថា ទ្រង់នឹងចូលសមាបត្តិ មិនដាច់រយៈត្រឹមតែ ៣ ខែប៉ុណ្ណោះ តអំពីនោះ នឹងមិនចូល ។ លោកសំដៅយកសេចក្តីនោះ ទើបពោលថា **ឱស្សជ្ជិ** បាឋៈថា **ឧស្សជ្ជិ** ដូច្នេះក៏មាន ។ បទថា **មហាភូមិចាលោ** បានដល់មហាប្រឹថពីញាប់ញ័រ ។ បានឮថា គ្រានោះ លោកធាតុ ១ ម៉ឺនក៏ញាប់ញ័រ ។ បទថា **ភីសនកោ** បានដល់ កើតសេចក្តីគួរខ្លាច ។ បទថា

ឧេវឧុន្ទភិយោវ ជលឺសុ បានដល់ ពួកស្ពរទិព្វក៏បន្ទឺសំឡេង ផ្ពរក៏គ្រហឹមទាំងក្នុងរដូវប្រាំង ផ្ទេកបន្ទោរពុំជួកាលក៏ដាលច្រវាត់ ។ លោកអធិប្បាយថា ភ្ជៀងធ្លាក់មួយស្របក់ ។ ក្នុងបទថា **ឧធានំ ឧធានេសិ** សួរថា ទ្រង់ឧទានព្រោះហេតុអ្វី ឆ្ទើយថា ព្រោះបានព្ថថា ឈ្មោះថា បុគ្គលណាម្នាក់ នឹងគប្បីនិយាយថា ព្រះមានព្រះភាគ ត្រូវមារជាប់តាមទៅខាងក្រោយៗ រុកកួនថា សូមបរិ-និព្វានចុះៗ ទ្រង់ដាក់អាយុសង្ខារមិនមែនព្រោះខ្លាច ទើបទ្រង់បន្ទឺព្រះឧទានដែលបន្ទឺដោយកម្លាំងបីតិ ដើម្បីសម្ពែងសេចក្តីនេះថា ឈ្មោះថា ពាក្យឧទានរមែងមិនមានដល់អ្នកខ្លាចថា សូមមារកុំមានឱកាសឡើយ ។

[៩៦] ក្នុងឧទាននោះ ឈ្មោះថា **តុល** ព្រោះថ្ងឹងកំណត់ដោយភាវ: ដែលប្រចក្សរបស់សត្ធ មានឆ្កែស្រុក ចចកជាដើមទាំងអស់ ។ កម្មដែលថ្ងឹងបាននោះដូចម្តេច ។ បានដល់ កម្មផ្នែកកាមាវចរ ។ ឈ្មោះថា **អតុល** ព្រោះថ្ងឹងមិនបាន ។ ឬលោកិយកម្មយ៉ាងដទៃ ដែលប្រៀបដូចនឹងកាមាវចកម្មនោះមិនមាន ។ កម្មដែលថ្ងឹងមិនបាននោះដូចម្តេច បានដល់ កម្មផ្នែកមហគ្គត: ។ ម្យ៉ាងទៀត កាមាវចរកម្ម រូបាវចរកម្ម ចាត់ជាតុល អរូបាវចរកម្ម ចាត់ជាអតុល ។ ម្យ៉ាងទៀត កម្មដែលមានវិបាកតិច ឈ្មោះថា **តុល** ដែលមានវិបាកច្រើន ឈ្មោះថា **អតុល** ។ បទថា **សម្ភវំ** បានដល់ កម្មដែលធ្វើជាជុំ អធិប្បាយថា ធ្វើជាគំនរដែលជាហេតុកើត ។ បទថា **ភវសង្ខារំ** បានដល់ កម្មដែលតាក់តែងភពថ្មី ។ បទថា **អវស្សជ្ជិ** បានដល់ ធ្លាក់ចុះ ។ បទថា **មុនិ** បានដល់ អ្នកប្រាជ្ញ គឺព្រះពុទ្ធ ។ បទថា **អជ្ឈត្តរតោ** គឺត្រេកអរខាង

ក្នុងពិតប្រាកដ ។ បទថា **សមាហិតោ** គឺតាំងមាំហើយ ដោយឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា **អភិញ្ញេ កាវចមិវ** បានដល់ ទម្លាយកិលេសដូចកោះ ។ បទថា **អត្តសម្ភវំ** បានដល់ កិលេសដែលកើតហើយក្នុងខ្លួន ។ លោកអធិប្បាយថា ព្រះមុនីទ្រង់រួចផុតពីលោកិយកម្ម ពោល គឺតុលកម្ម និងអតុលកម្ម ដែលបានឈ្មោះថា សម្ភវៈ ព្រោះអត្តថា មានវិបាក ថាកវសង្ខារ ព្រោះអត្តថា តាក់តែងកព និងទ្រង់ត្រេកអរខាងក្នុងតាំងមាំហើយ ទម្លាយកិលេសដែលកើតក្នុងខ្លួន ដូចអ្នកចម្បាំងជំក្នុងសមរភូមិទម្លាយក្រោះ ដូច្នោះ ។ នយម្យ៉ាងទៀត បទថា **តុលំ** បានដល់ ប្លឹង គឺពិចារណា ។ បទថា **អតុលញ្ច សម្ភវំ** បានដល់ ព្រះនិព្វាន និងកព ។ បទថា **ភវសង្ខារំ** បានដល់ កម្មដែលទៅកាន់កព ។ បទថា **អវសុរ្ជ្ជិ មុនិ** សេចក្តីថា ព្រះមុនី គឺព្រះពុទ្ធ ទ្រង់ពិចារណាដោយនយជាដើមថា បញ្ចក្ខន្ធមិនទៀង ការរលត់បញ្ចក្ខន្ធ គឺនិព្វានជារបស់ទៀង ទ្រង់ឃើញទោសក្នុងកព និងអានិសង្សក្នុងនិព្វានហើយ ទ្រង់បន្សាត់ដោយអរិយមគ្គ ដែលធ្វើអោយអស់កម្ម ដែលលោកពោលយ៉ាងនេះថា កម្មគ្រឿងតាក់តែងកព ដែលជាមូលនៃខន្ធទាំងឡាយនោះ ប្រព្រឹត្តទៅដើម្បីការអស់កម្ម ដូច្នេះ ។ ព្រះអង្គទ្រង់ត្រេកអរខាងក្នុងតាំងមាំហើយ ទ្រង់ទម្លាយកិលេសដែលកើតក្នុងខ្លួន ដូចជាក្រោះបានយ៉ាងណា ។ សេចក្តីពិតព្រះមុនីនោះ ទ្រង់ត្រេកអរខាងក្នុង ដោយអំណាចវិបស្សនា ទ្រង់តាំងមាំដោយអំណាចសមថៈ រួមសេចក្តីថា ព្រះអង្គទ្រង់ទម្លាយសំណាញ់ គឺកិលេសទាំងអស់ ដែលជាគ្រឿងរួបរឹតអត្តភាពដូចក្រោះ ដែលបានឈ្មោះថា អត្តសម្ភវៈ ព្រោះកើតក្នុងខ្លួន ដោយកម្លាំងសមថៈ និងវិបស្សនា តាំងអំពីខាងដើម និង

លះកម្ម ដោយការលះកិលេសយ៉ាងនេះថា កម្មដែលធ្វើដោយមិនមានកិលេស ឈ្មោះថា នៅសល់ ព្រោះមិនមានបដិសន្ធិ ។ គប្បីជ្រាបថា ឈ្មោះថា ការខ្ចាចរបស់បុគ្គលដែលលះកិលេសបានហើយមិនមាន ព្រោះដូច្នោះ ព្រះមុនីទ្រង់មិនខ្ចាច ហើយទើបទ្រង់ដាក់អាយុសង្ខារ ព្រោះហេតុនោះ ទើបទ្រង់បន្ទឹ ឧទានដើម្បីឲ្យដឹងថា ទ្រង់មិនខ្ចាច ។

[๙๘] *បទថា* **យំ មហាវាតោ** *សេចក្តីថា ដោយសម័យណា ឬក្នុងសម័យណាខ្យល់ធំរមែងបក់ ។ បទថា* **មហាវាតោ វายន្តោ** *បានដល់ ធម្មតាថា ខ្យល់ឧក្ខេបក កាលកើតឡើង ក៏បក់កាត់ទឹកកម្រាស់ ๙๖๐๐๐๐ យោជន៍ បន្ទាប់ពីនោះ ក៏ធ្លាក់ចុះក្នុងអាកាស កាលទឹកធ្លាក់ចុះ ផែនដីក៏ធ្លាក់ចុះ ។ ខ្យល់ក៏ទ្រទឹកទុកទៀតដោយកម្លាំងរបស់ខ្លួន ដូចទឹកខាងក្នុងធម្មក្រក ។ តែទឹកនោះក៏បាញ់ឡើង ។ កាលទឹកខ្ពុរឡើង ផែនដីក៏ហើបឡើង ទឹកញ័រហើយ ក៏ធ្វើឲ្យផែនដីញ័រយ៉ាងនេះ ។ ការញ័ររបស់ទឹក និងផែនដី រមែងមានមកដរាបដល់សព្វថ្ងៃនេះ ដោយប្រការដូច្នេះ ។ តែការស្រុតចុះ និងហើបឡើង រមែងមិនប្រាកដព្រោះជារបស់ក្រាស់ ។*

បទថា **มหิทฺธิกา มหานุภาวา** *សេចក្តីថា សមណៈ ឬព្រាហ្មណ៍ ឈ្មោះថា អ្នកមានឫទ្ធិច្រើន ព្រោះមានសេចក្តីសម្រេចច្រើន ឈ្មោះថា អ្នកមានអានុភាពច្រើន ព្រោះវត្ថុដែលនឹងបានទទួលច្រើន ។ បទថា* **ปริตฺตา** *គឺ មានកម្លាំងតិច ។ បទថា* **อปฺปมาณา** *បានដល់ អ្នកមានកម្លាំង ។ បទថា* **សោ ឥមំ បឋវឹ កម្បេតិ** *សេចក្តីថា លោកធ្វើឫទ្ធិឲ្យកើតហើយ កើតសេចក្តីសង្វេគ ដូចព្រះមហាមោគ្គល្លាន ឬកាលទ្រង់សាកល្បង រមែងធ្វើឲ្យផែនដី*

ញ៉ែរ ដូចសង្ឃរក្ខិតសាមណេរក្មួយព្រះមហានាគត្ថេរ ។

បានឮថា សាមណេរនោះ ខណៈកោរសក់ប៉ុណ្ណោះ ក៏សម្រេចអរហត្ត គិតថា មានកិច្ចណាមួយទេហ្ន៎ ដែលធ្លាប់សម្រេចអរហត្ត ក្នុងថ្ងៃដែលបួសនុ៎ះឯង ហើយធ្វើវេជយ័ន្តប្រាសាទឲ្យញ៉ែរ ។ បន្ទាប់ពីនោះ ក៏ដឹងថា មិនមានទេបគិតថា អញនឹងធ្វើឲ្យញ៉ែរ រួចឈរលើកំពូលវេជយ័ន្តប្រាសាទ ហើយប្រើជើងតន្ត្រុំ ក៏មិនអាចធ្វើឲ្យញ៉ែរដោយកម្លាំងនៃអភិញ្ញា ។ គ្រានោះ ពួកទេពកញ្ញារបស់សក្កៈ ក៏ពោលនឹងសាមណេរនោះថា កូនសង្ឃរក្ខិត កូនប្រាថ្នានឹងធ្វើវេជយ័ន្តប្រាសាទឲ្យញ៉ែរ ដោយសីសៈដែលមានក្លិនស្អុយប៉ុណ្ណោះបាអើយ ប្រាសាទមានឱកាសតាំងនៅល្អហើយ កូនអាចធ្វើឲ្យញ៉ែរដូចម្តេចបាន ។ សាមណេរគិតថា ទេវតាទាំងនេះ ចំអកឡកឲ្យអញ តែអញមិនទាន់បានអាចារ្យ ព្រះមហានាគត្ថេរអ្នកនៅប្រចាំសមុទ្រ អាចារ្យរបស់អញ នៅទីណាហ្ន៎ ដឹងថា អាចារ្យសាងទីពួនសម្ងំក្នុងក្នុងមហាសមុទ្រ អង្គុយសម្រាកពេលថ្ងៃ ទើបទៅកាន់ទីនោះថ្វាយបង្គំព្រះថេរៈហើយឈរ ។ បន្ទាប់អំពីនោះ ព្រះថេរៈនិយាយនឹងសាមណេរនោះថា បាសង្ឃរក្ខិត អ្នកឯងមិនទាន់បានសិក្សា នឹងចូលទៅប្រយុទ្ធឬ ហើយសួរថា បាឯងមិនអាចធ្វើឲ្យវេជយ័ន្តប្រាសាទញាប់ញ៉ែរឬ ។ ឆ្លើយថា ខ្ញុំព្រះករុណាមិនទាន់បានអាចារ្យ ។ លំដាប់នោះ ទើបព្រះថេរៈពោលនឹងសាមណេរនោះថា នែបា កាលបុគ្គលដូចអ្នក ឲ្យញ៉ែរមិនបាន អ្នកជនៃណាហ្ន៎ នឹងឲ្យញ៉ែរបាន បាធ្លាប់ឃើញជុំអាចម៍គោអណ្តែតនៅលើផ្ទៃទឹកទេ ហើយពោលតទៅថា នែបា មនុស្សទាំងឡាយគេធ្វើនំអំបែងគេមិនកាត់ត្រង់ចុងទេ ចូរបាដឹងដោយឧបមានេះ ។ សាមណេរពោលថា

ប្រាសាទនោះនឹងវិល ដោយអាការត្រឹមតែប៉ុណ្ណោះ ហើយអធិដ្ឋានថា ទឹកចូរមានរហូតដល់ឱកាស ដែលប្រាសាទតាំងនៅ បែរមុខទៅកាន់វេជយ័ន្តប្រាសាទ ។ ពួកទេពធីតាឃើញសាមណេរហើយ និយាយគ្នាថា សាមណេរអៀនខ្មាសម្តងហើយ នៅតែមកទៀត ។ សក្កទេវរាជត្រាស់ថា ពួកនាងកុំនិយាយនឹងបុត្ររបស់យើងឡើយ ឥឡូវនេះ លោកបានអាចារ្យហើយ មួយរំពេចសោះ លោកនឹងធ្វើប្រាសាទឲ្យញ៉ូវបាន ។ សាមណេរប្រើម្រាមជើងជាន់កំពូលប្រាសាទ ។ ប្រាសាទក៏ឃ្លេងឃ្លោងទៅទាំង ៤ ទិស ។ ពួកទេវតាស្រែកឡើងថា នែកូន សូមឲ្យប្រាសាទតាំងនៅចុះ ។ សាមណេរដាក់ប្រាសាទទុកក្នុងទីដើម ហើយឈរលើកំពូលប្រាសាទ បន្ទឺឧទានថា

ខ្ញុំបួសថ្ងៃនេះ ក៏សម្រេចអាសវក្ខយៈថ្ងៃនេះ ខ្ញុំធ្វើប្រាសាទឲ្យញ៉ូវថ្ងៃនេះ ឱ ព្រះពុទ្ធ ទ្រង់មានព្រះគុណមហោឡារ ។ ខ្ញុំបួសថ្ងៃនេះ ក៏សម្រេចអាសវក្ខយៈថ្ងៃនេះ ខ្ញុំធ្វើប្រាសាទឲ្យញ៉ូវថ្ងៃនេះ ឱ ព្រះធម៌ មានព្រះគុណមហោឡារ ។ ខ្ញុំបួសថ្ងៃនេះ ក៏សម្រេចអាសវក្ខយៈថ្ងៃនេះ ខ្ញុំធ្វើប្រាសាទឲ្យញ៉ូវថ្ងៃនេះ ឱ ព្រះសង្ឃ មានព្រះគុណមហោឡារ ។

ពាក្យដែលគប្បីពោល ក្នុងរឿងផែនដីកម្រើក ៦ ប្រការ ក្រៅអំពីនេះ លោកបានពោលហើយ ក្នុងមហាបទានសូត្រ ។

ក្នុងហេតុផែនដីញ័រ ៨ ប្រការនេះ ដូចពោលមកនេះ ទី ១ ញ័រ ដោយធាតុកម្រើក ទី ២ ញ័រដោយអានុភាពរបស់អ្នកមានឫទ្ធិ ទី ៣ និងទី ៤ ញ័រដោយតេជៈនៃបុណ្យ ទី ៥ ញ័រដោយអំណាចនៃញាណ ទី ៦ ញ័រដោយ

អំណាចសាធុការ ទី ៧ ញ័រដោយអំណាចភាពជាអ្នកមានករុណា ទី ៨ ញ័រ ដោយការស្រែកយំ ។ កាលព្រះមហាសត្វចុះកាន់ព្រះគភ៌ព្រះមាតា និងប្រសូត នោះ ផែនដីញ័រដោយអំណាចនៃបុណ្យរបស់ព្រះអង្គ ។ កាលត្រាស់ដឹងអភិ-សម្ពោធិញ្ញាណ ផែនដីញ័រដោយអំណាចព្រះញាណ ។ កាលប្រកាសព្រះ ធម្មចក្រ ។ ផែនដីក៏ញ័រដោយសាធុការ ។ កាលដាក់អាយុសង្ខារ ផែនដីញ័រ ដោយសេចក្តីករុណា ទ្រាំការកម្រើកញ័រនៃចិត្តមិនបាន ក៏ញាប់ញ័រ ។ កាល បរិនិព្វាន ផែនដីក៏ត្រូវបន្ថែមដោយកម្លាំងការស្រែកយំ ក៏ញ័រ ។ សេចក្តីនេះ គប្បី ជ្រាបដោយអំណាចទេវតាប្រចាំផែនដី ។ តែប្រការនេះ មិនមានដល់បឋវី-ធាតុ ដែលជាមហាភូតរូប ព្រោះមិនមានចេតនានោះឯង ។

បទថា **ឥមេ** ក្នុងបទថា **ឥមេ ខោ អានន្ទ អដ្ឋ ហេតូ** នេះ ជាការ បង្ហាញសេចក្តីដែលទ្រង់សម្តែងមកហើយ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ព្រះ អានន្ទកំណត់ថា ព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារក្នុងថ្ងៃនេះពិត ។

[៩៩] ចំណែកព្រះមានព្រះភាគ ទោះទ្រង់ជ្រាបថា ព្រះអានន្ទកំណត់ បាន ក៏មិនប្រទានឱកាស ទ្រង់ប្រមូលហេតុទាំង ៨ ដទៃទៀតចូលផង ទើប ត្រាស់ថា **អដ្ឋ ខោ ឥមា** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **អនេកសតំ ខត្តិយបរិសំ** បានដល់ បរិស័ទ ដូចសមាគមព្រះបាទពិម្ពិសារ សមាគមព្រះញាតិ និងសមាគមស្តេចលិច្ឆវីជាដើម ។ ពាក្យនេះ ប្រើបាន សូម្បីក្នុងចក្រវាលដទៃៗ ។ បទថា **សល្ជបិតបុព្វំ** បានដល់ ធ្លាប់ធ្វើការ សន្ទនាប្រាស្រ័យ ។ បទថា **សាកច្ឆា** បានដល់ ធ្លាប់ចូលរួមសូម្បីតែការ សន្ទនាធម៌ ។ បទថា **យាធិសកោ តេសំ វណ្ណោ** សេចក្តីថា សមណ-

ព្រាហ្មណ៍ទាំងនោះ សម្បុរសខ្លះ សម្បុរខ្មៅខ្លះ សម្បុរពីរពណ៌ខ្លះ ព្រះសាស្តា មានព្រះឆវីលឿងដូចមាស ។ ពាក្យនេះ លោកពោលអាស្រ័យទ្រង់ទ្រាយ ។ ទ្រង់ទ្រាយរបស់សមណព្រាហ្មណ៍ទាំងនោះ ប្រាកដត្រឹមតែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកព្រះមានព្រះភាគ មិនមែនដូចជនជាតិមិលក្ខៈ ទាំងទ្រង់មិនពាក់មណីកុណ្ឌល គង់ដោយភេទរបស់ព្រះពុទ្ធប៉ុណ្ណោះ ។ សមណព្រាហ្មណ៍ទាំងនោះ រមែងឃើញថា ព្រះពុទ្ធអង្គមានទ្រង់ទ្រាយស្មើនឹងខ្លួន ។ បទថា **យាទិសកោ តេសំ សរោ** *សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ មានសំឡេងជាច់ខ្លះ មានសំឡេងដូចឈើអន្ទងខ្លះ មានសំឡេងដូចក្អែកខ្លះ ព្រះសាស្តាមានព្រះសូរសៀងដូចព្រហ្មប៉ុណ្ណោះ ។ តែពាក្យនេះ លោកពោលសំដៅដល់កាសាជទៃ ។ សេចក្តីពិត បើក្នុងបរិស័ទនោះ ព្រះសាស្តាគង់លើរាជាសនៈ មានព្រះបន្ទូល សមណព្រាហ្មណ៍ទាំងនោះ ក៏យល់ថា ថ្ងៃនេះ ព្រះរាជាត្រាស់ដោយព្រះសូរសៀងដ៏ពីរោះ ។ តែកាលព្រះមានព្រះភាគត្រាស់ហើយ ស្តេចចៀសទៅ សមណព្រាហ្មណ៍ទាំងនោះ ឃើញព្រះរាជាស្តេចត្រឡប់មកទៀត ក៏កើតការពិចារណាត្រឡប់ថា បុគ្គលនេះជាអ្នកណាហ្ន៎ ។ បណ្តាបទទាំងនោះ បទថា* **កោ ឆុ ោ អយំ** *សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ សូម្បីពិចារណាត្រឡប់យ៉ាងនេះ ក៏មិនដឹងថា បុគ្គលនេះជាអ្នកណា ត្រាស់ដោយភាសាមគធៈ ភាសាសីហឬៈ ដោយអាការល្អត់ល្ងង់ ក្នុងទីនេះ ឥឡូវនេះ ក៏បាត់ទៅមួយរំពេច ជាទេវតា ឬមនុស្ស ។ សួរថា ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ពួកជនអ្នកមិនដឹងយ៉ាងនេះ ដើម្បីប្រយោជន៍អ្វី ។ ឆ្លើយថា ដើម្បីអប់រំពិតហើយ កាលបើដូច្នេះ ធម៌ដែលជនទាំងនោះស្តាប់ហើយ ក៏នឹងជាបច្ច័យ*

ក្នុងអនាគនោះឯង ព្រោះហេតុនោះ ទ្រង់ប្រាថ្នាដល់អនាគត ទើបទ្រង់សម្តែង ។ គប្បីជ្រាបហេតុកើតនៃបរិស័ទទាំងឡាយ មានព្រាហ្មណបរិស័ទច្រើនរយជាដើម ដោយអំណាចសោណទណ្ឌសមាគម និងកូដទន្តសមាគមជាដើម និងដោយអំណាចចក្រវាលដទៃ ។

ព្រះមានព្រះភាគទ្រង់នាំបរិស័ទ ៨ នេះ មកដើម្បីអ្វី ដើម្បីសម្តែងភាពជាអ្នកមិនខ្វាច ។ បានញ្ចថា ព្រះអង្គនាំបរិស័ទទាំងនេះមក ត្រាស់យ៉ាងនេះថា អានន្ទ សេចក្តីខ្វាចក្តី សេចក្តីក្រៀវក្វាក្តី មិនមានដល់តថាគត[1] ដែលចូលទៅរកបរិស័ទទាំង ៨ នេះ ហើយសម្តែងធម៌ តែអ្នកណាហ្នឹ គួរនឹងឲ្យកើតសេចក្តីយល់យ៉ាងនេះថា តថាគតឃើញមារតែម្នាក់ហើយ គប្បីខ្វាច អានន្ទ តថាគតមិនខ្វាច មិនកត់ស្ទុត មានសតិសម្បជញ្ញៈ ជាក់អាយុសង្ខារ ដូច្នេះ ។

[១០០-១០១] បទថា **អភិភាយតនានិ** បានដល់ ហេតុគ្របសង្កត់ ។ គ្របសង្កត់អ្វី គ្របសង្កត់ធម៌ដែលជាសត្រូវខ្លះ អារម្មណ៍ខ្លះ ។ ការពិត ហេតុទាំងនោះ រមែងគ្របសង្កត់ធម៌ដែលជាសត្រូវ ព្រោះភាវៈដែលជាបដិបក្ខគ្រប់គ្រងអារម្មណ៍ ព្រោះជាបុគ្គលដ៏ក្រៃលែងដោយញាណ ។ ក្នុងបទថា **អជ្ឈត្តំរូបសញ្ញី** ដូច្នេះជាដើម បុគ្គលឈ្មោះថា មានសញ្ញាក្នុងរូបខាងក្នុងដោយអំណាចបរិកម្មក្នុងរូបខាងក្នុង ។ ពិតហើយ បុគ្គល កាលធ្វើបរិកម្មនីលកសិណក្នុងរូបខាងក្នុង រមែងធ្វើត្រង់សក់ ឬត្រង់ប្រមាត់ ឬត្រង់កែវភ្នែក កាលធ្វើបរិកម្មក្នុងបីតកសិណ រមែងធ្វើត្រង់ខ្វាញ់ខាប់ ត្រង់សម្បុរស្បែក ត្រង់ខ្នងដៃ ត្រង់ជើង ឬត្រង់ស្ថានពណ៌លឿងរបស់កែវភ្នែក ។

---

[1] - បាលីក្នុងអដ្ឋកថាថា កយំ វា សារជ្ជំ វា នត្ថិ ។

កាលធ្វើបរិកម្មក្នុងលោហិតកសិណ ធ្វើត្រង់សាច់ ឈាម អណ្តាត ឬត្រង់ស្ថានដែលមានពណ៌ក្រហមរបស់កែវភ្នែក ។ កាលធ្វើបរិកម្មក្នុងឧទាត-កសិណ រមែងធ្វើត្រង់ធ្មឹង ធ្មញ ក្រចក ឬត្រង់ស្ថានដែលមានពណ៌សរបស់កែវភ្នែក តែបរិកម្មនោះ ដែលមានពណ៌ខៀវល្អ លឿងល្អ ក្រហមល្អ សល្អក៏ទេ រមែងមិនបរិសុទ្ធនោះឯង ។ បទថា **ឯកោ ពហិទ្ធា រូចានិ បស្សតិ** សេចក្តីថា បរិកម្មនោះរបស់បុគ្គលណា កើតឡើងខាងក្នុង តែនិមិត្តកើតខាងក្រៅ ។ បុគ្គលនោះ មានសេចក្តីសម្គាល់ថា រូបខាងក្នុងដោយអំណាចបរិកម្មខាងក្នុង និងអប្បនាខាងក្រៅយ៉ាងនេះ ហៅថា **ឯកោ ពហិទ្ធា រូចានិ បស្សតិ** ។ បទថា **បរិត្តានិ** បានដល់ មិនច្រើន ។ បទថា **សុវណ្ណទុព្វណ្ណានិ** ប្រែថា មានពណ៌ល្អ ឬពណ៌អាក្រក់ ។ អភិភាយតនៈនេះ គប្បីជ្រាបថា លោកពោលដោយអំណាចបរិត្តារម្មណ៍ ។ បទថា **តានិ អភិភុយ្យ** សេចក្តីថា បុគ្គលមានក្រពះល្អ បានបាយត្រឹមតែមួយវែក ទើបគិតថា ល្មមបរិភោគ ឬធ្វើជា ១ ពំនូត យ៉ាងណា បុគ្គលដែលក្រៃលែងដោយញាណ មានញាណចាស់ក្លា គិតថា គប្បីចូលសមាបត្តិក្នុងអារម្មណ៍បន្តិចបន្តួចប៉ុណ្ណេះ នឹងល្មមឬ ។ នេះមិនធ្ងន់សម្រាប់អញ ហើយគ្របសង្កត់រូបទាំងនោះ ចូលសមាបត្តិ អធិប្បាយថា រមែងឲ្យដល់អប្បនាក្នុងអភិភាយតនៈនោះ ព្រមនឹងធ្វើនិមិត្តឲ្យកើតឡើងនោះឯង ។ ដោយបទថា **ជានាមិ បស្សាមិ** នេះ លោកពោលដល់ការជញ្ជឹងគិតនៃបុគ្គលនោះ ។ កាលចេញចាកសមាបត្តិ ការជញ្ជឹងគិតនោះ ក៏មិនមានខាងក្នុងសមាបត្តិ ។ បទថា **ឯវំសញ្ញី ហោតិ** សេចក្តីថា មានសញ្ញាយ៉ាងនេះ ដោយសញ្ញាក្នុងការពូកខ្ជះ ដោយសញ្ញាក្នុងឈានខ្ជះ ។ ពិតហើយ សញ្ញា

ជាគ្រឿងគ្របសង្កត់ រមែងមានដល់បុគ្គលនោះ សូម្បីខាងក្នុងសមាបត្តិ ។ ឯ សញ្ញាក្នុងការជញ្ជឹងគិត រមែងមាន កាលចេញចាកសមាបត្តិប៉ុណ្ណោះ ។ បទ ថា **អប្បមាណានិ** សេចក្តីថា មានប្រមាណដែលចម្រើនហើយ គឺធំ ។ ចំណែកក្នុងបទថា **អភិភុយ្យ** នេះ ប្រៀបដូចបុរសអ្នកបរិភោគច្រើន បាន បាយកំពុងចាន ក៏នៅតែគិតថា របស់ដទៃចូរលើកទុក បាយនេះនឹងល្មមដល់ អញឬហ្ន៎ មិនឃើញបាយនោះថា ច្រើន យ៉ាងណា បុគ្គលដែលក្រៃលែង ដោយញាណ មានញាណចាស់ក្លាក៏ដូច្នោះដែរ គិតថា នឹងចូលឈានក្នុង អារម្មណ៍នេះបានឬ អារម្មណ៍នេះមិនមានប្រមាណក៏ទេ ទើបគ្របសង្កត់អា- រម្មណ៍ទាំងនោះ ចូលឈានដោយគិតថា ក្នុងការធ្វើឯកគ្គតាចិត្ត មិនលំបាក ដល់អញទ្បើយ អធិប្បាយថា ឲ្យដល់អប្បនាក្នុងអារម្មណ៍នោះ ព្រមគ្នានឹង ចិត្តប្បាទនុ៎ះឯង ។ បទថា **អជ្ឈត្តំ រូបសញ្ញី** សេចក្តីថា វៀរចាកបរិកម្ម សញ្ញាក្នុងរូបខាងក្នុង ព្រោះមិនទាន់បាន ឬព្រោះមិនត្រូវការ ។ បទថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** សេចក្តីថា បរិកម្មក្តី និមិត្តក្តី របស់បុគ្គលណាកើត ទ្បើងខាងក្រៅតែម្យ៉ាង បុគ្គលនោះមានសេចក្តីសម្គាល់ថា អរូបខាងក្នុង ដោយ អំណាចបរិកម្ម និងអប្បនាខាងក្រៅយ៉ាងនេះ ហៅថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** ។ សេចក្តីដ៏សេស ក្នុងពាក្យនោះ មាននយដូចពោលហើយក្នុង អភិភាយតនៈទី ៤ នោះឯង ។ ក្នុងអភិភាយតនៈទាំង ៤ នេះ បរិត្ត- អភិភាយតនៈ មកដោយអំណាចវិតក្កចរិត អប្បមាណអភិភាយតនៈ មក ដោយអំណាចមោហចរិត សុវណ្ណអភិភាយតនៈ មកដោយអំណាចទោស- ចរិត ទុព្វណ្ណអភិភាយតនៈ មកដោយអំណាចរាគចរិត ។ ពិតហើយ អភិ-

កាយតនៈទាំងនេះ ជាសប្បាយរបស់អ្នកមានចរិតទាំងនេះ ។ សូម្បីអភិភាយតនៈជាសប្បាយនោះ ពោលពិស្ដារហើយ ក្នុងចរិតនិទ្ទេស ក្នុងវិសុទ្ធិមគ្គ ។

គប្បីជ្រាបវិន័យក្នុងអភិភាយតនៈទី ៥ ជាដើម ដូច្នេះ បទថា **នីលានិ** លោកពោលដោយសរុបទាំងអស់ ។ បទថា **នីលវណ្ណានិ** លោកពោលដោយពណ៌ ។ បទថា **នីលនិទស្សនានិ** លោកពោលជានិទស្សនៈ អធិប្បាយថា ពណ៌ដែលមិនលាយគ្នា ដែលមិនប្រាកដចន្លោះប្រហោង ប្រាកដជា មានពណ៌ខៀវដូចគ្នា ។ ចំណែកបទថា **នីលនិភាសានិ** នេះ លោកពោលដោយអំណាចឱភាស អធិប្បាយថា មានពន្លឺពណ៌ខៀវ គឺប្រកបដោយរស្មីខៀវ ។ ដោយបទនេះ លោកសម្ដែងដល់វណ្ណៈទាំងនោះបរិសុទ្ធ ។ ពិតហើយ លោកពោលថា អភិភាយតនៈទាំង ៤ នេះ ដោយពណ៌បរិសុទ្ធប៉ុណ្ណោះ ។ បទថា **ឧម្មារបុប្ផំ** សេចក្ដីថា ពិតហើយ ផ្កានេះ ស្រស់ស្រទន់ កំពុងឃើញក៏ខៀវទាំងអស់ ចំណែកផ្កាកណិការក្ដិជាដើម ដែលកំពុងឃើញក៏ស ព្រោះដូច្នោះទើបលោកកាន់យកផ្កាត្រកៀតនេះប៉ុណ្ណោះ ផ្កាកណិការក្ដិ លោកមិនកាន់យកឡើយ ។ បទថា **ពារាណសេយ្យកំ** ប្រែថា ដែលកើតក្នុងក្រុងពារាណសី បានឮថា ក្នុងក្រុងពារាណសីនោះ ទាំងសម្ពីក៏ទន់ ទាំងអ្នកខារអំបោះ ទាំងជាងតម្បាញក៏ឈ្លាស ។ ទឹកក៏ស្អាតល្អ ព្រោះដូច្នោះ ទើបសំពត់នោះរលោងទាំងពីរខាង គឺក្នុងខាងទាំងពីរក៏រលោង ប្រាកដជា ទន់ល្អ ។ ក្នុងបទថា **បិតានិ** ជាដើម ក៏គប្បីជ្រាបសេចក្ដីដោយន័យនេះឯង ។ កាលនឹងកំណត់នីលកសិណ រមែងកំណត់និមិត្តក្នុងពណ៌ខៀវ ។ ការធ្វើកសិណក្ដី ការបរិកម្មក្ដី អប្បនាវិធីក្ដី ក្នុងទីនេះ មានជាដើមថា **បុប្ផស្មឹ វា វត្ថស្មឹ វា វណ្ណធាតុយា**

ង ទាំងអស់មានន័យ ដូចពោលដោយពិស្ដារហើយ ក្នុងវិសុទ្ធិមគ្គ ។ អភិ-កាយតនៈទាំង ៨ នេះ លោកនាំមក ក៏ដើម្បីសម្ដែងដល់ភាពជាអ្នកមិនខ្លាច ។ បានឮថា ព្រះមានព្រះភាគ កាលត្រាស់អភិកាយតនៈទាំងនេះហើយ ទើបត្រាស់យ៉ាងនេះថា អានន្ទ សេចក្ដីខ្លាច ឬសេចក្ដីក្ដៀវក្លាមិនមានដល់តថាគតដែលកំពុងចូលសមាបត្តិទាំងនេះ និងកំពុងចេញ អ្នកណាហ្ន៎ គួរនឹងកើតការយល់យ៉ាងនេះថា តថាគតឃើញមារតែម្នាក់គប្បីខ្លាច អានន្ទ តថាគតមិនខ្លាច មិនតក់ស្លុត មានសតិសម្បជញ្ញៈ ដាក់អាយុសង្ខារ ។

កថាពោលអំពីរឿងវិមោក្ខ មានសេចក្ដីងាយយល់ហើយ ។ វិមោក្ខទាំង ៨ នេះ លោកនាំមកដើម្បីភាពជាអ្នកមិនខ្លាចដូចគ្នា ។ បានឮថា ព្រះមានព្រះភាគ កាលត្រាស់វិមោក្ខទាំងនេះហើយ ទើបត្រាស់យ៉ាងនេះថា ម្នាលអានន្ទ ការខ្លាច ឬការក្ដៀវក្លា មិនមានដល់តថាគតដែលកំពុងចូលសមាបត្តិទាំងនេះ និងកំពុងចេញ ។បេ។ ដាក់អាយុសង្ខារ ។

[១០២] ឥឡូវនេះ ព្រះមានព្រះភាគ ក៏មិនប្រទានឱកាសដល់ព្រះអានន្ទត្ថេរឡើយ ទ្រង់ផ្ដើមទេសនាដទៃទៀត ដោយន័យថា **ឯកមិទាហំ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **បឋមាភិសម្ពុទ្ធោ** បានដល់ ជាអ្នកត្រាស់ដឹងគ្រាដំបូងនោះឯង គឺក្នុងសប្ដាហ៍ទី ៨ ។ បទថា **ឱស្សដ្ឋោ** សេចក្ដីថា លះបង់ ។ បានឮថា កាលពោលយ៉ាងនេះ ទើបពោលថា ព្រោះហេតុនោះ ទើបលោកធាតុ ១ ម៉ឺន កម្រើកញាប់ញ័រ ។

បទថា **អលំ** នេះ ជាពាក្យបដិសេធ ។ បទថា **ពោធិ** បានដល់ ចាក់ធ្លុះដោយមគ្គញ្ញាណ ៤ ។ ដោយបទថា **សទ្ទហាសិ តុំ** លោកពោលថា អ្នកជឿ

តថាគតពោលយ៉ាងនេះដែរឬ ។ ដោយបទថា **តស្មាតិ ហានន្ទ** *ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រោះហេតុដែលអ្នកជឿពាក្យនេះ ដូច្នោះ ទើបប្រការនេះ ជាការធ្វើមិនល្អរបស់អ្នក ។*

[๑๐๓-๑๐๕] *ព្រះមានព្រះភាគផ្តើមពាក្យថា* **ឯកមិទាហំ** *ជាដើម ដើម្បីលើកទោសរបស់ព្រះថេរៈតែម្នាក់ ដោយប្រការផ្សេងៗ ដើម្បីបន្ទោបង់សេចក្តីសោកយ៉ាងនេះថា តថាគតមិនបានហៅអ្នកមកក្នុងទីនេះតែម្យ៉ាងប៉ុណ្ណោះទេ ។ សូម្បីក្នុងវេលាជនៃទៗ តថាគត ក៏ហៅមកធ្វើនិមិត្តយ៉ាងគ្រោតគ្រោត អ្នកក៏មិនបានដឹងនូវនិមិត្តនោះ នេះគឺជាសេចក្តីភ្លាំងភ្លាត់របស់អ្នកនោះឯង ។*

[๑๐๖-๑๐๘] *បទថា* **បិយេហិ មនាបេហិ** *ការផ្សេងគ្នាដោយជាតិ ការលះបង់ព្រោះមរណភាពជនៃព្រោះកព ព្រាត់ប្រាសអំពីមាតា បិតា បងប្រុស បងស្រីជាដើម ។ បទថា* **តំ** *ក្នុងបទថា* **តំ កុតេត្ថ លព្ភា** *ប្រែថា ព្រោះហេតុនោះ អធិប្បាយថា ព្រោះត្រូវព្រាត់ប្រាសចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ ដែលពេញចិត្តទាំងអស់ ដូច្នោះ តថាគតបំពេញបារមី ๑๐ ក្តី សម្រេចសម្មោធិញ្ញាណក្តី ប្រកាសធម្មចក្រក្តី សម្តែងយមកប្បាដិហារ្យក្តី ចុះអំពីទេវលោកក្តី សរីរៈណាដែលកើតហើយ មានហើយ ត្រូវតាក់តែងហើយ មានការវិនាសទៅជាធម្មតារបស់សរីរៈនៃព្រះតថាគតនោះ កុំវិនាសទៅឡើយ ។ នុ៎ះមិនមែនជាហានៈដែលនឹងមានបាន ទាំងអ្នកស្រែកយំ ទាំងអ្នកកន្ទក់កន្ទេញ ក៏អាចនឹងបានហានៈយ៉ាងនោះ ។ បទថា* **បុន បច្ចាគមិស្សតិ** *សេចក្តីថា វត្ថុដែលតថាគតលះបង់ហើយ បន្ទោបង់ហើយ វត្ថុនោះក៏នឹងត្រឡប់ប្រាកដទៀតមិនបានទេ ។*

បទថា **យជយិនំ ព្រហ្មចរិយំ** *សេចក្តីថា គឺសាសនព្រហ្មចរិយៈ ដែលសង្គ្រោះដោយសិក្ខា ๓ ។ បទថា* **អទុនិយំ** *គឺតាំងនៅយូរ ។ បទថា* **ចិរដ្ឋិតិកំ** *បានដល់ តាំងនៅយូរដោយអំណាចកើតយូរ ។ បទថា* **ចត្តារោ សតិបដ្ឋានា** *ជាដើមទាំងអស់ លោកពោលទាំងជាលោកិយ និងលោកុត្តរ ។ ចំណែកវិនិច្ឆ័យក្នុងពោធិបក្ខិយធម៌ទាំងនេះ លោកពោលក្នុងបដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស ក្នុងវិសុទ្ធិមគ្គដោយប្រការទាំងពួង ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ។*

តតិយភាណវារកថា ចប់

អធិប្បាយ មហាបទេស ๔

[๑๐๙] *បទថា* **ឆាគារលោកិតំ** *សេចក្តីថា ឆ្នឹងរបស់មហាជនចុងទល់ចុងតាំងនៅដូចអដ្ឋិរបស់ព្រះបច្ចេកពុទ្ធ ដែលជាប់គ្នាដូចកដីរី យ៉ាងណា អដ្ឋិរបស់ព្រះសម្មុទ្ធមិនដូច្នោះទេ្បីយ ព្រោះថា អដ្ឋិរបស់ព្រះពុទ្ធជាប់គ្នាតែមួយដូចជាដុំមាស ព្រោះដូច្នោះ ទើបក្នុងវេលាក្រឡេកមកក្រោយ មិនអាចងាកព្រះសូរងបាន ។ ស្តេចដីរីបំណងនឹងក្រឡេកមើលខាងក្រោយ ត្រូវងាកទៅទាំងខ្លួនយ៉ាងណា ព្រះមានព្រះភាគ ក៏ទ្រង់ងាកព្រះវរកាយទៅដូច្នោះ ។ តែពេលព្រះមានព្រះភាគ ប្រថាប់ឈរត្រង់ទ្វារព្រះនគរ ក៏ទ្រង់ព្រះចិន្តាថា នឹងទស្សនាក្រុងវេសាលី ផែនមហាប្រឹថពីនេះ ដូចនឹងក្រាបទូលថា បពិត្រព្រះមានព្រះភាគ ព្រះអង្គទ្រង់បំពេញបារមីមកច្រើនសែនកោដិកប្ប ទ្រង់មិនចាំ*

ปาจ์ธ្ងើ គឺងាកព្រះសូរង្គក្រឡេកមើល ទើបវិលដួចកង់ដី ធ្វើព្រះមានព្រះភាគ ឲ្យបែរព្រះកត្រឹង្គោះទៅកាន់ក្រុងវេសាលី ។ លោកសំដៅយកសេចក្តីនោះ ទើប ពោលថា **នាគាវលោកិតំ** នេះ ។ សួរថា ការទស្សនាក្រុងវេសាលី មិនមែន ជាបច្ចិមទស្សនៈតែម្យ៉ាងទេ ការទស្សនាក្នុងក្រុងសាវត្ថី ក្រុងរាជគ្រឹះ ក្រុង នាលន្ទា ស្រុកបាដលិគ្រាម កោដិគ្រាម នាទិកគ្រាម វេលាស្តេចចេញ ចាកទីនោះៗ ទាំងអស់នោះ ក៏ជាបច្ចិមទស្សនៈទាំងអស់មិនមែនឬ ហេតុអ្វីក្នុង ទីនោះៗ ទើបមិនជាការទស្សនា ជានាគាវលោក (គឺជាបច្ចិមទស្សនៈ) ។ ឆ្លើយថា ព្រោះមិនជាអស្ចារ្យ ។ ពិតហើយ ព្រះមានព្រះភាគត្រឡប់មកបែរ មើលក្នុងទីនោះ សេចក្តីនោះមិនគួរអស្ចារ្យ ព្រោះដូច្នោះ ទើបមិនឈ្មោះថា ទ្រង់ងាកព្រះវរកាយក្រឡេកមើល ។ មួយទៀត ពួកស្តេចលិច្ឆវី ក្រុង វេសាលីជិតវិនាស នឹងវិនាសទៅក្នុង ๓ ឆ្នាំខាងមុខ ព្រោះដូច្នោះ ទើបស្តេច លិច្ឆវីទាំងនោះ សាងចេតិយឈ្មោះថា នាគាបលោកិតចេតិយ ជិតទ្វារព្រះ នគរ នឹងបូជាចេតិយនោះដោយសក្ការៈ មានគ្រឿងក្រអូប និងផ្កាឈើជាដើម សេចក្តីនោះក៏នឹងមានប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរ ព្រោះ ដូច្នោះ ទើបងាកព្រះវរកាយក្រឡេកមើល ដើម្បីអនុគ្រោះស្តេចលិច្ឆវីទាំងនោះ ។

[๑๑๐-๑๑๑] បទថា **ទុក្ខស្សន្តករោ** បានដល់ ធ្វើទីបំផុតនៃវដ្តទុក្ខ ។ បទថា **ចក្ខុមា** បានដល់ ទ្រង់មានចក្ខុ ដោយចក្ខុ ๕ ។ បទថា **បរិនิព្พុតោ** បានដល់ បរិនិព្វានដោយកិលេសបរិនិព្វាន ។

[๑๑๒-๑๑๖] បទថា **មหาបเទเส** បានដល់ ក្នុងឱកាសធំ ឬក្នុងការអាងធំ អធិប្បាយថា ហេតុធំដែលលោកពោលអាងអ្នកធំ ដូចជាព្រះពុទ្ធ

ជាដើម ។

បទថា **អនភិនន្ទិតព្ពំ** គឺដែលបុគ្គលត្រេកអរ ឲ្យសាធុការក្នុងកាលស្តាប់មុនមិនមាន ។ ពិតហើយ កាលធ្វើយ៉ាងនេះ ខាងក្រោយ ត្រូវតវ៉ាថា ប្រការនេះមិនសមរម្យ ក៏ឆ្ងើយឆ្លងបានថា កាលមុន ប្រការនេះ ជាធម៌ ឥឡូវនេះមិនជាធម៌ឬ ឈ្មោះថា មិនលះបង់លទ្ធិ ។ បទថា **ន បដិក្កោសិតព្ពំ** សេចក្តីថា មិនគប្បីពោលមុនយ៉ាងនេះថា បុគ្គលពាលនេះ និយាយអ្វី ។ កាលត្រូវតវ៉ាថា នឹងមិនពោលសូម្បីតែពាក្យដែលគួរពោល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អនភិនន្ទិត្វា អប្បដិក្កោសិត្វា** ។ បទថា **បទព្យញ្ជនានិ** បានដល់ ព្យញ្ជនៈ ពោល គឺបទ ។ បទថា **សាធុកំ ឧគ្គ-ហេត្វា** បានដល់ កាន់យកដោយល្អថា លោកពោលបាលីទុកក្នុងទីនេះ ពោលសេចក្តីទុកក្នុងទីនេះ ពោលខាងដើម និងខាងចុងទុកក្នុងទីនេះ ។ បទថា **សុត្តេ ឱតារេតព្វានិ** បានដល់ គប្បីសាកសួរក្នុងព្រះសូត្រ ។ បទថា **វិនយេ សន្ទស្សេតព្វានិ** បានដល់ ប្រៀបធៀបក្នុងព្រះវិនយ ។ ក្នុងទីនេះ ដែលឈ្មោះថា សូត្រ បានដល់ វិនយ ។ ដូចដែលលោកពោលថា ហាមទុកក្នុងទីណា ហាមទុកក្នុងក្រុងសាវត្ថី ហាមទុកក្នុងសុត្តវិភង្គ (សុត្តៈក្នុងទីនេះសំដៅដល់វិនយ) ដែលឈ្មោះវិនយ បានដល់ ខន្ធកៈ ដូច ដែលលោកពោលទុកថា **កោសម្ពិយំ វិនយាតិសារេ** ក្នុងរឿងល្មើសព្រះវិនយ (វិនយក្នុងទីនេះសំដៅដល់ខន្ធកៈ) ក្នុងក្រុងកោសម្ពី ។ កាលបើដូច្នេះ ឈ្មោះថា មិនកាន់យកវិនយបិដក ។ ឈ្មោះថា កាន់យកព្រះវិនយយ៉ាងនេះ គឺឧភតោវិភង្គ ឈ្មោះថា សុត្តៈ ខន្ធកៈ បរិវារ ឈ្មោះថា វិនយ ។ ម្យ៉ាងទៀត កាន់យកបិដកទាំង ២

យ៉ាងនេះ គឺសុត្តន្តបិដក ឈ្មោះថា ព្រះសូត្រ វិនយបិដក ឈ្មោះថា វិន័យ ។ ម្យ៉ាងទៀត មុនដំបូង មិនកាន់យកបិដកទាំង ៣ យ៉ាងនេះ សុត្តន្តបិដក និងអភិធម្មបិដក ឈ្មោះថា សូត្រ វិនយបិដក ឈ្មោះថា វិន័យ ធម្មតា ពុទ្ធវចនៈណាមួយ ដែលឈ្មោះថា មិនមែនសូត្រ ក៏មាន គឺជាតក បដិសម្ភិទា និទ្ទេស សុត្តនិបាត ធម្មបទ ឧទាន ឥតិវុត្តកៈ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា អបទាន ។

ព្រះសុទិន្នត្ថេរ ជំទាស់ពាក្យនេះទាំងអស់ថា ព្រះពុទ្ធវចនៈ ឈ្មោះថា មិនមែនសូត្រមានឬ ដូច្នេះហើយពោលថា បិដក ៣ ឈ្មោះថា សូត្រ ឯវិន័យ ឈ្មោះថា ហេតុ ។ បន្ទាប់អំពីនោះ កាលនឹងសម្តែងហេតុនោះ ទើបនាំសូត្រនេះមកអាងថា ម្នាលនាងគោតមី នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីមានតម្រេក មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ប្រព្រឹត្តទៅដើម្បីប្រកបក្នុងទុក្ខ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រកាន់ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកសេចក្តីប្រកាន់ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស ប្រព្រឹត្តទៅដើម្បីសេចក្តីវិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម ប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួកគណៈ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងាត់ចាកពួក ប្រព្រឹត្តទៅដើម្បីការសន្សំ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំ ។ ម្នាលនាងគោតមី នាងគប្បីដឹងដោយចំណែកមួយថា នុ៎ះមិនមែនជាធម៌ នុ៎ះមិនមែនជាវិន័យ នុ៎ះមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា

ទេ ។ ម្នាលគោតមី នាងគប្បីដឹងធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីតម្រេក ប្រព្រឹត្តទៅដើម្បីប្រាសចាកការប្រកបក្នុងទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីការប្រកបក្នុងទុក្ខ ប្រព្រឹត្តទៅដើម្បីប្រាសចាកសេចក្តីប្រកាន់ មិនប្រព្រឹត្តទៅ ដើម្បីមានសេចក្តីប្រកាន់ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាច្រើន ប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស មិនប្រព្រឹត្តទៅ ដើម្បីមិនសន្តោស ប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងាត់ចាកពួក មិនប្រព្រឹត្តទៅ ដើម្បីច្រឡូកច្រឡំដោយពួក ប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំ មិនប្រព្រឹត្តទៅដើម្បីការសន្សំ ។ ម្នាលនាងគោតមី នាងគប្បីដឹងដោយចំណែកមួយថា នុ៎ះជាធម៌ នុ៎ះជាវិន័យ នុ៎ះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាហើយ ។ ព្រោះដូច្នោះ គប្បីដេញសាកសួរក្នុងព្រះត្រៃបិដក ពុទ្ធវចនៈ ដែលឈ្មោះថា សូត្រ គប្បីប្រៀបធៀបក្នុងហេតុ គឺវិន័យ មានរាគៈជាដើម ដែលឈ្មោះថា វិន័យ សេចក្តីក្នុងប្រការនេះ មានដូចពោលមកដូច្នេះ ។

បទថា **ន ចេវ សុត្តេ ទិស្សតិ** *សេចក្តីថា បទព្យញ្ជនៈទាំងនោះ មិនមកក្នុងទីណាមួយ តាមលំដាប់សូត្រ រៀរលែងតែខ្ចាតមកអំពីគុឡ្ហវេស្សន្តរគុឡ្ហឧម្មគ្គៈ គុឡ្ហវិន័យ វេទល្លៈ និងបិដកនៅមានប្រាកដ ។ ពិតហើយ បទព្យញ្ជនៈដែលមកយ៉ាងនេះ តែមិនប្រាកដក្នុងការកម្ចាត់កិលេស មានរាគៈជាដើម ក៏គប្បីចោល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុទាំងឡាយ ដូច្នោះ អ្នកគប្បីលះបង់សេចក្តីនោះចេញ ។ គប្បីជ្រាបសេចក្តីក្នុង*

ទីគ្រប់កន្លែង ដោយឧបាយនេះ ។ បទថា **ឥមំ ภิกฺขเว จตุตฺถំ มหาปเทสំ ธาเรยฺยาถ** សេចក្តីថា អ្នកគប្បីទ្រទ្រង់ចាំនូវឱកាស ជាទីប្រតិស្ឋាននៃធម៌ទាំង ៤ នេះ ។

ក្នុងទីនេះគប្បីជ្រាបបកិណ្ណកៈដូច្នេះថា ក្នុងព្រះសូត្រ មានមហាបទេស ៤ ក្នុងខន្ធកៈ មានមហាបទេស ៤ បញ្ហាព្យាករណ៍ ៤ សុត្តៈ ១ សុត្តានុលោម ១ អាចរិយវាទ ១ អត្តនោមតិ ១ សង្គីតិ ៣ ។

ក្នុងបកិណ្ណកៈទាំងនោះ កាលដល់ការវិនិច្ឆ័យធម៌ថា នេះធម៌ នេះវិន័យ មហាបទេសទាំង ៤ នេះកាន់យកជាប្រមាណ សេចក្តីណាសមក្នុងមហាបទេសទាំង ៤ នេះ សេចក្តីនោះគួរកាន់យក សេចក្តីក្រៅនេះ របស់អ្នកកាន់ខុស មិនគួរកាន់យក ។ កាលដល់ការវិនិច្ឆ័យសេចក្តីដែលគួរ និងមិនគួរថា វត្ថុនេះគួរ វត្ថុនេះមិនគួរ មហាបទេស ៤ ដែលត្រាស់ក្នុងខន្ធកៈដោយន័យថា

ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ ដូច្នេះជាដើម កាន់យកជាប្រមាណ ។ កថាវិនិច្ឆ័យមហាបទេសទាំងនោះ ពោលទុកក្នុងអដ្ឋកថា ព្រះវិន័យ ឈ្មោះថាសមន្តបាសាទិកា ដោយន័យដែលពោលទុកក្នុងទីនោះ គប្បីធ្វើសន្និដ្ឋានយ៉ាងនេះថា វត្ថុណាដែលចូលគ្នាបាននឹងវត្ថុដែលគួរ វត្ថុនោះគួរ ក្រៅពីនោះមិនគួរ ។

ឯកំសព្យាករណីយបញ្ហា ១ វិភជ្ជព្យាករណីយបញ្ហា ១ បដិបុច្ឆា-ព្យាករណីយបញ្ហា ១ ឋបនីយបញ្ហា ១ ទាំងនេះ ឈ្មោះថា បញ្ហាព្យាករណ៍ ៤ ។ ក្នុងបញ្ហាព្យាករណ៍ ៤ នោះ ត្រូវសួរថា ចក្ខុមិនទៀងឬ គប្បីព្យាករណ៍

มุនដោយចំណែកតែមួយថា កុณา មិនទៀង ។ ក្នុងសោត:ជាដើម ក៏មាន
នយនេះ ។ នេះឈ្មោះថា ឯកំសព្យាករណីយបញ្ហា ។ ត្រូវសួរថា ចក្ខុឬ ឈ្មោះ
ថា មិនទៀង ។ គប្បីចែក ហើយព្យាករណ៍យ៉ាងនេះថា មិនមែនចក្ខុប៉ុណ្ណោះ
សូម្បីតែសោត: ក៏មិនទៀង សូម្បីឃាន: ក៏មិនទៀង ។ នេះឈ្មោះថា វិភជ-
ព្យាករណីយបញ្ហា ។ ត្រូវសួរថា ចក្ខុយ៉ាងណា សោត:ក៏យ៉ាងនោះឬ សោត:
យ៉ាងណា ចក្ខុក៏យ៉ាងនោះឬ ដូច្នេះជាដើម ។ ទើបសាកសួរថា លោកសួរ
ដោយអត្ថដូចម្តេច កាលគេឆ្លើយថា សួរដោយអត្ថថា ឃើញ ទើបព្យាករថា
មិនមែន ។កាលគេឆ្លើយថា សួរដោយអត្ថថា មិនទៀង ទើបព្យាករថា មែន ។
នេះឈ្មោះថា បដិបុច្ឆាព្យាករណីយបញ្ហា ។ តែត្រូវសួរថា ជីវ:នោះ សរីរ:
នោះឬ ជាដើម គប្បីឈប់ដោយពោលថា សេចក្តីនេះ ព្រះមានព្រះភាគ
មិនព្យាករ ។ បញ្ហានេះមិនគប្បីព្យាករ ។ នេះឈ្មោះថា ឋបនីយបញ្ហា ។
ដូច្នោះ កាលបញ្ហាមកដល់ដោយអាការនោះ បញ្ហាព្យាករណ៍ទាំង ๔ នេះ
កាន់យកជាប្រមាណបាន ។ គប្បីព្យាករបញ្ហានោះ ដោយអំណាចបញ្ហា
ព្យាករណ៍ ๔ នេះ ។

បិដក ๓ ដែលលើកទ្បើងកាន់សង្គីតិ ๓ ឈ្មោះថា សុត្ត: ក្នុងបកិណ្ណក:
មានសុត្ត:ជាដើម ។ សេចក្តីដែលចូលគ្នា បានជាមួយកប្បិយ: ឈ្មោះថា
សុត្តានុលោម ។ អដ្ឋកថា ឈ្មោះថា អាចរិយវាទ ។ បដិភាណរបស់ខ្លួន តាម
ការគិតគ្នេរ ឈ្មោះថា អត្តនោមតិ ។ ក្នុងបកិណ្ណក:ទាំងនោះ សុត្ត: បុគ្គល
ណាជំទាស់មិនបាន កាលជំទាស់សុត្ត:នោះ ក៏ស្មើនឹងជំទាស់ព្រះពុទ្ធផង ។
ចំណែកសេចក្តីដែលចូលជាមួយនឹងកប្បិយ:បាន គួរកាន់យកចំពោះសេចក្តី

ដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅពីនោះមិនគួរកាន់យក ។ សូម្បីអាចរិយវាទ ក៏គួរកាន់យកតែសេចក្តីដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅអំពីនោះមិនគួរកាន់យក ។ ចំណែកអត្តនោមតិ អន់ជាងគេទាំងអស់ ។ សូម្បីអត្តនោមតិនោះ ក៏គួរកាន់យកតែសេចក្តីដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅពីនោះមិនគួរកាន់យក ។

សង្គីតិមាន ៣ គឺបញ្ចសតិកសង្គីតិ (សង្គាយនាលើកទី ១) សត្ត-សតិកសង្គីតិ (លើកទី ២) សហស្សិកសង្គីតិ (លើកទី ៣) ។ សូម្បីសុត្តៈដែលមកក្នុងសង្គីតិ ៣ នោះ គួរកាន់យកជាប្រមាណ ។ ក្រៅពីនោះជាការដែលលោកតិះដៀល មិនគួរកាន់យក ។ ពិតហើយ បទព្យញ្ជនៈដែលចូលគ្នាបានក្នុងសុត្តៈនោះ គប្បីជ្រាបថា ចូលគ្នាមិនបានក្នុងព្រះសូត្រ និងប្រៀបធៀបគ្នាមិនបានក្នុងព្រះវិន័យ ។

ចុន្ទកម្មារបុត្តកថា

[๑๑๗] បទថា **កម្មារបុត្តស្ស** បានដល់ កូនរបស់ជាងមាស ។ បានឮថា កូនជាងមាសនោះ ជាកុដុម្ពិកៈធំ ជាអ្នកសុកសទ្ធ ជាសោតាបន្ន ព្រោះឃើញព្រះមានព្រះភាគគ្រាដំបូងប៉ុណ្ណោះ បានសាងវត្តក្នុងចម្ការស្វាយរបស់ខ្លួនថ្វាយ ។ លោកសំដៅយកចម្ការស្វាយនោះ ទើបពោលថា **អម្ពវនេ** ។ បទថា **សូករមទ្ទវំ** បានដល់ បវត្តមំសៈរបស់ជ្រូកមួយដែលធំបំផុត មិនក្មេងពេក មិនចាស់ពេក ។ បានឮថា បវត្តមំសៈនោះ ទន់ល្អ ។ អធិប្បាយថា ឲ្យចាត់បវត្តមំសៈនោះ ធ្វើឲ្យឆ្អិនយ៉ាងល្អ ។ អាចារ្យពួកមួយពោលថា ពាក្យថា សូករមទ្ទវៈនេះ ជាឈ្មោះរបស់ជ្រូកទន់ ដែលផ្សំដោយបញ្ចគោរស (**ទធិ ឃត តក្ក ខោដិត**) និងសណ្តែក ដូចរបស់ឆ្អិនឈ្មោះថា គវបានៈ នំ

ផ្សុំទឹកដោះគោ ។ អាចារ្យពួកខ្លះពោលថា វិធីផ្សុំរស ឈ្មោះថា សូករមទฺวៈ សូករមទฺวៈនោះ មកក្នុងរសាយតនសាស្ត្រ ។ សូករមទฺวៈនោះ នាយចុន្ទ តាក់តែងតាមរសាយនវិធី ដោយបំណងថា បរិនិព្វានទីងមិនមានដល់ព្រះមានព្រះភាគ ។ តែពួកទេវតាក្នុងមហាទ្វីបទាំង ៤ ដែលមានទ្វីបតូច ២០០០ ជាបរិវារ ជាក់ឱជាចូលសូករមទฺวៈនោះ ។ ព្រះមានព្រះភាគ ទ្រង់បន្ទឺសីហនាទនេះថា **ឆាហាន្តំ** ដើម្បីអ្វី ។ ដើម្បីទ្រង់ដោះពាក្យស្តីបន្ទោសរបស់អ្នកជនៃ ។ ពិតហើយ ព្រះមានព្រះភាគ ស្តាប់ពាក្យរបស់ពួកដែលត្រូវការនីងពោលថា ព្រះមានព្រះភាគមិនប្រទានសូករមទฺวៈ ដែលព្រះអង្គសោយនៅសល់ ទាំងដល់ភិក្ខុ ទាំងដល់មនុស្សទាំងឡាយ បង្គាប់ឲ្យកប់ចោលក្នុងរណ្តៅ ធ្វើឲ្យវិនាសអស់ដូច្នេះ ទើបទ្រង់បន្ទឺសីហនាទ ដើម្បីដោះពាក្យតិះដៀលរបស់ជនពួកជនៃ ដោយព្រះបំណងថា នីងមិនមានឱកាសពោលស្តីបន្ទោសបាន ។

[๑๑๘] បទថា **ភុត្តស្ស ច សូករមទฺเวน** សេចក្តីថា អាពាធយ៉ាងខ្លាំងក្លា កើតឡើងដល់ព្រះអង្គអ្នកសោយ តែមិនមែនកើតព្រោះសូករមទฺวៈដែលសោយជាបច្ច័យ ។ ប្រសិនបើព្រះអង្គមិនសោយ នីងកើតអាពាធបាន នីងជាអាពាធដ៏ខ្លាំងក្លាទៀតផង ។ តែព្រោះសោយកោជនដែលស្និទ្ធ ទើបព្រះអង្គមានទុក្ខវេទនាធូរថយ ។ ដោយហេតុនោះឯង ទើបព្រះអង្គទ្រង់យាងទៅបាន ។ បទថា **វิរេចมาเนา** បានដល់ ព្រះអង្គទ្រង់ជាក់ព្រះលោហិតរឿយៗ ។ លោកពោលយ៉ាងនេះថា **អវោច** ក៏ដើម្បីប្រយោជន៍ដល់បរិនិព្វាន ក្នុងស្ថានទីដែលព្រះអង្គមានព្រះពុទ្ធបំណង ។ គប្បីជ្រាបសេចក្តីថា ក៏ព្រះធម្មសង្គាហកត្តេរតាំងគាថាទាំងនេះ ។

[១១៩] សព្ទថា **ឥជ្ឈ** ជានិបាត ចុះក្នុងអត្ថថា ជាស់តឿន ។ បទថា **អច្ឆោទកា** ប្រែថា មានទឹកថ្លា ។ បទថា **សាតោទកា** ប្រែថា មានទឹកឆ្ងាញ់ ។ បទថា **សីតោទកា** ប្រែថា មានទឹកត្រជាក់ល្អ ។ បទថា **សេតោទកា** ប្រែថា ប្រាសចាកភក់ ។ បទថា **សុបតិត្តា** ប្រែថា មានកំពង់ល្អ ។

[១២០] បទថា **បុក្ពុសោ** ជាឈ្មោះរបស់បុត្រមល្លក្សត្រនោះ ។ បទថា **មល្លបុត្តោ** ប្រែថា បុត្ររបស់មល្លក្សត្រ ។ បានព្ថថា ពួកមល្លក្សត្រផ្ទាស់ប្តូរគ្នាគ្រងរាជសម្បត្តិ ។ ជរាបណាវារៈរបស់មល្លក្សត្រពួកណា មិនទាន់មកដល់ ជរាបនោះ មល្លក្សត្រទាំងនោះ ក៏ទៅធ្វើការជួញដូរ ។ ស្តេចបុក្ពុសៈនេះ ក៏ធ្វើជំនួញដោយរទេះ ៥០០ ន៉ុះឯង កាលឲ្យល់បក់មកខាងមុខ ក៏ទៅខាងមុខ កាលឲ្យល់បក់មកពីក្រោយៗ ក៏បញ្ជូនពួករទេះទៅខាងមុខ ខ្ជូនឯងបរខាងក្រោយ ។ ក្នុងគ្រានោះ ឲ្យល់បក់ទៅខាងក្រោយ ព្រោះដូច្នោះ ទើបគាត់បញ្ជូនពួករទេះទៅខាងមុខ អង្គុយលើយានផ្ទុករតនៈទាំងអស់ ចេញចាកក្រុងកុសិនារា ធ្វើដំណើរទៅ សំដៅទៅក្រុងបាវា ។ ដោយហេតុនេះ ទើបលោកពោលថា ធ្វើដំណើរផ្ទូវឆ្ងាយ អំពីរក្រុងកុសិនារា ទៅកាន់ក្រុងបាវា ។

បទថា **អាឡារោ** ជាឈ្មោះរបស់តាបសនោះ ។ បានព្ថថា តាបសនោះ មានរាងខ្ពស់ និងលឿង ព្រោះហេតុនោះ ទើបលោកមានឈ្មោះថា អាឡារ ។ បទថា **កាលាមោ** បានដល់ គោត្រ ។ បទថា **យត្រ ហិ នាម** ស្មើនឹង **យោហិ នាម** ។ បទថា **នេវ ទក្ខតិ** ប្រែថា មិនឃើញ ។ តែលោកពោលពាក្យនេះជាអនាគតកាល ព្រោះប្រកបនឹង **យត្រ** សព្ទ ។ ពិតហើយពាក្យបែបនេះ ជាលក្ខណៈសព្ទក្នុងឋានៈដូច្នេះ ។ បទថា **និច្ចរន្តីសុ** ប្រែថា

សំឡេងឈូឆរ ។ បទថា **អសនិយា ផលន្តិយា** *បានដល់ ខ្លារខ្វរ ដូចវន្ទេះទាំង ៩ ។*

សេចក្តីពិត វន្ទេះមាន ៩ គឺ **អសញ្ញា វិចក្ខា សតេរា គគ្គរា កបិសីសា មច្ឆវិលោលិកា កុក្កុដកា ឧណ្ហមណិកា** *និង* **សុក្ខាសនិ ។** *បណ្តាវន្ទេះ ៩ នោះ វន្ទេះដែលឈ្មោះថា* **អសញ្ញា** *ព្រោះបាញ់ដោយមិនឲ្យសញ្ញា ។ វន្ទេះដែលឈ្មោះថា* **វិចក្ខា** *ព្រោះបាញ់ជាវង្វង់ដូចកង់ចក្រ ។ វន្ទេះដែលឈ្មោះថា* **សតេរា** *ប្រាកដដូចក្តោងសំពៅ ដែលត្រជាងទុកត្រង់សសរក្តោង ។ វន្ទេះដែលឈ្មោះថា* **គគ្គរា** *ព្រោះមានសំឡេងដូចញញួរធ្លាក់ ។ វន្ទេះដែលឈ្មោះថា* **កបិសីសា** *ព្រោះដូចស្វាញាក់ចិញ្ចើម ។ វន្ទេះដែលឈ្មោះថា* **មច្ឆវិលោលិកា** *ព្រោះដូចត្រីហូរទឹកភ្នែក ។ វន្ទេះដែលឈ្មោះថា* **កុក្កុដកា** *ព្រោះប្រាកដដូចមាន់ ។ វន្ទេះដែលឈ្មោះថា* **ឧណ្ហមណិកា** *ព្រោះមានសណ្ឋានដូចយាមនង្គ័ល ។ វន្ទេះដែលឈ្មោះថា* **សុក្ខាសនិ** *ព្រោះបាញ់បំបើងពីក្រោមឡើងលើ ។*

បទថា **នេវ វស្សន្តេ** *បានដល់ ផ្គរសោះកក្រោះ ក្នុងកាលភ្លៀងធ្លាក់បន្តិចបន្តួច ។*

[๑๒๑] *បទថា* **អាតុមាយំ** *សេចក្តីថា បានអាស្រ័យស្រុកអាតុមា ។ បទថា* **ភូសាគារេ** *បានដល់ ភោងលានស្រូវ ។ បទថា* **ឯត្ត សោ** *បានដល់ ពួកមហាជនដែលជំនុំគ្នា ព្រោះហេតុនេះ ។ បទថា* **ក្ហ អហោសិ** *កាត់បទជា* **កុហឹ អហោសិ ។** *បទថា* **សោ តំ ភន្តេ** *កាត់បទជា* **សោ ត្វំ ភន្តេ ។** *បទថា*

สิฏฺฐิวณฺณึ បានដល់ មានពណ៌ដូចមាសសិទ្ធិ ។ បទថា **យุคมตฺตึ** ប្រែថា រលោងទាំងគូ ។ អធិប្បាយថា សំពត់សាច់ម៉ដ្ត ១ គូ ។ បទថា **ธารณียึ** បានដល់ គប្បីប្រដាប់ អធិប្បាយថា គប្បីដណ្តប់ម្តងៗ ។ ស្តេចបុក្កុសៈនោះ ប្រើតែក្នុងថ្ងៃមហោស្រពប៉ុណ្ណោះ ក្នុងវេលាដទៃក៏រក្សាទុក ។ លោកសំដៅយកគូសំពត់មង្គលខ្ពង់ខ្ពស់ ទើបពោលយ៉ាងនេះ ។ បទថា **อนุกมฺปาย อุปาทาย** បានដល់ អាស្រ័យសេចក្តីករុណាដល់ខ្ញុំ ។ បទថា **อชฺชาเทหิ** នេះ ជាពាក្យទន់ភ្លន់ អធិប្បាយថា ចូរឲ្យដល់តថាគតមួយផ្ងាំង អានន្ទមួយផ្ងាំង ។ សួរថា ព្រះថេរៈទទួលសំពត់នោះឬ ឆ្លើយថា លោកទទួល ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមានកិច្ចដល់ទីបំផុតហើយ ។ សេចក្តីពិតព្រះអានន្ទនោះហាមលាភបែបនោះ បដិបត្តិកិច្ចជាឧបដ្ឋាកក៏ពិត តែកិច្ចឧបដ្ឋាករបស់លោកនោះដល់ទីបំផុតហើយ ព្រោះដូច្នោះ ទើបលោកទទួល ឬថា ជនទាំងឡាយណាគប្បីពោលយ៉ាងនេះថា ព្រះអានន្ទ មិនត្រេកអរ លោកឧបដ្ឋាកមកអស់ ២៥ ឆ្នាំ មិនធ្លាប់បានអ្វីអំពីសម្នាក់របស់ព្រះមានព្រះភាគសោះ ព្រោះដូច្នោះ ទើបលោកទទួលដើម្បីកាត់ឱកាសរបស់ជនទាំងនោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាបថា អានន្ទសូម្បីទទួល ក៏នឹងមិនប្រើដោយខ្លួនឯងគង់នឹងបូជាតថាគតប៉ុណ្ណោះ តែបុត្ររបស់មល្លៈក្សត្រ កាលបូជាអានន្ទ ក៏ស្មើនឹងបូជាព្រះសង្ឃផងដែរ កាលបើដូច្នេះ គំនរបុណ្យធំ ក៏នឹងមានដល់បុត្រមល្ល-ក្សត្រនោះ ព្រោះដូច្នោះ ទើបទ្រង់ប្រោស ឲ្យប្រគេនព្រះថេរៈមួយផ្ងាំង ។ ចំណែកព្រះថេរៈក៏ទទួល ព្រោះហេតុនោះដូចគ្នា ។ បទថា **ธมฺมิยา กถาย** បានដល់ ការពោលអនុមោទនាវត្ថុទាន ។

[១២២] បទថា **ភគវតោ កាយំ ឧបនាមិតំ** បានដល់ ការពាក់ដោយទំនងដូចស្មៀកដណ្តប់ ។ សូម្បីព្រះមានព្រះភាគ ទ្រង់ស្មៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង អំពីគូសំពត់នោះ ។ បទថា **ហតច្ចិកំ វិយ** សេចក្តីថា រងើកភ្លើងដែលប្រាសចាកអណ្តាត រមែងរុងរឿងខាងក្នុងប៉ុណ្ណោះ តែពន្លឺនៃរងើកភ្លើងនោះ មិនមានខាងក្រៅយ៉ាងណា គូសំពត់ ក៏ដូច្នោះដែរ ប្រាកដជាគ្មានពន្លឺខាងក្រៅ ។ សួរថា ក្នុងបទថា **ឥមេសុ ខោ អានន្ទ ទ្វីសុ កាលេសុ** ហេតុអ្វី ទើបកាយរបស់ព្រះតថាគត បរិសុទ្ធយ៉ាងក្រៃលែងយ៉ាងនេះ ក្នុងកាលទាំង ២ នេះ ឆ្លើយថា ព្រោះសេចក្តីវិសេសនៃអាហារម្យ៉ាង ព្រោះសោមនស្សមានកម្លាំងម្យ៉ាង ។ ក្នុងកាលទាំង ២ នេះ ពួកទេវតាក្នុងសាកលចក្រវាល ដាក់ឱជាចូលក្នុងអាហារ ។ ភោជននោះធ្លាក់ដល់ផ្ទៃ ក៏បង្កើតបសន្នរូប ។ ឥន្ទ្រិយដែលមានចិត្តជាគម្រប់ ៦ ក៏រុងរឿងក្រៃលែង ព្រោះមានរូប ដែលមានអាហារជាសមុដ្ឋានស្រស់ថ្លា ។ ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹងទ្រង់រំពឹងថា គំនរកិលេសដែលអាត្មាអញសន្សំមកច្រើនសែនកោដិកប្ប ថ្ងៃនេះអាត្មាអញលះបានហើយហ្ន៎ ទើបកើតសោមនស្សមានកម្លាំងឡើង ។ ចិត្តក៏ផូរផង់ ។ កាលចិត្តផូរផង់ លោហិតក៏ផូរផង់ ។ កាលលោហិតផូរផង់ ឥន្ទ្រិយ មានចិត្តជាគម្រប់ ៦ ក៏រុងរឿងយ៉ាងក្រៃលែង ។ ក្នុងថ្ងៃបរិនិព្វានទ្រង់រំពឹងថា ថ្ងៃនេះ ឥឡូវនេះ អាត្មាអញនឹងចូលទៅកាន់នគរ អមតមហានិព្វាន ដែលព្រះពុទ្ធច្រើនសែនព្រះអង្គចូលទៅហើយ ដូច្នេះ ទើបកើតសោមនស្ស មានកម្លាំងឡើង ។ ចិត្តក៏ផូរផង់ កាលចិត្តផូរផង់ លោហិតក៏ផូរផង់ កាលលោហិតផូរផង់ ឥន្ទ្រិយមានចិត្តជាគម្រប់ ៦ ក៏រុងរឿងយ៉ាងក្រៃលែង ។

គប្បីជ្រាបថា ព្រះវរកាយរបស់ព្រះតថាគតបរិសុទ្ធយ៉ាងក្រៃលែង មានក្នុងកាលទាំង ២ នេះ ដោយអាហារ និងសោមនស្សមានកម្ចាំង ដោយប្រការដូច្នេះ ។ បទថា **ឧបវត្តនេ** បានដល់ ក្នុងសាលវនត្រង់គល់ខាងកើត ។ បទថា **អន្តរេ យមកសាលានំ** គឺត្រង់ចន្ទោះសាលព្រឹក្សទាំងគូ ។

[១២៣] គាថាថា **សិផ្ធិវណ្ណំ** ជាដើម លោករចនាក្នុងពេលសង្គាយនា ។

[១២៤] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាថា **ន្ហាត្វា ច បិវិត្វា ច** ដូច្នេះ ជាដើម បានញ្ចថា ក្នុងកាលនោះ កាលព្រះមានព្រះភាគចុះស្រង់ទឹក អណ្តើកត្រីខាងក្នុងស្ទឹង និងជួរព្រៃមាត់ច្រាំងទាំង ២ ក៏មានពណ៌ដូចមាសដែរ ។ បទថា **អម្ពវនំ** បានដល់ ចម្ការស្វាយត្រង់ឆ្នេរស្ទឹងនោះឯង ។ បទថា **អាយ-ស្មន្តំ ចុន្ទកំ** សេចក្តីថា បានញ្ចថា ក្នុងខណៈនោះ ព្រះអានន្ទត្ទេរពួតសំពត់ស្រង់ទឹកហាលទុក ។ ព្រះចុន្ទត្ទេរក៏នៅក្នុងទីជិត ។ ព្រះមានព្រះភាគត្រាស់ហៅចុន្ទភិក្ខុមកហើយ ។

[១២៥] សូម្បីគាថានេះថា **គន្ត្វាន ពុទ្ធោ នធិកំ កកុធំ** លោករចនាក្នុងកាលសង្គីតិន៉ុះឯង ។ បណ្តាបទទាំងនោះ បទថា **បវត្តា ភគវា ឥធ ធម្មេ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ប្រកាសព្រះធម៌ក្នុងសាសនានេះ អធិប្បាយថា ទ្រង់ប្រកាសធម៌ ៨៤០០០ ព្រះធម្មក្ខន្ធ ។ បទថា **បមុទេ និសីទិ** បានដល់ អង្គុយត្រង់ព្រះភក្ត្រព្រះសាស្តា ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ព្រះថេរៈមកដល់ហើយ ។ គ្រានោះឯង ព្រះមានព្រះភាគត្រាស់ចំពោះព្រះអានន្ទដែលមកដល់ហើយយ៉ាងនេះ ។

[๑๒๖] *បទថា* **តេ អលาភា** *បានដល់ លាភ ពោល គឺអានិសង្ស ទាន ជាលាភរបស់អ្នកដទៃ មិនមែនលាភរបស់លោក ។ បទថា* **ទុល្លទ្ធំ** *បានដល់ ការបានអត្តភាពជាមនុស្សដោយបុណ្យវិសេស ក៏ចាត់ថា បានដោយក្រ ។ បទថា* **យស្ស តេ** *ស្មើនឹង* **យស្ស តវ** *ប្រែថា បុគ្គលណា ។ ក្រៅអំពីបាយ ឬវត្ថុសៅហ្មងយ៉ាងក្រៃលែង បុគ្គលណានឹងដីងបាន ព្រះតថាគតសោយ បិណ្ឌបាតពេលក្រោយយ៉ាងណាហើយទ្រង់បរិនិព្វាន ទានណាមួយ ឈ្មោះថា លោកឲ្យដោយពិត ។ បទថា* **លាភា** *បានដល់ ជាលាភ គឺអានិសង្សក្នុងការ ឲ្យទាន ដែលមានក្នុងបច្ចុប្បន្ន ឬប្រព្រឹត្តទៅក្នុងសម្បរាយភព ។ បទថា* **សុលទ្ធំ** *បានដល់ ការបានអត្តភាពជាមនុស្ស គឺលោកបានមកល្អហើយ ។ បទថា* **សមសមផលា** *ប្រែថា មានផលស្មើៗ គ្នា ដោយអាការទាំងពួង ។ សួរថា ព្រះតថាគតសរសើរបិណ្ឌបាតណា ដែលនាងសុជាតាថ្វាយហើយ ត្រាស់ដឹង បិណ្ឌបាតនោះ ព្រះអង្គសោយក្នុងវេលាដែលនៅមានរាគៈ ទោសៈ និងមោហៈ តែបិណ្ឌបាតនេះ ដែលនាយចុន្ទថ្វាយហើយ ព្រះអង្គសោយក្នុង វេលាដែលប្រាសចាករាគៈ ទោសៈ មោហៈ មិនមែនឬ តើហេតុអ្វីទើបបាន ជាបិណ្ឌបាតទាំងពីរនេះ មានផលស្មើៗ គ្នា ឆ្លើយថា ព្រោះស្មើគ្នា ដោយការ បរិនិព្វាន ស្មើគ្នាដោយការចូលសមាបត្តិ និងស្មើគ្នាដោយការរុកដល់ ។ ពិតហើយ ព្រះមានព្រះភាគសោយបិណ្ឌបាត ដែលនាងសុជាតាថ្វាយហើយ ទ្រង់បរិនិព្វានដោយសឧបាទិសេសនិព្វានធាតុ និងសោយបិណ្ឌបាត ដែល នាយចុន្ទថ្វាយហើយ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ រួមសេចក្តី ថា មានផលស្មើគ្នា ដោយការបរិនិព្វាន ។ ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹង

ព្រះអង្គទ្រង់ចូលសមាបត្តិរាប់បាន ២ លាន ៤ សែនកោដិ សូម្បីក្នុងថ្ងៃបរិនិព្វាន ទ្រង់ក៏ចូលសមាបត្តិទាំងអស់នោះ ។ រួមសេចក្តីថា មានផលស្មើគ្នាដោយសមាបត្តិស្មើគ្នា ។ ក្នុងកាលតមក នាងសុជាតាបានជ្រាបថា ឮមកថា បុគ្គលដែលអញឃើញនោះ មិនមែនរុក្ខទេវតា ជាព្រះពោធិសត្វ បានឮថា ព្រះពោធិសត្វនោះ ឆាន់បិណ្ឌបាតនោះហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រះអង្គតាំងនៅបានដោយបិណ្ឌបាតនោះ ៧ សប្តាហ៍ ។ កាលនាងបានស្តាប់ដូច្នោះ ក៏រឭកបានថា ជាលាភរបស់អញហ្ន៎ ទើបកើតបីតិសោមនស្សយ៉ាងខ្លាំង ។ លុះតមក នាយចុន្ទបានស្តាប់ថា បានឮថា បិណ្ឌបាត ត្រាចុងក្រោយបង្អស់ដែលអញបានថ្វាយ អញបានកំពូលធម៌ហើយ បានឮថា ព្រះសាស្តាសោយបិណ្ឌបាតរបស់អញ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ រឭកបានថា ជាលាភរបស់អញហ្ន៎ ទើបកើតសោមនស្សដ៏ខ្លាំងក្លា គប្បីជ្រាបថា មានផលស្មើគ្នាដោយការរឭកដល់ ស្មើគ្នាយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **យសសំវត្តនិកំ** បានដល់ ប្រព្រឹត្តទៅដើម្បីបរិវារ ។ បទថា **អធិបតេយ្យសំវត្តនិកំ** បានដល់ ប្រព្រឹត្តទៅដើម្បីភាពជាធំ ។

[១២៧] បទថា **សញ្ញមតោ** បានដល់ អ្នកមានការសង្រួមដោយការសង្រួមក្នុងសីល អធិប្បាយថា តាំងនៅក្នុងសំវរៈ ។ បទថា **វេរំ ន ចីយតិ** បានដល់ មិនបង្កពៀរទាំង ៥ ។ បទថា **កុសលោ ច ជហាតិ ចាបកំ** សេចក្តីថា បុគ្គលដែលឈ្លាសបរិបូណ៌ដោយបញ្ញា រមែងលះបាបអកុសលដ៏លាមកដោយមិនទៅសល់ដោយអរិយមគ្គ ។ បទថា **រាគទោសមោហក្ខយា និព្ពុតោ**

សេចក្តីថា អ្នកឈ្មាសនោះ លះអកុសលដ៏លាមកនេះ ហើយនិព្វានដោយកិលេសនិព្វាន ព្រោះអស់កិលេស មានរាគៈជាដើម ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ពិចារណាឃើញទក្ខិណារបស់នាយចុន្ទ និងទក្ខិណេយ្យសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់បន្ទឺព្រះឧទាន ដោយប្រការដូច្នេះ ។

ចតុត្ថភាណវារ ចប់

ពោលអំពីដើមរាំងចាំងគូ

[១២៨] *ក្នុងបទថា* **មហតា ភិក្ខុសង្ឃេន សទ្ធឹ** *នេះ ចំនួនរបស់ភិក្ខុទាំងឡាយកំណត់ពិតមិនបាន ។ ពេលបានជ្រាបថា ចាប់ផ្តើមតាំងពីព្រះអង្គទ្រង់គ្របសង្កត់វេទនានៅឯវេឡុវគ្រាម មិនយូរឡើយ ព្រះមានព្រះភាគក៏នឹងបរិនិព្វាន បណ្តាភិក្ខុដែលមកពីទីនោះៗ មិនមាន សូម្បីតែភិក្ខុមួយរូប ដែលឈ្មោះថា ចៀសទៅ ព្រោះដូច្នោះ ទើបភិក្ខុសង្ឃមានចំនួនរាប់មិនបាន ។ បទថា* **ឧបវត្តនំ មល្លានំ សាលវនំ** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់យាងចាកត្រើយម្ខាងនៃស្ទឹងហិរញ្ញវតី ឆ្ពោះកាន់សាលវនោទ្យាន ដូចចេញអំពីត្រើយស្ទឹងកលម្ពនទី ទៅកាន់ថូបារាមតាមផ្លូវទ្វារវត្តរបស់ព្រះរាជមាតា ។ សាលវែននោះ នៅក្នុងក្រុងកុសិនារា ដូចថូបារាមរបស់ក្រុងអនុរាធបុរី ។ ផ្លូវចូលព្រះនគរតាមទ្វារទិសទក្សិណពីថូបារាម បែរមុខទៅទិសខាងកើត ឆៀងទៅទិសឧត្តរយ៉ាងណា សាលវែនអំពីព្រះរាជឧទ្យាន បែរមុខទៅទិសខាងកើត ឆៀងទៅទិសខាងជើង ក៏យ៉ាងនោះ ដូច្នោះ ទើបសាលវែននោះ លោកហៅថា* **ឧបវត្តន** *គឺផ្លូវកោង ។ បទថា* **អន្តរេ យមកសាលានំ ឧត្តរសីសកំ** *សេចក្តីថា បានឮ*

ថា ដើមសាលព្រឹកមួយជួរនៅខាងសីសៈព្រះដំណេក មួយជួរនៅខាងចុងព្រះបាទ ។ ក្នុងជួរដើមសាលព្រឹក្សនោះ ដើមសាលព្រឹក្សជំទង់មួយដើម នៅជិតខាងផ្នែកព្រះសីសៈ មួយដើមនៅជិតព្រះបាទ ។ ម្យ៉ាងទៀត លោកពោលថា ដើមសាលព្រឹក្សដែលឈរ ដើមប្រកៀកគ្នានឹងគ្នាដោយឫស ដើម ប្រគាបមែក និងស្លឹក ឈ្មោះថា **យមកសាល** ។ ដោយបទថា **មញ្ចកំ បញ្ញបេថ** លោកពោលថា បានឮថា ព្រះថេរៈបន្ទំក្នុងព្រះរាជឧទ្យាននោះមាន ទ្រង់សំដៅដល់ព្រះថេរនោះ ទ្រង់ត្រាស់ឲ្យក្រាល ។ ព្រះថេរៈក៏រៀបចំព្រះថេរនោះថ្វាយ ។ បទថា **កិលន្តោស្មិ អានន្ទ ឯបដ្ឋិស្សាមិ** សេចក្តីថា សេចក្តីពិត ក្នុងពាក្យនេះថា ត្រកូលដ៏វិរឈ្មោះ គោចរី កលាបៈ គង្គេយ្យៈ បិង្គលៈ បព្វតេយ្យកៈ ហេមវតៈ តម្ពៈ មន្ទាកិនី ឧបោសថ ឆទ្ទន្ត ជាគម្រប់ ១០ ទាំងនេះ ជាកំពូលរបស់ដ៏វិរទាំងឡាយ កម្លាំងយ៉ាងណារបស់ព្រះតថាគត មានកម្លាំងស្មើនឹងកម្លាំងរបស់ដ៏វិរប្រក្រតី ១ ពាន់កោដិ ដោយនយគុណបន្ថែមនឹង ១០ យ៉ាងនេះ គឺ កម្លាំងរបស់ដ៏វិរប្រក្រតី ដែលហៅថា ដ៏វិរគោចរី ១០ ស្មើនឹងកម្លាំងរបស់ដ៏វិរត្រកូលកលាបៈ ១ ជាដើម កម្លាំងទាំងអស់នោះ ក៏អស់ទៅ ដូចទឹកដែលជាក់ក្នុងធម្មក្រក តាំងអំពីវេលាដែលសោយបិណ្ឌបាតរបស់នាយចុន្ទ ។ តាំងអំពីនគរបាវាដល់នគរកុសិនារា ចម្ងាយផ្លូវ ៣ គាវុត ។ ក្នុងចន្លោះនេះ ព្រះមានព្រះភាគទ្រង់ឈប់សម្រាក ២៥ ដង ទ្រង់យាងមកដោយឧស្សាហ៍ធំ ស្តេចចូលកាន់សាលវន ក្នុងវេលាល្ងាចព្រះអាទិត្យទៀបអស្តង្គត ។ ព្រះរោគក៏មកបៀតបៀនការមិនមានរោគ ដោយប្រការដូច្នេះ ។ ដូចទ្រង់សម្តែងសេចក្តីនេះ កាលត្រាស់ព្រះវាចា ឲ្យកើតសេចក្តីសង្វេគដល់សត្វលោកទាំងពួង ទើបត្រាស់

ថា **កិលញ្ជោស្មិ អានន្ទ ឯបច្ឆិសុភ្ទាមិ** ម្នាលអានន្ទ តថាគតល្ហិតល្ហែណាស់ តថាគតនឹងសិង ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ យាងមកក្នុងទីនេះ ដោយឧស្សាហៈធំ មិនអាចទៅបរិនិព្វានក្នុងទីដទៃឬ ។ ឆ្លើយថា មិនអាចទៅបរិព្វានក្នុងទីដទៃក៏មិនមែន តែទ្រង់យាងមកក្នុងទីនេះដោយហេតុ ៣ ប្រការ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនេះថា កាលតថាគតបរិនិព្វានក្នុងទីដទៃ អត្ថុប្បត្តិ គឺហេតុកើតរឿងរបស់មហាសុទស្សនសូត្រនឹងមិនមាន តែកាលបរិនិព្វានក្នុងនគរកុសិនារាវហូតដល់បានសម្តែងសម្បត្តិ ដែលតថាគតគប្បីសោយក្នុងទេវលោក ដែលសោយហើយក្នុងមនុស្សលោក ប្រជាប់ដោយការណាវារ ២ ជនជាច្រើនស្តាប់ធម៌របស់តថាគតហើយ នឹងសម្គាល់កុសលថា គួរធ្វើ ។ មួយទៀត ទ្រង់ឃើញសេចក្តីដទៃទៀតថា កាលតថាគតបរិនិព្វានក្នុងទីដទៃ សុភទ្ទនឹងមិនបានចូលគាល់ ព្រោះសុភទ្ទនោះ ជាពុទ្ធ-វេនេយ្យ មិនមែនជាសាវកវេនេយ្យទ្បើយ សាវកទាំងឡាយមិនអាចណែនាំសុភទ្ទនោះបាន ។ តែតថាគតបរិនិព្វាន ក្នុងនគរកុសិនារា សុភទ្ទៈនោះក៏នឹងចូលគាល់សួរបញ្ហាបាន និងទីបំផុតការឆ្លើយបញ្ហា សុភទ្ទក៏តាំងនៅក្នុងសរណៈ បានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់តថាគត ទទួលកម្មដ្ឋានហើយ នឹងសម្រេចអរហត្ត ជាបច្ឆិមសាវកក្នុងកាលតថាគតនៅមានជីវិត ។ ទ្រង់ឃើញមួយប្រការទៀតថា កាលតថាគតបរិនិព្វានក្នុងទីដទៃ នឹងកើតជម្លោះ វិវាទគ្នាយ៉ាងធំ ក្នុងវេលាចែកព្រះធាតុ ឈាមក៏នឹងហូរដូចស្ទឹង តែកាលតថាគតបរិនិព្វានក្នុងនគរកុសិនារា ទោណព្រាហ្មណ៍នឹងរម្ងាប់វិវាទនោះ ហើយចែក

ព្រះធាតុទាំងឡាយ ។ គប្បីជ្រាបថា ព្រះមានព្រះភាគ យាងមកក្នុងទីនេះ ដោយព្រះឧស្សាហៈធំយ៉ាងនេះ ក៏ដោយហេតុ ៣ ប្រការនេះ ។

ក្នុងបទថា **សីហសេយ្យំ** ជំណេកមានយ៉ាង ៤ គឺ **កាមភោគិសេយ្យា បេតសេយ្យា សីហសេយ្យា តថាគតសេយ្យា** ។ ក្នុងសេយ្យាទាំង ៤ នោះ សេយ្យាដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបរិភោគកាម ច្រើនតែដេកផ្អៀងទៅខាងធ្វេង នេះឈ្មោះថា **កាមភោគិសេយ្យា** ព្រោះថា សត្វអ្នកបរិភោគកាម ឈ្មោះថា ដេកផ្អៀងខាងស្តាំដោយច្រើនមិនមាន ។ សេយ្យាដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រេតច្រើនតែដេកផ្ទារ[1] នេះឈ្មោះថា **បេតសេយ្យា** ព្រោះថា មានសាច់ និងឈាមតិច ពួកប្រេតត្រូវគ្រោងធ្អឹងរាវាំងមិនអាចដេកផ្អៀងបាន ទើបដេកផ្ទារតែម្យ៉ាង ។ សេយ្យាដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ សម្រេចការដេកដោយខាងៗ ស្តាំ ។បេ។ រមែងត្រេកអរ ដោយការមិនភ្ជាំងភ្ជាត់ និងយ្ជៀងយ្ជាតនៃកាយនេះ នេះឈ្មោះថា **សីហសេយ្យា** ព្រោះថា ជាសត្វមានអំណាចច្រើន សីហមិគរាជ ដេកដាក់ជើងមុខទាំងពីរទុកម្ខាង ដាក់ជើងក្រោយទាំងពីរទុកម្ខាង ស៊ីកកន្ទុយទុកត្រង់គល់ភ្ជៅ កំណត់ទីជើងមុខក្រោយ និងកន្ទុយ ដាក់ក្បាលលើជើងមុខទាំង ២ ដេកពេលថ្ងៃ កាលភ្ជាក់ ក៏ភ្ជាក់ដោយមិនតក់ស្ទុត ងើបក្បាល ពិនិត្យជើងមុខជាដើម បើដាក់ខុសកន្ថែងបន្តិច ក៏ទោមនស្សថា នេះមិនសមគួរដល់ជាតិ និងសេចក្តីក្ជៀវក្ជាវបស់ខ្លួន ក៏ដេកក្នុងទីនោះទៀត មិនចេញទៅចាប់ចំណី តែកាលឃើញមិនខុសកន្ថែង ក៏ត្រេកអរថា នេះសមគួរដល់ជាតិ និងសេចក្តី

---

[1] - បិដកខ្មែរ ប្រែថា មនុស្សស្ទាប់ ។

ក្បៀវក្ខារបស់ខ្លួន ហើយក្រោកឡើង រលាស់បៃបរាជសីហ៍ រលាស់កេសរ គឺសំណុំរោមត្រង់ក បន្ទឺសីហនាទ ៣ ដង ហើយចេញទៅចាប់ចំណី ។ ឯ សេយ្យាក្នុងឈានទី ៤ លោកហៅថា **តថាគតសេយ្យា** *ក្នុងសេយ្យាទាំង នោះ ក្នុងទីនេះ សំដៅដល់សីហសេយ្យា ព្រោះថា សីហសេយ្យានេះ ជា កំពូលសេយ្យា ព្រោះជាឥរិយាបថច្រើនដោយអំណាច ។ បទថា* **ចារេ ឯ ចារំ** *បានដល់ យកព្រះបាទឆ្វេងត្រួតលើព្រះបាទស្តាំ ។ បទថា* **ឧច្ចាឆាយ** *បានដល់ តម្រួតលើគ្នា គឺដាក់ហួសគ្នាទៅបន្តិច ។ កាលយកកព្រះបាទត្រួត លើកព្រះបាទ ឬយកជង្គង់ត្រួតលើជង្គង់ នឹងកើតវេទនាឡើង ចិត្តមិនមាន អារម្មណ៍តែមួយ ការដេកមិនសប្បាយ តែកាលតម្រួតលើគ្នា ឲ្យហួសគ្នា បន្តិច វេទនានឹងមិនកើត ចិត្តមានអារម្មណ៍តែមួយ ការដេកនឹងសប្បាយ ព្រោះដូច្នោះ ទើបដេកយ៉ាងនេះ ។ តែក្នុងទីនេះ ព្រោះទ្រង់ចូលដល់អនុដ្ឋាន-សេយ្យា ទើបលោកមិនពោលថា ទ្រង់មនសិការដល់ឧដ្ឋានសញ្ញា ។ ក្នុង ទីនេះ គប្បីជ្រាបអនុដ្ឋាន ការមិនក្រោកឡើងដោយអំណាចព្រះវរកាយ ។ តែ ព្រះមានព្រះភាគ ទ្រង់មិនមានឱកាសនៃភវង្គចិត្ត ផ្តុំលក់រហូតដល់អស់រាត្រី នោះឡើយ ពិតហើយ ក្នុងបឋមយាម មានការសម្តែងធម៌ប្រោសពួកមល្លក្សត្រ ក្នុងមជ្ឈិមយាមប្រោសសុភទ្ទ ក្នុងបច្ឆិមយាមទ្រង់ឲ្យឱវាទភិក្ខុសង្ឃ ក្នុង វេលាទៀបភ្លឺ ទ្រង់បរិនិព្វាន ។*

[១២៩] *បទថា* **សព្វជាលិកុល្លា** *សេចក្តីថា ដើមសាលព្រឹក្សទាំងគូ មានផ្ការីកស្គុះស្គាយជេរជាសទៅតាំងពីគល់រហូតដល់ចុង មិនមែនមានតែដើម សាលព្រឹក្សទាំងគូប៉ុណ្ណោះ សូម្បីដើមឈើទាំងអស់ ក៏បញ្ចេញផ្កាស្គុះស្គាយ*

ដូចគ្នា ។ មិនមែនតែក្នុងឧទ្យាននោះតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីក្នុងចក្រវាលទាំង ១ ម៉ឺន ឈើផ្កាក៏ចេញផ្កា ឈើផ្លែក៏ចេញផ្លែ ។ ក្នុងដើមឈើគ្រប់ដើម ឈូកថ្នាំងចេញផ្កាអំពីថ្នាំង ឈូកមែកចេញផ្កាអំពីមែក ឈូកវល្លិចេញផ្កាអំពីវល្លិ ឈូកអាកាសចេញផ្កាត្រង់អាកាស ទណ្ឌបទុមក៏ទម្លុះផែនដីរីកឡើងមក ។ មហាសមុទ្រទាំងអស់ ដេរដាសទៅដោយឈូក ៥ ពណ៌ ព្រៃហិមពាន្តទំហំ ៣០០០ យោជន៍ បានជាទីរីករាយក្រៃលែងពេកដូចកន្ទុយក្អែក ដែលត្រជាងជាប់គ្នាជាផ្ទាំង ដូចកម្រង និងចង្កោមផ្កាជាប់គ្នាមិនមានចន្លោះ ដូចផ្កាប្រជាប់សីសៈ ដែលចងជ្រៀតគ្នាយ៉ាងល្អ និងដូចប្រអប់ដែលមានផ្កាឈើពេញ ។ បទថា **តេ តថាគតស្ស សរីរំ ឱកិរន្តិ** *សាលព្រឹក្សទាំងគូនោះ ត្រូវភូម្មទេវតាអង្រែនដើម មែក និងប្រគាប រោយចុះកាន់ព្រះសរីរៈព្រះមានព្រះភាគ គឺរោយផ្កាចុះលើព្រះសរីរៈ ។ បទថា* **អវ្ឋោកិរន្តិ** *រោយរាយចុះ ហាក់ដូចជន់លិច ។ បទថា* **អភិប្បកិរន្តិ** *បានដល់ បាចសាចចុះញយៗ គឺរឿយៗ ។ បទថា* **ទិព្វានិ** *បានដល់ ដែលកើតក្នុងនន្ទបោក្ខរណី ផ្កាមណ្ឌារៈទាំងនោះ មានពណ៌ដូចមាស មានស្វ័យប្រមាណប៉ុនឆត្រស្វ័យឈើ ។ ជាប់រេណូប្រមាណ ១ នាឡិធំ មិនមែនផ្កាមណ្ឌារៈតែម្យ៉ាងប៉ុណ្ណោះទេ ដែលជាទិព្វនោះ សូម្បីផ្កាដទៃក៏ជាទិព្វ ដូចផ្កាបារិច្ឆត្តកៈ គឺផ្កាវល្លិសផ្នងជាដើម ដែលទេវតានៅត្រង់កណ្តាប់ចក្រវាលក្តី ស្ថានតាវត្តិង្សក្តី ក្នុងព្រហ្មលោកក្តី ជាក់ពេញប្រអប់មាសនាំចូលទៅ រមែងធ្លាក់ចុះត្រង់អាកាស ។ បទថា* **តថាគតស្ស សរីរំ** *សេចក្តីថា មិនខ្ចាត់ខ្ចាយចេញក្នុងចន្លោះ មករោយរាយចំពោះព្រះសរីរៈនៃព្រះតថាគត ដោយត្របកកេសរ និងល្អងរេណូ ។ បទថា* **ទិព្វានិបិ ចន្ទន-**

ចុណ្ណានិ បានដល់ លម្អិតខ្វឹមចនួន៍ដែលធ្វើសម្រេចហើយរបស់ពួកទេវតា ។ មិនមែនតែលម្អិតខ្វឹមចនួន៍ ដែលជារបស់ទេវតាប៉ុណ្ណោះទេ ជារបស់នាគ គ្រុឌ និងមនុស្សផងដែរ ។ មិនមែនលម្អិតខ្វឹមចនួន៍តែម្យ៉ាងប៉ុណ្ណោះទេ នៅមានលម្អិតគន្ធជាតដែលជាទិព្វទាំងអស់ ដូចជាក្រស្នា និងចនួន៍ក្រហមជាដើម ។ លម្អងហរតាល កម្រងប្រាក់ និងមាស ដែលអប់ដោយក្លិនទិព្វទាំងអស់ ដែលទេវតានៅត្រង់កណ្តាប់ចក្រវាលជាដើម ជាក់ពេញប្រអប់ប្រាក់ និងប្រអប់មាសនាំចូលទៅ មិនរាត់រាយចេញក្នុងចន្លោះ រោយចុះកាន់ព្រះសរីរៈ របស់ព្រះតថាគតដូចគ្នា ។ បទថា **ឧព្វានិបិ តុរិយានិ** បានដល់ គ្រឿងប្រគំរបស់ពួកទេវតា ។ មិនមែនតែគ្រឿងប្រគំទាំងនោះទេ នៅមានគ្រឿងប្រគំរបស់ពួកទេវតាក្នុងចក្រវាល ១ ម៉ឺន នាគ គ្រុឌ មនុស្ស មានប្រភេទខ្សែពាសស្បែកក្រាស់ និងប្រហោងគ្រប់ប្រភេទ គប្បីជ្រាបថា ប្រជុំគ្នាក្នុងចក្រវាលតែមួយ បន្ទឹក្នុងអាកាស ។ បទថា **ឧព្វានិបិ សង្ខីតានិ** សេចក្តីថា បានញ្ចថា ពួកទេវតាដែលមានអាយុវែង ឈ្មោះថា វរុណ ទេវតាវរុណទាំងនោះ ជ្រាបថា ព្រះមហាបុរសកើតក្នុងដែនដីមនុស្ស នឹងបានជាព្រះពុទ្ធ ហើយផ្តើមក្រងកម្រងផ្ការដោយបំណងថា នឹងកាន់ទៅក្នុងថ្ងៃបដិសន្ធិ ។ ទេវតានោះ កំពុងក្រងកម្រងផ្ការ ជ្រាបថា ព្រះមហាបុរសកើតក្នុងគភ៌របស់មាតា ត្រូវសួរថា ពួកលោកក្រងកម្រងផ្ការ ដើម្បីអ្នកណា ឆ្លើយថា នៅមិនទាន់សម្រេចហើយប្រាប់ថា ពួកយើងក្រងស្រេចហើយ នឹងយកទៅក្នុងថ្ងៃស្តេចប្រសូតហើយជ្រាបថា ទ្រង់ប្រសូតចាកព្រះគភ៌ហើយ គិតថា នឹងទៅក្នុងថ្ងៃស្តេចចេញមហាភិនេស្ក្រមណ៍ ក៏បានជ្រាបថា ព្រះមហាបុរសទ្រង់គ្រប់គ្រងផ្ទះ ២៩

វស្សា ហើយថ្ងៃនេះ ក៏ស្តេច ចេញមហាកិនេស្រុកមណ៌ ហើយគិតថា នឹងទៅ ក្នុងថ្ងៃត្រាស់ដឹង ក៏ជ្រាបថា ទ្រង់ធ្វើសេចក្តីព្យាយាមធំរហូតដល់អស់ ៦ វស្សា ថ្ងៃនេះក៏ត្រាស់ដឹងហើយ គិតថា នឹងទៅក្នុងថ្ងៃប្រកាសធម្មចក្រ ក៏ ជ្រាបទៀតថា ប្រថាប់ត្រង់ពោធិមណ្ឌលដ្ឋាន ៧ សប្តាហ៍ ស្តេចទៅកាន់ឥសិ-បតនមិគទាយវ័ន ប្រកាសព្រះធម្មចក្រហើយ ក៏គិតថា នឹងទៅថ្ងៃដែលទ្រង់ សម្តែងយមកបាដិហារ្យ ក៏ជ្រាបថា ថ្ងៃនេះ ទ្រង់ធ្វើយមកប្បាដិហារ្យរួចហើយ គិតថា នឹងទៅក្នុងថ្ងៃស្តេចចុះអំពីទេវលោក ជ្រាបថា ថ្ងៃនេះ ស្តេចចុះអំពី ទេវលោកហើយ គិតថា នឹងទៅថ្ងៃទ្រង់ដាក់អាយុសង្ខារ ជ្រាបថា ថ្ងៃនេះ ទ្រង់ដាក់អាយុសង្ខារហើយ គិតថា នៅធ្វើមិនទាន់ស្រេច ក៏គិតនឹងទៅក្នុងថ្ងៃ បរិនិព្វាន ជ្រាបថា ថ្ងៃនេះ ព្រះមានព្រះភាគទ្រង់ផ្ទុំដោយសីហសេយ្យាផ្អៀងស្តាំ ត្រង់ចន្ទោះសាលព្រឹក្សទាំងគូ មានព្រះសតិសម្បជញ្ញៈ នឹងបរិនិព្វានវេលាជិតភ្លឺ មានសំឡេងសួរថា ពួកលោកក្រងកម្រងផ្កាដើម្បីអ្នកណា ក៏ពោលថា នែ លោក ថ្ងៃនេះឯង ព្រះមហាបុរសទ្រង់បដិសន្ធិ ក្នុងព្រះគភ៌របស់មាតា ថ្ងៃនេះ ក៏ចេញចាកព្រះគភ៌របស់មាតា ថ្ងៃនេះក៏ស្តេចចេញមហាកិនេស្រុកមណ៌ ថ្ងៃ នេះក៏បានត្រាស់ជាព្រះពុទ្ធ ថ្ងៃនេះក៏ប្រកាសព្រះធម្មចក្រ ថ្ងៃនេះក៏សម្តែង យមកប្បាដិហារ្យ ថ្ងៃនេះក៏ស្តេចចុះចាកទេវលោក ថ្ងៃនេះក៏ទ្រង់ដាក់អាយុ សង្ខារ ជ្រាបថា ថ្ងៃនេះក៏ស្តេចនឹងបរិនិព្វាន ព្រះអង្គគប្បីទ្រង់តាំងនៅត្រឹមមួយ ហុតបបរ ក្នុងថ្ងៃទី ២ ឬមិនមែនទេ ប្រការនេះ មិនសមគួរដល់ព្រះអង្គ ដែលទ្រង់បំពេញបារមី ១០ ហើយសម្រេចភាពជាព្រះពុទ្ធ អញត្រូវតែកាន់ យកកម្រងផ្កាដែលធ្វើមិនទាន់ស្រេចមក កាលមិនបានឱកាសខាងក្នុងចក្រ-

វាល ក៏បានបំពាក់លើកណ្តាប់ចក្រវាល ហែទៅតាមកណ្តាប់ចក្រវាល យកដៃផ្តុំនឹងដៃឲ្យក្រពុំ ប្រៀងប្រារព្ធព្រះរតនត្រ័យ ប្រារព្ធមហាបុរិសលក្ខណៈ ៣២ ព្រះឆព្វណ្ណរង្សី ៦ បារមី ១០ ជាតក ៥៥០ ពុទ្ធញ្ញាណ ១៤ ក្នុងទីបំផុតនៃព្រះពុទ្ធគុណនោះៗ ក៏ត្រូវលះបង់ទៅ ។ លោកអាស្រ័យសង្គីតនោះ ទើបពោលពាក្យនេះថា **ឥញ្ជានិបិ សង្គីតានិ អន្តលិក្ខេ វត្តន្តិ តថាគតស្ស បូជាយ** *ចម្រៀងជាទិព្វ ក៏លាន់ឮឯអាកាស ដើម្បីបូជាតថាគត ដូច្នេះ ។*

ឯព្រះមានព្រះភាគ ផ្ទំផ្អៀងខាងស្តាំ ចន្លោះដើមសាលព្រឹក្សទាំងគូ ទ្រង់ឃើញឧស្សាហៈយ៉ាងធំ របស់បរិស័ទដែលប្រជុំគ្នាតាំងពីលើផែនដី រហូតដល់កណ្តាប់ចក្រវាល និងតាំងពីកណ្តាប់ចក្រវាលរហូតដល់ព្រហ្មលោក ទើបត្រាស់ប្រាប់ព្រះអានន្ទ ។ ដោយហេតុនោះ ទើបលោកពោលថា **អថខោ ភគវា អាយស្មន្តំ អានន្ទំ ។បេ។ តថាគតស្ស បូជាយ ។** *កាលទ្រង់សម្តែងមហាសក្ការៈយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងភាពដែលព្រះអង្គជាអ្នកដែលបរិស័ទមិនសក្ការៈ ដោយមហាសក្ការៈទាំងនោះ ទើបត្រាស់ថា* **ន ខោ អានន្ទ ឯត្តាវតា** *ជាដើម ។ លោកអធិប្បាយទុកយ៉ាងនេះថា ម្នាលអានន្ទ តថាគតក្រាបទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមថាទីបង្ករ សមោធានធម៌ ៨ ប្រការ កាលនឹងធ្វើអភិនីហារ មិនមែនធ្វើអភិនីហារដើម្បីប្រយោជន៍ដល់ផ្តាកម្រងគ្រឿងក្រអូប តូរ្យតន្ត្រី និងចម្រៀង មិនមែនបំពេញបារមីទាំងឡាយដើម្បីប្រយោជន៍ដល់វត្ថុទាំងនោះឡើយ ព្រោះដូច្នោះ តថាគតមិនឈ្មោះថាគេបូជាហើយ ដោយការបូជាទាំងនេះឡើយ ។ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់សរសើរវិបាក ដែលសូម្បីព្រះពុទ្ធញ្ញាណ ក៏កំណត់មិនបាន*

នៃការបូជា ដែលបុគ្គលកាន់យកត្រឹមតែផ្កាកប្បាសមួយផ្កា រឭកដល់ព្រះពុទ្ធគុណបូជាហើយទុកក្នុងទីដទៃ ក្នុងទីនេះ បែរជាទ្រង់ជំទាស់ការបូជាធំយ៉ាងនេះ ។ ឆ្លើយថា ព្រោះដើម្បីទ្រង់អនុគ្រោះបរិស័ទ ១ ដើម្បីប្រាថ្នានឹងឲ្យព្រះសាសនាតាំងនៅអស់កាល ១ ។ ពិតហើយ ព្រះមានព្រះភាគ បើមិនជំទាស់យ៉ាងនោះសោត ក្នុងអនាគត ពុទ្ធបរិស័ទក៏មិនបំពេញសីល ក្នុងហាន: ដែលសីលមកដល់ នឹងមិនឲ្យសមាធិបរិបូណ៌ ក្នុងហាន:ដែលសមាធិមកដល់ មិនឲ្យកាន់បន្ទប់ គឺ វិបស្សនា ក្នុងហាន:ដែលវិបស្សនាមកដល់ បបួលហើយ បបួលទៀត នូវឧបដ្ឋាក ធ្វើការបូជាតែម្យ៉ាង ។ ពិតហើយ ឈ្មោះថា អាមិសបូជានោះ មិនអាចនឹងធ្វើព្រះសាសនាឲ្យតាំងនៅ សូម្បីត្រឹមមួយថ្ងៃ ឬត្រឹមមួយហុតបបរ ។ ពិតហើយ វិហារវាប់ពាន់ ដូចមហាវិហារ ចេតិយវាប់ពាន់ចេតិយ ដូចមហាចេតិយ ក៏តម្កល់ព្រះសាសនាទុកមិនបាន ។ បុណ្យអ្នកណាធ្វើទុក ក៏ជារបស់បុគ្គលនោះឯង ។ ចំណែកសម្មាបដិបត្តិ ឈ្មោះថាការបូជាដែលសមគួរដល់ព្រះតថាគត ។ សេចក្តីពិត បដិបត្តិបូជានោះ ឈ្មោះថា តាំងនៅហើយ អាចញ៉ាំងព្រះសាសនាទុកបាន ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបដិបត្តិបូជានោះ ទើបត្រាស់ថា **យោ ខោ អានន្ទ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ធម្មានុធម្មប្បដិបន្នោ** *បានដល់ បដិបត្តិបុព្វភាគប្បដិបទា ដែលជាធម៌សមគួរ ។ បដិបទានុ៎ះឯង លោកហៅថា* **សាមីចិ** *គឺប្រពៃក្រៃលែង ព្រោះជាបដិបទាដែលសមគួរ ។ ឈ្មោះថា* **សាមីចិប្ប-ដិបន្នោ** *ព្រោះបដិបត្តិធម៌ដ៏ប្រពៃក្រៃលែង ។ ឈ្មោះថា* **អនុធម្មចារី** *ព្រោះប្រព្រឹត្តបំពេញធម៌ដ៏សមគួរ ពោល គឺបុព្វភាគប្បដិបទានោះឯង ។ សីល*

អាចារប្បញ្ញត្តិ ការសមាទានធុតង្គ សម្មាបដិបទា រហូតដល់គោត្រភូញ្ញាណ គប្បីជ្រាបថា បុព្វភាគបដិបទា ។ ព្រោះដូច្នោះ ភិក្ខុតាំងនៅក្នុងអគារវៈ ៦ កន្ទង ព្រះបញ្ញត្តិ ចិញ្ចឹមជីវិតដោយអនេសនា ភិក្ខុនេះ ឈ្មោះថា មិនបដិបត្តិធម៌សមគួរដល់ធម៌ ចំណែកភិក្ខុណាមិនកន្ទងសិក្ខាបទ ដែលទ្រង់បញ្ញត្ត ហើយដល់ខ្លួនទាំងអស់ ដែលកម្រិតព្រំដែន និងជាខ្សែបន្ទាត់របស់ព្រះជិនស្រី សូម្បីមានប្រមាណតិច ភិក្ខុនេះ ឈ្មោះថា បដិបត្តិធម៌សមគួរដល់ធម៌ ។ សូម្បីក្នុងភិក្ខុនី ក៏នយនេះដូចគ្នា ។ ឧបាសកណាធ្វើពៀរវេរា ៥ អកុសលកម្មបថ ១០ ប្រព្រឹត្តស៊ប់សួន ឧបាសកនេះ ឈ្មោះថា មិនបដិបត្តិធម៌សមគួរដល់ធម៌ ។ ចំណែកឧបាសក បដិបត្តិឲ្យបរិបូណ៌ក្នុងសរណៈ ៣ សីល ៥ សីល ១០ រក្សាឧបោសថមួយខែ ៨ ដង ថ្វាយទាន បូជាដោយគ្រឿងក្រអូប បូជាដោយមាលា ទំនុកបម្រុង មាតាបិតា ទំនុកបម្រុងសមណព្រាហ្មណ៍ ឧបាសកនេះ ឈ្មោះថា ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ សូម្បីក្នុងឧបាសិកា ក៏នយនេះ ដូចគ្នា ។ បទថា **បរមាយ បូជាយ** *ប្រែថា ដោយការបូជាដ៏ឧត្តម ។ ព្រះមានព្រះភាគទ្រង់សម្តែងថា ពិតហើយ ឈ្មោះថា និរាមិសបូជានេះ អាចតម្កល់ព្រះសាសនារបស់តថាគតទុកបាន ។ ពិតហើយ បរិស័ទ ៤ នេះ នឹងបូជាតថាគតដោយការបូជានេះត្រឹមណា សាសនារបស់តថាគត ក៏នឹងរុងរឿងដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត អណ្តែតក្នុងលម្ហ ដូច្នោះ ។*

[๑๓๐] *បទថា* **អបសาเรสิ** *ប្រែថា ចូរចេញទៅ ។ បទថា* **អបេหิ** *ប្រែថា ចូរចៀសចេញទៅ ។ ដោយព្រះតម្រាស់តែមួយព្រះឱស្ឋប៉ុណ្ណោះ ព្រះថេរៈក៏ជាក់ផ្ចិតស្លឹកត្នោត ហើយឈរក្នុងចំណែកម្ខាង ។ ព្រះមានព្រះភាគ*

ទ្រង់សំដៅយក កាពដែលព្រះអង្គមិនមានឧបដ្ឋាកប្រចាំក្នុងបឋមពោធិកាល ទើបត្រាស់ពាក្យនេះថា **ឧបដ្ឋាកោ** ជាដើម ។ កាលព្រះថេរៈទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧបវាណមានអាយុ ។ ព្រះអានន្ទកំណត់កាព ដែលព្រះឧបវាណមានកំហុសថា ណ្ហើយចុះ អញនឹងក្រាបទូលសេចក្តីដែល ព្រះឧបវាណនោះមិនមានកំហុស ទើបព្រះមានព្រះភាគត្រាស់ថា **យេភុយ្យេន អានន្ទ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **យេភុយ្យេន** នេះ លោកពោលសំដៅយកអសញ្ញីសត្វ និងអរូបទេវតាត្រូវព្រងើយ ។ បទថា **អប្ផុដោ** បានដល់ មិនប៉ះពាល់ ឬមិនបានពាល់ត្រូវ ។ បានឮថា ក្នុងទីជិតព្រះមានព្រះភាគ ទេវតាអ្នកមានសក្តិធំ និម្មិតអត្តភាពដ៏ល្អិតក្នុងឱកាសប៉ុនចុងរោមទ្រាយ ១០ អង្គុ ។ ខាងមុខនៃទេវតា ១០ អង្គុ នោះ មានទេវតា ២០ អង្គុ ។ ខាងមុខទេវតា ២០ អង្គុ មានទេវតា ៣០ អង្គុ ខាងមុខទេវតា ៣០ អង្គុ មានទេវតា ៤០ អង្គុ ខាងមុខទេវតា ៤០ អង្គុ មានទេវតា ៥០ អង្គុ ខាងមុខទេវតា ៥០ អង្គ មានទេវតាឈរគាល់ ៦០ អង្គុ ទេវតាទាំងនោះ ជ្រៀតគ្នានឹងគ្នាដោយដៃជើង ឬសំពត់ ។ មិនមានហេតុដែលនឹងគប្បីពោលថា ចេញទៅកុំជ្រៀតបៀតខ្ញុំ ។ ទេវតាទាំងឮយ៉ាយក៏ដូចគ្នា នឹងដែលត្រាស់ថា ម្នាលសារីបុត្រ ឯពួកទេវតាទាំងនោះ មានចំនួន ១០ អង្គុខ្វះ ២០ អង្គុខ្វះ ៣០ អង្គុខ្វះ ៤០ អង្គុខ្វះ ៥០ អង្គុខ្វះ ៦០ អង្គុខ្វះ ឈរក្នុងឱកាស ល្មមចាក់ដោយចុងម្ជុលបាន តែមិនជ្រៀតបៀតដល់គ្នានឹងគ្នាឡើយ ។ បទថា **ឱរោរេន្តោ** គឺឈរជាំង ។ បានឮថា ព្រះថេរៈរាងកាយធំដូចជាកូនដំរី ដណ្តប់សំពត់បង្សុកូលក៏មើលទៅដូចធំសម្បើមណាស់ ។ បទថា **តថាគតស្ស ឧស្សន្នាយ** សេចក្តី

ថា ទេវតាទាំងឡាយ កាលមិនបានឃើញព្រះភក្ត្រព្រះមានព្រះភាគ ទើបតិះដៀលយ៉ាងនេះ ។ សួរថា ទេវតាទាំងនោះ មិនអាចមើលឆ្លុះព្រះថេរៈឬ ។ ឆ្លើយថា មិនអាចទេ ។ ព្រោះថា ពួកទេវតាអាចមើលឆ្លុះពួកបុថុជ្ជនបាន តែមើលមិនអាចមើលឆ្លុះព្រះខីណាស្រពបានឡើយ ទាំងមិនអាចចូលទៅជិតផង ។ ព្រោះព្រះថេរៈមានអានុភាពច្រើន មានអំណាចច្រើន ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈមានអំណាចច្រើន អ្នកដទៃមិនជាព្រះអរហន្តឬ ឆ្លើយថា ព្រោះលោកជាអារក្ខទេវតានៅក្នុងចេតិយរបស់ព្រះពុទ្ធកស្សប ។ បានឮមកថា កាលព្រះវិបស្សីសម្មាសម្ពុទ្ធបរិនិព្វានហើយ ជនទាំងឡាយបាននាំគ្នាសាងព្រះចេតិយមួយបញ្ចុះព្រះសារីរធាតុ ដែលដូចគ្នានឹងដុំមាស ។ ពិតហើយ ព្រះពុទ្ធដែលមានព្រះជន្មាយុវែងរមែងមានព្រះចេតិយតែមួយប៉ុណ្ណោះ មនុស្សទាំងឡាយប្រើឥដ្ឋមាសបណ្តាយ ១ ហត្ថ ទទឹងមួយចំអាម កម្រាស់ ៨ ធ្នាប់សាងព្រះចេតិយនោះ ក្បាប់ដោយហរិតាល និងមនោសិលាជំនួសជីឥដ្ឋ លាយដោយប្រេងល្ងជំនួសទឹក ហើយស្ថាបនាប្រមាណមួយយោជន៍ ។ តពីនោះ កុម្ភទេវតាក៏មួយយោជន៍ តពីនោះ អាកាសដ្ឋកទេវតា តពីនោះ ឧណ្ហវលាហកទេវតា តពីនោះ ក៏អព្ភវលាហកទេវតា តពីនោះ ទេវតាជាន់ចាតុម្មហារាជ តពីនោះ ទេវតាជាន់តាវត្តិង្ស ស្ថាបនាមួយយោជន៍ ។ ទើបព្រះចេតិយមាន ៧ យោជន៍ ដោយប្រការដូច្នេះ ។

កាលមនុស្សកាន់យកផ្កាកម្រង គ្រឿងក្រអូប និងសំពត់ជាដើមមក អារក្ខទេវតាទាំងឡាយ ក៏នាំគ្នាកាន់ផ្កាបូជាព្រះចេតិយ ទាំងដែលមនុស្សទាំងនោះក៏បានឃើញ ។ កាលនោះ ព្រះថេរៈនេះ ជាព្រាហ្មណ៍មហាសាល កាន់

សំពត់លៀងមួយផ្ទាំងទៅ ។ ទេវតាក៏ទទួលសំពត់អំពីដៃព្រាហ្មណ៍នោះ ទៅបូជាព្រះចេតិយ ។ ព្រាហ្មណ៍យើញដូច្នោះ ក៏មានចិត្តជ្រះថ្លា តាំងសេចក្តីប្រាថ្នាថា ក្នុងអនាគតកាល អញក៏សូមបានជាអារក្ខទេវតាក្នុងព្រះចេតិយរបស់ព្រះពុទ្ធមានអានុភាពបែបនេះ ដូច្នេះហើយ ចុតិអំពីអត្តភាពនោះ ក៏ទៅកើតក្នុងទេវលោក ។ កាលព្រាហ្មណ៍នោះអន្ទោលនៅ ក្នុងមនុស្សលោក និងទេវលោក ព្រះកស្សបដ៏មានព្រះភាគ ទ្រង់កើតឡើងលោក ហើយបរិនិព្វាន ។ ព្រះសរីរធាតុរបស់ព្រះអង្គ ក៏មានតែមួយកន្ទែងប៉ុណ្ណោះ ។ មនុស្សទាំងឡាយនាំព្រះសារីរធាតុនោះ សាងព្រះចេតិយមួយយោជន៍ ។ ព្រាហ្មណ៍ជាអារក្ខ-ទេវតាក្នុងព្រះចេតិយនោះ កាលព្រះសាសនាអន្តរធានទៅ ក៏កើតក្នុងឋានសួគ៌ក្នុងសាសនារបស់ព្រះមានព្រះភាគនៃយើង ចុតិអំពីឋានសួគ៌នោះហើយ ក៏បដិសន្ធិក្នុងត្រកូលធំ ចេញបួសហើយ សម្រេចអរហត្ត ។ គប្បីជ្រាបថាព្រះថេរៈមានអំណាចច្រើន ព្រោះជាអារក្ខទេវតា ក្នុងព្រះចេតិយមកហើយដោយប្រការដូច្នេះ ។

ដោយបទថា **ទេវតា អានន្ទ ទុជ្ជាយន្តិ** ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលអានន្ទ ពួកទេវតាតិះដៀល មិនមែនបុត្រតថាគតមានកំហុសអ្វីដទៃទេ ។ ព្រោះហេតុអ្វី ទើបព្រះអានន្ទទូលថា បពិត្រព្រះមានព្រះភាគដ៏ចម្រើនចុះពួកតេវតា ធ្វើទុកក្នុងចិត្តដូចម្តេច សេចក្តីថា បពិត្រព្រះមានព្រះភាគ ព្រះអង្គត្រាស់ថា ពួកទេវតាតិះដៀល ពួកទេវតានោះដូចម្តេច ទើបធ្វើទុកក្នុងចិត្តនឹងបញ្ឈប់បរិនិព្វានរបស់ព្រះអង្គឬ ។ កាលបើដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងភាវៈដែលពួកទេវតាទាំងនោះ បញ្ឈប់មិនបានថា តថាគត

มิនពោលហេតុនៃការបញ្ឈប់ ទើបត្រាស់ថា **សន្តានេ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **អាកាសេ បថវី សញ្ញិនិយោ** *បានដល់ និមិត្តផែនដីក្នុងអាកាស មានការសម្គាល់ក្នុងអាកាសនោះថា ជាផែនដី ។ បទថា* **កន្ទន្តិ** *ប្រែថា ស្រែកយំ ។ បទថា* **និន្នថានំ វិយ បបតន្តិ** *បានដល់ រលំដួលចុះដូចជាច់ត្រង់ពាក់កណ្តាលខ្លួន ។ បទថា* **វិវដ្តន្តិ** *បានដល់ ដួលចុះ រមៀលទៅ ។ ម្យ៉ាងទៀត រលំប្រមៀលទៅទីខាងមុខ ទីខាងក្រោយ ទីខាងឆ្វេង ទីខាងស្តាំ ហៅថា បម្រះននៀល ។ បទថា* **សន្តានេ ទេវតា បថវិយំ បថវីសញ្ញិនិយោ** *សេចក្តីថា បានឮថា ពួកទេវតាមិនអាចទប់ខ្លួនបានលើផែនដីប្រក្រតី ។ ពួកទេវតា រមែងលិចចុះក្នុងផែនដីនោះ ដូចហត្ថកព្រហ្ម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលហត្ថក: អ្នកចូរនិមិ្តនូវអត្តភាពយ៉ាងគ្រោតគ្រាត ។ ព្រោះដូច្នោះ លោកសំដៅយកពួកទេវតាដែលនិមិ្តផែនដីក្នុងផែនដី ទើបពោលថា ពួកទេវតាមានការសម្គាល់ក្នុងផែនដីថាជាផែនដី ។ បទថា* **វីតរាគា** *បានដល់ ពួកទេវតាដែលជាព្រះអនាគាមី និងព្រះខីណាស្រព ដែលមានទោមនស្សរលះបានហើយ ដូចគ្នានឹងសសរឫ ។*

[๑๓๑] *បទថា* **វស្សំ វុត្ថា** *សេចក្តីថា បានឮថា គ្រាពុទ្ធកាល ភិក្ខុប្រជុំគ្នា ๒ ពេល គឺ ជិតចូលវស្សាដើម្បីទទួលកម្មដ្ឋាន ๑ ចេញវស្សាហើយដើម្បីប្រាប់នូវគុណវិសេសដែលកើត ព្រោះការប្រកបរឿយៗ នូវព្រះកម្មដ្ឋាន ដែលទទួលមកហើយ ๑ ។ គ្រាព្រះពុទ្ធកាល យ៉ាងណា សូម្បីក្នុងកោះសីហឡៈក៏ដូច្នោះ ។ ភិក្ខុដែលនៅខាងត្រើយទន្លេគង្គាឯណោះ ប្រជុំគ្នាក្នុងលោហប្រាសាទ ភិក្ខុដែលនៅខាងត្រើយទន្លេគង្គាមួយទៀត ក៏ប្រជុំគ្នាក្នុង*

តិស្សមហាវិហារ ។ ក្នុងភិក្ខុទាំង ២ ពួកនោះ ភិក្ខុដែលនៅខាងត្រើយទន្លេគង្គា ឯណោះ កាន់យកអំបោសសម្រាប់បោសសំរាមចោលហើយ ប្រជុំគ្នាក្នុងមហាវិហារ បូកបាយអព្រះចេតិយ ចេញវស្សាហើយ ក៏មកប្រជុំគ្នាត្រង់លោហប្រាសាទ ធ្វើវត្តនៅក្នុងទីដែលសប្បាយ ចេញវស្សាហើយក៏មកសូត្របាលី និងអដ្ឋកថា ដែលខ្ជួនជំនាញហើយក្នុងសាលារៀននិកាយទាំង ៥ ក្នុងលោហប្រាសាទ ។ ពិចារណាដល់ភិក្ខុដែលរៀនបាលី ឬអដ្ឋកថាខុសក្ងាត់ថា លោករៀនក្នុងសម្នាក់អ្នកណា ឲ្យកាន់យកឲ្យត្រង់ ។ ចំណែកភិក្ខុដែលនៅម្ខាង ទន្លេគង្គាទៀត ក៏ប្រជុំគ្នាក្នុងតិស្សមហាវិហារ បណ្តាភិក្ខុដែលប្រជុំគ្នា ២ ពេលយ៉ាងនេះ ភិក្ខុពួកណារៀនកម្មដ្ឋានមុនចូលវស្សា ទៅហើយត្រឡប់មកប្រាប់គុណវិសេស លោកសំដៅយកភិក្ខុបែបនោះ ទើបពោលថា **បុព្ពេ ភត្តេ វស្សំវុត្ថា** ជាដើម ។ បទថា **មនោភាវនីយេ** បានដល់ ឲ្យចម្រើនហើយ អប់រំហើយដោយចិត្ត អធិប្បាយថា ភិក្ខុពួកណាចម្រើន កពូននូវមនោមនៈបន្សាត់កិលេសដូចធូលី មានរាគៈជាដើមចោល ភិក្ខុបែបនោះ ។ បានឮថា ព្រះថេរៈដល់ព្រមដោយវត្ត ជួបភិក្ខុចាស់ ក៏មិនព្រមអង្គុយ ក្រោកទៅទទួលឆត្រ ជាត្រ ចីវរ និងគោះតាំងប្រគេន កាលលោកអង្គុយក្នុងទីនោះហើយ ក៏ធ្វើវត្ត រៀបចំសេនាសនៈប្រគេន ជួបភិក្ខុបួសថ្មី ក៏មិននៅអង្គុយស្ងៀមចូលទៅជិតៗ ព្រះថេរៈនោះ ប្រាសចាកការមិនសាបសូន្យនៃវត្តបដិបត្តិនោះ ទើបពោលយ៉ាងនេះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា អានន្ទគិតថា អញនឹងមិនបានជួបភិក្ខុដែលគួរត្រេកអរ ណ្តើយចុះ តថាគតនឹងប្រាប់ស្ថានទីនឹងជួបភិក្ខុដែលគួរត្រេកអរដល់អានន្ទ ដែលគេមិនចាំបាច់ ត្រូវគ្រាច់ចរ

ទៅមក ក៏នឹងអាចជួបភិក្ខុដែលគួរត្រេកអរបាន ដូច្នេះ ទើបត្រាស់ថា **ចត្តារិ មានិ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **សទ្ធុស្ស** *សេចក្តីថា វត្តទាំងអស់ មានចេតិយង្គណវត្តជាដើម ដែលលោកធ្វើតាំងពីព្រឹក រមែងប្រាកដដល់កុលបុត្រ ដែលមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធជាដើម ដែលបរិបូណ៌ដោយវត្ត ។ បទថា* **ឧស្សន្នីយានិ** *បានដល់ គួរនឹងឃើញ គឺគួរទៅដើម្បីឃើញ ។ បទថា* **សំវេជនីយានិ** *បានដល់ ឲ្យកើតសេចក្តីសង្វេគ ។ បទថា* **ឋានានិ** *បានដល់ ហេតុ ឬស្ថានទី ។ បទថា* **យេ ហិ កេចិ** *នេះ លោកពោលដើម្បីសម្តែងដល់ការចារិកទៅក្នុងចេតិយដែលមានប្រយោជន៍ ។ បណ្តាបទទាំងនោះ ដោយបទថា* **ចេតិយចារិកំ អាហិណ្ឌន្តា** *លោកសម្តែងថា ភិក្ខុណាជោសលានព្រះចេតិយ ក្នុងទីនោះ សម្អាតអាសនៈ ស្រោចទឹកដើមពោធិ៍ ហើយត្រាច់ទៅក្នុងភិក្ខុទាំងនោះ មិនចាំបាច់ត្រូវពោលឡើយ ។ ពួកភិក្ខុដែលចេញពីវត្តទៅដោយគិតថា នឹងទៅថ្វាយបង្គំព្រះចេតិយក្នុងវត្តឯណោះ មានចិត្តជ្រះថ្លា សូម្បីធ្វើកាលកិរិយាតាមផ្លូវ ក៏នឹងទៅកើតក្នុងសួគ៌ដោយមិនមានអន្តរាយឡើយ ។*

[๑๓๒] *ដោយបទថា* **អឧស្សន្នំ អានន្ទ** *ទ្រង់សម្តែងថា ការមិនឃើញមាតុគ្រាមសោះឡើយ ជាការបដិបត្តិដ៏សមគួរក្នុងទីនេះ ពិតហើយ ភិក្ខុបើកទ្វារ អង្គុយលើសេនាសនៈ ជរាបណាដែលមិនទាន់ឃើញមាតុគ្រាមមកឈរត្រង់មុខទ្វារ ជរាបនោះ ភិក្ខុនោះរមែងមិនកើតលោកៈ ចិត្តមិនញាប់ញ័រដោយចំណែកមួយប៉ុណ្ណោះ ។ តែកាលឃើញ ទាំង ២ យ៉ាងនោះ រមែងកើតមាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **អឧស្សន្នំ អានន្ទ** *ដោយបទថា* **ឧស្សន្នេ បន ភគវា សតិ កថំ** *ព្រះអានន្ទទូលសួរថា កាល*

ឃើញក្នុងទីដែលភិក្ខុចូលទៅទទួលភិក្ខាជាដើម ភិក្ខុនឹងបដិបត្តិដូចម្តេច គ្រានោះ ព្រះមានព្រះភាគត្រាស់ថា បុរសឈរកាន់ដាវ ពោលថា បើលោកនិយាយនឹងយើង យើងនឹងកាត់ក្បាលលោកឲ្យដាច់ក្នុងទីនេះ ឬយកិនីឈរពោលថា បើលោកនិយាយនឹងយើង យើងនឹងពន្លះសាច់លោកស៊ីក្នុងទីនេះយ៉ាងនេះល្អជាង ព្រោះការវិនាស មានការនិយាយនោះជាបច្ច័យ រមែងមានតែក្នុងអត្តភាពមួយប៉ុណ្ណោះ មិនបានទៅសោយទុក្ខ ដែលកំណត់មិនបានក្នុងអបាយភូមិទាំងឡាយ ចំណែកកាលមានការចរចាប្រាស្រ័យជាមួយមាតុគ្រាមការស្និទ្ធស្នាលក៏មាន កាលមានការស្និទ្ធស្នាល ឱកាសក៏មាន ភិក្ខុដែលមានចិត្តត្រូវរាគៈគ្របសង្កត់ ក៏ដល់ការវិនាសសីល ត្រូវទៅពេញក្នុងអបាយភូមិព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **អនាលាបោ** ដូច្នេះ ។ សមដូចលោកពោលថា

> បុគ្គលចរចាជាមួយនឹងជន ដែលមានជាវក្នុងដៃក្តី ចរចាជាមួយនឹងបិសាចក្តី ប៉ះពាល់នឹងអាសិវិស ហើយត្រូវអាសិវិសចឹកស្ងាប់ក្តី (ប្រសើជាង) មិនគួរចរចាជាមួយនឹងមាតុគ្រាម តែមួយនឹងមួយឡើយ ។

បទថា **អាលបន្តេ បន** សេចក្តីថា បើមាតុគ្រាមសួរ ថ្លៃសូមសីលប្រាថ្នានឹងស្តាប់ធម៌ សួរបញ្ហា ឬក៏មានកិច្চកម្ម ដែលបព្វជិតត្រូវធ្វើដល់មាតុគ្រាមនោះៗ ក៏និយាយនឹងភិក្ខុដែលមិននិយាយក្នុងវេលានោះយ៉ាងនេះថា ភិក្ខុអង្គនេះឆ្កួតទេដឹង ថ្លង់ទេដឹង ធាន់រូចហើយ អង្គុយបិតមាត់ ព្រោះដូច្នោះ ភិក្ខុគប្បីនិយាយដោយពិត ។ ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គ កាលភិក្ខុ

និយាយយ៉ាងនេះ គប្បីបដិបត្តិយ៉ាងណា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដៅយកព្រះឱវាទដែលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរតាំងចិត្តឲ្យដូចជាមាតា ក្នុងពួកស្រីល្មមជាមាតា ចូរតាំងចិត្តឲ្យដូចជាបងប្អូនស្រី ក្នុងពួកស្រីល្មមជាបងប្អូនស្រី ចូរតាំងចិត្តឲ្យដូចជាកូនស្រី ក្នុងពួកស្រីល្មមជាកូនស្រី ។ ទើបត្រាស់ថា ម្នាលអានន្ទ គប្បីតាំងសតិ ដូច្នេះ ។

[១៣៣] បទថា **អព្យាវជា** បានដល់ មិនពាក់ព័ន្ធ មិនខ្ចល់ខ្ចាយ ។ បទថា **សធត្តេ ឃដថ** បានដល់ ព្យាយាមក្នុងព្រះអរហត្ត ដែលជាប្រយោជន៍ដ៏ឧត្តម ។ បទថា **អនុយុញ្ជថ** បានដល់ ចូរប្រកបរឿយៗ ដើម្បីសម្រេចអរហត្តនោះ ។ បទថា **អប្បមត្តា** បានដល់ មិននៅប្រាសចាកសតិ ។ ឈ្មោះថា អ្នកមានព្យាយាម ព្រោះប្រកបដោយធម៌ដែលជាគ្រឿងដុតកិលេស គឺសេចក្តីព្យាយាម ឈ្មោះថា មានខ្ជួនបញ្ជូនទៅ គឺមានចិត្តបញ្ជូនទៅ ព្រោះជាអ្នកមិនមានអាល័យក្នុងកាយ និងជីវិត ។ ដោយបទថា **កថំ បន ភន្តេ** ព្រះអានន្ទទូលសួរថា ជនទាំងនេះ មានក្សត្របណ្ឌិតជាដើម នឹងគប្បីបដិបត្តិដូចម្តេច ជនទាំងនោះនឹងសាកសួរខ្ញុំព្រះអង្គដោយពិតថា លោកម្ចាស់អានន្ទ យើងខ្ញុំនឹងបដិបត្តិក្នុងសរីរៈ របស់ព្រះតថាគតដូចម្តេច ខ្ញុំព្រះអង្គគប្បីឆ្លើយប្រាប់ពួកជនទាំងនោះដូចម្តេច ។ បទថា **អហតេន វត្តេន** បានដល់ សំពត់ថ្មីដែលធ្វើក្នុងដែនកាសី មិនជ្រាបប្រេង ព្រោះសាច់ម៉ដ្ឋ តែសំពត់សម្ងីជ្រាបព្រោះដូច្នោះ ទើបលោកពោលថា **ទិហតេន កប្បាសេន** ។ បទថា **អយសាយ** បានដល់មឈូសមាស ។ មឈូសមាស លោកបំណងយកថា **អយសំ** ក្នុងទីនេះ ។

[១៣៤] សួរថា ក្នុងបទថា **រាជា ចក្ពវត្តិ** ហេតុអ្វី ទើបព្រះមានព្រះភាគអនុញ្ញាតការសាងសថូបដល់ព្រះរាជា ដែលនៅគ្រប់គ្រងផ្ទះសុគតហើយ ទ្រង់មិនអនុញ្ញាតសម្រាប់ភិក្ខុដែលមានសីល ឆ្ងើយថា ព្រោះមិនគួរអស្ចារ្យ ។ ពិតហើយ កាលទ្រង់អនុញ្ញាតសថូបសម្រាប់ភិក្ខុ បុថុជ្ជនក៏មិនមានឱកាសសម្រាប់សថូបទាំងឡាយ ក្នុងកោះសីហឡៈ សូម្បីក្នុងទីដទៃៗ ក៏ដូចគ្នា ព្រោះដូច្នោះ សថូបទាំងនោះ មិនគួរអស្ចារ្យ ព្រោះហេតុនោះ ទើបទ្រង់មិនអនុញ្ញាត ។ ស្តេចចក្រពត្តិកើតតែមួយព្រះអង្គប៉ុណ្ណោះ ដោយហេតុនោះ ទើបសថូបរបស់ព្រះអង្គអស្ចារ្យ ។ ចំណែកភិក្ខុបុថុជ្ជនអ្នកមានសីល នឹងធ្វើសក្ការៈសូម្បីយ៉ាងធំដូចយ៉ាងភិក្ខុដែលបរិនិព្វាន ក៏គួរដូចគ្នា ។

[១៣៥] ចំណែករោងមូល លោកប្រាថ្នាយកថា វិហារក្នុងបទថា **វិហារំ** នេះ ។ ចូលទៅកាន់វិហារនោះ ។ បទថា **ឥបិសីសំ** បានដល់ត្រដោកទ្វារ ដែលតាំងនៅក្នុងត្រង់ចុងសន្ទះទ្វារ ។ បទថា **រោធមាធោ អជ្ឌាសិ** សេចក្តីថា បានព្ថថា ព្រះអានន្ទគិតថា ព្រះសាស្តាត្រាស់ស្ថានទីនៅដែលឲ្យកើតសេចក្តីសង្វេគដល់អញ ត្រាស់ការចារិកទៅក្នុងចេតិយថា មានប្រយោជន៍ ត្រាស់ឆ្ងើយបញ្ហារឿងដែលនឹងគប្បីបដិបត្តិក្នុងមាតុគ្រាម ត្រាស់ប្រាប់ការបដិបត្តិក្នុងសរីរៈរបស់ព្រះអង្គ ត្រាស់ថូបារហបុគ្គល ៤ ពួក ថ្ងៃនេះ ព្រះមានព្រះភាគបរិនិព្វានពិត ។ កាលលោកគិតយ៉ាងនេះហើយ ក៏កើតទោមនស្សយ៉ាងខ្លាំងក្លា ។ គ្រានោះ លោកបរិវិតក្កយ៉ាងនេះថា ឈ្មោះថាការយំក្នុងទីជិតព្រះមានព្រះភាគមិនជាសុខ អញនឹងទៅក្នុងទីដទៃមួយ បន្ទោបង់សេចក្តីសោកឲ្យធូរស្បើយខ្លះ ។ លោកបានធ្វើយ៉ាងនោះ ។ ដោយហេតុ

នោះ ទើបលោកពោលថា ព្រះអានន្ទឈរយំ ។ បទថា **អហញ្ច វតម្ហិ** កាត់បទជា **អហញ្ច វត អម្ហិ ។** បាឬះថា **អហំ វតម្ហិ** ដូច្នេះក៏មាន ។ បទថា **យោ មម អនុកម្បកោ** ប្រែថា បុគ្គលណា អនុគ្រោះទូន្មានន្ទូវអាត្មាអញ ។ បានញ្ចថា ចាប់តាំងពីថ្ងៃស្អែកនេះ ឥឡូវនេះ អញនឹងថ្វាយទឹកសម្រាប់លាងព្រះភក្ត្រដល់អ្នកណា និងលាងព្រះបាទដល់អ្នកណា នឹងបដិបត្តិសេនាសនៈដល់អ្នកណា នឹងទទួលបាត្រ និងចីវរបស់អ្នកណា ចារិកទៅ ។ បទថា **អាមន្តេសិ** បានដល់ មិនឃើញព្រះថេរៈក្នុងចន្ទោះ ទើបត្រាស់ហៅ ។ បទថា **មេត្តេន កាយកម្មេន** បានដល់ ដោយកាយកម្ម មានការថ្វាយទឹកលុបព្រះភក្ត្រជាដើម ដែលបដិបត្តិទៅដោយអំណាចចិត្តមានមេត្តា ។ បទថា **ហិតេន** បានដល់ ដែលធ្វើទៅដើម្បីសេចក្តីចម្រើននៃប្រយោជន៍ ។ បទថា **សុខេន** បានដល់ ដែលធ្វើទៅដោយអំណាចសុខកាយ សុខចិត្ត ។ អធិប្បាយថា មិនមានទុក្ខកាយទុក្ខចិត្ត ។ បទថា **អទ្ធយេន** បានដល់ មិនធ្វើឲ្យជា ២ ចំណែក ។ លោកអធិប្បាយថា ធ្វើចំពោះមុខ មិនធ្វើកំបាំងមុខ ១ ធ្វើកំបាំងមុខ មិនធ្វើចំពោះ ១ មិនធ្វើបែងចែកយ៉ាងនោះ ។ បទថា **អប្បមាណេន** បានដល់ រៀរចាកប្រមាណ ។ ទ្រង់សម្តែងថា ពិតហើយ ចក្រវាលគង់តូច ភវគ្គព្រហ្មក៏ទាប ព្រោះកាយកម្មដែលអ្នកធ្វើមក ។ បទថា **មេត្តេន វចីកម្មេន** បានដល់ វចីកម្ម មានការប្រាប់រៀលាលុបព្រះភក្ត្រជាដើម ដែលបដិបត្តិទៅដោយអំណាចនៃចិត្តប្រកបដោយមេត្តា ។ ម្យ៉ាងទៀត សូម្បីស្តាប់ឱវាទហើយ ទូលថា **សាធុ ភន្តេ** ចាត់ជាមេត្តាវចីកម្មដូចគ្នា ។ បទថា **មេត្តេន មនោកម្មេន** សេចក្តីថា ដោយមនោកម្ម ដែលបដិបត្តិពីព្រឹកព្រលឹម ហើយអង្គុយលើ

អាសនៈដ៏ស្ងាត់ ហើយបដិបត្តិយ៉ាងនេះថា សូមព្រះសាស្តា ព្រះអង្គកុំមានរោគ កុំមានទុក្ខបៀតបៀន សូមទ្រង់នៅជាសុខចុះ ។ ដោយបទថា **កត-បុញ្ញោសិ** *ទ្រង់សម្តែងថា អ្នកជាបុគ្គលដល់ព្រមដោយអភិនីហារ (បុណ្យចាស់) រហូតអស់ ១ សែនកប្ប ។ ដោយបទថា* **កតបុញ្ញោម្ហិ** *ទ្រង់សម្តែងថា ដោយហេតុមានប្រមាណប៉ុណ្ណេះ អ្នកកុំដាក់ចិត្តប្រមាទដោយពិត ចូរប្រកបសេចក្តីព្យាយាមរឿយៗ អ្នកប្រកបសេចក្តីព្យាយាមរឿយៗ យ៉ាងនេះហើយ នឹងជាអ្នកមិនមានអាសវៈដោយឆាប់ នឹងសម្រេចអរហត្ត ក្នុងវេលាសង្គាយនាធម៌ ការប្រតិបត្តិ ដែលអ្នកធ្វើចំពោះព្រះពុទ្ធ ដូចតថាគតឈ្មោះថាឥតផលមិនមាន ។ កាលត្រាស់យ៉ាងនេះហើយ ទ្រង់ផ្តើមពណ៌នាគុណរបស់ព្រះអានន្ទ ដូចជាផ្សាយទូទៅទាំងមហាបឋវី ដូចជាផ្សាយទូទៅទាំងអាកាស ដូចជាលើកឡើងកាន់កំពូលចក្រវាលគីរី ដូចជាលើកភ្នំសិនេរុ ដូចជាចាប់អង្រែនដើមព្រើងធំ គ្រានោះឯង ទើបព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយ ។ ក្នុងព្រះបាលីនោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគមិនត្រាស់ថា* **យេបិតេ ភិក្ខវេ ឯត្តរហិ ។** *ព្រោះព្រះពុទ្ធអង្គដទៃៗ មិនមាន ។ តែគប្បីជ្រាបពាក្យនោះ ដោយព្រះបាលីនេះថា ព្រះពុទ្ធអង្គដទៃៗ ក្នុងចន្លោះនៃចក្រវាលមិនមាន យ៉ាងណា ។ បទថា* **បណ្ឌិតោ** *ប្រែថា វាងវៃ ។ បទថា* **មេធាវី** *បានដល់ ឈ្លាសក្នុងធម៌មានខន្ធ ធាតុ និងអាយតនៈជាដើម ។*

[๑๓๖] *បទថា* **ភិក្ខុបរិសា អានន្ទំ ឧស្សន្នាយ** *សេចក្តីថា ជនទាំងឡាយណា ជ្រាបថានឹងគាល់ព្រះមានព្រះភាគ ចូលទៅរកព្រះថេរៈ ជនទាំងឡាយណាមក បានឮគុណរបស់ព្រះថេរៈថា បានឮថា ព្រះអានន្ទគួរ*

ជ្រះថ្លាសព្វទីកន្លែង គួរសរសើរ ជាពហូសូត អ្នកល្អក្នុងសង្ឃ លោកសំដៅយកជនទាំងនោះ ទើបពោលថា ភិក្ខុបរិស័ទចូលទៅជួបព្រះអានន្ទ ។ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។ បទថា **អត្តមនា** ឈ្មោះថា មានចិត្តជារបស់ខ្លួន គឺមានចិត្តត្រេកអរ ព្រោះឃើញសមដោយការស្តាប់មក ។ បទថា **ធម្មំ** បានដល់ ធម៌ គឺ បដិសណ្ឋារៈ បែបនេះថា អ្នកមានអាយុ លួមអត់ទ្រាំបានឬ លួមប្រព្រឹត្តទៅបានឬ លោកចូរធ្វើកិច្ចដោយយោនិសោមនសិការ ចូរបំពេញអាចរិយវត្ត និងឧបជ្ឈាយវត្ត ។ ក្នុងធម៌ គឺបដិសណ្ឋារៈនោះ មានការធ្វើដែលផ្សេងគ្នាក្នុងកិក្ខុនីទាំងឡាយដូច្នេះថា កិក្ខុនីទាំង ៤ ពួក លោកសមាទានប្រព្រឹត្តគរុធម៌ ៨ ខ្លះទេឬ ។ កាលឧបាសកទាំងឡាយមក មិនធ្វើបដិសណ្ឋារៈយ៉ាងនេះថា អ្នកមិនមានអាពាធសីសៈ ឬអវយវៈណាមួយទេឬ ។ តែនឹងធ្វើបដិសណ្ឋារៈយ៉ាងនេះថា ឧបាសកទាំងឡាយ សរណៈ ៣ ដូចម្តេច អ្នករក្សាសីល ៥ រក្សាសីលឧបោសថមួយខែ ៨ ដង ចូរធ្វើវត្ត គឺការទំនុកបម្រុងមាតាបិតា ចូរបដិបត្តិសមណព្រាហ្មណ៍ អ្នកតាំងនៅក្នុងធម៌ ។ ក្នុងឧបាសិកាទាំងឡាយ ក៏មានន័យដូចគ្នា ។

ឥឡូវនេះ កាលទ្រង់ធ្វើការប្រៀបធៀបនឹងស្តេចចក្រពត្តិ ចំពោះព្រះអានន្ទត្ថេរ ទើបត្រាស់ថា **ចត្តារោមេ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ខត្តិយា** បានដល់ ជាតិជាក្សត្រដែលបានទទួលមុទ្ធាភិសេក និងមិនបានទទួលមុទ្ធាភិសេក ។ បានឮថា ក្សត្រទាំងនោះ ស្តាប់ពាក្យពណ៌នាគុណរបស់ស្តេចចក្រពត្តិនោះថា ធម្មតាស្តេចចក្រពត្តិល្អ គួរសរសើរ គួរជ្រះថ្លា សព្វរទៅបានតាមអាកាស ទ្បើងគ្រងរាជសម្បត្តិ ទ្រទ្រង់ធម៌ ជាធម្មរាជា

ដូច្នេះ រមែងសប្បាយចិត្ត ក្នុងកាលបានឃើញ សមដោយបានឮព្រះគុណ ។ បទថា **ភាសតិ** បានដល់ ទ្រង់ធ្វើបដិសណ្ឋារៈថា នែបា ដូចម្តេចហៅថា បំពេញរាជធម៌ ដូចម្តេចហៅថា រក្សាបវេណី ។ តែក្នុងព្រាហ្មណ៍ទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា លោកអាចារ្យដូចម្តេច ឈ្មោះថា បង្រៀនមន្ត ពួកសិស្សក៏រៀនមន្ត ពួកលោកចូរធ្វើទក្ខិណាសំពត់ ឬគោក្របាម ។ ក្នុងគហបតីទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា នែបា ពួកអ្នកមិនត្រូវបៀតបៀនដោយអាជ្ញា ឬដោយពន្ធអាករអំពីព្រះរាជាមានទេឬ ភ្ញៀងធ្លាក់ត្រូវតាមរដូវកាលទេឬ ស្រូវអង្ករសម្បូរទេឬ ។ ក្នុងសមណៈទាំងឡាយ ក៏ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា លោកម្ចាស់ បរិក្ខារសម្រាប់បព្វជិតរកបានងាយទេឬ ពួកលោកកុំប្រមាទក្នុងសមណធម៌ឡើយ ។

មហាសុទស្សនសុត្តទេសនាកថា

[๑๓๗] បទថា **ពុទ្ធកនគរកេ** បានដល់ នគរតូច ដែលចង្អៀត ជានគរដែលត្រូវរីកចម្រើន ។ បទថា **ឧជ្ជង្គលនគរកេ** បានដល់ នគរដែលមានផែនដីមិនរាបស្មើ ។ បទថា **សាខនគរកេ** បានដល់ នគរតូច ដូចជាសាខារបស់នគរធំដទៃ ដូចមែកតូចៗ របស់ដើមឈើទាំងឡាយ ដូច្នោះ ។ បទថា **ខត្តិយ មហាសាលា** បានដល់ ព្រះមហាក្សត្រជាខត្តិយមហាសាល ។ ក្នុងបទទាំងពួងក៏នយនេះ ។ បណ្តាមហាសាលទាំងនោះ ដែលឈ្មោះថា ខត្តិយ-មហាសាល បានដល់ ពួកក្សត្រដែលរក្សាទ្រព្យរយកោដិខ្ទះ ពាន់កោដិខ្ទះ ចំណាយកហាបណៈប្រចាំថ្ងៃ មួយថ្ងៃ ១ រនេះ ពេលល្ងាចកហាបណៈចូលមកវិញមួយថ្ងៃ ២ រនេះ ។ ដែលឈ្មោះថា ព្រាហ្មណមហាសាល បានដល់

ពួកព្រាហ្មណ៍ដែលមានទ្រព្យ ៨០ កោដិ ចំណាយកហាបណៈទៅមួយថ្ងៃ ១ កុម្ភៈ ពេលល្ងាចទទួលចូលមកវិញ មួយថ្ងៃ ១ រទេះ ។ ដែលឈ្មោះថា គហបតីមហាសាល បានដល់ ពួកគហបតីដែលមានទ្រព្យសម្បត្តិ ៤០ កោដិ ចំណាយកហាបណៈរៀងរាល់ថ្ងៃ មួយថ្ងៃ ៥ អម្ពណៈ ពេលល្ងាចទទួលចូលមកវិញ មួយថ្ងៃ ១ កុម្ភៈ ។ បទថា **មា ហោវំ អានន្ទ អវច** បានដល់ អានន្ទ អ្នកកុំនិយាយយ៉ាងនោះ ។ ព្រះមានព្រះភាគត្រាស់ថា អ្នកមិនគួរនិយាយថា នគរនេះតូច សេចក្តីពិត តថាគតមកកាន់នគរនេះ ដោយឧស្សាហ៍ធំ ដោយការប្រឹងប្រែងធំ ឈរ អង្គុយ ច្រើនដង ក៏ដើម្បីនឹងពោលដល់សម្បត្តិរបស់នគរនេះដោយពិត ទើបត្រាស់ថា **ភូតបុព្វំ** ជាដើម ។

បទថា **សុភិក្ខា** បានដល់ បរិបូណ៌ដោយរបស់ទំពា និងរបស់បរិភោគ ។ បទថា **ហត្ថិសទ្ទេន** សេចក្តីថា កាលដំរីមួយស្រែកឡើង ដំរី ៨៤០០០ ក៏ស្រែកតាម ដូច្នោះ ទើបកុសាវតីរាជធានី មិនស្ងាត់នូវសំឡេងដំរី ។ សំឡេងសេះក៏ដូចគ្នា ។ សត្វទាំងឡាយក្នុងរាជធានីនេះ មានបុណ្យ មានរថដែលទឹមដោយសេះសិន្ធព ៤ តាមគ្នានឹងគ្នា សញ្ចរទៅក្នុងផ្លូវថ្នល់ ដូច្នោះ ទើបឈ្មោះថា មិនស្ងាត់ដោយសំឡេងរថ ។ មួយទៀត គ្រឿងប្រគំ មានស្គរជាដើម ក្នុងនគរនោះ ក៏គោះរណ្តំគ្នាជានិច្ច ដូច្នោះ ទើបឈ្មោះថា មិនស្ងាត់អំពីសំឡេងស្គរជាដើម ។ បណ្តាបទទាំងនោះ បទថា **សម្មសទ្ទោ** បានដល់សំឡេងរគាំង ។ បទថា **តាលសទ្ទោ** បានដល់ សំឡេងរនាតដែលគោះដោយដៃ និងរនាតរាងបួនជ្រុង ។ អាចារ្យខ្លះពោលថា **ក្ខជភេរិសទ្ទោ** សំឡេងស្គរឈ្មោះកូដ ដូច្នេះក៏មាន ។ បទថា **អសថ បិវថ ខាទថ** ប្រែថា ចូរស៊ី ចូរ

ផឹក ចូរទំពា ។ ក្នុងរឿងនេះ មានសេចក្តីសង្ខេបដូច្នេះថា កុសាវតីរាជធានី មិនស្ងាត់ចាកសំឡេងទី ១០ នេះថា អញ្ចឹញ្ចបរិកោគចុះលោកដ៏ចម្រើន មានសំឡេងមិនជាច់ឡើយ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា ក្នុងនគរដទៃៗ មានសំឡេងបែបនេះថា ពួកអ្នកចូរចោលសំរាម ចូរកាន់ចប ចូរកាន់កញ្ជើ យើងនឹងទៅ ១ រនោច ពួកអ្នកចូរកាន់ទែអង្ករ ចូរកាន់កញ្ចប់បាយ ចូរវៀបខែល និងអាវុធ ដូច្នេះ យ៉ាងណា ក្នុងកុសាវតីនេះ មិនមានសំឡេងបែបនេះឡើយ ។ កាលត្រាស់ថា មិនស្ងាត់ដោយសូរសំឡេង ១០ យ៉ាង ដូច្នេះហើយ ទ្រង់បញ្ចប់មហាសុទស្សនសូត្រទាំងអស់ថា ម្នាលអានន្ទ កុសាវតីរាជធានី ព័ទ្ធជុំវិញដោយកំពែង ៧ ជាន់ ទើបត្រាស់ថា **តច្ច ត្វំ អានន្ទ** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **អភិក្កមថ** *សេចក្តីថា ពួកលោកចូរឈានមកខាងមុខ ។ សួរថា ពួកមល្លក្សត្រនៃក្រុងកុសិនារា ទ្រង់មិនជ្រាបថា ព្រះមានព្រះភាគយាងមកទេឬ ឆ្លើយថា ទ្រង់ជ្រាប ។ ធម្មតា ក្នុងស្ថានទីដែលព្រះពុទ្ធទាំងឡាយស្តេចយាងទៅ រមែងកោលាហលច្រើន ទាំងដែលស្តេចមិនទាន់មក ក៏ព្រោះទ្រង់ប្រជុំគ្នាដោយករណីយ៉ាងណាមួយ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ពួកមល្លក្សត្រទាំងនោះមកហើយ នឹងត្រូវរៀបចំឱកាស ទីឈរ ទីអង្គុយ ប្រគេនដល់ភិក្ខុសង្ឃ ទើបបញ្ជូនព្រះអានន្ទទៅកាន់សម្នាក់របស់មល្លក្សត្រទាំងនោះ សូម្បីក្នុងវេលាដែលមិនគួរ ។* **ឆោ** *អក្ខរៈ ក្នុងបទថា* **អម្ហាកំ ច ឆោ** *នេះ ត្រឹមតែជានិបាត ។ បទថា* **អឃាវិឆោ** *បានដល់ដែលកើតទុក្ខ ។ បទថា* **ឆេតោឧក្ខេសមប្បិតោ** *បានដល់ អ្នកពោរពេញដោយទោមនស្ស ។ បទថា* **កុលបរិវត្តសោ កុលបរិវត្តសោ ឋបេត្វា** *សេចក្តីថា*

ពួកមល្លក្សត្រជាត្រកូលៗ គឺសង្ខេបថា ត្រកូលជាចំណែកៗ ដោយនៅថ្នល់តែមួយរួមគ្នា និងច្រកផ្លូវតែមួយរួមគ្នា ។

[๑๓๘] *បទថា* **សុភទ្ទោ នាម បរិព្វាជកោ** *បានដល់ បរិព្វាជកអ្នកស្មៀកជណ្តប់សំពត់ អំពីត្រកូលឧទិច្ចព្រាហ្មណមហាសាល ។ បទថា* **កង្ខាធម្មោ** *បានដល់ ធម៌ គឺសេចក្តីងឿងឆ្ងល់ ។ សួរថា ព្រោះហេតុអ្វី ទើបសុភទ្ទបរិព្វាជកនោះ មានការគិតយ៉ាងនេះ ក្នុងថ្ងៃនោះ ។ ឆ្លើយថា ព្រោះមានឧបនិស្សយយ៉ាងនោះ ។ បានឮថា អំពីមុនមានបងប្អូន ๒ នាក់ ក្នុងការបំពេញបុណ្យ ។ បងប្អូន ๒ នាក់នោះ បានធ្វើស្រែរួមគ្នា ក្នុង ๒ នាក់នោះ បងប្រុសគិតថា អញនឹងថ្វាយទានស្រូវដ៏ប្រសើរមួយឆ្នាំ ๙ ដង ។ រដូវសាបព្រោះ ថ្វាយគ្រាប់ដ៏ប្រសើរ ។ ក្នុងរដូវស្រូវផើម ប្រឹក្សានឹងប្អូនប្រុសថានឹងបកស្រូវផើមថ្វាយ ។ ប្អូនប្រុសជ្រាប់ថា បងត្រូវការនឹងឲ្យស្រូវខ្វិនាសឬ ។ បងប្រុសជឹងថា ប្អូនប្រុសមិនយល់ព្រម ទើបចែកស្រែគ្នា បកស្រូវផើមដែលជាចំណែករបស់ខ្លួន រម្ងាស់យកទឹកដោះ ផ្សំដោយទឹកដោះថ្លា និងទឹកអំពៅ ។ ក្នុងរដូវស្រូវលីងអំបុកបាន ក៏ឲ្យធ្វើអំបុកថ្វាយ ។ ក្នុងវេលាច្រូត ក៏បានថ្វាយបាយដ៏ប្រសើរ ។ ក្នុងវេលាចងកណ្តាប់ ក៏បានថ្វាយបាយដ៏ប្រសើរ ។ ក្នុងវេលារៀបកណ្តាប់ជាដើម ក៏បានថ្វាយបាយដ៏ប្រសើរ ។ ក្នុងវេលាជញ្ជូនទុកក្នុងលាន ក៏បានថ្វាយបាយដ៏ប្រសើរ ។ ក្នុងវេលាបោកបែនក៏បានថ្វាយបាយដ៏ប្រសើរ ។ ក្នុងវេលាជញ្ជូនជាក់ជង្រែក ក៏បានថ្វាយបាយដ៏ប្រសើរ ។ បានថ្វាយទានដ៏ប្រសើរ ក្នុងស្រូវមួយឆ្នាំ ๙ ដង ដូចពោលមកនេះ ។ ឯប្អូនប្រុសធ្វើស្រែសម្រេចហើយ ទើបថ្វាយ ។ ក្នុងបងប្អូន ๒ នាក់នោះ បងប្រុស*

เกิดเป็นพระอัญญาโกณฑัญญเถระ ฯ พระผู้มีพระภาค ทรงพิจารณาเห็นว่า ตถาคตจักแสดงธรรมโปรดใครก่อนหนอ ทรงพระดำริว่า โกณฑัญญะ ได้ถวายทานอันประเสริฐ ในสำนักของเราเมื่อ ๙ กัป ตถาคตจักแสดงธรรมอันประเสริฐนี้แก่โกณฑัญญะ ทรงแสดงธรรมโปรดมนุษย์และเทวดาทั้งหลาย ฯ โกณฑัญญะตั้งอยู่ในโสดาปัตติผล มีอายุได้ ๑๘ โกฏิกัป ฯ ท่านผู้นี้ได้ประสบความสุขอันยิ่งใหญ่ในความคิดอย่างนี้ ในขณะพระศาสดาปรินิพพาน เพราะได้ถวายทานในกาลภายหลัง จึงได้เป็นผู้มีความเชื่อมั่นในพระศาสดา ฯ

บทว่า **มา ภควนฺตํ ปิโยเชสิ** *ความว่า ได้ยินว่า พระเถระรู้ว่า ธรรมที่ชื่อว่าอินทรีย์ทั้งหลายเหล่านั้น ของสัตว์ทั้งปวง ในกาลที่พระผู้มีพระภาคเสด็จปรินิพพานนานแล้ว เพื่อประโยชน์แก่การสงเคราะห์ปัญหานั้น จึงทรงห้ามพระอานนท์ด้วยคำนี้ว่า ท่านอย่าได้ทำให้พระผู้มีพระภาคทรงลำบากเลย ฯ ปริพาชก ก็ตามจิตของพระเถระ ด้วยคิดว่า ภิกษุนี้ไม่ให้โอกาสแก่ผู้ที่ต้องการประโยชน์ ตามจิตของตนเลย จึงได้กล่าวคำ ๒-๓ กัป ฯ บทว่า* **อาเสฺวสิ โข** *ความว่า ในกาลที่พระเถระนั่งสนทนาอยู่ที่ซุ้มประตูพระเชตวันนั่นเอง พระผู้มีพระภาค ทรงได้ยินด้วยพระโสตตามปกติ ฯ ครั้นได้ยินแล้ว จึงได้ตรัสว่า* **อลํ อานนฺท** *เป็นต้น เพื่อประโยชน์แก่การทรงห้ามพระอานนท์ ฯ คำว่า* **อลํ** *ในบทว่า* **อลํ อานนฺท** *นี้ เป็นคำปฏิเสธ ใช้ในอรรถว่าห้าม ฯ บทว่า* **อญฺญาเปกฺโข** *แปลว่า ผู้ต้องการความรู้ ฯ*

บทว่า **อพฺภญฺญึสุ** *ได้ยินว่า ความรู้ตามที่เป็นจริงในธรรมเหล่านั้นแล ฯ*

លោកអធិប្បាយថា ប្តេជ្ញានោះ របស់ម្ចាស់លទ្ធិទាំងនោះ ជានិយ្យានិកសោត ពួកគេទាំងអស់ក៏ដឹងទូទៅ បើប្តេជ្ញារបស់ពួកគេ មិនមែនជានិយ្យានិកសោត ពួកគេក៏មិនដឹង ព្រោះដូច្នោះ ប្តេជ្ញារបស់ម្ចាស់លទ្ធិទាំងនោះ ជានិយ្យានិក ឬមិនជានិយ្យានិក ។ សេចក្តីនៃបញ្ហានោះ មានយ៉ាងនេះប៉ុណ្ណោះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់បដិសេធថា កុំឡើយ ព្រោះមិនជាហេតុណាមួយ ព្រោះ មិនមានឱកាសណាមួយ ដោយការត្រាស់ដល់សេចក្តីដែលប្តេជ្ញារបស់ម្ចាស់ លទ្ធិទាំងនោះ មិនមែនជានិយ្យានិក ទើបទ្រង់សម្តែងធម៌តែម្យ៉ាង ។ ព្រះមាន ព្រះភាគយាងមកដោយព្រះពុទ្ធបំណងថា នឹងសម្តែងធម៌ប្រោសពួកមល្លក្សត្រ ពេលបឋមយាម សម្តែងធម៌ប្រោសសុកទូពេលមជ្ឈិមយាម ទូន្មានភិក្ខុសង្ឃ ពេលបច្ឆិមយាម បរិនិព្វានក្នុងវេលាជិតភ្លឺ ។

បទថា **សមណោបិ តត្ថ ន ឧបលព្ភតិ** *សេចក្តីថា ក្នុងធម្មវិន័យនោះ មិនមានសូម្បីសមណៈទី ១ គឺព្រះសោតាបន្ន សមណៈទី ២ គឺព្រះសក-ទាគាមី សមណៈទី ៣ គឺព្រះអនាគាមី សមណៈទី ៤ គឺព្រះអរហន្ត ក៏មិន មានក្នុងធម្មវិន័យនោះ ។ ព្រះមានព្រះភាគ ត្រាស់ដោយមិនកំណត់ទេសនា ខាងដើម ឥឡូវនេះ កាលទ្រង់កំណត់សាសនារបស់ព្រះអង្គ ទើបត្រាស់ថា* **ឥមស្មឹ ខោ** *ជាដើម ។ បទថា* **សុញ្ញា បរប្បវាទា សមណេហិ** *សេចក្តីថា បរប្បវាទ គឺលទ្ធិរបស់ម្ចាស់លទ្ធិដទៃ សូន្យទទេចាកសមណៈ ១២ ពួក គឺបុគ្គលផ្តើមវិបស្សនា ដើម្បីប្រយោជន៍ដល់មគ្គ ៤ រួមជា ៤ ពួក បុគ្គលតាំង នៅក្នុងមគ្គជា ៤ ពួក បុគ្គលតាំងនៅក្នុងផលជា ៤ ពួក ។ បទថា* **ឥមេ ច សុភទ្ទ** *សេចក្តីថា ភិក្ខុទាំង ១២ ពួកនេះ ។ ក្នុងបទថា* **សម្មា វិហរេយ្យុំ** *ព្រះ*

សោតាបន្ន ប្រាប់ហាន:ដែលខ្លួនសម្រេចដល់អ្នកដទៃ ធ្វើអ្នកដទៃនោះ ឲ្យជា សោតាបន្ន ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងព្រះសកទាគាមីជាដើម ក៏មាន នយដូច្នេះ ។ ភិក្ខុតាំងនៅក្នុងសោតាបត្តិមគ្គ ធ្វើអ្នកដទៃឲ្យជាអ្នកតាំងនៅក្នុង សោតាបត្តិមគ្គ ក៏ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងបុគ្គលដែលតាំងនៅក្នុង មគ្គដ៏សេស ក៏មានន័យដូច្នេះ ។ ភិក្ខុផ្តើមវិបស្សនា ដើម្បីសោតាបត្តិមគ្គ កំណត់កម្មដ្ឋានដែលខ្លួនស្គាត់ជំនាញ ធ្វើអ្នកដទៃឲ្យជាអ្នកផ្តើមវិបស្សនាដើម្បី សោតាបត្តិមគ្គក៏ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងភិក្ខុផ្តើមវិបស្សនាដើម្បីមគ្គ ដ៏សេសក៏មានន័យដូច្នេះ ។ លោកសំដៅយកសេចក្តីនេះ ទើបពោលថា **សម្មា វិហារេយ្យុំ** *។ បទថា* **អសុញ្ញោ លោកោ អរហន្តេហិ អស្ស** *សេចក្តីថា គប្បី មិនមានរោងចន្ទោះដូចព្រៃបបុស និងព្រៃរាំងភ្នំ ដូច្នោះ ។*

[๑๓๙] *បទថា* **ឯកូនតីស វយសា** *បានដល់ ទ្រង់មានព្រះជន្មាយុ ๒๙ វស្សាដោយវ័យ ។ បទថា* **យំ** *ក្នុងបទថា* **យំ បញ្ញត្តិ** *នេះ ត្រឹមតែជា និបាត ។ បទថា* **កឺ កុសលានុបសី** *បានដល់ ទ្រង់ស្វែងរកថា អ្វីជាកុសល លោកប្រាថ្នាសព្វញ្ញុតញ្ញាណថា កុសល គឺអ្វីក្នុងបទថា* **កឺ កុសលានុបសី** *នោះ អធិប្បាយថា ទ្រង់ស្វែងរកសព្វញ្ញុតញ្ញាណនោះ ។ ដោយបទថា* **យតោ អហំ** *ទ្រង់សម្តែងថា ចាប់ផ្តើមតាំងពីកាលណា តែចន្ទោះនេះ តថាគត បួសមកលើស ๕๐ វស្សា ។ បទថា* **ញាយស្ស ធម្មស្ស** *បានដល់ ធម៌ គឺអរិយមគ្គ ។ បទថា* **បឋេសវត្តិ** *ប្រព្រឹត្តទៅក្នុងប្រទេស គឺក្នុងផ្លូវនៃ វិបស្សនា ។*

បទថា **ส{เตา ตถาคฺคา** *ខាងក្រៅសាសនារបស់តថាគត ។ បទថា* **สมณោปิ ฉตฺถิ** *សេចក្តីថា សមណៈអ្កបំពេញវិបស្សនា អ្កនៅក្នុងផ្លូវនៃវិបស្សនាមិនមាន លោកអធិប្បាយថា សមណៈទី ១ ជាសោតាបន្នមិនមាន ។*

[๑๔๐] *បទថា* **เย ฆฏฺฏ** *សេចក្តីថា ភិក្ខុពួកណា ដែលព្រះសាស្តាអភិសេកដោយអន្តេវាសិកាភិសេក ចំពោះព្រះភក្ត្រក្នុងសាសនានេះ ជាលាករបស់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ បានល្អហើយ ។ បានឮថា ក្នុងលទ្ធិខាងក្រៅអាចារ្យនិយាយជាមួយនឹងអន្តេវាសិកណាថា ចូរឲ្យបព្វជ្ជាបុគ្គលនេះ ចូរឲ្យឱវាទប្រៀនប្រដៅបុគ្គលនេះ អន្តេវាសិកនោះ រមែងជាចំណែកដែលអាចារ្យតាំងទុកក្នុងហាន:របស់ខ្លួន ព្រោះដូច្នោះ សេចក្តីទាំងនេះថា ចូរបំបួសបុគ្គលនេះ ចូរឲ្យឱវាទប្រៀនប្រដៅបុគ្គលនេះ ជាលាករបស់អន្តេវាសិកនោះ ។ សុភទ្ទបរិព្វាជកកាន់លទ្ធិខាងក្រៅនោះឯង ទើបពោលចំពោះព្រះថេរៈយ៉ាងនេះ ។ បទថា* **อลตฺถ เขา** *ប្រែថា បានហើយដូចម្តេច ។ បានឮថា ព្រះថេរៈនាំសុភទ្ទនោះ ទៅក្នុងទីមួយកន្លែង យកទឹកអំពីកុណ្ឌីស្រោចសីសៈ ប្រាប់តចបញ្ចកកម្មដ្ឋាន កោរសក់ និងពុកមាត់ ឲ្យគ្រងសំពត់កាសាយៈ ឲ្យសរណៈហើយនាំទៅកាន់សម្នាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ឲ្យឧបសម្បទាហើយ ត្រាស់ប្រាប់កម្មដ្ឋាន ។ លោកទទួលកម្មដ្ឋានហើយ អធិដ្ឋានចង្រ្កមក្នុងទីមួយកន្លែងនៃឧទ្យាន ប្រារព្ធសេចក្តីព្យាយាម ជម្រះវិបស្សនា សម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ហើយមកថ្វាយបង្គំព្រះមានព្រះភាគ អង្គុយចុះ ។ លោកសំដៅយកឧបសម្បទាកម្មនោះ ទើបពោលថា* **อจิรูปสมฺปนฺโน เขา ภนฺเต** *ជាដើម ។ ព្រះសុភទ្ទនោះ បានជាបច្ឆិមសក្ខីសាវ័ករបស់ព្រះមាន*

ព្រះភាគនោះឯង ។ ពាក្យរបស់ព្រះសង្គីតិកាចារ្យថា ក្នុងបណ្តាសាវ័កទាំងនោះ អង្គណាបព្វជ្ជា កាលព្រះមានព្រះភាគទ្រង់នៅមានព្រះជន្ម ខាងក្រោយបានឧបសម្បទា រៀនកម្មដ្ឋានសម្រេចអរហត្តក្តី បានឧបសម្បទាកាលព្រះមានព្រះភាគទ្រង់នៅមានព្រះជន្ម ខាងក្រោយរៀនកម្មដ្ឋានសម្រេចអរហត្តក្តី រៀនកម្មដ្ឋានកាលព្រះមានព្រះភាគ ទ្រង់នៅមានព្រះជន្ម ខាងក្រោយសម្រេចអរហត្តក្តី គ្រប់អង្គនោះ ក៏ឈ្មោះថា បច្ឆិមសក្ខីសាវ័ក ។ ចំណែកសុភទ្ទនេះ បព្វជ្ជាឧបសម្បទា រៀនកម្មដ្ឋាន សម្រេចអរហត្ត កាលព្រះមានព្រះភាគទ្រង់នៅមានព្រះជន្ម ។

បញ្ចមភាណវារកថា ចប់

បច្ឆិមពុទ្ធវចន

[๑๔๑] *ឥទ្បូវនេះ ដើម្បីសម្តែងការប្រទានឱវាទដល់ភិក្ខុសង្ឃ ដែលទ្រង់ផ្តើម ទើបពោលពាក្យថា* **អថ ខោ ភគវា** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ឧសិតោ បញ្ញត្តោ** *សេចក្តីថា ទាំងធម៌ ក៏ទ្រង់សម្តែងហើយ បញ្ញត្តហើយ ទាំងវិន័យក៏ទ្រង់សម្តែងបញ្ញត្តហើយ អធិប្បាយថា ឈ្មោះថា ទ្រង់បញ្ញត្ត បានដល់ តែងតាំងហើយ ។ បទថា* **សោ ភោ មមច្ចយេន** *បានដល់ ធម៌ និងវិន័យនោះ នឹងជាសាស្តារបស់អ្នកទាំងឡាយ អំណាះឥតអំពីតថាគតទៅ ។ ពិតហើយ តថាគតនៅមានព្រះជន្មនេះឯង សម្តែងឧភតោវិភង្គវិន័យ ព្រមទាំងខន្ធក: បរិវារដល់អ្នកទាំងឡាយ ក្នុងវត្តុដែលចាត់ទុកដោយអំណាចកងអាបត្តិទាំង ๗ ថា នេះអាបត្តិស្រាល នេះអាបត្តិធ្ងន់ នេះសតេកិច្ឆាបត្តិ*

នេះអតេកិច្ចាបត្តិ នេះអាបត្តិដែលជាលោកវជ្ជៈ នេះជាបណ្ណត្តិវជ្ជៈ នេះអាបត្តិចេញបានក្នុងសម្នាក់បុគ្គល នេះអាបត្តិចេញបានក្នុងសម្នាក់គណៈ នេះអាបត្តិចេញបានក្នុងសម្នាក់សង្ឃ ។ វិនយបិដកទាំងអស់នោះ កាលតថាគតបរិនិព្វានហើយ នឹងធ្វើកិច្ចរបស់សាស្តាដល់ពួកអ្នកឲ្យសម្រេច ។ ម្យ៉ាងទៀត តថាគតនៅមានព្រះជន្មនេះឯង ក៏ចែកធម៌ទាំងនេះ សម្តែងសុត្តន្តបិដក ដោយអាការនោះថា ទាំងនេះជាសតិប្បដ្ឋាន ๔ សម្មប្បធាន ๔ ឥទ្ធិបាទ ๔ ឥន្ទ្រិយ ๕ ពល ๕ ពោជ្ឈង្គ ๗ អរិយមគ្គមានអង្គ ๘ សុត្តន្តបិដកទាំងអស់នោះនឹងធ្វើកិច្ចជាសាស្តាដល់អ្នកទាំងឡាយឲ្យសម្រេច ។ ម្យ៉ាងទៀត តថាគតមានព្រះជន្មតាំងនៅនេះឯង ចែកធម៌ទាំងនេះ គឺខន្ធ ๕ អាយតនៈ ๑๒ ធាតុ ๑๘ សច្ចៈ ๔ ឥន្ទ្រិយ ๒๒ ហេតុ ๙ អាហារ ๔ ផស្សៈ ๗ វេទនា ๗ សញ្ញា ๗ សញ្ចេតនា ๗ ចិត្ត ๗ ក្នុងចិត្តនោះ ធម៌ប៉ុណ្ណេះជាកាមាវចរ ប៉ុណ្ណេះជារូបាវចរ ប៉ុណ្ណេះជាអរូបាវចរ ប៉ុណ្ណេះជាបរិយាបន្ន គឺធម៌ដែលទាក់ទងគ្នា ប៉ុណ្ណេះជាអបរិយាបន្ន គឺធម៌ដែលមិនទាក់ទងគ្នា ប៉ុណ្ណេះជាលោកិយ ប៉ុណ្ណេះជាលោកុត្តរ ហើយសម្តែងអភិធម្មបិដក ជាសមន្តប្បដ្ឋាន ๒๔ ប្រជាប់មហាបដ្ឋានអនន្តនយ អភិធម្មបិដកទាំងអស់ កាលតថាគតបរិនិព្វានហើយ នឹងធ្វើកិច្ចជាសាស្តាដល់អ្នកទាំងឡាយឲ្យសម្រេច ។

ម្យ៉ាងទៀត ព្រះពុទ្ធវចនៈទាំងអស់នេះ ដែលតថាគតកាសិតហើយ ពោលហើយ តាំងអំពីត្រាស់ដឹង ដរាបដល់បរិនិព្វាន មានច្រើនប្រភេទយ៉ាងនេះ គឺ បិដក ๓ និកាយ ๕ អង្គ ๙ រួមជា ๘๔๐๐๐ ព្រះធម្មក្ខន្ធ ។ ព្រះធម្មក្ខន្ធ ๘๔๐๐๐ នេះ តាំងនៅដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ កាលទ្រង់

សម្តែងហេតុជាច្រើនយ៉ាងនេះថា តថាគតនឹងបរិនិព្វានតែម្នាក់ឯង មួយវិញទៀត តថាគតឥឡូវនេះ ក៏ទូន្មានប្រៀនប្រដៅតែម្នាក់ឯងដូចគ្នា កាលតថាគតបរិនិព្វានហើយ ព្រះធម្មក្ខន្ធ ៨៤០០០ នេះ នឹងទូន្មានប្រៀនប្រដៅអ្នកទាំង-ឡាយ ទ្រង់ឲ្យឱវាទថា ធម្មវិនយនោះ នឹងជាសាស្តារបស់អ្នកទាំងឡាយ កាលតថាគតបរិនិព្វានទៅហើយ កាលទ្រង់សម្តែងចារិតក្នុងអនាគតកាល ទើបត្រាស់ថា **យថា ខោ បន** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **សមុទាចរន្តិ** *បានដល់ រមែងពោល រមែងហៅ ។ បទថា* **ឆាមេន វា គោត្តេន វា** *បានដល់ ភិក្ខុបួសមុន គប្បីហៅនវក:ភិក្ខុដោយឈ្មោះយ៉ាងនេះថា តិស្ស: នាគ: ឬដោយគោត្រយ៉ាងនេះថា កស្សបគោត្រ ឬដោយវាទ:ថា អាវុសោ យ៉ាងនេះថា អាវុសោតិស្ស: អាវុសោកស្សប ។ បទថា* **ភន្តេតិ វា អាយស្មាតិ វា** *បានដល់ គប្បីហៅយ៉ាងនេះថា* **ភន្តេ តិស្ស អាយស្មា តិស្ស** *។ បទថា* **សម្ភោនតុ** *បានដល់ កាលបំណង ចូរដក អធិប្បាយថា ប្រសិនបើប្រាថ្នា ក៏គប្បីដកចេញ ។ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគមិនត្រាស់ដោយចំណែកតែមួយថា ចូរដកចេញ តែត្រាស់ដោយពាក្យជាវិកប្ប ឆ្លើយថា ព្រោះទ្រង់ឃើញកម្លាំងរបស់ព្រះមហាកស្សប ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ឃើញថា កាលត្រាស់ថា ចូរដកចេញ ព្រះមហាកស្សបនឹងមិនដកក្នុងវេលាធ្វើសង្គាយនា ព្រោះដូច្នោះ ទើបត្រាស់ដោយពាក្យជាវិកប្បនុ៎ះឯង ។ រឿងតូច នឹងតូចដោយលំដាប់ មកក្នុងបញ្ចសតិកសង្គីតិ ដោយនយជាដើមថា បណ្តាព្រះថេរ:ទាំងនោះ ព្រះថេរ:ពួកខ្លះ ពោលយ៉ាងនេះថា រៀវបាវជិក ៤ ចេញ ក្រៅពីនោះ ក៏ជាអាបត្តិតូចៗ ។ វិនិច្ឆ័យក្នុងរឿង*

អាបត្តិតូច នឹងតូចដោយលំដាប់នេះ បានពោលហើយក្នុងអដ្ឋកថា ឈ្មោះ សមន្តបាសាទិកា ។ អាចារ្យពួកខ្លះពោលថា ព្រះនាគសេនស្គាល់អាបត្តិតូច និងតូចតាមលំដាប់ ព្រោះត្រូវព្រះបាទមិលិន្ទត្រាស់សួរថា បពិត្រព្រះនាគសេន អាបត្តិតូច តើដូចម្តេច អាបត្តិតូចតាមលំដាប់ តើដូចម្តេច ទូលឆ្លើយថា មហាបពិត្រ ទុក្កដជាអាបត្តិតូច ទុព្ភាសិតជាអាបត្តិតូចតាមលំដាប់ ។ ចំណែកព្រះមហាកស្សបត្ថេរ កាលមិនដឹងអាបត្តិតូច អាបត្តិតូចដោយលំដាប់នោះ ទើបប្រកាសថា អ្នកដ៏មានអាយុទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង ដែលជាចំណែករបស់គ្រហស្ថក៏មាន សូម្បីគ្រហស្ថទាំងឡាយក៏ដឹងថា សិក្ខាបទនេះ គួរដល់លោកទាំងឡាយ ដែលជាសមណសក្យបុត្រ សិក្ខាបទនេះ មិនគួរដល់លោកទាំងឡាយ ដែលជាសមណសក្យបុត្រ បើយើងដកសិក្ខាបទតូច និងតូចដោយលំដាប់ចេញ មនុស្សទាំងឡាយក៏នឹងពោលថា សិក្ខាបទដែលព្រះសមណគោតមបញ្ញត្តទុកដល់សាវកទាំងឡាយនោះ បានត្រឹមតែមួយផ្សែងភ្លើង សាវកទាំងនេះ សិក្សាក្នុងសិក្ខាបទទាំងឡាយជាបដែលព្រះសាស្តាតាំងនៅ កាលព្រះសាស្តារបស់សាវកទាំងនេះបរិនិព្វានហើយ ក៏រើរុះនូវសិក្ខាបទ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃមិនគប្បីបញ្ញត្តសិក្ខាបទ ដែលទ្រង់មិនបានបញ្ញត្ត មិនគប្បីដកសិក្ខាបទ ដែលទ្រង់បញ្ញត្តទុកហើយ គប្បីសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ ដែលទ្រង់បញ្ញត្តទុកហើយ នេះជាញត្តិ ។ លោកប្រកាសកម្មវាចាដូចពោលមកនេះ ។ សេចក្តីនោះ មិនគួរកាន់យកយ៉ាងនេះ ព្រះនាគសេនពោលយ៉ាងនោះ ដោយប្រាថ្នានឹងមិនឲ្យបរវាទីមានឱកាស ។ ព្រះមហា-

กสฺสปตฺเถรปฺปกาสกมฺมวาจานេះ ក៏ដោយបំណងមិនឲ្យដកអាបត្តិតូច និងតូច ដោយលំដាប់ ដូច្នេះឯង ។ សូម្បីវៀងព្រហ្មទណ្ឌ លោកក៏បានវិនិច្ឆ័យហើយ នៅក្នុងអដ្ឋកថាព្រះវិនัย ឈ្មោះសមន្តបฺปาสาទิกา ព្រោះមកហើយក្នុងបាលី សង្គីតិ ។

[๑๔๒] *បទថា* **กงฺขา** *គឺផ្លូវបែកជាពីរ ។ បទថា* **วิมតិ** *គឺមិនអាចនឹងវិនិច្ឆ័យបាន ។ សេចក្តីសង្ខេបក្នុងសេចក្តីនេះ យ៉ាងនេះថា បុគ្គលណាគប្បីកើតសេចក្តីសង្ស័យថា ជាព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធហ្ន៎ ជាព្រះធម៌ ឬមិនមែនព្រះធម៌ហ្ន៎ ជាព្រះសង្ឃ ឬមិនមែនព្រះសង្ឃហ្ន៎ ជាមគ្គ ឬមិនមែនមគ្គហ្ន៎ ជាបដិបទា ឬមិនមែនបដិបទាហ្ន៎ តថាគតនឹងពោលសេចក្តីនោះដល់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកចូរសួរ ដូច្នេះ ។ បទថា* **สตฺถุคารเวนาปิ น ปุจฺเฉยฺยาថ** *សេចក្តីថា បើពួកអ្នកមិនសួរដោយសេចក្តីគោរពក្នុងសាស្តាយ៉ាងនេះថា ពួកយើងបួសក្នុងសម្នាក់នៃព្រះសាស្តា សូម្បីបច្ច័យ ๔ ក៏ជារបស់ព្រះសាស្តានៃពួកយើង ក៏មិនគួរនឹងធ្វើការសង្ស័យ អស់កាលមានប្រមាណប៉ុណ្ណេះ ក្នុងថ្ងៃនេះ មិនគួរនឹងធ្វើការសង្ស័យក្នុងកាលខាងក្រោយ ។ បទថា* **สหายโกปิ ภิกฺขเว สหายกสฺส อาโรเจตุ** *ទ្រង់សម្តែងថា បណ្តាអ្នកទាំងឡាយ បុគ្គលណាសេពគប់គ្នានឹងភិក្ខុណា បុគ្គលនោះចូរប្រាប់ភិក្ខុនោះថា ខ្ញុំនឹងប្រាប់ដល់ភិក្ខុមួយរូប អ្នកទាំងឡាយស្តាប់ពាក្យភិក្ខុនោះហើយ នឹងអស់ការសង្ស័យគ្រប់រូប ។ បទថា* **มยา ปสนฺเนน** *សេចក្តីថា ខ្ញុំជឿយ៉ាងនេះ ។ បទថា* **ญาณเมว** *សេចក្តីថា ធ្វើភាពជាអ្នកអស់សេចក្តីសង្ស័យឲ្យប្រចក្ស ឈ្មោះថា សេចក្តីជឿនុ៎ះឯងរបស់តថាគត ក្នុងសេចក្តីនេះ មិនមែនត្រឹមតែការជឿ ។*

បទថា **สเมสญฺจิ อานนฺท** *សេចក្តីថា បណ្តាភិក្ខុទាំង ៥០០ រូប ដែលអង្គុយខាងក្នុងវាំងននេះ ។ បទថា* **យោ បจฺฉิมโก** *សេចក្តីថា ភិក្ខុណាទាបបំផុតដោយគុណ ។ លោកពោលសំដៅដល់ព្រះអានន្ទត្ថេរប៉ុណ្ណោះ ។*

[๑๔๓] *បទថា* **อปฺปมาเณน สมฺปาเทถ** *សេចក្តីថា ចូរញុំាងកិច្ចទាំងពួងឲ្យសម្រេចដោយសេចក្តីមិនប្រាសចាកសតិ ដូច្នោះ ព្រះមានព្រះភាគទ្រង់ផ្តំលើគ្រែបរិនិព្វាន ប្រទានព្រះឱវាទ ដែលប្រទាន ៤៥ វស្សា រួមចូលក្នុងបទ គឺសេចក្តីមិនប្រមាទតែម្យ៉ាងប៉ុណ្ណោះ ។ ពាក្យនេះថា* **បจฺฉิม วาจา** *ជាពាក្យរបស់ព្រះសង្គីតិកាចារ្យទាំងឡាយ ។*

[๑๔๔] *បន្ទាប់អំពីនេះទៅ ដើម្បីនឹងសម្តែងសេចក្តីដែលព្រះមានព្រះភាគ ទ្រង់ធ្វើបរិកម្មក្នុងបរិនិព្វាន ទើបពោលពាក្យថា* **อถ โข ภควา ปឋมชฺฌานํ** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ปรินิพฺพุโต ภเณ** *សេចក្តីថា ព្រះអានន្ទឃើញព្រះមានព្រះភាគចូលនិរោធសមាបត្តិ មិនមានអស្សាស-បស្សាសៈ ទើបសួរថា ព្រះមានព្រះភាគបរិនិព្វានហើយឬ ។ ព្រះអនុរុទ្ធឆ្លើយថា នៅទេអាវុសោ ។ ព្រះថេរៈជ្រាបរឿងនោះ ។ បានឮថា ព្រះថេរៈចូលសមាបត្តិនោះៗ ព្រមជាមួយព្រះសាស្តានុ៎ះឯង ទើបដឹងថា ព្រះមានព្រះភាគចេញចាកនេវសញ្ញានាសញ្ញាយតនៈ ហើយប្រព្រឹត្តទៅ ឥឡូវនេះ ចូលនិរោធសមាបត្តិ ឈ្មោះថា ការធ្វើកាលកិរិយាខាងក្នុងនិរោធសមាបត្តិមិនមាន ។ ក្នុងព្រះបាលីនេះថា គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកសញ្ញាវេទយិតនិរោធ ចូលនេវសញ្ញានាសញ្ញាយតនៈ ។បេ។ ចេញចាកតតិយជ្ឈាន ចូលចតុត្ថជ្ឈាន ព្រះមានព្រះភាគទ្រង់ចូលបឋមជ្ឈានក្នុងហានៈ ២៤ ទុតិយជ្ឈាន*

ក្នុងហាន: ๑๓ តតិយជ្ឈានក៏ដូចគ្នា ចូលចតុត្ថជ្ឈានក្នុងហាន: ๑๕ ។ សួរថា ចូលដូចម្តេច ឆ្លើយថា គឺចូលបឋមជ្ឈានក្នុងហាន:ទាំង ๒๔ នេះ មានអសុក ๑๐ អាការ ๓๒ កសិណ ๘ មេត្តា ករុណា មុទិតា អានាបានស្សតិ បរិច្ឆេទាកាសជាដើម ។ តែវៀរអាការ ๓๒ និងអសុក ๑๐ ចូលទុតិយជ្ឈានក្នុងហាន:ដ៏សេស ๑๓ និងចូលតតិយជ្ឈានក្នុងហាន: ๑๓ នោះដូចគ្នា ។ មួយទៀត ចូលចតុត្ថជ្ឈានក្នុងហាន:ទាំង ๑๕ នេះ គឺកសិណ ๘ ឧបេក្ខាព្រហ្មវិហារ អានាបានស្សតិ បរិច្ឆេទាកាស អរូប ๔ ។ ពោលដោយសង្ខេបមានប្រមាណប៉ុណ្ណេះ ។ តែព្រះមានព្រះភាគជាធម្មសាមី ស្តេចចូលព្រះនគរ គឺបរិនិព្វាន ទ្រង់ចូលសមាបត្តិទាំងអស់ រាប់បាន ๒๔ សែនកោដិ ហើយសោយសុខក្នុងសមាបត្តិទាំងនោះ ដូចបុគ្គលទៅកាន់ប្រទេសដទៃ បានឱបក្រសោបជនដែលញាតិ ដូច្នោះ ។ ក្នុងពាក្យនេះថា ព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈាន លំដាប់មក ទ្រង់បរិនិព្វាន គឺក្នុងលំដាប់ទាំង ๒ គឺក្នុងលំដាប់នៃឈាន ក្នុងលំដាប់នៃបច្ចវេក្ខណញ្ញាណ ។ ព្រះមានព្រះភាគចេញចាកឈានហើយ ចូលកាន់ភវង្គ ហើយបរិនិព្វានក្នុងចន្លោះនោះ ឈ្មោះថាចន្លោះឈាន ក្នុងលំដាប់ ๒ នោះ ។ ព្រះមានព្រះភាគ ទ្រង់ចេញចាកឈានហើយ ពិចារណាអង្គឈានទៀត ចូលកាន់ភវង្គ ហើយបរិនិព្វានក្នុងចន្លោះនោះឯង ឈ្មោះថា ចន្លោះបច្ចវេក្ខណញ្ញាណ ។ ទាំង ๒ នេះ ក៏ឈ្មោះថាចន្លោះទាំងនោះ ។ ព្រះមានព្រះភាគចូលឈាន ទ្រង់ចេញចាកឈាន ពិចារណាអង្គឈានហើយ បរិនិព្វានដោយភវង្គចិត្ត ជាអព្យាក្រឹត ជាទុក្ខសច្ច ។ សត្វពួកណាមួយ មិនថា ព្រះពុទ្ធ ឬព្រះសាវក យ៉ាងទាប ស្រមោចខ្មៅ

ស្រមោចក្រហម ត្រូវធ្វើកាលកិរិយាដោយភវង្គចិត្តដែលជាអព្យាក្រឹត ជាទុក្ខសច្ចទាំងអស់នោះឯង ។

[๑๔๕] *រឿងផែនដីធំញ័រជាដើម មានន័យដូចពោលហើយនោះឯង ។*

[๑๔๖] *បទថា* **ភូតា** *បានដល់ សត្វទាំងឡាយ ។ បទថា* **អប្បដិបុគ្គលោ** *បានដល់ ប្រាសចាកបុគ្គលដែលប្រៀបធៀបបាន ។ បទថា* **ពលប្បត្តោ** *គឺអ្នកដល់ទសពលញ្ញាណ ១០ ។*

[๑๔๗] *បទថា* **ឧប្បាឧវយធម្មិនោ** *បានដល់ មានការកើត និងរលត់ជាសភាវៈ ។ បទថា* **តេសំ វូបសមោ** *សេចក្តីថា ការរម្ងាប់សង្ខារទាំងនោះ គឺព្រះនិព្វានដែលមិនមានបច្ច័យតាក់តែងមែនពិតជាសុខ ។*

[๑๔๘] *បទថា* **ឆាហុ អស្សាសបស្សាសោ** *គឺមិនកើតអស្សាសៈបស្សាសៈ ។ បទថា* **អនេជោ** *ឈ្មោះថា* **អនេជ** *ព្រោះមិនមានកិលេសជាគ្រឿងញាប់ញ័រ គឺតណ្ហា ។ បទថា* **សន្តិមារព្ភ** *បានដល់ ប្រារព្ធអាស្រ័យសំដៅយកអនុបាទិសេសនិព្វាន បទថា* **យំ កាលមករិ** *សេចក្តីថា បុគ្គលណាបានធ្វើកាលកិរិយា លោកអធិប្បាយថា អាវុសោ ព្រះពុទ្ធជាមុនី គឺសាស្តានៃយើងអង្គណា ទ្រង់ប្រារព្ធសន្តិថា តថាគតនឹងដល់សន្តិ ទ្រង់ធ្វើកាលកិរិយាហើយ ឥឡូវនេះ ព្រះពុទ្ធជាមុនីអង្គនោះ មានចិត្តតាំងមាំ មិនមានអស្សាសៈបស្សាសៈ គឺមិនមានការប្រព្រឹត្តទៅ ។ បទថា* **អសល្លីនេន** *គឺដោយចិត្តមិនរួញរា រីករាយល្អហើយ ។ បទថា* **វេទនំ អជ្ឈាវសយិ** *ទ្រង់គ្របសង្កត់វេទនាហើយ គឺមិនរសាប់រសល់ ប្រព្រឹត្តទៅតាមអំណាចរបស់វេទនា ។ បទ*

ថា **វិមោក្ខោ** បានដល់ រួចផុត មិនជាប់ជំពាក់ ដោយធម៌ណាមួយ ដល់ការមិនមានបញ្ញត្តិ ដោយប្រការទាំងពួង ដូចគ្នានឹងការរលត់ នៃភ្លើងដែលឆេះសន្ធោសន្ធៅ ។

[๑๔๙] លោកពោលថា **តថាសិ** សំដៅយកផែនដីញាប់ញ័រ ដែលលោកពោលទុកក្នុងខាងដើមយ៉ាងនេះថា មហាប្រឋពី ញាប់ញ័រព្រមជាមួយនឹងបរិនិព្វាន ។ ពិតហើយ ការញ័រនៃផែនដីនោះ ធ្វើឲ្យកើតការព្រឺរោម និងគួរតក់ស្លុត ។ បទថា **សញ្ជាការវរូបេតេ** ប្រែថា ចូលដល់ហេតុដ៏ប្រសើរទាំងពួង ។

[๑๕๐] បទថា **អរិយសាវកា** បានដល់ បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ពិតហើយ បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ លះទោមនស្សមិនទាន់បាន ព្រោះដួច្នោះ លោកទាំងនោះផ្គងដៃទាំងពីរឃំរៀបរាប់ ដាក់ដៃទាំងពីរទុកលើសីស:ស្រែកឃំ ។ រឿងទាំងអស់ គប្បីជ្រាបដោយន័យមុននុ៎ះឯង ។

[๑๕๑] បទថា **ឧជ្ឈាយន្តិ** គឺទេវតាលើកទោស ពោលថា លោកម្ចាស់ទាំងឡាយ មិនអាចអត់ទ្រាំសូម្បីចំពោះខ្លួនឯងបាន នឹងលួងលោមជនដ៏សេសបានដូចម្តេច ។ បទថា **កថំ ភគវា បន ភន្តេ អនុរុទ្ធ** សេចក្តីថា លោកម្ចាស់ដ៏ចម្រើន ពួកទេវតាគិតដូចម្តេច ។ ព្រះអនុរុទ្ធកំណត់ថា ទេវតាទាំងនោះ នឹងបញ្ឈប់បរិនិព្វានរបស់ព្រះសាស្តាបានឬ ។ តមក ដើម្បីសម្តែងការប្រព្រឹត្តទៅនៃទេវតាទាំងនោះ ទើបព្រះថេរៈពោលថា **សន្តាវុសោ** ជាដើម ។ ពាក្យនោះ មានសេចក្តីដូចពោលទុកហើយនោះឯង ។

បទថា **រត្តាវសេសំ** គឺរាត្រីដែលនៅសល់វេលាបន្តិចបន្តួច ព្រោះបរិនិព្វានក្នុងវេលាជិតភ្លឺ ។ បទថា **ធម្មិយា កថាយ** គឺមិនមានធម្មកថា ដែលបែកចេញទៅយ៉ាងដទៃ ។ តែព្រះថេរៈទាំងពីរ ញ្ចុាំងវេលាឲ្យកន្លងទៅ ដោយកថាដែលសម្បយុត្តដោយមរណៈបែបនេះថា អាវុសោទាំងឡាយ មច្ចុរាជនេះ មិនខ្ទាសចំពោះព្រះសាស្តា ដែលមិនមានបុគ្គលប្រៀបក្នុងលោក ព្រមទាំងទេវ-លោកក៏នឹងចាំបាច់ពោលទៅថ្វីថា នឹងខ្ទាសចំពោះលោកិយមហាជន ។ កាលព្រះថេរៈទាំងពីរពោលកថានោះ អរុណក៏រះឡើងដោយត្រឹមតែមួយភ្លែតប៉ុណ្ណោះ ។ បទថា **អថខោ** សេចក្តីថា កាលអរុណរះ ព្រះថេរៈក៏ពោលចំពោះព្រះថេរៈ ។

[១៥២] បទថា **តេន ករណីយេន** សេចក្តីថា ករណីយ៍ណាយ៉ាងនេះ គឺគប្បីចាត់ចែងសក្ការៈ មានផ្កាកម្រង និងគ្រឿងក្រអូបជាដើមក្នុងទីបរិនិព្វានដូចម្តេចហ្នឹ ។ នឹងគប្បីចាត់ចែងទីអង្គុយសម្រាប់ភិក្ខុសង្ឆដូចម្តេច ។ នឹងគប្បីចាត់ចែងខាទនីយភោជនីយៈដូចម្តេច ដែលបុគ្គលដឹងរឿងព្រះមានព្រះភាគបរិនិព្វានហើយ គប្បីធ្វើពួកមល្លក្សត្រ ប្រជុំគ្នាដោយករណីដូច្នោះ ។

បទថា **សព្វញ្ញ តាឌ្បាវចរំ** បានដល់ គ្រឿងតូរ្យតន្ត្រីគ្រប់ប្រភេទ ។ បទថា **សន្និចាតេថ** សេចក្តីថា រាយស្គរហៅប្រជុំ មល្លក្សត្រទាំងនោះបាននាំគ្នាធ្វើយ៉ាងនោះ ។ បទថា **មណ្ឌលមាលេ** បានដល់ កម្រងពិដានសំពត់ ។ បទថា **បដិយាទេន្តា** ប្រែថា រៀបចំ ។ បទថា **ទក្ខិណេន ទក្ខិណំ** គឺទិសា-ភាគ ផ្នែកខាងត្បូងនៃព្រះនគរ ។ បទថា **ពាហិរេន ពាហិរំ** បានដល់ មិនចូលទៅខាងក្នុងព្រះនគរ នាំទៅខាងក្រៅ ដោយខាងក្រៅព្រះនគរនុ៉ះឯង ។ បទ

ថា **ឧក្កិណ្ណាតោ ឯតរស្ស** សេចក្តីថា តម្កល់ទុកក្នុងស្ថានទីដូចគ្នា និងទ្វារផ្នែកខាងត្បូងនៃក្រុងអនុរាធបុរៈ ធ្វើសក្ការៈរាប់អានហើយ និងធ្វើឈាបនកិច្ច ក្នុងស្ថានទីដូចគ្នានឹងវត្តជេតពន ។

[១៥៣] បទថា **អដ្ឋ មល្លចាមោក្ខា** បានដល់ ពួកមល្លក្សត្រមជ្ឈិមវ័យបរិបូណ៌ដោយកម្លាំង ។ បទថា **សីសំ ន្ហាតា** បានដល់ ជម្រះសីសៈងូតទឹកហើយ ។ បទថា **អាយស្មន្តំ អនុរុទ្ធំ** សេចក្តីថា ព្រះថេរៈតែមួយរូប ប្រាកដថា ជាអ្នកមានទិព្វចក្ខុ ព្រោះដូច្នោះ កាលព្រះថេរៈអង្គដទៃៗមានពួកមល្លក្សត្រទាំងនោះ ក៏ហៅសួរចំពោះព្រះថេរៈ ដោយបំណងថា ព្រះអនុរុទ្ធត្តេរនេះ នឹងប្រាប់ដល់ពួកយើងបានច្បាស់លាស់ ។ បទថា **កថំ បន ភន្តេ ទេវតានំ អធិប្បាយោ** សេចក្តីថា ពួកមល្លក្សត្រសាកសួរថា លោកម្ចាស់ កាលមុនពួកយើងដឹងសេចក្តីប្រាថ្នារបស់ពួកយើង តែបំណងរបស់ពួកទេវតាដូចម្តេច ។ ព្រះថេរៈកាលសម្តែងបំណងរបស់ពួកមល្លក្សត្រប៉ុណ្ណោះទើបពោលថា **តុម្ហាកំ ខោ** ជាដើម ។ ពាក្យថា ចេតិយរបស់ពួកមល្លក្សត្រឈ្មោះមកុដពន្ធនៈនេះ ជាឈ្មោះរបស់សាលាមង្គល ជាកន្លែងតាក់តែងព្រះកាយរបស់ពួកមល្លក្សត្រ ។ សាលានេះ លោកហៅថា ចេតិយ ព្រោះអត្ថថាកសាងយ៉ាងស្អាត ។ ក្នុងបទថា **យាវ សទ្ទំសមលសង្ឃដិតា** នេះ ទីតនៃផ្ទះឈ្មោះថា **សទ្ទំ** អណ្តូង កម្ទាត់គំនរលាមក គឺរណ្តៅលាមក ឈ្មោះថា **សមល** ទីចាក់សំរាមឈ្មោះថា **សង្ឃដិតា** ។ បទថា **ឱព្ភេហិ ច មានុសកេហិ ច ឧច្ឆេហិ** សេចក្តីថា វត្ថុ ការពាររបស់ពួកទេវតាមានក្នុងខាងលើរបស់ពួកមនុស្សមានខាងក្រោម ។ ក្នុងការច្រៀងជាដើមក៏នយនេះ ។ មួយទៀត ក្នុងបន្ទោះ

ពួកទេវតា ក៏មានពួកមនុស្ស ក្នុងចន្ទោះពួកមនុស្ស ក៏មានទេវតា ទាំងទេវតា និងមនុស្ស បាននាំគ្នាទៅសក្ការៈបូជា ដោយប្រការដូចពោលមកនេះ ។ បទ ថា **មជ្ឈេន មជ្ឈំ នគរស្ស ហរិត្វា** សេចក្តីថា កាលព្រះសរីរៈរបស់ព្រះមាន ព្រះភាគត្រូវគេនាំមកយ៉ាងនេះ ភរិយារបស់ពន្ធុលសេនាបតី ឈ្មោះថា មល្ទិកា ជ្រាបថា គេនាំព្រះសរីរៈរបស់ព្រះមានព្រះភាគមក ក៏គិតថា អញនឹងឲ្យគេនាំ គ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍ ដូចគ្នានឹងគ្រឿងប្រដាប់របស់នាង វិសាខា ដែលអញរក្សាទុកមិនបានប្រើប្រាស់មកតាំងពីស្វាមីរបស់អញស្ទាប់ ទៅ នឹងបូជាព្រះសាស្តាដោយមហាលតាបសាធន៍នេះ ដូច្នេះហើយ ឲ្យធ្វើ ការសម្អាតមហាលតាបសាធន៍នោះ ជម្រះដោយទឹកក្រអូប ហើយដាក់ទុកជិត ទ្វារ ។ បានឮថា គ្រឿងប្រដាប់នោះ មាននៅក្នុងស្ថានទី ៣ កន្ទែង គឺនៅផ្ទះ របស់ស្ត្រីទាំងពីរនោះ (នាងវិសាខា និងនាងមល្ទិកា) និងផ្ទះរបស់ចោរ ឈ្មោះថា ទេវនានិយៈ ។ នាងមល្ទិកានោះពោលថា កាលព្រះសរីរៈរបស់ ព្រះសាស្តាមកដល់ទ្វារហើយ បាទាំងឡាយ ចូរដាក់ព្រះសរីរៈរបស់ព្រះ-សាស្តាចុះហើយ ពាក់គ្រឿងប្រដាប់នេះលើព្រះសរីរៈរបស់ព្រះសាស្តា ។ គ្រឿងប្រដាប់នោះ ពាក់តាំងពីព្រះសិរសាដរាបទល់ផ្ទៃព្រះបាទ ព្រះសរីរៈ របស់ព្រះមានព្រះភាគដែលមានព្រះឆវីវណ្ណដូចមាស ប្រដាប់ដោយមហា-លតាបសាធន៍ ដែលធ្វើដោយរតនៈ ៧ ប្រការ ក៏រុងរឿងក្រៃពេក ។ នាង មល្ទិកានោះឃើញដូច្នោះហើយ ក៏មានចិត្តថ្លាផូរផង់ធ្វើសេចក្តីប្រាថ្នាថា បពិត្រ ព្រះមានព្រះភាគ ខ្ញុំព្រះអង្គត្រាច់ទៅក្នុងវដ្តសង្សារដរាបណា ដរាបនោះ សូម កិច្ចដោយគ្រឿងប្រដាប់ កុំបែកអំពីខ្ញុំព្រះអង្គ សូមឲ្យសរីរៈដូចគ្នានឹងគ្រឿង

ប្រជាប់ដែលពាក់ហើយជានិច្ចចុះ ។ គ្រានោះ ពួកស្តេចមល្លបាមោក្ខ លើក ព្រះមានព្រះភាគ ព្រមដោយគ្រឿងមហាលតាបសាធន៍ ដែលធ្វើដោយរតន: ៧ ប្រការ ចេញផ្លូវទ្វារទិសបូព៌ា ជាក់ព្រះសរីរៈរបស់ព្រះមានព្រះភាគចូល ក្នុងមកុដពន្ធនចេតិយរបស់ពួកមល្លក្សត្រ ផ្លូវខាងទិសបូព៌ានៃព្រះនគរ ។

[๑๕๔] បទថា **ចារាយ កុสินารំ** សេចក្តីថា ព្រះមហាកស្សបដើរ ផ្លូវឆ្ងាយដោយបំណងថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងនគរបាវា ហើយនឹងទៅ កាន់នគរកុសិនារា ។ ក្នុងពាក្យថា គង់ក្រោមម្លប់ឈើនេះ តើហេតុអ្វី ទើប លោកមិនពោលថា សម្រាកពេលថ្ងៃ ។ ព្រោះលោកមិនអង្គុយ ដើម្បីនឹង សម្រាកពេលថ្ងៃ ។ សេចក្តីពិត ពួកភិក្ខុបរិវាររបស់ព្រះថេរៈសុទ្ធតែចម្រើន ដោយសេចក្តីសុខ មានបុណ្យច្រើន លោកធ្វើដំណើរដោយជើងលើផែនដី ដែល ដូចផ្ទាំងថ្មដ៏ក្តៅ ក្នុងវេលាថ្ងៃត្រង់ មានការលំបាក ។ ព្រះថេរៈឃើញភិក្ខុទាំង នោះ ក៏គិតថា ភិក្ខុទាំងឡាយមានការលំបាក ទាំងទីដែលត្រូវទៅ ក៏នៅឆ្ងាយ នឹងសម្រាកបន្តិចបន្តួចរម្ងាប់សេចក្តីលំបាក ពេលល្ងាចដល់នគរកុសិនារា នឹង ចូលគាល់ព្រះទសពល ទើបឆៀងចូលចុះអំពីផ្លូវ ក្រាលសង្ឃាដីត្រង់គល់ ឈើមួយកន្លែង ហើយយកទឹកអំពីកុណ្ឌីលាបដៃ និងជើងឲ្យត្រជាក់ ហើយ អង្គុយចុះ ។ សូម្បីពួកភិក្ខុបរិវាររបស់លោក ក៏អង្គុយត្រង់គល់ឈើ ញ៉ាំង យោនិសោមនសិការក្នុងកម្មដ្ឋាន អង្គុយសរសើរគុណព្រះរតនត្រ័យ ដូច្នោះ ទើបលោកមិនពោលថា សម្រាកពេលថ្ងៃ ព្រោះអង្គុយដើម្បីបន្ទោបង់សេចក្តី ហត់នឿយ ។ បទថា **មណ្ឌារបុប្ផំ គហេត្វា** បានដល់ យកឈើដោតផ្កា មណ្ឌារៈ ប៉ុនថាសធំ កាន់មកដូចឆត្រ ។ បទថា **អទ្ទสา เอา** បានដល់

ឃើញអាជីវកដើរមកពីចម្ងាយ ។ កាលឃើញហើយ ព្រះថេរៈគិតថា នុ៎ះផ្កាមណ្ឌារវៈ ប្រាកដនៅក្នុងដៃរបស់អាជីវកនេះ ផ្កាមណ្ឌារវៈនោះ មិនប្រាកដក្នុងដែលជីរបស់មនុស្សឡើយ មានចំពោះកាលអ្នកមានឫទ្ធិខ្លះ ដែលលោកសម្តែងឫទ្ធិ និងចំពោះកាលព្រះសព្វញ្ញុពោធិសត្វស្តេចចុះកាន់ព្រះគភ៌របស់ព្រះមាតាជាដើម តែថ្ងៃនេះ អ្នកមានឫទ្ធិណាមួយ ក៏មិនបានសម្តែងឫទ្ធិនេះ ព្រះសាស្តារបស់យើង ទ្រង់ក៏មិនចុះកាន់ព្រះគភ៌របស់ព្រះមាតា ទ្រង់មិនបានប្រសូត ថ្ងៃនេះ ព្រះអង្គក៏មិនបានត្រាស់ដឹង មិនបានប្រកាសធម្មចក្រ មិនបានសម្តែងយមកប្បាដិហារ្យ មិនបានស្តេចចុះចាកទេវលោក ទ្រង់មិនបានដាក់អាយុសង្ខារ តែព្រះសាស្តារបស់យើងទ្រង់ព្រះជរា ស្តេចនឹងបរិនិព្វានដោយពិត ។ លំដាប់នោះ ព្រះថេរៈកើតចិត្តគិតថា នឹងសួរអាជីវក ទើបត្រិះរិះថា បើអញអង្គុយសួរនឹងមិនគោរពក្នុងព្រះសាស្តា ដូច្នេះហើយ ទើបក្រោកឡើងដណ្តប់បង្សុកូលចីវរពណ៌ផ្ទៃមេឃដែលព្រះទសពលប្រទាន ប្រៀបដូចស្តេចដំរីឆទ្ទន្ត ចៀសចេញអំពីទីឈរ ដណ្តប់ស្បែកកែវមណីដូច្នោះ លើកអញ្ជលីដ៏រុងរឿងដោយទសនខៈសមោធានទុកលើសីសៈ បែរមុខត្រង់ចំពោះអាជីវកដោយគារវៈដែលធ្វើក្នុងព្រះសាស្តាពោលសួរថា អ្នកមានអាយុ លោកជ្រាបដំណឹងព្រះសាស្តារបស់យើងដែរឬ ។ សួរថា ព្រះមហាកស្សប ដឹងការបរិព្វានរបស់ព្រះសាស្តា ឬមិនដឹង ទើបសួរ ។ អាចារ្យពួកមួយពោលថា ការដឹងរបស់ព្រះខីណាស្រពទាំងឡាយ ត្រូវទាក់ទងនឹងអាវជ្ជនៈការនឹក ព្រះមហាកស្សបមិនដឹង ទើបសួរ ព្រោះលោកមិនបាននឹក ។ ព្រះថេរៈច្រើនដោយសមាបត្តិ ញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដោយការច្រើនទៅដោយសមាបត្តិ

ជានិច្ច ក្នុងទីនៅពេលយប់ ទីសម្រាកពេលថ្ងៃ ទីពួនសម្ងំ និងមណ្ឌបជាដើម ចូលស្រុកនៃត្រកូល ក៏ចូលសមាបត្តិគ្រប់មុខផ្ទះ ចេញចាកសមាបត្តិហើយ ទើបទទួលភិក្ខា បានឮថា ព្រះថេរៈធ្វើសេចក្តីតាំងចិត្តយ៉ាងនេះថា ដោយអត្តភាពចុងក្រោយនេះ អញនឹងអនុគ្រោះមហាជន ជនពួកណាថ្វាយភិក្ខា ឬធ្វើសក្ការៈដោយគ្រឿងក្រអូប ... និងផ្កាជាដើមដល់អញ ទានរបស់ជនទាំងនោះ ចូរមានផលច្រើន ដូច្នេះ ព្រោះដូច្នោះ ទើបលោកមិនដឹង ព្រោះច្រើនទៅដោយសមាបត្តិ ដូច្នោះ ។ អាចារ្យពួកមួយពោលថា លោកមិនដឹង ទើបសួរ ។ ពាក្យនោះមិនគួរកាន់យក ។ ព្រោះថា មិនមានហេតុដែលនឹងមិនដឹងក្នុងសេចក្តីនោះ ។ បរិនិព្វានរបស់ព្រះសាស្តាបានកំណត់ទុកច្បាស់ហើយ ដោយនិមិត្តទាំងឡាយ មានលោកធាតុ ១ ម៉ឺនញាប់ញ័រជាដើម ព្រះថេរៈបានដឹង តែសួរដើម្បីឲ្យកើតសតិដល់ភិក្ខុទាំងឡាយ ដោយគិតថា ក្នុងបរិស័ទរបស់ព្រះថេរៈ ភិក្ខុពួកខ្លះ ក៏ធ្លាប់ឃើញព្រះមានព្រះភាគ ពួកខ្លះ ក៏មិនធ្លាប់ឃើញ បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកណាធ្លាប់ឃើញហើយ ភិក្ខុទាំងនោះក៏នៅតែចង់ឃើញ ភិក្ខុពួកណាមិនធ្លាប់ឃើញ ភិក្ខុទាំងនោះ ក៏ចង់ឃើញដូចគ្នា បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកណាមិនធ្លាប់ឃើញ ភិក្ខុទាំងនោះក៏ទៅ ព្រោះអនួះសាចង់ឃើញព្រៃលែងណាស់ សួរថា ព្រះមានព្រះភាគនៅទីណា ជ្រាបថា បរិនិព្វានហើយ ក៏មិនអាចទប់ស្មារតីឲ្យតាំងមាំបាន ចោលបាត្រ ចីវរ ស្បៃកសំពត់តែមួយផ្ទាំងខ្លះ ស្បៃកមិនល្អខ្លះ ជណ្តប់មិនល្អខ្លះ គក់ទ្រែងស្រែកទ្រហោយំក្នុងទីនោះ មនុស្សទាំងឡាយនឹងសម្តែងទោសដល់អញថា ពួកភិក្ខុដែលកាន់បង្សុកូលចីវរកិត្តិធុតង្គ ដែលមកជាមួយព្រះមហាកស្សប ស្រែកយំដោយខ្លួន

ឯង ដូចមនុស្សស្រី កិកូទាំងនោះនឹងលួងលោមពួកយើងបានដូចម្តេច ព្រៃធំនេះគង់នឹងសូន្យទទេ កាលកិកូទាំងឡាយស្រែកយំខ្លាំងៗ ក្នុងទីនេះ ដែលឈ្មោះថា ទោសគង់នឹងមិនមាន ព្រោះដឹងរឿងជាមុន សូម្បីមានការសោកសៅ ក៏គង់នឹងធូរស្រាលខ្លះ ដូច្នេះ ។

បទថា **អជ្ជ សត្តាហំ បរិនិព្ពុតោ សមណោ គោតមោ** *ប្រែថា រាប់ដល់ថ្ងៃនេះ ព្រះសមណគោតមបរិនិព្វានបាន ៧ ថ្ងៃហើយ ។ បទថា* **តតោ មេ ឥទំ** *បានដល់ ផ្កាមន្ទារវៈនេះ ខ្ញុំរើសមកហើយអំពីទីបរិនិព្វានរបស់ព្រះសមណគោតមនោះ ។*

[១៥៥] *បទថា* **សុភទ្ទោ នាម វុឌ្ឍបព្វជិតោ** *សេចក្តីថា ពាក្យថា សុភទ្ទ ជាឈ្មោះរបស់កិកូនោះ តែព្រោះកិកូនោះ បួសឯចាស់ ទើបលោកហៅថា វុឌ្ឍបព្វជិត ។ ព្រោះហេតុអ្វី ទើបសុភទ្ទកិកូនោះ ពោលយ៉ាងនេះ ។ ព្រោះអាឃាតក្នុងព្រះមានព្រះភាគ ។ បានឮថា សុភទ្ទកិកូនេះ ធ្លាប់ជាជាងកោរកាត់ក្នុងក្រុងអាតុមានគរ ដែលមកក្នុងខន្ធកៈ បួសក្នុងវេលាចាស់ ជ្រាបថា កាលព្រះមានព្រះភាគស្តេចចេញចាកនគរកុសិនារា ទៅកាន់អាតុមានគរ ព្រមនឹងកិកូ ២៥០ រូប ។ ព្រះមានព្រះភាគ ស្តេចកំពុងមក ទើបគិតថា នឹងធ្វើយាគូទានថ្វាយក្នុងវេលាស្តេចមក ទើបហៅបុត្រ ២ នាក់ ដែលត្រៀមខ្លួននឹងបួសជាសាមណេរ ប្រាប់ថា នែបា បានឮថា ព្រះមានព្រះភាគព្រមទាំងព្រះកិកូសង្ឃជាច្រើន ចំនួន ២៥០ អង្គ យាងមកកាន់អាតុមានគរ ចូរបាកាន់កាំបិតកោរ នាឡិ និងទៃហើយ ទៅគ្រប់លំជាប់ផ្ទះ ចូរប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្គរខ្លះ ខាទនីយៈខ្លះ យើងនឹងធ្វើយាគូ ថ្វាយដល់ព្រះមានព្រះភាគ ដែល*

យាងមក ។ បុត្រ ២ នាក់នោះ ក៏បានធ្វើយ៉ាងនោះ ។ ពួកមនុស្សឃើញ ក្មេងទាំងនោះ មានសំឡេងពីរោះ មានការរាងវៃ ខ្លះប្រាថ្នានឹងឲ្យធ្វើ ខ្លះប្រាថ្នានឹងមិនឲ្យធ្វើ តែក៏ឲ្យធ្វើគ្រប់គ្នា សួរថា នែបា បានឹងទទួលក្នុងវេលាធ្វើឬ ។ ក្មេង ២ នាក់នោះប្រាប់ថា ពួកខ្ញុំមិនត្រូវការអ្វីដទៃ តែឪពុករបស់ខ្ញុំប្រាថ្នានឹងថ្វាយយាគូទាន ក្នុងវេលាដែលព្រះមានព្រះភាគយាងមក ។ ពួកមនុស្សបានស្តាប់ដូច្នោះហើយ ក៏មិនជំទាស់ ព្រមឲ្យវត្ថុដែលក្មេងទាំង ២ នាក់នោះអាចនាំទៅបានទាំងអស់ ដែលមិនអាចនាំទៅបាន ក៏បញ្ជូនបុរសឲ្យនាំទៅ ។ គ្រាព្រះមានព្រះភាគទ្រង់មកកាន់អាតុមានគរ ទ្រង់ក៏ចូលទៅកាន់រោងលានស្រូវក្នុងវេលាល្ងាច សុភទ្ទភិក្ខុក៏ទៅកាន់ចន្លោះស្រុក ហៅមនុស្សមកប្រាប់ថា ឧបាសកឧបាសិកាទាំងឡាយ ខ្ញុំមិនបានទទួលអ្វីៗ យ៉ាងដទៃអំពីសម្នាក់របស់លោកទាំងឡាយ អង្គវជាដើម ដែលកូនរបស់អាត្មានាំមក ក៏គ្រប់ល្មមដល់សង្ឃ ពួកលោកចូរឲ្យត្រឹមតែអ្នកមកជួយកិច្ចការចុះ ។ សួរថា ពួកខ្ញុំនឹងធ្វើយ៉ាងណាលោកម្ចាស់ ។ សុភទ្ទភិក្ខុនិយាយថា ពួកលោកចូរកាន់យកវត្ថុនេះៗ ហើយឲ្យកាន់គ្រឿងឧបករណ៍ទាំងអស់ ឲ្យធ្វើជើងក្រានជិតវិហារ ខ្លួនឯងស្លៀកកាសាវៈខ្មៅមួយផ្ទាំង ដណ្តប់មួយផ្ទាំង ហើយប្រាប់ថា ចូរធ្វើវត្ថុនេះសញ្ជឹងគិតរហូតអស់ ១ យប់ លះបង់ទ្រព្យមួយសែន ឲ្យគេរៀបចំយាគូសម្រាប់បរិភោគ និងទឹកឃ្មុំ ដុំស្ករអំពៅ ។ យាគូដែលគប្បីបរិភោគ ហើយហុត ឈ្មោះថា យាគូសម្រាប់បរិភោគ ។ របស់ មានទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅ ត្រី សាច់ ផ្កា ផ្លែឈើ និងរសជាដើមណាមួយ ឈ្មោះថា របស់ទំពា ជាក់របស់ទំពាទាំងអស់ចូលក្នុងយាគូនោះ ។ គន្ធជាតិដែលក្រអូប ដែល

គេប្រើលាបក្បាល សម្រាប់អ្នកត្រូវការលេងកីឡាក៏មាន ។ លុះវេលាព្រឹក ព្រលឹម ព្រះមានព្រះភាគបជិបត្តិព្រះសរីរកិច្ចហើយ មានភិក្ខុសង្ឃចោមរោម យាងទៅកាន់អាតុមានគរ ដើម្បីគ្រាច់បិណ្ឌបាត ។ មនុស្សទាំងឡាយ ក៏ប្រាប់ដល់សុភទ្ទភិក្ខុនោះថា ព្រះមានព្រះភាគទ្រង់កំពុងយាង ចូលស្រុកបិណ្ឌបាត លោកវៀបចំយាគូទុកដើម្បីអ្នកណា ។ សុភទ្ទភិក្ខុនោះ ស្បៃកដណ្តប់សំពត់កាសាវៈខ្មៅទាំងនោះ យកដៃម្ខាងចាប់វែក និងបោយ លុតជង្គង់ខាងស្តាំចុះលើផែនដី ថ្វាយបង្គំដូចព្រហ្មទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាទ្រង់ទទួលយាគូរបស់ខ្ញុំព្រះអង្គចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់សួរ និងទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់តិះដៀល សុភទ្ទ-វុឌ្ឍបព្វជិតនោះ ។ ព្រោះរឿងនោះ ទ្រង់បញ្ញត្ត ២ សិក្ខាបទ គឺសិក្ខាបទពោលអំពីការបំបួលក្នុងវត្តជាអកប្បិយៈ និងសិក្ខាបទដោយការរក្សាគ្រឿងកាំបិតកោរ ដោយនយដែលមកក្នុងខន្ធកៈថា ព្រះតថាគត សូម្បីទ្រង់ជ្រាបក៏ទ្រង់សួរដូច្នេះជាដើម ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលស្វែងរកកោជន កន្ទងទៅដល់ច្រើនកោដិកប្ប ពួកអ្នកបរិភោគកោជន ដែលជាអកប្បិយៈរបស់ពួកអ្នក ដែលកើតឡើងមិនប្រកបដោយធម៌ នឹងត្រូវទៅកើតក្នុងអបាយទាំងឡាយ ច្រើនសែនអត្តភាព ចូរចៀសទៅ ដូច្នេះហើយ ទ្រង់យាងទៅដើម្បីភិក្ខា សូម្បីភិក្ខុមួយរូប ក៏មិនបានទទួលរបស់ណាមួយឡើយ ។ សុភទ្ទភិក្ខុទោមនស្ស ក៏ចង់អាឃាតក្នុងព្រះមានព្រះភាគថា ព្រះមានព្រះភាគនេះយល់ថា តថាគតដឹងគ្រប់វត្តុយ៉ាង ទើបគ្រាច់ទៅ បើទ្រង់មិនជ្រាបថានឹងទទួល ក៏គួរបញ្ជូនមនុស្សឲ្យទៅជ្រាប ដែលឈ្មោះថា អាហារ

ដែលឆ្អិនហើយនេះ កាលនឹងតាំងនៅយូរបាន គប្បីតាំងនៅបានត្រឹមតែ ៧ ថ្ងៃ ពិតហើយ របស់នេះនឹងគប្បីជារបស់ដែលអញរៀបចំទុកមួយជីវិត ព្រះអង្គ ក៏ទ្រង់ធ្វើឲ្យវិនាសអស់ ព្រះមានព្រះភាគនេះ ទ្រង់មិនមានបំណងល្អចំពោះ អញឡើយ ។ កាលព្រះទសពលទ្រង់នៅមានព្រះជន្មនៅឡើយ ទើបមិនអាច ពោលពាក្យណាមួយបាន ។ បានឮថា សុភទ្ទកិក្ខុនោះគិតយ៉ាងនេះថា ព្រះ មហាបុរសនេះ បួសអំពីត្រកូលខ្ពស់ បើអញនិយាយអ្វីទៅ ក៏ទ្រង់នឹងគំរាម យើងតែម្នាក់ ។ លុះបានឮថា ព្រះមានព្រះភាគអង្គនេះ បរិនិព្វានហើយក្នុង ថ្ងៃនេះ ក៏ត្រេកអរដូចបានខ្សល់ដកដង្ហើម ទើបពោលយ៉ាងនេះ ។ ព្រះថេរៈ ស្តាប់ពាក្យនោះហើយ មិនបានសម្គាល់ថា ដូចជាត្រូវប្រហារត្រង់ហទយៈ ដូចជាមេឃប្រាសចាកពពកជាច់ធ្លាក់លើអំបែងក្បាល ។ តែព្រះថេរៈកើត ធម្មសង្វេគ ។ ព្រះមានព្រះភាគបរិនិព្វានបានត្រឹមតែ ៧ ថ្ងៃ ថ្ងៃនេះ ព្រះសរីរៈ របស់ព្រះអង្គ មានព្រះឆវីវណ្ណដូចមាស ក៏កំពុងតាំងនៅ ។ មន្ទិលចម្រូង ចម្រាសដ៏ធំកើតឡើងរហ័សយ៉ាងនេះ ក្នុងព្រះសាសនាដែលព្រះមានព្រះភាគ ទ្រង់នាំមកដោយទុក្ខលំបាក បុរសអាក្រក់នេះ កាលធំធាត់ បានអ្នកជំទែបែប នោះជាបក្ខពួក ក៏អាចនឹងធ្វើព្រះសាសនាឲ្យសាបសូន្យបាន ។ លំដាប់នោះ ព្រះថេរៈគិតថា បើអញឲ្យបុរសចាស់នេះស្លៀកសំពត់ចាស់ យកផេះរោយ សីសៈ បណ្តេញចេញទៅ មនុស្សទាំងឡាយ ក៏នឹងនាំគ្នាលើកទោសពួក យើងថា កាលព្រះសរីរៈរបស់ព្រះសមណគោតមតាំងនៅ នៅឡើយ ពួក សាវ័កក៏វិវាទគ្នា ព្រោះដូច្នោះ ទើបអញអត់សង្កត់ទុកសិន ឯធម៌ដែលព្រះ ដ៏មានព្រះភាគសម្តែងហើយនោះ ប្រៀបដូចផ្កាឈើទាំងឡាយ ដែលត្រូវខ្សល់

រមែងខ្ចាត់ខ្ចាយទៅ យ៉ាងណា សិក្ខាបទ ១-២ សិក្ខាបទ ក្នុងវិនយ ក៏នឹងវិនាស បញ្ហាវារៈ ១-២ វារៈ ក្នុងសូត្រក៏នឹងវិនាស ភូមិដទៃ ១-២ ភូមិក្នុងអភិធម្មក៏នឹងវិនាស ក្នុងកាលកន្លងទៅ ដោយអំណាចបុគ្គលអាក្រក់បែបនេះ ក៏ដូច្នោះដែរ ។ កាលឫសគល់វិនាសទៅយ៉ាងនេះ ពួកយើងក៏នឹងដូចជាបិសាច ។ ព្រោះដូច្នោះ យើងចាំបាច់ត្រូវសង្គាយនាព្រះធម៌វិនយ បើដូច្នេះ ធម៌នេះ វិនយនេះ ក៏នឹងរឹងមាំដូចផ្កាឈើដែលរក្សាទុកដោយអំបោះដ៏ស្អិត ក៏ដើម្បីប្រយោជន៍យ៉ាងនេះ ព្រះមានព្រះភាគទ្រង់មកទទួលអញ្ជើរហូតដល់អស់ផ្លូវចម្ងាយ ៣ គាវុត ប្រទានឧបសម្បទាដោយឱវាទ ៣ ប្រការ ទ្រង់ប្តូរចីវរអំពីព្រះវរកាយ ត្រាស់បដិបទាប្រៀបដូចជួងចន្ទ ដូចជាគ្រវីដៃក្នុងអាកាស ទ្រង់លើកតម្កើងអញជាកាយសក្ខី (មានវិហារធម៌ស្មើដោយព្រះអង្គ) ទ្រង់ប្រគល់ភាពជាសកលសាសនទាយាទ ៣ ជង់ថា កាលភិក្ខុដូចអញតាំងនៅភិក្ខុអាក្រក់នេះ នឹងមិនបានសេចក្តីចម្រើនក្នុងព្រះសាសនា ។ អធម៌មិនរុងរឿង ធម៌ក៏នឹងមិនសាបសូន្យអន់ថយ អវិនយមិនរុងរឿង វិនយក៏នឹងមិនសាបសូន្យអន់ថយ ចំណែកអធម្មវាទីមិនមានកម្លាំង ចំណែកធម្មវាទីក៏នឹងមិនខ្សោយកម្លាំង ចំណែកអវិនយវាទីមិនមានកម្លាំង ចំណែកវិនយវាទីក៏នឹងមិនខ្សោយកម្លាំងត្រឹមណា អញក៏នឹងសង្គាយនាធម៌ និងវិនយត្រឹមនោះ ។ តពីនោះ ពួកភិក្ខុរបួរមភិក្ខុដែលជាសកាគគ្នា ប្រហាក់ប្រហែលនឹងខ្លួន ក៏នឹងពោលវត្ថុដែលគួរ និងមិនគួរបាន បើដូច្នេះ ភិក្ខុអាក្រក់នេះឯងក៏ជួបនូវនិគ្គហៈមិនអាចងើបក្បាលបានទៀត ព្រះសាសនាក៏នឹងរឹងមាំ និងផ្សាយទូទៅ ។ ព្រះថេរៈគិតថា អញកើតចិត្តគិតយ៉ាងនេះហើយ មិនអាចប្រាប់ដល់បុគ្គលណា

មួយ បានត្រឹមតែលួងលោមភិក្ខុសង្ឆ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អថខោ មហាកស្សបោ អាយស្មា ។បេ។ នេតំ ឋានំ វិជ្ជតិ** ដូច្នេះ ។

[១៥៦] បទថា **ចិតកំ** បានដល់ ជើងថ្ពរ ដែលធ្វើដោយឈើចន្ទន៍ ប្រដាប់ដោយរតនៈពីរពាន់ ។ បទថា **អាលិម្បេស្សាម** បានដល់ នាំគ្នាដុតភ្លើង ។ បទថា **ន សក្ពោន្តិ** គឺជនទាំងឡាយ ៨ នាក់ខ្លះ ១៦ នាក់ខ្លះ កាន់គប់ភ្លើងជាគូ។ ដើម្បីធួលភ្លើង បក់ដោយស្លឹកត្នោត បាញ់ខ្យល់ដោយស្នប់ សូម្បីធ្វើការណ៍នោះ។ ក៏មិនអាចធ្វើឲ្យភ្លើងឆេះបាន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ទេវតានំ អធិប្បាយោ** នេះ ដូច្នេះថា បានញ្ចថា ទេវតាទាំងនោះ ជាទេវតាឧបដ្ឋាករបស់ព្រះថេរៈនុ៉ះឯង ។ សេចក្តីពិត ព្រោះចិត្តជ្រះថ្លាក្នុងព្រះអសីតិ-មហាសាវ័ក ឧបដ្ឋាក ៨០០០០ ត្រកូល របស់ព្រះមហាសាវ័កទាំងនោះ ក៏ទៅកើតក្នុងស្ថានសួគិ ។ លំដាប់នោះ ពួកទេវតាអ្នកមានចិត្តជ្រះថ្លាក្នុងព្រះថេរៈ ហើយកើតក្នុងសួគិ មិនឃើញព្រះថេរៈក្នុងសមាគមនោះ គិតថា ព្រះថេរៈប្រចាំត្រកូលរបស់ពួកយើងទៅទីណាហ្នឹ ក៏ឃើញលោកធ្វើដំណើរត្រង់ចន្លោះផ្លូវ ទើបនាំគ្នាអធិដ្ឋានថា កាលព្រះថេរៈប្រចាំត្រកូលរបស់ពួកយើងមិនទាន់បានថ្វាយបង្គំព្រះសរីរៈរបស់ព្រះមានព្រះភាគ សូមជើងថ្ពរកុំឆេះឡើយ ដូច្នេះ ។ ពួកមនុស្សស្តាប់រឿងនោះហើយ គិតថា បានញ្ចថា ព្រះមហាកស្សបពោលថា នែភិក្ខុ យើងនឹងថ្វាយបង្គំព្រះបាទរបស់ព្រះទសពល ព្រមនឹងភិក្ខុ ៥០០ រូប ដូច្នេះហើយ ទើបមក កាលមកមិនទាន់ដល់ជើងថ្ពរ ក៏មិនឆេះ អ្នកដ៏ចម្រើន ភិក្ខុនោះដូចម្តេច ឡៅ ស ខ្ពស់ ទាប កាលភិក្ខុដូច្នេះតាំងនៅ ហេតុដូចម្តេច ទើបព្រះទសពលបរិនិព្វាន ដូច្នេះហើយ ពួកខ្លះ កាន់គ្រឿង

ក្រអូប និងផ្កាជាដើម ដើរបញ្ជ្រោសផ្លូវ ពួកខ្លះ ធ្វើផ្លូវឲ្យស្អាតល្អ ឈរទន្ទឹងមើលផ្លូវ ។

បទថា **អថខោ អាយស្មា មហាកស្សបោ យេន កុសិនារា ។បេ។ សិរសោ វន្ទិ** *សេចក្តីថា បានឮថា ព្រះថេរៈធ្វើប្រទក្សិណជើងថ្កបណ្តើរ រំឭកកំណត់ថា ត្រង់នេះព្រះសិរសា ត្រង់នេះព្រះបាទ ។ តពីនោះ ព្រះថេរៈក៏ឈរជិតព្រះបាទទាំងពីរចូលចតុត្ថជ្ឈាន ដែលជាបាទនៃអភិញ្ញា ចេញចាកឈានហើយ អធិដ្ឋានថា សូមព្រះយុគលបាទរបស់ព្រះទសពល ដែលប្រកបដោយចក្កលក្ខណៈ ព្រមដោយកាំ ១០០០ ប្រតិស្ឋានហើយ សូមញែកគូសំពត់ ៥០០ គូ ព្រមនឹងជាន់សម្ថៈ មឃុសមាស និងជើងថ្កដែលសម្រេចអំពីឈើចន្ទន៍ចេញជា ២ ប្រហោង ប្រតិស្ឋានលើសីសៈរបស់ខ្ញុំព្រះអង្គផងចុះ ។ ដំណាលគ្នានឹងចិត្តអធិដ្ឋាន ព្រះបាទទាំងគូ ក៏ជ្រែកសំពត់ ៥០០ គូទាំងនោះជាដើមផុសចេញមក ដូចព្រះចន្ទ ១៥ កើត ចេញចាកចន្លោះវលាហកៈ ដូច្នោះ ។ ព្រះថេរៈលូកដៃទាំង ២ ដូចផ្កាបទុមក្រហមដែលរីកហើយ ចាប់ព្រះយុគលបាទរបស់ព្រះសាស្តា ដែលមានព្រះឆវីវណ្ណដូចមាស ជាបដល់កព្រះបាទទុកមាំហើយ ប្រតិស្ឋានទុកលើសិរ្សដ៏ប្រសើររបស់ខ្លួន ដោយហេតុនោះ ទើបលោកពោលថា បើកអំពីខាងព្រះបាទ ថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគដោយសិរ្ស ។ មហាជនឃើញសេចក្តីអស្ចារ្យដូច្នោះហើយ បន្ទឺសីហនាទដ៏ទ្រហឹងឡើងព្រមគ្នា បូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ហើយថ្វាយបង្គំតាមសេចក្តីពេញចិត្ត ។ លុះព្រះថេរៈ មហាជន និងភិក្ខុទាំង ៥០០ រូបនោះថ្វាយបង្គំហើយ ក៏មិនមានកិច្ចដែលនឹងត្រូវអធិដ្ឋានទៀត ។*

ដោយអំណាចអធិដ្ឋានតាមប្រក្រតីប៉ុណ្ណោះ បាតព្រះយុគលបាទរបស់ព្រះមានព្រះភាគមាន មានពណ៌ដូចទឹកលក្ត ផុតពីដៃរបស់ព្រះថេរៈហើយ មិនធ្វើឃើចនួន៍ជាដើមណាមួយឲ្យកម្រើក ប្រតិស្ឋាននៅក្នុងទីដើម ។ ពិតហើយ កាលព្រះយុគលបាទរបស់ព្រះមានព្រះភាគចេញមក ឬចូលទៅ សរសៃសម្ងីក្តី សរសៃសំពត់ក្តី ជំណក់ប្រេងក្តី ចម្រៀកឈើក្តី មិនឃ្លាតចាកទីទ្បើយ ទាំងអស់តាំងនៅដូចដើមនុ៉ះឯង ។ តែកាលព្រះយុគលបាទ របស់ព្រះតថាគតតាំងទ្បើងហើយក៏បាត់ភ្លាមទៅ ដូចព្រះចន្ទ និងព្រះអាទិត្យអស្តង្គត មហាជននាំគ្នាស្រែកយំយ៉ាងទ្រហឹង គួរករុណាក្រៃលែងជាងកាលបរិនិព្វានទៅទៀត ។ បទថា **សមយេវ ភគវតោ ចិតកោ បជ្ជលិ** នេះ លោកពោលដោយអំណាចមើលមិនឃើញបុគ្គលណាមួយ ដែលព្យាយាមនឹងធួលភ្លើង ។ ជើងថ្ពរនោះ ធេះភ្លាមនោះឯងដោយជុំវិញ ដោយអានុភាពរបស់ទេវតា ។ បទថា **សរីរាឆេវ អវសិស្សឹសុ** សេចក្តីថា កាលមុនបានឈ្មោះថា សរីរៈ ក៏ព្រោះតាំងនៅដោយគ្រោងធ្ម៉ឹងតែម្យ៉ាង ឥឡូវនេះ លោកពោលថា សរីរៈទាំងអស់ខ្ចាត់ខ្ចាយទៅហើយ ។ អធិប្បាយថា ព្រះធាតុទាំងឡាយ ក៏ដូចផ្ការម្ងិះក្រពុំ ដូចកែវមុក្តាដែលម្ជៃហើយ និងដូចកម្ទេចមាសនៅសល់ ។ ពិតហើយ សរីរៈ របស់ព្រះពុទ្ធដែលមានព្រះជន្មាយុវែងទាំងឡាយ រមែងជាប់គ្នាជាដុំដូចនឹងដុំមាស ។ ចំណែកព្រះមានព្រះភាគ ទ្រង់អធិដ្ឋានព្រះធាតុ ឲ្យបែកជាបំណែកថា តថាគតនៅបានមិនយូរ ក៏នឹងបរិនិព្វាន សាសនារបស់តថាគតមិនទាន់ផ្សាយច្រើនទៅក្នុងទីទាំងពួងទេ ព្រោះដូច្នោះ កាលតថាគតបរិនិព្វានហើយ មហាជនកាន់យកព្រះធាតុ សូម្បីទំហំប៉ុនគ្រាប់ស្ពៃ ធ្វើចេតិយក្នុងទីនៅរៀងៗ

ខ្លួន ប្រតិបត្តិ ចូរមានសួគ៌ជាទីទៅក្នុងខាងមុខ ។ សួរថា ព្រះធាតុណា របស់ព្រះអង្គ បែកជាបំណែក ព្រះធាតុណាមិនបែកជាបំណែក ។ ឆ្លើយថា ព្រះធាតុ ៧ នេះ គឺព្រះចង្កូមកែវ ៤ ព្រះអក្ខកធាតុ គឺឆ្អឹងដងកាំបិត ២ ព្រះឧណ្ហិស្ស គឺឆ្អឹងថ្ពាស ១ មិនបែកជាបំណែក ក្រៅអំពីនោះបែកជាបំណែក ។ បណ្តាព្រះធាតុទាំងនោះ ព្រះធាតុខ្នាតតូចៗ ទាំងអស់មានទំហំប៉ុនគ្រាប់ស្ពៃ ។ ព្រះធាតុខ្នាតកណ្តាលមានទំហំប៉ុនគ្រាប់អង្កាវបាក់ពាក់កណ្តាល ព្រះធាតុខ្នាតធំមានទំហំប៉ុនគ្រាប់សណ្តែកបាយមួយចំហៀង ។ បទថា **ឧទកធារា** *សេចក្តីថា ធ្លាវទឹកទំហំប៉ុនកដៃក្តី ទំហំប៉ុនស្មងជើងក្តី ទំហំប៉ុនដើមត្នោតក្តី ធ្លាក់អំពីអាកាសមកវម្ចត់ ។ បទថា* **ឧទកំ សាលតោបិ** *នេះ លោកពោលសំដៅយកដើមសាលព្រឹក្សដែលដុះជុំវិញ ។ ធ្លាវទឹកចេញពីចន្ទោះដើម និងចន្ទោះប្រគាបនៃដើមសាលព្រឹក្សទាំងនោះរម្ចត់ភ្លើង ។ ជើងថ្ករបស់ព្រះមានព្រះភាគខ្នាតធំ ។ ធ្លាវទឹកទំហំប៉ុនយាមនង្គ័ល ជ្រែកដីដោយជុំវិញ ដូចកម្រងកែវផលិកផុសឡើងរម្ចត់ជើងថ្ករ ។ បទថា* **គន្ធោឧកេន** *បានដល់ ទឹកក្រអូបច្រើនប្រភេទ ដែលគេដាក់ក្នុងភ្នួមមាស ភ្នួមប្រាក់ឲ្យពេញនាំមក ។ បទថា* **ឯញ្ជាបេសុំ** *សេចក្តីថា ពួកមល្លក្សត្រម្ចត់ជើងថ្ករ ធាយដោយដំបង ៨ កំណាត់ ដែលធ្វើដោយមាស និងប្រាក់ ។ កាលភ្លើងកំពុងឆេះជើងថ្ករនោះ អណ្តាតភ្លើងក៏បាញ់ឡើងអំពីចន្ទោះមែក ប្រគាប ស្វឹកនៃដើមសាលព្រឹក្ស ដែលដុះជុំវិញ ។ ស្វឹក មែក ឬផ្កាមិនឆេះឡើយ ។ ស្រមោចក្រហមក្តី ស្វាក្តី សត្វតូចៗក្តី ត្រាច់ទៅតាមចន្ទោះអណ្តាតភ្លើង ។ ធម្មតាក្នុងធ្លាវទឹក ដែលធ្លាក់អំពីអាកាសក្តី ក្នុងធ្លាវទឹកដែលចេញពីដើមសាលព្រឹក្សក្តី ក្នុងធ្លាវទឹកដែលញែក*

ផែនដីចេញមកក្តី គួរកាន់យកជាប្រមាណ ។ រម្ងាត់ជើងថ្ងៃយ៉ាងនេះហើយ ពួកស្តេចមល្លៈក៏ឲ្យប្រោះព្រំដោយគន្ធជាតិ ๔ ប្រភេទ ត្រង់សណ្ឋាគារ រោយផ្កាមានលាជជាគម្រប់ ๕ ប្រក់ពិតានសំពត់ទុកខាងលើ រំលេចដោយផ្កាយមាសជាដើម ព្យួរកម្រងក្រអូប កម្រងផ្កា និងកម្រងកែវ ឲ្យព័ទ្ធជាំជនន និងកន្ទេលផែងសងខាង តាំងពីសណ្ឋាគារដរាបដល់មង្គលសាលា ដែលប្រជាប់សីសៈពោល គឺមកុដពន្ធនៈ ហើយប្រក់ពិតានសំពត់ខាងលើ បន្តោងដោយផ្កាយមាសជាដើម ព្យួរកម្រងក្រអូប កម្រងផ្កា និងកម្រងកែវក្នុងទីនោះ ឲ្យលើកទង់ ๕ ពណ៌ ដែលមានជង់ជាមណី និងឫស្សី ព័ទ្ធទង់ជ័យ និងទង់ជ្ងាលាដោយជុំវិញ តម្កល់ដើមចេក និងក្អមទឹកតាមជង់ផ្លូវទាំងឡាយដែលប្រោះទឹក ហើយពង្រាបផ្លូវ អុជប្រទីបមានជង់ តម្កល់មឈូសមាស ព្រមដោយព្រះធាតុទាំង-ឡាយ លើកជំរំដែលប្រជាប់ហើយ បូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម លេងសាធុកីឡា នាំចូលទៅខាងក្នុងព្រះនគរ តម្កល់លើបល្ល័ង្កដែលធ្វើដោយរតនៈ ๗ ប្រការក្នុងសណ្ឋាគារ ជាំងស្វេតច្ឆត្រទុកខាងលើ ។ លុះធ្វើដូច្នេះហើយ គ្រានោះ ពួកមល្លក្សត្រអ្នកនគរកុសិនារា ឲ្យទាហានកាន់លំពែងធ្វើជារបងការពារ ឲ្យទាហានកាន់ធ្នូជាកំពែងព័ទ្ធត្រង់សណ្ឋាគារ បូជាព្រះសរីរៈរបស់ព្រះមានព្រះភាគ ដោយការលេងរបាំ ច្រៀង ការប្រគំ ផ្កាកម្រងគ្រឿងក្រអូប អស់ ๗ ថ្ងៃ បណ្ឌិតគប្បីជ្រាបដូចពោលមកដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សត្តិបញ្ជរំ ករិត្វា** បានដល់ ចាត់ពួកបុរសកាន់លំពែងឡោមព័ទ្ធ ។ បទថា **ធនុបាការំ** បានដល់ ចាត់ពួកជំរឿងលំជាប់ពោងទល់គ្នា ព័ទ្ធជុំវិញជាមុន តពីនោះ ចាត់ពួកសេះ រឿងលំជាប់កនិងកទល់គ្នា បន្ទាប់

អំពីនោះ ចាត់ពួករថរៀងលំដាប់ ចុងស្នៀតកង់រថទល់គ្នា ចាត់ពលថ្មើរជើងរៀងលំដាប់ដៃទល់ដៃតគ្នាព័ទ្ធជុំវិញទៀត ។ ចាត់ពួកធ្នូរៀងលំដាប់តគ្នាព័ទ្ធជុំវិញ ។ ពួកមល្ជក្សត្រចាត់រក្សារហូតដល់អស់ទីប្រមាណ មួយយោជន៍ ដោយជុំវិញ ៧ ថ្ងៃ ធ្វើដូចជាកូនគោពាក់ក្រោះ ដោយប្រការដូច្នេះ ។ លោកសំដៅយកសេចក្តីនោះ ទើបពោលថា **ធនុចាការំ បរិក្ខិចាបេត្វា** ដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ទើបពួកមល្ជក្សត្រទាំងនោះបានធ្វើដូច្នោះ ។ ឆ្លើយថា ក្នុង ២ សប្តាហ៍ដំបូងនេះ មល្ជក្សត្រទាំងនោះ ធ្វើឱកាសដែលឈរ និងអង្គុយសម្រាប់ភិក្ខុសង្ឆ ចាត់ចែងរបស់ទំពា របស់ធាន់ប្រគេន មិនបានឱកាសលេងសាធុកីឡា ។ បន្ទាប់អំពីនោះ មល្ជក្សត្រទាំងនោះគិតគ្នាថា ពួកយើងនឹងលេងសាធុកីឡារហូតអស់ ១ សប្តាហ៍នេះ ។ សេចក្តីដែលបុគ្គលណាមួយដឹងថា ពួកយើងប្រមាទ ហើយមកកាន់យកព្រះធាតុទាំងឡាយចេញទៅ មិនជាឋាន: ដែលនឹងប្រព្រឹត្តទៅបាន ព្រោះដូច្នោះ ពួកយើងនឹងត្រូវតាំងកងរក្សាហើយលេងកីឡា ដោយហេតុនោះ ទើបមល្ជក្សត្រទាំងនោះ ធ្វើដូច្នោះ ។

ការចែកព្រះធាតុ

[១៥៧] បទថា **អស្សោសិ ខោ រាជា** សេចក្តីថា ព្រះបាទអជាតសត្តុទ្រង់ជ្រាបហើយ ។ បានញ្ចថា ពួកអមាត្យរបស់ព្រះរាជាគិតតាំងអំពីដំបូងថា ធម្មតាថា ព្រះសាស្តាបរិនិព្វានហើយ បុគ្គលណាមួយ ក៏មិនអាចនាំព្រះអង្គមកបាន តែមិនមានអ្នកស្មើដូចព្រះរាជារបស់យើង ដោយសទ្ធារបស់បុថុជ្ជនបើព្រះរាជាអង្គនេះនឹងទ្រង់ស្តាប់ដោយទំនងនេះ ហប្ចទ័យរបស់ទ្រង់នឹងត្រូវបែក តែពួកយើងគួរប្រុងប្រយ័ត្នរក្សាព្រះរាជា ដូច្នេះ ។ ទើបអមាត្យទាំងនោះ

នាំមឈូសមាស ៣ ជាក់មធុរសពេញ នាំទៅកាន់រាជសម្នាក់ ក្រាបទូលថា បពិត្រទេវៈ ពួកខ្ញុំព្រះអង្គយល់សប្តិឃើញព្រះអង្គ គួរស្មៀកសំពត់សម្បកឈើពីរជាន់ ហើយផ្ងុំក្នុងមឈូស ដែលពេញដោយមធុរស ៤ យ៉ាង ទុកតែប្រហោងដកដង្ហើម ដើម្បីកម្ចាត់ការយល់សប្តិនោះចេញ ព្រះរាជាស្តាប់ពាក្យរបស់ពួកអមាត្យអ្នកប្រាជ្ញាល្អ ទ្រង់ត្រាស់ថា នែបា យកមកចុះ ទ្រង់បានធ្វើយ៉ាងនោះ ។ លំដាប់នោះ អមាត្យម្នាក់ដោះគ្រឿងប្រដាប់ ហើយរម្សាយសក់ឲ្យបែរមុខទៅទិសដែលព្រះសាស្តាបរិនិព្វាន ផ្គងអញ្ជលីទូលព្រះរាជាថា ព្រះអង្គ ដែលឈ្មោះថា សត្វអ្នករួចផុតអំពីសេចក្តីស្លាប់មិនមានទេ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាអ្នកចម្រើនជន្មាយុ ជាចេតិយដ្ឋាន ជាបុញ្ញក្ខេត្ត ជាព្រះទែនអភិសេក ជាសាស្តានៃយើងទាំងឡាយ បរិនិព្វានហើយ ក្នុងនគរកុសិនារា ព្រះរាជាទ្រង់ស្តាប់ហើយ ក៏ដល់នូវវិសញ្ញីភាព គឺសន្លប់ បញ្ចេញចំហាយក្តៅក្នុងមឈូសដែលពេញដោយមធុរស ៤ យ៉ាង លំដាប់នោះ ពួកអមាត្យក៏លើកព្រះអង្គទ្បើងអំពីមឈូសទី ១ នោះ ឲ្យផ្ងុំក្នុងមឈូសទី ២ ។ ទ្រង់ដឹងខ្លួនទ្បើង ត្រាស់សួរថា នែបា ពួកអ្នកនិយាយអ្វីហ្ន៎ ។ អមាត្យក្រាបទូលថា បពិត្រមហារាជ ព្រះសាស្តាបរិនិព្វានហើយ ។ ព្រះរាជាទ្រង់ក៏វិសញ្ញីភាពម្តងទៀត បញ្ចេញចំហាយក្តៅក្នុងមឈូសដែលមានមធុរស ៤ យ៉ាង ។ លំដាប់នោះពួកអមាត្យនាំគ្នាលើក ព្រះរាជាទ្បើងអំពីមឈូសទី ២ នោះ ហើយឲ្យផ្ងុំក្នុងមឈូសទី ៣ ។ ព្រះរាជាទ្រង់ដឹងខ្លួនទ្បើងត្រាស់សួរថា នែបា ពួកបានិយាយអ្វីហ្ន៎ ។ អមាត្យក្រាបទូលថា ព្រះសាស្តាបរិនិព្វានហើយ ។ ព្រះរាជាក៏ទ្រង់វិសញ្ញីភាពទៀត ។ គ្រានោះ ពួកអមាត្យនាំគ្នាលើក

ព្រះអង្គឡើងឲ្យស្រង់ទឹក យកភ្នែមទឹកក្តៅស្រោចលើព្រះសិរ្ស ។ ព្រះរាជាទ្រង់ចាំបានហើយ ក្រោកចាកទីប្រថាប់រម្យាយព្រះកេសា ដែលមានពណ៌ដូចកែវមណី អប់ដោយគ្រឿងក្រអូបទម្លាក់សក់ទៅលើព្រះបិដ្ឋិ ដែលមានពណ៌ដូចផែនមាស យកព្រះហស្តគក់ទ្រូង ចាប់ទ្រូងដែលមានពណ៌ដូចផ្ទៃបាសមាស ហាក់បីដូចជាចាក់ដោយម្រាមព្រះហស្តដ៏មូលស្រឡូន ដែលមានពណ៌ដូចពន្លកកែវពពាល ទ្រង់ទួញយំ យាងចុះទៅក្នុងចន្ទោះផ្លូវ ដោយកេរបស់អ្នកវិកលចរិត ទ្រង់មានឥរិយាបថដែលតែងខ្លួនហើយជាបរិវារ ស្តេចចេញចាកព្រះនគរទៅកាន់ចម្ការស្វាយរបស់ពេទ្យជីវក ទតស្តានទីដែលព្រះមានព្រះភាគគង់សម្តែងធម៌ បរិទេវនាការដដែលៗ ថា ព្រះមានព្រះភាគជាសព្វញ្ញូ គង់សម្តែងធម៌ទីនេះ មិនមែនឬ ទ្រង់បន្ទោបង់សេចក្តីសោករបស់ខ្ញុំព្រះអង្គ ព្រះអង្គទ្រង់នាំសេចក្តីសោករបស់ខ្ញុំព្រះអង្គចេញទៅ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមកកាន់សម្នាក់របស់ព្រះអង្គហើយ តែឥឡូវនេះ ព្រះអង្គមិនប្រទានសូម្បីពាក្យឆ្លើយឆ្លងដល់ខ្ញុំព្រះអង្គ និងគ្រាស់ពាក្យជាដើមយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គស្តាប់មកក្នុងវេលាជទៃ មិនមែនឬថា ក្នុងវេលាបែបនោះ ព្រះអង្គមានភិក្ខុសង្ឃពួកធំជាបរិវារ ស្តេចចារិកទៅក្នុងភាគផែនជីជម្ពូទ្វីប តែឥឡូវនេះ ខ្ញុំព្រះអង្គក៏បានតែស្តាប់រឿងដែលមិនសមគួរមិនគួរដល់ព្រះអង្គឡើយ ហើយទ្រង់រំឭកព្រះគុណ របស់ព្រះមានព្រះភាគដោយគាថាប្រមាណ ៦០ ទ្រង់ព្រះតម្រិះថា អ្វីៗ រមែងមិនសម្រេចបានដោយបរិ-ទេវនាការរបស់អញ អញនឹងឲ្យនាំព្រះបរមធាតុរបស់ព្រះទសពលមក ។ ទ្រង់ស្តាប់មកយ៉ាងនេះហើយ កាលទ្រង់បាត់វិសញ្ញីភាពជាដើមហើយ ក៏បញ្ជូនទូត

ទៅ ។ លោកសំដៅយកវៀងនោះ ទើបពោលថា **អថ ខោ រាជា** *ជាដើម ។ បណ្តាបទទាំងនោះ បទថា* **ទូតំ បាហេសិ** *បានដល់ ទ្រង់បញ្ជូនទូត និង បណ្តាការទៅ ។ ព្រះបាទអជាតសត្តុទ្រង់ព្រះតម្រិះថា បើពួកមល្លក្សត្រឲ្យ ក៏ ជាការល្អ បើគេមិនឲ្យអញនឹងត្រូវនាំមកដោយឧបាយ គឺនាំមកឲ្យខាងតែបាន ដូច្នេះហើយ ទ្រង់ចាត់កងទ័ព ៤ ពួក យាងចេញទៅដោយព្រះអង្គឯង ។ សូម្បីពួកស្តេចលិច្ឆវីជាដើម ក៏បញ្ជូនទូតទៅ យាងចេញទៅដោយព្រះអង្គឯង ព្រមដោយកងទ័ព ៤ ពួក ដូចព្រះបាទអជាតសត្តុដូច្នោះ ។ បើមានពាក្យ សួរថា បណ្តាស្តេចទាំងនោះ មល្លក្សត្រអ្នកនគរបាវា មានចម្ងាយជិតជាងគេ ទាំងអស់ នៅក្នុងនគរបាវាចម្ងាយ ៣ គាវុត អំពីនគរកុសិនារា សូម្បីព្រះ មានព្រះភាគស្តេចយាងទៅនគរបាវាហើយ ស្តេចក៏យាងទៅកាន់នគរកុសិនារា បើដូច្នោះ ព្រោះហេតុអ្វី ទើបពួកមល្លក្សត្រនគរបាវា ស្តេចមិនមកជាមុន ។ ឆ្លើយថា ព្រោះថា ពួកស្តេចទាំងនោះ មានបរិវារច្រើន កាលធ្វើកិច្ចចំពោះ បរិវារដ៏ច្រើន ទើបមកតាមក្រោយ ។ បទថា* **តេ សព្ពេ គណោ ឯតទវោចុំ** *សេចក្តីថា ពួកស្តេច និងព្រាហ្មណ៍ទាំងអស់នោះ រួមជាអ្នកនគរ ៧ នគរ នាំ គ្នាមកហើយ ប្រកាសពាក្យជាច់ខាតថា ពួកស្តេចមល្លៈនឹងឲ្យព្រះបរមធាតុ ដល់ពួកយើង ឬក៏ច្បាំង ។ ហើយតាំងទ័ពឡោមព័ទ្ធនគរកុសិនារា ពួកស្តេច មល្លៈក៏បានពោលពាក្យឆ្លើយឆ្លងទៅថា ព្រះមានព្រះភាគស្តេចបរិនិព្វានក្នុង គាមក្ខេត្តរបស់ពួកយើងនេះ ។ បានឮថា ស្តេចទាំងនោះ ត្រាស់យ៉ាងនេះថា ពួកយើងមិនបានបញ្ជូនដំណឹងរបស់ព្រះសាស្តា ពួកយើងទៅក៏មិនបាននាំ ដំណឹងមក តែព្រះសាស្តាស្តេចមកដោយព្រះអង្គឯង ទ្រង់បញ្ជូនដំណឹងទៅ*

ត្រាស់បង្គាប់ឲ្យហៅពួកយើង ទោះបីពួកលោក ក៏មិនឲ្យរតន:ដែលកើតក្នុង គាមក្ខេត្តរបស់ពួកលោកដល់ពួកយើងដែរ ធម្មតាថា រតន: ដែលស្មើដោយ ពុទ្ធរតន:មិនមានក្នុងលោក ព្រមទាំងទេវលោក ពួកយើងបានរតន:ដ៏ឧត្តុង្គ ឧត្តមបំផុតបែបនេះនឹងមិនព្រមឲ្យ ពួកលោកប៉ុណ្ណោះឬ ដែលផឹកទឹកដោះ របស់មាតា ពួកយើងមិនបានផឹកឬ ។ ពួកលោកប៉ុណ្ណោះជាកូនប្រុស ពួក យើងមិនមែនជាកូនប្រុសទេឬ គឺដូចតែគ្នា ក៏ធ្វើអហង្ការបញ្ជូនសាសន៍ឆ្លើយ ឆ្លងគ្នា ប្រើមានះគំរាមដល់គ្នានឹងគ្នា ។ កាលបើមានការច្បាំងគ្នា ចំណែកពួក មល្លក្សត្រក្រុងកុសិនារា គួរបានជ័យជម្នះ ។ ព្រោះហេតុអ្វី ព្រោះពួកទេវតា ដែលនាំគ្នាមកដើម្បីបូជាព្រះបរមធាតុ ត្រូវជាបក្ខពួករបស់មល្លក្សត្រក្រុង កុសិនារាទាំងអស់ ។ តែក្នុងព្រះបាលីមកត្រឹមតែប៉ុណ្ណោះថា មល្លក្សត្រក្រុង កុសិនារាពោលថា ព្រះមានព្រះភាគ បរិនិព្វានក្នុងគាមក្ខេត្តរបស់ពួកយើង ពួកយើងនឹងមិនព្រមឲ្យចំណែកនៃព្រះសរីរៈរបស់ព្រះមានព្រះភាគ ដូច្នេះ ។

[១៥៨] *បទថា* **ឯវំ វុត្តេ ទោណោ ព្រាហ្មណោ** *សេចក្តីថា ទោណ-ព្រាហ្មណ៍ស្តាប់រឿងវិវាទរបស់ក្សត្រ និងព្រាហ្មណ៍ទាំងនោះហើយ ត្រិះរិះថា ពួកស្តេចទាំងនេះបង្កវិវាទគ្នាក្នុងស្ថានទីព្រះមានព្រះភាគបរិនិព្វាន ។ ជាការ មិនសមគួរ ។ ការឈ្លោះគ្នានេះ គួរនឹងលួមប៉ុណ្ណឹងហើយ អញនឹងរម្ងាប់ វិវាទនោះចេញ ដូច្នេះហើយ ក៏ទៅពោលសេចក្តីនេះដល់ពួកគណៈ ស្តេចទាំង នោះ ។ សួរថា ពោលដូចម្តេច ឆ្លើយថា ទោណព្រាហ្មណ៍ ឈរក្នុងទីទួល បានពោលគាថា ដែលឈ្មោះថា* **ទោណគជិត** *(ការបន្ទឹរបស់ទោណ-ព្រាហ្មណ៍) ប្រមាណ ២ ភាណវារ ។ បណ្តាភាណវារទាំង ២ នោះ ភាណវារ*

មុន ពួកស្តេចទាំងនោះមិនដឹង សូម្បីតែមួយបទ ។ ចប់ភាណវារទី ២ ពួកស្តេចទាំងអស់និយាយគ្នាថា អ្នកដ៏ចម្រើននោះ មើលទៅដូចជាសំឡេងរបស់លោកអាចារ្យនេះៗ ហើយ ក៏នាំគ្នាស្ងាត់សំឡេង ។ បានឮថា ក្នុងភាគផែនដីជម្ពូទ្វីប អ្នកដែលកើតក្នុងផ្ទះរបស់ត្រកូលដោយច្រើន ឈ្មោះថា មិនជាសិស្សរបស់ទោណព្រាហ្មណ៍នោះ មិនមានឡើយ ។ គ្រានោះ ទោណព្រាហ្មណ៍ដឹងថា ស្តេចទាំងនោះ ស្តាប់ពាក្យរបស់ខ្លួនហើយនៅស្ងៀម ទើបបានពោលពាក្យដដែល បានពោល ២ គាថានេះថា **សុណន្តុ ភោន្តោ** *ជាដើម ។*

បណ្តាបទទាំងនោះ បទថា **អម្ហាកំ ពុទ្ធោ** *ប្រែថា ព្រះពុទ្ធរបស់ពួកយើង ។ បទថា* **អហុ ខត្តិយោ** *សេចក្តីថា ព្រះអង្គសូម្បីមិនទាន់សម្រេចពុទ្ធភូមិ ទ្រង់បំពេញបារមីទាំងឡាយ ទ្រង់មិនធ្វើសេចក្តីក្រោធក្នុងអ្នកដទៃៗ បានធ្វើតែខន្តីតែម្យ៉ាង ទ្រង់សរសើរខន្តីតែម្យ៉ាង សម័យសោយព្រះជាតិ ជាខន្តិវាទិតាបស សម័យជាធម្មបាលកុមារ សម័យជាស្តេចជីវកុទ្ទាល សម័យជាស្តេចនាគឈ្មោះភូរិទត្ត សម័យជាស្តេចនាគឈ្មោះចម្បេយ្យកៈ សម័យជាស្តេចនាគឈ្មោះសង្ខបាល សម័យជាមហាកប្បិ និងក្នុងជាតកដទៃៗ ជាច្រើន ។ នឹងចាំបាច់ពោលទៅថ្វីឥឡូវនេះ ព្រះពុទ្ធនៃយើងទ្រង់សម្រេចលក្ខណៈ កាពជាបុគ្គលមិនញាប់ញ័រ មាំក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ មានព្រះវាទៈក្នុងរឿងខន្តី ។ ការដែលពួកយើងមកកាប់សម្លាប់គ្នា ក្នុងហេតុរឿងចែកព្រះសរីរៈរបស់ព្រះអង្គដែលជាឧត្តមបុគ្គល ដូចពោលមកនេះ មិនល្អឡើយ ។ បទថា* **ន ហិ សាធុយំ** *កាត់បទជា* **ន ហិ សាធុ អយំ** *។ បទថា* **សរីរភាគេ** *ប្រែថា និមិត្តនៃចំណែករបស់ព្រះសរីរៈ អធិប្បាយថា ហេតុចំណែកនៃព្រះបរម-*

ធាតុ ។ បទថា **សិយ សម្ឆហាវោ** លោកអធិប្បាយថា ការប្រហារគ្នាដោយ អាវុធមិនល្អទ្បើយ ។ បទថា **សព្វេវ ភោន្តោ សហិតា** សេចក្តីថា នែលោក ដ៏ចម្រើនទាំងឡាយ ពួកលោកទាំងអស់ចូររួបរួមគ្នា កុំបែកគ្នាទ្បើយ ។ បទថា **សមគ្គា** បានដល់ ចូរជាអ្នកព្រមព្រៀងគ្នា និយាយពាក្យជាមួយគ្នា សាមគ្គីគ្នា តាមផ្លូវកាយ និងវាចាចុះ ។ បទថា **សម្មោទមានា** បានដល់ ចូរជាអ្នក រីករាយរកគ្នានឹងគ្នា សូម្បីតាមផ្លូវចិត្តចុះ ។ បទថា **ឥវោមជ្ជ ភាគេ** សេចក្តី ថា ចូរបែងចែកព្រះសរីរៈរបស់ព្រះមានព្រះភាគជា ៨ ចំណែក ។ បទថា **ចក្ខុមតោ** បានដល់ ព្រះពុទ្ធទ្រង់មានចក្ខុដោយចក្ខុ ៥ ។ ទោណព្រាហ្មណ៍ បានពោលហេតុជាច្រើន ឲ្យយល់ថា មិនមែនពួកលោកតែម្នាក់ដែលជ្រះថ្លា សូម្បីមហាជនក៏ជ្រះថ្លា ជនទាំងនោះ ដែលឈ្មោះថា មិនគួរនឹងបានចំណែក ព្រះសរីរៈមិនមាន សូម្បីតែម្នាក់ ។

[១៥៩] បទថា **តេសំ សង្ឆានំ គណានំ បដិស្សុណិត្វា** សេចក្តីថា ព្រោះពួកគណៈដែលមកប្រជុំគ្នាអំពីទីនោះៗ ទាំងនោះ ព្រមស្តាប់ គឺយល់ ព្រម ទើបទោណព្រាហ្មណ៍ បែងចែកព្រះសរីរៈរបស់ព្រះមានព្រះភាគជា ៨ ចំណែក ស្មើៗ គ្នា ។ លំដាប់សេចក្តីក្នុងរឿងនោះ មានដូច្នេះ បានត្ថថា ព្រោះ ស្តេចទាំងនោះយល់ព្រម ទើបទោណព្រាហ្មណ៍បង្គាប់ឲ្យបើកមឈូសមាស ។ ស្តេចទាំងឡាយក៏មកឈរ ត្រង់មឈូសមាសនុ៉ះឯង នាំគ្នាមើលឃើញព្រះ បរមធាតុទាំងឡាយ មានពណ៌ដូចមាស នាំគ្នាយំរៀបរាប់ថា បពិត្រព្រះមាន ព្រះភាគជាសព្វញ្ញូ អំពីមុនខ្ញុំព្រះអង្គទាំងឡាយបានឃើញព្រះសរីរៈ របស់ ព្រះអង្គមានពណ៌ដូចមាស ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ

វិចិត្តដោយព្រះពុទ្ធរស្មី មានពណ៌ ៦ ប្រការ ល្អរុងរឿងដោយអនុព្យញ្ជន: ៨០ ប្រការ តែឥឡូវនេះ ក៏នៅសល់តែព្រះបរមធាតុ មានពណ៌ដូចមាស បពិត្រព្រះមានព្រះភាគ ការណ៍នេះមិនសមគួរដល់ព្រះអង្គឡើយ ។ សម័យ នោះ សូម្បីទោណព្រាហ្មណ៍ដឹងថា ស្តេចទាំងនោះឆ្ងល់ប្រហែស ក៏កាន់យក ព្រះចង្កឹមកែវខាងស្តាំ រក្សាទុកក្នុងសំពត់ជួតក្បាល ។ តមកខាងក្រោយ ទើប បែងចែកជា ៨ ចំណែកស្មើៗ គ្នា ព្រះបរមធាតុទាំងអស់ រួមបាន ១៦ នាឡិ ដោយនាឡិតាមប្រក្រតី ស្តេចមួយនគរៗ បាន ២ នាឡិគ្រប់គ្នា ។ ចំណែក ទោណព្រាហ្មណ៍កាលកំពុងបែងចែកព្រះបរមធាតុនុ៎ះឯង សក្កទេវរាជជាស្តេច ទេវតាពិចារណាមើលថា អ្នកណាហ្ន៎យកព្រះចង្កឹមកែវខាងស្តាំរបស់ព្រះមាន ព្រះភាគ ដែលជាបច្ច័យនៃការគ្រាស់រឿងសច្ច: ៤ ដើម្បីទ្រង់ប្រាថ្នាកាត់ សេចក្តីសង្ស័យរបស់លោក ព្រមទាំងទេវលោក ក៏ទ្រង់ឃើញថា ព្រាហ្មណ៍ កាន់យកទៅ ។ ទ្រង់ត្រិះរិះថា សូម្បីព្រាហ្មណ៍ ក៏មិនអាចធ្វើសក្ការៈដ៏គួរដល់ ព្រះចង្កឹមកែវបាន ចាំបាច់យើងនឹងកាន់យកព្រះចង្កឹមកែវនោះ ហើយទ្រង់កាន់ យកអំពីសំពត់ជួតក្បាល ជាក់ក្នុងប្រអប់មាសនាំទៅកាន់ទេវលោក ប្រតិស្ឋាន ក្នុងព្រះចូឡាមណីចេតិយ ។ ចំណែកព្រាហ្មណ៍ លុះបែងចែកព្រះបរមធាតុ ហើយ មិនឃើញព្រះចង្កឹមកែវ តែព្រោះខ្ជនកាន់យកដោយកិរិយានៃចោរ ទើប មិនអាចនឹងសួរថា អ្នកណាយកព្រះចង្កឹមកែវរបស់យើងទៅ ។ ឃើញតែការ លើកទោសក្នុងខ្ជនឯងថា អ្នកឯងប៉ុណ្ណោះ បែងចែកព្រះបរមធាតុមិនមែនឬ ហេតុដូចម្តេចអ្នកឯងមិនដឹងថា ព្រះបរមធាតុរបស់ខ្ជនមាន ឬមិនមាន ។ គ្រា នោះ ព្រាហ្មណ៍គិតថា នាឡិមាសនេះ ក៏មានគតិដូចព្រះបរមធាតុ អញនឹងធ្វើ

នាឡិមាសដែលវាល់ព្រះបរមធាតុរបស់ព្រះតថាគត ជាសប្ញបហើយ ទើបទូលថា លោកដ៏ចម្រើនទាំងឡាយ មេត្តាប្រទាននាឡិនេះដល់ខ្ញុំចុះ ។

[១៦០] *ពួកស្តេចមោរិយៈ ក្រុងបិប្ផលិវ័ន ក៏បញ្ជូនទូតទៅត្រៀមការច្បាំង លើកចេញទៅ ដូចព្រះបាទអជាតសត្តុជាដើម ។*

[១៦១] *ព្រះបាទអជាតសត្តុ ទ្រង់បានសាងព្រះសប្ញប បញ្ចុះព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ និងធ្វើបុណ្យដ៏ធំក្នុងក្រុងរាជគ្រឹះ ។ សួរថា ទ្រង់ធ្វើដូចម្តេច ឆ្លើយថា ទ្រង់ធ្វើតាំងពីក្រុងកុសិនារា រហូតដល់ក្រុងរាជគ្រឹះ មានចម្ងាយផ្លូវ ២៥ យោជន៍ ។ ក្នុងចន្លោះនោះ ទ្រង់ឲ្យធ្វើផ្លូវទទឹង ៨ ឧសភៈ ពង្រាបដីឲ្យរាបស្មើ បង្គាប់ឲ្យធ្វើការបូជាក្នុងផ្លូវ ២៥ យោជន៍ ដូចដែលពួកស្តេចមល្លៈបង្គាប់ឲ្យធ្វើការបូជាចន្លោះមកុដពន្ធនចេតិយ និងសណ្ឋាគារ ទ្រង់ពង្រីកទៅក្នុងចន្លោះផ្សារក្នុងទីគ្រប់កន្លែង ដើម្បីអនុគ្រោះដល់មនុស្សលោក ទ្រង់ឲ្យការពារព្រះបរមធាតុ ដែលបញ្ចុះក្នុងមឈូសមាស ដោយរបងលំពែងឲ្យមនុស្សប្រជុំគ្នាជាបរិមណ្ឌល ៥០០ យោជន៍ ក្នុងដែនរបស់ព្រះអង្គ ។ មនុស្សទាំងនោះទទួលព្រះបរមធាតុ លេងសាធុកីឡា ចេញចាកក្រុងកុសិនារា ឃើញផ្កាមានពណ៌ដូចមាសក្នុងទីណាៗ ក៏បេះផ្កាទាំងនោះក្នុងទីនោះៗ បូជាព្រះបរមធាតុក្នុងចន្លោះលំពែង កាលផ្កាទាំងនោះអស់ហើយ ក៏ធ្វើដំណើរតទៅ កាលកន្លុះរនេះមកដល់ស្ថាននៃនិម[1] ក៏នាំគ្នាលេងសាធុកីឡាមួយកន្លែងៗ ៧ ថ្ងៃ កាលមនុស្សទទួលព្រះបរមធាតុនាំគ្នាមក ដោយអាការយ៉ាងនេះ វេលាក៏កន្លងទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ពួកមនុស្សមិច្ឆាទិដ្ឋិនាំគ្នាតិះដៀលថា តាំងអំពី*

១- សេចក្តីថា ប្រវែង ១ រនេះ ទ្រង់ឈប់ ៧ ថ្ងៃៗ ហើយលេងសាធុកីឡា ។

ព្រះសមណគោតមបរិនិព្វាន ពួកយើងក៏ក្រវល់ក្រវាយ ដោយការលេង សាធុកីឡា ដោយពលការ ការងាររបស់ពួកយើងវិនាសទៅអស់ហើយ ក៏ អាក់អន់ចិត្ត ទៅកើតក្នុងអបាយប្រមាណ ៨៦០០០ នាក់ ។ ពួកព្រះខីណាស្រព ពួកហើយ ឃើញថា មហាជនក្តៅក្រហាយចិត្ត កើតក្នុងអបាយ ហើយ ត្រិះរិះថា នឹងឲ្យសក្កទេវរាជធ្វើឧបាយ នាំព្រះបរមធាតុមក ដូច្នេះ ទើបនាំគ្នា ទៅកាន់សម្នាក់សក្កទេវរាជនោះ ទូលប្រាប់រឿងនោះ ហើយទូលថា បពិត្រ មហារាជ សូមទ្រង់មេត្តាធ្វើឧបាយ នាំព្រះបរមធាតុមកចុះ ។ សក្កទេវរាជ ត្រាស់ថា បពិត្រលោកម្ចាស់ ដែលឈ្មោះថាបុថុជ្ជនដែលមានសទ្ធាស្មើដោយ ព្រះបាទអជាតសត្តុមិនមាន ព្រះអង្គទ្រង់មិនជឿខ្ញុំទេ តែខ្ញុំនឹងសម្តែងវត្ថុដែល គួរភ័យខ្លាច ។ ដូចមារដែលគួរភ័យខ្លាច នឹងប្រកាសឲ្យលាន់ឮ នឹងធ្វើជាអ្នក ជំងឺញ័រទ្រើត ដូចមនុស្សរន្ធោចចូល សូមលោកម្ចាស់ទូលថា មហាបពិត្រ ពួកអមនុស្សគេក្រោធខឹង មេត្តាឲ្យនាំព្រះបរមធាតុទៅដោយរហ័ស ដោយ ឧបាយយ៉ាងនេះ ព្រះរាជាក៏នឹងទ្រង់ឲ្យនាំព្រះបរមធាតុទៅ ។ គ្រានោះឯង សក្កទេវរាជក៏បានធ្វើវត្ថុគ្រប់យ៉ាងដូចពោលនោះ ចំណែកព្រះថេរៈទាំងឡាយ ក៏ចូលទៅគាល់ព្រះរាជាទូលថា ថ្វាយព្រះពរ ពួកអមនុស្សគេក្រោធខឹង មេត្តា ឲ្យនាំព្រះបរមធាតុទៅចុះ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ចិត្តរបស់ ញោមមិនទាន់អស់សេចក្តីត្រេកអរ តែបើដូច្នោះ ក៏នឹងឲ្យគេនាំព្រះបរមធាតុ ទៅ ។ ក្នុងថ្ងៃទី ៧ មនុស្សទាំងឡាយ ក៏នាំព្រះបរមធាតុមកដល់ ។ ព្រះ រាជាទ្រង់ទទួលព្រះបរមធាតុមកដោយអាការយ៉ាងនោះ ទ្រង់សាងព្រះសថូប ក្នុងក្រុងរាជគ្រឹះ និងទ្រង់ធ្វើមហកម្ម គឺបុណ្យធំ ។ សូម្បីពួកស្តេចដទៃៗ ក៏នាំ

ទៅតាមសមគួរដល់កម្ចាំង វៀងៗ ខ្ជួន សាងព្រះសថូបក្នុងស្ថាន វៀងៗ ខ្ជួន ហើយធ្វើការបូជាធំ ។ បទថា **ឯវមេតំ ភូតបុព្វំ** *សេចក្តីថា ការចែកព្រះបរមធាតុ និងការសាងព្រះសថូប ១០ កន្លែងនេះ ធ្លាប់មានមកហើយក្នុងជម្ពូទ្វីប ដោយប្រការដូច្នេះ ។ ខាងក្រោយ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលទុក ។*

កាលនាំគ្នាស្ថាបនាព្រះសថូបដូច្នេះហើយ ព្រះមហាកស្សបត្ថេរឃើញអន្តរាយរបស់ព្រះបរមធាតុទាំងឡាយ ទើបចូលទៅគាល់ព្រះបាទអជាតសត្តុទូលថា បពិត្រមហារាជ ទ្រង់គួរការពារព្រះបរមធាតុទុកដោយឧបាយយ៉ាងនេះៗ ព្រះបាទអជាតសត្តុត្រាស់ថា សាធុ លោកម្ចាស់ កិច្ចដោយការរក្សាព្រះបរមធាតុរបស់ញោម ចូរលើកទុកសិន តែញោមនឹងនាំព្រះបរមធាតុដ៏សេសមកបានដូចម្តេច ។ ព្រះថេរៈទូលថា ថ្វាយព្រះពរ ការនាំព្រះបរមធាតុមកមិនមែនការៈរបស់មហាបពិត្រ តែជាការៈរបស់ពួកអាត្មា ។ ព្រះរាជាត្រាស់ថា សាធុ សូមលោកម្ចាស់នាំព្រះបរមធាតុមកចុះ ញោមនឹងរក្សាទុក ។ ព្រះថេរៈវៀរទុកត្រឹមតែព្រះធាតុ ដែលរាជត្រកូលនោះៗ បិទបាំង ព្រះធាតុដ៏សេសនាំមក ។ ចំណែកព្រះបរមធាតុទាំងឡាយក្នុងរាមគ្រាម ពួកនាគនាំគ្នាឡើងមកថែរក្សា ។ ព្រះថេរៈត្រិះរិះថា ការអន្តរាយរបស់ព្រះបរមធាតុទាំងនោះមិនមាន តទៅក្នុងអនាគតកាល មនុស្សទាំងឡាយ នឹងរក្សាក្នុងព្រះមហាចេតិយនាមមហាវិហារលង្កាទ្វីប ដូច្នេះហើយ មិននាំព្រះបរមធាតុទាំងនោះមក នាំមកពីនគរទាំង ៧ ដ៏សេស ប្រតិស្ឋានទុកក្នុងទិសខាងកើត ចៀងខាងត្បូងនៃក្រុងរាជគ្រឹះ អធិដ្ឋានថា ថ្មណាមាននៅក្នុងទីនេះ ថ្មនោះចូរអន្តរធានទៅ ចូរមានដី

ស្អាតល្អ ចូរទឹកកុំជ្រាបឡើងមកដល់ ដូច្នេះ ។ ព្រះរាជាបង្គាប់ឲ្យជីកទីនោះ កកាយដីចេញអំពីទីនោះ រៀបឥដ្ឋជំនួស ត្រាស់បង្គាប់ឲ្យសាងចេតិយសម្រាប់ព្រះអសីតិមហាសាវក ។ អាចារ្យពួកខ្លះពោលថា បើមានមនុស្សសួរថា ព្រះរាជាបង្គាប់ឲ្យសាងអ្វីក្នុងទីនេះ ឆ្លើយថា ឲ្យសាងព្រះចេតិយសម្រាប់ព្រះមហាសាវកទាំងឡាយ ។ តែក្នុងទីនោះ ជម្រៅ ៨០ ហត្ថ ទ្រង់ឲ្យក្រាលកម្រាលលោហៈខាងក្រោម សាងប្រអប់ដែលធ្វើដោយឈើចន្ទន៍លឿងជាដើម និងព្រះសថូបទុកមួយកន្លែងៗ ៨ ។ គ្រានោះ ព្រះរាជាដាក់ព្រះបរមធាតុរបស់ព្រះមានព្រះភាគក្នុងប្រអប់ចន្ទន៍លឿង ទ្រង់ដាក់ប្រអប់ចន្ទន៍លឿងនោះ ក្នុងប្រអប់ចន្ទន៍លឿងមួយទៀត ហើយទ្រង់ដាក់ប្រអប់ចន្ទន៍លឿងនោះ ក្នុងប្រអប់ចន្ទន៍លឿងមួយទៀត ដូចពោលមកដូច្នេះ ជាការទ្រង់រួមប្រអប់ ៨ ក្នុងប្រអប់តែមួយ ដោយឧបាយយ៉ាងនោះឯង ទ្រង់ដាក់ប្រអប់ទាំង ៨ នោះក្នុងព្រះសថូបចន្ទន៍លឿង ៨ ទ្រង់ដាក់សថូបចន្ទន៍លឿងទាំង ៨ ក្នុងប្រអប់ចន្ទន៍ក្រហម ៨ ទ្រង់ដាក់ប្រអប់ចន្ទន៍ក្រហមទាំង ៨ ក្នុងព្រះសថូបចន្ទន៍ក្រហម ៨ ទ្រង់ដាក់សថូបចន្ទន៍ក្រហមទាំង ៨ ក្នុងប្រអប់ភ្លុក ទ្រង់ដាក់ប្រអប់ភ្លុកទាំង ៨ ក្នុងសថូបភ្លុក ៨ ហើយទ្រង់ដាក់សថូបភ្លុកទាំង ៨ ក្នុងប្រអប់រតនៈ ៨ ទ្រង់ដាក់ប្រអប់រតនៈ ៨ ក្នុងសថូបរតនៈ ៨ ទ្រង់ដាក់សថូបរតនៈ ៨ ចូលក្នុងប្រអប់មាស ៨ ទ្រង់ដាក់ប្រអប់មាស ៨ ក្នុងសថូបមាស ៨ ទ្រង់ដាក់សថូបមាស ៨ ក្នុងប្រអប់ប្រាក់ ៨ ទ្រង់ដាក់ប្រអប់ប្រាក់ ៨ ក្នុងសថូបប្រាក់ ៨ ទ្រង់ដាក់សថូបប្រាក់ ៨ ក្នុងប្រអប់មណី ៨ ទ្រង់ដាក់ប្រអប់មណី ៨ ក្នុងសថូបមណី ៨ ទ្រង់ដាក់សថូបមណី ៨ ក្នុងប្រអប់កែវទទឹម ៨ ហើយទ្រង់

ជាក់ប្រអប់កែវទទឹម ៨ ក្នុងសថូបកែវទទឹម ៨ ទ្រង់ជាក់សថូបកែវទទឹម ៨ ក្នុងប្រអប់កែវមកិត ៨ ហើយទ្រង់ជាក់ប្រអប់កែវមកិត ៨ ក្នុងសថូបកែវមកិត ៨ ទ្រង់ជាក់សថូប[1] កែវមកិត ៨ ក្នុងប្រអប់កែវផលិក ៨ ហើយទ្រង់ជាក់ប្រអប់កែវផលិក ៨ ក្នុងសថូបកែវផលិក ៨ ។

ចេតិយកែវផលិកមានមុនចេតិយទាំងអស់ កាន់យកជាប្រមាណនៃចេតិយក្នុងថូបារាម ។ លើចេតិយកែវផលិកនោះ បញ្ជាឲ្យសាងផ្ទះធ្វើដោយរតន: ។ លើផ្ទះរតន:នោះ ឲ្យសាងផ្ទះធ្វើដោយមាស លើផ្ទះមាសនោះ ឲ្យសាងផ្ទះដោយប្រាក់ លើផ្ទះប្រាក់នោះឲ្យសាងផ្ទះធ្វើដោយស្ពាន់ លើផ្ទះស្ពាន់នោះ រោយគ្រាប់ខ្បាច់ធ្វើដោយរតន:ទាំងអស់ រោយផ្កាទឹក ផ្កាគោក ១០០០ ផ្កា ឲ្យសាងជាតក ៥៥០ ជាតក ព្រះអសីតិមហាថេរ: ព្រះបាទសុទ្ធោទនមហារាជ ព្រះនាងមហាមាយាទេវី សហជាតទាំង ៧ ទាំងអស់ដូចពោលមកនេះ ធ្វើដោយមាសទាំងអស់ ។ បង្គាប់ឲ្យតម្កល់ភ្នមទឹកពេញ ដែលធ្វើដោយមាសនិងប្រាក់ មួយមុខៗ ៥០០ ភ្នម ឲ្យលើកទង់មាស ៥០០ ឲ្យធ្វើប្រទីបមាស ៥០០ ប្រទីបប្រាក់ ៥០០ ទ្រង់ជាក់សរសៃសំពត់សម្បកឈើទុកក្នុងប្រទីបទាំងនោះ ជាក់ប្រេងក្រអូប ។ គ្រានោះ ព្រះមហាកស្សបអធិដ្ឋានថា កម្រងផ្កាកុំស្វិត ភ្លិនក្រអូបកុំបាត់ ប្រទីបកុំរលត់ ហើយឲ្យចារឹកអក្សរទុកក្នុងដំបារមាសថា ក្នុងអនាគតកាល ព្រះរាជកុមារព្រះនាមថា អសោក នឹងគ្រប់គ្រងរាជសម្បត្តិ ជាព្រះបាទអសោកមហារាជ ទ្រង់នឹងធ្វើព្រះបរមធាតុទាំងនេះឲ្យផ្សាយទៅ ដូច្នេះ ។

១- សថូបក្នុងទីនេះ ប្រហែលជាកោដិទេដឹង ទើបអាចជាក់ក្នុងប្រអប់បាន ។

ព្រះរាជាទ្រង់យកគ្រឿងប្រដាប់ទាំងអស់បូជា ទ្រង់បិទទ្វារហើយស្តេចចេញទៅ ។ ព្រះរាជាកាលបិទទ្វារស្រាន់ហើយ ទ្រង់ប្រថាប់គ្រាកូនសោត្រង់ខ្សែចង ទ្រង់ដាក់ដុំកែវមណីមួយដុំធំនៅត្រង់ទីនោះឯង ឲ្យចារឹកអក្សរថា ក្នុងអនាគតកាល ស្តេចផែនដីដែលក្រីក្រ ចូរកាន់យកកែវមណីនេះ ធ្វើសក្ការៈព្រះបរមធាតុទាំងឡាយហោង ។

សក្កទេវរាជ ហៅវិស្សកម្មទេវបុត្រមក បង្គាប់ដោយព្រះតម្រាស់ថា នែបា ព្រះបាទអជាតសត្តុ ទ្រង់រក្សាព្រះបរមធាតុហើយ អ្នកចូរតាំងកងទ័ពរក្សាការណ៍នោះចុះ ។ វិស្សកម្មទេវបុត្រមកប្រកបរូបយន្តមានសរីរៈ ជារូបឈើ កាន់ព្រះខ័នពណ៌កែវផលិក ក្នុងបន្ទប់ព្រះបរមធាតុ កម្រើកខ្លួនបានរហ័សដូចខ្យល់ ។ វិស្សកម្មទេវបុត្រប្រកបរូបយន្ត ហើយធ្វើស្នៀតគន្លឹះត្រង់ទីតែមួយប៉ុណ្ណោះ យកសិលាព័ទ្ធដោយជុំវិញ ដោយអាការដូចផ្ទះសាងអំពីឥដ្ឋខាងលើបិទដោយផ្ទាំងសិលាតែមួយ ពេយធូលី ហើយធ្វើផែនដីឲ្យរាប ហើយប្រតិស្ឋានសថូបថ្មលើទីនោះ ។ កាលការរក្សាព្រះបរមធាតុសម្រេចរៀបរយយ៉ាងនេះហើយ ឯព្រះថេរៈតាំងនៅជរាបជល់អស់អាយុ ក៏បរិនិព្វាន ចំណែកព្រះរាជាក៏ស្តេចទៅតាមយថាកម្ម ពួកមនុស្សទាំងនោះ ក៏ស្លាប់ទៅ ។

ក្រោយមក កាលអសោកកុមារគ្រប់គ្រងរាជសម្បត្តិ ជាព្រះធម្មរាជា ព្រះនាមថា អសោក ទ្រង់ទទួលព្រះបរមធាតុទាំងនោះហើយ ទ្រង់បានធ្វើព្រះធាតុឲ្យផ្សាយទៅ ។ សួរថា ទ្រង់ធ្វើឲ្យផ្សាយទៅដូចម្តេច ឆ្លើយថា ព្រះបាទអសោកនោះ អាស្រ័យនិគ្រោធសាមណេរ ក៏ជ្រះថ្លាក្នុងព្រះសាសនា ឲ្យសាងវិហារ ៨៤០០០ ហើយគ្រាស់សួរភិក្ខុសង្ឃថា ញោមឲ្យសាងវិហារ ៨៤០០០

ហើយ នឹងបានព្រះបរមធាតុមកអំពីណា ។ ភិក្ខុសង្ឃទូលថា ថ្វាយព្រះពរ ពួកអាត្មាភាពបានឮមកថា ទីក្បាព្រះបរមធាតុមាន តែមិនដឹងថានៅទីណា ។ ព្រះរាជាឲ្យរើព្រះចេតិយក្នុងក្រុងរាជគ្រឹះក៏មិនឃើញ ទ្រង់ឲ្យធ្វើព្រះចេតិយវិញ ល្អដូចមុន ហើយទ្រង់នាំបរិស័ទ ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទៅកាន់ក្រុងវេសាលី ក្នុងទីនោះក៏មិនបាន ក៏ទៅកាន់ក្រុងកបិលពស្តុ ក្នុងទីនោះក៏មិនបាន ហើយទៅកាន់រាមគ្រាម ពួកនាគក្នុងរាមគ្រាមក៏មិនព្រមឲ្យរើព្រះចេតិយ ។ ចបដែលធ្លាក់ត្រូវព្រះចេតិយ ក៏ត្រូវបាក់បែកជាកំណាត់តូចធំ ដោយអាការយ៉ាងនេះ ក្នុងទីនោះក៏មិនបាន ក៏ទៅកាន់ក្រុងអល្លកប្បៈ វេដ្ឋទីបៈ ជាវកុសិនារា ក្នុងទីគ្រប់កន្លែង ដូចពោលមកនេះ រើព្រះចេតិយហើយ ក៏មិនបានព្រះបរមធាតុឡើយ កាលធ្វើចេតិយទាំងនោះឲ្យល្អដូចដើមហើយ ក៏ត្រឡប់ទៅកាន់ក្រុងរាជគ្រឹះទៀត ទ្រង់ប្រជុំបរិស័ទ ៤ ហើយត្រាស់សួរថា អ្នកណាធ្លាប់បានឮថា ទីកប់ព្រះបរមធាតុក្នុងទីឈ្មោះនោះមានដែរទេ ។ ក្នុងទីប្រជុំនោះ ព្រះថេរៈមួយរូបអាយុ ១២០ ឆ្នាំ ពោលថា អាត្មាភាពក៏មិនដឹងថា ទីក្បាព្រះបរមធាតុនៅត្រង់ទីនោះ តែកាលពីអាត្មាភាពអាយុ ៧ ឆ្នាំ ព្រះមហាថេរៈបិតា ឲ្យអាត្មាភាពនាំហិបកម្រងផ្កា ពោលថា មកនេះសាមណេរ ចន្លោះគុម្ពឈើត្រង់ទីនោះ មានសបូបថ្ម យើងនាំគ្នាទៅទីនោះចុះ ហើយបូជា លោកនិយាយថា សាមណេរ គួរពិចារណាទីត្រង់នេះ ។ ថ្វាយព្រះពរ អាត្មាដឹងត្រឹមប៉ុណ្ណោះ ព្រះរាជាត្រាស់ថា ទីនុ៎ះឯង ហើយឲ្យកាប់គុម្ពឈើ ហើយនាំសបូបថ្ម និងធូលីចេញ ហើយទ្រង់ឃើញទីគំនរបូកបាយអរ បន្ទាប់អំពីនោះ ទ្រង់ទម្លាយបាយអ និងដុំឥដ្ឋហើយ ស្តេចចូលកាន់បរិវេណតាមលំដាប់ ទត

ឃើញខ្សាច់រតនៈ ៧ ប្រការ និងរូបឈើកាន់ដាវដើរជុំវិញ ស្តេចបង្គាប់ឲ្យពួកមនុស្សចេះមន្តខ្មោចមក សូម្បីឲ្យធ្វើការសែនបួងសួងហើយ ក៏មិនឃើញទីបំផុតខាងដើមខាងចុងឡើយ ទើបទ្រង់នមស្ការទេវតាទាំងឡាយ ហើយត្រាស់ថា ខ្ញុំទទួលព្រះបរមធាតុទាំងនេះហើយ បញ្ចុះនៅក្នុងវិហារ ៨៤០០០ នឹងធ្វើសក្ការៈ សូមទេវតាកុំធ្វើអន្តរាយដល់ខ្ញុំឡើយ ។

សក្កទេវរាជ ស្តេចចារិកទៅទ្រង់ឃើញព្រះបាទអសោកនោះហើយ ហៅវិស្សកម្មទេវបុត្រមកប្រាប់ថា នែបា អសោកធម្មរាជ ទ្រង់ទឹងនាំព្រះបរមធាតុទៅ ព្រោះដូច្នោះ ចូរបាចុះកាន់បរិវេណ ទម្លាយរូបឈើចេញ វិស្សកម្ម-ទេវបុត្រនោះ ក៏កាឡាខ្លួនជាក្មេងអ្នកស្រុក ទុកជុក ៥ កញ្ចុំ ឈរកាន់ធ្នូត្រង់ព្រះភក្ត្ររបស់ព្រះរាជា ហើយទូលថា ខ្ញុំនឹងនាំទៅ មហារាជ ។ ព្រះរាជាត្រាស់ថា នាំទៅចុះបា ។ វិស្សកម្មទេវបុត្រចាប់ធ្នូ បាញ់ត្រង់ទីចំណងតុក្កតាយន្តនោះឯង ធ្វើឲ្យគ្រប់យ៉ាងអន្តរធានទៅ ។ គ្រានោះ ព្រះរាជាទ្រង់កាន់ត្រាកូនសោរ ដែលជាប់នៅត្រង់ខ្សែចង ទតឃើញដុំកែវមណី និងឃើញអក្សរចារឹកថា ក្នុងអនាគតកាល ស្តេចផែនដីដែលក្រីក្រ ចូរកាន់យកកែវមណីនេះ ហើយធ្វើសក្ការៈព្រះបរមធាតុទាំងឡាយ ទ្រង់ក្រោធថា មិនគួរនិយាយមើលងាយព្រះរាជាដូចអញថា ស្តេចផែនដីក្រីក្រ ដូច្នេះហើយ ទ្រង់គោះដដែលៗ ឲ្យទ្វាររបើក ស្តេចចូលទៅខាងក្នុងផ្ទះប្រទីបដែលអុជ កាលពី ២១៨ ឆ្នាំមុន នៅតែឆេះយ៉ាងនោះឯង ផ្កាឈូកខៀវដូចនាំមកជាក់ខណៈនោះឯង កម្រាលផ្កាដូចក្រាលខណៈនោះឯង គ្រឿងក្រអូបដូចគេកិនជាក់ កាលអម្បាញ់មិញនេះឯង ។ ព្រះរាជាទ្រង់កាន់ដំបារមាស ទ្រង់អានថា តទៅក្នុងអនាគតកាល

กุมารព្រះនាមថា អសោកនឹងគ្រប់គ្រងរាជសម្បត្តិ ជាព្រះធម្មរាជាព្រះនាមថា អសោក ទ្រង់នឹងធ្វើព្រះបរមធាតុទាំងនេះ ឲ្យផ្សាយទៅកាន់ទីច្រើន ដូច្នេះ ហើយ គ្រាស់ថា លោកដ៏ចម្រើនទាំងឡាយ លោកម្ចាស់មហាកស្សបត្ថេរ ឃើញខ្ញុំហើយ ទ្រង់លើកព្រះហស្តឆ្វេងទះនឹងព្រះហស្តស្តាំ ។ ព្រះរាជារៀរ តែមតែព្រះបរមធាតុដែលបិទបាំងក្នុងទីនោះ ទ្រង់ធ្វើព្រះបរមធាតុដ៏សេសទាំង អស់មកហើយ បិទទ្វារព្រះបរមធាតុដូចដើម ទ្រង់ធ្វើទីគ្រប់កន្លែងឲ្យជាប្រក្រតី ដូចដើម ហើយឲ្យប្រតិស្ឋានបាសាណចេតិយខាងលើ ទ្រង់បញ្ចុះព្រះបរម-ធាតុក្នុងវិហារ ๘๔๐๐๐ ទ្រង់ថ្វាយបង្គំព្រះមហាថេរៈ ហើយគ្រាស់សួរថា លោកម្ចាស់ ញោមជាទាយាទក្នុងព្រះពុទ្ធសាសនាហើយឬនៅ ព្រះមហាថេរៈ ទូលថា ថ្វាយព្រះពរមហាបពិត្រ នៅជាមនុស្សខាងក្រៅនៃព្រះសាសនា នឹង ជាទាយាទដូចម្តេចទៅ ។ ព្រះរាជាគ្រាស់សួរថា ញោមបរិច្ចាគទ្រព្យ ๙๖ កោដិ ឲ្យសាងវិហារដល់ទៅ ๘๔๐๐๐ នៅមិនទាន់ជាទាយាទ អ្នកដទៃណា ហ្នឹងនឹងជាទាយាទ ។ ព្រះថេរៈពោលថា ថ្វាយព្រះពរមហាបពិត្រ បានឈ្មោះ ថា ជាបច្ចយទាយក បុគ្គលណាបំបួសបុត្រ ឬធីតារបស់ខ្លួន ទើបបុគ្គលនេះ ឈ្មោះថា ជាទាយាទរបស់ព្រះសាសនា ។ ទើបទ្រង់ឲ្យព្រះឱរស និងព្រះធីតា បួស ។ គ្រានោះ ព្រះថេរៈទាំងឡាយទូលព្រះរាជាថា ថ្វាយព្រះពរ ឥឡូវនេះ មហាបពិត្រជាទាយាទក្នុងព្រះសាសនាហើយ ។

បទថា **ឱរមេតំ ភូតបុព្វំ** *សេចក្តីថា ការកប់ព្រះបរមធាតុក្នុងអតីតកាល នេះ ធ្លាប់មានមកហើយក្នុងផែនដីជម្ពូទ្វីប ដោយប្រការដូច្នេះ ។ ការកសង្ឃ ដែលធ្វើសង្គាយនាលើកទី ๓ ក៏បានរចនាបទនេះ ។*

[១៦២] គាថាជាដើមថា **អជ្ជធោណំ ចក្ខុមតោ សរីរំ** ជាដើមនេះ ព្រះថេរៈអ្នកសីហឡទ្វីប ពោលទុកហើយនោះឯង ។

មហាបរិនិព្វានសូត្រ ចប់
សូត្រធី ៣ ចប់

ក្បាលដី ១០

សុត្តន្តបិដក ចាលីប្រែ - ១៥

សន្ទីកចន្អុលប្រាប់មាតិកា

មាតិកា	លេខទំព័រ
មហាសីហនាទសូត្រដី ៨	២
អដ្ឋកថា មហាសីហនាទសូត្រ	២៦
អចេលកស្សបកថា	២៦
ការសាកសួរ	៣១
មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ	៣៣
សម្បទា ៣ យ៉ាង	៤០
ចោដ្ឋចាទសូត្រដី ៩	៥១
អដ្ឋកថា ចោដ្ឋចាទសូត្រ	៩០
ចោដ្ឋបាទបិញ្ចាជកកថា	៩០
អភិសញ្ញានិរោធកថា	៩៦
អហេតុកសញ្ញុប្បាទនិរោធកថា	១០០
អត្តសញ្ញា	១០៩
ចិត្តហត្ថិសារីបុត្តកថា	១១៣
ឯកំសិកធម្មកថា	១១៥
សុភសូត្រដី ១០	១២២
អដ្ឋកថា សុភសូត្រ	១៥៥
សុភមាណពកថា	១៥៥
សីលក្ខន្ធ	១៥៩

កេវដ្ដសូត្រទី ๑๑ .... ๑๖๒

អដ្ឋកថាកេវដ្ដសូត្រ ๑๗๘

កេវដ្ដគហបតិបុត្តកថា ๑๗๘

ឥទ្ធិបាដិហារ្យកថាជាដើម ๑๗๙

កិក្ខុស្វែងរកទីរម្ងាប់មហាភូតរូប ๑๘๒

លោហិច្ចសូត្រទី ๑๒ .... ๑๘๘

អដ្ឋកថាលោហិច្ចសូត្រ ๒๐๕

សាស្តា ๓ ពួកដែលគួរចោទ ๒๐๘

សាស្តាដែលមិនគួរចោទ ๒๑๐

តេវិជ្ជសូត្រទី ๑๓ .... ๒๑๒

អដ្ឋកថា តេវិជ្ជសូត្រ ๒๓๙

ឧបមាអំពីស្ទឹងអចិរវតី ๒๔๕

សុត្តន្តបិដក ចាលីប្រែ -๑๖

មហាបទានសូត្រទី ๑ .... ๒๕๔

អដ្ឋកថាមហាបទានសូត្រ ๓๔๐

កប្បដែលមានព្រះត្រៃស់ និងមិនមានព្រះត្រៃស់ ๓๔๖

អធិប្បាយការកំណត់អាយុជាដើម ๓๕๐

និយាម ๕ យ៉ាង ๓๘๑

បុព្វនិមិត្តក្នុងថ្ងៃប្រសូត ๓๙๓

ពោលអំពីមហាបុរិសលក្ខណ ๓๒ ប្រការ ๓๙๗

អត្តរបស់ គតិ សព្វ ๓๙๘

អធិប្បាយអំពីទេវទូត ๔๒๐

ព្រហ្មយាចនកថា ๔๓๖

មហានិទានសូត្រទី២ .... ๔๖๗

អដ្ឋកថាមហានិទានសូត្រ ๔๙๕

ទំហំត្រី គ្រុឌ និងរាហូអសុរិន្ទ ๕๐๔

អធិប្បាយ វិញ្ញាណដ្ឋិតិ ๗ .... ๕๔๔

ពោលអំពីវិមោក្ខ ๘ .... ๕๕๑

មហាបរិនិព្វានសូត្រទី៣ .... ๕๕๖

អដ្ឋកថាមហាបរិនិព្វានសូត្រ ๗๐๔

និទានកថា ๗๐๔

អធិប្បាយ អបរិហានីយធម៌ ๗๐๖

រឿងកិកុបំពេញសាវណីយធម៌ ๗๓๖

ព្រះមានព្រះភាគទ្រង់មានអាពាធខ្លាំងក្លា ๗๕๘

អគ្គសាវកបរិនិព្វានកថា ๗๖๓

មារយាចនកថា ๗๗๔

អធិប្បាយ មហាបទេស ๔ .... ๗๙๐

ចុន្ទកម្មារបុត្តកថា ๗๙๗

បិណ្ឌបាតពីរមានផលស្មើគ្នា ๘๐๔

ពោលអំពីដើមរាំងទាំងគូ ๘๐๖

កម្ចាំងព្រះតថាគត ๘๐๗

ជំណេក ๔ យ៉ាង ๘๐๙

មហាសុទស្សនសុត្តទេសនាកថា ๘๒๙

បច្ឆិមពុទ្ធវចន ๘๓๗

ការចែកព្រះធាតុ ๘๖๒

ការកប់ព្រះធាតុ ๘๗๐